01357918

F36

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2016, 11:00
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក./អ.ជ.ត.ក.

Case File/Dossier Nº. 002/19-09-2007/ECCC/SC

| | |
|---|---|
| ចំពោះមុខ | ចៅក្រម គង់ ស្រីម ប្រធាន |
| | ចៅក្រម Chandra Nihal JAYASINGHE |
| | ចៅក្រម សោម សិរីវឌ្ឍ |
| | ចៅក្រម Agniezska KLONOWIECKAMILART |
| | ចៅក្រម ម៉ុង មុន្នីចរិយា |
| | ចៅក្រម Florence Ndepele Mwachande MUMBA |
| | ចៅក្រម យ៉ា ណារិន |
| ក្រឡាបញ្ជីសវនាការ | Volker NERLICH ស៊ា ម៉ៅ |
| | Paolo LOBBA ផន ធឿន |
| កាលបរិច្ឆេទប្រកាសសាលដីកា | ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ |
| ភាសាដើម | ភាសាខ្មែរ/ភាសាអង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

# សាលដីកា

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក./អ.ជ.ត.ក.

ឯកសារលេខ F36

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

# មាតិកា

**១.ប្រវត្តិនីតិវិធី ........................................ 12**

**២.សំណើសុំដាក់ភស្តុតាងបន្ថែម ........................................ 17**

២.ក.ប្រវត្តិនីតិវិធី ........................................ 17

២.ខ.ក្របខ័ណ្ឌច្បាប់ ........................................ 19

២.ខ.១.“កត្តាកំណត់”តាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ........................................ 21

២.ខ.២.“ផលប្រយោជន៍យុត្តិធម៌”ទាក់ទងទៅនឹងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ........................................ 24

២.គ.សំណើសុំកោះហៅសាក្សី GAUTAM KUL CHANDRA (SCW-1) និង PAUL IGNATIEFF (SCW-2) ........................................ 25

២.ឃ.សំណើសុំកោះហៅសាក្សី ហេង សំរិន និង អ៊ុក ប៊ុនឈឿន ........................................ 26

២.ង.សំណើសុំទាក់ទងទៅនឹងសាក្សី ថេត សម្បត្តិ និង ROBERT LEMKIN ........................................ 29

២.ង.១.ភាពជាប់ពាក់ព័ន្ធនៃការបែកបាក់នៅក្នុង ប.ក.ក. ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ នួន ជា ........................................ 30

២.ង.២.ភាពអាចទទួលយកបានចំពោះភស្តុតាងបន្ថែម ........................................ 35

២.ច.សំណើសុំឱ្យទទួលយកជាភស្តុតាងនូវបទសម្ភាសន៍របស់ ថេត សម្បត្តិ ជាមួយវិទ្យុសម្លេងអាមេរិកកាំងជាខេមរភាសា ........................................ 39

២.ឆ.សំណើសុំឱ្យទទួលយកជាភស្តុតាងនូវបទសម្ភាសន៍របស់ CARTWRIGHT និងសេចក្តីដកស្រង់នៃសៀវភៅរបស់ LEMONDE ........................................ 40

២.ជ.សំណើសុំឱ្យទទួលយកប្រតិចារឹករបស់សាក្សី ពេជ្រ ជឹម ជាភស្តុតាង និងការទទួលយក*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*នូវកិច្ចសម្ភាសន៍របស់សាក្សី សៅ វ៉ន ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) ........................................ 43

២.ឈ.ការស្នើសុំនៅក្នុងសំណើទីប្រាំសុំដាក់ភស្តុតាងបន្ថែម (F2/7) ........................................ 45

២.ញ.ការស្នើសុំនៅក្នុងសំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) ........................................ 48

**៣.មូលដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ ........................................ 52**

៣.ក.ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ ........................................ 53

៣.ខ.ការចោទប្រកាន់អំពីកំហុសអង្គហេតុ ........................................ 54

៣.គ.ការជំទាស់ទៅនឹងការសម្រេចស្តីពីចរិតលក្ខណៈនៃនីតិវិធី ........................................ 61

៣.ឃ.ឥទ្ធិពលនៃកំហុសនានាដែលធ្វើឱ្យប៉ះពាល់ដល់សាលក្រម ........................................ 63

៣.ង.លក្ខខណ្ឌតម្រូវក្នុងការផ្តល់មូលដ្ឋានគាំទ្រអំណះអំណាងនៅដំណាក់កាលបណ្តឹងសាទុក្ខ .............. 64

៤.បណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ........................................ 65

៤.ក.ធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង ........................................ 65

៤.ខ.ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ........................................ 70

៤.ខ.១.សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងឥតលម្អៀង ........................................ 70

៤.ខ.២.សិទ្ធិទទួលបានការការពារក្តីដោយប្រសិទ្ធភាព ........................................ 86

៤.ខ.២.ក.ការសម្រេចមិនកោះហៅសាក្សី ........................................ 86

៤.ខ.២.ក.១.សាក្សី ហេង សំរិន ........................................ 87

៤.ខ.២.ក.២.សាក្សី អ៊ុក ប៊ុនឈឿន ........................................ 103

៤.ខ.២.ក.៣.សាក្សី Robert LEMKIN ........................................ 106

៤.ខ.២.ក.៤.សាក្សីទាក់ទងទៅនឹងស្ថានភាពមុនជម្លៀស ........................................ 110

៤.ខ.២.ក.៥.សាក្សីទាក់ទងទៅនឹងគោលនយោបាយក្នុងការកំណត់គោលដៅលើអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ........................................ 111

៤.ខ.២.ខ.ការទទួលយក និងការប្រើប្រាស់ឯកសារ ........................................ 111

៤.ខ.២.ខ.១.តម្រូវការចាំបាច់ឱ្យភាគីការពារក្តីដាក់បញ្ជីឯកសារ ........................................ 111

៤.ខ.២.ខ.២.នីតិវិធីទាក់ទងទៅនឹងការទទួលយកឯកសារជាភស្តុតាង ........................................ 117

៤.ខ.២.គ.ពេលវេលា និងចំនួនទំព័រពុំគ្រប់គ្រាន់ ........................................ 121

៤.ខ.២.ឃ.លំដាប់លំដោយនៃនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ........................................ 125

៤.ខ.៣.សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុពេញលេញ ........................................ 129

៤.ខ.៤.សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទ/វិសាលភាពនៃការជំនុំជម្រះ ........................................ 135

៤.ខ.៤.ក.យុត្តាធិការពេលវេលា ........................................ 135

៤.ខ.៤.ខ.ការយល់ឃើញផ្នែកអង្គហេតុដែលពុំមាននៅក្នុងបទចោទក្នុងសំណុំរឿង ០០២/០១........ 142

៤.ខ.៤.គ.វិសាលភាពនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ................................ 150

៤.គ.វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកភស្តុតាង ................................ 156

៤.គ.១.ការកម្រិតឱកាសក្នុងការសួរស្តងក្នុងពេលជំនុំជម្រះ ........................................ 158

៤.គ.២.ការអនុញ្ញាតឱ្យសាក្សីពិនិត្យមើលចម្លើយរបស់ខ្លួនពីមុន និងការសួរបញ្ជាក់សាក្សីអំពីខ្លឹមសារនៃចម្លើយនោះនៅក្នុងសវនាការ .................................................................. 165

៤.គ.៣.ការរឹតត្បិតលើវិសាលភាពនៃការសួរសំណួរ ................................................ 172

៤.គ.៤.ការទទួលយក និងការប្រើប្រាស់ភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់ ..... 178

៤.គ.៤.ក.បទដ្ឋានគតិយុត្តក្នុងការទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់ 181

៤.គ.៤.ខ.ទម្ងន់នៃភស្តុតាង ដែលបានផ្តល់ទៅលើចម្លើយជាលាយលក្ខណ៍អក្សរ ជំនួសសក្ខីកម្មផ្ទាល់មាត់ .................................................................................. 187

៤.គ.៥.ការវាយតម្លៃលើភស្តុតាងចចាមអារ៉ាម........................................................ 191

៤.គ.៦.ការសំអាងហេតុលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ...................................... 195

៤.គ.៦.ក.ការសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........................................ 198

៤.គ.៦.ខ.ការសំអាងលើសេចក្តីថ្លែងអំពីទុក្ខវេទនា និងសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ ... 201

៥.គ.៧.ការសំអាងលើសក្ខីកម្មរបស់អ្នកជំនាញ និងប្រភពមិនផ្ទាល់ ...................................... 206

៤.គ.៨.ការវាយតម្លៃលើតម្លៃជាភស្តុតាងរបស់សាក្សីអង្គហេតុ ........................................ 216

៤.គ.៨.ក.អ្នកជំនាញ François PONCHAUD និង Stephen HEDER........................ 217

៤.គ.៨.ខ.សាក្សី ឌុច ភី ភួន និង លឹម សាត ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន និង នូ ម៉ៅ ......... 222

៤.គ.៨.គ.ជនជាប់ចោទ នួន ជា ................................................................ 231

៤.គ.៨.ឃ.សេចក្តីសន្និដ្ឋាន..................................................................... 233

៤.គ.៩.ការដកចេញភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ........................................ 233

៤.គ.១០.ការបង្ហាញឯកសារដែលសាក្សីពុំស្គាល់ ..................................................... 235

៤.គ.១១.ការបដិសេធសំណើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ ...................................... 236

៤.គ.១២.ការសំអាងលើបទដ្ឋានពុំត្រឹមត្រូវស្តីពីបន្ទុកនៃការបង្ហាញភស្តុតាង............................ 240

៤.ឃ.បទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព ........................................ 242

៤.ឃ.១.ការធ្វើមនុស្សឃាត ........................................................................ 242

៤.ឃ.១.ក.ការកំណត់និយមន័យអំពីធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ........................................................................ 245

៤.ឃ.១.ខ.ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ........................................................................ 259

៤.ឃ.១.ខ.១.ការសម្លាប់ជនស៊ីវិល ........................................................................ 259

៤.ឃ.១.ខ.១.ក.ការសម្លាប់ដោយសារការមិនធ្វើតាមបញ្ជា ........................................ 270

៤.ឃ.១.ខ.១.ខ.ការសម្លាប់អ្នកដែលព្យាយាមត្រឡប់មកក្រោយវិញ ................................ 276

៤.ឃ.១.ខ.១.គ ការសម្លាប់ដោយ“គ្មានហេតុផល” ................................................ 277

៤.ឃ.១.ខ.២.ការស្លាប់ដោយសារលក្ខខណ្ឌក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ .... 287

៤.ឃ.១.ខ.៣.ការសម្លាប់ទាហាន និងអ្នករដ្ឋការស៊ីវិល ................................................ 297

៤.ឃ.១.ខ.៣.ក.អ្នករដ្ឋការជាន់ខ្ពស់ ........................................................................ 299

៤.ឃ.១.ខ.៣.ខ.អ្នករដ្ឋការស៊ីវិល និង *ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ* ត្រូវបានសម្លាប់នៅនឹងកន្លែង ........................................................................ 302

៤.ឃ.១.ខ.៣.គ.ទាហានដែលត្រូវបានយកទៅសម្លាប់នៅកន្លែងផ្សេងទៀត ................................ 307

៤.ឃ.១.ខ.៣.ឃ.ការសម្លាប់ទាហានដែលបានធ្វើតាមការអំពាវនាវ ........................................ 308

៤.ឃ.១.ខ.៣.ង.ទាហានដែលត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យ .............. 313

៤.ឃ.១.ខ.៣.ច.ការរាយការណ៍អំពីការសម្លាប់នៅក្បៀនស្វាយ និងបាត់ដំបង ........................ 314

៤.ឃ.១.ខ.៣.ឆ.សេចក្តីសន្និដ្ឋានទាក់ទងទៅនឹងការសម្លាប់អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ........................................................................ 315

៤.ឃ.១.គ.ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ........................................ 316

៤.ឃ.១.គ.១.កិច្ចប្រជុំរបស់គណៈភូមិភាគ និងការបញ្ជាសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ........................................................................ 317

៤.ឃ.១.គ.២.ភាពពុំស៊ីសង្វាក់គ្នាដទៃទៀតនៅក្នុងភស្តុតាងរបស់សាក្សីទាក់ទងទៅនឹងការប្រជុំនៅក្នុងសាលាខេត្តពោធិ៍សាត់ ............ 321

៤.ឃ.២.ការសម្លាប់រង្គាល ............ 327

៤.ឃ.២.ក.ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាក់ទងទៅនឹងការកំណត់និយមន័យនៃការសម្លាប់រង្គាល..... 327

៤.ឃ.២.ក.១.ការធៀបគ្នារវាង“ទំនងជា” និង“មានបំណង” ............ 330

៤.ឃ.២.ក.២.“ការសម្លាប់ក្នុងទ្រង់ទ្រាយធំ” ............ 335

៤.ឃ.២.ខ.ការសម្លាប់រង្គាលដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ............ 338

៤.ឃ.២.ខ.១.ការសម្លាប់រង្គាលលើជនស៊ីវិល ............ 339

៤.ឃ.២.ខ.២.ការសម្លាប់រង្គាលលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ............ 344

៤.ឃ.២.ខ.៣.សេចក្តីសន្និដ្ឋាន ............ 344

៤.ឃ.២.គ.ការសម្លាប់រង្គាលដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ............ 345

៤.ឃ.២.ឃ.ការសម្លាប់រង្គាលដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ ............ 357

៤.ឃ.៣.អំពើអមនុស្សធម៌ផ្សេងៗទៀត............ 359

៤.ឃ.៣.ក.វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំដែលជា“អំពើអមនុស្សធម៌ផ្សេងៗទៀត” ............ 361

៤.ឃ.៣.ខ. លក្ខខណ្ឌនៃការជម្លៀស និងការប្រើអំពើហិង្សាក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ............ 375

៤.ឃ.៣.គ.យុត្តិកម្មដែលបានអះអាងសម្រាប់ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ......... 387

៤.ឃ.៣.ឃ.លក្ខខណ្ឌ និងកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ............... 393

៤.ឃ.៣.ឃ.១.ការយល់ឃើញទូទៅទាក់ទងទៅនឹងលក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ............ 397

៤.ឃ.៣.ឃ.២.ការយល់ឃើញទូទៅថា មានមនុស្សស្លាប់ និងការទុកសាកសពចោល............. 403

៤.ឃ.៣.ឃ.៣.ការសន្និដ្ឋានដែលថា ប្រជាជនភាគច្រើនដែលត្រូវបានផ្លាស់ទីលំនៅ គឺជា"ប្រជាជនថ្មី" ..... 405

៤.ឃ.៣.ឃ.៤.ការយល់ឃើញទាក់ទងទៅនឹងការសម្លាប់..... 407

៤.ឃ.៣.ឃ.៥.ការយល់ឃើញដែលថា ប្រជាជនត្រូវបានបង្ខំ គំរាម ឬបោកបញ្ឆោត ឱ្យផ្លាស់ទីលំនៅ..... 409

៤.ឃ.៣.ឃ.៦.អនីត្យានុកូលភាពនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ..... 412

៤.ឃ.៣.ង.ការយល់ឃើញទាក់ទងទៅនឹងការធ្វើឱ្យបាត់ខ្លួនអ្នកដែលត្រូវបានជម្លៀស ..... 415

៤.ឃ.៣.ច.ថាតើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ គឺជា"អំពើអមនុស្សធម៌" ដែរ ឬយ៉ាងណា ក្នុងកាលៈទេសៈនោះ ..... 418

៤.ឃ.៣.ច.១.ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ..... 419

៤.ឃ.៣.ច.២.ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ..... 420

៤.ឃ.៤.ការធ្វើទុក្ខបុកម្នេញ ..... 422

៤.ឃ.៤.ក.ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងពីបទធ្វើទុក្ខបុកម្នេញ ..... 423

៤.ឃ.៤.ខ.ការយល់ឃើញដែលថា "ប្រជាជនថ្មី" គឺជាក្រុមដែលអាចកំណត់បានច្បាស់លាស់..... 431

៤.ឃ.៤.គ.ការធ្វើទុក្ខបុកម្នេញនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ .. 434

៤.ឃ.៤.ឃ.ការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ..... 441

៤.ឃ.៥.ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ..... 445

៤.ឃ.៥.ក.ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ..... 449

៤.ឃ.៥.ខ.ផែនការ ឬគោលនយោបាយរបស់រដ្ឋ..... 457

៤.ឃ.៥.គ.ទំនាក់ទំនងជាមួយនឹងការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធសំដៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ..... 464

៤.ឃ.៥.គ.១.ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធសំដៅទៅលើប្រជាជនស៊ីវិល ..... 464

៤.ឃ.៥.គ.២.ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ..... 469

៤.ឃ.៥.គ.៣.ទំនាក់ទំនងជាមួយនឹងការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ..... 473

៤.ឃ.៥.គ.៤.ការដឹង..... 476

៤.ឃ.៦.ភាពអាចដឹងជាមុន/គោលការណ៍នីត្យានុកូលភាព ............................................ 477

៤.ង.ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ ........................... 484

៤.ង.១.ការរួមចំណែកក្នុងគោលបំណងរួម(“សហឧក្រិដ្ឋកម្មរួម”)......................................... 484

៤.ង.១.ក.អត្ថិភាព និងវិសាលភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើការរួមចំណែកយ៉ាងសំខាន់នៅក្នុងគោលបំណងរួម........................................................................ 484

៤.ង.១.ខ.គោលបំណងរួមជាបទល្មើស ........................................................................ 520

៤.ង.១.គ.អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន ............................ 524

៤.ង.១.គ.១.អត្ថិភាពនៃគោលនយោបាយផ្លាស់ទីលំនៅអ្នកទីក្រុងដោយបង្ខំ និងគោលបំណងនេះ .. 525

៤.ង.១.គ.២.អត្ថិភាពនៃគោលនយោបាយចំពោះការផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត ................................................................................................ 531

៤.ង.១.គ.៣.ឧក្រិដ្ឋកម្មដែលមានរួមបញ្ចូលនៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ........................................................................................ 541

៤.ង.១.គ.៣.ក.អំពើអមនុស្សធម៌ផ្សេងៗទៀត .................................................... 545

៤.ង.១.គ.៣.ខ.ការធ្វើមនុស្សឃាត..................................................................... 546

៤.ង.១.គ.៣.ខ.១.ការស្លាប់ដែលបណ្ដាលមកពីលក្ខខណ្ឌនៃការជម្លៀស ........................ 546

៤.ង.១.គ.៣.ខ.២.ការសម្លាប់ជនស៊ីវិល .............................................................. 547

៤.ង.១.គ.៣.ខ.៣.ការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ.................. 549

៤.ង.១.គ.៣.គ.ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ.................................... 550

៤.ង.១.គ.៤.បទឧក្រិដ្ឋដែលមានរួមបញ្ចូលនៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ .................................................................................... 550

៤.ង.១.គ.៤.ក.អំពើអមនុស្សធម៌ផ្សេងៗទៀត..................................................... 551

៤.ង.១.គ.៤.ខ.ការធ្វើមនុស្សឃាត ..................................................................... 552

៤.ង.១.ឃ.អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយកំណត់គោលដៅ ................................ 553

៤.ង.១.ឃ.១.ការបង្ហាញពុំច្បាស់លាស់អំពីគោលនយោបាយ........................................ 554

៤.ង.១.ឃ.២.អត្ថិភាពនៃលំនាំ ................................................................................ 556

៤.ង.១.ឃ.២.ក.ការចោទប្រកាន់អំពីការសម្លាប់នៅឧដុង្គក្នុងឆ្នាំ ១៩៧៤ .......................... 556

៤.ង.១.ឃ.២.ខ.ភស្តុតាងដទៃទៀតនៃការសម្លាប់មុនឆ្នាំ ១៩៧៥ ................................... 562

៤.ង.១.ឃ.២.គ.ការចោទប្រកាន់អំពីការសម្លាប់នៅចុងខែ មេសា និង ខែឧសភា ឆ្នាំ ១៩៧៥ .... 566

៤.ង.១.ឃ.២.ឃ.ការចោទប្រកាន់អំពីការសម្លាប់នៅចុងឆ្នាំ ១៩៧៥ ១៩៧៦ និងក្រោយមកទៀត 572

៤.ង.១.ឃ.៣.លំនាំទាក់ទងទៅនឹងបែបបទសម្រាប់ការកំណត់អត្តសញ្ញាណទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងវាសនាចុងក្រោយរបស់ពួកគេ ............................................. 578

៤.ង.១.ឃ.៤.សេចក្តីថ្លែងការណ៍ សេចក្តីប្រកាស និងបទបញ្ជារបស់ ប.ក.ក. ...................... 582

៤.ង.១.ឃ.៤.ក.មនោគមវិជ្ជារបស់ ប.ក.ក. និងការពិភាក្សាអំពី“បទពិសោធន៍នៅឧដុង្គ”........ 583

៤.ង.១.ឃ.៤.ខ.សេចក្តីណែនាំរបស់ ប.ក.ក. ........................................................ 587

៤.ង.១.ឃ.៥.ភាពសមហេតុផលនៃការសន្និដ្ឋានជាទូទៅ ............................................ 602

៤.ង.១.ង.បរិបទនយោបាយទូទៅ និងការយល់ឃើញដែលថា ប.ក.ក. បានអនុវត្តគោលនយោបាយស្តីពីការតស៊ូប្រដាប់អាវុធ......................................................................................... 609

៤.ង.១.ច.បទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការរួមចំណែកក្នុងគោលបំណងរួម ......................... 611

៤.ង.១.ឆ.ការយល់ឃើញដែលថា ការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមអាចធ្វើឡើងតាមរយៈអំពើអកម្ម ................................................................................................................ 617

៤.ង.១.ជ.ការរួមចំណែករបស់ នួន ជា ក្នុងការអនុវត្តគោលបំណងរួម .................................. 618

៤.ង.១.ឈ.ការរួមចំណែករបស់ ខៀវ សំផន ក្នុងការអនុវត្តគោលបំណងរួម .......................... 627

៤.ង.១.ឈ.១.ការចូលរួមរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំស្តីពីគោលនយោបាយបង្កើតគោលបំណងរួម ........................................................................................................... 630

៤.ង.១.ឈ.១.ក.កិច្ចប្រជុំរបស់ ប.ក.ក. ក្នុងខែ មិថុនា ឆ្នាំ ១៩៧៤................................ 633

៤.ង.១.ឈ.១.ខ.កិច្ចប្រជុំរបស់ ប.ក.ក. ក្នុងខែ មេសា ឆ្នាំ ១៩៧៥................................ 636

៤.ង.១.ឈ.២.ការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំណែនាំដើម្បីផ្សព្វផ្សាយគោលបំណងរួម. 637

៤.ង.១.ឈ.៣.តួនាទីរបស់ ខៀវ សំផន ជាអ្នកសេដ្ឋកិច្ចក្នុងការអនុវត្តគោលបំណងរួម ............. 641

៤.ង.១.ឈ.៤.សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន ដែលគាំទ្រគោលបំណងរួម.... 643

៤.ង.១.ឈ.៥.តួនាទីការទូតរបស់ ខៀវ សំផន ក្នុងការការពារគោលបំណងរួម ...................... 647

៤.ង.១.ឈ.៦.ការរួមចំណែកជាទូទៅរបស់ ខៀវ សំផន តាមរយៈសិទ្ធិអំណាច និងឥទ្ធិពល ........ 650

៤.ង.១.ឈ.៧.សេចក្តីសន្និដ្ឋាន ............................................................................ 651

៤.ង.១.ញ.ការយល់ឃើញថា ប.ក.ក. ជាបក្សដែលមានការឯកភាព និងឋានានុក្រម និងថា កងកម្លាំងប្រដាប់អាវុធដែលពាក់ព័ន្ធក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានការឯកភាពគ្នា ......... 653

៤.ង.១.ដ.តួនាទីរបស់គណៈកម្មាធិការមជ្ឈិម............................................................ 663

៤.ង.១.ឋ.គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ....................................................... 665

៤.ង.១.ឌ.ច្បាប់ពាក់ព័ន្ធទៅនឹងចេតនាតម្រូវ............................................................ 668

៤.ង.១.ឍ.ចេតនារបស់ នួន ជា ........................................................................... 671

៤.ង.១.ណ.ចេតនារបស់ ខៀវ សំផន ..................................................................... 676

៤.ង.២.គោលការណ៍នីត្យានុកូលភាពពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវ........................ 696

៤.ង.៣.ទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ................................................................ 697

៤.ច.ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការប្រកាសទោសជនជាប់ចោទ និងផលប៉ះពាល់នៃកំហុសលើការប្រកាសទោសនេះ ............................................................................. 700

៤.ច.១.បទដ្ឋាននៃការពិនិត្យឡើងវិញ.......................................................................... 702

៤.ច.២.ការកំណត់អំពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ....................................... 703

៤.ច.៣.ផលប៉ះពាល់នៃការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីការប្រកាសទោស ...... 707

**៥.បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា**................................................................ 710

៥.ក.សារណាស្តីពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ.................................................. 710

៥.ខ.ការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូល ......................................................... 715

**៦.ផ្នែកសម្រេចសេចក្តី** .................................................................................. 722

១.**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ចេញសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញកាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ក្នុងសំណុំរឿង ០០២/០១[1] ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។

## ១.ប្រវត្តិនីតិវិធី

២.នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទត្រូវជាប់ពិរុទ្ធពីបទការសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (មានដូចជា ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ) នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងនៅលើទឹកដីនៃប្រទេសកម្ពុជានៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៧ និងបានផ្តន្ទាទោសជនជាប់ចោទទាំងពីរម្នាក់ៗដាក់ពន្ធនាគារអស់មួយជីវិត[2]។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងព្យសនកម្មដោយផ្ទាល់ពីបទឧក្រិដ្ឋដែល នួន ជា និង ខៀវ សំផន ត្រូវបានដាក់ពិរុទ្ធនោះអាស្រ័យហេតុនេះបានទទួលយកផ្នែកខ្លះនៃសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដោយបានសម្រេចផ្តល់សំណងចំនួន ១១ ដល់ដើមបណ្តឹងរដ្ឋប្បវេណី[3]។

៣.នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ នួន ជា និង ខៀវ សំផន បានដាក់សំណើចំនួន ៦ សុំដាក់ភស្តុតាងបន្ថែម ហើយសំណើទាំងនេះត្រូវបានរៀបរាប់លម្អិតនៅក្នុងផ្នែកពាក់ព័ន្ធខាងក្រោម[4]។

---

[1] *សូមមើល* ពាក់ព័ន្ធទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីបី (E301/9/1/1/3)។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ (E284/4/8)។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ (E163/5/1/13)។ ការយោងពេញលេញទៅលើសេចក្តីសម្រេចទាំងនេះ ការដាក់សារណា និងឯកសារដទៃទៀតដែលបានដកស្រង់នៅក្នុងសាលដីកានេះមាននៅក្នុង ឧបសម្ព័ន្ធ ក - តារាងពន្យល់ (F36.1)។

[2] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៦០, ១១០៦ ដល់ ១១០៧ និងផ្នែកសម្រេចសេចក្តី។

[3] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១៥០ ដល់ ១១៦០ និងផ្នែកសម្រេចសេចក្តី។

[4] *សូមមើលខាងក្រោម* កថាខណ្ឌ ១៧ *ជាអាទិ៍*។

៤.នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ បន្ទាប់ពីបានទទួលការអនុញ្ញាតឱ្យបន្ថែមពេលវេលា[5] នួន ជា ខៀវ សំផន និងសហព្រះរាជអាជ្ញា បានដាក់សេចក្តីជូនដំណឹងរៀងៗខ្លួនអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[6]។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា បានបង្ហាញនូវទទ្បីករណ៍ចំនួន ២២៣ ដោយបានអះអាងថា រាល់កំហុសអង្គហេតុ ទោះបីតែឯកឯង ឬរួមជាមួយនឹងកំហុសដទៃទៀត សុទ្ធតែបណ្តាលឱ្យមានភាពអយុត្តិធម៌ និងថា រាល់កំហុសអង្គច្បាប់ទាំងអស់ យ៉ាងហោចណាស់បានធ្វើឱ្យផ្នែកខ្លះនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានសុពលភាពឡើយ[7]។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន បានលើកឡើងនូវទទ្បីករណ៍ចំនួន ១៤៨ និងបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងបង្គាប់ឱ្យដោះលែងរូបគាត់ឱ្យមានសេរីភាពជាបន្ទាន់[8]។ សហព្រះរាជអាជ្ញាបានប្រកាសថា ខ្លួនដាក់បណ្តឹងសាទុក្ខ"ដើម្បីប្រយោជន៍ច្បាប់"ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលក្នុងរឿងក្តីនេះបានសម្រេចមិនពិចារណាលើទម្រង់ III នៃសហឧក្រិដ្ឋកម្មរួមដែលជាទម្រង់មួយនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[9]។

៥.នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[10]។

៦.នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ បន្ទាប់ពីបានទទួលការអនុញ្ញាតបន្ថែមពេលវេលា និងចំនួនទំព័រ[11] នួន ជា

---

[5] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាលើបណ្តឹងសទុក្ខ (F3/3)។

[6] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា (E313/1/1)។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (E313/2/1)។

[7] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ (E 313/1/1) កថាខណ្ឌ ២។

[8] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ (E313/2/1) កថាខណ្ឌ ១៥៣។

[9] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E313/3/1)។

[10] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (F11)។

[11] សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតប (F9)។ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ និងពេលវេលាក្នុងការឆ្លើយតប (F13/2)។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំដាក់សារណាបន្ថែម (F15/1)។

បានដាក់សារណាបណ្តឹងសាទុក្ខតែភាសាអង់គ្លេស[12] ហើយ ខៀវ សំផន បានដាក់តែភាសាបារាំងមួយប៉ុណ្ណោះ[13]។ សំណៅបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ត្រូវបានជូនដំណឹងនៅថ្ងៃទី ២៤ និង ២៥ ខែ មីនា ឆ្នាំ ២០១៥ រៀងៗខ្លួន[14]។

៧.នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥ បន្ទាប់ពីបានទទួលការអនុញ្ញាតបន្ថែមពេលវេលា[15] ជនជាប់ចោទទាំងពីរបានដាក់សារណាតបរៀងៗខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[16]។

៨.នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាំងពីរ[17]តែភាសាអង់គ្លេសមួយប៉ុណ្ណោះ[18]។ សំណៅបកប្រែជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥។

៩.នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ បន្ទាប់ពីបានទទួលការអនុញ្ញាត[19] សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណាតបរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទតែភាសាអង់គ្លេសមួយប៉ុណ្ណោះ[20]។ សំណៅបកប្រែជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥។

១០.នៅថ្ងៃទី ០២ ០៣ និង ០៦ ខែ កក្កដា ឆ្នាំ ២០១៥[21] អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការសួរ

---

[12] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា។

[13] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំកែតម្រូវលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (F18/3)។

[14] ការបកប្រែជាភាសាអង់គ្លេសនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ត្រូវបានជូនដំណឹងនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥។

[15] សេចក្តីសម្រេចស្តីពីការបន្ថែមពេលវេលា និងចំនួនទំព័រ ដើម្បីធ្វើការឆ្លើយតប (F13/2)។

[16] សារណាតបរបស់ នួន ជា។ សារណាតបរបស់ ខៀវ សំផន។

[17] សារណាតបរបស់សហព្រះរាជអាជ្ញា។

[18] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបតែជាភាសាអង់គ្លេសមួយប៉ុណ្ណោះ (F21/1)។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីការបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ធ្វើការឆ្លើយតប (F23/1)។

[19] សេចក្តីសម្រេចស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី (F10/2)។

[20] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[21] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F1/1.1។ ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F1/2.1។ ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ F1/3.1។

សាក្សីចំនួន ៣ នាក់[22] ដែល នួន ជា បានស្នើសុំឱ្យកោះហៅ[23]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ភាគីពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយណាដែលទំនងជាបានទទួលតាមរយៈការធ្វើទារុណកម្មឡើយ[24]។

១១.នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៦ ដល់ ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងបានជូនដំណឹងដល់ភាគីអំពី"ការកែប្រែប្រភេទបទចោទ"ជាសក្តានុពល ដោយបានអញ្ជើញភាគីដាក់សារណាពាក់ព័ន្ធបញ្ហានេះ[25]។ ដោយសារបញ្ហាគ្រប់គ្រង សវនាការត្រូវបានពន្យារពេលនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥[26]។

១២.នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការលើបណ្តឹងសាទុក្ខ ប៉ុន្តែមួយរយៈខ្លីក្រោយមកបានផ្អាក ដោយសារខ្វះមេធាវីការពារស្របច្បាប់សម្រាប់ នួន ជា ដែលសហមេធាវីការពាក្តីរបស់គាត់បានដើរចេញពីបន្ទប់សវនាការ[27] ទើបបណ្តាលឱ្យអង្គជំនុំជម្រះសម្រេចដាក់ទណ្ឌកម្មលើសហមេធាវីការពារក្តីជាតិរបស់ នួន ជា ចំពោះកំហុសវិជ្ជាជីវៈរបស់ខ្លួន[28] និងបានណែនាំអង្គភាពគាំពារការការពារក្តីឱ្យជ្រើសតាំងមេធាវីបម្រុងសម្រាប់ការពារក្តី នួន ជា[29]។

១៣.នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ បន្ទាប់ពីការជ្រើសតាំងមេធាវី ផាត់ ពៅស៊ាង ធ្វើជាមេធាវីបម្រុងសម្រាប់ នួន ជា[30] អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា សវនាការបណ្តឹងសាទុក្ខត្រូវបន្តនៅថ្ងៃទី ១៦ ខែ

---

[22] ដីកាកំណត់កាលបរិច្ឆេទសវនាការលើភស្តុតាង (F24)។ សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ (F26)។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរក្នុងគោលបំណងដើម្បីវាយតម្លៃភាពអាចជឿជាក់បានរបស់សាក្សី (F28/4)។

[23] *សូមមើល* សេចក្តីសម្រេចលើសំណើសុំកោះហៅសាក្សី (F2/5)។

[24] សេចក្តីសម្រេចលើភស្តុតាងដែលបានទទួលតាមរយៈការធ្វើទារុណកម្ម (F26/12)។

[25] ដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខ (F30)។

[26] ដីកាកំណត់កាលបរិច្ឆេទស្ពាពរលើសវនាការបណ្តឹងសាទុក្ខ (F30/4)។

[27] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1។

[28] សេចក្តីសម្រេចស្តីពីប្រព្រឹត្តរបស់មេធាវីការពារក្តី (F30/18)។

[29] អនុស្សរណៈស្តីពីការជ្រើសតាំងមេធាវីបម្រុង (F30/15)។ *សូមមើលផងដែរ* អនុស្សរណៈដោះស្រាយលើទំនាស់ផលប្រយោជន៍ (F30/15/1/1)។

[30] ការជ្រើសតាំងមេធាវីបម្រុងរបស់អង្គភាពគាំពារការការពារក្តី (F30/15/2)។ *សូមមើលផងដែរ* សេចក្តីសម្រេចបដិសេធសារណាររបស់សហព្រះរាជអាជ្ញា (F30/16/1)។

កុម្ភៈ ឆ្នាំ ២០១៦ រហូតដល់ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦[31]។

១៤.នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានបន្តសវនាការលើបណ្តឹងសាទុក្ខនេះ[32] និងបន្ទាប់ពីបានស្តាប់សារណាផ្ទាល់មាត់របស់ ខៀវ សំផន សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានប្រកាសបិទសវនាការនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦[33]។

១៥.នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានចេញដីកាកំណត់កាលបរិច្ឆេទប្រកាសសាលដីកាលើបណ្តឹងសាទុក្ខដែលត្រូវធ្វើឡើងនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦[34]។

១៦.នៅថ្ងៃទី ០៨ ខែ មេសា និង ទី១១ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តីសំណុំរឿង ០០៣ និង ០០៤ សុំធ្វើបទអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ឬដាក់សារណារបស់*អ្នកដែលពុំមែនជាភាគីនៃរឿងក្តី*[35]។

---

[31] ដីកាសម្រេចបន្តសវនាការលើបណ្តឹងសាទុក្ខ (F30/17) ។

[32] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ F1/5.1។

[33] ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ F1/7.1 ទំព័រ ៦៧។

[34] ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលដីកា (F34)។

[35] សេចក្តីសម្រេចទីមួយស្តីពីបទអន្តរាគមន៍ (F20/1)។ សេចក្តីសម្រេចទីពីរស្តីពីបទអន្តរាគមន៍ (F31/1)។

## ២.សំណើសុំដាក់ភស្តុតាងបន្ថែម

## ២.ក.ប្រវត្តិនីតិវិធី

១៧.នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ នួន ជា បានលើកឡើងជាច្រើនតាមរយៈសំណើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយក និងពិចារណាភស្តុតាងបន្ថែម។ សំណើរបស់គាត់បានរួមបញ្ចូលការស្វែងរកដើម្បីឱ្យទទួលបានសម្ភារជាសោតទស្សន៍ ការស្នើសុំឱ្យកោះហៅបុគ្គលចំនួន ១៦ នាក់មកធ្វើជាសាក្សី និងការទទួលយកសម្ភារជាឯកសារ ឬសោតទស្សន៍ ធ្វើជាភស្តុតាង[36]។

១៨.នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកផ្នែកខ្លះនៃសំណើរបស់ នួន ជា និងបានផ្តួចផ្តើមបើកកិច្ចស៊ើបសួរបន្ថែមដោយចៅក្រមតំណាងពីររូប អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង[37]។ នៅក្នុងក្របខ័ណ្ឌនៃកិច្ចស៊ើបសួរនេះ Robert LEMKIN បានផ្តល់កំណត់ហេតុរបស់គាត់ដែលពុំបានផ្សព្វផ្សាយជាសាធារណៈ និងបានអះអាងថា កំណត់ហេតុទាំងនេះគឺជាសេចក្តីសង្ខេបខ្លឹមសារនៃកិច្ចសម្ភាសន៍ដែល រូបគាត់ និង ថេត សម្បត្តិ បានធ្វើឡើងជាមួយបុគ្គលចំនួន ៤ នាក់ ដែលបុគ្គលនេះគាត់បានលើកឡើងនៅក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងចៅក្រមតំណាង[38] (“កំណត់ហេតុរបស់ Robert LEMKIN”)[39]។ ផ្អែកតាមសេចក្តីសម្រេចបណ្តោះអាសន្នទីបីស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3/3/5) Robert LEMKIN ក្រោយមកបានផ្តល់អ្វីដែលគាត់ហៅថា ប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយនឹងបុគ្គលបួននាក់នោះ (“ប្រតិចារឹក LEMKIN ”)[40]។

១៩.នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកផ្នែកខ្លះនៃសំណើបន្ថែមរបស់ នួន ជា សុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ទាត់ ធឿន[41](SCW-5) ធ្វើជាភស្តុតាង

---

[36] *សូមមើល* សេចក្តីសង្ខេបនៃប្រវត្តិនីតិវិធី ផ្នែកសម្រេចសេចក្តីលើសំណើសុំដាក់ភស្តុតាងបន្ថែមដែលពុំទាន់បានសម្រេច (F2/9)។

[37] សេចក្តីសម្រេចបណ្តោះអាសន្នទីមួយស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3) កថាខណ្ឌ ២៤ ដល់ ២៦។

[38] កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ Robert LEMKIN ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ (F2/4/3/1)។

[39] ឧបសម្ព័ន្ធ-កំណត់ហេតុរបស់ Robert LEMKIN ស្តីពីកម្មវិធីនយោបាយរបស់ ញឹម រស់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ (F2/4/3/3.1)។

[40] ប្រតិចារឹកដែលបានផ្តល់ដោយ Robert LEMKIN ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ (F2/4/3/3/6.2)។

[41] កត់សម្គាល់ថា ឈ្មោះរបស់គាត់ប្រកបជាភាសាឡាតាំង “TOIT Thoeurn”(ទាត់ ធឿន)។ នៅក្នុងរាល់សេចក្តីសម្រេចក្នុងសំណុំរឿង ០០២/០១ រួមទាំងសាលដីកានេះផងដែរ អង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់ភាសាឡាតាំងនេះ។

និងកោះហៅសាក្សី សំ សិទ្ធី (SCW-3) សាក្សី សៅ វ៉ន (SCW-4) និងទាត់ ធឿន មកផ្ដល់សក្ខីកម្ម[42] ដែលអ្នកទាំងអស់នេះបានធ្វើឡើងនៅថ្ងៃទី ០២ ទី០៣ និង ទី០៦ ខែ កក្កដា ឆ្នាំ ២០១៦[43]។

២០.នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្ដីសម្រេចមួយដោះស្រាយលើសំណើដែលនៅសេសសល់របស់ នួន ជា ដែលសុំឱ្យទទួលយកភស្តុតាងបន្ថែម[44] ដោយបានផ្ដល់សំអាងហេតុដូចតទៅថា ដោយអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានទទួលយកជាភស្តុតាងនូវ (i) កំណត់ហេតុជាវីដេអូនៃកិច្ចសម្ភាសន៍របស់ចៅក្រម Silvia CARTWRIGHT ដែលបានធ្វើឡើងនៅវិទ្យាស្ថាន Aspen ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៣ ដែលពេលនោះ លោកស្រី គឺជាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង (“កិច្ចសម្ភាសន៍របស់ចៅក្រម CARTWRIGHT”)[45] (ii) សេចក្ដីដកស្រង់ចេញពីសៀវភៅចំណងជើងថា *ចៅក្រម និងខ្មែរក្រហម* និពន្ធដោយអតីតសហចៅក្រមស៊ើបអង្កេត Marcel Lemonde (“សេចក្ដីដកស្រង់ចេញពីសៀវភៅរបស់ LEMONDE”)[46] (iii) ប្រតិចារឹកចំនួន ២ របស់ ពេជ្រ ជឹម នៃសក្ខីកម្មចុះថ្ងៃទី ២៣ និង ២៤ ខែ មេសា ឆ្នាំ ២០១៥ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ (“ប្រតិចារឹករបស់ ពេជ្រ ជឹម”)[47] (iv) ប្រតិចារឹករបស់ ទាត់ ធឿន នៃកិច្ចសម្ភាសន៍ជាមួយនឹង ថេត សម្បត្តិ និង Robert LEMKIN[48] និងផ្អែកតាមគំនិតផ្តួចផ្តើមរបស់ខ្លួន (v) កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាលាយលក្ខណ៍អក្សររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ជាមួយ សៅ វ៉ន (“កិច្ចសម្ភាសន៍របស់ DC-Cam ជាមួយ សៅ

---

[42] សេចក្ដីសម្រេចស្ដីពីការកោះហៅសាក្សីនៅដំណាក់កាលបណ្ដឹងសាទុក្ខ (F2/5) កថាខណ្ឌ ២៦។

[43] ដីកាកំណត់កាលបរិច្ឆេទសវនាការលើភស្តុតាង (F24)។

[44] ផ្នែកសម្រេចសេចក្ដីស្ដីពីសំណើសុំដាក់ភស្តុតាងបន្ថែមដែលពុំទាន់បានសម្រេច (F2/9) កថាខណ្ឌ ៦ ដល់ ៧។

[45] ឧបសម្ព័ន្ធ ៣៖ កិច្ចសម្ភាសន៍របស់ចៅក្រម Silvia Cartwright នៅវិទ្យាស្ថាន Aspen (ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ F2/9.3R។

[46] ឧបសម្ព័ន្ធ ៤៖ សេចក្ដីដកស្រង់ចេញពីសៀវភៅ Marcel Lemonde៖ Un juge face aux Khmers Rouges (ចៅក្រម និងខ្មែរក្រហម) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F2/9.4 (ការបញ្ចូលគ្នានូវសេចក្ដីដកស្រង់ចេញពីសៀវភៅដែលបានដាក់ក្នុងសំណុំរឿង E189/3/1/7.1.1 E189/3/1/7.1.2 E189/3/1/7.1.3 និង E189/3/1/7.1.4)។

[47] ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម)(សំណុំរឿង ០០២/០២) ឯកសារលេខ F2/6.1.1។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម)(សំណុំរឿង ០០២/០២) ឯកសារលេខ F2/6.1.2។

[48] កិច្ចសម្ភាសន៍របស់ ទាត់ ធឿន ជាមួយ ថេត សម្បត្តិ និង Robert LEMKIN ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ (F2/9.2) (សេចក្ដីដកស្រង់ចេញពីប្រតិចារឹករបស់ LEMKIN)។

វ៉ន")[49] ហេតុនេះ អង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសេសសល់ដទៃទៀតរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម និងបិទកិច្ចស៊ើបសួរបន្ថែមដែលខ្លួនបានធ្វើឡើង។

២១.នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធសំណើរបស់ នួន ជា ដែលស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាលើផ្នែកសម្រេចសេចក្តីរបស់ខ្លួនឡើងវិញ ស្តីពីសំណើសុំដាក់ភស្តុតាងបន្ថែមដែលពុំទាន់បានសម្រេច (F2/9) ឬផ្តល់សំអាងហេតុពាក់ព័ន្ធឱ្យបានមុនការបន្តសវនាការលើបណ្តឹងសាទុក្ខ ហើយអង្គជំនុំជម្រះបានបញ្ជាក់ថា សំអាងហេតុទាំងនោះនឹងត្រូវផ្តល់នៅក្នុងសាលដីកានេះលើផ្នែកអង្គសេចក្តីនៃបណ្តឹងសាទុក្ខ[50]។

២២.ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងផ្នែកសម្រេចសេចក្តីរបស់ខ្លួនស្តីពីសំណើសុំដាក់ភស្តុតាងបន្ថែមដែលពុំទាន់បានសម្រេចនោះ(F2/9)។

## ២.ខ.ក្របខ័ណ្ឌច្បាប់

២៣.នៅក្នុងសេចក្តីសម្រេចស្តីពីកោះហៅសាក្សីនៅដំណាក់កាលបណ្តឹងសាទុក្ខ (F2/5)[51] អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សេចក្តីសង្ខេបនៃច្បាប់ជាធរមាន សម្រាប់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខដូចខាងក្រោម៖

> អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា មានលក្ខខណ្ឌពីរសម្រាប់អង្គជំនុំជម្រះ ក្នុងការទទួលយកភស្តុតាងថ្មីលើបណ្តឹងសាទុក្ខ។ ទីមួយ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង បានកំណត់លក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្តតាម ក្នុងការសម្រេចលើសំណើរបស់ភាគីសុំដាក់ភស្តុតាងបន្ថែម។ នេះជាលក្ខខណ្ឌធម្មតាសម្រាប់ការបង្ហាញភស្តុតាងលើបណ្តឹងសាទុក្ខ។ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងចែងដូចនៅក្នុងផ្នែកដែលពាក់ព័ន្ធថា៖
>
> > ភាគី អាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង បើសិនជាភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ ហើយដែលជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែម

---

[49] កិច្ចសម្ភាសន៍របស់ សៅ វ៉ន ជាមួយ DC-Cam នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១ (F2/9.1)។

[50] សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យធ្វើការពិចារណាឡើងវិញ (F2/10/3) ទំព័រ ៤ ដល់ ៥។

[51] សេចក្តីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5) កថាខណ្ឌ ១៥ ដល់ ១៧។

> ភស្តុតាង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនេះជាមួយនឹងសម្អាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក។
>
> អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា វិធាននេះអនុវត្តទៅលើអង្គហេតុថ្មីដែលទើបតែរកឃើញ និងមធ្យោបាយថ្មីដែលជាភស្តុតាង (*facta noviter producta* and *facta noviter reperta*)[52]។

ដូច្នេះ បន្ថែមទៅលើបទដ្ឋានទូទៅនៃភាពអាចទទួលយកបានតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង បទដ្ឋានដែលមានបីចំណុចនេះ បានអនុវត្តចំពោះសេចក្ដីសម្រេចលើសំណើសុំភស្តុតាងបន្ថែមនៅដំណាក់កាលបណ្ដឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលត្រូវជឿជាក់ដោយខ្លួនឯងថា ភស្តុតាងដែលបានផ្តល់ឱ្យនោះ៖ (i) ពុំអាចរកបានពេលជំនុំជម្រះ (ii) ជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្ដីសម្រេចនៅក្នុងសវនាការលើបណ្ដឹងសាទុក្ខ និង (iii) ទាក់ទងទៅនឹងសម្អាងហេតុជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង។ ទាក់ទងទៅនឹងចំណុចទីមួយ យុត្តិសាស្ត្រនៅកម្រិតអន្តរជាតិ តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំត្រូវបង្ហាញថា "ភស្តុតាង [ដែលបានស្នើឡើង] ពុំអាចរកបាននៅពេលជំនុំជម្រះ បើទោះបីជាបានប្រឹងប្រែងស្វែងរកដោយយកចិត្តទុកដាក់យ៉ាងណាក៏ដោយ"[53]។ លក្ខខណ្ឌតម្រូវនេះមានសារៈសំខាន់សម្រាប់ជៀសវាងកុំឱ្យប្រើប្រាស់យុត្តិសាស្ត្រតវ៉ាក្ដីដែលជាការរំខាន និងគ្មានប្រសិទ្ធិភាព[54]។

ទីពីរ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងបញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូល អាច"កោះហៅសាក្សីថ្មី" ក្នុងការសម្រេចលើបណ្ដឹងសាទុក្ខដែលខ្លួនបានទទួល។ អំណាចនេះ ជាឆន្ទានុសិទ្ធិដែលអង្គជំនុំជម្រះអាចប្រើប្រាស់*តាមគំនិតផ្តួចផ្តើម*របស់ខ្លួន នៅពេលដែលប្រយោជន៍យុត្តិធម៌តម្រូវ ដោយធ្វើការពិចារណាទៅលើកាលៈទេសៈជាក់លាក់នៃរឿងក្ដី[55]។ ក្នុងការកំណត់បែបនេះ អង្គជំនុំជម្រះនឹងត្រូវ

---

[52] [ជើងទំព័រ ៤៨ ក្នុងសេចក្ដីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5)][សេចក្ដីសម្រេចបណ្ដោះអាសន្នទីមួយស្ដីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3) ] កថាខណ្ឌ ១៥។

[53] [ជើងទំព័រ ៤៩ ក្នុងសេចក្ដីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5)] *សូមមើល* សាលដីកា*រឿងក្ដី Lubanga* (ICC) កថាខណ្ឌ ៥០ (សង្ខេបយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ត្រង់ចំណុចនេះ)។

[54] [ជើងទំព័រ ៥០ ក្នុងសេចក្ដីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី ឯកសារលេខ (F2/5)] *សូមមើល* សាលដីកា*រឿងក្ដី Nahimana* (ICTR)] កថាខណ្ឌ ៤ ដល់ ៥។ [សេចក្ដីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម*រឿងក្ដី Kupreškić* (ICTY) ] កថាខណ្ឌ ៣។

[55] [ជើងទំព័រ ៥១ ក្នុងសេចក្ដីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5)] *សូមមើល* [សាលដីកា*រឿងក្ដី Lubanga* (ICC)] កថាខណ្ឌ ៦២ (ក្នុងនោះ អង្គជំនុំជម្រះសាលាកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានយល់ឃើញថា អង្គជំនុំជម្រះមាន

ពិចារណា ថាតើភស្តុតាងថ្មីនេះ"នឹងជួយក្នុងការស្វែងរកការពិត" ដែរ ឬយ៉ាងណា[56]។ ការប្រើប្រាស់អំណាចនេះពុំបានធ្វើឱ្យប៉ះពាល់ដល់ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើទឡ្ហីករណ៍របស់នួន ជា ដែលបានលើកឡើងថា អង្គជំនុំជម្រះគប្បីប្រើប្រាស់យុត្តាធិការបណ្តឹងសាទុក្ខក្នុងការជំនុំជម្រះ *សាជាថ្មី* លើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ឡើយ[57]។

២៤.នៅក្នុងផ្នែកខាងក្រោមនេះ អង្គជំនុំជម្រះតុលាការកំពូលពិភាក្សាលម្អិតលើច្បាប់ជាធរមានទាក់ទងទៅនឹងភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ។

## ២.ខ.១."កត្តាកំណត់"តាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង

២៥.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់តាំងពីដំបូងថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំបានចែងអំពីសេចក្តីណែនាំជាបទដ្ឋានស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់គ្រប់គ្រងការបង្ហាញភស្តុតាងថ្មី នៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ[58]។ បន្ថែមលើនេះទៀត ដូចបានបង្ហាញនៅខាងក្រោម អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា "ច្បាប់ អ.វ.ត.ក. បានកំណត់នីតិវិធីនៃការពិនិត្យឡើងវិញមួយដាច់ដោយឡែក"[59] ដែលជាចាំបាច់ត្រូវបានបំពេញបន្ថែមដោយវិធានស្តីពីការដាក់ភស្តុតាងបន្ថែមដែលស្របជាមួយច្បាប់ អ.វ.ត.ក. ប៉ុន្តែខុសប្លែកពីវិធានក្នុងស្រុក។ អាស្រ័យហេតុនេះ ក្នុងការបកស្រាយវិធាន ១០៨(៧) អង្គជំនុំជម្រះតុលាការកំពូលស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ[60]។

២៦.វិធាន ១១៥(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស

---

ឆន្ទានុសិទ្ធិទទួលយកភស្តុតាងលើបណ្តឹងសាទុក្ខ បើទោះបីជាមានការយល់ឃើញអវិជ្ជមានមួយ ឬច្រើនអំពីលក្ខណៈវិនិច្ឆ័យដែលកំណត់ភាពអាចទទួលយកបាននៃភស្តុតាងលើបណ្តឹងសាទុក្ខក៏ដោយ)។

[56] [ជើងទំព័រ ៥២ ក្នុងសេចក្តីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5)] *សូមមើល* វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលត្រូវអានភ្ជាប់ជាមួយនឹងវិធាន ១០៤ *ស្ទួន* នៃវិធានផ្ទៃក្នុង។

[57] សេចក្តីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5) កថាខណ្ឌ ១៥ ដល់ ១៧។

[58] *សូមមើល*មាត្រា ៣៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ចែងថា "ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថា មានប្រយោជន៍។ សាក្សី និងអ្នកជំនាញនឹងត្រូវបានគេស្តាប់ចម្លើយលុះត្រាតែតុលាការបង្គាប់ឱ្យធ្វើដូច្នោះ")។

[59] *សូមមើលខាងក្រោម* កថាខណ្ឌ ៩១ *ជាអាទិ៍*។

[60] *សូមអាន* មាត្រា ៣៣ ថ្មី ផ្គួបជាមួយនឹងមាត្រា ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

យូហ្គោស្លាវី(“ICTY”) និងវិធាន ១១៥(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា(“ICTR”)ចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធដូចខាងក្រោម៖

> ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងបន្ថែមនេះពុំអាចរកបាននៅពេលជំនុំជម្រះមានការជាប់ពាក់ព័ន្ធ និងមានភាពអាចជឿជាក់បាន អង្គជំនុំជម្រះនឹងត្រូវកំណត់ ថាតើភស្តុតាងនេះអាចជាកត្តាកំណត់ដែលនាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅពេលជំនុំជម្រះ ដែរ ឬយ៉ាងណា[61]។

២៧.ដោយផ្អែកលើបទប្បញ្ញត្តិខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានរកឃើញថា ភស្តុតាងបន្ថែមនៅក្នុងបណ្តឹងឧទ្ធរណ៍*ក្នុងចំណោមនោះ* ត្រូវតែជាប់ពាក់ព័ន្ធទៅនឹង“ការយល់ឃើញផ្នែកអង្គហេតុដែលជាមូលដ្ឋានសម្រាប់ការដាក់ពិរុទ្ធភាព ឬការប្រកាសទោស ក្នុងន័យថា ការយល់ឃើញទាំងនោះ មានសារៈសំខាន់ ឬចាំបាច់បំផុតសម្រាប់ការដាក់ពិរុទ្ធភាព ឬការប្រកាសទោស”[62] និងថា ភស្តុតាងដែលស្នើឡើងនេះ “*អាច*មានឥទ្ធិពលដល់ការសម្រេចដាក់ពិរុទ្ធភាព បើនិយាយម្យ៉ាងទៀត ភស្តុតាងនេះត្រូវតែជាភស្តុតាងដែលអាចបង្ហាញថា ការសម្រេចនោះពុំទាន់មានមូលដ្ឋានរឹងមាំនៅឡើយ ប្រសិនបើពិចារណាក្នុងបរិបទនៃភស្តុតាងដែលបានបង្ហាញនៅពេលជំនុំជម្រះ”[63]។ ដូចនេះ តម្រូវឱ្យមានការបង្ហាញនូវ“លទ្ធភាពជាក់ស្តែងថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អាចមានភាពខុសប្លែកពីមុន ប្រសិនបើភស្តុតាងថ្មីត្រូវបានទទួលយក”[64]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក៏បានអះអាងផងដែរថា ជាកាតព្វកិច្ចរបស់ភាគីដែលស្នើសុំដាក់ភស្តុតាងបន្ថែមលើបណ្តឹងឧទ្ធរណ៍ ដែលជាអ្នកបង្ហាញអំពីឥទ្ធិពលនោះ[65]។

២៨.ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) បានអះអាងថា ទោះបីជា វិធាន ៦២ នៃបទប្បញ្ញត្តិរបស់ ICC ពុំបានតម្រូវជាពិសេសក៏ដោយ៖

---

[61] វិធាន ១១៥(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង វិធាន ១១៥(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR។

[62] សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម*រឿងក្តី Popović* (ICTY) កថាខណ្ឌ ៨។

[63] សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម*រឿងក្តី Popović* (ICTY) កថាខណ្ឌ ៩។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម*រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ៦ (“ភស្តុតាងត្រូវតែ*អាច*មានឥទ្ធិពលលើសាលក្រម *ខ.* ភស្តុតាង*បានបង្ហាញ*ថា ការសម្រេចដាក់ពិរុទ្ធភាពមានមូលដ្ឋានពុំរឹងមាំ”។

[64] សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម*រឿងក្តី Popović* (ICTY) កថាខណ្ឌ ៩។

[65] សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម*រឿងក្តី Krajisnik* (ICTY) កថាខណ្ឌ ៧។

[ក៏] ជាការចាំបាច់ត្រូវលើកពីលក្ខណៈវិនិច្ឆ័យបង្ហាញថា ភស្តុតាងបន្ថែមនេះអាចនាំឱ្យអង្គជំនុំជម្រះសាលាដំបូងឈានទៅកែប្រែការសម្រេចដាក់ពិរុទ្ធភាពខុសប្លែកពីមុនទាំងស្រុង ឬផ្នែកខ្លះ។ លក្ខណៈវិនិច្ឆ័យនេះ ផ្អែកលើគោលការណ៍ដែលថា ភស្តុតាងគប្បីត្រូវបានបង្ហាញឱ្យបានច្រើនតាម ដែលអាចធ្វើទៅបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែមិនមែននៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ឡើយ។ អាស្រ័យហេតុនេះ ប្រសិនបើភស្តុតាងបន្ថែមពុំបានបង្ហាញថា មានសារៈសំខាន់គ្រប់គ្រាន់ និងពុំអាចធ្វើឱ្យការសម្រេចដាក់ពិរុទ្ធភាពប្រែប្រួលទេនោះ គឺពុំមានហេតុផលណាដែលត្រូវអនុញ្ញាតឱ្យលើកឡើងនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ឡើយ[66]។

២៩.អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងគោលការណ៍ដូចបានរំឭកខាងលើថា តាមធម្មតា ភស្តុតាងគប្បីត្រូវបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ការធ្វើដូច្នេះ គឺស្របជាមួយនឹងចរិតលក្ខណៈជាអ្នកកែតម្រូវនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនៅ អ.វ.ត.ក. ដែលជាប្រព័ន្ធមួយក្នុងនោះអង្គជំនុំជម្រះសាលាដំបូង"មានកាតព្វកិច្ចសំខាន់ក្នុងការផ្តល់ការយល់ឃើញផ្នែកអង្គហេតុ" ហើយអង្គជំនុំជម្រះតុលាការកំពូលមានតួនាទីក្នុងការផ្ទៀងផ្ទាត់ឱ្យឃើញថា លក្ខខណ្ឌក្នុងការបង្ហាញធាតុផ្សំនៃបទចោទឱ្យហួសពីវិមតិសង្ស័យត្រូវបានបំពេញ ដោយពុំចាំបាច់ធ្វើការវាយតម្លៃ*សាជាថ្មី*លើភស្តុតាងឡើយ[67]។

៣០.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដើម្បីបញ្ជាក់ថា ភស្តុតាងបន្ថែមដែលបានស្នើឡើងនោះ អាចជាកត្តាឈានទៅរកការធ្វើសេចក្តីសម្រេចបាន ភាគីដែលស្នើសុំភស្តុតាងត្រូវតែបង្ហាញថា ភស្តុតាងនេះ ប្រសិនបើបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អាចនាំឱ្យអង្គជំនុំជម្រះនេះធ្វើការសម្រេចពីពិរុទ្ធភាពខុសប្លែកពីមុនទាំងស្រុង ឬផ្នែកខ្លះ។ ក្នុងការវាយតម្លៃបែបនេះ ភស្តុតាងបន្ថែមដែលបានស្នើឡើង ត្រូវតែបានវាយតម្លៃទៅតាមបរិបទនៃភស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការយល់ឃើញផ្នែកអង្គហេតុ ដែលមានលក្ខណៈសំខាន់ ឬចាំបាច់បំផុតចំពោះការសម្រេចដាក់ពិរុទ្ធភាព ឬការប្រកាសទោស។ អាស្រ័យលើភាគីដែលស្នើសុំដាក់ភស្តុតាងបន្ថែម ក្នុងការបង្ហាញពីឥទ្ធិពលរបស់ភស្តុតាងដែលបានស្នើសុំដាក់បន្ថែមនោះ។

---

[66] សាលាដីកា*រឿងក្តី* *Lubanga* (ICC) កថាខណ្ឌ ៥៩ (ជើងទំព័រលុបចោល)។

[67] *សូមមើលខាងក្រោម* កថាខណ្ឌ ៩៤។

## ២.៦.២.“ផលប្រយោជន៍យុត្តិធម៌”ទាក់ទងទៅនឹងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង

៣១.ទាក់ទងទៅនឹងការពិនិត្យភស្តុតាង“ថ្មី” តាមវិធាន ១០៤(១)[68] នៃវិធានផ្ទៃក្នុង លក្ខណៈវិនិច្ឆ័យនៃ“កត្តាកំណត់”ពុំបានកំណត់ច្បាស់លាស់ឡើយ។ ជាក់ស្តែង វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងពុំបានបញ្ជាក់ច្បាស់លាស់ថាតើអង្គជំនុំជម្រះតុលាការកំពូលគប្បីផ្អែកលើលក្ខណៈវិនិច្ឆ័យណាខ្លះ ក្នុងការពិនិត្យភស្តុតាងបន្ថែមនៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខឡើយ។ នៅក្នុងសេចក្តីសម្រេចស្តីពីកោះហៅសាក្សីនៅដំណាក់កាលបណ្តឹងសាទុក្ខ (F2/5) អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដើម្បីកោះហៅសាក្សីដែលជាភស្តុតាង“ថ្មី” អង្គជំនុំជម្រះត្រូវពិចារណាលើបញ្ហា ថាតើការកោះហៅសាក្សីនេះ“មានផលប្រយោជន៍យុត្តិធម៌”ក្នុងន័យថា “អាចជួយស្វែងរកការពិតបាន”[69] ដែរ ឬយ៉ាងណា។ នេះរួមបញ្ចូលករណីដែលអង្គជំនុំជម្រះត្រូវប្រឈមជាមួយនឹងភស្តុតាងដោះបន្ទុកមានសក្តានុពល ដែលភស្តុតាងនេះចាំបាច់ត្រូវទទួលយកដើម្បីជៀសវាងភាពមិនយុត្តិធម៌ ឬក្នុងករណីដែលជនជាប់ចោទបានលើកពីភាពមន្ទិលសង្ស័យ ដែលមានលក្ខណៈធ្ងន់ធ្ងរទាក់ទងទៅនឹងភាពសមស្របនៃការធ្វើកំណត់ហេតុភស្តុតាងគន្លឹះ[70]។ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងក៏បានអនុញ្ញាតផងដែរឱ្យបង្ហាញភស្តុតាងដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងភស្តុតាងដទៃទៀត ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ឬដែលអាចមានឥទ្ធិពលយ៉ាងខ្លាំងលើភាពអាចជឿទុកចិត្តបាន ឬភាពអាចជឿជាក់បាន។

៣២.ហេតុនេះ សេចក្តីសម្រេចកោះហៅសាក្សីដែលជាភស្តុតាងបន្ថែមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង គឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូលទាំងស្រុង។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលនៅពេលប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការអនុវត្តតួនាទីរបស់ខ្លួន ជាចម្បងត្រូវកំណត់ ថាតើសាលក្រមមានកំហុសដោយមូលហេតុកំហុសអង្គច្បាប់នាំឱ្យមោឃៈ ឬកំហុសអង្គហេតុនាំឱ្យមានភាពមិនយុត្តិធម៌ ដែរ ឬយ៉ាងណាដោយមិនចាំបាច់បើកការជំនុំជម្រះលើអង្គសេចក្តីជាលើកទីពីរឡើយ[71]។ ក្នុងរឿងនេះ ក៏ត្រូវផ្តល់ព័ត៌មានអំពីការកំណត់ថា ភស្តុតាងបន្ថែមនោះ គឺ“អាចជួយស្វែងរកការពិត”បាន ហើយអង្គជំនុំជម្រះតុលាការកំពូលពុំគប្បីទទួលយកដោយងាយៗនូវភស្តុតាងបន្ថែមដែលជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលពុំមានសក្តានុពលនាំឱ្យ

---

[68] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[69] សេចក្តីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5) កថាខណ្ឌ ១៧។

[70] សេចក្តីសម្រេចទីមួយលើសំណើសុំកោះហៅសាក្សី (F2/5) កថាខណ្ឌ ២៣ និង ២៥។

[71] *សូមមើលខាងក្រោម* កថាខណ្ឌ ៩៤។

មានឥទ្ធិពលដល់ការសម្រេចដាក់ពិរុទ្ធភាព ពីព្រោះបើទទួលយកដោយងាយៗ នោះជាបញ្ហាប្រឈមទៅនឹងតួនាទីរបស់ខ្លួន ដោយសារជាការបំពេញការងារដែលពុំជាប់ពាក់ព័ន្ធ។ ហេតុនេះ លើកលែងតែមានករណីពិសេស អង្គជំនុំជម្រះតុលាការកំពូលជាគោលការណ៍ អាចពិនិត្យភស្តុតាងបន្ថែមនៅក្នុងនីតិវិធីបណ្តឹងសាទុក្ខតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងបាន ក្នុងកាលៈទេសៈដែលភស្តុតាងនេះ ប្រសិនបើបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ អាចនាំឱ្យអង្គជំនុំជម្រះនេះធ្វើការសម្រេចពីពិរុទ្ធភាពខុសប្លែកពីមុនទាំងស្រុង ឬផ្នែកខ្លះ។ ក្នុងការវាយតម្លៃបែបនេះ ភស្តុតាងដែលបានស្នើឡើង ត្រូវតែបានវាយតម្លៃទៅតាមបរិបទនៃភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការយល់ឃើញផ្អែកអង្គហេតុដែលមានសារៈសំខាន់ ឬចាំបាច់បំផុតដល់ការសម្រេចដាក់ពិរុទ្ធភាពនោះ។

៣៣.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការបកស្រាយវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងតាមវិធីសាស្ត្រដែលបានលើកឡើងខាងលើ នាំឱ្យមានភាពត្រួតគ្នាជាច្រើនរវាងបទប្បញ្ញត្តិនេះ និងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណាក្តី ពុំមែនមានន័យថា វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង មិនសំខាន់នោះទេ។ ជាការកត់សម្គាល់ ផ្អែកតាមវិធាននេះ ភស្តុតាងអាចត្រូវបានទទួលយកនៅក្នុងនីតិវិធីបណ្តឹងសាទុក្ខ ប្រសិនបើភស្តុតាងនោះ អាចរកបាននៅពេលជំនុំជម្រះលើអង្គសេចក្តី ប៉ុន្តែ ដោយផ្អែកលើហេតុផលផ្សេងៗ ទើបពុំត្រូវបានទទួលយក។ ដូចគ្នានេះដែរ វិធាននេះ អាចជាមូលដ្ឋានក្នុងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីពិនិត្យភស្តុតាងតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ដោយពុំចាំបាច់មានសំណើសុំរបស់ភាគីឡើយ។

៣៤.អង្គជំនុំជម្រះតុលាការកំពូលគប្បីពិចារណាលើសំណើសុំដាក់ភស្តុតាង ដោយផ្អែកលើក្របខ័ណ្ឌច្បាប់ដែលបានលើកឡើងខាងលើ។ សេចក្តីសង្ខេបនៃសេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងសំណើនីមួយៗនឹងត្រូវធ្វើឡើងនៅក្នុងផ្នែកខាងក្រោម។

## ២.គ.សំណើសុំកោះហៅសាក្សី Gautam Kul CHANDRA (SCW-1) និង Paul IGNATIEFF (SCW-2)

៣៥.តាមការស្នើសុំនៅក្នុងសារណាបណ្តឹងសាទុក្ខ នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល កោះហៅសាក្សី Kul CHANDRA (SCW-1) និង Paul IGNATIEFF (SCW-2) "អនុលោមតាមយុត្តាធិការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ"[72] និងហាក់បីដូចជាស្នើឡើងថា អង្គជំនុំជម្រះតុលាការកំពូល គប្បីកោះហៅ

---

[72] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៣០ (គ)។

បុគ្គលពីររូបនេះ*តាមគំនិតផ្ដួចផ្ដើម*របស់ខ្លួន ដែលបានទទួលស្គាល់នៅក្នុងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណាក្ដី នួន ជា ពុំបានពន្យល់ពីមូលហេតុអ្វីដែលសាក្សីទាំងនេះគប្បីត្រូវបានកោះហៅ និងថាតើសំណើនេះ ស្របជាមួយនឹងវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង យ៉ាងដូចម្ដេចឡើយ[73]។ បុគ្គលពីររូបនេះពុំត្រូវបានលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខ ប៉ុន្តែបានលើកឡើងនៅក្នុងសំណើសុំតែម្ដង។ ដោយពុំបានលើកពីមូលដ្ឋានគាំទ្រនូវមូលហេតុដែលបុគ្គលពីររូបនេះគប្បីត្រូវបានកោះហៅនោះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធសំណើនេះចោល។

## ២.ឃ.សំណើសុំកោះហៅសាក្សី ហេង សំរិន និង អ៊ុក ប៊ុនឈឿន

៣៦.នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលកោះហៅសាក្សី ហេង សំរិន និង អ៊ុក ប៊ុនឈឿន ដោយស្របតាមវិធាន ១០៨(៧)[74]នៃវិធានផ្ទៃក្នុង។ ដូចបានរៀបរាប់ខាងលើ បទប្បញ្ញត្តិនេះត្រឹមតែអនុញ្ញាតឱ្យលើកនៅដំណាក់កាលបណ្ដឹងសាទុក្ខ នូវភស្តុតាងដែល“ពុំអាចរកបាននៅពេលសវនាការ”ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្ដី នួន ជា បានស្គាល់សាក្សីពីររូបដែលបានស្នើឡើងនោះនៅពេលជំនុំជម្រះ និងបានស្នើឡើងម្ដងហើយម្ដងទៀតឱ្យសាក្សីនេះបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផងដែរ[75]។ ចុងក្រោយ អង្គជំនុំជម្រះ

---

[73] សាក្សី Gautam Kul CHANDRA ទំនងជាបម្រើការជាមន្ត្រីទទួលបន្ទុកផ្នែកកម្មវិធីសម្រាប់អង្គការ UNICEF នៅក្នុងភ្នំពេញចាប់ពីឆ្នាំ ១៩៧៣ ដល់ ១៩៧៥។ នួន ជា បានស្នើឱ្យគាត់មកធ្វើជាសាក្សីនៅពេលជំនុំជម្រះដោយបានអះអាងថា គាត់បានផ្ដល់ភស្តុតាងអំពីលក្ខខណ្ឌទូទៅលើប្រជាជនមុនរបបកម្ពុជាប្រជាធិបតេយ្យ (*សូមមើល* ឧបសម្ព័ន្ធ ៣៖ សេចក្ដីសង្ខេបសាក្សី (E93/4.3) ទំព័រ ៣៥ ដល់ ៣៦)។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធលើសំណើនេះ ដោយបានពិចារណាឃើញថា សក្ខីកម្មរបស់គាត់ពុំជាប់ពាក់ព័ន្ធ ឬច្រំដែរ (*សូមមើល* សេចក្ដីសម្រេចស្ដាពស្ដីពីសាក្សី (E312) ឧបសម្ព័ន្ធ II៖ បុគ្គលត្រូវបានស្នើឡើង ប៉ុន្តែពុំត្រូវបានស្ដាប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (E312.2) ទំព័រ ៦ ដល់ ៧)។ ទាក់ទងទៅនឹងសាក្សី Paul IGNATIEFF ទំនងជាប្រធានអង្គការ UNICEF ក្នុងទីក្រុងភ្នំពេញចាប់ពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥ និងថា នួន ជា ទំនងជាបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីសម្រាប់ហេតុផលដូចគ្នានឹងការកោះហៅ Gautam Kul CHANDRA (*សូមមើល* ឧបសម្ព័ន្ធ ៣៖ សេចក្ដីសង្ខេបសាក្សី (E93/4.3) ទំព័រ ៥១ ដល់ ៥២ (ភាសាអង់គ្លេស))។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ពុំមានភាពចាំបាច់ក្នុងការកោះហៅគាត់ ដោយផ្អែកលើភស្តុតាងជារួមដែលមាននៅចំពោះមុខអង្គជំនុំជម្រះ (*សូមមើល* សេចក្ដីសម្រេចស្ដាពស្ដីពីសាក្សី (E312) ឧបសម្ព័ន្ធ II៖ បុគ្គលត្រូវបានស្នើឡើង ប៉ុន្តែពុំត្រូវបានស្ដាប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (E312.2) ទំព័រ ៨)។

[74] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៣០(ក)។

[75] សំណើទីប្រាំមួយរបស់ នួន ជា សុំឱ្យកោះហៅសាក្សី ហេង សំរិន (E236/5/1/1) កថាខណ្ឌ ៣ ដល់ ៨ (សង្ខេបប្រវត្តិនីតិវិធីនៃសំណើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង)។

សាលាដំបូងពុំបានទទួលយកសំណើនេះឡើយ[76]។ អាស្រ័យហេតុនេះ បើទោះបីជាសាក្សីទាំងនេះពុំត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចកោះហៅមកផ្ដល់សក្ខីកម្ម (ការសម្រេចនេះត្រូវបានជំទាស់នៅដំណាក់កាលបណ្ដឹងសាទុក្ខ)[77] និងជាការខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់ពេញលេញរបស់ជនជាប់ចោទក៏ដោយ ក៏ពុំអាចនិយាយបានថា សាក្សីទាំងពីររូបនេះ"ពុំអាចរកបាននៅពេលសវនាការ"ដូចមានចែងក្នុងមាត្រា ១០៨(៧) នៃវិធានផ្ទៃក្នុងដែលចែងដោយស្របទៅនឹងតួនាទីរបស់អង្គជំនុំជម្រះតុលាការកំពូលថា មានតែ"អង្គហេតុថ្មីដែលទើបរកឃើញ" ឬ"មធ្យោបាយថ្មីដែលជាភស្តុតាង"ប៉ុណ្ណោះ ទើបអាចទទួលយកបាននៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ អាស្រ័យហេតុនេះ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងពុំអាចអនុវត្តបានចំពោះសំណើសុំកោះហៅសាក្សី ហេង សំរិន និង អ៊ុក ប៊ុនឈឿន ឡើយ។

៣៧.ទាក់ទងទៅនឹងបញ្ហា ថាតើអង្គជំនុំជម្រះតុលាការកំពូលគប្បីប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន និងគប្បីកោះហៅសាក្សី ហេង សំរិន និង អ៊ុក ប៊ុនឈឿន ស្របតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន នួន ជា បានលើកទឡ្ហីករណ៍មួយចំនួនដោយផ្អែកលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានកំហុសដោយសារពុំបានកោះហៅបុគ្គលទាំងពីរនេះ។ នួន ជា បានអះអាងជាពិសេសថា ការសម្រេចមិនកោះហៅ ហេង សំរិន គឺជាកង្វះនូវឯករាជភាពរបស់ចៅក្រមជាតិនៃអង្គជំនុំជម្រះសាលដំបូង[78]ថា ចៅក្រមជាតិនៃអង្គជំនុំជម្រះនេះមានកំហុសដោយពុំបានចេញសេចក្ដីសម្រេចលើការទាមទាររបស់គាត់ស្ដីពីភាពត្រឹមត្រូវនៃការជំនុំជម្រះ ទាក់ទងទៅនឹងការសម្រេចមិនកោះហៅ ហេង សំរិន[79]ថា សិទ្ធិរបស់គាត់ក្នុងការបង្ហាញភស្តុតាងដើម្បីការពារខ្លួន ត្រូវបានរំលោភបំពានដោយសារការសម្រេចមិនកោះហៅ ហេង សំរិន[80]ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារពុំបានកោះហៅ អ៊ុក ប៊ុនឈឿន មកធ្វើសាក្សី[81]ថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដល់សំអាង

---

[76] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៨៧ ដល់ ១១១ (ក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ពុំអាចស្វែងរកមតិភាគច្រើនលើសលុបដែលត្រូវការសម្លេងចៅក្រមបួនរូបទាក់ទងទៅនឹងបញ្ហា ថាតើ ហេង សំរិន គប្បីត្រូវកោះហៅមកផ្ដល់សក្ខីកម្ម ដែរ ឬយ៉ាងណា ហើយអង្គជំនុំជម្រះបានផ្ដល់សំអាងហេតុពីរដាច់ដោយឡែកពីគ្នាលើបញ្ហានេះ)។

[77] *សូមមើលខាងក្រោម* កថាខណ្ឌ ១៣៣។

[78] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨ ដល់ ៦៩។

[79] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧០ ដល់ ៧៣។

[80] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៥។ *សូមមើលផងដែរ* កថាខណ្ឌ ២៩៩ និង ៥៦៩ ដល់ ៥៧០ និង ៦១០។

[81] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨២។ *សូមមើលផងដែរ* កថាខណ្ឌ ៥៧១។

ហេតុពេញលេញ ពីព្រោះអង្គជំនុំជម្រះពុំបានពិភាក្សាលើសារណារបស់មេធាវីការពារក្តីទាក់ទងទៅនឹងចម្លើយក្រៅតុលាការរបស់បុគ្គលពីររូបនេះដែលពាក់ព័ន្ធទៅនឹងគោលនយោបាយប្រឆាំងនឹងទាហាននៃរបបសាធារណរដ្ឋខ្មែរ[82]ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបដិសេធមិនស្តាប់សាក្សីសំខាន់បំផុតទាក់ទងទៅនឹងទំនាក់ទំនងរវាងថ្នាក់ដឹកនាំរបស់ ប.ក.ក. ជាមួយនឹងកម្មាភិបាលដែលមានអំណាច[83] និងថា ដោយសារការសម្រេចមិនកោះហៅ ហេង សំរិន ផ្អែកនៅក្នុងសាលក្រមដែលដោះស្រាយលើការចេញបញ្ជាក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងបានផ្អែកលើសក្ខីកម្មរបស់សាក្សីតែម្នាក់គត់[84]។

៣៨.ក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើបញ្ហា ថាតើប្រយោជន៍យុត្តិធម៌ដ៏ប្រសើរបំផុតមានអត្ថិភាព ដែរ ឬយ៉ាងណា ក្នុងការកែតម្រូវកំហុសដែលបានចោទប្រកាន់ តាមរយៈការកោះហៅសាក្សីដែលបានស្នើឡើងនោះ ដោយផ្អែកលើការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដែលអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។ ការធ្វើបែបនេះជាការផ្ទុយទៅនឹងគោលការណ៍ដែលកំណត់ថា ភស្តុតាងគប្បីត្រូវបានស្តាប់ដោយអង្គជំនុំជម្រះសាលាដំបូង ពុំមែនស្តាប់ដោយអង្គជំនុំជម្រះតុលាការកំពូលនោះទេ ពីព្រោះការធ្វើបែបនេះទំនងជាអាចពន្យារពេលដល់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ[85]។ ជាជម្រើស អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយទឡ្ហីករណ៍ពាក់ព័ន្ធនៃបណ្តឹងសាទុក្ខរបស់ នួន ជា និងធ្វើសេចក្តីសន្និដ្ឋានណាក៏ដោយឱ្យបានជាប្រយោជន៍ដល់ជនជាប់ចោទ ដែលនេះអាចចាត់ទុកថា ជាការចាំបាច់ និងសមស្រប[86]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា វិធីសាស្ត្រចុងក្រោយនេះមានលក្ខណៈសមស្របបំផុតក្នុងកាលៈទេសៈនេះ និងថា កិច្ចដំណើរការនីតិវិធីតាមរបៀបនេះនឹងពុំបានប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទណាមួយឡើយ និងជួយរួមចំណែកក្នុងការជំរុញប្រសិទ្ធិភាពនៅក្នុងកិច្ចដំណើរការនីតិវិធី។

---

[82] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១១។

[83] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤២។ *សូមមើលផងដែរ* កថាខណ្ឌ ៦២១។

[84] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១០។

[85] *សូមមើលខាងលើ* កថាខណ្ឌ ២៣។ *សូមមើលខាងក្រោម* កថាខណ្ឌ ៨៩។

[86] សាលដីកា*រឿងក្តី Limaj* (ICTY) កថាខណ្ឌ ២១។ សាលដីកា*រឿងក្តី Naletilić* (ICTY) កថាខណ្ឌ ១២០។ សាលក្រម*រឿងក្តី Čelebići* (ICTY) កថាខណ្ឌ ៦០១។ សាលក្រម*រឿងក្តី Akayesu* (ICTR) កថាខណ្ឌ ៣១៩។

## ២.ង.សំណើសុំទាក់ទងទៅនឹងសាក្សី ថេត សម្បត្តិ និង Robert LEMKIN

៣៩.ខៀវ សំផន[87]បានគាំទ្រសំណើរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលកោះហៅ ថេត សម្បត្តិ និង Robert LEMKIN មកផ្តល់សក្ខីកម្ម ដោយស្របតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង[88]។ នួន ជា បានរំឭកថា សាក្សីដែលបានស្នើឡើងទាំងពីររូបនេះ គឺជាសហផលិតករនៃឯកសារភាពយន្ត*សត្រូវរបស់ប្រជាជន និងមួយថ្ងៃនៅទួលពោធិ៍ជ្រៃ* ដែលត្រូវបានយកមកសំអាងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[89]។ ផ្អែកតាម នួន ជា បានឱ្យដឹងថា ឈុតខ្សែវីដេអូដែលពុំទាន់ផ្សព្វផ្សាយនៅក្នុងដៃរបស់អ្នកទាំងពីរដែលមាន"កិច្ចសម្ភាសន៍ជាមួយសាក្សីដែលនិយាយដោយស្ទាក់ស្ទើរជាមួយ[សហចៅក្រមស៊ើបអង្កេត]" អាចនឹងចោទជាមន្ទិលសង្ស័យដល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បក្សកុម្មុយនីស្តកម្ពុជា(ប.ក.ក.)មានឋានានុក្រមតឹងរ៉ឹង និង រួបរួមគ្នា និងលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា (ជាពិសេស ការសម្លាប់នៅទួលពោធិ៍ជ្រៃ) ដោយបានបង្ហាញថា ឧក្រិដ្ឋកម្មដែលចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១ ត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលខ្មែរក្រហម ដែល"បានអនុវត្តផ្ទុយពីគោលនយោបាយរបស់បក្សចាប់តាំងពីពេលដំបូងនៃកម្ពុជាប្រជាធិបតេយ្យមក"[90]។

៤០.សហព្រះរាជអាជ្ញាបានជំទាស់ថា សម្ភារដែលជាប្រភពដើមនៅក្នុងដៃ ថេត សម្បត្តិ និង Robert LEMKIN អាចជាជំនួយច្រើនជាងសក្ខីកម្មរបស់ពួកគាត់ និងបានជំទាស់ទៅនឹងភាពអាចជឿទុកចិត្តបាន ការយល់ដឹង ជំនាញ ឆន្ទៈរបស់ពួកគាត់ក្នុងការសហការជាមួយ អ.វ.ត.ក. និងការកំណត់ចរិតលក្ខណៈនៃសក្ខីកម្ម

---

[87] មតិគាំទ្ររបស់មេធាវីការពារក្តីលោក ខៀវ សំផន ចំពោះសំណើពីរដំបូងរបស់មេធាវីការពារក្តីលោក នួន ជា សុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងទៅនឹងបណ្តឹងសាទុក្ខ (F2/1/1)។

[88] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣, ២៤២, ៧៣០(ក)។ សំណើទីមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2) កថាខណ្ឌ ១៨(ខ)។ *សូមមើលផងដែរ* សារណារបស់ នួន ជា ស្តីពីកំណត់ហេតុរបស់ LEMKIN និង ថេត សម្បត្តិ (F2/4/3/3/1) កថាខណ្ឌ ៩។ សេចក្តីសង្កេតរបស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការបង្គាប់ឱ្យស្វែងរកព័ត៌មានបន្ថែម (F2/4/3/3/2) កថាខណ្ឌ ៧ និង ១៣។

[89] សំណើទីមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2) កថាខណ្ឌ ១ និង ១៤ ដល់ ១៥។

[90] សំណើទីមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2) កថាខណ្ឌ ១៤។ សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧, ៨៣ និង ២៤២។

ដែលរំពឹងចង់បាននោះ[91]។ ជាការឆ្លើយតប នួន ជា បានជំទាស់ទៅនឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញា ប៉ុន្តែបានយល់ស្របថា ជម្រើសដ៏ប្រសើរ គឺគប្បីស្វែងរក និងទទួលយកឈុតខ្សែវីដេអូនោះ[92]។

## ២.ង.១.ភាពជាប់ពាក់ព័ន្ធនៃការបែកបាក់នៅក្នុង ប.ក.ក. ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ នួន ជា

៤១.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា គោលបំណងចម្បងនៅក្នុងសំណើរបស់ នួន ជា គឺដើម្បីទទួលបានឈុតខ្សែវីដេអូដែលគេជឿថាមាននៅក្នុងដៃរបស់សហផលិតករនេះ[93]។ អាស្រ័យហេតុនេះ បន្ទាប់ពីមានការអះអាងថា ឈុតខ្សែវីដេអូនេះអាចរកបាន និងជាប់ពាក់ព័ន្ធនោះ មានសកម្មភាពជាបន្តបន្ទាប់ជាច្រើន ត្រូវបានធ្វើឡើងដើម្បីវាយតម្លៃ ថាតើឈុតខ្សែវីដេអូនេះអាចទទួលបានភ្លាមៗ និង*តាមសេចក្តីបញ្ជាក់ដំបូង* ជាប់ពាក់ព័ន្ធ ដែរ ឬយ៉ាងណា[94]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលបានទទួលកំណត់ហេតុ និងប្រតិចារិករបស់ LEMKIN។ បន្ទាប់ពីបានពិនិត្យលើសម្ភារនេះរួចមក អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សម្ភារនេះមានផ្នែកជាច្រើនជាប់ពាក់ព័ន្ធទៅនឹងការបែកបាក់នៅក្នុង ប.ក.ក. និងសកម្មភាពផ្តួលរំលំ ប៉ុល ពត និងការដឹកនាំរបស់ នួន ជា[95]។ ដោយពិចារណាឃើញថា នួន ជា ពុំបានបញ្ជាក់ច្បាស់លាស់អំពីសារៈសំខាន់នៃកាលៈទេសៈទាំងនោះទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះបទឧក្រិដ្ឋដែល នួន ជា

---

[91] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរសុំដាក់ភស្តុតាងបន្ថែម (F2/2) កថាខណ្ឌ ៩, ១០ ដល់ ១៦។

[92] ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/3) កថាខណ្ឌ ៣ និង ៥។

[93] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧ ("មេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលកោះហៅ ថេត សម្បត្តិ និង […] Rob LEMKIN ដើម្បីបញ្ជាក់នូវចរិតលក្ខណៈនៃភស្តុតាងដែលមាននៅក្នុងដៃរបស់ពួកគាត់")។ ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/3) កថាខណ្ឌ ៣ ("មេធាវីការពារក្តីយល់ស្របទាំងស្រុងជាមួយនឹងសហព្រះរាជអាជ្ញាថា ការទទួលយកឈុតខ្សែវីដេអូ គឺជាការល្អប្រសើរបំផុត")។ *សូមមើលផងដែរ* សារណាតបរបស់ នួន ជា ស្តីពីកំណត់ហេតុរបស់ LEMKIN និង ថេត សម្បត្តិ (F2/4/3/3/1) កថាខណ្ឌ ៩។

[94] សេចក្តីសម្រេចបណ្តោះអាសន្នលើកទីមួយស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3) កថាខណ្ឌ ២៤ ដល់ ២៦។ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី Lemkin ឯកសារលេខ F2/4/3/1។ សេចក្តីសម្រេចបណ្តោះអាសន្នលើកទីពីរស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3/3)។ សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបីស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3/3/5)។

[95] សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបួនស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3/3/6) ទំព័រ ៣។

ត្រូវបានសម្រេចដាក់ពិរុទ្ធនោះ អង្គជំនុំជម្រះបានផ្ដល់ឱកាសបន្ថែមទៀតឱ្យគាត់លើកសារណាលើចំណុចនេះ[96]។

៤២.ទាក់ទងទៅនឹងការទទួលខុសត្រូវដែលផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម នួន ជា បានអះអាងជាដំបូងថា បើទោះបីជាគាត់បានរួមចំណែកនៅក្នុងការរៀបចំគោលនយោបាយរបស់ ប.ក.ក. ក៏ដោយ ក៏គោលនយោបាយនេះពុំបានគិតទុកជាមុននូវឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តឡើងដោយ“កម្មាភិបាលមិនល្អ”ដែលស្ថិតនៅក្រោមឥទ្ធិពលនៃមហាអំណាចបរទេស និងបានងាកចេញពីមាគ៌ាបក្ស[97]។ អាស្រ័យហេតុនេះ លទ្ធភាពនិងឆន្ទៈរបស់កម្មាភិបាលទាំងនោះក្នុងការអនុវត្តដោយឯករាជ្យពីសេចក្ដីណែនាំរបស់មជ្ឈិមបក្ស មានការជាប់ពាក់ព័ន្ធ ដែលទាំងអស់នេះ ទាក់ទងទៅនឹងការយល់ឃើញស្ដីពីគោលនយោបាយរបស់ ប.ក.ក. ដែលអង្គជំនុំជម្រះសាលាដំបូងបានទាញយកហេតុផលយ៉ាងច្រើនចេញពី“លំនាំនៃការប្រព្រឹត្ត នៅក្នុងចំណោមកម្មាភិបាលថ្នាក់ក្រោម”[98]។ ទីពីរ នួន ជា បានអះអាងថា រចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក. ត្រូវបានគេយល់ដឹងយ៉ាងទូលំទូលាយថា ជាបញ្ហាសំខាន់បំផុត និងជា “មូលដ្ឋាន”សម្រាប់ការជំនុំជម្រះនាពេលអនាគត[99]។ ទាក់ទងទៅនឹងបញ្ហានេះ នួន ជា បានអះអាងថា ភស្តុតាងបន្ថែមដែលគាត់បានផ្ដល់នោះ បានធ្វើឱ្យការគ្រប់គ្រងដោយមានប្រសិទ្ធភាពដោយមជ្ឈិមបក្សទៅលើថ្នាក់ក្រោម មានមន្ទិលសង្ស័យថា ការបែកបាក់ដែលមានផែនការក្បត់ប្រឆាំងនឹងថ្នាក់ដឹកនាំបក្ស មានអត្ថិភាពតាំងពីដើមខែឧសភា ឆ្នាំ ១៩៧៥ មក[100]។ ទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវដទៃទៀត នួន ជា បានរំឭកថា ដោយសារការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ បានផ្អែកលើសិទ្ធិអំណាច*តាមព្រឹត្តិហេតុ* ឬការគ្រប់គ្រងដោយមានប្រសិទ្ធភាពលើកម្មាភិបាលខ្មែរក្រហម ទើបបានបង្ហាញឱ្យឃើញថា ភាពជាប់ពាក់ព័ន្ធនៃការបែកបាក់ផ្ទៃក្នុងនៅក្នុង ប.ក.ក. “មានលក្ខណៈច្បាស់លាស់”[101]។

---

[96] សេចក្ដីសម្រេចបណ្ដោះអាសន្នលើកទីបួនស្ដីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3/3/6) ទំព័រ ៣ ដល់ ៤។

[97] សារណារបស់ នួន ជា ស្ដីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ១៩ ដល់ ២០។

[98] សារណារបស់ នួន ជា ស្ដីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ២២។ *សូមមើលផងដែរ* ២១, ២៤ និង ៦១។

[99] សារណារបស់ នួន ជា ស្ដីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ២៧ ដល់ ២៩ និង ៤៧ ដល់ ៤៩។

[100] សារណារបស់ នួន ជា ស្ដីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៣១ ដល់ ៤៤។

[101] សារណារបស់ នួន ជា ស្ដីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៦៦។

៤៣.សហព្រះរាជអាជ្ញាបានលើកឡើងថា ការអះអាងផ្នែកអង្គហេតុរបស់ នួន ជា ជាញឹកញាប់ពុំត្រូវបានគាំទ្រ ដោយភស្តុតាង ដែលគាត់បានយោងទៅលើ ដោយសារភស្តុតាងនេះពុំអាចជឿទុកចិត្តបាន ឬភាគច្រើនពុំគួរឱ្យជឿជាក់ ឬផ្ទុយទៅនឹងភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង ហើយភស្តុតាងនេះទាំងមូល គ្មានឥទ្ធិពលលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីរចនាសម្ព័ន្ធ និងឋានានុក្រមរបស់ ប.ក.ក. ឡើយ[102]។ ជាសំខាន់បំផុត សហព្រះរាជអាជ្ញាបានអះអាងថា អត្ថិភាពនៃការបែកបាក់ ឬការមិនពេញចិត្តនៅក្នុង ប.ក.ក. "ពុំមែនមានន័យថា ឋានានុក្រមនៃអង្គការបានឈប់ដំណើរការ" ឬថា សមាជិកបក្ស"លែងធ្វើការជាមួយគ្នា ដើម្បីឆ្ពោះទៅកាន់ផែនការប្រព្រឹត្តបទល្មើសរួមនោះឡើយ"[103]។ សហព្រះរាជអាជ្ញាចាត់ទុកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីរចនាសម្ព័ន្ធ ប.ក.ក. ថាមានសារៈសំខាន់ក្នុងការបញ្ជាក់ថា គោលនយោបាយបក្សបានចងកាតព្វកិច្ចដល់សមាជិកបក្ស និងត្រូវបានអនុវត្តពិតប្រាកដមែន ប៉ុន្តែបានអះអាងថា ការលើកឡើងរបស់ នួន ជា អំពីការបែកបាក់ បើទោះបីជាត្រឹមត្រូវទាំងស្រុងក៏ដោយ ក៏ពុំមានឥទ្ធិពលលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ[104]។

៤៤.សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា នួន ជា ពុំបានដោះស្រាយលើសំណួររបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ ដោយសារ នួន ជា ពុំបានបង្ហាញ ថាតើការបែកបាក់ដែលកើតមាននៅក្នុង ប.ក.ក. នោះ មានឥទ្ធិពលលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលជាមូលដ្ឋានក្នុងការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ ដូចម្តេចឡើយ[105]។

៤៥.អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា នៅក្នុងសំណើជាច្រើនរបស់គាត់ដែលស្នើសុំដាក់ភស្តុតាងបន្ថែម នួន ជា បានផ្តោតទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីរចនាសម្ព័ន្ធនៃឋានានុក្រមរបស់ ប.ក.ក. ការគ្រប់គ្រងដោយប្រសិទ្ធភាពទៅលើកម្មាភិបាលថ្នាក់ក្រោម និងលទ្ធភាពរបស់កម្មាភិបាលទាំងនោះ ក្នុងការអនុវត្តដោយឯករាជ្យពីគោលនយោបាយដែលថ្នាក់ដឹកនាំបក្សបានដាក់ចេញ[106]។ ទោះជា

[102] សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1/1) កថាខណ្ឌ ៧ ដល់ ១៨។

[103] សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1/1) កថាខណ្ឌ ២១ ដល់ ២២។

[104] សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1/1) កថាខណ្ឌ ២៣។

[105] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1/2) កថាខណ្ឌ ៣ និង ៧ ដល់ ២០។

[106] *សូមមើលឧ.* សំណើទីមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2) កថាខណ្ឌ ១៤។ សំណើទីបីរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/4) កថាខណ្ឌ ១៨ ដល់ ២០។ សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ១០ ដល់ ១៣។

យ៉ាងណាក្តី ការគ្រប់គ្រងដោយប្រសិទ្ធភាព គឺពុំមែនជាលក្ខខណ្ឌតម្រូវសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមឡើយ។ តាមការកត់សម្គាល់របស់សហព្រះរាជអាជ្ញា[107]ថា ផែនការសម្លាត់ក្នុងការបះបោរ ឬសកម្មភាពជាក់ស្តែងដែលគ្រោងទុកដើម្បីផ្តួលរំលំថ្នាក់ដឹកនាំបក្ស ពុំបានសបញ្ជាក់ឱ្យឃើញជាចាំបាច់ថា ក្នុងពេលនោះ កម្មាភិបាល ប.ក.ក. បានឈប់អនុវត្តសេចក្តីណែនាំពីថ្នាក់លើរបស់ខ្លួនឡើយ។ បើទោះបីជា នួន ជា ជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប្រធានភូមិភាគពុំបានអនុវត្តដោយឯករាជ្យយ៉ាងណាក៏ដោយ[108] ក៏ នួន ជា ពុំបានពន្យល់ ថាតើការសន្និដ្ឋានបែបនេះមានឥទ្ធិពលលើការយល់ឃើញជាក់លាក់ដែលជាមូលដ្ឋានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋជាក់លាក់ និងទម្រង់នៃការទទួលខុសត្រូវ ដូចម្តេចឡើយ។

៤៦.នួន ជា បានអះអាងថា ការទាញយកហេតុផលនៃគោលនយោបាយចេញពីលំនាំនៃការប្រព្រឹត្ត គឺជាការជជែកវែកញែកដោយពុំត្រឹមត្រូវ ដោយសារលំនាំដែលបានលើកឡើងនោះ រួមបញ្ចូលនូវសកម្មភាពរបស់កម្មាភិបាលថ្នាក់ក្រោមដែលប្រឆាំងនឹងមាគ៌ាបក្ស[109]។ ទោះជាយ៉ាងណាក្តី ពុំមានការបង្ហាញថា ភស្តុតាងដែលបានស្នើឡើងនោះអាចធ្វើឱ្យការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ពុំសមហេតុផលនោះឡើយ នៅពេលដែលការយល់ឃើញនេះបានផ្អែកទៅលើលំនាំនៃព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរយៈពេលមួយយ៉ាងយូរ និងពាសពេញផ្ទៃប្រទេស។ ជាការពិត នៅក្នុងការគាំទ្រសំណើរបស់ខ្លួន នួន ជា បានយោងទៅលើសារណាដទៃទៀត ដែលជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាពនៃលំនាំ (ដែលត្រូវបានចោទប្រកាន់ថា បានផ្អែកលើភស្តុតាងពុំគ្រប់គ្រាន់)[110] ប៉ុន្តែពុំបានយោងទៅលើភស្តុតាងណាមួយដែលបង្ហាញថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើលំនាំនោះ គឺជាការពិចារណា“ពុំសមហេតុផល”ឡើយ។

---

សារណាតបរបស់ នួន ជា ស្តីពីកំណត់ហេតុរបស់ LEMKIN (F2/4/3/3/1) កថាខណ្ឌ ៣។ សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៣១ ដល់ ៣៦។

[107] សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1/1) កថាខណ្ឌ ២១ ដល់ ២២។

[108] សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៣៣។

[109] សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ២២។

[110] *សូមមើល* សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) ជើងទំព័រ ៦៦ យោងទៅលើកថាខណ្ឌ ៥៣ ដល់ ៦០។

៤៧.អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការដែលថា តើរចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក. ត្រូវបានចាត់ទុកជាបញ្ហាគន្លឹះនៅពេលជំនុំជម្រះដែរ ឬយ៉ាងណានោះ ជាការពុំជាប់ពាក់ព័ន្ធ លើកលែងតែសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីអង្គហេតុដែលពាក់ព័ន្ធ បានផ្តល់មូលដ្ឋានគាំទ្រដល់ធាតុផ្សំបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញមានអង្គសេចក្តីខ្លះនៅក្នុងការអះអាងរបស់ នួន ជា ដែលថា ឧក្រិដ្ឋកម្មពុំអាចដាក់ឱ្យសមាជិកនៃសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវបានឡើយ ដោយសារ ឧក្រិដ្ឋកម្មនេះ ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងផែនការរួម មានន័យថា នៅពេលដែលឧក្រិដ្ឋកម្មនេះពុំមែនជាផ្នែកមួយ ឬពុំត្រូវបានប្រព្រឹត្តឡើងក្នុងការជំរុញផែនការនោះ។ ទោះជាយ៉ាងណាក្តី អត្ថិភាពនៃការបែកបាក់គ្នានៅក្នុង ប.ក.ក. និងសកម្មភាពដើម្បីផ្តួលរំលំថ្នាក់ដឹកនាំ ពុំត្រូវបានចាត់ទុកថា ជាភស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថា បទឧក្រិដ្ឋពុំមាននៅក្នុងគោលបំណងល្មើសរួម ឬត្រូវបានប្រព្រឹត្តឡើងក្នុងការជំរុញគោលបំណងបទល្មើសរួមនោះឡើយ។

៤៨.សរុបសេចក្តីមក ផ្ទុយទៅនឹងការលើកឡើងរបស់ នួន ជា អង្គជំនុំជម្រះតុលាការកំពូលពុំបានចាត់ទុករចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក. ថា ជា"ធាតុផ្សំចាំបាច់"នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើបទឧក្រិដ្ឋណាមួយដែល នួន ជា ត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមឡើយ[111]។ មូលដ្ឋានចម្បងសម្រាប់ការដាក់ឱ្យ នួន ជា ទទួលខុសត្រូវនោះ គឺថា យ៉ាងហោចណាស់មានសមាជិកនៃសហឧក្រិដ្ឋកម្មរួមណាម្នាក់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ដែលនេះបានបណ្តាលឱ្យមានការដាក់សមាជិកទាំងអស់ឱ្យទទួលខុសត្រូវ រួមទាំង នួន ជា ផងដែរ[112]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា តួនាទីរបស់គាត់ក្នុងរដ្ឋអំណាច គឺមាន"ការភ្ជាប់ទំនាក់ទំនងគ្រប់គ្រាន់" រវាងឧក្រិដ្ឋកម្មរបស់ចារីផ្ទាល់ ជាមួយនឹង នួន ជា[113]ក៏ដោយ ក៏នេះគ្រាន់តែជាធាតុផ្សំពុំចាំបាច់មួយបន្ថែមក្នុងការដាក់ឱ្យ នួន ជា ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលស្ថិតក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះ។

៤៩.ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវចំពោះការបញ្ជា ការញុះញង់ អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញថា សារណារបស់ នួន ជា ទាក់ទងទៅនឹងឥទ្ធិពលនៃការបែកបាក់នោះ មានលក្ខណៈសង្ខេបខ្លី និងមាន

---

[111] សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៤៨។

[112] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ៨៦២។

[113] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ៨៦២។

ផ្អែកខ្លះជាន់គ្នាជាមួយនឹងការលើកឡើងដែលទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម[114]។ យោងតាមហេតុផលដែលបានពន្យល់ខាងលើ និងផ្ទុយពីការអះអាងរបស់ នួន ជា[115] "អត្ថិភាពនៃការបែកបាក់នៅក្នុង ប.ក.ក." ពុំបានផ្ទុយទៅនឹងតួនាទីរបស់គាត់ក្នុងរដ្ឋអំណាចទៅលើកម្មាភិបាលថ្នាក់ក្រោមរបស់បក្ស និងពុំចោទជាមន្ទិលសង្ស័យដែលថា កម្មាភិបាលទាំងនេះត្រូវទទួលយកសេចក្តីណែនាំពីរូបគាត់ ឬគោលនយោបាយរបស់ ប.ក.ក. ឡើយ។ ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ នួន ជា ដែលជាថ្នាក់លើ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា ដោយសារពុំមានការសម្រេចដាក់ពិរុទ្ធភាពណាមួយត្រូវបានធ្វើឡើងក្រោមទម្រង់នៃការទទួលខុសត្រូវនេះ ការជំទាស់ទៅនឹងការសម្រេចនេះពុំបានធ្វើឱ្យសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

## ២.ង.២.ភាពអាចទទួលយកបានចំពោះភស្តុតាងបន្ថែម

៥០.ផ្នែកនេះជាការរៀបរាប់អំពីវិធីសាស្ត្រ ដែលអង្គជំនុំជម្រះតុលាការកំពូលអនុវត្តគោលការណ៍ដែលបានលើកឡើងខាងលើចំពោះសំណើជាក់លាក់នានា ដែលបានស្នើសុំដាក់ភស្តុតាងបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះ។ ដោយសារការកោះហៅ ថេត សម្បត្តិ និង Robert LEMKIN ជាចម្បងត្រូវបានស្នើឡើងដើម្បីបំភ្លឺលើកិច្ចសម្ភាសន៍ដែលអ្នកទាំងពីរបានធ្វើឡើង និងដោយពិចារណាឃើញថា អង្គជំនុំជម្រះតុលាការកំពូលបានទទួលសម្ភារផ្ទាល់ និងមិនផ្ទាល់ ដូចជា ប្រតិចារិក LEMKIN និងកំណត់ហេតុ LEMKIN ទាក់ទងទៅនឹងកិច្ចសម្ភាសន៍ដែល ផ្អែកតាម Robert LEMKIN គឺជាការបង្ហាញនូវទស្សនៈនយោបាយរបស់ រស់ ញឹម(ញឹម រស់) និងការប៉ុនប៉ងផ្តួលរំលំ ប៉ុល ពត និងការដឹកនាំរបស់ នួន ជា នៅក្នុង ប.ក.ក.[116]នោះ ការពិចារណាអំពីភាពអាចទទួលយកបានទាក់ទងទៅនឹងសាក្សីដែលបានស្នើឡើងទាំងពីរនេះ ត្រូវបានធ្វើឡើងរួចរាល់ហើយ រួមគ្នាជាមួយនឹងការពិចារណាពាក់ព័ន្ធទៅនឹងសម្ភារដើម។

៥១.នួន ជា បានលើកឡើងថា កំណត់ហេតុ LEMKIN និង ប្រតិចារឹក LEMKIN គប្បីត្រូវបានទទួលយកជាភស្តុតាង ដោយសារមានការជាប់ពាក់ព័ន្ធ អាចជឿទុកចិត្តបាន និងជាភស្តុតាង"គន្លឹះដោះបន្ទុក"ដែលអាចបង្ហាញថា ប.ក.ក. មានការបែកបាក់ និងថា រស់ ញឹម(ញឹម រស់) បានអនុវត្តដោយឯករាជ្យពីមជ្ឈិមបក្សតាំង

---

[114] សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៦៦។

[115] សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៦៦។

[116] កំណត់ហេតុស្តាប់ចម្លើយរបស់ LEMKIN (F2/4/3/1) កថាខណ្ឌ ក៣៤។

ពីដើមដំបូងនៃយុត្តាធិការពេលវេលា[117]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការទទួលយកភស្តុតាងដែលបានស្នើឡើងនេះទាក់ទងទៅនឹងភាពអាចជឿទុកចិត្តបាន តម្លៃជាភស្តុតាង និងកត្តាកំណត់នៃភស្តុតាងនេះ[118]។ សហព្រះរាជអាជ្ញាបានលើកឡើង*ក្នុងចំណោមនោះ*ថា ជំនាញរបស់ Robert LEMKIN ពុំអាចប្រដូចបានទៅនឹងជំនាញរបស់បុគ្គលដែលអង្គជំនុំជម្រះសាលាដំបូងបានស្តាប់មានដូចជា Philip SHORT François PONCHAUD និង Stephen HEDER និងថា ថេត សម្បត្តិ មានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹង នួន ជា និងថា វិធីសាស្ត្រក្នុងការយកបទសម្ភាសន៍របស់ពួកគាត់ គួរឱ្យសង្ស័យ[119]។ ជាការឆ្លើយតប នួន ជា បានជំទាស់ថា ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ពោរពេញទៅដោយ“ការបំភ្លៃ បំភ័ន្ត ការនិយាយខុសពីការពិត”[120]។

៩២.អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញថា អំណះអំណាងមួយចំនួនរបស់សហព្រះរាជអាជ្ញាដែលពុំបានផ្តល់តម្លៃជាភស្តុតាងនូវសម្ភារដែលបានស្នើឡើងនោះ ជាការលើកឡើងផ្ទុយ ពុំសមស្រប ឬជាក់លាក់ឡើយ។ ជាឧទាហរណ៍ នួន ជា បានស្នើសុំកោះហៅ Robert LEMKIN ក្នុងនាមជាសាក្សី ពុំមែនជាអ្នកជំនាញ និងដើម្បីផ្តល់សក្ខីកម្មទាក់ទងទៅនឹងខ្លឹមសារនៃកិច្ចសម្ភាសន៍ដែលគាត់បានធ្វើជាមួយ ថេត សម្បត្តិ ពុំមែនលើអ្វីដែលពាក់ព័ន្ធទៅនឹងចំណេះដឹងរបស់គាត់អំពីប្រវត្តិរបស់ខ្មែរក្រហមឡើយ ប៉ុន្តែលើលក្ខណៈសម្បត្តិរបស់គាត់ក្នុងវិជ្ជាជីវៈសារព័ត៌មានផ្នែកស៊ើបសួរទៅវិញ។ បន្ថែមលើនេះទៀត អំណះអំណាងខ្លះរបស់សហព្រះរាជអាជ្ញាដែលបានផ្អែកទៅលើក្នុងគោលបំណងកាត់បន្ថយភាពសំខាន់នៃការជាប់ពាក់ព័ន្ធរបស់ Robert LEMKIN ក្នុងកិច្ចការផ្ទាល់ជាមួយនឹង ថេត សម្បត្តិ និងភាពសំខាន់នៃតម្លៃជាភស្តុតាងចំពោះកំណត់ហេតុរបស់ LEMKIN នោះ គឺជាការលើកឡើងដោយប៉ាន់ស្មាន[121]។ ស្ទើរតែពុំគួរឱ្យជឿផងដែរថា សហព្រះរាជអាជ្ញាបានជំទាស់ទៅ

---

[117] សារណាតបរបស់ នួន ជា ស្តីពីកំណត់ហេតុរបស់ LEMKIN និង ថេត សម្បត្តិ (F2/4/3/3/1) កថាខណ្ឌ ៣ ដល់ ៧។ សារណារបស់ នួន ជា ស្តីពីការជម្លោះរបស់ ប.ក.ក (F2/4/3/3/6/1) កថាខណ្ឌ ៥ ដល់ ៩។

[118] សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីកំណត់ហេតុរបស់ LEMKIN (F2/4/3/3/3) កថាខណ្ឌ ៩ ដល់ ២៩ និង ៤១។ សារណារបស់សហព្រះរាជអាជ្ញាស្តីពីប្រតិចារឹករបស់ LEMKIN (F2/4/3/3/6/3) កថាខណ្ឌ ១៣ ដល់ ៤០។

[119] សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីកំណត់ហេតុរបស់ LEMKIN (F2/4/3/3/3) កថាខណ្ឌ ៩ ដល់ ១៨។

[120] ការឆ្លើយតបរបស់ នួន ជា ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីកំណត់ហេតុរបស់ LEMKIN (F2/4/3/3/4) កថាខណ្ឌ ៣២។

[121] *ប្រៀបធៀប* សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/2) កថាខណ្ឌ ១៦ *ជាមួយនឹង* កំណត់ហេតុស្តាប់ចម្លើយរបស់ LEMKIN (F2/4/3/1) កថាខណ្ឌ ក១៤, ក១៦ ដល់ ក១៨, ក២១ ដល់ ក២៣។ *សូមមើលផងដែរ* សេចក្តី

នឹងភាពអាចជឿទុកចិត្តបាននៃសម្ភារដែលបានផ្តល់ដោយ Robert LEMKIN ផ្អែកលើកង្វះចំណេះដឹងភាសាខ្មែរ និងកង្វះព័ត៌មានអំពីអត្តសញ្ញាណ ជីវប្រវត្តិ និងការជំរុញទឹកចិត្តជាសក្តានុពលឱ្យនិយាយកុហករបស់អ្នកដែលត្រូវបានសម្ភាសន៍[122] ដោយហេតុថា សហព្រះរាជអាជ្ញាបានអះអាងម្តងហើយម្តងទៀតថា អង្គជំនុំជម្រះតុលាការកំពូល គប្បីទទួលយកការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការរៀបរាប់របស់ជនភៀសខ្លួនអនាមិក សាក្សីជំនាញដែលពុំមានចំណេះដឹងភាសាខ្មែរ និងភស្តុតាងចចាមអារ៉ាមអនាមិក[123]។

៩៣.ទោះជាយ៉ាងណាក្តី ដោយសារពុំមានការបង្ហាញថា សម្ភារនេះជាប់ពាក់ព័ន្ធ ឬជាកត្តាកំណត់ឈានដល់ការសម្រេចដាក់ពិរុទ្ធភាព ទើបអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធលើសំណើរបស់ នួន ជា ដែលស្នើសុំឱ្យទទួលយកប្រតិចារឹក LEMKIN និងកំណត់ហេតុ LEMKIN ធ្វើជាភស្តុតាង។ ជាដំបូង ភាគច្រើននៃសកម្មភាពក្បត់ដែលបានយោងទៅលើនោះ គឺបានកើតឡើងនៅក្រោយពេលការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងក្រោយការសម្លាប់នៅទួលពោធិ៍ជ្រៃ[124]។ បើទោះបីជាបានដាក់សារណាមួយចំនួនទាក់ទងចំណុចនេះក៏ដោយ ក៏ នួន ជា ពុំបានបង្ហាញជាសំខាន់ថា សកម្មភាពទាំងនេះដូចជា ការបង្វែរស្បៀងអាហារ ប្រេងឥន្ធនៈ និងអាវុធ ការក្បត់ផ្ទៃក្នុង ការរៀបចំការបះបោរយោធា អាចធ្វើឱ្យការយល់ឃើញរបស់អង្គជំនុំជម្រះពុំមានមូលដ្ឋានរឹងមាំសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ឡើយ[125]។ ជាការកត់សម្គាល់ នួន ជា ពុំបានបង្ហាញថា សកម្មភាពទាំងនេះអាចនាំទៅរកការធ្វើសេចក្តីសន្និដ្ឋានមួយដែលថា បទឧក្រិដ្ឋដែល

---

សម្រេចស្នើឱ្យដាក់សារណា (F2/4/3/3/6) ទំព័រ ៤ ការពិពណ៌នាលើកទីបី។ សេចក្តីសម្រេចបណ្តោះអាសន្នលើកទីមួយស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3) កថាខណ្ឌ ២៥។

[122] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/2) កថាខណ្ឌ ១៦។ សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1/1) កថាខណ្ឌ ១១។ សារណាតបរបស់សហព្រះរាជអាជ្ញាស្តីពីកំណត់ហេតុរបស់ LEMKIN (F2/4/3/3/3) កថាខណ្ឌ ១៥។

[123] *សូមមើល ឧ.* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦២ ជើងទំព័រ ៦០២ (ការរៀបរាប់អនាមិករបស់ជនភៀសខ្លួន) កថាខណ្ឌ ១៧៤ ជើងទំព័រ ៦៧២ (ការរៀបរាប់អនាមិករបស់ជនភៀសខ្លួន) កថាខណ្ឌ ២៧៤ ជើងទំព័រ ១១២១ (Philip SHORT) កថាខណ្ឌ ៣៤៤ ជើងទំព័រ ១៤១៧ (Philip SHORT) កថាខណ្ឌ ៣៦១ ជើងទំព័រ ១៤៩៣ (Philip SHORT និងការរៀបរាប់អនាមិករបស់ជនភៀសខ្លួន)។

[124] ប្រតិចារឹករបស់ LEMKIN (F2/4/3/3/6.2) ទំព័រ (ភាសាអង់គ្លេស) ១៣, ៣៣, ១១០ និង ១១២។

[125] សារណាតបរបស់ នួន ជា ស្តីពីកំណត់ហេតុរបស់ LEMKIN និង ថេត សម្បត្តិ (F2/4/3/3/1) កថាខណ្ឌ ៦។ សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ៦(ខ-គ-ង)។

គាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពនោះស្ថិតនៅក្រៅវិសាលភាពនៃផែនការរួម ឬពុំត្រូវបានប្រព្រឹត្តឡើងដើម្បីជំរុញផែនការនេះឡើយ។

៥៤.ទាក់ទងទៅនឹង"កិច្ចប្រជុំសម្ងាត់"ដែលបានដឹកនាំដោយ សោ ភឹម និង រស់ ញឹម(ញឹម រស់) ប្រហែលជាក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ក្នុងទីក្រុងភ្នំពេញ[126] អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា នួន ជា បានព្យាយាមបង្ហាញការប្រជុំនេះដោយផ្អែកលើកំណត់ហេតុរបស់ LEMKIN ដែលជាប្រភពមិនផ្ទាល់ និងពុំបានយោងទៅលើផ្នែកណាមួយនៃបទសម្ភាសន៍ជាមូលដ្ឋាននោះឡើយ។ ដូច្នេះ នួន ជា ពុំបានផ្តល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់ការអះអាងរបស់ខ្លួន។ បន្ថែមលើនេះទៀត បើទោះបីជាសាក្សី ទាត់ ធឿន បានផ្តល់សក្ខីកម្មថា កិច្ចប្រជុំមួយដែល រស់ ញឹម(ញឹម រស់) និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀតរបស់ ប.ក.ក. បានចូលរួមនោះប្រហែលជាបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៥ ក៏ដោយ ក៏គាត់បានអះអាងថា ពុំមានផែនការបះបោរប្រឆាំងនឹង ប៉ុល ពត ត្រូវបានពិភាក្សាក្នុងអំឡុងពេលនោះឡើយ លើកលែងតែសំណើឱ្យកែប្រែគោលនយោបាយមួយចំនួនរបស់ ប.ក.ក. ប៉ុណ្ណោះ[127]។ ដូច្នេះ បើទោះបីជាមានការបង្ហាញថា ការ"ប្រជុំសម្ងាត់"បានធ្វើឡើងក៏ដោយ ក៏ផ្អែកតាមរបៀបវារៈនៃកិច្ចប្រជុំនោះ ពុំមានការបញ្ជាក់ថា ការប្រជុំនេះអាចមានឥទ្ធិពលណាមួយទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា ចំពោះបទឧក្រិដ្ឋណាមួយដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពឡើយ។

៥៥.ផ្អែកតាម នួន ជា ការបង្ហាញសំខាន់មួយផ្សេងទៀតដែលថា សកម្មភាពក្បត់មានដូចជា"ផែនការនៃការបះបោរ*ប្រដាប់អាវុធ*ប្រឆាំង ប៉ុល ពត" បានកើតឡើងនៅមុនពេលចាប់ផ្តើមនៃយុត្តាធិការពេលវេលានោះ គឺជាសំដីរបស់ ទាត់ ធឿន ដែលថា ក្នុងឆ្នាំ ១៩៧៥ គាត់បានសង់ឃ្លាំងលាក់ទុកអាវុធ[128]។ ប៉ុន្តែ នៅពេលសួរដេញដោលនៅក្នុងតុលាការអំពីកាលៈទេសៈទាំងនោះ ទាត់ ធឿន បានបញ្ជាក់ដដែលៗថា តាមដែលគាត់ដឹង ឃ្លាំងលាក់ទុកអាវុធនៅពេលនោះ ពុំមានជាប់ពាក់ព័ន្ធទៅនឹងផែនការបះបោរណាមួយឡើយ[129]។

---

[126] សារណាតបរបស់ នួន ជា ស្តីពីកំណត់ហេតុរបស់ LEMKIN និង ថេត សម្បត្តិ (F2/4/3/3/1) កថាខណ្ឌ ៦។ សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក (F2/4/3/3/6/1) កថាខណ្ឌ ៦(ក)។

[127] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ២៧ ដល់ ២៩។

[128] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤២ និង ៤៦២។ *សូមមើលផងដែរ* សំណើទីបីសុំដាក់ភស្តុតាងបន្ថែម (F2/4) កថាខណ្ឌ ១៩ និង ២៤។

[129] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ២០ ដល់ ២១, ២៨, ៣៧ ដល់ ៣៨។

៥៦.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កំណត់ហេតុ LEMKIN និងប្រតិចារឹក LEMKIN ពុំបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការទទួលយកភស្តុតាងបន្ថែមនៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ។ អាស្រ័យហេតុនេះ យោងតាមមាត្រា ១០៤(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកតែផ្នែកខ្លះនៃប្រតិចារឹក LEMKIN ទាក់ទងទៅនឹងកិច្ចសម្ភាសន៍ជាមួយ ទាត់ ធឿន ពីព្រោះគាត់បានចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះក្នុងនាមជាសាក្សី ហើយចម្លើយរបស់គាត់ពីមុនមានការជាប់ពាក់ព័ន្ធទៅនឹងការវាយតម្លៃលើភាពជឿទុកចិត្តបាន និងភាពជឿជាក់បាននៃសក្ខីកម្មរបស់គាត់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភាពចាំបាច់ក្នុងការកោះហៅសាក្សីរូបនេះតាមការស្នើសុំរបស់ នួន ជា ម្តងទៀតឡើយ[130]។

៥៧.ដោយពិចារណាឃើញថា ជាចម្បង នួន ជា បានស្នើសុំឱ្យកោះហៅ ថេត សម្បត្តិ និង Robert LEMKIN ពីព្រោះពួកគាត់បានធ្វើកិច្ចសម្ភាសន៍នេះ និងបានយល់ឃើញថា នួន ជា ពុំបានអះអាងពីមូលហេតុដែលគួរឱ្យជឿជាក់បានថា សម្ភារនៃកិច្ចសម្ភាសន៍ទាំងនេះអាចជាប់ពាក់ព័ន្ធ និងជាកត្តាកំណត់ឈានដល់ការសម្រេចដាក់ពិរុទ្ធភាពបាននោះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធសំណើសុំកោះហៅបុគ្គលទាំងពីររូបនេះ។

## ២.ច.សំណើសុំឱ្យទទួលយកជាភស្តុតាងនូវបទសម្ភាសន៍របស់ ថេត សម្បត្តិ ជាមួយវិទ្យុសម្លេងអាម៉េរិកកាំងជាខេមរភាសា

៥៨.នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកជាភស្តុតាងនូវខ្សែអាត់សម្លេងនៃបទសម្ភាសន៍ដែល ថេត សម្បត្តិ បានផ្តល់ទៅឱ្យវិទ្យុសម្លេងអាម៉េរិកកាំងជាខេមរភាសាកាលពីថ្ងៃទី ១២ និង ១៣ ខែ សីហា ឆ្នាំ ២០១៤ ("បទសម្ភាសន៍ ថេត សម្បត្តិ")។ អង្គជំនុំជម្រះតុលាការកំពូលបានសង្ខេបនូវអំណះអំណាងរបស់ភាគី ពាក់ព័ន្ធទៅនឹងការទទួលយកបទសម្ភាសន៍ ថេត សម្បត្តិ និងបានដោះស្រាយមួយចំនួននៅក្នុងសេចក្តីសម្រេចបណ្តោះអាសន្នលើកទីមួយស្តីពីការស៊ើបសួរបន្ថែម (F2/4/3)[131]។ នៅក្នុងផ្នែកសម្រេចសេចក្តីរបស់ខ្លួនលើសំណើសុំដាក់ភស្តុតាងបន្ថែមដែលពុំទាន់បានសម្រេច (F2/9) អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធសំណើរបស់ នួន ជា។

---

[130] សារណារបស់ នួន ជា ស្តីពីជម្លោះនៅក្នុង ប.ក.ក. (F2/4/3/3/6/1) កថាខណ្ឌ ១០ ដល់ ១៥ និង ៦៧(ខ)។

[131] សេចក្តីសម្រេចបណ្តោះអាសន្នលើកទីមួយស្តីពីកិច្ចស៊ើបសួរបន្ថែម កថាខណ្ឌ ៥ ដល់ ១៣ និង ២០។

៥៩.នួន ជា បានអះអាងថា បទសម្ភាសន៍ ថេត សម្បត្តិ អាចចោទជាបញ្ហាដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក. និងជាពិសេស ការទទួលខុសត្រូវរបស់គាត់ចំពោះការសម្លាប់នៅទួលពោធិ៍ជ្រៃ[132]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអះអាងរបស់ ថេត សម្បត្តិ ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការចោទជាបញ្ហាដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសារពុំបានផ្តល់ព័ត៌មានថ្មីដែលជាប់ពាក់ព័ន្ធឡើយ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានទទួលសម្ភារដើមដែលតាមការសន្មត ថេត សម្បត្តិ បានបញ្ចេញមតិយោបល់ដូចគ្នាទៅនឹងអ្វីដែលគាត់បានអះអាងនៅក្នុងបទសម្ភាសន៍ និងបានយល់ឃើញថា ពុំមែនជាភស្តុតាងសមស្របក្នុងការដោះបន្ទុក នួន ជា ឡើយ[133]។ ទាក់ទងទៅនឹងការអះអាងរបស់ នួន ជា ដែលថា បទសម្ភាសន៍ ថេត សម្បត្តិ គឺជាភស្តុតាងបញ្ជាក់ឱ្យឃើញថា ដោយសារមានការជ្រៀតជ្រែកពីរដ្ឋាភិបាល ទើបភស្តុតាងដោះបន្ទុកពុំត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងនោះ[134] អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកការអះអាងរបស់ ថេត សម្បត្តិ ពុំមានលក្ខណៈជាក់លាក់ និងពុំមានមូលដ្ឋានគាំទ្រ ហើយដូច្នេះ មានតម្លៃជាភស្តុតាងតិចតួចបំផុតពុំអាចទទួលយកជាភស្តុតាងបានឡើយ។

## ២.ឆ.សំណើសុំឱ្យទទួលយកជាភស្តុតាងនូវបទសម្ភាសន៍របស់ CARTWRIGHT និងសេចក្តីដកស្រង់នៃសៀវភៅរបស់ LEMONDE

៦០.នួន ជា បានលើកឡើងថា បទសម្ភាសន៍របស់ចៅក្រម CARTWRIGHT គប្បីត្រូវបានទទួលយកជាភស្តុតាង ពីព្រោះបទសម្ភាសន៍នេះមានចម្លើយមួយចំនួន ដែល“ពាក់ព័ន្ធទៅនឹងក្តីបារម្ភដ៏សមហេតុផលរបស់សាធារណជនអំពីភាពលម្អៀង [របស់លោកស្រី] ប្រឆាំងនឹង ប.ក.ក. និង នួន ជា” និងពាក់ព័ន្ធទៅនឹងភាពអនាគតិរបស់ចៅក្រមជាតិដែលកំពុងជំនុំជម្រះនៅក្នុងអង្គជំនុំជម្រះសាលាដំបូង[135]។ ទាក់ទងទៅនឹងសេចក្តីដកស្រង់នៃសៀវភៅរបស់ចៅក្រម LEMONDE នួន ជា បានអះអាងថា បទពិសោធន៍នៃអនិយ័តភាពដែលបានរៀបរាប់

[132] សំណើទីមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2) កថាខណ្ឌ ១៥។

[133] *សូមមើលខាងលើ* កថាខណ្ឌ ៥៣ *ជាអាទិ៍*។

[134] សំណើទីមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2) កថាខណ្ឌ ១៦។ សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧ និង ៧៥។

[135] សំណើទីពីររបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/1) កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩ ដល់ ៥៣។

ដោយអតីតសហចៅក្រមស៊ើបអង្កេត LEMONDE ពេលនោះបានបង្ហាញឱ្យឃើញកាន់តែច្បាស់ឡើងតាមរយៈបទពិសោធន៍របស់សហចៅក្រមស៊ើបអង្កេត Laurent KASPER-ANSERMET ដែលបានចូលកាន់តំណែងបន្តក្នុងចំណោមសហចៅក្រមស៊ើបអង្កេតដទៃទៀត និងដូច្នេះបានបង្ហាញឱ្យឃើញថា ការប៉ះពាល់ដោយសារអនិយ័តភាព និងការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ពុំខុសប្លែកគ្នាពីការប៉ះពាល់នៅក្នុងសំណុំរឿង ០០២ ឡើយ ដែលគ្រាន់តែជាការបន្តគ្នាប៉ុណ្ណោះ[136]។

៦១.សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើទាំងពីរនេះ។ សហព្រះរាជអាជ្ញាបានអះអាងថា ពុំមានការអះអាងនៅក្នុងបទសម្ភាសន៍របស់ចៅក្រម CARTWRIGHT ដែលលើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបាន"ធ្វើឱ្យប៉ះពាល់ដោយសារបទពិសោធន៍ផ្ទាល់ខ្លួន ការលម្អៀង ឬការជ្រៀតជ្រែកផ្នែកនយោបាយឡើយ"[137]។ សហព្រះរាជអាជ្ញាបានអះអាងបន្តទៀតថា ចៅក្រម CARTWRIGHT គ្រាន់តែបានពិភាក្សាលើ"គំនិតគាំទ្រ និងគំនិតប្រឆាំងនឹងតុលាការចម្រុះមួយ" និងបានប៉ាន់ស្មានលើ"ការប៉ះពាល់ផ្លូវចិត្ត" ដែលអាចកើតមានលើចៅក្រមដែលបានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យនោះ[138]។ ទាក់ទងទៅនឹងសេចក្តីដកស្រង់នៃសៀវភៅរបស់ LEMONDE សហព្រះរាជអាជ្ញាបានជំទាស់ថា សំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកមកធ្វើជាភស្តុតាង ត្រូវបានសម្រេចបដិសេធនៅពេលជំនុំជម្រះរួចហើយ ដូច្នេះ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងពុំអនុញ្ញាតឱ្យស្នើសុំឱ្យទទួលយកនៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ[139]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានរំឭកថា ភាពពុំត្រឹមត្រូវនៅក្នុងការស៊ើបសួរត្រូវបានដោះស្រាយតាមរយៈដីកាដំណោះស្រាយ និងពុំអនុញ្ញាតឱ្យលើកម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលឡើយ[140]។

---

[136] សំណើទីពីររបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/1) កថាខណ្ឌ ១៦ ដល់ ១៧។ សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦។

[137] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/2) កថាខណ្ឌ ២១។

[138] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/2) កថាខណ្ឌ ១៨ ដល់ ១៩។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២ ដល់ ៣៦។

[139] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/2) កថាខណ្ឌ ២៣។

[140] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីរ (F2/2) កថាខណ្ឌ ២៤។

៦២.អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកបទសម្ភាសន៍របស់ចៅក្រម CARTWRIGHT ធ្វើជាភស្តុតាងអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដោយសារ យោបល់ដែលគាត់បានធ្វើឡើងក្នុងក្រុមពិភាក្សានៅវិទ្យស្ថាន Aspen គឺជាមូលដ្ឋានសម្រាប់ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលថា មានការបង្ហាញពីភាពលម្អៀង និងដោយសារផលប្រយោជន៍យុត្តិធម៌ដែលតម្រូវឱ្យដាក់បញ្ចូលទៅក្នុងសំណុំរឿង ដើម្បីអាចឱ្យភាគីធ្វើការតវ៉ាដោយគ្មានការរឹតត្បិត និងអាចធ្វើការពិនិត្យលើអង្គសេចក្តីនៃសារណារបស់ នួន ជា ទាក់ទងទៅនឹងបញ្ហាមូលដ្ឋាននៃភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី[141]។

៦៣.អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចផងដែរថា ដោយអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដើម្បីផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យទទួលយកសំណើរបស់ នួន ជា សុំឱ្យទទួលយកសេចក្តីដកស្រង់ចេញពីសៀវភៅរបស់ចៅក្រម LEMONDE ធ្វើជាភស្តុតាង។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ភស្តុតាងនេះអាចរកបាននៅពេលជំនុំជម្រះ និងរំឭកថា សម្ភារនេះត្រូវបានស្នើឡើងរួចហើយទាក់ទងទៅនឹងបណ្តឹងសាទុក្ខភ្លាមៗនៅចំពោះមុខខ្លួន និងថា នៅពេលនោះ ត្រូវបានបដិសេធចោលដោយសារមូលហេតុនីតិវិធី ប៉ុន្តែបានបញ្ជាក់ថា នួន ជា នៅមានឱកាស“ដាក់សំណើក្នុងពេលអនាគតដោយផ្អែកលើមូលដ្ឋានភស្តុតាង និងអំណះអំណាងដែលមាន”នៅក្នុងសំណើសុំនោះ[142]។ ទាក់ទងទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា និយ័តភាពជាសក្តានុពលនៃការស៊ើបសួរត្រូវបានដោះស្រាយតាមរយៈដីកាដំណោះស្រាយនោះ អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតឃើញថា នួន ជា ពុំបានស្នើសុំមោឃៈទាំងមូល ឬផ្នែកខ្លះនៃកិច្ចស៊ើបសួរឡើយ ប៉ុន្តែគ្រាន់តែបង្ហាញថា កិច្ចដំណើរការនីតិវិធីទាំងមូល រួមទាំងនៅដំណាក់កាលជំនុំជម្រះផងនោះ មានការជ្រៀតជ្រែកផ្នែកនយោបាយយ៉ាងទូលំទូលាយដែលបានធ្វើឱ្យកិច្ចដំណើរការនីតិវិធីទាំងនេះមានភាពពុំត្រឹមត្រូវជាមូលដ្ឋាន។

៦៤.បញ្ហា ថាតើកិច្ចសម្ភាសន៍របស់ចៅក្រម CARTWRIGHT និងសេចក្តីដកស្រង់ចេញពីសៀវភៅរបស់ចៅក្រម LEMONDE បានគាំទ្រដល់អំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដែរ ឬយ៉ាងណា ហើយប្រសិនបើមាន តើដល់កម្រិតណា គឺជាបញ្ហាដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយនៅក្នុងសាលដីកានេះ[143]។

---

[141] *សូមមើលខាងក្រោម* កថាខណ្ឌ ១១៥។

[142] សេចក្តីសម្រេចលើសំណើសុំចំណាត់ជាការបន្ទាន់ (E189/3/1/8) កថាខណ្ឌ ១០ ដល់ ១១។

[143] *សូមមើលខាងក្រោម* កថាខណ្ឌ ១១៤, ១១៩។

## ២.ផ.សំណើសុំឱ្យទទួលយកប្រតិចារឹករបស់សាក្សី ពេជ្រ ជឹម ជាភស្តុតាង និងការទទួលយក*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*នូវកិច្ចសម្ភាសន៍របស់សាក្សី សៅ វ៉ន ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)

៦៥.យោងតាមវិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុង នួន ជា បានស្នើសុំបង្ហាញប្រតិចារឹករបស់ ពេជ្រ ជឹម ទាក់ទងទៅនឹងកាលៈទេសៈពីរដែលបានរៀបរាប់នៅក្នុងនោះ។ នួន ជា បានលើកឡើងថា ភស្តុតាងនេះស្របជាមួយនឹងការរៀបរាប់របស់ សៅ វ៉ន(*ហៅ* សៅ ពត) ដែលថា ក្នុងកិច្ចប្រជុំនៅខេត្តតាកែវក្រោយថ្ងៃរំដោះ តាម៉ុក បានប្រកាសថា ហាមប៉ះពាល់ទាហានរបប លន់ នល់ ពីស័ក្តិមួយដល់ស័ក្តិប្រាំ[144]។ ទីពីរ នួន ជា កត់សម្គាល់ថា ភស្តុតាងនេះមានការពន្យល់របស់ ពេជ្រ ជឹម ទាក់ទងទៅនឹងអត្ថន័យនៃពាក្យថា“កម្ចាត់” ដែលសំដៅទៅលើការប្រព្រឹត្តរបស់ខ្មែរក្រហមទៅលើបុគ្គល ដែលពាក់ព័ន្ធទៅនឹងរបបសាធារណរដ្ឋខ្មែរ[145]។ តាមគំនិតរបស់ នួន ជា ពេជ្រ ជឹម បានបញ្ជាក់បន្ថែមទៅលើការអះអាងរបស់ សៅ វ៉ន និង ហេង សំរិន ថា ពុំមានគោលនយោបាយសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃឡើយ[146]។

៦៦.សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើនេះ ដោយបានអះអាងថា ភស្តុតាងដែលបានស្នើឡើងនោះបើពិចារណាតាមបរិបទ និងជារួម ពុំអាចជាកត្តាកំណត់ អនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងឡើយ[147]។ សហព្រះរាជអាជ្ញាបានអះអាងថា កិច្ចប្រជុំដែល ពេជ្រ ជឹម បានសំដៅទៅលើនោះ កើតឡើងប៉ុន្មានខែក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ និងថា សក្ខីកម្មរបស់គាត់ត្រូវតែវាយតម្លៃដោយធៀបនឹងភស្តុតាងដាក់បន្ទុកដទៃទៀត និងថា ការបកស្រាយរបស់គាត់អំពីពាក្យ“កម្ចាត់”ពុំមានលក្ខណៈប្រាកដប្រជាឡើយ[148]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងបន្ថែមទៀតថា ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលទទួលយកភស្តុតាងដែលបានស្នើឡើងដោយ នួន ជា ពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់គោលដៅនោះ នួន ជា នឹងអាចស្នើសុំឱ្យទទួលយកភស្តុតាងជំទាស់ថ្មីបន្ថែមទៀត[149]។

---

[144] សំណើទីបួនរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/6) កថាខណ្ឌ ៧។

[145] សំណើទីបួនរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/6) កថាខណ្ឌ ៨។

[146] សំណើទីបួនរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/6) កថាខណ្ឌ ១៤ ដល់ ១៦។

[147] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីបួនសុំដាក់ភស្តុតាងបន្ថែម (F2/6/2) កថាខណ្ឌ ១, ៣, ១៤ ដល់ ១៦។

[148] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីបួនសុំដាក់ភស្តុតាងបន្ថែម (F2/6/2) កថាខណ្ឌ ៦ ដល់ ១១។

[149] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីបួនសុំដាក់ភស្តុតាងបន្ថែម (F2/6/2) កថាខណ្ឌ ១៦។

៦៧.សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា សំណើរបស់ នួន ជា គប្បីបដិសេធចោល។ តាមគំនិតរបស់សហមេធាវីនាំមុខ នួន ជា មានឱកាសសួរដេញដោល ពេជ្រ ជឹម នៅពេលសាក្សីរូបនេះបានបង្ហាញខ្លួននៅក្នុងសំណុំរឿង ០០២/០១ កន្លងមក ប៉ុន្តែដោយការធ្វេសប្រហែស នួន ជា ពុំបានសួរដេញដោលឡើយ។ បន្ថែមលើនេះទៀត ភស្តុតាងដែលបានស្នើឡើងនោះពុំអាចប៉ះពាល់ភស្តុតាងណាមួយដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ និងពុំអាចជួយស្វែងរកការពិតនៅដំណាក់កាលបណ្តឹងសាទុក្ខនេះបានឡើយ។ ចុងក្រោយ សហមេធាវីនាំមុខបានអះអាងថា ការទទួលយកភស្តុតាងទាំងនេះ គឺផ្ទុយទៅនឹងភាពចាំបាច់ក្នុងការធានាបាននូវកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខឆាប់រហ័សបាន[150]។

៦៨.អង្គជំនុំជម្រះតុលាការកំពូលបានស្របជាមួយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលថា សំណើរបស់ នួន ជា បានស្នើសុំឱ្យទទួលយកប្រតិចារឹករបស់ ពេជ្រ ជឹម ជាភស្តុតាងពុំបានបំពេញតាមលក្ខខណ្ឌតម្រូវនៃក្នុងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងឡើយ។ បើទោះបីជា នួន ជា បានអះអាងថា សំណើសុំឱ្យទទួលយកផ្នែកខ្លះនៃសក្ខីកម្មរបស់ ពេជ្រ ជឹម ត្រូវបាន“ជំរុញដោយផ្ទាល់”ពីកំណត់ហេតុស្តាប់ចម្លើយដែលបានបង្ហាញក្រោយការបញ្ចប់ការជំនុំជម្រះសំណុំរឿង ០០២/០១ ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នួន ជា គួរតែសួរ ពេជ្រ ជឹម ឱ្យបានច្បាស់លាស់ទាក់ទងទៅនឹងបញ្ហាដែលជាប់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដូចជា ប្រធានបទអំពីខ្មាំង ការកម្ទេច និងជាពិសេស ការណែនាំក្នុងពេលប្រជុំដែល តា ម៉ុក បាននិយាយអំពីខ្មាំង ការណែនាំពាក់ព័ន្ធទៅនឹង“ការបោសសម្អាតមន្ត្រី” និងការប្រព្រឹត្តចំពោះអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ[151]។ អាស្រ័យហេតុនេះ ភស្តុតាងទាំងនេះពុំចាត់ទុកថា ពុំអាចរកបាននៅពេលជំនុំជម្រះឡើយ។

៦៩.អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ទោះជាយ៉ាងណាក្តី ដើម្បីផលប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះត្រូវទទួលយកប្រតិចារឹករបស់ ពេជ្រ ជឹម ធ្វើជាភស្តុតាងអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ព្រោះខ្លឹមសារនៃប្រតិចារឹកនេះពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនៅខេត្តតាកែវ មានការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងកាលៈទេសៈនៃអង្គហេតុសំខាន់ ដោយផ្អែកលើកាលៈទេសៈនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចកោះហៅសាក្សី សៅ វ៉ន មកផ្តល់សក្ខីកម្មនៅដំណាក់កាលបណ្តឹងសាទុក្ខ និងមានសារៈសំខាន់សម្រាប់វាយតម្លៃអំពីភាព

---

[150] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើទីបួនសុំដាក់ភស្តុតាងបន្ថែម (F2/6/1) កថាខណ្ឌ ១៤ ដល់ ៣១។

[151] ប្រតិចារឹកចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (ពេជ្រ ជឹម) ឯកសារលេខ E1/215.1 ទំព័រ ១៥ ដល់ ១៦, ២៥ ដល់ ២៧, ៣០ ដល់ ៣១, ៥៣, ៦១ ដល់ ៦៣។

ជឿទុកចិត្តបាន និងភាពជឿជាក់បានរបស់ សៅ វ៉ន។

៧០.អង្គជំនុំជម្រះតុលាការកំពូល *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* បានទទួលយកបទសម្ភាសន៍របស់ DC-Cam ជាមួយ សៅ វ៉ន ដែលមានសារៈសំខាន់សម្រាប់វាយតម្លៃអំពីភាពជឿទុកចិត្ត និងជាចម្លើយពីមុនរបស់សាក្សីដែលបានចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។

## ២.ឈ.ការស្នើសុំនៅក្នុងសំណើទីប្រាំសុំដាក់ភស្តុតាងបន្ថែម (F2/7)

៧១.នៅក្នុងសំណើទីប្រាំសុំដាក់ភស្តុតាងបន្ថែម (F2/7) នួន ជា បានស្នើសុំដោយផ្អែកតាមវិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុង៖ (i) ឱ្យទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយចំនួន ៤ ដែលបានបង្ហាញនៅក្នុងសំណុំរឿង ០០៤ (ii) ឱ្យទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយរបស់ ទាត់ ធឿន និងឧបសម្ព័ន្ធភ្ជាប់ជាមួយ និង (iii) ការកោះហៅសាក្សីចំនួន ៥ នាក់[152]។ នួន ជា បានស្នើសុំឱ្យទទួលយកភស្តុតាងបន្ថែមដែលបង្ហាញថា មជ្ឈិមបក្សបានគ្រប់គ្រងដោយមានកម្រិតប៉ុណ្ណោះ និងមានការបែកបាក់យ៉ាងខ្លាំង និងថា ប្រធានភូមិភាគ ជាពិសេស រស់ ញឹម(ញឹម រស់) និង សោ ភឹម មានសិទ្ធិអំណាចឯករាជ្យយ៉ាងច្រើន ហើយពួកគេបានយកអំណាចនេះមកប្រើប្រាស់ដើម្បីបះបោរប្រឆាំងនឹង ប.ក.ក.[153]។ នួន ជា ក៏បានស្នើឡើងនូវភស្តុតាងនេះផងដែរ"ក្នុងការបញ្ជាក់បន្ថែម និងផ្ទៀងផ្ទាត់"លើសក្ខីកម្មរបស់ ទាត់ ធឿន ដែលបានចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[154]។ ការស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់ ទាត់ ធឿន និងឧបសម្ព័ន្ធ គឺក្នុងគោលបំណងដើម្បី"ជួយដល់អង្គជំនុំជម្រះឱ្យយល់បានពេញលេញអំពីព័ត៌មាន នៅក្នុងសំណុំរឿងពាក់ព័ន្ធទៅនឹង"សាក្សីរូបនេះ[155]។

៧២.សហព្រះរាជអាជ្ញា បានជំទាស់ទៅនឹងសំណើទាំងអស់នោះលើកលែងតែកំណត់ហេតុស្តាប់ចម្លើយរបស់ ទាត់ ធឿន និងឧបសម្ព័ន្ធភ្ជាប់ជាមួយប៉ុណ្ណោះ[156]។ ទាក់ទងទៅនឹងបទប្បញ្ញត្តិគ្រប់គ្រងក្នុងការទទួលយកភស្តុតាងបន្ថែមនៅដំណាក់កាលបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានលើកឡើងថា សិទ្ធិអំណាចជាឆន្ទានុសិទ្ធិ

---

[152] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ១៣, ៦១, ៦៧។

[153] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ៥៣ ដល់ ៥៧, ៥៩ ដល់ ៦៥។

[154] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ៤ និង ៦២។

[155] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ៥៨ និង ៦៦។

[156] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំសុំដាក់ភស្តុតាងបន្ថែម (F2/7/1) កថាខណ្ឌ ៥៣។

របស់អង្គជំនុំជម្រះតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ពុំគប្បីត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយឡើយ ខ្លាច មានការប៉ះពាល់ដល់តួនាទីរបស់ខ្លួនដែល"ជាអ្នកកំណត់បទដ្ឋាននៃការទទួលយកភស្តុតាងថ្មី" តាមវិធាន ១០៨ (៧) នៃវិធានផ្ទៃក្នុង[157]។ ទាក់ទងទៅនឹងអង្គសេចក្តី សហព្រះរាជអាជ្ញាបានលើកឡើងថា ពុំមានភស្តុតាងណា មួយដែលអាចត្រូវបានចាត់ទុកថាជាកត្តាកំណត់នៅពេលជំនុំជម្រះឡើយ ដោយសារភស្តុតាងទាំងនេះពុំជាប់ ពាក់ព័ន្ធ និងសុទ្ធតែបញ្ជាក់ពីអត្ថិភាពនៃរចនាសម្ព័ន្ធឋានានុក្រមនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ ជ្រៃ[158]។

៧៣.អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា "លទ្ធភាពសាមញ្ញសម្រាប់ការលើកបង្ហាញភស្តុតាងបន្ថែមនៅ ដំណាក់កាលបណ្តឹងសាទុក្ខ" មានតាមរយៈវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង[159]។ អាស្រ័យហេតុនេះ អង្គជំនុំ ជម្រះតុលាការកំពូលផ្តល់ហេតុផលថា ភាគីពុំអាចសំអាងលើវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដើម្បីគេចចេញពី លក្ខខណ្ឌតម្រូវតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ដែល"សំខាន់បំផុតដើម្បីជៀសវាងការប្រើប្រាស់យុត្តិសា ស្ត្រនៃការតវ៉ាក្តីដែលពុំមានប្រសិទ្ធភាព និងជាការរំខាន"[160]។ នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ នួន ជា បានស្នើសុំឱ្យ កោះហៅបុគ្គលបីរូប (2-TCW-959, 2-TCW-960 និង 2-TCW-961) ដែលអត្តសញ្ញាណ និងតួនាទីរបស់ បុគ្គលទាំងនេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបង្ហាញជាសាធារណៈចាប់តាំងពីការផ្សព្វផ្សាយ សៀវភៅមួយនៅក្នុងឆ្នាំ ២០១០ ដែលមាននៅក្នុងសំណុំរឿង[161]។ ទាក់ទងទៅនឹងការស្នើសុំសក្ខីកម្មរបស់ បុគ្គលទាំងនេះ នួន ជា ពុំបានសំអាងលើព័ត៌មានណាមួយដែលគាត់ពិតជាពុំបានដឹងនៅក្នុងឆ្នាំ ២០១០ ទេ ដូច្នេះ ព័ត៌មាននេះគួរត្រូវបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ការអះអាងដែលថា គាត់បានរង់ចាំ មើល ថាតើ Robert LEMKIN និង ថេត សម្បត្តិ ផ្តល់ឈុតខ្សែវីដេអូដែលទំនងជាបង្ហាញពីបទសម្ភាសន៍ ជាមួយនឹងសាក្សីបីនាក់ដែលបានស្នើឡើង ដែរ ឬយ៉ាងណា[162]នោះ ពុំជាប់ពាក់ព័ន្ធឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ក្នុងផ្នែកនេះនៃសំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម

[157] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំសុំដាក់ភស្តុតាងបន្ថែម (F2/7/1) កថាខណ្ឌ ៤ ដល់ ៥។

[158] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំសុំដាក់ភស្តុតាងបន្ថែម (F2/7/1) កថាខណ្ឌ ៧ ដល់ ១០។

[159] សេចក្តីសម្រេចលើសំណើសុំកោះហៅសាក្សី (F2/5) កថាខណ្ឌ ១៥។

[160] សេចក្តីសម្រេចលើសំណើសុំកោះហៅសាក្សី (F2/5) កថាខណ្ឌ ១៦។

[161] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ៤២។

[162] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ៦៣។

(F2/7) ត្រូវបដិសេធចោល ដោយសារភស្តុតាងដែលបានស្នើឡើងនោះ អាចរកបាននៅពេលជំនុំជម្រះ និងពុំមានមូលហេតុសមស្របក្នុងការប្រើប្រាស់សិទ្ធិអំណាចជាឆន្ទានុសិទ្ធិតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងឡើយ។

៧៤.អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើសុំរបស់ នួន ជា ពាក់ព័ន្ធទៅនឹងសាក្សីទី ១ ទី ២ ទី ៣ និង ទី ៤ ដោយផ្អែកលើមូលដ្ឋាននៃភាពពុំជាប់ពាក់ព័ន្ធយ៉ាងច្បាស់ ទៅនឹងការយល់ឃើញណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងដែលជាមូលដ្ឋាននៃការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់។ ផ្អែកតាមកំណត់ហេតុស្តាប់ចម្លើយ សាក្សីបានយោងជាចម្បងទៅលើកាលៈទេសៈពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ រួមមាន រស់ ញឹម (រស់ ញឹម) ដោយកម្មាភិបាលភូមិភាគនិរតី ដែលកើតឡើងដំបូងបំផុត គឺចាប់ពីពាក់កណ្តាល/ចុងឆ្នាំ ១៩៧៦[163] មានន័យថា ជាងមួយឆ្នាំក្រោយពីព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ។ ក្រៅតែពីពេលវេលាពុំជាប់ពាក់ព័ន្ធច្បាស់លាស់ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា កាលៈទេសៈដែលដូចគ្នាទៅនឹងខាងលើនេះ ពុំអាចមានអានុភាពទៅលើការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា ឡើយ។ ទាក់ទងទៅនឹងអ្វីដែល នួន ជា បានចាត់ទុកថា "ជាឧទាហរណ៍ជាក់លាក់នៃសកម្មភាពជាជំហានឆ្ពោះទៅរកការបះបោរ"[164] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា តាមសម្តីរបស់សាក្សី គឺសំដៅទៅលើ រស់ ញឹម (ញឹម រស់) ដែលបានយកឯកសណ្ឋានយោធាពីកងទ័ពវៀតណាមក្នុងឆ្នាំ ១៩៧៧ និងផែនការ"ប្រឆាំង ប៉ុល ពត"ដែលឈានដល់ការចាប់ខ្លួនក្នុងពាក់កណ្តាលឆ្នាំ ១៩៧៧[165]។ សកម្មភាពទាំងនោះមិនត្រឹមតែពុំជាប់ពាក់ព័ន្ធទៅនឹងពេលវេលាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពុំអាចមោឃៈការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលជាមូលដ្ឋាននៃការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា ដូចការលើកឡើងជាទូទៅខាងលើ[166]។ អាស្រ័យហេតុនេះ ភស្តុតាងដែលបានស្នើឡើងត្រូវបានចាត់ទុកថា ពុំមែនជាកត្តាកំណត់ និងពុំអាចជួយស្វែងរកការពិតនោះឡើយ។

៧៥.ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ ទាត់ ធឿន និងឧបសម្ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីមួយដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ជាធម្ម

---

[163] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ២០, ២៤ ដល់ ២៥, ២៧, ៣២, ៣៩ និង ៤១។

[164] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ៥៦។

[165] សំណើទីប្រាំរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/7) កថាខណ្ឌ ១៦, ២៧ ដល់ ២៨។

[166] *សូមមើលខាងក្រោម* កថាខណ្ឌ ៤៥ ដល់ ៤៩។

តាគប្បីដាក់ចូលក្នុងសំណុំរឿង ដោយអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។ ប៉ុន្តែ នៅក្នុងរឿងក្តីបច្ចុប្បន្ន ព័ត៌មាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយពុំមានការជាប់ពាក់ព័ន្ធទៅនឹងបញ្ហាដែលសាក្សីបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដូច្នេះពុំអាចប្រើប្រាស់ដើម្បីសួរដេញដោលអំពីភាពជឿទុកចិត្តបានរបស់សាក្សីឡើយ។ អាស្រ័យហេតុនេះ សំណើសុំរបស់ នួន ជា ចំណុចនេះត្រូវបដិសេធចោល។

## ២.ញ.ការស្នើសុំនៅក្នុងសំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8)

៧៦.នៅក្នុងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម នួន ជា បានស្នើសុំដោយផ្អែកតាមវិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុងថា (i) ឱ្យទទួលយកជាភស្តុតាងនូវសក្ខីកម្មចំនួន ១០ (កំណត់ហេតុស្តាប់ចម្លើយ ប្រតិចារឹកជំនុំជម្រះ និងចម្លើយពី DC-Cam) (ii) ឱ្យទទួលយកជាភស្តុតាងនូវឯកសារចំនួន ១២ របស់រដ្ឋាភិបាលបរទេស ដូចជា របាយការណ៍នៃការស៊ើបការណ៍ ទូរលេខស្ថានទូត និង (iii) ការកោះហៅសាក្សីពីររូប[167]។ នួន ជា បានអះអាងថា ភស្តុតាងបន្ថែមទាំងនេះអាចបដិសេធចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប.ក.ក. មានរចនាសម្ព័ន្ធឋានានុក្រមតឹងរ៉ឹង ដោយមានកម្មាភិបាលអនុវត្តស្មោះត្រង់ចំពោះការណែនាំពីថ្នាក់ដឹកនាំ និងថា នួន ជា បានប្រើប្រាស់អំណាចធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុង ប.ក.ក. និងគ្រប់គ្រងដោយមានប្រសិទ្ធភាពលើកម្មាភិបាលថ្នាក់ក្រោម។ ភស្តុតាងដែលបានស្នើឡើងនេះ ក៏បានឆ្លើយតបផងដែរទៅនឹងការមន្ទិលសង្ស័យរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អ្នកដែល ប.ក.ក. បានកំណត់អត្តសញ្ញាណថា ជា“ខ្មាំង”បានបង្កការគំរាមកំហែងពិតប្រាកដ នៅពេលពិចារណាទៅលើផែនការរបស់វៀតណាមក្នុងការពង្រីកការគ្រប់គ្រងរបស់ខ្លួនលើកម្ពុជា[168]។ នួន ជា បានលើកឡើងថា ភស្តុតាងបន្ថែមនេះ បានបង្ហាញពី“សិទ្ធិអំណាចឯករាជ្យយ៉ាងច្រើន”របស់ប្រធានភូមិភាគមួយចំនួនដែលបានបង្កការបះបោរប្រឆាំងនឹង ប.ក.ក. ដោយមានការគាំទ្រពីវៀតណាម[169]។

៧៧.នួន ជា បានអះអាងដោយផ្អែកលើមូលដ្ឋាននេះថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចយល់ឃើញថា គាត់បានរួមចំណែកក្នុងគោលបំណងរួមមួយ“ដែលមានមេដឹកនាំនានាព្យាយាមបង្កការបះបោរ”

---

[167] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ៧០ និង ១៥៦ ដល់ ១៦០។

[168] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ២ ដល់ ៨ និង ១៥១ ដល់ ១៥២។

[169] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ៩ ដល់ ១២។

01357966



ប្រឆាំងនឹងរូបគាត់នោះបានឡើយ[170]។ ទាក់ទងទៅនឹងបញ្ហានេះ នួន ជា បានអះអាងថា ជាការសំខាន់ក្នុងការបំភ្លឺអំពីមូលហេតុជាឫសគល់ និងផលវិបាកនៃព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃ ប.ក.ក. ដូចជា ការផ្តោតទៅលើការប៉ុនប៉ងរបស់វៀតណាមបង្កអស្ថិរភាព និងចុងក្រោយផ្តួលរំលំរដ្ឋាភិបាល“ស្របច្បាប់ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ” និងការសំអាងលើក្រុមបះបោរនៅក្នុង ប.ក.ក.[171]។ តាមការលើកឡើងរបស់ នួន ជា ភស្តុតាងទាំងនេះ គឺជាការបង្ហាញអំពីផែនការ“ក”របស់វៀតណាម ដូចជាការគ្រប់គ្រងកម្ពុជាតាមរយៈការបះបោរផ្ទៃក្នុង និងផែនការ“ខ”ការគ្រប់គ្រងកម្ពុជាតាមរយៈការឈ្លានពានដោយយោធាផ្ទាល់[172]។

៧៨.សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា បើទោះបីជាសំណើរបស់ នួន ជា បានព្យាយាមបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងនរណាជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមក៏ដោយ ក៏ នួន ជា ពុំបានជំទាស់ទៅនឹងការយល់ឃើញទាំងនេះនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនឡើយ[173]។ សហមេធាវីនាំមុខបានកត់សម្គាល់ថា ការយល់ឃើញពាក់ព័ន្ធទាំងនេះពុំមែនផ្អែកលើតួនាទីនីមួយៗរបស់បុគ្គលនីមួយនៅក្នុង ប.ក.ក. នោះឡើយ ប៉ុន្តែផ្អែកលើកត្តាផ្សេងៗដែលពុំជាប់ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក.[174]។ សហមេធាវីនាំមុខបានលើកឡើងថា បើទោះបីជារចនាសម្ព័ន្ធអង្គការអាចជាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើក៏ដោយ ក៏ នួន ជា ពុំត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើមូលដ្ឋាននេះដែរ[175]។ បន្ថែមលើនេះទៀត សហមេធាវីនាំមុខបានអះអាងថា ភស្តុតាងមួយចំនួនក្នុងចំណោមភស្តុតាងដែលបានស្នើសុំឱ្យទទួលយកនោះ ពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការពេលវេលានៃសំណុំរឿង ០០២/០១ ឡើយ[176]។

---

[170] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ១៣ (សេចក្តីបញ្ជាក់លុបចោល)។

[171] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ១៧ ដល់ ៦៩។

[172] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ១៥៣ ដល់ ១៥៥។ *សូមមើលផងដែរ* កថាខណ្ឌ ២៩ ដល់ ៥៣ (“ផែនការ ក”) កថាខណ្ឌ ៥៤ ដល់ ៦៩ (“ផែនការ ខ”)។

[173] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/1) កថាខណ្ឌ ១៣ ដល់ ១៦។

[174] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/1) កថាខណ្ឌ ១៧ ដល់ ២០។

[175] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/1) កថាខណ្ឌ ២៣ ដល់ ២៨។

[176] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/1) កថាខណ្ឌ ២៩ ដល់ ៣០។

៧៩.សហព្រះរាជអាជ្ញាបានចាត់ទុកសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8) ជាការឥតប្រយោជន៍ និងពន្យារពេល ដូច្នេះ ត្រូវបដិសេធចោលដោយពុំចាំបាច់ធ្វើការពិចារណាបន្តទៀតឡើយ[177]។ ជាពិសេស សហព្រះរាជអាជ្ញាបានអះអាងថា ភស្តុតាងដែលស្នើឡើងនោះពុំបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ១០៨(៧) ឬ ១០៤(១) នៃវិធានផ្ទៃក្នុងឡើយ ដោយសារផ្នែកខ្លះនៃភស្តុតាងអាចរកបាននៅពេលជំនុំជម្រះ ហើយភស្តុតាងទាំងមូលនេះ"ពុំមានទំនាក់ទំនងគួរឱ្យជឿបាន"ទៅនឹងបទឧក្រិដ្ឋដែល នួន ជា ត្រូវបានសម្រេចដាក់ពិរុទ្ធភាព[178]។ ជាការកត់សម្គាល់ ក្រៅតែពីការលើកបង្ហាញដោយបំភ័ន្ត និងដោយត្រួសៗ នួន ជា ពុំបានបង្ហាញថា ជម្លោះផ្ទៃក្នុងនៅក្នុង ប.ក.ក. រួមទាំងតួនាទីរបស់វៀតណាមក្នុងការគាំទ្រសកម្មភាពបះបោរនោះ អាចមានឥទ្ធិពលលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់នៅក្នុងសំណុំរឿង ០០២/០១ ឡើយ[179]។

៨០.នួន ជា បានឆ្លើយតបថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពុំបានបង្ហាញអំពីសិទ្ធិរបស់ខ្លួនដែលអាចធ្វើបណ្ដឹងសាទុក្ខបាន និងថា នៅគ្រប់កាលៈទេសៈទាំងអស់ អំណះអំណាងរបស់ពួកគេ គ្មានមូលដ្ឋានគាំទ្រឡើយ[180]។ នួន ជា ក៏បានអះអាងបន្ថែមទៀតថា សហព្រះរាជអាជ្ញាពុំបានយោងទៅលើបទដ្ឋានត្រឹមត្រូវក្នុងការទទួលយកភស្តុតាងថ្មីនៅដំណាក់កាលបណ្ដឹងសាទុក្ខ និងពុំបានដោះស្រាយលើអំណះអំណាងរបស់គាត់ទាំងមូលឡើយ[181]។

៨១.បញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយអំណះអំណាងរបស់ នួន ជា ដែលថា សហ

---

[177] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/5) កថាខណ្ឌ ៤, ៧ និង ៤១ ដល់ ៤២។

[178] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/5) កថាខណ្ឌ ២ និង ៤៥។

[179] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/5) កថាខណ្ឌ ៥, ១៩, ២៦ ដល់ ២៧, ៣៩ និង ៤៤។

[180] ការឆ្លើយតបរបស់ នួន ជា ទៅនឹងសារណាតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណុំទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/4) កថាខណ្ឌ ៤ ។ *សូមមើលផងដែរ* កថាខណ្ឌ ៥ ដល់ ១៧។

[181] ការឆ្លើយតបរបស់ នួន ជា ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/6) កថាខណ្ឌ ៨, ១០ និង ១៤។ *សូមមើលផងដែរ* កថាខណ្ឌ ៦ ដល់ ៧ និង ១១ (ក្នុងនោះ នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលស្ដីបន្ទោសសហព្រះរាជអាជ្ញាចំពោះការប្រើប្រាស់ពាក្យពេចន៍"មាក់ងាយ" និង"ភាសាធ្វើឱ្យខឹងសម្បា")។ សេចក្ដីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើភាពអាចជឿជាក់បានរបស់សាក្សី (F28/4) ទំព័រ ៦ ដល់ ៧ (អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយការតវ៉ានេះនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើសំណើសុំបំពេញកិច្ចស៊ើបសួរនេះរួចហើយ)។

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំមានសិទ្ធិឆ្លើយតបទៅនឹងសំណើទីប្រាំមួយរបស់គាត់សុំដាក់ភស្តុតាងបន្ថែម។ នៅក្នុងសំណើនេះ អង្គជំនុំជម្រះយល់ស្របជាមួយ នួន ជា ត្រង់ចំណុចដែលថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំបានផ្តល់មូលដ្ឋានគាំទ្រ ថាតើសារណារបស់ខ្លួនស្របតាមគោលការណ៍ដូចបានកំណត់នៅក្នុងយុត្តិសាស្ត្រមុនៗយ៉ាងដូចម្តេចឡើយ[182] ដូចជា ថាតើសំណើរបស់ នួន ជា មានផលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួនយ៉ាងដូចម្តេចឡើយ។ ការគ្រាន់តែយោងទៅលើភាពចាំបាច់ដើម្បីធានាបាននូវ"តុល្យភាពរបស់ភាគី" មានលក្ខណៈជាទូទៅពុំអាចបំពេញតាមលក្ខខណ្ឌតម្រូវ បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានសាលក្រមទាន់ពេលវេលាក៏ដោយ[183]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល ពុំពិចារណាលើសារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/1) ឡើយ។

៨២.ទាក់ទងទៅនឹងមូលដ្ឋានគាំទ្រ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នួន ជា ពុំបានបង្ហាញថា ភស្តុតាងដែលបានស្នើឡើងឱ្យទទួលយកនោះ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ឡើយ។ ហេតុផលជាឫសគល់ និងផលវិបាកនៃសកម្មភាពមួយចំនួនអាចជាកម្មវត្ថុសមស្របក្នុងការពិចារណាពាក់ព័ន្ធទៅនឹងប្រវត្តិនៃព្រឹត្តិការណ៍ ប៉ុន្តែពុំមានអានុភាពចំពោះការទទួលខុសត្រូវផ្នែក*ព្រហ្មទណ្ឌ*ឡើយ ប៉ុន្តែជាការទទួលខុសត្រូវផ្នែកសីលធម៌របស់បុគ្គលប៉ុណ្ណោះ។ បើទោះបីសន្មតថា ភស្តុតាងដែលបានស្នើឡើងនោះបង្ហាញថា វៀតណាមមានផែនការផ្តួលរំលំការដឹកនាំរបស់ ប៉ុល ពត និង នួន ជា នៅក្នុង ប.ក.ក. តាមរយៈការជួយដល់ការបះបោរផ្ទៃក្នុង ឬការឈ្លានពានដោយផ្ទាល់លើប្រទេសកម្ពុជាក៏ដោយ ក៏ នួន ជា ពុំបានបង្ហាញ ថាតើទាំងអស់នេះមានឥទ្ធិពលលើការយល់ឃើញណាមួយ ដែលជាមូលដ្ឋាននៃការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋជាក់លាក់ និងទម្រង់នៃការទទួលខុសត្រូវនៅក្នុងសំណុំរឿង ០០២/០១ ដែរ ឬយ៉ាងណា។ ដូចបានលើកឡើងខាងលើ បើទោះបីជាមានសកម្មភាពត្រៀមប្រឆាំងបានកើតឡើងយ៉ាងទូលំទូលាយក៏ដោយ ក៏ការបែកបាក់ជាសក្តានុពលនៅក្នុង ប.ក.ក. ពុំត្រូវបានចាត់ទុកជាធាតុផ្សំសំខាន់ឡើយ លើកលែងតែអាចបដិសេធធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវបាន[184]។ បន្ថែមលើនេះ សាក្សីទី ៥ កែវ លឿ សាក្សីទី ៦ សាក្សីទី ៧ ឡុត សួយ និងសាក្សី 2-TCW-918 បានសំដៅលើសកម្មភាពដែលបានកើតឡើងនៅចុងឆ្នាំ ១៩៧៦ ១៩៧៧ ឬ

---

[182] សេចក្តីសម្រេចលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី (F10/2) កថាខណ្ឌ ១៤ និង ១៧។

[183] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើទីប្រាំមួយសុំដាក់ភស្តុតាងបន្ថែម (F2/8/1) កថាខណ្ឌ ៣២។

[184] *សូមមើលខាងលើ* កថាខណ្ឌ ៤៥ ដល់ ៤៩។

១៩៧៨ ដោយគ្មានទំនាក់ទំនងច្បាស់លាស់ទៅនឹងអំឡុងពេលពីដំបូងណាមួយ ឬវិសាលភាពនៃបទចោទនានានោះទេ[185]។ បន្ថែមលើនេះទៀត បើទោះបីជាសាក្សី សែម ហឿន បានផ្តល់សក្ខីកម្មអំពីចលនាបះបោរសម្ងាត់បានកើតឡើងក្នុងឆ្នាំ ១៩៧៥[186]ក៏ដោយ ក៏ពុំមានការបញ្ជាក់ថា ឃ្លាំងទុកអាវុធសម្ងាត់ដែល សែម ហឿន បានលើកឡើងបង្ហាញថា ក្រុមបះបោរដែលមានសក្តានុពលនោះលែងអនុវត្តតាមគោលនយោបាយរបស់ ប.ក.ក. តទៅទៀតឡើយ។ ទាក់ទងទៅនឹងឯកសារដែលចេញពីរដ្ឋាភិបាលបរទេស ក្រៅតែពីភាពអាចរកបានឯកសារនេះនៅពេលជំនុំជម្រះ ដូចសហព្រះរាជអាជ្ញាបង្ហាញយ៉ាងត្រឹមត្រូវ[187] ឯកសារនេះពុំជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងដែលជាមូលដ្ឋានក្នុងការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា នោះ។

៨៣.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងដែលបានលើកឡើងនៅក្នុងសំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) ពុំអាចធ្វើជាកត្តាកំណត់នៅពេលជំនុំជម្រះ និងពុំអាចជួយស្វែងរកការពិតបាននោះឡើយ។ អាស្រ័យហេតុនេះ សំណើនេះត្រូវបដិសេធចោល។

## ៣.បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ

៨៤.វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចែងថា មូលដ្ឋាននៃបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង គឺជា"កំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រម [...] ឬកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌"[188]។ ម្ចាស់បណ្តឹងសាទុក្ខក្នុងរឿងក្តីបច្ចុប្បន្នបានលើកឡើងពីកំហុសទាំងពីរ គឺកំហុសអង្គច្បាប់ និង កំហុសអង្គហេតុ ហើយលើសពីនេះទៅទៀត ម្ចាស់បណ្តឹងសាទុក្ខក៏បានជំទាស់ផងដែរទៅនឹងការសម្រេចមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចរិតលក្ខណៈ

---

[185] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ៧២, ៧៩ និង ៨២ (កែវ ឈឿ បានរៀបរាប់ថា បានឃើញឡានដឹកអាវុធពាក់ព័ន្ធទៅនឹងប្រជុំមួយដែល អឿន ជាអ្នករៀបចំ និងថា អឿន ត្រូវបានចាប់ខ្លួននៅយប់បន្ទាប់ពីការប្រជុំនោះ។ សំអាងលើកាលបរិច្ឆេទនៃការចាប់ខ្លួនរបស់ អឿន ការឃើញរបស់ កែវ ឈឿ អាចនៅដើមឆ្នាំ ១៩៧៧)។ *សូមមើលផងដែរ* កថាខណ្ឌ ១០០, ១០៤, ១០៨ ដល់ ១០៩ និង ១១១។

[186] ឯកសារភ្ជាប់ ៥៖ ឯកសារលេខ E1/320.1 *ប្រតិចារឹករបស់ សែម ហឿន ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារលេខ F2/8.1.5 ទំព័រ ៨ ដល់ ៩។

[187] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំដាក់ភស្តុតាងបន្ថែម (F2/8/5) កថាខណ្ឌ ៩៥ ដល់ ៩៧ និង ១០៥។

[188] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

នៃនីតិវិធី ដែលបានធ្វើឡើងក្នុងអំឡុងពេលសវនាការ។ អង្គជំនុំជម្រះតុលាការកំពូល នឹងប្រើប្រាស់បទដ្ឋាននៃការពិនិត្យឡើងវិញនៅក្នុងនីតិវិធីលើបណ្តឹងសាទុក្ខនេះ ដើម្បីដោះស្រាយតាមប្រភេទនៃកំហុសទាំងនេះ។

## ៣.ក.ការចោទប្រកាន់អំពីកំហុសអង្គច្បាប់

៨៥.ទាក់ទងទៅនឹងការចោទប្រកាន់អំពីកំហុសអង្គច្បាប់ នៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28) ដោយបានយោងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា៖

> នៅពេលភាគីលើកឡើងនូវទឡ្ហីករណ៍ណាមួយ អង្គជំនុំជម្រះតុលាការកំពូល ដែលជាតុលាការចុងក្រោយវិនិច្ឆ័យលើអង្គច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក. ជាគោលការណ៍ ត្រូវបានចងកាតព្វកិច្ចក្នុងការសម្រេច ថាតើកំហុសអង្គច្បាប់ត្រូវបានប្រព្រឹត្តឡើងយ៉ាងជាក់ស្តែងលើបញ្ហានីតិវិធី ឬអង្គសេចក្តី ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល ត្រូវពិនិត្យលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីបញ្ហាអង្គច្បាប់ ដើម្បីសម្រេច ថាតើការយល់ឃើញទាំងនេះ ត្រឹមត្រូវ ដែរ ឬយ៉ាងណា ដោយមិនគ្រាន់តែសម្រេចថា ការយល់ឃើញនោះ សមហេតុផល ដែរ ឬយ៉ាងណានោះទេ[189]។

៨៦.អង្គជំនុំជម្រះតុលាការកំពូលក៏បានលើកឡើងផងដែរថា៖

> នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា មានកំហុសអង្គច្បាប់នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលកើតចេញពីការភ័ន្តច្រឡំក្នុងការអនុវត្តនូវបទដ្ឋានផ្លូវច្បាប់នោះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់នូវបទដ្ឋានផ្លូវច្បាប់ដ៏ត្រឹមត្រូវមួយ ហើយត្រូវពិនិត្យឡើងវិញ នូវផ្នែកសំអាងហេតុដែលពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូង។ ការធ្វើបែបនេះ អង្គជំនុំជម្រះតុលាការកំពូល មិនត្រឹមតែកែតម្រូវកំហុសអង្គច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តនូវបទដ្ឋានផ្លូវច្បាប់ដោយត្រឹមត្រូវចំពោះភស្តុតាង ដែលមាននៅក្នុងកំណត់ហេតុនៃការជំនុំជម្រះ ហើយក្នុងករណីចាំបាច់ត្រូវកំណត់ ថាតើខ្លួនជឿជាក់លើបទដ្ឋានពាក់ព័ន្ធនៃការបង្ហាញភស្តុតាងទាក់ទងទៅនឹងសំអាងហេតុដែលត្រូវបានជំទាស់ដោយភាគីណាមួយ នៅមុនពេលដែលសំអាងហេតុនេះ ត្រូវបានទទួលយកនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលអាចកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបាន តែក្នុងករណីដែលខ្លួនរកឃើញថា មានកំហុសអង្គច្បាប់ដែល"នាំឱ្យសាលក្រម ឬសេចក្តីសម្រេចមោឃៈ"។ ប៉ុន្តែ មិនមែនរាល់កំហុសអង្គច្បាប់ទាំងអស់សុទ្ធ

---

[189] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១៤។

តែតម្រូវឱ្យមានការបដិសេធ ឬការកែប្រែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ[190]។

៨៧.ពុំមានភាគីណាមួយនៅក្នុងបណ្ដឹងសាទុក្ខបច្ចុប្បន្ន បានជំទាស់ទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងទៅនឹងកំហុសអង្គច្បាប់ ដែលរងការជំទាស់ឡើយ។ អង្គជំនុំជម្រះរកពុំឃើញមូលហេតុណាមួយ ក្នុងការងាកចេញពីបទដ្ឋាននេះ នៅពេលដោះស្រាយលើការចោទប្រកាន់ក្នុងបណ្ដឹងសាទុក្ខបច្ចុប្បន្ននេះឡើយ។

## ៣.ខ.ការចោទប្រកាន់អំពីកំហុសអង្គហេតុ

៨៨.ទាក់ទងទៅនឹងការចោទប្រកាន់អំពីកំហុសអង្គហេតុនៅក្នុងសាលដីកា *រឿងក្ដី ឌុច* (001-F28) ដោយបានយោងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY អង្គជំនុំជម្រះតុលាការកំពូលបានអះអាងថា៖

> អនុវត្តបទដ្ឋាននៃភាពសមហេតុផលក្នុងការពិនិត្យឡើងវិញនូវផ្នែកសំអាងហេតុ ដែលរងការជំទាស់ ប៉ុន្តែមិនគិតថា សំអាងហេតុនោះត្រឹមត្រូវ ឬមានកំហុសនោះទេ។ ដើម្បីសម្រេច ថាតើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ស្រប ឬមិនស្របទៅនឹងសំអាងហេតុរបស់តុលាការអង្គហេតុដែលមានលក្ខណៈសមហេតុផលណាមួយនោះ អង្គជំនុំជម្រះតុលាការកំពូល“មិនត្រូវប៉ះពាល់បន្តិចណាឡើយ ដល់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង”[191]។

៨៩.អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា អង្គជំនុំជម្រះបានយល់ស្របជាមួយនឹងវិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ចំពោះការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង[192]ដែលអង្គជំនុំជម្រះបានបញ្ជាក់ដូចខាងក្រោម៖

> យោងតាមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មទានា ការស្ដាប់ ការវាយតម្លៃ និងការថ្លឹងថ្លែងភស្តុតាងដែលបង្ហាញនៅពេលជំនុំជម្រះ ជាចម្បង គឺជាកិច្ចការរបស់អង្គជំនុំជម្រះសាលាដំបូង។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកជាបានការនូវការយល់ឃើញផ្នែកអង្គហេតុដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង។ លើកលែងតែភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងយកមកសំអាងនោះ មិនអាចទទួលយកបាន ដោយតុលាការឧក្រិដ្ឋកម្មណាមួយដែលវិនិច្ឆ័យលើភាពសមហេតុផលនៃអង្គហេតុ ឬលើកលែងតែការវាយតម្លៃលើភស្តុតាងនោះមាន“ការភ័ន្តច្រឡំទាំងស្រុង”

---

[190] សាលដីកា *រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ១៦។

[191] សាលដីកា *រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ១៧។

[192] សាលដីកា *រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ១៧។

ទើបអង្គជំនុំជម្រះតុលាការកំពូលអាចដាក់ការយល់ឃើញរបស់ខ្លួនជំនួសការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបាន។

[…]

មូលហេតុបានបង្ហាញឱ្យឃើញច្បាស់លាស់ថា អង្គជំនុំជម្រះតុលាការកំពូលមិនត្រូវប៉ះពាល់ដល់ការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះសាលាដំបូងមានអាទិភាពជាង ក្នុងការពិនិត្យលើសាក្សីដោយផ្ទាល់ ដូច្នេះ ស្ថិតនៅក្នុងតួនាទីមួយដែលប្រសើរជាងអង្គជំនុំជម្រះតុលាការកំពូល ក្នុងការវាយតម្លៃលើភាពដែលគួរឱ្យជឿទុកចិត្តបាន និងជឿជាក់បាននៃភស្តុតាង។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានតួនាទីចម្បងក្នុងការកំណត់ ថាតើសាក្សីណាមួយគួរឱ្យជឿបាន ហើយសម្រេច ថាតើសក្ខីកម្មរបស់សាក្សីណាដែលខ្លួនចង់ស្តាប់ ដោយមិនចាំបាច់បញ្ជាក់ពីដំណាក់កាលនីមួយៗនៃសំអាងហេតុ ក្នុងការសម្រេចសេចក្តីលើចំណុចទាំងនេះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ឆន្ទានុសិទ្ធិនេះត្រូវបានប្រើប្រាស់ក្នុងកម្រិតនៃកាតព្វកិច្ចរបស់ខ្លួន ក្នុងការផ្តល់នូវសំអាងហេតុ [...][193]។

៩០.អាស្រ័យហេតុនេះ ចំណុចចាប់ផ្តើមដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើការវាយតម្លៃទៅលើភាពសមហេតុផលនៃការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង គឺការផ្តល់ជាសំអាងហេតុក្រោយពីការវិភាគលើអង្គហេតុ ដូចជាទាក់ទងទៅនឹងផ្នែកនីមួយៗនៃភស្តុតាងដែលចោទជាបញ្ហានោះ។ ជាពិសេស នៅ

[193] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១៧ ដកស្រង់សាលដីកា*រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៣០ និង ៣២។ *សូមមើលផងដែរ* សាលដីកា*រឿងក្តី Ntagerura* (ICTR) កថាខណ្ឌ ១២ និង ២១៣។ សាលដីកា*រឿងក្តី Kajelijeli* (ICTR) កថាខណ្ឌ ៥០។ សាលដីកា*រឿងក្តី Rutaganda* (ICTR) កថាខណ្ឌ ២១ (“ការទទួលយកជាបានការ ត្រូវបានផ្អែកយ៉ាងសំខាន់លើការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងមានតួនាទីសំខាន់ក្នុងការសង្កេតសាក្សីដោយផ្ទាល់ និងស្តាប់សាក្សីនៅពេលផ្តល់សក្ខីកម្មនោះ និងតួនាទីប្រសើរក្នុងការជ្រើសរើសរវាងការរៀបរាប់ខុសគ្នាពីព្រឹត្តិការណ៍ និងដូចព្រឹត្តិការណ៍”)(ជើងទំព័រលុបចោល)។ សាលដីកា*រឿងក្តី Simba* (ICTR) កថាខណ្ឌ ៩។ សាលដីកា*រឿងក្តី Munyakazi* (ICTR) កថាខណ្ឌ ៨។ សាលដីកា*រឿងក្តី Mrkšić* (ICTY) កថាខណ្ឌ ១៤ (“កាតព្វកិច្ចក្នុងការស្តាប់ ការវាយតម្លៃ និងការថ្លឹងថ្លែងភស្តុតាងដែលត្រូវបានបង្ហាញនៅពេលជំនុំជម្រះ ត្រូវផ្តល់ជាចម្បងទៅឱ្យអង្គជំនុំជម្រះសាលាដំបូង”) (ដកស្រង់សាលដីកា*រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៣០) និងកថាខណ្ឌ ៣០៦ (“ដោយសារអង្គជំនុំជម្រះសាលាដំបូងមានតួនាទីពិសេសក្នុងការថ្លឹងថ្លែងអាកប្បកិរិយារបស់សាក្សីផ្តល់សក្ខីកម្ម នៅពេលមានការជំទាស់ផ្នែកអង្គហេតុពាក់ព័ន្ធទៅនឹងបញ្ហានៃភាពអាចជឿជាក់បានរបស់សាក្សីនោះ ការទទួលយកជាបានការនូវការសម្រេចរបស់តុលាការអង្គហេតុ គឺការសមស្របបំផុត”)។ សាលដីកា*រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ២៩៣។ សាលដីកា*រឿងក្តី Krstić* (ICTY) កថាខណ្ឌ ៤០។ សាលដីកា*រឿងក្តី Blaškić* (ICTY) កថាខណ្ឌ ១៧។

ពេលដែលប្រឈមទៅនឹងបញ្ហាភស្តុតាងដែលមិនស៊ីសង្វាក់គ្នា ឬឯកសារដែលពុំសូវមានតម្លៃជាភស្តុតាង (ដូចជាចម្លើយនៅក្រៅតុលាការ ឬភស្តុតាងចចាមអារ៉ាម) ការពន្យល់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហា ថាតើសាលាដំបូងអាចឈានដល់ការធ្វើសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុដែលសំអាងលើភស្តុតាងទាំងនេះដោយរបៀបណានោះ គឺទំនងជាមានសារៈសំខាន់សម្រាប់ធ្វើការវាយតម្លៃ ថាតើសេចក្តីសន្និដ្ឋាននេះ សមហេតុផល ដែរ ឬយ៉ាងណា។ ស្របតាមវិធានទូទៅ ក្នុងករណីភស្តុតាងដែលជាមូលដ្ឋាន មើលទៅទំនងជាមានកម្រិតទាប គឺតម្រូវឱ្យផ្តល់សំអាងហេតុឱ្យបានច្រើនជាង នៅពេលដែលភស្តុតាងនោះមានមូលដ្ឋានសំអាងត្រឹមត្រូវ។ ដូចគ្នានេះដែរ អំណះអំណាងដែលមានកម្រិតត្រឹមតែជំទាស់ទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង និងសារណាដែលបានផ្អែកទៅលើការបកស្រាយភស្តុតាងដដែល ដោយពុំបានលើកអំណះអំណាងគាំទ្រផ្សេងទៀតនោះ ពុំគ្រប់គ្រាន់សម្រាប់បដិសេធការយល់ឃើញផ្នែកអង្គហេតុរបស់តុលាការអង្គហេតុបានឡើយ[194]។

---

[194] សាលដីកា *រឿងក្តី Kalimanzira* (ICTR) កថាខណ្ឌ ៥០។ សាលដីកា *រឿងក្តី Kamuhanda* (ICTR) កថាខណ្ឌ ២៥២ និង ៣៣៧ ("ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែស្នើសុំដាក់ការវាយតម្លៃផ្ទាល់ខ្លួនលើភស្តុតាង ជំនួសការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានបង្ហាញ ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមិនសមហេតុផល ឬមានកំហុសទាំងស្រុង ដែរ ឬយ៉ាងណាឡើយ។ ការធ្វើបែបនេះ មិនអាចក្លាយជាមូលដ្ឋានសម្រាប់បណ្តឹងសាទុក្ខបានឡើយ")។ សាលដីកា *រឿងក្តី Niyitegeka* (ICTR) កថាខណ្ឌ ២៥៦ (បដិសេធអំណះអំណាងដែលគ្រាន់តែស្នើសុំការ"ការបកស្រាយមួយផ្សេងនៃភស្តុតាងប៉ុណ្ណោះ")។ សាលដីកា *រឿងក្តី Ntabakuze* (ICTR) កថាខណ្ឌ ២៥៤ (បដិសេធអំណះអំណាងពីព្រោះម្ចាស់បណ្តឹងសាទុក្ខ"គ្រាន់តែស្នើសុំដាក់ការវាយតម្លៃរបស់ខ្លួនលើភស្តុតាង ជំនួសការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងដោយគ្មានការបង្ហាញនូវកំហុសជាក់លាក់ណាមួយឡើយ")។ សាលដីកា *រឿងក្តី D.Milošević* (ICTY) កថាខណ្ឌ ១០១ ("ក្នុងករណីដែលម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែស្នើសុំដាក់ការវាយតម្លៃផ្ទាល់ខ្លួនលើភស្តុតាងជំនួសការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានព្យាយាមបង្ហាញកំហុសជាក់លាក់ណាមួយ សារណាបែបនេះត្រូវបានបដិសេធចោលដោយពុំចាំបាច់ពិនិត្យបន្តទៀតឡើយ")។ សាលដីកា *រឿងក្តី Orić* (ICTY) កថាខណ្ឌ ១៣។ សាលដីកា *រឿងក្តី Hadžihasanović* (ICTY) កថាខណ្ឌ ១៦៩ ("អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការថ្លឹងថ្លែងភស្តុតាងសាក្សីផ្សេងៗក្នុងពេលសវនាការ និងរំឭកថា ការអះអាងរបស់ភាគីដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីជឿជាក់សាក្សីមួយណាជាងនោះ គឺ*ពុំមែនជាការជំទាស់ទាល់តែសោះ*ឡើយ"[ពាក្យដើម])(ដកស្រង់សាលដីកា *រឿងក្តី Galić* (ICTY) កថាខណ្ឌ ៣០០)។ សាលដីកា *រឿងក្តី Strugar* (ICTY) កថាខណ្ឌ ២១ (ចាត់ទុកការបដិសេធដោយពុំចាំបាច់ពិចារណាបន្តទៀត ជាការសមស្រប"ក្នុងករណីដែលម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែស្នើសុំដាក់ការវាយតម្លៃរបស់ខ្លួនលើភស្តុតាងជំនួសការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង ឬអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចយោងទៅលើសេចក្តីសន្និដ្ឋានមួយចំនួនចេញពីភស្តុតាងមិនផ្ទាល់ ដោយគ្មានបានផ្តល់ការអះអាង ឬការពន្យល់ពីមូលហេតុអ្វីបានជាមិនសមហេតុ និងថា

៩១.ទាក់ទងទៅនឹងបញ្ហា ថាតើកំហុសអង្គហេតុបណ្ដាលឱ្យមានភាពមិនយុត្តិធម៌នៅពេលណានោះ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា គឺត្រូវតែបង្ហាញឱ្យឃើញ"ថា កំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្កើតឱ្យមានវិមតិសង្ស័យសមហេតុផលមួយទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ"[195]។

៩២.នួន ជា បានជំទាស់ទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងទៅនឹងការចោទប្រកាន់អំពីកំហុសអង្គហេតុ[196] ដូចបានលើកឡើងនៅក្នុងសាលដីកា*រឿងក្ដី ឌុច* (001-F28)។ នៅក្នុងសារណារបស់ នួន ជា បានឱ្យដឹងថា អនុលោមតាមមាត្រា ៩ ថ្មី នៃច្បាប់ អ.វ.ត.ក. ចែងថា អង្គជំនុំជម្រះតុលាការកំពូល"ដែលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផង និងសម្រេចសេចក្ដីចុងក្រោយផង" តួនាទីរបស់អង្គជំនុំជម្រះនេះ គឺត្រូវធ្វើការពិនិត្យឡើងវិញលើបណ្ដឹងឧទ្ធរណ៍ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលរួមបញ្ចូលការពិនិត្យឡើងវិញដោយធ្វើការជំនុំជម្រះ*សាជាថ្មី*លើអង្គហេតុ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចចុងក្រោយ[197]។ នួន ជា បានអះអាងថា ខុសពីតុលាការ ICTY និងយុត្តិសាស្ត្រនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ពុំមានមូលហេតុអ្វីដែលអង្គជំនុំជម្រះតុលាការកំពូល ទទួលយកជាបានការនូវការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ[198]។

៩៣.អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងដោយមិនសមហេតុផល។ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា នៅក្នុងសាលដីកា*រឿងក្ដី ឌុច* (001-F28) អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា "ដំណោះស្រាយដែលមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធនៃបណ្ដឹងសាទុក្ខមួយដែលមាន*លក្ខណៈពិសេស* (*sui generis*)"[199]។ អនុលោមតាមមាត្រា ៩ ថ្មីនៃច្បាប់ អ.វ.ត.ក. ពុំមែនមានន័យថា អង្គជំនុំជម្រះតុលាការកំពូលត្រូវតែជំនុំជម្រះ*សាជាថ្មី*ដោយផ្អែកតាមមាត្រា ៣៧៣ នៃ

---

អង្គជំនុំជម្រះគប្បីបានដកការសន្និដ្ឋានបែបនេះចេញ")(ជើងទំព័រលុបចោល)។ សាលដីកា*រឿងក្ដី Galić* (ICTY) កថាខណ្ឌ ២៩០។ សាលដីកា*រឿងក្ដី Vasiljević* (ICTY) កថាខណ្ឌ ១៦ ("អង្គជំនុំជម្រះតុលាការកំពូលពុំបានពិចារណាលើអំណះអំណាងទាំងនោះ ក្នុងករណីដែលម្ចាស់បណ្ដឹងសាទុក្ខពុំបានអះអាងអំពីកំហុស ផ្ទុយទៅវិញគ្រាន់តែផ្ដល់ការយោងទៅលើភស្តុតាងប៉ុណ្ណោះ")។ សាលដីកា*រឿងក្ដី Gatete* (ICTR) កថាខណ្ឌ ១៥៦។

[195] សាលដីកា*រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ១៨។

[196] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣ ដល់ ១១។

[197] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦។

[198] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១០។ *សូមមើលផងដែរ* កថាខណ្ឌ ៨ ដល់ ៩។

[199] សាលដីកា*រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ១៣។

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលខុសពីបណ្តឹងសាទុក្ខតាមមាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ ផ្ទុយទៅវិញ ប្រវត្តិនៃការតាក់តែងច្បាប់ អ.វ.ត.ក. ទាក់ទងទៅនឹងមាត្រា ៩ បានបង្ហាញថា គោលគំនិតដំបូងបានប្រមើលឃើញអំពីដំណើរការនីតិវិធីមានបីដំណាក់កាល ដែលក្នុងនោះប្រព័ន្ធស្តីពីការពិនិត្យឡើងវិញមានដូចជា សាលាឧទ្ធរណ៍ត្រូវស្តាប់បណ្តឹងឧទ្ធរណ៍ និងតុលាការកំពូលត្រូវស្តាប់បណ្តឹងសាទុក្ខ ហើយចុងក្រោយសាលាឧទ្ធរណ៍ត្រូវបានលុបចេញពីមាត្រា ៩ ថ្មីនេះ[200]។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានដ៏សមស្របមួយគឺថា ច្បាប់ អ.វ.ត.ក. បានកំណត់យកនីតិវិធីស្តីពីការពិនិត្យឡើងវិញមួយខុសប្លែកពីគេ រួមទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ។

៩៤.អាស្រ័យហេតុនេះ ដូចបានលើកឡើងនៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28) អង្គជំនុំជម្រះតុលាការកំពូលត្រូវបានអនុញ្ញាតដោយមាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង អ.វ.ត.ក.) ធ្វើការស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ទាក់ទងទៅនឹងវិសាលភាពនៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ ដូចមានចែងក្នុងវិធានផ្ទៃក្នុង[201] និងត្រូវស្វែងរកការណែនាំពីវិធីសាស្ត្រនានារបស់តុលាការ ICTY និង ICTR[202] ទាក់ទងទៅនឹងការពិនិត្យឡើងវិញចំពោះការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ ការបកស្រាយអំពី

---

[200] មាត្រា ៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ David Scheffer "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" M. Cherif Bassiouni (ed.) *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទី ៣ Koninklijke Brill NV ឆ្នាំ ២០០៨ ទំព័រ ២៤៧ ("អង្គជំនុំជម្រះតុលាការកំពូលជាកន្លែងសម្រាប់តែទទួលពាក្យបណ្តឹងឧទ្ធរណ៍មួយគត់សម្រាប់ អ.វ.ត.ក. ហើយសេចក្តីសម្រេចរបស់តុលាការនេះចូលជាស្ថាពរទាំងអង្គច្បាប់ និងអង្គហេតុ។ ច្បាប់ អ.វ.ត.ក. ដំបូង ត្រូវបានចរចាក្នុងឆ្នាំ ២០០០ និងបានអនុម័តក្នុងឆ្នាំ ២០០១ ចែងសម្រាប់អង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ភ្លាមៗនៅចន្លោះអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល។ ទោះជាយ៉ាងណាក្តី [...] វិសោធនកម្មលើច្បាប់ អ.វ.ត.ក. នេះដែលបានអនុម័តក្នុងឆ្នាំ ២០០៤ [...] បានដកអង្គជំនុំជម្រះឧទ្ធរណ៍ចេញពី អ.វ.ត.ក."(ជើងទំព័រលុបចោល)) ទំព័រ ២៥១ ("ច្បាប់ អ.វ.ត.ក. ផ្តល់សិទ្ធិអំណាចដល់អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក ក្នុងការ*សម្រេចលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក.*")។ របាយការណ៍របស់អគ្គលេខាធិការស្តីពីការកាត់ទោសខ្មែរក្រហម កថាខណ្ឌ ២៦ ([...] រចនាសម្ព័ន្ធបីថ្នាក់ដែលបានកំណត់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងអំឡុងពេលនៃការចរចាលើកដំបូងត្រូវបានកែប្រែមកពីរថ្នាក់ដែលសាមញ្ញជាង")។

[201] វិធាន ១០៤(១)*ស្ទួន* នៃវិធានផ្ទៃក្នុង។

[202] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១៣។

ដំណើរការនីតិវិធីដែលមានពីរដំណាក់កាល ដូចបានលើកឡើងនៅក្នុងឯកសារជាមូលដ្ឋានរបស់ អ.វ.ត.ក. ទទួលបានការគាំទ្រយ៉ាងច្រើន នៅពេលពិចារណាអំពីវិសាលភាពជាក់លាក់ និងភាពស្មុគស្មាញនៃការជំនុំជម្រះទាក់ទងទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានចោទប្រកាន់នោះ ទើបធ្វើឱ្យការជំនុំជម្រះ*សាជាថ្មី* ពុំអាចធ្វើទៅបាន និងពុំគួរធ្វើនៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ។ ការធ្វើបែបនេះអាចពន្យារពេលយ៉ាងច្រើនដល់កិច្ចដំណើរការនីតិវិធី។ លើសពីនេះទៀត ផ្អែកតាមទម្រង់នីតិវិធីដែលប្រើប្រាស់ការជំនុំជម្រះលើអង្គហេតុ*សាជាថ្មី* តុលាការនៃបណ្តឹងសាទុក្ខ មានសិទ្ធិអំណាចសមស្របក្នុងការពិនិត្យឡើងវិញយ៉ាងទូលំទូលាយ ដើម្បីកែប្រែសាលក្រមឱ្យស្របតាមអង្គហេតុដែលបានបង្ហាញយ៉ាងដូច្នោះ និងមានជម្រើសក្នុងការបង្វិលសំណុំរឿងឱ្យធ្វើការជំនុំជម្រះឡើងវិញបាន តាមរយៈបណ្តឹងសាទុក្ខដែលស្នើសុំឱ្យធ្វើការពិនិត្យឡើងវិញជាចុងក្រោយ។ ទម្រង់ប្រភេទនេះ បានសន្មតជាមុនថា កិច្ចដំណើរការនីតិវិធីរបស់តុលាការ ចេះតែបន្តរហូតទាល់តែអាចកំណត់បាននូវ"ការពិតជាសត្យានុម័ត"អំពីព្រឹត្តិការណ៍ដែលចោទជាបញ្ហានោះ។ ចំណែកនៅក្នុងបរិបទរបស់ អ.វ.ត.ក. ដោយសារកង្វះធនធាន បានរារាំងការប្រកាសពិរុទ្ធភាព និងទោសនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍[203] បូករួមជាមួយនឹងការហាមឃាត់ការបង្វិលសំណុំរឿងត្រឡប់ទៅតុលាការជាន់ដំបូងឱ្យជំនុំជម្រះឡើងវិញនោះ[204] គឺបានបង្ហាញនូវការផ្តោតទៅលើការពន្លឿនកិច្ចដំណើរការនីតិវិធី ដោយសារតួនាទីក្នុងការកែតម្រូវទៅលើដំណើរនីតិវិធីនៅបណ្តឹងឧទ្ធរណ៍ ត្រូវបានកម្រិត និងលុបចោល ក្នុងគោលបំណងដើម្បីការពារផលប្រយោជន៍ជនជាប់ចោទ និង/ឬមេធាវីការពារក្តី (ភាគីការពារក្តី)។ អាស្រ័យហេតុនេះ ដើម្បីឱ្យមានលក្ខណៈស្របទៅតាមទម្រង់នៃនីតិវិធីបណ្តឹងឧទ្ធរណ៍របស់ អ.វ.ត.ក. គឺត្រូវពិនិត្យមើលលើតួនាទីរបស់អង្គជំនុំជម្រះតុលាការកំពូល បន្ថែមពីលើការកែតម្រូវកំហុសអង្គច្បាប់ជាចម្បង ក្នុងការពិនិត្យផ្ទៀងផ្ទាត់លើបញ្ហា ថាតើលក្ខខណ្ឌក្នុងការបង្ហាញធាតុផ្សំនៃបទចោទត្រូវបានបំពេញ ដែរ ឬយ៉ាងណា ជាជាងការបើកសវនាការថ្មីដែល ហើយយកការយល់ឃើញផ្ទាល់របស់ខ្លួន មកជំនួសការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងវិញ។ ទម្រង់នីតិវិធីដែល នួន ជា

---

[203] វិធាន ១១០ និង ១១១ នៃវិធានផ្ទៃក្នុង ភ្ជាប់ជាមួយនឹងមាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ *សូមមើល ឧ. រឿងក្តី Gomariz ទល់នឹង ប្រទេសអេស្ប៉ាញ* (លិខិតទំនាក់ទំនងរបស់គណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស) កថាខណ្ឌ ១៣៩ ("បើទោះបីជាបុគ្គលដែលត្រូវបានសម្រេចឱ្យរួចខ្លួននៅដំណាក់ដំបូង អាចត្រូវបានសម្រេចដាក់ពិរុទ្ធភាពនៅដំណាក់កាលបណ្តឹងសាទុក្ខដោយតុលាការបណ្តឹងសាទុក្ខក៏ដោយ ក៏កាលៈទេសៈនេះមិនអាចរារាំងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការពិនិត្យឡើងវិញលើការដាក់ពិរុទ្ធភាព និងការប្រកាសទោសនេះពីតុលាការជាន់ខ្ពស់បានឡើយ បើទោះបីជារដ្ឋភាគីពុំត្រូវបានចងកាតព្វកិច្ចក៏ដោយនោះ")។

[204] មាត្រា ៣៦ ថ្មីនៃច្បាប់ អ.វ.ត.ក.។

អះអាងក្នុងការបកស្រាយចេញពីមាត្រា ៩ ថ្មី អាចនឹងផ្តល់ផលប្រយោជន៍ដល់ភាគីការពារក្តី ប៉ុន្តែពុំបានធ្វើឱ្យមានប្រសិទ្ធភាព និងតុល្យភាពទាំងស្រុងឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានមូលដ្ឋានសំអាងណាមួយសម្រាប់ភាគីការពារក្តីនៅក្នុងខ្លឹមសារនៃមាត្រា ៩ ថ្មី ឬនៅក្នុងគោលបំណងនៃច្បាប់ អ.វ.ត.ក. ឡើយ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបដិសេធនូវការលើកឡើងរបស់ នួន ជា ដែលថា ដោយសារតែក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានយកលំនាំតាមប្រភពដើមនៃប្រព័ន្ធច្បាប់ស៊ីវិល (Romano-Germanic) ទើប"សារៈសំខាន់របស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ក្នុងនាមជាអ្នកស្វែងរកការពិតបានថយចុះ [...]"[205]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដូចរឿងក្តីនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលដទៃទៀតដែរ ដែលបានកម្រិតការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ចំពោះការយល់ឃើញផ្នែកអង្គហេតុ[206]បានធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ក្លាយជាតុលាការជាន់ដំបូងមួយដ៏សំខាន់ដែលមានភារកិច្ចក្នុងការយល់ឃើញផ្នែកអង្គហេតុ។ ចុងក្រោយ ដូច នួន ជា បានអះអាង[207]ដែលថា អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តីបច្ចុប្បន្ន បានផ្អែកយ៉ាងច្រើនទៅលើភស្តុតាងក្រៅតុលាការ និងថា ទឡ្ហីករណ៍ជាច្រើននៃបណ្តឹងសា

---

[205] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១០។

[206] បទប្បញ្ញត្តិប្រហាក់ប្រហែលគ្នានេះមាននៅក្នុងមាត្រា ៤៥២(១)នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសប៉ូឡូញ ("តុលាការឧទ្ធរណ៍ពុំត្រូវបានអនុញ្ញាតឱ្យបើកសវនាការលើភស្តុតាងទាក់ទងទៅនឹងចរិតលក្ខណៈពិសេសនៃសំណុំរឿងឡើយ") ផ្នែក ៥៦៩(៣)នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់សាធារណរដ្ឋ Latvia ("តុលាការជាន់ខ្ពស់ពុំអាចវាយតម្លៃលើភស្តុតាងនៅក្នុងសំណុំរឿង*សាឡើងវិញ*បានឡើយ") មាត្រា ៣៩៧.២ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេស Azerbaijan ("អង្គហេតុដែលបានបង្ហាញដោយតុលាការជាន់ដំបូងត្រូវតែពិនិត្យឡើងវិញដោយតុលាការឧទ្ធរណ៍ក្នុងដែនកំណត់នៃពាក្យបណ្តឹង ឬបណ្តឹងសាទុក្ខតែប៉ុណ្ណោះ") មាត្រា ២៩៧(ខ)នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេស Georgia ("ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ មានតែភស្តុតាងដែលស្នើដាក់ថ្មីនៅចំពោះមុខតុលាការឧទ្ធរណ៍ប៉ុណ្ណោះ ដែលអាចយកមកពិនិត្យបាន ហើយរាល់ភស្តុតាងដែលបានពិនិត្យដោយតុលាការជាន់ដំបូងត្រូវបានចាត់ទុកបានពិនិត្យរួចហើយ លើកលែងករណីដែលភស្តុតាងត្រូវបានពិនិត្យដោយមានការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ ហើយភាគីមានសិទ្ធិដាក់សំណើសុំឱ្យពិនិត្យលើភស្តុតាងនេះសាឡើងវិញបាន")។ មាត្រា ៣៩៨(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេស Montenegro ("តុលាការឧទ្ធរណ៍ត្រូវកម្រិតការពិនិត្យឡើងវិញរបស់ខ្លួនត្រឹមតែការរំលោភបំពានដែលមានចែងនៅក្នុងកថាខណ្ឌ ១ ចំណុច ១ និង ២ នៃមាត្រានេះ")។ ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេស Macedonia មាត្រា ៤២៧(១) ("តុលាការឧទ្ធរណ៍ត្រូវពិនិត្យតែលើផ្នែកនៃសាលក្រមដែលត្រូវបានជំទាស់នៅដំណាក់បណ្តឹងឧទ្ធរណ៍") មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេស Ukraine ("ការពិនិត្យលើការជំនុំជម្រះដោយតុលាការឧទ្ធរណ៍ត្រូវធ្វើឡើងដោយស្របតាមជំពូក ២៦ នៃក្រមបច្ចុប្បន្ន តែក្នុងករណីពាក់ព័ន្ធទៅនឹងផ្នែកណាមួយនៃសាលក្រម ដែលភាពនីត្យានុកូលភាព និងសុពលភាពរបស់សាលក្រមនេះ ត្រូវបានជំទាស់នៅដំណាក់កាលបណ្តឹងសាទុក្ខប៉ុណ្ណោះ")។

[207] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨។

ទុក្ខរបស់គាត់ គឺជាប់ពាក់ព័ន្ធទៅនឹងកំហុសក្នុងការវាយតម្លៃលើភស្តុតាង[208]។ ទោះជាយ៉ាងនេះក្តី ពុំបានប៉ះពាល់ដល់បទដ្ឋាននៃការពិនិត្យឡើងវិញឡើយ។ ប្រសិនបើលើកផ្ទុយពីនេះ បទដ្ឋាននៃការពិនិត្យឡើងវិញលើកំហុសអង្គហេតុ គឺអាស្រ័យលើភាពជាក់លាក់នៃរឿងក្តីនីមួយៗ និងអំណះអំណាងដែលបានលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខ ដូច្នេះទឡ្ហីករណ៍នេះច្បាស់ណាស់គ្មានមូលដ្ឋានគាំទ្រឡើយ។

៩៥.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវវាយតម្លៃលើរាល់ការចោទប្រកាន់អំពីកំហុសអង្គហេតុ ទៅលើបទដ្ឋាននៃការពិនិត្យឡើងវិញ ដូចមាននៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28) ដែលបានសង្ខេបខាងលើ។

## ៣.គ.ការជំទាស់ទៅនឹងការសម្រេចស្តីពីចរិតលក្ខណៈនៃនីតិវិធី

៩៦.អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា នួន ជា និង ខៀវ សំផន បានជំទាស់ដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការសម្រេចមួយចំនួនពាក់ព័ន្ធទៅនឹងចរិតលក្ខណៈនៃនីតិវិធី ដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តក្នុងអំឡុងពេលជំនុំជម្រះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការជំទាស់នេះអាចត្រូវបានចាត់ទុកថា ជាការចោទប្រកាន់អំពីកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុ ហើយអាចត្រូវបានធ្វើឡើងដោយអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

៩៧.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងជាញឹកញាប់ បានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធី[209]។ ដោយស្របតាមគោលការណ៍ដែលបានកំណត់នៅក្នុងប្រយោគចុងក្រោយនៃវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល អនុវត្តវិធីសាស្ត្រក្នុងការពិនិត្យឡើងវិញដែលទទួលយកជាបានការនូវសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ និងធ្វើអន្តរាគមន៍ទៅលើការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង តែក្នុងករណីដែល“កំហុសស្តែងចេញពីការប្រើឆន្ទានុសិទ្ធិ [...] ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ”។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ICTR និងតុលាការ

---

208 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៩។

209 *សូមមើល* សេចក្តីសម្រេចលើសំណើសុំចំណាត់ការជាបន្ទាន់ (E189/3/1/8) កថាខណ្ឌ ២១ និង ២៦។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ (E163/5/1/13) កថាខណ្ឌ ៣០។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116/1/7) កថាខណ្ឌ ៣៣។

ICC បានអនុវត្តបទដ្ឋានក្នុងការពិនិត្យឡើងវិញដែលទទួលយកជាបានការនូវសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ[210]។ ជាឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានសម្រេចថា៖

> ៧៩. អង្គជំនុំជម្រះតុលាការកំពូល ពុំត្រូវជ្រៀតជ្រែកក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ [...] ពីព្រោះ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីដែលខ្លួនមានសិទ្ធិអំណាច អាចធ្វើការសម្រេចផ្សេងពីនេះ។ ការធ្វើដូច្នេះ គឺជាការដណ្ដើមយកអំណាច ដែលពុំត្រូវបានប្រគល់ឱ្យខ្លួន និងធ្វើឱ្យអំណាចដែលបានប្រគល់ឱ្យយ៉ាងពិសេសដល់អង្គបុរេជំនុំជម្រះប្រែក្លាយទៅជាគ្មានតម្លៃ។
>
> ៨០. [...] មុខងាររបស់អង្គជំនុំជម្រះតុលាការកំពូល បានរួមបញ្ចូលការពិនិត្យឡើងវិញលើការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ ដើម្បីធានាថា អង្គជំនុំជម្រះនេះត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលពុំត្រូវជ្រៀតជ្រែកក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះ [...] លើកលែងតែមានការបង្ហាញថា សេចក្ដីសម្រេចនោះត្រូវទុកជាមោឃៈ ដោយសារមានកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬកំហុសផ្នែកនីតិវិធី និងតែក្នុងករណីដែលកំហុសនេះ បានប៉ះពាល់ជាសត្យានុម័តលើសេចក្ដីសម្រេចនោះ តែប៉ុណ្ណោះ។ ន័យខាងដើមនេះបង្កើតអានុភាពថា អង្គជំនុំជម្រះតុលាការកំពូលត្រូវជ្រៀតជ្រែកក្នុងសេចក្ដីសម្រេចដែលផ្អែកលើឆន្ទានុសិទ្ធិ តែក្នុងលក្ខខណ្ឌមានកម្រិតប៉ុណ្ណោះ។ គោលជំហរនេះ ត្រូវបានគាំទ្រដោយយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត រួមទាំងយុត្តិសាស្ត្ររបស់តុលាការក្នុងស្រុកផងដែរ។ តុលាការទាំងនោះ បានកំណត់អំពីលក្ខខណ្ឌត្រឹមត្រូវក្នុងការធ្វើអន្តរាគមន៍នៅដំណាក់កាលបណ្ដឹងសាទុក្ខគឺ (១) នៅពេលដែលការប្រើប្រាស់ឆន្ទានុសិទ្ធិ មានកំហុសក្នុងការបកស្រាយច្បាប់ (២) នៅពេលដែលការប្រើប្រាស់ឆន្ទានុសិទ្ធិនេះ មានកំហុសយ៉ាងច្បាស់ក្នុងការកំណត់អង្គហេតុ ឬ (៣) សេចក្ដីសម្រេចដែលមានភាពមិនយុត្តិធម៌ និងពុំសមហេតុផល នាំឱ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិ[211]។

៩៨.អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និង ICTR បានដាក់ចេញនូវបទដ្ឋានដែលមានលក្ខណៈ

---

[210] *សូមមើលឧ.* សាលដីកា*រឿងក្ដី Kony* (ICC) កថាខណ្ឌ ៧៩ ដល់ ៨០។ សាលដីកា*រឿងក្ដី Krajišnik* (ICTY) កថាខណ្ឌ ៨១។ សាលដីកា*រឿងក្ដី Kupreškić* កថាខណ្ឌ ៣០ និង ៣២។ សាលដីកា*រឿងក្ដី Setako* (ICTR) កថាខណ្ឌ ១៩។ សាលដីកា*រឿងក្ដី Nchamihigo* (ICTR) កថាខណ្ឌ ១៨។

[211] សាលដីកា*រឿងក្ដី Kony* (ICC) កថាខណ្ឌ ៧៩ ដល់ ៨០ (ដើងទំព័រលុបចោល)។

ប្រហាក់ប្រហែលគ្នានេះ ក្នុងការពិនិត្យឡើងវិញលើសេចក្ដីសម្រេចដែលផ្អែកលើឆន្ទានុសិទ្ធិ[212]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បទដ្ឋានទទួលយកជាបានការក្នុងការពិនិត្យឡើងវិញ ដែលបានយកមកអនុវត្តដោយតុលាការឧក្រិដ្ឋកម្មទាំងនេះ មានលក្ខណៈសមស្របជាមួយនឹងបរិបទនៃ អ.វ.ត.ក. ហើយអង្គជំនុំជម្រះនឹងត្រូវធ្វើការវាយតម្លៃលើកំហុសដែលរងការចោទប្រកាន់ នៅក្នុងសេចក្ដីសម្រេចដែលផ្អែកលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងជាមួយនឹងបទដ្ឋាននេះ។

## ៣.ឃ.ឥទ្ធិពលនៃកំហុសនានាដែលធ្វើឱ្យប៉ះពាល់ដល់សាលក្រម

៩៩.អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ការកំណត់ត្រឹមតែអត្តសញ្ញាណនៃកំហុសនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជាការពុំគ្រប់គ្រាន់ ដើម្បីឈានទៅកែប្រែសាលក្រម នៅក្នុងនីតិវិធីនៃបណ្ដឹងសាទុក្ខបានឡើយ។ ផ្ទុយទៅវិញ សាលក្រមដែលមានកំហុសអង្គច្បាប់ត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកំហុសអង្គហេតុនោះបណ្ដាលឱ្យមានភាពមិនយុត្តិធម៌។ សាលក្រមមួយដែលអាចចាត់ទុកជាមោឃៈដោយសារកំហុសអង្គច្បាប់ ហើយប្រសិនបើកំហុសនោះមិនឈានទៅដល់មោឃៈសាលក្រមទេ នោះសាលក្រមអាចនឹងត្រូវបានសម្រេចកែប្រែការប្រកាសដាក់ពិរុទ្ធភាពទាំងស្រុង ឬផ្នែកខ្លះ[213]។ សាលក្រមដែលមានភាពមិនយុត្តិធម៌សំដៅលើន័យថា "លទ្ធផលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការមានភាពមិនយុត្តិធម៌ទាំងស្រុង"[214]។ ទាក់ទងទៅនឹងកំហុសអង្គហេតុ ដែលនាំឱ្យសាលក្រមមានភាពមិនយុត្តិធម៌ សំដៅលើ"កំហុសធ្ងន់ធ្ងរដល់ការប្រកាសអំពីពិរុទ្ធភាព"[215]។ ភាគីត្រូវមានកាតព្វកិច្ចបង្ហាញឱ្យឃើញ ថាតើកំហុសអង្គហេតុនោះពិតជាស្ដែងឱ្យឃើញភាពមិនយុត្តិធម៌ ដែរ ឬទេ។

---

[212] *សូមមើល ឧ.* សាលដីកា*រឿងក្ដី Šainović* (ICTY) កថាខណ្ឌ ២៩។ សាលដីកា*រឿងក្ដី Ndahimana* (ICTR) កថាខណ្ឌ ១៤។

[213] *សូមមើល ឧ.* សាលដីកា*រឿងក្ដី Popović* (ICTY) កថាខណ្ឌ ១៧ ("ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ដែលពុំមានឱកាសកែប្រែលទ្ធផលនៃការសម្រេច អាចត្រូវបានបដិសេធចោលដោយផ្អែកលើមូលហេតុនោះ")។ *សូមមើលផងដែរ* សាលដីកា*រឿងក្ដី Lubanga* (ICC) កថាខណ្ឌ ១៩ (កំហុសអង្គច្បាប់អាចនាំឱ្យមានការបដិសេធសាលក្រម ប្រសិនបើសាលក្រមនោះទទួលរងឥទ្ធិពល "ជាសត្យានុម័ត"ដោយសារកំហុសនោះ ដែលអាចនិយាយក្នុងករណីថា "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង*ចេញសាលក្រមមួយដែលខុសប្លែកគ្នាពីសេចក្ដីសម្រេចដែលមានកំហុសនោះ អង្គជំនុំជម្រះពុំមានកំហុសឡើយ*"។

[214] សាលដីកា*រឿងក្ដី Furundžija* (ICTY) កថាខណ្ឌ ៣៧ យោងតាមវចនានុក្រម Black's Law បោះពុម្ពលើកទី ៧ ឆ្នាំ ១៩៩៩។

[215] សាលដីកា*រឿងក្ដី Kupreškić* (ICTY) កថាខណ្ឌ ២៩។

១០០.ទាក់ទងទៅនឹងកំហុសអំពីចរិតលក្ខណៈនៃកិច្ចដំណើរការនីតិវិធី និងជាពិសេស កំហុសទាក់ទងទៅនឹងការប្រើប្រាស់ឆន្ទានុសិទ្ធិ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចែងពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខភ្លាមៗថា កំហុសនៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិ ត្រូវតែ"បណ្តាលឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ"។ នៅក្នុងបរិបទនៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែលត្រូវបានចេញនៅពេលបញ្ចប់នៃកិច្ចជំនុំជម្រះ ស្របតាមវិធាន ១០២ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាលើបញ្ហា ថាតើការប៉ះពាល់ដល់សិទ្ធិដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌កើតមាននៅក្នុងអំឡុងពេលនៃកិច្ចជំនុំជម្រះទាំងមូល ដែរ ឬយ៉ាងណា។ ម្យ៉ាងវិញទៀត ពុំមែនកំហុសនៃកិច្ចដំណើរការនីតិវិធីទាំងអស់សុទ្ធតែនាំទៅរកការកែប្រែសាលក្រមនោះឡើយ លើកលែងតែកំហុសនោះបណ្តាលឱ្យ"មានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ"។ នៅក្នុងការសម្រេច ថាតើកើតមានករណីនេះ ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវធ្វើការពិចារណាគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ដោយរួមទាំងចំណាត់ការដែលបានធ្វើឡើងនៅក្នុងអំឡុងពេលមានបណ្តឹងសាទុក្ខ។

## ៣.ង.លក្ខខណ្ឌតម្រូវក្នុងការផ្តល់មូលដ្ឋានគាំទ្រអំណះអំណាងនៅដំណាក់កាលបណ្តឹងសាទុក្ខ

១០១.នៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28) អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា៖

> នៅបណ្តឹងសាទុក្ខ ភាគីមិនអាចគ្រាន់តែលើកទឡ្ហីករណ៍ដដែលៗ ដែលពុំទទួលបានជោគជ័យនៅដំណាក់កាលជំនុំជម្រះឡើយ ដរាបណា ភាគីបង្ហាញថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងលើទឡ្ហីករណ៍នេះ គឺជាកំហុសមួយដែលត្រូវតែមានការអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល។ ទឡ្ហីករណ៍របស់ភាគីដែលពុំមានសក្តានុពលធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់នោះ អាចត្រូវបានបដិសេធចោល ឬកែប្រែនោះ អាចត្រូវបានបដិសេធចោលភ្លាមៗដោយអង្គជំនុំជម្រះតុលាការកំពូល និងពុំចាំបាច់ត្រូវធ្វើការពិចារណាលើអង្គសេចក្តីឡើយ។ ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលវាយតម្លៃលើទឡ្ហីករណ៍របស់ភាគីនៅដំណាក់កាលបណ្តឹងសាទុក្ខ ភាគីបណ្តឹងសាទុក្ខត្រូវបានរំពឹងថា នឹងផ្តល់ការយោងទៅលើទំព័រប្រតិចារឹកពាក់ព័ន្ធ ឬកថាខណ្ឌជាក់លាក់នៅក្នុងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងដែលរងការជំទាស់។ បន្ថែមលើសនេះទៀត អង្គជំនុំជម្រះតុលាការកំពូល "មិនតម្រូវឱ្យពិចារណាសារណារបស់ភាគីជាលម្អិតនោះទេ ប្រសិនបើសារណាទាំងនោះ មានលក្ខណៈមិនច្បាស់លាស់ មានលក្ខណៈផ្ទុយ និងមានលក្ខណៈស្រពេចស្រពិល ឬមានភាពមិនពេញលេញជាផ្លូវការដែលបង្ហាញឱ្យឃើញយ៉ាងជាក់ស្តែង"។ អង្គជំនុំជម្រះតុលាការកំពូល មានឆន្ទានុសិទ្ធិ ក្នុងការជ្រើសរើសសារណា

ណាមួយដែលស័ក្តិសម ក្នុងការទទួលបាននូវការពិនិត្យពិចារណាដោយល្អិតល្អន់ជាលាយលក្ខណ៍អក្សរ ។ អង្គជំនុំជម្រះតុលាការកំពូល អាចបដិសេធទឡ្ហីករណ៍ណាដែលមិនមានមូលដ្ឋានសំអាងគ្រប់គ្រាន់ ដោយមិនចាំបាច់ផ្តល់សំអាងហេតុលម្អិតឡើយ[216]។

១០២.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវអនុវត្តវិធីសាស្ត្រដូចគ្នាលើបណ្តឹងសាទុក្ខនៅចំពោះមុខនេះ។ ជាការកត់សម្គាល់ អង្គជំនុំជម្រះពុំធ្វើការពិចារណាលើអំណះអំណាងដែលគ្រាន់តែលើកឡើងថា សេចក្តីសម្រេច ឬសម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយពុំបានលើកមូលដ្ឋានគាំទ្រ ថាតើមូលហេតុអ្វីបានជាសេចក្តីសម្រេច ឬសម្អាងហេតុនេះ មានកំហុសនោះឡើយ។

## ៤.បណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន

### ៤.ក.ធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង

១០៣.នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នួន ជា បានជំទាស់ទៅនឹងធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង ដោយបានអះអាងថាៈ

-ការអនុម័តវិធាននេះ គឺជាការប្រើប្រាស់អំណាចនីតិប្បញ្ញត្តិដែលជាការផ្ទុយទៅនឹងមាត្រា ៩០ នៃរដ្ឋធម្មនុញ្ញកម្ពុជា

-កិច្ចប្រជុំពេញអង្គរបស់ចៅក្រមនៃ អ.វ.ត.ក. ពុំមានសិទ្ធិអំណាចអនុម័តវិធានផ្ទៃក្នុងឡើយ និង

-វិធានផ្ទៃក្នុងមានភាពផ្ទុយទៅនឹងមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក.[217]។

អង្គជំនុំជម្រះសាលាដំបូង បានបដិសេធការជំទាស់នេះនៅក្នុងសេចក្តីសម្រេចស្តីពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង (E51/14) ដោយបានកត់សម្គាល់ឃើញថា ការអនុម័តវិធានផ្ទៃក្នុងពុំត្រូវបានហាមឃាត់ដោយកិច្ចព្រមព្រៀង អ.វ.ត.ក. ឡើយ[218] និងថា គោលបំណងនៃវិធានផ្ទៃក្នុង គឺជាការ“រួមបញ្ចូលគ្នារវាងនីតិវិធីជាធរមានរបស់កម្ពុជា ដែលត្រូវបានបំពេញបន្ថែមដោយបទដ្ឋានអន្តរជាតិ ក្នុងករណីចាំបាច់ និងសមស្រប”[219]។ អង្គជំនុំជម្រះ

---

[216] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២០ (ជើងទំព័រលុបចោល)។

[217] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥ យោងទៅលើអញ្ញត្រកម្មបឋម (E51/3) កថាខណ្ឌ ៦៦ ដល់ ៧១។

[218] សេចក្តីសម្រេចស្តីពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង (E51/14) កថាខណ្ឌ ៦។

[219] សេចក្តីសម្រេចស្តីពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង (E51/14) កថាខណ្ឌ ៧។

សាលាដំបូងបានពន្យល់ថា "ការជំនុំជម្រះនៅ អ.វ.ត.ក. មានភាពខុសគ្នាយ៉ាងច្រើនពីករណីនៅតុលាការជាតិកម្ពុជា"[220] និង ថា "តុលាការអន្តរជាតិដទៃទៀតដែលជំនុំជម្រះរឿងក្តីប្រហាក់ប្រហែលគ្នាទៅនឹងរឿងក្តីនៅចំពោះមុខ អ.វ.ត.ក. ក៏បានអនុម័តវិធានស្តីពីនីតិវិធី និងភស្តុតាងផងដែរ ដើម្បីសម្រួលយ៉ាងពិសេសឱ្យស្របតាមតម្រូវការនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ ដែលមានលក្ខណៈស្មុគស្មាញ"[221]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងមានលក្ខណៈ"ស្របជាមួយនឹងកាតព្វកិច្ចរបស់ អ.វ.ត.ក. [...] ក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធី ដោយស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការតាមច្បាប់កំណត់"[222]។ ការលើកឡើងរបស់ នួន ជា អំពីកំហុសអង្គច្បាប់មួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងនេះ[223] អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការដោះស្រាយតាមលំដាប់លំដោយ។

១០៤.ទីមួយ ចំពោះការលើកឡើងរបស់ នួន ជា ដែលថា មូលដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការអនុវត្តរបស់តុលាការខ្មែរក្រហម និងអង្គជំនុំជម្រះអន្តរជាតិនានាមានភាពពុំត្រឹមត្រូវ ដោយសារតុលាការ និងអង្គជំនុំជម្រះទាំងនោះពុំត្រូវបានកម្រិតដោយច្បាប់ក្នុងស្រុក និងមានបទប្បញ្ញត្តិជាក់លាក់ដែលអនុញ្ញាតឱ្យធ្វើការអនុម័តវិធានស្តីពីនីតិវិធី និងភស្តុតាង[224]នោះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា អង្គជំនុំជម្រះសាលាដំបូង ពិតជាពុំបានពន្យល់អំពីហេតុផលអ្វីដែលអង្គជំនុំជម្រះសាលាដំបូងយោងទៅលើការអនុវត្តរបស់តុលាការដទៃទៀតនោះមែន ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលមិនចាត់ទុកថា នេះជាកំហុសអង្គច្បាប់ ឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សំអាងហេតុថា *ដោយសារតែ*តុលាការខ្មែរក្រហម និងអង្គជំនុំជម្រះអន្តរជាតិនានាបានអនុម័តវិធានជាក់លាក់នោះ ទើប អ.វ.ត.ក. ក៏អាចធ្វើដូច្នេះបានផងដែរ។ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបានធ្វើការកត់សម្គាល់អំពីអត្ថិភាពនៃវិធានជាក់លាក់ទាំងនេះ និងថា វិធានទាំងនេះ ត្រូវបានយោងនៅក្នុងអំឡុងពេលធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុងតែប៉ុណ្ណោះ។ ការសង្កេតដែលមានភាពពាក់ព័ន្ធខាងដើមនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយោងមិនត្រឹមតែលើសមត្ថកិច្ចក្នុង

---

[220] សេចក្តីសម្រេចស្តីពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង (E51/14) កថាខណ្ឌ ៧ យោងទៅលើសាលដីកាស្តីពីដីកាបដិសេធពាក្យសុំមោឃភាព (D55/I/8) កថាខណ្ឌ ១៤។

[221] សេចក្តីសម្រេចស្តីពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង (E51/14) កថាខណ្ឌ ៧។

[222] សេចក្តីសម្រេចស្តីពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង (E51/14) កថាខណ្ឌ ៧។

[223] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦។

[224] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦។

ការអនុម័តវិធានផ្ទៃក្នុង ដែលកើតចេញពីលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការចម្រុះអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្ហាញនូវភាពចាំបាច់សម្រាប់តុលាការទាំងនោះក្នុងការបង្កើតឱ្យមានវិធានជាក់លាក់ដើម្បីប្រតិបត្តិការណ៍របស់ខ្លួន។

១០៥.ទីពីរ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជាការពិត ច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក. ពិតជាពុំបានចែងច្បាស់លាស់អំពីការអនុញ្ញាតឱ្យកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក. ធ្វើការអនុម័តវិធានផ្ទៃក្នុងនោះឡើយ។ ប៉ុន្តែ យោងតាមវាក្យខណ្ឌទីមួយមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. ចែងថា "នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា" និងថា៖

> នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ[225]។

១០៦.ដូច្នេះ មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. រំពឹងទុកយ៉ាងជាក់ច្បាស់ថា នីតិវិធីនៅចំពោះមុខ អ.វ.ត.ក. អាចឃ្លាតចេញពីនីតិវិធីព្រហ្មទណ្ឌទូទៅរបស់កម្ពុជា។ នៅក្នុងច្បាប់ អ.វ.ត.ក. ការអនុញ្ញាតនេះត្រូវបានបញ្ជាក់យ៉ាងពិសេសនៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចដំណើរការនីតិវិធី ដោយបានផ្តល់សិទ្ធិអំណាចដល់ស្ថាប័នពាក់ព័ន្ធរបស់តុលាការ ក្នុងការស្វែងរកសេចក្តីណែនាំពី"វិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ"[226]។ ឃ្លានេះពុំមែនមានន័យដូចការអះអាងរបស់ នួន ជា ដែលថា ចៅក្រមរបស់ អ.វ.ត.ក. អាច*ត្រឹមតែ*លើកយកបទដ្ឋានសម្រាប់ការអនុវត្ត*ពិសេស*នៅក្នុងស្ថានការណ៍ជាក់លាក់ ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី និងត្រូវបានហាមឃាត់មិនឱ្យអនុម័តវិធានដែលត្រូវបានបង្កើតឡើងក្នុងអត្ថន័យទូទៅ និងអរូបីនោះទេ ជាពិសេសមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. ពុំបានកំណត់លក្ខខណ្ឌដល់ស្ថាប័នតុលាការជាក់លាក់ឡើយ ប៉ុន្តែត្រូវបានបង្កើតឡើងក្នុងអត្ថន័យទូទៅ។ អាស្រ័យហេតុនេះ ក្នុងន័យសមស្រប មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. ពុំបានហាមឃាត់ការអនុម័តវិធានផ្ទៃក្នុងដោយកិច្ចប្រជុំពេញអង្គចៅក្រមឡើយ។ ទោះជាយ៉ាងណាក្តី ក្នុងការសម្រេចលើអំណះអំណាងរបស់ នួន ជា តម្រូវឱ្យមានការពិចារណាទៅលើ សំណួរពីរ៖ ជាដំបូង ថាតើវិធានផ្ទៃក្នុងមានខ្លឹមសារយ៉ាងដូចម្តេច និងទីពីរ ថាតើ វិធាន

---

[225] មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក.។

[226] មាត្រា ២០(១) ថ្មី, ២៣(១) ថ្មី, ៣៣(១) ថ្មីនៃច្បាប់ អ.វ.ត.ក.។

ផ្ទៃក្នុងដែលបានអនុម័តដោយកិច្ចប្រជុំពេញអង្គចៅក្រម ចងកាតព្វកិច្ចលើស្ថាប័ននៃ អ.វ.ត.ក. ដែរ ឬយ៉ាងណា។ ទាក់ទងទៅនឹងសំណួរទីមួយ ត្រូវធ្វើការកត់សម្គាល់ថា វិធានផ្ទៃក្នុងមិនមែនស្របគ្នាគ្រប់ផ្នែកទាំងអស់នោះទេ មានផ្នែកខ្លះជាការលើកឡើងវិញអំពីច្បាប់កម្ពុជា ផ្នែកខ្លះជាការលើកឡើងលម្អិតអំពីបទដ្ឋានអន្តរជាតិ និងផ្នែកខ្លះទៀត ជាវិធានបន្ថែមដែលត្រូវបានអនុម័ត "នៅពេលណាដែលច្បាប់កម្ពុជាជាធរមានពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្ត ឬក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ"[227]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកជាអាសារបង់នូវអំណះអំណាងទាក់ទងទៅនឹងអធម្មនុញ្ញភាពដែលបានលើកឡើងថា វិធានផ្ទៃក្នុងបានបញ្ជាក់ឡើងវិញនូវច្បាប់ជាធរមាន ដោយគ្មានបន្ថែមខ្លឹមសារណាមួយក្រៅតែពីច្បាប់កម្ពុជាជាធរមាននោះ។ ទាក់ទងទៅនឹងសំណួរទីពីរ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង នួន ជា ដែលលើកឡើងថា ពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងឯកសារដើមនៃការបង្កើត អ.វ.ត.ក. ឬក្នុងច្បាប់កម្ពុជាជាធរមាន ដែលផ្តល់អំណាចនីតិប្បញ្ញត្តិដល់កិច្ចប្រជុំពេញអង្គចៅក្រមឡើយ។ ផ្អែកតាមមូលហេតុនេះ វិធានផ្ទៃក្នុងពុំមានអានុភាពចងកាតព្វកិច្ចដូចច្បាប់ទូទៅទេ ហើយដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីខាងដើម និងដូចមានចែងក្នុងមាត្រា ៣៣ ថ្មីនៃច្បាប់ អ.វ.ត.ក. ការិយាល័យ និងអង្គជំនុំជម្រះរបស់ អ.វ.ត.ក. នៅតែមានសិទ្ធិអំណាចអនុវត្តច្បាប់ដែលខ្លួនយល់ឃើញថាសមស្របនៅក្នុងករណីនីមួយៗ រួមទាំង"ការកែប្រែ"*ពិសេស*ក្នុងករណីចាំបាច់[228]។ ទាក់ទងទៅនឹងបញ្ហានេះ វិធានផ្ទៃក្នុងត្រូវតែបានបង្ហាញជាចម្បងថា ការបកស្រាយច្បាប់ជាធរមានត្រូវតែមានការឯកភាពគ្នា រួមបញ្ចូលទាំងភាពចាំបាច់ដែលតម្រូវឱ្យមាន"ការកែប្រែ"ផងដែរ។ ទោះជាយ៉ាងណាក្តី អានុភាពចងកាតព្វកិច្ចនេះកើតមានដរាបណា វិធាននេះផ្តល់តម្លៃគួរឱ្យជឿជាក់បាន និងត្រូវបានអនុម័តចេញពីការពិភាក្សា និងការឯកភាពពីមតិភាគច្រើនរបស់ចៅក្រម អ.វ.ត.ក. ហើយវិធាននេះ បានរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ភាពអាចព្យាករណ៍ទុកជាមុនបានអំពីច្បាប់ ជាជាងក្នុងករណីដែល អ.វ.ត.ក. ផ្អែកតែទៅលើសិទ្ធិអំណាចរបស់អង្គជំនុំជម្រះនីមួយៗ ក្នុងការបំពេញភាពខ្វះចន្លោះ និងស្វែងរកសេចក្តីណែនាំពីវិធានអន្តរជាតិក្នុងស្ថានភាពជាក់លាក់នោះ[229]។ អាស្រ័យហេតុនេះ វិធានផ្ទៃក្នុងបានបង្ហាញអំពីការរួមបញ្ចូលគ្នានូវក្របខ័ណ្ឌច្បាប់ជាធរមានដែលពុំមែនជាការ

[227] កថាខណ្ឌទីប្រាំបុព្វកថានៃវិធានផ្ទៃក្នុង។

[228] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៤២៣។

[229] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៤២៣។

ដណ្តើមយកសិទ្ធិអំណាចនីតិបញ្ញត្តិនោះទេ។ អាស្រ័យហេតុនេះ អំណះអំណាងដែលថា វិធានផ្ទៃក្នុងមានអធម្មនុញ្ញភាពទាំងមូល ត្រូវបានបដិសេធចោល។

១០៧.នួន ជា បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានយល់ឃើញថា វិធានអន្តរជាតិ អាចយកមកសំអាងបាន"ក្នុងករណីចាំបាច់ និងសមស្រប" ពីព្រោះមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. អនុញ្ញាតសម្រាប់បទដ្ឋានណាដែលមានលក្ខណៈតូចចង្អៀតប៉ុណ្ណោះ[230]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការអនុវត្តវិធានអន្តរជាតិត្រូវតែស្របជាមួយនឹងមាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក.។ ទោះជាយ៉ាងណាក្តី បទប្បញ្ញត្តិនេះត្រូវតែអានរួមជាមួយបញ្ហាជាច្រើនទៀតដែលកើតឡើងពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ និងអាណត្តិជាក់លាក់របស់ អ.វ.ត.ក. ព្រមទាំងច្បាប់កម្ពុជាផងដែរ។ មានភស្តុតាងបង្ហាញថា នីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពុំស្របទាំងស្រុងតាមលក្ខណៈពិសេសរបស់ អ.វ.ត.ក. ឡើយ ទីមួយ ពាក់ព័ន្ធទៅនឹងការិយាល័យនីមួយៗរបស់តុលាការនេះ សមាសភាពជាតិត្រូវបានបំពេញបន្ថែមដោយសមាសភាពអន្តរជាតិ ដែលបង្ហាញឱ្យឃើញពី"ការបារម្ភយ៉ាងខ្លាំង"របស់សហគមន៍អន្តរជាតិអំពី "ការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[231]។ ទីពីរ រចនាសម្ព័ន្ធរបស់ អ.វ.ត.ក. ខុសប្លែកពីប្រព័ន្ធតុលាការកម្ពុជាត្រង់ដំណាក់កាលឧទ្ធរណ៍នៅ អ.វ.ត.ក. ត្រូវបានច្របាច់បញ្ចូលគ្នាតែមួយ[232] ទីបី កិច្ចដំណើរការនីតិវិធីត្រូវធ្វើឡើងជាច្រើនភាសាជាដើម។ គោលបំណងទាំងមូលក្នុងមាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក. បានអនុញ្ញាតឱ្យ អ.វ.ត.ក. ជំនះរាល់ការលំបាកជាសក្តានុពលនានាដែលអាចកើតចេញពីហេតុការណ៍ពិតទាំងនេះ ដើម្បីធានាបាននូវភាពត្រឹមត្រូវទាំងមូលនៃកិច្ចដំណើរការនីតិវិធី។ នៅក្នុងបរិបទនេះ លក្ខណៈវិនិច្ឆ័យនៅក្នុងមាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក. ដែលចែងថា"ច្បាប់កម្ពុជា ពុំអាចដោះស្រាយលើបញ្ហាជាក់លាក់ណាមួយ"បានគ្របដណ្តប់លើបញ្ហាដែលជាផលវិបាកជៀសមិនផុត ដោយសារលក្ខណៈពិសេសរបស់ អ.វ.ត.ក.។ ផ្ទុយទៅវិញ ការបកស្រាយពាក្យពេចន៍ទាំងនេះក្នុងន័យចង្អៀត ជាការប្រថុយប្រថាន ដោយសារប្រសិនបើត្រូវគោរពដោយត្រង់ៗតាមនីតិវិធីកម្ពុជា នោះ អ.វ.ត.ក. នឹងជំរុញខ្លួនឯងឱ្យជួបការលំបាកក្នុងការប្រតិបត្តិ និងប្រាកដជាដើរ

---

[230] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦។

[231] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ 57/228A ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ A/RES/57/228 បុព្វកថា។

[232] *សូមមើល* សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១១។

ផ្ទុយទៅនឹងស្មារតីរបស់កិច្ចព្រមព្រៀង អ.វ.ត.ក.។ ជាសរុប អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលការលើកឡើងថា បទដ្ឋានដែលប្រើប្រាស់"ក្នុងករណីចាំបាច់ និងសមស្រប"អាចនឹង*ផ្ទុយទៅនឹងច្បាប់*នោះ។

១០៨.ជាសរុបសេចក្តី អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង។

## ៤.ខ.ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី

១០៩.នួន ជា និង ខៀវ សំផន បានលើកឡើងថា មានការរំលោភជាច្រើនលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយដូចខាងក្រោម។

### ៤.ខ.១.សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឧក្រិដ្ឋកម្មឯករាជ្យ និងឥតលម្អៀង

១១០.នួន ជា បានអះអាងថា សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មឥតលម្អៀង និងឯករាជ្យ ត្រូវបានរំលោភបំពាន។ នួន ជា បានលើកឡើងជាច្រើនទាក់ទងទៅនឹងការស៊ើបអង្កេតដែលបានធ្វើឡើងមុនពេលជំនុំជម្រះ[233]ហើយក៏បានទទួលស្គាល់ផងដែរថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងរបស់សហចៅក្រមស៊ើបអង្កេត ដែលធ្វើឡើងក្នុងអំឡុងពេលស៊ើបអង្កេតនៃរឿងក្តីនេះ ពុំអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលដើម្បីធ្វើការពិនិត្យបានឡើយ[234]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវលើកយកសារណាទាំងនេះមកពិចារណា តែត្រង់ចំណុចដែលពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍របស់ នួន ជា ទាក់ទងទៅនឹងការអះអាងពីបញ្ហាកង្វះឯករាជភាព និងភាពអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ។

១១១.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានភាពលម្អៀងយ៉ាងខ្លាំងប្រឆាំងនឹងរូបគាត់ និងថា "សាលក្រម គឺជាការបង្ហាញឱ្យឃើញពីភាពត្រឹមត្រូវ*ក្រោយហេតុការណ៍*នៃជំនឿយូរមកហើយថា ជនជាប់ចោទ គឺជាមនុស្សគួរឱ្យស្អប់ខ្ពើម ហើយសមនឹងទទួលការដាក់ទណ្ឌកម្មធ្ងន់ធ្ងរបំផុត"[235]។ នៅក្នុងសារណា នួន ជា លើកឡើងថា ភាពលម្អៀង បានបង្ហាញតាមរយៈការបកស្រាយពុំត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលា

---

[233] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨ ដល់ ៣៩។

[234] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨។

[235] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤១។

ដំបូងទៅលើភស្តុតាង[236] ដែលពុំមានលក្ខណៈស៊ីសង្វាក់គ្នា ឬការយល់ឃើញផ្នែកអង្គហេតុពុំសមហេតុផល[237] និងបទដ្ឋានច្បាប់ពុំមានលក្ខណៈស៊ីសង្វាក់គ្នា[238]។ ដើម្បីគាំទ្រនូវទឡ្ហីករណ៍ទាំងនេះ នួន ជា បានយោងជាឧទាហរណ៍ទៅលើការលើកឡើងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអង្គជំនុំជម្រះនេះ ត្រូវបានចោទប្រកាន់ថា មានកំហុស[239]។

១១២.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចៅក្រមត្រូវតែបានសន្មតថា មានភាពអនាគតិ[240]។ មានការលើកឡើងថា “ដើម្បីបង្ហាញនូវភាពលម្អៀងពិតប្រាកដ ភាគីត្រូវផ្តល់ភស្តុតាងដែលអាចជឿជាក់បានថា ចិត្តគំនិតរបស់ចៅក្រម មាន ឬអាចមានជាប់ពាក់ព័ន្ធទៅនឹងការគ្រោងទុកជាមុន ក្នុងការដោះស្រាយបញ្ហានានានៅចំពោះមុខខ្លួនជាលក្ខណៈបុរេវិនិច្ឆ័យ”[241]។ ភាពលម្អៀង ឬអានុភាពនៃការស្តែងចេញឱ្យឃើញពីភាពលម្អៀង កើតមាននៅក្នុងកាលៈទេសៈដែលអ្នកសង្កេតការណ៍ឥតលម្អៀងណាម្នាក់ ក្រោយពីបានទទួលព័ត៌មានត្រឹមត្រូវគ្រប់គ្រាន់ហើយ អាចយល់បានដោយសមហេតុផលថា មានភាពលម្អៀង[242]។ ការបង្ហាញពីភាពលម្អៀង ឬការស្តែងចេញឱ្យឃើញពីភាពលម្អៀង អាចត្រូវបានរកឃើញ*ក្នុងចំណោមនោះ*នៅក្នុងសំអាងហេតុ

---

[236] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣។

[237] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤។

[238] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥។

[239] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ១០៥ ដល់ ១០៩។

[240] សាលក្រម *រឿងក្តី Kyprianou ទល់នឹង Cyprus* (ECtHR) កថាខណ្ឌ ២៨។ សាលក្រម *រឿងក្តី Albert and Le Compte ទល់នឹង ប្រទេសបែលហ្ស៊ិក* (ECtHR) កថាខណ្ឌ ៣២។ សាលក្រម *រឿងក្តី Hauschildt ទល់នឹង ប្រទេសដាន់ម៉ាក់* (ECtHR) កថាខណ្ឌ ៤៧។ សាលដីកា *រឿងក្តី Akayesu* (ICTR) កថាខណ្ឌ ៩១។ សេចក្តីម្រេចទាក់ទងទៅនឹងវិធាន ១៥ (ខ) *រឿងក្តី Blagojević និង Jokić* (ICTY) កថាខណ្ឌ ១៣។ មតិដាច់ដោយឡែកស្តីពីការប្រមាថតុលាការក្នុង *រឿងក្តី S. Milošević* (ICTY) កថាខណ្ឌ ៧។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី Furundžija* (ICTY) កថាខណ្ឌ ១៩៦ ដល់ ១៩៧ (“តម្រូវឱ្យមានបទដ្ឋានខ្ពស់ក្នុងការជំទាស់ទៅនឹងសច្ចធារណ៍ឥតលម្អៀង [...] ការដកខ្លួនចេញត្រូវបានធ្វើឡើងតែក្នុងករណីដែលមានការបង្ហាញឱ្យឃើញថា មានភាពលម្អៀងសមហេតុផល តាមរយៈបុរេវិនិច្ឆ័យ ហើយនេះត្រូវតែ *បង្ហាញឱ្យបានច្បាស់លាស់*”)។

[241] បណ្តឹងជំទាស់ *រឿងក្តី El Sayed* (STL) កថាខណ្ឌ ២៥។

[242] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម (E55/4) កថាខណ្ឌ ១១។ សេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់ចៅក្រម *សោម សិរីវឌ្ឍ* (1/4) កថាខណ្ឌ ១០។ សាលដីកា *រឿងក្តី Furundžija* (ICTY) កថាខណ្ឌ ១៨៩។ សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី *រឿងក្តី Karemera* (ICTR) កថាខណ្ឌ ១៨។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ *រឿងក្តី Brdjnanin* (ICTY) កថាខណ្ឌ ៦។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ *រឿងក្តី Seromba* (ICTR) (ការពិភាក្សាសម្រេច កថាខណ្ឌ ១)។

នៃសេចក្តីសម្រេចមួយរបស់តុលាការដែលរងការចោទប្រកាន់[243]។ ដោយសារ នួន ជា បានទទួលស្គាល់នៅក្នុងសារណារបស់ខ្លួនដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ នោះអង្គជំនុំជម្រះតុលាការកំពូល ពុំចាំបាច់ពិនិត្យលើបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូង មានកំហុស ដែរ ឬយ៉ាងណា នោះឡើយ លើកលែងតែបញ្ហា ថាតើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញពីកង្វះនូវភាពអនាគតិ ដែរ ឬយ៉ាងណានោះ[244]។ នួន ជា បានយោងទៅលើការយល់ឃើញមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានអះអាងថា កំហុសទាំងអស់នេះ"គឺជាកំហុសដែលមិនសមហេតុផលខ្លាំងដែលមិនមែនកើតចេញពីការវិភាគ ឬការយល់ឃើញពីអង្គហេតុដោយមិនលម្អៀងនោះឡើយ"[245]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ឧទាហរណ៍ដែល នួន ជា បានដកស្រង់ កង្វះភាពអនាគតិនោះទេ ហើយក៏ពុំមែនជាកំហុសអង្គហេតុ ឬអង្គច្បាប់ដែរ។ ភាគីដែលធ្វើបណ្តឹងជំទាស់ដើម្បីសច្ចធារណ៍នៃភាពអនាគតិរបស់ចៅក្រម មានបន្ទុកត្រូវបង្ហាញភស្តុតាងក្នុងកម្រិតខ្ពស់[246]។ ក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកអំណះអំណាងនេះ ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ ហើយពុំចាំបាច់ធ្វើការពិចារណាបន្តទៀតនៅក្នុងបរិបទនៃអំណះអំណាងដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងឡើយ។

១១៣.លើសពីនេះទៀត នួន ជា បានយោងទៅលើបទសម្ភាសន៍ដែលចៅក្រម CARTWRIGHT បានផ្តល់នៅ

---

[243] សេចក្តីសម្រេចទាក់ទងទៅនឹងវិធាន ១៥ (ខ) *រឿងក្តី* Blagojevic *និង* *Jokić* (ICTY) កថាខណ្ឌ ១៤ ("ដោយសារស្ថាប័នពុំបានបដិសេធទាំងស្រុងលើលទ្ធភាពដែលថា សេចក្តីសម្រេចដែលបានចេញដោយចៅក្រម និងអង្គជំនុំជម្រះខ្លួនឯងអាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីភាពលម្អៀងជាក់ស្តែង ដែលនេះកើតមានតែក្នុងករណីពិសេសប៉ុណ្ណោះ")។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ *រឿងក្តី* Seromba (ICTR) កថាខណ្ឌ ១២។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ *រឿងក្តី* *Bagosora* (ICTR) កថាខណ្ឌ ១០។ បណ្តឹងជំទាស់ *រឿងក្តី* *El Sayed* (STL) កថាខណ្ឌ ២១។

[244] សំណើរបស់ នួន ជា សុំធ្វើបណ្តឹងជំទាស់លើចៅក្រម (E314/6) កថាខណ្ឌ ២៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងជំទាស់ *រឿងក្តី* Seromba (ICTR) កថាខណ្ឌ ១២ ("ករណីដែលមានការចោទប្រកាន់[អំពីភាពលម្អៀង] ស្ថាប័នមានកាតព្វកិច្ចពិនិត្យលើខ្លឹមសារនៃសេចក្តីសម្រេចរបស់តុលាការដែលជាភស្តុតាងនៃការលម្អៀងនោះ។ គោលបំណងនឹងការពិនិត្យនេះ គឺពុំមែនស្វែងរកកំហុសនោះទេ ប៉ុន្តែដើម្បីកំណត់ ថាតើកំហុសនោះ ប្រសិនបើមាន បង្ហាញថា ចៅក្រមមួយរូប ឬច្រើន មានភាពលម្អៀងជាក់ស្តែង ឬថា មានការស្តែងឡើងនូវភាពលម្អៀង ដែរ ឬយ៉ាងណា")។ បណ្តឹងជំទាស់ *រឿងក្តី* *El Sayed* (STL) កថាខណ្ឌ ២១។

[245] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦។

[246] សាលដីកា *រឿងក្តី* *Furundžija* (ICTY) កថាខណ្ឌ ១៩៦ ដល់ ១៩៧។ សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចៅក្រម *សោម សិរីវឌ្ឍ* (1/4) កថាខណ្ឌ ១០។

01357990



សហរដ្ឋអាម៉េរិក នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣[247] ដែលថា ផ្នែកមួយចំនួននៃបទសម្ភាសន៍នេះ បានឆ្លុះបញ្ចាំងពី"ភាពលម្អៀងយ៉ាងខ្លាំង"[248]។ នួន ជា បានកត់សម្គាល់ជាពិសេសថា លោកស្រីចៅក្រមបានលើកឡើងថា រដ្ឋាភិបាលកម្ពុជា បានប្រគល់ជនជាប់ចោទមានសក្តានុពលទៅឱ្យ អ.វ.ត.ក. "យ៉ាងងាយស្រួល" និងថា ខ្មែរក្រហមបាន"បោសសម្អាតបញ្ញវន្ត" "អ្នកដែលត្រូវបានសង្ស័យថា ជាទាហាននៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់"ថា "*ប្រជាជនរាប់ពាន់នាក់បានស្លាប់* ដោយសារការសាងសង់ទំនប់*ឥតប្រយោជន៍*" និងថា "គោលបំណងនៃការជំនុំជម្រះទាំងឡាយនៅ អ.វ.ត.ក. គឺដើម្បីធានាថា *ជនផ្តាច់ការនឹងត្រូវនាំមកជំនុំជម្រះ និងបានធ្វើឱ្យអាម៉ាស់*"[249]។ នួន ជា បានលើកឡើងថា "បញ្ហានេះ គឺជាបញ្ហាសំខាន់នៅក្នុងសំណុំរឿង ០០២/០១" និងថា "ពុំមានចៅក្រមណាម្នាក់ បន្ទាប់ពីបានពិនិត្យលើអង្គហេតុឃើញតាមរយៈការលើកឡើងគ្មានមូលដ្ឋាន និងបំផ្លើសហួសពីការពិតរបស់ចៅក្រម CARTWRIGHT រួចហើយ នៅតែអាចវាយតម្លៃលើការចោទប្រកាន់បានត្រឹមត្រូវ និងឥតលម្អៀងនោះទេ"[250]។ ខៀវ សំផន បានយល់ស្របជាមួយនឹងអំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធទៅនឹងបញ្ហានេះ[251]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការលើកឡើងរបស់ នួន ជា និងបានកត់សម្គាល់*ក្នុងចំណោមនោះ*ថា សេចក្តីអធិប្បាយរបស់ចៅក្រម CARTWRIGHT បានកើតឡើងនៅពេលដែលសវនាការលើភស្តុតាងបានបញ្ចប់ ហើយអង្គជំនុំជម្រះសាលាដំបូងបានទទួលសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សររួចហើយ[252]។

១១៤.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើទឡ្ហីករណ៍របស់ នួន ជា ដែលថា ការលើកឡើងរបស់ចៅក្រម CARTWRIGHT ស្តែងឱ្យឃើញថា មានភាពលម្អៀងនោះឡើយ។ នៅក្នុងការលើកឡើងដែលរងការជំទាស់នេះ ចៅក្រម CARTWRIGHT បានលើកឡើងជាលក្ខណៈទូទៅតែប៉ុណ្ណោះ គាត់ពុំបាននិយាយសំដៅទៅលើ នួន ជា ឡើយ។ គួរកត់សម្គាល់ផងដែរ នៅពេលនិយាយអំពីគោលបំណងក្នុងការនាំយកជនផ្តាច់ការមកកាត់ទោស និងធ្វើឱ្យអាម៉ាស់ គ្មានបុគ្គលសមហេតុផលណាម្នាក់ បន្ទាប់ពីបានទទួលព័ត៌មានត្រឹមត្រូវ

---

[247] ឧបសម្ព័ន្ធ ៣៖ បទសម្ភាសន៍របស់ចៅក្រម Silvia Cartwright ជាមួយវិទ្យាស្ថាន Aspen (ថៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ F2/9.3R។

[248] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩ ដល់ ៥០។

[249] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩។

[250] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០។

[251] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៨។

[252] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២។

គ្រប់គ្រាន់ហើយអាចយល់បានថា គាត់សំដៅទៅលើ នួន ជា ដែលនៅពេលនោះ សាលាដំបូងពុំទាន់បាន សម្រេចនៅឡើយ ថាតើ នួន ជា ជាប់ពិរុទ្ធភាព ឬក៏គ្មានទោសយ៉ាងណានោះទេ។ ផ្ទុយទៅវិញ អ្នកសង្កេត ការណ៍ឥតលម្អៀងណាក៏អាចនឹងយល់បានថា គាត់និយាយសំដៅក្នុងន័យទូទៅអំពីប្រតិកម្មរបស់តុលាការ ចំពោះអំពើឃោរឃៅដែលមានភាពធំធេង[253]។

១១៥.ទាក់ទងទៅនឹងការយោងទៅលើសារណាបណ្តឹងជិតចិត្តចៅក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២[254] នួន ជា បានលើកឡើងបន្ថែមទៀតថា ការលើកឡើងរបស់ចៅក្រម CARTWRIGHT ក៏បានបង្ហាញឱ្យឃើញផងដែរថា ចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងចំពោះរូបគាត់[255] ។ នួន ជា បានរំលឹកថា ចៅក្រម CARTWRIGHT បានលើកឡើងថា ចៅក្រមជាតិជាញឹកញាប់"*វង្វេងទាំងបែបរិះគន់*និង"បញ្ចេញ*មតិយ៉ាងគ្រោតគ្រាត*ចំពោះភស្តុតាងដោះបន្ទុក"[256]។ លោកស្រីចៅក្រមអះអាងថា ចៅក្រមជាតិពីររូបបានទទួលរងឥទ្ធិពលដោយផ្ទាល់ពីទង្វើរបស់ខ្មែរក្រហម[257]។

១១៦.អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការលើកឡើងរបស់ចៅក្រម CARTWRIGHT ពុំបានបង្ហាញឱ្យឃើញពីភាពលម្អៀងពីសំណាក់ចៅក្រមជាតិឡើយ។ ទាក់ទងទៅនឹង"មតិយ៉ាងគ្រោតគ្រាត" ដែលត្រូវបានចោទប្រកាន់លើចៅក្រមជាតិ បើតាមសមត្ថភាពផ្ទាល់របស់ចៅក្រម CARTWRIGHT គឺគាត់ពុំអាចយល់ភាសាខ្មែរបានឡើយ ហើយគ្រាន់តែជា"ការស្រមើស្រមៃ"ប៉ុណ្ណោះដែលថា មតិដែលលើកឡើងដោយចៅក្រមជាតិ មានលក្ខណៈគ្រោតគ្រាត និងរិតតែបង្ហាញច្បាស់ថា លោកស្រីចៅក្រមគ្មានសំអាងអ្វីដែលខ្លួនគាត់បានសន្និតយ៉ាងដូច្នេះនោះឡើយ។ ប្រហាក់ប្រហែលគ្នាដែរ ហេតុការណ៍ដែលថា យោងតាមចៅក្រម CARTWRIGHT ចៅក្រមជាតិមួយចំនួនដែលទទួលរងដោយផ្ទាល់ពីទង្វើរបស់ខ្មែរក្រហមនោះ *ជាធម្មតា* ពុំបានស្តែងឱ្យឃើញពីភាពលម្អៀងឡើយ។ នៅពេលដែលអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំត្រូវបានជំនុំជម្រះក្នុងស្រុក ទំនងជាមានចៅក្រមមួយចំនួន ឬទាំងអស់ដែលចូលរួមជម្រះរឿងក្តីនោះ បានឆ្លងកាត់អំឡុងពេលនៃអំពើ

---

[253] *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥។

[254] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២ យោងទៅលើសំណើរបស់ នួន ជា សុំធ្វើបណ្តឹងជិតចិត្តចៅក្រម (E314/6) កថាខណ្ឌ ៥៣ ដល់ ៦០។

[255] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២។

[256] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២។

[257] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២។

នេះ និងមានបទពិសោធន៍រៀងៗខ្លួនទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ ប្រសិនបើមានការយល់ឃើញថា ហេតុការណ៍ខាងដើមនេះបានធ្វើឱ្យចៅក្រមមានភាពលម្អៀងនោះ ព្រឹត្តិការណ៍ឧក្រិដ្ឋកម្មអន្តរជាតិពុំគប្បីមានការជំនុំជម្រះនៅក្នុងស្រុកនោះឡើយ។ សំខាន់បំផុត គឺថា ចៅក្រមដែលមានវិជ្ជាជីវៈ ត្រូវបានគេរំពឹងថា នឹងមិនយកបទពិសោធន៍ដែលខ្លួនបានឆ្លងកាត់មកលាយឡំ នៅពេលធ្វើការវិនិច្ឆ័យរឿងក្ដីនោះឡើយ ហើយបញ្ហានេះក៏ត្រូវបានកំពុងអនុវត្តផងដែរ ចំពោះស្ថានការណ៍ក្រោយជម្លោះ និងបញ្ហាប្រឈមនៃអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ។ ព្រឹត្តិការណ៍ដែលបានពិពណ៌នាដោយចៅក្រម CARTWRIGHT តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ជាមួយនឹងចៅក្រមពីររូបទៀត បើទោះបីជាត្រឹមត្រូវក៏ដោយ ក៏ពុំបានសំដៅលើជនជាប់ចោទណាមួយ ឬបុគ្គលជាក់លាក់ណាមួយ និងពុំជាប់ពាក់ព័ន្ធទៅនឹងបទចោទដែលបានជំនុំជម្រះក្នុងរឿងក្ដីបច្ចុប្បន្ននេះ ប៉ុន្តែពាក់ព័ន្ធទៅនឹងលក្ខខណ្ឌទូទៅនៃជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[258]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ នួន ជា ត្រូវបដិសេធចោល។

១១៧.នួន ជា បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំមានឯករាជភាពគ្រប់គ្រាន់[259]។ ក្នុងការចោទប្រកាន់ថា ប្រព័ន្ធតុលាការកម្ពុជាពុំមានលក្ខណៈឯករាជ្យនោះ នួន ជា បានបង្ហាញដល់អង្គជំនុំជម្រះតុលាការកំពូលតាមរយៈសារណារបស់ខ្លួនទាក់ទងទៅនឹងការបំពេញកិច្ចស៊ើបសួរ ក៏ដូចជាការលើកឡើងនៅក្នុងបណ្ដឹងមិនទុកចិត្តចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងចេញពីសមត្ថកិច្ចជំនុំជម្រះសំណុំរឿង ០០២/០២[260]។

១១៨.ចំពោះអំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានពិចារណា និងសម្រេចបដិសេធកន្លងមកនូវអំណះអំណាងរបស់ នួន ជា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ។ នៅក្នុងសេចក្ដីសម្រេចស្ដីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ[261] អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា "ការចោទប្រកាន់ផ្នែកអង្គហេតុដែលពាក់ព័ន្ធផ្ទាល់ទៅនឹងសំណុំរឿង ០០២

---

[258] *សូមមើល* សំណើទីពីររបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/1) ទំព័រ ២ ដល់ ៣។

[259] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០។

[260] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៤ យោងទៅលើសំណើរបស់ នួន ជា សុំធ្វើបណ្ដឹងមិនទុកចិត្តចៅក្រម (E314/6) កថាខណ្ឌ ៤៣ ដល់ ៥១ (អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នួន ជា ពុំបានយោងទៅលើកថាខណ្ឌជាក់លាក់នៃឯកសារក្រោយ។ ទោះបីជាយ៉ាងណាក៏ដោយ កថាខណ្ឌ ៤៣ ដល់ ៥១ មានការលើកឡើងទាក់ទងទៅនឹងការអះអាងពីកង្វះឯករាជភាពនៅក្នុងរចនាសម្ពន្ធរបស់តុលាការកម្ពុជា)។

[261] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខស្ដីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116/1/7)។

បានឆ្លងកាត់ការតវ៉ាក្តី និងក្រោមការពិចារណាយ៉ាងទូលំទូលាយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ" ហើយរកពុំឃើញកំហុសនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចបដិសេធពុំវិនិច្ឆ័យម្តងទៀតលើការជំទាស់នេះឡើយ[262]។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងសេចក្តីសម្រេចស្តីពីសំណើសុំចំណាត់ការជាបន្ទាន់[263] អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា កំណត់ហេតុដែលបានដាក់ដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ KASPER-ANSERMET ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៣ និង ០០៤ ពុំ*បានបង្ហាញជាសេចក្តីបញ្ជាក់ដំបូង*នូវការជ្រៀតជ្រែកនៅក្នុងសំណុំរឿង ០០២ ឡើយ[264]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានហេតុផលត្រូវពិនិត្យលើបញ្ហាទាំងនេះឡើងវិញឡើយ។ ប៉ុន្តែអង្គជំនុំជម្រះកត់សម្គាល់ឃើញថា នួន ជា បានលើកឡើងបន្ថែមនូវអំណះអំណាងដើម្បីគាំទ្រការជំទាស់របស់ខ្លួនដែលថា អង្គជំនុំជម្រះសាលាដំបូងមិនមានឯករាជភាពគ្រប់គ្រាន់ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការដោះស្រាយអំណះអំណាងទាំងនេះដូចខាងក្រោម។

១១៩.ទីមួយ នួន ជា បានលើកឡើងថា ឥទ្ធិពលផ្នែកនយោបាយទៅលើកិច្ចស៊ើបសួរត្រូវបានបង្ហាញឱ្យឃើញតាមរយៈការអះអាងរបស់ចៅក្រម Marcel LEMONDE នៅក្នុងសៀវភៅមួយស្តីអំពីមុខងាររបស់គាត់ជាអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅ អ.វ.ត.ក.។ នួន ជា បានយោងជាពិសេសទៅលើសៀវភៅនោះត្រង់ចំណុចថា "រាល់ចៅក្រមកម្ពុជាទាំងអស់ ចុងក្រោយត្រូវតែធ្វើតាមរដ្ឋាភិបាល ដោយសារតែការភ័យខ្លាច ឬដោយសារតែភាពជិតស្និទ្ធជាមួយអ្នកមានអំណាច និងថា រាជរដ្ឋាភិបាលកម្ពុជាជាអ្នក*ញាក់ខ្សែ*នៅពីក្រោយចៅក្រមកម្ពុជាទាំងអស់នោះ"[265]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា សេចក្តីថ្លែងការណ៍ទីមួយ គឺ

---

[262] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116/1/7) កថាខណ្ឌ ៣២។

[263] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីសំណើសុំចំណាត់ការជាបន្ទាប់ (E189/3/1/8)។

[264] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីសំណើសុំចំណាត់ការជាបន្ទាប់ (E189/3/1/8) កថាខណ្ឌ ១៩ និង ២២។

[265] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កថាខណ្ឌដែលលើកឡើងនោះ ពុំមានការយោងជាក់លាក់ទៅលើសៀវភៅនោះឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នួន ជា សំដៅទៅលើការលើកឡើងនៅក្នុងទំព័រ ៥១ ក្នុងសៀវភៅដែលថា៖ "*នៅពេលពិពណ៌នាអំពីបញ្ហាសង្គម ចៅក្រមបានលើកឡើងថា ខ្ញុំត្រូវតែប្រុងប្រយ័ត្នចំពោះចៅក្រមកម្ពុជាទាំងអស់: ពួកគេរស់នៅក្នុងភាពភ័យខ្លាចអ្នកដែលមានអំណាច ឬអ្នកដែលនៅជិតស្និទ្ធ ប៉ុន្តែនៅគ្រប់ករណីទាំងអស់ បញ្ហានេះពុំអាចជឿទុកចិត្តបាន និងឯករាជ្យឡើយ*" (សេចក្តីដកស្រង់សៀវភៅ ទំព័រ ១២ ERN

ពាក់ព័ន្ធទៅនឹងការបញ្ចេញមតិរបស់ចៅក្រមកម្ពុជាមួយរូបដែលមិនបញ្ចេញឈ្មោះ បាននិយាយទៅកាន់ចៅក្រម LEMONDE ក្នុងបរិបទស្តីពីការតែងតាំងសហចៅក្រមស៊ើបអង្កេតជាតិ ដែលជាប្រធានសាលាឧទ្ធរណ៍។ ដោយសារតែមានលក្ខណៈជាទូទៅ និងកង្វះនូវការយោងទៅលើសំណុំរឿង ០០២ សេចក្តីថ្លែងការណ៍នេះពុំមានលក្ខណៈសមស្រប ក្នុងការបង្ហាញអំពីកង្វះឯករាជភាពរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍ទីពីរ ដូចបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង[266] ការលើកឡើងដែលថា រាជរដ្ឋាភិបាលកម្ពុជាជាអ្នក*ញាក់ខ្សែ*បានផ្ទុះបញ្ចាំងនូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ចៅក្រម LEMONDE ក្នុងអំឡុងពេលនៃដំណាក់កាលដំបូងរបស់តុលាការ និងការធ្វើសេចក្តីព្រាងនៃវិធានផ្ទៃក្នុង[267]។ អាស្រ័យហេតុនេះ ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីកង្វះឯករាជភាពពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ។

១២០.ទីពីរ នួន ជា បានអះអាងថា តាមការលើកឡើងរបស់ ថេត សម្បត្តិ នៅក្នុងបទសម្ភាសន៍ បានបង្ហាញឱ្យឃើញពីកង្វះឯករាជភាពរបស់អង្គជំនុំជម្រះសាលាដំបូង[268]។ ជាពិសេស ចម្លើយទៅនឹងសំណួរ ថាតើសាក្សីសក្តានុពលមាន"ការបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន" ដែរ ឬយ៉ាងណានោះ ថេត សម្បត្តិបានឆ្លើយថា៖

> បាទគាត់...ពេលដែលគាត់និយាយហ៉ាស គាត់សួរខ្ញុំ គាត់ថាតើប្រសិនបើជាខ្ញុំនិយាយតើ រឿងហ្នឹងសុវត្ថិភាពគាត់គិតយ៉ាងម៉េច។ ខ្ញុំសួរគាត់ថាហេតុអ្វី? ខ្ញុំដឹងហើយ ខ្ញុំដឹងព្រោះអី។ ប៉ុន្តខ្ញុំចង់ដឹងពីយោបល់គាត់ គាត់ឆ្លើយប្រាប់ខ្ញុំថា លោកដឹងថាអ្នកដឹកនាំនៅក្នុងរដ្ឋាភិបាលអ្នកណាទេ? ប៉ា! ខ្ញុំថាខ្ញុំដឹង។ អញ្ចឹងបើខ្ញុំនិយាយទៅគេមិនសម្លាប់ខ្ញុំ។ គាត់និយាយអញ្ចឹងបាទ។ បើសិនមានការធានាពិតប្រាកដថាធានាអាយុ សន្តិសុខរបស់ពួកគាត់ ពួកគាត់នឹងឡើងនិយាយ[269]។

១២១.ការលើកឡើងរបស់ ថេត សម្បត្តិ ថា បុគ្គលដែលមានទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលកម្ពុជាអាចបង្ក

---

(ភាសាបារាំង) 00893650) រួមទាំងការលើកឡើងនៅក្នុងទំព័រ ៣២ "*ជាក់ស្តែង មានអ្នកនៅពីក្រោយចៅក្រមកម្ពុជានៅក្នុងរដ្ឋាភិបាលដែលជាអ្នកញាក់ខ្សែ*" (សេចក្តីដកស្រង់សៀវភៅ LEMONDE ERN (ភាសាបារាំង) 00893641)។

[266] សេចក្តីសម្រេចស្តីពីសេចក្តីដកស្រង់សៀវភៅរបស់ LEMONDE (E280/2/1)។

[267] សេចក្តីសម្រេចស្តីពីសេចក្តីដកស្រង់សៀវភៅរបស់ LEMONDE (E280/2/1) កថាខណ្ឌ ១៧។

[268] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧។

[269] សំណើទីមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2) កថាខណ្ឌ ៦។ អត្ថបទដែលបានដកស្រង់ គឺជាប្រតិចារឹកមិនផ្លូវការនៃកិច្ចសម្ភាសន៍របស់ ថេត សម្បត្តិ ដែលបានផ្តល់ដោយមេធាវីការពារក្តី នួន ជា។

គ្រោះថ្នាក់ដល់សាក្សីដែលមកផ្តល់សក្ខីកម្ម។ បើទោះបីជាការចោទប្រកាន់នេះមានភាពប្រាកដប្រជា (ប៉ុន្តែពុំមានភស្តុតាងគាំទ្រ) យ៉ាងណាក៏ដោយ ក៏ពុំអាចសន្និដ្ឋានបានថា ការគំរាមកំហែងលើសាក្សី ប្រសិនបើមានប្រាកដមែន អាចនឹងប៉ះពាល់ដល់ឯករាជភាពរបស់អង្គជំនុំជម្រះសាលាដំបូង ឬសមាជិកណាម្នាក់នៃអង្គជំនុំជម្រះនេះឡើយ។ ម្យ៉ាងវិញទៀត ការចោទប្រកាន់អំពីការបំភិតបំភ័យសាក្សី និងការជំទាស់អំពីកង្វះឯករាជភាពរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាបញ្ហាដែលពុំមានជាប់ពាក់ព័ន្ធគ្នាឡើយ។

១២២.ទីបី នួន ជា បានលើកឡើងថា “សំអាងហេតុរបស់ចៅក្រមជាតិ ក្នុងការគាំទ្រសេចក្តីសម្រេចមិនកោះហៅ ហេង សំរិន មកផ្តល់សក្ខីកម្ម”បានបង្ហាញឱ្យឃើញពីកង្វះឯករាជភាពរបស់ចៅក្រមជាតិ[270]។ ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បញ្ហាថាតើ ហេង សំរិន រួមទាំងសាក្សីដទៃទៀត គប្បីត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម ដែរ ឬយ៉ាងណានោះ គឺជាកម្មវត្ថុនៃសេចក្តីសម្រេចមួយចំនួននៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ និងការជំនុំជម្រះ[271]។ នៅក្នុងសេចក្តីសម្រេចទាំងនេះ ចៅក្រមជាតិនៃអង្គជំនុំជម្រះនីមួយៗយល់ឃើញថា ការកោះហៅ ហេង សំរិន មកធ្វើជាសាក្សី ពុំមានភាពចាំបាច់នោះឡើយ ចំណែកឯចៅក្រមអន្តរជាតិបានយល់ឃើញថា ហេង សំរិន គប្បីត្រូវបានកោះហៅ។ នៅក្នុងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) អង្គជំនុំជម្រះសាលាដំបូង*ក្នុងចំណោមនោះ*បានសម្រេចមិនកោះហៅសាក្សី ហេង សំរិន ដោយហេតុថា អង្គជំនុំជម្រះពុំទទួលបានសម្លេងភាគច្រើនលើសលុប ដូច្នេះពុំអាចកោះហៅសាក្សីរូបនេះបានឡើយ[272]។

១២៣.នួន ជា បានលើកអំណះអំណាងមួយចំនួនក្នុងការគាំទ្រការជំទាស់របស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូង គួរតែកោះហៅសាក្សី ហេង សំរិន មកផ្តល់សក្ខីកម្ម និងបានជំទាស់ទៅនឹងសំអាងហេតុរបស់ចៅក្រមជាតិទាក់ទងទៅនឹងមូលហេតុ ដែលសម្រេចមិនកោះហៅសាក្សីរូបនេះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហាដែលត្រូវពិចារណាគឺពុំមែន ថាតើសាក្សី ហេង សំរិន គប្បីត្រូវកោះហៅ ដែរ ឬយ៉ាង

---

[270] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨។

[271] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៨៦ ដល់ ១១១។ ការបញ្ជាក់ដំបូងរបស់បុគ្គលដែលត្រូវបានស្តាប់ (E236/1) កថាខណ្ឌ ១ ដល់ ៣ និង ៦។ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) កថាខណ្ឌ ៣៧ ដល់ ៣៩។ ដីកាសម្រេចលើសំណើសុំកោះហៅសាក្សី (D314) កថាខណ្ឌ ៧ និង ១៦ ដល់ ១៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំកោះហៅសាក្សី (D314/1/7 D314/1/8) កថាខណ្ឌ ១៣។ សាលដីកាទីពីរលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំកោះហៅសាក្សី (D314/2/10 D314/1/12) កថាខណ្ឌ ៤០ ដល់ ៤១។

[272] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៨៦។

ណានោះទេ ប៉ុន្តែ ត្រូវពិចារណាលើបញ្ហា ថាតើសំអាងហេតុរបស់ចៅក្រមជាតិ“បានបង្ហាញឱ្យឃើញពីកង្វះឯករាជភាព និងសុចរិតភាព” ដែរ ឬយ៉ាងណា[273]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហាខាងក្រោយនេះ ពុំមានលក្ខណៈច្បាស់លាស់អាចសន្និដ្ឋានបានថា ជាកង្វះឯករាជភាព និងសុចរិតភាពនោះឡើយ។ ចៅក្រមជាតិទទួលស្គាល់នូវភាពពាក់ព័ន្ធជាបឋមនៃសក្ខីកម្មរបស់សាក្សី ហេង សំរិន ប៉ុន្តែបានអះអាងថា ភាពពាក់ព័ន្ធនេះនៅមានកម្រិត ហើយជាបញ្ហាដែលត្រូវបានពិភាក្សាវែកញែក ក្នុងការខ្វែងយោបល់គ្នាដោយធៀបនឹងភស្តុតាងដទៃទៀត។ ក្នុងចំណោមនោះ ចៅក្រមជាតិបានទទួលស្គាល់ថា សាក្សី ហេង សំរិន ពិតជាបានលើកឡើងនូវចំណុចដែល នួន ជា យកមកសំអាង។ បន្ថែមលើនេះ ចៅក្រមជាតិបានថ្លឹងថ្លែងលើតម្លៃជាសក្តានុពលអំពីសក្ខីកម្មរបស់សាក្សី ហេង សំរិន ជាមួយនឹង“ភាពជាក់ស្តែងដែលគាត់បានបដិសេធមិនគោរពតាមដីកាកោះ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយដែលត្រូវបានសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាអំពីវិធានការបង្ខំឱ្យផ្តល់សក្ខីកម្មតាមរយៈការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ”[274] ដោយសារចំណុចនេះហើយ ទើបចោទជាបញ្ហាដល់សមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្គាប់ឱ្យចូលខ្លួនដល់សាក្សីតាមរយៈវិធានការចាប់បង្ខំចំពោះសាក្សីសក្តានុពលដែលមានអភ័យឯកសិទ្ធិសភា[275]។ ហេតុនេះហើយ សេចក្តីសម្រេចរបស់ចៅក្រមជាតិដែលបានធ្វើឡើង អាចមានតម្លៃត្រឹមតែជារូបភាព ដែលមានន័យថា ជាការទទួលស្គាល់នូវភាពទន់ខ្សោយនៃសិទ្ធិអំណាចរបស់ អ.វ.ត.ក. ដែលត្រូវអនុវត្តចំពោះសាក្សីមិនសហការ និងជាបញ្ហាដែលកើតមានជាធម្មតាចំពោះមុខតុលាការព្រហ្មទណ្ឌដែលមានកម្រិតអន្តរជាតិ និងតុលាការឧក្រិដ្ឋកម្មនានា ដែលនេះពុំមែនជាបញ្ហាកង្វះឯករាជភាពនោះទេ។ បញ្ហាមួយចំនួនដែលទាក់ទងទៅនឹងការមិនកោះហៅសាក្សី ហេង សំរិន ត្រូវពិចារណាដូចខាងក្រោម៖

-ថាតើបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការការពារខ្លួនដោយប្រសិទ្ធភាព ដែរ ឬយ៉ាងណា

-ថាតើមានការប្រើប្រាស់វិធីសាស្ត្រខុសគ្នាក្នុងការទទួលយកភស្តុតាង ដែរ ឬយ៉ាងណា និង

-ថាតើពុំមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការប្រកាសពិរុទ្ធភាពដូច នួន ជា បានអះអាង ដែរ ឬយ៉ាងណា

---

[273] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៤។

[274] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៩៦។

[275] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៩៧។

នោះ[276] គឺជាបញ្ហាដែលត្រូវដោះស្រាយក្នុងផ្នែកបន្តបន្ទាប់នៅក្នុងសាលដីកានេះ។

១២៤.ជាមួយគ្នានេះដែរ នៅក្រោមចំណងជើងទូទៅដែលថា "ឯករាជភាព និងភាពអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូង" នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយបានដកចេញនូវសក្ខីកម្មពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ក្រោយឆ្នាំ ១៩៧៩[277]។ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានដកចេញនូវសំណួរ ឬភស្តុតាងមួយចំនួន បើទោះបីជាពាក់ព័ន្ធព្រឹត្តិការណ៍ក្រោយអំឡុងពេលនៃបទចោទក៏ដោយ ក៏អាចបង្ហាញនូវតួនាទីរបស់វៀតណាមដែលបានធ្វើយុត្តិកម្មលើការឈ្លានពានខុសច្បាប់ និងការត្រួតត្រារបស់ខ្លួនថាត្រឹមត្រូវមកលើប្រទេសកម្ពុជា តាមរយៈការប្រឌិតយ៉ាងងងើលថាជាអំពើសាហាវយង់ឃ្នងរបស់បក្សកុម្មុយនីស្តកម្ពុជា និងជាការទទួលខុសត្រូវរបស់មេដឹកនាំរបស់បក្សនេះ[278]។ ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងចំណុចនេះ ពុំមានសារណាណាមួយនៅលើបណ្តឹងសាទុក្ខ និងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែល នួន ជា យោងទៅលើ[279] បានបង្ហាញនូវមូលហេតុដែលថា ការបដិសេធមិនទទួលយកភស្តុតាង ឬមិនអនុញ្ញាតឱ្យសួរសំណួរលើប្រធានបទនេះ ក្លាយជាឫសគល់នៃកង្វះភាពឯករាជ្យនោះឡើយ ក្រៅតែពីធ្វើឡើងតាមរយៈការយល់ដឹងអំពីភាពពុំជាប់ពាក់ព័ន្ធនៃព្រឹត្តិការណ៍ ដែលនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ប៉ុណ្ណោះ និងលើសពីនេះទៀត ដោយមិនបង្ហាញពីការជាប់ពាក់ព័ន្ធទៅនឹងភស្តុតាងជាក់លាក់ណាមួយឡើយ។ ដោយសារពុំមានការលើកភស្តុតាងគាំទ្របន្ថែម អំណះអំណាងនេះត្រូវបដិសេធចោល។

១២៥.ទាក់ទងទៅនឹងប្រព័ន្ធតុលាការកម្ពុជា នួន ជា បានរំលឹកថា ចៅក្រមនៅក្នុងប្រទេសកម្ពុជា រួមទាំងចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបានតែងតាំង តម្លើងឋានន្តរស័ក្តិ បញ្ឈប់មុខតំណែង និងដាក់វិន័យដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយសមាជិកឧត្តមប្បូនរូបត្រូវបានតែងតាំងដោយអង្គនីតិប្រតិបត្តិ រួមទាំងសហព្រះរាជអាជ្ញាជាតិ និងសហចៅក្រមស៊ើបអង្កេតជាតិនៃ អ.វ.ត.ក. ផងដែរ[280]។ នួន ជា បានកត់សម្គាល់ផងដែរថា ចៅក្រមជាតិនៅអង្គជំនុំជម្រះសាលាដំបូង កំពុងបន្តកាន់តួនាទីរបស់ខ្លួនពេញម៉ោងនៅក្នុង

---

[276] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨ ដល់ ៧៥។

[277] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៦ ដល់ ៧៩។

[278] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៧។

[279] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៩ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា (E295/6/3) កថាខណ្ឌ ៥៧ ដល់ ៥៩។

[280] បណ្តឹងជិតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម (E314/6) កថាខណ្ឌ ៤៣។

ប្រព័ន្ធតុលាការជាតិ[281]។ នួន ជា ក៏បានចង្អុលបង្ហាញផងដែរថា ចៅក្រមនៅក្នុងប្រទេសកម្ពុជា ទទួលបានប្រាក់បៀវត្សទាប និងពុំមានសុវត្ថិភាពក្នុងមុខតំណែង និង មានការចោទប្រកាន់ថា មានការរីករាលដាលនៃអំពើពុករលួយ[282]។

១២៦.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទំនាក់ទំនងរវាងប្រព័ន្ធតុលាការ និងស្ថាប័នដទៃទៀតរបស់រដ្ឋ នៅតែមានទំនាស់ និងមានភាពតានតឹងនឹងគ្នា ដូចជានៅក្នុងប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យជឿនលឿន ដែលប្រាថ្នាចង់បានយ៉ាងខ្លាំងនូវស្តង់ដារនីតិរដ្ឋខ្ពស់បំផុត ដូចជា នៅសហរដ្ឋអាម៉េរិក និងរដ្ឋសមាជិកនានានៃក្រុមប្រឹក្សាអឺរ៉ុបដែរ[283]។ បញ្ហាប្រឈមនៃរចនាសម្ព័ន្ធរួមមានរបៀបនៃការជ្រើសរើស និងតែងតាំងចៅក្រម ដើម្បីរារាំងកុំឱ្យមានអតុល្យភាពក្នុងចំណោមស្ថាប័នរដ្ឋ និងការថ្លឹងថ្លែងនូវសុវត្ថិភាពមុខតំណែងរបស់ចៅក្រម ដោយធៀបជាមួយនឹងការពង្រឹងប្រសិទ្ធភាព និងវិន័យ ពុំមែនជាករណីពិសេសចំពោះតែប្រទេសកម្ពុជានោះឡើយ ហើយក៏ជាការសមស្របក្នុងការនិយាយថា ពុំទាន់មានប្រព័ន្ធដ៏ល្អឥតខ្ចោះណាមួយ ត្រូវបានអនុវត្តនោះឡើយ។ ដោយសារការកែទម្រង់ប្រព័ន្ធតុលាការក្នុងទិសដៅដើម្បីពង្រឹងស្វ័យភាព និងឯករាជភាព[284] នៅតែផ្តល់សារៈសំខាន់ ទោះជាយ៉ាងណាក៏ដោយ តាមការលើកឡើងរបស់ នួន ជា ដែលបដិសេធនូវភាពស្របច្បាប់នៃការជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក. ដោយគ្រាន់តែផ្អែកលើភាពមិនស្របគ្នាជាអរូបីយរវាងទម្រង់នៃស្ថាប័ននៅក្នុងប្រព័ន្ធតុលាការកម្ពុជា ជាមួយនឹងបទដ្ឋានអន្តរជាតិ ជាការពុំសមស្របទេ។ ការលើកអំណះអំណាងបែបនេះ ជាគោលការណ៍អាចនឹងចោទជាបញ្ហាចំពោះ*មូលហេតុនៅពីក្រោយ*តុលាការឧក្រិដ្ឋកម្មចម្រុះនានា ដែលនេះគឺជាការសន្និដ្ឋានមួយពុំអាចទទួលយកបានសម្រាប់ស្ថាប័ន ដែលប្រតិបត្តិក្រោមការឧបត្ថម្ភគាំទ្រពីអង្គការសហប្រជាជាតិ។ ផ្ទុយទៅវិញ បញ្ហារចនាសម្ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវ ប្រាកដជាជាប់ពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីជាក់លាក់ ដែលអាចធ្វើការវាយតម្លៃបានថា កិច្ចដំណើរការនីតិវិធីនេះ ទំនងជាមានការស្តែងឱ្យឃើញពិតប្រាកដ និងសមហេតុផលនូវភាពលម្អៀងណាមួយនោះ។ ពាក់ព័ន្ធទៅនឹង

---

[281] បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម (E314/6) កថាខណ្ឌ ៤៣។

[282] បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម (E314/6) កថាខណ្ឌ ៤៤។

[283] *សូមមើល* មតិយោបល់លេខ ១០ (ឆ្នាំ ២០១៥) ស្តីពីជំហរនៃរបស់តុលាការ (CCJE) កថាខណ្ឌ ២។ មិតយោបល់លេខ ១០ (២០០៧) ស្តីពីក្រុមប្រឹក្សាសម្រាប់តុលាការដើម្បីសេវាសង្គម (CCJE)។

[284] សម្ព័ន្ធកម្ពុជាសម្រាប់លើកកម្ពស់ និងការពារសិទ្ធិមនុស្ស "កំណែទម្រង់ប្រព័ន្ធតុលាការ និងច្បាប់ក្នុងកម្ពុជា" ខែ កុម្ភៈ ឆ្នាំ ២០០៦ ទំព័រ ២ គេហទំព័រ៖ http://www.licadho-cambodia.org/reports/files/79LICADHOLegalJudicialReformPaper06.pdf។

បញ្ហានេះ បើទោះបីជាអាចជំទាស់បានថា សមាសភាពនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រមកម្ពុជា ពុំបានបំពេញតាមនិយាមរបស់ក្រុមប្រឹក្សាអឺរ៉ុបយ៉ាងណាក៏ដោយ[285] តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលក៏បញ្ហានេះ ពុំមែនជាការស្តែងឱ្យឃើញពិតប្រាកដនូវភាពលម្អៀងពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ទីមួយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខុសពីសាលក្រមរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ក្នុង*រឿងក្តី Volkov ទល់នឹង ប្រទេសអ៊ុយក្រែន*[286] ដែល នួន ជា យោងទៅលើនោះ ត្រង់ថា នៅ អ.វ.ត.ក. សមាជិកនៃអង្គនីតិប្រតិបត្តិ ពុំបានចូលរួមក្នុងការជំនុំជម្រះរឿងក្តីបច្ចុប្បន្ននេះទេ និងពុំមានការចោទប្រកាន់លើកឡើងថា មានចៅក្រមជាតិណាមួយនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ត្រូវបានដាក់ឱ្យស្ថិតក្រោមកិច្ចដំណើរការនីតិវិធីដាក់វិន័យដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។ ដូច្នេះ ការចោទប្រកាន់ដែលថាមុខងាររបស់ចៅក្រមនៅ អ.វ.ត.ក. ស្ថិតក្រោមឥទ្ធិពលនៃអង្គនីតិប្រតិបត្តិតាមរយៈឧត្តមក្រុមប្រឹក្សានេះ គឺពុំមានភាពជាក់ស្តែង និងរឹងមាំឡើយ។ លើសពីនេះទៀត ទាក់ទងទៅនឹងការអះអាងដែលថា បានធ្វើឱ្យប៉ះពាល់ដល់អនាគតិរបស់អង្គជំនុំជម្រះសាលាដំបូងដោយសារសហព្រះរាជអាជ្ញាជាតិ ជាសមាជិកនៃឧត្តមក្រុមប្រឹក្សានោះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា កំណត់ត្រានៅក្នុងសំណុំរឿង ០០១ និង ០០២ បានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំមានការស្ទាក់ស្ទើរក្នុងការសម្រេចលើបញ្ហាសត្យានុម័តជាច្រើន ដែលប្រឆាំងនឹងជំហររបស់សហព្រះរាជអាជ្ញា និងឃើញថាពុំមានការភិតភ័យដោយសារតែតួនាទីរបស់សហព្រះរាជអាជ្ញាជាតិ នៅខាងក្រៅ អ.វ.ត.ក. ឡើយ។ ពាក់ព័ន្ធទៅនឹងការអះអាងលើបញ្ហាប្រាក់បៀវត្សពុំគ្រប់គ្រាន់ និងអំពើពុករលួយដោយគ្មានការបង្ហាញនូវភាពពិតជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលចង្អុលបង្ហាញថា នៅ អ.វ.ត.ក. ការធានាមួយចំនួនត្រូវបានផ្តល់ទៅឱ្យគ្រប់ផ្នែកទាំងអស់ ដូចជាប្រាក់បៀវត្សគ្រប់គ្រាន់ ការទប់ស្កាត់អំពើពុករលួយ ដែលអាចរាំងចៅក្រមនៃ អ.វ.ត.ក. ពីបញ្ហាទាំងនោះបាន។ ចំពោះបញ្ហាដទៃទៀត ដែលទាំងចៅក្រមអន្តរជាតិ និងចៅក្រមជាតិត្រូវប្រឈមមានដូចជា៖ ការកម្រិតរយៈពេលកាន់មុខតំណែង ថវិកាផ្អែកទាំងស្រុងទៅលើប្រទេសផ្តល់ជំនួយ និងសម្ពាធមកលើការបំពេញការងារតាមអាណត្តិ។ ទាំងអស់នេះ ត្រូវបានពិភាក្សាយ៉ាងផុសផុលនៅក្នុងយុត្តិសាស្ត្រអន្តរជាតិ[287]និងក្នុងឯកសាររបស់អ្នកសិក្សាស្រាវជ្រាវ។ អង្គជំនុំជម្រះ

---

[285] អនុសាសន៍ CM/Rec (ឆ្នាំ ២០១០) ស្តីពីចៅក្រម៖ ឯករាជភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ។ មតិយោបល់លេខ ១ ស្តីពីបទដ្ឋានពាក់ព័ន្ធនឹងឯករាជភាពរបស់តុលាការ (CCJE)។

[286] សាលក្រម *រឿងក្តី Volkov ទល់នឹងប្រទេសអ៊ុយក្រែន* (ECtHR)។

[287] សេចក្តីសម្រេចលើអញ្ញត្រកម្ម(ឯករាជភាពរបស់តុលាការ) (SCSL) កថាខណ្ឌ ៣៧ ដល់ ៣៨។

តុលាការកំពូលយល់ច្បាស់ថា បណ្តឹងសាទុក្ខនេះពុំបានចោទប្រកាន់ថា អ.វ.ត.ក. ជាគោលការណ៍ មានកំហុសពាក់ព័ន្ធទៅនឹងបញ្ហានោះឡើយ។

១២៧.ខៀវ សំផន បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូង មានគំនិតលម្អៀងចំពោះរូបគាត់។ នៅក្នុងការគាំទ្រនូវការចោទប្រកាន់នេះ ខៀវ សំផន បានលើកនូវទឡ្ហីករណ៍មួយចំនួន ដែលអង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការដោះស្រាយដូចខាងក្រោម។

១២៨.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនីតិវិធី“ស្តង់ដារពីរ” ដែលលម្អៀងទៅរកសហព្រះរាជអាជ្ញា ដោយធ្វើឱ្យខូចប្រយោជន៍ដល់ភាគីការពារក្តី[288]។ ក្នុងការគាំទ្រនូវអំណះអំណាងរបស់ខ្លួន ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងទំនងជាបានបំភិតបំភ័យសាក្សីរបស់ភាគីការពារក្តី តែបែរជាការពារសាក្សីដែលផ្តល់សក្ខីកម្មប្រឆាំងនឹងជនជាប់ចោទទៅវិញ[289]។ ជាពិសេស ខៀវ សំផន បានសំដៅដល់ការលើកឡើងរបស់ចៅក្រម LAVERGNE នៅក្នុងពេលសួរសំណួរសាក្សី និងសំណួររបស់សហព្រះរាជអាជ្ញា និងបានបង្ហាញពីភាពផ្ទុយគ្នារវាងការលើកឡើងទាំងនោះ និងការសួរសំណួរ ជាមួយការប្រព្រឹត្តរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសាក្សី ភី ភួន[290]។ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យឡើងវិញលើទំព័រនីមួយៗនៃប្រតិចារឹកដែលបានយោងដោយ ខៀវ សំផន និងដោយសារគ្មានការលើកភស្តុតាងគាំទ្រច្បាស់លាស់ណាមួយ អង្គជំនុំជម្រះតុលាការកំពូលពុំអាចកំណត់អំពីលក្ខណៈពុំសមស្របរបស់អង្គជំនុំជម្រះសាលាដំបូង ឬរបស់ចៅក្រមណាម្នាក់នៃអង្គជំនុំជម្រះនេះដែលបានប្រព្រឹត្តដាក់សាក្សីទាំងនេះឡើយ។ បើទោះជា ខៀវ សំផន នៅតែលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយបានកាត់បន្ថយពេលវេលារបស់ខ្លួនក្នុងការសួរសាក្សី ភី ភួន ក៏ដោយ[291] ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មេធាវីការពារក្តី ខៀវ សំផន បានបញ្ចប់ការសួរសំណួររបស់ខ្លួនពេញលេញទៅតាមពេលវេលាដែលបានផ្តល់

---

288 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤១។

289 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤១។

290 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤១។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សាក្សីឈ្មោះ ភី ភួន ឬ រ៉ចាម តុន *ហៅ* “វីជាម”។ *សូមមើល*ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (ភី ភួន) ឯកសារលេខ E1/96.1 ទំព័រ ៤៣។

291 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ១០៥។

ឱ្យនោះ[292]។ ជាសរុបមក ពាក់ព័ន្ធទៅនឹងបញ្ហានេះ ខៀវ សំផន ពុំបានបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសណាមួយដែលមានភាពលម្អៀងចំពោះរូបគាត់ឡើយ។

១២៩.ខៀវ សំផន បានលើកបន្ថែមទៀតថា ការប្រព្រឹត្តពុំស្មើគ្នារបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានបង្ហាញឱ្យឃើញតាមរយៈការដោះស្រាយលើសំណើ សុំឱ្យទទួលយកភស្តុតាងជាឯកសារបញ្ចូលទៅក្នុងសំណុំរឿង[293]។ ខៀវ សំផន ដំបូងបានកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចលើសំណើសុំឱ្យទទួលយកអត្ថបទកាសែតជាភស្តុតាង យោងតាមអត្ថបទកាសែតនេះ សាក្សីដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្រោយមកបានបដិសេធចម្លើយរបស់ខ្លួនវិញ[294]។ ការដែលអង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន បើទោះបីជា មានការរំឭកពីមេធាវីការពារក្តីក៏ដោយ ហើយដែលអាចចាត់ទុកថាមានកំហុសនោះ[295] ក៏អង្គជំនុំជម្រះតុលាការកំពូលពុំអាចយល់ស្របតាមការលើកឡើងរបស់ ខៀវ សំផន ដែរ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំអាចធ្វើយុត្តិកម្មលើការបដិសេធសំណើសុំនេះបានទេ ទើបជ្រើសរើសពុំអើពើលើសំណើសុំនេះ។ ដោយពិចារណាឃើញអំពីភាពច្រើនសន្ធឹកសន្ធាប់នៃឯកសារដែលភាគីបានស្នើសុំឱ្យទទួលយកជាភស្តុតាង និងជាក់ស្តែង ជាញឹកញាប់ អង្គជំនុំជម្រះសាលាដំបូង តែងតែផ្អាកការសម្រេចរបស់ខ្លួនរហូតដល់ពេលអង្គជំនុំជម្រះមានឱកាសពិភាក្សាសម្រេចនោះ ដូច្នេះអាចមានកង្វះការសម្រេចដែលគ្រាន់តែជាការមើលរំលងប៉ុណ្ណោះ ប៉ុន្តែពុំមែនជាបញ្ហាមិនសមហេតុសមផលនោះឡើយ។

១៣០.ខៀវ សំផន ក៏បានអះអាងផងដែរថា ភាពលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានស្តែងឱ្យឃើញតាមរយៈការដែលអង្គជំនុំជម្រះ បានទទួលយកសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឱ្យបញ្ចូលទៅក្នុងសំណុំរឿងនូវប្រតិចារឹកនៃបាឋកថារបស់សាក្សីជំនាញ Philip SHORT ប៉ុន្តែ បានបដិសេធសំណើរបស់ នួន

---

[292] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/101.1 ទំព័រ ៤៥ (មេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា ខ្លួនពុំមានសំណួរបន្តសួរសាក្សី រ៉ចាម តុន ទៀតទេ)។

[293] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២។

[294] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២ យោងទៅលើសំណើរបស់ ខៀវ សំផន សុំឱ្យទទួលយកឯកសារថ្មី (E220)(ភាសាខ្មែរ និងបារាំង)។

[295] ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារលេខ E1/207.1 ទំព័រ ៦៦ (មេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា អង្គជំនុំជម្រះពុំបានសម្រេចលើសំណើសុំរបស់ ខៀវ សំផន ឱ្យទទួលយកអត្ថបទកាសែតធ្វើជាភស្តុតាង)។

ជា ដែលសុំឱ្យទទួលយកអត្ថបទកាសែតពាក់ព័ន្ធទៅនឹងវិធីសាស្ត្រក្នុងការតាក់តែងសៀវភៅរបស់ Philip SHORT ទៅវិញ[296]។ ខៀវ សំផន បានលើកឡើងទៀតថា ហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចបដិសេធសំណើរបស់គាត់ ជាពិសេសត្រង់ចំណុច ការសាកសួរសាក្សីជំនាញ នៅក្នុងតុលាការទាក់ទងសំណួរទាំងនោះ ក៏ត្រូវតែអនុវត្តឱ្យដូចគ្នាចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញាផងដែរ[297]។ បន្ទាប់ពីពិនិត្យលើឯកសារពាក់ព័ន្ធ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[298] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីសម្រេចបដិសេធនេះ មានមូលដ្ឋានគ្រប់គ្រាន់។ ឯកសារដែល នួន ជា ស្នើសុំឱ្យទទួលយក គឺជាសេចក្តីដកស្រង់ខ្លីមួយចេញពីអត្ថបទកាសែតដែលពិភាក្សាលើសៀវភៅរបស់ Philip SHORT ស្តីពី ប៉ុល ពត ប៉ុណ្ណោះ[299]។ ដូចគ្នាទៅនឹងការពិពណ៌នាដោយមិនផ្ទាល់ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការតាក់តែងនេះ ដែលជាការពិតជា បញ្ហាមួយចាំបាច់ត្រូវតែមានការដេញដោលក្នុងអំឡុងពេលនៃការសួរសាក្សី។ ផ្ទុយទៅវិញ ឯកសារដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយក គឺជាខ្សែអាត់សំឡេងដ៏វែងមួយនៃបាឋកថាផ្ទាល់របស់ Philip SHORT[300]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយបញ្ហាពាក់ព័ន្ធទៅនឹងភាពអាចជឿទុកចិត្តបាននៃឯកសារមួយចំនួន ដែលត្រូវបានស្នើសុំឱ្យទទួលយក ដែលឯកសារទាំងនេះ ទំនងជាត្រូវបានរៀបចំដោយក្រុមមេធាវីការពារក្តី នួន ជា[301]។ បន្ទាប់ពីពិនិត្យលើឯកសារដែលស្នើឡើងដោយ នួន ជា អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ឯកសារនេះ ទំនងជាស្ថិតនៅក្នុងប្រភេទឯកសារ ដែលបានផ្តល់នូវយុត្តិកម្មបន្ថែមទៀតសម្រាប់ការបដិសេធចោល បើធៀបទៅនឹងឯកសារ ដែលសហព្រះរាជអាជ្ញាបានស្នើឡើងនោះ។

១៣១.ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា កង្វះអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានបង្ហាញ

---

[296] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២។

[297] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២។

[298] ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង (E260)។

[299] Philip Short៖ ព្រឹត្តិប័ត្រ *Asian Wall Street* (E226.1)។

[300] *សូមមើល* ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង (E260) កថាខណ្ឌ ៤។ សំណើរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E230) កថាខណ្ឌ ២ ដល់ ៣។

[301] ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង (E260) កថាខណ្ឌ ៨។

ឱ្យឃើញតាមរយៈការមិនយកចិត្តទុកដាក់ជាប្រព័ន្ធលើភស្តុតាងដោះបន្ទុក[302] ការបំភ្លៃភស្តុតាង រួមទាំងសក្ខីកម្មផ្ទាល់ខ្លួនរបស់ ខៀវ សំផន ផងដែរ ដើម្បីធ្វើសេចក្តីសន្និដ្ឋានប្រឆាំងនឹងគាត់[303] និងអនុវត្តពុំត្រឹមត្រូវទៅតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*[304]។ ខៀវ សំផន ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១[305]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អំណះអំណាងរបស់ ខៀវ សំផន មានលក្ខណៈមិនស៊ីជម្រៅ និងពុំមានមូលដ្ឋានគាំទ្រ ថាតើកំហុសនោះ ប្រសិនបើមាន បានបង្ហាញឱ្យឃើញនូវភាពលម្អៀងយ៉ាងដូចម្តេចឡើយ[306]ដែលពុំមែនជាកំហុសអង្គច្បាប់ ឬអង្គហេតុ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចពុំពិចារណាលើអំណះអំណាងនេះបន្តទៀតឡើយ។

## ៤.ខ.២.សិទ្ធិទទួលបានការការពារក្តីដោយប្រសិទ្ធភាព

១៣២.នួន ជា និង ខៀវ សំផន បានលើកអំណះអំណាងមួយចំនួនដើម្បីគាំទ្រការអះអាងរបស់ខ្លួនដែលថា សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការការពារក្តីដោយប្រសិទ្ធភាព ត្រូវបានរំលោភបំពាន។ អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយលើអំណះអំណាងនេះតាមលំដាប់លំដោយ។

### ៤.ខ.២.ក.ការសម្រេចមិនកោះហៅសាក្សី

១៣៣.នួន ជា បានលើកឡើងថា សិទ្ធិរបស់គាត់ក្នុងការទទួលបានការការពារក្តីដោយប្រសិទ្ធភាពត្រូវបានរំលោភបំពាន ពីព្រោះអង្គជំនុំជម្រះសាលាដំបូងពុំបានកោះហៅសាក្សីមួយចំនួន[307]។ សាក្សីទាំងនេះ មានដូចជា ហេង សំរិន[308] អ៊ុក ប៊ុនឈឿន[309] និង Robert LEMKIN[310] រួមទាំងសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្មលើស្ថាន

---

[302] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣។

[303] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៤ ដល់ ៤៥។

[304] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦។

[305] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៧។

[306] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១។

[307] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨០ ដល់ ៨១។

[308] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨១។

[309] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨២។

ភាពនៅក្នុងទីក្រុងភ្នំពេញនៅមុនពេលជម្លៀស ក្នុងខែ មេសា ឆ្នាំ ១៩៧៥[311] និងសាក្សីដែលសក្ខីកម្មរបស់ខ្លួនអាចជាប់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើមានគោលនយោបាយប្រឆាំងនឹងអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែរ ឬយ៉ាងណា[312]។ មុនពេលធ្វើការវាយតម្លៃលើទឡ្ហីករណ៍នេះ អង្គជំនុំជម្រះតុលាការកំពូលមានបំណងបង្ហាញថា ដោយឥតមន្ទិលសង្ស័យ សិទ្ធិស្នើសុំឱ្យកោះហៅសាក្សីដែលស្ថិតក្នុងចំណោមសិទ្ធិទទួលបានមធ្យោបាយការពារខ្លួន គឺជាសមាសភាគចាំបាច់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិនេះពុំមែនជាសិទ្ធិដាច់ខាតនោះទេ។ ស្របតាមរបបនីតិវិធីរបស់ អ.វ.ត.ក. អាស្រ័យទៅលើអង្គជំនុំជម្រះសាលាដំបូងដែលជាអ្នកសម្រេចលើសំណើសុំឱ្យស្តាប់សក្ខីកម្មនេះ។ សេចក្តីសម្រេចនេះជាចម្បងស្របទៅតាមប្រយោគចុងក្រោយនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងដែលបានកំណត់ពីមូលដ្ឋានសំអាងក្នុងការបដិសេធសំណើសុំឱ្យស្តាប់សក្ខីកម្ម។ សេចក្តីសម្រេចនេះ គឺពាក់ព័ន្ធទៅនឹងផ្នែកមួយនៃឆន្ទានុសិទ្ធិដែលអង្គជំនុំជម្រះតុលាការកំពូល ត្រូវទទួលយកជាបានការនូវការយល់ដឹងច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងអំពីរឿងក្តីដោយសារអង្គជំនុំជម្រះជាអ្នកគ្រប់គ្រងផ្ទាល់លើភស្តុតាង ដោយផ្អែកតាមបទដ្ឋាននៃការពិនិត្យឡើងវិញដូចបានលើកឡើងខាងលើ[313]។

## ៤.ខ.២.ក.១.សាក្សី ហេង សំរិន

១៣៤.ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការការពារខ្លួនដោយប្រសិទ្ធភាព ពីព្រោះអង្គជំនុំជម្រះពុំបានកោះហៅ ហេង សំរិន នោះ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា បញ្ហាថាតើសាក្សីរូបនេះគប្បីត្រូវកោះហៅមកផ្តល់សក្ខីកម្ម ដែរ ឬយ៉ាងណា គឺបានកើតឡើងជាច្រើនលើកច្រើនសាមកហើយនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។

១៣៥.នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ កាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ មេធាវីការពារក្តី នួន ជា បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែល*ក្នុង*

---

[310] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣។

[311] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៤។

[312] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៥។

[313] *សូមមើលខាងលើ* កថាខណ្ឌ ៩៧។

*ចំណោមនោះ*បានស្នើសុំឱ្យស្តាប់ចម្លើយ ហេង សំរិន ទាក់ទងទៅនឹងប្រធានបទមួយចំនួន[314]។ នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel LEMONDE បានចេញដីកាកោះហៅសាក្សី ហេង សំរិន[315] ប៉ុន្តែ សាក្សី ហេង សំរិន ពុំបានអនុវត្តតាមដីកាកោះនេះទេ។ នៅក្នុងលិខិតកំណត់សម្គាល់ (Note of International co-investigating Judge) ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា "ដូច្នេះយើងមើលឃើញយ៉ាងច្បាស់ថា បុគ្គលទាំងនោះរួមមាន ហេង សំរិន ផងដែរ បានបដិសេធក្នុងការមកផ្តល់សក្ខីកម្ម"[316]។ ទាក់ទងទៅនឹងបញ្ហា ថាតើគេអាចបង្ខំជនទាំងនោះ រួមមាន ហេង សំរិន ឱ្យចូលមកបង្ហាញខ្លួនដោយប្រើប្រាស់អាជ្ញាធរសាធារណៈបាន ដែរ ឬទេ នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់លើបញ្ហាស្មុគស្មាញនៃអភ័យឯកសិទ្ធិតំណាងរាស្ត្រមានសក្តានុពលដែលបុគ្គលទាំងនោះអាចជ្រកកោនបាន រួមទាំង"ការលំបាកជាក់ស្តែង" ដែល"ក្នុងករណីបែបនេះ អាចនឹងពន្យារពេលដោយឥតសមស្របដល់ការបិទកិច្ចស៊ើបសួរ ដែលផ្ទុយទៅនឹងភាពចាំបាច់ក្នុងការពន្លឿនកិច្ចដំណើរការនីតិវិធី"[317]។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា "យើងគួរទុកលទ្ធភាពជូនអង្គជំនុំជម្រះសាលាដំបូង [...] ក្នុងការប្រើប្រាស់នូវវិធានការចាប់បង្ខំនានា តាមរយៈសិទ្ធិអំណាចនៃការចេញសេចក្តីសម្រេចក្នុងនាមជាស្ថាប័នជំនុំជម្រះក្តី"[318]។

១៣៦.នៅក្នុងដីកាសម្រេចលើសំណើសុំឱ្យកោះហៅសាក្សី (D314) សហចៅក្រមស៊ើបអង្កេត*ក្នុងចំណោមនោះ*បានជូនដំណឹងដល់ភាគីអំពីការខ្វែងយោបល់គ្នារបស់ពួកគេ "លើបញ្ហាទាក់ទងទៅនឹងការដោះស្រាយលើសំណើសុំកោះហៅ និងសាកសួរ [...] ហេង សំរិន [...] អ៊ុក ប៊ុនឈឿន [...]" និងប្រកាសថា "ចំពោះសហចៅក្រមស៊ើបអង្កេតជាតិ សំណើទាំងនេះត្រូវបដិសេធចោល" និង"ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បើទោះបីជាសំណើនេះត្រូវបានទទួលយកជាគោលការណ៍ក៏ដោយ ក៏មិនអាចបំពេញបានដូចមានបញ្ជាក់អំពីហេតុផលនៅក្នុងលិខិតកំណត់សម្គាល់ដោយឡែក ដែលមាននៅក្នុងសំណុំរឿង (E301)"[319]។ ទាក់ទងទៅនឹង

---

[314] សំណើទីដប់របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ (D136)។

[315] ដីកាកោះសាក្សី ហេង សំរិន (D136/3/1)។

[316] លិខិតកំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេត (D301) ទំព័រ ៦។

[317] លិខិតកំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេត (D301) ទំព័រ ៦។

[318] លិខិតកំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេត (D301) ទំព័រ ៦។

[319] ដីកាសម្រេចលើសំណើសុំឱ្យកោះហៅសាក្សី (D314) កថាខណ្ឌ ៣ ដល់ ១៨។

លិខិតកំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេត ដែលបានសម្រេចទុកលទ្ធភាពឱ្យអង្គជំនុំជម្រះសាលាដំបូងដោះស្រាយបញ្ហាទាក់ទងទៅនឹងការប្រើប្រាស់វិធានការចាប់បង្ខំនានា*ក្នុងចំណោមនោះ*សាក្សី ហេង សំរិន នោះ អង្គបុរេជំនុំជម្រះបានយល់ឃើញនៅក្នុងការសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ថា សេចក្ដីសន្និដ្ឋានបែបនេះបានធ្វើឡើងដោយត្រឹមត្រូវ ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះ បានផ្ដល់សំអាងហេតុផ្ទាល់ខ្លួនជំនួសឱ្យសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[320]។ ជាការកត់សម្គាល់ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ជាការ"ពុំអាចទទួលយកបាន"ចំពោះគោលជំហររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា "បុគ្គលដែលត្រូវបានកោះ រួមទាំង [ហេង សំរិន] ផងនោះ បាន*បដិសេធមិនចូលរួមផ្ដល់សក្ខីកម្ម*"[321]។

១៣៧.នៅក្នុងកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នួន ជា បានលើកសំណើម្ដងហើយម្ដងទៀត*ក្នុងចំណោមនោះ*ថា ហេង សំរិន គប្បីត្រូវបានកោះហៅមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[322]។ នួន ជា បានលើកឡើងថា ហេង សំរិន គប្បីផ្ដល់សក្ខីកម្មមិនត្រឹមតែលើព្រឹត្តិការណ៍ដែលជាប្រធានបទនៃបទចោទប្រឆាំងនឹងជនជាប់ចោទប៉ុណ្ណោះទេ ថែមទាំងទាក់ទងទៅនឹងអត្តចរិតរបស់គាត់ដែលជាបញ្ហាជាប់ពាក់ព័ន្ធទៅនឹងការប្រកាសទោស ប្រសិនបើមានការសម្រេចដាក់ពិរុទ្ធភាពនោះ[323]។

១៣៨.អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសំណើសុំកោះហៅសាក្សី ហេង សំរិន មកផ្ដល់សក្ខីកម្មនៅក្នុងសេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312)។ ចៅក្រម និល ណុន យ៉ា សុខន និង យូរ ឧត្តរា ("មតិភាគច្រើន") បានយល់ឃើញថា ហេង សំរិន ពុំគួរគប្បីកោះហៅមកផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះឡើយ[324]។ មតិភាគច្រើនបានធ្វើការកត់សម្គាល់ថា "ដីកាកោះ គឺជាដីកាបង្គាប់ដល់បុគ្គលណាម្នាក់ឱ្យចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក. ក្នុងករណីដែលមិនបានអនុវត្តតាមដីកានេះទេ នោះអាចនឹងនាំឱ្យមានការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ"[325]។ ដោយបានរំឭកពីប្រវត្តិនីតិវិធីទាក់ទងទៅនឹងសំណើសុំឱ្យ ហេង សំរិន មកផ្ដល់សក្ខីកម្ម

---

[320] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឱ្យកោះហៅសាក្សី (D314/1/8 D314/2/7)។

[321] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឱ្យកោះហៅសាក្សី (D314/1/8 D314/2/7) កថាខណ្ឌ ៦៨។

[322] *សូមមើល* សំណើទីប្រាំមួយរបស់ នួន ជា សុំឱ្យកោះហៅសាក្សី ហេង សំរិន (E236/5/1/1) កថាខណ្ឌ ៣ ដល់ ៧ (រៀបរាប់សំណើផ្សេងៗទៀតដែលស្នើសុំឱ្យកោះហៅ ហេង សំរិន ដែល នួន ជា បានស្នើសុំនៅមុខអង្គជំនុំជម្រះសាលាដំបូង)។

[323] សំណើទីប្រាំរបស់ នួន ជា សុំឱ្យកោះហៅសាក្សី ហេង សំរិន (E236/5/1)។

[324] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៨៧ ដល់ ១០៣។

[325] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៨៩។

នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរនោះ មតិភាគច្រើនបានកត់សម្គាល់ថា ហេង សំរិន "បានបដិសេធមិនមកផ្ដល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក."[326] និងថា "បញ្ហាចោទនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ គឺមិនត្រឹមតែពិចារណាលើបញ្ហា ថាតើគួរ ឬមិនគួរចេញដីកាកោះប៉ុណ្ណោះទេ ថែមទាំងត្រូវពិចារណាផងដែរ ថាតើគួរ ឬមិនគួរប្រើប្រាស់វិធានការចាប់បង្ខំ ដែរ ឬយ៉ាងណា"[327]។ មតិភាគច្រើនបានរំឭកការយល់ឃើញរបស់អង្គបុរេជំនុំជម្រះដែលថា "លទ្ធភាពនៃការដកអភ័យឯកសិទ្ធិតំណាងរាស្ត្រអាចមានការពន្យារពេលយូរ ទម្រាំដល់ពេល ហេង សំរិន អាចមកផ្ដល់សក្ខីកម្មនៅក្នុងដំណាក់កាលស៊ើបអង្កេត"[328]។

១៣៩.ទាក់ទងទៅនឹងភាពជាប់ពាក់ព័ន្ធនៃសក្ខីកម្មរបស់ ហេង សំរិន ដែលគេរំពឹងទុកនោះ មតិភាគច្រើនបានរំឭកនូវប្រធានបទទាក់ទងទៅនឹងខ្លឹមសារដែលបានស្នើសុំនេះ[329] និងបានពន្យល់ថា តាមការវាយតម្លៃរបស់ខ្លួន ប្រធានបទនេះត្រូវបានដោះស្រាយរួចរាល់ហើយនៅក្នុងសេចក្ដីសម្រេចស្ដីពីប្រវត្តិនីតិវិធី ឬដោយសារពុំមានជាប់ពាក់ព័ន្ធទៅនឹងការជំនុំជម្រះ (ដូចជា ការជ្រៀតជ្រែកខាងនយោបាយ និងតួនាទីរបស់វៀតណាម) ហើយសក្ខីកម្មរបស់ ហេង សំរិន ស្ដីពីប្រធានបទដទៃទៀត"មានភាពច្រំដែល" ឬ"ពុំមែនជារឿងថ្មី"(វចនាសម្ព័ន្ធយោធា និងការជម្លៀសចេញពីទីក្រុងភ្នំពេញ)[330]។ ទាក់ទងទៅនឹងសក្ខីកម្មដែលអាចជាប់ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ នោះ មតិភាគច្រើនបានរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់ភស្ដុតាងពាក់ព័ន្ធទៅនឹងបញ្ហានេះ ដូច្នេះ មានន័យថា "ភស្ដុតាងបន្ថែមណាមួយនោះអាចនឹងមានលក្ខណៈច្រំដែល" និងថា នួន ជា ទំនងជាព្យាយាមបញ្ចុះបញ្ចូលអង្គជំនុំជម្រះតាមរយៈការបញ្ជាក់ថា នួន ជា បានប្រើប្រាស់ពាក្យ*កម្ចាត់* ពុំមែនពាក្យ*កម្ទេច* នៅពេលពិពណ៌នាអំពីគោលនយោបាយ ប.ក.ក. ចំពោះទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះ[331]។ មតិភាគច្រើនមានមន្ទិលសង្ស័យទាក់ទងទៅនឹងភាពជាប់ពាក់ព័ន្ធនៃបញ្ហានេះ ដោយបានកត់សម្គាល់លើសក្ខីកម្មរបស់សាក្សីជំនាញ Stephen HEDER អំពីអត្ត

[326] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩០។

[327] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩៧។

[328] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី កថាខណ្ឌ ៩១ ដកស្រង់សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឱ្យកោះហៅសាក្សី (D314/2/7 D314/1/8) កថាខណ្ឌ ៦៩។

[329] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩២។

[330] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩៣។

[331] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩៤។

ន័យនៃពាក្យ*កម្មាត់* ដែលមេធាវីពុំបានតវ៉ានៅពេលនោះឡើយ[332]។ ផ្អែកតាមទិដ្ឋភាពមានកម្រិតនៃរឿងក្ដីដែលអាចជាប់ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ ហេង សំរិន នោះ តាមការយល់ឃើញរបស់ខ្លួន មតិភាគច្រើនបានសន្និដ្ឋានថា ពុំបានត្រៀមលក្ខណៈចេញដីកាកោះឡើយ[333]។ ទាក់ទងទៅនឹងសិទ្ធិរបស់ នួន ជា ក្នុងការសុំឱ្យកោះហៅសាក្សីដើម្បីការពារខ្លួននោះ មតិភាគច្រើនពិចារណាថា នួន ជា ពុំបានទទួលរងផលប៉ះពាល់ដោយសារសេចក្ដីសម្រេចមិនកោះហៅ ហេង សំរិន ឡើយ ពីព្រោះមិន“គួរឱ្យជឿបាន”ថា សក្ខីកម្មរបស់គាត់នឹងមានប្រយោជន៍ធំធេងដល់ការការពារខ្លួនរបស់ នួន ជា នោះទេ[334]។ មតិភាគច្រើនបានសង្កេតឃើញថា កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ Ben KIERNAN ជាមួយ ហេង សំរិន ដែលត្រូវបានទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បាន“បង្ហាញគួរឱ្យជឿជាក់បាន”ថា ហេង សំរិន ពិតជាបានផ្ដល់ចម្លើយដែល នួន ជា មានបំណងយកមកសំអាង និងថា “ការកោះហៅសាក្សីនេះមកបញ្ជាក់ខ្លឹមសារនៃកិច្ចសម្ភាសន៍នោះ ក៏ពុំអាចបង្ហាញឱ្យឃើញពីនត្ថិភាពនៃគោលនយោបាយកម្ទេចអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះដែរ។ បញ្ហានេះគប្បីត្រូវបានថ្លឹងថ្លែងដោយផ្អែកលើភស្តុតាងទាំងមូល”[335]។

១៤០.ទាក់ទងទៅនឹងសំណើសុំកោះហៅសាក្សី ហេង សំរិន មកធ្វើជា“សាក្សីអត្តចរិត” មតិភាគច្រើនកត់សម្គាល់ឃើញថា ភស្តុតាងអំពីអត្តចរិតល្អរបស់ជនជាប់ចោទមុនព្រឹត្តិការណ៍ដែលជនជាប់ចោទត្រូវបានចោទប្រកាន់នេះពុំជាប់ពាក់ព័ន្ធ[336]ឡើយ។ មតិភាគច្រើនពុំយល់ស្របជាមួយនឹងការលើកឡើងរបស់ នួន ជា ដែលថា ទំនាក់ទំនងការងាររបស់គាត់ជាមួយ ហេង សំរិន បានបន្តរហូតដល់អំឡុងពេលដែលជាប់ពាក់ព័ន្ធទៅនឹងបទចោទនោះទេ[337]។ មតិភាគច្រើនបានបង្ហាញក្ដីបារម្ភថា នួន ជា លើកសំណើសុំកោះហៅ ហេង សំរិន នេះ “ក្នុងគោលបំណងព្យាយាមបង្កឱ្យមានភាពចម្រូងចម្រាស” និងថា នេះ គឺជា“យុទ្ធសាស្ត្រមកលើការជំនុំជម្រះ”[338]។ មតិភាគច្រើនបានកត់សម្គាល់ថា លទ្ធភាពដែលអាចធ្វើទៅបានក្នុងការដោះស្រាយ“បញ្ហាជាប់ពាក់ព័ន្ធនេះ [...] គឺត្រឹមតែការផ្ដល់ទម្ងន់ជាភស្តុតាងតិចតួចដល់សក្ខីកម្ម”នោះប៉ុណ្ណោះ ប៉ុន្តែបានសន្និដ្ឋានថា សំណើសុំឱ្យកោះ

---

[332] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩៥។

[333] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩៦។

[334] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩៨។

[335] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ៩៨។

[336] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១១៦។

[337] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១១៧។

[338] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១១៧។

01358009



ហៅសាក្សី ហេង សំរិន គប្បីត្រូវបដិសេធចោល ដោយសារ តាមការយល់ឃើញរបស់ខ្លួន ទំនងជាថា ការទទួលយកសំណើនេះនឹងអាចអូសបន្លាយពេលវេលានៃកិច្ចដំណើរការនីតិវិធី និងថា សំណើនេះ គឺធ្វើឡើងក្នុងហេតុផលយុទ្ធសាស្ត្រ[339]។

១៤១.ចៅក្រម Silvia CARTWRIGHT និង Jean-Marc LAVERGNE ("មតិភាគតិច") ពុំយល់ស្រប ជាមួយនឹងសេចក្ដីសន្និដ្ឋានរបស់មតិភាគច្រើនត្រង់ ថាតើ ហេង សំរិន គប្បីត្រូវកោះហៅ ដែរ ឬយ៉ាងណា[340]។ មតិភាគតិចបានរំឭកថា ដូចពលរដ្ឋទូទៅដែរ ហេង សំរិន មានកាតព្វកិច្ចជួយដល់តុលាការក្នុងការស្វែងរកការពិត ដោយបានកត់សម្គាល់ទៅលើសារៈសំខាន់នៃរឿងក្ដីសម្រាប់ប្រជាជនកម្ពុជាទាំងមូល[341]។ មតិភាគតិចបានបញ្ជាក់ថា បញ្ហាអភ័យឯកសិទ្ធិសភាអាចយកមកប្រើប្រាស់តែក្នុងករណីដែលសាក្សីបដិសេធមិនព្រមមកផ្ដល់សក្ខីកម្មតែប៉ុណ្ណោះ និងថា លទ្ធភាពដែលសាក្សីអាចជ្រកកោនក្រោមអភ័យឯកសិទ្ធិនេះ "ពុំអាចបញ្ឈប់កាតព្វកិច្ចរបស់អង្គជំនុំជម្រះមិនឱ្យកោះហៅសាក្សីមកស្ដាប់សក្ខីកម្មបានឡើយ"[342]។ មតិភាគតិចបានរំឭកថា អភ័យឯកសិទ្ធិត្រូវបង្ហាញឱ្យឃើញប្រាកដ ថា ពិតជាបានយកមកប្រើប្រាស់ដោយបុគ្គលពាក់ព័ន្ធមែន "ជាជាងត្រឹមតែជាការរំពឹងទុកយ៉ាងដូច្នោះពីអង្គជំនុំជម្រះ" និងថា ពុំមាន"ព័ត៌មានបង្ហាញថា សាក្សីសក្ដានុពលទាំងនេះបានបង្ហាញឆន្ទៈផ្ទាល់ខ្លួនណាមួយមិនព្រមមកផ្ដល់សក្ខីកម្មក្នុងតុលាការនោះឡើយ"[343]។ អាស្រ័យហេតុនេះ តាមការយល់ឃើញរបស់មតិភាគតិច បញ្ហា ថាតើអភ័យឯកសិទ្ធិសភាអាចយកមកប្រើប្រាស់ និងរារាំង ហេង សំរិន មិនឱ្យមកផ្ដល់សក្ខីកម្ម ដែរ ឬយ៉ាងណានោះ គឺជា"ការប៉ាន់ស្មាន និងពុំជាប់ពាក់ព័ន្ធឡើយ"[344]។ មតិភាគតិចបានរំឭកថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តឱ្យបានស្មើៗគ្នាចំពោះសាក្សីទាំងអស់ និងថា "ការជំនុំជម្រះនៅ អ.វ.ត.ក. មានគោលបំណងជំរុញឱ្យមានការផ្សះផ្សាជាតិ លើកស្ទួយកាតព្វកិច្ចដើម្បីបម្រើយុត្តិធម៌ ដែលមន្ត្រីរបស់កម្ពុជា តាមការសន្មត ត្រូវតែមានការយកចិត្តទុកដាក់"[345]។ មតិភាគតិចបានលើកហេតុផល

---

[339] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១១៨។

[340] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១០៤ ដល់ ១១១។

[341] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១០៦។

[342] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១០៧។

[343] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១០៧។

[344] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១០៧។

[345] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី (E312) កថាខណ្ឌ ១០៩។

បន្ថែមទៀតថា ហេង សំរិន ទំនងជាមានព័ត៌មានដែលសាក្សីផ្សេងទៀតពុំបានដឹង[346] អាស្រ័យហេតុនេះ គប្បីកោះហៅមកធ្វើជាសាក្សី[347]។ ទាក់ទងទៅនឹងបញ្ហានៃការពន្យារពេលដែលអាចបណ្តាលមកពីការកោះហៅសាក្សី ហេង សំរិន មតិភាគតិចបានយល់ឃើញថា ការពន្លឿនកិច្ចដំណើរការនីតិវិធីពុំអាចយកមកធ្វើយុត្តិកម្មសម្រាប់ការសម្រេចមិនកោះហៅសាក្សីដែលអាចមានសារៈសំខាន់បានឡើយ និងថា អង្គជំនុំជម្រះសាលាដំបូងគប្បីកោះហៅសាក្សីនេះនៅដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ប្រសិនបើមានមតិភាគច្រើនតម្រូវឱ្យធ្វើដូច្នោះ[348]។ មតិភាគតិចបានសម្រេចមិនបញ្ចេញមតិយោបល់លើបញ្ហា ថាតើការសម្រេចមិនកោះហៅ ហេង សំរិន នាំឱ្យមានការរំលោភបំពានលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ ដែរ ឬយ៉ាងណានោះទេ[349]។

១៤២.នួន ជា បានលើកឡើងជាចម្បងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនព្រមកោះហៅ ហេង សំរិន ក្នុងន័យថា អង្គជំនុំជម្រះសាលាដំបូងខ្វះឯករាជភាព បញ្ហានេះអង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយរួចហើយ[350]។ ទោះជាយ៉ាងណាក្តី នួន ជា ក៏បានលើកឡើងផងដែរថា ការសម្រេចមិនកោះហៅ ហេង សំរិន បានរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការការពារខ្លួនដោយប្រសិទ្ធភាពដែលមានឥទ្ធិពលផ្ទាល់ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងគោលនយោបាយរបស់ ប.ក.ក. ចំពោះអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ[351]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនកោះហៅ ហេង សំរិន គឺជាការប្រើប្រាស់ឆន្ទានុសិទ្ធិត្រឹមត្រូវ[352] និងថា នៅគ្រប់កាលៈទេសៈទាំងអស់ នួន ជា ពុំបានបង្ហាញពីផលប៉ះពាល់ណាមួយដោយសារការដែល ហេង សំរិន មិនបានមកផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះឡើយ[353]។

---

[346] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០៨។

[347] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០៨។

[348] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១១០។

[349] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១១១។

[350] *សូមមើលខាងលើ* កថាខណ្ឌ ១២២ *ជាអាទិ៍*។

[351] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៥។ *សូមមើលផងដែរ* កថាខណ្ឌ ៥៦៩ ដល់ ៥៧០។

[352] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៩ ដល់ ៤៧។

[353] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៨ ដល់ ៥៤។

១៤៣.ដោយសារបញ្ហា ថាតើ ហេង សំរិន គប្បីត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម ដែរ ឬយ៉ាងណានោះ គឺពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឆន្ទានុសិទ្ធិ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវថ្លឹងថ្លែងអំពីភាពត្រឹមត្រូវនៃការសម្រេចមិនកោះហៅ ហេង សំរិន ជាមួយនឹងបទដ្ឋាននៃការពិនិត្យឡើងវិញក្នុងការទទួលយកជាបានការនូវសេចក្តីសម្រេចដែលជាឆន្ទានុសិទ្ធិ[354]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅពេលដែលរកឃើញថាមានកំហុស គឺតម្រូវឱ្យមានការបង្ហាញ ថាតើកំហុសនេះ"បណ្តាលឱ្យមានការប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខ មានន័យថា "កំហុសនេះនាំឱ្យលទ្ធផលខុសឆ្គងធ្ងន់ធ្ងរនៅក្នុងកិច្ចដំណើរការនីតិវិធី ដែរ ឬយ៉ាងណា"[355]។

១៤៤.លក្ខណៈវិនិច្ឆ័យដែលសំខាន់បំផុតសម្រាប់សេចក្តីសម្រេចទាក់ទងទៅនឹងបញ្ហា ថាតើសាក្សីត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ដែរ ឬយ៉ាងណា គឺជាភាពជាប់ពាក់ព័ន្ធនៃសក្ខីកម្មទៅនឹងព្រឹត្តិការណ៍ដែលជាកម្មវត្ថុនៃបទចោទទាំងនោះ។ ជាមួយគ្នានេះដែរ និងជាពិសេស នៅពេលសាក្សីសក្តានុពលមួយចំនួន ឬមធ្យោបាយដទៃទៀតដែលជាភស្តុតាង មានអត្ថិភាពពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នោះ អង្គជំនុំជម្រះនឹងត្រូវជ្រើសរើសយកសាក្សីដែលត្រូវកោះហៅ ក្នុងគោលបំណងដើម្បីធានានូវការពន្លឿនកិច្ចដំណើរការនីតិវិធី។ ការសម្រេចបែបនេះបានឆ្លុះបញ្ចាំង*ក្នុងចំណោមទោះ*នៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដែលរៀបរាប់ពីមូលដ្ឋានសម្រាប់ការបដិសេធសំណើសុំឱ្យពិនិត្យភស្តុតាង រួមមានភស្តុតាងដែល"មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា"។ ជាទូទៅ អង្គជំនុំជម្រះសាលាដំបូងគប្បីប្រឹងប្រែងរកសាក្សី ឬមធ្យោបាយផ្សេងៗដែលជាភស្តុតាងដែលអាចបំភ្លឺលើព្រឹត្តិការណ៍នោះបានល្អប្រសើរ។

១៤៥.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នួន ជា បានស្នើសុំឱ្យកោះហៅ ហេង សំរិន មកធ្វើជាសាក្សីដោយផ្អែកលើតួនាទីរបស់ ហេង សំរិន ជាអតីតអនុមេបញ្ជាការកងពលភូមិភាគបូព៌ា និងជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលមានឋានៈខ្ពស់បំផុតដែលនៅរស់ និងមានការជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ ដែលជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗនៅក្នុងសំណុំរឿង ០០២/០១។ យោងតាមកំណត់ហេតុនៃបទសម្ភាសន៍របស់ ហេង សំរិន ដែលបានធ្វើឡើងជាមួយនឹង Ben KIERNAN នួន ជា ក៏បានអះអាងផងដែរថា ហេង សំរិន អាចផ្តល់សក្ខីកម្មទាក់ទងទៅនឹងកិច្ចប្រជុំមួយនៅទីក្រុងភ្នំពេញដែលបានប្រព្រឹត្តឡើងកាលពីថ្ងៃទី ២០ ខែ

---

354 *សូមមើលខាងលើ* កថាខណ្ឌ ៩៧ *ជាអាទិ៍*។

355 *សូមមើលខាងលើ* កថាខណ្ឌ ១០០។

ឧសភា ឆ្នាំ ១៩៧៥ ដែលនៅពេលប្រជុំនោះគោលនយោបាយរបស់ ប.ក.ក. ត្រូវបានផ្សព្វផ្សាយផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សក្ខីកម្មរបស់ ហេង សំរិន អាចមានការជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/០១ ជាការពិតមួយដែលមិនត្រឹមតែមតិភាគតិចបានទទួលស្គាល់ប៉ុណ្ណោះទេ ថែមទាំងមតិភាគច្រើននៃអង្គជំនុំជម្រះសាលាដំបូងក៏បានទទួលស្គាល់ផងដែរ ប៉ុន្តែនៅក្នុងកម្រិតតិចតួចប៉ុណ្ណោះ[356]។

១៤៦.ទោះជាយ៉ាងណាក្តី បើទោះបីជាបានទទួលស្គាល់ថា សក្ខីកម្មរបស់ ហេង សំរិន អាចមានភាពជាប់ពាក់ព័ន្ធ និងមានសារៈសំខាន់យ៉ាងណាក៏ដោយ ក៏មតិភាគច្រើនបានពិចារណាថា ពុំគប្បីកោះហៅឡើយ ដោយសារមូលហេតុពន្យារពេលដែលទំនងជាបណ្តាលមកពីការចេញសេចក្តីសម្រេចកោះហៅ ហើយនឹងអាច“ធ្វើឱ្យអង្គជំនុំជម្រះធ្លាក់ចូលទៅក្នុងស្ថានភាពមួយដែលពោរពេញទៅដោយភាពលំបាកលំបិន”[357]។ ហេតុផលសម្រាប់ការពន្យារពេល និងការលំបាកដែលមានដូចការរំពឹងទុកនេះ គឺជាការសន្មតប៉ុណ្ណោះដែលថា ហេង សំរិន ពុំមានឆន្ទៈគោរពតាមដីកាកោះ ថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែសំអាងលើវិធានការចាប់បង្ខំក្នុងការអនុវត្តដីកានេះ ថា ហេង សំរិន អាចនឹងយកអភ័យឯកសិទ្ធិសភាមកប្រើប្រាស់ទាក់ទងទៅនឹងវិធានការចាប់បង្ខំនោះ និងថា ស្ថានភាពនេះពុំអាចដោះស្រាយបានក្នុងពេលឆាប់ៗឡើយ។

១៤៧.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសន្មតនេះ បានផ្អែកជាមូលដ្ឋានយ៉ាងធំលើការប៉ាន់ស្មានប៉ុណ្ណោះ ដូច្នេះ ពុំអាចក្លាយជាមូលដ្ឋានសមស្របសម្រាប់ការប្រើប្រាស់ឆន្ទានុសិទ្ធិឡើយ។ ដូចបានលើកឡើងខាងលើ មានតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិប៉ុណ្ណោះដែលបានព្យាយាមស្វែងរកសក្ខីកម្មរបស់ ហេង សំរិន នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរអស់រយៈពេលជិតប្រាំឆ្នាំនៅមុនអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេច។ បើទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋាន*សម្រាប់គោលបំណងនៃកិច្ចស៊ើបសួរ* ថា ហេង សំរិន បានបដិសេធមិនផ្តល់សក្ខីកម្ម និងថា មានបញ្ហាអភ័យឯកសិទ្ធិសភាជាសក្តានុពល អាចបង្កឱ្យមានការពន្យារពេលក៏ដោយ[358] ក៏ពុំមានការប្រឹងប្រែងបន្ថែមទៀតត្រូវបានធ្វើឡើងដើម្បីកោះហៅនោះឡើយ។ លើសពីនេះទៀត ពុំមានការអះអាងណាមួយរបស់ ហេង សំរិន នៅក្នុងសំណុំរឿងបង្ហាញថា គាត់មានឆន្ទៈជាក់ស្តែងពុំមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងយកអភ័យឯកសិទ្ធិសភាមកប្រើប្រាស់

---

[356] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៩៦៖ (ទទួលស្គាល់ថា “បើទោះបីជាទទួលយកក៏ដោយ ក៏សក្ខីកម្មរបស់សាក្សី [ហេង សំរិន] អាចពាក់ព័ន្ធតិចតួចនៅក្នុងសំណុំរឿង ០០២/០១”។

[357] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៩៧។

[358] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត (D301) ទំព័រ ៦។

ឡើយ ប្រសិនបើគាត់ត្រូវបានកោះហៅមែននោះ។ ជាការពិត អង្គបុរេជំនុំជម្រះបានរិះគន់ថា ជាការពុំអាចទទួលយកបានទេចំពោះការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែល*ក្នុងចំណោមនោះ* ថា ហេង សំរិន "បានបដិសេធមិនចូលមកផ្តល់សក្ខីកម្ម"នោះ[359]។ បើទោះបីជា មានការសន្មតថា ហេង សំរិន ពុំមានឆន្ទៈមកផ្តល់សក្ខីកម្មនៅដំណាក់កាលស៊ើបសួរក៏ដោយ ក៏ពុំមានការបញ្ជាក់ថា ហេង សំរិន បានរក្សាគោលជំហរនេះដដែល នៅពេលរឿងក្តីជាក់ស្តែងបានមកដល់ដំណាក់កាលជំនុំជម្រះ។ ផ្ទុយទៅវិញ គេអាចសន្មតបានថា អ្នកនយោបាយនាំមុខគេរបស់កម្ពុជា ពុំស្ទាក់ស្ទើរក្នុងការរួមចំណែកបំពេញអាណត្តិរបស់ អ.វ.ត.ក. ដែលជាស្ថាប័នមួយបង្កើតឡើងដោយច្បាប់ដែលបានអនុម័តដោយសភាជាតិកម្ពុជាតែមួយ ហើយគាត់ជាប្រធាន។

១៤៨.អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគប្បីប្រឹងប្រែងទទួលបានការចូលខ្លួនរបស់សាក្សី ហេង សំរិន មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ មានតែក្នុងករណីដែល ហេង សំរិន បដិសេធមិនឆ្លើយតបទៅនឹងដីកាកោះប៉ុណ្ណោះ ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវប្រើប្រាស់វិធានការចាប់បង្ខំ ហើយប្រសិនបើសាក្សីយកអភ័យឯកសិទ្ធិសភាមកប្រើប្រាស់ នោះអង្គជំនុំជម្រះត្រូវសម្រេចអំពីផលប៉ះពាល់នៃការប្រើប្រាស់អភ័យឯកសិទ្ធិទៅលើការអនុវត្តវិធានការនោះ។ មានតែក្នុងករណីដែលបង្ហាញថា ពុំអាចមានលទ្ធភាពទទួលបានសក្ខីកម្មពីសាក្សី ហេង សំរិន ទាល់តែសោះ ឬអាចទទួលបានក្នុងពេលវេលាពុំសមស្របប៉ុណ្ណោះ ដែលសំណើសុំនេះត្រូវបដិសេធចោលដោយសមហេតុផល តាមវិធាន ៨៧(៣-ខ) នៃវិធានផ្ទៃក្នុង។

១៤៩.ទាក់ទងទៅនឹងលទ្ធភាពដែលបង្កឱ្យមានការពន្យារពេលនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បញ្ហាថាតើ ហេង សំរិន គប្បីចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណានោះ ត្រូវបានដឹងឮនៅពេលរឿងក្តីនេះបានមកដល់អង្គជំនុំជម្រះសាលាដំបូង។ នួន ជា បានស្នើសុំឱ្យកោះហៅ ហេង សំរិន មកធ្វើជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជាលើកដំបូងនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១១[360] និងបន្ទាប់មកបានលើកសំណើនេះជាច្រើនលើកច្រើនសា។ ប៉ុន្តែផ្ទុយទៅវិញ អស់រយៈពេលបីឆ្នាំកន្លះគិតចាប់ពីសំណើលើកទីមួយនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយលើសំណើនេះនៅក្នុងខែសីហា ឆ្នាំ ២០១៤ ប៉ុណ្ណោះ។ នេះពុំមានការបញ្ជាក់ថា បញ្ហានៃការចូលបង្ហាញខ្លួនរបស់ ហេង សំរិន

---

[359] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំកោះហៅសាក្សី (D314/2/7 D314/1/8) កថាខណ្ឌ ៦៨។

[360] ឧបសម្ព័ន្ធទៅនឹងសេចក្តីសង្ខេបរបស់ នួន ជា អំពីសាក្សីដែលបានស្នើឡើង (E9/10.1) ទំព័រ ៦៨។

01358014



ក្នុងនាមជាសាក្សី ត្រូវបានដោះស្រាយនៅក្នុងពេលនោះឡើយ។ អាស្រ័យហេតុនេះ ការសន្និដ្ឋានណាមួយរបស់មតិភាគច្រើនទៅលើការពន្យារពេលជាសក្តានុពលនោះ ពុំជាប់ពាក់ព័ន្ធ និងពុំអាចធ្វើយុត្តិកម្មបានឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលអាចសន្និដ្ឋានថា ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសំណើសុំឱ្យកោះហៅសាក្សី ហេង សំរិន ពុំសមហេតុផលឡើយ និងមានកំហុស។

១៥០.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដូចបានលើកឡើងខាងលើ ជាពិសេសប្រសិនបើមានសាក្សី ឬភស្តុតាងមួយចំនួនទាក់ទងទៅនឹងកម្មវត្ថុនៃអង្គហេតុដូចគ្នា អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចមិនកោះហៅទាំងអស់ឡើយ ប៉ុន្តែអាចកោះហៅត្រឹមតែសាក្សីណាដែលមានការពាក់ព័ន្ធច្រើនបំផុតនៅក្នុងរឿងក្តីចំពោះមុខប៉ុណ្ណោះ[361]។

១៥១.នួន ជា បានលើកឡើងថា ហេង សំរិន គឺ“ជាសាក្សីសំខាន់បំផុត”ទាក់ទងទៅនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[362]។ ដោយសារ ហេង សំរិន ទទួលបន្ទុកកងវរសេនាធំលេខ ១២៦ នៃកងពលធំលេខ ១ ក្នុងភូមិភាគបូព៌ា និងជាអនុមេបញ្ជាការកងពលធំលេខ ១ នួន ជា បានអះអាងថា ហេង សំរិន ប្រាកដជា“បានដឹងដោយផ្ទាល់”ពីបទបញ្ជារបស់កម្មាភិបាលថ្នាក់កំពូលទាក់ទងទៅនឹងការជម្លៀស និងទាក់ទងទៅនឹង“ជម្លោះរវាងភូមិភាគ និងភូមិភាគក្នុងចំណោមកងកម្លាំងដែលបានរំដោះទីក្រុងភ្នំពេញ”[363]។ លើសពីនេះទៀត នួន ជា បានអះអាងថា សក្ខីកម្មរបស់ ហេង សំរិន អាចនឹងដោះបន្ទុកដោយផ្អែកលើបទសម្ភាសន៍របស់ Ben KIERNAN ជាមួយ ហេង សំរិន។ ជាពិសេស នួន ជា បានលើកឡើងថា យោងតាមកំណត់ហេតុនៃបទសម្ភាសន៍ ហេង សំរិន បានអះអាងថា នៅពេលប្រជុំក្នុងទីក្រុងភ្នំពេញកាលពីខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា បានប្រើប្រាស់ពាក្យមួយទាក់ទងទៅនឹងគោលនយោបាយរបស់ ប.ក.ក. ចំពោះអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរថា គប្បី“ដកអ្នកទាំងនេះចេញពីក្របខ័ណ្ឌ” ប៉ុន្តែពុំមែនឱ្យសម្លាប់នោះទេ។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានអះអាងថា សក្ខីកម្មរបស់ ហេង សំរិន ពុំមានអ្វីប្លែក និងពុំមែនជាភស្តុតាងដោះបន្ទុកនោះទេ[364]។

---

[361] *សូមមើល*ទាក់ទងទៅនឹងបញ្ហានេះ សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៩១។

[362] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩។

[363] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩, ៦៤ (ជើងទំព័រ ១៥១)។

[364] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨។

01358015



១៥២.ដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ពុំមានការបញ្ជាក់ណាមួយដែលថា ហេង សំរិន បានទទួលព័ត៌មានទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលសាក្សីដទៃទៀតពុំបានដឹងនោះឡើយ។ បើទោះបីគាត់ជាមេបញ្ជាការកងវរសេនាធំលេខ ១២៦ និងជាអនុមេបញ្ជាការកងពលធំលេខ ១ នៅក្នុងអំឡុងពេលជាប់ពាក់ព័ន្ធនោះក៏ដោយ ក៏គាត់បានទទួលបទបញ្ជាពី ច័ន្ទ ចក្រី ជាមេបញ្ជាការកងពលធំដែលត្រូវរាយការណ៍ទៅលេខាភូមិភាគ ដូចដែល នួន ជា បានទទួលស្គាល់[365]។ នៅក្នុងសំណុំរឿង ពុំមានការបញ្ជាក់ថា គាត់មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងសេចក្តីណែនាំ ឬបទបញ្ជាដែលចេញពីមជ្ឈិមបក្សនោះទេ ផ្ទុយទៅវិញ ព័ត៌មាននេះត្រូវបានបញ្ជូនបន្តមកឱ្យ នួន ជា តាមរយៈមេបញ្ជាការកងពលរបស់គាត់[366] ដែលស៊ីសង្វាក់ជាមួយនឹងខ្សែបណ្តាញនៃការទំនាក់ទំនង ដែលបានអះអាងដោយអតីតមេបញ្ជាការកងវរសេនាធំម្នាក់ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[367]។ អង្គជំនុំជម្រះតុលាការកំពូលក៏កត់

---

[365] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦៣។

[366] កំណត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713946 (ហេង សំរិន បានអះអាងថា គាត់មិនបានចូលរួមផ្ទាល់នៅក្នុងកិច្ចប្រជុំដែលមជ្ឈិមបក្សបានផ្តល់ការណែនាំពាក់ព័ន្ធទៅនឹងការវាយប្រហារ និងការជម្លៀសទីក្រុងភ្នំពេញដោយផ្ទាល់នោះទេ ប៉ុន្តែគាត់ត្រូវបានប្រាប់ត្រួសៗដោយមេបញ្ជាការកងពលធំរបស់គាត់ គឺចក្រី)។ *សូមមើលផងដែរផងដែរ* កំណត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713956-7 (បានអះអាងថា ក្រៅពីនៅក្នុងកិច្ចប្រជុំប្រជាហែលក្នុងថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ គាត់ធ្លាប់បានជួប ប៉ុល ពត ម្តងទៀតប៉ុណ្ណោះ ក្នុងពេល"ប្រជុំធំ"ក្នុងឆ្នាំ ១៩៧៧)។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះ ចំណុចនេះផ្ទុយគ្នាទៅនឹងសម្មតិកម្មដែលថា ហេង សំរិន មានទំនាក់ទំនងផ្ទាល់ជាមួយនឹងមជ្ឈិមបក្សនៅពេលជម្លៀសនោះ។

[367] សាក្សី មាស វឿន ដែលប្រហាក់ប្រហែលនឹង ហេង សំរិន ដែរ គឺជាមេបញ្ជាការកងវរសេនាធំទទួលបន្ទុកលើទាហាន ៦០០ នាក់ នៅក្នុងអំឡុងពេលវាយប្រហារទីក្រុងភ្នំពេញ។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/129.1 ទំព័រ ៧១, ៧៦, ៧៨។ គាត់បានផ្តល់សក្ខីកម្មថា គាត់បានទទួលបទបញ្ជាពីមេបញ្ជាការកងពល I ដែលរាយការណ៍ផ្ទាល់ទៅលេខាភូមិភាគ និងថា អ្វីដែលគាត់បានដឹងគឺត្រឹមកម្រិតភូមិភាគ។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/129.1 ទំព័រ ៧២ ដល់ ៧៩ និងប្រតិចារឹកចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/130.1 ទំព័រ ១៨ និងប្រតិចារឹកចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/132.1 ទំព័រ ១០។ គាត់បានបញ្ជាក់ថា គាត់ពិតជាបានទទួលផែនការវាយប្រហារទីក្រុងភ្នំពេញពីមេបញ្ជាការកងពលធំ ដែលបានទទួលក្នុងអំឡុងពេលប្រជុំដែលដឹកនាំដោយ នួន ជា។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/129.1 ទំព័រ ៧៤ និងប្រតិចារឹកចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/130.1 ទំព័រ ៧៣។ អ៊ុង រ៉េន ដែលជាមេបញ្ជាការកងវរសេនាធំ បានអះអាងថា គាត់ពុំបានដឹងអំពីទំនាក់ទំនងរវាងមេបញ្ជាការកងពលធំ និងថ្នាក់លើឡើយ។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី

សម្គាល់ផងដែរថា មន្ត្រីយោធាដែលបានបង្ហាញខ្លួនជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជាក់ស្តែង ត្រូវបានសួរដេញដោលយ៉ាងទូលំទូលាយទាក់ទងទៅនឹងបទបញ្ជា ដែលត្រូវបានធ្វើឡើងពាក់ព័ន្ធទៅនឹងការវាយប្រហារ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[368]។ ដូច្នេះ ពុំមែនមានតែសក្ខីកម្មរបស់ ហេង សំរិន តែមួយគត់នោះឡើយ។ ទីពីរ ផ្អែកតាម នួន ជា បានឱ្យដឹងថា តម្លៃស្នូលនៃសក្ខីកម្មរបស់ ហេង សំរិន គឺថា គាត់ "បានចូលរួមយ៉ាងសកម្ម"នៅក្នុងជម្លោះរវាងភូមិភាគ និងមជ្ឈិម និងរវាងភូមិភាគ និងភូមិភាគ"ដែលចាប់ផ្តើម

---

០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ឯកសារលេខ E1/157.1 ទំព័រ ៥០។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ឯកសារលេខ E1/193.1 ទំព័រ ៦, ១០, ១១ (អៀង ផាន ដែលជាមេបញ្ជាការនៃកងវរសេនាតូច បានអះអាងថា មេបញ្ជាការកងពលតូច និងកងពលធំត្រូវបានតម្រូវឱ្យចូលរួមប្រជុំតែនៅក្នុងកម្រិតភូមិភាគប៉ុណ្ណោះ)។

[368] *សូមមើលខ.* ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/130.1 ទំព័រ ៩ (មាស វឿន ត្រូវបានសួរ ថាតើបទបញ្ជានោះជាបទបញ្ជាអ្វីនៅក្នុងកិច្ចប្រជុំដែលគាត់បានចូលរួមនោះ)។ ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/131.1 ទំព័រ ៧០ (គាត់ត្រូវបានសួរអំពីបទបញ្ជាដទៃទៀតដែលបានទទួលទាក់ទងទៅនឹងការវាយប្រហារទីក្រុងភ្នំពេញ)។ ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ឯកសារលេខ E1/157.1 ទំព័រ ២៧ ដល់ ២៨, ៣៣។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (អ៊ុង រ៉េន) ឯកសារលេខ E1/158.1 ទំព័រ ៣៩ ដល់ ៤១ (អ៊ុង រ៉េន ត្រូវបានសួរអំពីការជម្លៀស និងបទបញ្ជាដែលគាត់បានដឹងថា ចេញទាក់ទងទៅនឹងបញ្ជានោះ)។ ប្រតិចារឹកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ឯកសារលេខ E1/193.1 ទំព័រ ១០ ដល់ ១២, ១៤ (អៀង ផាន ត្រូវបានសួរសំណួរអំពីបទបញ្ជាឱ្យជម្លៀសប្រជាជនចេញពីទីក្រុង និងមូលហេតុ)។ ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/159.1 ទំព័រ ៣៤, ៣៥, ៤៩, ៥៣ ដល់ ៥៤។ ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ (ឆោម សែ) ឯកសារលេខ E1/177.1 ទំព័រ ៥៣ ដល់ ៥៤, ៦៣, ៦៧ ដល់ ៦៩ (ឆោម សែ ដែលអនុមេបញ្ជាការកងពលធំមានទាហាន ១០០ នាក់ ជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសទីក្រុងភ្នំពេញ។ គាត់ត្រូវបានសួរសំណួរយ៉ាងទូលំទូលាយអំពីលក្ខណៈ និងការអនុវត្តជាក់ស្តែងនូវបទបញ្ជាដែលទទួលបានពាក់ព័ន្ធបញ្ជានោះ)។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ឯកសារលេខ E1/138.1 ទំព័រ ៧២ និង ៨៤ ដល់ ៨៥។ ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ឯកសារលេខ E1/139.1 ទំព័រ ៤ ដល់ ៥ (គង់ គឹម បានអះអាងថា គាត់ជាកូនទាហានក្នុងអំឡុងពេលនៃការវាយប្រហារទីក្រុងភ្នំពេញ បន្ទាប់មកត្រូវបានតម្លើងជាប្រធានកងនៅពេលទីក្រុងស្ថិតក្រោមការកាន់កាប់)។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ឯកសារលេខ E1/138.1 ទំព័រ ៧២ ដល់ ៧៦, ៨៤ ដល់ ៨៦ និងប្រតិចារឹកចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២ (គង់ គឹម) ឯកសារលេខ E1/139.1 ទំព័រ ៥ ដល់ ៦, ៨, ៤៣ ដល់ ៤៧ (គង់ គឹម ត្រូវបានសួរសំណួរជាក់លាក់ និងប្រភពនៃបទបញ្ជាដែលបានទទួល រួមមានបណ្តាញនៃការបញ្ជា និងមន្ត្រីដែលជាអ្នកវាយការណ៍)។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ៩, ១០ ដល់ ១១, ១៣, ១៩ ដល់ ២២, ៣៨, ៣៩, ៤៤, ៥៥ និង ៥៩ (ស៊ុំ ជា ដែលជាកូនទាហានសាមញ្ញ ត្រូវបានសួរសំណួរអំពីខ្លឹមសារ និងប្រភពនៃបទបញ្ជាពាក់ព័ន្ធទៅនឹងការជម្លៀសនោះ)។

តាំងពីដើមឆ្នាំ ១៩៧៣ និងបន្តរហូតដល់ថ្ងៃចូលទីក្រុងភ្នំពេញ"[369]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជាការរៀបរាប់របស់ ហេង សំរិន ឃើញថា មានអត្ថិភាពនៃភាពជាសត្រូវនឹងគ្នា ក្នុងកម្រិតមួយរវាងភូមិភាគនិងភូមិភាគចាប់តាំងពីឆ្នាំ ១៩៧៣[370]ក៏ដោយ ក៏ ហេង សំរិន បានលើកឡើងម្តងហើយម្តងទៀតយ៉ាងច្បាស់ថា ពុំមានសកម្មភាពបះបោរធំដុំបានកើតឡើងប្រឆាំងនឹងមជ្ឈិមបក្សនៅមុនខែសីហា ឆ្នាំ ១៩៧៨ ឡើយ កុំថាដល់ទៅមានការប្រឆាំងនឹងបទបញ្ជារបស់បក្សនោះ[371]។ យោងតាមកំណត់

[369] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩ និង ៦៤។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នួន ជា មានកំហុសនៅពេលបញ្ជាក់ថា Stephen HEDER "បានយល់ស្រប" ថា ហេង សំរិន"បានប្រឆាំងនឹងកងទ័ពដែលគាំទ្រមជ្ឈិមបក្ស" ក្នុងខែ មេសា ឆ្នាំ ១៩៧៥ (*ធៀប*សំណើទីប្រាំមួយរបស់ នួន ជា សុំកោះហៅ ហេង សំរិន (E236/5/1/1) កថាខណ្ឌ ១៤ *ជាមួយនឹង*ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/224.1 ទំព័រ ៧៣ ដល់ ៧៥)។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤២ និងជើងទំព័រ ៦៧៤ បានអះអាងថា ការបែកបាក់ដែលដឹកនាំដោយលេខាភូមិភាគពាយ័ព្យ រស់ ញឹម(ញឹម រស់) ទំនងជាមានផែនការបះបោរប្រដាប់អាវុធប្រឆាំងនឹង ប៉ុល ពត តាំងពីដើមឆ្នាំ ១៩៧៥។ ការអះអាងនេះផ្អែកលើព័ត៌មានដែលថា នៅក្នុងឆ្នាំ ១៩៧៥ ទាត់ ធឿន បានសាងសង់ឃ្លាំងទុកអាវុធសម្ងាត់ដែលរឹបអូសបានពីទាហាន លន់ នល់។ ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបានសង្កេតលើសក្ខីកម្មរបស់ ទាត់ ធឿន នៅពេលផ្តល់សក្ខីកម្មចំពោះមុខខ្លួន ដោយគាត់បានបដិសេធថា អាវុធនោះត្រូវបានប្រមូលក្នុងគោលបំណងប្រើប្រាស់ក្នុងពេលបះបោរប្រឆាំងនឹងមជ្ឈិមបក្សឡើយ។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ២០, ២៣ ដល់ ២៤។

[370] កំណត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713952-3 (ពិពណ៌នាអំពីការប៉ះទង្គិចរវាងកងទ័ពភូមិភាគបូព៌ាជាមួយនឹងនិរតីកើតឡើងឆ្នាំ ១៩៧៣)។ ERN (ភាសាខ្មែរ) 00713949-52 (រៀបរាប់តាមរយៈពាក្យពេចន៍ពុំច្បាស់លាស់ថា "ការបះបោរប្រឆាំងនឹង ប៉ុល ពត"ក្នុងឆ្នាំ ១៩៧៤ ក្នុងកោះកុង)។ ERN (ភាសាខ្មែរ) 00713946-7 (រំឭកថា ដោយសារការគ្រប់គ្រងទីក្រុងភ្នំពេញ ត្រូវបានបែងចែកក្នុងចំណោមកងផ្សេងៗ ទាហានពុំត្រូវបានអនុញ្ញាតឱ្យចូលតំបន់របស់កងដទៃឡើយ និងថា ពេលគាត់ព្យាយាមចូលទៅតំបន់ដទៃ គេគំរាមចាប់ខ្លួនគាត់)។

[371] កំណត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713959-60, 0071394-5 (អះអាងថា ការបះបោរប្រឆាំងនឹងកងទ័ពរបស់ ប៉ុល ពត ចាប់ផ្តើមនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៧៨), 00713961, 00713962-3, 00713965, 00713974-5 (បញ្ជាក់ថា បើទោះបីជាគាត់ និងអ្នកដទៃទៀតបានរក្សាទុកតាមគោលនយោបាយរបស់បក្សចាប់តាំងពីឆ្នាំ ១៩៧៥ ក៏ដោយ ក៏ទើបតែត្រឹមខែ កញ្ញា ដល់ តុលា ឆ្នាំ ១៩៧៦ ប៉ុណ្ណោះ នៅពេលថ្នាក់ដឹកនាំបានកែប្រែលក្ខន្តិកៈរបស់ ប.ក.ក. ដែលពួកគាត់ចាត់ទុកសកម្មភាពរបស់ ប៉ុល ពត ថា មិនល្អ និងដូចជាអ្វីនោះ និងគ្រប់កាលៈទេសៈទាំងអស់ ក្នុងឆ្នាំ ១៩៧៦ ដល់ ១៩៧៧ ពួកគាត់ពុំហ៊ាននិយាយអ្វីសោះ។ ពួកគាត់បានធ្វើការតស៊ូស្ងាត់ៗ ប៉ុន្តែ"នៅពេលនោះវាមានសភាពតឹងរឹង និងរិតត្បិតខ្លាំង ពុំមានឱកាសដើម្បីក្រោកតស៊ូឡើយ" ដូច្នេះ ពួកគាត់ចាំតែឱកាសបះបោរប៉ុណ្ណោះ)។ ERN (ភាសាខ្មែរ) 00713990 (សោកស្តាយថា គាត់ទើបបានដឹងអំពើរបស់ ប៉ុល ពត ចាប់ពីឆ្នាំ ១៩៧៦ តែកន្លងមក ហេង សំរិន ពុំ

ហេតុនៃបទសម្ភាសន៍របស់ ហេង សំរិន យ៉ាងហោចណាស់ដល់ខែ កញ្ញា ឆ្នាំ ១៩៧៧ "គ្មាននរណាម្នាក់"រួមទាំងរូបគាត់ និង សោ ភឹម ផងដែរនោះ"ហ៊ាន"ជំទាស់ទៅនឹងសេចក្តីណែនាំដែលចេញដោយមជ្ឈិមបក្សឡើយ បើហ៊ាន"គេប្រាកដជាសម្លាប់ចោល"[372]។ ដូច្នេះ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលពុំបានបដិសេធការជាប់ពាក់ព័ន្ធ*តាមសេចក្តីបញ្ជាក់ដំបូង*នៃសក្ខីកម្មដែលថា ហេង សំរិន អាចមកផ្តល់ទាក់ទងទៅនឹងអង្គហេតុចំណុចនេះក៏ដោយ ក៏*តាមសេចក្តីបញ្ជាក់ដំបូង* ពុំទំនងជាថា សក្ខីកម្មរបស់គាត់ពាក់ព័ន្ធទៅនឹងបញ្ហានេះ អាចជាភស្តុតាងដោះបន្ទុកនោះឡើយ។

១៥៣.ចុងក្រោយ នួន ជា បានអះអាងថា កំណត់ហេតុនៃបទសម្ភាសន៍របស់ ហេង សំរិន គឺ"ជាភស្តុតាងផ្ទាល់តែមួយគត់ដែលអាចបញ្ជាក់អំពី"ចេតនា"របស់គាត់ទាក់ទងទៅនឹងការប្រព្រឹត្តចំពោះអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ[373]។ នួន ជា បានចង្អុលបង្ហាញទៅលើការអះអាងរបស់ ហេង សំរិន ដែលថា នៅក្នុងកិច្ចប្រជុំនៅទីក្រុងភ្នំពេញដែលបានប្រព្រឹត្តឡើងប្រហែលជានៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ដើម្បីផ្សព្វផ្សាយពីគោលជំហរផ្នែកនយោបាយរបស់ ប.ក.ក. នួន ជា បានប្រើប្រាស់ពាក្យ"កម្ចាត់"ក្នុងការពិពណ៌នាគោលនយោបាយពាក់ព័ន្ធទៅនឹងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[374]។ ហេង សំរិន បានយល់ច្បាស់ថា ពាក្យនេះ គឺមានន័យថា "មិនត្រូវទុកពួកគេឲ្យនៅក្នុងក្របខ័ណ្ឌទៀតឡើយ" និងបានបញ្ជាក់ថា វាគ្មិននៅពេលប្រជុំ

---

ហ៊ានរើបម្រះ ពីព្រោះបើទោះបីជាមានការសង្ស័យពីដំបូងក៏ដោយ គាត់នៅតែ"ជឿលើបក្ស") ERN (ភាសាខ្មែរ) 00713974 (បានអះអាងថា ចាប់តាំងពីពេលគាត់ដឹងថា "ប៉ុល ពត ជាជនក្បត់"ក្នុងឆ្នាំ ១៩៧៦ គាត់បានព្យាយាមរើបម្រះប្រឆាំងនឹង"វិធានការ"ចេញពីថ្នាក់ដឹកនាំ ប៉ុន្តែពុំទាន់មានលទ្ធភាពធ្វើដូច្នោះនៅឡើយ) ERN (ភាសាខ្មែរ) 00713974-7, 00713979-80, 00713992 (បង្ហាញថា លេខាភូមិភាគបូព៌ា សោ ភឹម ដែលមជ្ឈិមបក្សបានសង្ស័យថា គាត់បង្កចលនាបះបោរ បាននិយាយក្នុងឆ្នាំ ១៩៧៧ ថា ចលនាតស៊ូពុំគប្បី"វាយប្រហារមិត្ត" តែគប្បី"ស្តាប់តាមបទបញ្ជា"របស់បក្សយ៉ាងហោចណាស់បានមួយរយៈ ក្រោយមកក្នុងឆ្នាំ ១៩៧៨ សោ ភឹម "នៅតែពុំមានជំហរច្បាស់លាស់" និង"នៅតែជឿលើ ប៉ុល ពត" ដូច្នេះក៏បានបញ្ឈប់ផែនការបះបោររើបម្រះ)។ ការរៀបរាប់របស់ ជា ស៊ីម ក្នុងឆ្នាំ ១៩៩១ ផ្អែកតាមរបាយការណ៍របស់ Ben KIERNAN បានយល់ស្របជាមួយនឹងទិដ្ឋភាពជាច្រើននៃចម្លើយរបស់ ហេង សំរិន។ *សូមមើល* កំហាត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN សារលេខ E3/1568 ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ ឯក ERN (ភាសាខ្មែរ) 00713946។

[372] កំហាត់ហេតុនៃកិច្ចសម្ភាសន៍សរសេរដោយដៃរបស់ KIERNAN ឯកសារលេខ E3/5593 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713939។

[373] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩។

[374] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩ យោងទៅលើកំហាត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713955។

នោះពុំបានប្រើប្រាស់ពាក្យ"កម្ទេច"ដែលមានន័យថា ធ្វើឱ្យខ្ទេច ឬសម្លាប់ឡើយ[375]។ នួន ជា ក៏បានលើកឡើងបន្ថែមទៀតថា គោលនយោបាយដែលបានលើកឡើងនៅពេលប្រជុំក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ នោះ"ជាប់ពាក់ព័ន្ធទៅនឹង*មេដឹកនាំ* នៃរដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរតែប៉ុណ្ណោះ" ដូចការអះអាងរបស់ ហេង សំរិន និង ជា ស៊ីម នៅក្នុងបទសម្ភាសន៍នោះ[376]។

១៥៤.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កំណត់ហេតុនៃបទសម្ភាសន៍បានលើកឡើងនូវបញ្ហាជាច្រើនពាក់ព័ន្ធទៅនឹងបទចោទនៅក្នុងសំណុំរឿង ០០២/០១[377] ដែលបញ្ហាមួយចំនួនគួរបានបញ្ជាក់តាមរយៈ

---

[375] កំហាត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00713955។

[376] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦៧ យោងទៅលើថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៨១ឯ កសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00713955 (ហេង សំរិន) និង ERN (ភាសាខ្មែរ) 00713927-8 (ជា ស៊ីម)។

[377] ជាដំបូង ពុំមានភាពច្បាស់លាស់ថាតើ ហេង សំរិន និង ជា ស៊ីម បាននិយាយសំដៅជាក់លាក់ទៅលើ"មេដឹកនាំ"នៃរបប លន់ នល់ មិនមែនសំដៅលើទាហាន ឬមន្ត្រីធម្មតានៃរបបសាធារណរដ្ឋខ្មែរ ដែរ ឬយ៉ាងណា ឬថាតើមានតែ Ben KIERNNAN ដែលជាអ្នកសន្និដ្ឋានថា អ្នកដែលត្រូវបានគេយកសម្ភាសន៍បាននិយាយអំពីមេដឹកនាំប៉ុណ្ណោះនេះ ដោយសារនៅក្នុងកំណត់ហេតុនៃបទសម្ភាសន៍នោះ ការសំដៅបែបនេះទំនងជាដាក់ក្នុងរង្វង់ក្រចកដែលជាធម្មតាប្រើប្រាស់ដើម្បីបង្ហាញថា ជាគំនិតរបស់ Ben KIERNAN (*សូមមើល* កំហាត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00713955 (ហេង សំរិន) និង ERN (ភាសាខ្មែរ) 00713927-8 (ជា ស៊ីម))។ ការសំដៅជាក់ស្តែងរបស់ ហេង សំរិន ទៅលើមេដឹកនាំនៃរបប លន់ នល់ មានភាពមន្ទិលសង្ស័យបន្ថែមទៀត ដោយសារតែជាការបកប្រែឃ្លានេះទាំងមូលរបស់ Ben KIERNAN ថា "*komchat puok rattakar chinh*" (កម្ចាត់ពួករដ្ឋការចេញ) (កំណត់ហេតុនៃកិច្ចសម្ភាសន៍សរសេរដោយដៃរបស់ KIERNAN ឯកសារលេខ E3/5593 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00713934) ដែលក្នុងនោះ ពាក្យ"rattakar" បកប្រែថា "អ្នករដ្ឋការនៃរបប[លន់ នល់]" ដោយគ្មានការកម្រិតជាក់លាក់ណាមួយឡើយ។ ទីពីរ ហេង សំរិន បានរំឭកនូវពាក្យដូចគ្នាដែល នួន ជា បាននិយាយ និងអត្ថន័យត្រង់នៃពាក្យនេះ ប៉ុន្តែពុំបានពន្យល់ថា គាត់យល់យ៉ាងដូចម្តេចអំពីពាក្យនេះនៅក្នុងបរិបទនោះឡើយ។ តាមការជាក់ស្តែង នួន ជា បានប្រើប្រាស់ពាក្យថា "komchat"*កម្ចាត់* ក្នុងន័យសម្រាលដើម្បីផ្តល់ជាសារដែលមានន័យបង្កប់ ប៉ុន្តែច្បាស់លាស់អាចយល់បានចំពោះអ្នកស្តាប់។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ហេង សំរិន និង ជា ស៊ីម បាននិយាយអំពីការប្រើប្រាស់ពាក្យសម្រាលប្រហាក់ប្រហែលគ្នានេះ (*សូមមើល* កំណត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00713927-8 ("មើលថែ"មានន័យ"សម្លាប់") ERN (ភាសាខ្មែរ) 00713931 ("សម្រិតសម្រាំងដោយប្រុងប្រយ័ត្ន"មានន័យ"សម្លាប់"))។ ទីបី ទំនងជាមានភាពមិនស្របគ្នាផ្នែកអក្សរសាស្ត្រក្នុងចំណោមអ្នកសិក្សាលើការបកប្រែត្រឹមត្រូវនៃពាក្យ"កម្ចាត់"ជាភាសាអង់គ្លេស។ Ben KIERNAN កបប្រែពាក្យ"komchat" ថា "scatter" ឬ "don't allow them to remain in the framework" *កុំទុកឱ្យនៅក្នុង*

សក្ខីកម្មផ្ទាល់របស់ ហេង សំរិន។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរថា លទ្ធភាពនៃការបកស្រាយ ពាក្យបើយោងតាម ហេង សំរិន ត្រូវបានប្រើប្រាស់នៅពេលប្រជុំនោះ អាចជាភស្តុតាងដោះបន្ទុក។ ទោះជាយ៉ាងណាក្តី កំណត់ហេតុនៃកិច្ចសម្ភាសន៍នោះ ជាក់ស្តែងត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ។ មតិភាគច្រើនបានបញ្ជាក់ច្បាស់លាស់ថា កំណត់ហេតុនេះ“បានបង្ហាញគ្រប់គ្រាន់ និងអាចជឿទុកចិត្តបានថា [ហេង សំរិន] បានបញ្ជាក់នូវពាក្យនេះ និងយោបល់ណែនាំដែលមេធាវីការពារក្តី នួន ជា ព្យាយាមសំអាងទៅលើនោះ”[378]។ អាស្រ័យហេតុនេះ សក្ខីកម្មរបស់ ហេង សំរិន ប្រហែលជាពុំបានផ្តល់ព័ត៌មានសំខាន់បន្ថែមសម្រាប់ជាភស្តុតាងដោះបន្ទុកទាក់ទងទៅនឹងកិច្ចប្រជុំនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ឡើយ។

១៥៥.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនកោះហៅសាក្សី ហេង សំរិន ពុំបណ្តាលឱ្យមាន“លទ្ធផលខុសឆ្គងធ្ងន់ធ្ងរនៅក្នុងកិច្ចដំណើរការនីតិវិធី” នោះឡើយ។ ទាក់ទងទៅនឹងបញ្ហាដែលថា ព័ត៌មានដែលមាននៅក្នុងកំណត់ហេតុនៃបទសម្ភាសន៍ អាចត្រូវបានចាត់ទុកថាជាភស្តុតាងដោះបន្ទុក ព័ត៌មាននេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ។ បញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើព័ត៌មានគ្រប់គ្រាន់ ដែរ ឬយ៉ាងណានោះ គឺជាបញ្ហាដាច់ដោយឡែក ដែលអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយដូចខាងក្រោម ជាមួយទឡ្ហីករណ៍ពាក់ព័ន្ធនៃបណ្តឹងសាទុក្ខ[379]។ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីសមស្របនឹងត្រូវធ្វើសេចក្តីសន្និដ្ឋានជាប្រយោជន៍ដល់ជនជាប់ចោទដោយផ្អែកលើកំណត់ហេតុនៃបទសម្ភាសន៍របស់ ហេង សំរិន។

### ៤.ខ.២.ក.២.សាក្សី អ៊ុក ប៊ុនឈឿន

---

*ក្របខ័ណ្ឌ* (សៀវភៅរបស់ Ben KIERNAN៖ *របប ប៉ុល ពត: ការស្វែងរកអំណាច និងប្រល័យពូជសាសន៍នៅក្នុងកម្ពុជាក្រោមរបបខ្មែរក្រហម ឆ្នាំ ១៩៧៥ ដល់ ១៩៧៩* ឯកសារលេខ E3/1593 ទំព័រ ៨៩ ERN (ភាសាខ្មែរ) 00637444) ប៉ុន្តែចំណែកឯ Stephen HEDER បានផ្តល់សក្ខីកម្មថា “កម្ចាត់”មានន័យធ្ងន់ជាង“scatter” និងមានន័យថា “បំបាត់ចេញ លុបបំបាត់” ដូច្នេះស្ទើរដូចគ្នានឹងពាក្យកម្ទេច(*ពាក្យដើម*)”។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/224.1 ទំព័រ ៧៨។

378 សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៩៨។

379 *សូមមើលខាងក្រោម* កថាខណ្ឌ ៨៤៦ *ជាអាទិ៍*។

១៥៦.ប្រវត្តិនីតិវិធីទាក់ទងទៅនឹងបញ្ហា ថាតើ អ៊ុក ប៊ុនឈឿន គប្បីត្រូវបានកោះហៅ ដែរ ឬយ៉ាងណា គឺដូចគ្នាទៅនឹងបញ្ហារបស់ ហេង សំរិន ដែរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាកោះក្នុងឆ្នាំ ២០០៩ ទោះជាយ៉ាងណាក្តី អ៊ុក ប៊ុនឈឿន ពុំបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមឡើយ[380]។ នួន ជា បានស្នើសុំនៅក្នុងដើមឆ្នាំ ២០១១ ថា អង្គជំនុំជម្រះគប្បីកោះហៅ អ៊ុក ប៊ុនឈឿន មកផ្តល់សក្ខីកម្មនៅចំពោះមុខខ្លួន និងក្រោយមកបានលើកសំណើនេះសាជាថ្មីទៀត[381]។ នៅក្នុងសេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) មតិភាគច្រើនសន្និដ្ឋានថា អ៊ុក ប៊ុនឈឿន ពុំគប្បីត្រូវបានកោះហៅឡើយ[382]។ ដោយកត់សម្គាល់ថា នួន ជា បានស្នើសុំសក្ខីកម្មរបស់សាក្សីរូបនេះអំពីតួនាទីរបស់វៀតណាមរួចហើយ មតិភាគច្រើនបានចាត់ទុកបញ្ហានេះពុំជាប់ពាក់ព័ន្ធទៅនឹងបទចោទឡើយ[383]។ ទាក់ទងទៅនឹងបញ្ហានៃការជ្រៀតជ្រែកខាងនយោបាយដែលជាប្រធានបទមានសក្តានុពលនៃសក្ខីកម្ម មតិភាគច្រើនរំឭកអំពីការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា "ពុំមានមូលដ្ឋានក្នុងការកោះហៅសាក្សីមកផ្តល់សក្ខីកម្មលើបទចោទបែបនោះ"[384]។ ទាក់ទងទៅនឹងរចនាសម្ព័ន្ធបញ្ជាមួយផ្សេងទៀតនៅក្នុង ប.ក.ក. មតិភាគច្រើនកត់សម្គាល់ឃើញថា សាក្សីដទៃទៀតបានផ្តល់សក្ខីកម្មលើបញ្ហានេះរួចហើយ ដូច្នេះ សក្ខីកម្មរបស់ អ៊ុក ប៊ុនឈឿន អាចជាន់គ្នាទាំងស្រុង។ ទាក់ទងទៅនឹងចម្លើយដែលធ្វើឡើងនៅក្នុងកិច្ចសម្ភាសន៍របស់ Stephen HEDER ជាមួយ អ៊ុក ប៊ុនឈឿន ដែលថា នៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ ផែនការត្រូវបានបង្កើតឡើង ដើម្បីសាងសង់ទីជម្រកសម្រាប់អ្នកដែលនឹងត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញក្រោយពេលដួលរលំ មតិភាគច្រើនបានកត់សម្គាល់ថា កំណត់ហេតុនៃកិច្ចសម្ភាសន៍ គឺជាផ្នែកមួយនៃភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងអាចសំអាងទៅលើបាន។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនេះគឺគ្រប់គ្រាន់ផងដែរសម្រាប់ដោះស្រាយត្រង់ចំណុចដែល នួន ជា បានអះអាងថា ចម្លើយនេះជាភស្តុតាងដោះ

---

[380] ដីកាកោះសាក្សី អ៊ុក ប៊ុនឈឿន ឯកសារលេខ A298/1។

[381] ឧបសម្ព័ន្ធទៅនឹងសេចក្តីសង្ខេបរបស់ នួន ជា អំពីសាក្សីដែលបានស្នើឡើង (E9/10.1) ទំព័រ ១៤៨។

[382] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ៩៩ ដល់ ១០៣។

[383] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០០។

[384] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០០ យោងទៅលើសាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៧៩ ដល់ ៨០ (អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា បញ្ហា ថាតើបុគ្គលម្នាក់ គឺជា"មេដឹកនាំជាន់ខ្ពស់" ឬ"ទទួលខុសត្រូវខ្ពស់បំផុត" លើបទឧក្រិដ្ឋនៃរបបខ្មែរក្រហម ដែរ ឬយ៉ាងណា ពុំអាចជំនុំជម្រះបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ ប៉ុន្តែត្រូវស្ថិតក្រោមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា)។

បន្ទុកនោះ ដូច្នេះ ពុំមានភាពចាំបាច់កោះហៅ អ៊ុក ប៊ុនឈឿន មកបញ្ជាក់លើចម្លើយនេះឡើយ[385]។ មតិភាគច្រើនបានសន្និដ្ឋានថា "បញ្ហាលំបាក និងអាចអូសបន្លាយ នឹងកើតមានទាក់ទងទៅនឹងអភ័យឯកសិទ្ធិរបស់ [អ៊ុក ប៊ុនឈឿន] ពីការចោទប្រកាន់" និងថា ពុំគួរពិចារណាលើ"បញ្ហាច្បាប់ និងការលំបាកជាក់ស្តែងដែលមិនមានភាពចាំបាច់"[386]ឡើយ។

១៥៧.មតិភាគតិចពុំយល់ស្របទៅនឹងសេចក្តីសន្និដ្ឋានរបស់មតិភាគច្រើន និងបានបង្ហាញការយល់ឃើញរបស់ខ្លួនថា អ៊ុក ប៊ុនឈឿន គប្បីត្រូវបានកោះហៅសម្រាប់មូលហេតុដូចគ្នាទៅនឹង ហេង សំរិន ដែលគប្បីត្រូវបានកោះហៅនោះដែរ[387]។ មតិភាគតិចបានកត់សម្គាល់ថា "សក្ខីកម្មរបស់ អ៊ុក ប៊ុនឈឿន ដែលជាមេដឹកនាំភូមិភាគ តាមការអះអាងរបស់ នួន ជា បានប្រយុទ្ធគ្នាជាមួយកងទ័ពមជ្ឈិមនៅចុងទសវត្សឆ្នាំ ១៩៧០ អាចផ្តល់ភស្តុតាងពាក់ព័ន្ធផ្ទាល់ និងមានតម្លៃជាភស្តុតាងអំពីសេចក្តីណែនាំនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ ដែលពាក់ព័ន្ធទៅនឹងផែនការផ្តល់ទីជម្រកដល់អ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ"[388]។

១៥៨. ដូចករណី ហេង សំរិន ដែរ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសម្រេចរបស់មតិភាគច្រើនមិនកោះហៅសាក្សី អ៊ុក ប៊ុនឈឿន គឺជាកំហុសនៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិ ពីព្រោះបើផ្អែកតាមព័ត៌មានដែលអង្គជំនុំជម្រះសាលាដំបូងអាចរកបាននោះ ពុំមានការបញ្ជាក់ច្បាស់លាស់ថា សាក្សីជាក់ស្តែងបានបដិសេធមិនមកផ្តល់សក្ខីកម្ម និងថា បញ្ហានេះបានបង្កឱ្យមានការពន្យារពេលដោយពុំសមហេតុផលនោះឡើយ[389]។ ទោះជាយ៉ាងណាក្តី ដូចករណី ហេង សំរិន ពុំមានការបញ្ជាក់ថា កំហុសផ្នែកប្រវត្តិនីតិវិធីជាក់ស្តែងបានធ្វើឱ្យប៉ះពាល់ដល់ នួន ជា និងបណ្តាលឱ្យមាន"លទ្ធផលខុសឆ្គងធ្ងន់ធ្ងរនៅក្នុងកិច្ចដំណើរការនីតិវិធី"ឡើយ។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹង Stephen HEDER អ៊ុក ប៊ុនឈឿន តាមការរាយការណ៍ បានអះអាងថា នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ ប៉ុល ពត បានចេញគោលនយោបាយសម្ងាត់មួយឱ្យ"បោសសម្អាតសមាសភាពទាំងអស់នៃរបប លន់ នល់" ដោយបានបញ្ជាក់នូវការកំណត់

---

[385] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០១ ដល់ ១០២។

[386] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០៣។

[387] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០៤ ដល់ ១១១។

[388] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី (E312) កថាខណ្ឌ ១០៨។

[389] *សូមមើលខាងលើ* កថាខណ្ឌ ១៤៧ ដល់ ១៤៩។

គោលដៅជាក់លាក់ដែលត្រូវតែ"បោសសម្អាត" ឬ"បោសឱ្យស្អាត"[390]។ ទាក់ទងទៅនឹងកិច្ចប្រជុំក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ អ៊ុក ប៊ុនឈឿន តាមរបាយការណ៍ បានប្រកាសថា ថ្នាក់ដឹកនាំ ប.ក.ក.បានណែនាំឱ្យ "ប្រឆាំងម៉ឺងម៉ាត់ និងគាស់រំលើង"នូវរបបចាស់ខាងវិស័យ"នយោបាយសតិអារម្មណ៍ និងផ្នែកចាត់តាំង"[391]។ ទាក់ទងទៅនឹងការចូលរួមរបស់គាត់នៅក្នុងសកម្មភាពបះបោរផ្ទៃក្នុងនៅក្នុង ប.ក.ក. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ផ្អែកលើបទសម្ភាសន៍នេះ សកម្មភាពនេះបានកើតឡើងចាប់ពីឆ្នាំ ១៩៧៨[392]។ ទាក់ទងទៅនឹងបញ្ហានៃព័ត៌មានដែលអាចចាត់ទុកថា ជាភស្តុតាងដោះបន្ទុក តាមការកត់សម្គាល់របស់មតិភាគច្រើន ព័ត៌មាននេះត្រូវបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងទម្រង់ជាកំណត់ហេតុនៃកិច្ចសម្ភាសន៍ ដូច្នេះ ត្រូវបានយកមកពិចារណារួចរាល់ហើយ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខនេះត្រូវបដិសេធចោល។

### ៤.៦.២.ក.៣.សាក្សី Robert LEMKIN

១៥៩.នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានបដិសេធសំណើរបស់គាត់ដែលសុំឱ្យកោះហៅ Robert LEMKIN ឬធ្វើចំណាត់ការស៊ើបអង្កេតដើម្បីទទួលបានឈុតខ្សែវីដេអូពីសាក្សីរូបនេះ ដែលតាមការអះអាងថា ខ្សែវីដេអូនេះអាចមានភស្តុតាងបញ្ជាក់ថា នួន ជា គ្មានការទទួលខុសត្រូវលើព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[393]។

១៦០.ក្នុងការបដិសេធសំណើរបស់ នួន ជា សុំស្ដាប់សាក្សី Robert LEMKIN ឬចាត់វិធានការស៊ើបអង្កេត អង្គជំនុំជម្រះសាលាដំបូងបានលើកហេតុផលដូចតទៅ៖ (i) Robert LEMKIN បានបង្ហាញពីការមិនសហការ

---

[390] កិច្ចសម្ភាសន៍របស់ D-Cam ជាមួយ អ៊ុក ប៊ុឈឿន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩០ ឯកសារលេខ E3/387 ទំព័រ ៦។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា ការសង្កេតរបស់ នួន ជា ទាក់ទងទៅនឹងបញ្ហា ថាតើ"បោសសម្អាត" គឺជាពាក្យបកប្រែត្រឹមត្រូវជាភាសាខ្មែរ ដែរ ឬទេ (*សូមមើល* សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា (E295/6/3) កថាខណ្ឌ ៣៨៦ ជើងទំព័រ ៨៣៧) និងការពិចារណាលើសក្ខីកម្មរបស់ Stephen HEDER លើចំណុចនេះ (*សូមមើល*ប្រតិចារឹកចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/222.1 ទំព័រ ៨) យល់ឃើញថា ពាក្យ"បោសសម្អាត" និង"បោសឱ្យស្អាត"អាចត្រូវបានចាត់ទុកជំនួសគ្នាបាននៅក្នុងបរិបទនៃអត្ថបទសម្ភាសន៍របស់ អ៊ុក ប៊ុនឈឿន។

[391] កិច្ចសម្ភាសន៍របស់ D-Cam ជាមួយ អ៊ុក ប៊ុឈឿន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩០ ឯកសារលេខ E3/387 ទំព័រ ៨។

[392] កិច្ចសម្ភាសន៍របស់ D-Cam ជាមួយ អ៊ុក ប៊ុឈឿន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩០ ឯកសារលេខ E3/387 ទំព័រ ២២ *ជាអាទិ៍*
។

[393] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣។

ជាមួយតុលាការកន្លងមក និងតាមរយៈអ៊ីមែលដែលគាត់បានផ្ញើទៅកាន់មេធាវីការពារក្តី នួន ជា កាលពីថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៣ និងតាមការស្នើសុំរបស់ នួន ជា ពុំបានបញ្ជាក់ ថាតើគាត់បានត្រៀមខ្លួនបោះបង់នូវបុព្វសិទ្ធិជាអ្នកសារព័ត៌មាន ដែរ ឬយ៉ាងណាឡើយ (ii) ឈុតខ្សែវីដេអូនោះជាក់ស្តែងពុំមែនទើបតែថតថ្មីៗនេះទេ គឺថតតាំងពីមុនខែ ឧសភា ឆ្នាំ ២០០៩ មកម្ល៉េះ (iii) នួន ជា បានពន្យារពេលយ៉ាងយូរក្នុងការបោះបង់ការសន្យារក្សាការសម្ងាត់ទាក់ទងនឹងការសម្ភាសន៍របស់គាត់ជាមួយនឹង ថេត សម្បត្តិ (iv) ដោយពុំមានព័ត៌មានច្បាស់លាស់ទាក់ទងទៅនឹងភស្តុតាងដែលបានស្នើសុំ ដូចនេះការស៊ើបអង្កេត អាចនឹងកើតមានហានិភ័យ ដោយសារ"ការស្វែងរកភស្តុតាងដោយគ្មានទីបញ្ចប់"ដែលនាំឱ្យអូសបន្លាយពេលវេលាដោយពុំសមស្រប (v) បើទោះបីជាសម្ភារមានតម្លៃជាភស្តុតាងសក្តានុពលក៏ដោយ ក៏ត្រូវតែធ្វើការថ្លឹងថ្លែងរវាងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីជាមួយនឹងតម្រូវការចាំបាច់ក្នុងការជំនុំជម្រះឱ្យបានឆាប់រហ័សផងដែរ និង (vi) បើទោះបីជា Robert LEMKIN បានសហការជាមួយ អ.វ.ត.ក. ក៏ដោយ ក៏ត្រូវចំណាយពេលយូរសម្រាប់ការដាក់សម្ភារនេះចូលក្នុងសំណុំរឿង ហើយតុលាការ និងភាគីក៏ត្រូវចំណាយពេលយូរ ក្នុងការមើលសម្ភារនេះផងដែរ[394]។

១៦១.ទោះបីជាផ្អែកតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង[395]ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូង ពុំបានធ្វើការសម្រេចឱ្យស្របទៅតាមលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដែលចែងជាពិសេសអំពីភស្តុតាង គឺភស្តុតាង"មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ" "មិនជាប់ពាក់ព័ន្ធ" ឬ"មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី"ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែចោទជា"សំណួរ"ប៉ុណ្ណោះ ទាក់ទងទៅនឹងបញ្ហា ថាតើឈុតខ្សែវីដេអូនេះអាចទទួលយកបានតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា *មានដូចជា* ថាតើ នួន ជា អាចបង្ហាញថា ឈុតខ្សែវីដេអូនេះពិតជាពុំអាចរកបានមុនពេលចាប់ផ្តើមសវនាការ ដែរ ឬទេ[396] ក្រៅពីនោះពុំបានកំណត់អ្វីផ្សេងទៀតទាក់ទងបញ្ហានេះឡើយ។

១៦២.អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបដិសេធពុំធ្វើការស៊ើបអង្កេតលើខ្លឹមសារជាក់លាក់ និងអត្ថិភាពនៃខ្សែវីដេអូដែលអាចរកបាន ដោយសារតែអង្គជំនុំជម្រះព្រួយបារម្ភអំពីការចេញសាលក្រមមិនទាន់ពេលកំណត់

---

[394] សេចក្តីសម្រេចលើភស្តុតាងថ្មី ការស៊ើបសួរ និងការកោះហៅសាក្សី (E294/1) កថាខណ្ឌ ១៦ និង ១៩ ដល់ ២៤។

[395] សេចក្តីសម្រេចលើភស្តុតាងថ្មី ការស៊ើបសួរ និងការកោះហៅសាក្សី (E294/1) កថាខណ្ឌ ១០។

[396] សេចក្តីសម្រេចលើភស្តុតាងថ្មី ការស៊ើបសួរ និងការកោះហៅសាក្សី (E294/1) កថាខណ្ឌ ២០។

និងហានិភ័យដែលថា ការស៊ើបអង្កេតនេះពុំអាចបញ្ចប់បានក្នុងពេលសមស្របមួយ[397]។ ពាក់ព័ន្ធបញ្ហានេះ ជាបឋម អង្គជំនុំជម្រះតុលាការកំពូល ពុំយល់ស្របទៅនឹងការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចដែលថា ត្រូវតែមានការថ្លឹងថ្លែងរវាងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ជាមួយនឹងតម្រូវការក្នុងការជំនុំជម្រះឱ្យបានឆាប់រហ័ស[398]។ អង្គជំនុំជម្រះនីមួយៗក្នុងតុលាការនេះ ត្រូវស្ថិតក្រោមកាតព្វកិច្ចក្នុងការធានាថា កិច្ចដំណើរការនីតិវិធីត្រូវប្រព្រឹត្តទៅដោយត្រឹមត្រូវ និងឆាប់រហ័ស[399]។ ទិដ្ឋភាពពីរយ៉ាងដែលជាប់ពាក់ព័ន្ធទៅនឹងការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះ គឺសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះគ្មានការពន្យារពេលដោយមិនសមហេតុផល[400] និងសិទ្ធិ"សុំឱ្យសាក្សីចូលខ្លួន និងសិទ្ធិសួរសំណួរសាក្សីក្នុងនាមខ្លួន"[401] ដោយពិចារណាទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះ គ្មានការពន្យារពេលដោយមិនសមហេតុផល តម្លៃភស្តុតាងដែលរំពឹងថានឹង*គាំទ្រ*បទចោទនោះ អាចត្រូវបានថ្លឹងថ្លែងឱ្យមានតុល្យភាពជាមួយនឹងពេលវេលាដែលចាំបាច់ក្នុងការទទួលបានភស្តុតាង[402]។ ទោះជាយ៉ាងណាក្តី សិទ្ធិទទួលបានការជំនុំជម្រះគ្មានការពន្យារពេលដោយមិនសមហេតុផលនេះ ពុំបានកម្រិតសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានភស្តុតាង*សម្រាប់ធ្វើជាមធ្យោបាយការពារខ្លួន*ឡើយ។ ប៉ុន្តែ ក្តីបារម្ភទូទៅអំពីដំណើរការនីតិវិធីឆាប់រហ័សបានកម្រិតសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានភស្តុតាងនេះ ដោយសារតែសំណើសុំឱ្យទទួលយកភស្តុតាងជាក់ស្តែង ពុំមានប្រយោជន៍ជាមធ្យោបាយការពារខ្លួន ដូចបានកំណត់ក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង

---

[397] សេចក្តីសម្រេចលើភស្តុតាងថ្មី ការស៊ើបសួរ និងការកោះហៅសាក្សី (E294/1) កថាខណ្ឌ ២៤។

[398] សេចក្តីសម្រេចលើភស្តុតាងថ្មី ការស៊ើបសួរ និងការកោះហៅសាក្សី (E294/1) កថាខណ្ឌ ១៩។

[399] មាត្រា ៣៣ (ថ្មី)នៃច្បាប់ អ.វ.ត.ក.។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីភស្តុតាង*រឿងក្តី Aleksovski* (ICTY) កថាខណ្ឌ ១៩។

[400] មាត្រា ១៤(៣-គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[401] មាត្រា ១៤(៣-ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយធានាថា សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវរបស់ភាគី រួមបញ្ចូលសិទ្ធិបង្ហាញភស្តុតាង។ ពាក្យថា"សាក្សី"មានអត្ថន័យស្វ័យប្រវត្តិដែលត្រូវបានអនុវត្តចំពោះភស្តុតាងប្រភេទផ្សេងៗ រួមទាំងសាក្សីជំនាញ សហជនជាប់ចោទ ជនរងគ្រោះ ឬភស្តុតាងជាឯកសារ។ *សូមមើល ឧ.* សាលក្រម*រឿងក្តី S.N.ទល់នឹងប្រទេសស៊ុយអែត* (ECtHR) កថាខណ្ឌ ៤៥។ សាលក្រម*រឿងក្តី Trofimov ទល់នឹងប្រទេសរុស្ស៊ី* (ECtHR) កថាខណ្ឌ ៣៤ ដល់ ៣៧។ សាលក្រម*រឿងក្តី Romanov ទល់នឹងប្រទេសរុស្ស៊ី* (ECtHR) កថាខណ្ឌ ៩៧។ សាលក្រម*រឿងក្តី Mirilashvili ទល់នឹងប្រទេសរុស្ស៊ី* (ECtHR) កថាខណ្ឌ ១៥៨ ដល់ ១៥៩។

[402] *សូមមើលឧ.* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខសុំឱ្យបើករឿងក្តីសាឡើងវិញ*រឿងក្តី Gotovina* (ICTY) កថាខណ្ឌ ២៣។ សាលដីកា*រឿងក្តី Čelebići* (ICTY) កថាខណ្ឌ ២៩០ ដល់ ២៩៣។

និងដោយហេតុថា ភស្តុតាងដែលស្នើឱ្យទទួលយកនោះ ពុំមានជាប់ពាក់ព័ន្ធ និងច្រំដែល ឬក៏ធ្វើឡើងក្នុងគោលបំណងអូសបន្លាយកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ[403]។

១៦៣.ផ្អែកតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា នៅក្នុងសេចក្ដីសម្រេចស្ដីពីការដាក់ឯកសារថ្មី ការបើកកិច្ចស៊ើបសួរ និងកោះហៅសាក្សី (E294/1) អង្គជំនុំជម្រះសាលាដំបូងបកស្រាយមិនបានត្រឹមត្រូវទៅលើច្បាប់ជាធរមាន ដោយចាត់ទុកភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីនេះសំខាន់ជាងការពិចារណាទៅលើភាពត្រឹមត្រូវនៃការជំនុំជម្រះ និងសិទ្ធិទទួលបានភស្តុតាង។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូង ពិតជាមានកំហុសផ្នែកនីតិវិធី ដោយហេតុថា បានសម្រេចមិនកោះហៅ Robert LEMKIN ឬមិនចាត់វិធានការស៊ើបអង្កេតលើឈុតខ្សែវីដេអូនេះ។

១៦៤.ដូចបានកត់សម្គាល់ខាងលើ ទោះជាយ៉ាងណាក៏ដោយ ពុំមែនរាល់កំហុសផ្នែកនីតិវិធីសុទ្ធតែបានរំលោភបំពានលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការការពារខ្លួនប្រកបដោយប្រសិទ្ធភាពនោះឡើយ។ ប៉ុន្តែ ជាការចាំបាច់ត្រូវតែធ្វើការវាយតម្លៃ ថាតើជនជាប់ចោទពិតជាបានទទួលរងផលប៉ះពាល់ដោយសារកំហុសនេះ ដែរឬយ៉ាងណា ដោយពិចារណាទៅលើកិច្ចដំណើរការនីតិវិធីទាំងមូល រួមទាំងវិធានការនានាដែលបានធ្វើឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលបណ្ដឹងសាទុក្ខ។ ទាក់ទងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អង្គជំនុំជម្រះតុលាការកំពូលបានបើកកិច្ចស៊ើបសួរបន្ថែមដើម្បីឱ្យដឹង ថាតើឈុតខ្សែវីដេអូដែលមាននៅក្នុងដៃរបស់ ថេត សម្បត្តិ និង Robert LEMKIN អាចទទួលបានក្នុងពេលវេលាសមស្រប ដែរ ឬយ៉ាងណា និង ថាតើមានព័ត៌មានអ្វីខ្លះដែលអាចយកបានពីឈុតខ្សែវីដេអូនេះ[404]។ លទ្ធផលនៃកិច្ចស៊ើបសួរបន្ថែមដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួល គឺសម្ភារដែលជាប្រភពផ្ទាល់ និងមិនផ្ទាល់ មានដូចជា ប្រតិចារឹករបស់ Robert LEMKIN និងកំណត់ហេតុរបស់ Robert LEMKIN ទាក់ទងទៅនឹងបទសម្ភាសន៍ដែល

---

[403] *សូមមើល* សេចក្ដីសម្រេចស្ដីពីភស្តុតាងថ្មី*រឿងក្ដី Galić* (ICTY) ដែលបានដកស្រង់នៅក្នុងសេចក្ដីសម្រេចស្ដីពីភស្តុតាងថ្មី ការស៊ើបសួរ និងការកោះហៅសាក្សី (E294/1) ជើងទំព័រ ៣៦។ *សូមមើលផងដែរ* សេចក្ដីសម្រេចស្ដីពីការបើករឿងក្ដីសាឡើងវិញ *រឿងក្ដី Kanyabashi* (ICTR) កថាខណ្ឌ ២៣ ដល់ ២៥ (បញ្ជាក់ថា ភស្តុតាងថ្មីមានតម្លៃជាភស្តុតាង ចាំបាច់ត្រូវតែសំខាន់ជាងការប៉ះពាល់ដែលបានបង្កឡើងដោយសារការពន្យារពេលនៃកិច្ចដំណើរការនីតិវិធីឆាប់រហ័ស និងត្រឹមត្រូវ និងថា កត្តាពាក់ព័ន្ធដែលត្រូវពិចារណា រួមមានដំណាក់កាលដែលការជំនុំជម្រះបានធ្វើឡើង និងសក្ដានុពលសម្រាប់ការពន្យារពេលនេះ)។

[404] សេចក្ដីសម្រេចបណ្ដោះអាសន្នទីមួយស្ដីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3) កថាខណ្ឌ ២៤ ដល់ ២៦។

Robert LEMKIN បានចាត់ទុកថា មានការបង្ហាញអំពីតួនាទីរបស់ ញឹម រស់ នៅទួលពោធិ៍ជ្រៃ និងការប៉ុនប៉ងផ្តួលរំលំការដឹកនាំ ប.ក.ក. របស់ ប៉ុល ពត និង នួន ជា[405]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ឱកាសគ្រប់គ្រាន់ឱ្យភាគីធ្វើសារណាស្តីពីភាពពាក់ព័ន្ធនៃសម្ភារដែលបានផ្តល់ដោយ Robert LEMKIN ព្រមទាំងស្តីពីការភ្ជាប់ការបែកបាក់នៅក្នុង ប.ក.ក. ទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ នួន ជា ផងដែរ[406]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា សម្ភារនេះពុំគប្បីទទួលយកជាភស្តុតាងនោះទេ ព្រោះសម្ភារនេះពុំមែនជាកត្តាកំណត់ដល់ការសម្រេច ឬជាប់ពាក់ព័ន្ធទៅនឹងការវិនិច្ឆ័យលើអង្គហេតុឡើយ[407]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដោយផ្អែកលើកិច្ចដំណើរការនីតិវិធីទាំងមូល នួន ជា ពុំបានទទួលរងផលប៉ះពាល់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

## ៤.ខ.២.ក.៤.សាក្សីទាក់ទងទៅនឹងស្ថានភាពមុនជម្លៀស

១៦៥.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយហេតុថា អង្គជំនុំជម្រះបានសម្រេចមិនកោះហៅសាក្សីដែលទាក់ទងទៅនឹងស្ថានភាពក្នុងទីក្រុងភ្នំពេញ នៅមុនការជម្លៀសប្រជាជនក្នុងខែមេសា ឆ្នាំ ១៩៧៥[408]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសារណារបស់សហព្រះរាជអាជ្ញា[409] ដែលថា ការសម្រេចមិនកោះហៅសាក្សីបន្ថែមទាក់ទងបញ្ហានេះ ពុំធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ឡើយ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់រួចហើយនៅក្នុងសាលក្រមរបស់ខ្លួនថា លក្ខខណ្ឌនៅមុនពេលជម្លៀសក្នុងទីក្រុងភ្នំពេញ មានការលំបាក និងថា មានកង្វះស្បៀងអាហារ[410]។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា កត្តាខាងដើមនេះពុំអាចធ្វើយុត្តិកម្មលើការជម្លៀសចេញពីទីក្រុងភ្នំពេញបានឡើយ។ បញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរ ឬយ៉ាងណា ទាក់ទងទៅនឹងការ

---

[405] កំណត់ហេតុស្តាប់ចម្លើយ LEMKIN (F2/4/3/1) កថាខណ្ឌ ក៣៤។

[406] សេចក្តីសម្រេចបណ្តោះអាសន្នទីពីរស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3/3)។ សេចក្តីសម្រេចបណ្តោះអាសន្នទីបួនស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3/3/6)។

[407] *សូមមើលខាងលើ* កថាខណ្ឌ ៥៣, ៥៦ *ជាអាទិ៍*។

[408] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៤។

[409] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦១។

[410] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៧។

វាយតម្លៃលើភាពជាប់ពាក់ព័ន្ធនៃស្ថានភាពខាងលើនេះនឹងត្រូវបានដោះស្រាយនៅក្នុងសាលដីកានេះ ដូចជានៅក្នុងការពិភាក្សាអំពីយុត្តិកម្មនៃការជម្លៀសប្រជាជនដំណាក់កាលទីមួយ[411]។

### ៤.ខ.២.ក.៥.សាក្សីទាក់ទងទៅនឹងគោលនយោបាយក្នុងការកំណត់គោលដៅលើអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ

១៦៦.ពាក់ព័ន្ធទៅនឹងអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅពេលសម្រេចបដិសេធសំណើសុំកោះហៅសាក្សី ដែលនឹងត្រូវផ្តល់សក្ខីកម្មអំពីអត្ថិភាពនៃគោលនយោបាយក្នុងការកំណត់គោលដៅលើអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ[412] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នួន ជា បានស្នើសុំឱ្យកោះហៅបុគ្គលទាំងនេះ គឺដើម្បីតទល់ទៅនឹងការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះទទួលយករាល់ចម្លើយមុនៗរបស់បុគ្គលទាំងនេះ មកធ្វើជាភស្តុតាង។ ដូច្នេះ សារៈសំខាន់នៃបញ្ហានេះ គឺថាតើអង្គជំនុំជម្រះសាលាដំបូងអាចសំអាងលើចម្លើយមុនៗរបស់សាក្សីទាំងនោះ ក្នុងវិសាលភាពប៉ុនណា ទើបពុំមានតម្រូវការឱ្យសាក្សីទាំងនោះមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។ បញ្ហានេះនឹងត្រូវដោះស្រាយនៅក្នុងសាលដីកានេះ[413]។

### ៤.ខ.២.ខ.ការទទួលយក និងការប្រើប្រាស់ឯកសារ

១៦៧.អំណះអំណាងមួយចំនួនរបស់ នួន ជា គឺពាក់ព័ន្ធទៅនឹងការទទួលយកជាភស្តុតាង និងការប្រើប្រាស់ឯកសារនៅពេលជំនុំជម្រះ ហើយអំណះអំណាងនេះនឹងត្រូវដោះស្រាយដូចខាងក្រោម។

### ៤.ខ.២.ខ.១.តម្រូវការចាំបាច់ឱ្យភាគីការពារក្តីដាក់បញ្ជីឯកសារ

១៦៨.នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ភាគី*ក្នុងចំណោមនោះ*ឱ្យដាក់យ៉ាងយូរត្រឹមថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១ (ក្រោយមក កាលបរិច្ឆេទត្រូវបានពន្យារពេលដល់ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១) នូវបញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿង ដែលភាគីមានបំណងប្រើប្រាស់នៅចំពោះមុខ

---

[411] *សូមមើលខាងក្រោម* កថាខណ្ឌ ៦០៤ *ជាអាទិ៍*។

[412] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៥។

[413] *សូមមើលខាងក្រោម* កថាខណ្ឌ ២៧៩ *ជាអាទិ៍*។

01358029



អង្គជំនុំជម្រះ[414]។ នួន ជា ពុំបានដាក់បញ្ជីឯកសារនេះទេ ដោយបានអះអាងថា គាត់“ពុំជាប់កាតព្វកិច្ច និងក្នុងកាលៈទេសៈ ដែលពុំអាចកំណត់អត្តសញ្ញាណឯកសារជាក់លាក់ពី[បញ្ជីឯកសារទាំងអស់នៅក្នុងសំណុំរឿង] ដែលគាត់មានបំណងប្រើប្រាស់នៅពេលជំនុំជម្រះឡើយ”[415]។ ជាការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូង“ហាមឃាត់មេធាវីការពារក្តី នួន ជា ក្នុងការប្រើប្រាស់ឯកសារដែលពុំត្រូវបានកំណត់អត្តសញ្ញាណនៅពេលជំនុំជម្រះ ដោយអនុលោមតាមដីកាបង្គាប់រៀបចំសវនាការ” ឬជាជម្រើស ត្រូវបង្គាប់ឱ្យ នួន ជា ដាក់បញ្ជីឯកសារសមស្របក្នុងរយៈពេលពីរសប្តាហ៍[416]នោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា៖

> ឯកសារដែលពុំត្រូវបានដាក់តាមកាលបរិច្ឆេទពីដំបូង ផ្អែកតាមវិធាន ៨៧(៣) [*ពាក្យដើម*] នៃវិធានផ្ទៃក្នុង ត្រូវតែបំពេញទៅតាមលក្ខខណ្ឌដែលមានកម្រិតខ្ពស់បំផុតក្នុងការបង្ហាញថា ឯកសារទាំងនេះពិតជាពុំអាចរកបាននៅក្នុងអំឡុងពេលនៃកាលបរិច្ឆេទជាធរមាននោះ បើទោះបីជាមានការស្វះស្វែងរកយ៉ាងហ្មត់ចត់ក៏ដោយ និងថា ដើម្បីផលប្រយោជន៍យុត្តិធម៌ ការទទួលយកឯកសារយឺតពេលនៅតែជាការសំខាន់[417]។

១៦៩.ការបើកកិច្ចពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១[418]។ យ៉ាងហោចណាស់ នៅពេលណាមួយក្នុងអំឡុងពេលជំនុំជម្រះ និងដើម្បីផលប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យ នួន ជា ប្រើប្រាស់ឯកសារមួយនៅចំពោះមុខខ្លួន ដែលមាននៅក្នុងសំណុំរឿងតាំងពីចុងឆ្នាំ ២០០៧ មកម្ល៉េះ បើទោះបីជា នួន ជា ពុំបានដាក់បញ្ជីឯកសារនោះក៏ដោយ[419]។

១៧០.នៅក្នុងបណ្តឹងសាទុក្ខ នួន ជា បានលើកអំណះអំណាងពីរ៖ ទីមួយ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានលក្ខណៈតឹងតែងហួសហេតុ ដោយតម្រូវឱ្យគាត់បង្ហាញអត្តសញ្ញាណឯកសារនៅក្នុងសំណុំរឿងសម្រាប់ទទួលយកជាភស្តុតាង ក្នុងរយៈពេលមួយយ៉ាងយូរមុននឹងចាប់ផ្តើមការជំនុំជម្រះ[420]។ ទីពីរ

---

[414] ដីកាបង្គាប់ដាក់សម្ភារដើម្បីរៀបចំសវនាការ (E9) កថាខណ្ឌ ១២ i)។

[415] សារណារបស់ នួន ជា ទាក់ទងទៅនឹងឯកសារថ្មី (E9/26) កថាខណ្ឌ ២។

[416] សំណើសុំរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងបញ្ជីឯកសាររបស់ នួន ជា (E109/5) កថាខណ្ឌ ២។

[417] អនុស្សរណៈស្តីពីបញ្ជីសាក្សី (E131/1) ទំព័រ ៤។

[418] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧។

[419] អនុស្សរណៈស្តីពីសំណើតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង (E276/2) កថាខណ្ឌ ៥។

[420] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៩ ដល់ ១០០។

នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារមានការរឹតត្បិតទៅលើការប្រើប្រាស់ឯកសារសម្រាប់គោលបំណង*សួរដេញដោល* សាក្សី[421]។

១៧១.ទាក់ទងទៅនឹងអំណះអំណាងមួយចំនួនពីដំបូង និងយោងតាមសំអាងហេតុខាងក្រោម អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង មានកំហុស។ យោងតាមវាក្យខណ្ឌទីមួយនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដាក់ពិរុទ្ធភាព ដោយផ្អែកតែលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងប៉ុណ្ណោះ ប្រសិនបើភាគីបានយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះ បានយកមកដាក់នៅចំពោះមុខភាគី។ យោងតាមមាត្រា ៣២១(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងអំពីករណីលើកលែងចំពោះវិធាននេះថា "តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែល *មាននៅក្នុងសំណុំរឿង* ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ"(សេចក្តីបញ្ជាក់បន្ថែម)។ នៅ អ.វ.ត.ក. ការដាក់ភស្តុតាងចូលក្នុងសំណុំរឿង គឺពុំទាន់គ្រប់គ្រាន់នៅឡើយទេ ប៉ុន្តែថែមទាំងតម្រូវឱ្យកំណត់អត្តសញ្ញាណជាក់លាក់ពីភស្តុតាងដែលត្រូវប្រើប្រាស់។ អត្ថប្រយោជន៍សម្រាប់វិធាននេះ គឺដើម្បីធានាអំពីភាពច្បាស់លាស់ថា នៅគ្រប់ពេលទាំងអស់ ភស្តុតាងណាមួយដែលអង្គជំនុំជម្រះសាលាដំបូងយកធ្វើជាមូលដ្ឋាន ក្នុងការសម្រេចដាក់ពិរុទ្ធ ដោយហេតុថា ទោះបីជាមានឯកសារច្រើនសន្ធឹកសន្ធាប់ ដែលត្រូវបានដាក់ចូលនៅក្នុងសំណុំរឿងក្នុងអំឡុងពេលនៃការស៊ើបអង្កេតក៏ដោយ ក៏ពុំមែនគ្រប់ឯកសារទាំងអស់នោះអាចជាប់ពាក់ព័ន្ធទៅនឹងបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយដែរ។ បន្ថែមលើនេះ នីតិវិធីនេះបានជួយពង្រឹងចរិតលក្ខណៈនៃកិច្ចដំណើរការនីតិវិធីតទល់ រួមទាំងគោលការណ៍ស្តីពីការដេញដោលផ្ទាល់មាត់ផងដែរ។

១៧២.ស្របតាមវិធាន ៨០(៣-ឃ) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យភាគីដាក់"បញ្ជីឯកសារថ្មីដែលខ្លួនមានបំណងចង់លើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង [...] និងបញ្ជីឯកសារមានស្រាប់នៅក្នុងសំណុំរឿង ដែលត្រូវបានបង្ហាញអត្តសញ្ញាណយ៉ាងច្បាស់លាស់"ទៅតាមកាលបរិច្ឆេទដែលបានកំណត់ដោយអង្គជំនុំជម្រះ។ នេះ គឺជាសេចក្តីអះអាងមួយដែលស្របជាមួយនឹងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដើម្បីអនុញ្ញាតឱ្យមានការរៀបចំកិច្ចដំណើរការនីតិវិធីបានត្រឹមត្រូវ។ ដូច្នេះ ភាគីតម្រូវឱ្យដាក់បញ្ជីឯកសារមុនការជំនុំជម្រះដែលជាឧបករណ៍ចម្បងសម្រាប់អង្គជំនុំជម្រះសាលាដំបូងដើម្បីចាត់ចែងកិច្ចដំណើរការនីតិវិធី។

---

[421] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១០១ ដល់ ១០៤។

១៧៣.វិធាន ៨០(៣) នៃវិធានផ្ទៃក្នុងពុំបានចែងជាក់លាក់លើបញ្ហា ថាតើ និងក្នុងកាលៈទេសៈណាខ្លះដែលភាគីអាចលើកឡើង នៅក្នុងពេលសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងនូវឯកសារដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែពុំមាននៅក្នុងបញ្ជីឯកសាររបស់ខ្លួន។ ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួននឹងអនុវត្តទៅតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និងសួរបញ្ជាក់ ជាពិសេស ថាតើភាគីដែលស្នើសុំនោះពិតជាបានយកចិត្តទុកដាក់ស្វះស្វែងរកយ៉ាងហ្មត់ចត់ ដែរ ឬយ៉ាងណា។ ទោះជាយ៉ាងណាក្តី ដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យមានការបង្ហាញឯកសារទាំងនោះ ដើម្បីប្រយោជន៍យុត្តិធម៌ បើទោះបីជាពុំបានបំពេញតាមលក្ខខណ្ឌនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏ដោយ។

១៧៤.យោងតាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ផ្អែកតាមលទ្ធផលឃើញថា វិធីសាស្ត្រនេះពុំមានកំហុសឆ្គងឡើយ។ តាមការលើកឡើងរបស់ នួន ជា[422]បានឱ្យដឹងថា វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងមានការចម្រូងចម្រាសគ្នាត្រង់ ថាតើវិធាននេះមានខ្លឹមសារអនុវត្តទៅលើឯកសារដែលបានដាក់ចូលក្នុងសំណុំរឿង ឬសម្រាប់តែភស្តុតាង"ថ្មី"សុទ្ធសាធប៉ុណ្ណោះ។ ប៉ុន្តែ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងបានស្របជាមួយនឹងវិធាន ៣៩ នៃវិធានផ្ទៃក្នុងដែលផ្តល់ឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយដល់អង្គជំនុំជម្រះ ក្នុងការកំណត់ផលវិបាកនៃអំឡុងពេលកំណត់ដែលត្រូវធ្វើឡើងដោយអង្គជំនុំជម្រះ។ ជាការកត់សម្គាល់ ភាគីដែលបានគិតថាពេលវេលាដែលបានផ្តល់ឱ្យខ្លួននោះតិចតួចពេក គួរតែស្នើសុំការពន្យារអំឡុងពេលកំណត់នេះ។ ក្នុងករណីដែលភាគី មិនគោរពតាមអំឡុងពេលកំណត់ក្នុងការ"ដាក់"ឯកសារចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងពិចារណាទៅលើបញ្ហា ថាតើភាគីដែលស្នើសុំនោះពិតជាបានយកចិត្តទុកដាក់សមស្របក្នុងការរៀបចំបញ្ជីដោយអនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា និងដើម្បីប្រយោជន៍យុត្តិធម៌ បើទោះបីជាភាគីពុំបានរៀបចំបញ្ជីឱ្យបានត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៅតែអាចអនុញ្ញាតឱ្យមានការបង្ហាញឯកសារនោះបានដដែល[423]។ វិធីសាស្ត្រនេះបានថ្លឹងថ្លែងពីតម្រូវការចាំបាច់ក្នុងការគ្រប់គ្រងការជំនុំជម្រះឱ្យបានសមស្រប និងមានភាពបត់បែនបាន នៅពេលតម្រូវឱ្យមានការធានាបាននូវកិច្ចដំណើរការនីតិវិធីដោយត្រឹមត្រូវនោះ។

១៧៥.អង្គជំនុំជម្រះតុលាការកំពូលពុំមានការជឿជាក់លើអំណះអំណាងដែលលើកឡើងថា អង្គជំនុំជម្រះ

---

[422] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៩៥ ដល់ ៩៩។

[423] សេចក្តីសម្រេចស្តីពីឯកសារថ្មី (E190) កថាខណ្ឌ ២១។ អនុស្សរណៈស្តីពីសំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E276/2) កថាខណ្ឌ ២។

សាលាដំបូងពុំបានគោរពទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា "ភស្តុតាងអាចជូនបានដោយសេរី" និងអាចដាក់រហូតដល់ថ្ងៃចុងក្រោយនៃការជំនុំជម្រះបាន[424]។ ដូចបានលើកឡើងខាងលើ វិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ដែលត្រូវបកស្រាយបានជាមួយនឹងបរិបទនៃវិធាន ៨៧ នៃវិធានផ្ទៃក្នុង មានន័យថា ជាឧបករណ៍សម្រាប់គ្រប់គ្រងសំណុំរឿងដែលពុំអាចបដិសេធនូវចំណែក ឬប្រភេទណាមួយនៃភស្តុតាងបានឡើយ ប៉ុន្តែអាចជាការដាក់វិន័យលើភាគីក្នុងកម្រិតណាមួយ និងមានភាពចាំបាច់ដោយសារតែទំហំធំធេងនៃសំណុំរឿងនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. និងត្រូវធ្វើឡើងជាបីភាសាផងដែរ។ ដូច្នេះ អ.វ.ត.ក. ត្រូវបានអនុញ្ញាតឱ្យអនុម័តវិធានផ្ទៃក្នុងទាំងនេះ ដើម្បីសម្រេចគោលដៅនៃការជំនុំជម្រះដោយត្រឹមត្រូវ និងធានាបាននូវការជំនុំជម្រះឆាប់រហ័ស[425]។ អាស្រ័យហេតុនេះ បើទោះបីជាមិនមានការអនុវត្តខ្លះតាមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដោយ ក៏នៅតែត្រូវបានចាត់ទុកថា ជាការសមហេតុផលដែរ។ វិធានផ្ទៃក្នុងបានបង្កើតឡើងដើម្បីកំណត់នីតិវិធីសម្រាប់ការបង្ហាញភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងសំអាងទៅលើ ដូច្នេះវិធាននេះ គឺជាការជួយជំរុញដំណើរការនីតិវិធីជាចំហ និងតាមលំដាប់លំដោយ។

១៧៦.ដោយផ្អែកតាមអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា វិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ ជាក់ស្តែង ឃ្លាតឆ្ងាយចេញពីការអនុវត្តរបស់តុលាការ ICC ICTY និង ICTR[426] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អ.វ.ត.ក. ពុំតម្រូវឱ្យចម្លងតាមការអនុវត្តអន្តរជាតិ ប៉ុន្តែត្រឹមតែអនុញ្ញាតឱ្យស្វែងរកការណែនាំពីកម្រិតអន្តរជាតិប៉ុណ្ណោះ[427]។ គួរកត់សម្គាល់ផងដែរទាក់ទងទៅនឹងបញ្ហានេះថា លិខិតុបករណ៍ច្បាប់ដែលតុលាការ ICC ICTY និង ICTR យកមកអនុវត្តតាមនោះ ពុំបានចែងអំពីការស៊ើបអង្កេត និងការបញ្ជូន*សំណុំឯកសារ*នៃការស៊ើបអង្កេតទាំងអស់ទៅតុលាការជំនុំជម្រះឡើយ។ បន្ថែមលើសពីនេះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការដែលមានបទដ្ឋានអន្តរជាតិដទៃទៀត បានដាក់កាតព្វកិច្ចដល់ភាគីត្រូវតែដាក់បញ្ជីឯកសារមុនពេលសវនាការ[428] បើទោះបីជា អាចមានការអនុវត្តខុសប្លែកគ្នាខ្លះក៏ដោយ។ ទោះជាយ៉ាង

---

[424] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៩០ យោងទៅលើមាត្រា ៣២១ និង ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[425] *សូមមើលខាងលើ* កថាខណ្ឌ ១០៣ *ជាអាទិ៍*។

[426] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៩២ ដល់ ៩៤។

[427] មាត្រា ១២(១) នៃច្បាប់ អ.វ.ត.ក.។

[428] *សូមមើល* វិធាន ៦៥ *ស្ទួនពីរ* (ឆ-២) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY។ វិធាន ៧៣ *ស្ទួនពីរ* (ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR។

ណាក្តី សំខាន់បំផុតនោះ គឺ នួន ជា ពុំបានបង្ហាញដល់អង្គជំនុំជម្រះតុលាការកំពូលនូវហេតុការណ៍ណាមួយ ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអនុញ្ញាតឱ្យគាត់ប្រើប្រាស់ឯកសារជាក់លាក់ណាមួយនៅក្នុងរឿងក្តី ទោះបីជាគាត់ពុំបានដាក់បញ្ជីឯកសារក៏ដោយចុះ និងថា គាត់ពុំអាចដេញដោលលើភស្តុតាងប្រឆាំងនឹងរូបគាត់ ឬក៏ពុំអាចបន្ថែមមធ្យោបាយការពារខ្លួនបានឡើយ។ ហេតុដូច្នេះ ដូចការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ឃើញថា គ្រប់កាលៈទេសៈទាំងអស់ ពុំមានការប៉ះពាល់ណាមួយត្រូវបានកើតឡើងឡើយ[429]។

១៧៧.យោងតាមសំអាងហេតុដូចគ្នា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភាពចាំបាច់ក្នុងការ ដោះស្រាយលម្អិតទៅលើអំណះអំណាងនីមួយៗក្នុងផ្នែកទីពីររបស់ នួន ជា ដែលបានលើកឡើងថា វិធីសាស្ត្រ របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការប្រើប្រាស់*ឯកសារសម្រាប់សួរដេញដោល* គឺមានការខុសឆ្គង នោះឡើយ[430]។ នួន ជា ពុំបានបង្ហាញពីកំហុសដែលមានមូលដ្ឋានគាំទ្រច្បាស់លាស់ ថាតើអង្គជំនុំជម្រះសាលា ដំបូង ពិតជាបានហាមឃាត់គាត់មិនឱ្យសួរដេញដោលទៅលើភាពអាចជឿទុកចិត្តបាន ឬអាចជឿជាក់បាន របស់សាក្សីណាមួយនោះឡើយ។

១៧៨.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តវិធានដូចគ្នាទាក់ទងទៅនឹងការទទួល យកឯកសារជាភស្តុតាង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសាកសួរសាក្សី[431]។ និយាយជាទូទៅ អង្គជំនុំ ជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលលើកឡើងថា អំណះអំណាងនេះពុំបាន ពិចារណាទៅលើការពិតដែលថា អំឡុងពេលកំណត់សម្រាប់ការបង្ហាញភស្តុតាង ពិតប្រាកដណាស់ គឺជាវិធាន ដែលមិនត្រឹមតែត្រូវអនុវត្តលើភាគីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើអង្គជំនុំជម្រះផងដែរ[432]។ ទោះជាយ៉ាងណាក្តី ពាក់ព័ន្ធទៅនឹងការដែលថា អំឡុងពេលកំណត់ទាំងនេះមានតួនាទីដើម្បីធានាតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ភាគីគប្បីទទួលបានផលប្រយោជន៍ផងដែរ ពីការជូនដំណឹងសមស្របទាក់ទងទៅនឹងការប្រើប្រាស់ឯកសារ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ក្រៅតែពីការតវ៉ាជាទូទៅអំពីភាពមិនប្រាកដ ប្រជានៃវិធានផ្ទៃក្នុងដែលអនុវត្តមកលើរូបគាត់ ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រច្បាស់លាស់ថា គាត់ពិត ជាបានទទួលរងនូវផលប៉ះពាល់ពីការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងប្រាកដមែននោះឡើយ។

---

[429] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៥។

[430] សារណារបស់ នួន ជា កថាខណ្ឌ ១០១ ដល់ ១០៤។

[431] សារណារបស់ ខៀវ សំផន កថាខណ្ឌ ៣៨។

[432] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៤។

## ៤.ខ.២.ខ.២.នីតិវិធីទាក់ទងទៅនឹងការទទួលយកឯកសារជាភស្តុតាង

១៧៩.ខៀវ សំផន បានលើកឡើងនូវអំណះអំណាងមួយចំនួនទាក់ទងទៅនឹងការទទួលយកឯកសារដោយអង្គជំនុំជម្រះសាលាដំបូង។

១៨០.ដូចបានកត់សម្គាល់ខាងលើ ចាប់តាំងពីដំបូងនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យភាគីដាក់បញ្ជីឯកសារនានាដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ[433]។ អង្គជំនុំជម្រះសាលាដំបូងក៏បានជូនដំណឹងដល់ភាគីផងដែរថា ខ្លួនមានបំណងដាក់នៅចំពោះមុខភាគីនូវឯកសារទាំងអស់ដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ (D427) ក្នុងវិសាលភាពដែលឯកសារទាំងនោះពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ [434]។

១៨១.បន្ទាប់មកទៀត អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសឱ្យភាគីលើកសេចក្តីជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងឯកសារដែលបានស្នើឡើងដោយភាគីដទៃទៀត[435]។ អង្គជំនុំជម្រះក៏បានកំណត់កាលបរិច្ឆេទសវនាការ ក្នុងគោលបំណងស្តាប់សារណារបស់ភាគីស្តីពីការទទួលយកឯកសារ ("សវនាការស្តីពីការទទួលយកឯកសារ")[436]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទសវនាការក្នុងគោលបំណងកំណត់អត្តសញ្ញាណនូវឯកសារណាដែលតាមទស្សនៈរបស់ភាគី មានជាប់ពាក់ព័ន្ធខ្លាំងបំផុតទៅនឹងសំណុំរឿង

---

[433] *សូមមើលខាងលើ* កថាខណ្ឌ ១៦៨។

[434] ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឱ្យដាក់សម្ភារដើម្បីរៀបចំការជំនុំជម្រះ (E9) កថាខណ្ឌ ១២ iii)។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E1/4.1 ទំព័រ ២២។ ដីកាកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់លើឯកសារ ខែ មករា ឆ្នាំ ២០១២ (E159) កថាខណ្ឌ ១។ *សូមមើលផងដែរ* ដីកាបំបែកកិច្ចដំណើរការនីតិវិធី (E124) កថាខណ្ឌ ២។

[435] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ជីសាក្សី (E131/1) ទំព័រ ១ ដល់ ២។ សេចក្តីជំទាស់របស់ ខៀវ សំផន លើភាពអាចទទួលយកបាន (E131/1/11) កថាខណ្ឌ ២ *ជាអាទិ៍*។ សេចក្តីជំទាស់របស់ នួន ជា លើភាពអាចទទួលយកបាន (E131/1/12)។

[436] ដីកាកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់លើឯកសារ ខែ មករា ឆ្នាំ ២០១២ (E159) កថាខណ្ឌ ៨ ដល់ ៩។ ដីកាកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់លើឯកសារ ខែ កុម្ភៈ ឆ្នាំ ២០១២ (E170) កថាខណ្ឌ ៦ ដល់ ៧។ អនុស្សរណៈសម្រាប់សវនាការផ្ទាល់មាត់បន្ថែមលើឯកសារស្តីពីឯកសារ (E172/1)។ អនុស្សរណៈត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់សវនាការបន្ទាប់លើឯកសារ (E172/5)។ ដីកាកំណត់កាលបរិច្ឆេទដែលត្រូវបានកែប្រែសម្រាប់សវនាការខាងមុខលើឯកសារ (E223/3) ។ សេចក្តីសម្រេចទីបីស្តីពីសេចក្តីជំទាស់ទៅនឹងឯកសារសម្រាប់ការទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង E185/2 កថាខណ្ឌ ៤ ដល់ ១២ (លើកឡើងអំពីប្រវត្តិនីតិវិធីនៃសវនាការស្តីពីភាពអាចទទួលយកបាននៅចំពោះមុខងអង្គជំនុំជម្រះ)។

(“សវនាការស្តីពីឯកសារ”)[437] ពីក្នុងចំណោមឯកសារដែលត្រូវបានទទួលយកនោះ។ នៅក្នុងសវនាការនេះ ជាដំបូង គឺមានតែ នួន ជា និង ខៀវ សំផន ប៉ុណ្ណោះ ដែលត្រូវបានផ្តល់ឱកាសឱ្យធ្វើសារណាស្តីពីឯកសារទាំងនោះ បន្ទាប់មកទៀតភាគី ក៏ត្រូវបានអញ្ជើញឱ្យធ្វើសារណាស្តីពីតម្លៃនៃភស្តុតាងទៅលើឯកសារទាំងនោះ[438]។ ជាទូទៅ ឯកសារណាដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងត្រូវបានផ្តល់លេខសំគាល់ ‘E3’ (“ឯកសារលេខ E3”)[439]នៅក្នុងសំណុំរឿង។

១៨២.ខៀវ សំផន បានលើកអំណះអំណាងមួយចំនួនទាក់ទងទៅនឹងនីតិវិធីសម្រាប់ទទួលយកភស្តុតាង។ ចំពោះអំណះអំណាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ច្បាស់លាស់អំពីចំណាត់ថ្នាក់ឯកសារដែលត្រូវបានផ្តល់លេខសំគាល់ E3 នៅក្នុងសំណុំរឿង និងពុំបានផ្តល់បញ្ជីឯកសារដល់ភាគីឡើយ[440] នោះអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន បានផ្តល់មូលដ្ឋានគាំទ្រត្រឹមតែបានយោងនៅក្នុងជើងទំព័រទៅលើអនុស្សរណៈចំនួន ៤ ដែលអង្គជំនុំជម្រះសាលាដំបូងបានចេញក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីដើម្បីឆ្លើយតបទៅនឹងសំណើផ្សេងៗរបស់ភាគី[441]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដោយសារពុំបានពន្យល់ពីមូលហេតុ ថាតើអនុស្សរណៈទាំងនេះមានកំហុសយ៉ាងដូចម្តេច និងពុំបានផ្តល់មូលដ្ឋានគាំទ្រច្បាស់លាស់[442]។

១៨៣.ទាក់ទងទៅនឹងអំណះអំណាងផ្សេងទៀតដែលលើកឡើងថា នីតិវិធីទាក់ទងទៅនឹងការទទួលយកភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកអនុវត្តនោះ ពុំស្របតាមលក្ខខណ្ឌតម្រូវនៃគោលការណ៍តទល់

---

[437] ដីកាកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់លើឯកសារ ខែ កុម្ភៈ ឆ្នាំ ២០១២ (E170)។ សេចក្តីណែនាំដល់ភាគីឱ្យតាមដានសវនាការកាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ (E233)។ ដីកាកំណត់កាលបរិច្ឆេទដែលត្រូវបានកែប្រែសម្រាប់សវនាការខាងមុខលើឯកសារ (E223/3)។ សេចក្តីប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសវនាការដែលនៅសេសសល់ (E288)។ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការស្តាពរលើឯកសារ និងសវនាការដទៃទៀត (E288/1/1)។

[438] ដីកាកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់លើឯកសារ ខែ កុម្ភៈ ឆ្នាំ ២០១២ (E170)។ សេចក្តីណែនាំដល់ភាគីឱ្យតាមដានសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ (E233) កថាខណ្ឌ ៣ ដល់ ៤។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨។

[439] *សូមមើល* ដីកាកំណត់កាលបរិច្ឆេទសវនាការផ្ទាល់មាត់លើឯកសារ ខែ មករា ឆ្នាំ ២០១២ (E159) កថាខណ្ឌ ៥។

[440] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២១។

[441] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២១ ជើងទំព័រ ៤៥។

[442] *សូមមើលខាងលើ* កថាខណ្ឌ ១០១ *ជាអាទិ៍*។

ចំពោះមុខឡើយ[443] អង្គជំនុំជម្រះតុលាការកំពូលពិនិត្យឃើញថា ខៀវ សំផន បានលើកឡើងនូវបញ្ហាពីរដូចតទៅ ទីមួយ គឺទាក់ទងទៅនឹងវិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការទទួលយកឯកសារជាភស្តុតាង រួមទាំងការសម្រេចរបស់ខ្លួនក្នុងការផ្តល់លេខសំគាល់ E3 លើឯកសារទាំងអស់ដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ (D427) ទាក់ទងទៅនឹងសំណុំរឿង ០០២/០១ (ហេតុនេះឃើញថា ក្នុងចំណោមឯកសារទាំងនោះ អាចត្រូវបានយកមកសំអាងនៅពេលចេញសាលក្រម) និងទីពីរ គឺការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើឯកសារជាក់លាក់ដែលពុំបានផ្តល់លេខសំគាល់ E3 និងការទទួលយកឯកសារផ្សេងទៀតដែល ខៀវ សំផន បានធ្វើការជំទាស់។

១៨៤.ទាក់ទងទៅនឹងបញ្ហាទីមួយ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់លេខសំគាល់ E3 លើឯកសារទាំងអស់ដែលបានយោងនៅក្នុងដីកាដំណោះស្រាយ (D427) ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ក្នុងអំឡុងពេលនៃការស៊ើបអង្កេត"សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃលើឯកសារទាំងអស់ដែលបានដាក់នៅក្នុងសំណុំរឿងដើម្បីកំណត់ពីភាពជាប់ពាក់ព័ន្ធ និងបានផ្តល់តម្លៃជាភស្តុតាងទៅលើឯកសារមួយចំនួនដែលបានយោងនៅក្នុងដីកាដំណោះស្រាយ"[444]។ អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា ដីកាដំណោះស្រាយ (D427) "គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្មតទុកជាមុននូវឯកសារដែលបានយោងនៅក្នុងដីកាដំណោះស្រាយ(D427)ថា មានភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន (រួមទាំងភាពត្រឹមត្រូវនៃឯកសារ) និងបានដាក់លេខសំគាល់ E3 ចំពោះឯកសារទាំងនោះ"[445]។ អង្គជំនុំជម្រះតុលាការកំពូលរំលឹកផងដែរថា អង្គជំនុំជម្រះសាលាដំបូង បន្ទាប់មកបានផ្តល់ឱកាសឱ្យភាគីលើកឡើងពីបញ្ហានៃឯកសារទាំងនោះ នៅពេលសវនាការស្តីពីឯកសារ[446] និងក្នុងអំឡុងពេលនៃការធ្វើសារណាផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរស្តីពីការបិទកិច្ចពិភាក្សាដេញដោល។ ប្របហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹងការទទួលយកភស្តុតាងជាឯក

---

[443] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣ និង ២៦។

[444] អនុស្សរណៈចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (E162) កថាខណ្ឌ ៣។

[445] អនុស្សរណៈចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (E162) កថាខណ្ឌ ៣។

[446] អនុស្សរណៈស្តីពីការកំណត់កាលបរិច្ឆេទកិច្ចប្រជុំមិនផ្លូវការ (E141) ទំព័រ ២។ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E1/27.1 ទំព័រ ១។ ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E1/28.1 ទំព័រ ១។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E1/29.1 ទំព័រ ១។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E1/30.1 ទំព័រ ៣។

សារ ជាទូទៅ ភាគីអាចលើកសេចក្ដីជំទាស់ប្រឆាំងទៅនឹងការទទួលយកឯកសារនេះជាលាយលក្ខណ៍អក្សរ និងអាចលើកឡើងពីខ្លឹមសារនៃឯកសារនេះនៅក្នុងសវនាការស្ដីពីឯកសារ ព្រមទាំងតាមសារណាជាលាយលក្ខណ៍អក្សរ និងលើកឡើងដោយផ្ទាល់មាត់នៅក្នុងការបិទកិច្ចពិភាក្សាដេញដោល។

១៨៥.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងពុំបានរំលោភបំពានទៅលើគោលការណ៍តទល់ចំពោះមុខនោះទេ។ គោលការណ៍ស្ដីពីកិច្ចដំណើរការនីតិវិធីតទល់ចំពោះមុខតម្រូវមុនគេបង្អស់គឺថា គ្រប់ភាគីត្រូវបានផ្ដល់ឱកាសឱ្យផ្ដល់យោបល់ទៅលើភស្ដុតាងដែលបានដាក់បង្ហាញនៅពេលសវនាការ និងទៅលើសារណារបស់ភាគីដែលធ្វើការជំទាស់ ក្នុងគោលបំណងដើម្បីឱ្យមានឥទ្ធិពលទៅលើសេចក្ដីសម្រេចរបស់តុលាការ[447]។ គោលការណ៍នេះពុំបានតម្រូវថា ត្រូវតែផ្ដល់ឱកាសឱ្យភាគីក្នុងពេលជាក់លាក់ណាមួយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីឡើយ ឧទាហរណ៍ដូចជា ត្រូវផ្ដល់នៅមុនពេលទទួលយកជាភស្ដុតាង និងពុំបានតម្រូវថា ភាគីត្រូវតែធ្វើសារណាស្ដីពីភស្ដុតាងទាំងនោះឡើយ បើទោះបីជាភាគីនីមួយៗ មានឱកាសធ្វើដូច្នោះក៏ដោយ[448]។ នៅក្នុងរឿងក្ដីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ពីឯកសារនៅក្នុងសំណុំរឿងដែលអាចយកមកសំអាងក្នុងសាលក្រមរបស់ខ្លួន ដោយរួមទាំងឯកសារទាំងអស់ដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ (D427)។ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ឱកាសផងដែរដល់ភាគីឱ្យផ្ដល់យោបល់ទៅលើឯកសារទាំងអស់នោះ រួមទាំងលើតម្លៃជាភស្ដុតាង និងភាពជឿទុកចិត្តបាននៃឯកសារនោះ។ អាស្រ័យហេតុនេះ ការលើកឡើងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហានេះ ត្រូវបដិសេធចោល។

១៨៦.ទាក់ទងទៅនឹងបញ្ហាទីពីរដែល ខៀវ សំផន បានលើកឡើងថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើឯកសារដែលពុំមានលេខសំគាល់ E3[449]នោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា កង្វះលេខសំគាល់ឯកសារនេះ ទំនងជាមានបញ្ហាផ្នែក

---

[447] សាលក្រម *រឿងក្ដី Laukkanen ទល់នឹងប្រទេស Finland* (ECtHR) កថាខណ្ឌ ៣៤។ *សូមមើលផងដែរ* សាលក្រម *រឿងក្ដី Kamasinski ទល់នឹង Austria* (ECtHR) កថាខណ្ឌ ១០២។ សាលក្រម *រឿងក្ដី Brandstetter ទល់នឹង Austria* (ECtHR) កថាខណ្ឌ ៦៧។ សាលក្រម *រឿងក្ដី Rowe ទល់នឹងចក្រភពអង់គ្លេស* (ECtHR) កថាខណ្ឌ ៦០។ សាលក្រម *រឿងក្ដី Fitt ទល់នឹងចក្រភពអង់គ្លេស* (ECtHR) កថាខណ្ឌ ៤៤។ សាលក្រម *រឿងក្ដី Göç ទល់នឹងប្រទេសតួគី* (ECtHR) កថាខណ្ឌ ៣៤។

[448] សាលក្រម *រឿងក្ដី Nideröst-Huber ទល់នឹងប្រទេសស្វីហ្សែលឡែន* (ECtHR) កថាខណ្ឌ ២០ ដល់ ២៤។

[449] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦ ជើងទំព័រ ៨៧។

រដ្ឋបាលដោយសារការមើលរំលងប៉ុណ្ណោះ[450]។ ទោះបីជាយ៉ាងណាក៏ដោយ ខៀវ សំផន ធ្លាប់បានទទួលស្គាល់[451]ឯកសារនេះរួចហើយ ដែលជាក់ស្តែងត្រូវបានបង្ហាញក្នុងអំឡុងពេលនៃសវនាការ ហើយគាត់ក៏ធ្លាប់បានជំទាស់ទៅនឹងការប្រើប្រាស់ឯកសារនេះផងដែរ[452]។ ផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន[453] អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសេចក្តីជំទាស់នេះ ដោយបានដោះស្រាយរួមគ្នាជាមួយបញ្ហាផ្សេងទៀតក្នុងពេលតែមួយ[454]។ អាស្រ័យហេតុនេះ លក្ខខណ្ឌតម្រូវនៃគោលការណ៍ចំពោះមុខត្រូវបានគោរព ហើយអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហានេះ ត្រូវបដិសេធចោល។

## ៤.ខ.២.គ.ពេលវេលា និងចំនួនទំព័រពុំគ្រប់គ្រាន់

១៨៧.ទាក់ទងទៅនឹងការសួរសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដោយភាគី អង្គជំនុំជម្រះសាលាដំបូងបានបែងចែកពេលវេលាស្មើៗគ្នា ដោយមួយផ្នែកសម្រាប់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី រីឯមួយផ្នែកទៀតសម្រាប់ក្រុមមេធាវីការពារក្តីដែលមានបីក្រុម ក្រោយមកមានពីរក្រុម[455]។ នួន ជា បានអះអាងថា ការកំណត់ពេលវេលាក្នុងការសួរសំណួរមានលក្ខណៈតឹងរ៉ឹង និងពុំគ្រប់គ្រាន់ និងថា គាត់ ជាទូទៅទទួលបានតែមួយភាគបីនៃពេលវេលាតែប៉ុណ្ណោះ បើធៀបជាមួយនឹងសហព្រះរាជអាជ្ញា[456]។ នួន ជា និង ខៀវ សំផន ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានរឹតត្បិតចំនួនទំព័រពុំត្រឹមត្រូវសម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ បន្ថែមលើនេះទៀត យោងតាមការកំណត់ពេលវេលារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សរបញ្ចប់កិច្ចពិភាក្សាដេញដោលត្រឹមថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៣ ខៀវ សំផន បានអះអាងថា ខ្លួនមានពេលវេលាខ្លីពេក បើគិតចាប់ពីពេលចេញសេចក្តីសម្រេចលើការជំទាស់ទៅនឹងការទទួលយកចម្លើយរបស់សាក្សី (E299) ដែលសេចក្តីសម្រេចនេះបានទទួល

---

[450] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៦។

[451] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦។

[452] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ (E1/167.1) ទំព័រ ៦០ *ជាអាទិ៍*។

[453] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦។

[454] ប្រតិចារឹកចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E1/168.1 ទំព័រ ២។

[455] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១០៥។ សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៧។ *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមពេលវេលា (E236/5/4/1) កថាខណ្ឌ ៣។

[456] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១០៥ ដល់ ១០៦។

យកចម្លើយជាលាយលក្ខណ៍អក្សរដែលមានចំនួនរាប់រយធ្វើជាភស្តុតាង និងបានចេញនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ដែលមានពេលតែប្រាំមួយសប្តាហ៍មុនពេលកំណត់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលប៉ុណ្ណោះ[457]។

១៨៨.ដូចអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ខាងដើមថា គោលការណ៍ស្តីពីតុល្យភាពតទល់ពុំតម្រូវថា ពេលវេលាត្រូវតែបែងចែកដោយស្វ័យប្រវត្តិទៅឱ្យភាគីសម្រាប់សួរសាក្សីនោះឡើយ[458]។ បើទោះបីជាគោលការណ៍ស្តីពីតុល្យភាពតទល់នេះធានាថា ពុំមានភាគីណាមួយត្រូវបានបាត់បង់អត្ថប្រយោជន៍ដោយផ្អែកលើគោលការណ៍សមធម៌នៃនីតិវិធីក៏ដោយ ក៏ពុំមែនមានន័យថា ជនជាប់ចោទ“ត្រូវតែទទួលបានរយៈពេល ឬចំនួនសាក្សីស្មើគ្នាទៅនឹងអយ្យការដែរ ពីព្រោះអយ្យការត្រូវទទួលបន្ទុកក្នុងការបង្ហាញឱ្យហួសពីវិមតិសង្ស័យនូវធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់”[459]។ ផ្ទុយទៅវិញ ការកំណត់ទៅលើទំនាក់ទំនងរវាងរយៈពេល និងចំនួនសាក្សីដែលត្រូវបែងចែករវាងអយ្យការ និងជនជាប់ចោទ តុលាការបានអនុវត្តតាមគោលការណ៍ស្តីពីភាពសមាមាត្រជាមូលដ្ឋាន តែពុំបានអនុវត្តតាម“គោលការណ៍រឹតត្បិតស្តីពីតុល្យភាពស្វ័យប្រវត្តិ” ឡើយ[460]។ លើសពីនេះទៀត នៅក្នុងរឿងក្តីដែលមានជនជាប់ចោទច្រើន ការប៉ះពាល់ដែលបណ្តាលមកពីបញ្ហាសមាមាត្រកើតមានជាក់ស្តែងដោយសារអយ្យការត្រូវការបង្ហាញភស្តុតាងច្រើន ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវនីមួយៗរបស់ជនជាប់ចោទជាច្រើន[461]។ អាស្រ័យហេតុនេះ បញ្ហាពុំស្ថិតនៅត្រង់ការលើកហេតុផល ថាតើការដែលពុំមានភាពសមាមាត្ររវាងអយ្យការ និងជនជាប់ចោទបានធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ភាគីក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន ដែរ ឬយ៉ាងណានោះឡើយ ផ្ទុយទៅវិញអំណះអំណាងរបស់ភាគី គប្បីផ្តោត

---

[457] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២០។

[458] សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែម (F26/2/2) កថាខណ្ឌ ៦។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាប់បង្គំ *រឿងក្តី Orić* (ICTY) កថាខណ្ឌ ៧។

[459] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធមិនសម្រេចលើភស្តុតាង *រឿងក្តី Prlić* (ICTY) កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ *រឿងក្តី Orić* (ICTY) កថាខណ្ឌ ៧។

[460] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងការបដិសេធមិនសម្រេចលើភស្តុតាង *រឿងក្តី Prlić* (ICTY) កថាខណ្ឌ ១៤ និង ១៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ *រឿងក្តី Orić* (ICTY) កថាខណ្ឌ ៧។

[461] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទប្រឆាំងនឹងសេចក្តីសម្រេចបែងចែកពេលវេលា *រឿងក្តី Prlić* (ICTY) កថាខណ្ឌ ៣៥ និង ៣៩។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងការបដិសេធមិនសម្រេចលើភស្តុតាង *រឿងក្តី Prlić* (ICTY) កថាខណ្ឌ ១៥។

ទៅលើ“ការចោទប្រកាន់ជាក់លាក់ថា ពិតជាបានប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនប្រាកដមែន”[462]។

១៨៩.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្រៅតែពីការប្រៀបធៀបចំនួនពេលវេលា នួន ជា ពុំបានផ្តល់មូលដ្ឋានគាំទ្រច្បាស់លាស់ទាក់ទងទៅនឹងមូលហេតុដែលធ្វើឱ្យប៉ះពាល់ដល់រឿងក្តីរបស់ខ្លួន ដោយសារតែការបែងចែកពេលវេលាសម្រាប់សួរសំណួរសាក្សីឡើយ។ វិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ ដូចជាផ្តល់ពេលវេលាស្មើៗគ្នា មួយផ្នែកទៅឱ្យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ហើយមួយផ្នែកទៀតទៅឱ្យក្រុមមេធាវីការពារក្តីនោះ ពុំមែនជាការផ្តល់ពេលវេលាដែលពុំសមហេតុសមផលនោះទេ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរទៅលើសារណាររបស់សហព្រះរាជអាជ្ញាដែលបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានភាពបត់បែនទាក់ទងទៅនឹងការបែងចែកពេលវេលានេះ[463]។ ដូចនេះ នួន ជា ពុំបានបង្ហាញពីកំហុសណាមួយដែលស្តែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការវាយតម្លៃទៅលើសមាមាត្រនៃការបែងចែកពេលទៅឱ្យអយ្យការ និងជនជាប់ចោទសម្រាប់សួរសាក្សីឡើយ។

១៩០.ទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការកំណត់ចំនួនទំព័រនៅពេលសវនាការ និងថា សេចក្តីសម្រេចនេះត្រូវបានទទួលយកជាបានការក្នុងកម្រិតមួយនៅដំណាក់កាលបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះសាលាដំបូងជាដំបូងបានកំណត់ចំនួនទំព័រសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗត្រឹម ១០០ ទំព័រ និងបន្ថែម ២០ ទំព័រទៀតសម្រាប់សេចក្តីសន្និដ្ឋានរបស់ក្រុមនីមួយៗលើកពីមូលដ្ឋានសំអាងផ្លូវច្បាប់។ ចំនួនទំព័រសម្រាប់សហព្រះរាជអាជ្ញាត្រូវបានកំណត់ត្រឹម ២០០ ទំព័រ (និងបន្ថែម ២០ ទំព័រទៀតសម្រាប់លើកពីមូលដ្ឋានសំអាងផ្លូវច្បាប់) និងចំនួនទំព័រសម្រាប់សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី(ដោយពុំគិតបញ្ចូលសំណាង) ត្រូវបានកំណត់ត្រឹម ៨០ ទំព័រ (និង បន្ថែម ២០ ទំព័រទៀតសម្រាប់លើកពីមូលដ្ឋានសំអាងផ្លូវច្បាប់)[464]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបន្ថែម ២៥ ទំព័រទៀតសម្រាប់សេចក្តីសន្និដ្ឋាននីមួយៗ[465]

---

[462] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ *រឿងក្តី Orić* (ICTY) ជើងទំព័រ ២៥។

[463] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៧។

[464] អនុស្សរណៈជូនដំណឹងអំពីទម្រង់បែបបទសម្រាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (E163/5/4) ទំព័រ ១។

[465] ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារលេខ E1/227.1 ទំព័រ ៥៦។

។ ការកំណត់ទំព័រទាំងនេះ ពុំបានគិតបញ្ចូលនូវកំណត់សម្គាល់ចុងទំព័រ (ឯកសារយោង) ឡើយ[466]។ មានការបញ្ជាក់បន្ថែមលើការស្នើឱ្យភាគីដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរថា ភាគីបានជំទាស់តវ៉ាលើរឿងក្តីរបស់ខ្លួនផ្ទាល់មាត់ក្នុងអំឡុងពេលនៃការជំនុំជម្រះ ហើយអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ពេលបីថ្ងៃឱ្យសហព្រះរាជអាជ្ញា មួយថ្ងៃឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងពីរថ្ងៃឱ្យក្រុមមេធាវីការពារក្តីនីមួយៗ នៅមុនការធ្វើសេចក្តីសន្និដ្ឋានតប ហើយចុងក្រោយ ក្រុមមេធាវីការពារក្តី និង/ឬ នួន ជា និង ខៀវ សំផន មានឱកាសធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ[467]។

១៩១.ផ្អែកលើប្រវត្តិនីតិវិធី អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ នួន ជា[468] និង ខៀវ សំផន[469] ដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកម្រិតពេលវេលាមិនគ្រប់គ្រាន់សម្រាប់ភាគី ក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោយឡើយ។

១៩២.ទាក់ទងទៅនឹងការកំណត់ពេលវេលា សម្រាប់ការដាក់សារណាជាលាយលក្ខណ៍អក្សរបញ្ចប់កិច្ចពិភាក្សាដេញដោល[470] អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តពុំសមហេតុផលនោះឡើយ ដោយសារដូចបានកំណត់នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[471] បញ្ហានៃការទទួលយកភស្តុតាងដែលជាឯកសារ គឺជាកម្មវត្ថុនៃការដាក់សារណា សវនាការ និងសេចក្តីសម្រេចតៗគ្នាចាប់តាំងពីពេលចាប់ផ្តើមការជំនុំជម្រះរហូតមក។ ខៀវ សំផន ត្រូវបានរំពឹងឱ្យត្រៀមរៀបចំមធ្យោបាយការពារខ្លួនរួមទាំងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនផងដែរ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងជាឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយពុំគិតពីបញ្ហា ថាតើការសម្រេចស្តីពីភាពអាចទទួលយកបាននូវភស្តុតាងនោះ ត្រូវបានចេញនៅពេលណានោះឡើយ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះ

---

[466] អនុស្សរណៈស្តីពីកាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗ (E288/1/1) កថាខណ្ឌ ១០។

[467] អនុស្សរណៈស្តីពីកាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗ (E288/1/1) កថាខណ្ឌ ១២។

[468] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១០៧ ដល់ ១០៩។

[469] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣។

[470] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២០។

[471] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣ *ជាអាទិ៍*។

តុលាការកំពូលកត់សម្គាល់ ដោយស្របជាមួយនឹងសាលដីការបស់តុលាការកំពូលនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិរបស់ប្រទេសរវ៉ាន់ដា (ICTR) *ក្នុងរឿងក្តី Kanyarukiga*[472] និងសាលដីការបស់តុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) *ក្នុងរឿងក្តី Bemba*[473]បង្ហាញថា ការរក្សាទុកសិទ្ធិក្នុងការសម្រេចពីភាពអាចទទួលយកបាននូវភស្តុតាងរហូតដល់ចុងបញ្ចប់នៃការជំនុំជម្រះ ពុំបានផ្ទុយទៅនឹងលក្ខខណ្ឌស្តីពីភាពត្រឹមត្រូវនៃការជំនុំជម្រះឡើយ។ ខៀវ សំផន ពុំបានបង្ហាញឱ្យឃើញថា វិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងយកមកប្រើប្រាស់ពាក់ព័ន្ធទៅនឹងបញ្ហានេះ មានលក្ខណៈពុំសមស្របនោះឡើយ។

## ៤.ខ.២.ឃ.លំដាប់លំដោយនៃនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង

១៩៣.ខៀវ សំផន លើកឡើងថា លំដាប់លំដោយនៃនីតិវិធីមួយចំនួនដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់នៅពេលជំនុំជម្រះ បានរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានមធ្យោបាយការពារខ្លួនប្រកបដោយប្រសិទ្ធិភាព។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការដោះស្រាយដូចតទៅ ទីមួយ ខៀវ សំផន បានអះអាងថា ប្រធានអង្គជំនុំជម្រះបានធ្វើអន្តរាគមញឹកញាប់ពេក និងពុំសមហេតុផលក្នុងអំឡុងពេលនៃការសួរសាក្សី និងថា អង្គជំនុំជម្រះសាលាដំបូង ជារឿយៗបានរារាំងចំពោះការលើកឡើងរបស់ភាគីការពារក្តី[474]។ ទោះជាយ៉ាងណាក្តី ក្រៅតែពីការយោងទៅលើប្រតិចារឹកជាច្រើននៃសវនាការយកមកធ្វើជាឧទាហរណ៍ ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រតាមរយៈការពន្យល់ថាតើ ការអន្តរាគមន៍របស់ប្រធានអង្គជំនុំជម្រះសាលាដំបូង បានប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទយ៉ាងដូចម្តេចនោះទេ។ ដោយសារពុំមានការផ្តល់មូលដ្ឋានគាំទ្រ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានផលប៉ះពាល់ណាមួយឡើយ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ដោះស្រាយលើការអះអាងនេះបន្តទៀតឡើយ។

១៩៤.យោងតាមសំអាងហេតុដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងទូទៅរបស់ខៀវ សំផន[475] ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានប្រើប្រាស់នូវអ្វីដែលគេយល់ឃើញថា

---

[472] សាលដីកា*រឿងក្តី Kanyarukiga* (ICTR) កថាខណ្ឌ ៥២ ដល់ ៥៣។ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសាលដីកានេះនៅក្នុងសាលក្រមរបស់ខ្លួន កថាខណ្ឌ ៦៥ ជើងទំព័រ ១៦១។

[473] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង III *រឿងក្តី Bemba* (ICC) កថាខណ្ឌ ៣៦ ដល់ ៣៧។

[474] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១ ដល់ ៣២។

[475] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៥។

ជាវិធាននៃនីតិវិធីតាមអំពើចិត្ត និងមិនស្របគ្នា។ ដោយសារពុំបានផ្តល់មូលដ្ឋានគាំទ្រច្បាស់លាស់ ក្រៅតែពីការលើកឡើងនូវបញ្ហាការប្រើប្រាស់ឯកសារក្នុងអំឡុងពេលសួរសាក្សី ដែលបានពិភាក្សា*ខាងដើម*ក្នុងសាលដីកានេះ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពុំអាចដោះស្រាយអំណះអំណាងនេះបានឡើយ។

១៩៥.ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ខ្លួនមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតឱ្យដាក់ការឆ្លើយតបទៅនឹងសារណាតប គឺជាការរំលោភបំពានលើមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. ដែលចែងអំពីការដាក់ការឆ្លើយតបតែនៅក្នុងកាលៈទេសៈមួយចំនួននោះ[476] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា គោលបំណងនៃសេចក្តីណែនាំអនុវត្តនេះ គឺដើម្បីសម្រួលដល់ការរៀបចំកិច្ចដំណើរការនីតិវិធីឱ្យបានត្រឹមត្រូវប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី មាត្រា ៨.៤ ត្រូវតែអានផ្គួបជាមួយនឹងមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្តដែលទទួលស្គាល់សិទ្ធិរបស់អង្គជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេច ខុសពីវិធានដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តនេះ។ ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រអំពីបញ្ហា ថាតើវិធីសាស្ត្រដែលអង្គជំនុំជម្រះយកមកប្រើប្រាស់តាំងពីដំបូងនៅក្នុងកិច្ចដំណើរការនីតិវិធីសម្រាប់ឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃរឿងក្តី[477]នោះ មានលក្ខណៈពុំសមហេតុផលយ៉ាងណាឡើយ។

១៩៦.ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា សំណើសុំការពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនៗនោះ ពុំអាចទទួលយកបាននៅចំពោះមុខ អ.វ.ត.ក .[478] ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រចំពោះការលើកឡើងរបស់ខ្លួនឡើយ ដោយបានត្រឹមតែយោងទៅលើសេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញរបស់អង្គបុរេជំនុំជម្រះ ដែលតាមរូបភាពហាក់បីដូចជាស្របជាមួយនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចដែលថា អង្គជំនុំជម្រះអាចពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនរបស់ខ្លួនបាន តែក្នុងករណីដែលមានកាលៈទេសៈប្រែប្រួលប៉ុណ្ណោះ[479]។ ទាក់ទងទៅនឹងអំ

---

[476] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៥ ជើងទំព័រ ៨៥។

[477] *សូមមើល* សេចក្តីណែនាំស្តីពីការដាក់តែមួយភាសា (E64)។ អនុស្សរណៈស្តីពីការឆ្លើយតប (E126)។

[478] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧។

[479] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧ យោងទៅលើសេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ (C22/I/8) និងសាលក្រមរបស់អង្គជំនុំជម្រះ កថាខណ្ឌ ៤២ ដល់ ៤៤ និង ១៣៦ ជើងទំព័រ ៣៩១។ តាមរយៈកថាខណ្ឌទាំងនេះ ទំនងជាបង្ហាញ

ណៈអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅពេលដែលសំអាងទៅលើឯកសារមួយ គឺទូរលេខរបស់ស្ថានទូតអូស្ត្រាលីពាក់ព័ន្ធនឹងទស្សនកិច្ចរបស់ ខៀវ សំផន ទៅកាន់ប្រទេសឡាវ ហើយដែលពីដំបូងអង្គជំនុំជម្រះ បានសម្រេចពុំទទួលយកឯកសារនេះជាភស្តុតាងនោះ[480] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពន្យល់រួចហើយថា ខ្លួនបានសម្រេចទទួលយកជាភស្តុតាង ពីព្រោះ ផ្នែកខ្លះនៃឯកសារនេះមានព័ត៌មានដោះបន្ទុក[481]។ បើទោះបីជា ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឯកសារនេះប្រឆាំងនឹងរូបគាត់ក៏ដោយ[482] ក៏គាត់បានត្រឹមតែយោងទៅលើកថាខណ្ឌ ១៣៨ និង ១៤២ នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ ផ្ទុយទៅវិញក្នុងកថាខណ្ឌនេះនៃសាលក្រមពុំបានយោងទៅលើឯកសារនេះឡើយ។ អាស្រ័យហេតុនេះ ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រច្បាស់លាស់អំពីការប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនឡើយ។

១៩៧.បន្ថែមលើនេះទៀត ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានសិទ្ធិរបស់គាត់ក្នុងការមិនឆ្លើយតបទៅនឹងសំណួរ។ ជាដំបូង គាត់បានពន្យល់ថា អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងពុំត្រឹមត្រូវនូវបញ្ហាទាក់ទងទៅនឹងសិទ្ធិមិនឆ្លើយតបទៅនឹងសំណួរ នៅក្នុងសាលក្រមត្រង់ចំណុចស្តីពីប្រវត្តិនីតិវិធី[483]។ ជាពិសេស ខៀវ សំផន ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងជាញឹកញាប់បានឱ្យគាត់បញ្ចេញយោបល់ទៅលើបញ្ហានានា ទោះបីជាគាត់បានបញ្ជាក់ច្បាស់ថា គាត់សម្រេចប្រើប្រាស់សិទ្ធិរបស់គាត់មិនឆ្លើយតបទៅនឹងសំណួររួចហើយក៏ដោយ[484]។ ខៀវ សំផន បានយោងជាពិសេសទៅលើប្រតិចារឹកសវនាការ នៅក្នុងអំឡុងពេលដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យគាត់បញ្ចេញយោបល់លើឯកសារ ឬឆ្លើយតបទៅនឹងសំណួរ ដែលបានសួរដោយដើមបណ្តឹងរដ្ឋប្បវេណី[485]។ ទោះជាយ៉ាងណាក្តី ខៀវ សំផន ពុំបានពន្យល់ពីមូលហេតុ ថាតើមានកំហុសដូចម្តេចទាក់ទងទៅនឹងបញ្ហានេះ និងថាតើ គាត់ទទួលរងផលប៉ះពាល់

---

ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងជាទូទៅធ្វើការពិចារណាឡើងវិញតែក្នុងករណីដែលមានការកែប្រែប៉ុណ្ណោះ ប៉ុន្តែថា ខ្លួនមានឆន្ទានុសិទ្ធិធ្វើដូច្នោះក្នុងកាលៈទេសៈដទៃទៀតដែលគ្មានការកែប្រែផងដែរ។

[480] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧។

[481] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៦ ជើងទំព័រ ៣៩១។

[482] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧ ជើងទំព័រ ៩២។

[483] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩។

[484] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩។

[485] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩ ជើងទំព័រ ៩៨។

បែបណានោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ពុំមានអ្វីដែលអាចបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានដាក់សម្ពាធលើ ខៀវ សំផន ដែលត្រូវបានការពារស្របច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល ឱ្យលះបង់សិទ្ធមិនឆ្លើយនឹងសំណួរនោះឡើយ ប៉ុន្តែអង្គជំនុំជម្រះគ្រាន់តែអញ្ជើញ ខៀវ សំផន ឱ្យបញ្ចេញយោបល់លើបញ្ហាមួយចំនួននៅក្នុងអំឡុងពេលនៃការជំនុំជម្រះដ៏វែងអន្លាយនេះតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

១៩៨.ខៀវ សំផន ក៏បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភអំណាចរបស់ខ្លួន ដោយបានបង្ខំឱ្យគាត់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងកាលៈទេសៈ ដែលគាត់បានលះបង់សិទ្ធិចូលរួមសវនាការ[486]។ ដើម្បីគាំទ្រលើអំណះអំណាងនេះ ខៀវ សំផន បានរៀបរាប់នូវសេចក្តីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង និងបានយោងសេចក្តីសម្រេចចំនួនពីររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ICTY)។ អង្គជំនុំជម្រះតុលាការកំពូលយល់ច្បាស់ថា ខៀវ សំផន បកស្រាយសិទ្ធិចូលរួមសវនាការក្នុងន័យថា ជនជាប់ចោទអាចជ្រើសរើសការចូលរួម ឬក៏មិនចូលរួមសវនាការបាន។ ការបកស្រាយបែបនេះពុំត្រឹមត្រូវឡើយ។ សិទ្ធិចូលរួមសវនាការ តាមអត្ថន័យនៃមាត្រា ១៤(៣-ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលបានកំណត់នៅក្នុងមាត្រា ៣៥ ថ្មី(ឃ) នៃច្បាប់ អ.វ.ត.ក. មានអត្ថន័យជាទូទៅថា តុលាការពុំអាចដំណើរការដោយមិនមានវត្តមានជនជាប់ចោទឡើយ[487]។ ទោះជាយ៉ាងណាក្តី ជាផលវិបាកមាត្រានេះពុំផ្តល់សិទ្ធិដល់ជនជាប់ចោទនូវសិទ្ធិមិនចូលរួមក្នុងការជំនុំជម្រះដោយសេរីឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងជាពិសេសថា ជនជាប់ចោទមានកាតព្វកិច្ចចូលរួមសវនាការ ហើយលើសពីនេះទៀត បានផ្តល់សិទ្ធិអំណាចដល់តុលាការក្នុងការបង្ខំឱ្យជនជាប់ចោទមានវត្តមានក្នុងករណីដែលខ្លួនគិតថា សមស្រប[488]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះចោល។

---

[486] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤០។

[487] ទោះជាយ៉ាងណាក្តី កត់សម្គាល់ថា យោងតាមមាត្រា ៣៦១ និង ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា បើទោះបីជាជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការក៏ដោយ ក៏តុលាការនៅតែអាចចេញសាលក្រមបានដែរ។

[488] *សូមមើល* មាត្រា ៣០០(១) និងមាត្រា ៣០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

## ៤.ខ.៣.សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុពេញលេញ

១៩៩.នួន ជា[489] និង ខៀវ សំផន[490] បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភសិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានសេចក្ដីសម្រេចដោយមានសំអាងហេតុ ដោយហេតុថា អង្គជំនុំជម្រះពុំបានផ្ដល់ ឬបានផ្ដល់សំអាងហេតុពុំគ្រប់គ្រាន់សម្រាប់សេចក្ដីសម្រេចសំខាន់ៗ ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ ។ ទាក់ទងទៅនឹងបញ្ហានេះ ខៀវ សំផន បានយោងនៅក្នុងមូលដ្ឋានសំអាងផ្លូវច្បាប់នៃសារណាបណ្ដឹងសាទុក្ខរបស់ខ្លួននូវបញ្ជីនៃសេចក្ដីសម្រេចចំនួន ៦០ ដីកាសម្រេច អនុស្សរណៈនានារបស់អង្គជំនុំជម្រះ និងរបាយការណ៍ចំនួនមួយរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ[491]។ ខៀវ សំផន បានអះអាងនៅក្នុងជើងទំព័រនៃសារណាបណ្ដឹងសាទុក្ខថា គាត់កំពុងដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចទាំងអស់នៅក្នុងមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប៉ះពាល់ដល់សិទ្ធិរបស់គាត់[492]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការអះអាងខាងលើនេះពុំបានបំពេញទៅតាមលក្ខខណ្ឌនៃការផ្ដល់មូលដ្ឋានគាំទ្រទេ[493] ហេតុនេះ អង្គជំនុំជម្រះពុំធ្វើការវាយតម្លៃលើអំណះអំណាងនេះតទៅទៀតឡើយ។

២០០.នួន ជា បានអះអាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា អង្គជំនុំជម្រះពុំបានផ្ដល់សំអាងហេតុពេញលេញនៅក្នុងសេចក្ដីសម្រេចដែលបានធ្វើឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី[494]។ នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន នួន ជា បានអះអាងឡើងវិញថា ជាប្រព័ន្ធអង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដល់នូវសំអាងហេតុពេញលេញនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយលើ“អំណះអំណាងយ៉ាងលម្អិត” ដែលមានក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ (E295/6/3) ដែលបានលើកបង្ហាញពីកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង[495]។ នួន ជា បានអះអាងជាពិសេសថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបង្ហាញនៅក្នុងជើងទំព័រចំនួនពីរនៅក្នុងសាល

---

[489] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១០ ដល់ ១១១។

[490] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៤។

[491] តារាងសំអាងផ្លូវច្បាប់នៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (F17.1) ទំព័រ ៧ ដល់ ១១ (ភាសាបារាំង)។

[492] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៤ ជើងទំព័រ ៨២។

[493] *សូមមើលខាងលើ* កថាខណ្ឌ ១០១។

[494] សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា (E295/6/3) កថាខណ្ឌ ៨៩ ដល់ ៩០។

[495] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១០ ជើងទំព័រ ២៥៧ យោងទៅលើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា (E295/6/3) កថាខណ្ឌ ៨៩ ដល់ ៩០។

ក្រមរបស់អង្គជំនុំជម្រះដែលថា អំណះអំណាងរបស់គាត់មានលក្ខណៈទូទៅពេក និងពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់[496]។ នួន ជា បានចង្អុលបង្ហាញថា នៅក្នុងជើងទំព័រនៃកថាខណ្ឌពាក់ព័ន្ធក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (E295/6/3) មានការយោងទៅលើកថាខណ្ឌដទៃទៀត ដោយមានការលើកឡើងនូវអំណះអំណាងបន្ថែម[497]។ អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់លើការអះអាងនេះឡើយ។ បើទោះបីជា ជើងទំព័រដែលបានលើកឡើងនោះ មានការយោងទៅលើផ្នែកដទៃទៀតនៃសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (E295/6/3) ពិតប្រាកដក៏ដោយ ក៏កថាខណ្ឌដែលបានយោងទៅលើនោះពុំបានដោះស្រាយនូវបញ្ហាកង្វះសំអាងហេតុ និងថាតើអង្គសេចក្ដីនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រឹមត្រូវ ដែរ ឬយ៉ាងណានោះទេ។ ហេតុនេះ ក្រៅតែពីការលើកជាទូទៅនៅក្នុងសេចក្ដីសន្និដ្ឋានអំពីកង្វះសំអាងហេតុនោះ អំណះអំណាងនេះពុំបានផ្ដល់មូលដ្ឋានគាំទ្រគ្រប់គ្រាន់ឡើយ។ អាស្រ័យហេតុនេះ ការសម្រេចបដិសេធការចោទប្រកាន់របស់ នួន ជា អំពីកង្វះសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ពុំអាចចាត់ទុកថាមានកំហុសឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឱ្យពិចារណាលើកង្វះសំអាងហេតុនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ ដោយសារ នួន ជា ពុំបានចង្អុលបង្ហាញជាក់លាក់ទាក់ទងទៅនឹងបញ្ហាថាតើសេចក្ដីសម្រេចនោះខ្វះសំអាងហេតុអ្វីខ្លះនោះឡើយ។

២០១.នួន ជា បានលើកឡើងផងដែរថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ ក៏ពុំមានសំអាងហេតុគ្រប់គ្រាន់ដែរ។ នៅក្នុងសារណាបណ្ដឹងសាទុក្ខ នួន ជា បានចង្អុលបង្ហាញឱ្យអង្គជំនុំជម្រះតុលាការកំពូលពិនិត្យលើ“សារណាលម្អិតមួយចំនួនរបស់មេធាវីការពារក្ដី ស្ដីពីបញ្ហាគន្លឹះនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ”ដែលតាមការលើកឡើងរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើបញ្ហាគន្លឹះនេះឡើយ[498]។

២០២.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា តាមវិធាន ៩៨ នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេច ព្រមទាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវតែមានសំអាងហេតុគ្រប់គ្រាន់ដែលជាធាតុផ្សំដ៏សំខាន់នៃ

---

[496] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១០ ជើងទំព័រ ២៥៨ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១១១ ដល់ ១៤៧។

[497] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១០ យោងទៅលើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា (E295/6/3) ជើងទំព័រ ២០៨ ដល់ ២១១។

[498] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១១។

01358048



ការជំនុំជម្រះដោយត្រឹមត្រូវ។ ចំណុចនេះបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈអត្ថបទច្បាប់របស់តុលាការដែលថា វិធាន ១០១(១) នៃវិធានផ្ទៃក្នុងចែងជាពិសេសថា សាលក្រមត្រូវតែមាន*ក្នុងចំណោមនោះ* "...មូលហេតុខាងអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេច"។ វិធាន ១០១(៤) នៃវិធានផ្ទៃក្នុងចែងថា "ផ្នែកសំអាងហេតុនៅក្នុងសាលក្រម ត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលបានធ្វើឡើងដោយភាគីទាំងអស់"។

២០៣.លក្ខខណ្ឌតម្រូវក្នុងការផ្តល់សំអាងហេតុឱ្យបានគ្រប់គ្រាន់នៅក្នុងសេចក្តីសម្រេច ត្រូវបានគាំទ្រដោយយុត្តិសាស្ត្រអន្តរជាតិ។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) *រឿងក្តី Hadjianastassiou ទល់នឹងប្រទេសក្រិច* បានអះអាងថា តុលាការត្រូវតែ"បញ្ជាក់ឱ្យបានច្បាស់លាស់នូវមូលដ្ឋានដែលខ្លួនបានផ្អែកទៅលើនៅក្នុងសេចក្តីសម្រេច" ដើម្បីគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវដែលធានាដោយមាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR) ដែល"បានផ្តល់លទ្ធភាពដល់ជនជាប់ចោទក្នុងការប្រើប្រាស់នូវសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ដែលជាប្រយោជន៍របស់ខ្លួន"[499]។ នៅក្នុងសេចក្តីសម្រេចក្រោយមកទៀត អង្គជំនុំជម្រះជាន់ខ្ពស់របស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានពន្យល់ថា បើទោះបីជា"តុលាការពុំត្រូវបានតម្រូវឱ្យផ្តល់ចម្លើយពិស្តារទៅលើរាល់អំណះអំណាងនីមួយៗដែលបានលើកឡើងក៏ដោយ[...] ក៏ត្រូវបង្ហាញឱ្យច្បាស់ថា តាមរយៈសេចក្តីសម្រេចនោះ បញ្ហាសំខាន់ៗនៃរឿងក្តី*ត្រូវបានដោះស្រាយ*"(សេចក្តីបញ្ជាក់បន្ថែម)[500]។

២០៤.អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានអះអាងនៅក្នុងបរិបទនៃសេចក្តីសម្រេចដែលពុំអនុញ្ញាតឱ្យមានការបង្ហាញព័ត៌មានដល់ភាគីការពារក្តី និងនៅក្នុងសេចក្តីយោងទៅលើរឿងក្តីដែលបានដកស្រង់ពីតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ខាងលើថា៖

> សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលអនុញ្ញាតឱ្យលាក់អត្តសញ្ញាណសាក្សីរបស់អយ្យការចំពោះភាគីការពារក្តី ត្រូវតែបានគាំទ្រដោយសំអាងហេតុពេញលេញ។ វិសាលភាពនៃសំអាងហេតុគឺអាស្រ័យលើកាលៈទេសៈនៃរឿងក្តី ប៉ុន្តែ ជាការចាំបាច់ដែលត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់នូវមូលដ្ឋាននៃសេចក្តីសម្រេចនេះ។ សំអាងហេតុនេះ ពុំតម្រូវជាចាំបាច់លើកមកបញ្ជាក់ម្តងមួយៗនូវរាល់ចំណុច ដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ ប៉ុន្តែសំអាងហេតុនេះ ត្រូវបញ្ជាក់ថា

---

[499] សាលក្រម *រឿងក្តី Hadjianastassiou ទល់នឹងប្រទេសក្រិច* (ECtHR) កថាខណ្ឌ ៣៣។

[500] សាលដីការបស់អង្គជំនុំជម្រះជាន់ខ្ពស់ *រឿងក្តី Taxquet ទល់នឹងប្រទេសបែលហ្ស៊ិក* (ECtHR) កថាខណ្ឌ ៩១។ *សូមមើលផងដែរ* សាលក្រម *រឿងក្តី Affaire Boldea c. Roumanie* (ECtHR) កថាខណ្ឌ ៣០។

តើ អង្គហេតុណាខ្លះដែលមានការជាប់ពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសន្និដ្ឋាន[501]។

២០៥.ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់ថា សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុគ្រប់គ្រាន់ គឺជាធាតុផ្សំនៃសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងថា ការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខអាចធ្វើទៅបានដោយសមស្រប មានតែផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចដែលមានសំអាងហេតុគ្រប់គ្រាន់ប៉ុណ្ណោះ[502]។ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY ក៏បានបញ្ជាក់ផងដែរថា "ជាអប្បបរមា អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់មូលដ្ឋានដើម្បីគាំទ្រដល់ការយល់ឃើញទាក់ទងទៅនឹងការពិចារណាលើអង្គសេចក្តីដែលពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់ខ្លួន"[503]។

២០៦.ពិសេសជាងនេះទៅទៀត ពាក់ព័ន្ធទៅនឹងភាពចាំបាច់ ក្នុងការផ្តល់សំអាងហេតុទាក់ទងនឹងការវាយតម្លៃភស្តុតាង អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានបកស្រាយថា៖

> វាជាបញ្ហាចម្បងសម្រាប់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវកំណត់ ថាតើសាក្សីណាមួយអាចជឿទុកចិត្តបាន ដែរ ឬយ៉ាងណា និងត្រូវសម្រេច ថាតើសក្ខីកម្មរបស់សាក្សីណាខ្លះ ដែលខ្លួនបានជឿជាក់ ដោយពុំចាំបាច់បង្ហាញច្បាស់លាស់នូវរាល់ជំហានទីមួយៗនៃការផ្តល់សំអាងហេតុ ដើម្បីឈានដល់ការសម្រេចលើចំណុចទាំងនេះឡើយ។ ទោះជាយ៉ាងណាក្តី ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង គឺ

---

[501] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I *រឿងក្តី Lubanga* (ICC) កថាខណ្ឌ ២០។

[502] សាលដីកា *រឿងក្តី Nikolić* (ICTY) កថាខណ្ឌ ៩៦ "មានតែការផ្តល់សំអាងហេតុគ្រប់គ្រាន់ដែលជាធាតុផ្សំមួយនៃលក្ខខណ្ឌតម្រូវក្នុងការជំនុំជម្រះដោយយុត្តិធម៌ ដូចមានចែងក្នុងមាត្រា ២០ និង ២១ នៃលក្ខន្តិកៈប៉ុណ្ណោះ ដែលអាចឱ្យអង្គជំនុំជម្រះតុលាការកំពូលបំពេញតួនាទីរបស់ខ្លួនស្របតាមមាត្រា ២៥ នៃលក្ខន្តិកៈក្នុងពិចារណា និងពិនិត្យលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបាន"។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី Furundžija* (ICTY) កថាខណ្ឌ ៦៨ ដល់ ៦៩ ដែលក្នុងនោះអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកំណត់ថា មាត្រា ២៣ នៃលក្ខន្តិកៈបានផ្តល់សិទ្ធិដល់ជនជាប់ចោទក្នុងការទទួលបានសេចក្តីសម្រេចមានសំអាងហេតុដែលជាធាតុផ្សំនៃលក្ខខណ្ឌតម្រូវក្នុងការជំនុំជម្រះដោយត្រឹមត្រូវ "ដូចមានចែងនៅក្នុងមាត្រា ២០ និង ២១ នៃលក្ខន្តិកៈ" និង *សូមមើល* សាលដីកា *រឿងក្តី Kunarac* (ICTY) កថាខណ្ឌ ៤១ "អនុលោមតាមមាត្រា ២៣(២) នៃលក្ខន្តិកៈកំណត់ថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ […] ធាតុផ្សំនេះធ្វើឱ្យការប្រើប្រាស់សិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខរបស់ជនដែលត្រូវបានសម្រេចដាក់ពិរុទ្ធកាន់តែមានប្រយោជន៍។ បន្ថែមលើនេះទៀត មានតែការផ្តល់សំអាងហេតុគ្រប់គ្រាន់ប៉ុណ្ណោះដែលអាចឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាបាន និងពិនិត្យលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងរួមទាំងការវាយតម្លៃលើភស្តុតាងផងដែរ"។

[503] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ *រឿងក្តី Milutinović* (ICTY) កថាខណ្ឌ ១១។

ស្ថិតក្រោមកាតព្វកិច្ចក្នុងការចេញសេចក្តីសម្រេចដោយមានសំអាងហេតុ[504]។

២០៧.យោងតាមការលើកឡើងខាងលើដែលថា ការតម្រូវឱ្យមានសំអាងហេតុដើម្បីធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ជានិច្ចកាល អាស្រ័យទៅលើកាលៈទេសៈជាក់លាក់នៃរឿងក្តី។ ការលើកឡើងបែបនេះពុំមែនមានន័យថា អង្គជំនុំជម្រះត្រូវតែផ្តល់ជាស្វ័យប្រវត្តិនូវសំអាងហេតុចំពោះអំណះអំណាងនីមួយៗ ដែលភាគីបានលើកឡើងនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ និងថា ការពុំបានអនុវត្តដូច្នោះ បានរំលោភបំពានជាស្វ័យប្រវត្តិទៅលើសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចមួយដោយមានសំអាងហេតុនោះឡើយ[505]។ អ្វីដែលសំខាន់នោះគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃលើភស្តុតាង និងធ្វើសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុ និងអង្គច្បាប់ អាចយល់បានដល់កម្រិតណា។

២០៨.គប្បីកត់សម្គាល់ផងដែរថា យុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ដែលបានដកស្រង់ខាងលើ អាចវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃសំអាងហេតុរបស់តុលាការត្រង់ចំណុចណាមួយបានដរាបណាកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបញ្ចប់រួចរាល់ទាំងស្រុង។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ជាទូទៅផ្តល់ការយល់ឃើញទាក់ទងទៅនឹងភាពត្រឹមត្រូវនៃការជំនុំជម្រះដោយផ្អែកលើកិច្ចដំណើរនីតិវិធីទាំងមូល។ ផ្ទុយទៅវិញ កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនេះកំពុងបន្តនៅឡើយ ហេតុនេះហើយការខ្វះចន្លោះនៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង អាចដោះស្រាយបាន និងអាចជៀសវាងការរំលោភបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សំអាងហេតុដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូង គឺជាចំណុចចាប់ផ្តើមសម្រាប់ការវិភាគទាក់ទងទៅនឹងបញ្ហា ថាតើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងសមហេតុផល ដែរ ឬយ៉ាងណា[506]។ ហេតុដូច្នេះ ជាជាងការឈានទៅធ្វើសេចក្តីសន្និដ្ឋានថា ការជំនុំជម្រះទាំងមូល

---

[504] សាលដីកា *រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៣២។ អង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់ចំណុចនេះនៃសាលដីកាដោយស្របជាមួយនឹងសាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១៧។

[505] *សូមមើលឧ.* សាលក្រម *រឿងក្តី Van de Hurk ទល់នឹងប្រទេសហូឡង់* (ECtHR) កថាខណ្ឌ ៦១ "មាត្រា ៦ កថាខណ្ឌ ១ [នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស]បានតម្រូវឱ្យតុលាការផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួន ប៉ុន្តែពុំចាំបាច់តម្រូវឱ្យមានព័ត៌មានពិស្តារចំពោះរាល់អំណះអំណាងនោះឡើយ"។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់ *រឿងក្តី García Ruiz ទល់នឹងប្រទេសអេស្ប៉ាញ* (ECtHR) កថាខណ្ឌ ២៦។ សាលក្រម *រឿងក្តី Helle ទល់នឹងប្រទេស Finland* (ECtHR) កថាខណ្ឌ ៥៥។

[506] *សូមមើលខាងលើ* កថាខណ្ឌ ៩០។

ពុំត្រឹមត្រូវនោះ ការផ្តល់សំអាងហេតុពុំគ្រប់គ្រាន់ទាក់ទងទៅនឹងការយល់ឃើញនានាផ្នែកអង្គហេតុ អាចធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានបានថា ការយល់ឃើញផ្នែកអង្គហេតុដែលពាក់ព័ន្ធនេះបានធ្វើឡើងដោយពុំសមហេតុផល និងនាំឱ្យមានកំហុស។

២០៩.ទាក់ទងទៅនឹងការអះអាងជាក់លាក់មួយ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើអំណះអំណាងរបស់គាត់ទាក់ទងទៅនឹងសក្ខីកម្មរបស់ Stephen HEDER អំពីការកំណត់គោលដៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរនៅខេត្តកំពង់ចាមក្នុងឆ្នាំ ១៩៧៣ សក្ខីកម្មរបស់ Philip SHORT អំពីការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅឧដុង្គក្នុងឆ្នាំ ១៩៧៤ ចម្លើយរបស់ ភី ភួន ហេង សំរិន និង អ៊ុក ប៊ុនឈឿន អំពីអត្ថិភាពនៃគោលនយោបាយក្នុងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ សក្ខីកម្មរបស់ ឈូក រិន ទាក់ទងទៅនឹងការស្អប់“អ្នកទីក្រុង” អំណាចរបស់មេដឹកនាំភូមិភាគនានានៅក្នុងបក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធបញ្ជានៅក្នុងទីក្រុងភ្នំពេញក្រោយពេលដួលរលំ និង“ភាពខុសគ្នារវាងទ្រឹស្តីស្តីពីវណ្ណៈដែលបានពន្យល់នៅក្នុងឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងចេតនាប្រព្រឹត្តអំពើឧក្រិដ្ឋនានា”[507]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បើទោះបីជាការពិតដែលថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើអំណះអំណាងរបស់ នួន ជា ជាពិសេសក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ពីវិធីសាស្ត្ររបស់ខ្លួនពាក់ព័ន្ធទៅនឹងការយល់ឃើញនីមួយៗ ដោយលើកភស្តុតាងដែលបានយកមកធ្វើជាមូលដ្ឋានសំអាង[508]។ បញ្ហា ថាតើការយល់ឃើញណាមួយក្នុងចំណោមនោះមានកំហុស ដូចការអះអាង

---

[507] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១១។

[508] ទាក់ទងទៅនឹងការកំណត់គោលដៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរនៅក្នុងខេត្តកំពង់ចាមក្នុងឆ្នាំ ១៩៧៤ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣០ ជើងទំព័រ ២៦២០។ ទាក់ទងទៅនឹងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅឧដុង្គ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៤ ដល់ ១២៧ និង ៨៣០។ ទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២០ ដល់ ១២៧ និង ៨៣០ ដល់ ៨៣៤។ ទាក់ទងទៅនឹងសក្ខីកម្មរបស់ ឈូក រិន ស្តីពី“ប្រជាជនថ្មី” *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៧។ ទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់ ប.ក.ក. និងអំណាចរបស់មេដឹកនាំភូមិភាគ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៩ ដល់ ២២៨។ ទាក់ទងទៅនឹងរចនាសម្ព័ន្ធការបញ្ជាក្នុងទីក្រុងភ្នំពេញបន្ទាប់ពីការដួលរលំ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២៤០។ “ការខុសប្លែកគ្នារវាងទ្រឹស្តីវណ្ណៈដែលមាននៅក្នុងការផ្សព្វផ្សាយរបស់ ប.ក.ក. និងចេតនាប្រព្រឹត្តអំពើឧក្រិដ្ឋ” *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១១១ ពុំត្រូវបានពិភាក្សាបែបនេះនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបាន

របស់ នួន ជា នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ដែរ ឬយ៉ាងណា[509] នឹងត្រូវដោះស្រាយនៅផ្នែកខាងក្រោម។

## ៤.ខ.៤.សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទ/វិសាលភាពនៃការជំនុំជម្រះ

២១០.នួន ជា និង ខៀវ សំផន បានលើកអំណះអំណាងមួយចំនួនដែលទាក់ទងទៅនឹងសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទលើពួកគាត់ យុត្តាធិការពេលវេលារបស់ អ.វ.ត.ក. និងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងទាំងនេះដែលមានលក្ខណៈទូទៅនៅក្នុងផ្នែកនេះ ហើយទន្ទឹមនឹងនេះអង្គជំនុំជម្រះនឹងដោះស្រាយអំណះអំណាងពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មជាក់លាក់ ឬទម្រង់នៃការទទួលខុសត្រូវនៅក្នុងផ្នែកនីមួយនៃសាលដីកានេះ[510]។

## ៤.ខ.៤.ក.យុត្តាធិការពេលវេលា

២១១. ផ្អែកតាមការយោងជាពិសេសទៅលើសាលដីកា*រឿងក្ដី Nahimana* (ICTR)[511] នួន ជា និង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសដែនកំណត់យុត្តាធិការពេលវេលា ដោយសារទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ អង្គជំនុំជម្រះបានផ្អែកយ៉ាងពិសេសទៅលើអង្គហេតុ និងអំពើប្រព្រឹត្តដែលបានកើតឡើងមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[512]។

២១២.សហព្រះរាជអាជ្ញាបានឆ្លើយតបថា បទប្បញ្ញត្តិទាក់ទងទៅនឹងយុត្តាធិការពេលវេលាបានកម្រិត អ.វ.ត.

---

ពិចារណា និងវាយតម្លៃលើឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. និងជាញឹកញាប់បានផ្ដល់ការយល់ឃើញរបស់ខ្លួនអំពីបញ្ហានេះនៅក្នុងសាលក្រម។

[509] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៤៨ (ទាក់ទងទៅនឹងសក្ខីកម្មរបស់ Stephen Heder ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅកំពង់ចាម) កថាខណ្ឌ ៥៣០ ដល់ ៥៣៣ (ទាក់ទងទៅនឹងសក្ខីកម្មរបស់ Philip Short ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅឧដុង្គ) កថាខណ្ឌ ៣៧៦ (ទាក់ទងទៅនឹងសក្ខីកម្មរបស់ ឈូក រិន ស្ដីពីអ្នកទីក្រុង) កថាខណ្ឌ ៥៦៩ ដល់ ៥៧១ (ទាក់ទងទៅនឹងភស្តុតាងរបស់ ហេង សំរិន និង អ៊ុក ប៊ុនឈឿន)។

[510] *សូមមើលខាងក្រោម* កថាខណ្ឌ ៦៣៦, ៧៤១, ៨២៨, ៩៩៩, ១០២៨។

[511] សាលដីកា *រឿងក្ដី Nahimana* (ICTR)។

[512] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២៧ ដល់ ៦៣៥ និង ៦៦៣។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩ និង*សូមមើលផងដែរ* កថាខណ្ឌ ២៣១។

ក. យ៉ាងជាក់ច្បាស់ត្រឹមអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម។ យោងតាមហេតុផលនេះ បទប្បញ្ញត្តិនេះពុំអាចបកស្រាយដូចគ្នាទៅនឹងបទប្បញ្ញត្តិរបស់តុលាការ ICTR ស្តីពីយុត្តាធិការពេលវេលា ដែលបានរួមបញ្ចូលអំឡុងពេលនៅមុនការចាប់ផ្តើមប្រព្រឹត្តជាក់ស្តែងនៃអំពើប្រល័យពូជសាសន៍ ដើម្បីគ្របដណ្តប់លើការរៀបចំផែនការ និងការត្រៀមរៀបចំឧក្រិដ្ឋកម្មឡើយ[513]។

២១៣.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ច្បាប់ អ.វ.ត.ក បានផ្តល់យុត្តាធិការឱ្យ អ.វ.ក.ត. ក្នុងការជំនុំជម្រះឧក្រិដ្ឋកម្ម"ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលចន្លោះពីថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"[514]។ បទប្បញ្ញត្តិនេះបង្ហាញច្បាស់លាស់ថា អ.វ.ត.ក. ពុំមានយុត្តាធិការពេលវេលាគ្រប់គ្រាន់លើអំពើ*សត្យានុម័ត*នៃបទឧក្រិដ្ឋមួយ(*ខ.*ការធ្វើមនុស្សឃាត) ដែលត្រូវបានប្រព្រឹត្តឡើងក្រៅអំឡុងពេលនេះ។ ទោះជាយ៉ាងណាក្តី អ្វីដែលត្រូវកំណត់ គឺថាតើអំពើប្រព្រឹត្តដែលបង្កើតបានជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈប្រាកដជាបានកើតឡើងនៅក្នុងអំឡុងពេលនោះ ដែរ ឬយ៉ាងណា ក្នុងករណីដែលជនជាប់ចោទពុំបានប្រព្រឹត្តអំពើ*សត្យានុម័ត*ដោយផ្ទាល់នោះ។

២១៤.នេះគឺបញ្ហាមួយដែលចាំបាច់ត្រូវពិចារណា ដំបូងដោយផ្អែកលើមូលដ្ឋានច្បាប់សារធាតុ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ត្រូវបានបង្ហាញជាចម្បងដោយផ្អែកលើការរួមចំណែកក្នុងការអនុវត្តគោលបំណងល្មើសរួម ដែលគ្របដណ្តប់រយៈពេលយ៉ាងយូរ ហើយការរួមចំណែករបស់ជនជាប់ចោទបានកើតឡើងទាំងមុន និងក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[515]។ នៅពេលដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលខ្លួនពុំបានប្រព្រឹត្តដោយផ្ទាល់នោះ អង្គជំនុំជម្រះសាលាដំបូងបានសំអាង*ក្នុងចំណោមនោះ*ទៅលើសកម្មភាពក្នុងកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលនានា សុន្ទរកថា និងសេចក្តីថ្លែងការណ៍ដែលជនជាប់ចោទបានធ្វើឡើងនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[516]។

---

[513] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១១ ដល់ ១១៥។

[514] មាត្រា ២ ថ្មីនៃច្បាប់ អ.វ.ត.ក.។

[515] *សូមមើលខាងក្រោម* កថាខណ្ឌ ៩៨៨ *ជាអាទិ៍*។

[516] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៥, ៨៧០, ៨៧៥ (ក្នុងការកំណត់ថា នួន ជា បានរួមចំណែកក្នុងការអនុវត្តគោលបំណងល្មើសរួម អង្គជំនុំជម្រះសាលាដំបូងបានសំអាង*ក្នុងចំណោមនោះ*លើការចូលរួមរបស់គាត់នៅក្នុងការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងកិច្ចប្រជុំដែលបានធ្វើឡើងនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងដើមខែ មេសា ឆ្នាំ

២១៥.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្នុងករណីដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងរួមគ្នាដោយបុគ្គលដែលចូលរួមក្នុងគោលបំណងល្មើសរួម អំពើប្រព្រឹត្តរបស់អ្នកដែលបង្កើតគោលបំណងល្មើសរួម និងអ្នកដែលរួមចំណែកតាមវិធីសាស្ត្រពាក់ព័ន្ធក្នុងការអនុវត្តគោលបំណងនេះ បង្កើតបានជាបណ្តុំនៃការអនុវត្តផែនការយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកដែលប្រព្រឹត្តអំពើ*សត្យានុម័ត*ដោយផ្ទាល់ ដូច្នេះអ្នកទាំងអស់នេះត្រូវបានចាត់ទុកថាជាសហចារី ដែលជាធាតុផ្សំសំខាន់នៅក្នុងការព្រមព្រៀងគ្នាជំរុញគោលបំណងរួម។ ពេលវេលានៃការអនុវត្តផែនការនេះគិតចាប់ពីពេលរួមចំណែកដំបូងក្នុងគោលបំណងរួម ដែលជាការបង្ហាញឱ្យឃើញច្បាស់អំពីចេតនាល្មើសរួម និងបញ្ចប់នៅពេលសកម្មភាពល្មើសបន្ថែមទៀតណាមួយរបស់សហឧក្រិដ្ឋកម្មនេះឈប់បន្ត ឬពាក់ព័ន្ធទៅនឹងបុគ្គលដែលបានរួមចំណែកនៅក្នុងការអនុវត្តនោះដកខ្លួនចេញពីសហឧក្រិដ្ឋកម្ម ដែលការដកខ្លួននេះតម្រូវឱ្យមានការបញ្ឈប់នូវការរួមចំណែកណាមួយបន្តទៀត ព្រមទាំងការបោះបង់ចេតនាល្មើសរួមផងដែរ។ ផ្អែកតាមស្មារតីនៃច្បាប់សារធាតុ ជាការពុំសមស្របក្នុងការបំបែកចេញនូវការបំពេញកិច្ចការនេះដែលមានលក្ខណៈស្មុគស្មាញ និងអូសបន្លាយរយៈពេលយូរ ដែលអាចយល់បានតែក្នុងករណីដែលសមាសភាពទាំងអស់នៃសហឧក្រិដ្ឋកម្មរួមត្រូវបានពិចារណារួមគ្នា។ វិធីសាស្ត្រនេះនៅតែមានសុពលភាព បើទោះបីជាអាចមានភាពចាំបាច់ក្នុងការកាត់បង្រួមដើម្បីប្រកាសពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម តាមរយៈការកំណត់ដែនយុត្តាធិការ ដូចជា អាជ្ញាយុកាល អាយុរបស់ចារី ការកម្រិតដែនកំណត់ពេលវេលា ជាដើម។

២១៦.ការពិចារណានេះ បើទោះបីជាពុំមាននៅក្នុងយុត្តិសាស្ត្រនៅកម្រិតអន្តរជាតិដែលបញ្ហាបែបនេះទំនងជាពុំដែលកើតមានក៏ដោយ ក៏ទទួលបានការគាំទ្រនៅក្នុងយុត្តាធិការក្នុងស្រុកដែលប្រើប្រាស់ទម្រង់នៃការទទួលខុសត្រូវសម្រាប់ការចូលរួមនៅក្នុងសកម្មភាពល្មើសដែលមានចារីផ្ទាល់ច្រើន ដែលប្រហាក់ប្រហែលគ្នាទៅនឹង

---

១៩៧៥ និងបាន“ផ្តោតយ៉ាងសកម្មលើការឃោសនា និងការបណ្តុះបណ្តាលកម្មាភិបាលខ្មែរក្រហម” រួមទាំង“នៅក្នុងឆ្នាំមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ”) *សូមមើលផងដែរ* កថាខណ្ឌ ៩៦៦, ៩៧៣ (យោងទៅលើកថាខណ្ឌ ៣៦៧), ៩៨១, ៩៨២, ៩៨៩ (ទាក់ទងទៅនឹងការរួមចំណែករបស់ ខៀវ សំផន នៅក្នុងការអនុវត្តគោលបំណងល្មើសរួម អង្គជំនុំជម្រះសាលាដំបូងបានសំអាង*ក្នុងចំណោមនោះ*ទៅលើការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងដើមខែ មេសា ឆ្នាំ ១៩៧៥ ដែលពេលនោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានពិភាក្សា និងបានសម្រេច ការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំស្តីពីការការណែនាំ និងការបណ្តោះមនោគមន៍វិជ្ជា និងផ្សព្វផ្សាយនៅមុនឆ្នាំ ១៩៧៥ ការចូលរួមក្នុងកិច្ចប្រជុំសស្តីពីការណែនាំ និងការឃោសនាក្នុងដើមឆ្នាំ ១៩៧០ សេចក្តីថ្លែងជាសាធារណៈក្នុងខែ មិថុនា ឆ្នាំ ១៩៧៣ ខែ ធ្នូ ឆ្នាំ ១៩៧៤ និងខែ មីនា និងដើមខែ មេសា ឆ្នាំ ១៩៧៥ និងការចូលរួមនៅក្នុងបេសកម្មផ្នែកការទូត និងក្នុងការទទួលបដិសណ្ឋារកិច្ចភ្ញៀវកិត្តិយសក្នុងឆ្នាំ ១៩៧៣ និង ឆ្នាំ ១៩៧៤)។

សហឧក្រិដ្ឋកម្មរួមដែរ។ ពាក់ព័ន្ធផ្ទាល់លើចំណុចនេះ និងយោងតាមយុត្តិសាស្ត្ររបស់អង់គ្លេស និងវែល៍ (Wales) សមាជិកណាមួយនៃសហឧក្រិដ្ឋកម្មរួមនឹងត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះរាល់អំពើរបស់សមាជិកដទៃទៀត លើកលែងតែសមាជិកនោះបានបង្ហាញចេតនាក្នុងការដកខ្លួនដល់សមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែលមានចេតនាបន្តនោះ ដែលការដកខ្លួននេះត្រូវមានលក្ខណៈច្បាស់លាស់ និងទាន់ពេល[517]។ យុត្តិសាស្ត្រនេះ ផ្តោតទៅលើការបន្តចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តអំពើ*សត្យានុម័ត* ជាជាងទៅលើការរួមចំណែកជាលក្ខណៈបុគ្គលក្នុងសហឧក្រិដ្ឋកម្មនេះ។ ចំណុចសំខាន់នៃធាតុផ្សំនៃកិច្ចព្រមព្រៀងបន្តសហឧក្រិដ្ឋកម្មរួម មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងបទសមគំនិត។ អាស្រ័យហេតុនេះ យុត្តិសាស្ត្រស្តីពីយុត្តាធិការពេលវេលានៃការសមគំនិតក៏បានផ្តល់ជាការណែនាំផងដែរ។ នៅក្នុងប្រទេសអង់គ្លេស និងវែល៍ បើទោះបីជាបទឧក្រិដ្ឋនៃការសមគំនិតត្រូវបានចាត់ទុកថា បានប្រព្រឹត្តនៅពេលណាមានការព្រមព្រៀងរវាងអ្នកសមគំនិតត្រូវបានធ្វើឡើងក៏ដោយ ក៏បទឧក្រិដ្ឋនេះបន្តរហូតដរាបណាផែនការនៃការសមគំនិតនេះនៅតែបន្តអនុវត្ត[518]។ នៅក្នុងច្បាប់ព្រហ្មទណ្ឌអាម៉េរិក ទាក់ទងទៅនឹងការសមគំនិតដែលត្រូវបានចាត់ទុកថា ជាបទឧក្រិដ្ឋដែលកំពុងបន្ត អាជ្ញាយុកាលនឹងត្រូវចាប់គិតតែក្នុងករណីដែលការព្រមព្រៀងលើបទល្មើសបានបញ្ចប់ បានបោះបង់ចោល ឬបន្ទាប់ពីសកម្មភាពឥតលាក់លៀមចុងក្រោយក្នុងការជំរុញការព្រមព្រៀងត្រូវបានធ្វើឡើង ហើយនេះពុំជាប់ពាក់ព័ន្ធទៅនឹងពេលវេលា ថាតើសមាជិកដែលបានលើកឡើងអំពីអាជ្ញាយុកាល

---

[517] *រឿងក្តី R. ទល់នឹង* Becerra (តុលាការឧទ្ធរណ៍ ចក្រភពអង់គ្លេស)។ *សូមមើលផងដែរ រឿងក្តី R. ទល់នឹង O'Flaherty* (តុលាការឧទ្ធរណ៍ ចក្រភពអង់គ្លេស) កថាខណ្ឌ ៦៤ បានដកស្រង់*រឿងក្តី R. ទល់នឹង* Mitchell *និង* King (តុលាការឧទ្ធរណ៍ផ្នែកព្រហ្មទណ្ឌប្រទេសស្កុតឡែន)("គណៈវិនិច្ឆ័យ [...] ត្រូវជឿជាក់ថា (ក) មានការទទួលខុសត្រូវចំពោះព្យសនកម្មដល់អាយុជីវិតដរាបណាដែលសហឧក្រិដ្ឋកម្មរួមនៅតែបន្ត និងថា ជនជាប់ចោទនៅតែប្រព្រឹត្តនៅក្នុងសហឧក្រិដ្ឋកម្មរួមនោះ និង (ខ) អំពើដែលបង្កឱ្យស្លាប់នោះ គឺស្ថិតក្នុងវិសាលភាពនៃសហឧក្រិដ្ឋកម្មរួម")។

[518] *រឿក្តី DPP ទល់នឹង Doot* (សភាជាន់ខ្ពស់របស់ចក្រភពអង់គ្លេស)("បើទោះបីជាការសមគំនិតបានបញ្ចប់ និងក្លាយជាបទឧក្រិដ្ឋមួយនៅពេលដែលមានការព្រមព្រៀងបានធ្វើឡើងក៏ដោយ ក៏ការសមគំនិតនេះនៅតែបានបន្តអត្ថិភាពដរាបណាភាគីពីរ ឬច្រើននៃកិច្ចព្រមព្រៀងនេះមានចេតនាអនុវត្តផែនការនោះ" )។ *សូមមើលផងដែរ រឿងក្តី R. ទល់នឹងប្រធាននៃពន្ធនាគារ* Brixton (សភាជាន់ខ្ពស់ ចក្រភពអង់គ្លេស)។ *រឿងក្តី R. ទល់នឹង Anderson (William Ronald)* ("ច្បាប់[ច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៧៧ បានវិសោធនកម្ម] ពុំបានចែងថា ភាគីទាំងអស់សុទ្ធបានបន្តប្រព្រឹត្តអំពើដែលខ្លួនមានបំណងទាក់ទងទៅការប្រព្រឹត្តបទល្មើសនោះឡើយ ប៉ុន្តែថា យ៉ាងហោចណាស់ក៏មានបុគ្គលណាម្នាក់ក្នុងចំណោមនោះដែលបានយល់ស្របជាមួយនឹងជនល្មើសដទៃទៀតបានប្រព្រឹត្តបទល្មើសនោះដែរ")។

មកសំអាងនោះបានរួមចំណែកក្នុងឧក្រិដ្ឋកម្មរួមក្រោយគេ ដែរ ឬយ៉ាងណា នោះឡើយ[519]។

២១៧.ផ្អែកលើការពិចារណាអំពីច្បាប់សារធាតុ និងដោយហេតុថា ការរួមចំណែករបស់ជនជាប់ចោទដែលមានអត្ថិភាពនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គឺជាផ្នែកនៃបណ្តុំក្នុងការអនុវត្តផែនការសហឧក្រិដ្ឋកម្មរួម ដែលបានបន្តអស់មួយរយៈពេល និងបានចេញជាផ្លែផ្កានោះ អំពើ*សត្យានុម័ត*ពាក់ព័ន្ធត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃយុត្តាធិការរបស់ អ.វ.ត.ក. ហើយឧក្រិដ្ឋកម្មនេះ“ត្រូវបានប្រព្រឹត្តឡើង”នៅក្នុងយុត្តាធិការពេលវេលានៃ អ.វ.ត.ក. ដូចមានចែងនៅក្នុងមាត្រា ២ ថ្មី នៃច្បាប់ អ.វ.ត.ក.[520] ហើយជនជាប់ចោទនៅតែទទួលខុសត្រូវចំពោះបញ្ហាទាំងអស់នេះ លើកលែងតែនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ជនជាប់ចោទបានបោះបង់ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។

២១៨.ការបញ្ជាក់របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ក្នុង*រឿងក្តី Nahimana* ដែលជនជាប់ចោទបានយោងទៅលើនោះ មានការជាប់ពាក់ព័ន្ធតិចតួចទៅនឹងការបកស្រាយមាត្រា ២ ថ្មី នៃច្បាប់ អ.វ.ត.ក.។ ក្នុង*រឿងក្តី Nahimana* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានយល់ឃើញថា មាត្រា ១ នៃលក្ខន្តិកៈរបស់តុលាការ ICTR ដែលបានផ្តល់យុត្តាធិការលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង“ចន្លោះពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤” ត្រូវតែបកស្រាយថា៖

---

[519] *សូមមើល រឿងក្តី សហរដ្ឋអាម៉េរិក ទល់នឹង Kissel* (តុលាការកំពូល សហរដ្ឋអាម៉េរិក)។ *រឿងក្តី Fiswick* (តុលាការកំពូល សហរដ្ឋអាម៉េរិក)។ *រឿងក្តី សហរដ្ឋអាម៉េរិក ទល់នឹង Scarpa* (តុលាការកំពូល សហរដ្ឋអាម៉េរិក)។ *រឿងក្តី សហរដ្ឋអាម៉េរិក ទល់នឹង Maloney* (តុលាការឧទ្ធរណ៍ សហរដ្ឋអាម៉េរិក)ដកស្រង់*រឿងក្តី សហរដ្ឋអាម៉េរិក ទល់នឹង Elwell* (តុលាការកំពូល សហរដ្ឋអាម៉េរិក)។ *សូមមើលផងដែរ រឿងក្តី សហរដ្ឋអាម៉េរិក ទល់នឹង Seher* (តុលាការឧទ្ធរណ៍ សហរដ្ឋអាម៉េរិក) (“រដ្ឋាភិបាលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃដែនកំណត់អាជ្ញាយុកាលសម្រាប់អំពើសមគំនិតដែលពុំបង្ហាញច្បាស់លាស់ ក្នុងករណីដែលរដ្ឋាភិបាលចោទប្រកាន់ និងបង្ហាញថា ការសមគំនិតបានបន្តនៅក្នុងដែនកំណត់អាជ្ញាយុកាលពេលវេលា”)។ *រឿងក្តី សហរដ្ឋអាម៉េរិក ទល់នឹង Rouphael* (តុលាការឧទ្ធរណ៍ សហរដ្ឋអាម៉េរិក) (“ប្រសិនបើការសមគំនិតកំពុងបន្ត ‘សច្ចធារណ៍នៃការបន្ត’ បានធ្វើឱ្យជនជាប់ចោទ Rouphael ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើរបស់សហចារីរបស់ខ្លួន បើទោះបីជាគាត់ពុំបានប្រព្រឹត្តផ្ទាល់ ដោយសារការសមគំនិតក្នុងអំឡុងពេលនៃដែនកំណត់អាជ្ញាយុកាលពេលវេលាពាក់ព័ន្ធ”)។ *រឿងក្តី Smith ទល់នឹង សហរដ្ឋអាម៉េរិក* (តុលាការកំពូល សហរដ្ឋអាម៉េរិក)។

[520] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា មាត្រា ២ ថ្មីនៃច្បាប់ អ.វ.ត.ក. ផ្ទុយទៅនឹងមាត្រា ២៤(១) នៃលក្ខន្តិកៈរបស់តុលាការ ICC ដែលចែងថា “ពុំមានបុគ្គលណាម្នាក់ត្រូវដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមលក្ខន្តិកៈនេះចំពោះអំពើប្រព្រឹត្តមុនការចូលជាធរមាននៃលក្ខន្តិកៈនេះឡើយ” (សេចក្តីបញ្ជាប់បន្ថែម)។

១-បទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពត្រូវបានប្រព្រឹត្តឡើងនៅក្នុងឆ្នាំ ១៩៩៤។
២-អំពើសកម្ម ឬអកម្មរបស់ជនជាប់ចោទក្នុងការបង្ហាញអំពីការទទួលខុសត្រូវតាមទម្រង់ណាមួយនៃការទទួលខុសត្រូវដែលបានយោងទៅលើមាត្រា ៦(១-៣) នៃលក្ខន្តិកៈនេះមានអត្ថិភាពក្នុងឆ្នាំ ១៩៩៤ ហើយនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តអំពើសកម្ម ឬអកម្មនេះ ជនជាប់ចោទមានចេតនាតម្រូវ(*ធាតុផ្សំអត្តនោម័ត*) ដែលអាចដាក់ពិរុទ្ធភាពបានដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវនោះ[521]។

២១៩.អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានផ្ដល់ការសន្និដ្ឋាននេះដោយផ្អែកជាចម្បងលើបំណងរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលនៅក្នុងអំឡុងពេលនៃការធ្វើសេចក្ដីព្រាងលក្ខន្តិកៈរបស់តុលាការ ICTR បានធ្វើការកែប្រែបទប្បញ្ញត្តិសាឡើងវិញទាក់ទងទៅនឹងយុត្តាធិការពេលវេលានៃលក្ខន្តិកៈរបស់តុលាការ ICTR ឱ្យគ្របដណ្ដប់លើអំឡុងពេលចាប់តាំពីដំបូងនៃចន្លោះខែ មេសា ឆ្នាំ ១៩៩៤ (នៅពេលដែលការប្រព្រឹត្តជាក់ស្ដែងនៃបទប្រល័យពូជសាសន៍បានចាប់ផ្ដើម)ដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤។ យោងតាមអ្នកតំណាងរបស់ប្រទេសបារាំង និងប្រទេសញូហ្សេឡែន (New Zealand) យុត្តាធិការនេះត្រូវបានបង្កើតឡើងដើម្បីគ្របដណ្ដបអំពើនៃការរៀបចំផែនការ និងការត្រៀមរៀបចំប្រព្រឹត្តបទឧក្រិដ្ឋ[522]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ក៏បានកត់សម្គាល់ផងដែរលើការលើកឡើងរបស់អ្នកតំណាងប្រទេសរវ៉ាន់ដានៅក្នុងក្រុមប្រឹក្សាសន្តិសុខ ដែលបានរិះគន់ថា ទាក់ទងទៅនឹងការបង្កើតវិសាលភាពពេលវេលាដែលត្រូវបានអនុម័តនោះ តុលាការ ICTR នឹងពុំអាចកាត់ទោស“បុគ្គលដែលទទួលខុសត្រូវចំពោះអំពើនៃការរៀបចំផែនការដែលបានប្រព្រឹត្តឡើងមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤”[523]។ ដូច្នេះ ការបកស្រាយរបស់តុលាការ ICTR លើមាត្រា ១ នៃលក្ខន្តិកៈរបស់ ICTR កើតចេញពីការពិចារណាលើប្រវត្តិនៃការធ្វើសេចក្ដីព្រាងជាក់លាក់នៃបទប្បញ្ញត្តិនោះ និងការទទួលស្គាល់របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR នូវបំណងរបស់អ្នកធ្វើសេចក្ដីព្រាងលក្ខន្តិកៈនេះ។ ដូច្នេះទាំងអស់នេះពុំអាចយកមកធ្វើជាមូលដ្ឋានដើម្បីបកស្រាយមាត្រា ២ ថ្មី នៃច្បាប់ អ.វ.ត.ក បានឡើយ។

២២០.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានយល់ឃើញថា “អត្ថិភាពនៃអំពើប្រព្រឹត្តដែលកំពុងបន្ត ពុំមែនជាករណីលើកលែង”ចំពោះវិធានដែលថា ICTR អាច

---

[521] *សូមមើល* សាលដីកា *រឿងក្ដី Nahimana* (ICTR) កថាខណ្ឌ ៣១៣។

[522] *សូមមើល* សាលដីកា *រឿងក្ដី Nahimana* (ICTR) កថាខណ្ឌ ៣១១។

[523] *សូមមើល* សាលដីកា *រឿងក្ដី Nahimana* (ICTR) កថាខណ្ឌ ៣១១។

ត្រឹមតែពិចារណាលើអំពើប្រព្រឹត្តដែលបានកើតឡើងនៅក្នុងយុត្តាធិការពេលវេលារបស់ខ្លួន និងថា "សូម្បីនៅពេលដែលអំពើប្រព្រឹត្តនេះបានចាប់ផ្ដើមនៅមុនឆ្នាំ ១៩៩៤ និងបានបន្តនៅក្នុងនោះ ការសម្រេចដាក់ពិរុទ្ធភាពអាចត្រឹមតែសំអាងលើផ្នែកនៃអំពើប្រព្រឹត្តដែលមានអត្ថិភាពនៅក្នុងឆ្នាំ ១៩៩៤ ប៉ុណ្ណោះ"[524]។ ការយល់ឃើញនេះដែលចៅក្រម Fausto Pocar ជំទាស់[525] ពុំមានលក្ខណៈស៊ីជម្រៅ[526] និងជាក់ស្ដែងពុំមានការជាប់ពាក់ព័ន្ធទៅនឹងផ្នែកសម្រេចសេចក្ដីនៃរឿងក្ដីចំពោះមុខតុលាការ ICTR ដោយសារ ដរាបណាមានការជាប់ពាក់ព័ន្ធទៅនឹងការញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលជាបទឧក្រិដ្ឋមួយពុំជាប់ពាក់ព័ន្ធទៅនឹងបទចោទនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានពិចារណាឃើញថា ឧក្រិដ្ឋកម្មនេះបានប្រព្រឹត្តឡើងភ្លាមក្រោយពេលមានការប្រើប្រាស់ពាក្យពេចន៍ញុះញង់ និងបានលើកឡើងថា បទឧក្រិដ្ឋនេះពុំបានបន្តហួសពីដែនកំណត់នោះឡើយ និងថា តុលាការ ICTR ខ្វះយុត្តាធិការលើអំពើញុះញង់ដែលបានកើតឡើងមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤[527]។ ទាក់ទងទៅនឹងបទចោទនៃការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានបដិសេធពុំធ្វើការពិភាក្សាលើបញ្ហា ថាតើបទឧក្រិដ្ឋនេះបានបន្ត ដែរ ឬយ៉ាងណា នោះឡើយ ដោយហេតុថា អង្គជំនុំជម្រះបានយល់ឃើញថា នៅគ្រប់កាលៈទេសៈទាំងអស់ បទចោទពុំត្រូវបានបង្ហាញហួសពីវិមតិសង្ស័យឡើយ[528]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ពុំបានពិភាក្សាលើបណ្ដឹងនៃការអនុវត្តផែនការដូចនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ ដូចជា ករណីដែលជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវដោយផ្អែកលើការរួមចំណែករបស់ខ្លួនលាតសន្ធឹងអស់រយៈពេលយ៉ាងយូរនៅក្នុងការអនុវត្តគោលបំណងរួម ទោះបីជាយ៉ាងណាក្ដី ពុំបានប្រព្រឹត្តអំពើ*សត្យានុម័ត*ដោយ

---

[524] សាលដីកា *រឿងក្ដី Nahimana* (ICTR) កថាខណ្ឌ ៣១៧។

[525] សាលដីកា *រឿងក្ដី Nahimana* (ICTR) ទំព័រ ៣៤៩ កថាខណ្ឌ ២។

[526] ក្នុងការគាំទ្រសេចក្ដីសន្និដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានយោងទៅលើមតិដាច់ដោយឡែករបស់ចៅក្រម Lal Chand Vohrah និងចៅក្រម Rafael Nieto-Navia នៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បង្ខំពីដំបូង (*សូមមើល* សាលដីកា *រឿងក្ដី Nahimana* (ICTR) កថាខណ្ឌ ៣១៧ ជើងទំព័រ ៧៦០ យោងទៅលើសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បង្ខំ *រឿងក្ដី Nahimana* (ICTR))។ ទោះជាយ៉ាងណាក្ដី ត្រូវកត់សម្គាល់ថា មតិដាច់ដោយឡែកនៃការយល់ឃើញពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋបន្តនេះបានផ្អែកតែមួយមុខគត់ទៅលើប្រវត្តិនៃសេចក្ដីព្រាងលក្ខន្តិកៈរបស់តុលាការ ICTR និងបំណងរបស់ក្រុមប្រឹក្សាសន្តិសុខ (*សូមមើលដូចគ្នានេះ* មាត្រា ១១ ដល់ ១៨)។

[527] សាលដីកា *រឿងក្ដី Nahimana* (ICTR) ទំព័រ ៣៤៩ កថាខណ្ឌ ៧២៣។

[528] សាលដីកា *រឿងក្ដី Nahimana* (ICTR) ទំព័រ ៣៤៩ កថាខណ្ឌ ៣១៨ និង ៩១២។

ផ្ទាល់នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់នោះក៏ដោយ។

២២១.សរុបសេចក្តី អង្គជំនុំតុលាការកំពូលពិចារណាឃើញថា យោងតាមមាត្រា ២ ថ្មីនៃច្បាប់ អ.វ.ត.ក. អំពើ*សត្យានុម័ត*នៃបទឧក្រិដ្ឋដែលជាកម្មវត្ថុនៃបទចោទ ត្រូវស្ថិតក្នុងអំឡុងពេលនៃចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៧ ចំណែកអំពើប្រព្រឹត្តដែលបង្កើតឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដោយផ្អែកលើការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អាចមានអត្ថិភាពនៅមុននេះ ប្រសិនបើអំពើប្រព្រឹត្តនេះ គឺជាផ្នែកនៃការរួមចំណែកយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តគោលបំណងរួមដែលបានបន្តនៅក្រោយថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥។ ទាក់ទងទៅនឹងរឿងក្តីចំពោះមុខ គួរកត់សម្គាល់ថា នេះពុំមែនជារឿងក្តីដែលមានអំពើតែមួយ (ដូចជា ការរៀបចំផែនការ ឬការញុះញង់) ដែលបានប្រព្រឹត្តឡើងក្រៅវិសាលភាពពេលវេលានៃយុត្តាធិការរបស់ អ.វ.ត.ក. ដែលចុងក្រោយក្លាយជាបទល្មើសនៅក្នុងយុត្តាធិការពេលវេលានេះឡើយ។ ផ្ទុយទៅវិញ អំពើប្រព្រឹត្តដែលចោទជាបញ្ហានោះ គឺជាផ្នែកនៃការរួមចំណែកយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តគោលបំណងរួមដែលបានបន្តនៅក្នុងអំឡុងពេលក្រោយថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥។ ជាពិសេស ជនជាប់ចោទបានចូលរួមនៅក្នុងការត្រួតពិនិត្យទីក្រុងភ្នំពេញបន្ទាប់ពីការបណ្តេញប្រជាជនចេញពីទីក្រុង និងបានបន្តរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួម។ ដូច្នេះ ពុំមានការបង្ហាញថា ជនជាប់ចោទបានដកខ្លួនចេញពីគោលបំណងរួមនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឬពេលណាមួយក្រោយមកទៀតនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.។

### ៤.ខ.៤.ខ.ការយល់ឃើញផ្នែកអង្គហេតុដែលពុំមាននៅក្នុងបទចោទក្នុងសំណុំរឿង ០០២/០១

២២២.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង"បានផ្តល់ការយល់ឃើញយ៉ាងច្រើនពាក់ព័ន្ធទៅនឹងអង្គហេតុ និងគោលនយោបាយដែលពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១"[529] ដែលបើទោះបីជាពុំបានធ្វើឱ្យសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈ ឬមានភាពមិនយុត្តិធម៌ក៏ដោយ ក៏"ត្រូវតែជាកម្មវត្ថុនៃការពិនិត្យឡើងវិញនៅដំណាក់កាលបណ្តឹងសាទុក្ខ ដោយផ្អែកលើយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការជំនុំជម្រះ*សាជាថ្មី*លើបណ្តឹងសាទុក្ខ"[530]។ អំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹង (i) ការយល់

[529] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១២ និង ៦២៧ ដល់ ៦៣៨។

[530] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១២។

ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹង"ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"ថា ជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[531] (ii) សេចក្តីសង្ខេបពីភស្តុតាងរបស់អង្គជំនុំជម្រះ និងអំណះអំណាងរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងតួនាទីរបស់គាត់នៅមន្ទីរសន្តិសុខ ស-២១[532] (iii) ការសន្និដ្ឋានរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងចំនួនមនុស្សស្លាប់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[533]។ នួន ជា បានលើកឡើងថា ក្នុងការធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់ការយល់ឃើញទាំងនេះនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ ដោយសារបានសំអាងទៅលើភស្តុតាងដែលប្រើប្រាស់ក្នុងគោលបំណង ដើម្បីបង្ហាញពីការអនុវត្តនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[534]។ នួន ជា ក៏បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយកម្ទេចខ្មាំង និងបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហានេះពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងគ្រប់កាលៈទេសៈទាំងអស់ ជាកំហុសអង្គហេតុ[535]។

២២៣.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញលើបញ្ហាដែលពុំមែនជាផ្នែកនៃសំណុំរឿង ០០២/០១ បើទោះជាបានបំបែកហើយក៏ដោយ ក៏នៅតែយោងជាពិសេសទៅលើបញ្ហានៃសមូហភាវូបនីយកម្ម សហករណ៍ ពលកម្មដោយបង្ខំ ជាដើម[536]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា "ភាពពុំជាក់លាក់នៃបទចោទដែលត្រូវបានដកចេញពីសំណុំរឿង ០០២/០១" និងភាពពុំច្បាស់លាស់អំពីអត្ថន័យនៃសំណុំរឿង ០០២/០១ ដែលយកមកធ្វើជា"មូលដ្ឋានរួម"សម្រាប់សំណុំរឿង ០០២/០២ នោះ បានបណ្តាល

---

[531] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១៦ ដល់ ២១៩ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៨ ដល់ ១៣០។

[532] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២០ ដល់ ២២១ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤២ ដល់ ៣៤៦។

[533] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២២ ដល់ ២២៤ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៤។

[534] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១៣ ដល់ ២១៥។

[535] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦៨ ដល់ ២៨០។

[536] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១២ *សូមមើលផងដែរ* កថាខណ្ឌ ៤៧, ១៩៧, ៥៨១, ៥៨២។

ឱ្យគាត់ទទួលរងផលប៉ះពាល់[537]។ ខៀវ សំផន ក៏បានជំទាស់ទៅនឹង"ការដាក់បញ្ចូល"របស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលនយោបាយកំណត់គោលដៅទៅក្នុងគោលនយោបាយ"កម្ទេចខ្មាំង" ទោះជាយ៉ាងណាក្តី គាត់ពុំបានបញ្ជាក់ថា គាត់បានទទួលរងផលប៉ះពាល់ដោយសារបញ្ហានេះឡើយ[538]។

២២៤.សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ នួន ជា គប្បីបដិសេធចោលដោយពុំចាំបាច់ពិចារណាបន្តទៀតឡើយ ដោយសារគាត់បានទទួលស្គាល់ថា ការចោទប្រកាន់អំពីកំហុស បើទោះបីជាត្រូវបានបង្ហាញក៏ដោយ ក៏ពុំអាចធ្វើឱ្យសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈ ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះឡើយ។ បន្ថែមលើនេះ សហព្រះរាជបានអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីតួនាទីរបស់ នួន ជា នៅក្នុងមន្ទីរសន្តិសុខ ស-២១ ដែលមិនត្រឹមតែតាមរយៈការកំណត់អំពីការទទួលខុសត្រូវរបស់គាត់ចំពោះបទឧក្រិដ្ឋដែលបានកើតឡើងនៅទីនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើជាផ្នែកនៃការពិចារណាលើតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមផងដែរ[539]។ សហព្រះរាជអាជ្ញាក៏បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ប៉ុន្តែត្រឹមតែអត្ថិភាពនៃការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ដែលអង្គជំនុំជម្រះបានសួរសម្រាប់គោលបំណងសាវតារប៉ុណ្ណោះ[540]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញអំពីចំនួនមនុស្សស្លាប់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ[541]។ ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការបំបែកសំណុំរឿង សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងទាំងនេះពុំបានបំពេញតាមបទដ្ឋានជាធរមាននៃការពិនិត្យឡើងវិញឡើយ[542]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានសន្និដ្ឋានដោយពុំត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងខ្វះសមត្ថកិច្ច"ក្នុងការពិនិត្យលើភស្តុតាងនៃគោលនយោបាយ ដែលពុំមែនជាភស្តុតាងពាក់ព័ន្ធទៅនឹងបទចោទនៃការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងសំណុំរឿង ០០២/០១"[543]។ ផ្ទុយទៅ

[537] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៣ ដល់ ១៥។

[538] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៤៣។

[539] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១៧។

[540] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១៩។

[541] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២០។

[542] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២១។

[543] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២៤។

វិញ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងជានិច្ចកាលបញ្ជាក់ច្បាស់លាស់ថា គោលនយោបាយទាំងប្រាំ គឺជាចំណោទបញ្ហានៅក្នុងសំណុំរឿង ០០២/០១ បើទោះបីជាមានតែគោលនយោបាយពីរប៉ុណ្ណោះ ដែលត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់បទចោទនៅក្នុងសំណុំរឿង ០០២/០១ ក៏ដោយ[544]។

២២៥.អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា វិសាលភាពនៃការជំនុំជម្រះលើ នួន ជា និង ខៀវ សំផន ពីដំបូងមានលក្ខណៈទូលំទូលាយ។ ប៉ុន្តែនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងនេះ ដោយបានកម្រិតត្រឹមផ្នែកខ្លះនៃបទចោទនានាក្នុងដីកាដំណោះស្រាយ (D427) ដាក់ក្នុងសំណុំរឿង ០០២/០១ ដូចមាន "ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនៅដំណាក់កាលទីមួយ និងទីពីរ ការសម្លាប់ដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃបន្ទាប់ពីការជម្លៀសចេញពីទីក្រុងភ្នំពេញ និងបទឧក្រិដ្ឋពាក់ព័ន្ធមួយចំនួនទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[545]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ គឺជាការបន្តពីកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០១ [...] ភស្តុតាងដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ នឹងត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់សំណុំរឿង ០០២/០២"[546]។ ទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលរងការចោទប្រកាន់ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ពីដំបូងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីថា៖

> ដូច្នេះ អ្វីដែលរំពឹងទុក គឺជាការបង្ហាញជាទូទៅពីគោលនយោបាយទាំងប្រាំនោះ បើទោះបីបញ្ហាជាក់ស្តែងសម្រាប់សួរដេញដោលនៅក្នុងដំណាក់កាលដំបូង ត្រូវបានកម្រិតត្រឹមការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទីមួយ និងទីពីរ) យ៉ាងណាក៏ដោយ។ ដូច្នេះ នឹងពុំមានការពិនិត្យលើការអនុវត្តនូវគោលនយោបាយផ្សេងៗ ក្រៅតែពីគោលនយោបាយដែលពាកព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទីមួយ និងទីពីរ) ឡើយ[547]។

២២៦.អង្គជំនុំជម្រះសាលាដំបូងបានរំលឹកថា ខ្លួនបានជូនដំណឹងដល់ភាគីពីដំបូងមកថា "ភាគីអាចលើកភស្តុ

---

[544] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២៤។

[545] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ (E284) ទំព័រ ១២៦។

[546] អនុស្សរណៈបំភ្លឺ (E302/5) កថាខណ្ឌ ៧។

[547] អនុស្សរណៈស្តីពីការកំណត់កាលបរិច្ឆេទកិច្ចប្រជុំក្រៅផ្លូវការ (E141) ទំព័រ ២។ កត់សម្គាល់ថា នៅពេលចេញអនុស្សរណៈនេះ ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃពុំត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។

តាងទាក់ទងទៅនឹងគោលនយោបាយទាំងប្រាំនោះធ្វើជាមូលដ្ឋាន ប៉ុន្តែថា អង្គជំនុំជម្រះនឹងត្រូវសួរតែទៅលើការអនុវត្តនូវគោលនយោបាយទាំងនោះទាក់ទងទៅនឹងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ (ដូចជា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការសម្លាប់អ្នកដែលសន្មតថាជាខ្មាំងនៃរបប)" និងបញ្ជាក់ថា "អត្ថិភាពនៃគោលនយោបាយដទៃទៀត ត្រូវបានសួរសម្រាប់គោលបំណងសាវតារតែប៉ុណ្ណោះ"[548]។

២២៧.ដោយកត់សម្គាល់លើការបែងចែក"សាវតារ"ចេញពី"ការអនុវត្ត"នៅតែពុំមានភាពច្បាស់លាស់ និងផលវិបាកដែលអាចកើតមានសម្រាប់ការកំណត់កម្មវត្ថុនៃភស្តុតាង អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថានៅគ្រប់កាលៈទេសៈទាំងអស់ អង្គជំនុំជម្រះសាលាដំបូងត្រូវបានហាមឃាត់មិនឱ្យសម្រេចលើការដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋ ដែលស្ថិតនៅក្រៅវិសាលភាពនៃបទចោទក្នុងសំណុំរឿង ០០២/០១។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការកំណត់ ថាតើអង្គហេតុណាខ្លះដែលជាប់ពាក់ព័ន្ធទៅនឹងបទចោទសម្រាប់កំណត់បទចោទនៅចំពោះមុខខ្លួន បើទោះបីជាអង្គហេតុនោះទាក់ទងទៅនឹងមូលដ្ឋានអង្គហេតុនៃបទចោទដទៃទៀតក៏ដោយ[549]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា គោលនយោបាយទាំងប្រាំរបស់ ប.ក.ក. ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយ (D427)[550] ពុំអាចផ្តាច់ចេញពីគ្នាបាន និងមានលក្ខណៈដាច់ដោយឡែកច្បាស់លាស់ឡើយ។ ផ្ទុយទៅវិញគោលនយោបាយនេះ គឺជាមធ្យោបាយសម្រាប់ធ្វើការវិភាគអំពីការកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជា។ ក្នុងនោះ ក៏ទំនងជាមានទំនាក់ទំនងគ្នាដ៏សំខាន់ទៅនឹងអ្វីដែលគេហៅគោលនយោបាយផ្លាស់ទីលំនៅប្រជាជន

---

[548] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៣ ជើងទំព័រ ២៨៧។

[549] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា *ការយល់ឃើញ*មួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងដែល នួន ជា បានយោងទៅលើ ជាក់ស្តែងពុំមែនជាការយល់ឃើញដែលមានក្នុងព្រឹត្តិការណ៍ណាមួយឡើយ។ អង្គជំនុំជម្រះសាលាដំបូង ជាក់ស្តែងពុំបានធ្វើសេចក្តីសន្និដ្ឋានណាមួយទាក់ទងទៅនឹងចំនួនមនុស្សស្លាប់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែគ្រាន់តែសង្ខេបនៅក្នុងចំណងជើងថា "ទស្សនៈទូទៅ៖ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩" ទស្សនៈរបស់អ្នកជំនាញផ្សេងៗទាក់ទងទៅនឹងចំនួនមនុស្សស្លាប់សរុប (សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៤)។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងសង្ខេបភស្តុតាងដែលត្រូវបានផ្តល់ទាក់ទងទៅនឹងតួនាទីរបស់ នួន ជា ដែលរងការចោទប្រកាន់នៅក្នុងមន្ទីរសន្តិសុខ ស-២១ (សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤២ ដល់ ៣៤៥) និងបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះនឹង"ពុំផ្តល់ការយល់ឃើញពាក់ព័ន្ធទៅនឹងបញ្ហានេះនៅក្នុងសាលក្រមឡើយ" (សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤៦)។

[550] *សូមមើល* ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៥៧។

និងគោលនយោបាយបង្កើតការដ្ឋានធ្វើការ ជាមួយនឹងការដ្ឋានធ្វើការ គឺថា យោងតាមដីកាដំណោះស្រាយ (D427) គោលដៅមួយក្នុងចំណោមនោះអំពីការផ្លាស់ទីលំនៅប្រជាជន គឺ"ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវការងារសហករណ៍ និងការដ្ឋានធ្វើការ"[551]។ ប្រហាក់ប្រហែលគ្នានេះដែរ ទំនងជាមានការត្រួតគ្នារវាងគោលនយោបាយនៃការអប់រំកែប្រែ និងការសម្លាប់ខ្មាំង ជាមួយនឹងគោលនយោបាយកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ជាឧទាហរណ៍ បើទោះបីជាដីកាដំណោះស្រាយ (D427) បានរួមបញ្ចូលបទចោទទាក់ទងទៅនឹងឧក្រិដ្ឋកម្មនៅតាមមន្ទីរសន្តិសុខ ដែលស្ថិតក្រោមការគ្រប់គ្រងនៃគោលនយោបាយសម្លាប់ខ្មាំង[552] នៅពេលដែលការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានភ្ជាប់ទំនាក់ទំនងទៅនឹងគោលនយោបាយកំណត់គោលដៅក៏ដោយ[553] ក៏ដីកាដំណោះស្រាយបានចោទប្រកាន់ថា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ និងកម្មាភិបាលខ្មែរក្រហម គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខ សង់ មន្ទីរសន្តិសុខ ក្រាំងតាចាន់ មន្ទីរសន្តិសុខ កោះខ្យង ជាដើម[554]។ បើទោះបីជាការត្រួតគ្នានៃគោលនយោបាយនេះ អាចមានការលំបាកក្នុងការកំណត់អត្តសញ្ញាណនៃភស្តុតាងដែលពាក់ព័ន្ធទៅនឹងបទចោទក៏ដោយ ក៏បញ្ហាសំខាន់សម្រាប់ការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ គឺនៅត្រង់ការបង្ហាញគ្រប់គ្រាន់ទាក់ទងទៅនឹងបទចោទអំពី"ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទីមួយ និងទីពីរ ការសម្លាប់នៅទួលពោធិ៍ជ្រៃក្រោយពេលភ្លាមៗនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធដទៃទៀត"[555] និងចុងក្រោយ ភាពគ្រប់គ្រាន់នៃការយល់ឃើញផ្នែកអង្គហេតុដែលជាមូលដ្ឋានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាព ហើយពុំមែនជាការចាត់ទុកភស្តុតាងមូលដ្ឋាននៃរឿងក្តីថា មានសារៈខាន់តិចជាងគោលនយោបាយនោះឡើយ។ ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្តល់ការយល់ឃើញអំពីអត្ថិភាពនៃគោលនយោបាយរបស់ ប.ក.ក. ក្នុងការ"កម្ទេចខ្មាំង" និងការអនុវត្តគោលនយោបាយនេះ ដែលមានឥទ្ធិពលលើសេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទងទៅនឹងឧក្រិដ្ឋកម្មនៅទួល ពោធិ៍ជ្រៃ និងលើគោលនយោបាយកំណត់គោលដៅទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋ

---

[551] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៦១។

[552] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៧៨។

[553] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ២០៩។

[554] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ៤៣២, ៤៧៩, ៤៩៨, ៥២៤។

[555] ដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ (E284) ទំព័រ ១១៧ ដល់ ១១៨។

ខ្មែរ[556] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បើទោះបីជាដីកាដំណោះស្រាយ (D427) បានភ្ជាប់ទំនាក់ទំនងអង្គហេតុនៅទួលពោធិ៍ជ្រៃទៅនឹងគោលនយោបាយសម្លាប់ខ្មាំងក៏ដោយ ក៏អង្គជំនុំជម្រះពុំត្រូវបានចងកាតព្វកិច្ចដោយសារបញ្ហានេះឡើយ ហើយខ្លួនអាចពិចារណាលើព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃដោយផ្អែកលើមូលដ្ឋាននៃគោលនយោបាយកំណត់គោលដៅជំនួសវិញ[557]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា នៅក្នុងផ្នែកខ្លះនៃដីកាដំណោះស្រាយ (D427) ដែលពិភាក្សាអំពីគោលនយោបាយកំណត់គោលដៅទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ(ព្រមទាំងក្រុមគោលដៅដទៃទៀតដូចជា ជនជាតិចាម វៀតណាម និងក្រុមពុទ្ធសាសនិក) សហចៅក្រមស៊ើបអង្កេតបានយោងទៅលើកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីចំនួន ៣ នាក់ ដែលបានផ្តល់សក្ខីកម្មទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ហើយបើទោះបីជានៅក្នុងផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយ (D427) ព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃត្រូវបានរៀបរាប់នៅក្នុងផ្នែកចំណងជើងថា "មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស"ក៏ដោយ ក៏ផ្នែកដែលមានការយល់ឃើញផ្នែកអង្គហេតុទាក់ទងទៅនឹង"ការធ្វើបាបលើក្រុមជាក់លាក់" ពុំបានសំដៅទៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប៉ុន្តែត្រឹមតែសំដៅទៅលើការធ្វើបាបក្រុមពុទ្ធសាសនិក ជនជាតិចាម វៀតណាម ព្រមទាំងទៅលើការដាក់បទបញ្ជារៀបអាពាហ៍ពិពាហ៍ប៉ុណ្ណោះ[558]។ នេះបង្ហាញអំពីការត្រួតគ្នាម្តងទៀតរវាង *ក្នុងចំណោមនោះ* គោលនយោបាយសម្លាប់ខ្មាំង ជាមួយនឹងគោលនយោបាយកំណត់គោលដៅ។ យោងតាមហេតុផលដូចគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានបង្កើតឱ្យមានភាពពុំច្បាស់លាស់ផ្នែកនីតិវិធីដែលពុំត្រូវបានអនុញ្ញាតនៅពេលបញ្ចេញភ្លាមៗមុនពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីថា វិសាលភាពនៃការជំនុំជម្រះបានរួមបញ្ចូលគោលនយោបាយមួយក្នុងចំណោមនោះ គឺ"ការសម្លាប់ខ្មាំង

---

[556] សារណាបណ្តឹងសាទុក្ខ នួន ជា កថាខណ្ឌ ២៦៨ ដល់ ២៦៩, ២៧៨។

[557] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៣។

[558] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ២០៩ជើងទំព័រ ៧១៣ (យោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ុម អាឡាត់ *ហៅ* ផុង ឡាត់ និង លឹម សាត) កថាខណ្ឌ ៦៩៨ *ជាអាទិ៍*។ (នៅទួលពោធិ៍ជ្រៃ) ត្រូវបានរកឃើញនៅក្នុងផ្នែកទី ៨ គ។ ការប្រព្រឹត្តលើក្រុមជាក់លាក់នេះត្រូវបានពិភាក្សានៅក្នុងផ្នែកផ្សេងៗទៀត ក្នុងកថាខណ្ឌ ៧៤០ ជាអាទិ៍។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៣ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងពន្យល់ពីមូលហេតុដែលខ្លួនចាត់ទុកព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃស្ថិតក្រោមគោលនយោបាយកំណត់គោលដៅ។

01358066



នៃរបបដែលបានសន្មតទុក”[559]។

២២៨.ទាក់ទងទៅនឹងភាពស្មុគស្មាញជាសក្តានុពល ដែលបណ្តាលមកពីភាពត្រួតគ្នានៃការយល់ឃើញផ្នែកអង្គហេតុនៅក្នុងស្ថានភាព ដែលមានជនជាប់ចោទដដែលកំពុងត្រូវបានជំនុំជម្រះម្តងទៀតដោយក្រុមប្រឹក្សាដដែលសម្រាប់បទឧក្រិដ្ឋដែលកើតចេញពីមូលដ្ឋាននៃអង្គហេតុរួមតែមួយ និងទាក់ទងទៅនឹងភាពពុំសមស្របក្នុងការចាត់ទុកការយល់ឃើញក្នុងរឿងក្តីមួយធ្វើជា“មូលដ្ឋាន”សម្រាប់រឿងក្តីមួយផ្សេងទៀត អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បញ្ហានេះម្តងហើយម្តងទៀត និងរំឭកអំពីការយល់ឃើញរបស់ខ្លួននៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធី[560]។ ទោះជាយ៉ាងណាក្តី បញ្ហានេះពុំមានឥទ្ធិពលលើរឿងក្តីបច្ចុប្បន្នឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញមានភាពចាំបាច់ក្នុងការវាយតម្លៃលើបញ្ហានេះបន្តទៀតឡើយ។

២២៩.ទាក់ទងទៅនឹងការអះអាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះតុលាការកំពូលគប្បីពិនិត្យឡើងវិញលើសំអាងហេតុពាក់ព័ន្ធទៅនឹង“គោលនយោបាយ” និងព្រឹត្តិការណ៍ក្រៅបទចោទក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវធ្វើដូច្នោះ ដរាបណាសំអាងហេតុនេះមានការជាប់ពាក់ព័ន្ធទៅនឹងការសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដោយបង្ខំនៅដំណាក់កាលទីមួយ និងទីពីរ និងប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ[561]។ សំអាងហេតុក្រៅពីនេះរបស់អង្គជំនុំជម្រះសាលាដំបូងមានតម្លៃ*អាចយកជាការបាន* អាស្រ័យហេតុនេះ ពុំតម្រូវឱ្យមានការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខផ្នែកនេះឡើយ។

---

559 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៤ យោងទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៣ (E284/6) ដែលបានយោងទៅលើដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ (E284) កថាខណ្ឌ ១១៨។

560 សេចក្តីសម្រេចលើបណ្តឹងប្រឆាំងនឹងការបំបែកិច្ចដំណើរការនីតិវិធីលើកទីមួយ (E163/5/1/13) កថាខណ្ឌ ៤៧។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ (E284/4/8) កថាខណ្ឌ ២៨ *ជាអាទិ៍*។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ (E301/9/1/1/3) កថាខណ្ឌ ៤៥, ៧១ *ជាអាទិ៍*។

561 សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ (E284) ទំព័រ ១១៧ ដល់ ១១៨។

01358067



## ៤.ខ.៤.គ.វិសាលភាពនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

២៣០.នួន ជា និង ខៀវ សំផន បានលើកអំណះអំណាងមួយចំនួនទាក់ទងទៅនឹងវិសាលាភាពនៃបទចោទពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។

២៣១.នួន ជា បានលើកឡើងថា ទាក់ទងទៅនឹងបទធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានសំអាងភាគច្រើនទៅលើហេតុការណ៍ដែលជាក់ស្តែងពុំមែនជាផ្នែកនៃការផ្លាស់ទីលំនៅប្រជាជន ដូច្នេះពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ឡើយ[562]។ ក្នុងការគាំទ្រអំណះអំណាងនេះ នួន ជា បានអះអាងថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ត្រឹមតែបានរួមបញ្ចូលការផ្លាស់ទីលំនៅប្រជាសម្រាប់គោលបំណង“បែងចែកកម្លាំងពលកម្មសាជាថ្មី” និងការអនុវត្ត“ផែនការកសិកម្មរបស់ ប.ក.ក.”ប៉ុណ្ណោះ[563]។ នួន ជា បានលើកឡើងថា “ការដែលគ្រាន់តែថា បុគ្គលម្នាក់ត្រូវបានផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងពេលណាមួយនៅចន្លោះចុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ នោះ ពុំគ្រប់គ្រាន់ក្នុងការដាក់ព្រឹត្តិការណ៍នោះឱ្យស្ថិតក្នុងវិសាលភាពនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរឡើយ”[564]។ នួន ជា បានអះអាងថា ការយល់ឃើញទាក់ទងទៅនឹងការចាប់ខ្លួន និងសម្លាប់“ប្រជាជនថ្មី” និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ពុំស្ថិតក្នុងវិសាលាភាពនៃសំណុំរឿង ០០២/០១[565]។ នួន ជា បានលើកឡើងបន្ថែមទៀតថា ទាក់ទងទៅនឹងបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅគុក តានៃ ភ្នំស្រូក់ មន្ទីរសន្តិសុខ ថ្កោល ព្រឹត្តិការណ៍ទាំងនេះពុំត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ (D427) អាស្រ័យហេតុនេះ គាត់ពុំត្រូវបានផ្តល់ដំណឹងគ្រប់គ្រាន់អំពីការចោទប្រកាន់ទាំងនេះឡើយ[566]។

២៣២.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពិចារណាថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរបានបន្តរហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ ដោយបានសំអាងទៅលើអង្គហេតុដែលពុំ

---

[562] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៥ ដល់ ៣៩៨, ៤៤២ ដល់ ៤៤៣។

[563] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៥។

[564] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៥ *សូមមើលផងដែរ* កថាខណ្ឌ ៣៩៧។

[565] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៥។

[566] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៥។

បានលើកឡើងនៅក្នុងដីកាដំណោះស្រាយ (D427) បើទោះបីជាក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង មានការបញ្ជាក់ច្បាស់លាស់ថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរបានបញ្ចប់នៅចុងឆ្នាំ ១៩៧៦ ក៏ដោយនោះ[567]។ ខៀវ សំផន បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បន្ទាប់ពីទៅដល់សហករណ៍ ក្រៅពីអ្នកដែលត្រូវបានជម្លៀស អ្នកដែលពុំអាចទុកចិត្តបានត្រូវបានចាត់តាំងការងារផ្សេងទៀត និងបានយោងផងដែរទៅលើការបែងចែកប្រជាជននៅតាមសហករណ៍[568]។ ខៀវ សំផន បានអះអាងថា ក្នុងការសំអាងទៅលើការយល់ឃើញទាំងនេះសម្រាប់បទធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសវិសាលភាពសំណុំរឿង ០០២/០១ ដោយសារការប្រព្រឹត្តដាក់ប្រជាជននៅតាមសហករណ៍នោះពុំមែនជាផ្នែកនៃវិសាលភាពនេះទេ[569]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ក្នុងការយល់ឃើញថា ប្រជាជនត្រូវបានបាញ់ប្រហារ"ទាំងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ទាំងនៅពេលទៅដល់ទីកន្លែងត្រូវទៅនោះ"[570]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនតាមព្រំដែនវៀតណាម សម្រាប់គោលបំណងអប់រំកែប្រែ អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែមួយមុខគត់ទៅលើភស្តុតាងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ក្នុងឆ្នាំ ១៩៧៨ ដែលពុំស្ថិតក្នុងវិសាលភាពពេលវេលានៃសំណុំរឿង ០០២/០១[571]។

២៣៣.សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងអំណះអំណាងរបស់ជនជាប់ចោទ និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងត្រឹមត្រូវនូវវិសាលភាពនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[572]។

២៣៤.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អំណះអំណាងរបស់ជនជាប់ចោទបានលើកបញ្ហាយ៉ាងទូលំទូលាយបីយ៉ាង គឺថា៖ (១) តើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរដូចដែលបានចោទប្រកាន់

---

567 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១, ៦៣៧ *សូមមើលផងដែរ* កថាខណ្ឌ ៥០៣។

568 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៨៤, ៤៨៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២១, ៦២២។

569 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៨៤, ៤៨៥។

570 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៧ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។

571 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៧២។

572 សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២៣, ២២១, ២២៧។

នៅក្នុងដីកាដំណោះស្រាយ (D427) ត្រូវបានកម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជនសម្រាប់មូលហេតុសេដ្ឋកិច្ច ដែរ ឬយ៉ាងណា (២) តើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការពិចារណាលើអង្គហេតុ ដែលពុំបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ប៉ុន្តែអង្គហេតុបន្ទាប់ ការទៅដល់ទីកន្លែងរបស់អ្នកដែលត្រូវបានជម្លៀនោះ និង (៣) តើវិសាលភាពពេលវេលានៃការផ្លាស់ទីលំនៅ ប្រជាជនដំណាក់កាលទីពីរ ត្រូវបានកម្រិតត្រឹមការផ្លាស់ទីលំនៅដែលបានកើតឡើងត្រឹមចុងឆ្នាំ ១៩៧៦ ដែរ ឬ យ៉ាងណា។

២៣៥.ទាក់ទងទៅនឹងបញ្ហាទីមួយ ផ្អែកលើ"ការពិចារណាយ៉ាងជិតដល់លើដីកាដំណោះស្រាយ" អង្គជំនុំជម្រះ សាលាដំបូងបានយល់ឃើញថា យោងតាមបទចោទប្រឆាំងនឹងជនជាប់ចោទ "ការធ្វើបាបធ្ងន់ធ្ងរលើ*ប្រជាជនថ្មី* ដែលត្រូវបានចាត់ទុកថា ការអប់រំកែប្រែនោះ ត្រូវបានប្រព្រឹត្តដោយមានប្រសិទ្ធភាពជាពិសេសតាមរយៈអំពើ នៃការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ"[573]។ ហេតុនេះ យោងតាមការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង បទចោទបានបង្ហាញថា ការផ្លាស់ទីលំនៅនេះ គឺត្រូវចាត់ជាអំពើធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ជាការពិត ដីកាដំណោះស្រាយ ពុំបានកម្រិតការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ត្រឹមការផ្លាស់ទីលំនៅប្រជាជនដែលបានកើតឡើង ក្នុងការគោលបំណងបែងចែកកម្លាំងពលកម្មសាជាថ្មី និងសម្រេចគោលដៅដែលបានកំណត់ក្នុងផែនការកសិ កម្មរបស់ ប.ក.ក. នោះឡើយ។ ដីកាដំណោះស្រាយបានបញ្ជាក់ថា បើទោះបីជា"គោលដៅមួយក្នុងចំណោម នោះនៃការផ្លាស់ទីលំនៅប្រជាជន គឺដើម្បីបំពេញតាមលក្ខខណ្ឌពលកម្មនៃសហករណ៍ និងការដ្ឋានធ្វើការ"ក៏ ដោយ ក៏"ឯកសាររបស់ ប.ក.ក. ដែលចុះកាលបរិច្ឆេទក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ បង្ហាញគោលដៅចម្បងមួយ ផ្សេង គឺត្រូវដកហូតសិទ្ធិនយោបាយ និងសេដ្ឋកិច្ចរបស់អ្នកទីក្រុង និងអ្នករដ្ឋការស៊ីវិល ហើយប្រែក្លាយពួកគេ ទៅជាកសិករ"[574]។ បើទោះបីជាតាមការពិតភស្តុតាងដែលបានដកស្រង់ដើម្បីគាំទ្រដល់ការចោទប្រកាន់នោះ បានសំដៅទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក៏ដោយ ក៏ដីកាដំណោះស្រាយ (D427) បានចោទ ប្រកាន់ជាក់លាក់ថា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទីពីរ "មានប្រជាជនមួយចំនួនបាន ធ្វើឱ្យបាត់ខ្លួន"[575]។ ដីកាដំណោះស្រាយក៏បានលើកភស្តុតាងបង្ហាញផងដែរថា "ប្រជាជនថ្មី"ត្រូវបានផ្លាស់ទី

---

[573] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥២ (ជើងទំព័រលុបចោល)។

[574] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៦១។

[575] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ២៧០។

លំនៅចេញពីបូព៌ានៅពេលការប្រយុទ្ធជាមួយវៀតណាមបានកើតឡើង (ដែលបង្ហាញថា "ប្រជាជនចាស់"ពុំត្រូវបានផ្លាស់ទីលំនៅ)[576]។ ជាសំខាន់ នៅក្នុងផ្នែកដែលមានការយល់ឃើញផ្នែកអង្គច្បាប់ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដីកាដំណោះស្រាយ (D427) បានចោទប្រកាន់ជាក់លាក់ថា "ប្រជាជនថ្មី"ត្រូវបានកំណត់គោលដៅសម្រាប់ការផ្លាស់ទីលំនៅដោយបង្ខំ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[577]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ក្នុងការសំអាងទៅលើការផ្លាស់ទីលំនៅប្រជាជនដែលបានកើតឡើងសម្រាប់ហេតុផលផ្សេងក្រៅពីហេតុផលសេដ្ឋកិច្ច ដូចជាសម្រាប់គោលបំណង"អប់រំកែប្រែ"។ បញ្ហាដែលថាតើអំពើប្រព្រឹត្តនេះត្រូវបានបង្ហាញនៅក្នុងរឿងក្តីចំពោះមុខ ដែរ ឬយ៉ាងណា និងថាតើអំពើនេះ ត្រូវចាត់ជាបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណានោះ ត្រូវបានពិភាក្សានៅក្នុងសាលដីកានេះ[578]។

២៣៦.ទាក់ទងទៅនឹងបញ្ហា ថាតើអំពើដែលបានកើតឡើងបន្ទាប់ពីការទៅដល់កន្លែងរបស់អ្នកដែលត្រូវបានជម្លៀសនោះ គឺជាផ្នែកនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការផ្លាស់ទីលំនៅប្រជាជនជាក់ស្តែង ស្របតាមអត្ថន័យធម្មតានៃការផ្លាស់ទីលំនៅប្រជាជន ដូចបានកំណត់ដោយដីកាដំណោះស្រាយ (D427) ប៉ុន្តែការប្រព្រឹត្តនៅពេល និងក្រោយការមកដល់របស់ប្រជាជនមិនស្របទៅនឹងអត្ថន័យនៃការផ្លាស់ទីលំនៅប្រជាជនឡើយ។ បន្ថែមលើនេះទៀត ការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការបំបែកសំណុំរឿង បានបញ្ជាក់ថា អំពើដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍ និងការដ្ឋានធ្វើការពុំមែនជាផ្នែកនៃបទចោទដែលបានជំនុំជម្រះក្នុងសំណុំរឿង ០០២/០១[579] ហើយអង្គជំនុំជម្រះសាលាដំបូងពុំបានដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើ*សត្យានុម័ត*

---

[576] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ២៧៨។

[577] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៤៦៨។

[578] *សូមមើលខាងក្រោម* កថាខណ្ឌ ៦៩៨ *ជាអាទិ៍*។

[579] *សូមមើល* ដីកាបំបែកកិច្ចដំណើរការនីតិវិធី (E124) កថាខណ្ឌ ៧ "ពុំមានសហករណ៍ ការដ្ឋានធ្វើការ មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬអង្គហេតុពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅដំណាក់កាលទីបី នឹងត្រូវពិនិត្យនៅក្នុងអំឡុងពេលនៃការជំនុំជម្រះទីមួយ"។

ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទាំងនេះឡើយ[580]។ ទោះជាយ៉ាងណាក្តី ការបំបែកសំណុំរឿងពុំបានកម្រិតសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងមិនឱ្យពិចារណាលើព្រឹត្តិការណ៍នៅមុន ឬក្រោយបទចោទដែលអាចមានការជាប់ពាក់ព័ន្ធក្នុងការបង្ហាញអង្គហេតុដែលជាមូលដ្ឋាននៃបទចោទនោះ។ ជាឧទាហរណ៍ ភស្តុតាងអាកប្បកិរិយាដែលបានកើតឡើងភ្លាមៗនៅមុន ឬក្រោយការផ្លាស់ទីលំនៅប្រជាជនអាចត្រូវបានយកមកពិចារណាក្នុងការបង្ហាញពីលំនាំនៃអំពើប្រព្រឹត្ត ឬផ្នត់គំនិតរបស់ចារីនៅក្នុងអំឡុងពេលនៃអង្គហេតុ។ ជាពិសេស ការយល់ឃើញនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការធ្វើបាប“ប្រជាជនថ្មី” នៅតាមទីកន្លែងដែលពួកគាត់ទៅដល់ បានផ្តល់អំពីបរិបទផ្នែកអង្គហេតុនៃផលវិបាកនៃការផ្លាស់ទីលំនៅប្រជាជន ដែលអាចមានការជាប់ពាក់ព័ន្ធទៅនឹងការកំណត់អំពីគោលបំណង។ អាស្រ័យហេតុនេះ បញ្ហាដែលដីកាដំណោះស្រាយ (D427) បានយោងជាក់លាក់ទៅលើព្រឹត្តិការណ៍នៅគុក តានៃ ភ្នំ ស្រុក និងមន្ទីរសន្តិសុខ ថ្កោល[581]នោះជាការពុំជាប់ពាក់ព័ន្ធ ដោយសារព្រឹត្តិការណ៍នេះនៅគ្រប់កាលៈទេសៈទាំងអស់ពុំអាចក្លាយជាមូលដ្ឋានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពក្នុងសំណុំរឿង ០០២/០១បានឡើយ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ហេតុការណ៍ដែលប្រជាជនត្រូវបានផ្លាស់ទីលំនៅទៅកាន់ទីកន្លែងផ្សេងដែលខុសពីកន្លែងពួកគេបានប្រាប់ និងការបំបែកក្រុមគ្រួសារបានកើតឡើងបន្ទាប់ពីការផ្លាស់ទីលំនៅប្រជាជននោះ ត្រូវបានបញ្ចប់ដូច្នេះស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ នោះឡើយ។ ជាការពិត ការចោទប្រកាន់ទាំងនេះបានលើកឡើងជាពិសេសនៅក្នុងដីកាដំណោះស្រាយ (D427) នៅក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[582]។ ចុងបញ្ចប់ ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ក្នុងការយល់ឃើញថា ខ្មែរក្រហមបានបាញ់ប្រហារប្រជាជននៅពេលទៅដល់ទីកន្លែងដែលពួកគាត់ត្រូវទៅនោះ[583] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន បានដកស្រង់ពុំត្រឹមត្រូវនូវសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញ

---

[580] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំង កថាខណ្ឌ ៦៥៤ ដែលពិពណ៌អំពើរើសអើងដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនជាក់ស្តែង។ *សូមមើលផងដែរ* កថាខណ្ឌ ៦៥៦ ដែលបញ្ជាក់អំពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដែលនេះជាអំពើរើសអើង។

[581] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៥។

[582] ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ២៧០។

[583] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៧។

01358072



ថា ប្រជាជនត្រូវបានបាញ់ប្រហារនៅពេលទៅដល់ទីកន្លែងដែលពួកគាត់ត្រូវទៅនោះឡើយ[584]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់គាត់ត្រូវបដិសេធចោល។

២៣៧.ទាក់ទងទៅនឹងវិសាលភាពពេលវេលានៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយ (D427) ខៀវ សំផន បានអះអាង[585]ថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីរដងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីថា វិសាលភាពនេះត្រូវបានកម្រិតត្រឹមអំឡុងពេលរហូតដល់ចុងឆ្នាំ ១៩៧៦ និងបានយោងទៅលើការលើកឡើងចំនួនពីររបស់ចៅក្រម CARTWRIGHT កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១២ ដែលថា អំឡុងពេលពាក់ព័ន្ធគិតចាប់ពីឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៦[586]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដូចអង្គជំនុំជម្រះសាលាដំបូងបានពន្យល់ ដីកាដំណោះស្រាយ (D427) បានបញ្ជាក់ច្បាស់ថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរបានពន្លាតដល់ឆ្នាំ ១៩៧៧[587] ហើយដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបានយោងទៅលើផ្នែកនោះនៃការផ្លាស់ទីលំនៅប្រជាជន ដោយពុំបានបញ្ជាក់អំពីការកម្រិតពេលវេលាណាមួយឡើយ។ ប្រសិនបើការលើកឡើងរបស់ចៅក្រម CARTWRIGHT នៅក្នុងអំឡុងពេលនៃការជំនុំជម្រះនោះបានបណ្ដាលឱ្យមានការភាន់ច្រឡំពីសំណាក់ ខៀវ សំផន គាត់គប្បីសួរបញ្ជាក់បញ្ហានេះ។ ទោះបីជាយ៉ាងណាក្ដី ខៀវ សំផន ពុំបានលើកបញ្ហានេះរហូតដល់ពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល[588]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើហួសវិសាលភាពពេលវេលានៃបទចោទទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ហើយអង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ខៀវ សំផន ពុំត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីវិសាលភាពនេះឡើយ។

២៣៨.ចំពោះអំណះអំណាងដែលថា ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីព្រំដែនវៀតណាមសម្រាប់គោលបំណងអប់រំកែប្រែ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទាំងស្រុងទៅលើភស្តុតាងក្រៅវិសាល

---

[584] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។ កថាខណ្ឌនេះមានឃ្លាថា "ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ឬពេលទៅដល់" ទន្ទឹមនឹងនេះក៏មានជាប់ពាក់ព័ន្ធទៅនឹងកង្វះក្នុងការផ្ដល់ស្បៀងអាហារ ទឹក និងទីជម្រក។

[585] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១។

[586] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារលេខ E1/91.1 ទំព័រ ១៧ ដល់ ១៨។

[587] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២៩។

[588] *សូមមើល* សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (E295/6/4) (ភាសាបារាំង) កថាខណ្ឌ ៦១។

ភាពពេលវេលានៃសំណុំរឿង ០០២/០១[589] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជាការពិត ភស្តុតាងដែលអង្គជំនុំជម្រះបានសំអាងទៅលើក្នុងការបង្ហាញថា "*សមាសភាពមិនល្អ*ត្រូវបានផ្លាស់ទីលំនៅទៅកាន់ជួរក្រោយសម្រាប់អប់រំកែប្រែ បែងចែក និងសម្រិតសម្រាំង"[590] ទាំងអស់នេះសុទ្ធតែពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងក្នុងឆ្នាំ ១៩៧៨ បន្ទាប់ពីការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរបានបញ្ចប់ ដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយ (D427)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការបង្ហាញឱ្យឃើញខុសគ្នារវាងដំណាក់កាលនីមួយៗនៅក្នុងការផ្លាស់ទីលំនៅប្រជាជន ដែលបានត្រូវបានប្រើប្រាស់នៅក្នុងបទចោទ អាចជួយដល់ការពិចារណាអំពីអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក្តី ការបំបែកសំណុំរឿងដោយផ្អែកតាមការបែងចែកនេះ នាំទៅរកការបំបែកជាផ្នែកដាច់ដោយឡែកពីគ្នានៃព្រឹត្តិការណ៍ជាប្រវត្តិដែលរងការចោទប្រកាន់នោះ។ ដោយផ្អែកលើវិសាលភាពនៃសំណុំរឿង ០០២/០១ នេះ អង្គជំនុំជម្រះសាលាដំបូង ពុំអាចដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើអំពើដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដែលបានកើតឡើងក្រោយឆ្នាំ ១៩៧៧ បានឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ទាក់ទងទៅនឹងបញ្ហានេះថា អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងពុំបានធ្វើដូច្នោះដែរ ព្រោះក្នុងផ្នែកនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានសេចក្តីសន្និដ្ឋានផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពុំមានការយោងណាមួយទៅលើការយល់ឃើញពីដំបូងដែលបានផ្អែកលើអង្គហេតុដែលបានកើតឡើងក្នុងឆ្នាំ ១៩៧៨ ឡើយ[591]។

២៣៩.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងវិសាលភាពនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។

## ៤.គ.វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកភស្តុតាង

២៤០.នួន ជា និង ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសជាច្រើនក្នុងវិធីសា

---

[589] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៧២។

[590] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២៥។

[591] បើទោះបីជាកថាខណ្ឌ ៦២៥ នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលពាក់ព័ន្ធ បានយោងទៅលើកថាខណ្ឌ ៦៥៥ ជើងទំព័រ ២០៥៦ ក៏ដោយ ក៏នេះពុំស្ថិតក្នុងបរិបទនៃការយល់ឃើញទាក់ទងទៅនឹងការអប់រំកែប្រែ"សមាសភាពមិនល្អ"ដែលត្រូវបានផ្លាស់ទីលំនៅចេញពីព្រំដែនវៀតណាម។

ស្រ្តទទួលយកភស្តុតាង ដែលក្នុងនោះរួមមាន (i) ការកម្រិតឱកាសសម្រាប់ការស៊ើបសួរក្នុងពេលជំនុំជម្រះ[592] (ii) ការអនុញ្ញាតឱ្យសាក្សីពិនិត្យលើចម្លើយពីមុនរបស់ខ្លួនមុនពេលផ្តល់សក្ខីកម្ម និងការឆ្លើយចំពោះសំណួរនាំមុខដោយផ្អែកលើចម្លើយពីមុននោះ[593] (iii) ការរឹតត្បិតពុំត្រឹមត្រូវលើវិសាលភាពនៃការសាកសួរសាក្សីរបស់ភាគីម្ខាងដោយភាគីម្ខាងទៀត[594] (iv) ការទទួលយក និងសំអាងលើចម្លើយជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់[595] (v) ការសំអាងលើភស្តុតាងចចាមអារ៉ាម[596] (vi) ការសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមកធ្វើជាភស្តុតាងសត្យានុម័ត[597] (vii) ការសំអាងលើសក្ខីកម្មរបស់អ្នកជំនាញ និងប្រភពមិនផ្ទាល់មកធ្វើជាភស្តុតាងផ្ទាល់[598] និង (viii) ការវាយតម្លៃសាក្សីអង្គហេតុពុំត្រឹមត្រូវ[599]។

២៤១.នួន ជា បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មពុំអាចទទួលយកបានឡើយ នៅគ្រប់កាលៈទេសៈទាំងអស់[600]។

២៤២.បន្ថែមលើនេះ ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលក្នុងនោះរួមមាន (i) ការបង្ហាញឯកសារដល់សាក្សីដែលឯកសារនោះសាក្សីពុំស្គាល់[601] (ii) ការបដិសេធការទាមទាររបស់មេធាវីការពារក្តីទាក់ទងទៅនឹងការបង្ហាញសំណៅដើមនៃឯកសារ និងដំណើរនៃការរក្សាទុកឯកសារ[602] (iii)

---

592 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣០ ដល់ ៣៩, ១៣០ ដល់ ១៣១ និង ១៣៣ ដល់ ១៣៤។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥។

593 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៥ ដល់ ១៤៧។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៦។

594 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤៨ ដល់ ១៥៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១។

595 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥៤ ដល់ ១៦៥។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩ និង ១១៧។

596 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៦ ដល់ ១៧១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១៦។

597 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៥ ដល់ ២០៦។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣០។

598 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០៧ ដល់ ២១១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤ និង ១១៨។

599 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧២ ដល់ ១៨៤។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣ និង ១១៤ ដល់ ១១៥។

600 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧០៦ ដល់ ៧២២។

601 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧។

602 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨។

01358075



ការទទួលយកឯកសារដោយគ្មានការពិភាក្សាដេញដោល[603] និង (iv) ការសំអាងលើបទដ្ឋានពុំត្រឹមត្រូវស្តីពីបន្ទុកនៃការបង្ហាញភស្តុតាង[604]។

២៤៣.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងមានហេតុផលសមស្របក្នុងការប្រើប្រាស់វិធីសាស្ត្រទទួលយកភស្តុតាងនៅពេលជំនុំជម្រះ និងថា នួន ជា និង ខៀវ សំផន ពុំបានបង្ហាញពីកំហុសណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិនោះឡើយ[605]។

## ៤.គ.១.ការកម្រិតឱកាសក្នុងការសើុបសួរក្នុងពេលជំនុំជម្រះ

២៤៤.ជាការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន និង នួន ជា ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងលើភស្តុតាងដែលកើតចេញពីការសើុបសួរមានភាពខុសឆ្គងដោយមានកំហុសនីតិវិធី និងមានជាប់ពាក់ព័ន្ធទៅនឹងការជ្រៀតជ្រែកផ្នែកនយោបាយ ដែលនាំឱ្យមានការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកការសម្រេចពីមុនរបស់ខ្លួនថា "នៅក្នុងដំណាក់កាលមុនអង្គសេចក្តី ជនជាប់ចោទបានប្រើប្រាស់យ៉ាងទូលំទូលាយនូវការធានាផ្នែកនីតិវិធីដែលមានក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. ដើម្បីដោះស្រាយវិការៈនៅក្នុងការសើុបសួរនៅចំពោះមុខសហចៅក្រមសើុបអង្កេត ឬនៅក្នុងបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ"[606]។ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមទៀតថា "ទោះជាយ៉ាងនេះក្តី ក្នុងករណីវិការៈក្នុងការសើុបសួរដែលរងការចោទប្រកាន់ទាំងនោះ មានភាពជាក់លាក់គ្រប់គ្រាន់ និងពាក់ព័ន្ធច្បាស់លាស់ទៅនឹងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះនឹងពិចារណាលើបញ្ហាទាំងនេះនៅក្នុងការវាយតម្លៃលើភ័ស្តុតាងជាចុងក្រោយរបស់ខ្លួន"[607]។

២៤៥.នៅដំណាក់កាលបណ្តឹងសាទុក្ខ នួន ជា និង ខៀវ សំផន បានអះអាងម្តងទៀតថា ការសើុបសួរពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ មានកំហុសធ្ងន់ធ្ងរ និងមានអនិយ័តភាពផ្នែកនីតិវិធីជាច្រើន ដែលនាំឱ្យមានភាពមិន

---

[603] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦។

[604] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៨ ដល់ ១១៣ និង ១១៩។

[605] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៨ ដល់ ១១០។

[606] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤២។

[607] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤២។

ត្រឹមត្រូវ និងមានផលប៉ះពាល់[608]។ ពួកគាត់បានអះអាងថា ភាគីការពារក្តីបានព្យាយាមលើកឡើងច្រើនដង ចំពោះមុខអង្គជំនុំជម្រះនូវក្តីបារម្ភ ក្នុងគោលបំណងទទួលបានដំណោះស្រាយនៅដំណាក់កាលជំនុំជម្រះចំពោះការខ្វះខាតមួយចំនួន ដែលបានបង្កឡើងនៅដំណាក់កាលស៊ើបសួរមានដូចជា ការស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបើកការស៊ើបសួរបន្ថែមជាដើម និងបានអះអាងថា ការបដិសេធចំពោះសំណើទាំងនេះ គឺជាកំហុស[609]។ ជាពិសេស នួន ជា បានរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា គាត់ពុំមានសិទ្ធិបើកកិច្ចស៊ើបសួរផ្ទាល់ខ្លួនឡើយ[610] ក្នុងខណៈដែលអង្គជំនុំជម្រះបានបដិសេធសំណើរបស់គាត់សុំឱ្យចាត់វិធានការស៊ើបសួរដោយខ្លួនឯងលើចំណុចដែលសហចៅក្រមស៊ើបអង្កេតពុំបានបំពេញកិច្ចស៊ើបសួរ[611]។ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសនោះ គឺកម្រិតត្រឹមការអះអាងថា កិច្ចស៊ើបសួរបន្ថែមគប្បីត្រូវបានធ្វើឡើងដើម្បីបង្ហាញឱ្យឃើញអំពីកំហុសផ្នែកនីតិវិធីនៅក្នុងកិច្ចស៊ើបសួរ[612]។

២៤៦.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការបដិសេធសំណើសុំឱ្យស៊ើបសួរបន្ថែម និងថា អំណះអំណាងរបស់ នួន ជា និង ខៀវ សំផន ពុំបានលើកឡើងពីកំហុស ឬការប៉ះពាល់ណាមួយឡើយ[613]។

២៤៧.អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា កំហុសដែល នួន ជា បានចោទប្រកាន់លើអង្គជំនុំជម្រះសាលាដំបូងមានពីរចំណុចគឺ ទីមួយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលថា ភាគីការពារក្តីពុំមានសិទ្ធិក្នុងការស៊ើបសួរ និងទីពីរ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលបានបដិសេធសំណើរបស់គាត់សុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម។ សំណើនេះនឹងត្រូវដោះស្រាយដូចខាងក្រោម។

---

[608] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣០ ដល់ ៣៨ និង ១៣០ ដល់ ១៣១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥។

[609] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩ និង ១៣៣ ដល់ ១៣៤។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥។

[610] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៣ ជើងទំព័រ ៣៣១ *យោងទៅលើ* អនុស្សរណៈស្តីពីការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) (E211/2) កថាខណ្ឌ ៤។

[611] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៤ *យោងទៅលើ*សេចក្តីសម្រេចស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116) កថាខណ្ឌ ១៩ ដល់ ២០ និងសំណើសុំបើកកិច្ចស៊ើបសួរតាមវិធាន ៩៣ (E88)។

[612] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥។

[613] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៨ ដល់ ៧៩ និង ១០៨ ដល់ ១០៩។

២៤៨.ក្របខ័ណ្ឌនីតិវិធីរបស់ អ.វ.ត.ក. ពុំបានចែងអំពីកិច្ចស៊ើបសួរដែលត្រូវតែធ្វើឡើងឱ្យបានពេញលេញទៅតាមការស្នើសុំរបស់ភាគី ដូចការស៊ើបសួរនៅក្នុងប្រព័ន្ធដេញដោលចំពោះមុខឡើយ។ ផ្ទុយទៅវិញ ដោយស្របទៅនឹងទម្លាប់នៃនីតិវិធីជាទូទៅរបស់កម្ពុជា កិច្ចស៊ើបសួរនៅ អ.វ.ត.ក. ត្រូវធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលមានសិទ្ធិអំណាចយ៉ាងទូលំទូលាយក្នុងការស៊ើបសួរដែលបានកំណត់នៅក្នុងវិធាន ៥៥ នៃវិធានផ្ទៃក្នុង ដូចជា ការចេញដីកានានាដើម្បីបំពេញកិច្ចស៊ើបសួរក្នុងករណីចាំបាច់ ការចុះដល់ទីកន្លែង ស្តាប់ចម្លើយសាក្សី ធ្វើការឆែកឆេរ ចាប់យកវត្ថុតាង ការបង្គាប់ឱ្យធ្វើកោសលវិច័យ ជាដើម[614]។ នៅដំណាក់កាលជំនុំជម្រះ អង្គជំនុំជម្រះអាចបំពេញកិច្ចស៊ើបសួរបន្ថែមបាន ដោយមានសិទ្ធិអំណាចយ៉ាងទូលំទូលាយក្នុងការស៊ើបសួរប្រហាក់ប្រហែលគ្នាដូចមានកំណត់ក្នុងវិធាន ៩៣ នៃវិធានផ្ទៃក្នុង[615]។ សិទ្ធិអំណាចនេះអាចប្រើប្រាស់ផងដែរនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ[616]។

២៤៩.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា វិធានជាធរមាននៅចំពោះមុខ អ.វ.ត.ក. ពុំបានចែងអំពីការផ្ទេរអំណាចទាំងនេះទៅឱ្យភាគីណាមួយធ្វើការជំនួសឡើយ[617]។ ដូច្នេះ ទាក់ទងទៅនឹងការទាមទាររបស់ នួន ជា ដើម្បីទទួលបានសិទ្ធិអំណាចស៊ើបសួរពីអង្គជំនុំជម្រះសាលាដំបូងតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការបដិសេធសំណើរបស់គាត់ឡើយ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា ពុំមានមូលដ្ឋានផ្លូវច្បាប់ ឬមូលហេតុជាក់ស្តែងគួរឱ្យជឿជាក់ដែលហាមឃាត់ភាគីការពារក្តីធ្វើការស៊ើបសួរស្វែងរកភស្តុតាងពាក់ព័ន្ធ ដរាបណាការស៊ើបសួរនោះមិននាំឱ្យមានការប៉ះពាល់ដល់សាក្សី ឬការបំភ្លៃភស្តុតាងឡើយ។ ជាពិសេស ភាគីការពារក្តីគប្បីត្រូវបានអនុញ្ញាតបើកកិច្ចស៊ើបសួរក្នុងកម្រិតមួយ ដែលតម្រូវសម្រាប់បំពេញចំណុចទីមួយនៃបទដ្ឋានស្តីពីភាពអាចទទួលយកបានចំពោះសំណើសុំបើកកិច្ចស៊ើបសួរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ជាអាទិ៍ កិច្ចស៊ើបសួរដែលស្នើសុំ“ត្រូវតែបង្ហាញអំពី

---

[614] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគន្ថី ៤៖ ការស៊ើបអង្កេត។

[615] *សូមមើលផងដែរ* មាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[616] សេចក្តីសម្រេចទីមួយបណ្តោះអាសន្នស្តីពីកិច្ចស៊ើបសួរបន្ថែម (F2/4/3) កថាខណ្ឌ ១៩។

[617] ជាឧទាហរណ៍ សិទ្ធិអំណាចក្នុងការស៊ើបសួររបស់អង្គជំនុំជម្រះសាលាដំបូង អាចត្រឹមតែប្រគល់ទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌ដើម្បីអនុវត្តដីកាចាត់ឱ្យសួរជំនួសប៉ុណ្ណោះ។ *សូមមើល* វិធាន ៩៣(៣) នៃវិធានផ្ទៃក្នុង។

ភាពជាក់លាក់គ្រប់គ្រាន់"[618] ដូចជា ការកំណត់អត្តសញ្ញាណសាក្សីសក្តានុពល។ ជាអប្បបរមា គប្បីមានភាពបត់បែនទៅតាមហេតុការណ៍នីមួយៗនៅពេលពិចារណាទៅលើអត្ថប្រយោជន៍ដែលជាប់ពាក់ព័ន្ធនោះ។

២៥០.ទាក់ទងទៅនឹងកំហុសពាក់ព័ន្ធទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបំពេញកិច្ចស៊ើបសួរបន្ថែម និងរំឭកថា នៅចន្លោះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៨ ដល់ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០ នួន ជា បានដាក់សំណើចំនួន ២៦ ទៅកាន់សហចៅក្រមស៊ើបអង្កេត[619] សុំឱ្យបំពេញកិច្ចស៊ើបសួរ។ នួន ជា បានអះអាងថា "ស្ទើរតែគ្រប់ករណីទាំងអស់ដែល[សហចៅក្រមស៊ើបអង្កេត]បដិសេធ[សំណើសុំបំពេញកិច្ចស៊ើបសួរ]ជាក់លាក់(មួយផ្នែក ឬទាំងស្រុងដែរ) ឬមិនបានចាត់វិធានការឱ្យបានគ្រប់គ្រាន់ចំពោះកិច្ចដែលបានស្នើសុំ" និងថា "ចំពោះការប្ដឹងឧទ្ធរណ៍វិញ វិធីសាស្ត្ររបស់[សហចៅក្រមស៊ើបអង្កេត]ត្រូវបានយល់ស្របដោយអង្គបុរេជំនុំជម្រះ"[620]។ ក្នុងការសម្រេចបដិសេធសំណើសុំរបស់ នួន ជា អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សំអាងហេតុ*ក្នុងចំណោមនោះ* មានដូចតទៅ៖

> ក្នុងអំឡុងពេលស៊ើបសួរដែលបានប្រើរយៈពេលជិតពីរឆ្នាំកន្លះនោះ ជនជាប់ចោទមានឱកាសច្រើនដើម្បីស្នើសុំឱ្យ[សហចៅក្រមស៊ើបអង្កេត]បំពេញនូវរាល់កិច្ចស៊ើបសួរ ដែលជនជាប់ចោទយល់ឃើញថា មានភាពពាក់ព័ន្ធ ហើយក៏មានឱកាសក្នុងការតវ៉ាទៅនឹងការបដិសេធណាមួយរបស់[សហចៅក្រមស៊ើបអង្កេត]លើសំណើសុំទាំងនេះ ទៅអង្គបុរេជំនុំជម្រះផងដែរក្នុងករណីចាំបាច់។ នៅពេលដែលមានការបដិសេធពី[សហចៅក្រមស៊ើបអង្កេត]ទៅលើ[សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយ] ដោយយល់ថា ជាការលម្អៀងទៅរកភស្តុតាងដាក់បន្ទុក សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ត្រូវបានធានាដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ។ ជនជាប់ចោទមិនបានបង្ហាញថា មូលហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងពេលនោះ ត្រូវតែយល់ព្រមតាម[សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនានា]ដែលបានគូសបញ្ជាក់ដើម្បីធានានូវភាពយុត្តិធម៌នៃការជំនុំជម្រះក្ដីនោះទេ[621]។

---

[618] សេចក្ដីសម្រេចស្ដីពីកិច្ចស៊ើបសួរអំពីបទឧក្រិដ្ឋនៃការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ (004-D301/5) កថាខណ្ឌ ៣៣។

[619] *សូមមើល* សំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង (E88) កថាខណ្ឌ ៣(ក ដល់ ន) និងសេចក្ដីយោងដកស្រង់នៅទីនោះ។

[620] សំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង (E88) កថាខណ្ឌ ៤។

[621] សេចក្ដីសម្រេចស្ដីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116) កថាខណ្ឌ ១៩ (ដើងទំព័រលុបចោល) *សូមមើលផងដែរ* កថាខណ្ឌ ២០ ("ទាក់ទងទៅនឹងសំណើរបស់ជនជាប់ចោទសុំបើកកិច្ចស៊ើបសួរទាក់ទងទៅនឹងព្រឹត្តិការណ៍ពុំស្ថិតក្នុងអំឡុងពេលនៃការចោទប្រកាន់

២៥១.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា វិធាន ៩៣ នៃវិធានផ្ទៃក្នុងបានផ្តល់ឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែម"គ្រប់ពេលទាំងអស់" ប្រសិនបើខ្លួនយល់ឃើញថា ជាការ"ចាំបាច់"។ ដូច្នេះ ភាគីដែលស្នើសុំការស៊ើបសួរបន្ថែមត្រូវតែបង្ហាញឱ្យឃើញថា មានភាពចាំបាច់។ នៅក្នុងសំណើសុំទៅអង្គជំនុំជម្រះសាលាដំបូង នួន ជា បានសំអាងលើសារណាពីមុនៗរបស់ខ្លួនដែលបានធ្វើឡើងទៅសហចៅក្រមស៊ើបអង្កេត[622] ដោយបានបញ្ជាក់ថា "ទាក់ទងទៅនឹងភាពចាំបាច់(ក្នុងវិធាន ៩៣(១) នៃវិធានផ្ទៃក្នុង) នៃកិច្ចស៊ើបសួរជាក់លាក់នីមួយៗដែលបានស្នើសុំ មេធាវីការពារក្តីសូមដាក់បញ្ចូលអំណះអំណាងដែលបានលើកឡើងនៅក្នុង[សំណើសុំបំពេញកិច្ចស៊ើបសួរនីមួយៗ] និងក្នុងបណ្តឹងឧទ្ធរណ៍ជាបន្តបន្ទាប់"[623]។ នួន ជា ក៏បានលើកឡើងផងដែរថា កិច្ចស៊ើបសួរនេះ គឺ"ចាំបាច់ដើម្បីកែកំហុសនានាដែលកើតឡើងក្នុងកិច្ចស៊ើបសួរ និងជាចុងក្រោយ ដើម្បីធានាដំណើរការនីតិវិធីជំនុំជម្រះក្តីដោយយុត្តិធម៌"[624]។

២៥២.ក្នុងការវាយតម្លៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវពិចារណាលើចំណុចពីរដូចតទៅ ទីមួយ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងចែងថា "លើកលែងតែកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ" និងបន្ថែមថា "គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធទៅនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"។ ជាផលវិបាក អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើមោឃភាពនីតិវិធី ដែលត្រូវបានធ្វើ"បន្ទាប់ពីមានដីកាដំណោះស្រាយ"[625]។ អាស្រ័យហេតុនេះ ត្រឹមតែថា មានកំហុសនីតិវិធីនៃកិច្ចស៊ើបសួរ ពុំអាចបង្ហាញថា មានភាពចាំបាច់ដូចមានចែងនៅក្នុងវិធាន ៩៣ នៃវិធានផ្ទៃក្នុង ហើយបទប្បញ្ញត្តិនេះពុំអាចយកមកសំអាងដើម្បីឱ្យរួចផុតពីការសម្រេចចុងក្រោយរបស់សហ

---

អង្គជំនុំជម្រះកត់សម្គាល់ឱ្យឃើញថា អង្គជំនុំជម្រះត្រូវថ្លឹងថ្លែងសំណើនេះជាមួយនឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាថា សិទ្ធិរបស់ជនជាប់ចោទទទួលបានការជំនុំជម្រះដោយឆាប់រហ័ស។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានសម្រេចរួចហើយថា បញ្ហាតាមបរិបទដែលជាប្រវត្តិ និងព្រឹត្តិការណ៍ក្រៅយុត្តាធិការពេលវេលានៃ អ.វ.ត.ក. នឹងត្រូវពិចារណាតែក្នុងករណីដែលពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក. និងវិសាលភាពនៃការជំនុំជម្រះដូចអង្គជំនុំជម្រះបានកំណត់តែប៉ុណ្ណោះ")។

[622] សំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង (E88) កថាខណ្ឌ ៣ ដល់ ៥, ១៣ និង ១៨។

[623] សំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង (E88) កថាខណ្ឌ ១៨ (ជើងទំព័រលុបចោល)។

[624] សំណើសុំបំពេញកិច្ចស៊ើបសួរតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង (E88) កថាខណ្ឌ ១។

[625] វិធាន ៨៩ (១-គ) នៃវិធានផ្ទៃក្នុង។

ចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានតួនាទីជាតុលាការនៃបណ្តឹងឧទ្ធរណ៍ ក្នុងការសម្រេចលើការចោទប្រកាន់អំពីកំហុសសាជាថ្មីលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះនោះទេ[626]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងផ្អែកទៅតាមលក្ខខណ្ឌនៃភស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះតាមរយៈការិយាល័យនានារបស់តុលាការ។

២៥៣.នេះមានន័យថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចដាច់ដោយឡែកដែលឯករាជ្យពីសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ក្នុងការកំណត់វាល់កាលៈទេសៈដែលពាក់ព័ន្ធសម្រាប់ការជំនុំជម្រះរឿងក្តី។ ក្នុងការបន្តនីតិវិធី កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជាប់ពាក់ព័ន្ធទៅនឹងភស្តុតាងក្នុងកម្រិតខ្ពស់ជាង។ មេធាវីការពារក្តីមានសិទ្ធិស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបើកកិច្ចស៊ើបសួរបន្ថែម ដើម្បីកាត់បន្ថយអានុភាពនៃការយល់ឃើញដែលបានធ្វើឡើងនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ។ ក្នុងស្ថានភាពបែបនេះ កិច្ចស៊ើបសួរត្រូវបានធ្វើឡើងពុំមែនក្នុងន័យជំទាស់ ឬពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនោះទេ ប៉ុន្តែ ដើម្បីបង្ហាញការពិតដែលអាចខុសប្លែកពីការយល់ឃើញផ្អែកអង្គហេតុដែលបានធ្វើឡើងនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ។ ទោះជាយ៉ាងណាក្តី បញ្ហា គឺស្ថិតត្រង់ថាតើក្តីបារម្ភជាក់លាក់របស់ នួន ជា ពាក់ព័ន្ធទៅនឹងមូលដ្ឋានភស្តុតាងនៃរឿងក្តីនោះ ចាំបាច់ឱ្យមានកិច្ចស៊ើបសួរបន្ថែម ដែរ ឬយ៉ាងណា។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងមានការយល់ដឹងយ៉ាងទូលំទូលាយ ហើយដើម្បីលើកឡើងឱ្យបានជោគជ័យនៅដំណាក់កាលបណ្តឹងសាទុក្ខ ជនជាប់ចោទចាំបាច់ត្រូវបង្ហាញថា វិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល និងបណ្តាលឱ្យមានការប៉ះពាល់ដល់ខ្លួន។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដំណោះស្រាយដទៃទៀតសម្រាប់ការកែតម្រូវកំហុសនីតិវិធីនៅក្នុងកិច្ចស៊ើបសួរ មានដូចជា៖

> ជនជាប់ចោទមានឱកាសក្នុងការស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីដោះបន្ទុក បង្ហាញភស្តុតាងជាឯកសារ ឬភស្តុតាងផ្សេងទៀតដែលចាំបាច់ដើម្បីបញ្ជាក់ការពិត សួរសំណួរទៅកាន់សាក្សីរបស់ភាគីម្ខាងទៀត និងតតាំងជាមួយភស្តុតាងនានា ព្រមទាំងការចោទប្រកាន់ផ្សេងៗមកលើគាត់ ដែលជាការជួសជុលភាពខ្វះចន្លោះនៃកិច្ចស៊ើបសួរដែលត្រូវបានចោទប្រកាន់មកទល់នឹងពេលនេះ[627]។

---

[626] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ឯកសារលេខ (E116/1/7) កថាខណ្ឌ ៣២។

[627] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116) កថាខណ្ឌ ១៩ (ជើងទំព័រលុបចោល)។

២៥៤.ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឮកសេចក្តីសម្រេចពីមុនរបស់ខ្លួនដែលមានអត្ថន័យដូចគ្នាថា៖

> បញ្ហាដែលពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ជនជាប់ចោទ គឺទាក់ទងទៅនឹងសាក្សីមួយចំនួនដែលបានស្នើដោយមេធាវីការពារក្តីដែលសាក្សីទាំងនេះ មិនទាន់បានស្តាប់ចម្លើយនៅក្នុងដំណាក់កាលស៊ើបអង្កេត។ បញ្ហានេះត្រូវតែសម្រេចនៅក្នុងអំឡុងពេលសវនាការនៃសំណុំរឿង ០០២ ដែលកំពុងបន្ត និងផ្តល់លទ្ធភាពច្រើនក្នុងការដោះស្រាយក្តីបារម្ភដែលថា អាចមានការរារាំងដោយពុំត្រឹមត្រូវនូវភស្តុតាងដោះបន្ទុកនៅពេលសវនាការ។ ជាឧទាហរណ៍ បញ្ហាអាស្រ័យលើ ថាតើមេធាវីការពារក្តីទទួចស្នើសុំភស្តុតាង ដែរ ឬយ៉ាងណា ថាតើ សំណើសុំនោះអាចទទួលយកបានតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា ថាតើអង្គហេតុនៃសក្ខីកម្មដែលបានស្នើឡើងនោះ រងការជំទាស់ ដែរ ឬយ៉ាងណា ថាតើសាក្សីដែលត្រូវបានកោះហៅបានបង្ហាញខ្លួន ដែរ ឬយ៉ាងណា និងប្រសិនបើពុំបានបង្ហាញខ្លួននោះ ថាតើអង្គហេតុនៃសក្ខីកម្មរបស់សាក្សីនេះ អាចត្រូវបានបង្ហាញ ដែរ ឬយ៉ាងណា[628]។

២៥៥.អាស្រ័យហេតុនេះ ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកម្រិតឱកាសសម្រាប់កិច្ចស៊ើបសួរបន្ថែមនៅពេលជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នួន ជា និង ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង ទីមួយ បានរំលោភឆន្ទានុសិទ្ធិ និងទីពីរ *ជាពិសេស* ពុំបានបង្ហាញថា សេចក្តីសម្រេចនេះមានការប៉ះពាល់ដល់ពួកគាត់ឡើយ។ ទាក់ទងទៅនឹងការតវ៉ារបស់ នួន ជា ពាក់ព័ន្ធទៅនឹងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងពុំបើកកិច្ចស៊ើបសួរទៅលើសម្ភារ ដែលមាននៅក្នុងដៃរបស់អ្នកផលិតខ្សែវីដេអូ គឺ ថេត សម្បត្តិ និង Robert LEMKIN[629] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជាសន្មតថា សេចក្តីសម្រេចនោះក្លាយទៅជាមោឃៈ ដោយសារ *ក្នុងចំណោមនោះ* កំហុសឆ្គងដែលអង្គជំនុំជម្រះតុលាការកំពូលបានរកឃើញ[630]ក៏ដោយ ក៏នេះពុំបានធ្វើឱ្យជនជាប់ចោទទទួលរងផលប៉ះពាល់ដែរ ដោយហេតុថា បន្ទាប់ពីបានបើកកិច្ចស៊ើបសួរដោយខ្លួនឯង តាមការស្នើសុំ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា សម្ភារដែល នួន ជា បានស្នើសុំនោះ ពុំជាប់ពាក់ព័ន្ធទៅនឹងធាតុផ្សំណាមួយនៃឧក្រិដ្ឋកម្មដែលខ្លួនត្រូវបានសម្រេចដាក់ពិរុទ្ធភាពឡើយ[631]។ អំណះអំណាងផ្សេងទៀតរបស់ នួន ជា គឺជាប់ពាក់ព័ន្ធទៅ

---

[628] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116/1/7) កថាខណ្ឌ ៣២ (ជើងទំព័រលុបចោល)។

[629] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៣, ៥៧២។

[630] សេចក្តីសម្រេចទីមួយបណ្តោះអាសន្នលើកិច្ចស៊ើបសួរបន្ថែម (F2/4/3) កថាខណ្ឌ ២២។

[631] *សូមមើលខាងលើ* កថាខណ្ឌ ៣៩ *ជាអាទិ៍*។

នឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់អានុភាពចំពោះមធ្យោបាយ ដែលភាគីការពារក្តីមាន *តាមផ្លូវច្បាប់* ដូចជា សំណើសុំឱ្យកោះហៅសាក្សីដោះបន្ទុក បង្ហាញភស្តុតាងជាឯកសារ ឬភស្តុតាងដទៃទៀត ដើម្បីជំទាស់ទៅនឹងការចោទប្រកាន់មកលើខ្លួន និងសួរដេញដោលសាក្សី[632]។ អំណះអំណាងទាំងនេះត្រូវបាន លើកឡើងបន្ថែមទៀតនៅក្នុងបណ្តឹងសាទុក្ខ ដែលអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយនៅក្នុងបរិបទនោះ។

២៥៦.អាស្រ័យហេតុនេះ ទឡ្ហីករណ៍បណ្តឹងសាទុក្ខទាក់ទងទៅនឹងបញ្ហានេះ ត្រូវបដិសេធចោល។

## ៤.គ.២.ការអនុញ្ញាតឱ្យសាក្សីពិនិត្យមើលចម្លើយរបស់ខ្លួនពីមុន និងការសួរបញ្ជាក់សាក្សីអំពីខ្លឹមសារនៃចម្លើយនោះនៅក្នុងសវនាការ

២៥៧.នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា “ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីអាចត្រូវបានធ្វើឱ្យប្រសើរឡើង ប្រសិនបើ នៅមុនពេលផ្តល់សក្ខីកម្ម សាក្សីត្រូវបានផ្តល់ឱកាសរំឭកនូវការចងចាំរបស់ខ្លួនឡើងវិញ តាមរយៈការពិនិត្យមើលចម្លើយរបស់ខ្លួនពីមុន”[633]។ នៅក្នុងសេចក្តីណែនាំខាងក្រោមទៅកាន់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីជួយដល់សាក្សីក្នុងការពិនិត្យឡើងវិញលើចម្លើយរបស់ពួកគាត់មុនពេលផ្តល់សក្ខីកម្ម អង្គជំនុំជម្រះបានផ្តល់ហេតុផលថា៖

> ការផ្តួចផ្តើមគំនិតនេះ គឺក្នុងគោលបំណងបញ្ចៀសការខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃនៅក្នុងតុលាការ ប្រសិនបើសាក្សី នៅមុនពេលសួរសំណួរនៅក្នុងតុលាការ ចាំបាច់ត្រូវការរំឭកឱ្យពួកគាត់នឹកឃើញចម្លើយពីមុនៗរបស់ខ្លួន ឬបង្ហាញថា សាក្សីបានឆ្លើយចម្លើយទាំងនេះ (ជាឧទាហរណ៍ តាមរយៈការផ្ទៀតផ្ទាត់ហត្ថលេខា ឬស្នាមមេដៃ)។ អង្គជំនុំជម្រះពិចារណាឃើញថា សាក្សីអាចត្រូវបានផ្តល់ឱកាសឱ្យអានចម្លើយពីមុនរបស់ខ្លួន គឺដូចគ្នាទៅនឹងការខិតខំប្រឹងប្រែងជាធម្មតារបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការណែនាំពួកគាត់ឱ្យស្គាល់បន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មផងដែរ[634]
> ។

---

[632] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៤ ដកស្រង់សេចក្តីសម្រេចស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E116) កថាខណ្ឌ ១៩ (ជើងទំព័រលុបចោល)។

[633] អនុស្សរណៈស្តីពីការកំណត់កាលបរិច្ឆេទកិច្ចប្រជុំមិនផ្លូវការ (E141) ទំព័រ ៧។

[634] អនុស្សរណៈទៅកាន់អង្គភាពគាំពារសាក្សី និងអ្នកជំនាញស្តីអំពីចម្លើយពីមុនរបស់សាក្សី (E141/1) ទំព័រ ១។

២៥៨.នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជំនុំជម្រះក្នុងសាលបានបញ្ជាក់ថា៖

> ចាប់ផ្តើមក្នុងខែ មិថុនា ឆ្នាំ ២០១២ ដើម្បីជាប្រយោជន៍នៃភាពឆាប់រហ័ស ប្រធានអង្គជំនុំជម្រះបានចាប់ផ្តើមសួរសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីឱ្យគាត់បញ្ជាក់អំពីភាពត្រឹមត្រូវនៃចម្លើយ ដែលពួកគាត់ធ្លាប់បានឆ្លើយឱ្យទៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងមានសរសេរនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយទាំងនោះ [...] បន្ទាប់ពីសួរបញ្ជាក់រួចហើយ និងដោយកត់សម្គាល់អំពីសិទ្ធិរបស់ភាគីក្នុងការពិនិត្យទៅលើភាពគួរឱ្យជឿទុកចិត្តបាន នូវអ្វីដែលបុគ្គលទាំងនោះធ្លាប់បានឆ្លើយកន្លងមក ឬបញ្ហាទាក់ទងទៅនឹងចម្លើយទាំងនោះ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគីសួរសំណួរបន្ថែមដល់បុគ្គលទាំងនោះ ប៉ុន្តែកម្រិតត្រឹមតែសំណួរ ដែលចាំបាច់ដើម្បីបញ្ជាក់ពីភាពពាក់ព័ន្ធទៅលើបញ្ហាដែលមិនទាន់បានរៀបរាប់គ្រប់គ្រាន់នៅឡើយនៅក្នុងចម្លើយទាំងនេះ ឬមិនត្រូវបានសួរកាលពីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ[635]។

២៥៩.នៅដំណាក់កាលបណ្តឹងសាទុក្ខ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាអំពីច្បាប់កម្ពុជា ក៏ដូចជាការអនុវត្តនៅកម្រិតអន្តរជាតិផងដែរ ក្នុងការអនុញ្ញាតឱ្យសាក្សីពិនិត្យចម្លើយរបស់ខ្លួនពីមុន និងបានសំអាងលើកត្តានានាដែលពុំជាប់ពាក់ព័ន្ធ[636]។ ជាពិសេស គាត់បានអះអាងថា ការបង្ហាញដល់សាក្សីនូវចម្លើយរបស់ខ្លួនពីមុន ត្រូវបានហាមឃាត់នៅក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅចំពោះមុខតុលាការកម្ពុជា ក៏ដូចជាក្នុងប្រព័ន្ធច្បាប់ស៊ីវិលផងដែរ[637] និងថា ពុំអាចយកការអនុវត្តស្តីពីការប្រឹក្សាសាក្សីនៅតុលាការ ICTR និង ICTY មកអនុវត្តនៅក្នុងតុលាការព្រហ្មទណ្ឌចម្រុះដែលប្រើប្រព័ន្ធស៊ើបសួរ និងដេញដោលចំពោះមុខនោះទេ[638]។ នួន ជា បានបន្ថែមថា ការធ្វើយុត្តិកម្មបឋមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្ហាញដល់សាក្សីនូវចម្លើយពីមុននេះថា ពួកគាត់អាចមានការលំបាកក្នុងការរំឭកការចងចាំឡើងវិញនោះ ជាការជំរុញឱ្យអនុម័តយកវិធីសាស្ត្របែបនោះទៅវិញ[639]។ ទាក់ទងទៅនឹងការអនុវត្តនៅចំពោះមុខតុលាការ ICC

---

[635] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣១។

[636] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៦ ដល់ ១៤៦។

[637] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៨ ដល់ ១៣៩ និង ១៤៦។

[638] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤០ ដល់ ១៤៤ យោងទៅលើសេចក្តីសម្រេច *រឿងក្តី Lubanga* (ICC) ស្តីពីការប្រឹក្សាសាក្សី។

[639] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤៥ ដល់ ១៤៦។

នួន ជា បានព្យាយាមលើកបង្ហាញភាពខុសគ្នារវាង *រឿងក្ដី Lubanga* (សាក្សីអាចពិនិត្យចម្លើយពីមុនៗរបស់ខ្លួនបាន) និងរឿងក្ដីនៅចំពោះមុខ ដោយបានកត់សម្គាល់ថា រយៈពេលដែលសាក្សីត្រូវផ្ដល់សក្ខីកម្ម និងកំណត់ហេតុស្ដាប់ចម្លើយពីមុនរបស់ខ្លួន ខ្លីជាងរយៈពេលនៅក្នុងរឿងក្ដីបច្ចុប្បន្ន និងថា នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខតុលាការ ICC ភាគីទាំងពីរមានសិទ្ធិស៊ើបអង្កេតរឿងក្ដី[640]។ នួន ជា បានចោទប្រកាន់ប្រហាក់ប្រហែលគ្នានេះដែរថា ជាកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាសួរសំណួរនាំមុខដល់សាក្សី ដោយបានអានខ្លឹមសារនៃចម្លើយពីមុនក្នុងអំឡុងពេលសួរសំណួរដល់សាក្សី បើតាមការអះអាងរបស់ នួន ជា ថា យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ពុំបានអនុញ្ញាតឱ្យអនុវត្តបែបនេះឡើយ[641]។

២៦០.ខៀវ សំផន ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការផ្ដល់ដល់សាក្សីនូវចម្លើយរបស់ពួកគាត់ពីមុន និងឯកសារដទៃទៀតមុនពេលសាក្សីធ្វើសក្ខីកម្ម ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីដែលអង្គជំនុំជម្រះចាត់ទុកថា មានសារៈសំខាន់ខ្លាំងជាងនោះ គឺបានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍តុល្យភាពតទល់[642]។ ខៀវ សំផន និង នួន ជា បានអះអាងថា ពួកគាត់ទទួលរងការប៉ះពាល់ ដោយសារសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានកំហុស ព្រោះពុំបានផ្ដល់ឱកាសឱ្យធ្វើការដេញដោលប្រកបដោយអត្ថន័យ ឬលទ្ធភាពក្នុងការជំទាស់ទៅនឹងភាពអាចជឿជាក់បាន ឬភាពអាចជឿទុកចិត្តបានចំពោះការចងចាំរបស់សាក្សី និងភាពអាចជឿទុកចិត្តបានចំពោះការស៊ើបសួរដែលមានកំហុស តាមរយៈការវាយតម្លៃ ថាតើសក្ខីកម្មក្នុងតុលាការស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយពីមុន ដែរ ឬយ៉ាងណា[643]។

២៦១.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យសាក្សីពិនិត្យចម្លើយរបស់ខ្លួនពីមុនឡើងវិញនៅមុនពេលផ្ដល់សក្ខីកម្ម គឺជាការត្រឹមត្រូវ និងថា"ការប្រើប្រាស់យុត្តិសាស្ត្រចំពោះការសួរសំណួរនាំមុខក្នុងពេល*សួរសំណួរផ្ទាល់* គឺជាការពុំសមស្របទេ ពីព្រោះភាពខុសគ្នាត្រង់ថា ភាគីសួរឱ្យសាក្សីរបស់ខ្លួនឆ្លើយតាម ចំណែកឯអង្គជំនុំជម្រះសាលាដំបូងត្រឹមតែសួរឱ្យសាក្សីឆ្លើយបញ្ជាក់នូវចម្លើយរបស់ខ្លួនពី

---

[640] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤១ ដល់ ១៤៤។

[641] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៥, ១៤៧។

[642] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩, ២៦។

[643] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៥, ១៤៣, ១៤៧។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៦។

មុន ដែលបានធ្វើសម្បថប៉ុណ្ណោះ"[644]។

២៦២.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬវិធានផ្ទៃក្នុងពុំបានដោះស្រាយឱ្យបានច្បាស់លាស់អំពីបញ្ហាដែលថា អង្គជំនុំជម្រះសាលាដំបូងអាចអនុញ្ញាតឱ្យសាក្សីពិនិត្យលើចម្លើយរបស់ខ្លួនពីមុន ឬឯកសារដទៃទៀតនៅមុនពេលផ្តល់សក្ខីកម្ម ឬអះអាងខ្លឹមសារនៃចម្លើយពីមុននៅក្នុងតុលាការឡើយ ទោះជាយ៉ាងណាក្តី តាមការអនុវត្តនៅចំពោះមុខតុលាការកម្ពុជា ពុំដែលធ្វើដូច្នេះឡើយ។ នួន ជា បានអះអាងថា ការអនុវត្តបែបនេះ"ជាទូទៅត្រូវបានហាមឃាត់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធស៊ើបសួរ" ហើយ នួន ជា បានយោងទៅលើការអនុវត្តនៅចំពោះមុខ*តុលាការព្រហ្មទណ្ឌ* (*Cour d'assises*)[645] ក្នុងប្រទេសបារាំង។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជាការពិត នៅក្នុងយុត្តាធិការមួយចំនួនផ្សេងទៀតដែលបានយកលំនាំតាមប្រភពដើមនៃប្រព័ន្ធច្បាប់ស៊ីវិល (Romano-Germanic) ការប្រើប្រាស់ឯកសារពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះដែលអាចសម្រេចបានគ្រប់ករណី ដូចជាក្នុងករណីចាំបាច់នៅពេលផ្តល់សក្ខីកម្ម ត្រូវរំឭកការចងចាំរបស់សាក្សី ឬសួរដេញដោលភាពពុំស៊ីសង្វាក់គ្នាជាដើម[646]។ ដូចការកត់សម្គាល់របស់អ្នកអត្ថាធិប្បាយមួយចំនួនទៅលើខ្លឹមសារយ៉ាងទូលំទូលាយស្តីពីការប្រឹក្សាសាក្សី ដែលពាក់ព័ន្ធទៅនឹងការត្រៀមលក្ខណៈរបស់សាក្សីក្នុងការផ្តល់សក្ខីកម្ម ដែលមាននៅក្នុងប្រព័ន្ធដែលយកលំនាំតាមប្រភពដើមនៃប្រព័ន្ធច្បាប់ស៊ីវិល (Romano-Germanic) ប៉ុន្តែការប្រឹក្សាសាក្សីនេះពុំអាចទទួលយកបានជាទូទៅឡើយ[647]។ នៅក្នុង

---

[644] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨១ ដល់ ៨៣។

[645] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៣៩ និងជើងទំព័រ ៣៤៥។

[646] *សូមមើល* មាត្រា ៣៣១(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។ មុនពេលចាប់ផ្តើមផ្តល់សក្ខីកម្ម សាក្សីត្រូវធ្វើសម្បថ*ថា ត្រូវនិយាយដោយគ្មានការភ័យខ្លាច និងគ្មានការស្អប់ ត្រូវនិយាយការណាដែលពិតទាំងអស់ និងមិននិយាយអ្វីក្រៅតែពីការពិតឡើយ។ នេះគឺសម្រាប់សាក្សីដែលផ្តល់សក្ខីកម្មផ្ទាល់មាត់។ ប្រធានអាចអនុញ្ញាតឱ្យសាក្សីពិនិត្យដោយខ្លួនឯងនូវឯកសារក្នុងពេលសវនាការ* ("*les témoins prêtent le serment ' de parler sans haine et sans crainte, de dire toute la vérité, rien que la vérité '. Cela fait les témoins déposent oralement. Le président peut autoriser les témoins à s'aider de documents au cours de leur audition*" មាត្រា ៣៩១ និង ៣៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ូឡូញ ផ្នែក ២៥០ ដល់ ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ (អនុញ្ញាតឱ្យមានការអានចម្លើយពីមុននៅពេលសាក្សីបដិសេធពុំផ្តល់សក្ខីកម្ម ឬផ្តល់សក្ខីកម្មខុសពីមុន ឬពុំចងចាំ ឬពុំមានអត្ថិភាព ឬនៅពេលមានការទទួលស្គាល់ពីតុលាការ និងភាគីថា ការពិនិត្យពុំចាំបាច់ឡើយ)។

[647] *សូមមើល* ការប្រឹក្សាសាក្សីរបស់អ្នកនិពន្ធឈ្មោះ Ambos, K. ទំព័រ ៦០៥ ដល់ ៦០៦ "ការប្រឹក្សាសាក្សីនៅចំពោះមុខ ICC៖ ពុំអាចទទួលយកបានតាមច្បាប់ និងពុំចាំបាច់" នៅក្នុង៖ ការបោះពុម្ពផ្សាយរបស់ Carsten STAHN, Göran Sluiter (eds) *ការលេច*

ប្រព័ន្ធច្បាប់ទាំងនេះ សក្ខីកម្មភ្លាមៗរបស់សាក្សីត្រូវបានចាត់ទុកថា មានសារសំខាន់ពិសេសណាមួយ ដែលនឹងអាចបាត់បង់ប្រសិនបើសាក្សីត្រូវបានអនុញ្ញាតឱ្យរំឭកការចងចាំរបស់ខ្លួនមុនពេលផ្តល់សក្ខីកម្ម ឬត្រឹមតែសួរឱ្យបញ្ជាក់ខ្លឹមសារនៃសក្ខីកម្មនេះនៅក្នុងតុលាការប៉ុណ្ណោះ[648]។

២៦៣.សរុបសេចក្តីមក បើទោះបីជាពុំមានការហាមឃាត់ច្បាស់លាស់ក្នុងការអនុញ្ញាតឱ្យសាក្សីអានចម្លើយរបស់ខ្លួនពីមុន នៅមុនពេលផ្តល់សក្ខីកម្ម និងឱ្យសាក្សីឆ្លើយបញ្ជាក់ក្នុងតុលាការនូវខ្លឹមសារនៃចម្លើយរបស់ខ្លួនក៏ដោយ ក៏ការពុំផ្អែកលើការអនុវត្តបែបនេះកាន់តែស៊ីសង្វាក់គ្នាទៅនឹងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងទំនៀមទម្លាប់ច្បាប់កម្ពុជាថែមទៀត។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការបន្តនីតិវិធីដោយផ្អែកលើការសន្មតថា បញ្ហានេះពុំត្រូវបានដោះស្រាយដោយច្បាប់កម្ពុជា ឬថា ច្បាប់កម្ពុជាពិតជាមានភាព"ពុំច្បាស់លាស់"ត្រង់ចំណុចនេះ ដោយអនុលោមតាមវិធាន ២ នៃវិធានផ្ទៃក្នុងដែលត្រូវអានផ្គួបជាមួយមាត្រា ៣៣ ថ្មីនៃច្បាប់ អ.វ.ត.ក. និងមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក.។ ចំពោះបញ្ហាផ្សេងទៀតដែលត្រូវដោះស្រាយគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងបានស្វែងរកការណែនាំសមស្របក្នុង"បទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" ដែរ ឬយ៉ាងណា[649]។

២៦៤.ទាក់ទងទៅនឹងបញ្ហានេះ ការប្រឹក្សាសាក្សីត្រូវបានប្រើប្រាស់ទៀងទាត់នៅតុលាការ ICTR និង ICTY ដែលការអនុវត្តកិច្ចដំណើរការនីតិវិធីរបស់ខ្លួនធ្វើតាមគោលការណ៍តទល់ចំពោះមុខ។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុង*រឿងក្តី Haradinaj* បានប្រកាន់យកការអនុវត្តនេះ និងបានកំណត់ថា "ជាការជួបគ្នារវាងភាគីនៃកិច្ចដំណើរការនីតិវិធី ជាមួយនឹងសាក្សីដែលជាធម្មតាបានធ្វើឡើងភ្លាមៗនៅមុនពេលសាក្សីត្រូវផ្តល់សក្ខីកម្មក្នុងតុលាការ ក្នុងគោលបំណងដើម្បីត្រៀមលក្ខណៈ និងជួយសាក្សីឱ្យស្គាល់នីតិវិធីក្នុងបន្ទប់សវនាការ និងពិនិត្យភស្តុតាងរបស់សាក្សី"[650]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ក្នុង*រឿងក្តី Karemera*

---

*ឡើងនៃអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ* Martinus Nijhof Publishers ឆ្នាំ ២០០៨ ទំព័រ ៦០០ *ជាអាទិ៍* និង ៦០៥ ដល់ ៦០៦។

[648] *សូមមើល* Hannah. GARRY៖ "ការប្រឹក្សាសាក្សី នៅក្នុង៖ Linda CARTER and Fausto POCAR *នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ/ ចំណុចប្រសព្វនៃប្រព័ន្ធច្បាប់ស៊ីវិល និងច្បាប់អង់គ្លូសាក់សុង (Common Law)* ការបោះពុម្ពផ្សាយរបស់ Edward Elgar ឆ្នាំ ២០១៣ ទំព័រ ៦៦ *ជាអាទិ៍* ៧២ ដល់ ៧៣។

[649] មាត្រា ៣៣ (ថ្មី)នៃច្បាប់ អ.វ.ក.ត. និងមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក.។

[650] សេចក្តីសម្រេចស្តីពីការប្រឹក្សាសាក្សីក្នុង*រឿងក្តី Haradinaj* (ICTY) កថាខណ្ឌ ៨។

ក៏បានប្រកាន់យកការអនុវត្តនៃការប្រឹក្សាសាក្សីនេះផងដែរ ប៉ុន្តែដរាបណា"ការអនុវត្តនេះពុំមែនជាការកែខៃភស្តុតាងរបស់សាក្សី"[651] ដោយសេចក្តីសម្រេចមួយត្រូវបានទទួលយកដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ដែលបានបញ្ជាក់ម្តងទៀតថា ការពិភាក្សាចម្លើយមុនៗ និងសក្ខីកម្មដែលនឹងត្រូវធ្វើនៅពេលខាងមុខជាមួយសាក្សី *តាមពិត* ពុំមែនជាការមិនសមស្របនោះឡើយ លើកលែងតែការពិភាក្សានោះ គឺជាការប៉ុនប៉ងប្រើឥទ្ធិពលលើខ្លឹមសារនៃសក្ខីកម្មក្នុងបំណងបិទបាំង ឬបំភ្លៃការពិត[652]។

២៦៥.នៅតុលាការ ICC អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី* *Lubanga* បានអនុញ្ញាតជាក់ច្បាស់ឱ្យសាក្សីពិនិត្យចម្លើយពីមុនរបស់ខ្លួនដើម្បីរំឭកការចងចាំ មុនពេលផ្តល់ភស្តុតាងក្នុងតុលាការ ប៉ុន្តែត្រូវធ្វើតាមរយៈអង្គភាពគាំពារសាក្សី និងជនរងគ្រោះរបស់តុលាការ ICC តែប៉ុណ្ណោះ និងបានកត់សម្គាល់ឃើញថា ការធ្វើដូច្នេះ "នឹងជួយបង្ហាញភស្តុតាងយ៉ាងមានប្រសិទ្ធភាព និងជួយដល់អង្គជំនុំជម្រះសាលាដំបូងស្វែងរកការពិត"។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានហាមឃាត់ភាគីមិនឱ្យជួបពិភាក្សាជាមួយសាក្សីរបស់ខ្លួនអំពីសក្ខីកម្មដែលរំពឹងទុកនោះឡើយ ឧទាហរណ៍ដូចជាតាមរយៈការពិនិត្យចម្លើយពីមុនរបស់ខ្លួន[653]។ ទម្រង់បែបបទនីតិវិធីរបស់តុលាការ ICC និងទម្រង់ដែលបានយកមកអនុវត្តនៅក្នុងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. មានចំណុចប្រហាក់ប្រហែលគ្នាខ្លាំងត្រង់ថា នៅ អ.វ.ត.ក. អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលជាស្ថាប័នអព្យាក្រឹតរបស់តុលាការ ជាអ្នកផ្តល់ចម្លើយទាំងនោះទៅឱ្យសាក្សីពិនិត្យ។

២៦៦.ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹងការអនុវត្តដែលឱ្យសាក្សីផ្ទៀងបញ្ជាក់អំពីខ្លឹមសារនៃចម្លើយរបស់ខ្លួនពីមុននៅចំពោះមុខតុលាការ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការអនុវត្តបែបនេះពុំមានចែងជាក់លាក់នៅក្នុងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICC[654]នោះទេ។

---

[651] សេចក្តីសម្រេចស្តីពីការប្រឹក្សាសាក្សីក្នុង*រឿងក្តី* *Karemera* (ICTR) កថាខណ្ឌ ១៥។

[652] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការប្រឹក្សាសាក្សីក្នុង*រឿងក្តី* *Karemera* (ICTR) កថាខណ្ឌ ៩ ដកស្រង់សាលដីកា*រឿងក្តី* *Gacumbitsi* (ICTR)។

[653] សេចក្តីសម្រេចស្តីពីការប្រឹក្សាសាក្សីក្នុង*រឿងក្តី* *Lubanga* (ICC) កថាខណ្ឌ ៥១ ដល់ ៥៧។

[654] *សូមមើល* វិធាន ៩២ *ស្ទួនពីរ* នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និងវិធាន ៦៨(៣) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នួន ជា ពុំបានលើកឡើងនូវបទប្បញ្ញត្តិពាក់ព័ន្ធនៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICC ផ្ទុយទៅវិញគ្រាន់តែបានយោងទៅលើសេចក្តីសម្រេចស្តីពីសំណួរនាំមុខដែលពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហានៅចំពោះមុខឡើយ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤៧។

២៦៧.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបង្ហាញសាក្សីនូវអ្វីដែលគាត់បាននិយាយពីមុននោះ អាចជាការជ្រៀតជ្រែក ឬការបំភាន់ដល់ការចងចាំរបស់សាក្សី និងបំភាន់ការពិត ដោយសារកាត់បន្ថយចម្លើយ ដែលកើតឡើងដោយឯកឯងក្នុងការផ្តល់ភស្តុតាងនៅក្នុងតុលាការ។ ការធ្វើដូចគ្នានេះកើតមានផងដែរចំពោះ ការអញ្ជើញសាក្សីឱ្យបញ្ជាក់ខ្លឹមសារក្នុងចម្លើយពីមុនរបស់ខ្លួននៅពេលចាប់ផ្តើមផ្តល់សក្ខីកម្ម ដោយសារភាគី នៃកិច្ចដំណើរការនីតិវិធី និងអង្គជំនុំជម្រះពុំអាចសង្កេត ថាតើសាក្សីនេះភ្ជាប់ទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍នោះ យ៉ាងដូចម្តេចឡើយ។ ជាលទ្ធផល កាន់តែធ្វើឱ្យមានការលំបាកសម្រាប់ភាគី ឬអង្គជំនុំជម្រះសាលាដំបូងក្នុង ការតាមដានភាពមិនស៊ីសង្វាក់គ្នារវាងសក្ខីកម្មផ្ទាល់ និងចម្លើយមុនៗ ដែលជាមូលដ្ឋានក្នុងការកំណត់ភាពអាច ជឿជាក់បាន។ អាស្រ័យហេតុនេះ ការធ្វើបែបនេះត្រូវបានវាយតម្លៃតាមរយៈការថ្លឹងថ្លែងពេលវេលាក្នុងតុលា ការសម្រាប់បង្ការចំពោះហានិភ័យដែលកើតមានដូចជាសាក្សីពុំអាចឆ្លើយភ្លាមៗបាន។ ដោយសារទំហំនៃកិច្ច ដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. ទាក់ទងទៅនឹងចំនួនសាក្សីដ៏ច្រើន និងការកម្រិតពេលវេលាសវនា ការជារៀងរាល់ថ្ងៃដោយសារលក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទ ដូច្នេះការចំណេញត្រឹមដប់នាទីសម្រាប់ សាក្សីម្នាក់ ក៏អាចមានឥទ្ធិពលដល់ការអនុវត្តនេះដែរ ចុះបើទម្រាំចំណេញដល់មួយម៉ោងសម្រាប់សាក្សីម្នាក់ នោះ នឹងអាចកាត់បន្ថយការជំនុំជម្រះបានច្រើនសប្តាហ៍ និងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន។ ទិដ្ឋភាពមួយ ផ្សេងទៀតដែលគួរថ្លឹងថ្លែងនោះ គឺគុណភាពនៃភស្តុតាងដែលពាក់ព័ន្ធ និងទំនោរនៃការបំភ្លៃការពិត ឧទាហរណ៍ ប្រសិនបើចម្លើយពីមុនរបស់សាក្សី *តាមការបញ្ជាក់ដំបូង* ពោរពេញទៅដោយភាពមិនស៊ីសង្វាក់គ្នា ជាការ ប្រសើរសាក្សីពុំចាំបាច់ពិនិត្យចម្លើយជាមុនឡើយ ដើម្បីអាចធ្វើការវាយតម្លៃសមស្របលើភាពអាចជឿជាក់ បានរបស់សាក្សី។ ម្យ៉ាងវិញទៀត ពុំឃើញមានផលប្រយោជន៍អ្វីដែលត្រូវអនុញ្ញាតឱ្យសាក្សីពិនិត្យលើចម្លើយ ដែលខ្វះភាពលម្អិតទាំងស្រុងនោះទេ។ ការពិចារណានេះ ពុំត្រូវបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំ ជម្រះសាលាដំបូង ដែលផ្ទុយទៅវិញបានអនុវត្តវិធីសាស្ត្រមួយដែលគ្របដណ្តប់គ្រប់ចំណុចទាំងអស់។

២៦៨.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ហានិភ័យជាក់ស្តែងដែលបណ្តា លមកពីការពិនិត្យឡើងវិញ ឬចម្លើយមុនៗក្នុងករណីនេះ ពុំមែនជាបញ្ហាធំដុំឡើយ។ ទីមួយ ក្នុងអំឡុងពេលសវ នាការ ចម្លើយដែលកើតឡើងដោយឯកឯងក្នុងតុលាការ អាចត្រូវបោះបង់ចោលនៅគ្រប់កាលៈទេសៈទាំងអ ស់។ បន្ទាប់ពីសួរសំណួរដោយអ្នកស៊ើបអង្កេត អ.វ.ត.ក. សាក្សីទទួលបានឯកសារចម្លងនៃកំណត់ហេតុស្តាប់ ចម្លើយជាលាយលក្ខណ៍អក្សរមួយច្បាប់។ ប្រសិនបើសាក្សីចង់ពិនិត្យចម្លើយនេះ សាក្សីអាចធ្វើដូច្នោះបាន ដោយខ្លួនឯងមុនពេលផ្តល់សក្ខីកម្មក្នុងតុលាការ។ បន្ថែមលើនេះ ការដែលអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

បានបំពេញកាតព្វកិច្ចជួយដល់សាក្សីនៅក្នុងនីតិវិធីនេះដែលមិនមែនជាភាគីនោះ តាមធម្មតាបានកើតឡើងនៅក្នុងតុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍* គឺជាការទប់ស្កាត់ឥទ្ធិពលពីខាងក្រៅនានា។ សាក្សីទាំងអស់ រួមទាំងសាក្សីដែលបានស្នើឡើងដោយមេធាវីការពារក្តី បានទទួលអត្ថប្រយោជន៍ដូចៗគ្នា។ ចុងបញ្ចប់ តាមការពិនិត្យលើកំណត់ហេតុជំនុំជម្រះឃើញថា ក្នុងករណីខ្លះ សាក្សីបានអះអាងក្នុងតុលាការថា ខ្លឹមសារនៃចម្លើយរបស់ខ្លួនពីមុនពុំត្រឹមត្រូវនោះទេ[655]។ ជាទូទៅ ការប្រៀបធៀបភាពពុំស៊ីសង្វាក់គ្នារវាងចម្លើយពីមុន និងសក្ខីកម្មផ្ទាល់ គ្រាន់តែជាវិធានការមួយក្នុងចំណោមវិធានការជាច្រើនក្នុងការវាយតម្លៃសាក្សីអំពីភាពអាចជឿជាក់ និងទុកចិត្តបាន ដែលនេះ ជាវិធានការមួយក្នុងចំណោមវិធានការជាច្រើន ដែលមានដូចជា ការកំណត់អត្តសញ្ញាណនៃភាពពុំស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មផ្ទាល់របស់សាក្សី ឬភាពពុំស៊ីសង្វាក់គ្នាជាមួយនឹងសក្ខីកម្មរបស់សាក្សីដទៃទៀត ការបញ្ជាក់បន្ថែមពីភស្តុតាងដាច់ដោយឡែក និងការវាយតម្លៃលើគុណភាពនៃសក្ខីកម្ម (ឧ.ពាក្យចចាមអារ៉ាម ការជំរុញទឹកចិត្តឱ្យនិយាយកុហកជាដើម) ទាំងអស់នេះពុំបានទទួលរងការប៉ះពាល់ដោយសារការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុញ្ញាតឱ្យពិនិត្យចម្លើយពីមុននៅមុនពេលផ្តល់សក្ខីកម្មឡើយ។

២៦៩.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងគួរតែប្រើប្រាស់វិធីសាស្ត្រមួយដែលខុសប្លែកពីវិធីសាស្ត្រ ដែលមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយការអនុវត្តរបស់កម្ពុជា និងទំនៀមទម្លាប់ច្បាប់ដែលបានអនុវត្តក្នុងប្រព័ន្ធរបស់កម្ពុជា។ ទោះជាយ៉ាងនេះក្តី នួន ជា ពុំបានបង្ហាញថា ការប្រើប្រាស់វិធានស្តីពីនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ជាការពុំសមហេតុផលដល់កម្រិតមួយដែលជាការរំលោភឆន្ទានុសិទ្ធិឡើយ។

២៧០.អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាក់ទងទៅនឹងបញ្ហានេះ ត្រូវបដិសេធចោល។

## ៤.គ.៣.ការរឹតត្បិតលើវិសាលភាពនៃការសួរសំណួរ

២៧១.ជាការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា និង ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានកម្រិតលក្ខខណ្ឌតាមអំពើចិត្ត និងពុំត្រឹមត្រូវលើវិសាលភាពនៃការសួរ

---

[655] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (ខៀវ នៅ) ឯកសារលេខ E1/89.1 ទំព័រ ៧៨។ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ (សៅ សារុន) ឯកសារលេខ E1/85.1 ទំព័រ ៨៥ ដល់ ៨៦។

សំណួរ និងសម្ភារដែលអាចប្រើប្រាស់ដើម្បីជំទាស់ទៅនឹងភាពជឿជាក់បានលើបុគ្គលនានា ដែលបានផ្តល់សក្ខីកម្មនៅក្នុងតុលាការ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

> យោងតាមវិធាន ៨៥ និង៨៧ នៃវិធានផ្ទៃក្នុង ប្រធាន និងអង្គជំនុំជម្រះអាចបដិសេធនូវរាល់កិច្ចដំណើរការនីតិវិធី និងសំណួរដែលនាំឱ្យមានការពន្យារពេលឥតចាំបាច់ដល់ការជំនុំជម្រះ ឬដែលពុំអាចទៅដល់ការស្វែងរកការពិត។ អង្គជំនុំជម្រះបានជំរុញឱ្យភាគីទាំងអស់កម្រិតការសួរសំណួររបស់ខ្លួនលើបុគ្គល ដែលបានកោះហៅពេលជំនុំជម្រះ ត្រឹមបញ្ហាដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ បន្ថែមលើនេះទៀត ដោយពិចារណាលើសមត្ថភាពរបស់បុគ្គលដែលត្រូវបានកោះហៅមកផ្តល់ភស្តុតាង អង្គជំនុំជម្រះបានកម្រិតវិសាលភាពនៃការសួរសំណួរនេះ ដើម្បីធានាថា ការសួរសំណួរពុំងាកទៅរកប្រធានបទដែលពុំជាប់ពាក់ព័ន្ធឡើយ [...]
>
> ទោះបីជា ជនជាប់ចោទលើកឡើងពីការកម្រិតដែលមិនមានភាពស្មើគ្នាចំពោះលទ្ធភាពរបស់ពួកគេក្នុងការជំទាស់ទៅនឹងភ័ស្តុតាង និងការសួរដេញដោលសាក្សីក៏ដោយ ក៏ជនជាប់ចោទមិនបានបង្ហាញពីផលប៉ះពាល់ ឬ មិនបានបង្ហាញថា ពួកគេបានប្រើប្រាស់មធ្យោបាយដទៃទៀតដែលមាននោះទេ ឧទាហរណ៍តាមរយៈការស្នើសុំការជំទាស់តវ៉ា ឬការស្នើសុំផ្តល់ភ័ស្តុតាងជាឯកសារ។ អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការជំទាស់ទៅលើភ័ស្តុតាង និងក្នុងការសួរសំណួរដល់សាក្សីមិនត្រូវបានរំលោភបំពាននោះឡើយ[656]។

២៧២.នៅដំណាក់កាលបណ្តឹងសាទុក្ខ ខៀវ សំផន និង នួន ជា បានអះអាងម្តងទៀតអំពីការទាមទាររបស់ខ្លួនដែលថា អង្គជំនុំជម្រះសាលាដំបូង បានរំលោភបំពានលើសិទ្ធិរបស់ពួកគាត់ជាច្រើនដង ទាក់ទងទៅនឹងការជំទាស់ទៅនឹងភស្តុតាងប្រឆាំងនឹងរូបគាត់[657]។ នួន ជា បានរំឭកនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន អំពីការជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើបញ្ហាដែលគាត់មានគោលបំណងបង្ហាញពីវិការៈក្នុងការប្រមូលភស្តុតាងនៅក្នុងអំឡុងពេលនៃការស៊ើបសួរ[658]។ គាត់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងក៏បានកម្រិតលទ្ធភាពរបស់គាត់ដែរ ក្នុងការសួរបញ្ជាក់អំពីភាពជឿទុកចិត្តបាននៃភស្តុតាង ទោះបីជាវិធីសាស្ត្រនៃការសួរបញ្ជាក់នោះ ពុំចោទជាបញ្ហាក៏ដោយ ដែលចំណុចនេះគាត់បាន

---

656 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២។

657 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤៨ ដល់ ១៥៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១។

658 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤៩ យោងទៅលើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា (E295/6/3) កថាខណ្ឌ ៧៦។

ចង្អុលបង្ហាញជាពិសេសទៅលើសក្ខីកម្មរបស់ Philip SHORT Stephen HEDER និង ឆាង យុ[659]។ ខៀវ សំផន បានលើកបង្ហាញយ៉ាងជាក់លាក់អំពីការអន្តរាគមន៍របស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលដែលភាគីការពារក្តីចោទសំណួរដល់សាក្សី ភី ភួន[660]។

២៧៣.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងសមស្រប ក្នុងការគ្រប់គ្រងវិសាលភាពនៃការសួរសំណួរ[661]។

២៧៤.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធី និងចាត់វិធានការនានាក្នុងការកម្រិតការសួរសំណួរទាំងឡាយណាដែលអង្គជំនុំជម្រះចាត់ទុកថា មានភាពច្រំដែល និង/ឬពុំជាប់ពាក់ព័ន្ធ។ ដោយហេតុថា សេចក្តីសម្រេចខាងលើនេះត្រូវចាត់ទុកជាបានការក្នុងកម្រិតមួយយ៉ាងខ្ពស់ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើអន្តរាគមន៍ចំពោះតែករណីណាដែលមានកំហុសកើតចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិ ជាពិសេសសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលពុំត្រឹមត្រូវជាដើម[662]។ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការវាយតម្លៃលើអំណះអំណាងរបស់ នួន ជា និង ខៀវ សំផន ដោយផ្អែកតាមបទដ្ឋាននេះ។

២៧៥.ដូចបានកត់សម្គាល់ខាងលើ នួន ជា បានអះអាងជាដំបូង និងបានលើកជាថ្មីទៀតនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយបានរារាំងគាត់មិនឱ្យសួរបញ្ជាក់អំពីភាពមិនប្រក្រតីដែលកើតមាននៅក្នុងដំណាក់កាលនៃការស៊ើបសួរ[663]។ ការលើកឡើងនេះ បានយោងទៅលើសារណាមួយចំនួន សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី

---

[659] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥០ ដល់ ១៥២។ គាត់លើកឡើងអំពីសក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ និង សួង ស៊ីគឿន។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៣៧៨។

[660] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/99.1 ទំព័រ ៧៥។ ប្រតិចារឹកចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/100.1 ទំព័រ ២៤ ដល់ ២៥, ២៩ ដល់ ៣០ និង ៤៣ និងប្រតិចារឹកចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/101.1 ទំព័រ ២៥ និង ២៨ ដល់ ២៩។

[661] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨៤ ដល់ ៨៥។

[662] *សូមមើលខាងលើ* កថាខណ្ឌ ៩៧ ដល់ ៩៨។

[663] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៤៩។

ប៉ុន្តែពុំបានបញ្ជាក់ច្បាស់ពីមូលហេតុដែលថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ពុំសមហេតុផលនោះឡើយ។ លើសពីនេះទៀត ផ្អែកតាម*សេចក្តីបញ្ជាក់ដំបូង* លើកំណត់ហេតុនៃការជំនុំជម្រះ និងសារណារបស់ នួន ជា ឃើញថា ពុំបានលើកបង្ហាញអំពីកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកម្រិតសំណួរទាក់ទងទៅនឹងវិធីសាស្ត្រនៃការស៊ើបសួរ ដែលត្រូវបានចាត់ទុកថា មានភាពច្រំដែល និង/ឬពុំជាប់ពាក់ព័ន្ធឡើយ។ នួន ជា ក៏ពុំបានភ្ជាប់ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងអំណះអំណាងរបស់គាត់នៅក្នុងសាលក្រមដូចដែលបានបង្ហាញខាងលើ។ សរុបសេចក្តីមក នួន ជា ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសទាក់ទងទៅនឹងបញ្ហានេះទេ។

២៧៦.ទាក់ទងទៅនឹងការបញ្ជាក់ជាក់លាក់ដែល នួន ជា បានចង្អុលបង្ហាញដើម្បីគាំទ្រដល់ការជំទាស់របស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានកម្រិតលទ្ធភាពរបស់គាត់ក្នុងការសួរបញ្ជាក់អំពីភាពជឿទុកចិត្តបាននៃភស្តុតាង ទោះបីជាវិធីសាស្ត្រនៃការសួរបញ្ជាក់នោះ ពុំចោទជាបញ្ហាក៏ដោយនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នួន ជា ពុំបានបង្ហាញពីកំហុស និងការប៉ះពាល់ណាមួយឡើយ។ តាមសារណារបស់ នួន ជា ទាក់ទងទៅនឹងសក្ខីកម្មរបស់ Philip SHORT បង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានបដិសេធឱកាស នួន ជា ក្នុងការសួរសំណួរដល់អ្នកជំនាញអំពីភាពជឿទុកចិត្តបាននៃភស្តុតាងឡើយ ប៉ុន្តែ នួន ជា គ្រាន់តែមិនពេញចិត្តជាមួយនឹងលទ្ធផលនេះប៉ុណ្ណោះ[664]។ សារណារបស់ នួន ជា ទាក់ទងទៅនឹងសក្ខីកម្មរបស់ ឆាង យុ និង ឌុច បង្ហាញថា គាត់ មិនត្រឹមតែត្រូវបានផ្តល់ឱកាសឱ្យសួរសំណួរដល់សាក្សីទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពេញចិត្តនឹងលទ្ធផលទាំងនោះទៀតផង[665]។ បន្ថែមលើនេះទៀត ជាការពុំគ្រប់គ្រាន់

---

[664] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥០ ដែល នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង "ចាត់ទុកសំណួររបស់មេធាវីការពារក្តីច្រំដែល និងបានហាមឃាត់មិនឱ្យសួរដេញដោយបន្ថែមទៀត" បន្ទាប់ពី Philip SHORT បានផ្តល់"ចម្លើយច្របូកច្របល់ និងផ្ទុយគ្នាជាហូរហែពាក់ព័ន្ធទៅនឹងប្រភពនៃការអះអាងរបស់គាត់ដែលថា [...] ការសម្លាប់[ទាហាននៃរបបសាធារណៈរដ្ឋខ្មែរ]បានកើតឡើង[បន្ទាប់ពី ប.ក.ក. ដណ្តើមបានឧដុង្គក្នុងឆ្នាំ ១៩៧៤]" និងបន្ទាប់មក អង្គជំនុំជម្រះ"ពុំបានអើពើសំណួររបស់មេធាវីការពារក្តីទាល់តែសោះ [ក្នុងការសំអាងលើសក្ខីកម្មរបស់ Philip SHORT តែមួយមុខគត់មកធ្វើជាមូលដ្ឋាននៃការយល់ឃើញដែលមានកំហុសច្បាស់ក្រឡែតនោះថា ទាហាននៃរបបសាធារណៈរដ្ឋខ្មែរត្រូវបានសម្លាប់នៅឧដុង្គ]"។

[665] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥២ ដែល នួន ជា បានលើកឡើងទាក់ទងទៅនឹងសក្ខីកម្មរបស់ ឆាង យុ ដែលថា ទោះបីជាការពិតដែលថា "ការជំទាស់របស់សហព្រះរាជអាជ្ញាដែលពុំមានការជាប់ពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏ត្រូវបានគាំទ្រដោយប្រធានអង្គជំនុំជម្រះ" "ថ្ងៃបន្ទាប់ មេធាវីការពារក្តីបានលើកប្រធានបទនេះសាឡើងវិញ [ទាក់ទងទៅនឹងបញ្ហា ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាជាប់ពាក់ព័ន្ធទៅនឹងគម្រោងមួយចំនួន ដែលកម្រិតការចោទប្រកាន់កម្មាភិបាលកម្រិតទាបនៃកម្ពុជាប្រជា

ឡើយដោយគ្រាន់តែចង្អុលទៅលើហេតុការណ៍កើតឡើងជាក់ស្តែង គឺការកាត់ផ្តាច់ការសួរសំណួរ ដែល នួន ជា បានយោងទៅលើការផ្តល់សក្ខីកម្មរបស់ សួង ស៊ីគឿន ដោយពុំបានផ្តល់មូលដ្ឋានគាំទ្រការចោទប្រកាន់ជាទូទៅ ដែលថា មានកំហុសក្នុងរឿងនេះ[666] ឬដែល ខៀវ សំផន បានយោងទៅលើការផ្តល់សក្ខីកម្មរបស់ ភី ភួន ដោយពុំបានលើកបង្ហាញពីភាពជាប់ពាក់ព័ន្ធ ឬការប៉ះពាល់នៅក្នុងបញ្ហារបស់ខ្លួនឡើយ[667]។

---

ធិបតេយ្យ ដែរ ឬយ៉ាងណា] ហើយពេលនេះត្រូវបានអនុញ្ញាតឱ្យបន្ត" និងអាចទាញយកសេចក្តីសន្និដ្ឋានលើ"ការទទួលយកដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពអាចជឿទុកចិត្តបាននៃភស្តុតាងដែលបានផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជា [និង] ដែលអាចនឹងពុំមានភាពច្បាស់លាស់ឡើយ ប្រសិនបើមេធាវីការពារក្តីពុំបានសួរបញ្ជាក់នោះ បើទោះបីជាមានការសម្រេចពីមុនក៏ដោយ"។ ទាក់ទងទៅនឹងសក្ខីកម្មរបស់ ឌុច នួន ជា បានលើកឡើងថា "មេធាវីការពារក្តីត្រូវបានរារាំងមិនឱ្យសួរសំណួរ ឌុច ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើគាត់ជឿលើខ្លឹមសារនៃចម្លើយសារភាពដែលទទួលបានពីមន្ទីរ ស-២១ ដែរ ឬយ៉ាងណា"។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៣៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/58.1 ទំព័រ ៦៧ ដល់ ៦៨។ ការពិនិត្យឡើងវិញលើផ្នែកនៅក្នុងប្រតិចារឹកនៃសក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ ដែល នួន ជា បានយោងទៅលើនោះ ទោះជាយ៉ាងណាក្តីបានបង្ហាញថា ក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញាទៅលើការសួរសំណួររបស់មេធាវីការពារក្តី *មុនពេល*សក្ខីកម្មនេះត្រូវបានគាំទ្រដោយអង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តីបានអះអាងថា "ខ្ញុំជឿជាក់ថា ចម្លើយរបស់គាត់ កន្លងមក មានមន្ទិលសង្ស័យតិចតួចអំពីភាពប្រាកដប្រជារបស់គាត់ [អំពីបញ្ហា ថាតើចម្លើយសារភាពនោះ គឺជាការពិត ដែរ ឬយ៉ាងណា]។ នេះ គឺជាអ្វីដែលខ្ញុំបានព្យាយាមបង្ហាញ។ ខ្ញុំសប្បាយចិត្តក្នុងការបន្តទៅប្រធានបទបន្ទាប់" ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/58.1 ទំព័រ ៦៨។

[666] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៣៧៨ ដែល នួន ជា បានលើកឡើងថា "មេធាវីការពារក្តីត្រូវបានរារាំងមិនឱ្យ[កំណត់បញ្ហា ថាតើ]ប្រភពនៃចំណេះដឹងត្រូវបានធ្វើឱ្យខូចដោយសារការផ្សព្វផ្សាយបច្ចុប្បន្នជាសាធារណៈអំពីកន្លែងឧក្រិដ្ឋកម្មនៅក្នុងដីកាដំណោះស្រាយ ដែលជាប់ពាក់ព័ន្ធទៅនឹងរូបគាត់ ដែរ ឬយ៉ាងណា"។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១ និងការយោងដែលបានដកស្រង់ក្នុងជើងទំព័រ ៧៦។

[667] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១ ដែល ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានហាមឃាត់ភាគីការពារក្តីម្តងហើយម្តងទៀត បានផ្តល់ចម្លើយដល់ រ៉ចាម គុន *ហៅ* ភី ភួន និងបានកាត់បន្ថយម៉ោងរបស់ភាគីការពារក្តីតាមអំពើចិត្តក្នុងការសួរសំណួរដោយពុំបានជូនដំណឹងជាមុន។ ក្នុងការគាំទ្រអំណះអំណាងនេះ ខៀវ សំផន បានយោងទៅលើផ្នែកជាក់លាក់ក្នុងសក្ខីកម្មរបស់ រ៉ចាម គុន *ហៅ* ភី ភួន។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៧៧។ ការពិនិត្យឡើងវិញលើការដកស្រង់ទាំងនេះឃើញថា ការយោងភាគច្រើន គឺទាក់ទងទៅនឹងសំណួរសួរទៅកាន់សាក្សីដោយសហមេធាវីការពារក្តី អៀង សារី ទាក់ទងតែអៀង សារី ប៉ុណ្ណោះ។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម គុន *ហៅ* ភី ភួន) ឯកសារលេខ E1/99.1 ទំព័រ ៧៥ *និង*ប្រតិចារឹកចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ (រ៉ចាម គុន *ហៅ* ភី ភួន) ឯកសារលេខ E1/100.1 ទំព័រ ២៥, ២៨ ដល់ ២៩, ៤៣។ មានតែការយោងមួយប៉ុណ្ណោះដែលទាក់ទងទៅនឹងការអន្តរាគមន៍របស់ប្រធានអង្គជំនុំជម្រះសាលាដំបូងដែលបានប្រាប់ជាចម្លើយមួយទៅនឹងសំណួរ។ ទោះជាយ៉ាងណាក្តី ការពិនិត្យឡើងវិញលើផ្នែកពាក់ព័ន្ធក្នុងប្រតិ

២៧៧.ទាក់ទងទៅនឹងអ្នកជំនាញ Stephen HEDER នៅក្នុងបណ្ដឹងសាទុក្ខ នួន ជា បានលើកយកការប្រព្រឹត្ត របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសាកសួរអ្នកជំនាញរូបនេះ មកធ្វើជាផ្នែកមួយដើម្បីចោទប្រកាន់យ៉ាង ទូលំទូលាយជាបន្តបន្ទាប់ទៅលើអង្គជំនុំជម្រះសាលាដំបូង ដែលបានសំអាងលើសក្ខីកម្មរបស់អ្នកជំនាញខាង លើនេះ សម្រាប់គោលបំណងពុំត្រឹមត្រូវ[668]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយការចោទប្រកាន់ ទាំងនេះជារួមដូចខាងក្រោម[669]។ ទោះជាយ៉ាងណាក្ដី ទាក់ទងទៅនឹងការចោទប្រកាន់ដែលថា អង្គជំនុំជម្រះ សាលាដំបូងបានរឹតត្បិតពុំត្រឹមត្រូវលើវិសាលភាពនៃការសួរសំណួររបស់ នួន ជា លើសាក្សី អង្គជំនុំជម្រះ តុលាការកំពូលយល់ឃើញថា នួន ជា ពុំបង្ហាញថា អង្គជំនុំជម្រះបានប្រព្រឹត្តពុំសមហេតុផល។

២៧៨.អាស្រ័យហេតុនេះ ទឡ្ហីករណ៍ទាក់ទងទៅនឹងបញ្ហានេះត្រូវបដិសេធចោល។

---

ចារឹកបង្ហាញថា ប្រធានបានលើកមតិយោបល់ជាសម្មតិកម្ម និងក្នុងគោលបំណងធ្វើឱ្យសាក្សីស្ងប់អារម្មណ៍ដែលហាក់បីដូចជាមាន ការមិនពេញចិត្ត។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/101.1 ទំព័រ ២៥ ("ហើយលោកសាក្សីសម្រួលអារម្មណ៍បន្តិចទៅ នេះជានីតិវិធីនៃការសួរដេញដោលតាមផ្លូវតុលាការ។ អាចមានបញ្ហាប្រឈម ខ្លះហើយលើបញ្ហាសតិអារម្មណ៍ ពីព្រោះគេហៅនីតិវិធីដេញដោល ឬក៏ឈ្លោះចសួរចម្លើយ នេះគឺគេអនុវត្តនៅក្នុងផ្លូវតុលាការ។ អាច មានបញ្ហាប្រឈម លោកអាចឆ្លើយបានលោកឆ្លើយ លោកឆ្លើយមិនបាន លោកមិនឆ្លើយទៅ ហើយឧទាហរណ៍ថា កម្ពស់ដំបូកប៉ុន្មាន លោកអាចឆ្លើយថា អាហ្នឹងលោកមិនដឹង ព្រោះមិនបានវាស់ផង មិនដឹងកម្ពស់ប៉ុន្មាន ព្រោះពាក្យថា កម្ពស់ទាល់តែច្បាស់លាស់។ អ៊ីចឹ ងហើយបានយើងប្រាប់លោកតាំងពីដើម សូមឱ្យលោករៀបចំនូវការស្ដាប់សំណួរឱ្យបាន លោកអាចឆ្លើយតបខ្លីៗឱ្យចំនឹងសំណួរ លើកលែងតែងសំណួរនុំងវាវែងឱ្យអត្ថាធិប្បាយ យើងធ្វើអត្ថាធិប្បាយ")។ នៅគ្រប់កាលៈទេសៈ ភី ភួន បានឆ្លើយរួចរាល់ហើយនូវ សំណួរដែលបានសួរដោយមេធាវីការពារក្ដី ខៀវ សំផន មុនពេលប្រធានអង្គជំនុំជម្រះប្រាប់ចម្លើយនោះ ដូចនេះ ពុំមានការប៉ះពាល់ ណាមួយឡើយ។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/101.1 ទំព័រ ២៥ ("តើដំបូកហ្នឹងមានកម្ពស់ប៉ុន្មានដែរលោកសាក្សី ? [...] វាកម្ពស់ហ្នឹង ប៉ុន្មានប្រហែលជាមួយម៉ែត្រជាងហ្នឹង")។ ការយោង ដែលនៅសេសសល់របស់ ខៀវ សំផន ពិតប្រាកដណាស់ចង្អុលទៅលើការកាត់ផ្ដាច់ភ្លាមៗនៅពេលវេលាដែលបានផ្ដល់ឱ្យមេធាវី ការពារក្ដីរបស់គាត់ក្នុងការសួរសំណួរ ភី ភួន។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/101.1 ទំព័រ ២៧ ដល់ ២៨។ ទោះជាយ៉ាងណាក្ដី មេធាវីការពារក្ដីទំនងជាអាចបញ្ចប់សំណួររបស់ខ្លួនលើសាក្សី យ៉ាងពេញចិត្តទៅតាមពេលវេលាដែលបានផ្ដល់ឱ្យនោះ។ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ E1/101.1 ទំព័រ ៥៤ ("លោកប្រធាន ខ្ញុំគិតថា លោកប្រធានប្រហែលជាសប្បាយចិត្តនឹងខ្ញុំហើយ ពីព្រោះអ៊ីខ្ញុំឈប់--ចប់សួរចប់ ហើយលោកប្រធាន")។

[668] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥១ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨០ ដល់ ១៨២។

[669] *សូមមើលខាងក្រោម* កថាខណ្ឌ ៣៤០ *ជាអាទិ៍*។

## ៤.គ.៤.ការទទួលយក និងការប្រើប្រាស់ភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់

២៧៩.នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ នៅក្នុងអំឡុងពេលនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. និងយោងតាមវិធានដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ក្រោមលក្ខខណ្ឌមួយចំនួន ភស្តុតាងរបស់បុគ្គលដែលមានទម្រង់ជាចម្លើយលាយលក្ខណ៍អក្សរ ឬប្រតិចារឹក ដែលប្រើសម្រាប់បញ្ជាក់បញ្ហានានាដែលពុំមែនជាសកម្មភាព ឬការប្រព្រឹត្តរបស់ជនជាប់ចោទ អាចទទួលយកបាន បើទោះបីជាជនជាប់ចោទពុំមានឱកាសសួរសំណួរដល់សាមីបុគ្គលនោះ និងថា អង្គជំនុំជម្រះអាចសំអាងជាមូលដ្ឋានលើសម្ភារនោះបាន តែក្នុងលក្ខខណ្ឌមួយចំនួនប៉ុណ្ណោះ[670]។ អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់អំពីកត្តានានាដែលផ្តល់ប្រយោជន៍ក្នុងការទទួលយក និងផ្តល់តម្លៃជាភស្តុតាងទាំងនេះ និងបានបញ្ជាក់ជាក់លាក់ថា ការពុំមានឱកាសដេញដោល ជាពិសេសក្នុងករណីចម្លើយដោយគ្មានការធ្វើសម្បថរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានរៀបចំឡើងដោយអង្គភាពអន្តរការី អាចយកមកធ្វើជាការពិចារណាអំពីភាពពាក់ព័ន្ធបាន ប៉ុន្តែទម្ងន់នៃភស្តុតាងត្រូវបានកាត់បន្ថយ[671]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកចំនួន ១.១២៤ របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលពុំបានបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះ[672]។

២៨០.នៅក្នុងការអនុវត្តវិធីសាស្ត្ររបស់ខ្លួនចំពោះការវាយតម្លៃចុងក្រោយលើភស្តុតាងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះបានរំឭកថា អង្គជំនុំជម្រះពុំអាចពិចាណារលើចម្លើយណាដែលប្រើប្រាស់ជាភស្តុតាងបញ្ជាក់ពីសកម្មភាព និងការប្រព្រឹត្តរបស់ជនជាប់ចោទបានទេ ដោយសារអង្គជំនុំជម្រះពុំមានឱកាសក្នុងការដេញដោលលើភស្តុតាង ដែលករណីបែបនេះ "អង្គជំនុំជម្រះពុំអាចយកមកធ្វើជាសំអាងក្នុងការ

---

[670] សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២២ ដល់ ២៣។

[671] សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២៤ ដល់ ២៥, ២៧ និង ២៩។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤ ("ដោយសារគ្មានឱកាសពិនិត្យប្រភពដើម ឬសាមីបុគ្គលម្ចាស់ចម្លើយ ភស្តុតាងនេះអាចត្រូវបានផ្តល់ទម្ងន់យ៉ាងតិចតួច")(ជើងទំព័រលុបចោល)។

[672] *សូមមើល* សេចក្តីសម្រេចទីពីរស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) និងឧបសម្ព័ន្ធ ក សម្ងាត់ (E299.1)។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣២។

សម្រេចដាក់ពិរុទ្ធភាពណាមួយបានឡើយ"[673] លើកលែងតែក្នុងករណីដែលសាក្សីទទួលមរណភាព។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ផងដែរថា "ដោយសារពុំមានឱកាសក្នុងការសួរដេញដោលលើប្រភព ឬសាមីជននៃភស្តុតាង នាំឱ្យទម្ងន់នៃភស្តុតាងនោះ ត្រូវបានកាត់បន្ថយ"[674]។ ទាក់ទងទៅនឹងការជ្រើសរើសសាក្សីមកផ្តល់សក្ខីកម្ម អង្គជំនុំសាលាដំបូងបានលើកឡើងថា ខ្លួន"បានថ្លឹងថ្លែងលើសិទ្ធិរបស់ភាគីទាំងអស់ក្នុងការស្នើសុំឱ្យពិនិត្យភស្តុតាង និងតម្រូវការចាំបាច់ក្នុងការបើកសវនាការជាសាធារណៈ បន្ទាប់ពីមានការស៊ើបសួរជាសម្ងាត់ សិទ្ធិរបស់ជនជាប់ចោទក្នុងការដេញដោលសាក្សី និងសិទ្ធិរបស់ជនជាប់ចោទនីមួយៗក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងឆាប់រហ័ស"[675]។ អង្គជំនុំជម្រះបានបញ្ជាក់ថា បានស្តាប់សាក្សីចំនួន ៩២ នាក់ប៉ុណ្ណោះ ក្នុងចំណោមសាក្សីសរុបដែលបានស្នើឡើងចំនួន ១.០៥៤ នាក់នោះ[676] ប៉ុន្តែបានបញ្ជាក់ថា "ទោះជាយ៉ាងណាក្តី មានយន្តការដទៃទៀតជាច្រើន ត្រូវបានផ្តល់ដល់ភាគីដើម្បីឱ្យមានលទ្ធភាពលើកបង្ហាញជាលាយលក្ខណ៍អក្សរនូវចម្លើយជាប់ពាក់ព័ន្ធ និងព័ត៌មានដទៃទៀតទាក់ទងទៅនឹងសាក្សីដែលពុំត្រូវបានកោះហៅនោះ"[677]។

២៨១.នួន ជា និង ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ពីបទដ្ឋានដើម្បីទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់ និងការសំអាងជាបន្តបន្ទាប់របស់អង្គជំនុំជម្រះទៅលើភស្តុតាងនោះយ៉ាងច្រើនសន្ធឹកសន្ធាប់ដោយពុំបានប្រឹងប្រែងសមស្រប ក្នុងការវាយតម្លៃពីភាពជឿទុកចិត្តបាន ឬតម្លៃជាភស្តុតាងឡើយ[678]។ ជាពិសេស ពួកគាត់បានលើកឡើងថា អង្គជំនុំជម្រះ

---

[673] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣១ ជើងទំព័រ ៨៥ យោងទៅលើសេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២១ ដល់ ២២, ៣២ ដល់ ៣៣ និងសេចក្តីសម្រេចទីពីរស្តីពីភាពអាចទទួលយកបាន (E299) កថាខណ្ឌ ២៩ ដល់ ៣០។

[674] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤។

[675] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១។

[676] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១ ដល់ ៥២។

[677] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤។

[678] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥៤ ដល់ ១៦៥។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩ និង ១១៧។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦៨។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានចេញសេចក្តីសម្រេចពុំមានសំអាង

សាលាដំបូងបានពង្រីកបទដ្ឋានអន្តរជាតិទាក់ទងទៅនឹងការទទួលយកភស្តុតាងទាំងនោះ ដោយបានផ្តោតជាសំខាន់តែទៅលើភស្តុតាងដែលត្រូវប្រើប្រាស់សម្រាប់បញ្ជាក់ពីអំពើប្រព្រឹត្តរបស់ជនជាប់ចោទប៉ុណ្ណោះ និងពុំបានធ្វើការពិចារណាទៅលើកត្តាជាច្រើនដទៃទៀត ដែលមានដូចជាបញ្ហា ថាតើ ភស្តុតាងនោះ ជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងវិវាទរវាងភាគី ដែរ ឬយ៉ាងណា ឡើយ[679]។ បន្ថែមលើនេះទៀត ពួកគាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ពុំបានពិចារណាអំពីច្បាប់ជាធរមាន ដែលតម្រូវឱ្យមានការបង្ហាញខ្លួន និងការសាកសួររបស់ភាគីម្ខាងទៅលើសាក្សីដាក់បន្ទុកក្នុងពេលជំនុំជម្រះឡើយ ហើយអង្គជំនុំជម្រះបានទទួលយកមកធ្វើជាភស្តុតាងនូវឯកសារយ៉ាងច្រើនដែលពុំធ្លាប់មានពីមុនមក និងពុំគួរឱ្យជឿទុកចិត្តបាន[680]។ ពួកគាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងម្តងហើយម្តងទៀត បានផ្តល់ការយល់ឃើញជាគន្លឹះ ដោយផ្អែកលើចម្លើយដែលពុំអាចជឿទុកចិត្តបាន និង/ឬ ពុំមានការបញ្ជាក់ត្រឹមត្រូវ បើទោះបីជាអង្គជំនុំជម្រះបានបញ្ជាក់ថា ប្រសិនបើមានចម្លើយទាំងនោះមានទម្ងន់ជាភស្តុតាងតិចតួចក្តី[681]។

២៨២.សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងត្រឹមត្រូវនូវបទដ្ឋានក្នុងការទទួលយក និងវាយតម្លៃលើចម្លើយ និងប្រតិចារឹកជាលាយលក្ខណ៍អក្សរនៅក្រៅតុលាការ និងបានកំណត់អង្គហេតុនានាយ៉ាងត្រឹមត្រូវដោយផ្អែកលើបទដ្ឋាននេះ[682]។

២៨៣.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជនជាប់ចោទបានលើកបញ្ហាពាក់ព័ន្ធចំនួនពីរគឺ ទី

---

ហេតុគ្រប់គ្រាន់ និងយឺតពេលស្តីពីការទទួលយកឯកសារ រួមទាំងចម្លើយជាលាយលក្ខណ៍អក្សរ។ អំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹងបញ្ហានេះ បានកម្រិតត្រឹមតែពេលវេលានៃការចេញសេចក្តីសម្រេច ហើយពុំបានពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវផ្នែកគតិយុត្តឡើយ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៦។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះចោលដោយសារខ្វះមូលដ្ឋានគាំទ្រ។

679 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥៤ ដល់ ១៥៥, ១៥៧, ១៦០ ដល់ ១៦២។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩។

680 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥៥ ដល់ ១៥៩។

681 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៣ ដល់ ១៦៥។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩ និង ១១៧។

682 សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨៦ ដល់ ៩០។ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤៨ ដល់ ៦៥។

មួយ បញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានគតិយុត្តជាការត្រឹមត្រូវ ក្នុងការទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់ ដែរ ឬយ៉ាងណា និង ទីពីរ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភស្តុតាងជាលាយលក្ខណ៍អក្សរបែបនេះ ធ្វើជាមូលដ្ឋានសំអាងក្នុងការយល់ឃើញផ្នែកអង្គហេតុក្នុងសាលក្រមនោះ ដែរ ឬយ៉ាងណា។

### ៤.គ.៤.ក.បទដ្ឋានគតិយុត្តក្នុងការទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់

២៨៤.វិធាន ៨៧ នៃវិធានផ្ទៃក្នុងចែងថា ជាគោលការណ៍ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយកនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក. លើកលែងតែភស្តុតាងនោះ មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ច្បាប់មិនអនុញ្ញាត ឬមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

២៨៥.គោលជំហរជាចម្បងរបស់ ខៀវ សំផន និង នួន ជា គឺថា ច្បាប់កម្ពុជាតម្រូវឱ្យមានការបង្ហាញខ្លួនរបស់សាក្សីដាក់បន្ទុកទាំងអស់នៅពេលសវនាការ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "សាក្សីដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឱ្យចូលរួមក្នុងសវនាការ"។ ប្រហាក់ប្រហែលគ្នានេះដែរ វិធាន ៨៤(១) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់អំពី"ជនជាប់ចោទមានសិទ្ធិដាច់ខាត ស្នើសុំឱ្យកោះហៅសាក្សីដាក់បន្ទុក ដែលជនជាប់ចោទមិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ"[683]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បើទោះជាមានបទប្បញ្ញត្តិនេះក៏ដោយ ក៏អង្គជំនុំជម្រះ ត្រូវស្ថិតក្រោមលក្ខខណ្ឌអនុញ្ញាតមួយចំនួន ក្នុងការទទួលយក (និងចុងក្រោយសំអាងលើ)ភស្តុតាងជាលាយលក្ខណ៍អក្សរបាន និងបើទោះបីជាសាមីបុគ្គលនោះ ពុំបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬពុំត្រូវបានសួរសំណួរដោយភាគីការពារក្តីយ៉ាងណាក៏ដោយ។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើបញ្ហា ទីមួយ វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង ក្នុងសំណៅជាភាសាអង់គ្លេសមានពាក្យថា សិទ្ធិ*ដាច់ខាត*របស់ភាគីការពារក្តីក្នុងការស្នើសុំឱ្យកោះហៅសាក្សី និងទី

---

683 អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សំណៅជាភាសាខ្មែរបានយោងទៅលើ"សិទ្ធិរបស់ជនជាប់ចោទក្នុងការកោះហៅសាក្សី" និងជាភាសាបារាំង "L'accusé a le droit d'exiger la comparution d'un témoin avec lequel il n'a pas eu l'occasion d'être confronté au stade de l'instruction (ជនជាប់ចោទមានសិទ្ធិឱ្យកោះហៅសាក្សីដែលខ្លួនពុំទាន់មានឱកាសសួរដេញដោលនៅក្នុងដំណាក់កាលកិច្ចស៊ើបសួរ)"។ *សូមមើល* វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង(ភាសាបារាំង)។

ពីរ មាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានផ្តល់អំណាចដល់ប្រធានអង្គជំនុំជម្រះក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ធ្វើការ"បដិសេធចេញពីការពិភាក្សាដេញដោលនូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលនេះដោយឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសំដែងឱ្យឃើញការពិត"[684]។

២៨៦.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សិទ្ធិក្នុងការសួរដេញដោលសាក្សីដែលប្រឆាំងនឹងជនជាប់ចោទ ដូចមានចែងក្នុងវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង និងមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺជាការឆ្លុះបញ្ចាំងអំពីសិទ្ធិដែលមានចែងក្នុងមាត្រា ១៤(៣-ង) នៃកតិកាតិស្តីពីសិទ្ធិពលរដ្ឋ និងសញ្ញាអន្តរជាសិទ្ធិនយោបាយក្នុងការ"សួរដេញដោល ឬសុំឱ្យសួរដេញដោលលើសាក្សីដែលប្រឆាំងនឹង[ជនជាប់ចោទ]"។ ស្រដៀងគ្នានេះដែរ មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. បានធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការ "សួរដេញដោល ឬសុំឱ្យសួរដេញដោលសាក្សីដែលប្រឆាំងនឹងរូបគាត់" ចំណែកមាត្រា ៣៥ ថ្មី(ង)នៃច្បាប់ អ.វ.ត.ក. ធានាសិទ្ធិរបស់ជនជាប់ចោទក្នុងការ"ពិនិត្យដេញដោលភស្តុតាងដែលប្រឆាំងនឹងរូបគាត់"។ បើទោះបីជាគោលការណ៍ស្តីពីភាពត្រឹមត្រូវនៃការជំនុំជម្រះ មានសារៈសំខាន់ជាសារវ័ន្តក្តី ក៏សិទ្ធិខាងលើនេះពុំមានភាពដាច់ខាតឡើយ[685] ហើយអាចមានការថ្លឹងថ្លែងជាមួយនឹងសិទ្ធិ និងផលប្រយោជន៍សំខាន់ៗដទៃទៀត នៅក្នុងបរិបទនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌមួយ។ ជាការពិត សិទ្ធិដែលជនជាប់ចោទទទួលបានយ៉ាងទូលំទូលាយក្នុងការសួរដេញដោលសាក្សីដែលប្រឆាំងនឹងរូបគាត់បែបនេះ អាចនឹងមានហានិភ័យធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់តុលាការក្នុងការផ្តល់យុត្តិធម៌នៅក្នុងរឿងក្តីដែលមានទំហំធំ និងមានភាពស្មុគស្មាញដូចរឿងក្តីបច្ចុប្បន្ននេះ ដែលតុលាការត្រូវជ្រើសរើស គឺការកោះហៅក្នុងចំណោមសាក្សីដ៏ច្រើនសន្ធឹកសន្ធាប់មកផ្តល់សក្ខី

---

[684] សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ១៨។

[685] *សូមមើល* មតិយោបល់ទូទៅរបស់គណៈកម្មាធិការស្តីពីសិទ្ធិមនុស្ស (HRC) លេខ ៣២ កថាខណ្ឌ ៣៩៖ ("សិទ្ធិស្របតាមវិធាន ១៤(៣-ង) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ] ទោះជាយ៉ាងណាក្តី ពុំបានផ្តល់សិទ្ធិដោយឥតកំណត់ក្នុងការទទួលបាននូវកោះហៅសាក្សីណាមួយដែលត្រូវបានស្នើសុំដោយជនជាប់ចោទ ឬមេធាវីរបស់ខ្លួនឡើយ ប៉ុន្តែផ្តល់ត្រឹមតែសិទ្ធិសុំឱ្យតុលាការទទួលយកសាក្សីដែលជាប់ពាក់ព័ន្ធសម្រាប់ការពារខ្លួន និងផ្តល់ឱកាសសមស្របក្នុងការសួរសំណួរ និងជំទាស់សាក្សីដែលប្រឆាំងនឹងខ្លួននៅពេលណាមួយនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ")។ *សូមមើលផងដែរ* សាលក្រម *រឿងក្តី S.N. ទល់នឹងប្រទេសស្វីស* (ECtHR) កថាខណ្ឌ ៤៤ ("មាត្រា ៦ [នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស] ពុំបានផ្តល់សិទ្ធិដោយគ្មានព្រំដែនដល់ជនជាប់ចោទក្នុងការធានាបាននូវការចូលខ្លួនរបស់សាក្សីចំពោះមុខតុលាការឡើយ។ ជាធម្មតា អាស្រ័យលើតុលាការក្នុងការសម្រេចថាតើ ជាការចាំបាច់ ឬជាការសមស្របក្នុងការស្តាប់សាក្សីនោះ ដែរ ឬយ៉ាងណា")។ ស្រដៀងគ្នានេះដែរ *រឿងក្តី Trofimov ទល់នឹង ប្រទេសរុស្ស៊ី* (ECtHR) កថាខណ្ឌ ៣៣។ *រឿងក្តី F និង M ទល់នឹង ប្រទេសហ្វាំងឡង់* (ECtHR) កថាខណ្ឌ ៥៦។

កម្មចំពោះមុខតុលាការ ដែលនាំឱ្យមានការលំបាកក្នុងការរៀបចំសវនាការ និងចំណាយពេលយ៉ាងយូរហួសកំណត់ ឬត្រូវលះបង់ការសំអាងទៅលើភស្តុតាងដែលអាចសំខាន់ក្នុងការបំភ្លឺជាបរិបទ និងភាពធំធេងនៃរឿងក្ដី ប៉ុន្តែប្រហែលជាពុំស៊ីជម្រៅដល់បញ្ហាស្នូលនៃរឿងក្តីនោះ។

២៨៧.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង និងមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវបានបកស្រាយយ៉ាងច្បាស់ថា "បានផ្តល់សិទ្ធិដោយមានការកម្រិត" បន្ថែមលើនេះ បទប្បញ្ញត្តិទាំងនេះបានអនុញ្ញាតឱ្យមានការរឹតត្បិតនូវសិទ្ធិក្នុងគោលបំណងជាពិសេសដើម្បីប្រយោជន៍ពន្លឿនកិច្ចដំណើរការនីតិវិធី។ ទាក់ទងទៅនឹងការលើកឡើងដែលថា វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង និយាយពីសិទ្ធិ"ដាច់ខាត" យោងតាមសំណៅជាភាសាអង់គ្លេសឃើញថា មិនមានពាក្យដូច្នេះឡើយនៅក្នុងសំណៅជាភាសាខ្មែរ និងបារាំង។ ទាក់ទងទៅនឹងវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង ដោយយោងតាមសំណៅជាភាសាខ្មែរ និងបារាំងឃើញថា មានខ្លឹមសារសមស្របជាងសម្រាប់បរិបទរបស់តុលាការដូច អ.វ.ត.ក. នេះ ដូច្នេះហើយទើបសំណៅទាំងពីរនេះ ទទួលបានអាទិភាពជាងសំណៅជាភាសាអង់គ្លេស។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសទេក្នុងការយល់ឃើញថា សិទ្ធិក្នុងការសួរដេញដោលសាក្សីដែលប្រឆាំងនឹងជនជាប់ចោទត្រូវបានកម្រិត[686]។

២៨៨.បញ្ហាចោទបន្ទាប់គឺ ថាតើអង្គជំនុំជម្រះសាលាដំបូង មានកំហុស ដែរ ឬយ៉ាងណា ក្នុងការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសភស្តុតាងផ្ទាល់មាត់ ដោយផ្អែកលើការអនុវត្តអន្តរជាតិ។ មាត្រា ៣៣ ថ្មី(១) នៃច្បាប់ អ.វ.ត.ក. និងមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. ចែងថា នីតិវិធីនៅចំពោះមុខ អ.វ.ត.ក. ត្រូវតែស្របជាមួយនឹងច្បាប់កម្ពុជា ប៉ុន្តែក្នុងករណីដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ "គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងពិតជាបានអនុវត្តដូចមានចែងខាងលើ ដោយបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននូវចម្លើយជាលាយលក្ខណ៍អក្សរ (E96/7)[687] និងនៅក្នុងសេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299)[688] ប៉ុន្តែបែរជា នួន ជា និង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងធ្វើពុំបានត្រឹមត្រូវ

---

[686] សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ១៧ ដល់ ១៩។

[687] *សូមមើល* កថាខណ្ឌ ២៤ *ជាអាទិ៍* នោះ។

[688] *សូមមើល* សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) កថាខណ្ឌ ១៧ *ជាអាទិ៍*។

01358101



ទៅវិញ។

២៨៩.ជាការកត់សម្គាល់ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការទទួលយកចម្លើយមកប្រើប្រាស់ជាភស្តុតាងបញ្ជាក់ពីអំពើប្រព្រឹត្តរបស់គាត់ គឺជាការរំលោភបំពានលើវិធានដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ[689]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញយ៉ាងច្បាស់ថា ភស្តុតាងជាលាយលក្ខណ៍អក្សរដែលប្រើប្រាស់សម្រាប់បញ្ជាក់ពីសកម្មភាព ឬការប្រព្រឹត្តរបស់ជនជាប់ចោទ ពុំអាចទទួលយកបានឡើយ[690]។ ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងផ្តល់ការយល់ឃើញដោយ"ភ្ជាប់អំពើប្រព្រឹត្តរបស់ជនជាប់ចោទ"ទៅនឹងគោលនយោបាយនៃការរៀបការដោយបង្ខំ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចំណុចនៃសាលក្រមដែល ខៀវ សំផន បានយោងនោះ អង្គជំនុំជម្រះសាលាដំបូងពុំបានលើកឡើងអំពីសកម្មភាព ឬការប្រព្រឹត្តរបស់គាត់ឡើយ ហើយភស្តុតាងដែលអង្គជំនុំជម្រះបានយោងនោះ ពុំបានជាប់ពាក់ព័ន្ធទៅនឹងបញ្ហានេះទេ[691]។ ផ្ទុយពីការលើកឡើងរបស់ ខៀវ សំផន ឃើញថា ពុំមានភាពគ្រប់គ្រាន់ស្តែងឱ្យឃើញថា សំអាងហេតុ"មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងទម្រង់នៃការទទួលខុសត្រូវដែលពាក់ព័ន្ធ ជាពិសេស ទៅនឹងអំពើប្រព្រឹត្តរបស់ជនជាប់ចោទឡើយ"[692]។ យោងតាមហេតុផលដូចគ្នានេះ ការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដដែលៗ ក្នុងការផ្តល់សំអាងហេតុនានាពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ គឺជាការពុំត្រឹមត្រូវឡើយ ដោយហេតុថា សំអាងហេតុដែលរងការចោទប្រកាន់នោះ ពុំមានជាប់ពាក់ព័ន្ធទៅនឹង"អំពើប្រព្រឹត្ត"របស់គាត់ឡើយ[693]។

២៩០.នួន ជា បានអះអាងដោយបានយោងនៅក្នុងជើងទំព័រទៅលើវិធាន ៩២ *ស្ទួន*(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកជាភស្តុតាងនូវឯកសារលាយ

---

689 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩។

690 *សូមមើល* សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២២។

691 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៨ និង ជើងទំព័រ ៣៧២។

692 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩។ *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំ *រឿងក្តី* Galić (ICTY) កថាខណ្ឌ ៩។

693 *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨ និងជើងទំព័រ ១៧៦៧, ១៧៦៨ និង ១៧៦៩។

លក្ខណ៍អក្សរជាច្រើន មានដូចជា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះ ដែលពុំបាន"បំពេញទៅតាមលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់ការទទួលយកនៅក្នុងតុលាការឧក្រិដ្ឋកម្ម *មិនអចិន្ត្រៃយ៍*" ដែលតុលាការឧក្រិដ្ឋកម្មនេះពុំធ្លាប់ទទួលយកយ៉ាងច្រើនដូច្នេះទេ[694]។ បទប្បញ្ញត្តិនេះតម្រូវថា សាមីបុគ្គលម្ចាស់ចម្លើយជាលាយលក្ខណ៍អក្សរដែលត្រូវបានទទួលយកជាភស្តុតាង ត្រូវធ្វើការប្រកាសទាក់ទងទៅនឹងភាពប្រាកដប្រជានូវខ្លឹមសារចម្លើយនេះ នៅចំពោះមុខបុគ្គលដែលមានសមត្ថកិច្ចណាម្នាក់។ វិធាន ៩២ *ស្ទួន*(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR មានចែងអំពីវិធានសម្រាប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ ICTR ដូចគ្នានឹងបទប្បញ្ញត្តិខាងលើ ចំណែកវិធាន ៦៨ (២-ខ-២ និង ៣) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC មានចែងប្រហាក់ប្រហែលគ្នានេះដែរ។ ផ្ទុយទៅវិញ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ SCSL ព្រមទាំងវិធានរបស់តុលាការ STL ពុំបានតម្រូវថា សាមីជនម្ចាស់ចម្លើយជាលាយលក្ខណ៍អក្សរអាចប្រកាសបែបនេះឡើយ[695]។ ដូច្នេះ ការអនុវត្តជាអន្តរជាតិពាក់ព័ន្ធទៅនឹងបញ្ហានេះ ពុំមានលក្ខណៈស្របគ្នាទាំងស្រុងនោះឡើយ ហើយពុំអាចចាត់ទុកថា ការដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចយកលក្ខខណ្ឌតម្រូវដូចមានចែងក្នុងវិធាន ៩២ ស្ទួន(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY មកប្រើប្រាស់ថា មានកំហុសនោះទេ។

២៩១.នួន ជា បានអះអាងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅពេលដែលអង្គជំនុំជម្រះនេះបានយកលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលយកចម្លើយក្រៅតុលាការមកប្រើប្រាស់លើភស្តុតាងជាលាយលក្ខណ៍អក្សរ ដែលបានប្រមូលដោយពុំមានគោលបំណងជាក់លាក់សម្រាប់តវ៉ាក្តី ដោយយោង*ក្នុងចំណោមនោះ*ទៅលើការរៀបរាប់របស់បុគ្គលនានា ដែលប្រមូលបានដោយ Henri Locard, François Ponchaud និង Stephen Heder។ នួន ជា បានអះអាងថា យោងតាមការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មមិនអចិន្ត្រៃយ៍ បទដ្ឋានសម្រាប់ការទទួលយកភស្តុតាងចចាមអារ៉ាមគួរតែត្រូវបានយកមកអនុវត្ត[696]។ ទោះជាយ៉ាងណាក្តី នួន ជា ពុំបានផ្តល់មូលដ្ឋានគាំទ្រថា ការអនុវត្តតាមបទដ្ឋាននោះ នឹងនាំឱ្យភស្តុតាងត្រូវបានបដិសេធឡើយ។ អាស្រ័យហេតុនេះ អំ

---

[694] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥៨ និង ជើងទំព័រ ៤០០។

[695] *សូមមើល* វិធាន ៩២*ស្ទួន* នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ SCSL និងវិធាន ១៥៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL ។

[696] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥៨ និង ជើងទំព័រ ៤០២។ *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ *រឿងក្តី Galić* (ICTY) កថាខណ្ឌ ២៨។

ណះអំណាងនេះ ត្រូវបានបដិសេធចោល។ ទាក់ទងទៅនឹងបញ្ហានេះ គួរកត់សម្គាល់ផងដែរថា លក្ខខណ្ឌតម្រូវក្នុងការទទួលយកចម្លើយរបស់សាក្សីជំនួសសក្ខីកម្មផ្ទាល់មាត់បង្ហាញថា មានលក្ខណៈ“រឹតត្បិត”ជាងលក្ខខណ្ឌតម្រូវផ្សេងទៀតចំពោះការទទួលយកសម្ភារ ដែលបានប្រមូលដោយពុំមានគោលបំណងដាក់លាក់សម្រាប់កិច្ចដំណើរការនីតិវិធី[697]។

២៩២.នួន ជា បានយោងទៅលើគោលការណ៍មួយចំនួនដែលចែងអំពីការទទួលយកនូវចម្លើយជាលាយលក្ខណ៍អក្សរនៅក្នុងតុលាការឧក្រិដ្ឋកម្មមិនអចិន្ត្រៃយ៍ (ដូចជា ភស្តុតាងជាលាយលក្ខណ៍អក្សរត្រូវតែស៊ីសង្វាក់គ្នាជាមួយភស្តុតាងផ្ទាល់) ដែលតាមការលើកឡើងរបស់គាត់ថា អង្គជំនុំជម្រះពុំបានអើពើឡើយ[698]។ ទោះជាយ៉ាងណាក្តី ផ្ទុយទៅនឹងអ្វីដែលគាត់បានអះអាង អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់យ៉ាងច្បាស់លាស់លើការពិចារណាទាំងនេះ នៅក្នុងសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃចម្លើយជាលាយលក្ខណ៍អក្សរ និងបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងយកមកអនុវត្ត នៅពេលធ្វើការសម្រេចលើការទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរ[699]។ ប៉ុន្តែ នួន ជា ពុំបានផ្តល់មូលដ្ឋានគាំទ្រចំពោះការអះអាងយ៉ាងទូលំទូលាយរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការពិចារណាទាំងនេះឡើយ[700]។

២៩៣.លើសពីនេះទៀត នួន ជា បានលើកឡើងថា ចម្លើយណាមួយដែល“លើកឡើងពីធាតុផ្សំសំខាន់នៃរឿងក្តី ឬជាប់ពាក់ព័ន្ធបញ្ហាចំពោះមុខវាងភាគី ប៉ុន្តែពុំមែនបញ្ហាពាក់ព័ន្ធតូចតាច ឬបន្ទាប់បន្សំនោះទេ”ត្រូវតែដាក់ឱ្យធ្វើការដេញដោល[701]។ ដើម្បីគាំទ្រអំណះអំណាងនេះ នួន ជា បានយោងទៅលើសេចក្តីសម្រេចរបស់តុលាការ ICTY និង ICTR ដែលបានបញ្ជាក់ថា ក្នុងកាលៈទេសៈបែបនេះ ប្រសិនបើភស្តុតាងជាលាយលក្ខណ៍អក្សរដែលធ្វើដោយសាក្សី អាចត្រូវបានទទួលយក សាក្សីនោះក៏អាចត្រូវបានកោះហៅ ដើម្បីសួរដេញដោលដោយភា

[697] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ *រឿងក្តី Galić* (ICTY) កថាខណ្ឌ ៣១។

[698] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦១ ដល់ ១៦២។

[699] *សូមមើល* សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២៤។ សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងភាពអាចទទួលកបាន (E299) កថាខណ្ឌ ១៨ *ជាអាទិ៍*។

[700] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៣។

[701] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦២។

01358104



គឺជំទាស់[702]។ ដូច្នេះ បញ្ហាពុំមែនស្ថិតនៅលើ ថាតើភស្តុតាងជាលាយលក្ខណ៍អក្សរអាចត្រូវបានទទួលយក ដែរ ឬយ៉ាងណានោះឡើយ ប៉ុន្តែស្ថិតនៅលើ ថាតើវិធានការបន្ថែមអ្វីខ្លះ ដែលបានធ្វើឡើងដើម្បីធានាសិទ្ធិរបស់ជនជាប់ចោទនោះ។ បញ្ហានេះ ត្រូវបានបញ្ជាក់តាមរយៈយុត្តិសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើនៅក្នុងសេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) ហើយដោយផ្អែកលើយុត្តិសាស្ត្រនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងរបស់ជនជាប់ចោទដែលលើកឡើងថា ចម្លើយជាលាយលក្ខណ៍អក្សរទាក់ទងទៅនឹង"បញ្ហាសំខាន់" ពុំអាចទទួលយកជាភស្តុតាងនោះ[703]។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយការសំអាងរបស់អង្គជំនុំជម្រះ លើភស្តុតាងដែលពុំត្រូវបានពិនិត្យដោយភាគីការពារក្តីនៅក្នុងផ្នែកខាងក្រោមក្នុងសាលដីកានេះ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នួន ជា ពុំបានបង្ហាញពីកំហុសក្នុង*ការទទួលយក*ភស្តុតាងជាលាយលក្ខណ៍អក្សរនេះឡើយ។

២៩៤.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នួន ជា និង ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលដែលសម្រេចថា ចម្លើយជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់ អាចទទួលយកបាន ប៉ុន្តែត្រូវស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួន។ អាស្រ័យហេតុនេះ សារណារបស់ នួន ជា និង ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះ ត្រូវបដិសេធចោល។

### **៤.គ.៤.ខ.ទម្ងន់នៃភស្តុតាង ដែលបានផ្តល់ទៅលើចម្លើយជាលាយលក្ខណ៍អក្សរ ជំនួសសក្ខីកម្មផ្ទាល់មាត់**

២៩៥.បញ្ហាទីពីរដែលត្រូវដោះស្រាយគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់ធ្ងន់ពេកទៅលើភស្តុតាងជាលាយលក្ខណ៍អក្សរ ដែរ ឬយ៉ាងណា។ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"ខកខានម្តងហើយម្តងទៀត"ក្នុងការវាយតម្លៃឱ្យបានត្រឹមត្រូវលើភាពអាចជឿទុកចិត្តបាន និងតម្លៃជាភស្តុតាងចំពោះចម្លើយជាលាយលក្ខណ៍អក្សរ[704]។ ខៀវ សំផន បានអះអាងប្រហាក់ប្រហែលគ្នានេះដែរ ប៉ុន្តែលើកឡើងពុំបានលម្អិត[705]។ អំណះអំណាងសំខាន់របស់ពួកគាត់ គឺថា (i) អង្គជំនុំជម្រះសាលាដំបូងគួរតែបានផ្តល់សំអាងហេតុជាលាយ

---

[702] សេចក្តីសម្រេចលើសំណើទីបីរបស់ភាគីការពារក្តីសុំឱ្យទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ និងឯកសារភ្ជាប់ជាមួយ *រឿងក្តី Nzabonimana* (ICTR) កថាខណ្ឌ ១៨។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំ*រឿងក្តី Galić* (ICTY) កថាខណ្ឌ ១៣។

[703] *សូមមើល* សេចក្តីសម្រេចទីពីរស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) កថាខណ្ឌ ១៩ និងជើងទំព័រ ៧១។

[704] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៥៩។

[705] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩, ១១៧ និង ៤៦៨។

លក្ខណ៍អក្សរ ក្នុងការសម្រេចរបស់ខ្លួនអំពីតម្លៃជាភស្តុតាងទៅលើចម្លើយជាលាយលក្ខណ៍អក្សរនីមួយៗ[706] (ii) អង្គជំនុំជម្រះសាលាដំបូងបានផ្អែកតែទៅលើចម្លើយជាលាយលក្ខណ៍អក្សរប៉ុណ្ណោះក្នុងការបង្ហាញនូវអង្គហេតុគន្លឹះដែលចោទជាបញ្ហា[707] និង (iii) អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាពីភាពអាចជឿទុកចិត្តបានលើប្រភពនៃចម្លើយជាលាយលក្ខណ៍អក្សរ[708]។

២៩៦.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ភស្តុតាងជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពុំបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ និងភាគីនោះ ជាទូទៅត្រូវតែផ្តល់តម្លៃជាភស្តុតាងទាបជាងភស្តុតាងនៃសក្ខីកម្មដែលសាក្សីបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ។ លើកលែងតែកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតជាគោលការណ៍ តម្លៃជាភស្តុតាងទាបត្រូវផ្តល់ចំពោះភស្តុតាងដែលពុំត្រូវបានប្រមូលជាក់លាក់សម្រាប់គោលបំណងនៃការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ ដូចជាក្នុងករណីនៃការរៀបរាប់ដែលប្រមូលដោយ Henri LOCARD François PONCHAUD និង Stephen HEDER។ ទីមួយ នេះគឺដោយសារអង្គជំនុំជម្រះសាលាដំបូងអាចនឹងពុំមានឱកាសក្នុងការវាយតម្លៃលើអត្តចរិតរបស់បុគ្គល ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម និងសួរដេញដោលបំភ្លឺលើបញ្ហានានាឡើយ។ ទីពីរ យោងតាមយុត្តិសាស្ត្រដែលគួរឱ្យជឿជាក់បានរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ការដាក់ពិរុទ្ធភាពពុំអាចផ្អែកតែមួយមុខ ឬដោយពុំបានពិចារណាវែងឆ្ងាយទៅលើភស្តុតាងរបស់សាក្សីណាម្នាក់ដែលភាគីការពារក្តីពុំមានឱកាសសួរដេញដោលឡើយ លើកលែងតែជនជាប់ចោទត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការជំទាស់ភស្តុតាងប្រឆាំងនឹងខ្លួន[709]។ ទីបី ភាពគួរជឿទុកចិត្តបាន ភាពច្បាស់លាស់ និងត្រឹមត្រូវនៃចម្លើយក្រៅតុលាការដែល ប្រមូលបានពីខាងក្រៅក្របខ័ណ្ឌនៃនីតិវិធីរបស់តុលាការ ទទួលរងផល

---

[706] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៣។

[707] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩ ១១៧ និង ៤៦៨។

[708] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៤ ដល់ ១៦៥។

[709] *សូមមើល ឧ.* សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់ *រឿងក្តី Al-Khawaja ទល់នឹងចក្រភពអង់គ្លេស* (ECtHR) កថាខណ្ឌ ១២៧, ១៤៧។ សាលដីកា *រឿងក្តី Kazakov ទល់នឹងប្រទេសរុស្ស៊ី* (ECtHR) កថាខណ្ឌ ២៩។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី Popović* (ICTY) កថាខណ្ឌ ៩៦ ("ការសម្រេចដាក់ពិរុទ្ធភាពពុំអាចសំអាងតែមួយមុខគត់ ឬដោយខ្វះការពិចារណាវែងឆ្ងាយលើភស្តុតាងរបស់សាក្សីដែលជនជាប់ចោទគ្មានឱកាសនឹងសួរសំណួរ ឬពុំបានសួរក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ឬនៅពេលជំនុំជម្រះ។ គោលការណ៍នេះអនុវត្តចំពោះ"អង្គហេតុណាដែលសំខាន់ពុំអាចខ្វះបានសម្រាប់ការដាក់ពិរុទ្ធភាព"(ជើងទំព័រលុបចោល))។

ប៉ះពាល់ដោយសារកង្វះទម្រង់បែបបទ និងការធានាបាន ហើយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានឆ្លុះបញ្ចាំងនូវក្តីបារម្ភអំពីតម្លៃជាភស្តុតាងចំពោះភស្តុតាងក្រៅតុលាការ ដោយបានបញ្ជាក់ថា "អង្គជំនុំជម្រះក៏បានពិចារណាផងដែរលើការកំណត់អត្តសញ្ញាណ ការសួរដេញដោល ភាពលម្អៀង ប្រភព និងកត្តាជំរុញ ឬកង្វះនៃកត្តាទាំងនេះរបស់សាមីបុគ្គល និងប្រភពនៃភស្តុតាង។ ដោយសារគ្មានឱកាសក្នុងការសួរដេញដោលអំពីប្រភព ឬសាមីបុគ្គលនៃភស្តុតាង ភស្តុតាងនេះត្រូវបានផ្តល់ទម្ងន់ស្រាល"[710]។ អង្គជំនុំជម្រះសាលាដំបូងបានយកចិត្តទុកដាក់ទៅលើ"បញ្ហា ថាតើភាគីមានឱកាសជំទាស់ទៅនឹងភស្តុតាង"[711] និងបានស្តាប់សារណាលម្អិតក្នុងអំឡុងពេលសវនាការស្តីពីភាពអាចទទួលយកបានលើតម្លៃជាភស្តុតាង និងទម្ងន់ដែលត្រូវផ្តល់ទៅលើភស្តុតាង[712]ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងក៏បានយកចិត្តទុកដាក់ផងដែរអំពីបញ្ហាដែលភាគីការពារក្តីពុំមានឱកាសសួរដេញដោលសាមីជនម្ចាស់ចម្លើយជាលាយលក្ខណ៍អក្សរ និងថា បញ្ហានេះនាំឱ្យមានឥទ្ធិពលលើទម្ងន់ដែលត្រូវផ្តល់ទៅលើចម្លើយជាលាយលក្ខណ៍អក្សរនោះ[713]។ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីទទួលយកចម្លើយប្រភេទនេះមួយចំនួន បន្ទាប់ពីបានស្តាប់ការសារណារបស់ភាគីលើឯកសារនីមួយៗ[714] ហើយបានពន្យល់ពីលក្ខណៈពិសេសនៃប្រភេទឯកសារនីមួយៗ[715]។ ឧទាហរណ៍ អង្គជំនុំ

---

[710] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤។

[711] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤។

[712] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦។

[713] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤។ សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) កថាខណ្ឌ ១៩។ សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២៥។

[714] សវនាការលើកទីបីស្តីពីឯកសារ៖ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E1/46.1។ ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E1/47.1។ ប្រតិចារឹកចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E1/49.1។ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងឧបសម្ព័ន្ធ ក១ ដល់ ក៥ របស់សហព្រះរាជអាជ្ញា និងទៅនឹងឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនៃសេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ២១ និង ៣០។ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងឧបសម្ព័ន្ធ ក៦ ដល់ ក១១ របស់សហព្រះរាជអាជ្ញា និង ដោយភាគីដទៃទៀត ឯកសារលេខ (E185/1.3) ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៣, ១៩។ សេចក្តីសម្រេចលើកទីបីលើការជំទាស់ទៅនឹងឯកសារ ដែលបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (E185/2) កថាខណ្ឌ ២០, ២៤ និង ២៦។ សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) កថាខណ្ឌ ២១, ២៣, ២៦, ៣០ និង ៣២។

ជម្រះបានរកឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បើទោះជាអាចទទួលយកបានក៏ដោយ ក៏ពុំអាចទទួលបានសច្ចធារណ៍នៃភាពអាចជឿទុកចិត្តបាន និងក្នុងករណីដែលកាលៈទេសៈពុំមានភាពច្បាស់លាស់ក្នុងការបំពេញពាក្យសុំទាំងនេះ ដូច្នេះពាក្យសុំទាំងនេះ ប្រហែលជា"ទទួលបានតម្លៃជាភស្តុតាងទាបប៉ុណ្ណោះប្រសិនបើមាន"[716]។

២៩៧.ក្នុងការគាំទ្រអំណះអំណាងដែលថា អង្គជំនុំជម្រះពុំបានអនុវត្តបទដ្ឋានទាំងនោះ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះពុំបានផ្តល់"ការយោងជាក់លាក់សូម្បីតែម្តង [...] ទៅលើបញ្ហានៃការពុំបានសួរដេញដោល ឬភាពអាចជឿទុកចិត្តបាននៃកំណត់ហេតុស្តាប់ចម្លើយ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬពាក្យបណ្តឹងណាមួយឡើយ"[717]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហានេះពុំមែនជាកំហុសទូទៅនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទេ បើធៀបទៅនឹងកំហុសក្នុងការយល់ឃើញផ្នែកអង្គហេតុជាក់លាក់នោះ។ ទីមួយ ដោយសារពុំមានលក្ខខណ្ឌតម្រូវនៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. ថា ត្រូវផ្តល់សំអាងហេតុជាលាយលក្ខណ៍អក្សរក្នុងការវាយតម្លៃលើចម្លើយនីមួយៗ[718] ហើយការធ្វើបែបនេះពុំបានជាប្រយោជន៍ក្នុងការជំនុំជម្រះដោយឆាប់រហ័សឡើយ។ បន្ថែមលើនេះទៀត មានឧទាហរណ៍ជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូង បានផ្តល់ការយោងយ៉ាងជាក់លាក់ទៅលើភាពអាចជឿទុកចិត្តបាននៃចម្លើយជាលាយលក្ខណ៍អក្សរនីមួយៗ[719]។

---

[715] សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងភាពអាចទទួលយកបាន (E299) កថាខណ្ឌ ២៣ ដល់ ៤៤។ សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២៦ ដល់ ៣៣។

[716] សេចក្តីសម្រេចស្តីពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ (E96/7) កថាខណ្ឌ ២៩។

[717] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៣។

[718] អ.វ.ត.ក. ពុំបានអនុម័តបទដ្ឋាននៃការទទួលយកចម្លើយក្រៅតុលាការដូចមានចែងនៅក្នុងវិធាន ៦៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC។ អាស្រ័យហេតុនេះ ការសម្រេចនៅក្នុងសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃភស្តុតាង *រឿងក្តី Bemba* កថាខណ្ឌ ៨១ ដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC មានកំហុសដោយបានសម្រេច"ទទួលយកចម្លើយដែលបានកត់ត្រាពីមុនដោយគ្មានការពិចារណាលើចំណុចនីមួយៗដោយប្រុងប្រយ័ត្ន"នោះ ពុំអាចអនុវត្តបានចំពោះរឿងក្តីបច្ចុប្បន្នឡើយ។

[719] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០ (សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃកាលៈទេសៈដែលក្នុងនោះ កំណត់ហេតុនៃការស្តាប់ចម្លើយរវាង នួន ជា និង ខៀវ សំផន ត្រូវបានធ្វើឡើង និងបានរកឃើញថា ប្រតិចារឹកជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយមានមូលដ្ឋានគួរឱ្យជឿទុកចិត្តបានសម្រាប់ការយល់ឃើញអំពីអង្គហេតុ)។ អង្គជំនុំជម្រះ

២៩៨.ទីពីរ បញ្ហាដែលស្មុគស្មាញជាងនេះទៀតនោះ ថាតើអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើចម្លើយជាលាយលក្ខណ៍អក្សរក្រៅតុលាការជ្រុលហួសហេតុពេក ដែរ ឬយ៉ាងណា។ នួន ជា បានលើកឡើងថា ចម្លើយក្រៅតុលាការរបស់សាក្សីតែមួយ ពុំអាចយកមកធ្វើជាមូលដ្ឋានក្នុងការបង្ហាញអង្គហេតុគន្លឹះដែលជាបញ្ហាវិវាទរវាងភាគីបានឡើយ និងបានយោងទៅលើចំណុចមួយចំនួននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលអង្គជំនុំជម្រះបានធ្វើដូច្នោះ[720]។ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណានៅក្នុងផ្នែកសមស្របនៃសាលដីកានេះ ប្រសិនបើចម្លើយក្រៅតុលាការត្រូវបានផ្តល់តម្លៃជាភស្តុតាងខ្ពស់ពេកនោះ និងជាពិសេសលើបញ្ហា ថាតើការដាក់ពិរុទ្ធភាពបានផ្អែកទៅលើចម្លើយក្រៅតុលាការតែមួយមុខគត់ ឬដោយពុំបានពិចារណាវែងឆ្ងាយទៅលើចម្លើយរបស់បុគ្គលដែលភាគីការពារក្តីពុំត្រូវបានផ្តល់ឱកាសសួរដេញដោល។

២៩៩.ទោះជាយ៉ាងណាក្តី នួន ជា និង ខៀវ សំផន ពុំបានបង្ហាញឱ្យឃើញពីកំហុសទាក់ទងទៅនឹងវិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះការទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មក្នុងតុលាការ។ អាស្រ័យហេតុនេះ រាល់ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះត្រូវបដិសេធចោល។

## ៤.គ.៥.ការវាយតម្លៃលើភស្តុតាងចចាមអារ៉ាម

៣០០.ដោយហេតុថា ពុំមានការយោងជាក់លាក់ទៅលើពាក្យដែលថា "ភស្តុតាងចចាមអារ៉ាម" អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "ដោយពុំមានឱកាសពិនិត្យលើប្រភពដើម ឬសាមីបុគ្គលនៃភស្តុតាង ភស្តុតាងនោះអាចនឹងត្រូវបានផ្តល់ទម្ងន់ស្រាល"[721]។ នួន ជា និង ខៀវ សំផន ពុំបានជំទាស់ទៅនឹងការបញ្ជាក់ច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងអំពីបទដ្ឋាន ដែលអាចអនុវត្តបានចំពោះការវាយតម្លៃលើភស្តុតាងចចាមអារ៉ាមនោះទេ[722] ប៉ុន្តែ ពួកគាត់បែរជាចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូង ពុំបានអនុវត្តបទដ្ឋានក្នុងការវាយតម្លៃលើភស្តុតាងនេះទៅវិញ[723]។ ជាពិសេស នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ជា

---

សាលាដំបូង កថាខណ្ឌ ៣៩៧ (អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា កំណត់ត្រានៃការសម្ភាសន៍ដែលបានធ្វើឡើងដោយ Stephen HEDER ពុំគប្បីត្រូវបានផ្តល់តម្លៃជាភស្តុតាងសំខាន់ឡើយ)។

[720] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៣ និង ១៦៥។

[721] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤។

[722] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៦ ដល់ ១៨៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១៦។

[723] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧០ ដល់ ១៧១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១៦។

ច្រើនលើកច្រើនសា បានផ្អែកលើភស្តុតាងចចាមអារ៉ាមដែលមានលក្ខណៈអនាមិក និង/ឬពុំមានអ្វីគាំទ្របន្ថែម ក្នុងការផ្តល់ការយល់ឃើញអំពីអង្គហេតុសំខាន់ៗដែលត្រូវបានបង្ហាញនៅក្នុងវិវាទនោះ[724]។ គាត់ជំទាស់ថា អង្គជំនុំជម្រះសាលាដំបូង ជារឿយៗធ្វើពុំបានត្រឹមត្រូវក្នុងការកំណត់ចរិតលក្ខណៈ ឬក្នុងការពិចារណាលើភស្តុតាងចចាមអារ៉ាម[725]។ គាត់បានលើកឡើងថា "ការបំពានយ៉ាងធ្ងន់ធ្ងរទៅលើភស្តុតាង ត្រូវបានបង្ហាញច្បាស់នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ទាហាននៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់នៅឧដុង្គក្នុងឆ្នាំ ១៩៧៤ ដែលបានផ្អែក*តែ*ទៅលើការសន្ទនារបស់ Philip SHORT ជាមួយនឹង*អ្នកភូមិ*ប៉ុណ្ណោះ" ដែលការយល់ឃើញនេះ "បន្ទាប់មក បានក្លាយជាមូលដ្ឋានដ៏សំខាន់ក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលនយោបាយរបស់ ប.ក.ក. ក្នុងការកំណត់គោលដៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរ កើតមានចាប់តាំងពីមុនឆ្នាំ ១៩៧៥ រហូតមក"[726]។

៣០១.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវលើភស្តុតាងចចាមអារ៉ាម និងថា ការលើកឡើងរបស់ នួន ជា អំពីកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង បានធ្វើឱ្យមានការភាន់ច្រឡំ និងគ្មានអង្គសេចក្តីឡើយ[727]។ ទាក់ទងទៅនឹងសារណារបស់ ខៀវ សំផន សហព្រះរាជអាជ្ញាបានជំទាស់ថា ខៀវ សំផន ពុំបានយោងជាក់លាក់ណាមួយដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនឡើយ ដូច្នេះការអះអាងដែលគ្មានមូលដ្ឋានគាំទ្រ គប្បីបដិសេធចោលដោយពុំចាំបាច់ធ្វើការពិចារណាបន្តទៀតឡើយ[728]។

៣០២.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការចង្អុលបង្ហាញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីបទដ្ឋានដែលអាចអនុវត្តបានចំពោះការវាយតម្លៃលើភស្តុតាងចចាមអារ៉ាម ពុំចោទជាបញ្ហាឡើយ ហើយ នួន ជា ក៏បានទទួលស្គាល់ផងដែរថា មានភាពស្របគ្នាទៅនឹងយុត្តិសាស្ត្រអន្តរជាតិ[729]។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTR បានបង្ហាញថា "តម្លៃជាភស្តុតាង និងទម្ងន់ដែលត្រូវផ្តល់ទៅឱ្យភស្តុតាង

---

[724] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧០។

[725] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧១។

[726] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧០។

[727] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩១ ដល់ ៩៣។

[728] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០៧។

[729] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៦៨ ដល់ ១៦៩។

[ចចាមអារ៉ាម] ជាធម្មតាអាចស្រាលជាងភស្តុតាងដែលសាក្សីបានផ្តល់ក្រោមការធ្វើសម្បថ និងសាក្សីដែលត្រូវបានសួរដេញដោលដោយភាគី"[730] និងថា អាស្រ័យទៅតាម"កាលៈទេសៈផ្សេងៗដែលកើតមានជុំវិញភស្តុតាងចចាមអារ៉ាមនោះ"[731]។ នេះជាយុត្តិសាស្ត្រដែលត្រូវបានទទួលស្គាល់ដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍*ដែលថា ភស្តុតាងចចាមអារ៉ាមអាចទទួលយកបាន លុះត្រាតែមានតម្លៃជាភស្តុតាង[732] និងថា អង្គជំនុំជម្រះសាលាដំបូងមួយអាចសំអាងទៅលើភស្តុតាងចចាមអារ៉ាមដែលពុំមានការបញ្ជាក់បន្ថែម ក្នុងការបង្ហាញពីអត្ថិភាពនៃធាតុផ្សំបទឧក្រិដ្ឋឡើយ បើទោះបីជាការប្រុងប្រយ័ត្ន គឺជាលក្ខខណ្ឌតម្រូវនៅក្នុងកាលៈទេសៈបែបនេះក៏ដោយ[733]។ ទោះជាយ៉ាងណាក្តី ការអនុវត្តតាមគោលការណ៍នេះបាននាំឱ្យអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR យល់ឃើញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចផ្តល់សេចក្តីសន្និដ្ឋានផ្នែកអង្គហេតុដោយផ្អែកតែមួយមុខគត់ទៅលើពាក្យចចាមអារ៉ាមពុំច្បាស់លាស់ និងពុំត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវក្នុងករណីដែលពុំមានការផ្តល់ភាពជាក់លាក់ណាមួយបង្ហាញអំពីភាពអាចជឿទុកចិត្តបាននៃការរៀបរាប់ ដែលសាក្សីនិយាយសំដៅទៅលើនោះឡើយ[734]។ សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងមួយមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការពិចារណាដោយប្រុងប្រយ័ត្ន និងជឿជាក់លើភស្តុតាងចចាមអារ៉ាមសម្រាប់ធ្វើជាមូល

---

[730] សាលដីកា*រឿងក្តី* *Kalimanzira* (ICTR) កថាខណ្ឌ ៩៦ ដកស្រង់សាលដីកា*រឿងក្តី* *Karera* (ICTR) កថាខណ្ឌ ៣៩។

[731] សាលដីកា*រឿងក្តី* *Karera* (ICTR) កថាខណ្ឌ ៣៩ យោងទៅលើសេចក្តីសម្រេចស្តីពីភស្តុតាង*រឿងក្តី* *Aleksovski* កថាខណ្ឌ ១៥។

[732] សាលដីកា*រឿងក្តី* *Semanza* (ICTR) កថាខណ្ឌ ១៥៩។ សាលដីកា*រឿងក្តី* *Rutaganda* (ICTR) កថាខណ្ឌ ៣៤, ១៤៨, ២០៧ ២៦៥ និង ៣១១។ សាលដីកា*រឿងក្តី* *Karera* (ICTR) កថាខណ្ឌ ១៧៨ និង ២៥៦។ សាលដីកា*រឿងក្តី* *Lukić និងអ្នកដទៃទៀត* (ICTY) កថាខណ្ឌ ៣០៣។

[733] សាលដីកា*រឿងក្តី* *Gacumbitsi* (ICTR) កថាខណ្ឌ ១៣៣ ជើងទំព័រ ៣២០។ សាលដីកា*រឿងក្តី* *Hategekimana* (ICTR) កថាខណ្ឌ ២៧០។

[734] សាលដីកា*រឿងក្តី* *Ndindabahizi* (ICTR) កថាខណ្ឌ ១១៥ និងទំព័រ ៥៩។ *សូមមើលផងដែរ* សាលដីកា*រឿងក្តី* *Kalimanzira* (ICTR) កថាខណ្ឌ ៧៧ ដល់ ៨០ (បដិសេធការសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើសក្ខីកម្មរបស់សាក្សីដែលពុំមានព័ត៌មានលម្អិតពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃអង្គហេតុ និងពុំមានភាពច្បាស់លាស់ទាក់ទងទៅនឹងបញ្ហា ថាតើការរៀបរាប់ជាពាក្យចចាមអារ៉ាម ដែរឬយ៉ាងណា)។ សាលដីកា*រឿងក្តី* *Muvunyi* (ICTR) កថាខណ្ឌ ៦៨ ដល់ ៧០ (យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រព្រឹត្តសមហេតុផលដោយមានការប្រុងប្រយ័ត្នក្នុងកម្រិតមួយតម្រូវក្នុងការផ្អែកការសម្រេចដាក់ពិរុទ្ធភាពទាំងស្រុងលើភស្តុតាងមិនផ្ទាល់ និងពុំមានព័ត៌មានលម្អិត និងពាក្យចចាមអារ៉ាម)។

01358111



ដ្ឋាន ឬជាការគាំទ្រក្នុងការសម្រេចដាក់ពិរុទ្ធភាព[735] ហើយភាគីម្ចាស់បណ្តឹងសាទុក្ខត្រូវមានកាតព្វកិច្ចក្នុងការបង្ហាញឱ្យឃើញថា ពុំមានតុលាការអង្គហេតុសមស្របណាមួយដែលអាចយកភស្តុតាងបែបនេះ មកធ្វើសំអាងហេតុជាក់លាក់នោះឡើយ[736]។

៣០៣.ពាក់ព័ន្ធទៅនឹងអំណះអំណាងរបស់ជនជាប់ចោទ បើទោះបីជា នួន ជា បានយោងទៅលើឧទាហរណ៍មួយចំនួនទាក់ទងទៅនឹងការសំអាងលើភស្តុតាងចចាមអារ៉ាម នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ[737] ក៏គាត់បានត្រឹមតែអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយពុំបានទទួលស្គាល់ឱ្យបានច្បាស់លាស់ពីប្រភេទនៃភស្តុតាងចចាមអារ៉ាមបែបនោះ ឬការពិចារណាឱ្យបានល្អិតល្អន់ក្នុងការជឿជាក់លើភស្តុតាងនេះ[738]។ ការយល់ឃើញជាក់លាក់តែមួយគត់ ដែល នួន ជា បានលើកឡើងនៅក្នុងអំណះអំណាងរបស់ខ្លួនទាក់ទងទៅនឹងបញ្ហានេះ គឺពាក់ព័ន្ធនឹងគោលនយោបាយ ប.ក.ក.នៃការកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែល នួន ជា បានជំទាស់ការយល់ឃើញនេះថា បានផ្អែកតែមួយគត់លើសក្ខីកម្មចចាមអារ៉ាមរបស់ Philip SHORT អំពីការសម្លាប់នៅឧដុង្គ។ អង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើការវាយតម្លៃលើអំណះអំណាងដូចខាងក្រោមនេះនៅក្នុងបរិបទស្តីពីការពិភាក្សាអំពីអំណះអំណាងដទៃទៀត ដែលបានលើកឡើងប្រឆាំងនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានអត្ថិភាពនៃគោលនយោបាយនេះ។

---

[735] សាលដីកា*រឿងក្តី Rukundo* (ICTR) កថាខណ្ឌ ១៨៨។ សាលដីកា*រឿងក្តី Ndindabahizi* (ICTR) កថាខណ្ឌ ១១៥។ សាលដីកា*រឿងក្តី Gacumbitsi* (ICTR) កថាខណ្ឌ ១១៥។ សាលដីកា*រឿងក្តី Rutaganda* (ICTR) កថាខណ្ឌ ៣៤, ២០៧, ៣១១។ សាលដីកា*រឿងក្តី Muvunyi* ឆ្នាំ ២០០៨ (ICTR) កថាខណ្ឌ ៧០ និង ៨១។ សាលដីកា*រឿងក្តី Karera* (ICTR) កថាខណ្ឌ ៣៩ និង ១៧៨។ សាលដីកា*រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ២៨១។ សាលដីកា*រឿងក្តី Gatete* (ICTR) កថាខណ្ឌ ៩៩។ សាលដីកា*រឿងក្តី Đorđević* (ICTY) កថាខណ្ឌ ៣៩៧។

[736] សាលដីកា*រឿងក្តី Karera* (ICTR) កថាខណ្ឌ ៣៩, ១៩៦។

[737] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៤៤៦ ដល់ ៤៤៩, *យោងទៅលើ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៣៦០, ១៣៩១, ១៤០២, ១៤០៤, ១៤៤៩, ១៤៦២, ១៥២៩, ១៥៣៧, ២៦២០, ២៦៣៦, ២៦៣៩ និងកថាខណ្ឌ ៤៧១, ៤៧៤, ៤៨៦, ៤៩០, ៥១១ និង ៨៣២។

[738] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧០ ដល់ ១៧១។

៣០៤.ខៀវ សំផន បានត្រឹមតែអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានផ្អែកតែលើពាក្យចចាមអារ៉ាម ប៉ុន្តែពុំបានផ្តល់ការយោងជាក់លាក់ដើម្បីគាំទ្រអំណះអំណាងនេះឡើយ[739]។ ការដែលគ្រាន់តែអះអាងពីកំហុស ដោយគ្មានការបង្ហាញភស្តុតាងគាំទ្របន្ថែមឱ្យបានច្បាស់លាស់នោះ គឺពុំបានបំពេញតាមបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខឡើយ។ បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចត្រូវផ្តល់សំអាងហេតុពេញលេញក៏ដោយ ក៏អង្គជំនុំជម្រះពុំបានតម្រូវឱ្យបញ្ជាក់អះអាងគ្រប់ជំហាននៃការផ្តល់សំអាងហេតុរបស់ខ្លួនឱ្យបានពិស្តារនោះឡើយ ហើយអង្គជំនុំជម្រះត្រូវបានសន្មតថា បានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវរាល់ភស្តុតាងទាំងអស់នៅចំពោះមុខខ្លួន ដរាបណាគ្មានការបង្ហាញណាមួយថា អង្គជំនុំជម្រះពុំបានពិចារណាពេញលេញលើភស្តុតាងជាក់លាក់ណាមួយនោះ[740]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ខៀវ សំផន បានចង្អុលបង្ហាញផងដែរទៅលើការយល់ឃើញផ្អែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកដោយពុំត្រឹមត្រូវ តាមការអះអាងរបស់គាត់ ទៅលើភស្តុតាងចចាមអារ៉ាម[741]។ អាស្រ័យហេតុនេះ ប្រសិនបើជនជាប់ចោទបានលើកពេញលេញនូវការចោទប្រកាន់អំពីកំហុសនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួននោះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណាលើការចោទប្រកាន់ទាំងនោះតាមករណីសមស្រប។ ទោះជាយ៉ាងណាក្តី អំណះអំណាងដែលថា ជាទូទៅ អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តឱ្យបានត្រឹមត្រូវនូវបទដ្ឋានស្តីពីការទទួលយកភស្តុតាងចចាមអារ៉ាមនោះត្រូវបដិសេធចោល។

## ៤.គ.៦.ការសំអាងហេតុលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៣០៥.នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងរឿងក្តីតាមវិធីសាស្ត្របីប្រភេទ (i) តាមរយៈការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង(សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី) (ii) តាមរយៈការធ្វើសេចក្តីថ្លែងអំពីទុក្ខវេទនា

[739] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១៦ និងជើងទំព័រ ២៤១ (សម្រាប់ឧទាហរណ៍ជាក់ច្បាស់ *សូមមើលខាងក្រោម*)។

[740] *សូមមើលឧ.* សាលដីកា*រឿងក្តី Kalimanzira* (ICTR) កថាខណ្ឌ ១៩៥។ សាលដីកា*រឿងក្តី Simba* (ICTR) កថាខណ្ឌ ១៥២។ សាលដីកា*រឿងក្តី Haliliović* (ICTY) កថាខណ្ឌ ១២១។ សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ២៣។

[741] *សូមមើលឧ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៨២ ដល់ ១៨៣, ១៨៨, ២០៣, ២១១, ២១៧, ២១៩ ដល់ ២២០, ៣៥៥, ៤២៤, ៤៣០, ៥៣៥ ជើងទំព័រ ១១៦៥។

នៅចុងបញ្ចប់នៃការផ្តល់សក្ខីកម្មក្នុងតុលាការ(សេចក្តីថ្លែងអំពីទុក្ខវេទនា) និង (iii) តាមរយៈការផ្តល់សក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះនៅក្នុងសវនាការរយៈពេលបួនថ្ងៃ ដែលបានកំណត់កាលបរិច្ឆេទជាក់លាក់សម្រាប់គោលបំណងនោះនៅពេលចុងបញ្ចប់នៃការជំនុំជម្រះ ("សក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះ) និង (សេចក្តីថ្លែងរបស់ជនរងគ្រោះអំពីផលប៉ះពាល់") ដាច់ដោយឡែកពីគ្នា។

៣០៦.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការវាយតម្លៃលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមករណីជាក់ស្តែងនីមួយៗដោយផ្អែកលើភាពអាចជឿជាក់បាននៃសក្ខីកម្មនោះក្នុងការផ្តល់សំអាងហេតុទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ[742]។ នួន ជា ហាក់បីដូចជាចង់អះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសំអាងទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាល់តែសោះ នៅពេលធ្វើសំអាងហេតុស្តីពីពិរុទ្ធភាពរបស់ជនជាប់ចោទ បើទោះបីជាតាមរយៈអំណះអំណាងរបស់គាត់អាចយល់បានថា គាត់បានលើកជាយោបល់ថា ជាការពុំត្រឹមត្រូវទេចំពោះការសំអាងជាចម្បង ឬតែមួយមុខទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ឬថា ជាទូទៅ សក្ខីកម្មបែបនេះគប្បីត្រូវបានផ្តល់តម្លៃជាភស្តុតាងទាបជាងបើធៀបទៅនឹងសក្ខីកម្មរបស់សាក្សី[743]។ នួន ជា បានរំលឹកដែរថា នៅក្នុងអំឡុងពេលនៃការជំនុំជម្រះ សហព្រះរាជអាជ្ញាបានស្នើសុំការសម្រេចអំពីបញ្ហានេះ ហើយអង្គជំនុំជម្រះសាលាដំបូងក៏បាន"អនុញ្ញាតតាមសំណើសុំ"[744]។ គាត់បានលើកឡើងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ព្រោះថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក. មានកម្រិត ហើយបើយោងតាមវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីពុំអាចត្រូវបានស្តាប់ដូចសាក្សីឡើយ និងមានតួនាទីត្រឹមតែគាំទ្រសហព្រះរាជអាជ្ញាប៉ុណ្ណោះ[745]។ នួន ជា បានកត់សម្គាល់ថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីខ្វះលក្ខខណ្ឌធានាខុសពីសក្ខីកម្មរបស់សាក្សីដែលតម្រូវឱ្យមានដូចជា លក្ខខណ្ឌតម្រូវក្នុងការធ្វើសម្បថ និងការ

---

[742] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៩៤។

[743] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០៦។

[744] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៩៤ យោងទៅលើសារណារបស់សហព្រះរាជអាជ្ញាលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី (E267) និងសេចក្តីសម្រេចស្តីពីការថ្លែងអំពីទុក្ខសោកវេទនា (E267/3)។

[745] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៩៧ ដល់ ១៩៩។

ហាមឃាត់មិនឱ្យមានទំនាក់ទំនងជាមួយសហព្រះរាជអាជ្ញា និងភាគីការពារក្ដីមុនពេលផ្ដល់សក្ខីកម្ម រីឯដើមបណ្ដឹងរដ្ឋប្បវេណី មានសេរីភាពក្នុងការពិគ្រោះយោបល់ជាមួយនឹងមេធាវីរបស់ខ្លួនបាន[746]។

៣០៧.ពាក់ព័ន្ធទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសេចក្ដីថ្លែងអំពីទុក្ខវេទនា និងសក្ខីកម្មស្ដីពីផលប៉ះពាល់របស់ជនរងគ្រោះ នួន ជា បានលើកឡើងថា សេចក្ដីថ្លែងអំពីទុក្ខវេទនា និងសក្ខីកម្មស្ដីពីផលប៉ះពាល់របស់ជនរងគ្រោះ "គប្បីត្រូវបានដកចេញទាំងស្រុងពីការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអង្គសេចក្ដីនៃការចោទប្រកាន់"[747] និងថា "រាល់សំអាងហេតុនីមួយៗទាក់ទងទៅនឹងសក្ខីកម្មស្ដីពីផលប៉ះពាល់របស់ជនរងគ្រោះ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់គោលបំណងណាមួយ គឺជាកំហុសអង្គច្បាប់ លើកលែងតែសំអាងហេតុទាក់ទងទៅនឹងសំណង និងការប្រកាសទោស"[748]។ នួន ជា បានអះអាងថា ការសំអាងទៅលើសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ គឺផ្ទុយទៅនឹងការបញ្ជាក់ម្ដងហើយម្ដងទៀតរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សក្ខីកម្មនេះ"ពុំចាត់ជាភស្តុតាងសម្រាប់ដាក់ពិរុទ្ធភាព"[749]ឡើយ។ នួន ជា ក៏បានយោងផងដែរទៅលើការអនុវត្តរបស់តុលាការ ICTY និងតុលាការ ICC រួមទាំងការអនុវត្តនៃយុត្តាធិការក្នុងស្រុក ដើម្បីគាំទ្រការជំទាស់របស់គាត់ដែលថា សក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ អាចប្រើប្រាស់ត្រឹមតែសម្រាប់គោលបំណងនៃការប្រកាសទោសប៉ុណ្ណោះ[750]។

៣០៨.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្ដល់សំអាងហេតុដោយផ្អែកលើសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ និងបានលើកឡើងថា "តាមទស្សនៈទូទៅនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង សេចក្ដីថ្លែងទាំងនេះ [...] មិនបង្កើតជាភស្តុតាងដែលធ្វើឱ្យប៉ះពាល់ដល់ជនជាប់ចោទឡើយ"[751]។

---

746 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០១ ដល់ ២០៦។

747 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៧។

748 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៩៣។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៥២៧ ("ដោយសារហេតុនេះហើយទើបការយល់ឃើញនីមួយៗនៃអង្គហេតុដែលបានផ្អែកលើតែសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ គឺជាកំហុសអង្គហេតុ។ កំហុសអង្គហេតុជាក់លាក់ដែលពាក់ព័ន្ធទៅនឹងបទចោទត្រូវបានរៀបរាប់នៅក្នុងសារណានេះទាំងមូល")។

749 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៩០។

750 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៨ និង ១៩២។

751 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣០។

៣០៩.សហព្រះរាជអាជ្ញាបានឆ្លើយតបថា សារណារបស់ នួន ជា បានបំភ្លៃការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងមិនអើពើពីប្រវត្តិនីតិវិធីដែលពាក់ព័ន្ធស្តីពីបញ្ហានេះ ហើយបានលើកឡើងថា មានការព្រមព្រៀងគ្នាទៅវិញទៅមករវាងភាគី ក្នុងការសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហាអង្គហេតុដែលជាប់ពាក់ព័ន្ធ[752]។ សហព្រះរាជអាជ្ញាបានជំទាស់ថា នួន ជា បច្ចុប្បន្នប្រកាន់គោលជំហរផ្ទុយពីគោលជំហរក្នុងពេលជំនុំជម្រះ និងថា ការផ្លាស់ប្តូរនេះបានរារាំង នួន ជា មិនឱ្យជំទាស់តវ៉ាអំពីបញ្ហានេះនៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ[753]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ភាគីទាំងអស់បានដឹងថា ធាតុផ្សំនៃសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះពាក់ព័ន្ធទៅនឹងពិរុទ្ធភាពនោះ អាចត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង[754]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ ខៀវ សំផន ពុំមានអង្គសេចក្តីដូចគ្នា និងគ្រប់ពេលទាំងអស់ពុំបានចោទប្រកាន់កំហុសដែលនាំឱ្យមោឃៈសាលក្រម ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌ទេ[755]។

៣១០.សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបថា អំណះអំណាងរបស់ នួន ជា គ្មានមូលដ្ឋានគ្រប់គ្រាន់ ពីព្រោះ នួន ជា បានដឹងហើយថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យផ្តល់ភស្តុតាងជាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ និងសេចក្តីថ្លែងអំពីទុក្ខវេទនា[756]។ សហមេធាវីនាំមុខបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានត្រឹមត្រូវក្នុងការកំណត់នីតិវិធី និងទម្រង់បែបបទសម្រាប់សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកបានយកភស្តុតាងទាំងនេះមកសំអាងសម្រាប់ការយល់ឃើញរបស់ខ្លួន[757]។

## ៤.គ.៦.ក.ការសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៣១១.អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក. ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ថា ជា"ភាគី"មួយ ស្របជាមួយនឹងសហព្រះរាជអាជ្ញា និងជនត្រូវចោទ/ជនជាប់

---

[752] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩៩ ដល់ ១០១។

[753] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០២។

[754] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០៣។

[755] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០៨ ដល់ ១០៩។

[756] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៨៤ ដល់ ៩១។

[757] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ កថាខណ្ឌ ៧០ ដល់ ១៦៨។

ចោទដែរ។ ផ្អែកតាមការសង្កេតរបស់អង្គជំនុំជម្រះតុលាការកំពូល[758]ក្នុងឋានៈនេះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិមួយចំនួនក្នុងការចូលរួម ព្រមទាំងសិទ្ធិក្នុងការសុំឱ្យកោះហៅសាក្សី និងសួរសំណួរសាក្សីផងដែរ ប៉ុន្តែ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បី"គាំទ្រអយ្យការ" និងទាមទារសំណង។

៣១២.ដូច នួន ជា បានកត់សម្គាល់[759] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុងចែងថា "ដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចត្រូវបានសួរសំណួរដូចសាក្សីធម្មតានៅក្នុងរឿងក្តីតែមួយនេះបានទេ" និងបង្ហាញឱ្យឃើញផងដែរនៅក្នុងមាត្រា ៣១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលចែងថា "ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានគេស្តាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ"។ ទោះជាយ៉ាងណាក្តី មាត្រានេះពុំមែនមានន័យថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចផ្តល់សក្ខីកម្មទៅលើបញ្ហាពាក់ព័ន្ធទៅនឹងការដាក់ពិរុទ្ធភាពរបស់ជនជាប់ចោទ ឬថា អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលយកសក្ខីកម្មទាំងនោះមកពិចារណាបានឡើយ នៅពេលផ្តល់ការយល់ឃើញផ្អែកអង្គហេតុរបស់ខ្លួន។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គលដែលបានអះអាងថា គាត់ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់នេះ ជាញឹកញាប់ទទួលបានតួនាទីយ៉ាងសំខាន់ក្នុងការពណ៌នាអំពីព្រឹត្តិការណ៍ ដែលបង្កើតបានជាមូលដ្ឋានក្នុងការចោទប្រកាន់។ ប្រសិនបើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលយកបាន វាពិតជាពុំអាចនាំទៅរកការបង្ហាញការពិតអំពីការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទបានឡើយ។

៣១៣.ពិតប្រាកដណាស់ វិធានផ្ទៃក្នុងបានសន្មតថា ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ព័ត៌មានទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។ វិធាន ៥៩ នៃវិធានផ្ទៃក្នុងចែងអំពីលក្ខខណ្ឌ ដោយផ្អែកតាមលក្ខខណ្ឌនេះ សហចៅក្រមស៊ើបអង្កេតអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ នៅក្នុងបទប្បញ្ញត្តិនេះពុំបានកំណត់ថា ការសួរសំណួរត្រូវបានកម្រិតត្រឹមតែបញ្ហាពាក់ព័ន្ធទៅនឹងសំណង និងពុំត្រូវប៉ះពាល់ដល់បញ្ហាពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនសង្ស័យឡើយ។ ប្រហាក់ប្រហែលគ្នានេះដែរ វិធាន ៩១(១) នៃវិធានផ្ទៃក្នុងចែងថា "អង្គជំនុំជម្រះត្រូវស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ទៅតាមលំដាប់លំដោយដែលខ្លួនយល់ថា មានប្រយោជន៍"។ ដូចនេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានលើកយកមកនិយាយ ព្រមគ្នាជាមួយនឹងសាក្សី និងអ្នកជំនាញថា ជាមធ្យោបាយសម្រាប់បង្ហាញការពិតទាក់ទងទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងអាចសំអាងលើសក្ខីកម្ម

[758] សេចក្តីសម្រេចស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី (F10/2) កថាខណ្ឌ ១១ ដល់ ១៤។

[759] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៩៧។

របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់អំពីពិរុទ្ធភាព ដូចគ្នាទៅនឹងការដែលអង្គជំនុំជម្រះសំអាងលើសក្ខីកម្មរបស់ជនជាប់ចោទផងដែរ ប្រសិនបើជនជាប់ចោទសម្រេចចិត្តផ្តល់សក្ខីកម្ម[760]។ ដោយហេតុថា ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចជាប់ពាក់ព័ន្ធទៅនឹងតម្លៃជាភស្តុតាង និង/ឬភាពអាចជឿជាក់បាននៃសក្ខីកម្ម ពុំមានហេតុផលអ្វីត្រូវបដិសេធសក្ខីកម្មនេះឡើយ។

៣១៤.យោងតាមសំអាងហេតុខាងលើ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចត្រូវបានចាត់ទុកថា ជាកំហុសឡើយ។ អៀង សារី បានលើកបញ្ហា ថាតើដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានអនុញ្ញាតឱ្យផ្តល់សក្ខីកម្មតាមការដឹងឮរបស់ខ្លួនអំពីរឿងក្តីព្រហ្មទណ្ឌបានដែរ ឬយ៉ាងណា និងបានជំទាស់ថា យ៉ាងហោចណាស់ ដើមបណ្តឹងរដ្ឋប្បវេណីគប្បីត្រូវបានតម្រូវឱ្យផ្តល់សក្ខីកម្មក្រោមការធ្វើសម្បថ[761]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចអនុវត្តតាមវិធីសាស្ត្រដូចគ្នានៅក្នុងសំណុំរឿង ០០១[762] នៅពេលដែលអង្គជំនុំជម្រះបញ្ជាក់ថា ទម្ងន់ដែលបានផ្តល់ទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវធ្វើការវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ ដោយផ្អែកលើភាពអាចជឿជាក់បាននៃសក្ខីកម្ម និងថា ដើមបណ្តឹងរដ្ឋប្បវេណីពុំតម្រូវឱ្យផ្តល់សក្ខីកម្មក្រោមការធ្វើសម្បថឡើយ[763]។ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យធ្វើការវាយតម្លៃអំពីតម្លៃជាភស្តុតាងនៃសក្ខីកម្មនីមួយៗ ដោយផ្អែកលើកត្តាមួយចំនួនដូចជា អត្តចរិតរបស់បុគ្គលដែលផ្តល់សក្ខីកម្ម ភាពស៊ីសង្វាក់គ្នា ឬមិនស៊ីសង្វាក់គ្នាទាក់ទងទៅនឹងអង្គហេតុសត្យានុម័ត ការជំរុញទឹកចិត្តដោយខ្លួនឯង ការអះអាងបំភ្លឺបន្ថែម និងកាលៈទេសៈនានានៃរឿងក្តី[764]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងជាក់លាក់នៅក្នុងសាលក្រម (បើទោះជាជាប់ពាក់ព័ន្ធទៅនឹងភស្តុតាងជាឯកសារក៏ដោយចុះ)ថា ក្នុងការវាយតម្លៃភស្តុតាង អង្គជំនុំជម្រះបានពិចារណាលើ“អត្តសញ្ញាណ ការសួរ

---

[760] *សូមមើល* វិធាន ៩០ នៃវិធានផ្ទៃក្នុង។

[761] សំណើរបស់ អៀង សារី ស្តីពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី (E57)។

[762] សាលក្រម *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ៤២, ៥៣។

[763] *សូមមើល* កិច្ចប្រជុំរៀបចំសវនាការ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E1/2.1 ទំព័រ ៨២។ សេចក្តីសម្រេចស្តីពីការធ្វើសម្បថរបស់ដើមបណ្តឹងរដ្ឋប្បវេណី (E74) ទំព័រ ១។ សេចក្តីសម្រេចស្តីពីការថ្លែងអំពីទុក្ខសោកវេទនា (E267/3) កថាខណ្ឌ ២១-២២។

[764] *សូមមើល ករណីចាំបាច់កែប្រែ* (*mutatis mutandis*) សម្រាប់ភស្តុតាងសាក្សី សាលដីកា *រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ១៣៨។ សាលដីកា *រឿងក្តី Đorđević* (ICTY កថាខណ្ឌ ៣៩។ សាលដីកា *រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ១៩៤។ សាលដីកា *រឿងក្តី Bikindi* (ICTR) កថាខណ្ឌ ១១៤។ សាលដីកា *រឿងក្តី Musema* (ICTR) កថាខណ្ឌ ៣៦។

សំណួរ ភាពលំអៀង ប្រភពដើម និងកត្តាជំរុញ ឬកង្វះនៃកត្តាជំរុញរបស់សាមីជន និងប្រភពដើមនៃភស្តុតាង "[765]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ឋានៈពិសេសរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលផ្តល់សក្ខីកម្មនោះ[766]។

៣១៥.ពាក់ព័ន្ធទៅនឹងបញ្ហាដែល នួន ជា បានយោងទៅលើកត្តាដែលមានលក្ខណៈពិសេសដាច់ដោយឡែកអំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីពុំបានធ្វើសម្បថ ផលប្រយោជន៍ចម្បងរបស់ពួកគេដើម្បីទាមទារសំណង និងកង្វះការដាក់ទណ្ឌកម្មចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយ និងលទ្ធភាពក្នុងការពិគ្រោះពិភាក្សាជាមួយនឹងមេធាវីក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី[767]) កត្តាទាំងអស់នេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលក្នុងការអនុវត្តនូវវិធីសាស្ត្ររបស់ខ្លួន និងត្រូវបានពិចារណានៅពេលធ្វើការវាយតម្លៃលើតម្លៃជាភស្តុតាង និងលើទម្ងន់នៃសក្ខីកម្មរបស់ដើមបណ្តឹររដ្ឋប្បវេណីនីមួយៗ។ *តាមធម្មតា* កត្តាទាំងនេះពុំបានបង្ហាញពីកំហុសអង្គច្បាប់នៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

៣១៦.អាស្រ័យហេតុនេះ អំណះអំណាងរបស់ នួន ជា ត្រូវបដិសេធចោល។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាចំពោះការលើកឡើងជាក់លាក់បន្ថែមទៀតរបស់ នួន ជា ទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងផ្នែកពាក់ព័ន្ធនៃសាលដីកានេះ។

### ៤.គ.៦.ខ.ការសំអាងលើសេចក្តីថ្លែងអំពីទុក្ខវេទនា និងសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ

៣១៧.អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣ នាក់ ដែលធ្វើសេចក្តីថ្លែងអំពីទុក្ខវេទនា បន្ទាប់ពីការផ្តល់សក្ខីកម្មរបស់ខ្លួននៅក្នុងសវនាការលើអង្គសេចក្តី[768] និងបានស្តាប់ដើមបណ្តឹង

---

[765] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤។

[766] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣០។

[767] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៩៧ ដល់ ២០៦។

[768] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ឯកសារលេខ E1/117.1។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ ជុំ សុខា) ឯកសារលេខ E1/136.1។ ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1។ ប្រតិចារឹកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ឯកសារលេខ E1/141.1។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ឯកសារលេខ E1/145.1។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី, ថៅ នី) ឯកសារលេខ E1/146.1។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1។ ប្រតិចារឹកចុះថ្ងៃ ០៦ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ឯកសារ E1/149.1។ ប្រតិ

រដ្ឋប្បវេណីចំនួន ១៥ នាក់ ក្នុងអំឡុងពេលនៃសវនាការអំពីផលប៉ះពាល់របស់ជនរងគ្រោះ[769]។ ភាគីមានឱកាសសួរសំណួរដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលសវនាការលើអង្គសេចក្ដី ប៉ុន្តែភាគីត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីអធិប្បាយលើការថ្លែងអំពីទុក្ខវេទនាតែក្នុងករណីដែលដើមបណ្ដឹងរដ្ឋប្បវេណីនោះបានចាកចេញពីបន្ទប់សវនាការប៉ុណ្ណោះ[770]។ ភាគីក៏អាចសួរសំណួរដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃសវនាការអំពីផលប៉ះពាល់របស់ជនរងគ្រោះបានផងដែរបើទោះបីត្រឹមតែសង្ខេបប៉ុណ្ណោះ[771]។

៣១៨.បញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា នៅពេលសំអាងទៅលើសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ ឬសេចក្តីថ្លែងអំពីទុក្ខសោកក្នុងការផ្ដល់ការយល់ឃើញផ្នែកអង្គហេតុទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា *តាមការពិនិត្យជាបឋម* ពុំឃើញមានអត្ថបទច្បាប់ជាធរមានណាមួយដែលបានចែងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងទៅលើសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ ឬសេចក្តីថ្លែងអំពីទុក្ខវេទនាសម្រាប់គោលបំណងក្នុងការផ្តល់ការយល់ឃើញនោះឡើយ។ អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការទទួលយកភស្តុតាងណាមួយដែល*ក្នុងចំណោមនោះ*មានការជាប់ពាក់ព័ន្ធ និងអាចជឿទុកចិត្តបាន។

---

ចារឹកចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៣ (Denise AFFONCO) ឯកសារលេខ E1/153.1។ ប្រតិចារឹកចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1។

[769] ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊ូ សុទ្ធាវី) ឯកសារលេខ E1/197.1។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ឯកសារលេខ E1/197.1។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ឯកសារលេខ E1/197.1។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ឯកសារលេខ E1/197.1។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ឯកសារលេខ E1/198.1។ ប្រតិចារឹកចុះថ្ងៃ ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព) ឯកសារលេខ E1/198.1។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហួ ចន្ថា) ឯកសារលេខ E1/198.1។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ឯកសារលេខ E1/198.1។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នួរ ហ៊ាន់) ឯកសារលេខ E1/199.1។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ឯកសារលេខ E1/199.1។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (យិន វំដួល) ឯកសារលេខ E1/199.1។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ឯកសារលេខ E1/199.1។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ឯកសារលេខ E1/200.1។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សឿន សុវណ្ណី) ឯកសារលេខ E1/200.1។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (សេង ស៊ីវត្ថា) ឯកសារលេខ E1/200.1។

[770] សេចក្ដីសម្រេចស្ដីពីការថ្លែងអំពីទុក្ខសោកវេទនា (E267/3) កថាខណ្ឌ ១៨។

[771] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/194.1 ទំព័រ ៩៣។

៣១៩.អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងមិនផ្ទុយពីការអនុវត្តមុនៗ ឬការអះអាងក្នុងអំឡុងពេលនៃការជំនុំជម្រះឡើយ។ ការសំអាងរបស់ នួន ជា ទៅលើសំណុំរឿង ០០១ ពុំជាប់ពាក់ព័ន្ធនោះទេ។ នៅក្នុងផ្នែកនៃសាលក្រម *រឿងក្តី ឌុច* (001-E188) ដែលគាត់បានយោងទៅលើនោះ[772] អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបានយល់ឃើញថា ផលប៉ះពាល់នៃបទឧក្រិដ្ឋលើជនរងគ្រោះ គឺជាការលើកយកមកពិចារណាបញ្ហាពាក់ព័ន្ធ នៅពេលធ្វើការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា សក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះ ពុំអាចយកមកសំអាងក្នុងការយល់ឃើញអំពីពិរុទ្ធភាពឡើយ។ ប្រហាក់ប្រហែលគ្នានេះដែរ សេចក្តីសម្រេចដទៃទៀតនៅក្នុងសំណុំរឿង ០០១ ដែល នួន ជា បានយោងទៅលើ[773] ដែល*ក្នុងចំណោមនោះ*ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការសួរជនជាប់ចោទ សាក្សី និងអ្នកជំនាញដែលត្រូវផ្តល់សក្ខីកម្មលើអត្តចរិតរបស់ជនជាប់ចោទ អំពីបញ្ហាពាក់ព័ន្ធទៅនឹងការផ្តន្ទាទោស ដែរ ឬយ៉ាងណា។ នៅក្នុងសេចក្តីសម្រេចនោះ ពុំឃើញមានចំណុចណាដែលអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា សក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះ ពុំអាចយកមកប្រើប្រាស់ដើម្បីកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ។

៣២០.នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងជាទូទៅបានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណី “បង្ហាញជាទូទៅអំពីទុក្ខវេទនាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ” បន្ទាប់ពីបញ្ចប់សក្ខីកម្មរបស់ខ្លួន ហើយអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នៅគ្រប់ពេលទាំងអស់ខ្លួនបាន“ធ្វើការបែងចែករវាងសក្ខីកម្មលើអង្គហេតុដែលចោទជាបញ្ហា ដែលត្រូវបានកម្រិតត្រឹមវិសាលភាពនៃសំណុំរឿង ០០២/០១ និងត្រូវដាក់ឱ្យស្ថិតក្រោមការពិភាក្សាដេញដោលជាមួយនឹងការថ្លែងជាទូទៅអំពីទុក្ខវេទនា ដែលដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងដោយសេរីនៅពេលបញ្ចប់ការផ្តល់សក្ខីកម្មរបស់ខ្លួន”[774]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានប្រមើលឃើញថា សេចក្តីថ្លែងអំពីទុក្ខវេទនាអាចនឹងមានព័ត៌មានពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។ ជាការកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងបានណែនាំសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋ

---

[772] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៩ ជើងទំព័រ ៥១២ យោងទៅលើសាលក្រម *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ៥៩៦។

[773] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៩ ជើងទំព័រ ៥១៣ យោងទៅលើសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីការប្រកាសទោស (001-E72/3) កថាខណ្ឌ ៤៦។

[774] សេចក្តីសម្រេចស្តីពីការថ្លែងអំពីទុក្ខសោកវេទនា (E267/3) កថាខណ្ឌ ១៤។

ប្បវេណី“កុំឱ្យមានការជំរុញធ្វើការចោទប្រកាន់ថ្មីៗទៀតប្រឆាំងនឹងជនជាប់ចោទនៅដំណាក់កាលនោះ” និង បានកត់សម្គាល់ឃើញថា “ក្នុងករណីដែលមានការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទ ភាគីការពារក្តីត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ឱ្យធ្វើការជំទាស់”[775]។ ជាសំខាន់ នៅក្នុងស្ថានភាពមួយដែលសេចក្តីថ្លែងអំពីទុក្ខវេទនាបានធ្វើការចោទប្រកាន់ថ្មីប្រឆាំងនឹង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើរបស់ជនជាប់ចោទសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើការចោទប្រកាន់នោះមកសួរបន្ថែម[776]។ មានការបញ្ជាក់ចំនួន ២ ចំណុច ដូចតទៅ ទីមួយ នៅពេលដែលសេចក្តីថ្លែងអំពីទុក្ខវេទនាពុំត្រូវបានធ្វើឡើងក្នុង*គោលបំណង*បង្ហាញនូវព័ត៌មានថ្មីពាក់ព័ន្ធទៅនឹងបទចោទនានា អង្គជំនុំជម្រះសាលាដំបូង និងភាគីបានដឹងថានឹងមានបញ្ហានេះបានកើតឡើង។ ទីពីរ ការដែលថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីសាឡើងវិញ បញ្ជាក់ឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងយល់ថា ព័ត៌មានដែលមាននៅក្នុងសេចក្តីថ្លែងអំពីទុក្ខវេទនាជាសក្តានុពល អាចត្រូវបានប្រើប្រាស់សម្រាប់ការកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ប៉ុន្តែប្រសិនបើផ្ទុយពីនេះវិញ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ផ្តល់ឱកាសឱ្យជនជាប់ចោទស្នើសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការសួរដេញដោលសាឡើងវិញឡើយ។ អាស្រ័យទៅលើ នួន ជា ខ្លួនឯងក្នុងការធ្វើសំណើសុំបែបនេះនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ។

៣២១.ទាក់ទងទៅនឹងសក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទម្រង់បែបបទដែលភាគីស្នើឡើងសម្រាប់សួរសំណួរដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃសវនាការអំពីផលប៉ះពាល់ដល់ជនរងគ្រោះដែលត្រូវបានអនុម័តយកដោយអង្គជំនុំជម្រះសាលាដំបូង[777] បង្ហាញអំពីការរំពឹងរបស់ភាគីថា ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ភស្តុតាងដែលពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ[778]។ ជាសំខាន់ មានការយល់ស្រប*ក្នុងចំណោមនោះ*ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានសួរអំពីបញ្ហាទាំងអស់ដែលពាក់ព័ន្ធទៅនឹងរឿងក្តី[779] និងអាចផ្តល់ភស្តុតាងដែលជាចំណុចសំខាន់នៃការផ្លាស់ទីលំនៅដោយ

---

[775] សេចក្តីសម្រេចស្តីពីការថ្លែងអំពីទុក្ខសោកវេទនា (E267/3) កថាខណ្ឌ ១៧។

[776] *សូមមើល* សេចក្តីសម្រេចស្តីពីការថ្លែងអំពីទុក្ខសោកវេទនា (E267/3) កថាខណ្ឌ ១៩។

[777] ប្រតិចារឹកចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/194.1ទំព័រ ៩៣។

[778] ប្រតិចារឹកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/193.1 ទំព័រ ៨២ ដល់ ៨៩។

[779] ប្រតិចារឹកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/193.1 ទំព័រ ៨៦។

បង្អុំ[780] និងអាចត្រូវបានជំទាស់ដោយសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីដែលត្រូវបានផ្តល់ពេលវេលាជាក់លាក់សម្រាប់សួរសំណួរនោះ[781]។

៣២២.សរុបសេចក្តីមក ពុំមានការបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងផ្តល់ការចាប់អារម្មណ៍ថាព័ត៌មាននៅក្នុងសេចក្តីថ្លែងអំពីទុក្ខសោក ឬសក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះពុំអាចយកមកប្រើប្រាស់ដើម្បីកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទនោះទេ ដូច្នេះ អំណះអំណាងរបស់ នួន ជា ចំពោះបញ្ហានេះត្រូវបដិសេធចោល។

៣២៣.អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា ការអនុវត្តរបស់តុលាការក្នុងស្រុក និងអន្តរជាតិបានបង្ហាញថា សេចក្តីថ្លែងអំពីទុក្ខវេទនារបស់ជនរងគ្រោះពុំអាចយកមកប្រើប្រាស់ដើម្បីកំណត់អំពីពិរុទ្ធភាពបានឡើយ[782]។ យុត្តិសាស្ត្រដែល នួន ជា បានយោងទៅលើនោះមានដូចជាប្រទេសអូស្ត្រាលី កាណាដា អ៊ីស្រាអែល ញូហ្សីលែន និងសហរដ្ឋអាមេរិក ព្រមទាំងតុលាការ ICC ផងដែរ មានរបបនីតិវិធីខុសៗគ្នា ដែលក្នុងនោះពុំមានដើមបណ្តឹងរដ្ឋប្បវេណីចូលរួមឡើយ។ អាស្រ័យហេតុនេះ ដើមបណ្តឹងរដ្ឋប្បវេណី មានការជាប់ពាក់ព័ន្ធក្នុងកម្រិតតិចតួចទៅនឹងបញ្ហាចំពោះមុខ។

៣២៤.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសំអាងទៅលើសេចក្តីថ្លែងអំពីទុក្ខវេទនា និងសក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះដើម្បីយកមកធ្វើជាភស្តុតាងសត្យានុម័តឡើយ។ ការចោទប្រកាន់ជាក់លាក់ពាក់ព័ន្ធទៅនឹងតម្លៃជាភស្តុតាង និងទម្ងន់ដែលបានផ្តល់ទៅលើសេចក្តីថ្លែងអំពីទុក្ខវេទនានីមួយៗ និងសក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះ នឹងត្រូវដោះស្រាយនៅក្នុងផ្នែកដែលពាក់ព័ន្ធនៅក្នុងសាលដីកានេះ[783]។

---

[780] ប្រតិចារិកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/193.1 ទំព័រ ៨៦។

[781] ប្រតិចារិកចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/193.1 ទំព័រ ៨៦ ដល់ ៨៧។ ប្រតិចារិកចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/194.1ទំព័រ ៩៣។

[782] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៨។

[783] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៥០៣។

## ៥.គ.៧.ការសំអាងលើសក្ខីកម្មរបស់អ្នកជំនាញ និងប្រភពមិនផ្ទាល់

៣២៥.ក្នុងការពិភាក្សាអំពីភាពអាចទទួលយកបាននូវភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នៅក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០១ ខ្លួនបានស្តាប់មតិយោបល់របស់អ្នកជំនាញស្តីពី"បញ្ហាបច្ចេកទេសជាក់លាក់ ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការស្វែងយល់អំពីភស្តុតាងដែលបានបង្ហាញនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ"[784]។ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ចម្លើយអ្នកជំនាញចំនួន ៣ នាក់[785] មានដូចជា Philip SHORT David CHANDLER និង ឈឹម សុធារ៉ា។ ឈឹម សុធារ៉ា បានផ្តល់សក្ខីកម្មអំពីផលប៉ះពាល់ផ្លូវចិត្តរបស់ជនរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[786]។ ជនជាប់ចោទពុំបានលើកអំណះអំណាងណាមួយពាក់ព័ន្ធទៅនឹងបញ្ហានេះឡើយ។

៣២៦.នួន ជា និង ខៀវ សំផន បានលើកឡើងថា ជាគោលការណ៍ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ច្បាស់លាស់នូវកម្រិតមតិយោបល់របស់អ្នកជំនាញ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង អង្គជំនុំជម្រះបានផ្អែកទៅលើសក្ខីកម្មរបស់អ្នកជំនាញជាប្រចាំ ដើម្បីយកមកធ្វើជាភស្តុតាងផ្ទាល់ក្នុងការគាំទ្រដល់សំអាងហេតុដែលកំពុងមានវិវាទរវាងភាគី[787]។ ពួកគាត់បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរដោយសារសំអាងជាញឹកញាប់ទៅលើកិច្ចការរបស់អ្នកនិពន្ធដែលពុំបានមកផ្តល់សក្ខីកម្មនៅក្នុងតុលាការ ដើម្បីយកមកធ្វើជាប្រភពដើមដ៏មានសារៈសំខាន់ជាច្រើន ក្នុងការគាំទ្រដល់ការយល់ឃើញផ្នែកអង្គហេតុដែលកំពុងមានវិវាទនេះ និងថា អង្គជំនុំជម្រះសាលាដំបូង ពុំបានខិតខំប្រឹងប្រែងពិតប្រាកដក្នុងការវាយតម្លៃលើជំនាញរបស់អ្នកនិពន្ធនីមួយៗ ឬអ្នកជំនាញ ឬពន្យល់ពីមូលហេតុដែលខ្លួនបានចាត់ទុកកំណត់ត្រានៃអង្គហេតុនេះថា មានភាពអាចជឿទុកចិត្តបាននោះឡើយ[788]។

---

[784] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៣០។

[785] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣២។

[786] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១៤២ និង ១១៥០។

[787] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០៧ ដល់ ២០៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១៨។

[788] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០៧ ដល់ ២១១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤ និង ១១៨។

៣២៧.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន និង នួន ជា ពុំបានបង្ហាញពីកំហុសណាមួយដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងរបស់អ្នកជំនាញ និងប្រភពមិនផ្ទាល់[789]នោះទេ។

៣២៨.វិធាន ៣១(១) នៃវិធានផ្ទៃក្នុងចែងថា "សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចស្វែងរកជំនួយពីមតិយោបល់របស់អ្នកជំនាញអំពីបញ្ហាដែលយល់ឃើញថា មានសារៈសំខាន់ចាំបាច់ដល់ការស៊ើបសួរ ឬកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក."។ ផ្នែកដទៃទៀតនៃបញ្ញត្តិនេះ មានចែងលម្អិតទាក់ទងទៅនឹងវិធីសាស្ត្រដែលអ្នកជំនាញបានបំពេញកិច្ចការរបស់ខ្លួន។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានចែងអំពីការចាត់តាំងអ្នកជំនាញឱ្យជួយចៅក្រមលើទិដ្ឋភាពបច្ចេកទេសនៃរឿងក្តី និងបានបង្កើតបទប្បញ្ញត្តិលម្អិតទាក់ទងទៅនឹងការប្រើប្រាស់អ្នកជំនាញក្នុងកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលស៊ើបសួរ[790]។ ប្រហាក់ប្រហែលគ្នានេះដែរ យុត្តិសាស្ត្រ និងការអនុវត្តជាអន្តរជាតិបានទទួលស្គាល់ថា សាក្សីជំនាញត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្តល់ចំណេះដឹងឯកទេស ដែលអាចជួយដល់តុលាការអង្គហេតុឱ្យយល់ដឹងអំពីភស្តុតាងដែលបានបង្ហាញ[791]។ យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍*បានបញ្ជាក់ថា តួនាទីរបស់អ្នកជំនាញក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការទាំងនេះ គឺដើម្បីផ្តល់សក្ខីកម្មចំពោះបញ្ហាស្របតាមជំនាញជាក់លាក់របស់ខ្លួន ប៉ុន្តែមិនផ្តល់សក្ខីកម្មលើអង្គហេតុដែលមានជម្លោះ ឬចំពោះអំពើ ឬការប្រព្រឹត្ត ឬការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដូចសាក្សីធម្មតាឡើយ[792]។ យោងតាមមូលហេតុនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអំពើមនុស្សឃាតដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព ដែលបានផ្អែកតែមួយមុខគត់លើសក្ខីកម្មរបស់សាក្សីជំនាញដែលជាពាក្យចចាមអារ៉ាមតគ្នាពីរដងនោះ ត្រូវបានបដិសេធចោលនៅដំណាក់បណ្តឹងសាទុក្ខ[793]។ យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR បានបញ្ជាក់បន្ថែមទៀតថា នៅ

---

[789] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០៤ ដល់ ១០៧។

[790] *សូមមើល* មាត្រា ១៦២ ដល់ ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[791] សាលដីកា*រឿងក្តី Renzaho* (ICTR) កថាខណ្ឌ ២៨៧។ សាលដីកា*រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ១៩៨។ សាលដីកា*រឿងក្តី Semanza* (ICTR) កថាខណ្ឌ ៣០៣។ សាលដីកា*រឿងក្តី Simba* (ICTR) កថាខណ្ឌ ១៧៤។ សាលដីកា*រឿងក្តី D.Milošević* (ICTY) កថាខណ្ឌ ១១៧។

[792] សាលដីកា*រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ២១២, ៥០៩ និង ៥១១។ សាលដីកា*រឿងក្តី Renzaho* (ICTR) កថាខណ្ឌ ២៨៨។ សាលដីកា*រឿងក្តី Bagosora* (ICTR) កថាខណ្ឌ ២២៦ ជើងទំព័រ ៥០៣។

[793] សាលដីកា*រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ៥០៨ ដល់ ៥០៩។

ចំពោះមុខតុលាការឧក្រិដ្ឋកម្មទាំងនេះ (i) សាក្សីជំនាញត្រូវបានផ្តល់សេរីភាពឆ្លើយទៅតាមជំនាញរបស់ខ្លួន[794] (ii) នៅពេលផ្តល់សក្ខីកម្មលើបញ្ហាក្រៅជំនាញរបស់ខ្លួន សក្ខីកម្មនោះ"នឹងត្រូវចាត់ទុកថា ជាមតិយោបល់ផ្ទាល់ខ្លួនរបស់សាក្សីជំនាញ ហើយនឹងត្រូវថ្លឹងថ្លែងសមស្របផងដែរ"[795] (បញ្ជាក់ថា មតិនេះនៅតែអាចត្រូវបានពិចារណាដោយតុលាការអង្គហេតុ) និង (iii) បុគ្គលនេះអាចមានលទ្ធភាពដើរតួនាទីជាសាក្សីជំនាញផង និងតួនាទីរបស់សាក្សីអង្គហេតុផងដែរ[796]។

៣២៩.នួន ជា បានយោងទៅលើឧទាហរណ៍មួយចំនួនដែលក្នុងនោះបានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើសក្ខីកម្មរបស់ Philip SHORT និង David CHANDLER[797]។ ទោះជាយ៉ាងណាក្តី ដូចបានកត់សម្គាល់ខាងលើ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មរបស់អ្នកជំនាញដើម្បីឈានទៅធ្វើការសន្និដ្ឋានអំពីអង្គហេតុណាមួយ *តាមធម្មតា* ពុំត្រូវបានហាមឃាត់ ដរាបណាតួនាទីរបស់អ្នកជំនាញ ត្រូវបានកម្រិតត្រឹមជួយដល់តុលាការអង្គហេតុក្នុងការ"ស្វែងយល់អំពីភស្តុតាងដែលបានបង្ហាញក្នុងអំឡុងពេលនៃការជំនុំជម្រះ"[798] ដោយពុំក្លាយជាយន្តការសម្រាប់លើកបង្ហាញភស្តុតាងដែលពុំអាចជឿទុកចិត្តបាននោះឡើយ។ អាស្រ័យហេតុនេះ កត្តាជាគន្លឹះក្នុងការវាយតម្លៃអំពីភាពអាចជឿទុកចិត្តបាន និងតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញ ត្រូវមានការពិនិត្យពិច័យដោយប្រុងប្រយ័ត្នអំពី

---

[794] សាលដីកា *រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ១៩៨ (ដកស្រង់សាលដីកា *រឿងក្តី Semanza* (ICTR) កថាខណ្ឌ ៣០៣)។ សាលដីកា *រឿងក្តី Renzaho* (ICTR) កថាខណ្ឌ ២៨៧។ សាលដីកា *រឿងក្តី Bagosora* (ICTR) កថាខណ្ឌ ២២៥។

[795] សេចក្តីសម្រេចស្តីពីការទទួលយករបាយការណ៍របស់អ្នកជំនាញ Robert Donia *រឿងក្តី D.Milošević* (ICTY) កថាខណ្ឌ ១១។

[796] *សូមមើល* សាលដីកា *រឿងក្តី Renzaho* (ICTR) កថាខណ្ឌ ២៨៨ "ដូច្នេះ ដោយសាររបាយការណ៍ និងសក្ខីកម្មរបស់សាក្សីជំនាញអាចផ្អែកលើអង្គហេតុដែលបានពិពណ៌នាដោយសារសាក្សីធម្មតា ឬបានផ្អែកលើអង្គហេតុពីភស្តុតាងដទៃទៀត សាក្សីជំនាញជាគោលការណ៍ពុំអាចផ្តល់សក្ខីកម្មដោយផ្ទាល់ខ្លួនអំពីសកម្មភាព ឬអំពើប្រព្រឹត្តរបស់ជនជាប់ចោទ *ដោយគ្មានការកោះហៅផងដែរមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីអង្គហេតុ និងដោយគ្មានការបង្ហាញចម្លើយរបស់គាត់ផងដែរ ដោយអនុលោមតាមវិធានជាធរមានពាក់ព័ន្ធទៅនឹងសាក្សីអង្គហេតុ"* (ជើងទំព័រលុបចោល សេចក្តីបញ្ជាក់បន្ថែម)។

[797] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០៩។ នៅក្នុងជើងទំព័រពាក់ព័ន្ធ នួន ជា បានត្រឹមតែយោងទៅលើចំណុចដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើអ្នកជំនាញទាំងពីររូបនេះ។

[798] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបុង កថាខណ្ឌ ៣០ ជើងទំព័រ ៨២។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ១៩៨ (រួមបញ្ចូលសេចក្តីយោងដកស្រង់នៅក្នុងជើងទំព័រ ៤៧៣)។

ប្រភពដែលអ្នកជំនាញបានទាញយកមកធ្វើសេចក្ដីសន្និដ្ឋាន[799]។ ជាទូទៅ នេះត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការសួរដេញដោល[800]។ ករណីដែលប្រភពដើមពុំអាចទទួលបាន និងផ្ទៀងផ្ទាត់ពេញលេញ ភស្តុតាងរបស់អ្នកជំនាញនេះត្រូវផ្ដល់ទម្ងន់ខ្សោយ ដោយសារលទ្ធភាពត្រូវបានរឹតត្បិតសម្រាប់ភាគី និងតុលាការសួរដេញដោលលើការសន្និដ្ឋានរបស់អ្នកជំនាញនោះ[801]។

---

[799] *សូមមើល ឧ.* សេចក្ដីសម្រេចស្ដីពីការទទួលយករបាយការណ៍របស់អ្នកជំនាញ Ratko *រឿងក្ដី Tolimir* (ICTY) កថាខណ្ឌ ១៥ (“នៅក្នុងការបង្ហាញអំពីភាពអាចជឿទុកចិត្តបាន ត្រូវតែមានព័ត៌មានគ្រប់គ្រាន់ទាក់ទងទៅនឹងប្រភពដែលប្រើប្រាស់ក្នុងការគាំទ្រចម្លើយរបស់អ្នកជំនាញដែលត្រូវតែបង្ហាញច្បាស់លាស់ ដែលអាចឱ្យភាគីដទៃទៀត ឬអង្គជំនុំជម្រះសួរដេញដោលលើមូលដ្ឋានដែលសាក្សីបានផ្អែកចម្លើយរបស់ខ្លួនសម្រាប់ការធ្វើសេចក្ដីសន្និដ្ឋាននោះ។ ក្នុងករណីគ្មានការយោងច្បាស់លាស់ ឬប្រភពអាចរកបានទេនោះ អង្គជំនុំជម្រះនឹងត្រូវចាត់ទុកចម្លើយនេះជាមតិយោបល់ផ្ទាល់ខ្លួនរបស់សាក្សី និងថ្លឹងថ្លែងអំពីភស្តុតាងដោយសមស្រប” (ជើងទំព័រលុបចោល))។ សេចក្ដីសម្រេចស្ដីពីការទទួលយករបាយការណ៍របស់អ្នកជំនាញ Robert Donia *រឿងក្ដី D. Milošević* (ICTY) កថាខណ្ឌ ៨។ សេចក្ដីសម្រេចស្ដីពីការជូនដំណឹងរបស់ភាគីការពារក្ដីតាមវិធាន ៩៤ *ស្ទួន* ពាក់ព័ន្ធទៅនឹងសាក្សីជំនាញរបស់អយ្យការ Richard Butler (ICTY) កថាខណ្ឌ ៣០ (តម្លាភាពនៅក្នុងវិធីសាស្ត្រ និងប្រភពដែលប្រើប្រាស់ដោយសាក្សីជំនាញ រួមទាំងការសំអាងទៅលើអង្គហេតុដែលសន្មត និងបានបង្ហាញនោះ គឺជាកត្តាមួយដែលត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃភាពអាចជឿទុកចិត្តបាន និងតម្លៃជាភស្តុតាងនៃសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញ)។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការវាយតម្លៃដោយប្រុងប្រយ័ត្នលើប្រភពរបស់អ្នកជំនាញ ជាការសមស្រប ជាពិសេស ដូចក្នុងរឿងក្ដីបច្ចុប្បន្ន តុលាការអង្គហេតុពិចារណាលើភស្តុតាងដែលបានផ្ដល់ដោយអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ (Philip SHORT និង David CHANDLER) ព្រោះចំណេះដឹងរបស់អ្នកជំនាញនេះ និងការវិភាគ តាមការកត់សម្គាល់របស់ នួន ជា (ក្នុងសារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១១) ស្ទើរតែដូចគ្នានឹងការពិចារណារបស់ចៅក្រមដែលពាក់ព័ន្ធនឹងរឿងក្ដីបច្ចុប្បន្នដែរ។

[800] សេចក្ដីសម្រេចលើបណ្ដឹងរបស់ភាគីការពារក្ដីជិតចិត្តអ្នកជំនាញ Richard Butler (ICTY) កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើចម្លើយរបស់សាក្សីជំនាញ *រឿងក្ដី Galić* (ICTY) ទំព័រ ៦ ដល់ ៧ (ប្រភពដែលប្រើប្រាស់ដោយសាក្សីជំនាញក្នុងការធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន ត្រូវតែបង្ហាញឱ្យច្បាស់លាស់ និងងាយស្រួលដល់ភាគីអាចរកបានតាមការស្នើសុំដើម្បីត្រៀមរៀបចំសម្រាប់សួរដេញដោល)។

[801] *សូមមើល* សេចក្ដីសម្រេចលើសំណើសុំដកចេញនូវរបាយការរបស់អ្នកជំនាញ *រឿងក្ដី Karadžić* (ICTY) កថាខណ្ឌ ២២ ដល់ ២៣ (បានទទួលយករបាយការណ៍របស់អ្នកជំនាញធ្វើជាភស្តុតាង បើទោះបីជាមានការបញ្ជាក់តិចតួចអំពីប្រភពចំពោះការសន្និដ្ឋាននោះក៏ដោយ ក៏ប៉ុន្តែបានបញ្ជាក់ថា កត្តានេះនឹងត្រូវយកមកពិចារណានៅពេលវាយតម្លៃលើទម្ងន់ដែលត្រូវផ្ដល់ទៅឱ្យរបាយការណ៍នេះនៅពេលដែលអ្នកជំនាញត្រូវបានសួរដេញដោល និងដោយផ្អែកលើភស្តុតាងទាំងមូល)។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ភាពអាចរកបាន និងការផ្ទៀងផ្ទាត់លើប្រភពរបស់អ្នកជំនាញ តាមការពិភាក្សាបច្ចុប្បន្ន គឺជាកត្តាដែលពាក់ព័ន្ធទៅនឹងការវាយតម្លៃលើតម្លៃភស្តុតាង។ អាស្រ័យហេតុនេះ ការពិតដែលថា យុត្តិសាស្ត្រអន្តរជាតិពុំបានដោះស្រាយទាក់ទងទៅនឹងសារៈសំខាន់នៃកត្តានេះនៅដំណាក់កាលនៃភាពអាចទទួលយកបាន ពុំសំខាន់ឡើយ។ *សូមមើល* A. Singh, ‘ភស្តុតាងរបស់អ្នកជំនាញ’ in K. Khan, C.

៣៣០.ជាក់លាក់ជាងនេះទៀត នួន ជា បានជំទាស់ថា មានការយល់ឃើញជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានកំហុសក្នុងការសំអាងទៅលើមតិយោបល់របស់អ្នកជំនាញ[802]។ នួន ជា បានលើកអំណះអំណាងដូចគ្នាទាក់ទងទៅនឹងការយល់ឃើញដែលបានគាំទ្រដោយការដកស្រង់កិច្ចការផ្នែកសិក្សា ឬប្រភពមិនផ្ទាល់ដទៃទៀត[803]។ អង្គជំនុំជម្រះតុលាការកំពូលត្រឹមតែធ្វើការសង្កេតនៅក្នុងដំណាក់កាលនេះថា ការយោងភាគច្រើនដែល នួន ជា បានចង្អុលបង្ហាញនោះ ត្រឹមតែជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញផ្អែកលើភស្តុតាងមិនផ្ទាល់(មានន័យថា ការយល់ឃើញនេះពុំមែនជាស្នូល ឬមូលដ្ឋានសម្រាប់បង្ហាញពីអំពើប្រព្រឹត្តរបស់ជនជាប់ចោទឡើយ) និង/ឬ ត្រូវបានដកចេញពីប្រភពផ្សេងៗទៀតនៃភស្តុតាង រួមទាំងសក្ខីកម្មផ្ទាល់ផងដែរ[804]។

---

Buisman, C. Gosnel (eds), *គោលការណ៍ស្តីពីភស្តុតាងនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* (Oxford: ព្រឹត្តិប័ត្រព័ត៌មានសាកលវិទ្យាល័យ Oxford ឆ្នាំ ២០១០) ទំព័រ ៦២៩។

[802] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០៩។

[803] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១០។

[804] ជាឧទាហរណ៍ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១៤ ជើងទំព័រ ៣១៨ យោងទៅលើភស្តុតាងរបស់អ្នកជំនាញ និងឯកសារសិក្សាក្នុងគាំទ្រការសម្រេចថា នៅក្នុងអំឡុងពេលរហូតមកដល់ខែ មេសា ឆ្នាំ ១៩៧៥ "ប.ក.ក. បានដាក់ចេញលក្ខខណ្ឌការងារកាន់តែលំបាកឡើងៗទៅលើសមាជិកសហករណ៍"។ ដូចបានលើកឡើងដោយ នួន ជា បើទោះបីជា នេះពុំមានប្រភពគាំទ្រក្រៅតែពីភស្តុតាងរបស់អ្នកជំនាញ និងឯកសារសិក្សា(សាក្សីអង្គហេតុដែលបានដកស្រង់ពុំបានសំដៅទៅលើ"លក្ខខណ្ឌការងារកាន់តែលំបាកឡើងៗ"នៅក្នុងសហករណ៍)ក៏ដោយ ក៏ នួន ជា ពុំបានបង្ហាញថា ការយល់ឃើញនេះ គឺជាមូលដ្ឋានសម្រាប់ការដាក់ពិរុទ្ធភាពឡើយ។ អង្គជំនុំជម្រះសាលាដំបូងបាយល់ឃើញថា មានទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទជាមួយនឹងការវាយប្រហារលើប្រជាជនស៊ីវិល និងថា ជនជាប់ចោទបានដឹងអំពីការវាយប្រហារ និងដឹងថា អំពើរបស់ខ្លួន គឺជាផ្នែកនៃការវាប្រហារនេះ ដោយសារការវាយប្រហារនេះត្រូវបានធ្វើឡើងដើម្បីជំរុញ និងស្របតាមគោលនយោបាយ និងផែនការរបស់បក្ស (សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៧។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានាដោយបង្ខំ"ត្រូវបានបង្កើតឡើងស្របតាមមាគ៌ានយោបាយបក្សយូរលង់ណាស់មកហើយ ដែលផ្តោតលើការធ្វើកសិកម្ម"(សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩០ យោងទៅលើ *ក្នុងចំណោមនោះ* កថាខណ្ឌ ១១៦)។ ទោះជាយ៉ាងណាក្តី ពុំមានការយល់ឃើញណាមួយបានផ្អែកលើលក្ខខណ្ឌការងារនៅសហករណ៍ ប៉ុន្តែបានផ្អែកលើអត្ថិភាពនៃគោលនយោបាយបក្សក្នុងការបង្កើតសហករណ៍។ បន្ថែមលើនេះទៀត ការយល់ឃើញនេះបានផ្អែកលើកាលៈទេសៈបន្ថែម។ ឧទាហរណ៍មួយទៀត គឺជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា នួន ជា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុងបក្ស និងថា ការគ្រប់គ្រងរបស់គាត់លាតសន្ធឹងដល់បញ្ហាយោធា(*សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤៨)។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងនៅពេលផ្តល់ការយល់ឃើញទាំងនោះ"បានយល់ស្រប"ជាមួយនឹងទស្សនៈរបស់អ្នកជំនាញពីររូបនោះក៏ដោយ ក៏សេចក្តីសន្និដ្ឋានរបស់ខ្លួនបានផ្អែកលើភស្តុតាងជាច្រើន រួមទាំងសក្ខីកម្មរបស់សាក្សីអង្គហេតុ

ចំណុចមួយចំនួនដែលអង្គជំនុំជម្រះបានសំអាងទៅលើភស្តុតាងរបស់អ្នកជំនាញ ឬប្រភពមិនផ្ទាល់តែមួយមុខគត់ក្នុងការទាញយកសេចក្តីសន្និដ្ឋានស្នូលនោះ នឹងត្រូវដោះស្រាយនៅក្នុងផ្នែកដែលពាក់ព័ន្ធខាងក្រោម[805]។ ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធទៅនឹងតួនាទីរបស់ Philip SHORT ជាការកត់សម្គាល់ផងដែរថា នៅក្នុងសេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញពាក់ព័ន្ធទៅនឹង Philip Short ថា គាត់"ត្រូវបានភាគីស្នើឡើងជាចម្បង ដោយសារចំណេះដឹងផ្ទាល់ខ្លួនរបស់គាត់ចំពោះអង្គហេតុពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ [...]។ ដូច្នេះហើយ[គាត់]ត្រូវបានកោះហៅក្នុងនាមជា[សាក្សីជំនាញ] បើទោះបីជា[គាត់]អាចនឹងត្រូវបានសួរសំណួរអំពីអង្គហេតុតាមការយល់ដឹងផ្ទាល់ខ្លួន[របស់គាត់]ទាក់ទងទៅនឹងសំណុំរឿង ០០២/០១ ក៏ដោយ"[806]។ ដូច្នេះ បង្ហាញឱ្យឃើញច្បាស់តាំងពីដំបូងថា លោក Philip SHORT មិនត្រឹមតែមានតួនាទីធ្វើជាអ្នកជំនាញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសាក្សីអង្គហេតុផងដែរ។ ទាក់ទងទៅនឹងចំណុចមួយដែល នួន ជា បានយោងទៅលើ ដែលក្នុងនោះ Philip SHORT បានបញ្ចេញមតិយោបល់ដែលទំនងជាខុសជំនាញរបស់គាត់[807] នួន ជា ពុំបានបង្ហាញ ថាតើការយល់ឃើញពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងនេះ[808] ជាមូលដ្ឋានស្នូលសម្រាប់ការសម្រេចដាក់ពិរុទ្ធភាពយ៉ាងដូចម្តេចឡើយ និងពុំបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានចាត់ទុកទស្សនរបស់ Philip SHORT គ្រាន់តែជាមតិយោបល់ផ្ទាល់ខ្លួនប៉ុណ្ណោះ ឬពុំបានថ្លឹងថ្លែងលើទស្សនៈនេះឱ្យបានសមស្រប។

៣៣១.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានវាយតម្លៃលើឯកទេសរបស់អ្នកជំនាញនោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បន្ទាប់ពីបានស្តាប់ភាគីទាំងអស់អំពីបញ្ហាអ្នកជំនាញនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់គុណវុឌ្ឍិដល់ David CHANDLER និង Philip SHORT ថាជាអ្នកជំនាញអំពី ប.ក.ក. និងរឿងរ៉ាវនានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[809] ហើយរួមទាំង នួន ជា ផងដែរ ក៏បានទទួលស្គាល់ពួកគាត់ថា ជាអ្នកមានជំនាញពាក់ព័ន្ធ ដោយបានបញ្ចូលឈ្មោះរបស់អ្នកទាំងពីរទៅក្នុង

---

និងឯកសាររបស់កម្ពុជាប្រជាធិបតេយ្យនាសម័យនោះ(*សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៣៤ ដល់ ៣៤១)។

[805] *សូមមើលខ.* កថាខណ្ឌ ៨៨០ ដល់ ៨៨១, ៨៨៨, ៩២០។

[806] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ១៨។

[807] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២០៩។

[808] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៨ ដល់ ៥៣៩។

[809] សេចក្តីសម្រេចស្តីពីការចាត់តាំងអ្នកជំនាញ (E215) កថាខណ្ឌ ១៧ ដល់ ១៨។

បញ្ជីសាក្សីដែលខ្លួនបានស្នើសុំ[810]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើការជំទាស់របស់ នួន ជា អំពីអ្នកជំនាញនៅក្នុងបណ្ដឹងសាទុក្ខឡើយ[811]។

៣៣២.នួន ជា បានជំទាស់ចំពោះការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើអត្ថបទសរសេរដោយ Ben KIERNAN និង Elizabeth BECKER ដែលជា"ប្រភពមិនផ្ទាល់"នៃភស្តុតាង បើទោះបីជាប្រើប្រាស់សម្រាប់ហេតុផលផ្សេងក៏ដោយ និងក៏បានជំទាស់ផងដែរអំពីការកង្វះនូវភាពប្រាកដប្រជារបស់អង្គជំនុំជម្រះសាលាដំបូង និងកង្វះជំនាញរបស់អ្នកនិពន្ធទាំងពីរ[812]។ សារណាទូទៅរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រច្បាស់លាស់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចយកមតិយោបល់របស់អ្នកជំនាញធ្វើជាមូលដ្ឋានក្នុងការយល់ឃើញរបស់ខ្លួន និងការបញ្ជាក់ពុំច្បាស់ ថាតើប្រភពដែលបានប្រើប្រាស់ដោយអ្នកជំនាញនោះបានបំពេញតាមបទដ្ឋាននៃការទទួលយកភស្តុតាង ដែរ ឬយ៉ាងណា[813]។ ចំពោះបញ្ហានេះ ខៀវ សំផន បានបង្ហាញជាក់លាក់ត្រឹមតែពីរចំណុច គឺទាក់ទងទៅនឹងកិច្ចការរបស់ Ben KIERNAN ដែលគាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើកិច្ចការនេះដើម្បីគាំទ្រក្នុងការផ្ដល់សំអាងហេតុមួយចំនួនរបស់ខ្លួន បើទោះបីជាកិច្ចការនេះមានតម្លៃជាភស្តុតាងក្នុងកម្រិតតិចតួចក្ដី[814] និងទាក់ទងទៅនឹងកិច្ចការរបស់ Elizabeth BECKER ដែលគាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើប្រភពដើមតែមួយមុខគត់ ក្នុងការគាំទ្រការយល់ឃើញរបស់ខ្លួនផ្សេងទៀត[815]។

---

[810] *សូមមើល* សេចក្ដីសង្ខេបអំពីបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងដោយ នួន ជា (E9/10) និងឧបសម្ព័ន្ធទៅនឹងសេចក្ដីសង្ខេបនេះ (E9/10.1) ទំព័រ ២៩ ដល់ ៣២ និង ១៨២ ដល់ ១៨៥។ សេចក្ដីសង្ខេបដែលត្រូវបានធ្វើបច្ចុប្បន្នភាពអំពីបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងដោយ នួន ជា (E93/4) *និង*ឧបសម្ព័ន្ធទៅនឹងសេចក្ដីសង្ខេបនេះ (E93/4.3) ទំព័រ ២២ និង ១២០ (ភាសាអង់គ្លេស)។

[811] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១១។

[812] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១១ ("ការស្នាក់នៅមួយរយៈពេលខ្លីរបស់ Elizabeth Becker ជាអ្នករាយការណ៍នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៧៣ ដល់ ១៩៧៤ សឹងតែពុំអាចឱ្យគាត់មានមូលដ្ឋាន ជំនាញ ឬចំណេះដឹងធ្វើការវាយតម្លៃយ៉ាងទូលំទូលាយអំពី ប.ក.ក. ឬធ្វើការអះអាងបញ្ជាក់អំពីព្រឹត្តិការណ៍ដែលគាត់ពុំបាននៅជិត និងពុំបានសង្កេត។ [...] Ben KIERNAN អាចមានជំនាញតិចតួចបំផុត ប៉ុន្តែភាពមិនលម្អៀងក្នុងការវិភាគរបស់គាត់ដែលជា *មនុស្សអប្រិយ និងគួរឱ្យស្អប់ខ្ពើមដែលធ្វើអ្វីៗដើម្បីលុយ* អំពីជនជាតិវៀតណាមនោះ គួរឱ្យសង្ស័យ")។

[813] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤ និង ១១៨។

[814] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤ និងសេចក្ដីយោងដែលបានដកស្រង់ជើងទំព័រ ៥៥។

[815] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤ និងសេចក្ដីយោងដែលបានដកស្រង់ ជើងទំព័រ ៥៦។

៣៣៣.ការជំទាស់របស់ នួន ជា ចំពោះការទទួលយកអត្ថបទ និងជំនាញរបស់ Elizabeth BECKER មកធ្វើជាភស្តុតាងនោះ ពុំមានមូលដ្ឋានគាំទ្រឡើយ ហើយផ្ទុយគ្នាទៅនឹងជំហរពីដំបូងរបស់ នួន ជា ផងដែរដែលថា លោកស្រី Elizabeth BECKER គប្បីត្រូវបានកោះហៅឱ្យមកធ្វើជាសាក្សីអង្គហេតុដើម្បីផ្តល់សក្ខីកម្ម*ក្នុងចំណោមនោះ*អំពីរចនាសម្ព័ន្ធបញ្ជារបស់ ប.ក.ក. ព្រមទាំងបានបង្ហាញថា លោកស្រីអាចផ្តល់នូវការយល់ដឹងអំពីលក្ខខណ្ឌមុនឆ្នាំ ១៩៧៥ ក្នុងរបបសាធារណរដ្ឋខ្មែរ និងថា ក្នុងនាមជាអ្នកសារព័ត៌មានជនជាតិអាម៉េរិកម្នាក់ក្នុងចំណោមពីរនាក់ប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យចូលមកប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យមួយរយៈពេលខ្លីនៅឆ្នាំ ១៩៧៨ ដែលលោកស្រីអាចផ្តល់នូវការបំភ្លឺអំពីស្ថានការណ៍នាពេលនោះបាន[816]។ បន្ថែមលើនេះ កិច្ចការរបស់ Elizabeth BECKER ត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងត្រឹមតែពាក់ព័ន្ធទៅនឹងការយល់ឃើញផ្អែកលើភស្តុតាងមិនផ្ទាល់ប៉ុណ្ណោះ[817] ឬការយល់ឃើញដែលបានធ្វើឡើងតាមរយៈប្រភពផ្សេងៗនៃភស្តុតាង[818]។ ខៀវ សំផន ក៏បានជំទាស់ផងដែរទៅនឹងការទទួលយកកិច្ចការរបស់ Elizabeth BECKER មកធ្វើជាភស្តុតាង ប៉ុន្តែបានជំទាស់តែត្រង់ចំណុចដែលអង្គជំនុំជម្រះបានយោងទៅលើកិច្ចការនេះជាពិសេសប៉ុណ្ណោះ[819]។ តាមការពិនិត្យទៅលើសំអាងហេតុដែលពាក់ព័ន្ធទៅនឹងការយោងទៅលើកិច្ចការទាំងនេះបង្ហាញឱ្យឃើញថា បានប្រើប្រាស់ត្រឹមតែបរិបទប្រវត្តិសាស្ត្រតែប៉ុណ្ណោះ ហើយពុំមានអានុភាពណាមួយទៅលើការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា ឬ ខៀវ សំផន នោះទេ[820]។ ហេតុដូច្នេះ ការជំទាស់

---

[816] *សូមមើល* សេចក្តីសង្ខេបអំពីបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងដោយ នួន ជា (E9/10) *និង* ឧបសម្ព័ន្ធទៅនឹងសេចក្តីសង្ខេបនេះ (E9/10.1) ទំព័រ ១៤ ដល់ ១៦។ សេចក្តីសង្ខេបដែលត្រូវបានធ្វើបច្ចុប្បន្នភាពអំពីបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងដោយ នួន ជា (E93/4) *និង*ឧបសម្ព័ន្ធទៅនឹងសេចក្តីសង្ខេបនេះ (E93/4.3) ទំព័រ ១០ (ភាសាអង់គ្លេស)។

[817] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២០០, ២០៣, ២០៥, ២០៩, ២១៤, ២១៨, ២២២, ២២៤, ២៣៤, ២៦៤,៩០៦,១០៥៧, ១០៧៩។

[818] *សូមមើលឧ.*សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៦៧២, ៧៧២, ១២២០, ១២២៧, ១៧៣០, ១៧៥៤, ១៨៤១, ២៥០០។

[819] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤។

[820] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤ ជើងទំព័រ ៥៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១ (“ការវិវឌ្ឍន៍ដំបូងអំពីប្រវត្តិសាស្ត្រនៃលិទ្ធិកុម្មុយនីស្តក្នុងកម្ពុជា ជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងការប្រឆាំងនឹងរដ្ឋអំណាចអាណានិគមបារាំង និងជាពិសេស ការតស៊ូប្រដាប់អាវុធបន្ទាប់ពីសង្គ្រាមលោកលើកទីពីរដែលធ្វើឡើងដោយខ្មែរឥស្សរ និងបក្សកុម្មុយនីស្តឥណ្ឌូចិន”) កថាខណ្ឌ ៨២ (“នៅចុងឆ្នាំ ១៩៥៣ បន្ទាប់សម្តេចនរោត្តមសីហនុបានទទួលជ័យជម្នះនៅក្នុង*ព្រះរាជបូទីយកិច្ចទាមទារឯករាជ្យ* ប្រទេសកម្ពុជាបានទទួលឯករាជ្យឡើងវិញ។ បន្ទាប់ពីចុះហត្ថលេខាលើអនុសញ្ញាទីក្រុងហ្សឺ

របស់ នួន ជា និង ខៀវ សំផន ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើកិច្ចការរបស់លោកស្រី Elizabeth BECKER ត្រូវបដិសេធចោល។

៣៣៤.ពាក់ព័ន្ធទៅនឹង Ben KIERNAN តាមការពិនិត្យលើកំណត់ហេតុសវនាការឃើញថា អង្គជំនុំជម្រះសាលាដំបូង បានព្យាយាមទទួលបានសក្ខីកម្មរបស់គាត់ផ្ទាល់ក្នុងតុលាការ ដោយសារអង្គជំនុំជម្រះបាន“ទទួលស្គាល់ […] ថា គាត់ គឺជាអ្នកជំនាញម្នាក់ក្នុងចំណោមអ្នកជំនាញអន្តរជាតិដ៏ល្បីអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងថា អង្គជំនុំជម្រះបានចាត់ទុកថា ជំនាញរបស់គាត់ទំនងជាអាចរួមចំណែកដល់ការស្វែងរកការពិតក្នុងសំណុំរឿង ០០២ បាន”[821]។ ដោយសារពុំទទួលបានជោគជ័យក្នុងកិច្ចខិតខំប្រឹងប្រែងកោះហៅ Ben KIERNAN អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា “សេចក្តីសន្និដ្ឋានរបស់ Ben KIERNAN ប្រសិនបើមានតម្លៃជាភស្តុតាង ក៏មានតិចតួចដែរនៅក្នុងសំណុំរឿង ០០២ នេះ ព្រោះអ្នកនិពន្ធរូបនេះមិនត្រូវបានសួរដេញដោលចំពោះមុខនោះទេ”[822]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើអត្ថបទបង្រៀនរបស់ Ben KIERNAN ជាច្រើនលើកច្រើនសា[823]។ ប៉ុន្តែ ដូចបានបង្ហាញខាងលើ[824] ភាគច្រើននៃសេចក្តីយោងទាំងនេះ គឺគ្រាន់តែជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញផ្អែកលើភស្តុតាងមិនផ្ទាល់ប៉ុណ្ណោះ និងបានផ្អែកលើប្រភពផ្សេងៗនៃភស្តុតាង រួមទាំងសក្ខីកម្មផ្ទាល់ផងដែរ។ ការជំទាស់របស់ នួន ជា ចំពោះភាពប្រាកដប្រជារបស់ Ben KIERNAN ទាក់ទងទៅនឹងបញ្ហានេះ ពុំអាចជឿជាក់បានឡើយ។

---

ណែវឆ្នាំ ១៩៥៤ ដែលគ្រាន់តែជាការបញ្ចប់លើក្រដាសប៉ុណ្ណោះនូវសង្គ្រាមដំបូងនៅឥណ្ឌូចិន […]”) កថាខណ្ឌ ៨៣ (“ក្នុងឆ្នាំ ១៩៥៥ សម្តេច នរោត្តម សីហនុ បានប្រកាសដាក់រាជ្យបល្ល័ង្កដើម្បីធ្វើជាប្រធានរដ្ឋនៃកម្ពុជា។ ព្រះអង្គបានទទួលជ័យជម្នះក្នុងការបោះឆ្នោត និងបានបង្កើតបក្សសង្គមរាស្ត្រនិយម ដែលមានគោលនយោបាយបរទេសអព្យាក្រឹត្យដែលរួមបញ្ចូលគោលនយោបាយបដិសេធមិនចូលរួមអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍”) កថាខណ្ឌ ៧៧៤ (“ទោះជាយ៉ាងណាក្តី [នៅចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៦៧] ការគ្រប់គ្រងបក្សនៅកម្ពុជានៅពុំទាន់រឹងមាំគ្រប់គ្រាន់នៅឡើយក្នុងការបើកទូលាយប្រទេស”)(ជើងទំព័រលុបចោល)។

[821] អនុស្សរណៈស្តីពីសក្ខីកម្មរបស់ Ben KIERNAN (E166/1/4) ទំព័រ ២។

[822] អនុស្សរណៈស្តីពីសក្ខីកម្មរបស់ Ben KIERNAN (E166/1/4) ទំព័រ ២។

[823] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៣១៨, ៣៤០, ៣៥២, ៣៥៦, ៦៧២ ដល់ ៦៧៣, ៦៧៧, ៦៨៣, ៦៨៦, ៦៩៤ ដល់ ៦៩៧, ៧៥៥, ៨១៣, ១០៥៧, ១០៦២, ១០៨១, ១១៤២, ១៥៦២, ១៩៤៤ និង ២៣៨៥។

[824] *សូមមើលខាងលើ* កថាខណ្ឌ ៣៣៤។

៣៣៥.មានសេចក្តីយោងចំនួន ៣ ទាក់ទងទៅនឹងកិច្ចការរបស់ KIERNAN ដែលត្រូវបានប្រើប្រាស់ដើម្បីគាំទ្រការយល់ឃើញពាក់ព័ន្ធទៅនឹងអាជីព និងដំណើរជីវិតរបស់ ខៀវ សំផន ពីដំបូង[825] ប៉ុន្តែ ការយល់ឃើញទាំងនេះបានផ្អែកជាចម្បងទៅលើសក្ខីកម្ម និងអត្ថបទសរសេរដោយផ្ទាល់របស់ ខៀវ សំផន[826]។ ចំពោះសេចក្តីយោងចំនួន ២ ទៀត របស់អង្គជំនុំជម្រះសាលាដំបូងទៅលើអត្ថបទសរសេររបស់ Ben KIERNAN អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការយោងទាំងនេះទំនងជាគាំទ្រដល់ការយល់ឃើញទាក់ទងទៅនឹងការអំពើប្រព្រឹត្តរបស់ ខៀវ សំផន ដែលជាមូលដ្ឋាននៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ ដូចជា ការចូលរួមយ៉ាងសកម្មនៅក្នុងវគ្គបណ្តុះបណ្តាលមនោគមន៍វិជ្ជា ដើម្បីឱ្យជនជាតិខ្មែរដែលរស់នៅបរទេសត្រឡប់មកប្រទេសខ្លួនវិញ[827]។ អង្គជំនុំជម្រះតុលាការកំពូល នឹងធ្វើការដោះស្រាយអំពីផលប៉ះពាល់នៃសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើអត្ថបទសរសេរទាំងនេះ ដើម្បីកំណត់ពីភាពសមហេតុផលនៃសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងផ្នែកនៃសាលដីកានេះដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន[828]។

---

[825] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៥២ ("ពីពីរទៅបីខែបន្ទាប់ពីគាត់បានមកដល់ទីក្រុងប៉ារីស ខៀវ សំផន បានចូលរួម*ក្រុមម៉ាក់ស៊ីស* ដែលត្រូវបានបង្កើត និងចូលរួមជាប្រចាំដោយនិស្សិតខ្មែរដទៃទៀតនៅក្នុងប្រទេសបារាំង រួមមាន អៀង សារី សាឡុត ស អៀង ធីរិទ្ធ និង សុន សេន") កថាខណ្ឌ ៣៥៣ ("ដូចសមាជិកដទៃទៀតក្នុងក្រុមនោះដែរ ខៀវ សំផន បានចូលរួមជាមួយបក្សកុម្មុយនីស្តបារាំង") កថាខណ្ឌ ៣៥៨ ("ទោះជាយ៉ាងណាក៏ដោយ ខៀវ សំផន បានរក្សាមុខតំណែងក្នុងក្រុមរបស់គាត់រហូតដល់គាត់ត្រូវបានបង្ខំឱ្យលាលែងមុខតំណែងនេះនៅពាក់កណ្តាលឆ្នាំ ១៩៦៣")។

[826] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១០៥៧, ១០៦២, ១០៨១ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ឯកសារលេខ E1/21.1 ទំព័រ ៤៩ ដល់ ៥១, ៥២, ៥៩ ដល់ ៦០, ៦២ និងសៀវភៅរបស់ ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងជំហររបស់ខ្ញុំបន្តបន្ទាប់* (E3/18) ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ១៥ ដល់ ១៦ និង ៣៨ ដល់ ៣៩។

[827] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៧៩ ("រួមទាំងការធ្វើសុន្ទរកថា ខៀវ សំផន បានដើរតួនាទីក្នុងការអប់រំអ្នកដែលត្រឡប់ពីបរទេស ដោយបានបើកវគ្គសិក្សាអប់រំគោលនយោបាយយ៉ាងហោចណាស់មួយជាមួយអ្នកទាំងនោះក្នុងឆ្នាំ ១៩៧៥ ") កថាខណ្ឌ ៧៥៧ ("ខៀវ សំផន បានបើកវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាលើបញ្ញវន្តដែលត្រឡប់មកពីបរទេស និងអ្នករដ្ឋការក្នុងចុងឆ្នាំ ១៩៧៥ និង ១៩៧៦ នៅ ក-១៥។ ក្នុងអំឡុងវគ្គសិក្សាទាំងនេះ គាត់បានបង្ហាញថា ការជម្លៀសចេញពីទីក្រុង គឺជាការត្រឹមត្រូវដែលគាត់បានអះអាងថា បានបំបាត់ចោលនូវកម្មសិទ្ធិឯកជន និងទប់ស្កាត់ការអត់ឃ្លាន និងបានបង្រៀនថា ចំណេះវិជ្ជាដែលបានមកពីការអប់រំរបស់ពួកអាណានិគម និងចក្រពត្តិត្រូវតែលុបបំបាត់ចោលឱ្យអស់")។

[828] *សូមមើលខាងក្រោម* កថាខណ្ឌ ១០១៥។

៣៣៦.បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបដិសេធការអះអាងជាទូទៅរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូង "ពុំបានប្រឹងប្រែងដោយស្មោះត្រង់ក្នុងការវាយតម្លៃលើឯកទេសរបស់អ្នកជំនាញ ឬ អ្នកនិពន្ធទាំងនោះឡើយ"[829] ដោយសារពុំបានបង្ហាញមូលដ្ឋានគាំទ្រគ្រប់គ្រាន់។

៣៣៧.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នួន ជា និង ខៀវ សំផន ពុំបានបង្ហាញពីកំហុសណាមួយដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍របស់តុលាការលើបណ្តឹងសាទុក្ខ ចំពោះការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ ឬ"ប្រភពមិនផ្ទាល់"។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាក់ទងទៅនឹងបញ្ហានេះ ត្រូវបដិសេធចោល។

## ៤.គ.៨.ការវាយតម្លៃលើតម្លៃជាភស្តុតាងរបស់សាក្សីអង្គហេតុ

៣៣៨.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់អ្នកជំនាញ ច្រើនជាងសក្ខីកម្មផ្ទាល់របស់សាក្សីអង្គហេតុ ដើម្បីឈានទៅធ្វើសេចក្តីសន្និដ្ឋាន នៅពេលដែលសក្ខីកម្មរបស់សាក្សីអង្គហេតុនេះ"គឺជាមូលដ្ឋាននៃសាលក្រមនោះ"[830]។ នួន ជា បានជំទាស់បន្ថែមទៀតថា សក្ខីកម្មរបស់សាក្សីអង្គហេតុពីរទៅបីនាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកនៅក្នុងការយល់ឃើញរបស់ខ្លួននោះ ពុំអាចជឿទុកចិត្តបាន ឬជាការសំអាងដោយពុំមានការពន្យល់បកស្រាយ ជាពិសេសចំពោះសក្ខីកម្មរបស់ François PONCHAUD Stephen HEDER ឌុច ភី ភួន និង លឹម សាត[831]។ នួន ជា បានបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងម្តងហើយម្តងទៀតទៅលើសក្ខីកម្មរបស់គាត់ផ្ទាល់សម្រាប់ដាក់បន្ទុក ដោយពុំជឿទាល់តែសោះចំពោះភស្តុតាងដោះបន្ទុករបស់គាត់នោះទេ[832]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពិចារណាឱ្យបាន

---

[829] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២១១។

[830] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៣។

[831] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៤ ដល់ ១៨២។

[832] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៣ ដល់ ១៨៤។

សមស្របលើភស្តុតាងដោះបន្ទុក និងភស្តុតាងដែលបានដេញដោលទៅលើភាពអាចជឿជាក់បាននៃសាក្សី ដោយចង្អុលបង្ហាញជាពិសេសចំពោះ អែម អឿន នូ ម៉ៅ ភី ភួន និង ឌុច[833]។

៣៣៩.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងត្រឹមត្រូវលើតម្លៃជាភស្តុតាងនៃសាក្សីអង្គហេតុ និងថា នួន ជា និង ខៀវ សំផន ពុំបានបង្ហាញពីកំហុសណាមួយពាក់ព័ន្ធទៅនឹងបញ្ហានេះទេ[834]។

### ៤.គ.៨.ក.អ្នកជំនាញ François PONCHAUD និង Stephen HEDER

៣៤០.នួន ជា បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងយ៉ាងទូលំទូលាយទៅលើភស្តុតាងរបស់ François PONCHAUD និង Stephen HEDER "ក្នុងគោលបំណងមិនសមហេតុផល"គឺថា "ហួសឆ្ងាយពីដែនកំណត់"ក្នុងការកោះហៅអ្នកទាំងពីរមកផ្តល់សក្ខីកម្ម ជាសាក្សីអង្គហេតុចំពោះព្រឹត្តិការណ៍ពាក់ព័ន្ធចំនួនតិចតួចដែលគាត់បានឃើញដោយផ្ទាល់ប៉ុណ្ណោះ[835]។ ក្នុងការគាំទ្រអំណះអំណាងនេះ នួន ជា បានចង្អុលទៅលើជើងទំព័រមួយចំនួននៅក្នុងសាលក្រម និងបានលើកឡើងថា "ការយោងទៅលើជើងទំព័រនីមួយៗនេះ មានកំហុសអង្គច្បាប់"[836]។

៣៤១.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា François PONCHAUD និង Stephen HEDER ត្រូវបានកោះហៅស្របពេលជាមួយនឹង David CHANDLER និង Philip SHORT ដើម្បីមកផ្តល់សក្ខីកម្មអំពី

[833] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣។ ខៀវ សំផន បានលើកបន្ថែមថា នៅពេលពិចារណាលើភស្តុតាងទាំងមូល អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលខ្លួនទទួលយកភស្តុតាងរបស់សាក្សីដែលជាអ្នកសមគំនិត អ្នកដែលទទួលផល ប្រយោជន៍ក្នុងការកុហក និងសក្ខីកម្មរបស់អ្នកដែលបង្ហាញភាពផ្ទុយគ្នាជាសត្យានុម័ត។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១៤ ដល់ ១១៥។ ផ្ទុយពីការចោទប្រកាន់របស់គាត់ទាក់ទងទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើសាក្សី អែម អឿន នូ ម៉ៅ ភី ភួន និង ឌុច សារណារបស់គាត់ទាក់ទងទៅនឹងបញ្ហានេះ ពុំមានការយោងណាមួយគាំទ្រជាក់លាក់លើសក្ខីកម្មដែលបានបញ្ជាក់ខាងដើមនេះ អាស្រ័យហេតុនេះត្រូវបានបដិសេធចោលដោយពុំចាំបាច់ពិចារណាបន្តទៀតឡើយ។

[834] សារណាតបរបស់សហព្រះរាជអាជ្ញា កថាណ្ឌ ៩៤ ដល់ ៩៧ ១០៧ និងជើងទំព័រ ៨៦ ដល់ ៨៧។

[835] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨០។

[836] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨០ និងការយោងដែលបានដកស្រង់ក្នុងជើងទំព័រ ៤៧៩។

ព្រឹត្តិការណ៍មុនឆ្នាំ ១៩៧៥ ដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ (D427)[837]។ ក្នុងចំណោមនោះ Stephen HEDER ក៏ត្រូវបានកោះហៅផងដែរពាក់ព័ន្ធទៅនឹងលក្ខណៈពិសេសរបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទ[838]។ François PONCHAUD ត្រូវបានស្តាប់សក្ខីកម្មក្នុងចំណោមសាក្សីចំនួន ២៣ នាក់ដទៃទៀត ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ[839]។

៣៤២.តាមការពិនិត្យសេចក្តីយោងនៅជើងទំព័រ ក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសក្ខីកម្មរបស់ François PONCHAUD និង Stephen HEDER បានបង្ហាញឱ្យឃើញថា សក្ខីកម្មទាំងនេះពាក់ព័ន្ធទៅនឹងការយល់ឃើញដែលមានភស្តុតាងគាំទ្រដទៃទៀត និងកើតចេញមិនត្រឹមតែពីការបានឃើញដោយផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងបានឮពីសាក្សី ឬបានសម្ភាសន៍ដោយផ្ទាល់ ឬបានស្រាវជ្រាវរកឃើញផងដែរ។ ផ្ទុយទៅនឹងការអះអាងរបស់ នួន ជា ដែលថា François PONCHAUD និង Stephen HEDER “បានឃើញយ៉ាងយូរត្រឹមតែពីពីរទៅបីម៉ោងប៉ុណ្ណោះនូវព្រឹត្តិការណ៍មួយចំនួន ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ”[840] ដោយហេតុថា François PONCHAUD បានរស់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៦៥[841] ហើយអាចនិយាយភាសាខ្មែរបានយ៉ាងស្ទាត់[842] ដែលជាជនបរទេសម្នាក់ក្នុងចំណោមជនបទេសចុងក្រោយបង្អស់ដែលបានចាកចេញពីប្រទេសកម្ពុជា បន្ទាប់ពីខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញ[843] និងបានផ្តល់សក្ខីកម្មថា បានឃើញព្រឹត្តិការណ៍ពាក់ព័ន្ធមួយចំនួនកើតឡើងប៉ុន្មានឆ្នាំមុននោះ និងរួមទាំងក្នុងអំឡុងពេលនៃរបប

---

[837] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី (E312) កថាខណ្ឌ ៣១។

[838] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី (E312) កថាខណ្ឌ ៤២។

[839] សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី (E312) កថាខណ្ឌ ៦០ ដល់ ៦១។

[840] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៤។ នួន ជា ក៏បានលើកឡើងអំពី Sydney SCHANBERG និង Al ROCKOFF ប៉ុន្តែគ្រាន់តែបានពិភាក្សាភស្តុតាងរបស់ François PONCHAUD និង Stephen HEDER។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៤, ១៨០ ដល់ ១៨២ ជើងទំព័រ ៤៥៦។

[841] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៦ ដល់ ៨។

[842] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៤ ដល់ ៦ និង ៩។

[843] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៦ ដល់ ៨, ២៧ ដល់ ២៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៤៧៨។

កម្ពុជាប្រជាធិបតេយ្យ[844]។ បន្ទាប់ពីគាត់បានចាកចេញពីប្រទេសកម្ពុជា នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៥ គាត់បានប្រមូលការវិវឌ្ឍន៍ព័ត៌មានយ៉ាងច្រើន ដូចជាការសម្ភាសន៍ជនភៀសខ្លួននៅក្នុងប្រទេសថៃ និងប្រទេសបារាំង ស្តាប់វិទ្យុរបស់ខ្មែរក្រហម និងអានឯកសារផ្សេង[845]។ ប្រភពទាំងនេះបានក្លាយជាមូលដ្ឋានមួយផ្នែកក្នុងសក្ខីកម្មរបស់គាត់[846]។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញអំពីភាពមិនប្រក្រតីរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសំអាងលើភស្តុតាងរបស់ François PONCHAUD។

៣៤៣.ទាក់ទងទៅនឹង Stephen HEDER នួន ជា បានលើកឡើងថា "អង្គជំនុំជម្រះ[សាលាដំបូង] បានពិចារណាយ៉ាងពិសេសទៅលើមតិយោបល់[របស់គាត់]" និងរំឭកថា Stephen HEDER ធ្លាប់បានបម្រើការនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត និងការិយាល័យសហព្រះរាជអាជ្ញានៃ អ.វ.ត.ក. និងថា គាត់ជាអ្នកព្រាង"ប្លង់សម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងខែមីនា ឆ្នាំ ២០០៤ ដោយតាមរយៈការបោះពុម្ពផ្សាយសៀវភៅស្តីពី *បុគ្គលប្រាំពីររូបសម្រាប់ការចោទប្រកាន់*"[847]។ ទោះជាយ៉ាងណាក៏ដោយ អំណះអំណាងរបស់ នួន ជា ដែលថា "ប្រសិនបើ Heder ត្រូវបានកោះហៅមកធ្វើជាអ្នកជំនាញ គាត់ត្រូវផ្តល់សក្ខីកម្ម*ដោយអព្យាក្រឹតបំផុត និងដោយភាពសត្យានុម័តជាលក្ខណៈវិទ្យាសាស្ត្រ*"[848] ពុំអាចជឿជាក់បានឡើយ។ ពុំមានសញ្ញាណាមួយបង្ហាញថា Stephen HEDER បានផ្តល់សក្ខីកម្មដោយមិនអព្យាក្រឹត និងពុំមានសត្យានុម័តជាក់ស្តែងនោះទេ ឬថា សក្ខីកម្មរបស់គាត់គួរតែមានអព្យាក្រឹតភាព និងភាពសត្យានុម័តច្រើនជាងនេះ ប្រសិនបើគាត់បានផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ ដែលពុំមែនក្នុងនាមជាសាក្សីអង្គហេតុនោះ។ នួន ជា ខ្លួនឯងផ្ទាល់ក៏បានស្នើសុំឱ្យកោះហៅ Stephen HEDER មកធ្វើជាសាក្សី និងបានទទួលស្គាល់គាត់ថា ជា"អ្នកជំនាញនាំ

---

[844] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៩ ដល់ ៤០, ៤៣ ដល់ ៤៥, ៤៩ ដល់ ៥០។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤ ដល់ ៨, ១៣ ដល់ ១៤, ២៨ ដល់ ៣១, ៣៥ ដល់ ៣៦, ៤៧, ៦៥ ដល់ ៦៦, ៦៨ ដល់ ៦៩ និង ៧៦។

[845] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៤៧, ៥៧ ដល់ ៧២។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៩, ១៧ ដល់ ១៩, ២១ ដល់ ២៣, ២៦ ដល់ ២៨, ៣៩ ដល់ ៤០, ៤៧ ដល់ ៥២, ៦៥ ដល់ ៦៦, ៦៩, ៧៥ ដល់ ៧៦។

[846] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E1/179.1 ទំព័រ ៤០ ដល់ ៥០។

[847] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨២។

[848] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨២។

មុខគេស្ដីពីកម្ពុជា"[849] និងបានទទួលស្គាល់ថា Stephen HEDER មានវត្តមាននៅក្នុងទីក្រុងភ្នំពេញចន្លោះពីឆ្នាំ ១៩៧៣ រហូតដល់ ឆ្នាំ ១៩៧៥ ព្រមទាំងបានធ្វើដំណើរកម្សាន្តទៅកាន់ខេត្តកំពង់ចាម និងឧដុង្គ បន្ទាប់ពីការចូលកាន់កាប់ដោយកងទ័ពខ្មែរក្រហមក្នុងឆ្នាំ ១៩៧៣ និង ១៩៧៤[850]។ បន្ថែមលើនេះទៀត អត្ថបទជាច្រើនសរសេរដោយ Stephen HEDER ដែលជាកម្មវត្ថុនៃសក្ខីកម្មរបស់គាត់នោះ ត្រូវបាននិពន្ធឡើងនៅមុនពេលចូលបម្រើការងារនៅ អ.វ.ត.ក. ដូច្នេះ ពុំមានឥទ្ធិពលពីការបម្រើការងាររបស់គាត់នៅ អ.វ.ត.ក. នោះឡើយ[851]។

៣៤៤.ដូចបានកត់សម្គាល់ខាងលើ នួន ជា ក៏បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភសិទ្ធិរបស់គាត់ក្នុងការជំទាស់ទៅនឹងភស្តុតាងប្រឆាំងនឹងរូបគាត់ និងសិទ្ធិទទួលបានតុល្យភាពតទល់ដោយបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាទទួលបានមតិយោបល់របស់ Stephen HEDER តាមរយៈការបង្កើតសំណួររបស់ខ្លួនជាលក្ខណៈស៊ើបសួរពីអង្គហេតុទាក់ទងទៅនឹងការស្រាវជ្រាវបឋមរបស់គាត់ ប៉ុន្តែករណីនេះពុំបានអនុញ្ញាតឱ្យសាកសួរដូចគ្នានៅពេលមានការសួរដេញដោលដោយភាគីការពារក្ដីទៀតនោះទេ[852]។ នួន ជា បាន

---

[849] *សូមមើល* សេចក្ដីសង្ខេបបញ្ជីឈ្មោះសាក្សីដែលស្នើដោយ នួន ជា (E9/10) *និង*ឧបសម្ព័ន្ធទៅនឹងសេចក្ដីសង្ខេបនេះ (E9/10.1) ទំព័រ ៦៣ ដល់ ៦៦។ សេចក្ដីសង្ខេបត្រូវបានធ្វើបច្ចុប្បន្នភាពអំពីបញ្ជីឈ្មោះសាក្សីដែលស្នើដោយ នួន ជា (E93/4) និងឧបសម្ព័ន្ធទៅនឹងសេចក្ដីសង្ខេបនេះ (E93/4.3) ទំព័រ ៤០ (ភាសាអង់គ្លេស)។

[850] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៩៧៨។

[851] *សូមមើល* សៀវភៅរបស់ S. HEDER និង B. TITTEMORE *បុគ្គលប្រាំពីរនាក់សម្រាប់ការកាត់ទោស៖ ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម* ឯកសារលេខ E3/48 ឆ្នាំ ២០០៤។ សៀវភៅរបស់ S. HEDER៖ *លិទ្ធិកុម្មុយនីស្តនៅកម្ពុជា និងគំរូវៀតណាម* ឯកសារលេខ E3/22 ឆ្នាំ ២០០៤។ របាយការណ៍របស់ S. HEDER និង M. MATSUSHITA៖ កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនខ្មែរថៃ ឯកសារលេខ E3/1714 ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨០។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ Steve HEDER (SH) ជាមួយ អៀង សារី (IS) ឯកសារលេខ E/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៨៦ (កាលបរិច្ឆេទនៃកិច្ចសម្ភាសន៍)។ កិច្ចសម្ភាសន៍របស់ S. HEDER ជាមួយ អៀង សារី ឯកសារលេខ E3/543 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៨៦។ កិច្ចសម្ភាសន៍របស់ S. HEDER ជាមួយ អៀង សារី ឯកសារលេខ E190 ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៩។ ប្រតិចារឹកកំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ S. HEDER ជាមួយ អៀង សារី ឯកសារលេខ E573 ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៩។ របាយការណ៍របស់ S. HEDER៖ *ការវាយតម្លៃឡើងវិញនូវតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងកម្មាភិបាលថ្នាក់ក្រោមក្នុងឧក្រិដ្ឋកម្មនៃកម្ពុជាប្រជាធិបតេយ្យ៖ ការទទួលខុសត្រូវរបស់កម្ពុជានៅក្នុងទស្សនៈប្រហាក់ប្រហែល* ឯកសារលេខ E3/4527 ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៣។

[852] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨២ ជើងទំព័រ ៤៩០ យោងទៅលើការដកសេចក្ដីជូនដំណឹងពីបំណង (E287/2) កថាខណ្ឌ ៦ ដល់ ១២ ជើងទំព័រ ២៣។ នួន ជា ក៏បានស្នើសុំជាបឋមឱ្យកោះហៅ Stephen HEDER មកផ្ដល់សក្ខីកម្មអំពី"គោលបំណង និងគុណភាពនៃកិច្ចស៊ើបសួរនៃការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០២" ជាពិសេស កិច្ចប្រជុំក្នុង

លើកឡើងថា ដើម្បីទូទាត់ចំពោះការរំលោភបំពានដែលចោទប្រកាន់នេះ អង្គជំនុំជម្រះសាលាដំបូងពុំគប្បីសំអាងទៅលើសក្ខីកម្មរបស់ Stephen HEDER ឡើយ[853]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានវិធីសាស្ត្រធ្វើឱ្យភាន់ច្រឡំទាក់ទងទៅនឹងការសាកសួរ Stephen HEDER នៅក្នុងតុលាការ ដែលប្រហែលជាកើតមកពីការចាត់តាំងរូបគាត់ជាសាក្សីអង្គហេតុ ប៉ុន្តែមិនមែនសាក្សីជំនាញនោះ[854]។ ទាក់ទងទៅនឹងបញ្ហានេះគួរកត់សម្គាល់ថា ដោយសារចម្លើយរបស់គាត់ជាច្រើនបានផ្អែកលើបទសម្ភាសន៍ជាមួយនឹងបុគ្គលផ្សេងៗ ឬឯកសារដែលគាត់បានពិនិត្យ ដូច នួន ជា បានលើកឡើង[855] ទើបនេះជាការពុំសមស្របក្នុងការបែងចែកភាពខុសគ្នារវាងមួយផ្នែកការដឹងរបស់ HEDER ដែលទទួលបានតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន និងមួយផ្នែកទៀតជាមួយនឹងមតិយោបល់ដែលបានផ្អែកលើការស្រាវជ្រាវរបស់គាត់នោះឡើយ[856]។ នួន ជា បានចង្អុលបង្ហាញទៅលើចំណុចជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូង "បានធ្វើហួសឆ្ងាយ"ពីដែនកំណត់នៃតួនាទីរបស់ HEDER ជាសាក្សីអង្គហេតុ[857] ប៉ុន្តែពុំបានពន្យល់លម្អិត ថាតើការធ្វើឱ្យភាន់ច្រឡំបែបនេះបានរំលោភលើសិទ្ធិ

---

ខែ សីហា ឆ្នាំ ២០០៩ ដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេត Marcel LEMONDE បានបង្ហាញចេតនាចង់ប្រមូលភស្តុតាងដែលមានលក្ខណៈដាក់បន្ទុកជាង សម្រាប់សំណុំរឿង ០០២។ *សូមមើល* សេចក្តីសង្ខេបបញ្ជីឈ្មោះសាក្សីដែលស្នើដោយ នួន ជា (E9/10) *និង*ឧបសម្ព័ន្ធទៅនឹងសេចក្តីសង្ខេបនេះ (E9/10.1) ទំព័រ ៦៣ ដល់ ៦៦។ សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពអំពីបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើងដោយ នួន ជា (E93/4.3) ទំព័រ ៤០ ដល់ ៤១ (ភាសាអង់គ្លេស)។ ការតវ៉ាដំបូងរបស់គាត់អំពីការមិនផ្តល់ឱកាសក្នុងការសួរសំណួរ Stephen HEDER លើព្រឹត្តិការណ៍ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (*សូមមើល* ការដកសេចក្តីជូនដំណឹងពីបំណង (E287/2) កថាខណ្ឌ ១៣) ពុំត្រូវបានបញ្ជាក់សាជាថ្មីនៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ។

[853] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨២។

[854] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារលេខ E1/224.1 ទំព័រ ១៧ ដល់ ២០, ៣៧, ៤៩ ដល់ ៥១, ៥៣, ៥៥ ដល់ ៥៧, ៦៦ ដល់ ៦១, ៦៥, ៩១ ដល់ ៩៣។

[855] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨១។

[856] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៣៣៥ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/222.1 ទំព័រ ៣៩ ដល់ ៤០ (HEDER បានសំអាងទៅលើកិច្ចសម្ភាសន៍របស់គាត់ជាមួយ កែវ ពក) ៣៤០ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារលេខ E1/221.1 ទំព័រ ៧១ ដល់ ៧៣ (ចម្លើយផ្អែកលើកិច្ចសម្ភាសន៍ជាមួយនឹងជនភៀសខ្លួន) ៣៤៤ (ចម្លើយផ្អែកលើកាលកំណត់ពេលវេលារបស់ Tim Carney ដែលបានផ្អែកបន្តទៀតលើការបកប្រែរបស់ FBIS) ៤៧៩ (ផ្អែកលើកិច្ចសម្ភាសន៍របស់គាត់ជាមួយអ្នកជំនាញយោធាជនជាតិជប៉ុន) ៦៦៥ (ផ្អែកលើកិច្ចសម្ភាសន៍ជាមួយបុគ្គលម្នាក់) ២៦៥៤ (ផ្អែកលើកិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួន)។

[857] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨០ និងជើងទំព័រ ៤៧៩។

របស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវដូចម្ដេចឡើយ[858]។ ដូចគ្នាដែរ ទោះបីជាមានការមិនពេញចិត្តយ៉ាងណាក៏ដោយ ក៏សហមេធាវីការពារក្ដី នួន ជា នៅតែមានលទ្ធភាពសាកសួរសាក្សីដែរ ហើយបញ្ហានេះក៏មិនបានបង្ហាញឱ្យឃើញថា នួន ជា បានទទួលរងផលប៉ះពាល់ដោយវិធីសាស្ត្ររឹតត្បិតរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកម្រិតវិសាលភាពនៃការតាំងសំណួរទៅកាន់ Stephen HEDER ឡើយ។

## ៤.គ.៨.ខ.សាក្សី ឌុច ភី ភួន និង លីម សាត ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន និង នូ ម៉ៅ

៣៨៥.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើភស្តុតាងដោះបន្ទុកដែលទទួលបានពី ឌុច[859]នោះឡើយ។ ខៀវ សំផន បានចង្អុលបង្ហាញនោះ គឺសំដៅលើសេចក្ដីថ្លែងរបស់ ឌុច ដែលថា សមមិត្ត"លីន" និង/ឬ"ជាម"នៅក្រសួងការបរទេស ជាទូទៅជាអ្នកទទួលបន្ទុកនាំអ្នកទោសទៅកាន់មន្ទីរសន្តិសុខ ស-២១[860]។ គប្បីបដិសេធចោលដោយពុំចាំបាច់ធ្វើការពិចារណាបន្តទៀតចំពោះការចោទប្រកាន់របស់ ខៀវ សំផន ដែលថា សេចក្ដីថ្លែងខាងលើជាភស្តុតាងដោះបន្ទុកដែលអង្គជំនុំជម្រះសាលាដំបូងពុំបានលើកមកពិចារណា ដោយហេតុថា ខៀវ សំផន ពុំបានបញ្ជាក់ច្បាស់ ថាតើសេចក្ដីថ្លែងនេះបង្កើតឱ្យមានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់គាត់យ៉ាងដូចម្ដេចឡើយ។

---

[858] អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅក្នុងករណីមួយចំនួន ចម្លើយរបស់ Stephen HEDER អាចចាត់ទុកយ៉ាងសមស្របថា ជាទស្សនៈផ្ទាល់ខ្លួន (*សូមមើលខ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៦២៩ (HEDER បញ្ចេញយោបល់លើការប្រើប្រាស់ពុំច្បាស់លាស់នូវពាក្យ"មជ្ឈិមបក្ស") ៦៣១, ៦៣៧, ៦៣៨, ៦៤៤ និង ៦៤៦ (HEDER បានបញ្ជាក់អំពីអត្ថន័យនៃលេខសម្ងាត់"៨៧០" និងបានពន្យល់ថា ប.ក.ក. មានចេតកែប្រែពាក្យពេចន៍ដើម្បីលាក់បាំងធាតុពិតរបស់ថ្នាក់ដឹកនាំ) ១៧១៧ (ការបកស្រាយពាក្យ"komchat"*កម្ទាត់*)។ ទោះជាយ៉ាងណាក្ដី ដូចបានបញ្ជាក់ នួន ជា ពុំបានបង្ហាញ ថាតើការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើមតិយោបល់ផ្ទាល់ខ្លួនរបស់សាក្សីអង្គហេតុបានរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ ឬបណ្ដាលឱ្យមានកំហុសអង្គច្បាប់ដែលអាចមោឃៈសាលក្រមបានយ៉ាងដូចម្ដេចឡើយ។

[859] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣ យោងទៅលើប្រតិចារិកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E1/62.1 (កាំង ហ្គេកអ៊ាវ *ហៅ* ឌុច) ទំព័រ ៥៨ ដល់ ៥៩។

[860] *សូមមើល* ប្រតិចារិកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/62.1 ទំព័រ ៦១ (ភាសាខ្មែរ), ៨៨ (ភាសាបារាំង)។ *សូមមើលផងដែរ* ប្រតិចារិកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E1/62.1 ទំព័រ ៦១ ដល់ ៦២ (ភាសាខ្មែរ ពិពណ៌នាអំពីសមមិត្ត"លីន""ជាម") ៧៦ ដល់ ៧៧ (ភាសាអង់គ្លេស"Chean"/"Cheang")។

៣៤៦.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើទៅនឹងការជំទាស់របស់គាត់ចំពោះភាពអាចជឿជាក់បានរបស់ ភី ភួន[861] តាមការពិត អង្គជំនុំជម្រះបានដោះស្រាយយ៉ាងពិសេសលើការជំទាស់របស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះ[862]។ ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើបញ្ហានៃការចងចាំ ភាពផ្ទុយគ្នាសំខាន់ៗ និងភាពជឿជាក់បាននៃសក្ខីកម្មរបស់ អែម អឿន និង នូ ម៉ៅ[863]។

៣៤៧.តាមការពិនិត្យនៅក្នុងប្រតិចារឹករបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ដែល ខៀវ សំផន បានជំទាស់នោះ បានបង្ហាញឱ្យឃើញថា មានភាពមិនស៊ីសង្វាក់គ្នាខ្លះនៅក្នុងសក្ខីកម្ម[864]។ អែម អឿន បានទទួលស្គាល់ថា មានបញ្ហាលំបាកក្នុងការរំលឹកឡើងវិញទៅតាមលំដាប់លំដោយ នូវព្រឹត្តិការណ៍ដែលបានកើតឡើងអស់រយៈពេល ៤០ ឆ្នាំកន្លងទៅ និងដោយមានការប៉ះទង្គិចផ្លូវចិត្ត បានធ្វើឱ្យប៉ះពាល់ដល់ការចងចាំរបស់គាត់[865]។ ទោះជាយ៉ាងណាក្តី ខៀវ សំផន ពុំបានផ្តល់សេចក្តីយោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ឬចំណុចប៉ះពាល់ណាមួយដែលបង្ហាញឱ្យឃើញថា ការដែលអង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណា បានធ្វើឱ្យប៉ះពាល់ដល់ការសម្រេចនៅក្នុងសាលក្រម។ ទាក់ទងទៅនឹងសក្ខីកម្មរបស់ នូ ម៉ៅ ខៀវ សំផន ពុំបានផ្តល់ការយោងណាមួយដែលបញ្ជាក់អំពីភាពពុំស៊ីសង្វាក់គ្នា ឬការភ្ជាប់ទំនាក់ទំនងសក្ខីកម្មដែលអះអាងថា ពុំត្រឹមត្រូវនោះទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះដែលបានចោទប្រកាន់ថា មានកំហុសនោះទេ។ អាស្រ័យហេតុនេះ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះត្រូវបដិសេធចោល។

៣៤៨.នួន ជា បានលើកឡើងថា ដោយឃើញថា ភស្តុតាងពុំស៊ីសង្វាក់គ្នា និងពុំអាចជឿទុកចិត្តបានក៏ដោយ អង្គជំនុំជម្រះសាលាដំបូង នៅតែចចេសមិនព្រមអនុវត្តកាតព្វកិច្ចផ្តល់ហេតុផលនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន

---

[861] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣។

[862] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៤២៥។

[863] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣។

[864] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ឯកសារលេខ E1/117.1 ទំព័រ ១៤ ដល់ ១៥ (បង្ហាញពីកាលបរិច្ឆេទខុសគ្នាទាក់ទងទៅនឹងការស្លាប់ឪពុករបស់គាត់) ទំព័រ ២១ ដល់ ២២ (បង្ហាញពីភាពផ្ទុយគ្នាក្នុងការរៀបរាប់នៃការស្លាប់ម្តាយរបស់គាត់ និងការរស់នៅក្នុងវត្តមួយ)។

[865] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (អែម អឿន) ឯកសារលេខ (E1/117.1) ទំព័រ ១៩ ដល់ ២០។

នេះគឺជា"កំហុសអង្គច្បាប់យ៉ាងធំធេង"[866]។ បន្ទាប់មក នួន ជា បានយោងទៅលើការប្រព្រឹត្តរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសក្ខីកម្មរបស់ ឌុច ដែលទាក់ទងទៅនឹងបញ្ហានេះ នួន ជា បានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើបញ្ហានៃភាពអាចជឿជាក់បានរបស់ ឌុច[867]។ ជាពិសេស នួន ជា បានរំលឹកអំពីការបញ្ជាក់របស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសាលដីកា*រឿងក្តី ឌុច* (001-F28) ដែលថា ឌុច បានស្វះស្វែងស្នើសុំការ"សម្រាលតួនាទីរបស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មនានា" និង"ទម្លាក់ការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ឧក្រិដ្ឋកម្មទៅឱ្យអ្នកដទៃ"[868] និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ទោះជាយ៉ាងណាក្តី"បានយោងទៅលើសក្ខីកម្មរបស់ ឌុច ជានិច្ច និងជាញឹកញាប់បានយកមកធ្វើជាប្រភពដ៏មានសារៈសំខាន់ ក្នុងការគាំទ្រដល់ការយល់ឃើញផ្នែកអង្គហេតុដែលមានការជំទាស់យ៉ាងខ្លាំង"[869] ដោយពុំបានប្រឹងប្រែងបង្ហាញឱ្យឃើញថា ការសំអាងបែបនេះត្រឹមត្រូវឡើយ និងពុំបានពិចារណាលើការទទួលស្គាល់របស់ ឌុច ម្តងហើយម្តងទៀតដែលថា គាត់ពុំបានដឹងដោយផ្ទាល់ក្នុងពេលនោះចំពោះសំអាងហេតុមួយចំនួនដែលគាត់បានផ្តល់សក្ខីកម្មទេ[870]។ នួន ជា ក៏បានជំទាស់ផងដែរទៅនឹងការសំអាងម្តងហើយម្តងទៀតរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសក្ខីកម្មរបស់ ភី ភួន ក្នុងគោលបំណងដាក់បន្ទុកដែលគ្មានភស្តុតាងដាក់បន្ទុក ហើយប្រសិនបើមានក៏មានតិចតួចបំផុត ក្នុងការគាំទ្រដល់ការយល់ឃើញសំខាន់ៗដែលត្រូវបានជំទាស់ដោយភាគីការពារក្តី[871] ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានបដិសេធ ឬពុំអើពើទៅលើភស្តុតាងដោះបន្ទុក ដូចជាសេចក្តីណែនាំរបស់ ប៉ុល ពត មិនត្រូវ"ប៉ះពាល់"ទាហាននៃរបបសាធារណរដ្ឋខ្មែរ[872]។ នួន ជា បានអះអាងថា ការដែលអង្គជំនុំជម្រះសាលាដំបូងពុំបានទទួលស្គាល់ភស្តុតាងដោះបន្ទុកដែលមាននៅចំពោះមុខ គឺជា"កំហុសអង្គច្បាប់ជាក់ស្តែង"[873]។ បន្ថែមលើនេះទៀត នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា លឹម សាត ដែលជាសាក្សីម្នាក់ក្នុងចំណោមសាក្សីបីនាក់ដែលបានផ្តល់ភស្តុតាងអំពីការសម្លាប់នៅទួលពោធិ៍ជ្រៃ បាននិយាយ

---

[866] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៦។

[867] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៥ ដល់ ១៧៧។

[868] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៦ យោងទៅលើសាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៣៦៨។

[869] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៦។

[870] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៦ ដល់ ១៧៧ និងសេចក្តីយោងនៅក្នុងជើងទំព័រ ៤៧១។

[871] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៨ និងសេចក្តីយោងក្នុងជើងទំព័រ ៤៧២។

[872] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៨ យោងទៅលើកថាខណ្ឌ ៥៦៦។

[873] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៨។

កុហកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយថា ការចងចាំរបស់ លឹម សាត ពុំត្រឹមត្រូវលើចំណុចជាច្រើន ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងអាចយកសក្ខីកម្មនេះមកសំអាងដោយពុំចាំបាច់ផ្តល់ហេតុផល ក្នុងការធ្វើដូច្នោះឡើយ[874]។

៣៤៩.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ផ្អែកលើអំណះអំណាងត្រង់ចំណុចនេះ នួន ជា ពុំបានចោទប្រកាន់អំពីកំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែបានចោទលើកំហុសអង្គច្បាប់ដោយសារការពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់។ ដូចបានកត់សម្គាល់ខាងលើ[875]ទាក់ទងទៅនឹងទិដ្ឋភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យចេញសេចក្តីសម្រេចមានសំអាងហេតុ។ ទោះជាយ៉ាងណាក្តី ពុំមែនរាល់ចំណុចនៃសំអាងហេតុក្នុងសាលក្រមសុទ្ធតែធ្វើឱ្យកិច្ចដំណើរការនីតិវិធីពុំបានប្រព្រឹត្តឡើងដោយត្រឹមត្រូវនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា មានចំណុចខ្វះខាតមួយចំនួននៅក្នុងការពិភាក្សារបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ ឌុច ដែលគប្បីត្រូវបានពិចារណាដោយប្រុងប្រយ័ត្ន ដោយសារមានការសម្រេចនៅក្នុងសំណុំរឿង ០០១ ថា ឌុច ខ្វះនូវភាពអាចជឿជាក់បានដោយសារមានការជំរុញក្នុងការស្វះស្វែងទម្លាក់ការទទួលខុសត្រូវចេញពីខ្លួន បើទោះបីជា គាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពនៅដំណាក់កាលបណ្តឹងសាទុក្ខក៏ដោយ ហើយសំណុំរឿងរបស់គាត់ក្នុងពេលបច្ចុប្បន្នត្រូវបានបញ្ចប់ក៏ដោយ ក៏គាត់នៅតែសុំសម្រាលកត្តាជំរុញនានាដើម្បីឱ្យផុតពីការចោទប្រកាន់ដែរ។ ទោះជាយ៉ាងណាក្តី ការពិនិត្យឡើងវិញលើសំអាងហេតុ និងសេចក្តីយោងទៅលើសក្ខីកម្មរបស់ ឌុច ដែល នួន ជា បានជំទាស់ បង្ហាញឱ្យឃើញថា ការយោងទាំងនេះពុំតម្រូវឱ្យចងភ្ជាប់ទៅនឹងការយល់ឃើញសំខាន់ៗ និង/ឬ ពុំតម្រូវឱ្យមានភស្តុតាងដទៃទៀតគាំទ្រយ៉ាងច្រើននៅក្នុងសំណុំរឿងឡើយ។ អាស្រ័យហេតុនេះ ការសំអាងលើសក្ខីកម្មរបស់ ឌុច ត្រង់ចំណុចនេះពុំមែនជាចំណុចសំខាន់ទេ[876]។ បន្ថែមលើនេះទៀត ការពិនិត្យឡើងវិញលើ

---

[874] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៩។

[875] *សូមមើលខាងលើ* កថាខណ្ឌ ២០៥ *ជាអាទិ៍*។

[876] ប្រៀបធៀបសេចក្តីយោងដកស្រង់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៤៧១ ជាមួយនឹងសាលក្រមសាលាដំបូងជើងទំព័រ ៣២៦ ដល់ ៣៤០ (ប្រភពភស្តុតាងមួយចំនួនអំពីគោលនយោបាយរបស់ ប.ក.ក. ក្នុងការកម្ទេចខ្មាំង) ជើងទំព័រ ៦១៥ (សំអាង*ក្នុងចំណោមនោះ*លើកំណត់ហេតុស្តាប់ចម្លើយរបស់ ខៀវ សំផន ឯកសារលេខ E3/27 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨ ("គណៈមជ្ឈិមមិនមានអំណាចពិតប្រាកដនោះទេ ខុសពីគណៈអចិន្ត្រៃយ៍")) ១០០៤ ដល់ ១០០៦ (សំអាងលើសក្ខីកម្មរបស់ សាឡុត បាន និង នង សុផង់ បន្ថែមលើ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ដើម្បីគាំទ្រការយល់ឃើញថា ជាផ្នែកមួយនៃការទទួលខុសត្រូវរបស់គាត់សម្រាប់"កិច្ចការសាធារណៈ" តួនាទីរបស់ នួន ជា រួមបញ្ចូលការចាត់តាំង និងការដាក់ពិន័យសមាជិកបក្ស) ១៧២ (សំអាង*ក្នុង*

ការយល់ឃើញ ឬការយោងទៅលើសក្ខីកម្មរបស់ ឌុច ដែល នួន ជា ពុំបានចង្អុលបង្ហាញជាក់លាក់ឃើញថា ផ្ទុយទៅនឹងការអះអាងបញ្ជាក់របស់គាត់ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិចារណាលើការទទួលស្គាល់របស់ ឌុច ដែលថា គាត់ក្នុងពេលនោះពុំបានដឹងអំពីអង្គហេតុមួយចំនួនដែលគាត់ផ្តល់សក្ខីកម្ម ដូចជា តួនាទីជាន់ខ្ពស់របស់ ខៀវ សំផន នៅក្នុង"មន្ទីរ ៨៧០" ដែលជាការចោទប្រកាន់មួយថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា *ឌុច* បាននិយាយសំដៅលើតួនាទីជាន់ខ្ពស់ជាទូទៅរបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអត្ថបទសម្រាប់សិក្សា និងពាក្យចចាមអារ៉ាម[877]។

៣៩០.ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹងសក្ខីកម្មរបស់ *ភី ភួន* អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាលើតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ *ភី ភួន* ថា អាចជឿជាក់ និងទុកចិត្តបាន។ ឧទាហរណ៍ នៅពេលដេញដោលលើភស្តុតាងដែលមានការជំទាស់ទាក់ទងទៅនឹងវត្តមានរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំនៅខែ មិថុនា ឆ្នាំ ១៩៧៤ នៅក្នុងភូមិមាយជាកន្លែងដែលបានយល់ស្របជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[878] អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា សក្ខីកម្មរបស់ *ភី ភួន* "មានភាពច្បាស់លាស់" ដូចគ្នាជាមួយនឹង"ព័ត៌មានដែលផ្តល់ដោយ ស្អួង ស៊ីគឿន" ដែលនេះមានលក្ខណៈគួរឱ្យទុកចិត្តបានជាងសេក្ខីកម្មរបស់ប្រពន្ធ នួន ជា ខៀវ សំផន ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃពេញលេញមុនពេលបដិសេធថា ពុំអាចជឿ

---

*ចំណោមទោះ*លើលិខិតរបស់ ខៀវ សំផន ក្នុងការគាំទ្រការយល់ឃើញថា គណៈកម្មាធិការមជ្ឈិមបក្ស ភូមិភាគ តំបន់ និងស្រុក មានសិទ្ធិក្នុងការផ្លាស់ទីលំនៅ ឬផ្ទេរប្រជាជននៅក្នុងតំបន់របស់ខ្លួនបាន) ១៧៦០ (សំអាងលើភស្តុតាងផ្ទាល់ និងជាឯកសារមួយចំនួន ជាពិសេស លើឯកសាររបស់កម្ពុជាប្រជាធិបតេយ្យៈ ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំប្រទេសគ្រប់ផ្នែក ឯកសារលេខ E3/781 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលបញ្ជាក់ក្នុងទំព័រ ៣១ ថា "ព្រះវិហារស្មើ [ប្រជាជន] ៥ ម៉ឺនចំពោះមុខសិន។ […] ដូច្នេះបណ្តើរៗ ជូន ២ ម៉ឺនសិន"ក្នុងការគាំទ្រការយល់ឃើញដំណាល់គ្នាក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៦) ជើងទំព័រ ១៨៧៣ (សំអាងលើទូរលេខរបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ឯកសារលេខ E3/3559 រួមទាំងអត្ថបទរបស់ François PONCHAUD ជាការបន្ថែមលើសក្ខីកម្មរបស់ ឌុច ក្នុងការពិភាក្សាតួនាទីរបស់កងចល័តក្នុងសហករណ៍) ១៩២៣ *ជាអាទិ៍* (ប្រភពភស្តុតាងជាច្រើនស្តីអំពីការតស៊ូវណ្ណៈ និងគោលនយោបាយបក្សប្រឆាំងនឹង"ប្រជាជនថ្មី") ២៥៤២ (ប្រភពភស្តុតាងជាច្រើន ដូចជា ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីគាំទ្រការយល់ឃើញដំណាលគ្នាក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៨) ២៦៤៣ (ប្រភពភស្តុតាងជាច្រើនក្នុងការគាំទ្រការយល់ឃើញដែលថា នៅចុងឆ្នាំ ១៩៧៥ ខ្មែរក្រហមបានបន្តកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណៈខ្មែរ និងគ្រួសាររបស់ពួកគេ)។

[877] សាលក្រមរបស់អង្គជនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៩៦។

[878] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៤៧២។

ទុកចិត្តបាន និងធ្វើឡើងក្នុងគោលបំណងជួយប្តីរបស់គាត់[879]។ ស្រដៀងគ្នានេះដែរ ក្នុងការសន្និដ្ឋានថា មានកិច្ចប្រជុំមួយផ្សេងទៀតដែលបានចូលរួមដោយមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. កាលពីដើមខែមេសា ឆ្នាំ ១៩៧៥ ដើម្បីពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ភី ភួន "មានវត្តមាននៅក្បែរទីនោះដែរ និងបានរៀបរាប់អំពីដំណើររឿងយ៉ាងលម្អិត" និងថា ខ្លួន"បានទទួលយកភស្តុតាងរបស់ ភី ភួន ទាក់ទងទៅនឹងការពិពណ៌នាទូទៅនៃកិច្ចប្រជុំនេះ និងអ្នកចូលរួមមានដូចជា នួន ជា និង ខៀវ សំផន" និងថា "ភស្តុតាងរបស់ ភី ភួន លើបញ្ហានេះត្រូវបានបញ្ជាក់បន្ថែមចំណុចសំខាន់ៗដោយជនជាប់ចោទ"[880]។

៣៩១.ទាក់ទងទៅនឹងការលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើសក្ខីកម្មដោះបន្ទុករបស់ ភី ភួន ដែលថា ប៉ុល ពត បានណែនាំជាក់លាក់ "ពុំត្រូវប៉ះពាល់ទាហាននៃរបបសាធារណរដ្ឋខ្មែរ" ដែលត្រូវបានផ្តល់តម្លៃភស្តុតាងពុំស្មើគ្នានឹងភស្តុតាងដាក់បន្ទុកនោះ[881] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសក្ខីកម្មរបស់ ភី ភួន ក្នុងការផ្តល់ការយល់ឃើញថា ផែនការវាយលុកចុងក្រោយក្នុងការរំដោះប្រទេស ត្រូវបានរៀបចំឡើងនៅក្នុងកិច្ចប្រជុំកាលពីខែ កក្កដា ឆ្នាំ ១៩៧៤ ដែលក្នុងពេលនោះ "នួន ជា ប៉ុល ពត ខៀវ សំផន ប្រធានភូមិភាគ ប្រធានតំបន់ និងមេទ័ពផ្សេងទៀត បានពិភាក្សាគ្នាអំពីបទពិសោធរបស់បក្សនៅឧដុង្គ ជាកន្លែងដែលអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំ" និងថា ផែនការនេះត្រូវបានអះអាងបញ្ជាក់ក្នុងកិច្ចប្រជុំនៅដើមខែ មេសា ឆ្នាំ ១៩៧៥[882]។ អង្គជំនុំជម្រះសាលាដំបូងក៏បានសំអាងលើផ្នែកខ្លះនៃសក្ខីកម្មរបស់ ភី ភួន ក្នុងការយល់ឃើញថា គោលនយោបាយរបស់បក្សទាក់ទងទៅនឹង"ខ្មាំង"ដែលផ្នែកតាមអង្គជំនុំជម្រះ បានរួមបញ្ចូលទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរផងដែរនោះ ត្រូវបានផ្សព្វផ្សាយតាមរយៈវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ដោយមេដឹកនាំបក្ស រួមមាន

---

[879] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៩។ អង្គជំនុំជម្រះតុលាការកំពូលដោះស្រាយបញ្ហា ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងសមហេតុផលដែរ ឬយ៉ាងណា *ខាងក្រោម* កថាខណ្ឌ ១០០៩។

[880] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៥។ អង្គជំនុំជម្រះតុលាការកំពូលដោះស្រាយលើបញ្ហា ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងសមហេតុផល ដែរ ឬយ៉ាងណា *ខាងក្រោម* កថាខណ្ឌ ១០១០។

[881] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៦។

[882] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ផ្នែកទី ៣៖ សាវតារប្រវត្តិ កថាខណ្ឌ ១៤៣ ដល់ ១៤៧ (យោងទៅលើ រ៉ាចម គុន *ហៅ* ភី ភួន ជាញឹកញាប់ និងជាពិសេសត្រង់កថាខណ្ឌ ១៤៤ ដល់ ១៤៦ និងជើងទំព័រ ៤១៦ ដល់ ៤២៥)។

នួន ជា និង ខៀវ សំផន[883]។ ភី ភួន ក៏បានអះអាងថា នៅពេលគាត់បានមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ គាត់ទទួលបានការណែនាំពី ប៉ុល ពត មិនឱ្យប៉ះពាល់ទាហាន លន់ នល់ ពីព្រោះពួកគេបានចុះចាញ់ខ្មែរក្រហមហើយ[884]។ អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការយោងទាល់តែសោះទៅលើផ្នែកនេះនៃសក្ខីកម្មរបស់ ភី ភួន ក្នុងសាលក្រមឡើយ។

៣៥២.ការត្រឹមតែថា មានភស្តុតាង ប៉ុន្តែពុំត្រូវបានយោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនោះពុំមែនមានន័យថា ភស្តុតាងនោះពុំត្រូវបានអង្គជំនុំជម្រះយកមកធ្វើការពិចារណាក្នុងការវាយតម្លៃឡើយ ពីព្រោះអង្គជំនុំជម្រះមួយត្រូវបានសន្មតថា បានវាយតម្លៃរាល់ភស្តុតាងទាំងអស់ដែលមាននៅចំពោះមុខខ្លួន ដរាបណាពុំមានការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទាំងស្រុងលើភស្តុតាងជាក់លាក់ណាមួយ[885]។ គួរកត់សម្គាល់ ការសន្មតនេះអាចជំទាស់បានក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើភស្តុតាង

---

[883] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៨។

[884] កំណត់ហេតុស្តាប់ចម្លើយរបស់ វ៉ាចាម តុន *ហៅ* ភី ភួន ឯកសារលេខ E3/24 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤ (“ភភ៖ ខ្ញុំចូលភ្នំពេញនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ជាមួយនឹង សុន សេន ដើម្បីមើលសភាពការណ៍ ដោយ ប៉ុល ពត ជាអ្នកចាត់ឱ្យមក។ ខ្ញុំឃើញថា ប្រជាជនចេញចេញទៅគ្រប់ទិស និងមុខសញ្ញាទាំងអស់តែនៅមិនទាន់ចេញអស់ទេ។ [...] FL៖ តើមានបញ្ជាឱ្យតាមរកខ្មាំង ទេ? ភភ៖ អត់មានទេ ព្រោះគេលើកទង់សហើយ។ មានសេចក្តីណែនាំច្បាស់ថា កុំឱ្យប៉ះពាល់គេ [...] ពេលសង្គ្រាមនៅសមរភូមិគឺផ្សេង ឥឡូវគេចុះចាញ់យើងហើយយើងមិនត្រូវប៉ះពាល់គេទេមានតែស្វាគមន៍អបអរសាទរ និងជួយគេ ឆ្លើយនឹងសំណួរផ្សេងដែលគេសួរយើង។ គាត់និយាយថា [ពួកគាត់គឺជា] “ខ្មែរដូចគ្នា” កុំឱ្យប៉ះពាល់ឱ្យសោះ។ នេះជាសំដីរបស់ ប៉ុល ពត”)។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/98.1 ទំព័រ ៧០ (“ស៖ សំណួររបស់ខ្ញុំបន្ទាប់ទាក់ទងទៅនឹងទាហាននៃរបប លន់ នល់។ តើមានការបញ្ជា ឬការណែនាំជាក់លាក់អ្វីឱ្យធ្វើបាបអតីតទាហាន លន់ នល់ ដែរ ឬទេ? ច៖ បើគេចាញ់ គេលើកទង់ស។ យើងអត់មានអីនឹងប៉ះពាល់គេទេ។ អាហ្នឹងគេមានគោលនយោបាយច្បាស់លាស់តែម្តង។ នៅក្នុងសមរភូមិផ្សេង បើគេចាញ់ហើយ គេលើកទង់សទៅហើយ យើងអត់មានប៉ះពាល់ទេ គឺដាច់ខាតតែម្តង គឺណែនាំដាច់ខាតអត់មានឱ្យប៉ះពាល់ទេ”)។

[885] *សូមមើលក្នុងចំណោមនោះ* សាលដីកា*រឿងក្តី* *Kalimanzira* (ICTR) កថាខណ្ឌ ១៩៥។ សាលដីកា*រឿងក្តី* *Zigiranyirazo* (ICTR) កថាខណ្ឌ ៤៥។ សាលដីកា*រឿងក្តី* *Gacumbitsi* (ICTR) កថាខណ្ឌ ៧៤។ សាលដីកា*រឿងក្តី* *Brđanin* (ICTY) កថាខណ្ឌ ១១។ សាលដីកា*រឿងក្តី* *Ndindahabizi* (ICTR) កថាខណ្ឌ ៧៥។ សាលដីកា*រឿងក្តី* *Kvočka* (ICTY) កថាខណ្ឌ ២៣។ សាលដីកា*រឿងក្តី* *D.Milošević* (ICTY) កថាខណ្ឌ ១២៣។ សាលដីកា*រឿងក្តី* *Krajišnik* (ICTY) កថាខណ្ឌ ៣៥៣។ សាលដីកា*រឿងក្តី* *Galić* (ICTY) កថាខណ្ឌ ២៥៦។ សាលដីកា*រឿងក្តី* *Nchamihigo* (ICTR) កថាខណ្ឌ ១៦៦។ *Mrkšić និង Šljivančanin* (ICTY) កថាខណ្ឌ ២២៤។ សាលដីកា*រឿងក្តី* *Strugar* (ICTY) កថាខណ្ឌ ២៤។ សាលដីកា*រឿងក្តី* *Limaj* (ICTY) កថាខណ្ឌ ៨៦។ សាលដីកា*រឿងក្តី* (ICTY) កថាខណ្ឌ ៩២។

ដែលមានការជាប់ពាក់ព័ន្ធច្បាស់លាស់ទៅនឹងការយល់ឃើញដែលរងការជំទាស់នោះ[886]។ ជាឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានចាត់ទុកថា ជា"ការពុំអាចទទួលយកបាន"នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើភស្តុតាងនៃសក្ខីកម្មដែលខ្លួនពុំបានទាត់ចោល ក្នុងករណីដែលភស្តុតាងនេះពាក់ព័ន្ធទៅនឹងបញ្ហា"ដែលមានសារៈបំផុត"[887]។

៣៥៣.តាមការពិនិត្យលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងឃើញថា កំណត់ហេតុនៃសំណុំរឿងបានដាក់បញ្ចូលភស្តុតាងស្រដៀងគ្នាទៅនឹងភស្តុតាងដែលបានផ្តល់ដោយ ភី ភួន ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលយកយ៉ាងច្បាស់លាស់នោះ៖

> [បន្ទាប់ពីខ្មែរក្រហមបានចូល និងដណ្តើមបានទីក្រុងភ្នំពេញ] ទាហាននៃរបបសាធារណរដ្ឋខ្មែរជាច្រើនបានក្រវីទង់សស៊ុំចុះចាញ់ បានដាក់អាវុធចុះ និងដោះឯកសណ្ឋានរបស់ពួកគេចោល។ *កងទ័ពខ្មែរក្រហមត្រូវបានណែនាំមិនឱ្យបាញ់អ្នកដែលក្រវីទង់សឡើយ*[888]។
>
> កងទ័ពខ្មែរក្រហមផ្សេងទៀតបានទទួលបញ្ជាថា ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានដាក់អាវុធចុះ អាចត្រូវបានជម្លៀសជាប្រជាជន ឬត្រូវបានយកទៅរៀនសូត្រ តែបើអ្នកណាដែលមិនទម្លាក់អាវុធចុះទេ ត្រូវបាញ់សម្លាប់[889]។

៣៥៤.ភស្តុតាងនេះស៊ីសង្វាក់គ្នាជាមួយនឹងផ្នែកនៃសក្ខីកម្មរបស់ ភី ភួន ដែល នួន ជា បានចោទប្រកាន់អង្គជំនុំជម្រះថា ពុំបានលើកយកមកពិចារណានោះ ដូចជា បទបញ្ជាទាក់ទងទៅនឹងការប្រព្រឹត្តទៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានចូលសារភាព ត្រូវបានចេញដោយថ្នាក់ដឹកនាំបក្សមិនយូរប៉ុន្មាននៅមុនពេលដណ្តើមបានទីក្រុងភ្នំពេញ[890]។ ទោះជាយ៉ាងនេះក្តី បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានលើកបញ្ហាការណែនាំនេះ

---

[886] សាលដីកា *រឿងក្តី* *Zigiranyirazo* (ICTR) កថាខណ្ឌ ៤៥។ សាលដីកា *រឿងក្តី* *Kalimanzira* (ICTR) កថាខណ្ឌ ១៩៥។ សាលដីកា *រឿងក្តី* *Kvočka* (ICTY) កថាខណ្ឌ ២៣។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី* *Bagosora* (ICTR) កថាខណ្ឌ ៦១៨។

[887] សាលដីកា *រឿងក្តី* *Zigiranyirazo* (ICTR) កថាខណ្ឌ ៤៥ ដល់ ៤៦។ *សូមមើលផងដែរ* សាលដីការឿងក្តី *Ntabakuze* (ICTR) កថាខណ្ឌ ១៧១។

[888] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០២ (ជើងទំព័រលុបចោល និងសេចក្តីបញ្ជាក់បន្ថែម)។

[889] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៥។

[890] ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (មាស វឿន) ឯកសារលេខ E1/131.1 ទំព័រ ៦៩ ដល់ ៧០ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ មាស វឿន ឯកសារលេខ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00418519។

នៅក្នុងការពិភាក្សាអំពីការប្រព្រឹត្តលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយក៏ដោយ ក៏អង្គជំនុំជម្រះពុំបានធ្វើដូចគ្នានេះពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់ខ្លួនស្តីពីអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ផ្អែកតាមបរិបទនោះ ភស្តុតាងនៃការបញ្ជាណាមួយចេញពីថ្នាក់លើពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពិតជាមានការជាប់ពាក់ព័ន្ធខ្លាំងនៅក្នុងការសម្រេចអំពីបញ្ហានេះ។ កុំថាដល់ទៅពិចារណា ត្រឹមតែការពុំបានលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងសំខាន់ដែលមានតម្លៃដោះបន្ទុកបាននោះ គឺជាកំហុសអង្គច្បាប់ ហើយបញ្ហា ថាតើកំហុសនេះអាចមោឃៈផ្នែកដែលពាក់ព័ន្ធនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណានោះ នឹងត្រូវដោះស្រាយនៅក្នុងផ្នែកខាងក្រោម[891]។

៣៩៥.ទាក់ទងទៅនឹងអំណះអំណាងដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់ថា មូលហេតុអ្វីបានជាខ្លួនសំអាងលើសក្ខីកម្មរបស់ លឹម សាត ទាក់ទងទៅនឹងការយល់ឃើញអំពីព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដែលមានភាពមិនស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មរបស់ លឹម សាត នោះ[892] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាអំពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មនេះជាច្រើនដងនៅក្នុងសំអាងហេតុទាក់ទងទៅនឹងព្រឹត្តិការណ៍នោះ[893]។ អាស្រ័យហេតុនេះ អំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់ និងមានកំហុសអង្គច្បាប់នោះ ពុំមានមូលដ្ឋានគាំទ្រឡើយ។ នួន ជា បានលើកឡើងនូវអំណះអំណាងរបស់ខ្លួនពេញលេញអំពីខ្លឹមសារនៃភាពពុំស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មរបស់សាក្សីបីរូប ព្រមទាំងលើកនូវបញ្ហាពាក់ព័ន្ធទៅនឹងការសំអាងលើសក្ខីកម្មនីមួយៗរបស់សាក្សីទាំងនោះផងដែរ នៅក្នុងផ្នែកពាក់ព័ន្ធនៃសារណាបណ្តឹងសាទុក្ខរបស់គាត់ដែលចោទប្រកាន់អំពីកំហុសពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[894]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល

---

[891] *សូមមើល* ជាពិសេសសារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥១ ដល់ ៥៨០ *សូមមើលផងដែរខាងក្រោម* កថាខណ្ឌ ៩៤៨។

[892] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៧៩។

[893] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៤, ៦៦៥, ៦៦៩, ៦៧៦, ៦៧៧។

[894] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៩ *ជាអាទិ៍*។

នឹងត្រូវពិចារណាលើការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់សាក្សីទាំងនេះ នៅក្នុងផ្នែកសមស្របខាងក្រោម[895]។

## ៤.គ.៨.គ.ជនជាប់ចោទ នួន ជា

៣៩៦.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងលើសក្ខីកម្មរបស់គាត់សម្រាប់គោលបំណងដាក់បន្ទុក ដោយពុំដែលជឿជាក់លើភស្តុតាងដោះបន្ទុកណាមួយឡើយ និងថា គាត់កម្រស្នើសុំឱ្យបង្ហាញហេតុផលអំពីការវាយតម្លៃពីភាពអាចជឿជាក់បានលើសក្ខីកម្មរបស់គាត់[896]។

៣៩៧.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ផ្អែកលើកាលៈទេសៈនៃរឿងក្តីនេះ ជាទូទៅពុំមែនជាការមិនសមហេតុផលទេ ដែលអង្គជំនុំជម្រះសាលាដំបូងទទួលយកសក្ខីកម្មរបស់សាក្សីមួយផ្នែក ហើយបដិសេធផ្នែកដទៃទៀត និងថា នេះជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើភាពអាចជឿទុកចិត្តបានចំពោះផ្នែកដាច់ដោយឡែកផ្សេងទៀតនៃសក្ខីកម្មរបស់បុគ្គលណាម្នាក់ ដោយពុំចាំបាច់បង្ហាញលម្អិតពីមូលហេតុដែលខ្លួនទទួលយកផ្នែកខ្លះ ហើយបដិសេធចោលផ្នែកដទៃទៀតនោះឡើយ[897]។ អាស្រ័យហេតុនេះ ការអះអាងជាទូទៅដោយគ្មានមូលដ្ឋានរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសយកតែភស្តុតាងដាក់បន្ទុកមកសំអាង និងបានផ្តល់ត្រឹមតែការយោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ ប៉ុន្តែពុំបានពន្យល់លម្អិតបន្ថែមទាក់ទងទៅនឹងចំណុចណាដែលមានកំហុសនោះ ត្រូវបដិសេធចោល។

៣៩៨.ផ្អែកតាមលក្ខខណ្ឌតម្រូវ នួន ជា បានផ្តល់ការពន្យល់ច្បាស់លាស់តែមួយចំណុចប៉ុណ្ណោះ គឺទាក់ទងទៅនឹងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើសំដីរបស់គាត់ នៅក្នុងខ្សែភាពយន្តឯកសារ *សត្រូវរបស់*

---

[895] *សូមមើលខាងក្រោម* កថាខណ្ឌ ៤៨៧ *ជាអាទិ៍*។

[896] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៣ *និងសេចក្តីយោងត្រូវបានដកស្រង់*នៅក្នុងជើងទំព័រ ៤៩២។

[897] *សូមមើលក្នុងចំណោមនោះ* សាលដីកា *រឿងក្តី* *Rukundo* (ICTR) កថាខណ្ឌ ៨៦។ សាលដីកា *រឿងក្តី* *Kamuhanda* (ICTR) កថាខណ្ឌ ២៤៨។ សាលដីកា *រឿងក្តី* *Kajelijeli* (ICTR) កថាខណ្ឌ ១៦៧។ សាលដីកា *រឿងក្តី* *Ntakirutimana* (ICTR) កថាខណ្ឌ ១៨៤ និង ២៥៤។ សាលដីកា *រឿងក្តី* *Seromba* (ICTR) កថាខណ្ឌ ១១០។ សាលដីកា *រឿងក្តី* *Karera* (ICTR) កថាខណ្ឌ ៨៨ និង ១២៧។ សាលដីកា *រឿងក្តី* *Bagosora* (ICTR) កថាខណ្ឌ ២៤៣, ២៥៣។

*ប្រជាជន*[898]ដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការសំអាងលើផ្នែកនៃភស្តុតាងដាក់បន្ទុកដែលក្នុងនោះ នួន ជា បានទទួលស្គាល់ថា ខ្លួនបានយល់ស្របជាមួយនឹងការសម្រេចកម្ទេច“ជនមហាក្បត់”ចំនួន ៧ នាក់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានបដិសេធផ្នែកនៃភស្តុតាងដោះបន្ទុកដែលក្នុងនោះ នួន ជា បានបដិសេធថា ពុំបានដឹងអំពីការសម្លាប់ណាមួយលើទាហាន ឬអ្នករដ្ឋការសាមញ្ញនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃឡើយ[899]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើផ្នែកដែល នួន ជា បានទទួលស្គាល់នៅក្នុងខ្សែភាពយន្តនោះក្នុងចំណោមប្រភពជាច្រើនដទៃទៀតនៃភស្តុតាង ក្នុងការយល់ឃើញថា អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ភ្លាមបន្ទាប់ពីដណ្ដើមបានទីក្រុងភ្នំពេញ[900]។ ក្រោយមកទៀត នៅក្នុងការពិចារណាលើបញ្ហា ថាតើ នួន ជា ពុំបានរារាំង ឬពុំបានដាក់ទោសចំពោះការសម្លាប់នៅទួលពោធិ៍ជ្រៃ ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា “នៅក្នុងកិច្ចសម្ភាសន៍មួយ នួន ជា បានអះអាងថា ប្រសិនបើគាត់បានដឹងអំពីការសម្លាប់នៅទួលពោធិ៍ជ្រៃ គាត់នឹងចាត់វិធានការបញ្ឈប់ភ្លាម”[901] ប៉ុន្តែ អង្គជំនុំជម្រះពុំបានជឿជាក់លើការអះអាងនេះឡើយ និងបានកំណត់ថា “តួនាទីរបស់ នួន ជា ក្នុងការបង្កើតគោលនយោបាយដើម្បីកំណត់គោលដៅ បានបង្ហាញផ្ទុយពីនេះទៅវិញ”[902]។

៣៥៩.ផ្ទុយទៅនឹងការអះអាងបញ្ជាក់របស់ នួន ជា អង្គជំនុំជម្រះតុលាការកំពូលពុំបានចាត់ទុកការពិចារណានេះ ជា“ការពិចារណាវិលទៅវិលមក” ឬ“ពុំសមស្រប”[903]ឡើយ ដោយហេតុថា ការបង្កើត“គោលនយោបាយកំណត់គោលដៅ” នៅក្នុងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងបានកើតមានមុនការសម្លាប់នៅទួលពោធិ៍ជ្រៃ។ បន្ថែមលើនេះទៀត មានការបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងបានដឹងអំពីផ្នែកនៃភស្តុតាងដោះបន្ទុកដែលមាននៅក្នុងកិច្ចសម្ភាសន៍របស់ នួន ជា និងបានលើកយកមកពិចារណា ដែលបញ្ហានេះ

---

[898] ភាពយន្តឯកសាររបស់ ថេត សម្បត្តិ៖ សត្រូវរបស់ប្រជាជន ប្រតិចារឹក E3/4001 ឆ្នាំ ២០០៧។

[899] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៤។

[900] សាលក្រមរបស់អង្គជំនុំជម្រះសាលដំបូង កថាខណ្ឌ ៥០១ ដល់ ៥០៣ និងជើងទំព័រ ១៥១០។

[901] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៣៨ ជើងទំព័រ ២៨៧០ យោងទៅលើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (E295/6/3) កថាខណ្ឌ ៩៤៨ យោងទៅលើ**សត្រូវរបស់ប្រជាជន** (E3/4001R) ឈុតខ្សែវីដេអូបន្ថែម៖ **មួយថ្ងៃនៅពោធិ៍ជ្រៃ**។

[902] សាលក្រមរបស់អង្គជំនុំជម្រះសាលដំបូង កថាខណ្ឌ ៩៣៨។

[903] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ១៨៤។

បានបង្ហាញឱ្យឃើញតាមរយៈការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើផ្នែកនោះ នៅក្នុងសាលក្រមរបស់ខ្លួន។ បញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គោលនយោបាយកំណត់គោលដៅពិតជាមានអត្ថិភាព ដែរ ឬយ៉ាងណានោះ គឺជាកម្មវត្ថុនៃទឡ្ហីករណ៍បណ្តឹងសាទុក្ខដាច់ដោយឡែកមួយទៀត ដែល នួន ជា បានលើកឡើងយ៉ាងពេញលេញជាងនេះនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដោយបានលើកឡើងជាថ្មីទៀតអំពីការដែលអង្គជំនុំជម្រះសាលាដំបូង ពុំបានពិចារណាលើចំណុច ដែលជាភស្តុតាងដោះបន្ទុកនៅក្នុងកិច្ចសម្ភាសន៍របស់ខ្លួន[904] ដែលបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយនៅក្នុងផ្នែកសមស្របខាងក្រោម[905]។

## ៤.គ.៨.ឃ.សេចក្តីសន្និដ្ឋាន

៣៦០.សរុបសេចក្តីមក ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ដែលបានចោទប្រកាន់អំពីកំហុសនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការវាយតម្លៃលើសាក្សីអង្គហេតុ ត្រូវបដិសេធចោល។

## ៤.គ.៩.ការដកចេញភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម

៣៦១.អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "ភស្តុតាងដែលត្រូវបានទទួលយកសម្រាប់គោលបំណងមានកម្រិត ដូចជា ភស្តុតាងនៃចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្ម អាចយកមកសំអាងបានសម្រាប់តែគោលបំណងមានកម្រិតប៉ុណ្ណោះ ហើយពុំទាក់ទងទៅនឹងការបញ្ជាក់ការពិតនៃចម្លើយនោះឡើយ"[906]។

៣៦២.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់យ៉ាងដូច្នេះ និងបានជំទាស់ថា ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មពុំអាចប្រើប្រាស់*ប្រឆាំងនឹង*ជនជាប់ចោទបានឡើយ ប៉ុន្តែជនជាប់ចោទអាចប្រើប្រាស់ភស្តុតាងនេះក្នុងការការពារខ្លួនបាន[907]។ គាត់បញ្ជាក់ថា "កំហុសនេះពុំអាចធ្វើឱ្យ

---

[904] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥១ ដល់ ៥៨០។

[905] *សូមមើលខាងក្រោម* កថាខណ្ឌ ៨៦៩ *ជាអាទិ៍*។

[906] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៥ និងការយោងដកស្រង់ក្នុងជើងទំព័រ ៩៦។

[907] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧០៦ ដល់ ៧២២។

សាលក្រម[របស់អង្គជំនុំជម្រះសាលាដំបូង]ទៅជាមោឃៈនោះទេ ប៉ុន្តែចំណុចនេះមានសារៈសំខាន់ទូទៅសម្រាប់យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម”[908]។

៣៦៣.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការទទួលយកអំណះអំណាងរបស់ នួន ជា នឹងនាំឱ្យមានការលើកទឹកចិត្តចំពោះការធ្វើទារុណកម្ម ហើយ“ជាការបំភ្លៃផ្លូវច្បាប់ និងធ្វើឱ្យបាត់បង់ផ្នែកសីលធម៌”[909]។

៣៦៤.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា “ភាគីដែលមានបំណងប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ត្រូវ […] បញ្ជាក់អំពីការចោទប្រកាន់ចំពោះកំហុសអង្គច្បាប់*ដែលនាំឱ្យមោឃៈសាលក្រម*”[910]។ អាស្រ័យហេតុនេះ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ ដោយពុំបានបង្ហាញពីការប៉ះពាល់ដល់ការសម្រេចដាក់ពិរុទ្ធភាព ជាទូទៅពុំអាចទទួលយកបានសម្រាប់ការពិនិត្យឡើងវិញនៃបណ្តឹងសាទុក្ខលើអង្គសេចក្តីឡើយ។ គ្រប់កាលៈទេសៈទាំងអស់ អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃ និងបដិសេធរួចហើយនៅក្នុងសេចក្តីសម្រេចពីមុខ[911]លើខ្លឹមសារនៃអំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម បន្ទាប់ពីបានរួមបញ្ចូលគ្នានូវសារណាបណ្តឹងសាទុក្ខរបស់គាត់តាមរយៈការយោងនោះ។

៣៦៥.អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា ទាក់ទងបញ្ហានេះ ពុំត្រូវលើកមកពិចារណាតទៅទៀតឡើយ។

---

[908] សារណាបណ្តឹងសាទុក្ខ នួន ជា កថាខណ្ឌ ៧០៧។

[909] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។

[910] វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង(សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង(“អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចបណ្តឹងសាទុក្ខជំទាស់នឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង […] កំហុសលើអង្គច្បាប់បណ្តាលឱ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ”) *និង* វិធាន ១០៥(២) នៃវិធានផ្ទៃក្នុង (“ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបើកផ្លូវសាទុក្ខភ្លាមៗ […] ត្រូវ […] បញ្ជាក់អំពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថា កំហុសនោះបណ្តាលឱ្យសេចក្តីសម្រេចមានមោឃភាព”)។

[911] *សូមមើល* សេចក្តីសម្រេចស្តីពីភស្តុតាងបានមកពីការធ្វើទារុណកម្ម (F26/12) កថាខណ្ឌ ២៦ ដល់ ២៨, ៣០ ដល់ ៤៧, ៦០ ដល់ ៦៥, ៦៩។

01358152



## ៤.គ.១០.ការបង្ហាញឯកសារដែលសាក្សីពុំស្គាល់

៣៦៦.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការអនុញ្ញាតឱ្យមានការបង្ហាញឯកសារដែលសាក្សីពុំស្គាល់ក្នុងពេលជំនុំជម្រះ ដើម្បីឱ្យសាក្សីធ្វើការសន្និដ្ឋាន ដែលជាការជំរុញឱ្យសាក្សីធ្វើប្រមាណវិធីដែលពុំត្រូវបានអនុញ្ញាត និងថា ការបង្ហាញឯកសារដល់សាក្សីក្នុងអំឡុងពេលនៃការស៊ើបអង្កេតពុំអាចធ្វើយុត្តិកម្មចំពោះការបង្ហាញនេះនៅក្នុងពេលជំនុំជម្រះបានឡើយ[912]។

៣៦៧.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានលើកមូលដ្ឋានគាំទ្រការអះអាងរបស់គាត់អំពីកំហុសអង្គច្បាប់ ឬអង្គហេតុ និងពុំបានបង្ហាញអំពីផលប៉ះពាល់ដែលកើតចេញពីសក្ខីកម្មរបស់សាក្សីដែលបានចោទថា ធ្វើប្រមាណវិធីនោះឡើយ[913]។

៣៦៨.តាមការពិនិត្យលើផ្នែកនៃប្រតិចារឹកដែល ខៀវ សំផន បានយោងទៅលើក្នុងការគាំទ្រការជំទាស់របស់ខ្លួនឃើញថា ផ្ទុយទៅវិញអ្វីដែលគាត់បានអះអាង ជាទូទៅអង្គជំនុំជម្រះសាលាដំបូងពុំបានអនុញ្ញាតឱ្យមានការដាក់ឯកសារសួរដេញដោលសាក្សីដែលសាក្សីពុំបានដឹងពីមុនមកនោះទេ និងបានគាំទ្រការជំទាស់របស់ភាគីការពារក្តីពាក់ព័ន្ធបញ្ហានេះ ព្រមទាំងបានណែនាំសហព្រះរាជអាជ្ញាឱ្យជៀសវាងសួរសំណួរដែលនាំឱ្យសាក្សីធ្វើប្រមាណវិធី[914]។ ហេតុនេះ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ ពុំមានមូលដ្ឋានត្រឹមត្រូវឡើយ ហើយបណ្តឹងសាទុក្ខផ្នែកនេះត្រូវបដិសេធចោល។

---

[912] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E1/55.1 ទំព័រ ៣ ដល់ ១០។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ (ឈិន ណារី) ឯកសារលេខ E1/67.1 ទំព័រ ៥៤ ដល់ ៥៩។ ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ (ឈឹម សុធារ៉ា) ឯកសារលេខ E1/68.1 ទំព័រ ៣ ដល់ ១៥។ ប្រតិចារឹកចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សតឹម ល្អុត) ឯកសារលេខ E1/79.1 ទំព័រ ២៩ ដល់ ៣៨។

[913] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១០។

[914] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E1/55.1 ទំព័រ ៩ ("ប្រធានអង្គជំនុំជម្រះ៖ [...] តំណាងសហព្រះរាជអាជ្ញាប្រឹងប្រែងបញ្ចៀសនូវការតាំងសំណួរណាដែលនាំឱ្យសាក្សីផ្តល់ទស្សនៈផ្ទាល់ខ្លួន ឬបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនលើឯកសារ")។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E1/67.1 ទំព័រ ៥៨ ("ប្រធានអង្គជំនុំជម្រះ៖ បាទអរគុណច្រើនមេធាវីការពារក្តី។ លោកសហព្រះរាជអាជ្ញា ត្រូវអនុវត្តឱ្យបានត្រឹមត្រូវទៅតាមអ្វីដែលយើងបានអនុវត្តរួចកន្លងមកហើយតាំងពីដើមទីនៃការពិភាក្សាដេញដោលនៃរឿងក្តីនេះ។ ហើយចំពោះសាក្សីនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចំពោះឯកសារដែលមានបំណងចង់ដាក់ចំពោះមុខអង្គជំនុំជម្រះ។ ហើយត្រូវសួរដល់សាក្សីអំពីការដែលខ្លួនធ្លាប់បានឃើញ បានជួប និងបានស្គាល់

## ៤.គ.១១.ការបដិសេធសំណើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ

៣៦៩.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបដិសេធសំណើសុំបង្ហាញសំណៅដើមនៃឯកសារមួយចំនួន និងព័ត៌មានទាក់ទងទៅនឹងប្រភពដើម និងដំណើរនៃការរក្សាទុកឯកសារ[915] និងបានយោងទៅលើសេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) ដែលអង្គជំនុំជម្រះសាលាដំបូង

---

នូវឯកសារដែលខ្លួនប៉ុនប៉ងដាក់ដេញដោល ដែរ ឬទេ ? បើអត់ទេ អង្គជំនុំជម្រះនឹងបង្គាប់ឱ្យដកឯកសារនោះចេញ”)។ ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ឯកសារលេខ E1/68.1 ទំព័រ ១៤ ដល់ ១៥ (“ប្រធានអង្គជំនុំជម្រះ៖ […] សាក្សីនៅអាចចងចាំបានទេថា ឯកសារទាំងបួនទំព័រដែលយើងបានដាក់ជូនលោកពិនិត្យអម្បាញ់មិញនេះ តើលោកចងចាំទេថាលោកបានធ្លាប់បានឃើញ ឬក៏លោកត្រូវអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតនៅក្នុងអំឡុងពេលស្តាប់សក្ខីកម្មរបស់លោកនៅដំណាក់កាលនោះ តើគេបានបង្ហាញចំពោះលោក ដែរ ឬ ទេ នៅក្នុងខណ:ពេលដែលគេសួរចម្លើយលោកនោះ? លោក សាឡុត បាន៖ នៅក្នុងការសួរចម្លើយនោះ បានយកឯកសារឱ្យខ្ញុំពីរបីសន្លឹក។ ប៉ុន្តែ ខ្ញុំមើលទៅឃើញថា ដូចជាមិនមាននៅក្នុងឯកសារទាំងបួននេះទេ។ ខ្ញុំការចងចាំហ្នឹងគឺអ៊ីចឹង បានយកមកឱ្យខ្ញុំ។ ហើយខ្ញុំថា ខ្ញុំមិនដឹងទេ អក្សរពីណាទេ ខ្ញុំបានជម្រាបលោកអ៊ីចឹងបាទ។ […] ប្រធានអង្គជំនុំជម្រះ៖ […] មន្ត្រីរដ្ឋបាលតុលាការបង្គាប់ឱ្យដកយកឯកសារទាំងបួននោះត្រឡប់មកវិញ”)។ ប្រតិចារឹកចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សគីម ល្មុត) ឯកសារលេខ E1/79.1 ទំព័រ ៣២ ដល់ ៣៤ (“ប្រធានអង្គជំនុំជម្រះ៖ សាក្សីកុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញតំណាងមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ លោក PESTMAN៖ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់សំណួរនេះ។ ដោយសាក្សីបានចង្អុលបង្ហាញថា គាត់មិនដែលបានឃើញឯកសារនេះទេពីមុនមក។ ហើយសហព្រះរាជអាជ្ញាដូចជាព្យាយាមឱ្យសាក្សីគាត់សន្និដ្ឋានថា ឈ្មោះមនុស្សនៅលើឯកសារនេះ គឺជា--ដែលថាអ្នកផ្សេងទេដែលនិយាយពីរឿងនេះ។ ព្រោះថាសាក្សីមិនស្គាល់ មិនដឹង មិនឃើញឯកសារនេះគាត់មិនអាចធ្វើការទស្សន៍ទាយបានទេ ដោយផ្អែកទៅលើការសម្រេចរបស់តុលាការពីខាងដើមគឺថា--ហើយកុំឱ្យតុលាការដកយកឯកសារនេះមកវិញ […] ប្រធានអង្គជំនុំជម្រះ៖ សូមអញ្ជើញមេធាវីជាតិការពារក្តីលោក ខៀវ សំផន។ លោក គង់ សំអុន៖ បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមទៅលើសហការីដែលបានជំទាស់ទៀត។ គឺថា ជាពិសេសគឺសាក្សីមិនដែលបានបញ្ជាក់ថា សមមិត្ត ហែម នេះទទួលបន្ទុកខាងរណសិរ្ស និងរាជរដ្ឋាភិបាលហ្នឹងទេ គាត់មិនដែលបានឆ្លើយអ៊ីចឹងពីមុនមកទេ។ ហើយអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញ គឺជាការលើកនាំមុខទៀតផងបាទ […] ប្រធានអង្គជំនុំជម្រះ៖ សាក្សីមើលឯកសារហ្នឹងម្តងទៀតមើល៍ តើលោកធ្លាប់បានឃើញឯកសារនេះពីមុនមកទេ ជាពិសេសនៅក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មរបស់លោក ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានធ្វើសម្ភាសន៍ជាមួយលោកកន្លងមក។ លោក សគីម ល្មុត៖ សូមគោរពលោកប្រធាន ខ្ញុំបាទពេលដែលស៊ើបអង្កេតហ្នឹងមិនដែលបានបង្ហាញឯកសារនេះឱ្យខ្ញុំឃើញទេ។ ហើយបើនិយាយអំពីការចាត់តាំងរបៀបណាៗ ក្នុងរណសិរ្ស ឬកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិនដឹងជានរណាកាន់អ៊ីៗ ខ្ញុំមិនដែលបានដឹង បាននេះទេ។ ហើយខ្ញុំ--ឯកសារយើងទើបតែឃើញអម្បាញ់មិញហ្នឹង។ ប្រធានអង្គជំនុំជម្រះ៖ សេចក្តីជំទាស់របស់មេធាវីការពារក្តីទាំងពីរក្រុមមានប្រសិទ្ធភាព។ មន្ត្រីរដ្ឋបាលតុលាការ ដកឯកសារនេះចេញពីសាក្សី”)។

[915] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨។

បានអនុញ្ញាតឱ្យដាក់ឯកសារមួយចំនួននៅចំពោះមុខខ្លួន[916]។ ខៀវ សំផន បានជំទាស់ថា ដោយសារអំឡុងពេលនៃការកកើតព្រឹត្តិការណ៍បានកន្លងផុតជាយូរមកហើយ និងភាពច្របូកច្របល់ដែលបានកើតមាននៅប្រទេសកម្ពុជាបន្ទាប់ពីឆ្នាំ ១៩៧៩ ទើបទាមទារឱ្យមានការប្រុងប្រយ័ត្នក្នុងកម្រិតមួយ នៅពេលប្រើប្រាស់ឯកសារចម្លងដែលគ្មានឯកសារដើម និងបានយោងទៅលើសក្ខីកម្មរបស់ ឆាង យុ ដែលបានពន្យល់ថា "វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណប្រភពដើមដែលទីកន្លែងដើមពិតប្រាកដពុំត្រូវបានស្គាល់នោះ ជាវិធីសាស្ត្រប្រកបដោយភាពគ្រោះថ្នាក់" និងសក្ខីកម្មនេះបានជំទាស់ទៅនឹងសច្ចធារណ៍អំពីភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន[917]។ ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរក្នុងការយល់ឃើញថា នួន ជា បានប្រើប្រាស់សិទ្ធិមិនឆ្លើយតបទៅនឹងសំណួរ នៅពេលដែលគាត់ស្នើសុំពិនិត្យមើលឯកសារដើមមួយច្បាប់ដែល ខៀវ សំផន បានអះអាងថា ការយល់ឃើញបែបនេះ ជាចម្លើយគ្មានសុពលភាពទៅនឹងសំណើស្របច្បាប់ក្នុងការស្វែងរកការបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារ[918]។

៣៧០.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ ខៀវ សំផន ខ្វះភាពជាក់លាក់ និងពុំបានចង្អុលបង្ហាញ ថាតើកំហុសដែលបានចោទប្រកាន់នាំឱ្យមោឃៈការសម្រេចដាក់ពិរុទ្ធភាព ឬមានភាពមិនយុត្តិធម៌យ៉ាងដូចម្តេចនោះទេ[919]។

៣៧១.សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) បានបដិសេធការជំទាស់របស់ អៀង សារី នួន ជា និង ខៀវ សំផន ចំពោះការដាក់ឯកសារដែលបានស្នើដោយសហព្រះរាជអាជ្ញា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងឯកសារដែលបានយោងនៅក្នុងដីកាដំណោះស្រាយ (D427) បានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") នៅក្នុងពីរវគ្គដំបូងនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១[920] ដោយ*ក្នុងចំណោមនោះ* ផ្អែកលើមូលដ្ឋានប្រភពដើម និងការនិពន្ធនៃឯកសារខ្លះៗ និងបានសម្រេចស្នើឱ្យដកឯកសារទាំងនេះចេញ

---

[916] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៦៤។

[917] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨ និងសេចក្តីយោងដកស្រង់ក្នុងជើងទំព័រ ៦៥។

[918] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨ យោងទៅលើប្រតិចារឹកថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ឯកសារលេខ E1/25.1 ទំព័រ ២៧ ដល់ ២៩។ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ឯកសារលេខ E1/26.1 ទំព័រ ៣ ដល់ ៦ និង ២៨។

[919] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០៨ (v) និង ១០៩។

[920] ផ្នែកទីពីរដំបូងនៃសំណុំរឿង ០០២/០១ ពាក់ព័ន្ធទៅនឹង៖ (i) សាវតារ និង (ii) រចនាសម្ព័ន្ធរដ្ឋបាល និងការទំនាក់ទំនង និងធាតុផ្សំខ្លះនៃតួនាទីរបស់ជនជាប់ចោទ។ *សូមមើល* សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ១។

ដរាបណាមានការបញ្ជាក់ច្បាស់លាស់ទាក់ទងទៅនឹងដំណើរនៃការរក្សាទុកឯកសារ និងខ្លឹមសារ រួមទាំងការបញ្ជាក់ភាពត្រឹមត្រូវ និងភាពអាចទុកចិត្តបាននៃឯកសារទាំងនេះផងដែរ[921]។

៣៧២.ទាក់ទងទៅនឹងឯកសារដែលបានយោងនៅក្នុងដីកាដំណោះស្រាយ (D427) អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា ឯកសារទាំងនេះត្រូវបានសន្មតថា មានភាពជាប់ពាក់ព័ន្ធ និងអាចជឿទុកចិត្តបាន (រួមបញ្ចូលទាំងការបញ្ជាក់អំពីភាពត្រឹមត្រូវផងដែរ) ពីព្រោះថា ឯកសារទាំងនេះត្រូវបានពិនិត្យឡើងវិញ និងបានវាយតម្លៃដោយសហចៅក្រមស៊ើបអង្កេតអំពីភាពជាប់ពាក់ព័ន្ធ និងត្រូវបានផ្តល់តម្លៃជាភស្តុតាងខ្លះៗ និងម្យ៉ាងទៀត ដីកាដំណោះស្រាយ (D427) ត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះរួចហើយ[922]។ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចផងដែរ *ក្នុងចំណោមនោះ*ថា ឯកសារដើមមានលក្ខណៈសមស្រប និងទទួលបានទម្ងន់ធ្ងន់ជាងឯកសារថតចម្លង និងថា ដោយសារពុំមានលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនៅ អ.វ.ត.ក. ក្នុងការកោះហៅសាក្សីមកបញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារនោះទេ បើទោះជាយ៉ាងនេះក្តី ក៏សក្ខីកម្មទាក់ទងទៅនឹងដំណើរនៃការរក្សាទុកឯកសារ និងប្រភពដើម អាចនឹងជួយដល់ការវាយតម្លៃអំពីទម្ងន់ដែលត្រូវផ្តល់ទៅលើឯកសារមួយចំនួនដែរ[923]។

៣៧៣.អង្គជំនុំជម្រះសាលាដំបូងបានបដិសេធរាល់ការជំទាស់ទៅនឹងប្រភពដើមនៃឯកសាររបស់ DC-Cam ដោយបានយល់ឃើញថា វិធីសាស្ត្រដែល DC-Cam ប្រើប្រាស់ក្នុងការទទួលបាន ការរក្សាទុកដាក់ និងការពារឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ អាចជឿទុកចិត្តបាន[924]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សច្ចធារណ៍ដែលអាចជំទាស់បានដល់ឯកសាររបស់ DC-Cam ថា មានភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន*តាមសេចក្តីបញ្ជាក់ដំបូង* (រួមទាំងការបញ្ជាក់ពីភាពត្រឹមត្រូវផងដែរ)[925]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលផ្តល់សច្ចធារណ៍នេះ បានផ្អែកលើផ្នែកសំខាន់ខ្លះៗនៃសក្ខីកម្មរបស់ ឆាង យុ ជានាយករបស់ DC-Cam[926] ដែលបានអះអាងបញ្ជាក់*ក្នុងចំណោមនោះ*ថា ឯកសារចម្លង និងឯក

---

[921] *សូមមើល* សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ១១ និង ១៥ (ii) ១៥ (v) ១៥ (ix) ១៧ និង ១៩។

[922] សេចក្តីសម្រេចចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ (E185) កថាខណ្ឌ ២០ និងសេចក្តីយោងដកស្រង់ក្នុងជើងទំព័រ ៤៦។

[923] សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ២១ *និងសេចក្តីយោងដកស្រង់*ក្នុងជើងទំព័រ ៤៧។

[924] សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ២៨។

[925] សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ២៨។

[926] សេចក្តីសម្រេចស្តីពីការជំទាស់ទៅនឹងឯកសារ (E185) កថាខណ្ឌ ២៦ ដល់ ២៨។

សារស្កេន(scanned)ដែលបានផ្ញើទៅ អ.វ.ត.ក. គឺសុទ្ធតែចេញពីឯកសារដើម និងថា DC-Cam បានត្រៀមខ្លួនជួយដល់ភាគីលើការបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារចម្លងជាមួយនឹងឯកសារដើមតាមការស្នើសុំ[927]។ ខៀវ សំផន ពុំបានលើកមូលដ្ឋានគាំទ្រលើបញ្ហា ថាតើសក្ខីកម្មរបស់ ឆាង យុ មានមន្ទិលសង្ស័យទាក់ទងទៅនឹងនីតិវិធី ឬមូលហេតុអ្វីបានជាសក្ខីកម្មនេះចោទជាបញ្ហាទៅលើសច្ចធារណ៍ដែលថា ឯកសាររបស់ DC-Cam មានភាពត្រឹមត្រូវនោះឡើយ។

៣៧៤.ចុងក្រោយ តាមការពិនិត្យឡើងវិញលើផ្នែកនៃសក្ខីកម្មរបស់ នួន ជា ដែល ខៀវ សំផន បានយោងទៅលើ បង្ហាញឱ្យឃើញថា នួន ជា បានជំទាស់ទៅនឹងភាពត្រឹមត្រូវនៃឯកសារមួយចំនួនដែលដាក់ចំពោះមុខខ្លួនសម្រាប់ការសួរសំណួរ ដូចជា ឯកសារចម្លងនៃការបោះពុម្ពផ្សាយ *ទង់បដិវត្តន៍* ជាដើម[928]។ ឯកសារទាំងនេះ គឺស្ថិតក្នុងចំណោមឯកសារដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា នឹងទទួលបានអត្ថប្រយោជន៍ពីសច្ចធារណ៍ដែលអាចជំទាស់បាន *តាមសេចក្តីបញ្ជាក់ដំបូង*អំពីភាពអាចជឿទុកចិត្តបាន និងភាពត្រឹមត្រូវនៃឯកសារដោយសារប្រភពដើមនៃឯកសារនេះចេញពី DC-Cam[929]។ ការទទូចចង់ពិនិត្យមើលឯកសារដើម នៅមុនពេលគាត់ផ្តល់ចម្លើយចំពោះសំណួរណាមួយ ដោយផ្អែកលើមូលដ្ឋាននៃឯកសារនោះ ត្រូវបានឆ្លើយតបដោយអង្គជំនុំជម្រះសាលាដំបូងដែលបានរំឭកថា បន្ទាប់ពីបានសម្រេចអំពីបញ្ហានេះរួចរាល់ហើយ ការបន្តបដិសេធរបស់ នួន ជា មិនព្រមផ្តល់ចម្លើយចំពោះសំណួរ អាចនឹងត្រូវបានបកស្រាយថា ជាការប្រើប្រាស់សិទ្ធិមិនឆ្លើយតបនឹងសំណួរ ដែលគាត់បានអនុវត្តសិទ្ធិនេះយ៉ាងជាក់ច្បាស់ជាបន្តបន្ទាប់[930]។

៣៧៥.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងវិធីសាស្ត្រនេះឡើយ។ អាស្រ័យលើភាគីដែលជាអ្នកជំទាស់ទៅនឹងភាពត្រឹមត្រូវនៃឯកសារ ដែលតុលាការបានផ្តល់សច្ចធារណ៍ដែលអាចជំទាស់បានថា មានភាពត្រឹមត្រូវ*តាមសេចក្តីបញ្ជាក់ដំបូង* និងការផ្ទៀងផ្ទាត់គួរតែត្រូវបានស្នើឡើងដោយភាគីដែលជាអ្នកជំទាស់

---

[927] *សូមមើល*. ប្រតិចារឹកចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ) ឯកសារលេខ E1/38.1 ទំព័រ ១០ ដល់ ១៥។

[928] ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ឯកសារលេខ E1/25.1 ទំព័រ ២៩ ដល់ ៣០។

[929] *សូមមើល* បញ្ជីឯកសាររបស់ DC-Cam ក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ E161.1 ទំព័រ ១៤ ដល់ ១៧ (ភាសាអង់គ្លេស) (បញ្ជីឯកសារស្កេន និងចម្លងនៃការផ្សព្វផ្សាយរបស់ ប.ក.ក រួមទាំងឯកសារនៃទស្សនាវដ្តី*ទង់បដិវត្តន៍*ដែលទទួលបានពី DC-Cam)។

[930] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ឯកសារលេខ E1/25.1 ទំព័រ ២៨ ដល់ ៣០ និងប្រតិចារឹកចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ (នួន ជា) ឯកសារលេខ E1/26.1 ទំព័រ ៤ ដល់ ៦ និង ២៨។

01358157



ដែលក្នុងករណីនេះ នួន ជា គួរតែបញ្ជូនសមាជិកនៃក្រុមមេធាវីការពារក្តីរបស់ខ្លួនទៅ DC-Cam ដើម្បីពិនិត្យមើលឯកសារដើមដែលរងការជំទាស់នេះ ដូចអ្វីដែល ឆាង យុ បានបញ្ជាក់។ ពុំមានសញ្ញាណាមួយបង្ហាញថា នួន ជា បានធ្វើដូច្នោះឡើយ និងដោយពុំមានអ្វីយកមកធ្វើជាមធ្យោបាយក្នុងការជំទាស់ទៅនឹងសច្ចធារណ៍អំពីភាពត្រឹមត្រូវនៃឯកសារដែលចោទជាបញ្ហានេះ ក្រៅតែពីការតវ៉ាដែលគ្មានមូលដ្ឋានគាំទ្រប៉ុណ្ណោះ ដូច្នេះ សច្ចធារណ៍នេះចាត់ទុកថា នៅតែត្រឹមត្រូវដដែល។ ការបដិសេធរបស់ នួន ជា មិនឆ្លើយនឹងសំណួរដោយផ្អែកលើបញ្ហានៃឯកសារបោះពុម្ពផ្សាយ *ទង់បដិវត្តន៍* ដែលផ្តល់ដោយ DC-Cam ជាផលវិបាក ត្រូវបានបកស្រាយយ៉ាងសមហេតុផលដោយអង្គជំនុំជម្រះសាលាដំបូងថា ជាការសម្រេចចិត្តរបស់ នួន ជា ក្នុងការប្រើប្រាស់សិទ្ធិមិនឆ្លើយតបនឹងបញ្ហាទាំងនេះ។ នៅគ្រប់កាលៈទេសៈទាំងអស់ ខៀវ សំផន ពុំបានបង្ហាញ ថាតើខ្លួនបានទទួលរងផលប៉ះពាល់ ឬព្យសនកម្ម យ៉ាងដូចម្តេចខ្លះ ដោយសារវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការជំទាស់របស់ នួន ជា អំពីភាពត្រឹមត្រូវនៃឯកសារនេះឡើយ។

៣៧៦.អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ទាក់ទងបញ្ហានេះ ត្រូវបដិសេធចោល។

## ៤.គ.១២.ការសំអាងលើបទដ្ឋានពុំត្រឹមត្រូវស្តីពីបន្ទុកនៃការបង្ហាញភស្តុតាង

៣៧៧.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្តល់ការយល់ឃើញតាមរយៈការអនុវត្តនូវគោលគំនិតនៃប្រព័ន្ធច្បាប់ស៊ីវិលអំពីបទដ្ឋាន"*ជំនឿដោយឥស្សរចិត្ត*" ជាជាងបទដ្ឋានប្រព័ន្ធច្បាប់អង់គ្លូសាក់សុងក្នុងការបង្ហាញភស្តុតាង"ឱ្យហួសពីវិមតិសង្ស័យ"ដែលគាត់បានពិពណ៌នាថា មានលក្ខណៈអត្តនោម័តតិចតួច ហើយតឹងរ៉ឹងខ្លាំងជាង[931]។ គាត់បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្តល់សេចក្តីសន្និដ្ឋានមួយចំនួន ដោយពុំបានសំអាងលើភស្តុតាងដែលបានដាក់ពិភាក្សាដេញដោល និងពុំសមហេតុផលទាល់តែសោះ ហើយពុំបានផ្តល់ហេតុផលគាំទ្រដល់ការធ្វើសេចក្តីសន្និដ្ឋានទាំងនោះទេ[932]។ បន្ថែមលើនេះ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយបានអនុវត្តស្តង់ដារពីរផ្សេងគ្នា ចំពោះភស្តុតាងដែលដាក់ដោយមេធាវីការពារក្តី និងភស្តុតាងដែលដាក់ដោយអយ្យការ[933]។

[931] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៩ ដល់ ១១០។

[932] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១១០ ដល់ ១១៣។

[933] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ កថាខណ្ឌ ១១៩។

៣៧៨.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានផ្តល់មូលដ្ឋានគាំទ្រចំពោះអំណះអំណាងណាមួយរបស់ខ្លួន ដែលគ្រាន់តែអះអាងដោយគ្មានការបង្ហាញនូវកំហុសណាមួយឡើយ[934]។

៣៧៩.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា តាមសំណៅនៃសាលក្រមជាភាសាខ្មែរ និងភាសាអង់គ្លេស អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "ក្នុងការសម្រេចដាក់ពិរុទ្ធភាព អង្គជំនុំជម្រះត្រូវតែមានការជឿជាក់ថា ពិរុទ្ធភាពរបស់ជនជាប់ចោទត្រូវ *ហួសពីវិមតិសង្ស័យ*" រីឯសំណៅជាភាសាបារាំងលើកឡើងថា "[p]*our condamner un accusé, la Chambre de première instance doit avoir 'l'intime conviction' de sa culpabilité*"(ក្នុងការសម្រេចដាក់ពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវតែមាន *ជំនឿដោយឥស្សរចិត្ត*អំពីពិរុទ្ធភាពរបស់ជនជាប់ចោទនោះ)[935]។ នៅក្នុងសំណៅទាំងនេះ គឺជាការដកស្រង់ *ទាំងស្រុង*ចេញពីវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង ជាភាសាខ្មែរ អង់គ្លេស និងបារាំងតាមសំណៅនីមួយៗ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

> ដើម្បីដោះស្រាយភាពមិនស៊ីសង្វាក់គ្នារវាងការថែងខុសគ្នា នៅក្នុងសំណៅភាសាផ្សេងៗនៃវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងដែលបង្ហាញពីបទដ្ឋាន "ដោយលើសពីវិមតិសង្ស័យ" តាមច្បាប់កុំមិនឡ (Common Law) និងទស្សនាទាន "*ជំនឿដោយឥស្សរចិត្ត (intime convinction)*" តាមច្បាប់ស៊ីវិល (Civil Law) អង្គជំនុំជម្រះបានប្រើប្រាស់វិធីសាស្ត្ររួមមួយ វាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃភ័ស្តុតាង។ បន្ទាប់ពីបានវាយតម្លៃទៅលើភ័ស្តុតាងដោយមានសំអាងហេតុរួច *អង្គជំនុំជម្រះនឹងធ្វើការបកស្រាយវិមតិសង្ស័យដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ*[936]។

៣៨០.ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះបានសម្រេចយកបទដ្ឋានបង្ហាញភស្តុតាងឱ្យហួសពីវិមតិសង្ស័យ។ លើសពីនេះទៀត តាមការពិនិត្យលើសំណៅនៃសាលក្រមជាភាសាបារាំង ឆ្លុះបញ្ចាំងឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រើប្រាស់ពាក្យ *ជំនឿដោយឥស្សរចិត្ត (intime conviction)* ឡើយ ប៉ុន្តែប្រើពាក្យថា *ឱ្យហួសពីវិមតិសង្ស័យ (il ne fait aucun doute)* ទៅវិញទេ នៅពេល

---

[934] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០៧។

[935] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២២ យោងលើវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[936] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២២ (សេចក្តីបញ្ជាក់បន្ថែម)។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងជាភាសាបារាំង បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវដូចគ្នា("[អង្គជំនុំជម្រះ]ត្រូវបកស្រាយរាល់វិមតិសង្ស័យទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទឱ្យបានជាប្រយោជន៍ជនជាប់ចោទ")។

01358159



ធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួននោះ[937]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចយកបទដ្ឋានបង្ហាញភស្តុតាងឱ្យហួសពីវិមតិសង្ស័យនោះ ត្រូវបដិសេធចោល។

៣៨១.ទាក់ទងទៅនឹងចំណុចសេសសល់ដទៃទៀតនៅក្នុងសារណារបស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន ពុំបានផ្តល់នូវការយោងណាមួយឡើយ។ ផ្ទុយទៅវិញ គាត់បានត្រឹមតែយោងទៅលើសាលដីការបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍*ប៉ុណ្ណោះ និងត្រឹមតែចង្អុលបង្ហាញថា "សម្រាប់ជាឧទាហរណ៍ជាក់លាក់ សូមមើលដូច*ខាងក្រោម*" ដោយពុំបានបង្ហាញនូវកថាខណ្ឌនៃសារណាបណ្តឹងសាទុក្ខរបស់គាត់ដើម្បីឱ្យអាចកត់សម្គាល់បាន[938]។ សារណាដែលមានលក្ខណៈទូទៅ និងពុំមានមូលដ្ឋានគាំទ្រច្បាស់លាស់បែបនេះ ត្រូវបដិសេធចោលដោយពុំចាំបាច់ពិចារណាបន្តទៀតឡើយ។ អាស្រ័យហេតុនេះ ប្រសិនបើបញ្ហានេះបានលើកឡើងគ្រប់គ្រាន់នៅកន្លែងណាមួយក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់នោះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយសារណានេះតាមភាពសមស្រប។

## ៤.ឃ.បទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព

## ៤.ឃ.១.ការធ្វើមនុស្សឃាត

៣៨២.អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី

---

[937] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៤, ១៤២, ១៥២, ៣៤៧, ៤១១, ៤១៥ និង ៤២៦។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤០ ("អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់មិនបានធ្វើឱ្យមានវិមតិសង្ស័យនោះទេ ទាក់ទិននឹងវត្តមានរបស់ ខៀវ សំផន") កថាខណ្ឌ ៣៣៣ ("អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា គាត់ គឺជាសមាជិកគណៈកម្មាធិការយោធាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យបានទេ") កថាខណ្ឌ ៣៦២ ("អង្គជំនុំជម្រះពិចារណាឃើញថា នេះពុំមែនជាហេតុផលគ្រប់គ្រាន់ដែលអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យបានឡើយទាក់ទងទៅនឹង ខៀវ សំផន")។ គួរកត់សម្គាល់ថា សាលក្រមជាភាសាខ្មែរ អង់គ្លេស បារាំង ត្រូវបានចេញក្នុងពេលតែមួយជាឯកសារដើម។ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គម្របទំព័រ។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងភាសាបារាំងមិនមែនជាឯកសារបកប្រែ ដូចនេះ មានតម្លៃជាផ្លូវការស្មើគ្នាដូចនឹងភាសាខ្មែរ និងអង់គ្លេសដែរ។

[938] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ២៣១ ដល់ ២៣៣, ២៣៥ ដល់ ២៣៧ និង ២៤៧។ ជើងទំព័រ ២៣៤ ពុំមានប្រយោជន៍ដូចគ្នា ដោយសារគ្រាន់តែយោងទៅលើមាត្រា ៣៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ។

មួយ ជាការសម្លាប់ដោយខុសច្បាប់នូវជនស៊ីវិល និងទាហាន រួមទាំងការស្លាប់ដោយសារលក្ខខណ្ឌផ្សេងៗ និង កង្វះការផ្ដល់ជំនួយ ជាដើម[939] និង ទាក់ទងទៅនឹងការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋ ខ្មែរនៅទួលពោធិ៍ជ្រៃចាប់តាំងពីចុងខែ មេសា ឆ្នាំ ១៩៧៥[940]។

៣៨៣.នៅពេលវាយតម្លៃពីផលប៉ះពាល់ចំពោះការសម្រេចដាក់ពិរុទ្ធភាពច្រើនបទ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា ការយល់ឃើញសម្រាប់ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ និងក្នុង អំឡុងពេលការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ បានផ្អែកលើការសម្លាប់ដូចខាងលើនេះ[941]។ ដោយ សារបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំ អង្គជំនុំជម្រះសាលាដំបូងរកឃើញការសម្លាប់រង្គាលថា ជាបទល្មើសជាក់លាក់ជាង ដែលបានស្រូបបញ្ចូលការធ្វើមនុស្សឃាតផងដែរ[942]។ ជាលទ្ធផល នួន ជា និង ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាល (រួមបញ្ចូលការធ្វើមនុស្សឃាត) សម្រាប់ព្រឹត្តិ ការណ៍ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងនៅទួលពោធិ៍ជ្រៃ[943]។

៣៨៤.នៅក្នុងបណ្តឹងសាទុក្ខ នួន ជា បានអះអាងថា ភស្តុតាងនៃការធ្វើមនុស្សឃាតនីមួយៗ មិនមានភាពរឹងមាំ ដែលអាចឱ្យតុលាការអង្គហេតុឥតលម្អៀង ជឿជាក់ហួសពីវិមតិសង្ស័យថា ពិតជាមានការធ្វើមនុស្សឃាតណា មួយបានកើតឡើងនោះឡើយ[944]។ ជាពិសេស នួន ជា បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះ សាលាដំបូង មានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយសារអង្គជំនុំជម្រះសាលាដំបូង (i) បានផ្អែកលើភស្តុ តាងក្រៅតុលាការ និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី[945] (ii) បានបំផ្លើសលក្ខខណ្ឌនៃការជម្លៀស និង ការប្រើអំពើហិង្សា[946] (iii) ពុំបានពិចារណាបន្ថែមលើបញ្ហា ថាតើពិតជាកើតមានការសម្លាប់មនុស្សនីមួយៗ

---

[939] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៣ ដល់ ៥៥៩, ៩៤០ ដល់ ៩៤១, ១០៥៣។

[940] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៣, ៩៤០ ដល់ ៩៤១, ១០៥៣។

[941] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៥៥ ដល់ ១០៥៧។

[942] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៥៥ ដល់ ១០៥៧។

[943] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៥៧ ផ្នែកសម្រេចសេចក្តី។

[944] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨៤ ដល់ ២៨៥, ២៨៧ ដល់ ២៩៣, ៣១៩ ដល់ ៣២០, ៤៥១ ដល់ ៤៥៨, ៤៦៣ ដល់ ៤៦៦។

[945] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៦ ដល់ ២៩៨, ៣០០ ដល់ ៣០១, ៣០៦ ដល់ ៣១១, ៣១៣ ដល់ ៣១៨, ៣២៣ ដល់ ៣២៥ និង ៤២៦។

[946] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២២, ៣២៦, ៤២២ ដល់ ៤២៩។

01358161



ហើយមានភាពខុសច្បាប់ ដែរ ឬយ៉ាងណា[947] និង (iv) មានកំហុសដោយពុំបានយកចិត្តទុកដាក់ពិចារណាលើសក្ខីកម្មរបស់សាក្សីចំពោះព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ក្នុងការវាយតម្លៃលើភាពពុំស៊ីសង្វាក់គ្នាដែលប៉ះពាល់ដល់ភាពអាចជឿទុកចិត្តបាន[948]។

៣៨៥.ស្រដៀងគ្នានេះដែរ ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូង (i) បានសំអាងដោយពុំត្រឹមត្រូវលើភស្តុតាងក្រៅតុលាការ និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងផ្នែកសំអាងហេតុ[949] (ii) បានបំផ្លើសលក្ខខណ្ឌនៃការជម្លៀសចេញពីទីក្រុងភ្នំពេញដែលបណ្តាលឱ្យមានមនុស្សស្លាប់[950] (iii) បានរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព តាមរយៈការអនុវត្តនូវបទដ្ឋានពុំត្រឹមត្រូវចំពោះធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាត ដែលបានកើតឡើងក្នុងឆ្នាំ ១៩៧៥[951] និង (iv) មានកំហុសអង្គហេតុដោយបានបំភ្លៃសក្ខីកម្មរបស់សាក្សីចំពោះព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[952]។

៣៨៦.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ជនជាប់ចោទពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ឬអង្គច្បាប់ក្នុងការវាយតម្លៃរបស់ខ្លួនលើការធ្វើមនុស្សឃាតក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងថា អំណះអំណាងរបស់ជនជាប់ចោទ បានបំបែកចេញជាផ្នែកតូចៗដោយពុំបានផ្តល់ទម្ងន់ត្រឹមត្រូវដល់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងពុំបានកំណត់ចរិតលក្ខណៈត្រឹមត្រូវនៃវិធីសាស្ត្រក្នុងការទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ[953]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យយ៉ាងត្រឹមត្រូវចំពោះ*ធាតុផ្សំអត្តនោ*

---

[947] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៤។

[948] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៩ ដល់ ៤៥៨, ៤៦៣ ដល់ ៤៦៦។

[949] ខៀវ សំផន បានធ្វើការចោទប្រកាន់ជាទូទៅអំពីការប្រើប្រាស់ពុំសមស្របនូវចម្លើយក្រៅតុលាការនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទាំងមូលជាជាងការចោទប្រកាន់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន៖ *សូមមើលឧ.* កថាខណ្ឌ ២៩, ១១៧ និង ៤៦៨។

[950] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៥១ ដល់ ៣៥២។

[951] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៩ ដល់ ៦២។

[952] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២៩ ដល់ ៤៣៣។

[953] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤៣ ដល់ ១៤៧, ១៧៦ ដល់ ១៨៧, ២៣៨ ដល់ ២៤៧, ២៥២ ដល់ ២៦២, ៤៤២ ដល់ ៤៦៥។

*ម័ត*នៃការធ្វើមនុស្សឃាត ដែលមានអត្ថិភាពនៅក្នុងឆ្នាំ ១៩៧៥[954]។ ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងត្រឹមត្រូវលើភស្តុតាង រួមទាំងភាពពុំស៊ីសង្វាក់នានា ក្នុងការធ្វើសេចក្តីសន្និដ្ឋានយ៉ាងសមហេតុផលថា យ៉ាងហោចណាស់មានអតីតអ្នករដ្ឋការនៃរបប លន់ នល់ ចំនួន ២៥០ នាក់ ត្រូវបានសម្លាប់នៅទីនោះដែរ[955]។

## ៤.ឃ.១.ក.ការកំណត់និយមន័យអំពីធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣៨៧.ទាក់ទងទៅនឹងធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីបានបញ្ជាក់ថា ការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំតម្រូវឱ្យមានការគិតទុកជាមុន បានសំអាងលើបទដ្ឋានដែលខ្លួនបានអនុវត្តនៅក្នុងសំណុំរឿង ០០១ ដែលបទដ្ឋាននេះបានផ្អែកលើសាលដីកា*រឿងក្តី Kordić និង Čerkez* របស់តុលាការ ICTY[956] និងបានកំណត់និយមន័យអំពីធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតថាជា៖

> ចេតនារបស់ជនជាប់ចោទ ឬជនណាម្នាក់ ឬច្រើននាក់ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌទាំងការសម្លាប់ ឬទាំងការបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយដោយមានហេតុផលដឹងថា អំពើសកម្ម ឬអំពើអកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស[957]។

៣៨៨.ខៀវ សំផន បានលើកឡើងថា ការកំណត់និយមន័យបែបនេះពុំអាចអនុវត្តបានឡើយ ពីព្រោះនៅក្នុងអំឡុងពេលនៃអង្គហេតុ ចេតនាផ្ទាល់ក្នុងការសម្លាប់ គឺជាលក្ខខណ្ឌតម្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

[954] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩៧ ដល់ ១៩៨។

[955] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧១ ដល់ ២៩១។

[956] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១២ (ii) ជើងទំព័រ ១២៥៧ យោងទៅលើ*ក្នុងចំណោមនោះ* សាលដីកា*រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ៣៧ (ដោះស្រាយលើការកំណត់និយមន័យនៃអំពើមនុស្សឃាតថា ជាការរំលោភបំពានលើច្បាប់ និងទំនៀមទម្លាប់សង្គ្រាម អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានបំណងយោងទៅលើសាលដីកា*រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ១១៣ ដែលតម្កល់សាលក្រម*រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ២៣៥ ដល់ ២៣៦)។

[957] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១២(ii)។

ទាក់ទងទៅនឹងបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[958]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសំអាងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ដែលតាមការលើកឡើងរបស់គាត់ថា បានអនុវត្តបទដ្ឋាននៃ*ធាតុផ្សំអត្តនោម័ត* ដែលមានកម្រិតទាបជាលើកដំបូងនៅក្នុងប្រវត្តិនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[959]។ ខៀវ សំផន ក៏បានកត់សម្គាល់ផងដែរថា យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR ពុំមានលក្ខណៈឯកភាពគ្នាឡើយ ដោយបានយោងទៅលើសាលក្រមលើកដំបូងមួយរបស់តុលាការ ICTR ក្នុង*រឿងក្តី Kayishema និង Ruzindana*[960]។ ខៀវ សំផន បានអះអាងថា ការសំអាងលើបទដ្ឋាននៃ*ធាតុផ្សំអត្តនោម័ត*កម្រិតទាបនេះ នាំឱ្យអង្គជំនុំជម្រះសាលាដំបូងរំលោភលើគោលការណ៍នីត្យានុកូលភាព និងថា កំហុសនោះបាននាំឱ្យមោឃៈរាល់ការយល់ឃើញទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងចេតនារបស់ ខៀវ សំផន ក្នុងការប្រព្រឹត្តអំពើមនុស្សឃាត[961]។

៣៨៩.សហព្រះរាជអាជ្ញាបានលើកឡើងថា ការកំណត់និយមន័យនៃការធ្វើមនុស្សឃាតដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះ រួមមានការពាក់ព័ន្ធទៅនឹង*ធាតុផ្សំអត្តនោម័ត*គម្រូវ "ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងជាគោលការណ៍ទូទៅនៃច្បាប់នៅក្នុងប្រព័ន្ធច្បាប់ជាតិនៅឆ្នាំ ១៩៧៥"[962]។

៣៩០.ជាបញ្ហាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការកំណត់និយមន័យអំពីធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងសំអាងទៅលើនោះ អាចរួមបញ្ចូលផងដែរនូវគោលគំនិតនៃការធ្វើមនុស្សឃាតដោយប្រយោល។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតឃើញថា តុលាការ ICTY ក៏បានប្រើប្រាស់ផងដែរនូវសញ្ញាណនៃ *ចេតនាប្រយោល (dolus eventualis)* ដែលត្រូវបានស្គាល់នៅក្នុងយុត្តាធិការដែលកើតក្រោយប្រភពដើមនៃប្រព័ន្ធច្បាប់ស៊ីវិល (Romano-Germanic)។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូង*ក្នុងរឿងក្តី Stakić*

---

[958] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៩ ដល់ ៦២។

[959] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦០។

[960] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦០ យោងទៅលើសាលក្រម*រឿងក្តី Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១៣៧ ដល់ ១៤០។

[961] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦១ ដល់ ៦២។

[962] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩៨។

ដែលពន្យល់លម្អិតទៅលើការកំណត់និយមន័យនៃធាតុផ្សំ *អត្តនោម័ត*តម្រូវនៃបទមនុស្សឃាតថា ជាឧក្រិដ្ឋកម្មសង្គ្រាម បានយល់ឃើញថា៖

> ការកំណត់និយមន័យដែលជាលក្ខណៈបច្ចេកទេសលើ *ចេតនាប្រយោល (dolus eventualis)* មានដូចតទៅ៖ ប្រសិនបើចារីបង្ហាញពីអាកប្បកិរិយាដែលបង្កឱ្យបាត់បង់ជីវិត ចារីមានចេតនាសម្លាប់ ដោយសារចារី"សម្របសម្រួលខ្លួនទទួលយក" ឬ"ស្រុះស្រួលទទួលយក"បើទោះបីទំនងជានឹងមានការស្លាប់ក៏ដោយ។ ដូច្នេះ ប្រសិនបើការសម្លាប់ត្រូវបានប្រព្រឹត្តឡើងដោយ"មិនអើពើអំពីតម្លៃជីវិតរបស់មនុស្ស" បើទោះបីអំពើនោះមានហានិភ័យតិចតួចយ៉ាងណាក៏ដោយ ក៏អាចកំណត់បានជាការសម្លាប់មនុស្សដោយចេតនា។ ការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាការធ្វើមនុស្សឃាតដោយប្រយោលនៅក្នុងសហរដ្ឋអាម៉េរិក អាចបំពេញតាមលក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធច្បាប់ស៊ីវិលស្តីពី *ចេតនាប្រយោល (dolus eventualis)*។ អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថា គោលគំនិតនៃ *ចេតនាប្រយោល (dolus eventualis)* ពុំបានរួមបញ្ចូលនូវបទដ្ឋាននៃការធ្វេសប្រហែស ឬធ្វេសប្រហែសទាំងស្រុងឡើយ[963]។

៣៩១.បើទោះបីជាមានការទទួលស្គាល់ភាពខុសគ្នារវាងសញ្ញាណនៃ *Recklessness* និង *ចេតនាប្រយោល (dolus eventualis)* បើនិយាយដោយត្រួសៗគឺ ចំណុចទីមួយ ជាការផ្តោតទៅលើទិដ្ឋភាពនៃការយល់ដឹង ហើយទីពីរ លើទិដ្ឋភាពនៃឆន្ទៈនៅក្នុងអាកប្បកិរិយារបស់ចារីចំពោះលទ្ធផល[964]ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ពុំឃើញមានភាពខុសគ្នាច្បាស់លាស់នោះឡើយ ដោយសារនៅក្នុងគោលការណ៍នៃ *ចេតនាប្រយោល (dolus eventualis)* មានគោលគំនិតបញ្ជាក់ពីធាតុផ្សំសត្យានុម័តនៃភាពដែលនឹងកើតមាន និង"ការបង្ហាញពីភាពមិនអើពើ" ដែលនេះគ្រប់គ្រាន់សម្រាប់ដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[965] រីឯយុត្តិសាស្ត្រដែលផ្អែកលើគោលការណ៍ *Recklessness* ក៏មានការពាក់ព័ន្ធទៅនឹងការសន្និដ្ឋានអំពីចេតនាផង

---

[963] សាលក្រម *រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៥៨៧ (ជើងទំព័រលុបចោល)។

[964] *សូមមើល* Elies VAN SLIEDREGT៖ *ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្រោមច្បាប់អន្តរជាតិ* ព្រឹត្តិប័ត្រព័ត៌មានសាកលវិទ្យាល័យ Oxford ឆ្នាំ ២០១២ ទំព័រ ៥៥។

[965] *សូមមើលខ.* Cassazione Penale (Sezioni Unite, សំណុំរឿងលេខ 38343) (តុលាការជាន់ខ្ពស់ ប្រទេសអ៊ីតាលី)។ Bundesgerichtshof, 1 StR 262/88 (តុលាការកំពូលសហព័ន្ធ អាល្លឺម៉ង់) (ការឆ្លងមេរោគ HIV តាមរយៈការរួមភេទ)។ Bundesgerichtshof, 5 StR 35/55 (តុលាការកំពូលសហព័ន្ធ អាល្លឺម៉ង់) ទំព័រ ៣៦៣ *ជាដើម* ៣៦៩ (រឿងក្តីខ្សែក្រវ៉ាត់ស្បែក)។

ដែរ[966]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងប្រើប្រាស់ពាក្យ *ចេតនាប្រយោល (dolus eventualis)* នេះ ដូច អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុង *រឿងក្តី Stakić* ដែរ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះទទួលស្គាល់ថា ផ្អែកតាមករណីជាក់ស្តែង ការបង្ហាញពី *Recklessness* នៅក្នុងការធ្វើមនុស្សឃាត ទំនងជាបំពេញតាមលក្ខណៈវិនិច្ឆ័យនៃ *ចេតនាប្រយោល (dolus eventualis)* ហើយការបង្ហាញ *ចេតនាប្រយោល (dolus eventualis)* ទំនងជាបំពេញតាមលក្ខណៈវិនិច្ឆ័យនៃ *Recklessness* ដែលសញ្ញាណទាំងពីរនេះបំពេញគ្នាទៅវិញទៅមក។

៣៩២.បញ្ហាទីមួយដែលត្រូវដោះស្រាយគឺ ថាតើ“ការធ្វើមនុស្សឃាត”ដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានការគិតទុកជាមុន ដែរ ឬយ៉ាងណា ក្នុងន័យថា ចារីបានបង្ហាញពីចេតនាសម្លាប់មនុស្សបន្ទាប់ពីបានសញ្ជឹងគិតយ៉ាងច្បាស់មួយរយៈ ដែលពុំអាចប្រើប្រាស់នូវសញ្ញាណនៃ *ចេតនាប្រយោល (dolus eventualis)* បានឡើយ។ នេះគឺជាជំហររបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ក្នុង *រឿងក្តី Kayishema and Ruzindana* ដែល ខៀវ សំផន បានយោងទៅលើនោះ[967]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានកត់សម្គាល់ថា សំណៅជាភាសាបារាំងនៃលក្ខន្តិកៈរបស់តុលាការ ICTR បានប្រើប្រាស់នូវពាក្យឃាតកម្មគិតទុកជាមុន“*assassinat*” សម្រាប់“ការធ្វើមនុស្សឃាត” និងថា “នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលភាគច្រើន ការគិតទុកជាមុន គឺជានិច្ចកាលជាលក្ខខណ្ឌតម្រូវសម្រាប់ឃាតកម្មគិតទុកជាមុន ‘*assassinat*’” ដោយបានយោងនៅក្នុងជើងទំព័រទៅលើក្រមព្រហ្មទណ្ឌបារាំង[968]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR យល់ឃើញថា “បើទោះបីជាមានការជំទាស់ថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាជាង *ឃាតកម្មគិតទុកជាមុន* [...] តុលាការនេះត្រូវបានចងកាតព្វកិច្ចយ៉ាងពិសេសដោយពាក្យពេចន៍នៅក្នុងលក្ខន្តិកៈនៃតុលាការ ICTR”[969]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ពុំបានបញ្ជាក់ក្នុងការផ្តល់ការយល់ឃើញទាក់ទងទៅនឹងការគិតទុកជា

---

[966] *សូមមើលឧ. រឿងក្តី R ទល់នឹង* Woollin (សភាជាន់ខ្ពស់ ចក្រភពអង់គ្លេស)។ *រឿងក្តី R ទល់នឹង* Nedrick (តុលាការឧទ្ធរណ៍ ចក្រភពអង់គ្លេស)។ *សូមមើល* Elies VAN SLIEDREGT៖ *ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្រោមច្បាប់អន្តរជាតិ* ព្រឹត្តិប័ត្រព័ត៌មានសាកលវិទ្យាល័យ Oxford ឆ្នាំ ២០១២ ទំព័រ ៤៣។

[967] សាលក្រម *រឿងក្តី Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១៣៩។

[968] សាលក្រម *រឿងក្តី Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១៣៧ ជើងទំព័រ ៧៤។

[969] សាលក្រម *រឿងក្តី Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១៣៨។

មុនថា ជាលក្ខខណ្ឌតម្រូវតាមច្បាប់ទំនៀមទម្លាប់ឡើយ ប៉ុន្តែគ្រាន់តែបានបញ្ជាក់ថា ជាប់ពាក់ព័ន្ធទៅនឹងដែនកំណត់នៃយុត្តាធិការប៉ុណ្ណោះ។ គួរកត់សម្គាល់ផងដែរថា យុត្តិសាស្ត្រក្រោយៗមកទៀតរបស់តុលាការ ICTY រួមទាំងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការនេះផងដែរ ពុំបានទទួលយកការគិតទុកជាមុនថា ជាលក្ខខណ្ឌតម្រូវនៃការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិឡើយ[970] បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងមួយចំនួននៃតុលាការ ICTR បានអនុវត្តតាមវិធីសាស្ត្រក្នុង*រឿងក្តី Kayishema and Ruzindana* [971] យ៉ាងណាក៏ដោយ។

៣៩៣.ទាក់ទងទៅនឹងអំឡុងពេលនៅមុនអង្គហេតុដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងសំណៅជាភាសាបារាំងបានប្រើពាក្យ*ឃាតកម្មគិតទុកជាមុន(assassinat)* ចំណែកឯសំណៅជាភាសាអង់គ្លេសវិញបានប្រើពាក្យ*ការធ្វើមនុស្សឃាត (murder)* ហើយសំណៅជាភាសារុស្សីប្រើ

---

[970] សាលដីកា*រឿងក្តី Đorđević* (ICTY) កថាខណ្ឌ ៥៤៧។ សាលក្រម *រឿងក្តី Orić* (ICTY) កថាខណ្ឌ ៣៤៨។ សាលក្រម*រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ២៣៥។ សាលក្រម*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៣៨៦។ សាលក្រមក្នុង*រឿងក្តី Blaškić* (ICTY) កថាខណ្ឌ ២១៦។ *សូមមើលផងដែរ* សាលក្រម*រឿងក្តី Sesay* (SCSL) កថាខណ្ឌ ១៤០។ *ប្រៀបធៀប* សាលក្រម*រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៥៦១ ដែលនៅពេលយល់ឃើញថា ទាំងចេតនាសម្លាប់ទាំងចេតនាបង្កព្យសនកម្មធ្ងន់ធ្ងរដោយពុំអើពើពីជីវិតមនុស្ស គឺគ្រប់គ្រាន់នោះ បានយោងទៅលើសាលក្រម*រឿងក្តី Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១៣៩ ដែលតម្រូវឱ្យមានការគិតទុកជាមុន។ ទោះជាយ៉ាងណាក្តី សាលក្រម*រឿងក្តី Kupreškić* ពុំបានពិភាក្សាបញ្ហានេះបន្តទៀតឡើយ។ បន្ថែមលើនេះ នៅពេលអនុវត្តច្បាប់ទៅលើអង្គហេតុ អង្គជំនុំជម្រះពុំបានពិភាក្សាអំពីធាតុផ្សំនៃការគិតទុកជាមុន(*សូមមើល* កថាខណ្ឌ ៨១៨ ៨២០ និង ៨៣១)។

[971] *សូមមើល* សាលក្រម*រឿងក្តី Semanza* (ICTR) កថាខណ្ឌ ៣៣៩។ សាលក្រម*រឿងក្តី Ntagerura* (ICTR) កថាខណ្ឌ ៧០០។ សាលក្រម*រឿងក្តី Muhimana* (ICTR) កថាខណ្ឌ ៥៦៩ ដកស្រង់សាលក្រម*រឿងក្តី Semanza* (ICTR) កថាខណ្ឌ ៣៣៩។ សាលក្រម*រឿងក្តី Rutaganda* (ICTR) កថាខណ្ឌ ៧៩។ សាលក្រមក្នុង*រឿងក្តី Musema* (ICTR) កថាខណ្ឌ ២១៤។ *ប៉ុន្តែ សូមមើល* សាលក្រម*រឿងក្តី Akayesu* (ICTR) កថាខណ្ឌ ៥៨៨៖ "ច្បាប់ទំនៀមទម្លាប់អន្តរជាតិកំណត់ថា គឺជាអំពីនៃ*ការធ្វើមនុស្សឃាត*ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយពុំមែនជាឃាតកម្មគិតទុកជាមុន'Assassinat'ឡើយ។ ហេតុនេះ មានហេតុផលគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា សំណៅជាភាសាបារាំងនៃលក្ខន្តិកៈ មានកំហុសនៅក្នុងការបកប្រែ"។ ត្រង់ចំណុចនេះ មានការខុសគ្នានៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR *សូមមើល* Gideon Boas, James L. Bischoff និង Natalie L. Reid *ធាតុផ្សំនៃបទឧក្រិដ្ឋតាមច្បាប់អន្តរជាតិ* ព្រឹត្តិប័ត្រព័ត៌មានសាកលវិទ្យាល័យ Cambridge ឆ្នាំ ២០០៨ ទំព័រ ៥៨ ដល់ ៥៩។

ប្រាស់ពាក្យ *មនុស្សឃាត(убийство)*។ សំណៅទាំងបីមានការបញ្ជាក់ត្រឹមត្រូវដូចគ្នា[972] ដោយមានតែសំណៅភាសាបារាំងប៉ុណ្ណោះដែលបង្ហាញដោយប្រយោលនូវការគិតទុកជាមុន។ ការបកស្រាយលើធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ (IMT) តម្រូវឱ្យអនុម័តអត្ថន័យមួយដែលសម្របសម្រួលតាមអត្ថបទដែលពាក់ព័ន្ធទៅនឹងគោលដៅ និងគោលបំណងនៃសន្ធិសញ្ញា[973] ហើយពាក្យពេចន៍ *ការធ្វើមនុស្សឃាត (murder)* ឬ *"ubijstvo"* ហាក់ដូចជាមានមូលដ្ឋានឯកភាពគ្នាតែមួយ[974]។ ជាការកត់សម្គាល់ផងដែរថា នៅក្នុងការអនុម័តគោលការណ៍ Nuremberg របស់គណៈកម្មការនីតិអន្តរជាតិក្នុងឆ្នាំ ១៩៥០ អត្ថន័យខុសគ្នារវាងភាសាអង់គ្លេស និងបារាំងត្រូវបានកត់សម្គាល់ បើទោះបីជាមានភាពខុសគ្នា និងគ្មានការពិភាក្សាផុសផុលយ៉ាងណាក៏ដោយ ក៏ពាក្យទាំងនេះនៅតែប្រើប្រាស់ដែរ[975]។ សំណៅជាភាសាបារាំងនៃសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ ក៏បានប្រើប្រាស់ពាក្យ *ឃាតកម្មគិតទុកជាមុន (assassinat)* នៅក្នុងមាត្រា ២(១០) របស់ខ្លួនផងដែរ ដោយបានធ្វើក្រមនីយកម្មលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ ជាការគួរឱ្យចាប់អារម្មណ៍ ក្នុងមាត្រា ២(៩) ដែលបានធ្វើក្រមនីយកម្មលើបទឧក្រិដ្ឋប្រល័យពូជសាសន៍ សេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសប្រឆាំងមនុស្សជាតិ បានប្រើប្រាស់ពាក្យ *ការធ្វើមនុស្សឃាត (meurtre)*។ ការកែប្រែត្រូវបានធ្វើឡើងទាក់ទងទៅនឹងបទឧក្រិដ្ឋប្រល័យពូជសាសន៍ដោយផ្អែកលើមូលដ្ឋានថា "បទល្មើសដែលចោទជាបញ្ហានេះ អាចប្រកាសដាក់ទោសបាន បើទោះបីជាបទល្មើសនេះត្រូវបានប្រព្រឹត្តឡើងដោយមានការគិតទុកជាមុន ឬគ្មានក៏ដោយ"[976]។ ពុំមានរបាយការណ៍អំពីការលើកឡើងថា ជាការសមមូលគ្នារវាង*ការធ្វើមនុស្សឃាត/ឃាតកម្មគិតទុកជាមុន (assassinat)* ដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[977]។ អាស្រ័យហេតុនេះ កំណត់ត្រារបស់គណៈកម្មការនីតិអន្តរជាតិ (ILC) ពុំបានបញ្ជាក់ច្បាស់លាស់លើចំណុចនេះឡើយ។

---

[972] *សូមមើល* កិច្ចព្រមព្រៀងទីក្រុងឡុងដ៏ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥ ផ្នែកដែលមានអានុភាព។

[973] *សូមមើល* មាត្រា ៣៣(៤) នៃអនុសញ្ញាទីក្រុង Vienna ស្តីពីច្បាប់សន្ធិសញ្ញា។

[974] *សូមមើល*ប្រហាក់ប្រហែលគ្នាទៅនឹងបទមនុស្សឃាតនៃឧក្រិដ្ឋកម្មសង្គ្រាម *រឿងក្តី In Re Ahlbrecht (No. 2)* (តុលាការព្រហ្មទណ្ឌពិសេស ប្រទេសហូឡង់)។

[975] គោលការណ៍ច្បាប់អន្តរជាតិត្រូវបានទទួលស្គាល់នៅក្នុងលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្ម *Nuremberg* និងនៅក្នុងសាលក្រមរបស់តុលាការនេះ សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការស្តីពីច្បាប់អន្តរជាតិឆ្នាំ ១៩៥០ ភាគ II។ *សូមមើលផងដែរ* កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៤៨ ភាគ I ទំព័រ ៥៧ កថាខណ្ឌ ១០៥ ដល់ ១០៧។

[976] កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ២៦៧ ភាគ I ទំព័រ ១៣២ កថាខណ្ឌ ៥១។

[977] កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៤៨ ភាគ I ទំព័រ ៥៦ កថាខណ្ឌ ៩៤ និង ៩៥។

៣៩៤.អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញថា មានយុត្តិសាស្ត្រជាក់ស្តែងណាមួយនៅក្នុងអំឡុងពេលនោះ ដែលបានចែងថា ការគិតទុកជាមុន ជាធាតុផ្សំមួយនៃការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋប្រឆាំងមនុស្សជាតិឡើយ។ ចំណុចសំខាន់ គឺថា សំណៅសាលក្រមជាភាសាបារាំងរបស់តុលាការយោធាអន្តរជាតិ (IMT) បានប្រើប្រាស់ពាក្យ *ឃាតកម្មគិតទុកជាមុន (assassinat)* ដែលអាចជំនួសគ្នាទៅវិញទៅមកជាមួយនឹងពាក្យ *ការធ្វើមនុស្សឃាត (meurtre)* បាន ដោយរួមបញ្ចូលចំណុចដែលក្នុងនោះសំណៅសាលក្រមជាភាសាអង់គ្លេសប្រើប្រាស់តែពាក្យ *ការធ្វើមនុស្សឃាត (murder)* ប៉ុណ្ណោះ[978]។

៣៩៥.សាលក្រម *រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ* របស់តុលាការឧក្រិដ្ឋកម្មយោធាសហរដ្ឋអាម៉េរិកដែលបានជំនុំជម្រះក្នុងទីក្រុង Nuremberg បានផ្តល់នូវការបំភ្លឺអំពី *ធាតុផ្សំអត្តនោម័ត*នៃការធ្វើមនុស្សឃាតនៅក្នុងកិច្ចដំណើរការនីតិវិធីក្រោយសង្គ្រាមលោកលើកទី II។ តុលាការនេះបានដាក់ពិរុទ្ធភាពជនជាប់ចោទមួយចំនួនពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយសារការជាប់ពាក់ព័ន្ធទៅនឹងការធ្វើពិសោធន៍នានាផ្នែកវេជ្ជសាស្ត្រ[979]។ ការធ្វើពិសោធន៍នេះបានបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់រូបកាយជនរងគ្រោះ[980]។ នៅពេលដែលការបង្កព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ គឺជាបំណងដោយផ្ទាល់របស់ជនជាប់ចោទ ពីព្រោះជនជាប់ចោទក្នុងពេលនោះមានមូលហេតុសមស្របដឹងថា ជនរងគ្រោះទំនងជានឹងស្លាប់ដោយសារលទ្ធផលនៃការធ្វើពិសោធន៍នេះ។ ដូច្នេះ ដោយសារមានកង្វះក្នុងការកំណត់និយមន័យជាក់លាក់អំពី *ធាតុផ្សំអត្តនោម័ត*នៃការធ្វើមនុស្សឃាតនៅក្នុងសាលក្រម *រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ* ទើបអាចធ្វើការសន្និដ្ឋានយ៉ាងច្បាស់លាស់ថា តុលាការឧក្រិដ្ឋកម្មយោធារបស់សហរដ្ឋអាម៉េរិក ពុំបានតម្រូវឱ្យមានការបង្ហាញពីចេតនាដោយផ្ទាល់ក្នុងការសម្លាប់ ដើម្បីសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតនៅក្នុងកាលៈទេសៈនេះឡើយ។ ប៉ុន្តែ ជាការគ្រប់គ្រាន់

---

[978] *សូមមើលឧ.* សាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) [ក្នុងផ្នែកស្តីពីច្បាប់នៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពាក្យទាំងពីរនេះប្រើប្រាស់ជំនួសគ្នាបាន៖ "ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិច្បាស់ណាស់ថា នៅមុនពេលសង្គ្រាម អ្នកប្រឆាំងនយោបាយរបស់ណាហ្ស៊ី ត្រូវទទួលរងការឃុំខ្លួន ឬសម្លាប់ [...]។ គោលនយោបាយគៀបសង្កត់ ធ្វើទុក្ខបុកម្នេញ និងការសម្លាប់ជនស៊ីវិលដែលត្រូវបានសង្ស័យថាប្រឆាំងនឹងរដ្ឋាភិបាល ត្រូវបានប្រើប្រាស់ដោយឥតអៀនខ្មាស់ [...]"។ *សូមមើលផងដែរ* ទំព័រ ៦៩ (ការពិភាក្សាអំពី"ការធ្វើមនុស្សឃាត"ដែលជាផ្នែកនៃអំពើមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ "ផែនការនេះ រួមបញ្ចូលការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញលើអ្នកដែលត្រូវ ឬពុំត្រូវបានសង្ស័យ"។ ទំព័រ ១៩៥ ("ការសម្លាប់ជនជាតិជ្វីហ្វយ៉ាងតិច ៣ លាន់នាក់")។

[979] *រឿងក្តីពាក់ព័ន្ធទៅនឹងផ្នែកវេជ្ជសាស្ត្រ* ទំព័រ ១៩៨, ២០៧, ២៤០ ដល់ ២៤១, ២៤៨, ២៦៣, ២៧១, ២៩០។

[980] *រឿងក្តីពាក់ព័ន្ធទៅនឹងផ្នែកវេជ្ជសាស្ត្រ* ទំព័រ ១៨៩ ដល់ ២០៧, ២៣៥ ដល់ ២៤១, ២៥៣ ដល់ ២៦៣។

ក្នុងការបង្ហាញថា ជនជាប់ចោទបានដឹងថា អំពើសកម្ម និងអំពើអកម្មរបស់ខ្លួនទំនងជានាំឱ្យជនរងគ្រោះស្លាប់ និងព្រមទទួលយកលទ្ធផលនេះដែលស្របទៅនឹងសញ្ញាណនៃ *ចេតនាប្រយោល* *(dolus eventualis)* និង *Recklessness*។ នេះគឺជាការបញ្ជាក់យ៉ាងច្បាស់ថា ក្នុងអំឡុងពេលក្រោយសង្គ្រាមលោកលើកទី II ការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បានរួមបញ្ចូលសញ្ញាណនៃ *ចេតនាប្រយោល* *(dolus eventualis)* ផងដែរ។ បញ្ហានេះនឹងត្រូវបានបញ្ជាក់បន្ថែមទៀតនៅពេលធ្វើការពិចារណាទៅលើការអនុវត្តក្នុងស្រុកទាក់ទងទៅនឹងបទឧក្រិដ្ឋនៃការធ្វើមនុស្សឃាត។

៣៩៦.ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បើទោះបីជាការកំណត់និយមន័យជាក់លាក់ ខុសៗគ្នាក៏ដោយ ក៏ការធ្វើមនុស្សឃាតជាទូទៅត្រូវបានយល់ថា ជាការសម្លាប់មនុស្សដោយខុសច្បាប់និងដោយចេតនា(ខុសពីការធ្វេសប្រហែស)[981]។ នៅក្នុងយុត្តិសាស្ត្រជាច្រើនមានបទឧក្រិដ្ឋមួយចំនួនទាក់ទងទៅនឹងការសម្លាប់មនុស្សដោយចេតនា (ជាឧទាហរណ៍ "ការធ្វើមនុស្សឃាត" "មនុស្សឃាតគ្មានមរណចេតនា"ក្នុងច្បាប់កម្ពុជា[982] "ការធ្វើមនុស្សឃាត" "ការសម្លាប់មនុស្ស" និង"មនុស្សឃាតដោយប្រយោល"នៅក្នុងច្បាប់អង់គ្លេស និងវែល៍ (Wales) រួមទាំងប្រទេសអូស្ត្រាលី[983] *ឃាតកម្មគិតទុកជាមុន* *(assassinat)* *ការធ្វើមនុស្សឃាត(meurtre)* និង *មនុស្សឃាតដោយគ្មានបំណងសម្លាប់(homicide praeter intentionnel)* ក្នុងច្បាប់បារាំង[984] *ការធ្វើមនុស្សឃាត(Mord)* និង *ការសម្លាប់មនុស្ស(Totschlag)* ក្នុងច្បាប់អាល្លឺម៉ង់[985] *មនុស្សឃាតគិតទុកជាមុន(asesinato)* និង *ការសម្លាប់មនុស្ស(homicido)* ក្នុងច្បាប់អេស្ប៉ាញ[986] និង

---

981 អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អត្ថន័យនៃពាក្យ"intentional" *ចេតនា* ពុំមានលក្ខណៈស៊ីសង្វាក់គ្នានៅក្នុងយុត្តិសាស្ត្រក្នុងស្រុក និងថា យុត្តិសាស្ត្រខ្លះប្រើពាក្យ"culpable" *គួរដាក់ទណ្ឌកម្ម* បើទោះបីជាមានន័យផ្សេងៗគ្នាក៏ដោយ ក៏ដើម្បីបង្ហាញពីការសម្លាប់ខុសច្បាប់បានដែរ។ នៅក្នុងសាលដីកាបច្ចុប្បន្ន ពាក្យ"intentional" *ចេតនា* ត្រូវបានប្រើប្រាស់ក្នុងន័យដូចខាងក្រោម។

982 មាត្រា ៥០១ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ (ភាពខុសគ្នារវាងមនុស្សឃាតដោយចេតនា និងគ្មានមរណចេតនា) មាត្រា ៥០២ (មនុស្សឃាតដែលបង្កឡើង*ក្នុងចំណោមទោស*ដោយការធ្វេសប្រហែស) និងមាត្រា ៥០៣ (មនុស្សឃាតមរណចេតនាទេក្នុងឧក្រិដ្ឋថ្នាក់ទីមួយ រួមបញ្ចូលអំពើចេតនាបង្កព្យសនកម្មដោយគ្មានចេតនាសម្លាប់ តែបណ្តាលឱ្យស្លាប់) និង មាត្រា ៥០៤ (មនុស្សឃាត)។

983 *សូមមើលខាងក្រោម* កថាខណ្ឌ ៤០២ *ជាអាទិ៍*។

984 *សូមមើល* មាត្រា ២២១-១ នៃក្រមព្រហ្មទណ្ឌបារាំង (មនុស្សឃាតដោយចេតនា) មាត្រា ២២១-៣ *មនុស្សឃាតគិតទុកជាមុន* *(assassinat)* មាត្រា ២២២-៧ (អំពើហឹង្សា និងព្យសនកម្មលើរូបកាយដែលបានបណ្តាលឱ្យស្លាប់)។

985 ផ្នែក ២១១, ២១២ នៃក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ឆ្នាំ ១៨៧១។

*ការសម្លាប់មនុស្ស(Omicido)* *មនុស្សឃាតដោយគ្មានបំណងសម្លាប់(Omicidio preterintenziononale)* និង *ការធ្វើឱ្យមនុស្សស្លាប់ដែលកើតចេញពីអំពើខុសច្បាប់(Morte o lesione come conseguenza di altro delitto)* ក្នុងច្បាប់អ៊ីតាលី[987])។ ទោះជាយ៉ាងណាក្តី ពុំឃើញមានលក្ខណៈវិនិច្ឆ័យជារួម ដើម្បីអាចបែងចែកឱ្យឃើញភាពខុសគ្នារវាងទម្រង់ផ្សេងៗនៃការសម្លាប់ដោយចេតនាឡើយ[988]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អាចជាការពុំត្រឹមត្រូវក្នុងការផ្តល់ទម្ងន់ធ្ងន់ទៅលើការអនុវត្តក្នុងស្រុកទាក់ទងទៅនឹងបទឧក្រិដ្ឋជាក់លាក់ដែលសំដៅទៅលើ“ការធ្វើមនុស្សឃាត” (ឬភាពសមមូលជាភាសានៃយុត្តាធិការរបស់ប្រទេសនីមួយៗដែលស្ថិតក្រោមការពិចារណានេះ)[989]។ ផ្ទុយទៅវិញ ចាំបាច់ត្រូវពិនិត្យលើវាល់បទល្មើសទាំងអស់នៃអំពើមនុស្សឃាតដោយចេតនា។ ការពិចារណាបែបនេះ បង្ហាញនៅក្នុងយុត្តាធិការក្នុងស្រុកទាំងអស់ដែលអង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យនោះឃើញថា ធាតុផ្សំអត្តនោម័តនៃអំពើមនុស្សឃាតដោយចេតនា គឺជាលក្ខខណ្ឌតម្រូវ បើទោះបីជាចារីបានប្រព្រឹត្តអំពើដោយចេតនាក្នុងកម្រិតទាបជាងចេតនាដោយផ្ទាល់ក្នុងការសម្លាប់ក៏ដោយ។

៣៩៧.ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានរួមបញ្ចូលមិនត្រឹមតែបទឃាតកម្ម(ពុំមានលក្ខខណ្ឌតម្រូវអំពីការគិតទុកជាមុន) និងបទហានកម្ម(មនុស្សឃាតគិតទុកជាមុន)ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបទមនុស្សឃាតដោយគ្មានមរណចេតនា គឺនៅពេលដែលជនល្មើសមានចេតនាត្រឹមតែចង់ឱ្យឈឺចាប់លើរូបកាយបុគ្គលណាម្នាក់ ប៉ុន្តែ

---

[986] មាត្រា ១៣៨.១, ១៣៩.១ នៃក្រមព្រហ្មទណ្ឌអេស្ប៉ាញឆ្នាំ ១៩៩៥។

[987] មាត្រា ៥៧៥, ៥៨៤, ៥៨៦ នៃក្រមព្រហ្មទណ្ឌអ៊ីតាលី។

[988] ជាឧទាហរណ៍ ក្នុងច្បាប់បារាំង *មនុស្សឃាតគិតទុកជាមុន* (assassinat) និង *ការធ្វើមនុស្សឃាត* (meurtre) ខុសគ្នាដោយសារធាតុផ្សំនៃការគិតទុកជាមុន ចំណែកឯក្នុងច្បាប់របស់ប្រទេសអាល្លឺម៉ង់ និងអេស្ប៉ាញវិញ *ការធ្វើមនុស្សឃាត/ការធ្វើមនុស្សឃាតគិតទុកជាមុន* “Mord”/“asesinato” ខុសប្លែកពី *ការធ្វើមនុស្សឃាត/ការសម្លាប់មនុស្ស (Totschlag)/(hom icido)* ដោយសារកត្តាស្ថានទម្ងន់ទោសមួយចំនួន(ដូចជាចារីបានប្រព្រឹត្តដោយប្រើល្បិចកលគិតទុកជាមុន)។ នៅក្នុងប្រទេសប៉ូឡូញ និងរុស្ស៊ី ពាក្យ(ការសម្លាប់មនុស្ស)ត្រូវបានប្រើប្រាស់ជាប្រភេទនៃបទល្មើសរួមដែលមានប្រភេទបទល្មើសតូចៗដែលមានធាតុផ្សំបន្ថែម។

[989] *សូមមើល* សាលក្រម *រឿងក្តី Čelebići* (ICTY) កថាខណ្ឌ ៤៣១៖ “វិធីសាស្ត្រសាមញ្ញ ឬវិធីសាស្ត្រដែលបានកម្រិតទៅតាមភាពជាក់លាក់នៃយុត្តិសាស្ត្រពិសេសក្នុងស្រុក ត្រឹមតែអាចធ្វើឱ្យមានការភាន់ច្រឡំ ឬការស្រាវជ្រាវឥតប្រយោជន៍ទៅលើភាពសាមញ្ញដែល ពិបាកយល់នោះ។ នៅក្នុងប្រព័ន្ធច្បាប់ជាតិ ពាក្យពេចន៍ត្រូវបានប្រើប្រាស់នៅក្នុងបរិបទច្បាប់ជាក់លាក់ និងអត្ថន័យជាក់លាក់នៃពាក្យនេះត្រូវបានបញ្ជាក់ដោយផ្ទាល់តាមរយៈយុត្តិសាស្ត្រនៃប្រព័ន្ធនោះ។ អត្ថន័យនេះអាចពុំជាប់ពាក់ព័ន្ធ នៅពេលពាក្យពេចន៍ទាំងនេះត្រូវបានអនុវត្តនៅក្នុងយុត្តាធិការអន្តរជាតិ”។

អំពើនោះបណ្តាលឱ្យស្លាប់ទៅវិញ[990]។ បន្ថែមលើនេះ ក្រមនេះក៏ចែងផងដែរថា ចាត់ទុកថា មានចេតនាបាន កាលបើឃាតករប្រហារយ៉ាងពេញទំហឹង កាលបើមានមុខរបួសមុតសាំលើខ្លួនអ្នកស្លាប់ កាលបើឃើញថា ឃាតករបានរើសរកកន្លែងដំណំនៅលើខ្លួនអ្នកស្លាប់មែន[991]។

៣៩៨.ក្រមព្រហ្មទណ្ឌប្រទេសបារាំង តម្រូវឱ្យមានចេតនាដោយផ្ទាល់សម្រាប់បទឧក្រិដ្ឋនៃ*ការធ្វើមនុស្សឃាត (meurtre)*[992]។ ទោះជាយ៉ាងណាក្តី ពុំបានតម្រូវថា ចារីត្រូវតែមានចេតនាជាក់លាក់ក្នុងការសម្លាប់ឡើយ។ ជាការគ្រប់គ្រាន់ដែលថា ចារីបានប្រព្រឹត្តដោយចេតនានូវអំពើដែលខ្លួនដឹងថា អំពើទាំងនេះ *ជាធម្មតា*អាចធ្វើឱ្យជនរងគ្រោះស្លាប់បាន[993]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អាស្រ័យលើកាលៈទេសៈចំណុចនេះស្រដៀងគ្នានឹងសញ្ញាណនៃ*ចេតនាប្រយោល (dolus eventualis)*។ បន្ថែមលើនេះទៀត ក្នុងក្រមព្រហ្មទណ្ឌបារាំង *បទមនុស្សឃាតដោយគ្មានបំណងសម្លាប់ (homicide praeter intentionnel)* រួមបញ្ចូលនូវហេតុការណ៍ដែលក្នុងនោះ ចារីមានចេតនាប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះ ហើយលទ្ធផលដែលពុំមានចេតនានេះ បានបណ្តាលឱ្យជនរងគ្រោះស្លាប់[994]។

៣៩៩.ច្បាប់របស់ប្រទេសប៊ែលហ្ស៊ិក (Belgium) ក៏មានការបកស្រាយដូចគ្នានេះផងដែរអំពីធាតុផ្សំ*អត្តនោម័ត*នៃការធ្វើមនុស្សឃាត ដែលក្នុងនោះទទួលស្គាល់ថា ធាតុផ្សំ*អត្តនោម័ត*តម្រូវសម្រាប់*ការធ្វើមនុស្សឃាត* អាចត្រូវបានបំពេញដោយសារការដឹងរបស់ចារីថា អាចនឹងមានមនុស្សស្លាប់កើតឡើង។ ម៉្យាងវិញទៀត ដើម្បីដាក់ពិរុទ្ធភាពពីបទមនុស្សឃាត ជនល្មើសត្រូវតែបានប្រព្រឹត្តដោយចេតនាក្នុងការសម្លាប់ ឬទទួលយក*ផលវិបាកនៃ*

[990] *សូមមើល* មាត្រា ៥០៣ ដល់ ៥០៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។

[991] *សូមមើល* មាត្រា ៥០៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។

[992] មាត្រា ២២១-១ នៃក្រមព្រហ្មទណ្ឌបារាំង។ មាត្រា ៥០២ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។

[993] សវនាការនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩០ (តុលាការព្រហ្មទណ្ឌជាន់ខ្ពស់បារាំង)។ *សូមមើលផងដែរ* Jean-Yves MARECHAL "ធាតុផ្សំអត្តនោម័តនៃបទល្មើស" *LexisNexis* Jurisclasseur Code Fasc.20 ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០។

[994] *សូមមើល* មាត្រា ២២២-៧ នៃក្រមព្រហ្មទណ្ឌបារាំង៖ "អំពើហិង្សាបណ្តាលឱ្យស្លាប់ដោយគ្មានចេតនាសម្លាប់ ត្រូវដាក់ពន្ធនាគារ ១៥ ឆ្នាំ"។

*ការស្លាប់នេះ* "*[l]a réalisation de la conséquence mortelle de son acte pour l'éventualité où elle se produirait*"[995]។

៤០០.នៅក្នុងប្រទេសអាល្លឺម៉ង់ តាមរយៈយុត្តិសាស្ត្រតៗគ្នាបានទទួលស្គាល់ថា សម្រាប់ការដាក់ពិរុទ្ធភាពពីបទមនុស្សឃាតដោយចេតនា("*(Mord)/(Totschlag)*") *ចេតនាប្រយោល(dolus eventualis)* គឺគ្រប់គ្រាន់[996]។ ក្នុងប្រទេសអ៊ីតាលី[997] និងអេស្ប៉ាញ[998]ទទួលស្គាល់ដូចគ្នានេះដែរ។

៤០១.ក្នុងប្រទេសប៉ូឡូញ *ចេតនាប្រយោល (dolus eventualis)* តាមទម្លាប់ត្រូវបានចាត់ទុកជាទម្រង់នៃចេតនាដូចបានឆ្លុះបញ្ចាំងក្នុងបទប្បញ្ញត្តិដែលកំណត់ថា ការប្រព្រឹត្តអំពើដែលច្បាប់បានហាមឃាត់ គឺជាការប្រព្រឹត្តឡើងដោយចេតនា នៅពេលចារី"មានឆន្ទៈប្រព្រឹត្ត ឬប្រមើលឃើញនូវ*លទ្ធភាពអាចនឹងកើតឡើងនូវបច្ច័យ* ដោយសារការប្រព្រឹត្តអំពើនេះ ហើយចារីបានទទួលយក"[999]។

៤០២.យុត្តាធិការដែលប្រកាន់យកតាមប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក៏បានទទួលយកធាតុផ្សំ*អត្តនោម័ត* ក្នុងកម្រិតទាបជាងចេតនាដោយផ្ទាល់ចំពោះបទឧក្រិដ្ឋទាក់ទងទៅនឹងមនុស្សឃាតដោយចេតនា ដូចរៀបរាប់ខាងលក្រោម។

៤០៣.ចំពោះប្រទេសអង់គ្លេស និងវែល(Wales) ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយប្រយោល ឬដោយសារបច្ច័យដែលកើតឡើងពីអំពើខុសច្បាប់ អាចត្រូវបានចាត់ចំណាត់ថ្នាក់ជាមនុស្សឃាតដោយចេតនា។

---

[995] Jacques VERHAEGEN "ការពុំអើពើដោយចេតនា ឬចេតនាល្មើស ? ខ្សែបន្ទាត់បែងចែក" ព្រឹត្តិប័ត្ររបស់តុលាការ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០១ លេខ ៦០០៦។ *សូមមើលផងដែរ* Jacques Joseph HAUS៖ *គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌប៊ែលហ្ស៊ិកដោយ J-J Haus* ឆ្នាំ ១៨៧៩ N. 314-315។

[996] សេចក្តីសម្រេចចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ 1 StR 675/99 (តុលាការកំពូលសហព័ន្ធ អាល្លឺម៉ង់) ព្រឹត្តិប័ត្រប្រចាំសប្តាហ៍ស្តីពីយុត្តិធម៌ ឆ្នាំ ២០០០ ទំព័រ ១៧៣០។

[997] *សូមមើលឧ.* សម្រាប់រឿងក្តីបច្ចុប្បន្នណាមួយ ក្រមព្រហ្មទណ្ឌ Cassazione (Sez. I, សំណុំរឿងលេខ ១៦៥៨៥) (តុលាការតុលាការកំពូល អ៊ីតាលី)។

[998] *សូមមើលឧ.* សាលក្រមលេខ ៥១០/ឆ្នាំ ១៩៩៨ (តុលាការកំពូល អេស្ប៉ាញ), សាលក្រមលេខ ៥២៩/ឆ្នាំ ២០០៥ (តុលាការកំពូល អេស្ប៉ាញ)។

[999] មាត្រា ៩(១) នៃក្រមព្រហ្មទណ្ឌប៉ូឡូញឆ្នាំ ១៩៩៧ (សេចក្តីបញ្ជាក់បន្ថែម)។ មាត្រា ៧(១) នៃក្រមព្រហ្មទណ្ឌប៉ូឡូញឆ្នាំ ១៩៦៩។ មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌប៉ូឡូញឆ្នាំ ១៩៣២ ("នៅពេលប្រមើលដឹងពីលទ្ធភាពដែលអាចបណ្តាលឱ្យមានបទល្មើស ឬអំពើល្មើសនោះ នៅតែទទួលយក")។

ចំណុចទីមួយ បានរួមបញ្ចូលការធ្វើឱ្យស្លាប់ដោយចេតនា ឬចេតនាបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរលើរូបកាយ[1000]។ តុលាការប្រទេសអង់គ្លេសបានទទួលយកសញ្ញាណនៃ"*ចេតនាប្រយោល* ដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឱ្យ[ចារី] ប្រមើលមើលឃើញនូវលទ្ធផលដែលច្បាប់បានហាមឃាត់ ដែលមានលទ្ធភាពខ្ពស់ ឬប្រាកដថានឹងកើតឡើង បើទោះបីជាដឹងថា លទ្ធផលនោះ ពុំមែនជាគោលបំណងរបស់ខ្លួនក៏ដោយ"[1001]។ ក្នុងន័យនេះ សភាជាន់ខ្ពស់របស់ចក្រភពអង់គ្លេសបានអនុម័តថា ការធ្វើមនុស្សឃាតត្រូវបានបង្ហាញមិនត្រឹមតែនៅពេលចារីមានចេតនាសម្លាប់ ឬបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបកាយជនរងគ្រោះប៉ុណ្ណោះទេ ថែមទាំងនៅពេលដែលចារីបានដឹង ឬបានប្រមើលមើលឃើញថា អំពើរបស់ខ្លួនអាចធ្វើឱ្យមនុស្សស្លាប់ ឬក៏មានព្យសនកម្មធ្ងន់ធ្ងរលើរូបកាយអ្នកដទៃ ដោយគ្មានអើពើចំពោះផលវិបាកឡើយ[1002]។

៤០៤.នៅក្នុងសហរដ្ឋអាម៉េរិក ក្រមព្រហ្មទណ្ឌគំរូ (ដែលមានឥទ្ធិពលលើការបង្កើតច្បាប់នៅក្នុងរដ្ឋមួយចំនួនរបស់សហរដ្ឋអាម៉េរិក) បានចែងថា "បទមនុស្សឃាត គឺជាការធ្វើមនុស្សឃាត នៅពេលដែល៖ (ក) ត្រូវបានប្រព្រឹត្តឡើងដោយចេតនា ឬដោយដឹង ឬ (ខ) ត្រូវបានប្រព្រឹត្តឡើង*ដោយប្រយោល*ក្នុងកាលៈទេសៈដែលបង្ហាញឱ្យឃើញច្បាស់លាស់នូវការមិនអើពើទាំងស្រុងដល់តម្លៃនៃអាយុជីវិតមនុស្ស"[1003]។

៤០៥.ប្រហាក់ប្រហែលគ្នានេះដែរ តាមក្រមព្រហ្មទណ្ឌកាណាដា ឆ្នាំ ១៨៩២ ដែលបានធ្វើវិសោធនកម្មក្នុង ឆ្នាំ ១៩៨៥ ពុំបានកម្រិតការសម្លាប់មនុស្សដោយចេតនាត្រឹមតែករណីចេតនាដោយផ្ទាល់ប៉ុណ្ណោះទេ គឺ"បទឃាតកម្ម គឺជាអំពើមនុស្សឃាត (ក) នៅពេលដែលជនណាម្នាក់បានបង្កឱ្យមានការបាត់បង់អាយុជីវិតមនុស្ស (i) មានបំណងធ្វើឱ្យអ្នកដទៃស្លាប់ ឬ (ii) មានបំណងបង្កឱ្យអ្នកដទៃទទួលរងព្យសនកម្មខាងរូបកាយដែលជន

---

[1000] *រឿងក្តី Hyam ទល់នឹង R* (សភាជាន់ខ្ពស់របស់ចក្រភពអង់គ្លេស) ទំព័រ ៧៥។

[1001] អត្ថបទរបស់ Glanville Willians "ចេតនាប្រយោល" *ព្រឹត្តិប័ត្រច្បាប់របស់ Cambridge* ភាគ ៤៦ (ឆ្នាំ ១៩៨៧) ទំព័រ ៤១៧។

[1002] *រឿងក្តី Hyam ទល់នឹង R* (សភាជាន់ខ្ពស់របស់ចក្រភពអង់គ្លេស) ទំព័រ ៧៥។

[1003] ក្រមព្រហ្មទណ្ឌគំរូរបស់សហរដ្ឋអាម៉េរិក ផ្នែក ២១០.២(១) (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ផ្នែក ២.០២ (២-គ)៖ ដែលកំណត់និយមន័យការមិនយកចិត្តទុកដាក់ថា "ជនណាប្រព្រឹត្តដោយធ្វេសប្រហែលទាក់ទងទៅនឹងធាតុផ្សំសត្យានុម័តនៃបទល្មើស នៅពេលជននោះពុំបានគិតអំពីហានិភ័យខ្ពស់ដែលធាតុផ្សំសត្យានុម័តនឹងកើតមាន ឬនឹងកើតចេញពីអំពើរបស់ខ្លួន។ ហានិភ័យត្រូវតែស្ថិតក្នុងលក្ខណៈ ឬក្នុងកម្រិតមួយដែលនៅពេលពិចារណាលើលក្ខណៈនៃអំពើ និងគោលបំណងនៃអំពើរបស់ចារី និងកាលៈទេសៈ ដែលចារីបានដឹង ការពុំអើពើនេះពាក់ព័ន្ធទៅនឹងការមិនគោរពតាមបទដ្ឋានទាំងស្រុងនៃការប្រព្រឹត្តដែលបុគ្គលគោរពច្បាប់ទូទៅអាចសង្កេតដឹងនៅក្នុងស្ថានភាពរបស់ចារីបាន"។

01358174



នោះបានដឹងថា ព្យសនកម្មនេះអាចនឹងបណ្តាលឱ្យស្លាប់ ហើយជននោះពុំអើពើ ថាតើមានការស្លាប់កើតឡើង ឬក៏គ្មាននោះទេ”[1004]។

៤០៦.យោងតាមក្រមព្រហ្មទណ្ឌឥណ្ឌា ការសម្លាប់មនុស្ស គឺជាឃាតកម្មដែលត្រូវទទួលទោស “ប្រសិនបើអំពើដែលបណ្តាលឱ្យមនុស្សស្លាប់ ត្រូវបានប្រព្រឹត្តឡើងដោយចេតនាសម្លាប់ ឬ [...] ប្រសិនបើប្រព្រឹត្តឡើងដោយចេតនាបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ប៉ុន្តែចារីដឹងថា ការប្រព្រឹត្តបែបនេះ ជនរងគ្រោះទំនងជានឹងស្លាប់”[1005]។ ការកំណត់និយមន័យអំពីការធ្វើមនុស្សឃាតនេះ ក៏មានចែងដូចគ្នាផងដែរនៅក្នុងក្រមព្រហ្មទណ្ឌសិង្ហបុរី[1006]។

៤០៧.នៅប្រទេសអូស្ត្រាលី ការធ្វើមនុស្សឃាតត្រូវបានកំណត់និយមន័យថា ជាអំពើសកម្ម ឬអំពើអកម្មដែលធ្វើឱ្យមនុស្សស្លាប់“ដោយការមិនអើពើទៅលើអាយុជីវិតមនុស្ស ឬដោយចេតនាសម្លាប់ ឬចេតនាបង្កព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយលើបុគ្គលណាម្នាក់”[1007]។ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុងរបស់ប្រទេសអូស្ត្រាលី ក៏ទទួលស្គាល់មនុស្សឃាតដោយប្រយោលជាពីរប្រភេទធំៗគឺ ដោយចេតនា និងដោយគ្មានបំណងសម្លាប់។ មនុស្ស

---

[1004] ក្រមព្រហ្មទណ្ឌកាណាដា ជំពូក ៤៦, ផ្នែក ២២៩ (ក)។

[1005] ផ្នែក ៣០០ នៃក្រមព្រហ្មទណ្ឌឥណ្ឌា។

[1006] មាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌសិង្ហបុរី។

[1007] ក្រមព្រហ្មទណ្ឌ (New South Wales ប្រទេសអូស្ត្រាលី) ផ្នែក ១៨(១)(ក)។ *សូមមើលផងដែរ* ក្រមព្រហ្មទណ្ឌឆ្នាំ ១៩០២ (Western Australia ប្រទេសអូស្ត្រាលី) ផ្នែក ២៧៩។ ក្រមព្រហ្មទណ្ឌ (Queensland ប្រទេសអូស្ត្រាលី) ផ្នែក ៣០២។ ក្រមព្រហ្មទណ្ឌ (Australian Capital Territory ប្រទេសអូស្ត្រាលី) ផ្នែក ១២។ ក្រមព្រហ្មទណ្ឌ (Northern Territory ប្រទេសអូស្ត្រាលី) ផ្នែក ១៥៦។ ក្រមព្រហ្មទណ្ឌ (Tasmania ប្រទេសអូស្ត្រាលី) ផ្នែក ១៥៧(១)។ តុលាការក្នុងស្រុកបានទទួចជាទូទៅចង់បានកម្រិតមួយខ្ពស់នៃការយល់ដឹងជាមុនអំពីការស្លាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយដែលផលវិបាកអាចកើតមានសម្រាប់ការយល់ឃើញអំពីការធ្វើមនុស្សឃាត។ ការសម្រេចដាក់ពិរុទ្ធភាពអំពីការធ្វើមនុស្សឃាតនៅប្រទេសអូស្ត្រាលី កើតមានតែក្នុងករណីដែលមានការដឹងជាមុនពីភាពច្បាស់លាស់ (ដែលពុំមែនជាភាពទំនងជា) អំពីការស្លាប់ ឬព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយប៉ុណ្ណោះ។ *រឿងក្តី R ទល់នឹង Jakac* [ឆ្នាំ ១៩៦១] VR 367 យោងទៅលើដោយស្របគ្នាក្នុង*រឿងក្តី Hyam ទល់នឹង R* (សភាជាន់ខ្ពស់ ចក្រភពអង់គ្លេស)។ *រឿងក្តី R ទល់នឹង Hallett* (តុលាការកំពូល South Australia ប្រទេសអូស្ត្រាលី)។ *រឿងក្តី Pemble ទល់នឹង R* (តុលាការជាន់ខ្ពស់ ប្រទេសអូស្ត្រាលី)។ *រឿងក្តី R ទល់នឹង Windsor* (តុលាការកំពូល Victoria ប្រទេសអូស្ត្រាលី)។ *រឿងក្តី La Fontaine ទល់នឹង R* (តុលាការកំពូល Victoria ប្រទេសអូស្ត្រាលី)។ *រឿងក្តី Boughey ទល់នឹង R* (តុលាឧទ្ធរណ៍រឿងក្តីព្រហ្មទណ្ឌ ប្រទេសអូស្ត្រាលី)។ *រឿងក្តី R ទល់នឹង Crabbe* (តុលាការជាន់ខ្ពស់ ប្រទេសអូស្ត្រាលី)។

ឃាតដោយគ្មានបំណងសម្លាប់បានរួមបញ្ចូលមនុស្សឃាតដោយចេតនាប្រយោល[1008] តាមរយៈអំពើខុសច្បាប់[1009] ឬការមិនអើពើទាំងស្រុង[1010]។

៤០៨.នៅក្នុងទ្វីបអាហ្វ្រិកខាងត្បូង"ក្នុងការពិចារណាលើបញ្ហានៃចេតនាសម្លាប់មនុស្ស (ដើម្បីរកឱ្យឃើញនូវបទមនុស្សឃាតដែលត្រូវដាក់ទណ្ឌកម្ម) គឺត្រូវបង្ហាញ ថាតើ[ជនជាប់ចោទ]បានដឹងជាមុននូវលទ្ធភាពដែលថាអំពើរបស់ខ្លួន [...] អាចនឹងបណ្តាលឱ្យមានផលវិបាកដល់ស្លាប់ ដែរ ឬយ៉ាងណា និងថា ជនជាប់ចោទ*មិនអើពើ* ថាអំពើនេះបានបណ្តាលឱ្យមនុស្សស្លាប់នោះឡើយ"[1011]។

៤០៩.តាមការពិនិត្យលើការអនុវត្តនៅក្នុងយុត្តិសាស្ត្រដែលបានលើកឡើងខាងលើបង្ហាញថា ដោយសារពុំមានការឯកភាពទាក់ទងទៅនឹងបញ្ហា ថាតើចេតនាសម្លាប់ដែលស្ថិតក្នុងកម្រិតទាបជាងចេតនាដោយផ្ទាល់ត្រូវបានចាត់ទុកថាជា "ការធ្វើមនុស្សឃាត"(ឬជាពាក្យដែលមានន័យសមមូលនៅក្នុងភាសាពាក់ព័ន្ធផ្សេងៗទៀត) ដែរ ឬយ៉ាងណានោះ ដូច្នេះការធ្វើឱ្យមនុស្សស្លាប់ដោយចេតនាក្នុងកម្រិតទាបជាងចេតនាដោយផ្ទាល់ ប៉ុន្តែខ្ពស់ជាងការមិនអើពើនោះ (ដូចជា *ចេតនាប្រយោល* ឬ recklessness) គឺជាការទទួលខុសត្រូវព្រហ្មទណ្ឌ និងត្រូវបានចាត់ទុកថា ជាការធ្វើមនុស្សឃាតដោយចេតនា។ ដោយហេតុថា បទមនុស្សឃាត ក្នុងច្បាប់អន្តរជាតិ ត្រូវបាន

---

[1008] D. LANHAM *និងអ្នកដទៃទៀត ច្បាប់ព្រហ្មទណ្ឌប្រទេសអូស្ត្រាលី* ព្រឹត្តិប័ត្រព័ត៌មានរបស់សហព័ន្ធឆ្នាំ ២០០៦ ទំព័រ ២១០ ដល់ ២១១។

[1009] អំពើអនីត្យានុកូល គឺជាអំពើដែលផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌ។ អំពើគ្រោះថ្នាក់ គឺជាអំពើដែលធ្វើឡើងដោយមានហានិភ័យដែលអាចដឹងបានថា នឹងមានព្យសនកម្មធ្ងន់ធ្ងរកើតឡើង។ *សូមមើល រឿងក្តី Wilson ទល់នឹង R* (តុលាការជាន់ខ្ពស់ ប្រទេសអូស្ត្រាលី)។ *សូមមើលផងដែរ រឿងក្តី R ទល់នឹង Holzer* (តុលាការកំពូល Victoria ប្រទេសអូស្ត្រាលី)។ *រឿងក្តី Burns ទល់នឹង R* (តុលាការជាន់ខ្ពស់ ប្រទេសអូស្ត្រាលី) ទំព័រ ៧៥។ *រឿងក្តី Lane ទល់នឹង R* (តុលាការឧទ្ធរណ៍រឿងក្តីព្រហ្មទណ្ឌ New South Wales ប្រទេសអូស្ត្រាលី) ទំព័រ ៧៥។

[1010] ការមិនយកចិត្តទុកដាក់ដែលជាអំពើល្មើសរួមបញ្ចូលចេតនាក្នុងការធ្វើសកម្មភាពដែលបង្កឱ្យជនរងគ្រោះស្លាប់ ដោយហេតុថាការប្រព្រឹត្តអំពើនោះពាក់ព័ន្ធទៅនឹងការមិនគោរពតាមបទដ្ឋាននៃការប្រុងប្រយ័ត្ន ដែលតម្រូវសម្រាប់បុគ្គលសមហេតុផលនៅក្នុងកាលៈទេសៈនានា និងបង្កហានិភ័យកម្រិតខ្ពស់ ឬភវនីយភាពនៃការបណ្តាលឱ្យមានការស្លាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយ។ *សូមមើល រឿងក្តី Nydam ទល់នឹង R* (តុលាការកំពូល Victoria ប្រទេសអូស្ត្រាលី) ទំព័រ ៤៤៥ ត្រូវបានអនុម័ត*ក្នុងរឿងក្តី R ទល់នឹង Lavender* (តុលាការជាន់ខ្ពស់ ប្រទេសអូស្ត្រាលី) ទំព័រ ១៣៦។ *រឿងក្តី Wilson ទល់នឹង R* (តុលាការជាន់ខ្ពស់ ប្រទេសអូស្ត្រាលី) ទំព័រ ៤៩។*រឿងក្តី Burns ទល់នឹង R* (តុលាការជាន់ខ្ពស់ ប្រទេសអូស្ត្រាលី) ទំព័រ ១៩។

[1011] *រឿងក្តី រដ្ឋ ទល់នឹង Malinga* (ឆ្នាំ ១៩៦៣) ទំព័រ ៦៩៤ F - H និងទំព័រ ៦៩៥ (សេចក្តីបញ្ជាក់បន្ថែម)។

01358176



កំណត់និយមន័យថា ជាការសម្លាប់ដោយចេតនា ដូច្នេះមានការយល់ច្បាស់ថា ការធ្វើមនុស្សឃាតនេះត្រូវរួមបញ្ចូលចេតនាផ្ទាល់ ព្រមទាំងការសម្លាប់ដោយ *ចេតនាប្រយោល (dolus eventualis)*/reckless ផងដែរ។

៤១០.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥ ត្រូវតែកំណត់និយមន័យឱ្យមាន *លក្ខណៈទូលាយ (largo sensu)* ដើម្បីរួមបញ្ចូលនូវ *ចេតនាប្រយោល (dolus eventualis)*/reckless ផងដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

## ៤.ឃ.១.ខ.ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

៤១១.អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណនៃការសម្លាប់ ឬការស្លាប់ជាច្រើនប្រភេទ ដែលជាការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានកើតឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយថាជា៖

(i) ការសម្លាប់ជនស៊ីវិលដែលរឹងរូសមិនព្រមស្តាប់តាមបទបញ្ជា ដែលចង់ត្រឡប់មកក្រោយវិញ ឬសម្លាប់ដោយពុំមានហេតុផលទាល់តែសោះ

(ii) ការស្លាប់ជនរងគ្រោះជាច្រើនដោយសារលក្ខខណ្ឌនៃការជម្លៀស និង

(iii) ការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៤១២.នួន ជា និង ខៀវ សំផន ពុំបានលើកឡើងនូវអំណះអំណាងជាក់លាក់ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានគេ"កំណត់គោលដៅ"សម្រាប់ប្រហារជីវិត និងអ្នកដែលពុំបានរត់គេចខ្លួនចេញពីទីក្រុងត្រូវបានសម្លាប់ឡើយ។ ទោះជាយ៉ាងណាក្តី នួន ជា និង ខៀវ សំផន បានជំទាស់ការសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតទាំងមូល និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការកំណត់ប្រភេទដទៃទៀតនៃជនរងគ្រោះ។

### ៤.ឃ.១.ខ.១.ការសម្លាប់ជនស៊ីវិល

៤១៣.ទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិល ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ជនរងគ្រោះជាច្រើនដែលបានបដិសេធមិនចាកចេញពីផ្ទះសំបែង

របស់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជា អ្នកដែលមិនបានធ្វើតាមការណែនាំភ្លាមៗរបស់កងទ័ពខ្មែរក្រហមក្នុងអំឡុងពេលចាកចេញពីទីក្រុង ត្រូវបានបាញ់សម្លាប់នៅនឹងកន្លែង"[1012]។ អង្គជំនុំជម្រះសាលាដំបូងក៏បានសន្និដ្ឋានផងដែរថា "មានភស្តុតាងជាច្រើនបង្ហាញអំពីការសម្លាប់ជនស៊ីវិលទាំងនៅក្នុងទីក្រុងភ្នំពេញ និងក្នុងអំឡុងពេលនៃការជម្លៀសដោយគ្មានមូលហេតុសោះឡើយ" ដោយបានយោងនៅក្នុងជើងទំព័រទៅលើកថាខណ្ឌចំនួន ៣ តាំងពីដំបូង ដែលពីរកថាខណ្ឌពុំជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់ជនស៊ីវិល ប៉ុន្តែទាក់ទងទៅនឹងការសម្លាប់អ្នករដ្ឋការ ឬទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលជាជនរងគ្រោះក្នុងប្រភេទមួយដាច់ដោយឡែក[1013]។ ដោយសារការសន្និដ្ឋានទីពីរនេះមានលក្ខណៈពុំច្បាស់លាស់ ដែលអាចត្រូវបានយល់ថាគ្រាន់តែជាការទទួលស្គាល់នូវអត្ថិភាពនៃភស្តុតាង ជាជាងការយល់ឃើញដែលផ្អែកលើការវាយតម្លៃជាក់ស្តែងនៃភស្តុតាងនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញហួសពីវិមតិសង្ស័យថា ការសម្លាប់ជនស៊ីវិលបានកើតឡើង នៅពេលដែលជនស៊ីវិលទាំងនោះ ពុំធ្វើតាមការបញ្ជារបស់កងទ័ពខ្មែរក្រហម រួមទាំង "ការសម្លាប់ដោយគ្មានមូលហេតុទាល់តែសោះ"ផងដែរ។

៤១៤.ក្នុងកថាខណ្ឌនៃសាលក្រមដែលអង្គជំនុំជម្រះសាលាដំបូងបានយោង នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនស្តីពីការធ្វើមនុស្សឃាតមានសំអាងហេតុច្បាស់លាស់បង្ហាញថា "ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនបានរៀបរាប់ឡើងវិញ អំពីការបាញ់សម្លាប់ភ្លាមៗនៅនឹងកន្លែងចំពោះប្រជាជនណាដែលមិនព្រមស្តាប់តាមបញ្ជា" ដោយបានផ្តល់ការយល់ឃើញជាក់លាក់ជាបន្តបន្ទាប់ទៀត[1014] និងបង្ហាញថា "អ្នកដែលរឹងទទឹងព្យាយាមត្រឡប់មកទីក្រុងភ្នំពេញវិញ ត្រូវបានបាញ់សម្លាប់"[1015] និងថា "មានហេតុការណ៍ជាច្រើនទៀតដែលកងទ័ពខ្មែរក្រហម បានបាញ់សម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការជម្លៀស ដែលជនរងគ្រោះទាំងនោះ រួមទាំងតារាភាពយន្តល្បីឈ្មោះម្នាក់ អ្នកបើកបរយានយន្តមួយចំនួន និងសូម្បីតែអ្នកដែលខ្សោយកម្លាំងមិនអាចបន្តដំណើរទៅមុខទៀតបាន ក៏ត្រូវបាញ់សម្លាប់ផងដែរ"[1016]។ នៅក្នុងជើងទំព័រនៃការយល់ឃើញទាំងនេះ អង្គជំនុំ

---

[1012] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៣ និងជើងទំព័រ ១៦៥៤ យោងទៅលើកថាខណ្ឌ ៤៧៤ និង ៤៨៦។

[1013] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៣ និងជើងទំព័រ ១៦៥៥ យោងទៅលើកថាខណ្ឌ ៤៩០, ៥០៧ និង ៥១៣ (កថាខណ្ឌពីរចុងក្រោយនេះ ទាក់ទងទៅនឹងការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

[1014] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៤។

[1015] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៦។

[1016] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០។

ជម្រះសាលាដំបូងបានសរុបភស្តុតាងជាមូលដ្ឋាន ដោយបានបង្ហាញហេតុការណ៍ចំនួន ៥៥ ផ្សេងៗគ្នាចំពោះការសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការជម្លៀស[1017]។

៤១៥.នួន ជា បានចោទប្រកាន់ថា ការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ចំពោះការសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ជាកំហុសអង្គហេតុដែលនាំឱ្យមានភាពមិនយុត្តិធម៌ ពីព្រោះភស្តុតាងនៃការធ្វើមនុស្សឃាតមានលក្ខណៈពុំរឹងមាំ ដែលពុំមានតុលាការអង្គហេតុឥតលម្អៀងណាមួយអាចធ្វើសេចក្តីសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា មានការសម្លាប់ណាមួយបានកើតឡើងឡើយ[1018]។ នួន ជា បានអះអាងថា រាល់អំពើសម្លាប់នីមួយៗដែលយកមកធ្វើជាមូលដ្ឋាននៃការយល់ឃើញអំពីការធ្វើមនុស្សឃាតពុំមានមូលដ្ឋានគាំទ្រច្បាស់លាស់ឡើយ[1019]។ ជាពិសេស នួន ជា បានលើកឡើងថា អង្គជំនុំជម្រះ (i) ពុំបានវាយតម្លៃ និងថ្លឹងថ្លែងឱ្យបានសមស្របនូវតម្លៃជាភស្តុតាងណាមួយ ឬលើកាលៈទេសៈដែលភស្តុតាងនេះ

---

[1017] ការរៀបរាប់ទាំងនេះបានសំអាងលើការយល់ឃើញអំពីការធ្វើមនុស្សឃាតក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៤ ជើងទំព័រ ១៤០២ ដល់ ១៤០៥, កថាខណ្ឌ ៤៨៦ ជើងទំព័រ ១៤៥០, កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២ ដល់ ១៤៦៣។ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញការរៀបរាប់ចំនួន ៤៥ ដាច់ដោយឡែកពីគ្នានៃការសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលផ្តល់ដោយបុគ្គលចំនួន ៤៣ មានដូចជា៖ ផាម មឿន សុត សែម ប៉ុក សាឯម សួង ឃិត មា ឈិន សែន សុផុន ដៃ យឹន យ៉ាន ញ៉ អៀម ទៀង មាស មុត បេង បឿន សក្ខីកម្មរបស់ជនភៀសខ្លួនដែលជានិស្សិតច្បាប់ម្នាក់ សក្ខីកម្មរបស់ជនភៀសខ្លួនរបស់"កម្មករ" ពេជ្រ លឹមកុង/ពេជ្រ លឹមគួន ខឹម ណារ៉េត Denise AFFONÇO ពិន យ៉ាថៃ ឧត្តមសេនីយ៍ សរ ប៊ុន HUM Ponak ស៊ាង ចាន់ ខៀវ ហន ភួង មុំ ហេនរី ស៊ុន ស៊ុំ ជា ម៉ម ផៃបួន Sydney SCHANBERG ឡាយ បូនី យឹម សុវណ្ណ ធុច ផាន់ដារា-ស យស ផល មុម សំអឿន ជុំ សុខា មាស សាវ៉ាន់ គង់ ណារិន នង ប៉ុណ្ណា កែវ ឆែម ភួង ផល្លា លី រៀម ទៀង សុខុម ជូ គីមឡុន សាម ផា សែម វីរៈ ឆេង លី។ *ប្រៀបធៀប* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤៥ (រកឃើញការសម្លាប់ចំនួន ៤៨ ករណី) ទោះជាយ៉ាងណាក្តី លទ្ធភាពអាចកើតមានថា នៅពេលបុគ្គលម្នាក់ធ្វើការរៀបរាប់ជាច្រើនអំពីហេតុការណ៍នៃការសម្លាប់ដោយចេតនា ការរៀបរាប់មួយចំនួនអាចជាហេតុការណ៍តែមួយ។ *សូមមើលឧ.* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត សែមឯកសារលេខ E3/4689 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៨ ERN (ភាសាខ្មែរ) 00358732-3 (ដោយបានអះអាងថា ប្រជាជនត្រូវបានបញ្ជាឱ្យទៅតាមផ្លូវជាតិលេខ ១ និងថា អ្នកដែលជំទាស់តវ៉ាត្រូវបានបាញ់សម្លាប់ចោល)។ កំណត់ហេតុស្តាបចម្លើយរបស់ សុត សែម ឯកសារលេខ E3/4654 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ដល់ ៤ ERN (ភាសាខ្មែរ) 00390312-3 (បានអះអាងថា គាត់បានឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់ប្រជាជនមួយចំនួន ដែលប្រជាជនទាំងនោះទំនងជាម្ចាស់ផ្ទះដែលពុំព្រមចាកចេញពីផ្ទះរបស់ខ្លួន)។

[1018] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨៩ ដល់ ២៩៤, ២៩៦ ដល់ ៣២០។

[1019] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨៥។

ប្រមូលបាននោះ[1020] និង (ii) ការផ្តល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងមិនរឹងមាំដែលត្រូវបានដាក់ឱ្យពិភាក្សាដេញដោលទេ[1021]។ បន្ថែមលើនេះទៀត នួន ជា បានលើកឡើងថា ការសម្លាប់ណាមួយដែលបានចោទប្រកាន់ បើទោះបីជាមានភស្តុតាងបញ្ជាក់គ្រប់គ្រាន់ក៏ដោយ ក៏អាចត្រូវបានធ្វើយុត្តិកម្មស្របច្បាប់បានថា ជាការចាំបាច់ខាងយោធា ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងពុំបានពិនិត្យលើបញ្ហានេះទេ[1022]។

៤១៦.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិល ពុំបានជោគជ័យ ពីព្រោះ នួន ជា (i) ពុំបានកំណត់ចរិតលក្ខណៈត្រឹមត្រូវលើភស្តុតាង[1023] (ii) ពុំបានលើកភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនដែលថា ជាការសម្លាប់ដោយស្របច្បាប់នោះ[1024] (iii) បានបដិសេធដោយពុំត្រឹមត្រូវនូវភស្តុតាងជាច្រើនប្រភេទ រួមទាំងសក្ខីកម្មអំពីផលប៉ះពាល់ដល់ជនរងគ្រោះ ភស្តុតាងជាឯកសារ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1025] និង (iv) ពុំអើពើអំពីភស្តុតាងដែលបានបញ្ជាក់បន្ថែម[1026]។ សហព្រះរាជអាជ្ញាក៏បានអះអាងផងដែរថា វិធីសាស្ត្រត្រឹមត្រូវ គឺពុំមែនត្រូវវាយតម្លៃអំពើសម្លាប់នីមួយៗដាច់ដោយឡែកពីភស្តុតាងដទៃទៀតនោះទេ ប៉ុន្តែត្រូវវាយតម្លៃ ថាតើភស្តុតាងនោះត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ការធ្វើមនុស្សឃាតពិតជាបានកើតឡើងនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែរ ឬយ៉ាងណា[1027]។

៤១៧.យោងតាមខាងលើ ដំបូងអង្គជំនុំជម្រះតុលាការកំពូលត្រូវកំណត់ ថាតើអំពើសម្លាប់នីមួយៗដែលអង្គជំនុំជម្រះសាលាដំបូងបានយោងជាចម្បងក្នុងជើងទំព័រ ពិតជាតម្រូវឱ្យបង្ហាញហួសពីវិមតិសង្ស័យ ដែរ ឬយ៉ាង

---

[1020] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨៩ ដល់ ២៩៣។

[1021] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៣, ៣០២ ដល់ ៣០៧, ៣១២ ដល់ ៣១៨។

[1022] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៤។

[1023] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤៦ ដល់ ១៥០។

[1024] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤៩។

[1025] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥១ ដល់ ១៥៣។

[1026] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥៤ ដល់ ១៥៦។

[1027] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤៣ ដល់ ១៤៥។

ណា នោះ គឺជាអំណះអំណាងមូលដ្ឋានរបស់ នួន ជា ហើយសហព្រះរាជអាជ្ញាទំនងជាជំទាស់លើចំណុចនេះ[1028]។

៤១៨.យោងតាមយុត្តិសាស្ត្រដែលពាក់ព័ន្ធរបស់តុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍* ដែលអង្គជំនុំជម្រះតុលាការកំពូលជឿជាក់នោះ បានបង្ហាញថា ពុំមែនរាល់អង្គហេតុនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ លើកលែងតែអង្គហេតុដែលជាមូលដ្ឋាននៃធាតុផ្សំបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ រួមទាំងអង្គហេតុដែលសំខាន់ដោយខ្វះពុំបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាព ជាពិសេសអង្គហេតុដែលបង្កើតបានជាធាតុផ្សំនៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់លើជនជាប់ចោទ[1029]។ តាមពាក្យពេចន៍ជាក់ស្តែង អាចមានអង្គហេតុដទៃទៀតដែលចាំបាច់ត្រូវបង្ហាញឱ្យហួសពីវិមតិសង្ស័យ ដោយសារតែមានការតវ៉ាក្នុងរឿងក្តី[1030]។ ទោះជាយ៉ាងណាក្តី ក្នុងករណីមានតែភស្តុតាងមិនផ្ទាល់ហើយ"ប្រសិនបើភស្តុតាងណាមួយ ដែលតភ្ជាប់ទៅនឹងភស្តុតាងដទៃទៀតនោះពុំត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ នោះដំណើរជាខ្សែសង្វាក់នៃភស្តុតាងទាំងមូល ពុំគាំទ្រដល់ការដាក់ពិរុទ្ធភាពឡើយ"[1031]។ ទាក់ទងទៅនឹងការបង្ហាញពីធាតុផ្សំចាំបាច់យ៉ាងដូចម្តេច នេះមានន័យថា ត្រូវអនុវត្តតាមបទដ្ឋានក្នុងការបង្ហាញភស្តុតាងនីមួយៗដាច់ដោយឡែកពីគ្នាឱ្យហួសពីវិមតិសង្ស័យ។ ផ្ទុយទៅវិញ តុលាការអង្គហេតុត្រូវតែ"ជឿជាក់ឱ្យហួសពីវិមតិសង្ស័យ ដោយផ្អែកលើភស្តុតាងទាំងមូលថា មានការបង្ហាញរាល់អង្គហេតុទាំងអស់ដែលជាធាតុផ្សំនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ត្រូវបានធ្វើឡើង ព្រមទាំងអង្គហេតុដែលសំខាន់មិនអាចខ្វះបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាព[1032]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC យល់ឃើញថា នៅពេលកំណត់ពីបញ្ហា ថាតើបទដ្ឋាននេះត្រូវបានបំពេញ ដែរ ឬយ៉ាងណា តុលាការអង្គហេតុត្រូវ

---

[1028] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤៤។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ F1/7.1 ទំព័រ ៣។

[1029] សាលដីកា*រឿងក្តី Halilović* (ICTY) កថាខណ្ឌ ១២៩ យោងទៅលើសាលដីកា*រឿងក្តី Ntagerura* (ICTR) កថាខណ្ឌ ១៧៤ និងសាលដីកា*រឿងក្តី Blagojević និង Jokić* (ICTY) កថាខណ្ឌ ២២៦។ សាលដីការ*រឿងក្តី Milosević* (ICTY) កថាខណ្ឌ ២០ យោងទៅ*ក្នុងចំណោមនោះ*លើសាលដីកា*រឿងក្តី Ntagerura* (ICTR) កថាខណ្ឌ ១៧៤ ដល់ ១៧៥។

[1030] សាលដីកា*រឿងក្តី Halilović* (ICTY) កថាខណ្ឌ ១២៩។

[1031] សាលដីកា*រឿងក្តី Ntagerura* (ICTR) កថាខណ្ឌ ១៧៥។

[1032] សាលដីកា*រឿងក្តី Ntagerura* (ICTR) កថាខណ្ឌ ១៧៤។ សាលដីកា*រឿងក្តី Mrkšić និងរឿងក្តី Šljivančanin* (ICTY) កថាខណ្ឌ ២១៧។

បានតម្រូវឱ្យធ្វើការវាយតម្លៃជារួម និងថ្លឹងថ្លែងលើវាល់*ភស្តុតាងទាំងអស់បញ្ចូលគ្នា*ទាក់ទងទៅនឹងអង្គហេតុនោះ[1033]។

៤១៩.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា វិធីសាស្ត្រប្រើប្រាស់ចំពោះភស្តុតាងត្រួតគ្នា ឬទាំងមូល ត្រូវបានគិតទុកជាមុនដើម្បីប្រើប្រាស់ជាចម្បងទាក់ទងទៅនឹងភាពអាចជឿទុកចិត្តបានចំពោះភស្តុតាងនីមួយៗ ដោយផ្អែកលើអត្ថិភាពនៃការបញ្ជាក់បន្ថែមនៃភស្តុតាង[1034] ហើយពាក្យពេចន៍នេះត្រូវបានប្រើប្រាស់ទាក់ទងទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងមិនផ្ទាល់ក្នុងការបង្ហាញនូវអង្គហេតុសំខាន់ៗ ឱ្យហួសពីវិមតិសង្ស័យ ជាងអង្គហេតុដទៃទៀត[1035]។ ទោះជាយ៉ាងណាក្តី យុត្តិសាស្ត្រនេះពុំបានគាំទ្រដល់ការអះអាងដែលថា ភស្តុតាងផ្សេងៗជាច្រើន អាចបូកគ្នាដើម្បីបំពេញតាមលក្ខខណ្ឌក្នុងការបង្ហាញឱ្យហួសពីវិមតិសង្ស័យដោយផ្អែកលើភស្តុតាងរួម ដោយពុំគិតពីទម្ងន់នៃភស្តុតាងនីមួយៗឡើយ។ ពិតណាស់ វិធីសាស្ត្របែបនេះមានន័យថា ជនជាប់ចោទអាចត្រូវបានសម្រេចដាក់ពិរុទ្ធភាព ដោយត្រឹមតែផ្អែកលើមូលដ្ឋាននៃពាក្យចចាមអារ៉ាមទូទៅប៉ុណ្ណោះ។

៤២០.ជាពិសេសទាក់ទងទៅនឹងការធ្វើមនុស្សឃាត អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុង*រឿងក្តី Stakić* ត្រង់ចំណុចថា ការសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតពុំត្រូវបានដកចេញ ដោយសារតែពុំអាចកំណត់បាននូវចំនួនមនុស្សស្លាប់ជាក់លាក់ ឬអត្តសញ្ញាណរបស់ចារីផ្ទាល់ និងជនរងគ្រោះក្នុងករណីនីមួយៗ[1036] និងយល់ស្របជាមួយនឹងអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY ក្នុង*រឿងក្តី Kvočka* ដែលថា ការបង្ហាញឱ្យហួសពីវិមតិសង្ស័យទាក់ទងទៅនឹងការសម្លាប់បុគ្គលមួយ ពុំចាំបាច់តម្រូវឱ្យរកឃើញសាកសពរបស់បុគ្គលនោះទេ ផ្ទុយទៅវិញ អង្គហេតុនៃការស្លាប់របស់ជនរងគ្រោះ អាចត្រូវបានសន្និដ្ឋានតាមរយៈកាលៈទេសៈដែលកើតចេញពីភស្តុតាងទាំងអស់ដែលបានបង្ហាញ

---

[1033] សាលដីកា*រឿងក្តី Lubanga* (ICC) កថាខណ្ឌ ២២។

[1034] *ឧ.* សាលដីកា*រឿងក្តី Ntagerura* (ICTR) កថាខណ្ឌ ១៧៤។ សាលដីកា*រឿងក្តី Halilović* (ICTY) កថាខណ្ឌ ១១៩។ សាលដីកា*រឿងក្តី Martić* (ICTY) កថាខណ្ឌ ២៣២។ សាលដីកា*រឿងក្តី Limaj* (ICTY) កថាខណ្ឌ ១៥៣ ដល់ ១៥៤។

[1035] សាលដីកា*រឿងក្តី Martić* (ICTY) កថាខណ្ឌ ២៣៤។

[1036] សាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ២០១ ដកស្រង់ដោយសហព្រះរាជអាជ្ញាក្នុងប្រតិចារឹកសវនាការលើបណ្តឹងសាទុក្ខ សំណុំរឿង ០០២/០១ ឯកសារលេខ F1/7.1 ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ៣ ដល់ ៤ ERN (ភាសាខ្មែរ) 01208459-60។

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1037]។ ទោះជាយ៉ាងណាក្តី ដើម្បីផ្តល់មូលដ្ឋានគាំទ្រដល់ការយល់ឃើញទូទៅហួសពីវិមតិសង្ស័យចំពោះការសម្លាប់នោះ ហេតុការណ៍ជាក់លាក់នៃការសម្លាប់មនុស្សត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ ដោយពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើមានការសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតចំពោះហេតុការណ៍នីមួយៗ ដែរ ឬយ៉ាងណា នោះទេ។ អាស្រ័យហេតុនេះ ចំពោះសេចក្តីសន្និដ្ឋានទូទៅដែលបង្ហាញត្រឹមតែថា មានការធ្វើមនុស្សឃាតបានកើតឡើងនោះ ពុំមានន័យថា ជាការបង្ហាញហួសពីវិមតិសង្ស័យទេ ដរាបណាហេតុការណ៍ជាក់លាក់ណាមួយដែលជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋាននោះ ពុំត្រូវបានបង្ហាញត្រឹមត្រូវតាមបទដ្ឋាន។ ចំនួននៃការសម្លាប់ដែលចាំបាច់ត្រូវតែបង្ហាញឱ្យបានសមស្រប អាស្រ័យលើវិធីសាស្ត្រនៃការតវ៉ានៅក្នុងរឿងក្តីនីមួយៗ ដែលរឿងក្តីមួយអាចគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការយល់ឃើញអំពីការធ្វើមនុស្សឃាតបាន[1038] ចំណែកចំនួនច្រើនជាងនេះ គឺជាលក្ខខណ្ឌតម្រូវសម្រាប់បង្ហាញពីលំនាំ ឬចរិតលក្ខណៈក្នុងទ្រង់ទ្រាយធំតែប៉ុណ្ណោះ[1039]។

៤២១.អង្គជំនុំជម្រះតុលាការកំពូលក៏បានពិនិត្យផងដែរលើរឿងក្តីដទៃទៀត ដែលសហព្រះរាជអាជ្ញាបានយោងទៅលើនៅពេលសវនាការលើបណ្តឹងសាទុក្ខក្នុងការគាំទ្រការលើកឡើងរបស់ខ្លួនដែលថា ការធ្វើមនុស្សឃាតនីមួយៗពុំចាំបាច់ត្រូវបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ ដោយសារជនជាប់ចោទត្រូវបានចោទប្រកាន់ និងដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលដែលស្របបញ្ចូលបទមនុស្សឃាត[1040]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា យុត្តិសាស្ត្រនេះពុំមានការជាប់ព័ន្ធច្រើនខ្លាំងទៅនឹងបញ្ហាចំពោះមុខនោះទេ។ នៅក្នុង *រឿងក្តី Ntakirutimana* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានដោះស្រាយលើបញ្ហា ថាតើជនរងគ្រោះ

---

[1037] សាលដីកា *រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ២៦០ សំអាងដោយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៣។

[1038] *សូមមើល* សាលដីកា *រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៧៤៖ “ការសម្រេចដាក់ពិរុទ្ធភាពពីបទចោទណាមួយអាចធ្វើឡើងបានប្រសិនបើមានការយល់ឃើញជាប់ពាក់ព័ន្ធទៅនឹងហេតុការណ៍មួយនៅក្នុងបទចោទនោះ។ […] អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញហួសពីវិមតិសង្ស័យថា ហេតុការណ៍មួយចំនួននៃការធ្វើទុក្ខបុកម្នេញ ការសម្លាប់ ការធ្វើទារុណកម្ម និងការធ្វើបាប ត្រូវបានប្រព្រឹត្តឡើងទៅលើអ្នកជាប់ឃុំនៅក្នុងជំរំ Omarska”។

[1039] សាលដីកា *រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៣៥៧ ដល់ ៣៦០។

[1040] ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារលេខ F1/7.1 ទំព័រ ៣ ដល់ ៤ យោងទៅលើសាលដីកា *រឿងក្តី Ntakirutimana* (ICTR) កថាខណ្ឌ ៥១៨។ សាលដីកា *រឿងក្តី Rukundo* កថាខណ្ឌ ១៨៧, ១៨៩។ សាលដីកា *រឿងក្តី Gacumbitsi* (ICTR) កថាខណ្ឌ ៨៩។ សាលក្រម *រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៦៥៤។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ខ្លួនបានពិចារណាលើសាលក្រម *រឿងក្តី Stakić* (ICTY) រួចរាល់ហើយ។

នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាំបាច់ត្រូវបង្ហាញឈ្មោះ ឬពិពណ៌នា ដែរ ឬយ៉ាងណា ហើយបានយល់ឃើញថា នេះពុំមែនជាបញ្ហាចាំបាច់នោះទេ[1041]។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងយល់ឃើញបែបនេះក៏ដោយ ក៏នេះពុំមែនមានន័យថា ការធ្វើមនុស្សឃាតពុំចាំបាច់ត្រូវបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះឡើយ។ ក្នុងរឿងក្ដី *Gacumbitsi* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានយល់ឃើញថា បើទោះបីជា តំណាងអយ្យការពុំបានបង្ហាញថា បុគ្គលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះបានបង្ហាញឈ្មោះដូចជាជនរងគ្រោះនៃអំពើសម្លាប់រង្គាលនៅទីកន្លែងជាក់លាក់ណាមួយ ជាក់ស្ដែងត្រូវបានសម្លាប់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៃតុលាការនេះបានសន្និដ្ឋានយ៉ាងសមហេតុផលថា ការធ្វើមនុស្សឃាតត្រូវបានង្ហាញ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានយល់ឃើញថា អង្គហេតុសត្យានុម័តដែលចាំបាច់ត្រូវបង្ហាញនោះ គឺថា "ជនភៀសខ្លួនជាច្រើនត្រូវបានសម្លាប់" ប៉ុន្តែពុំបានយល់ឃើញថា ទាំងនេះពុំចាំបាច់បង្ហាញឱ្យហួសពីវិតិសង្ស័យនោះឡើយ[1042]។ ចុងក្រោយ ចំណុចដែលដកស្រង់ចេញពីសាលដីកា*រឿងក្ដី* *Rukundo* (ICTR) អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានពិភាក្សាអំពីមូលហេតុដែលអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដីនោះបានផ្ដល់ការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងអត្ថិភាពនៃការធ្វើមនុស្សឃាតក្នុងទ្រង់ទ្រាយធំ។ ចំណុចនេះពុំបានបង្ហាញថា ការធ្វើមនុស្សឃាតទាំងនេះពុំចាំបាច់ត្រូវបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ។

៤២២.ទាក់ទងទៅនឹងរឿងក្ដីបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការចោទប្រកាន់ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាត និង សម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ពុំបានផ្ដោតលើអំពើមួយៗនៃការសម្លាប់នោះទេ ប៉ុន្តែផ្ដោតលើការចោទប្រកាន់ជាទូទៅថា កងទ័ពខ្មែរក្រហមបានសម្លាប់ជនស៊ីវិលជាច្រើននៅក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ។ អង្គជំនុំជម្រះសាលាដំបូង ដូចបានពិពណ៌នាខាងលើយល់ឃើញថា ជនស៊ីវិលត្រូវបានសម្លាប់ ប្រសិនបើពួកគាត់មិនព្រមស្ដាប់បញ្ជា រួមទាំង"ការសម្លាប់ដោយគ្មានមូលហេតុទាល់តែសោះ"[1043]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងពុំបានពិភាក្សាលើមូលដ្ឋានសម្រាប់ការយល់ឃើញ

---

[1041] សាលដីកា*រឿងក្ដី* *Ntakirutimana* (ICTR) កថាខណ្ឌ ៥១៨។

[1042] សាលដីកា*រឿងក្ដី* *Gacumbitsi* (ICTR) កថាខណ្ឌ ៨៩។

[1043] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៣ និងជើងទំព័រ ១៦៥៤ និង ១៦៥៥ យោងទៅលើកថាខណ្ឌ ៤៧៤, ៤៨៤ និង ៤៩០ (ជើងទំព័រ ១៦៥៥ មានការយោងទៅលើកថាខណ្ឌ ៥០៧ និង ៥១៣ ដែលទោះជាយ៉ាងណាក្ដីបានដោះស្រាយលើការសម្លាប់អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ)។

របស់ខ្លួនទាក់ទងទៅនឹងការសម្លាប់មួយៗនោះទេ ប៉ុន្តែគ្រាន់តែបានសង្ខេបភស្តុតាងមូលដ្ឋាននេះ ភាគច្រើននៅក្នុងជើងទំព័រប៉ុណ្ណោះ[1044]។ គ្រប់ហេតុការណ៍ជាក់លាក់នៃការសម្លាប់ទាំងនេះ គឺជាធាតុផ្សំនៃការយល់ឃើញជាទូទៅផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង និងជាអង្គហេតុដែលត្រូវបានយកមកសំអាងក្នុងការដាក់ពិរុទ្ធភាពពីបទមនុស្សឃាត ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។ នេះគឺដោយសារប្រសិនបើហេតុការណ៍នៃការសម្លាប់ជាក់លាក់ពុំត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យទេនោះ ពុំអាចនិយាយបានថា ការយល់ឃើញដែលថា ជនស៊ីវិលត្រូវបានសម្លាប់ដោយសារតែពុំធ្វើតាមបទបញ្ជា រួមទាំងការសម្លាប់ដោយ“គ្មានហេតុផលទាល់តែសោះ”ត្រូវបានបង្ហាញឱ្យហួសពីវិតិសង្ស័យស្របតាមបទដ្ឋាននោះឡើយ។ យោងតាមហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់ ថាតើហេតុការណ៍សម្លាប់ជាក់លាក់អាចចាត់ទុកថា បានបង្ហាញដោយសមហេតុផល ដែរ ឬយ៉ាងណា បើផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ។

៤២៣.ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានកំណត់យកហេតុការណ៍នៃការសម្លាប់ចំនួន ៥៤ ករណី។ ក្នុងចំណោមនោះ មានហេតុការណ៍ចំនួន ២ បានសំអាងទៅលើសក្ខីកម្មរបស់សាក្សី ចំនួន ១០ លើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់ភស្តុតាងផ្ទាល់ភ្នែក ឬការរៀបរាប់ចចាមអារ៉ាមនៃការសម្លាប់ចំនួន ៣ លើកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី និង ចំនួន ២ លើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាភស្តុតាងប្រមូលក្រោមការអនុញ្ញាតរបស់សហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក. ដែលទោះជាយ៉ាងណាក្តី ភាគីការពារក្តី រួមទាំងអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀត ពុំមានឱកាសសួរដេញដោលនៅក្នុងសវនាការឡើយ។ ការយល់ឃើញដទៃទៀតនៃការសម្លាប់បានផ្អែកលើឯកសារចំនួន ២០ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ១ លើព័ត៌មាននៅក្នុងរបាយការណ៍របស់រដ្ឋាភិបាលន័រវេ (Norwegian Government) ទៅកាន់អង្គការសហប្រជាជាតិ ចំនួន ៩ លើពាក្យបណ្តឹងរបស់ជនរងគ្រោះ ចំនួន ៤ លើសក្ខីកម្មរបស់ជនភៀសខ្លួន និងចំនួន ៣ លើលិខិតផ្ញើដោយឯកអគ្គរដ្ឋស្ថានទូតបារាំងប្រចាំប្រទេសថៃ[1045]។

---

[1044] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៤ ជើងទំព័រ ១៤០២ ដល់ ១៤០៥ និង កថាខណ្ឌ ៤៨៦ ជើងទំព័រ ១៤៣០។

[1045] **សក្ខីកម្មរបស់សាក្សី**៖ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ១៩ ដល់ ២០។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារលេខ E1/203.1 (SCHANBERG Sydney) ទំព័រ ៣ ដល់ ៥។ **សក្ខីកម្មរបស់**

---

**ដើមបណ្តឹងរដ្ឋប្បវេណី៖** ប្រតិចារឹកចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/152.1 (AFFONO Denise) ទំព័រ ៥៥ ដល់ ៥៦។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាងថៃ) ឯកសារលេខ E1/170.1 ទំព័រ ៥៤ ដល់ ៥៥, ៦១។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/137.1 ទំព័រ ១៩។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៥៩។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ឯកសារលេខ E1/198.1 ទំព័រ ៥។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ឯកសារលេខ E1/197.1ទំព័រ ៦៩។ ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ឯកសារលេខ E1/141.1 ទំព័រ ១៣។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៧៥ ដល់ ៧៦។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ឯកសារលេខ E1/198.1 ទំព័រ ៦៨ ដល់ ៦៩, ៧៣។ **កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី៖** កំណត់ហេតុស្តាប់ចម្លើយរបស់ ខឹម ណារ៉េត ឯកសារលេខ E3/1747 ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00206387។ កំណត់ហេតុស្តាប់ចម្លើយរបស់ នង ប៉ុណ្ណា ឯកសារលេខ E3/5131 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00165227។ កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ាង ចាន់ ឯកសារលេខ E3/5505 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00398495 ទំព័រ ៣។ **កំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖** កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុត សែម ឯកសារលេខ E3/4654 ថ្ងៃទី ១៥ ខែ តុលាការ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00390312-3 ទំព័រ ៣ ដល់ ៤។ កំណត់ហេតុស្តាប់ចម្លើយ ខៀវ ហាន ឯកសារលេខ E3/5559 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00375523 ទំព័រ ៣ ។ **ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត សែម ឯកសារលេខ E3/4689 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00358732-3 ទំព័រ ៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុក សាឯម ឯកសារលេខ E3/4724 ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00421489-90 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្នួង ឃិត ឯកសារលេខ E3/4734 ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ (ភាសាខ្មែរ) 00484412-3 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មា ឈិន ឯកសារលេខ E3/4680 ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00323594-5 ទំព័រ ១៣ ដល់ ១៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ឯកសារលេខ E3/4821 ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00523263-4 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដៃ យឺន ឯកសារលេខ E3/4824 ថ្ងៃទី ១១ ខែ មករា ឆ្នា ២០០៨ ERN (ភាសាខ្មែរ) 00523380-1ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាល់ រតនៈ ឯកសារលេខ E3/4839 ថ្ងៃទី ២០ ខែ កុម្ភៈ ២០០៨ ERN (ភាសាខ្មែរ) ERN (ភាសាខ្មែរ) 00526068-9 ទំព័រ ៤ ដល់ ៥ ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាន ញ៉ ឯកសារលេខ E3/4987 ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00556117-8 ទំព័រ ៧ ដល់ ៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស មុត ឯកសារលេខ E3/4703 ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00368981 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បេង ហឿន ឯកសារលេខ E3/4719 ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00418273 ទំព័រ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឹម ណារ៉េត ឯកសារលេខ E3/4687 ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00356378 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី HUM Ponnak ឯកសារ E3/4759 ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០ ERN (ភាសាខ្មែរ) 00490224-5ទំព័រ ១ ដល់ ២។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ម ផៃបួន *ហៅ* មុនីរ័ត្ន ឯកសារលេខ E3/4901 ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ERN (ភាសាខ្មែរ) 00541002 និង

៤២៤.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដួច នួន ជា បានរំឭកទាក់ទងទៅនឹងហេតុការណ៍ជាក់លាក់នីមួយៗនៃការសម្លាប់ មានប្រភពភស្តុតាងផ្ទាល់តែមួយគត់ ក្រោមទម្រង់ជាសក្ខីកម្មផ្ទាល់ ឬឯកសារជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។ ពុំមានវិធានទូទៅណាមួយចែងថា ប្រសិនបើពុំមានភស្តុតាងច្រើនគាំទ្រការយល់ឃើញទេនោះ ការយល់ឃើញឱ្យហួសពីវិមតិសង្ស័យមួយ ពុំអាចត្រូវបានធ្វើឡើងដោយសមហេតុផលបានឡើយ[1046]។ ផ្ទុយទៅវិញ ការយល់ឃើញមួយត្រូវបានចាត់ទុកថា សមហេតុផល គឺអាស្រ័យលើភស្តុតាង ថាតើមានភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន ដែរ ឬយ៉ាងណា។ លើសពីនេះទៀត ភស្តុតាងអំពីហេតុ

---

00541003 ទំព័រ ៨ និង ៩។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន់ ឯកសារលេខ E3/3966 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00362176 ទំព័រ ៩។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ ណារិន ឯកសារលេខ E3/4773 ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00496951-2 ទំព័រ ៣ ដល់ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភួង ផល្លា ឯកសារលេខ E3/4757 ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00484907-8 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លី វៀម ឯកសារលេខ E3/4980 ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00554819-20 ទំព័រ ៣។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាម ផា ឯកសារលេខ E3/5005 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557817ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សែម វីរៈ ឯកសារលេខ E3/4678 ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00323529-30ទំព័រ ៥ ដល់ ៦។ **របាយការណ៍របស់រដ្ឋាភិបាលបរទេស និងលិខិតរបស់ស្ថានទូត៖** របាយការណ៍របស់រដ្ឋាភិបាលន័រវេស្រេបតាមសេចក្តីសម្រេចស្តីពីសិទ្ធិមនុស្សលេខ ៩ (XXXIV) (ECOSOC) ឯកសារលេខ E3/1805 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៣២ ERN (ភាសាខ្មែរ) 00228748 (ផាម មឿន)។ លិខិតស្ថានទូតបារាំង ប្រធានបទ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ សរ ប៊ុន ឯកសារលេខ E3/2666 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499663 ទំព័រ ៣។ **ពាក្យបណ្តឹងរបស់ជនរងគ្រោះ៖**ពាក្យបណ្តឹងរបស់ជនរងគ្រោះ អៀម ទៀង ឯកសារលេខ E3/5482 ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ERN (ភាសាខ្មែរ) 00512862-3 ទំព័រ ៩ ដល់ ១០។ ពាក្យបណ្តឹងរបស់ ភួង មុំ ឯកសារលេខ E3/5416 ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480918-9 ទំព័រ ៧ ដល់ ៨។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ហេនរី ស៊ុន ឯកសារលេខ E3/5457 ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00824580-81 ទំព័រ ៩ ដល់ ១០។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ កែវ ឆែម ឯកសារលេខ E3/5407 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480203-04ទំព័រ ៧ ដល់ ៨។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ទៀង សុខុម ឯកសារលេខ E3/5402 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480111-2 ទំព័រ ៧ ដល់ ៨។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ជូ គឹមឡួន ឯកសារលេខ E3/5469 ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០ ERN (ភាសាខ្មែរ) 00506462-3 ទំព័រ ៧ ដល់ ៨។ **សក្ខីកម្មរបស់ជនភៀសខ្លួនៈ** សក្ខីកម្មរបស់ជនភៀសខ្លួនដែលប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 ERN (ភាសាខ្មែរ) 00836100-1ទំព័រ ២៣ ដល់ ២៤, ERN (ភាសាខ្មែរ) 00836120 ទំព័រ ៤៣, ERN (ភាសាខ្មែរ) 00836256 ទំព័រ ១៧៩។

[1046] *សូមមើលខាងលើ* កថាខណ្ឌ ២៩៥។

ការណ៍ជាក់លាក់នៃការសម្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ពុំគប្បីត្រូវបានវាយតម្លៃដាច់ដោយឡែកពីគ្នាឡើយ។ តម្លៃនៃភស្តុតាងនេះអាចត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងដែលពាក់ព័ន្ធទៅនឹងហេតុការណ៍នៃការសម្លាប់ដែលបានកើតឡើងក្រោមកាលៈទេសៈប្រហាក់ប្រហែលគ្នា និងតាមរយៈការបញ្ជាក់បន្ថែមនេះ អាចបំពេញតាមលក្ខខណ្ឌនៃការបង្ហាញឱ្យហួសពីវិមតិសង្ស័យបាន។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវវាយតម្លៃ ថាតើការយល់ឃើញនីមួយៗរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើឡើងដោយសមហេតុផល ដែរ ឬយ៉ាងណា។

៤២៥.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើអំណះអំណាងរបស់ នួន ជា ដែលថា "អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញអត្តសញ្ញាណរបស់*បុគ្គលណាម្នាក់*ដែលបានពិពណ៌នាថា បានឃើញ*ការសម្លាប់មួយ*ដោយផ្ទាល់ភ្នែកនោះឡើយ"[1047]។ អំណះអំណាងនេះត្រូវបដិសេធចោល។ ដូចបង្ហាញខាងក្រោម សក្ខីកម្មក្នុងតុលាការមួយចំនួនដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ ជាប់ពាក់ព័ន្ធទៅនឹងការរៀបរាប់របស់សាក្សីផ្ទាល់ភ្នែកអំពីការសម្លាប់។

### ៤.ឃ.១.ខ.១.ក.ការសម្លាប់ដោយសារការមិនធ្វើតាមបញ្ជា

៤២៦.ទាក់ទងទៅនឹងការសម្លាប់មនុស្សដែលមិនធ្វើតាមបញ្ជារបស់ខ្មែរក្រហម[1048] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយផ្អែកលើសក្ខីកម្មក្នុងតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ Denise AFFONÇO និងរបស់សាក្សី ស៊ុំ ជា ព្រមទាំងចម្លើយក្រៅតុលាការ និងភស្តុតាងជាឯកសារផងដែរ[1049]។

៤២៧.ទាក់ទងទៅនឹងភស្តុតាងក្នុងតុលាការ នួន ជា បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ ដែលបានផ្អែកជាសំខាន់លើមូលដ្ឋាននៃសេចក្តីសង្ខេបដែលមិនត្រឹមត្រូវនៃសក្ខីកម្មនេះ[1050]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅពេលផ្តល់សក្ខីកម្មភ្លាមៗក្នុងតុលាការ ពិន យ៉ាថៃ បានពិពណ៌នាថា ការជម្លៀសចេញពីទីក្រុងភ្នំពេញ មានការបង្ខំខ្លាំង ប៉ុន្តែមិនមានអំពើ

---

[1047] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៦។

[1048] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៤។

[1049] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៤ ជើងទំព័រ ១៤០២ ដល់ ១៤០៥។

[1050] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៨។

ហិង្សា[1051]។ នួន ជា បានចោទប្រកាន់ថា ពិន យ៉ាថៃ ដាក់ស្តែងពុំបានផ្តល់សក្ខីកម្មនៅក្នុងតុលាការអំពីការស្តាប់ដូចខាងលើ ប៉ុន្តែគ្រាន់តែបានអះអាងថា គាត់បានសរសេរចំណុចពាក់ព័ន្ធនេះនៅក្នុងសៀវភៅមួយប៉ុណ្ណោះ[1052]។ ទោះជាយ៉ាងណាក្តី តាមការពិនិត្យលើប្រតិចារឹកភាសាខ្មែរបង្ហាញថា សាក្សីដាក់ស្តែងពុំបានបញ្ជាក់ថាចំណុចដែលអានឱ្យគាត់ស្តាប់នោះ ត្រឹមត្រូវឡើយ[1053]។ លើសពីនេះទៀត ពិន យ៉ាថៃ បានផ្តល់សក្ខីកម្មចចាមអារ៉ាមប៉ុណ្ណោះទាក់ទងទៅនឹងមូលហេតុដែលកងទ័ពខ្មែរក្រហម បានបាញ់សម្លាប់បុរសវ័យក្មេងម្នាក់ដោយសារបុរសនោះបានប៉ុនប៉ងត្រឡប់ទៅផ្ទះវិញ។ ទោះជាយ៉ាងណាក្តី ការរៀបរាប់នេះបានផ្តល់ទម្ងន់យ៉ាងច្រើនដោយបានបង្ហាញថា កងទ័ពខ្មែរក្រហមបានបាញ់សម្លាប់ជនស៊ីវិល។ បើទោះបីជា ពិន យ៉ាថៃ ពុំបានឃើញផ្ទាល់ភ្នែកអំពីការសម្លាប់ក៏ដោយ ក៏គាត់បានឮស្នូរកាំភ្លើង និងមួយរំពេចក្រោយមកបានឃើញសាកសព និងកងទ័ពខ្មែរក្រហមម្នាក់ប្រដាប់ដោយអាវុធឈរនៅជិតសាកសពនោះស្រែកថា "នេះហើយអ្វីដែលបានកើតឡើងចំពោះអ្នកណាដែលមិនព្រមធ្វើតាម"[1054] ដោយពិចារណាឃើញថា ការរៀបរាប់ពាក់ព័ន្ធទៅនឹងការសម្លាប់បុរសវ័យក្មេងនោះ ពុំមែនចំណុចសំខាន់ក្នុងសៀវភៅ ឬសក្ខីកម្មរបស់ ពិន យ៉ាថៃ ដែលមានច្រើនផ្នែក និងជាក់លាក់នោះទេ និងថា ក្នុងឋានៈរបស់គាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពុំទទួលបានអត្ថប្រយោជន៍ណាមួយនោះ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សក្ខីកម្មត្រង់ផ្នែកជាក់លាក់នេះមានហេតុផលត្រឹមត្រូវ និងអាចជឿជាក់បាន។ គួរកត់សម្គាល់ផងដែរនៅក្នុងបរិបទនេះថា នួន ជា បានបដិសេធក្នុងការសួរដេញដោល ពិន យ៉ាថៃ នៅក្នុងពេលសវនាការ[1055]។

---

[1051] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៥ ដល់ ៦, ១២ ដល់ ១៣, ១៧ ដល់ ១៨ និង ២២ ដល់ ២៣។

[1052] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៨។

[1053] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៤៣ (ជួរ ២៥) និង ៤៤ (ជួរ)( តើចម្លើយរបស់លោកនៅពេលនេះ ថាតើដូច្នេះមែន ដែរ ឬទេ អ្វីដែលលោកបានឃើញនៅពេលនោះ?)។ ការដែលថា សហព្រះរាជអាជ្ញាបានបញ្ជាក់នូវការបកស្រាយរបស់ នួន ជា អំពីការសួរសំណួរពីមុននោះ ជាការពុំជាប់ពាក់ព័ន្ធឡើយ។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៤៧។

[1054] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៤៤។

[1055] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៥៥។

01358189



៤២៨.ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី Denise AFFONÇO ដែលផ្តល់សក្ខីកម្មអំពីការសម្លាប់មិត្តរួមសាលាម្នាក់[1056] នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់នៅក្នុងសេចក្តីសង្ខេបនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះថា ភស្តុតាងរបស់លោកស្រី គឺជាភស្តុតាងចចាមអារ៉ាមនោះទេ[1057]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បើទោះបីជា ដើមបណ្តឹងរដ្ឋប្បវេណី Denise AFFONÇO ពុំបានឃើញផ្ទាល់ភ្នែកនូវការសម្លាប់មិត្តរួមសាលារបស់គាត់យ៉ាងណាក៏ដោយ ក៏សក្ខីកម្មរបស់គាត់បានរៀបរាប់លម្អិតក្នុងកម្រិតមួយដែលសមហេតុផល បង្ហាញឱ្យជឿបានថា ទំនងជាមានការសម្លាប់មិត្តរួមសាលារបស់គាត់នៅក្នុងកាលៈទេសៈដែលគាត់បានពិពណ៌នានោះមែន[1058]។ ទោះជាយ៉ាងណាក៏ដោយ ដោយសារសក្ខីកម្មរបស់គាត់មានលក្ខណៈជាពាក្យចចាមអារ៉ាម និងពុំមានភាពច្បាស់លាស់ទាក់ទងទៅនឹងប្រភពនៃការដឹងរបស់គាត់ ដែលអង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយនោះ សក្ខីកម្មរបស់ Denise AFFONÇO ពុំមានមូលដ្ឋានគ្រប់គ្រាន់បង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យថា មានការសម្លាប់មិត្តរួមសាលារបស់គាត់បានកើតឡើងនោះឡើយ។ ទោះជាយ៉ាងណាក្តី សក្ខីកម្មនេះអាចបញ្ជាក់បន្ថែមទៅលើការរៀបរាប់របស់ ពិន យ៉ាថៃ ត្រង់ថា បានពិពណ៌នាអំពីការសម្លាប់ក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា។

៤២៩.ទាក់ទងទៅនឹងសាក្សី ស៊ុំ ជា ដែលបានផ្តល់សក្ខីកម្មថា ប្រធានកងវរសេនាតូចបានប្រាប់គាត់ថា ប្រជាជនដែលរឹងទទឹងនឹងការជម្លៀសនេះត្រូវបានបាញ់សម្លាប់“អាហ្នឹងគេធ្វើបាបមួយពីរទៅ គេបាញ់មួយពីរទៅ បានលឿនតែម្តងប្រជាជន” និងថា ការវាយធ្វើបាបមកលើប្រជាជនពីសំណាក់កងទ័ពមកពីបូព៌ាខ្លាំងជាងគេនោះ[1059] នួន ជា បានអះអាងថា សក្ខីកម្មរបស់សាក្សីរូបនេះ គឺជាហេតុផលមួយផ្សេងទៀតដែលអង្គជំនុំជម្រះសាលាដំបូងគប្បីកោះហៅ ហេង សំរិន មកផ្តល់សក្ខីកម្ម[1060]។ ទោះជាយ៉ាងណាក្តី ដោយសារភាពអាចជឿ

---

[1056] ប្រតិចារឹកចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៥៦។

[1057] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៧។

[1058] ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៥៦៖ “នៅក្នុងសង្កាត់យើងមិនមានអ្នកណាជំទាស់ទេ យើងគោរពតាមបញ្ជាទាំងអស់។ ប៉ុន្តែក្រោយមកទៀតអ្នកដែលនៅហ្នឹងទៀតមិត្តភក្តិខ្ញុំនៅរៀននៅវិទ្យាល័យនោះ ដែលគាត់នៅភ្នំពេញដើម្បីចាំប្តីគាត់នោះ ប្តីគាត់មិនដែលត្រឡប់មកវិញទេ។ ហើយគាត់ ខ្លួនគាត់ មិត្តភក្តិខ្ញុំផ្ទាល់នោះក៏ត្រូវបានគេសម្លាប់ដែរសម្លាប់នៅនឹងកន្លែងតែម្តង។ ហើយដែលខ្ញុំដឹងនេះ ដោយសារបងប្អូនគាត់ហ្នឹងមកប្រាប់ខ្ញុំនៅប្រទេសបារាំងនេះ”។

[1059] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ១៩ ដល់ ២០។

[1060] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៩។ ចំពោះការជំទាស់របស់ នួន ជា ទៅនឹងភាពត្រឹមត្រូវនៃការបកប្រែភាសាអង់គ្លេសលើសក្ខីកម្មរបស់ ស៊ុំ ជា (សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ៨១៤) បន្ទាប់ពីពិនិត្យលើឯកសារដើមជា

បាននៃសក្ខីកម្មរបស់ ស៊ុំ ជា ទើបការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់សាក្សី ស៊ុំ ជា មានលក្ខណៈសមហេតុផល ហើយជាការសម្អាងដែលបញ្ជាក់បន្ថែមលើសក្ខីកម្មដោយផ្ទាល់ភ្នែករបស់ ពិន យ៉ាថៃ។ ការចោទប្រកាន់បន្ថែមរបស់ នួន ជា[1061] ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើក្នុងការយោងទៅលើភស្តុតាងរបស់កងទ័ពដែលថា ពុំមានជនស៊ីវិលណាមួយត្រូវបានសម្លាប់នោះ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិចារណារួចហើយលើសក្ខីកម្មដែលថា ពុំមានការប្រើអំពើហិង្សានោះឡើយ[1062]។

៤៣០.ភស្តុតាងដទៃទៀតដែលគាំទ្រការយល់ឃើញថា ជនស៊ីវិលដែលមិនស្តាប់តាមបញ្ជារបស់ខ្មែរក្រហមត្រូវបានបាញ់សម្លាប់ គឺជាភស្តុតាងក្រៅតុលាការ ដូចជារបាយការណ៍របស់រដ្ឋាភិបាលន័រវេ (Norwegian Government) ផ្ញើទៅកាន់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សទាក់ទងទៅនឹងការរៀបរាប់អំពីការសម្លាប់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ លិខិតចេញពីស្ថានទូតបារាំងប្រចាំប្រទេសថៃទាក់ទងទៅនឹងការរៀបរាប់របស់ឧត្តមសេនីយ៍ សរ ប៊ុន សក្ខីកម្មរបស់ជនភៀសខ្លួន កំណត់ហេតុស្តាប់ចម្លើយប្រមូលបានក្នុងពេលស៊ើបសួរ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះ។ ភស្តុតាងនេះមានតម្លៃទាប ដែលជាការពិត អង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែទទួលស្គាល់ជាទូទៅ ប៉ុន្តែពុំអាចយកប្រើប្រាស់ជាក់ស្តែងបានឡើយ[1063]។ ទាក់ទងទៅនឹងភស្តុតាងទាំងនេះ អង្គជំនុំជម្រះសាលាដំបូងពិតជាពុំបានពន្យល់ពីមូលហេតុដែលខ្លួនពិចារណាឃើញថា បើទោះបីជាមានតម្លៃជាភស្តុតាងកម្រិតទាបក៏ដោយ ក៏ខ្លួននៅតែផ្តល់ការយល់ឃើញដោយផ្អែកលើមូលដ្ឋាននេះហួសពីវិមតិសង្ស័យទាក់ទងទៅនឹងហេតុការណ៍មួយៗនៃការសម្លាប់។ តាមការពិនិត្យលើភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានយោងនោះឃើញថា ជាញឹកញាប់ភស្តុ

---

ភាសាខ្មែរ(ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (ភាសាខ្មែរ)(ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ២០ (ជួរ ១ ដល់ ៣)) អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញមានកំហុសធំដុំក្នុងការបកប្រែឡើយ។

[1061] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៩។

[1062] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៤០២ (ដកស្រង់កំណត់ហេតុស្តាប់ចម្លើយរបស់ មាស វឿន (E3/424) ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩) កថាខណ្ឌ ៤៧៥ (“ប្រជាជនខ្លះបានលើកឡើងថា ពួកគេពុំបានឃើញការរឹងរូសមិនស្តាប់តាមបញ្ជា ឬអំពើហិង្សាដែលកើតមាននាពេលក្រោយមកនោះទេ”) និង ១៤០៦ (ដែលមានសេចក្តីយោងទៅលើសក្ខីកម្ម និងភស្តុតាងដទៃទៀតដែលថា ពុំមានអំពើហិង្សា)។

[1063] *សូមមើលខាងលើ* កថាខណ្ឌ ២៩៥ *ជាដើម*។

តាងពុំមានការរៀបរាប់លម្អិត និង/ឬជាភស្តុតាងចចាមអារ៉ាម[1064]។ អាស្រ័យហេតុនេះ បើទោះបីជាភស្តុតាងនេះបង្ហាញថា អាចមានការសម្លាប់ជនស៊ីវិលដទៃទៀតដែលពុំស្តាប់តាមបញ្ជារបស់ខ្មែរក្រហម និងថាតើ ភស្តុតាងនេះផ្តល់ការបញ្ជាក់បន្ថែមទូទៅលើសក្ខីកម្មក្នុងតុលាការ ដែរ ឬយ៉ាងណាក៏ដោយ ក៏ពុំអាចជាមូលដ្ឋានសមស្របក្នុងការយល់ឃើញឱ្យហួសពីវិមតិសង្ស័យដែលថា តាមរយៈភស្តុតាងនេះមានការសម្លាប់កើតឡើងពិតប្រាកដនោះឡើយ។

---

[1064] អំពីភស្តុតាងចចាមអារ៉ាម និង/ឬគ្មានព័ត៌មានលម្អិត *សូមមើលផងដែរ របាយការណ៍របស់រដ្ឋាភិបាលទ័រវើស្របតាមសេចក្តីសម្រេចស្តីពីសិទ្ធិមនុស្សលេខ ៩(XXXIV)* (ECOSOC) ឯកសារលេខ E3/1805 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ ទំព័រ ៣២ ERN (ភាសាខ្មែរ) 00228748 (ផាម មឿន)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មា ឈិន ឯកសារលេខ E3/4680 ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00323594-5 ទំព័រ ១៣ ដល់ ១៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ឯកសារលេខ E3/4821 ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00523263-4 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដៃ យឺន ឯកសារលេខ E3/4824 ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00523380-1 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាន ញ៉ ឯកសារលេខ E3/4987 ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00556117-8 ទំព័រ ៧ ដល់ ៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បេង ហឿន ឯកសារលេខ E3/4719 ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ERN(ភាសាខ្មែរ) 00418273-4 ទំព័រ ៥ ដល់ ៦។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី HUM Ponnak ឯកសារលេខ E3/4759 ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០ ERN (ភាសាខ្មែរ) 00490224-5 ទំព័រ ១ ដល់ ២។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ ណារិន ឯកសារលេខ E3/4773 ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00496951-2 ទំព័រ ៣ ដល់ ៤។ ពាក្យបណ្តឹងជនរងគ្រោះ កែវ ឆែម ឯកសារលេខ E3/5407 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480203-4 ទំព័រ ៧ ដល់ ៨។ ពាក្យបណ្តឹងជនរងគ្រោះ ជូ គឹមឡូន ឯកសារលេខ E3/5469 ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00506462-3 ទំព័រ ៧ ដល់ ៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាម ផា ឯកសារលេខ E3/5005 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557817-8 ទំព័រ ៤ ដល់ ៥។ លើសពីនេះទៀត ការរៀបរាប់មួយចំនួនពុំមានលក្ខណៈច្បាស់លាស់ទាក់ទងទៅនឹងបញ្ហា ថាតើអ្នករៀបរាប់នោះបានសំដៅលើការសម្លាប់ដែលខ្លួនបានឃើញ ឬបានឮ ឬសំដៅលើការគំរាមកំហែងរបស់កងទ័ពខ្មែរក្រហមដែលថា អ្នកដែលពុំធ្វើតាមបញ្ជានឹងត្រូវបាញ់សម្លាប់។ *សូមមើលឧ.* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ុក សាឯម ឯកសារលេខ E3/4724 ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00421489-90 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្នួង ឃិត ឯកសារលេខ E3/4734 ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00484412-3 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាល់ រតនៈ ឯកសារលេខ E3/4839 ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00526068-9 ទំព័រ ៤ ដល់ ៥។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836194-5 ទំព័រ ១១៧ ដល់ ១១៨។

៤៣១.បើទោះជាមានការសន្និដ្ឋានថា ភស្តុតាងក្រៅតុលាការដូចបានរៀបរាប់ខាងលើទាំងមូលពុំមែនជាមូលដ្ឋានសមស្របក្នុងការយល់ឃើញឱ្យហួសពីវិមតិសង្ស័យយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោះជាយ៉ាងនេះក្តី នៅតែមានតម្លៃសមស្របក្នុងការពិចារណាលើអំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងភស្តុតាងជាក់លាក់នេះ។

៤៣២.នួន ជា បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ស៊ាង ចាន់ ដែលបានឆ្លើយថា គាត់បានឃើញមាន"ការបាញ់សម្លាប់ប្រជាជនដោយសារពួកគេវង្វេងមិនដឹងថាត្រូវទៅផ្លូវណា"[1065]។ នួន ជា បានអះអាងថា ចម្លើយនេះពុំជាប់ពាក់ព័ន្ធទៅនឹងប្រជាជនដែលត្រូវបានសម្លាប់ ដោយសារពួកគេពុំស្តាប់តាមបញ្ជាឱ្យចាកចេញពីទីក្រុងភ្នំពេញឡើយ[1066]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងនេះពុំអាចជឿជាក់បានទេ ពីព្រោះការវង្វេងនេះអាចត្រូវបានចាត់ទុកថា ជាទម្រង់មួយនៃការមិនស្តាប់បញ្ជា។

៤៣៣.អង្គជំនុំជម្រះសាលាដំបូង បានយោងផងដែរទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ ហន ដែលបានបញ្ជាក់ថា ខ្លួនបានឃើញការបាញ់សម្លាប់ជនដែលប្រឆាំងនឹងការបង្ខំឱ្យចាកចេញនោះ[1067] និងក្នុងជើងទំព័រដដែល អង្គជំនុំជម្រះបានយោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុត សែម ដែលបាននិយាយថា បានឃើញកងទ័ពខ្មែរក្រហមបានបាញ់សម្លាប់មនុស្សពីរបីនាក់[1068]។ តាមអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា ចម្លើយនៅក្នុងកំណត់ហេតុនោះមានភាពខ្លីពេក ដែលធ្វើឱ្យតុលាការអង្គហេតុមិនអាចវាយតម្លៃអំពីភាពអាចជឿទុកចិត្តបាននោះ[1069] មានមូលដ្ឋានត្រឹមត្រូវ។ ចម្លើយអំពីការបាញ់សម្លាប់ ដែលខុសពីចម្លើយដទៃទៀតដែលបានពិពណ៌នានូវបទពិសោធន៍ផ្ទាល់ខ្លួនក្នុងអំឡុងពេល

---

[1065] កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ាង ចាន់ ឯកសារលេខ E3/5505 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ទំព័រ ៣ ERN (ភាសាខ្មែរ) 00398495។ យោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៤ ជើងទំព័រ ១៩០៤។

[1066] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣០៣។

[1067] កំណត់ហេតុស្តាប់ចម្លើយ ខៀវ ហន ឯកសារលេខ E3/5559 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00375523 ទំព័រ ៣។ យោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៤ ជើងទំព័រ ១៩០៤។

[1068] កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុត សែម ឯកសារលេខ E3/4654 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩ ERN ERN (ភាសាខ្មែរ) 00390311-2 ទំព័រ ៣ ដល់ ៤ ។ យោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៤ ជើងទំព័រ ១៩០៤។

[1069] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣០៤ ដល់ ៣០៥។

ជម្លៀស និងបើទោះបីជាបានឃើញហេតុការណ៍ផ្ទាល់ភ្នែកអំពីការសម្លាប់មនុស្សមួយចំនួនក៏ដោយ ក៏ត្រឹមតែជាការនិយាយខ្លីៗ និងទំនងជានិទានធម្មតា ជាជាងបទពិសោធន៍ផ្ទាល់ខ្លួន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ចម្លើយទាំងនេះពុំអាចចាត់ទុកជាភស្តុតាងដែលបង្ហាញពីការសម្លាប់បានឡើយ ហើយចម្លើយនេះ ប្រសិនបើមានត្រឹមតែជាការបញ្ជាក់បន្ថែមតិចតួចអំពីការសម្លាប់ដទៃទៀតប៉ុណ្ណោះ។

៤៣៤.ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខឹម ណារ៉េត[1070] នួន ជា បានអះអាងថា ចម្លើយរបស់គាត់ គឺជាភស្តុតាងចចាមអារ៉ាមអនាមិក[1071]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខឹម ណារ៉េត បានផ្តល់ព័ត៌មានតិចតួចប៉ុណ្ណោះទាក់ទងទៅនឹងប្រភពដែលគាត់បានឮអំពីការសម្លាប់នោះ។ ដូច្នេះ កំណត់ហេតុស្តាប់ចម្លើយនេះពុំអាចយកមកធ្វើជាមូលដ្ឋានសមស្របក្នុងការយល់ឃើញអំពីការធ្វើមនុស្សឃាត ឬការបញ្ជាក់បន្ថែមទូទៅនោះឡើយ។

៤៣៥.សរុបសេចក្តីមក ទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិលដែលពុំស្តាប់តាមការបញ្ជារបស់កងទ័ពខ្មែរក្រហម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយផ្អែកទៅលើភស្តុតាងនៃការសម្លាប់មួយករណីដែល ពិន យ៉ាថៃ បានរៀបរាប់ ដូចបានបញ្ជាក់បន្ថែមដោយសក្ខីកម្មរបស់ Denise AFONÇO រួមទាំង ស៊ុំ ជា និងភស្តុតាងក្រៅតុលាការផងនោះ ពុំមានមូលដ្ឋានគ្រប់គ្រាន់បង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យឡើយ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គឺជាការបញ្ជាក់បន្ថែមលើភស្តុតាងក្នុងតុលាការ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការសម្លាប់អ្នកដែលពុំស្តាប់តាមបទបញ្ជាបានកើតឡើងនោះ ជាការសមហេតុផល។

## ៤.ឃ.១.ខ.១.ខ.ការសម្លាប់អ្នកដែលព្យាយាមត្រឡប់មកក្រោយវិញ

[1070] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខឹម ណារ៉េត ឯកសារលេខ E3/4687 ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00356378 ទំព័រ ៤ និងកំណត់ហេតុស្តាប់ចម្លើយរបស់ ខឹម ណារ៉េត ឯកសារលេខ E3/1747 ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00206387 ទំព័រ ៣។ យោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៤ ជើងទំព័រ ១៤០២។

[1071] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣០៥។

៤៣៦.ទាក់ទងទៅនឹង"ការបាញ់សម្លាប់អ្នកដែលវិងទទឹងព្យាយាមត្រឡប់មកភ្នំពេញវិញ"[1072] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយផ្អែកលើសក្ខីកម្មតែមួយគត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ដែល នួន ជា បានជំទាស់[1073]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សក្ខីកម្មរបស់ ឡាយ បូនី គឺជាភស្តុតាងប្រភេទចចាមអារ៉ាមទាក់ទងទៅនឹងមូលហេតុនៃការសម្លាប់ និងថា បើទោះបីជាសក្ខីកម្មផ្ទាល់ភ្នែកសម្រាប់ហេតុការណ៍ស្រដៀងគ្នានេះដែលអាចរកបានក៏ដោយ ក៏ពុំត្រូវបានដេញដោលនៅពេលសវនាការនោះទេ[1074]។ អាស្រ័យហេតុនេះ ដោយសារតែពុំមានការពន្យល់ណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងមូលហេតុដែលខ្លួនចាត់ទុកថា សក្ខីកម្មរបស់ ឡាយ បូនី មានភាពអាចជឿទុកចិត្តបានគ្រប់គ្រាន់នោះ ដូចនេះ ជាការពុំសមហេតុផលទេដែលថា ការយល់ឃើញដោយផ្អែកលើមូលដ្ឋាននេះបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យ។

## ៤.ឃ.១.ខ.១.គ ការសម្លាប់ដោយ"គ្មានហេតុផល"

៤៣៧.ទាក់ទងទៅនឹងការយល់ឃើញថា "មានហេតុការណ៍ដែលកងទ័ពខ្មែរក្រហមបាញ់សម្លាប់ជនស៊ីវិលជាច្រើនករណីក្នុងអំឡុងពេលនៃការជម្លៀស" បន្ថែមទៅលើភស្តុតាងក្រៅតុលាការ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦ រូប ដែលបានផ្តល់សក្ខីកម្មក្នុងពេលជំនុំជម្រះថាបានឃើញជនស៊ីវិលត្រូវបានសម្លាប់[1075]នោះ មានដូចជា យឹម សុវណ្ណ បានផ្តល់សក្ខីកម្មថា គាត់បានឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់អ្នកបើកបរយានយន្តម្នាក់ រួមទាំងហេតុការណ៍នៅផ្សារអូរឫស្សីជាកន្លែងដែលកង

---

[1072] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/137.1 និង ៧៧ ដល់ ៧៨ និងប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ២២។ កំណត់ហេតុស្តាប់ចម្លើយរបស់ ឡាយ បូនី ឯកសារលេខ E3/3958 ERN (ភាសាខ្មែរ) 00373246 ទំព័រ ៤។

[1073] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣០០។

[1074] *សូមមើលឧ.* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សែម វីរៈ ឯកសារលេខ E3/4678 ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ទំព័រ ៥ ERN (ភាសាខ្មែរ) 00356378 (យោធាខ្មែរក្រហមដែលមានកាំភ្លើង AK47s មិនរុញរានឹងសម្លាប់អ្នកដែលដើរតាមផ្លូវដែលត្រូវធ្វើដំណើរ ឬក៏ឃ្លាតឆ្ងាយពីផ្លូវនេះទេ គាត់ធ្លាប់បានឃើញការសម្លាប់បែបនេះដែរ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ HUM Ponnak ឯកសារលេខ E3/4759 ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១០ ERN (ភាសាខ្មែរ) 00490224 ទំព័រ ១ ដល់ ២ (គាត់បានឃើញអ្នកដែលប្រឆាំងបញ្ជាត្រូវខ្មែរក្រហមសម្លាប់ចោលភ្លាមៗនៅនឹងមុខគាត់)។

[1075] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២ ដល់ ១៤៦៤។

01358195



ទ័ពខ្មែរក្រហមបាញ់សោរផ្ទះ ហើយអូសមនុស្សចេញមកបាញ់ចោលនៅនឹងមាត់ទ្វារ[1076]។ យស ផល បានផ្តល់សក្ខីកម្មថា គាត់បានឃើញកងទ័ពខ្មែរក្រហម បាញ់សម្លាប់តៃកុងឡានម្នាក់នៅលើឡាន ហ្សេ.អឹម.សេ ដែលបានឈប់ជិតវត្តចិនដំដែក[1077]។ ធុច ផាន់ដារា-ស បានផ្តល់សក្ខីកម្មថា គាត់បានឮស្នូរកាំភ្លើង ក្រោយមកបានឃើញមនុស្សម្នាក់ដែលទើបតែស្លាប់ថ្មីៗ[1078]។ មុម សំអឿន បានឃើញផ្ទាល់ភ្នែកការបាញ់សម្លាប់ប្រជាជនតាមផ្លូវ[1079]។ ជុំ សុខា បានផ្តល់សក្ខីកម្មថា កងទ័ពខ្មែរក្រហម បានបាញ់សម្លាប់ប្រជាជនដែលព្យាយាមលួចអង្ករក្នុងឃ្លាំង[1080] និង ឆេង អេងលី បានផ្តល់សក្ខីកម្មថា ជិតដល់ស្ពានព្រះមុនីវង្ស គាត់បានឃើញខ្មែរក្រហមចាប់ហែកទារកជាពីរ[1081]។

៤៣៨.នួន ជា បានជំទាស់ថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ និងបានចោទប្រកាន់ថា ដើមបណ្តឹងរូបនេះពុំបានជាប់ពាក់ព័ន្ធនៅក្នុងហេតុការណ៍ដែលបានពិពណ៌នានោះទេ និងពុំបានពន្យល់ពីមូលហេតុអ្វីបានជាអ្នកបើកឡាននោះត្រូវបានបាញ់សម្លាប់ និងពុំត្រូវបានសួរដេញដោលដោយភាគីណាមួយលើការសម្លាប់នេះផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានមូលហេតុអ្វីដែលថា អង្គជំនុំជម្រះសាលាដំបូងមានហេតុផលពុំសមស្របក្នុងការសំអាងទៅលើការរៀបរាប់របស់ យឹម សុវណ្ណ នៅពេលដែលការរៀបរាប់អំពីហេតុការណ៍មួយនៃការសម្លាប់ប្រជាជនដែលបានចាក់សោរមិនព្រមចេញពីផ្ទះនៅម្តុំផ្សារអូរឫស្សី[1082] និងហេតុការណ៍មួយទៀតនៃការសម្លាប់អ្នកបើកបរឡាន[1083]។ នៅក្នុងកាលៈទេសៈនេះ ដោយពិចារណាឃើញថា យឹម សុវណ្ណ កង្វះព័ត៌មានលម្អិតអំពីការបានឃើញហេតុការណ៍តែមួយភ្លែតពេលដើរកាត់ និងកំពុងត្រូវបានជម្លៀសដោយបង្ខំ និងដោយសារកំណត់ហេតុសវនាការបានបង្ហាញថា នួន ជា ពុំត្រូវបានរារាំងមិនឱ្យសួរដេញដោលអំពីហេតុការណ៍ទាំងនេះនៅក្នុងពេលសវនាការ[1084] អង្គជំនុំ

---

[1076] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៥៩ និង ៦២។

[1077] ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ឯកសារលេខ E1/197.1 ទំព័រ ៦៤។

[1078] ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ឯកសារលេខ E1/198.1 ទំព័រ ៥។

[1079] ប្រតិចារឹកចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ឯកសារលេខ E1/141.1 ទំព័រ ១៣។

[1080] ប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៧៦។

[1081] ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ (ឆេង អេងលី) ឯកសារលេខ E1/198.1 ទំព័រ ៦៩ និង ៧៣។

[1082] ឯកសារលេខ E1/135.1 យឹម សុវណ្ណ ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៥៩។

[1083] ឯកសារលេខ E1/135.1 យឹម សុវណ្ណ ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៥៩ និង ៦២។

[1084] ឯកសារលេខ E1/135.1 យឹម សុវណ្ណ ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៨៧។

ជម្រះតុលាការកំពូល ពុំឃើញមានភាពពុំសមស្របណាមួយទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងនេះឡើយ ហើយការយល់ឃើញនេះ អនុវត្តដូចគ្នាទៅលើការជំទាស់របស់ នួន ជា ចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុម សំអឿន ផងដែរ[1085]។

៤៣៩. នួន ជា ក៏បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ក្នុងការបង្ហាញអំពីការសម្លាប់អ្នកដែលចូលលួចអង្ករនៅក្នុងឃ្លាំង[1086]។ ជុំ សុខា ក៏បានយកអង្ករមួយបាវរត់ចេញទៅផងដែរ។ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ភស្តុតាងនេះដើម្បីគាំទ្រដល់ការយល់ឃើញរបស់ខ្លួនដែលថា "មានហេតុការណ៍ច្រើនករណីដែលកងទ័ពខ្មែរក្រហមបានបាញ់សម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការជម្លៀសនោះ"[1087]។ នួន ជា បានអះអាងថា ភស្តុតាងនេះគប្បីបានគាំទ្រការយល់ឃើញដែលថា ការប្រើអំពើហិង្សានេះ គឺដើម្បីទប់ស្កាត់ចំពោះតែសកម្មភាពខុសច្បាប់ ដូចជាការលួចជាដើម[1088]។ ទោះជាយ៉ាងណាក្តី នេះគ្រាន់តែជាការបង្ហាញពីការបកស្រាយមួយបែបផ្សេងទៀតចំពោះភស្តុតាងរបស់ ជុំ សុខា ដែលមានភាពជឿជាក់បាន និងពុំត្រូវបានជំទាស់ ប៉ុន្តែពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងដោយពុំសមហេតុផលលើភស្តុតាងនេះ ដើម្បីគាំទ្រការយល់ឃើញរបស់ខ្លួនដែលថា ជនស៊ីវិលត្រូវបានសម្លាប់ ជាពិសេសនៅពេលសម្លាប់ជនស៊ីវិលដោយសារហេតុផលលួចអង្ករនេះ គឺជាការឆ្លើយតបពុំសមាមាត្រ។

៤៤០.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកសំអាងនោះ គឺជាភស្តុតាងក្រៅតុលាការមានតម្លៃភស្តុតាងទាប។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងនេះពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីការសម្លាប់ឱ្យហួសពីវិមតិសង្ស័យឡើយ។ ទាក់ទងទៅនឹងការជំទាស់ជាក់លាក់ដែលសំដៅលើភស្តុតាងនីមួយៗ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅពេលបានសំអាងលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស សារ៉ាន់

---

[1085] ប្រតិចារិកថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ឯកសារលេខ E1/141.1 ទំព័រ ១៣ (មុម សំអឿន បានឃើញផ្ទាល់ភ្នែកការបាញ់សម្លាប់ប្រជាជនតាមផ្លូវ) ទំព័រ ៤៦ ដល់ ៥០ (នួន ជា ពុំបានសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណីអំពីការសម្លាប់ ឬភស្តុតាងរបស់គាត់អំពីការជម្លៀស)។

[1086] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១០។

[1087] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២។

[1088] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩១ និង ៣១០។

ពីព្រោះអង្គជំនុំជម្រះបានប្រើប្រាស់ឯកសារបកប្រែ ដែលខុសគ្នាយ៉ាងខ្លាំងពីឯកសារដើមជាភាសាខ្មែរ និង ពីព្រោះ មាស សារ៉ាន់ បានអះអាងក្នុងតុលាការថា ត្រឹមតែបានឃើញគេយកមនុស្សចេញទៅប៉ុណ្ណោះ ដែល ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលស្គាល់ និងពុំបានធ្វើការពិចារណាឡើយ[1089]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជាការពិត មានភាពខុសគ្នាយ៉ាងខ្លាំងរវាងសំណៅដើមជាភាសាខ្មែរ ក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស សារ៉ាន់ ដែលថា ("នៅតាមផ្លូវ ខ្ញុំបានឃើញមនុស្ស ជាច្រើនដែល*ត្រូវបានគេយកទៅសម្លាប់*ជាហូរហែរដោយមិនដឹងមូលហេតុ"[1090] ជាមួយនឹងសំណៅបកប្រែជា ភាសាអង់គ្លេសដែលថា ("[a]long the road [on his travel from Phnom Penh to Battambang], I saw many people *were unreasonably killed*" (បកប្រែមកភាសាខ្មែរថា "នៅតាមផ្លូវដែល(គាត់ធ្វើដំណើរពីភ្នំពេញទៅបាត់ដំបង) ខ្ញុំបានឃើញមនុស្សច្រើននាក់*ត្រូវបានសម្លាប់*ដោយមិនដឹងពីមូលហេតុ") ប៉ុន្តែ យោង តាមសំណៅដើមដែលស្របជាមួយប្រតិចារឹកនៃសក្ខីកម្មក្នុងតុលាការថា "ខ្ញុំឃើញតែ*គេយកមនុស្សចេញ*ពីអ្នក ដែលដើរដំណើរជាមួយខ្ញុំ"[1091] ដែលនេះបញ្ជាក់ថា គាត់ពុំបានសង្កេតមើលការសម្លាប់ជាក់ស្តែង ឬឃើញសាក សពឡើយ ប៉ុន្តែត្រឹមតែសន្មតថា ប្រជាជនត្រូវបានសម្លាប់។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណា ឃើញថា ជាការពុំសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសេចក្តីដកស្រង់នៃចម្លើយរបស់ មាស សារ៉ាន់ ដោយពុំបានដោះស្រាយលើសំណៅដើមភាសាខ្មែរនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មក្នុងតុលាការ។

៤៤១.នួន ជា បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើការរៀបរាប់របស់ជនភៀសខ្លួន របស់ ពេជ្រ លីមកុង[1092]។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើការរៀបរាប់ដើម្បីគាំទ្រការយល់ឃើញ របស់ខ្លួនដែលថា មនុស្សទាំងអស់ត្រូវបានបង្ខំឱ្យចាកចេញ រួមទាំង"អ្នកជំងឺ និងអ្នករបួសចេញពីមន្ទីរពេទ្យ ក្រុង"[1093] និងថា ខ្មែរក្រហមបានសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលជម្លៀស ដូចជាអ្នកដែលខ្សោយពុំអាចបន្ត

---

[1089] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៤។

[1090] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ឯកសារលេខ E3/3966 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00362176 ទំព័រ ៤។

[1091] ប្រតិចារឹកចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មាស សារ៉ាន់) ឯកសារលេខ E1/145.1 ទំព័រ ២៩។

[1092] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៦។

[1093] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៦ ជើងទំព័រ ១៤១១។

ដំណើរទៅមុខបានផងដែរ[1094]។ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានវាយតម្លៃលើភាពអាចជឿទុកចិត្តបាននៃការរៀបរាប់នេះ បើទោះបីជាប្រភពផ្តល់ព័ត៌មាននៃការរៀបរាប់របស់ ពេជ្រ លឹមកុង មានមន្ទិលសង្ស័យក៏ដោយ[1095]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជនអៀសខ្លួន ពេជ លឹមគួន និង ពេជ្រ លឹមកុង(នៅសាលាដំបូង) ទំនងជាមនុស្សតែម្នាក់ដូចការកត់សម្គាល់របស់ នួន ជា[1096]។ ដូចដែល នួន ជា បានកត់សម្គាល់ត្រឹមត្រូវថា ពេជ្រ លឹមកុង(នៅសាលាដំបូង)/ពេជ លឹមគួន ពុំអាចឃើញដោយផ្ទាល់នូវការសម្លាប់នោះបានឡើយ ដោយសារ ពេជ្រ លឹមកុង(នៅសាលាដំបូង)/ពេជ លឹមគួន ទើបតែបានមកដល់ទីក្រុងភ្នំពេញភ្លាមៗក្រោយការជម្លៀស[1097]។ ទោះជាយ៉ាងនេះក្តី ផ្ទុយទៅនឹងការលើកឡើងរបស់ នួន ជា[1098] អង្គជំនុំជម្រះសាលាដំបូងពុំដែលបញ្ជាក់ថា ជនអៀសខ្លួនរូបនេះជាក់ស្តែងពិតជា“បានឃើញ”ហេតុការណ៍នេះទេ[1099]។ ប្រហាក់ប្រហែលគ្នានេះដែរ ការជំទាស់របស់ នួន ជា ទៅនឹងភាពគួរឱ្យទុកចិត្តបានរបស់ ពេជ្រ លឹមកុង(នៅសាលាដំបូង)/ពេជ លឹមគួន ពុំអាចជឿជាក់បានឡើយ ដោយបានផ្អែកលើការភាន់ច្រឡំទាក់ទងទៅនឹងថ្នាក់ដឹកនាំរបស់ ប.ក.ក. ដែលនេះពុំជាប់ពាក់ព័ន្ធទៅនឹងផ្នែកនៃការរៀបរាប់ដែលអង្គជំនុំជម្រះសាលដំបូងបាន

---

[1094] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២។

[1095] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៦។

[1096] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៦។ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៣៤ និង ៧០ ដល់ ៧២ (សេចក្តីយោងនេះត្រូវបានកែប្រែឱ្យស្របតាមសំដៅដែលបានកែតម្រូវ)។

[1097] *សូមមើល* កិច្ចសម្ភាសន៍ជាមួយ ពេជ លឹមគួន ឯកសារលេខ E3/4060 ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៧៦ (En) (ភាសាខ្មែរ) 00823179 ទំព័រ ១ (លឹមគួន “ត្រូវបានចាត់ឱ្យទៅធ្វើការនៅព្រលានយន្តហោះពោធិចិនតុង[ក្នុងទីក្រុងភ្នំពេញ]នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៥” អាស្រ័យហេតុនេះ ពុំទំនងជាថា គាត់បាននៅក្នុងទីក្រុងភ្នំពេញនៅពេលដែលអ្នកជំងឺត្រូវបានបង្ខំឱ្យចេញពីមន្ទីរពេទ្យឡើយ) (En) (ភាសាខ្មែរ) 00823180 ទំព័រ ២ (តាមរបាយការណ៍ គាត់បានអះអាងថា មានមិត្តភក្តិរបស់គាត់មួយចំនួនបានប្រាប់ថាមានការសម្លាប់មនុស្ស ប៉ុន្តែគាត់ពុំដែលឃើញគេសម្លាប់ម្តងណាឡើយ)។

[1098] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៦។

[1099] ផ្ទុយទៅវិញ យោងតាមអង្គជំនុំជម្រះសាលាដំបូង ណុប ថុល គឺជាអ្នក“បានឃើញ”អ្នកជំងឺត្រូវបានដេញចេញពីមន្ទីរពេទ្យៈ សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៦ ជើងទំព័រ ១៤១១ យោងទៅលើសក្ខីកម្មរបស់ជនអៀសខ្លួនដែលប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 ERN (ភាសាខ្មែរ) 00836295 ទំព័រ ២១៨។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញឈ្មោះ ណុប ថុល ឡើយ នៅពេលយោងទៅលើការរៀបរាប់នេះ ដូច្នេះធ្វើឱ្យមានការច្រឡំថា ជាការរៀបរាប់របស់ ពេជ លឹមគង់។

01358199



សំអាងនោះឡើយ។ សរុបសេចក្ដីមក អំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើកាលៈទេសៈជាក់លាក់ដែលប៉ះពាល់ដល់ភាពគួរឱ្យទុកចិត្តបានរបស់ ពេជ្រ លឹមកុង(នៅសាលាដំបូង)/ពេជ លឹមគួន ពុំទទួលបានជោគជ័យ។ ដូចបានកត់សម្គាល់ខាងលើ ដោយសារការរៀបរាប់នេះ គឺជាពាក្យចចាមអារ៉ាម និងពុំត្រូវបានសួរដេញដោលក្នុងតុលាការ ទើបពុំអាចបង្ហាញការសម្លាប់នេះឱ្យហួសពីវិមតិសង្ស័យ ដូច្នេះពុំអាចគាំទ្រដល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ទាហានខ្មែរក្រហមបានបាញ់ស្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការជម្លៀស រួមទាំង"អ្នកដែលខ្សោយកម្លាំងមិនអាចបន្តដំណើរទៅមុខបានផងដែរ"[1100]។

៤៤២.នួន ជា ក៏បានជំទាស់ផងដែរ[1101]ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលផ្អែកលើការរៀបរាប់របស់ជនភៀសខ្លួនដែលបានកត់ត្រាដោយ François PONCHAUD ដែលថា តារាភាពយន្តដ៏ល្បីម្នាក់ឈ្មោះ គង់ សាវួន(នៅសាលាដំបូង) ឬ គង់ សំអឿន[1102]ត្រូវបានខ្មែរក្រហមកាត់ក្បាលនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[1103]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយោងពុំត្រឹមត្រូវទៅលើភស្តុតាង បើតាមភស្តុតាងដែលឯកសារដើមជាភាសាបារាំងនៃសក្ខីកម្មរបស់ជនភៀសខ្លួនបានបញ្ជាក់ច្បាស់ថា អ្នកដែលត្រូវបានខ្មែរក្រហមកាត់ក្បាលនោះ គឺជាឱសថការីម្នាក់ មិនមែន គង់ សាវួន(នៅសាលាដំបូង) ឬ គង់ សំអឿន នោះទេ[1104]។ បន្ថែមលើនេះទៀត ផ្ទុយទៅនឹងសារណារបស់សហព្រះរាជអាជ្ញា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ ពុំបានបញ្ជាក់បន្ថែមលើភ

---

[1100] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០។

[1101] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៧។

[1102] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការរៀបរាប់របស់ជនភៀសខ្លួនដែលបានកត់ត្រាដោយ François PONCHAUD មានឈ្មោះ"គង់ សាវួន" ហើយឈ្មោះនេះក៏ត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងផងដែរ។ ផ្ទុយទៅវិញ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ប៉ាល់ រតនៈ E3/4839 ERN (ភាសាខ្មែរ) 00526069 ទំព័រ ៦ មានឈ្មោះ "គង់ សំអឿន"ជាតារាភាពយន្តដ៏ល្បីល្បាញ ហើយទំនងជាថា François PONCHAUD ធ្វើការកត់ត្រាពុំបានត្រឹមត្រូវ។

[1103] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២ យោងទៅលើសក្ខីកម្មរបស់ជនភៀសខ្លួន ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារលេខ E3/4590 ERN (ភាសាខ្មែរ) 00836101ទំព័រ ២៥។

[1104] *សូមមើល* សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារលេខ E3/4590 ERN (ភាសាខ្មែរ) 00836095-6 ទំព័រ ១៨៖ "មានអ្នកតវ៉ា ជាពិសេសឱសថការីម្នាក់៖ ខ្មែរក្រហមកាត់ក្បាលគាត់ ហើយទុកសពចោលលើផ្លូវ" ទំព័រ ២២ ERN (ភាសាបារាំង) 00410357៖ "*Des gens rouspètent, notamment un pharmacien: les KR lui coupent la tête, et laissent le cadavre sur la route*"។

ស្តុតាងទាក់ទងទៅនឹងការស្លាប់របស់(គង់ សាវួន(នៅសាលាដំបូង) ឬ គង់ សំអឿន)ឡើយ[1105]។ បើទោះបីជាសក្ខីកម្មរបស់ជនភៀសខ្លួនបញ្ជាក់ថា ខ្មែរក្រហមបានកាត់ក្បាលជនស៊ីវិលដោយខុសច្បាប់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង នួន ជា ត្រង់ថា ពុំមានលក្ខណៈច្បាស់លាស់ ថាតើបុគ្គលដែលបានរៀបរាប់នោះ ជាសាក្សីបានឃើញហេតុការណ៍ផ្ទាល់ភ្នែក ដែរ ឬយ៉ាងណា។ ប្រភពព័ត៌មានអនាមិករួមជាមួយនឹងភស្តុតាងដែលជាពាក្យចចាមអារ៉ាមតគ្នាពីរដង ពុំអាចយកមកធ្វើជាមូលដ្ឋានរឹងមាំដើម្បីផ្តល់ការយល់ឃើញអំពីការសម្លាប់ដោយផ្អែកលើភស្តុតាងនេះបានឡើយ។

៤៤៣.ដើម្បីគាំទ្រការយល់ឃើញដែលថា "អ្នកដែលខ្សោយកម្លាំងមិនអាចបន្តដំណើរទៅមុខបាន" ក៏ត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់ដែរនោះ អង្គជំនុំជម្រះសាលាដំបូងយោងនៅក្នុងជើងទំព័រ*ក្នុងចំណោមនោះ*ទៅលើការរៀបរាប់របស់ឧត្តមសេនីយ៍ សរ ប៊ុន ដែលត្រូវបានកត់ត្រានៅក្នុងលិខិតរបស់អគ្គរដ្ឋទូតបារាំងប្រចាំប្រទេសថៃដែលថា"ជនណាដែលមិនចង់ ឬមិនអាចជម្លៀសបាន ក៏ត្រូវបានពួកខ្មែរក្រហមសម្លាប់ចោលផងដែរ"[1106]។ នួន ជា បានអះអាងថា ភស្តុតាង គឺជា"ពាក្យចចាមអារ៉ាមតគ្នាពីរដង" និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានសម្របសម្រួលការរៀបរាប់របស់ សរ ប៊ុន ឱ្យស៊ីសង្វាក់គ្នាជាមួយនឹងការយល់ឃើញរបស់ខ្លួន និងពុំបានពិចារណាអំពីភាពអាចជឿទុកចិត្តបានរបស់ សរ ប៊ុន ឡើយ ប៉ុន្តែ នៅក្នុងការយល់ឃើញបានសំអាងលើការរៀបរាប់នេះ"ដែលហាក់ដូចជាគ្មានបញ្ហា និង ជាមូលដ្ឋានតែមួយគត់"[1107]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ឧត្តមសេនីយ៍ សរ ប៊ុន ត្រូវបានស្គាល់ថា ជាសាក្សីផ្ទាល់ភ្នែកលើការសម្លាប់អ្នកដែលមិនចង់ ឬមិនអាចជម្លៀសបាន និងបានឃើញសាកសពជាច្រើនរាយប៉ាយនៅតាមដងផ្លូវ[1108]។ កំណត់ហេតុនៃសក្ខីកម្មរបស់ សរ ប៊ុន ស្ទើរតែគួរឱ្យជឿជាក់បាន ហើយចំណុចខ្លះបានរៀបរាប់លម្អិតទៀតផង ប៉ុន្តែ ឃើញថា កំណត់ហេតុនេះពុំបានធ្វើឡើងក្រោមសម្បថ និងពុំបានសួរដេញដោលឡើយ ហើយត្រូវបានធ្វើឡើងដោយតតីយជនសម្រាប់គោលបំណងផ្សេង ដែលមិនមែនជាគោលបំណងនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងខ្វះភាព

---

[1105] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាល់ រតនៈ ឯកសារលេខ E3/4839 ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00526069 ទំព័រ ៦។

[1106] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២។

[1107] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៨។

[1108] លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុៈ សក្ខីកម្មរបស់ឧត្តមសេនីយ៍ សរ ប៊ុន ឯកសារលេខ E3/2666 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499663-4 ទំព័រ ៣ ដល់ ៤។

ជាក់លាក់ទាក់ទងទៅនឹងការសម្លាប់ដែល សរ ប៊ុន បានអះអាងថា បានឃើញដោយផ្ទាល់ភ្នែក ព្រមទាំងភាពមិនច្បាស់លាស់ ថាតើមានហេតុការណ៍នៃការសម្លាប់មួយ ឬច្រើនករណីនោះឡើយ។ អាស្រ័យហេតុនេះ ជាការពុំសមហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងលើឯកសារនេះសម្រាប់ការយល់ឃើញថា អ្នកណាដែលខ្សោយពុំអាចបន្តដំណើរទៅមុខបានត្រូវបានកងទ័ពខ្មែរក្រហមបាញ់សម្លាប់ក្នុងអំឡុងពេលនៃការជម្លៀសនោះឡើយ[1109]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា ការយល់ឃើញនេះពុំមានការគាំទ្រពីសក្ខីកម្មផ្ទាល់ ឬកំណត់ហេតុស្តាប់ចម្លើយណាមួយឡើយ។ បើផ្អែកលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន[1110]ឃើញថា សក្ខីកម្មនេះអាចមានអត្ថិភាព ប៉ុន្តែពុំត្រូវបានចាត់ចែងឱ្យមានការដេញដោលនៅពេលជំនុំជម្រះឡើយ។

៤៤៤.កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី នង ប៉ុណ្ណា គឺជាប្រភពមួយក្នុងចំណោមប្រភពជាច្រើន ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ក្នុងការគាំទ្រដល់ការយល់ឃើញរបស់ខ្លួនដែលថាមានហេតុការណ៍ជាច្រើនករណីដែលខ្មែរក្រហមបានបាញ់សម្លាប់ជនស៊ីវិល[1111]។ យោងតាមកំណត់ហេតុនេះបានសរសេរថា "អត់ធ្វើអីទេក្នុងវត្ត គ្រាន់តែបញ្ជាឱ្យចេញ តែនៅខាងក្រៅវត្ត មានគេបាញ់សម្លាប់មនុស្ស"[1112]។ នួន ជា បានអះអាងថា កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរនេះ ខ្វះសេចក្តីលម្អិតទាក់ទងទៅនឹងការសម្លាប់ទាំងនោះ និងថា សាក្សីរូបនេះពុំបានពន្យល់ ថាតើខ្លួនបានដឹងអំពីការសម្លាប់នោះដូចម្តេចឡើយ[1113]។ ការរៀបរាប់នេះពិតជាខ្វះសេចក្តីលម្អិតប្រាកដមែនទាក់ទងទៅនឹងការបាញ់សម្លាប់នោះ និងទំនងជាភស្តុតាងចចាមអារ៉ាមដែលមានតម្លៃជាភស្តុតាងទាប។

---

1109 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០។

1110 *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២។

1111 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩០ ជើងទំព័រ ១៤៦២។ *សូមមើលផងដែរខាងលើ* កថាខណ្ឌ ៤៣៧ *ជាអាទិ៍* ដែលពិភាក្សាអំណះអំណាងទាក់ទងទៅនឹងការយល់ឃើញដែលមាននៅក្នុងកថាខណ្ឌដដែលនេះ។

1112 កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ នង ប៉ុណ្ណា ឯកសារលេខ E3/5131 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00165226 ទំព័រ ២។

1113 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១២។

01358202



៤៤៥.ផ្ទុយទៅនឹងសារណារបស់ នួន ជា[1114] ពុំមានសញ្ញាណាមួយបង្ហាញថា ការសម្លាប់ណាមួយដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកសំអាងនោះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ ឬអាចធ្វើយុត្តិកម្មបានថា ជាការចាំបាច់ផ្នែកយោធាឡើយ។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនពុំបានសំអាងលើការសម្លាប់ដែល"អាចមានហេតុផលថា ដោយសារស្ថានភាពប្រយុទ្ធគ្នា" ឬក្នុងករណីដែលពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់បង្ហាញឱ្យឃើញថា មាន ឬគ្មានការប្រយុទ្ធនោះឡើយ[1115]។ ទាក់ទងទៅនឹងការអះអាងរបស់ នួន ជា ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងដោយពុំសមហេតុផលលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះក្នុងការយល់ឃើញថា មានការសម្លាប់ដោយ"គ្មានមូលហេតុទាល់តែសោះ" ដែលនេះមានន័យថា មិនអាចចាត់ទុកថា ជាការសម្លាប់ដោយខុសច្បាប់នោះឡើយ[1116] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះធ្លាប់បានយល់ឃើញហើយថា នៅគ្រប់កាលៈទេសៈទាំងអស់ ការយល់ឃើញអំពីការសម្លាប់ដែលបានសំអាងទៅលើភស្តុតាងប្រភេទនេះ ជាការពុំសមហេតុផល និងអាស្រ័យហេតុនេះ ពុំចាំបាច់ដោះស្រាយលើអំណះអំណាងរបស់ នួន ជា តទៅទៀតឡើយ។ ទោះជាយ៉ាងណាក្តី ការសម្លាប់ជនស៊ីវិលបើទោះជាស្ថិតនៅក្នុងស្ថានភាពប្រយុទ្ធគ្នាក៏ដោយ ក៏ពុំអាចសន្មតថាជាការសម្លាប់ស្របច្បាប់បានឡើយ។

៤៤៦.អាស្រ័យហេតុនេះ នៅពេលការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការសម្លាប់បានផ្អែកលើសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែក និងដោយមានការបញ្ជាក់បន្ថែមទៅវិញទៅមក ព្រមទាំងមានការបញ្ជាក់បន្ថែមពីភស្តុតាងមិនផ្ទាល់របស់សាក្សី និងភស្តុតាងជាឯកសារ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ពុំមានតុលាការអង្គហេតុសមស្របណាមួយអាចសន្និដ្ឋានបានថា ការសម្លាប់ទាំងនោះត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ ពីព្រោះមានការរៀបរាប់មួយចំពោះករណីនីមួយៗនៃការសម្លាប់នោះ។ កាន់តែមានលក្ខណៈស្របជាមួយនឹងការអនុវត្តត្រឹមត្រូវ និងស្របតាមគោលការណ៍នៃការជំនុំជម្រះដោយត្រឹមត្រូវថែមទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់នូវការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងករណីនៃការសម្លាប់មួយៗ និងបានពន្យល់មូលហេតុដែលសក្ខី

[1114] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩៤។

[1115] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៤។

[1116] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣១៣។

កម្មផ្ទាល់នេះត្រូវបានបញ្ជាក់បន្ថែមពីភស្តុតាងដទៃទៀត[1117]។ ទោះជាយ៉ាងណាក្តី បើទោះបីជាសន្មតថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងទាំងអស់ដែលខ្លួនបានយោងនោះ ដោយពុំបានបញ្ជាក់លម្អិតលើមូលដ្ឋាននៃការយល់ឃើញអំពីការសម្លាប់មួយៗ ដូច នួន ជា អះអាងនោះក៏ដោយ[1118] ក៏ពុំមែនជាកំហុសអង្គច្បាប់ធ្ងន់ធ្ងរដែលនាំឱ្យមោឃៈសាលក្រមឡើយ លើកលែងតែមានការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងទទួលយកភស្តុតាងទាំងនេះដោយពុំសមហេតុផល។

៤៤៧.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ នួន ជា អាចជឿជាក់បាននៅត្រង់ចំណុចថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញផ្នែកអង្គហេតុពាក់ព័ន្ធទៅនឹងហេតុការណ៍ជាក់លាក់នៃការសម្លាប់ដោយផ្អែកលើភស្តុតាងក្រៅតុលាការ និងដោយគ្មានការពន្យល់អំពីមូលហេតុណាមួយទាក់ទងទៅនឹងការវាយតម្លៃភស្តុតាងនេះ ដែលថាមានតម្លៃជាភស្តុតាងទាបជាងតម្លៃនៃភស្តុតាងក្នុងតុលាការ និងបន្ថែមលើនេះទៀត ជាទូទៅពុំសូវមានភាពជាក់លាក់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញទូទៅរបស់អង្គជំនុំជម្រះសាលាដំបូង នៅតែមានមូលដ្ឋានសមស្រប និងគ្រប់គ្រាន់ផ្អែកតាមភស្តុតាងក្នុងតុលាការដែលថា ជនស៊ីវិលត្រូវបានសម្លាប់ដោយគ្មានមូលហេតុ នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។

៤៤៨.ដោយហេតុថា ភស្តុតាងជាលាយលក្ខណ៍អក្សរបានបញ្ជាក់ច្បាស់ថា មានការសម្លាប់រីករាលដាលជាងការបង្ហាញទៅទៀត ហើយភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាទាក់ទងទៅនឹងចំនួននៃការសម្លាប់ ភាពញឹកញាប់ និងកាលៈទេសៈនោះ ពុំមែនជាមូលដ្ឋានសំអាងសមស្របក្នុងការសន្និដ្ឋានអំពីចំនួនជនរងគ្រោះ លំនាំ ឬទំហំធំធេងនៃការសម្លាប់នោះឡើយ។ អាស្រ័យហេតុនេះ ការពុំបានវាយតម្លៃលើភស្តុតាងរបស់អតីតកងទ័ពខ្មែរក្រហមដែលថា ពុំមានការបញ្ជាឱ្យសម្លាប់ជនស៊ីវិល ព្រមទាំងការពុំបានថ្លឹងថ្លែងភស្តុតាងរបស់ជនរងគ្រោះ ដែលពុំបានជួបប្រទះការប្រើហិង្សាក្នុងអំឡុងពេលនៃការជម្លៀសនោះ គឺជាការពុំសម

---

[1117] *សូមមើល* សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៧៣ "ផ្តល់ការយល់ឃើញផ្នែកអង្គហេតុទាក់ទងទៅនឹងហេតុការណ៍នីមួយៗ [...] ជាវិធីសាស្ត្រសមស្រប។ ជនជាប់ចោទមានសិទ្ធិដឹងថា តើខ្លួនត្រូវបានដាក់ពិរុទ្ធភាពពីបទល្មើសមួយទាក់ទងទៅនឹងហេតុការណ៍ដែលចោទប្រកាន់នោះស្របតាមគោលការណ៍នៃការជំនុំជម្រះដោយត្រឹមត្រូវ ដែរ ឬយ៉ាងណា" ដោយហេតុថា ការបញ្ជាក់នេះសំដៅលើការចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដូច្នេះជនជាប់ចោទមានសិទ្ធិដឹងថា តើខ្លួនត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីហេតុការណ៍ដែលបានរៀបរាប់នៅក្នុងសាលក្រម ដែរ ឬយ៉ាងណា។

[1118] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៩១។

ហេតុផល ដូចនេះបង្ហាញឱ្យឃើញថា ជាអប្បបរមា បទបញ្ជាឱ្យសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលជម្លៀស ពុំត្រូវបានដាក់ចេញ ឬអនុវត្តដោយទៀងទាត់ឡើយ។

## ៤.ឃ.១.ខ.២.ការស្លាប់ដោយសារលក្ខខណ្ឌក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ

៤៤៩.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "[ជនរងគ្រោះជាច្រើន បានស្លាប់នៅតាមផ្លូវផងដែរដោយសារមូលហេតុផ្សេងៗ រួមទាំងជំងឺដែលបណ្ដាលមកពីកងទ័ពខ្មែរក្រហមពុំបានផ្ដល់ចំណីអាហារ ទឹក ជំនួយវេជ្ជសាស្ត្រ ជម្រក ឬសម្ភារអនាម័យដល់អ្នកដែលត្រូវបានជម្លៀសទាំងនោះ"[1119] និងថា "ការស្លាប់របស់ [...] អ្នកដែលបានស្លាប់ដោយសារលក្ខខណ្ឌផ្សេងៗ និងការខ្វះការផ្ដល់ជំនួយ គឺជាការធ្វើមនុស្សឃាត"[1120]។ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់សេចក្ដីសន្និដ្ឋាន អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការយល់ឃើញផ្នែកអង្គហេតុនៅក្នុងសាលក្រមរបស់ខ្លួន[1121] ជាពិសេសបានយល់ឃើញថា "អ្នកដែលត្រូវបានជម្លៀសទាំងនោះ ក៏បានជួបប្រទះនូវលក្ខខណ្ឌដ៏លំបាកនៅក្នុងអំឡុងពេលធ្វើដំណើររបស់ពួកគេ ដូចជា ស្ថិតនៅក្រោមកម្ដៅថ្ងៃខ្លាំង ខ្វះស្បៀងអាហារ ទឹកស្អាត ថ្នាំពេទ្យ ឬជម្រកស្នាក់នៅគ្រប់គ្រាន់។ ដោយត្រូវបានបណ្ដេញចេញនៅក្នុងរដូវក្ដៅ ហើយត្រូវបានបង្ខំឲ្យដើរអស់រយៈពេលជាច្រើនថ្ងៃ ឬក៏អាចច្រើនសប្ដាហ៍ផងនោះ អ្នកដែលត្រូវបានជម្លៀស និងជាពិសេសកុមារតូចៗ ត្រូវបានទទួលរងការអស់កម្លាំងយ៉ាងខ្លាំង និងសឹងតែមិនអាចដើរទៅមុខរួច [...] អ្នកដែលត្រូវបានជម្លៀសជាច្រើនបានធ្លាក់ខ្លួនខ្សោយ ឬមានជំងឺ ដោយសារតែលក្ខខណ្ឌទាំងនេះ ហើយមានអ្នកខ្លះបានស្លាប់បាត់បង់ជីវិតផង" [1122] និងថា "នៅពេលជួបប្រទះនឹងលក្ខខណ្ឌលំបាកខ្លាំង និងឥតឈប់ឈរនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន អ្នកដែលត្រូវបានជម្លៀសមួយចំនួនបានធ្វើអត្តឃាត ឬបានស្លាប់ភ្លាមៗដោយសារតែការអស់កម្លាំងខ្លាំង ការហូបមិនគ្រប់គ្រាន់ ឬមានជំងឺ"[1123]។

---

[1119] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៦។

[1120] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៩។

[1121] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៦ យោងទៅលើកថាខណ្ឌ ៤៩១ ដល់ ៤៩២, ៤៩៥ ដល់ ៤៩៨។

[1122] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩១ (ជើងទំព័រលុបចោល)។

[1123] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៧។

៤៥០.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងអង្គច្បាប់ដោយបានសន្និដ្ឋានថា ការធ្វើមនុស្សឃាត ត្រូវបានប្រព្រឹត្តឡើងដោយសារលក្ខខណ្ឌនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ[1124]។ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"បំផ្លើសយ៉ាងខ្លាំងទៅលើឯកសណ្ឋានភាព និងភាពធ្ងន់ធ្ងរនៃលក្ខខណ្ឌនានាក្នុងអំឡុងពេលជម្លៀសប្រជាជន"[1125] និងបានសំអាងយ៉ាងច្រើនទៅលើចម្លើយក្រៅតុលាការដែលពុំអាចទទួលយកបាន សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី[1126] ឬភស្តុតាងពុំគ្រប់គ្រាន់[1127] ក្នុងការពិពណ៌នាលក្ខខណ្ឌក្នុងអំឡុងពេលនៃការជម្លៀស ហើយបានសន្និដ្ឋានដោយពុំត្រឹមត្រូវថា លក្ខខណ្ឌនេះបានបង្កឱ្យមានការស្លាប់។ នួន ជា ក៏បានជំទាស់ផងដែរទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើការយល់ឃើញអំពីអត្ថិភាពនៃសាកសពក្នុងការធ្វើសេចក្តីសន្និដ្ឋានថា ប្រជាជនបានស្លាប់ដោយសារលក្ខខណ្ឌក្នុងអំឡុងពេលនៃការជម្លៀស[1128]។

៤៥១.សហព្រះរាជអាជ្ញាបានអះអាងថា សារណារបស់ នួន ជា ពុំមានអង្គសេចក្តីឡើយ ពីព្រោះ មានភស្តុតាងច្រើនសន្ធឹកសន្ធាប់គាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា លក្ខខណ្ឌនៃការជម្លៀស និងកង្វះការជួយ បានបណ្តាលឱ្យអ្នកដែលត្រូវជម្លៀសស្លាប់[1129]។

៤៥២.ទាក់ទងទៅនឹងការជំទាស់របស់ នួន ជា លើការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលក្ខខណ្ឌទូទៅក្នុងអំឡុងពេលនៃការជម្លៀស[1130] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នួន ជា ពុំបានលើកអំណះអំណាងរបស់ខ្លួនឱ្យបានច្បាស់លាស់ ទាក់ទងទៅនឹងផ្នែកនៃបទមនុស្សឃាត នៅក្នុងបណ្តឹងសាទុក្ខនោះ

---

[1124] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៣ ដល់ ៣២៦។ *សូមមើលផងដែរ* កថាខណ្ឌ ៤២២ ដល់ ៤២៩ ដែល នួន ជា បានជំទាស់ជាទូទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងលក្ខខណ្ឌក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងទាំងនេះខាងក្រោមក្នុងកថាខណ្ឌ ៥៩៧ *ជាអាទិ៍*។

[1125] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២២។

[1126] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៣, ៣២៥ ដល់ ៣២៦។

[1127] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៣ ដល់ ៣២៤។

[1128] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៩, ៥០០។

[1129] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧៦ ដល់ ១៨៧។

[1130] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២២។

ទេ ប៉ុន្តែបានយោងទៅលើការលើកឡើងនៅកន្លែងផ្សេងទៀតទាក់ទងទៅនឹងបទឧក្រិដ្ឋនៃ"អំពើអមនុស្សធម៌ដទៃទៀត"[1131]ប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងទាំងនេះ ពិតជាជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទឧក្រិដ្ឋនោះ ហើយអង្គជំនុំជម្រះនឹងត្រូវដោះស្រាយការលើកឡើងទាំងនេះទាក់ទងទៅនឹងបរិបទនោះផងដែរ[1132]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលដោះស្រាយផ្នែកនេះតែអំណះអំណាងពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប្រជាជនស្លាប់ដោយសារលក្ខខណ្ឌដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការជម្លៀសប៉ុណ្ណោះ។

៤៥៣.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ជាថ្មីម្តងទៀតថា សម្រាប់ការបង្ហាញអំពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហេតុការណ៍នៃការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស ជាការចាំបាច់ត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ បានផ្អែក*ក្នុងចំណោមនោះ*ទៅលើសក្ខីកម្មផ្ទាល់របស់សាក្សីពីររូប Sidney SCHARNBERG និង ស៊ុំ ជា និងលើសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ ចាន់ សុភាព *ហៅ*ចាន់ សុជាតិ ផេង អេងលី នូវ ហ៊ាន់ ពេជ ស្រីផល និង ពិន យ៉ាថៃ។ ទាក់ទងទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ជា បានអះអាងថា មានដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រឹមតែបានផ្តល់ចម្លើយអំពីផលប៉ះពាល់ដល់ជនរងគ្រោះប៉ុណ្ណោះ ដែលគាត់ចាត់ទុកថា ជាភស្តុតាងពុំអាចទទួលយកបាន[1133]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបានសម្រេចបដិសេធលើអំណះអំណាងនេះរួចរាល់ហើយ[1134]។

៤៥៤.ទាក់ទងទៅនឹងខ្លឹមសារនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានតែសក្ខីកម្មរបស់ ពិន យ៉ាថៃ មួយគត់ដែលជាសក្ខីកម្មផ្ទាល់គាំទ្រការយល់ឃើញដែលថា "អ្នកដែលត្រូវបានជម្លៀស [...] បានធ្វើអត្តឃាត"[1135]ដោយសារលក្ខខណ្ឌនៃការជម្លៀស ដែលសាក្សីរូបនេះបានអះអាងថា តាមផ្លូវចេញពីទីក្រុងភ្នំពេញ គាត់"បានឃើញស្ត្រីពីររូបចងកសម្លាប់ខ្លួន [...] ពីរកន្លែង

---

[1131] *សូមមើល*សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២២ ជើងទំព័រ ៨៦២ និង ៨៦៣។

[1132] *សូមមើលខាងក្រោម* កថាខណ្ឌ ៥៩២ *ជាអាទិ៍*។

[1133] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៣។

[1134] *សូមមើលខាងលើ* កថាខណ្ឌ ៣១៧ *ជាអាទិ៍*។

[1135] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៥៩៧។

ខុសគ្នា”[1136]។ ទោះជាយ៉ាងណាក្តី ពិន យ៉ាថៃ ពុំបានរៀបរាប់លម្អិត ហើយអង្គជំនុំជម្រះសាលាដំបូង ឬភាគី ពុំបានសួរដេញដោលគាត់ទាក់ទងទៅនឹងបញ្ហានេះឡើយ។ ដោយសារសក្ខីកម្មរបស់គាត់ខ្វះភាពជាក់លាក់លើចំណុចនេះ និងពុំមានការបង្ហាញពីមូលដ្ឋានអ្វីដែលនាំឱ្យគាត់អាចសន្និដ្ឋានបានថា ស្ត្រីទាំងពីររូបនោះបានធ្វើអត្តឃាត និងគ្មានការបង្ហាញអំពីមូលហេតុនៃការសម្លាប់ខ្លួននោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានតុលាការអង្គហេតុសមស្របណាមួយអាចសន្និដ្ឋានបានថា ហេតុការណ៍ដែល ពិន យ៉ាថៃ បានរៀបរាប់នោះបង្ហាញឱ្យហួសពីវិមតិសង្ស័យ[1137]ថា ការធ្វើអត្តឃាតនេះ គឺបណ្តាលមកពីលក្ខខណ្ឌនៃការជម្លៀសឡើយ។ ភស្តុតាងមួយទៀតដែលទាក់ទងទៅនឹងការធ្វើអត្តឃាត គឺពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សុត ណាវី បានឃើញ“ការធ្វើអត្តឃាតនៅតាមផ្លូវ”[1138]។ ការរៀបរាប់នេះមិនត្រឹមតែខ្វះភាពជាក់លាក់ប៉ុណ្ណោះទេ ថែមទាំងជាភស្តុតាងដែលពុំត្រូវបានសួរដេញដោលទាំងស្រុងដែលមានតម្លៃទាប និងពុំគ្រប់គ្រាន់សម្រាប់បង្ហាញការយល់ឃើញឱ្យហួសពីវិមតិសង្ស័យឡើយ។

៤៥៥.ម្យ៉ាងវិញទៀត ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ដោយសារ“លក្ខខណ្ឌធ្ងន់ធ្ងរ និងគ្មានមេត្តាក្នុងអំឡុងពេលនៃការជម្លៀស អ្នកដែលត្រូវគេជម្លៀសមួយចំនួន ជាពិសេស កុមារបានស្លាប់ដោយសារការហេវហត់អស់កម្លាំង បូកជាមួយនឹងការខ្វះចំណីអាហារ ឬជំងឺផ្សេងៗ”[1139]ត្រូវបានគាំទ្រដោយសក្ខីកម្មផ្ទាល់របស់ ពេជ ស្រីផល និង បេ សុផានី ដែលបានរៀបរាប់លម្អិតយ៉ាងសមស្រប អំពីមូលហេតុដែលកុមារតូចៗបានស្លាប់ដោយសារការខ្វះចំណីអាហារ និងជំងឺ[1140]។ នួន ជា ពុំបានជំទាស់ទៅនឹងខ្លឹមសារនៃសក្ខីកម្ម

---

[1136] ប្រតិចារឹកចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ២២។

[1137] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា ក្នុងអំឡុងពេលសួរសំណួរសាក្សី ពិន យ៉ាថៃ សហព្រះរាជអាជ្ញាពុំបានបញ្ជាក់អំពីការពិតនៃខ្លឹមសារនៅក្នុងសៀវភៅរបស់គាត់ ប៉ុន្តែត្រឹមតែបានបញ្ជាក់ថា ពិន យ៉ាថៃ គឺពិតជាអ្នកសរសេរអត្ថបទនោះមែនប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ការរៀបរាប់អំពីការស្លាប់ពុំអាចនិយាយបានថា បានលើកឡើងម្តងទៀតនៅចំពោះមុខតុលាការឡើយ (*សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៧ ជើងទំព័រ ១៤៨៩ យោងទៅលើប្រតិចារឹក ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៤៤)។

[1138] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៤៩៧ ជើងទំព័រ ១៤៨៧ យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត ណាវី ឯកសារលេខ E3/4921 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00586773 ទំព័រ ៨។

[1139] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៧។

[1140] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៨ យោងទៅលើដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល ដែលបានរៀបរាប់ថា ក្នុងអំឡុងពេលនៃការជម្លៀស ដោយសារខ្វះអាហារ ថ្នាំពេទ្យ ទឹកដោះ ឬទឹក ទើបកូនរបស់គាត់ស្លាប់(ប្រតិចារឹកចុះ

របស់ បេ សុផានីឡើយ[1141]។ ទាក់ទងទៅនឹងការជំទាស់របស់ នួន ជា ទៅនឹងសក្ខីកម្មរបស់ ពេជ ស្រីផល[1142] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដែលសាក្សីបានពន្យល់ត្រឹមតែថា កូនរបស់គាត់ស្លាប់ដោយសារដាច់បាយ ដាច់ទឹក អត់ថ្នាំ អត់ទឹកដោះឱ្យកូនបៅ[1143] បើទោះបីជាគ្មានការបញ្ជាក់លម្អិតបន្ថែមលើមូលហេតុនៃការស្លាប់ក៏ដោយ ក៏ពុំបានធ្វើឱ្យសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការស្លាប់ដោយសារលក្ខខណ្ឌនោះ ទៅជាពុំសមហេតុផលឡើយ ដោយអង្គជំនុំជម្រះបានពិចារណាឃើញថា លទ្ធភាពដែលបណ្ដាលឱ្យស្លាប់នោះត្រូវបានបញ្ជាក់បន្ថែមពីភស្តុតាងដទៃទៀត រួមទាំងសុភវិនិច្ឆ័យផងដែរ។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានបញ្ជាក់បន្ថែមដោយសក្ខីកម្មរបស់ Sidney SCHARNBERG ដែលបានរៀបរាប់ថា អ្នកដែល“បានចូលស្ថានទូតនៅថ្ងៃបន្ទាប់នោះ បានរៀបរាប់ថា មានសាកសពនៅតាមផ្លូវ និងមនុស្សដែលស្លាប់ដោយសារជំងឺ ឬហត់នឿយពេលដើរតាមផ្លូវ” (ប្រតិចារឹកសំណៅភាសាខ្មែរបកប្រែខុសពីសំណៅដើមជាភាសាអង់គ្លេស)[1144] បើទោះបីជាសក្ខីកម្មនេះជាភស្តុតាងចចាមអារ៉ាមក៏ដោយ ក៏នេះកើតចេញពីសាក្សីដែលជឿជាក់បានជាទូទៅ និងផ្ទាល់នៅពេលនោះ ដូច្នេះបានផ្ដល់ការគាំទ្រដល់សក្ខីកម្មផ្ទាល់របស់ ពេជ ស្រីផល និង បេ សុផានី។ សក្ខីកម្មផ្ទាល់ដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានយោងនោះ[1145] មាន

---

ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ២១) និងយោងទៅលើដើមបណ្ដឹងរដ្ឋប្បវេណី បេ សុផានី ដែលបានពន្យល់លម្អិតថា ក្នុងអំឡុងពេលនៃការជម្លៀស កូនខ្ចីគាត់ឈឺខ្លាំង និងថា នៅពេលគាត់យកកូនរបស់គាត់ទៅពេទ្យយោធា កូនរបស់គាត់បានស្លាប់មួយរំពេចដោយសារប្រកាច់ ក្រោយពេលពេទ្យយោធានោះយកសឺរាំងចាក់អ្វីចូលក្បាលកូនគាត់(ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារលេខ E1/200.1 (បេ សុផានី) ទំព័រ ១០ ដល់ ១១)។

[1141] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៥ ជើងទំព័រ ៨៧៥ ដែល នួន ជា បានចោទប្រកាន់ថា សក្ខីកម្មរបស់ បេ សុផានី បានធ្វើឡើងក្នុងអំឡុងពេលនៃការលើកឡើងអំពីផលប៉ះពាល់ជនរងគ្រោះ ដូចនេះពុំអាចទទួលយកបានឡើយ(អំណះអំណាងនេះអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធរួចរាល់ហើយ)។

[1142] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៥។

[1143] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ២១។

[1144] សាលាក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៤៩៧ ជើងទំព័រ ១៤៨៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/203.1 ទំព័រ ៣។

[1145] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ៤, ១២ ដល់ ១៣។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៦០ ដល់ ៦១។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣៣។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ផេ

លក្ខណៈទូទៅ ដោយសារពុំមានការតាំងសំណួរពីភាគី ឬអង្គជំនុំជម្រះសាលាដំបូងដើម្បីបញ្ជាក់ការពិត និង ប្រភពជាក់លាក់នៃការរៀបរាប់ ទើបសក្ខីកម្មនេះពុំបានគាំទ្រដោយសមហេតុផលដល់ការសន្និដ្ឋានដែលថា បុគ្គលដែលពាក់ព័ន្ធនោះពិតជាបានឃើញផ្ទាល់នូវការស្លាប់ដោយសារលក្ខខណ្ឌ ដែលខុសពីការឃើញមនុស្ស ហេវហត់អស់កម្លាំងដួលសន្លប់ ឬបានឮថា មានមនុស្សស្លាប់[1146]។ តម្លៃនៃសក្ខីកម្មដែលមានចំណុចជាប់ពាក់ព័ន្ធទាំងនេះ មានតិចតួចត្រឹមបញ្ជាក់ពីលក្ខខណ្ឌធ្ងន់ធ្ងរក្នុងអំឡុងពេលជម្លៀស។ ទោះជាយ៉ាងណាក្ដី ការសំអាងលើចម្លើយទាំងនេះធ្វើជាភស្តុតាងបង្ហាញអំពីការស្លាប់ដោយសារលក្ខខណ្ឌ ជាការពុំសមហេតុផលនោះឡើយ។

៤៥៦.ទោះជាយ៉ាងណាក្ដី សក្ខីកម្មផ្ទាល់នេះត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងជាឯកសារ ដែលក្នុងនោះមានរបាយការណ៍ចំនួន ០២ របស់រដ្ឋាភិបាលនៃចក្រភពអង់គ្លេស និងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិដែលនៅពេលនោះរាយការណ៍អំពីការរៀបរាប់របស់វេជ្ជបណ្ឌិតកម្ពុជា ដែលតាមរបាយការណ៍បានអះអាងថា លក្ខខណ្ឌនៃការជម្លៀសដែលបណ្ដាលឱ្យមានកង្វះទឹក កង្វះការថែទាំផ្នែកវេជ្ជសាស្ត្រ និងមានការឆ្លងជំងឺ ដូចជា ជំងឺអាសន្នរោគ បានបណ្ដាលឱ្យមនុស្សស្លាប់ច្រើន[1147] និងថា ក្នុងអំឡុងពេលនៃការជម្លៀសពេលនោះគាត់បានឃើញខ្មោចកូនក្មេងម្នាក់នៅរៀងរាល់“២០០ យ៉ាត (yards)” ដែលកុមារភាគច្រើន

ង អេងលី) ឯកសារលេខE1/198.1 ទំព័រ ៦៨ ដល់ ៦៩។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នួន ហ៊ាន់) ឯកសារលេខ E1/199.1 ទំព័រ ៦។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៤៤ និង ៤៦។

[1146] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ទំព័រ ៦១ ដល់ ៦២ (រៀបរាប់ពីមនុស្សស្លាប់នៅតាមផ្លូវ ហើយនៅពេលនោះឃើញមានការជាន់គ្នាក៏មាន ហើយមានអ្នកដែលឈឺហ្នឹងក៏មាន ហើយរហូតដល់មានអ្នកស្លាប់ទៀត)។ ការសង្ខេបខ្លី និងទូទៅនៅក្នុងចម្លើយនេះដែលផ្ទុយទៅនឹងផ្នែកដទៃទៀតរបស់ យឹម សុវណ្ណ ដែលបានរៀបរាប់លម្អិតតាមលំដាប់លំដោយត្រឹមត្រូវនោះបានបង្ហាញថា ជាពាក្យចចាមអារ៉ាម ឬពាក្យលយដែលអាចមានន័យដូចទៅនឹងការបង្ហាញរូបភាពអំពីមនុស្សដួលពុំអាចដើរទៅមុខបាន។ ប្រហាក់ប្រហែលគ្នានេះដែរ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ១២ ដល់ ១៣ (បានឃើញមនុស្សបានស្លាប់តាមផ្លូវ)។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣២ ដល់ ៣៣ (បានឃើញអ្នកខ្លះស្លាប់តាមផ្លូវ) និងប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នួន ហ៊ាន់) ឯកសារលេខ E1/199.1 ទំព័រ ៦ (អ្នកខ្លះស្លាប់ និងទុកសាកសពចោលតាមផ្លូវ) នេះជាការនិយាយពុំច្បាស់លាស់គ្រប់គ្រាន់ ដែលផ្ទុយពីផ្នែកដទៃទៀតនៅក្នុងសក្ខីកម្មនោះ។

[1147] របាយការណ៍របស់រដ្ឋាភិបាលចក្រភពអង់គ្លេស៖ *ការរំលោភសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/3319 ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00699213 កថាខណ្ឌ ៦។

បានស្លាប់ដោយសារ"ជំងឺក្រពះ និងពោះវៀនដែលបណ្តាលឱ្យខ្វះជាតិទឹកទាំងស្រុង"[1148]។ បើទោះបីជាភស្តុតាងនេះជាពាក្យចចាមអារ៉ាម និងដោយសារពុំមានព័ត៌មានទាក់ទងទៅនឹងកាលៈទេសៈនៃប្រភពការរៀបរាប់ និងការវិភាគអំពីភាពអាចជឿទុកចិត្តបាន និងពុំសមស្របក្នុងការបង្ហាញចំនួនកុមារដែលបានស្លាប់ឱ្យហួសពីវិមតិសង្ស័យយ៉ាងណាក៏ដោយ ក៏ជាការបញ្ជាក់បន្ថែមទៅលើភស្តុតាងដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះ ពីព្រោះតាមការអះអាងរបស់វេជ្ជបណ្ឌិតអំពីមូលហេតុដែលបណ្តាលឱ្យស្លាប់ បានផ្អែកលើការវាយតម្លៃដោយសមហេតុផល និងដោយសារតាមភស្តុតាងបញ្ជាក់ នៅពេលដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌដូចលក្ខខណ្ឌក្នុងពេលជម្លៀសដូចជា កម្តៅថ្ងៃក្តៅខ្លាំង អស់កម្លាំងខ្លាំង កង្វះទឹក ជម្រក ការថែទាំផ្នែកវេជ្ជសាស្ត្រ ជាពិសេសកុមារងាយទទួលរងគ្រោះដល់ជីវិតដោយសារកង្វះជាតិទឹក។

៤៥៧.អង្គជំនុំជម្រះសាលាដំបូងក៏បានសំអាងលើភស្តុតាងជាឯកសារដទៃទៀត ដូចជា ការទំនាក់ទំនងការទូតកំណត់ហេតុស្តាប់ចម្លើយ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះ[1149]។ ភាគច្រើនពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះត្រឹមតែផ្តល់សេចក្តីសន្និដ្ឋានទូទៅដោយពុំមានពន្យល់នូវប្រភពអំពីការដឹងរបស់សាមីបុគ្គល[1150] ដូច្នេះអាចជា"ការចងចាំជារួម" ឬ

---

[1148] ការធ្វើវិភាគមួយដែលរៀបចំឡើងតាងនាមឱ្យអនុគណៈកម្មការរបស់អនុគណៈកម្មការនេះស្តីពីឯកសារនានាដែលបានដាក់ជូនអនុគណៈកម្មការនេះ និងគណៈកម្មការសិទ្ធិមនុស្សតាមសេចក្តីសំរេចលេខ ៩ (XXXIV) ឯកសារលេខ E3/2060 ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៧៩ ERN (ភាសាខ្មែរ) 00294954 ទំព័រ ១៩។

[1149] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៤៨៧ ដល់ ១៤៨៨ និង ១៤៩១ ដល់ ១៤៩២។

[1150] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៧ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផាត់ ហាន ឯកសារលេខ E3/4756 ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៤ ERN (ភាសាខ្មែរ) 00484884 (បានឃើញមនុស្សចាស់ជរាដែលដើរលែងរួច ត្រូវស្លាប់តាមផ្លូវ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាម ផា ឯកសារ E3/5005 ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557817 ទំព័រ ៤ (អ្នកខ្លះមានផ្ទៃពោះគ្រប់ខែឆ្លងទន្លេតាមផ្លូវ ពេលឆ្លងទន្លេហើយត្រូវពួកវាបង្ខំឱ្យបន្តដំណើរទៅមុខទៀត និងពុំអាចទ្រាំបាន អ្នកឆ្លងទន្លេក៏ដាច់ខ្យល់ស្លាប់តាមផ្លូវទាំងម្តាយ និងកូន អ្នកខ្លះទៀតឆ្លងទន្លេហើយទុកកូនចោលស្រមោចរោមឡើងខ្មៅ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ តូច មុនិន្ទ ឯកសារលេខ E3/4668 ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00211324 ទំព័រ ៤ (បានរៀបរាប់ថា មនុស្សចាស់ជរា មិនអាចធ្វើដំណើរទៅមុខបាន ម្យ៉ាងទៀតនៅតាមផ្លូវ ខ្ញុំឃើញមានសាកសពជាច្រើនដែលដេកស្លាប់យ៉ាងអាណោចអាធម៌ដូចសត្វធាតុ)។ ពាក្យបណ្តឹងជនរងគ្រោះ លាស់ វណ្ណាន ឯកសារលេខ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00451929 ទំព័រ ៧ (ប្រជាជនទាំងនោះ ខ្លះស្លាប់តាមផ្លូវ សាកសពស្អុយរលួយ ខ្លះទៀតធ្លាក់ខ្លួនឈឺដោយសារតែពុំមានអាហារគ្រប់គ្រាន់ ហើយដើរផ្លូវឆ្ងាយយ៉ាងដូចនេះ)។ ពាក្យបណ្តឹងជន

"ការពិពណ៌នាធម្មតា" ប៉ុន្តែពុំមែនបទពិសោធន៍ផ្ទាល់ខ្លួន ដែលនេះពុំសមស្របក្នុងការបង្ហាញអង្គហេតុពាក់ព័ន្ធឡើយ។ ទោះជាយ៉ាងណាក្តី ឯកសារដទៃទៀត ជាពិសេសឯកសារដែលមាននៅក្នុងពេលនោះ មានលក្ខណៈជាក់លាក់ជាង និងកើតចេញពីស្ថាប័នខាងក្រៅ[1151] ឬបង្ហាញព័ត៌មានលម្អិតច្បាស់លាស់នូវអ្វីដែលទំនងជាបទពិសោធន៍ផ្ទាល់ខ្លួន[1152] នេះអាចផ្តល់ការបញ្ជាក់បន្ថែមលើភស្តុតាងផ្ទាល់ និងសេចក្តីសន្និដ្ឋានទូទៅរបស់អង្គ

---

រងគ្រោះ ព្រាប ខេន ឯកសារលេខ E3/5406 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480181 ទំព័រ ៧ (បានឃើញមនុស្សស្លាប់តាមផ្លូវដោយសារអត់អាហារ ចាស់ៗស្លាប់)។

1151 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៧ ជើងទំព័រ ១៤៨៧ ទូរលេខរបស់ស្ថានទូតអាម៉េរិកប្រចាំបាងកក កម្មវត្ថុ៖ ជនភៀសខ្លួនខ្មែរត្រូវដើរចេញពីទីក្រុងភ្នំពេញ ឯកសារលេខ E3/3004 កថាខណ្ឌ ៣ ERN (ភាសាខ្មែរ) 00658221 (រាយការណ៍ថា អ្នកដែលត្រូវបានគេជម្លៀសបានអះអាងការខ្វះទឹក ឬទឹកមិនស្អាត និងកំដៅថ្ងៃខ្លាំង បានធ្វើឱ្យមនុស្សចាស់ជរា និងកុមារតូចៗស្លាប់ និងកើតជំងឺអាសន្នរោគ។ នៅពេលដែលអ្នកធ្វើដំណើរជិតទៅដល់ក្រុងកំពង់ចាម មនុស្សស្លាប់ដោយជម្ងឺអាសន្នរោគពី ៤ ឬ ៥ នាក់រៀងរាល់ថ្ងៃ)។ ទូរលេខស្ថានទូតអាម៉េរិកប្រចាំបាងកក កម្មវត្ថុ៖ កម្ពុជាថ្មី ឯកសារលេខ E3/3006 កថាខណ្ឌ ៦ ERN (ភាសាខ្មែរ) 00702181 (ជនជាតិឥណ្ឌា និងពីលីពីនដែលត្រូវបានបង្ខំដោយច្រឡំឱ្យចេញពីទីក្រុងភ្នំពេញនិយាយថា មនុស្សចាស់ ក្មេងតូចៗ និងអ្នកជំងឺជាច្រើនបានស្លាប់ភ្លាមៗ ខណៈដែលពួកគេបានធ្វើដំណើរ ដោយសារជំងឺអាសន្នរោគបានកើតឡើងក្នុងចំណោមហ្វូងមនុស្សដែលដើរជាជួរទៅខាងជើងកន្លែងដែលមានការខ្វះខាតស្បៀងអាហារ និងទឹកស្អាត)។

1152 *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៧ ជើងទំព័រ ១៤៨៧ យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លី រៀម ឯកសារលេខ E3/4980 ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00554820 ទំព័រ ៣ (បានអះអាងថា មានតែ ២០០ នាក់ប៉ុណ្ណោះ ដែលទៅដល់ភូមិនោះ ពីព្រោះអ្នកខ្លះស្លាប់ដោយសារការស្រេកឃ្លាន និងជំងឺ)។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៤៩១ យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុត ណាវី ឯកសារលេខ E3/4921 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00586773 ទំព័រ ៨ (នៅតាមផ្លូវ គាត់បានឃើញការធ្វើអត្តឃាត និងជនរងគ្រោះនៃការអត់អាហារ។ ប្អូនប្រុសម្នាក់ និងប្អូនស្រីរបស់លោកស្រីដែលនៅបៅដោះ បានស្លាប់បាត់បង់ជីវិតដោយសារអត់អាហារ)។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៨ ជើងទំព័រ ១៤៩១ សក្ខីកម្មជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836120 ទំព័រ ៤៣ (លោក S បានរៀបរាប់ថា នៅបន្ទាយ កូនក្មេងអាយុ ៧ ឆ្នាំ ដែលបានដើរជាមួយឪពុកម្តាយក្នុងអំឡុងពេលម៉ោងក្តៅបំផុតនៅពេលថ្ងៃបានស្លាប់ប៉ុន្មានម៉ោងក្រោយមកបន្ទាប់ពីផឹកទឹកតាមបឹង) ទំព័រ ១៧២ ដល់ ១៧៣ ERN (ភាសាខ្មែរ) 00836250-1 (ប៉ុក សារិត បានរៀបរាប់អំពីការស្លាប់របស់ទារកអាយុមួយខែ ដែលបានឈឺ ហើយសល់តែស្បែក និងឆ្អឹងប៉ុណ្ណោះ។ នៅព្រែកពោធិ៍ក្នុងស្រុកស្រីសន្ធរខេត្តកំពង់ចាម ខ្មែរក្រហមបានឆែកឆេរពួកគាត់ និងបានយកថ្នាំពេទ្យដែលគាត់ទុកឱ្យកូនដែលកំពុងតែឈឺ។ ២ ថ្ងៃក្រោយមក កូនរបស់ពួកគាត់បានស្លាប់ដោយសារមិនមានថ្នាំពេទ្យ។ ១៥ ថ្ងៃក្រោយមក កូនទីបួនរបស់ពួកគាត់អាយុ ៤ ឆ្នាំ បានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារតែមិនមានថ្នាំពេទ្យ) ERN (ភាសាខ្មែរ) 00836296 ទំព័រ ២១៩ (ណុប ចុល បានលើកឡើងថា ក្នុងចំណោមកូនទាំងអស់

ជំនុំជម្រះសាលាដំបូង ជាពិសេសទាក់ទងទៅនឹងការស្លាប់របស់កុមារតូចៗ។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញអំពីការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស ដោយផ្អែកលើការរៀបរាប់អំពីការស្លាប់របស់មនុស្សចាស់ និងអ្នកជំងឺ។ ដូច នួន ជា បានកត់សម្គាល់[1153] ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម ស៊ុន្នី បានអះអាងថា ម្តាយក្មេករបស់គាត់បានស្លាប់ក្នុងអំឡុងពេលជម្លៀសប្រជាជនដោយសារតែវ័យចាស់ជរា។ ដោយសារពុំមានពត៌មានបន្ថែមណាមួយទាក់ទងទៅនឹងកាលៈទេសៈនៃការស្លាប់របស់ម្តាយក្មេកគាត់ ជាការពុំសមហេតុផលក្នុងការសន្និដ្ឋានហួសពីវិមតិសង្ស័យថា ការស្លាប់នេះគឺបណ្តាលមកពីកាលៈទេសៈនៃការជម្លៀសទាំងស្រុងនោះទេ[1154]។ មានន័យថា នៅពេលពិចារណាលើលក្ខខណ្ឌធ្ងន់ធ្ងរក្នុងអំឡុងពេលជម្លៀស អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញថា ជាការពុំសមហេតុផលដែលថា លក្ខខណ្ឌដែលដាក់ទៅលើអ្នកដែលត្រូវបានជម្លៀសនោះ ជាកត្តាជាប់ពាក់ព័ន្ធទៅនឹងការស្លាប់ដែលបានកើតឡើងក្នុងអំឡុងពេលនៃការជម្លៀសក្នុងចំណោមក្រុម ដែលងាយទទួលរងគ្រោះបំផុតនោះ មានដូចជា ម្តាយក្មេករបស់ អ៊ឹម ស៊ុន្នី និងអ្នកជំងឺដែលត្រូវបានបោះបង់ចោលនៅលើគ្រែក្នុងមន្ទីរពេទ្យដែល ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល បានឃើញផ្ទាល់[1155]។

៤៥៨.ផ្ទុយទៅនឹងការលើកឡើងរបស់ នួន ជា[1156] អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើការរៀបរាប់របស់ សរ ប៊ុន ដែលបានលើកឡើងនៅក្នុងលិខិតរបស់ស្ថានទូតបារាំងដែលពុំបានសំដៅលើការស្លាប់ដោយសារលក្ខខណ្ឌ ប៉ុន្តែបានសំដៅទៅលើការប៉ាន់ស្មានរបស់ សរ ប៊ុន ដែលថា អ្នកដែលត្រូវបានជម្លៀសជាច្រើនបានស្លាប់ជាបន្តបន្ទាប់ដោយសារលក្ខខណ្ឌលំបាកវេទនា[1157]។ ចុងក្រោយ ទាក់ទងទៅនឹងការជំទាស់របស់ នួន ជា

ចំនួន ៧ នាក់ដែលចាកចេញពីភ្នំពេញជាមួយគាត់ កូនបីនាក់បានស្លាប់ដោយសារជំងឺ និងភាពអត់ឃ្លានក្នុងរយៈពេល ៣ ខែ) (ពាក្យបណ្តឹងរបស់ជនរងគ្រោះ កែម ខួន (កូនប្រុសទីបីរបស់គាត់បានស្លាប់តាមផ្លូវ"ដោយសារអត់បាយ")។

[1153] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៤។

[1154] កំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម ស៊ុន្នី ឯកសារលេខ E3/5555 ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00363533-4 ទំព័រ ៣ ដល់ ៤ ត្រូវបានយោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩៧ ជើងទំព័រ ១៤៨៧។

[1155] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ ពេជ ស្រីផល ឯកសារលេខ E1/148.1 ទំព័រ ១៥ ដល់ ១៦។

[1156] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៣។

[1157] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុៈ សក្ខីកម្មរបស់ឧត្តមសេនីយ៍ សរ ប៊ុន ឯកសារលេខ E3/2666 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499664-5 ទំព័រ ៤ ដល់ ៥ ត្រូវបានយោងនៅក្នុងជើងទំព័រ ១៤៧២ នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងជើងទំព័រនោះ មានការយោងទៅលើសាលាក្រមរបស់អង្គជំនុំជម្រះ

ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដែលបង្ហាញថា សាកសពនៅតាមដងផ្លូវគឺជាសាកសពរបស់អ្នកដែលត្រូវបានជម្លៀស ដែលស្លាប់ដោយសារលក្ខខណ្ឌក្នុងអំឡុងពេលនៃការជម្លៀស[1158] នួន ជា បានកំណត់ចរិតលក្ខណៈនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំត្រឹមត្រូវ។ ផ្ទុយទៅនឹងអ្វីដែល នួន ជា បានលើកឡើងនោះ អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើភស្តុតាងនេះ និងបានបង្ហាញនូវការមន្ទិលសង្ស័យ ថាតើសាកសពនៅតាមដងផ្លូវដែលបានពិពណ៌នានៅក្នុងសក្ខីកម្មនោះ គឺជាប្រជាជនដែលបានស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ដោយសារភស្តុតាងដែលបានពិភាក្សានៅក្នុងផ្នែក ១០.២.១៣ ("ការស្លាប់") [...] សាកសពដែលត្រូវបានឃើញនៅពេលជម្លៀសនោះ គឺជាទាហានរួមទាំងអ្នកដែលស្លាប់ក្នុងពេលប្រយុទ្ធ និងអ្នកដែលត្រូវបានជម្លៀស"[1159]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានដោយផ្អែកលើភស្តុតាងនៃការស្លាប់បណ្តាលមកពីលក្ខខណ្ឌនៃការជម្លៀសតាមរយៈការលើកឡើងរបស់សាក្សីដែលថា សាកសពមួយចំនួននោះ គឺជារបស់អ្នកដែលត្រូវបានជម្លៀសបានស្លាប់ដោយសារលក្ខខណ្ឌ។ អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការសន្និដ្ឋានចេញពីភស្តុតាងនៃសាកសពរបស់ជនរងគ្រោះដែលបានស្លាប់ដោយសារលក្ខខណ្ឌនោះឡើយ។

៤៥៩.ជាទូទៅ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយផ្អែកលើភស្តុតាងទាំងមូលដែលរួមបញ្ចូលសក្ខីកម្មផ្ទាល់ ការសន្និដ្ឋានដែលថា ការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀសនោះ ត្រូវបានបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យ ជាការសមហេតុផល។ បន្ថែមលើនេះទៀត បើទោះបីជាចំនួនមនុស្សស្លាប់ពុំអាចបញ្ជាក់បានពីភស្តុតាងដែលមាននៅក្នុងសំណុំរឿងក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា អាចជឿជាក់បានដោយសារចំនួនមនុស្សស្លាប់នេះអាចមានចំនួនច្រើនជាងចំនួនដែលបានបង្ហាញនៅក្នុងភស្តុតាងអំពីហេតុការណ៍មួយៗ។

៤៦០.ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា ទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ។

---

សាលាដំបូង កថាខណ្ឌ ៤៩៧ ដល់ ៤៩៨ ដែលដោះស្រាយជាក់លាក់លើការស្លាប់។ អាស្រ័យហេតុនេះ អាចសន្មតថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការយល់ឃើញនៅក្នុងកថាខណ្ឌទាំងនេះ ហើយពុំបានសំអាងទៅលើការរៀបរាប់របស់ សរ ប៊ុន សម្រាប់សេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ប្រជាជនបានស្លាប់ដោយសារលក្ខខណ្ឌ។

[1158] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៦។

[1159] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០០។

### ៤.ឃ.១.ខ.៣.ការសម្លាប់ទាហាន និងអ្នករដ្ឋការស៊ីវិល

៤៦១.អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា យោធា និងអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ និងក្រោយមកត្រូវបានសម្លាប់[1160]។ ជនរងគ្រោះ មានដូចជាអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបាន"កំណត់គោលដៅ"សម្រាប់ប្រហារជីវិតមុនពេលដួលរលំទីក្រុងភ្នំពេញ[1161] ទាហានសាមញ្ញដែលបាន*បាត់បង់សមត្ថភាពប្រយុទ្ធ* ឬលែងចូលរួមយ៉ាងសកម្មនៅក្នុងការប្រយុទ្ធ[1162] និងអ្នករដ្ឋការស៊ីវិល[1163]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការសម្លាប់ទាំងនេះ គឺជាការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានយល់ឃើញផងដែរថា មាន"ប្រតិបត្តិការទ្រង់ទ្រាយធំ មានការរៀបចំ និងគិតទុកជាមុន ដើម្បីសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បើទោះបីជាមិនមែនថា អ្នករដ្ឋការទាំងអស់បានជួបប្រទះជោគវាសនាដូចគ្នាបែបនេះក៏ដោយ"[1164]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញទាំងនេះ ដោយពុំបានសំអាងលើភស្តុតាងនៃការសម្លាប់ដែលបានកើតឡើងក្នុងអំឡុងពេលមួយហៅថា "ការផែកឆេរទីក្រុងលើកទីពីរ" (ដែលក្នុងអំឡុងពេលនោះ ជនរងគ្រោះអាចពុំមែនជា*ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ*) និងការធ្វើឱ្យបាត់ខ្លួនអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យ និងជោគវាសនារបស់ពួកគាត់ពុំដឹងជាយ៉ាងណាឡើយ[1165]។

---

[1160] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៣ (យោងទៅលើកថាខណ្ឌ ៥០៣, ៥១១, ៥១៣ ដល់ ៥១៥)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនរងគ្រោះច្រើននាក់"ត្រូវបានទុកមួយកន្លែងសម្រាប់សម្លាប់ចោលនៅកន្លែងផ្សេងទៀត"។ បើទោះបីជាការផ្តល់ការយល់ឃើញនេះពុំសូវច្បាស់លាស់ពីព្រោះអាចត្រូវបានយល់ថា ជាការយល់ឃើញមួយដែលប្រជាជនត្រូវបានទុកមួយកន្លែងសិនក្នុងគោលបំណងដើម្បីសម្លាប់អ្នកទាំងនេះ ប៉ុន្តែពុំត្រូវបានសម្លាប់វិញក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ច្បាស់ថា អង្គជំនុំជម្រះសាលាដំបូង ដោយសារបានផ្តល់ការយល់ឃើញអំពីការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនោះ បានពិចារណាឃើញថា ការសម្លាប់ទាហាន និងអ្នករដ្ឋការស៊ីវិលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។

[1161] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៤ យោងទៅលើ កថាខណ្ឌ ៥០៣។

[1162] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៤ យោងទៅលើ កថាខណ្ឌ ៥១០។

[1163] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៥ យោងទៅលើ កថាខណ្ឌ ៥១៣ ដល់ ៥១៤។

[1164] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦១។

[1165] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៤ ដល់ ៥៥៥ យោងទៅលើ កថាខណ្ឌ ៥១០ និង ៥១៣ ដល់ ៥១៤។

៤៦២.នួន ជា បានជំទាស់ទៅនឹងការយល់ឃើញដែលថា ទាហាន និងអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយបានយោងទៅលើការលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរឬយ៉ាងណា នៅពេលយល់ឃើញថា មានគោលនយោបាយកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ[1166]។ នៅពេលនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមស្របដែលត្រូវដោះស្រាយអំណះអំណាងទាំងនេះ ដោយសារមានការជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការសម្លាប់បានកើតឡើង[1167]។ ជាការកត់សម្គាល់ នួន ជា បានអះអាងថា ការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ ពុំត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ ដោយសារភស្តុតាងដែលបានលើកឡើងពុំត្រឹមត្រូវ មានតម្លៃទាប និងផ្នែកខ្លះមានលក្ខណៈដោះបន្ទុក[1168]។ នួន ជា បានអះអាងបន្ថែមទៀតថា ទាក់ទងទៅនឹងការយល់ឃើញផ្នែកអង្គហេតុ អង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នា"ទៅតាមអំពើចិត្តនូវហេតុការណ៍ពុំស៊ីសង្វាក់ និងពុំជាប់ទាក់ទងគ្នា"រវាងកងទ័ពខ្មែរក្រហមជាមួយនឹងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយពុំបានគាំទ្រដល់ការសន្និដ្ឋានយ៉ាងទូលំទូលាយរបស់ខ្លួនដែលថា ការសម្លាប់ត្រូវបានប្រព្រឹត្តឡើងទៅតាមប្រតិបត្តិការទ្រង់ទ្រាយធំ មានការរៀបចំ និងគិតទុកជាមុន[1169]។

៤៦៣.ខៀវ សំផន បានជំទាស់ដូចគ្នាដែរទាក់ទងទៅនឹងតម្លៃនៃភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានលើកយកមកសំអាង និងការសន្និដ្ឋាន ហើយបានអះអាងថា ទ្រឹស្តីអំពីប្រត្តិបត្តិការទ្រង់ទ្រាយធំ គឺស្ទើរតែពុំអាចទទួលយកបានជាមួយនឹងការពិតដែលថា ហេតុការណ៍ភាគច្រើនត្រូវបានរាយការណ៍ថា បានកើតឡើងនៅក្នុងភូមិភាគនិរតី[1170]។

---

[1166] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២១ យោងទៅលើកថាខណ្ឌ ៥៨៨ ដល់ ៥៩៦។

[1167] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩២ ដល់ ៥៩៦។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងនៃកថាខណ្ឌ ៥៨៨ ដល់ ៥៩១ ក្នុងបណ្តឹងសាទុក្ខរបស់ នួន ជា នៅក្នុងផ្នែកដែលពាក់ព័ន្ធទៅនឹងការដោះស្រាយលើការសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (*សូមមើលខាងក្រោម* កថាខណ្ឌ ៥២៩ ជាដើម)។

[1168] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២១, ៥៨៨, ៥៩២ ដល់ ៥៩៦។

[1169] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨៨ ដល់ ៥៩១ និង ៥៩៧ ដល់ ៥៩៩។

[1170] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៥៤ ដល់ ៣៥៦។

៤៦៤.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ដោយពិចារណាទៅលើ"ទម្ងន់ភស្តុតាងដែលបញ្ជាក់បន្ថែម បើពិនិត្យជារួម"ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលរងការជំទាស់នេះ ត្រូវបានធ្វើឡើងដោយសមហេតុផល[1171]។

៤៦៥.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការសម្លាប់ទាហាន និងអ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ បានផ្អែកលើការយល់ឃើញផ្នែកអង្គហេតុជាក់លាក់ជាច្រើនដូចជា (i) អ្នករដ្ឋការជាន់ខ្ពស់ដែលត្រូវបានកំណត់គោលដៅជាសាធារណៈសម្រាប់ប្រហារជីវិត នៅមុនពេលកាន់កាប់ទីក្រុងភ្នំពេញត្រូវបានសម្លាប់[1172] (ii) អ្នករដ្ឋការស៊ីវិល និងទាហានដែល*បាត់បង់សមត្ថភាពប្រយុទ្ធ* ត្រូវបានប្រហារជីវិតនៅនឹងកន្លែងក្នុងទីក្រុងភ្នំពេញ[1173] (iii) ទាហានត្រូវបាននាំយកទៅសម្លាប់នៅកន្លែងផ្សេងទៀត[1174] (iv) ទាហានដែលគោរពតាមសេចក្តីប្រកាសតាមវិទ្យុ និងមេក្រូឱ្យចូលបង្ហាញខ្លួន ត្រូវបានសម្លាប់នៅក្នុង ឬជុំវិញទីក្រុងភ្នំពេញ[1175] (v) ទាហានខ្លះទៀតដែលត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យតាមផ្លូវ ត្រូវបានសម្លាប់នៅនឹងកន្លែង ឬនាំចេញទៅ ដែលក្រោយមក មួយចំនួនត្រូវបានសម្លាប់[1176] (vi) អ្នកដែលបានចុះឈ្មោះនៅកៀនស្វាយ និងបាត់ដំបង ត្រូវបានសម្លាប់ ឬ"ត្រូវបាននាំចេញទៅ ហើយពុំដែលបានឃើញត្រឡប់មកវិញឡើយ"[1177]។

## ៤.ឃ.១.ខ.៣.ក.អ្នករដ្ឋការជាន់ខ្ពស់

៤៦៦.អង្គជំនុំជម្រះសាលាដំបូង ពុំបានបញ្ជាក់ច្បាស់លាស់អំពីការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរដែលខ្លួនចាត់ទុកថា បានបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យឡើយ[1178] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដោយផ្អែកលើភស្តុតាងដែលជនជាប់ចោទពុំបានលើកអំណះអំណាងជាក់លាក់ដើម្បី

---

[1171] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥៩ ដល់ ១៧៥។

[1172] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៣ និង ៥៥៣។

[1173] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៧។

[1174] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៨។

[1175] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១១។

[1176] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៣។

[1177] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៤។

[1178] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៣ យោងទៅលើកថាខណ្ឌ ៥០៣។

ជំទាស់នោះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលថា ជនមហាក្បត់ពីររូប (ឡុង បូរ៉េត និងព្រះអង្គម្ចាស់ សិរិមតៈ)[1179]ក្នុងចំណោម“ជនមហាក្បត់ទាំងប្រាំពីរ” និងអ្នករដ្ឋការជាន់ខ្ពស់ឈ្មោះ លន់ ណុន[1180] រួមទាំង អ៊ុំង ប៊ុនហ៊ា[1181]ផងដែរ ត្រូវបានប្រហារជីវិត[1182]។

---

[1179] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៣ ជើងទំព័រ ១៥០៨ ដល់ ១៥១០ យោងទៅលើ*ក្នុងចំណោមនោះ*ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/201.1 ទំព័រ ៣៥ ដល់ ៣៧ និងប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ឯកសារលេខ E1/165.1 ទំព័រ ៣៦ (បានអះអាងថា ឡុង បូរ៉េត បានមកដល់ក្រសួងព័ត៌មាននៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយ“មានខ្មែរក្រហមពីរបីនាក់មកជាមួយ” និងបើទោះបីជាពុំមានអាវុធភ្ជង់ដាក់ក៏ដោយ ក៏“បង្ហាញច្បាស់ថា ពួកគេគឺជាអ្នកទោស” និងថា ឡុង បូរ៉េត ត្រូវបានដឹកចេញទៅ ពីរ ឬបីនាទីក្រោយមក)។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/201.1 ទំព័រ ៤០ ដល់ ៤១ (*យោងទៅលើ* S. Schanberg៖ *កំណត់ហេតុប្រចាំថ្ងៃអំពីកម្ពុជាក្នុងឆ្នាំ ១៩៧៥* ឯកសារលេខ E236/1/4/3.1 ទំព័រ ១៤៤ ដល់ ១៤៥ ERN (ភាសាខ្មែរ) 00963983 បានអះអាងថា នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ គាត់បានឃើញកងទ័ពខ្មែរក្រហមមកស្ថានទូតបារាំង និងបាននាំមនុស្សមួយក្រុមចេញទៅរួមទាំងព្រះអង្គម្ចាស់ សិរិមតៈ និង ហុង បួនហោ (អ៊ុំង ប៊ុនហ៊ា ឬ អ៊ុំង ប៊ុនហរ)ផងដែរ)។ បាងកកប៉ុស្តិ៍៖ ការបញ្ជាក់អះអាងអំពីទំនាក់ទំនងនៅពេលប្រជាជនខ្មែរចាកចេញ និងការទទួលស្គាល់អំពីការប្រហារជីវិតឯកសារលេខ E3/604 ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00632772 (របាយការណ៍អំពីការបញ្ជាក់អះអាងរបស់ អៀង សារី ថា ឡុង បូរ៉េត ត្រូវបានប្រហារជីវិត)។ ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/202.1 ទំព័រ ១១ (បានឮតាមមន្ត្រីស្ថានទូតបារាំងថា ឡុង បូរ៉េត និងព្រះអង្គម្ចាស់ សិរិមតៈត្រូវបានសម្លាប់)។ ទូរលេខស្ថានទូតអាម៉េរិកប្រចាំបាំងកក កម្មវត្ថុ៖ ដំណើរទស្សនកិច្ចរបស់ អៀង សារី ទៅកាន់ប្រទេសថៃ ឯកសារលេខ E3/3358 ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ កថាខណ្ឌ ៥ ERN (ភាសាខ្មែរ) 00602536 (កត់សម្គាល់ឃើញថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌កម្ពុជាក្នុងពេលមួយផ្សេងទៀតបានប្រាប់ថៃថា គាត់បានឮដំណឹងថា ជនមហាក្បត់ប្រាំពីរនាក់ដែលត្រូវបានកំណត់គោលដៅសម្រាប់ប្រហារជីវិត អ្នកទាំងនោះដែលស្ថិតនៅក្នុងប្រទេសកម្ពុជា រួមទាំង ឡុង បុរ៉េត និងព្រះអង្គម្ចាស់ សិរិមតៈ ត្រូវបានសម្លាប់)។ ភាពយន្តឯកសាររបស់ ថេត សម្បត្តិ និង R. LEMKIN៖ *សត្រូវរបស់ប្រជាជន* ឯកសារលេខ E3/40001R ឆ្នាំ ២០០៧ (ឈុតខ្សែវីដេអូបន្ថែម៖ *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ*) នាទី ២២.០៧ ដល់ ២២.១១ (នួន ជា បានបញ្ជាក់ថា “បទបញ្ជានយោបាយ”របស់ ប.ក.ក. ដែលថា “ត្រូវកម្ទេច”ជនមហាក្បត់ជាក់ស្តែងត្រូវបានអនុវត្តឡើង)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា Sydney SCHANBERG បន្ទាប់មកបានបញ្ជាក់ថា កាលនៅស្ថានទូតបារាំងប្រហែលនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គាត់ពុំដែលបានឮការរៀបរាប់ផ្ទាល់អំពីការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរណាមួយឡើយ ប៉ុន្តែ“បានទទួលស្គាល់ថា ជាការពិត” ដោយសារគាត់ដឹងតាមរយៈមេខ្មែរក្រហមប៉ុន្មានឆ្នាំក្រោយមក(ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/203.1 ទំព័រ ៤ ដល់ ៦)។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្លាប់អ្នករដ្ឋការពីរនាក់នោះត្រូវបានបង្ហាញយ៉ាងសមហេតុផលដោយផ្អែកលើភស្តុតាងទាំងមូលដែលបានយោងទៅលើនោះ ហើយជនជាប់ចោទពុំបានជំទាស់ឡើយ។

---

[1180] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៥០៨ ដល់ ១៥១០ យោងទៅលើ*ក្នុងចំណោមនោះ*ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/201.1 ទំព័រ ៣៣ ដល់ ៣៦ (បានអះអាងថា គាត់បានឃើញអ្នកទោស ៥០ នាក់ ឈរនៅមុខក្រសួងព័ត៌មានឡោមព័ទ្ធដោយ"ក្រុមមនុស្សប្រដាប់អាវុធធុនធ្ងន់ពី ១០ ទៅ ១៥ នាក់" ក្នុងចំណោមនោះមាន លន់ ណុន ដែលបានស្វែងរកលទ្ធភាពឱ្យអ្នកទោស ឬអ្នករដ្ឋការកម្ពុជាដទៃទៀតចេញពីប្រទេសកម្ពុជា)។ បាងកកប៉ុស្ដិ៍៖ ការបញ្ជាក់អះអាងអំពីទំនាក់ទំនងនៅពេលប្រជាជនខ្មែរចាកចេញ ឯកសារលេខ E3/604 ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00632772 (របាយការណ៍អំពីការបញ្ជាក់របស់ អៀង សារី ថា លន់ ណុន ត្រូវបានប្រហារជីវិត)។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជា លន់ ណុន ពុំស្ថិតក្នុងចំណោម"ជនមហាក្បត់ទាំងប្រាំពីរ"ដែលត្រូវបានកំណត់គោលដៅដើម្បីប្រហារជីវិតក៏ដោយ ក៏គាត់ត្រូវបានកំណត់គោលដៅក្នុងចំណោម"ជនមហាក្បត់ ១៦ នាក់ទៀត"ដែល"សុទ្ធតែត្រូវឆ្លើយតបនៅចំពោះមុខតុលាការរដ្ឋនូវរាល់អំពើអាក្រក់រាប់មិនអស់ និងឧក្រិដ្ឋកម្មដ៏សាហាវព្រៃផ្សៃ" (របាយការណ៍សារព័ត៌មានកម្ពុជា៖ សេចក្តីថ្លែងការណ៍របស់សម្តេចប្រមុខរដ្ឋ *នរោត្តម សីហនុ* ឯកសារលេខ E3/1287 ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00351594) ទំព័រ ៤។

[1181] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៥០៩ ដល់ ២៥១០ និង ២៥៩៧ យោងទៅលើ*ក្នុងចំណោមនោះ* ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/201.1 ទំព័រ ៤០ ដល់ ៤១ និង ៤៤ (*ដកស្រង់* S. Schanberg៖ *កំណត់ហេតុប្រចាំថ្ងៃអំពីកម្ពុជាក្នុងឆ្នាំ ១៩៧៥* ឯកសារលេខ E236/1/4/3.1 ERN (ភាសាខ្មែរ) 00963983 ទំព័រ ១៤៥ បានអះអាងថា នៅថ្ងៃទី ២០ ខែ មេសា គាត់បានឃើញកងទ័ពខ្មែរក្រហមមកស្ថានទូតបារាំង ហើយបាននាំមនុស្សមួយក្រុមចេញទៅ រួមមាន ហុង បួនហេ ផងដែរ)។ ទូរលេខរបស់ក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ការចាកចេញរបស់ជនភៀសខ្លួន ឯកសារលេខ E3/2702 ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00492870 (យោងទៅលើទូលេខពីមុន៖ ទូរលេខក្រសួងការបរទេសបារាំង កម្មវត្ថុ៖ ការសុំសិទ្ធិជ្រកកោននយោបាយ ឯកសារលេខ E3/2694 ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥) កុងស៊ុលបារាំង Dyrac រាយការណ៍ថា ព្រះអង្គម្ចាស់ សិរិមតៈ និងអ្នកដទៃទៀត រួមមាន អ៊ុំង ប៊ុនហ៊័រ ត្រូវបាននាំចេញពីស្ថានទូតដោយសមាជិកនៃគណៈកម្មាធិការដែលពុំស្គាល់អត្តសញ្ញាណ ដែរជារណសិស្សរួបរួមជាតិកម្ពុជា ឬ NLA)។ ទូរលេខនាយកដ្ឋានសហរដ្ឋអាម៉េរិក កម្មវត្ថុ៖ ការផ្តល់ព័ត៌មានពីប្រជាជនអាម៉េរិកស្តីពីស្ថានភាពទីក្រុងភ្នំពេញបន្ទាប់ពីការដួលរលំ ឯកសារលេខ E3/4148 ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00664000 ទំព័រ ៧ (ជនជាតិអាម៉េរិកដែលត្រូវបានជម្លៀសរាយការណ៍ថា ប្រធានសភា អ៊ុំង ប៊ុនហរ បានចាកចេញពីស្ថានទូតបារាំងដោយមានកងទ័ពខ្មែរក្រហមតាមជាមួយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំង បូណាវ៉ាន់ ឯកសារលេខ E3/4679 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00323576 ទំព័រ ១០ (កូនប្រុសរបស់ អ៊ុំង ប៊ុនហ៊័រ បានកត់សម្គាល់ថា គាត់លែងមានដំណឹងអំពីឪពុករបស់គាត់ចាប់ពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ មក ដែលជាឆ្នាំអាជ្ញាធរបារាំងបានប្រគល់ឪពុករបស់គាត់ដោយបង្ខំទៅឱ្យពួកខ្មែរក្រហម)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើភាពខុសគ្នារវាងកាលបរិច្ឆេទដែលបានផ្តល់ដោយ អ៊ុំង បូណាវ៉ាន់ និងផ្តល់ដោយសាក្សីដទៃទៀតទាក់ទងទៅនឹងពេលដែល អ៊ុំង ប៊ុនហ៊័រ បានចាកចេញពីស្ថានទូតបារាំង ប៉ុន្តែជឿជាក់ថា ជាការពុំខុសគ្នាណាស់ណានោះទេ។ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អ៊ុំង ប៊ុនហ៊័រ ត្រូវបាននាំចេញពីស្ថានទូតបារាំងជាមួយព្រះអង្គម្ចាស់ សិរិមតៈ។ ដោយសារហេតុ

**៤.ឃ.១.ខ.៣.ខ.អ្នករដ្ឋការស៊ីវិល និង *ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ* ត្រូវបានសម្លាប់នៅនឹងកន្លែង**

៤៦៧.ក្នុងការគាំទ្រដល់ការយល់ឃើញដែលថា អ្នករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ និងទាហាន*បាត់បង់សមត្ថភាពប្រយុទ្ធ* ត្រូវបានសម្លាប់នៅនឹងកន្លែងនោះ[1183] អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីតែមួយគត់ ជាមួយនឹងកំណត់ហេតុស្តាប់ចម្លើយចំនួន ២ និងឯកសារក្រៅតុលាការចំនួន ៩ (ជាឧទាហរណ៍ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពាក្យបណ្តឹងរបស់ជនរងគ្រោះ សក្ខីកម្មរបស់ជនភៀសខ្លួន ចម្លើយ និងរបាយការណ៍ជាដើម)[1184]។

៤៦៨.ទាក់ទងទៅនឹងសក្ខីកម្មផ្ទាល់ ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអំពីហេតុការណ៍ ដែលឪពុកមារបស់គាត់មានឋានៈជាវរសេនីយ៍ឯកនៃរបបសាធារណរដ្ឋខ្មែរ ស្លៀកពាក់ឯកសណ្ឋានយោធា ត្រូវបានបាញ់សម្លាប់ដោយកងទ័ពខ្មែរក្រហម បន្ទាប់ពីគាត់បានបើកឡានហ្ស៊ីបដែលជាឡានរបស់ទាហានអាម៉េរិក មកឈប់នៅមុខផ្ទះរបស់គាត់នៅម៉ោង ៦ ព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ

---

ផលនេះហើយ ដោយពិចារណាលើការបាត់ខ្លួននៅពេលនោះ អង្គជំនុំជម្រះសាលាដំបូងបានយល់ដោយសមហេតុផលថា អ៊ុង ប៊ុនហ៊័រ និង ព្រះអង្គម្ចាស់ សិរិមតៈ បានជួបវាសនាអាក្រក់ដូចគ្នា។

[1182] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី ធុច ផាន់ដារា-ស ផ្តល់សក្ខីកម្មដែលគួរឱ្យជឿជាក់បានទាក់ទងទៅនឹងការសម្លាប់ឧត្តមសេនីយ៍ ថាច់ សារី (ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ឯកសារលេខ E1/198.1 ទំព័រ ២២ ដល់ ២៣ និង ២៧)។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះពុំអាចទទួលស្គាល់ហេតុការណ៍នេះថា បានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ ដោយសារ៖ (i) ការរៀបរាប់នេះ គឺជាពាក្យចចាមអារ៉ាមទាំងស្រុងទាក់ទងទៅនឹងកាលៈទេសៈពាក់ព័ន្ធ (ii) ពុំទំនងជាថា ហេតុការណ៍នេះពាក់ព័ន្ធទៅនឹងអ្នករដ្ឋការជាន់ខ្ពស់ដទៃទៀតដែលបានរៀបរាប់ខាងលើ ពុំមានភស្តុតាងបញ្ជាក់បន្ថែម និង (iii) ការសម្លាប់បុគ្គលនេះពុំត្រូវបានទទួលស្គាល់ដោយថ្នាក់ដឹកនាំខ្មែរក្រហមឡើយ។ បើទោះបីជា Al ROCKOFF បានអះអាងថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបានប្រមូលផ្តុំនៅក្រសួងព័ត៌មាននៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ "ត្រូវបានវាយសម្លាប់" គាត់ដឹងព័ត៌មាននេះ"ក្រោយមកទៀត" នៅពេលគាត់ពុំបានស្នាក់នៅក្នុងប្រទេសកម្ពុជាតទៅទៀត និង "ដឹងតាមប្រភពដទៃទៀតដែល[គាត់]ពុំស្គាល់" (ប្រតិចារឹកចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ឯកសារលេខ E1/165.1 ទំព័រ ៤៣)។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ (Sydney SCHANBERG) ឯកសារលេខ E1/201.1 ទំព័រ ៤៥។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ១៥ ដល់ ១៦ (ព្រះតេជព្រះគុណ សូ ហាយ លោកនិមន្តចូលរួមកិច្ចប្រជុំនៅក្រសួងព័ត៌មាន ដែល ឡុង បូរ៉េត ក៏នៅទីនោះ និងត្រឡប់មកវត្តខណាលោមវិញដោយសុវត្ថិភាព)។

[1183] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៧។

[1184] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលដំបូង កថាខណ្ឌ ៥០៧ ជើងទំព័រ ១៥១៨។

១៩៧៥[1185]។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានផ្តល់ព័ត៌មានលម្អិត និងគួរឱ្យជឿជាក់បាន អាស្រ័យហេតុនេះ ជាការសមស្របដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា មានការសម្លាប់កើតឡើង។ ទោះជាយ៉ាងណាក្តី ដូចដែល នួន ជា បានកត់សម្គាល់ ការសម្លាប់នេះបានកើតឡើងពីរបីម៉ោងមុនពេលបញ្ចប់ការប្រយុទ្ធគ្នាជាផ្លូវការ[1186]។ ហេតុការណ៍នេះ និងកាលៈទេសៈជុំវិញការសម្លាប់(ជនរងគ្រោះស្លៀកពាក់ឯកសណ្ឋានយោធា និងបានបើកបររថយន្តយោធា) បានបង្ហាញថា ជនរងគ្រោះប្រាកដជាត្រូវបានចាត់ទុកថា ជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលនៅពេលបាញ់សម្លាប់នោះ ជនរងគ្រោះពុំបានដាក់អាវុធចុះ ឬពុំចាត់ទុកថា បាន*បាត់បង់សមត្ថភាពប្រយុទ្ធ* ដោយសារជំងឺ របួស ឬស្ថិតក្នុងការឃុំឃាំង[1187] និងជាគោលដៅយោធា។ ការសម្លាប់នេះបើទោះបីជាអង្គហេតុត្រូវបានបង្ហាញយ៉ាងសមហេតុផលក៏ដោយ ក៏ពុំមានលក្ខណៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

៤៦៩.ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះ ដើមបណ្តឹងរដ្ឋប្បវេណី ឃិន សុខ បានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា គាត់បានឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ[1188]។ ផ្អែកតាមកំណត់ហេតុស្តាប់ចម្លើយ ជនរងគ្រោះពុំមានអាវុធក្នុងដៃ ប៉ុន្តែបានស្លៀកពាក់ឯកសណ្ឋានយោធា ហើយរឹងទទឹងមិនព្រមចាកចេញពីទីក្រុងភ្នំពេញ។ ក្នុងកាលៈទេសៈនេះ អាចនិយាយបានថា ជនរងគ្រោះពុំបានសារភាព ដូច្នេះនៅតែជាចំណុចគោលដៅយោធាដែលអង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើបញ្ហានេះ[1189]។ កំណត់ហេតុស្តាប់ចម្លើយដទៃទៀតរបស់ ខឹម សំហួន បានផ្តល់ភស្តុតាងចចាមអារ៉ាមពាក់ព័ន្ធទៅនឹងការសម្លាប់ទាហាន ដែលកំពុងព្យាបាលនៅក្នុងមន្ទីរ

---

[1185] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ឯកសារលេខ E1/148.1 ទំព័រ ៨៣ ដល់ ៨៤ និង ៩២ (ភាសាអង់គ្លេស), ទំព័រ ៧២ (ជួរ ៤ ដល់ ៥) និង ៨១ (ភាសាខ្មែរ)។ ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ឯកសារលេខ E1/149.1 ទំព័រ ១៧ ដល់ ១៨។

[1186] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩៣។

[1187] *សូមមើល* មាត្រា ៣(១) នៃអនុសញ្ញាទីក្រុងហ្សឺណែវផ្នែក I-IV។

[1188] កំណត់ហេតុស្តាប់ចម្លើយរបស់ ឃិន សុខ ឯកសារលេខ E3/5556 ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373186 ទំព័រ ៣។

[1189] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩៤។

ពេទ្យព្រះកេតុមាលា[1190]។ ដោយសារតែភស្តុតាងមានចរិតលក្ខណៈជាពាក្យចចាមអារ៉ាម ហើយសាក្សី ខឹម សំហួន ពុំបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទើបការសម្លាប់ទាំងនេះពុំត្រូវចាត់ទុកថា បានបង្ហាញហួសពីវិមតិសង្ស័យឡើយ។ ទោះជាយ៉ាងណាក្តី កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរនេះ បានបង្ហាញជាក់ច្បាស់អំពីការសម្លាប់ខុសច្បាប់នូវទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែល*បាត់បង់សមត្ថភាពប្រយុទ្ធ*។

៤៧០.កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរចុងក្រោយរបស់សាក្សី អ៊ុត សេង ដែលអង្គជំនុំជម្រះបានយោងទៅលើនោះ បានសំដៅលើហេតុការណ៍មួយដែលក្នុងនោះ មានបុគ្គលពីរនាក់“ទំនងជា”ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ដោយកងទ័ពនារីរបស់ខ្មែរក្រហម[1191]។ បើទោះបីជាព្រឹត្តិការណ៍នេះបានកើតឡើងក្រៅទីក្រុងភ្នំពេញ ហើយពុំបានគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការសម្លាប់បានកើតឡើង*ក្នុងទីក្រុងភ្នំពេញ*[1192]ក៏ដោយ ក៏នៅតែច្បាស់លាស់ថា គឺជាផ្នែកមួយនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។ ដូចការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ការរៀបរាប់របស់សាក្សី អ៊ុត សេង បានបង្ហាញនូវការបញ្ជាក់បន្ថែមទៅលើលិខិតរបស់ស្ថានទូតបារាំងប្រចាំប្រទេសថៃ ដែលរាយការណ៍អំពីបទពិសោធន៍របស់ឧត្តមសេនីយ៍ សរ ប៊ុន ថា ផ្អែកតាមលិខិតនេះ សរ ប៊ុន បានសង្កេតឃើញការសម្លាប់ទាហាននៅក្នុងតំបន់ដែលនោះដោយ“នារីកុម្មុយនីស្ត”[1193]។ ទោះជាយ៉ាងណាក្តី ដោយសារ អ៊ុត សេង ពុំបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំបានពន្យល់ពីមូលហេតុដែលគាត់អាចសន្និដ្ឋានបានថា

---

[1190] កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ខឹម សំហួន ឯកសារលេខ E3/3962 ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00287536 ទំព័រ ៤។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឯកសារនេះ បើទោះបីទំនងជាដូចជាមានកំហុសទាក់ទងទៅនឹងការសម្លាប់ទាហានដែលបានធ្វើតាមការអំពាវនាវរបស់ខ្មែរក្រហមឱ្យចូលសារភាពក៏ដោយ។ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១១ ជើងទំព័រ ១៥៣០ ដែលរៀបរាប់ភស្តុតាងគាំទ្រការយល់ឃើញដែលថា ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានធ្វើតាមការអំពាវនាវឱ្យចូលសារភាព ត្រូវបានសម្លាប់ ឬត្រូវបានធ្វើឱ្យបានខ្លួន។

[1191] កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី អ៊ុត សេង ឯកសារលេខ E3/5267 ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00271404 ទំព័រ ៣។

[1192] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៧។ *សូមមើលផងដែរ* ជើងទំព័រ ១៥១៨ (កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ុត សេង ត្រូវបានយោងទាក់ទងទៅនឹងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរក្នុងទីក្រុងភ្នំពេញ)។

[1193] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦៣ យោងទៅលើលិខិតស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ សរ ប៊ុន ឯកសារលេខ E3/2666 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499666 ទំព័រ ៦។

ជនរងគ្រោះទំនងជាទាហាន ទើបកំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរពុំអាចធ្វើជាមូលដ្ឋានសម្រាប់ការយល់ឃើញឱ្យហួសពីវិមតិសង្ស័យឡើយ។

៤៧១.ទាក់ទងទៅនឹងការរៀបរាប់អំពីការសម្លាប់នៅក្នុងឯកសារក្រៅតុលាការដទៃទៀត នួន ជា បានលើកឡើងថា ការរៀបរាប់នេះពុំគប្បីត្រូវបានយកមកពិចារណាឡើយ ដោយហេតុថា ភស្តុតាងនៃការសម្លាប់ដែលផ្តល់តាមរយៈសក្ខីកម្មផ្ទាល់ និងកំណត់ហេតុស្ដាប់ចម្លើយ“មានតិចតួច និងឃើញមានម្តងម្កាល”[1194]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សក្ខីកម្មផ្ទាល់របស់ ខឹម វ៉ាន់ឌី ពុំបានបង្ហាញថា ជាការសម្លាប់ខុសច្បាប់ឡើយ[1195] ហើយកំណត់ហេតុស្ដាប់ចម្លើយក៏ពុំមានលក្ខណៈសមស្របផងដែរ ក្នុងការបង្ហាញការសម្លាប់ទាហានទាំងនេះឱ្យហួសពីវិមតិសង្ស័យ បើទោះបីត្រូវពិនិត្យជារួមជាមួយនឹងភស្តុតាងដទៃទៀតក៏ដោយ។ ទាក់ទងទៅនឹងការរៀបរាប់ក្រៅតុលាការដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើនោះ មានការរៀបរាប់ជាច្រើនពុំបង្ហាញច្បាស់លាស់ថា ការសម្លាប់ខុសច្បាប់[1196] ពុំមានសេចក្តីលម្អិតគ្រប់គ្រាន់[1197] ត្រឹមតែបង្ហាញពីការធ្វើឱ្យបាត់ខ្លួនប៉ុណ្ណោះ[1198] ជាការពុំជាប់ពាក់ព័ន្ធទៅនឹងបទចោទនៅក្នុងសំណុំរឿង ០០២/០១ ទាក់ទងទៅនឹងលក្ខខណ្ឌភូមិសាស្ត្រ ឬពេលវេលា[1199] ឬត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាម[1200]។ តាម

---

[1194] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩៦។

[1195] *កថាខណ្ឌខាងលើ* កថាខណ្ឌ ៤៦៨។

[1196] ចម្លើយរបស់ ខាត់ ខេ ជាមួយ DC-Cam ឯកសារលេខ E3/5598 ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ ERN (ភាសាខ្មែរ) 00020698-9 ទំព័រ ១៧ ដល់ ១៨ (រៀបរាប់ថា មានបញ្ជាឱ្យសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានរកឃើញក្នុងពេលជម្លៀសទីក្រុងភ្នំពេញ ប៉ុន្តែក៏បានអះអាងផងដែរថា ការសម្លាប់ គឺជាប់ពាក់ព័ន្ធទៅនឹងអ្នកដែល“លាក់បំពួននៅក្នុងផ្ទះក្នុងអី ក្នុងលូរ ក្នុងទឹកអី” និងថា “បន្ទាប់ពីការដួលរលំក្នុងឆ្នាំ ១៩៧៥” អតីតទាហានត្រូវបានយកទៅអប់រំកែប្រែ និងឱ្យរួចជីវិត) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាល់ រតនៈ ឯកសារលេខ E3/4839 ERN (ភាសាខ្មែរ) 00526065 ទំព័រ ៥ (គាត់បានឃើញទាហាននៃរបបសាធារណៈរដ្ឋខ្មែរដែលត្រូវបានសម្លាប់ពេលព្យាយាមរត់គេច)។

[1197] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារលេខ E3/4590 ERN (ភាសាខ្មែរ) 00836195 ទំព័រ ១១៨។ របាយការណ៍របស់ H. LOCARD៖ *តំបន់បូព៌ា* ឯកសារ E3/3209 ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00822921-2 ទំព័រ ១៦ ដល់ ១៧ (ឈៀវ ស៊ីឡាង) ERN (ភាសាខ្មែរ) 00822938-9 ទំព័រ ៣៣ ដល់ ៣៤ (កេត ឈាន)។

[1198] ពាក្យបណ្តឹងរបស់ជនរងគ្រោះ ព្រុំ សុខា ឯកសារលេខ E3/5392 ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00479120 ទំព័រ ៧។

[1199] ពាក្យបណ្តឹងរបស់ជនរងគ្រោះ ព្រុំ សុខា ឯកសារលេខ E3/5392 ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00479120 ទំព័រ ៧ (សំដៅលើការសម្លាប់ទំនងជាបានកើតឡើងនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៧៨។ ផ្ទុយទៅវិញបានសន្មតថា មាន

ការកត់សម្គាល់របស់អង្គជំនុំជម្រះតុលាការកំពូលបង្ហាញឱ្យឃើញថា ការរៀបរាប់ដែលនៅសេសសល់ចំនួន ០៣ ផ្សេងទៀត បានបង្ហាញពីភស្តុតាងសក្ខានុពលជាក់លាក់ និងផ្ទាល់ចំពោះការសម្លាប់[1201] ប៉ុន្តែសាមីបុគ្គលម្ចាស់ចម្លើយនេះពុំដែលបានមកផ្តល់សក្ខីកម្មឡើយ។ អាស្រ័យហេតុនេះ ការរៀបរាប់ទាំងនេះពុំអាចបញ្ជាក់ពីការធ្វើមនុស្សឃាតឱ្យហួសពីវិមតិសង្ស័យឡើយ។ សរុបសេចក្តីមក ដោយសារភស្តុតាងបានបង្ហាញច្បាស់ថា ទាហាននៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ទាក់ទងទៅនឹងហេតុការណ៍ជាក់លាក់នៃការសម្លាប់ដែលបានយោងនៅក្នុងភស្តុតាងនោះ ពុំបានបង្ហាញ

---

ការអះអាងថា ការសម្លាប់នេះជាក់ស្តែងបានកើតឡើងនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៧៥ ដូចការអះអាងរបស់សហព្រះរាជអាជ្ញា (សារណាតបរបស់សហព្រះរាជអាជ្ញា ជើងទំព័រ ៦១២) អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកកាលបរិច្ឆេទនោះពុំមែនជាការពិត ដោយសារនៅខែ មករា ឆ្នាំ ១៩៧៥ ខ្មែរក្រហមពុំទាន់បានគ្រប់គ្រងព្រះបរមរាជវាំងក្នុងទីក្រុងភ្នំពេញនៅឡើយទេ)។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ម៉ី ណារី ឯកសារលេខ E3/5397 ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480825 ទំព័រ ៧ (បងប្អូនប្រុសរបស់គាត់ដែលត្រូវបាចោទប្រកាន់ថាជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ក្នុងភូមិមួយក្នុងខេត្តកំពង់ចាម)។

[1200] ពាក្យបណ្តឹងរបស់ជនរងគ្រោះ ម៉ី ណារី ឯកសារលេខ E3/5397 ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480825 ទំព័រ ៧ (ចាប់តាំងពីគាត់ត្រូវបានជម្លៀសចេញទីកាន់ខេត្តក្រចេះ ការសម្លាប់បងប្អូនប្រុសរបស់គាត់ដែលបានកើតឡើងនៅក្នុងខេត្តកំពង់ចាម ពុំទំនងជាត្រូវបានគាត់ឃើញដោយផ្ទាល់ភ្នែកនោះឡើយ ដូចការទទួលស្គាល់របស់សហព្រះរាជអាជ្ញា (សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦៤))។ របាយការណ៍របស់រដ្ឋាភិបាលន័រវេតាមរយៈគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ ៩ (XXXIV) (ECOSOC) ឯកសារលេខ E3/1805 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00228748 ទំព័រ ៣២ (ផាម មឿន បាននិយាយថា ឧត្តមសេនីយ៍ នាយទាហាន នាយទាហានរង ពលទាហាន និងនិយោជិកដែលខ្មែរក្រហមរកឃើញត្រូវបានប្រមូលផ្តុំ និងយកចេញនៅយប់នោះទៅកំពង់កន្ទួត"ជាកន្លែងដែលពួកគេត្រូវបានសម្លាប់" ប៉ុន្តែគាត់ទំនងជាពុំបានឃើញការសម្លាប់ទាំងនោះដោយផ្ទាល់ឡើយ)។

[1201] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម គ្រោះ ឯកសារលេខ E3/4822 ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៨ ទំព័រ ៥ ដល់ ៦ ERN (ភាសាខ្មែរ) 00523343-4 (គាត់បានឃើញទាហាននៃរបបសាធារណរដ្ឋខ្មែរ ៦ នាក់ ដែលត្រូវបានចងដៃទៅក្រោយខ្នងត្រូវបានបាញ់សម្លាប់នៅក្បែរច្រាំងទន្លេ មុនពេលប្រជាជន ៥០០ នាក់ផ្សេងទៀត ត្រូវបានបញ្ជូនទៅដាក់គុកទាំងអស់ដើម្បីអប់រំកែប្រែ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុត សូត្រ ឯកសារលេខ E3/4823 ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00523356-7 ទំព័រ ៣ ដល់ ៤ (ក្នុងពេលជម្លៀស គាត់បានឃើញទាហានរដ្ឋាភិបាលត្រូវបានពួកខ្មែរក្រហមចង និងបាញ់សម្លាប់)។ របាយការណ៍របស់រដ្ឋាភិបាលន័រវេតាមរយៈគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្សលេខ ៩ (XXXIV) (ECOSOC) ឯកសារលេខ E3/1805 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00228748 ទំព័រ ៣២ (ផាម មឿន បានឃើញការសម្លាប់ទាហានក្នុងឯកសណ្ឋានតាមមហាវិថីម៉ៅសេទុង)។

ផងដែរថា ជនរងគ្រោះគឺជាទាហានដែល*បាត់បង់សមត្ថភាពប្រយុទ្ធ* ឬបានសារភាពនៅពេលសម្លាប់។ អាស្រ័យហេតុនេះ ការសម្លាប់ជាក់លាក់នោះពុំត្រូវចាត់ទុកថា បានបង្ហាញយ៉ាងសមហេតុផលឱ្យហួសពីវិមតិសង្ស័យស្របតាមបទដ្ឋានតម្រូវក្នុងការបង្ហាញភស្តុតាង។

### ៤.ឃ.១.ខ.៣.គ.ទាហានដែលត្រូវបានយកទៅសម្លាប់នៅកន្លែងផ្សេងទៀត

៤៧២.អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើសក្ខីកម្មផ្ទាល់ ក្នុងការគាំទ្រដល់ការយល់ឃើញរបស់ខ្លួនដែលថា ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានយកទៅសម្លាប់នៅកន្លែងផ្សេងទៀត[1202]។ ការរៀបរាប់ជាលាយលក្ខណ៍អក្សរមួយចំនួនអំពីការសម្លាប់នោះ ទំនងជាភស្តុតាងចចាមអារ៉ាម[1203] ចំណែកការរៀបរាប់ភាគច្រើនដទៃទៀត ជាក់ស្តែងបង្ហាញតែពីការធ្វើឱ្យបាត់ខ្លួន ជាជាងការសម្លាប់ទៅវិញ[1204]។ ភស្តុតាងសេសសល់ផ្សេងទៀត គឺជារបាយការណ៍នៃកិច្ចសម្ភាសន៍មួយជាមួយជនភៀសខ្លួនម្នាក់[1205]។ យោងតាមរបាយការណ៍នេះ ជនភៀសខ្លួនជាទូទៅ បាននិយាយសំដៅទៅលើការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានមកដល់អមលាំង"ក្នុងឆ្នាំ ១៩៧៥"[1206]។ អាស្រ័យហេតុនេះ ពុំមានភាពច្បាស់លាស់ ថាតើការសម្លាប់ទាំងនេះបានកើត

---

[1202] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥០៨។

[1203] កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ាង ចាន់ ឯកសារលេខ E3/5505 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00398496 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រូ រ៉េន ឯកសារលេខ E3/4694 ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00365048 ទំព័រ ៨។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836265 ទំព័រ ១៨៨ (ពេជ្រ លឹម កុង)។

[1204] ពាក្យបណ្តឹងរបស់ជនរងគ្រោះ សូ សារី ឯកសារលេខ E3/5372 ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00477074 ទំព័រ ៧។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ គីម សារូ ឯកសារលេខ E3/5435 ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00483738 ទំព័រ ៧។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ សោ ធឿន ឯកសារលេខ E3/5436 ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00483749 ទំព័រ ៧។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ផាន់ យឹម ឯកសារលេខ E3/5424 ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00481187-8 ទំព័រ ៧ ដល់ ៨។

[1205] កំណត់ហេតុស្តាប់ចម្លើយ អ៊ុត សេង ឯកសារ E3/5267 ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00271404 ទំព័រ ៣។ របាយការណ៍របស់ S. HEDER និង M. MATSUSHITA៖ បទសម្ភាសន៍ជាមួយនឹងជនភៀសខ្លួនកម្ពុជានៅតាមព្រំដែនកម្ពុជាថៃ ឯកសារលេខ E3/1714 ខែ កុម្ភៈ ដល់ មីនា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 00324774 ទំព័រ ១០៣។

[1206] របាយការណ៍របស់ S. HEDER និង M. MATSUSHITA: កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជាថៃ ឯកសារលេខ E3/1714 ខែ កុម្ភៈ ដល់ មីនា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 003224774 ទំព័រ ១០៣។

ឡើងនៅក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ដែរ ឬយ៉ាងណា។ សរុបសេចក្ដីមក បើទោះបីជាមានភស្តុតាងបង្ហាញគួរឱ្យជឿជាក់បានថា មានការសម្លាប់ក៏ដោយ ក៏នៅតែពុំមានមូលដ្ឋានគ្រប់គ្រាន់សមហេតុផលសម្រាប់ការយល់ឃើញមួយដែលស្របតាមបទដ្ឋានតម្រូវក្នុងការបង្ហាញភស្តុតាងឡើយ។

## ៤.ឃ.១.ខ.៣.ឃ.ការសម្លាប់ទាហានដែលបានធ្វើតាមការអំពាវនាវ

៤៧៣.ដូចបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា[1207] អង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដាច់ភស្តុតាងនៃការធ្វើឱ្យបាត់ខ្លួនចេញពីភស្តុតាងនៃការសម្លាប់ទាហាន ដែលបានធ្វើតាមការអំពាវនាវឱ្យប្រគល់ខ្លួននោះឡើយ[1208]។ អង្គជំនុំជម្រះតុលាការកំពូលនឹងកម្រិតការពិចារណារបស់ខ្លួនត្រឹមបញ្ហា ថាតើការយល់ឃើញថា ការសម្លាប់ (ដែលខុសគ្នាពីការធ្វើឱ្យបាត់ខ្លួន)ដែលបានកើតឡើងនោះ មានលក្ខណៈពុំសមហេតុផល ដែរ ឬយ៉ាងណា បើតាមការអះអាងរបស់ នួន ជា និង ខៀវ សំផន[1209]។ ក្នុងចំណោមភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើ មានតែសក្ខីកម្មផ្ទាល់របស់សាក្សី ស៊ុំ ជា និងកំណត់ហេតុស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី សំ សិទ្ធី ខឹម សំហួន និង កុយ ម៉ុន ប៉ុណ្ណោះដែលពាក់ព័ន្ធទៅនឹងការសម្លាប់នោះ។

៤៧៤.ទាក់ទងទៅនឹង ស៊ុំ ជា គាត់បានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា ពីពីរទៅបីថ្ងៃក្រោយពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានការប្រកាសតាមមេក្រូបានធ្វើឡើងដើម្បីបញ្ចុះបញ្ចូលអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរឱ្យបង្ហាញខ្លួន និងថា ទាហានទាំងនេះក្រោយមកត្រូវបានសម្លាប់[1210]។ បើទោះបីជាការត្រឹមត្រូវដែលថា គាត់ពុំដែលឮដោយផ្ទាល់អំពីការប្រកាសតាមមេក្រូទាំងនេះ និងត្រឹមតែបានឮតាមបុគ្គលម្នាក់ដែលបម្រើការនៅកងផ្សេងប្រាប់ថា មានការសម្លាប់យ៉ាងណាក៏ដោយ[1211] ក៏ការរៀបរាប់របស់

---

[1207] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦៨។

[1208] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១១។

[1209] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩០, ៥៩៣ ដល់ ៥៩៦។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៥៥។

[1210] ប្រតិចារឹកចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ១៣ ដល់ ១៥, ២៥ ដល់ ២៦។

[1211] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ១៤, ២៥ ដល់ ២៦, ៤៦, ៤៩ ដល់ ៥០, ៨៦ (គាត់បានអះអាងថា ពុំដែលបានឃើញការសម្លាប់ណាមួយឡើយ ប៉ុន្តែបានឮព័ត៌មានទាំងនេះពី គឿន ដែលនៅក្នុងអង្គភាពជាមួយគាត់។ គាត់ក៏បានលើកឡើងថា មានអង្គភាពដទៃទៀតដាក់ការប្រកាសតាមមេក្រូយកទាហាននៃរបបសាធារណរដ្ឋខ្មែរ ប៉ុន្តែគាត់ពុំបានឮផ្ទាល់នោះទេ)។

គាត់មានលក្ខណៈលម្អិត និងបានសំអាងទៅលើប្រភពនាពេលនោះ គឺទាហានម្នាក់នៅក្នុងកងផ្សេងទៀតដែលជាប់ពាក់ព័ន្ធផ្ទាល់នៅក្នុងការសម្លាប់នោះ។ អាស្រ័យហេតុនេះ បើទោះបីជាសក្ខីកម្មនេះមានចរិតលក្ខណៈជាភស្តុតាងចចាមអារ៉ាមក៏ដោយ ក៏ពុំមែនជាការមិនសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងផ្អែកការយល់ឃើញរបស់ខ្លួនលើសក្ខីកម្មនេះដែរ ដែលតាមការពិភាក្សាខាងក្រោម បង្ហាញពីការបញ្ជាក់បន្ថែមទៅលើភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះ។

៤៧៥.ស៊ុំ ជា ក៏បានផ្តល់សក្ខីកម្មផងដែរអំពីហេតុការណ៍មួយដាច់ដោយឡែកនៃការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅទួលគោក ដែលទាហានទាំងនោះត្រូវបាន“បោកបញ្ឆោតឱ្យបង្ហាញអត្តសញ្ញាណ” តាមរយៈការផ្សព្វផ្សាយតាមមេក្រូ[1212]។ ការរៀបរាប់នេះ បើទោះបីជាមានលក្ខណៈជាពាក្យចចាមអារ៉ាមក៏ដោយ ក៏ជាការបញ្ជាក់បន្ថែមលើកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ ខឹម សំហួន បានផ្តល់សក្ខីកម្ម *ក្នុងចំណោមនោះ*អំពីការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅទួលគោកដោយបានពិពណ៌នាថា គាត់បានឃើញដំបងប្រឡាក់ឈាមដែលប្រើសម្រាប់សម្លាប់នោះ[1213]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា តុលាការអង្គហេតុសមហេតុផលអាចសន្និដ្ឋានបានថា ការសម្លាប់នៅទួលគោកនេះត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។

៤៧៦.ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី កុយ ម៉ុន គាត់បានអះអាងថា កងរបស់គាត់“ពុំបានប៉ះពាល់”ទាហាននៃរបបសាធារណរដ្ឋខ្មែរណាដែលបានសារភាពឡើយ ប៉ុន្តែគាត់ជឿថា ទាហានទាំងនេះដែលធ្វើតាមការណែនាំរបស់កងទ័ពភូមិភាគនិរតីឱ្យឡើងឡាន“ប្រហែលជាត្រូវបានសម្លាប់”[1214]។ អាស្រ័យហេតុនេះ ការអះអាងនេះផ្តល់ការបញ្ជាក់បន្ថែមលើការសម្លាប់ខុសច្បាប់នោះ។

---

[1212] ប្រតិចារិកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ៣៣។

[1213] *សូមមើលខាងលើ* កថាខណ្ឌ ៤៦៩។

[1214] កំណត់ហេតុស្តាប់ចម្លើយរបស់ កុយ ម៉ុន ឯកសារលេខ E3/369 ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00195440 ទំព័រ ៧។

៤៧៧.ទាក់ទងទៅនឹង សំ សិទ្ធី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ពាក់ព័ន្ធទៅនឹងបញ្ហាជុំវិញភាពអាចជឿជាក់ និងជឿទុកចិត្តបាននៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី សំ សិទ្ធី ដែល នួន ជា បានលើកឡើង[1215] អង្គជំនុំជម្រះបានសម្រេចកោះហៅសាក្សីរូបនេះ មកផ្តល់សក្ខីកម្មផ្ទាល់នៅដំណាក់កាលបណ្តឹងសាទុក្ខ[1216] ដែលគាត់បានផ្តល់នៅថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលតម្រូវឱ្យធ្វើការវាយតម្លៃលើភាពសមហេតុផលនៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានផ្អែកលើភស្តុតាងដែលមានអត្ថិភាពនៅពេលជំនុំជម្រះ រួមជាមួយនឹងភស្តុតាងដែលបានទទួលនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ[1217]។

៤៧៨.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ សំ សិទ្ធី បានរៀបរាប់ថា គាត់បានឃើញការសម្លាប់ប្រជាជនមួយក្រុម រួមទាំងគ្រួសាររបស់គាត់ដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1218]។ សំ សិទ្ធី បានពន្យល់ថា គាត់បានរួចផុតពីការសម្លាប់ដោយធ្វើពុតជាស្លាប់នៅពីក្រោយម្តាយរបស់គាត់ដែលត្រូវបានបាញ់សម្លាប់[1219]។ បើទោះបីជា សំ សិទ្ធី បានអះអាងទូលំទូលាយអំពីការរៀបរាប់នេះនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់គាត់ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលក្រោយពីបានសង្កេតលើអាកប្បកិរិយា និងបានវាយតម្លៃលើហេតុការណ៍ក្នុងការពិពណ៌នា បានយល់ឃើញថា សាក្សីរូបនេះពុំអាចជឿជាក់ និងទុកចិត្តបានដោយសារមូលហេតុដូចខាងក្រោម។

៤៧៩.ជាបឋម អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការរៀបរាប់របស់ សំ សិទ្ធី ពុំអាចជឿជាក់បានត្រង់ចំណុចថា គាត់អះអាងថា បានឆ្លងកាត់*ដោយផ្ទាល់* និងបានរួចផុតជីវិតពីការសម្លាប់ដែលគាត់បាន

---

[1215] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩៥ (កត់សម្គាល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយជាសម្លេងនៃកិច្ចសម្ភាសន៍របស់ សំ សិទ្ធី ត្រូវបានកាត់ផ្តាច់ដោយសារឧបករណ៍ថតសម្លេងមានបញ្ហាត្រង់ចំណុចដែលគាត់បានពិពណ៌នាថា បានឃើញការសម្លាប់ និងថា អ្នកស៊ើបអង្កេតដែលបានធ្វើបទសម្ភាសន៍នោះ ក៏មានការជាប់ពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតឡើងដូចគ្នាដែរ)។

[1216] សេចក្តីសម្រេចស្តីពីការកោះហៅសាក្សី (F2/5) កថាខណ្ឌ ២៣ និង ២៦។

[1217] សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៤២៦ (ដកស្រង់សាលដីកា*រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៧៥ ដល់ ៧៦)។

[1218] កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ឯកសារលេខ E3/5201 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00212122 ទំព័រ ៤។

[1219] កំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ឯកសារលេខ E3/5201 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00212122 ទំព័រ ៤។

ពិពណ៌នានេះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កាលៈទេសៈមួយចំនួនដែល សំ សិទ្ធី រៀបរាប់ក្នុងអំឡុងពេលផ្ដល់សក្ខីកម្មនោះ ស្ទើរតែពុំអាចជឿបាន។ ទីមួយ សក្ខីកម្មនេះពុំគួរឱ្យជឿបានឡើយដែលថា បន្ទាប់ពីបានឃើញការសម្លាប់ម្ដាយរបស់ខ្លួននោះ ក្មេងប្រុសអាយុ ១៣ ឆ្នាំ អាចនៅស្ងៀមឈឹងយ៉ាងប៉ិនប្រសប់ដោយមិនតក់ស្លុតបន្ទាប់ពីត្រូវបានបាញ់សំដៅទៅរកខ្លួន ត្រូវបានវាយនឹងដំបង និងត្រូវបានអូសទំលាក់អណ្ដូង[1220] និងពុំគួរឱ្យជឿដែលថា សំ សិទ្ធី និងប្អូនជីដូនមួយពីរនាក់ អាចរួចផុតជីវិតដោយគ្មានរងរបួស[1221] ក្រោយពីខ្មាន់កាំភ្លើងចំនួន ៦ នាក់ឈរជារង្វង់នៅជិតបានបាញ់រះសំដៅទៅរកក្នុងរយៈពេលយូរ ហើយបន្ទាប់មកមានការវាយក្បាលក្មេងៗនឹងដំបង[1222]។ ទីពីរ ឱកាសមានតិចតួចណាស់ដែលថា ផ្អែកតាមសក្ខីកម្មរបស់គាត់ ក្នុងចំណោមប្រាំពីរគ្រួសារដែលខ្មែរក្រហមបាននាំយកទៅនោះ មានតែ សំ សិទ្ធី ប្អូនស្រីតូចរបស់គាត់ និងប្អូនជីដូនមួយពីរនាក់ប៉ុណ្ណោះដែលរួចផុតអាយុជីវិតពីការសម្លាប់នេះ[1223]។ សំ សិទ្ធី ពុំបានផ្ដល់ឈ្មោះជនរងគ្រោះដទៃទៀតណាមួយនៃការសម្លាប់នេះឡើយ (បើទោះបីជាបានអះអាងថា មានសាច់ញាតិមួយចំនួននៅក្នុងក្រុមប្រជាជននោះក៏ដោយ)[1224] និងពុំបានផ្ដល់អត្តសញ្ញាណប្រជាជនដទៃទៀតដែលស្ថិតនៅក្នុងក្រុមនោះ និងអ្នកដែលនៅរស់រានមានជីវិតឡើយ ក្រៅតែពីប្អូនជីដូនមួយរបស់គាត់ប៉ុណ្ណោះ[1225]។ ទីបី ពុំមានភាពច្បាស់លាស់ថាតើ សំ សិទ្ធី បានដើរតាមក្រុមឪពុករបស់ខ្លួនយ៉ាងដូចម្ដេច បើគាត់ត្រូវបានដេញឱ្យត្រឡប់ក្រោយដោយអ្នកយាមខ្មែរក្រហម ៣ នាក់ដែលប្រដាប់ដោយកាំភ្លើងនោះ[1226] ថាតើ គាត់បានឃើញក្រុមនោះត្រូវបានយកទៅ

[1220] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ២៣ ដល់ ២៤, ៣០ ដល់ ៣១ និង ៣៥ ដល់ ៣៦។

[1221] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ២៤, ៣១ ដល់ ៣៣ (ប្អូនជីដូនមួយរបស់គាត់អត់មានឃើញត្រូវរបួសអីទេ។ ម្យ៉ាងវិញទៀត ប្អូនស្រីរបស់គាត់ត្រូវបានវាយនឹងដំបងចំក្បាល) ១០១ ដល់ ១០៦។

[1222] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ២១, ២៤, ៣៣ ដល់ ៣៤, ១០២ ដល់ ១០៣, ១០២ ដល់ ១០៣។

[1223] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ៣៧។

[1224] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ១៩។

[1225] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ១៩, ៣៧ ដល់ ៣៨ និង ៩៨ ដល់ ៩៩។

[1226] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ៥២ ("ហើយខ្ញុំហ្នឹងតូចជាងគេរត់តាមឪពុកទៅ ហើយគេដេញមកក្រោយវិញ ដេញឱ្យមកនៅជាមួយម្ដាយវិញ អត់ឱ្យទៅជាមួយឪពុកទេ។ តែខ្ញុំមិនមក ខ្ញុំនៅលួចមើលសកម្មភាពហ្នឹង"), ទំព័រ ៥៤ ("មកដល់កន្លែងទុកអីវ៉ែអីវ៉ាន់ហ្នឹង គេត្រូវបំបែកគ្នា ពីរនាក់នៅយាមប្រពន្ធ ម្នាក់នាំប្ដីចេញទៅកាប់ឈើទៅកាប់ឈើដើម្បីបោះជំរំនៅ ព្រោះវាជិតយប់ហើយ។ នៅពេលដែលបណ្ដើរចូលទៅក្នុងព្រៃនោះ ខ្ញុំក៏រត់ទៅតាម ឮថាទៅកាប់ឈើ ខ្ញុំ

បាញ់សម្លាប់យ៉ាងដូចម្ដេច[1227] បើគាត់ត្រូវត្រឡប់មកប្រាប់ក្រុមម្ដាយរបស់គាត់ប៉ុន្តែគ្មាននរណាជឿគាត់[1228] និង ចុងក្រោយ គាត់បានធ្វើដំណើរអស់ពេញមួយយប់ត្រឡប់មកវត្តច្រកស្ដេចវិញ[1229]។

៤៨០.បន្ថែមលើនេះទៀត សាក្សីរូបនេះបានគេចវេសមិនឆ្លើយនឹងសំណួរទាក់ទងទៅនឹងការលម្អិតនៃព្រឹត្តិការណ៍មុនពេលការសម្លាប់នោះ ដោយបានអះអាងដដែលៗនូវហេតុការណ៍នៃការសម្លាប់ដែលមានលក្ខណៈទូទៅ និងស្រពេចស្រពិល[1230]។ បន្ថែមលើនេះ ការដែលថា កន្លងមកមានការចុះផ្សាយក្នុងសារព័ត៌មានអំពីបទពិសោធន៍របស់គាត់[1231] អាចជាការបង្ហាញនូវអត្ថប្រយោជន៍ក្នុងការរៀបរាប់អំពីបទពិសោធន៍នេះម្ដងទៀតដោយពុំគិតពីការពិតឬយ៉ាងណានោះឡើយ។

---

រត់ទៅតាមឪពុកខ្ញុំ។ ដល់តែពេលគេដេញមកក្រោយវិញ ខ្ញុំអត់មក។ ខ្ញុំចេះតែតាមមើលគាត់រហូត។ ដល់ពេលចូលទៅផុតព្រៃនោះ ឃើញកម្លាំងប្រដាប់អាវុធប្រាំមួយនាក់ហ្នឹង ហើយឈ្លបមួយដែលនាំទៅ តែម្នាក់ទេនាំទៅ ពីរនាក់ទៀតនៅចាំប្រពន្ធកូននៅកន្លែងនេះ (កន្លែងទុកអីវ៉ែអីវ៉ាន់) យកប្រុសៗទៅមុន។ អីចឹងមានតែឈ្លបម្នាក់ទេ យកប្រុសៗទៅមុនហ្នឹងនោះ ថាទៅកាប់ឈើហ្នឹងនោះ។ នៅសល់ពីរនៅនឹងកន្លែងប្រពន្ធកូន")។

[1227] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ២៤។

[1228] *ប្រៀបធៀប*ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ៥២ ("ហើយមួយស្របក់ក្រោយមក ឮស្នូរផ្ទុះអាវុធ ខ្ញុំរត់មកប្រាប់ម្ដាយ មីងមាខាងក្រោយនេះ ថាឱ្យនាំគ្នារត់ទៅ គេយកប៉ាទៅបាញ់ចោលអស់ហើយ។ គាត់អត់ជឿ" "បាទ ខ្ញុំជឿថាឮ ព្រោះគ្រាន់តែពេលដែលបាញ់ប្រាវហើយ ខ្ញុំរត់មកក្រោយវិញ ខ្ញុំមកប្រាប់គាត់ឱ្យនាំគ្នារត់") *ជាមួយនឹង* ទំព័រ ៥៤ ("អីចឹងគ្រាន់តែក្រឡេកឃើញគេភ្ជង់ឪពុកហើយ ខ្ញុំក៏រត់មកក្រោយ ខ្ញុំថា *គេយកប៉ាទៅបាញ់ចោលហើយ*។ អីចឹងខ្ញុំឱ្យគាត់រត់ គាត់អត់រត់ទេ គាត់ថា គាត់មិនជឿខ្ញុំទេ។ ប្រហែលជាមួយម៉ោងក្រោយមក ឮផ្ទុះអាវុធ ឮផ្ទុះអាវុធនៅៗចំណុចដែលខ្ញុំសង្ស័យថាយកទៅសម្លាប់ហ្នឹងហើយ") *ជាមួយនឹង* ទំព័រ ៩៥ ("ដល់តែមួយសន្ទុះក្រោយមក មួយម៉ោងហ្នឹងហើយ យើង [ខ. គាត់ និងក្រុមម្ដាយរបស់គាត់] ឮអាវុធផ្ទុះ។ ឮអាវុធផ្ទុះ ខ្ញុំកញ្ជ្រោលឡើងម្ដងទៀត ខ្ញុំស្រែកយំកញ្ជ្រោលឡើងម្ដងទៀត ខ្ញុំរត់ចោលហ្វូងម្ដាយ ម្ដាយមីង ម្ដាយបង្កើតដែលនៅជាមួយខ្ញុំហ្នឹង ខ្ញុំរត់ចោលគាត់ទៅ គាត់ដេញចាប់ខ្ញុំប្រវាស់ប្រទោសយកមកខ្ញុំ។ មកៗវង់ចាំកន្លែងដដែលវិញ")។

[1229] ប្រតិចារឹកចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ៣៤ និង ៤៩ ដល់ ៥០។

[1230] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1ទំព័រ ១០ ដល់ ១១, ១២ ដល់ ១៣, ១៤ ដល់ ១៥, ១៩ ដល់ ២០, និង ២២។

[1231] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥ (សំ សិទ្ធី) ឯកសារលេខ F1/2.1 ទំព័រ ៤១ ដល់ ៤២, ១១០ ដល់ ១១២ (ពីរឆ្នាំមុនមានអត្ថបទចុះផ្សាយអំពីបទពិសោធន៍របស់គាត់នៅក្នុងកាសែត"កោះសន្តិភាព")។

៤៨១.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សក្ខីកម្មរបស់ សំ សិទ្ធី ខ្វះភាពអាចជឿជាក់បាន។ យោងតាមការលើកឡើងខាងលើ មានន័យថា មានភស្តុតាងដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដូចជា សក្ខីកម្មផ្ទាល់របស់ ស៊ុំ ជា ដែលបង្កើតជាមូលដ្ឋានសមហេតុផលសម្រាប់ការសន្និដ្ឋានបានថា អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានធ្វើតាមការអំពាវនាវឱ្យបង្ហាញអត្តសញ្ញាណត្រូវបានសម្លាប់។

### ៤.ឃ.១.ខ.៣.ង.ទាហានដែលត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យ

៤៨២.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជោគវាសនារបស់ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យពុំត្រូវបានដឹងឡើយ និងខ្លួនក៏ពុំអាចសន្និដ្ឋានច្បាស់លាស់ពីការធ្វើឱ្យបាត់ខ្លួនទាហានទាំងនោះថា ពួកគេត្រូវបានសម្លាប់នោះដែរ[1232]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងក៏បានអះអាងផងដែរថា "ប្រតិបត្តិការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"ត្រូវបានបង្ហាញ*ក្នុងចំណោមនោះ* តាមរយៈ"ការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានកំណត់អត្តសញ្ញាណ [...] នៅតាមប៉ុស្តិ៍ត្រួតពិនិត្យផ្សេងៗ"[1233]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មានការបង្ហាញហួសពីវិមតិសង្ស័យដែលថា យ៉ាងហោចណាស់ មានទាហានមួយចំនួនដែលត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យត្រូវបានសម្លាប់។

៤៨៣.ភស្តុតាងពាក់ព័ន្ធទៅនឹងហេតុការណ៍ជាក់ស្តែងនៃការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យ មានដូចជាលិខិតពីស្ថានទូតបារាំង កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ពាក្យបណ្តឹងរបស់ជនរងគ្រោះ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានការរៀបរាប់ចចាមអារ៉ាមរបស់ ជុំ សុខា ទៀង សុខុម និង បេង បឿន[1234]។ ដូចសហព្រះរាជអាជ្ញាបានទទួល

---

[1232] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៣ និង ៥៥៥។

[1233] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦១។

[1234] លិខិតស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្តមសេនីយ៍ សរ ប៊ុន ឯកសារលេខ E3/2666 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499667-8 ទំព័រ ៧ ដល់ ៨។ កំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ឯកសារលេខ E3/5788 ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373218 ទំព័រ ៥។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ទៀង សុខុម ឯកសារលេខ E3/5402 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480111-2 ទំព័រ ៧ ដល់ ៨។ ពាក្យសុំតាំងខ្លួនជា

ស្គាល់[1235] អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើការរៀបរាប់ទាំងនេះ ដើម្បីបង្ហាញថា បុគ្គលខ្លះ*"ក្រោយមកដឹង"*ថា ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់[1236]។ បើទោះបីជាភស្តុតាងទាំងនេះមានការបង្ហាញច្បាស់ថា មានការសម្លាប់បានកើតឡើងក៏ដោយ ក៏ដោយសារពុំមានការផ្តល់សក្ខីកម្មផ្ទាល់ពាក់ព័ន្ធបញ្ហានេះ ទើបជាការពុំសមស្របក្នុងការបង្ហាញសមហេតុផលថា ការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរបានកើតឡើងទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណរបស់ទាហានទាំងនេះនៅតាមប៉ុស្តិ៍ត្រួតពិនិត្យនានា។

## ៤.ឃ.១.ខ.៣.ច.ការរាយការណ៍អំពីការសម្លាប់នៅកៀនស្វាយ និងបាត់ដំបង

៤៨៤.ទាក់ទងទៅនឹងការយល់ឃើញអំពីការសម្លាប់នៅកៀនស្វាយ[1237] អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសក្ខីកម្មរបស់សាក្សី François PONCHAUD ដែលបានផ្តល់សក្ខីកម្មថា មនុស្សប្រុសម្នាក់ដែលគាត់បានជួបនៅស្ថានទូតបារាំងកាលពីថ្ងៃទី ២២ ឬ ២៣ ខែ មេសា ឆ្នាំ ១៩៧៥ បានប្រាប់គាត់ថា មន្ត្រីជាន់ខ្ពស់ និងទាហាន លន់ នល់ ត្រូវបានបង្ខំឱ្យសរសេរឈ្មោះលើក្តារខៀននៅកៀនស្វាយ និងបន្ទាប់មកអ្នកដែលបានធ្វើតាម ត្រូវបានសម្លាប់[1238]។ នួន ជា បានលើកឡើងថា ការរៀបរាប់នេះពុំស៊ីសង្វាក់គ្នាដោយសារបុរសម្នាក់ដែលនិយាយទៅកាន់ François PONCHAUD ពុំអាចឃើញការសម្លាប់នៅកៀនស្វាយ ដែលកើតឡើងពីរ ឬបីថ្ងៃក្រោយការជម្លៀស បន្ទាប់មកត្រូវត្រឡប់មកទីក្រុងភ្នំពេញវិញ និងចូលស្ថានទូតបារាំងដែលពេលនោះប្រជាជនកម្ពុជាទាំងអស់ត្រូវបានបង្ខំឲ្យចាកចេញពីស្ថានទូតនោះ[1239]។ ក្រៅពីភាពមិនស្របគ្នាដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់[1240] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះជាយ៉ាងណាក្តី ភស្តុតាងនេះបានង្ហាញ

---

ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន ឯកសារលេខ E3/4719 ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00418273-4 ទំព័រ ៥ ដល់ ៦។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ទៀង សុខុម ឯកសារលេខ E3/5402 ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00480111-2 ទំព័រ ៧ ដល់ ៨ (កត់សម្គាល់ថា ទៀង សុខុម ពុំបានអះអាងអំពីការកំណត់អត្តសញ្ញាណតាមប៉ុស្តិ៍ត្រួតពិនិត្យ)។

[1235] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦៧។

[1236] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៣ (សេចក្តីបញ្ជាក់បន្ថែម)។

[1237] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៤។

[1238] ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៩, ១៨ ដល់ ១៩, ៣៩ ដល់ ៤០។

[1239] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩៣។

[1240] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧៤។

01358232



ច្បាស់លាស់ថា មានការសម្លាប់កើតឡើងនៅកៀនស្វាយដែលស្ថិតនៅជិតទីក្រុងភ្នំពេញ[1241]។ ទោះជាយ៉ាងណាក្តី ភស្តុតាងដែលកម្រិតខ្សោយពុំអាចឱ្យតុលាការអង្គហេតុសមហេតុផលផ្តល់ការយល់ឃើញអំពីការសម្លាប់ឱ្យហួសពីវិមតិសង្ស័យបានឡើយ។

៤៨៥.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងក៏បានសំអាងផងដែរទៅលើសក្ខីកម្មរបស់ François PONCHAUD ទាក់ទងទៅនឹងការយល់ឃើញដែលថា ការសម្លាប់បានកើតឡើងនៅបាត់ដំបង។ ដោយសារតែព្រឹត្តិការណ៍នៅបាត់ដំបង ពុំជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទីមួយ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើភស្តុតាងនេះខាងក្រោមក្នុងបរិបទ ថាតើមានលំនាំនៃការសម្លាប់ ដែរ ឬយ៉ាងណា[1242]។

## ៤.ឃ.១.ខ.៣.ឆ.សេចក្តីសន្និដ្ឋានទាក់ទងទៅនឹងការសម្លាប់អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ

៤៨៦.ជាការសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់ ដូចជា ឡុង បូរ៉េត លន់ ណុន ព្រះអង្គម្ចាស់សិរិមតៈ និង អ៊ុង ប៊ុនហរ ជាការសមហេតុផល។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលធ្វើតាមការអំពាវនាវ ត្រូវបានបង្ហាញយ៉ាងសមហេតុផល ដោយផ្អែកលើភស្តុតាងដែលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមានដូចជា ភស្តុតាងផ្ទាល់របស់ ស៊ុំ ជា ដែលបានបញ្ជាក់បន្ថែមលើភស្តុតាងដទៃទៀត។ ភស្តុតាងបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបង្ហាញច្បាស់លាស់អំពីការសម្លាប់ខុសច្បាប់នូវទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលថា ពុំមានការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះឡើយ។

---

[1241] សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារលេខ E3/4590 ទំព័រ ១១ ERN (ភាសាខ្មែរ) 00836188 (ដែលដូចគ្នាទៅនឹងការរៀបរាប់ដែលបានសំអាងនៅក្នុងសៀវភៅរបស់ F. Ponchaud: *កម្ពុជាឆ្នាំសូន្យ* ឯកសារលេខ E243.1 ERN (ភាសាខ្មែរ) 00862316-7)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សក្ខីកម្មរបស់ François PONCHAUD ពុំមាន“ការបញ្ជាក់បន្ថែម”ពីការរៀបរាប់នេះដោយសារតែពុំមែនជាប្រភពដាច់ដោយឡែកពីគ្នានោះឡើយ។

[1242] *សូមមើលខាងក្រោម* កថាខណ្ឌ ៩១១។

## ៤.ឃ.១.គ.ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ

៤៨៧.ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងការចុះចាញ់របស់ទាហាននៃរបបសាធារណរដ្ឋខ្មែរ គណៈភូមិភាគពាយ័ព្យបានបើកកិច្ចប្រជុំមួយ ដែលបានចេញបញ្ជាឱ្យប្រមូលផ្តុំ និងសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1243]។ អាស្រ័យហេតុនេះ អតីតអ្នករដ្ឋការរាប់រយនាក់ត្រូវបានប្រមូលផ្តុំនៅសាលាខេត្តពោធិ៍សាត់ និងត្រូវបានប្រកាសប្រាប់ថា ពួកគេនឹងត្រូវទៅរៀនសូត្រ និងស្វាគមន៍សម្តេច នរោត្តម សីហនុ[1244]។ បន្ទាប់ពីកិច្ចប្រជុំនៅសាលាខេត្តនោះ មានអតីតទាហាន និងអ្នករដ្ឋការយ៉ាងតិច ២៥០ នាក់[1245] ត្រូវបានដឹកតាមឡាន[1246]យកទៅទួលពោធិ៍ជ្រៃ និងត្រូវបានសម្លាប់[1247]។ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ការសម្លាប់ទាំងនេះ គឺជាបទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1248]។

៤៨៨.នៅក្នុងសេចក្តីសន្និដ្ឋាន អង្គជំនុំជម្រះសាលាដំបូងបានសំអាងជាចម្បងទៅលើសាក្សីចំនួន ៣ នាក់ ដូចជា លឹម សាត ជាអនុបញ្ជាការកងអនុសេនាតូចនៃកងទ័ពខ្មែរក្រហម ស៊ុម អាឡាត់ ជាទាហាននៃរបបសាធារណរដ្ឋខ្មែរ និង អ៊ុំង ឆាត់ ជាកងទ័ពខ្មែរក្រហម[1249]។

៤៨៩.នួន ជា និង ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើភស្តុតាងពុំអាចទុកចិត្តបាន និង"ភស្តុតាងមិនផ្ទាល់ និងពុំជឿជាក់បាន" ក្នុងការផ្តល់ការយល់ឃើញពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ និងមានកំហុសអង្គហេតុដោយសារ"ប្រើប្រាស់វិធីសាស្ត្រពុំត្រឹមត្រូវក្នុងការវាយតម្លៃលើភស្តុតាង"[1250]។ ជាពិសេស ជនជាប់ចោទទាំងពីរបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលា

---

[1243] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៦។

[1244] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧២, ៦៧៣។

[1245] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៤។

[1246] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧៣។

[1247] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨១។

[1248] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៤។

[1249] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦០។

[1250] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥០។

ដំបូងបានសំអាងដោយពុំសមហេតុផលតែទៅលើអ្វីដែលត្រូវបានចាត់ទុកថា ជាសក្ខីកម្មពុំត្រឹមត្រូវរបស់ លឹម សាត ក្នុងការបង្ហាញថា គណៈភូមិភាគ បានចេញបញ្ជាឱ្យសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលបញ្ជានេះពុំត្រូវបានបញ្ជាក់បន្ថែមពីលំនាំនៃការប្រព្រឹត្ត និងរចនាសម្ព័ន្ធទំនាក់ទំនងឡើយ[1251]។ បន្ថែមលើនេះទៀត នួន ជា បានលើកឡើងថា ការប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្របសម្រួលភាពមិនស៊ីសង្វាក់គ្នានៅក្នុងភស្តុតាង ពុំសមហេតុផលឡើយ[1252]។ ចុងក្រោយ នួន ជា និង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះមានកំហុសក្នុងការយល់ឃើញថា មានមនុស្ស ២៥០ នាក់ ត្រូវបានសម្លាប់ ដោយបានផ្អែកទៅលើភស្តុតាងចចាមអារ៉ាម និងសក្ខីកម្មរបស់សាក្សីដែលពុំជឿទុកចិត្តបាន។ ដូច្នេះ ចំនួនទាហានដែលជាជនរងគ្រោះនោះពុំមានភស្តុតាងគាំទ្រឡើយ[1253]។

## ៤.ឃ.១.គ.១.កិច្ចប្រជុំរបស់គណៈភូមិភាគ និងការបញ្ជាសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៤៩០.ក្នុងការគាំទ្រដល់ការយល់ឃើញដែលថា គណៈភូមិភាគបានចេញបញ្ជាឱ្យប្រមូលផ្តុំ និងសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែទៅលើសាក្សី លឹម សាត មួយគត់ដែលផ្តល់សក្ខីកម្មអំពីការទទួលបញ្ជានេះ[1254]។

៤៩១.យោងតាមកំណត់ហេតុស្តាប់ចម្លើយរបស់ លឹម សាត មានកិច្ចប្រជុំមួយ(ដែលគាត់ពុំបានចូលរួម)របស់គណៈភូមិភាគដឹកនាំដោយ ញឹម រស់ តា កន និង តា សុត ប៉ុន្មានថ្ងៃមុនព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃដែល“ខ្លឹមសារប្រជុំ គឺប្រាប់មេៗខ្មែរក្រហមថា ពួកទាហា និងប៉ូលីសជំនាន់ លន់ នល់ ឱ្យតែមានពាក់ស័ក្តិត្រូវតែយកទៅសម្លាប់ចោលទាំងអស់”[1255]។ យោងតាមកំណត់ហេតុស្តាប់ចម្លើយមួយផ្សេងទៀត បទបញ្ជាដែល លឹម សាត

[1251] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦០ ដល់ ៤៦១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣១។

[1252] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥៤។

[1253] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៩, ៤៦៣ ដល់ ៤៦៦។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២៤ ដល់ ៤២៥, ៤២៧, ៤៣០ ដល់ ៤៣១។

[1254] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៦។

[1255] កំណត់ហេតុស្តាប់ចម្លើយរបស់ លឹម សាត ឯកសារលេខ E3/4601 ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00407761 ទំព័រ ៣។

បានទទួលនោះ គឺឱ្យ“ប្រមូលទាហាន និងប៉ូលីសដែលមានបណ្ដាលស័ក្តិទាំងតូចទាំងធំដែលមាននិន្នាការសម័យ លន់ នល់ យកទៅសម្លាប់ចោល”[1256]។ ទោះជាយ៉ាងណាក្ដី នៅពេលផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សាក្សីរូបនេះបានអះអាងថា គាត់ពុំបានដឹងថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវតែយកទៅសម្លាប់ចោល និងថា ការបញ្ជាត្រូវបានកម្រិតត្រឹមតែយកទាហាន និងមន្ត្រីទាំងនេះទៅរៀនសូត្រសិន ពេលត្រឡប់មកពីការរៀនសូត្រវិញ អង្គការនឹងឱ្យចូលធ្វើការវិញដដែល[1257]។

៤៩២.នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មផ្ទាល់របស់ លឹម សាត ពុំអាចជឿជាក់បានឡើយទាក់ទងទៅនឹង“ការយល់ដឹងរបស់គាត់នៅមានកម្រិតអំពីគោលបំណងឧក្រិដ្ឋនៃការបញ្ជានេះ”[1258]។ ជាការពិត លឹម សាត ឆ្លើយផ្ទុយនឹងខ្លួនឯងដែលបានបញ្ជាក់ពីដំបូងថា ការបញ្ជាសម្លាប់ដូចបានរំឭកដោយសហព្រះរាជអាជ្ញា “គឺជាការបញ្ជារបស់គណៈភូមិភាគ [តា ញឹម និង តា កន]”[1259]។ បន្ទាប់មក ទោះជាយ៉ាងណាក្ដី លឹម សាត បានបញ្ជាក់ថា “នៅពេលនោះ [គាត់ពិតជាបាននិយាយអំពីកិច្ចប្រជុំលើកទីពីរក្នុងសាលាខេត្តពោធិ៍សាត់] គេបានប្រមូលផ្ដុំទាហាន និងប៉ូលីស។ ខ្ញុំមិនដឹងចាប់អារម្មណ៍ គឺថាគេយកអ្នកទាំងនោះទៅសម្លាប់ចោលនោះឡើយ”[1260]។ ក្រោយមក លឹម សាត បានអះអាងសាជាថ្មីថា “គេប្រាប់[គាត់]ថា ពួកនេះត្រូវយកទៅសម្លាប់ចោល។ ព័ត៌មានដែលគាត់ទទួលបាន គឺថា អ្នកមានបណ្ដាស័ក្តិទាំងអស់ត្រូវទៅរៀនសូត្រសិន”[1261]។

៤៩៣.នៅពេលវាយតម្លៃអំពីភាពជឿជាក់ និងជឿទុកចិត្តបាន អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា៖

> អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា គាត់ត្រូវបានជំរុញឱ្យបន្ធូរបន្ថយ ឬកែប្រែការទទួលខុសត្រូវរបស់គាត់ចំពោះការពាក់ព័ន្ធនៅក្នុងព្រឹត្តិការណ៍ផ្សេងៗ ដែលចោទជាបញ្ហានេះ។ អង្គជំនុំជម្រះយល់

---

[1256] កំណត់ហេតុស្ដាប់ចម្លើយរបស់ លឹម សាត ឯកសារលេខ E3/364 ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00242422 ទំព័រ ២។

[1257] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ១៦, ១៩ ដល់ ២០, ៤០ ដល់ ៤១ (ដកស្រង់កំណត់ហេតុស្ដាប់ចម្លើយរបស់ លឹម សាត ឯកសារលេខ E3/4601 ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩)។ ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/188.1 ទំព័រ ១៥ ដល់ ១៦, ១៩។

[1258] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៥។

[1259] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ១៥។

[1260] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ១៧។

[1261] ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/188.1 ទំព័រ ១៩។

ឃើញថា សក្ខីកម្មរបស់ លឹម សាត ពាក់ព័ន្ធនឹងការដឹងដោយមានកម្រិតរបស់គាត់អំពីគោលបំណងឧក្រិដ្ឋនៃការបញ្ជាទាំងនេះ មិនគួរឲ្យជឿជាក់បានទេ។ ប៉ុន្តែសក្ខីកម្មដំបូងរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការបញ្ជាទាំងនេះ គឺស៊ីសង្វាក់គ្នាទៅនឹងលំនាំនៃការប្រព្រឹត្ត។ [...] លើសពីនេះទៀត សក្ខីកម្មរបស់ លឹម សាត ពាក់ព័ន្ធទៅនឹងស្ថានភាពនៃការទទួលបញ្ជាដែល“ថ្នាក់លើ”ផ្សព្វផ្សាយនោះ ក៏ស្របគ្នានឹងសំអាងហេតុរបស់អង្គជំនុំជម្រះអំពីប្រព័ន្ធទំនាក់ទំនងផងដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់ទាក់ទងទៅនឹងខ្លឹមសារនៃការបញ្ជាទាំងនេះ គឺគួរឲ្យជឿជាក់បាន[1262]។

៤៩៤.ទន្ទឹមនឹងការចោទប្រកាន់របស់ នួន ជា ដែលថា សក្ខីកម្មរបស់ លឹម សាត ពុំស៊ីសង្វាក់គ្នា និងពុំជឿទុកចិត្តបាន និងថា ជាលទ្ធផល ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល[1263] ចំណែក ខៀវ សំផន វិញបានលើកឡើងថា លឹម សាត គឺជាសាក្សី“ស្វាហាប់ និងអាចជឿទុកចិត្តបាន” ប៉ុន្តែចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយ និងការលម្អៀងទៅរកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ ជាងសក្ខីកម្មផ្ទាល់ ហេតុនេះបានរំលោភបំពានទៅលើ*គោលការណ៍ចំពោះមុខ*[1264]។

៤៩៥.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្នលើភស្តុតាង និងផ្តល់សំអាងហេតុពេញលេញទាក់ទងទៅនឹងមូលហេតុដែលខ្លួនបានសំអាងទៅលើភស្តុតាងជាលាយលក្ខណ៍អក្សររបស់ លឹម សាត បើធៀបទៅនឹងសក្ខីកម្មក្នុងតុលាការ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា “អាស្រ័យលើអង្គជំនុំជម្រះសាលាដំបូងទេ ដែលជាអ្នកវាយតម្លៃលើភាពពុំស៊ីសង្វាក់គ្នានៅក្នុងភស្តុតាងរបស់សាក្សី [...] ក្នុងការពិចារណាលើបញ្ហា ថាតើភស្តុតាងនេះបើពិចារណាជារួមអាចជឿទុកចិត្ត និងជឿជាក់បាន ហើយចុងក្រោយត្រូវទទួលយក ឬបដិសេធចោលនូវចំណុចដែលជាមូលដ្ឋាននៃភស្តុតាងនេះ ដែរឬយ៉ាងណា”[1265] និងនៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា“ខ្លឹមសារនៃការបញ្ជានេះ អាចជឿជាក់បាន”[1266]។ ដូចការកត់សម្គាល់របស់សហព្រះរាជអាជ្ញាដែរ[1267] អង្គជំនុំជម្រះសាលាដំបូង

---

[1262] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៥។

[1263] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥១។

[1264] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣០។

[1265] សាលដីកា*រឿងក្តី Popović* (ICTY) កថាខណ្ឌ ១២២៨។

[1266] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៥។

[1267] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨២។

មានតួនាទីក្នុងការពិនិត្យលើអាកប្បកិរិយារបស់ លឹម សាត និងវាយតម្លៃលើភាពអាចជឿជាក់បាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះពុំបានរំលោភបំពានលើគោលការណ៍នៃកិច្ចដំណើរការនីតិវិធីចំពោះមុខ ក្នុងការសំអាងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ លឹម សាត ជាជាងសំអាងទៅលើសក្ខីកម្មផ្ទាល់របស់សាក្សីរូបនេះ។

៤៩៦.បន្ថែមលើនេះ ទោះជា លឹម សាត គឺជាសាក្សីតែម្នាក់គត់ដែលជាមូលដ្ឋានសំអាងចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏អង្គជំនុំជម្រះបានរកឃើញនូវការបញ្ជាក់បន្ថែមត្រង់ថា (i) "មានលំនាំរួមនៃការប្រព្រឹត្ត" និង (ii) "រចនាសម្ព័ន្ធនៃការទំនាក់ទំនង"។ ទាក់ទងទៅនឹងចំណុចទីមួយ អង្គជំនុំជម្រះតុលាការកំពូលយោងទៅលើការយល់ឃើញដូចខាងក្រោម ដែលបដិសេធការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាពនៃលំនាំនៃការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1268]។ អាស្រ័យហេតុនេះ លំនាំនេះពុំអាចយកមកធ្វើជាការបញ្ជាក់បន្ថែមនៃភស្តុតាងរបស់ លឹម សាត ឡើយ។ ទោះជាយ៉ាងណាក្តី នេះពុំមែនចាត់ទុកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានសំអាងលើភស្តុតាងនៃចំណុចទីពីរនោះថា ពុំសមហេតុផលនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា "អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើមូលដ្ឋានសាក្សីតែម្នាក់បាន ប៉ុន្តែទោះជាយ៉ាងណាក្តី ភស្តុតាងនោះ ភស្តុតាងនោះត្រូវតែបានវាយតម្លៃដោយមានការប្រុងប្រយ័ត្នសមស្រប និងត្រូវមានការយកចិត្តទុកដាក់ដើម្បីទប់ស្កាត់ការជំរុញទឹកចិត្តជាមូលដ្ឋានទៅរកសាក្សីតែម្នាង"[1269]។ បន្ថែមលើនេះទៀត "អង្គជំនុំជម្រះសាលាដំបូងគប្បីយ៉ាងហោចណាស់ពន្យល់ដោយសង្ខេបពីមូលហេតុ ដែលខ្លួនបានទទួលយកភស្តុតាងរបស់សាក្សី ដែលអាចមានការជំរុញទឹកចិត្ត ឬការលើកទឹកចិត្តឱ្យដាក់បន្ទុកលើជនជាប់ចោទ។ តាមវិធីបែបនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញពីការវាយតម្លៃរបស់ខ្លួនដោយប្រុងប្រយ័ត្នលើភស្តុតាងនេះ"[1270]។ ដោយសារតែនៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សំអាងហេតុគ្រប់គ្រាន់ទាក់ទងទៅនឹងការវាយតម្លៃលើភាពអាចជឿទុកចិត្តបាន និងជឿជាក់បានរបស់ លឹម សាត អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈសមស្រប។

៤៩៧.ទាក់ទងទៅនឹងការបញ្ជាក់បន្ថែមនៃរចនាសម្ព័ន្ធទំនាក់ទំនង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បើទោះបីជារចនាសម្ព័ន្ធនេះពុំបានបញ្ជាក់បន្ថែមទៅលើខ្លឹមសារនៃសក្ខីកម្មពាក់ព័ន្ធទៅនឹងការបញ្ជា

---

[1268] *សូមមើលខាងក្រោម* កថាខណ្ឌ ៩៦២ *ជាអាទិ៍*។

[1269] សាលដីកា *រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ២៧៤។

[1270] សាលដីកា *រឿងក្តី Krajišnik* (ICTY)កថាខណ្ឌ ១៤៦។

សម្លាប់ក៏ដោយ ក៏នៅតែបង្ហាញថា សក្ខីកម្មរបស់គាត់អាចជឿទុកចិត្តបាន និងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងសមហេតុផលថា មេបញ្ជាការកងវរសេនាធំបានចេញបញ្ជានេះទៅឱ្យ លឹម សាត[1271]។

៤៩៨.ខៀវ សំផន ក៏បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើសក្ខីកម្មរបស់ លឹម សាត ក្នុងការយល់ឃើញថា តា ញឹម តា កន បានចេញបញ្ជាឱ្យប្រមូលអតីតទាហាន និងប៉ូលីស និងឱ្យសម្លាប់អ្នកទាំងនេះ ដោយសារ លឹម សាត ពុំបានចូលរួមកិច្ចប្រជុំរបស់គណៈភូមិភាគដោយផ្ទាល់ឡើយ[1272]។ តាមការពិនិត្យឡើងវិញលើសក្ខីកម្មរបស់ លឹម សាត ឃើញថា គាត់បានអះអាងច្បាស់លាស់ថា "មេបញ្ជាការកងវរសេនាធំបានប្រាប់គាត់"[1273]។ ដោយសារតែសំអាងហេតុពេញលេញរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានរំឭកខាងលើ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ពុំមានហេតុផលណាមួយដែលត្រូវបដិសេធសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះឡើយ។ បន្ថែមលើនេះទៀត ការដែលថា លឹម សាត ពុំបានចូលរួមកិច្ចប្រជុំដូចអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នោះ[1274] ពុំមែនជាកត្តាកំណត់អំពីភាពអាចជឿទុកចិត្តបាន និងទម្ងន់នៃភស្តុតាងឡើយ ដោយសារគាត់បានទទួលបញ្ជាពីមេបញ្ជាការកងវរសេនាធំបន្ទាប់ពីការប្រជុំនេះ[1275]។

៤៩៩.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ជនជាប់ចោទទាក់ទងទៅនឹងការសំអាងលើកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់សាក្សី លឹម សាត នៅក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងការបញ្ជាសម្លាប់។

## ៤.ឃ.១.គ.២.ភាពពុំស៊ីសង្វាក់គ្នាដទៃទៀតនៅក្នុងភស្តុតាងរបស់សាក្សីទាក់ទងទៅនឹងការប្រជុំនៅក្នុងសាលាខេត្តពោធិ៍សាត់

---

[1271] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៣ ដល់ ៦៦៥។

[1272] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣០។

[1273] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ៣៩។

[1274] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៣។

[1275] ប្រតិចារឹកចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ៣៩ ដល់ ៤០។

៥០០.ជនជាប់ចោទបានចង្អុលទៅលើបញ្ហាពុំស៊ីសង្វាក់គ្នា និងភាពផ្ទុយគ្នានៅក្នុងភស្តុតាងពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនៅសាលាខេត្តពោធិ៍សាត់[1276]។ អំណះអំណាងទាំងនេះមានការជាប់ពាក់ព័ន្ធទៅនឹងព័ត៌មានលម្អិត ដែលពុំបានចង្អុលបង្ហាញជាក់លាក់នៅក្នុងការយល់ឃើញផ្នែកអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខ្លឹមសារនៃភស្តុតាង ត្រូវបានយកមកពិចារណា និងធ្វើជាមូលដ្ឋានសម្រាប់ការយល់ឃើញផ្នែកអង្គហេតុ ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងសម្រាប់ធ្វើសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់របស់ខ្លួន។ ដូច្នេះ អំណះអំណាងនេះចាំបាច់ត្រូវដោះស្រាយ។

៥០១.ដំបូង នួន ជា បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ នៅពេលដែលអង្គជំនុំជម្រះបានសំអាងតែទៅលើសក្ខីកម្មរបស់ លឹម សាត ម្នាក់ប៉ុណ្ណោះក្នុងការផ្តល់ការយល់ឃើញ ដូចជា (i) របៀបនៃការបញ្ជូនសារទាក់ទងទៅនឹងការប្រជុំនៅសាលាខេត្តពោធិ៍សាត់ ត្រូវបានធ្វើឡើងទៅកាន់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ (ii) គោលបំណងនៃការប្រមូលផ្តុំអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ថាខ្មែរក្រហមបារម្ភថា ពួកគេអាចធ្វើបដិវត្តន៍ប្រឆាំងនឹង" និង (iii) បុគ្គលដែលជាអ្នកបើកឡាននោះ[1277]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ព័ត៌មាននេះ មាននៅក្នុងសក្ខីកម្មរបស់ លឹម សាត និងជាកម្មវត្ថុនៃការសួរដេញដោល[1278]។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងរបៀបនៃការបញ្ជូនសារ ពុំបានសំអាងតែលើភស្តុតាងរបស់ លឹម សាត ម្នាក់ប៉ុណ្ណោះទេ[1279]។ ដោយពិចារណា

---

[1276] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥៣ ដល់ ៤៥៧។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៣។

[1277] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥៣។

[1278] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) E1/187.1 ទំព័រ ១៩ ដល់ ២០។ ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) E1/187.1 ទំព័រ ១៧ ដល់ ១៨។

[1279] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ឯកសារលេខ E1/218.1 ទំព័រ ៥០ ដល់ ៥៤ ("ព័ត៌មានទាក់ទងទៅនឹងការហៅទៅប្រជុំត្រូវបានប្រាប់ពីមាត់មួយទៅមួយ។ ឧទាហរណ៍ សារត្រូវបានបញ្ជូនពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត")។ កំណត់ហេតុស្តាប់ចម្លើយរបស់ សៀម សឿន ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ E3/5235 ទំព័រ ៣ (បានស្តាប់ឮខ្មែរក្រហមប្រកាសអំពីអតីតទាហានដែលទៅរៀនសូត្រនៅអង្គរវត្ត)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហែម សារ៉ន ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ E3/4808 ទំព័រ ៣ ("ខ្មែរក្រហមប្រកាសតាមមេក្រូ")។ កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ុម អាឡាត់ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ ឯកសារលេខ E3/4637 ទំព័រ ៤ (លេខាតំបន់បានកោះហៅអ្នកទាំងនោះឱ្យចូលប្រជុំនៅសាលាខេត្ត)។

ផងដែរពីបញ្ហាដែល នួន ជា ពុំបានបង្ហាញ ថាតើកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងផ្នែកអង្គហេតុបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌យ៉ាងដូចម្តេចនោះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងទាំងនេះ។

៥០២.នួន ជា បានជំទាស់បន្ថែមទៀតទាក់ទងទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងថា "ទោះបីជាទាហាន និងមន្ត្រីរដ្ឋការជាច្រើនត្រូវបានអង្គភាពកងទ័ពខ្មែរក្រហមដឹកជញ្ជូនទៅចូលរួមប្រជុំក៏ដោយ ក៏ភស្តុតាងបង្ហាញថា ការចូលរួមប្រជុំរបស់ពួកគេគឺជាការស្ម័គ្រចិត្ត"[1280]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការចោទប្រកាន់អំពីកំហុសនេះ ពុំមានឥទ្ធិពលលើការយល់ឃើញទូទៅដែលថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានដឹកតាមឡានទៅសាលាខេត្តពោធិ៍សាត់ និងប្រាប់ថា ពួកគេនឹងទៅចូលគាល់សម្តេច នរោត្តម សីហនុ និងទៅរៀនសូត្រ[1281]។ តាមការពិនិត្យលើភស្តុតាងនេះឡើងវិញឃើញថា ការដែលថា ឡានរបស់ខ្មែរក្រហម បានមកដឹកអ្នកទាំងនោះទៅចូលរួមប្រជុំ ឬថា អ្នកខ្លះធ្វើដំណើរតាមរថយន្តផ្ទាល់ខ្លួនក៏ដោយចុះ ក៏ពុំមានឥទ្ធិពលលើការយល់ឃើញទូទៅនេះឡើយ[1282]។ អាស្រ័យហេតុនេះ ទាក់ទងទៅនឹងអំណះអំណាងនេះ នួន ជា គ្រាន់តែលើកឡើងនូវការបកស្រាយមួយផ្សេងអំពីភស្តុតាង ដោយពុំបានបង្ហាញកំហុសដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ទេ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ។

---

[1280] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៨។

[1281] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៥។

[1282] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ៦០ ("លោកនិយាយថា គេឱ្យលោកចាំទទួលឡានដែលប្រមូលអ្នកទាំងនោះ")។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត) ឯកសារលេខ E1/185.1 ទំព័រ ៦៤ ដល់ ៦៥ ("ខ្ញុំគ្រាន់តែសង្កេតឃើញថា អតីតទាហាន លន់ នល់ ត្រូវបានដឹកទៅតាមឡានចូលទៅសាលាខេត្ត")។ កំណត់ហេតុស្តាប់ចម្លើយរបស់ អោក ឆឹម ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ E3/5500 ទំព័រ ២ ដល់ ៣ ("ខ្ញុំឃើញខ្មែរក្រហមប្រមូលទាហាន និងប្រជាជនទៅប្រជុំនៅសាលាខេត្ត""ចំពោះអ្នករដ្ឋការ និងទាហាន លន់ នល់ ខ្ញុំឃើញអ្នកខ្លះមានជិះឡានផ្ទាល់ខ្លួនមកប្រជុំ ហើយចតឡាននៅខាងក្រៅរបងសាលាខេត្ត")។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហែម សារ៉ន ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ E3/4808 ទំព័រ ៤ ("បន្ទាប់ពីខ្មែរក្រហមបានប្រមូលផ្តុំអ្នកទាំងនោះរួច ខ្មែរក្រហមបានឱ្យអ្នកទាំងនោះមកប្រជុំនៅសាលាខេត្ត។ ខ្មែរក្រហមបានបញ្ជូនឡានយោធាទៅដឹកអ្នកទាំងនោះ")។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុន ប៊ុន ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ឯកសារលេខ E3/5344 ទំព័រ ៩ ("រូបខ្ញុំបានឃើញទាហានខ្មែរក្រហមធ្វើការដើរប្រមូលទាហាន និងកូនទាហានរបស់របប លន់ ណល់")។

01358241



៥០៣.បន្ថែមលើនេះទៀត ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា ស៊ុម អាឡាត់ ពុំអាចប្រាប់ឈ្មោះណាផ្សេងរបស់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រៅតែពីឈ្មោះរបស់អភិបាលខេត្តពោធិ៍សាត់នោះ[1283] អង្គជំនុំជម្រះតុលាការកំពូលពិចារណាដោយផ្អែកទៅលើសក្ខីកម្មនេះឃើញថា នួន ជា ពុំបានបង្ហាញត្រឹមត្រូវនូវការលើកឡើងរបស់សាក្សីនេះទេ។ ស៊ុម អាឡាត់ មិនត្រឹមតែបានផ្តល់ឈ្មោះមួយប៉ុណ្ណោះទេ (ដូចជាឈ្មោះ"ឧត្តមសេនីយ៍ លី ហួន")[1284] ដោយផ្អែកតាមការពិនិត្យប្រតិចារឹកឡើងវិញ ថែមទាំងបានបង្ហាញតាមរយៈចម្លើយរបស់គាត់ទៅនឹងសំណួរទាក់ទងទៅនឹងឈ្មោះអ្នកដែលចូលរួមប្រជុំនៅថ្ងៃទីពីរថា "មនុស្សដដែល សមាសភាពដដែល មកប្រជុំជាបន្តបន្ទាប់"[1285]ផងដែរ។

៥០៤.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា ឡានបានដឹកជាច្រើនជើង គឺជាកំហុស ពីព្រោះ ស៊ុម អាឡាត់ ពុំបានឃើញឡានដឹកច្រើនជើងនោះដោយផ្ទាល់ភ្នែកទេ[1286]អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការដែល ស៊ុម អាឡាត់ ពុំបានឃើញឡានដឹកច្រើនជើងនោះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងដោះស្រាយរួចរាល់ហើយ។ បន្ថែមលើនេះ ស៊ុម អាឡាត់ បានអះអាងថា "អ្នកដែលថា គឺចេះតែថាទេ គឺមួយជើងហ្នឹងចប់។ អត់មានឃើញរហូតរង់ចាំអត់មានឃើញទេ"[1287]។ បន្ទាប់ពីពីរ ឬបីម៉ោងក្រោយមក គាត់បានត្រឡប់ទៅផ្ទះ។ ប៉ុន្តែ សាក្សីដទៃទៀតបានពន្យល់ថា ការដឹកជញ្ជូនពីសាលាខេត្តទៅកាន់ទួលពោធិ៍ជ្រៃ ត្រូវចំណាយពេលពេញមួយថ្ងៃ[1288]។ ហេតុដូច្នេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា ជាការពុំសមហេតុផលឡើយ។

---

[1283] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥៧។

[1284] ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ឯកសារលេខ E1/218.1 ទំព័រ ៦៨។

[1285] ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ឯកសារលេខ E1/218.1 ទំព័រ ៦៧។

[1286] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥៦។

[1287] ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) E1/218.1 ទំព័រ ២៦។

[1288] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ២០១៣ ឯកសារលេខ E1/187.1 (លឹម សាត) ទំព័រ ២៤ (ការដឹកចាប់ពីម៉ោង ៩ ព្រឹក ដល់ ៥ ល្ងាច)។ កំណត់ហេតុស្តាប់ចម្លើយរបស់ សៀម សឿម ឯកសារលេខ E3/5235 ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00273438 ទំព័រ ៣ (កសិករម្នាក់រស់នៅក្នុងខេត្តពោធិ៍សាត់ បានឃើញខ្មែរក្រហមដឹកជញ្ជូនទាហានពេញមួយថ្ងៃតាំងពីព្រឹកដល់ល្ងាច)។ ធៀបនឹងឯកសាររបស់ ថេត សម្បត្តិ និង R. LEMKIN: *សត្រូវរបស់ប្រជាជន* ឯកសារលេខ E3/4001R ឈុតខ្សែវីដេអូបន្ថែម៖ *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ* ម៉ោង ៩ និង ០៩ នាទី (បុរសម្នាក់ពុំស្គាល់ឈ្មោះមកពី*កងការពារ*និយាយថា ពួកគាត់បានឮឡានបើកមកជិត [ទួលពោធិ៍ជ្រៃ]នៅម៉ោង ៧ ព្រឹក)។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយ អោក ឆឹម ឯកសារលេខ

៥០៥.ចុងក្រោយ ដូចបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង[1289] អំណះអំណាងរបស់ជនជាប់ចោទដែលថា សាក្សីដែលបានស្តាប់នោះសុទ្ធតែមិនមែនជាសាក្សីបានឃើញផ្ទាល់ភ្នែកនូវការសម្លាប់ ពុំមានឥទ្ធិពលមកលើការយល់ឃើញ ជាពិសេសបន្ទាប់ពីបានពិនិត្យលើភស្តុតាង[1290]។ បើទោះបីពុំមានសាក្សីណាមួយបានឃើញការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងភស្តុតាងមិនផ្ទាល់ដែលជឿជាក់បាន រួមទាំងភស្តុតាងចចាមអារ៉ាមក្នុងការសន្និដ្ឋានថា មានអត្ថិភាពនៃការសម្លាប់នោះ។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងរបស់ ស៊ុម អាឡាត់ ដែលនិយាយថា "បាននិយាយជាមួយទាហាន លន់ នល់ ឈ្មោះ ផាត និង ដោ ដែលបានរួចផុតពីការសម្លាប់នោះ។ ពួកគេបានប្រាប់ ស៊ុម អាឡាត់ ថា មិនទៅដល់កន្លែងទួលពោធិ៍ជ្រៃទេ ប្រហែលជានៅប្រហែល ៥០០ ទៅ ៧០០ ម៉ែត្រ ឬក៏មួយគីឡូម៉ែត្រពីខ្សែត្រៀមទាំងអស់ គឺត្រូវចុះពីឡានដើរចូលទៅជួបអង្គការ។ ប៉ុន្តែចូលទៅខ្សែទី ២ ឬខ្សែទី ៣។ ចូលខ្សែត្រៀមទី ២ គឺគេចងហើយ គេចង ចូលខ្សែទី គឺចូលដល់រណ្តៅដែលគេត្រូវបាញ់សម្លាប់"[1291]។ បន្ថែមលើបញ្ហាដែលគាត់បានទទួលឱ្យប្រមូលផ្តុំអតីតទាហានដើម្បីសម្លាប់ លឹម សាត បានផ្តល់សក្ខីកម្មថា គាត់បានឮស្នូរកាំភ្លើងតាមរយៈតេអ្វូ[1292]។ អ៊ុំង ផាត និង លឹម សាត បានពន្យល់ថា ឡានដែលដឹកអ្នកចូលប្រជុំទៅទួលពោធិ៍ជ្រៃ ពេលត្រឡប់មកវិញឃើញ

---

E3/5500 ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩ លេខ ERN (ភាសាខ្មែរ) 00366516 ទំព័រ ២ (កសិករម្នាក់នៅក្នុងមន្ទីរពេទ្យពោធិ៍សាត់នៅពេលនោះបានអះអាងថា មានការហៅទៅប្រជុំនៅម៉ោងប្រហែល ៩ ព្រឹក)។

[1289] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧៨។

[1290] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥៧។

[1291] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧៨ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ (ស៊ុម អាឡាត់) ឯកសារលេខ E1/218.1 ទំព័រ ២៩, ៧៥ ដល់ ៧៦។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ២៥ (ក៏បានឮតាមរយៈការទំនាក់ទំនងតេអ្វូពីទួលពោធិ៍ជ្រៃថា ទាហាន លន់ នល់ ម្នាក់បានរត់រួច)។ កំណត់ហេតុស្តាប់ចម្លើយរបស់ សៀម សឿម ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ E3/5235 ERN (ភាសាខ្មែរ) 00273440 ទំព័រ ៥ (មានទាហាន លន់ នល់ ពីរនាក់នៅរស់)។

[1292] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧៩ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ២៥ (គាត់បានឮស្នូរកាំភ្លើងតាមតេអ្វូ និងថា មានទាហាន លន់ នល់ ម្នាក់រត់រួច)។

ទទេ[1293]។ អ៊ុំង ឆាត ក៏បានឮផងដែរថា ពេលអ្នកភូមិបានឮស្នូរកាំភ្លើង ពួកគាត់ក៏រត់ទៅកន្លែងនោះឃើញសាកសពចងដៃទៅក្រោយ[1294]។ នៅពេលពិចារណាលើភស្តុតាងទាំងមូល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានយ៉ាងសមហេតុផល។

៥០៦.ខៀវ សំផន ក៏បានកត់សម្គាល់លើភាពមិនស៊ីសង្វាក់គ្នាក្នុងចំណោមសាក្សីពាក់ព័ន្ធទៅនឹងរយៈពេលនៃការប្រជុំនៅសាលាខេត្តពោធិ៍សាត់[1295]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាលើភាពមិនស្របគ្នា ទាក់ទងទៅនឹងអំឡុងពេលនៃការប្រជុំនោះ (មួយ ឬពីរថ្ងៃ) និងបានសន្និដ្ឋានដោយផ្អែកភស្តុតាងថា សក្ខីកម្មបានបញ្ជាក់ថា មានការប្រជុំយ៉ាងតិចពីរថ្ងៃ[1296]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ពុំបានបង្ហាញឱ្យឃើញថា ការសន្និដ្ឋាននេះពុំសមហេតុផលនោះឡើយ។

៥០៧.ចុងក្រោយ ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែល[1297] សហព្រះរាជអាជ្ញាបានទទួលស្គាល់នៅក្នុងអំឡុងពេលនៃការជំនុំជម្រះថា ភស្តុតាងនេះ ជាភស្តុតាងខ្សោយ និងបានសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីបីនាក់បន្ថែមទៀត ដែលក្នុងចំណោមនោះមានតែសាក្សី ស៊ុម អាឡាត់ ម្នាក់គត់ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នេះពុំមែនបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលទេ ហើយថា ការវាយតម្លៃលើភស្តុតាងមានកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះឡើយ។

---

[1293] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត) E1/186.1 ទំព័រ ៧៧ ដល់ ៧៨។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត) E1/186.1 ទំព័រ ៦ និង ១១។ ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) E1/187.1 ទំព័រ ២៦។

[1294] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ (អ៊ុំង ឆាត) ឯកសារលេខ E1/186.1 ទំព័រ ៩ ដល់ ១១, ១៦ ដល់ ១៨, ១៩ ដល់ ២០, ២១ ដល់ ២៤, ៧២ ដល់ ៧៦។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយរបស់ សៀម សឿម ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ E3/5235 ERN (ភាសាខ្មែរ) 00273438 ទំព័រ ៣ (កសិករម្នាក់រស់នៅខេត្តពោធិ៍សាត់បានឃើញសាកសពទាំងអស់ត្រូវបានចងដៃទៅក្រោយមានស្នាមគ្រាប់កាំភ្លើងបាញ់)។

[1295] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣២។

[1296] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៧។

[1297] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៥៨។

៥០៨.យោងតាមការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទទាក់ទងទៅនឹងការធ្វើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅទួលពោធិ៍ជ្រៃ។

## ៤.ឃ.២.ការសម្លាប់រង្គាល

៥០៩.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ទីពីរ និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ។ ដូចបានកត់សម្គាល់ខាងលើ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា បទមនុស្សឃាតដែលបានកើតឡើងត្រូវបានស្រូបបញ្ចូលទៅក្នុងបទសម្លាប់រង្គាល មានលក្ខណៈជាក់លាក់ជាង ដែលជាលទ្ធផល នួន ជា និង ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលនេះ(ដែលស្រូបបញ្ចូលបទមនុស្សឃាត) ចំពោះព្រឹត្តិការណ៍ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងនៅទួលពោធិ៍ជ្រៃ[1298]។ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរនៅក្នុងដីកាដំណោះស្រាយ (D427) បានចោទប្រកាន់ជនជាប់ចោទពីបទសម្លាប់រង្គាល ហើយពុំបានចោទប្រកាន់ពីបទមនុស្សឃាតឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទតែពីបទសម្លាប់រង្គាលប៉ុណ្ណោះ ដោយពុំបានដោះស្រាយពីបទមនុស្សឃាតនោះទេ[1299]។

### ៤.ឃ.២.ក.ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាក់ទងទៅនឹងការកំណត់និយមន័យនៃការសម្លាប់រង្គាល

៥១០.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការសម្លាប់រង្គាល គឺជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ និងថា នួន ជា និង ខៀវ សំផន "អាចដឹងគ្រប់គ្រាន់ជាមុនថា មានច្បាប់ចែង"[1300]។ អង្គជំនុំជម្រះបានយល់ឃើញថា ធាតុផ្សំ*សត្យានុម័ត*នៃការសម្លាប់រង្គាល"រួមមាន អំពើសកម្ម អំពើអកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ ដែលនាំឲ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ"

---

[1298] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៥៧។

[1299] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២៧ យោងទៅលើដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៣៨១ ដល់ ១៣៩០។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៨។

[1300] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៥។

ហើយការវាយតម្លៃធាតុផ្សំនេះបានផ្អែកតាមករណីជាក់ស្តែងនីមួយៗ[1301]។ ដោយសំអាងលើសាលក្រម *រឿងក្តី ឌុច* (001-E188) និងលើសាលក្រម *រឿងក្តី Krstić* (ICTY) អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ធាតុផ្សំ *អត្តនោម័ត*នៃបទសម្លាប់រង្គាល គឺជាចេតនា៖

> (១) សម្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬ (២) បង្ករបួសលើរូបកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឲ្យមានការស្លាប់ ដោយមានហេតុផលដឹងថា អំពើសកម្ម ឬអកម្មនោះមុខជាបង្កឲ្យមានការបាត់បង់ជីវិតមនុស្សច្រើន(*ចេតនាប្រយោល (dolus eventualis)*)[1302]។

៥១១.អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ធាតុផ្សំ*អត្តនោម័ត*នៃបទសម្លាប់រង្គាល ពុំត្រូវបានកំណត់និយមន័យដោយស៊ីសង្វាក់គ្នានៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍* និងថា "យុត្តិសាស្ត្ររបស់តុលាការកំពូលនៃតុលាការទាំងនេះ ហាក់ដូចឈានទៅលុបចោល*ចេតនាប្រយោល (dolus eventualis)* ចេញពីនិយមន័យនៃ*ធាតុផ្សំអត្តនោម័ត*ចំពោះបទសម្លាប់រង្គាល" ប៉ុន្តែបានពិចារណាឃើញថា "មិនមានមូលដ្ឋានណាមួយអាចឲ្យអង្គជំនុំជម្រះសាលាដំបូង ងាកចេញពីវិធីសាស្ត្រដំបូងដែលបានអនុវត្តនៅក្នុងសាលក្រម*រឿងក្តី Krstić* ដែលក្តោបរួមទាំង*ចេតនាប្រយោល (dolus eventualis)* និងយុត្តិសាស្ត្រដែលមាននៅមុនឆ្នាំ ១៩៧៥"[1303]។

៥១២.អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចបដិសេធអំណះអំណាងរបស់ នួន ជា ផងដែរ ដោយបានផ្អែកលើសាលក្រម*រឿងក្តី Vasiljević* (ICTY) ដែលលើកឡើងថា ជនជាប់ចោទត្រូវតែដឹងថា អំពើរបស់ខ្លួន"គឺជាផ្នែកមួយនៃ*ការសម្លាប់ក្នុងទ្រង់ទ្រាយធំ*"[1304]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក្នុង*រឿងក្តី Vasiljević* បានកំណត់លក្ខខណ្ឌនេះដោយផ្អែកលើ *រឿងក្តី Eichmann* និងសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT)។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានទាក់ទងទៅនឹងសាលក្រមនេះថា អង្គជំនុំជម្រះ"ពុំជឿជាក់ថា ការលើកឡើងទាំងនោះបង្កើតបានជាលក្ខខណ្ឌ

---

[1301] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៦។

[1302] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៧ យោងទៅលើសាលក្រម*រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ៣៣៤ និងសាលក្រម*រឿងក្តី Krstić* (ICTY) កថាខណ្ឌ ៤៩៥។

[1303] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៧។

[1304] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៨ ដល់ ៤១៩។

01358246



តម្រូវនៃធាតុផ្សំ*អត្តនោម័ត*ច្បាស់លាស់ឡើយ ប៉ុន្តែត្រឹមតែផ្ទុះបញ្ចាំងជាធម្មតាអំពីអង្គហេតុនៃរឿងក្តីនីមួយៗប៉ុណ្ណោះ”[1305]។

៥១៣.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសពីរយ៉ាងនៅក្នុងការកំណត់និយមន័យនៃធាតុផ្សំ*អត្តនោម័ត*នៃបទសម្លាប់រង្គាល ជាហេតុធ្វើឱ្យមានការយល់ឃើញដោយពុំត្រឹមត្រូវថា បទសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ[1306]។ ទីមួយ នួន ជា បានអះអាងថា ប្រសិនបើការសម្លាប់រង្គាលត្រូវបានបង្ហាញដោយផ្អែកលើការបង្កើតនូវលក្ខខណ្ឌដែលបណ្តាលឱ្យមានមនុស្សស្លាប់នោះ លក្ខខណ្ឌនោះត្រូវតែ“មានបំណង”ដើម្បីបំផ្លាញប្រជាជនមួយផ្នែក ជាជាងត្រឹមតែថា “ទំនងជា”នឹងបង្កឱ្យមានមនុស្សស្លាប់យ៉ាងច្រើននោះ(*ចេតនាប្រយោល dolus eventualis*) ដែលជាបទដ្ឋានមួយត្រូវបានអង្គជំនុំជម្រះសាលាដំបូងយកមកអនុវត្ត[1307]។ ទីពីរ នួន ជា បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់ថា ក្នុងការដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយផ្អែកតាមច្បាប់ដែលមានអត្ថិភាពត្រឹមឆ្នាំ ១៩៧៥ ចារីពុំចាំបាច់ត្រូវតែយល់ដឹងថា អំពើរបស់ខ្លួន គឺជាផ្នែកមួយនៃ“ការសម្លាប់ក្នុងទ្រង់ទ្រាយធំ”[1308]នោះទេ។

៥១៤.ខៀវ សំផន បានលើកឡើងថា បទដ្ឋាន*តែមួយគត់*ស្តីពីធាតុផ្សំ*អត្តនោម័ត*ដែលអនុវត្តបានចំពោះការសម្លាប់រង្គាលដោយសារលក្ខខណ្ឌក្នុងការរស់នៅក្នុងឆ្នាំ ១៩៧៥ ត្រូវតែជា“ចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ” និងថា ការដែលអង្គជំនុំជម្រះសាលាដំបូងយកបទដ្ឋានមួយផ្សេង ឬទាបជាងមកអនុវត្ត ដូចជា*ចេតនាប្រយោល (dolus eventualis)* គឺជាកំហុស[1309]។ ជនជាប់ចោទទាំងពីរបានអះអាងបន្ថែមទៀតថា ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានពិនិត្យមើលលើយុត្តិសាស្ត្រមុនឆ្នាំ ១៩៧៥ ជាហេតុធ្វើឱ្យមានកំហុសនៅក្នុងការសន្និដ្ឋានរបស់ខ្លួនដែលបានរំលោភលើគោលការណ៍នីត្យានុកូលភាព[1310]។

---

[1305] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៩។

[1306] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣១។

[1307] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣២ ដល់ ៣៣៧។

[1308] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣៨ ដល់ ៣៤៥។

[1309] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៣ ដល់ ៦៧។

[1310] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥ ដល់ ៦៦, ៥១១។ សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣០, ៣៣៥ ដល់ ៣៣៦, ៣៤០។

៥១៥.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ដោយផ្អែកលើសាលក្រម*រឿងក្តី* *Krstić* (ICTY) អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យយ៉ាងត្រឹមត្រូវចំពោះ*ធាតុផ្សំអត្តនោម័ត*នៃបទសម្លាប់រង្គាល ដូចគ្នាទៅនឹងបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានបញ្ជាក់នៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍*[1311]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាបានបដិសេធអំណះអំណាង របស់ នួន ជា ដែលថា ដើម្បីអាចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទសម្លាប់រង្គាលបាន លុះត្រាតែជនជាប់ចោទបានយល់ដឹងថាអំពើរបស់ខ្លួនរួមចំណែកនៅក្នុង"ការសម្លាប់ក្នុងទ្រង់ទ្រាយធំ" ដោយសារវិធីសាស្ត្រនេះពុំត្រូវបានអនុវត្តនៅក្នុងយុត្តិសាស្ត្រណាមួយក្រោយសង្គ្រាមលោកលើកទីពីរ និងត្រូវបានសម្រេចបដិសេធដោយសាលដីកា*រឿងក្តី* *Stakić* (ICTY)[1312]។ នៅគ្រប់ករណីទាំងអស់ សហព្រះរាជអាជ្ញាបានអះអាងថា ការចោទប្រកាន់របស់ នួន ជា អំពីកំហុស ពុំមានឥទ្ធិពលលើសាលក្រមនោះឡើយ ពីព្រោះបើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលទទួលយកការកំណត់និយមន័យរបស់គាត់ក៏ដោយ ក៏ នួន ជា នៅតែត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលដោយផ្អែកលើការយល់ឃើញផ្នែកអង្គហេតុ[1313]។

### ៤.ឃ.២.ក.១.ការធៀបគ្នារវាង"ទំនងជា" និង"មានបំណង"

៥១៦.អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា ជនជាប់ចោទទាំងពីរបានអះអាងថា ផ្អែកលើការអនុវត្តបទដ្ឋាន"ទំនងជា"ដែលផ្ទុយពីបទដ្ឋាន"មានបំណង"នោះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកដោយប្រាកដប្រជានូវសញ្ញាណនៃ*ចេតនាប្រយោល (dolus eventualis)* សម្រាប់បទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការយល់ឃើញខាងលើដែលថា *ចេតនាប្រយោល (dolus eventualis)* គឺធាតុផ្សំគ្រប់គ្រាន់សម្រាប់បទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1314]។ ទោះជាយ៉ាងណាក្តី ដោយផ្ទុយពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ពុំអាចនាំទៅរក"លទ្ធផលខុសពីធម្មតា"បានឡើយ បើទោះបីជាបទសម្លាប់រង្គាល និងបទមនុស្សឃាត មានលក្ខខណ្ឌតម្រូវខុសៗគ្នានោះ ទាក់ទងទៅនឹងធាតុផ្សំ*អត្តនោម័ត* ពីព្រោះនេះមានន័យថា ជនជាប់ចោទអាចត្រូវបានដាក់ពិរុទ្ធភាពពីបទមនុស្សឃាតក្នុង

---

[1311] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩៧ ដល់ ១៩៨, ជើងទំព័រ ៧៨៨ ដល់ ៧៨៩។

[1312] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០០។

[1313] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០១។

[1314] *សូមមើលខាងលើ* កថាខណ្ឌ ៥១០។

ទ្រង់ទ្រាយធំបាន ប៉ុន្តែពុំត្រូវបានដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលឡើយ"[1315]។ "បទមនុស្សឃាត" និង"បទសម្លាប់រង្គាល" គឺជាបទឧក្រិដ្ឋដាច់ដោយឡែកពីគ្នា ហើយការកំណត់និយមន័យនីមួយៗត្រូវតែមានលក្ខណៈឯករាជ្យ។

៥១៧.បទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានដាក់បញ្ចូលនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) និងតុលាការយោធាអន្តរជាតិចុងបូព៌ា (IMTFE) រួមទាំងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[1316] ជាទូទៅ ត្រូវបានកំណត់និយមន័យនៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ*មិនអចិន្ត្រៃយ៍*ថា "ជាការសម្លាប់ក្នុងទ្រង់ទ្រាយធំ"[1317]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងយុត្តិសាស្ត្ររបស់តុលាការយោធាអន្តរជាតិ (IMT) បានរួមបញ្ចូលនូវបទឧក្រិដ្ឋមួយដែលក្រោយមកត្រូវបានកំណត់ថា ជាបទប្រល័យពូជសាសន៍ ជាពិសេសនៅក្នុងបរិបទនៃ**ដំណោះស្រាយចុងក្រោយ**សម្រាប់ជនជាតិជ្វីហ្វ ដែលបង្ហាញឱ្យឃើញតាមរយៈសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ដែល នួន ជា បានយោងនោះ[1318]។ ក្នុងន័យនេះ បទសម្លាប់រង្គាល គឺជាយុត្តិសាស្ត្ររបស់បទប្រល័យពូជសាសន៍។

៥១៨.ចំពោះអំណះអំណាងពាក់ព័ន្ធទៅនឹង*រឿងក្តី Eichmann*[1319] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា តុលាការជាន់ថ្នាក់ស្រុករបស់ Jerusalem បានសម្រេចដាក់ពិរុទ្ធភាពលើ Adolf Eichmann *ក្នុងចំណោមនោះ*ពីបទសម្លាប់រង្គាលដែលជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជាបទឧក្រិដ្ឋប្រឆាំងជនជាតិជ្វីហ្វ។ តុលាការនេះបានយល់ឃើញថា ជនជាប់ចោទបានប្រព្រឹត្តដោយចេតនាក្នុងការកម្ទេចជនជាតិជ្វីហ្វទាំងមូល ឬផ្នែកខ្លះ (អនុលោមតាមច្បាប់ Israeli ដែលបានកំណត់និយមន័យជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងជនជាតិជ្វីហ្វ)

---

[1315] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩៩។

[1316] *សូមមើល* មាត្រា ៦ (គ) នៃធម្មនុញ្ញរបស់តុលាការ IMT។ មាត្រា ៥(គ) នៃធម្មនុញ្ញរបស់តុលាការ IMFTE។ មាត្រា II (១)(គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។

[1317] សាលក្រម*រឿងក្តី Karadžić* (ICTY) កថាខណ្ឌ ៤៨៣។ សាលដីកា*រឿងក្តី Lukić និង Lukić* (ICTY) កថាខណ្ឌ ៥៣៦។ សាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ២៥៩។ សាលដីកា*រឿងក្តី Seromba* (ICTR) កថាខណ្ឌ ១៨៩។

[1318] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣៥ យោងទៅលើសាលក្រមរបស់តុលាការឧក្រិដ្ឋកម្ម IMT ទំព័រ ២៤៩ ដល់ ២៥០។

[1319] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣៦។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥។

[1320] នៅរដូវក្តៅក្នុងឆ្នាំ ១៩៤១[1321]។ តុលាការបានពិចារណាលើភាពមន្ទិលសង្ស័យពាក់ព័ន្ធទៅនឹងអត្ថិភាពនៃចេតនាតម្រូវជាក់លាក់សម្រាប់អំឡុងពេលនៅមុនឆ្នាំ ១៩៤១ និងបានសន្និដ្ឋានថា "អាស្រ័យហេតុនេះ តុលាការនឹងត្រូវដោះស្រាយលើ [អំពើអមនុស្សធម៌នានាដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនោះ] ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[1322]។ ទោះជាយ៉ាងណាក្តី បើទោះបីជាសាលក្រមពាក់ព័ន្ធទៅនឹងបញ្ហានេះ មានលក្ខណៈស្រពេចស្រពិលក៏ដោយ ក៏តុលាការនេះពុំទំនងជាសម្រេចដាក់ពិរុទ្ធភាពពី *បទសម្លាប់រង្គាល* ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងអំឡុងពេលដំបូងនោះឡើយ[1323]។

---

[1320] *សូមមើលឧ.* កថាខណ្ឌ ១(ខ) នៃច្បាប់របស់អ៊ីស្រាអែលស្តីពីការនាំអ្នករួមគំនិតណាហ្ស៊ីមកកាត់ទោស ឆ្នាំ ១៩៥០ ដែលត្រូវបានចម្លងឡើងវិញនៅក្នុងសាលក្រម *រឿងក្តី Eichmann* (តុលាការថ្នាក់ស្រុក) កថាខណ្ឌ ១៦។

[1321] សាលក្រម *រឿងក្តី Eichmann* (តុលាការថ្នាក់ស្រុក) កថាខណ្ឌ ១៦៤ ដល់ ១៦៥។

[1322] សាលក្រម *រឿងក្តី Eichmann* (តុលាការថ្នាក់ស្រុក) កថាខណ្ឌ ១៨៦។

[1323] សាលក្រម *រឿងក្តី Eichmann* (តុលាការថ្នាក់ស្រុក) កថាខណ្ឌ ២០១ ដែលក្នុងនោះតុលាការបានរកឃើញថា នៅក្នុងខែ សីហា ឆ្នាំ ១៩៤១ Eichmann "បានចូលរួមក្នុងអំពើអមនុស្សធម៌ទាំងអស់ដែលបានលើកឡើងនៅក្នុងផ្នែកនៃអង្គច្បាប់[ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការបង្អត់អាហារ និងការនិរទេសប្រជាជនស៊ីវិល)"។ តុលាការបានសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ពីបទ"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជំនួសឱ្យឧក្រិដ្ឋកម្មប្រឆាំងជនជាតិជ្វីហ្វ ដោយសារសកម្មភាពរបស់គាត់នៅក្នុងការិយាល័យកណ្តាលសម្រាប់ការនិរទេសជនជាតិជ្វីហ្វនៅក្នុងទីក្រុង Vienna, Prague និង Berlin រហូតដល់ខែ តុលា ឆ្នាំ ១៩៤១ [...] និងដោយសារបានធ្វើការនិរទេសទៅកាន់ Nisko ការជម្លៀសជនជាតិជ្វីហ្វពីទឹកដីដែលជាឧបសម្ព័ន្ធរបស់អាណាចក្រ Reich នៅប៉ែកខាងកើត [...] ការបណ្តេញជនជាតិជ្វីហ្វពី Stetting និងការបណ្តេញជនជាតិជ្វីហ្វពី Baden និង Saar-Palatinate"។ *សូមមើល* សាលក្រម *រឿងក្តី Eichmann* (តុលាការថ្នាក់ស្រុក) កថាខណ្ឌ ២៤៤(៥) ដែលនៅក្នុងផ្នែកសន្និដ្ឋាននៃសាលក្រម តុលាការនេះបានបញ្ជាក់ថា ខ្លួនបានសម្រេចដាក់ពិរុទ្ធភាពលើ Eichmann ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"ត្រឹមអំឡុងពេលចាប់ពីខែ សីហា ឆ្នាំ ១៩៤១ ដល់ ខែ ឧសភា ឆ្នាំ ១៩៤៥ [...] គាត់ជាមួយនឹងអ្នកដទៃទៀតបានប្រព្រឹត្តអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការបង្អត់អាហារ និងការនិរទេសប្រជាជនស៊ីវិលជ្វីហ្វ" រួមទាំង"ថា គាត់ជាមួយនឹងអ្នកដទៃទៀត នៅក្នុងអំឡុងពេលចាប់ពីខែ មីនា ឆ្នាំ ១៩៣៨ ដល់ ខែ តុលា ឆ្នាំ ១៩៤១ បានបណ្តេញជនជាតិជ្វីហ្វចេញពីផ្ទះសម្បែងនៅក្នុងទឹកដីនៃអាណាចក្រ Old Reich, Austria និងរដ្ឋ Bohemia-Moravia ដែលត្រួតត្រា និងការពារដោយប្រទេសមហាអំណាច" និង"ត្រឹមអំឡុងពេលចាប់ពីខែ ធ្នូ ឆ្នាំ ១៩៣៩ ដល់ ខែ មីនា ឆ្នាំ ១៩៤១ គាត់ជាមួយនឹងអ្នកដទៃទៀត បាននិរទេសជនជាតិជ្វីហ្វទៅកាន់ Nisko និងការបណ្តេញជនជាតិជ្វីហ្វចេញពីតំបន់នៅក្នុងប៉ែកខាងកើតដែលជាឧបសម្ព័ន្ធរបស់អាណាចក្រ Reich និងចេញពីតំបន់អាណាចក្រ Reich ផ្ទាល់ឱ្យទៅកាន់តំបន់ត្រួតត្រាដោយអាល្លឺម៉ង់នៅក្នុងប៉ែកខាងកើត និងទៅប្រទេសបារាំង"។

៥១៩.អង្គជំនុំជម្រះតុលាការកំពូល នឹងពិចារណាបន្ថែមទៀតលើការពិភាក្សារបស់គណៈកម្មការនីតិអន្តរជាតិស្តីពីសេចក្តីព្រាងក្រមឆ្នាំ ១៩៩៦ នៃបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ (ទាក់ទងទៅនឹងមាត្រា ១៨) អំពីភាពខុសគ្នារវាងអំពើមនុស្សឃាត អំពើសម្លាប់រង្គាល និងអំពើប្រល័យពូជសាសន៍៖

> [ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល] គឺជាអំពើល្មើសខុសប្លែកគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដែលជាប់ពាក់ព័ន្ធទៅនឹងការដកហូតអាយុជីវិតរបស់ជនស្លូតត្រង់។ ការសម្លាប់រង្គាល គឺជាបទឧក្រិដ្ឋមួយដែលតាមចរិតលក្ខណៈរបស់វា គឺប្រព្រឹត្តទៅលើបុគ្គលមួយក្រុម។ បន្ថែមលើនេះ អំពើដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសនេះ ជាប់ពាក់ព័ន្ធទៅនឹងធាតុផ្សំនៃការបំផ្លាញក្នុងទ្រង់ទ្រាយធំដែលពុំមែនជាធាតុផ្សំសម្រាប់ការធ្វើមនុស្សឃាតឡើយ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ ការសម្លាប់រង្គាល គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបទប្រល័យពូជសាសន៍ត្រង់ថា បទឧក្រិដ្ឋទាំងពីរនេះ គឺសំដៅលើជនរងគ្រោះក្នុងចំនួនច្រើន។ ទោះជាយ៉ាងណាក្តី បទសម្លាប់រង្គាល អាចអនុវត្តនៅក្នុងស្ថានភាពដែលខុសប្លែកពីស្ថានភាពនៅក្នុងបទប្រល័យពូជសាសន៍។ ការសម្លាប់រង្គាលគ្របដណ្តប់លើស្ថានភាពដែលក្នុងនោះ បុគ្គលមួយក្រុមត្រូវបានសម្លាប់ដោយសារមានចរិតលក្ខណៈខុសប្លែកពីគេ[1324]។

៥២០.ដូច្នេះ ការសម្លាប់រង្គាលត្រូវតែយល់ថា ជាបទមនុស្សឃាតក្នុងទ្រង់ទ្រាយធំដែលកំណត់គោលដៅលើក្រុម ឬ(ផ្នែកណាមួយនៃ)ប្រជាជន។ នេះបង្ហាញតាមរយៈការពិនិត្យលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ[1325]។ ក្នុងន័យនេះ "ការសម្លាប់រង្គាលអាចខុសពីការធ្វើមនុស្សឃាតត្រង់ថា ការសម្លាប់រង្គាល គឺ*សំដៅលើ*ប្រជាជនមួយក្រុម ប៉ុន្តែមិនមែនលើបុគ្គលនីមួយៗទេ"[1326]។ គោលបំណងនៃការសម្លាប់រង្គាល គឺដើម្បីលុបបំបាត់បុគ្គលដែលជាផ្នែកនៃក្រុមមួយ។ ដូច្នេះ ជាការពុំស្របគ្នាជាមួយនឹងសញ្ញាណនៃ*ចេតនាប្រយោល (dolus eventualis)* ឡើយ។ ទោះជាយ៉ាងណាក្តីក៏ពុំមែនមានន័យថា បទសម្លាប់រង្គាលតម្រូវឱ្យមាន*ការដឹង*អំពីការស្លាប់ឡើយ ដូចការលើកឡើងរបស់សហព្រះរាជអាជ្ញាលើការអះអាងរបស់ នួន ជា[1327] ប៉ុន្តែ អ្វីដែលជាលក្ខខណ្ឌតម្រូវ គឺការបង្ហាញឱ្យឃើញថា ការសម្លាប់សមាជិកនៃក្រុមមួយ គឺជាចេតនារបស់ចារី ដោយពុំគិតពី

---

[1324] សេចក្តីព្រាងក្រមនៃបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិឆ្នាំ ១៩៩៦ ទំព័រ ៤៨។

[1325] សាលក្រមរបស់តុលាការ IMT ទំព័រ ២៤៧ ដល់ ២៥៥។ ឧទាហរណ៍ដទៃទៀតរួមបញ្ចូល *រឿងក្តី Hoess* (តុលាការកំពូលរបស់ប្រទេសប៉ូឡូញ) *រឿងក្តី RuSHA* ទំព័រ ៨៨ ដល់ ១៧០។

[1326] សាលក្រម *រឿងក្តី Semanza* (ICTR) កថាខណ្ឌ ៣៤០ (សេចក្តីបញ្ជាក់បន្ថែម)។

[1327] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០០។

បញ្ហា ថាតើចារីបានដឹងច្បាស់ថា ការសម្លាប់នេះនឹងកើតឡើងជាក់ស្តែង ដែរ ឬយ៉ាងណានោះឡើយ។ ការគ្រាន់តែដឹងថា មានការស្លាប់កើតឡើង ពុំគ្រប់គ្រាន់ឡើយ។

៥២១.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបកស្រាយអំពីធាតុផ្សំអត្តនោម័តនៃបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របគ្នាជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR រួមទាំងសាលក្រម *រឿងក្តី Krstić* (ICTY) ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើនោះផងដែរ[1328]។ បើទោះបីជាសាលក្រមនេះនៅក្នុងផ្នែកដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនោះ សំដៅលើការបញ្ជាក់អំពីធាតុផ្សំ*អត្តនោម័ត*សម្រាប់ការធ្វើមនុស្សឃាត (ដែលរួមបញ្ចូលសញ្ញាណនៃ*ចេតនាប្រយោល*)[1329]ក៏ដោយ ក៏សាលក្រមនេះបានកំណត់បន្ថែមលើធាតុផ្សំនៃបទសម្លាប់រង្គាល ដោយបានសន្និដ្ឋានថា ពិតជាមាន"ភស្តុតាងបង្ហាញថា ប្រជាជនមួយក្រុមត្រូវបានកំណត់គោលដៅ និងថា សមាជិករបស់ក្រុមនេះត្រូវបានសម្លាប់ ឬត្រូវបានដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌនៃការរស់នៅ ដោយមានបំណងបំផ្លាញផ្នែកសំខាន់ណាមួយនៃក្រុមនោះ"[1330]។ ដូច្នេះ បានបង្ហាញឱ្យឃើញថា ជាការពុំស្របជាមួយនឹងសញ្ញាណនៃ*ចេតនាប្រយោល (dolus eventualis)* និងអាស្រ័យហេតុនេះ បញ្ជាក់ការលើកឡើងខាងលើកាន់តែច្បាស់។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងសាលដីកា*រឿងក្តី Ntakirutimana* អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTR បានយល់ឃើញថា "បទសម្លាប់រង្គាលតម្រូវឱ្យមានការបង្ហាញថា ជនជាប់ចោទបានចូលរួមនៅក្នុងការសម្លាប់ជាប្រព័ន្ធ ឬជាទូទៅ ឬនៅក្នុងការដាក់លក្ខខណ្ឌជាទូទៅ ឬជាប្រព័ន្ធលើការរស់នៅរបស់ប្រជាជនជាច្រើន ដែលប្រាកដណាស់នឹងនាំឱ្យមានការស្លាប់ និងថា លទ្ធផលបែបនេះគឺ*ជាចេតនារបស់ជនជាប់ចោទដែលបានបង្កឡើងតាមរយៈអំពើសកម្ម ឬអកម្ម*"[1331]។ ចំណុចនេះត្រូវបានបញ្ជាក់នៅក្នុងសាលដីកា*រឿងក្តី Gacumbitsi* (ICTR)[1332]ផងដែរ។

៥២២.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅពេលយល់ឃើញថា ធាតុផ្សំ*អត្តនោម័ត*នៃបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានរួម

---

[1328] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៧។

[1329] សាលក្រម *រឿងក្តី Krstić* (ICTY) កថាខណ្ឌ ៤៩៥។

[1330] សាលក្រម *រឿងក្តី Krstić* (ICTY) កថាខណ្ឌ ៥០៣។

[1331] សាលដីកា *រឿងក្តី Ntakirutimana* (ICTR) កថាខណ្ឌ ៥២២ (សេចក្តីបញ្ជាក់បន្ថែម)។

[1332] សាលដីកា *រឿងក្តី Gacumbitsi* (ICTR) កថាខណ្ឌ ៨៦ (អនុម័តពាក្យពេចន៍"ទីបំផុតនាំទៅរក") យោងទៅលើសាលដីកា *រឿងក្តី Ntakirutimana* (ICTR) កថាខណ្ឌ ៥២២។

បញ្ចូលនូវសញ្ញាណ*ចេតនាប្រយោល (dolus eventualis)*។ ផ្ទុយទៅវិញ បទសម្លាប់រង្គាលតម្រូវឱ្យមានតែចេតនាផ្ទាល់ក្នុងការសម្លាប់ទ្រង់ទ្រាយធំ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាដូចខាងក្រោមលើឥទ្ធិពលនៃកំហុសដែលប៉ះពាល់ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បទសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងនៅទួលពោធិ៍ជ្រៃ។ ទោះជាយ៉ាងណាក្តី ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយនូវកំហុសអង្គច្បាប់ទីពីរដែល នួន ជា បានលើកឡើង។

### ៤.ឃ.២.ក.២.“ការសម្លាប់ក្នុងទ្រង់ទ្រាយធំ”

៥២៣.នួន ជា បានអះអាងថា ដើម្បីឱ្យក្លាយជាបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការស្លាប់ត្រូវតែជាផ្នែកនៃ“ការសម្លាប់ក្នុងទ្រង់ទ្រាយធំ” ដែលជនជាប់ចោទប្រាកដជាបានដឹងអំពីការសម្លាប់នេះ[1333] ហើយអំណះអំណាងនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធចោល[1334]។ នួន ជា បានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរដែលពាក់ព័ន្ធ រួមមាន*រឿងក្តី Eichmann* នៅពេលធ្វើការសម្រេច បើទោះបីជាសាលក្រម*រឿងក្តី Vasiljević* (ICTY) បានទទួលស្គាល់អត្ថិភាពនៃធាតុផ្សំនេះ ដោយផ្អែកលើយុត្តិសាស្ត្រទាំងនោះយ៉ាងណាក៏ដោយ[1335]។ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាថា បើទោះបីជា ពុំមានការទទួលស្គាល់ច្បាស់លាស់ទៅលើធាតុផ្សំអត្តនោម័តនៃបទសម្លាប់រង្គាល នៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ឬសាលក្រមរបស់តុលាការយោធាអាម៉េរិកដែលជំនុំជម្រះនៅក្នុងទីក្រុង Nuremberg ក៏ដោយ ក៏ធាតុផ្សំនៃបទឧក្រិដ្ឋនេះ ជាធម្មតាអាច“សន្និដ្ឋានចេញពីអង្គហេតុនៅពេលដែលតុលាការបានពិពណ៌នាអំពីអង្គហេតុនេះបាន” ដែលនេះជាវិធីសាស្ត្រមួយត្រូវបានអង្គជំនុំជម្រះតុលាការកំពូលយកមកប្រើប្រាស់នៅក្នុងសាលដីកា*រឿងក្តី ឌុច* (001-F28)[1336]។ នួន ជា ក៏បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូង“ពុំបានដោះ

[1333] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣៨ ដល់ ៣៤០។

[1334] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៨ ដល់ ៤១៩។

[1335] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣៨។

[1336] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៣៩។

ស្រាយនូវយុត្តិសាស្ត្រសំខាន់ៗ ដែលបង្ហាញពីទំនាក់ទំនងយ៉ាងច្បាស់លាស់រវាងការសម្លាប់រង្គាលជាមួយនឹងយុទ្ធនាការដោយមានការគិតទុកជាមុនក្នុងការសម្លាប់ ដែលរៀបចំឡើងដោយពួកណាហ្ស៊ី (Nazis)"[1337]។

៥២៤.សហព្រះរាជអាជ្ញាបានអះអាងថា នួន ជា បកស្រាយពុំត្រឹមត្រូវលើយុត្តិសាស្ត្រក្រោយសង្គ្រាមលើកទីពីរ រួមទាំងយុត្តិសាស្ត្ររបស់តុលាការ ICTY ផងដែរ[1338]។

៥២៥.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការសម្លាប់រង្គាលជាទូទៅត្រូវបានកំណត់និយមន័យថា ជា"ការសម្លាប់ក្នុងទ្រង់ទ្រាយធំ"[1339]។ ដូច្នេះ ធាតុផ្សំនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំនេះ គឺជាផ្នែកមួយនៅក្នុងសញ្ញាណនៃការសម្លាប់រង្គាល។ ធាតុផ្សំនេះមានអត្ថិភាពទាំង ធាតុ*អត្តនោម័ត* និងធាតុ*សត្យានុម័ត* ដែលមានន័យថា ការសម្លាប់ត្រូវតែកើតឡើងក្នុងទ្រង់ទ្រាយធំ និងចារីត្រូវតែដឹងអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំនេះ[1340]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការកំណត់ថា បទសម្លាប់រង្គាលតម្រូវឱ្យមានការបង្ហាញឱ្យឃើញនូវចេតនាផ្ទាល់ក្នុងការសម្លាប់ដែលមានន័យថា *ចេតនាប្រយោល (dolus eventualis)* គឺមិនគ្រប់គ្រាន់នោះឡើយ[1341]។

៥២៦.នៅក្នុងឆ្នាំ ២០០២ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុង*រឿងក្តី Vasiljević* បានបញ្ជាក់ថា តុលាការថ្នាក់ស្រុក ទី I របស់ Jerusalem ក្នុង*រឿងក្តី Eichmann* បានតម្រូវឱ្យមានការដឹងរបស់ជនជាប់ចោទអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដើម្បីបំពេញតាមលក្ខខណ្ឌធាតុផ្សំ*អត្តនោម័ត*នៃបទសម្លាប់រង្គាល[1342]។ ទោះជាយ៉ាងណាក្តី គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងនេះបានបង្ហាញពី"ការច្រឡំចូលគ្នានៅក្នុងសាលក្រម*រឿងក្តី* [*Eichmann*] នូវមូលដ្ឋានផ្នែកអង្គហេតុដែលពាក់ព័ន្ធទៅនឹង*ការសម្លាប់រង្គាល*ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង*ការសម្លាប់រង្គាល*ដែលមានគោលដៅប្រល័យពូជសាសន៍ និងថា ការសម្លាប់រង្គាល

---

[1337] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤០។

[1338] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០០។

[1339] *សូមមើលខាងលើ* កថាខណ្ឌ ៥១៧។

[1340] *សូមមើល* សាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ២៥៩។ *សូមមើលផងដែរ* សាលដីកា*រឿងក្តី Ntakirutimana* (ICTR) កថាខណ្ឌ ៥១៦។ សាលក្រម*រឿងក្តី Vasiljević* (ICTY) កថាខណ្ឌ ២២៩។

[1341] *សូមមើលខាងលើ* កថាខណ្ឌ ៥២២។

[1342] សាលក្រម*រឿងក្តី Vasiljević* (ICTY) កថាខណ្ឌ ២២៤។

"ដើរតួនាទីពិពណ៌នា"នៅក្នុងសាលក្រម*រឿងក្តី* *Eichmann*[1343]។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី* *Vasiljević* បានទទួលស្គាល់ការលំបាកក្នុងការ"កំណត់និយមន័យនៃធាតុផ្សំជាក់លាក់នៃ*បទសម្លាប់រង្គាល* ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតុលាការ Israeli បានយកមកអនុវត្តនោះ"[1344]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនេះបានសន្និដ្ឋានថា សាលក្រមនៃ*រឿងក្តី* Eichmann បានកំណត់លក្ខខណ្ឌតម្រូវសម្រាប់"ការសម្លាប់រង្គាល"ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា ត្រូវតែមានការបង្ហាញឱ្យឃើញអំពី"ការសម្លាប់ក្នុងទ្រង់ទ្រាយធំ" ដែល"សំដៅលើសមាជិកនៃក្រុមបុគ្គលមួយ (*ដូចជា* ជនជាតិជ្វីហ្វ) ហើយវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីសម្លាប់ ពុំជាប់ពាក់ព័ន្ធឡើយ ប៉ុន្តែការដឹងអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំជាលក្ខខណ្ឌតម្រូវ"[1345]។ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក៏បានយល់ឃើញផងដែរថា "ជាការពុំគ្រប់គ្រាន់ក្នុងការបង្ហាញអំពីការសម្លាប់រង្គាលថា ចារីមានចេតនាសម្លាប់បុគ្គលមួយក្រុមក្នុងទ្រង់ទ្រាយធំ ឬបង្កព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ដោយមានហេតុផលត្រឹមត្រូវដឹងថា អំពើសកម្ម ឬអកម្មរបស់ខ្លួនទំនងជានឹងបង្កឱ្យមានការស្លាប់មនុស្សដូចករណីនៃការធ្វើមនុស្សឃាត។ ជនជាប់ចោទត្រូវតែដឹងផងដែរអំពីផែនការសម្លាប់ក្រុមមនុស្សក្នុងទ្រង់ទ្រាយធំ និងត្រូវតែមានចេតនាចូលរួមនៅក្នុងផែនការនោះ"[1346]។ នៅក្នុងជើងទំព័រនៃចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានយោងទៅលើការយល់ឃើញរបស់តុលាការយោធាអន្តរជាតិ (IMT) ទាក់ទងទៅនឹងជនជាប់ចោទ Sauckel និង Fritzsche[1347]។ ទោះជាយ៉ាងណាក្តី ចំណុចដែលបានដកស្រង់ចេញពីសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ពុំបានបង្ហាញការគាំទ្រដល់ការយល់ឃើញដែលថា ជនជាប់ចោទត្រូវតែបានដឹងអំពី"ផែនការសម្លាប់ក្រុមមនុស្សក្នុងទ្រង់ទ្រាយធំ"[1348]។

---

[1343] សាលក្រម*រឿងក្តី* *Vasiljević* (ICTY) កថាខណ្ឌ ២២៤។

[1344] សាលក្រម*រឿងក្តី* *Vasiljević* (ICTY) កថាខណ្ឌ ២២៤។

[1345] សាលក្រម*រឿងក្តី* *Vasiljević* (ICTY) កថាខណ្ឌ ២២៤។

[1346] សាលក្រម*រឿងក្តី* *Vasiljević* (ICTY) កថាខណ្ឌ ២២៨។

[1347] សាលក្រម*រឿងក្តី* *Vasiljević* (ICTY) កថាខណ្ឌ ២២៨ ជើងទំព័រ ៥៨៨។

[1348] ពុំមានការបញ្ជាក់ច្បាស់លាស់ ថាតើទំព័រណាខ្លះដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY យោងទៅលើនៅក្នុងសាលក្រមរបស់តុលាការ IMT ពីព្រោះពុំបានបង្ហាញ ថាតើសំណៅនៃសាលក្រមរបស់តុលាការ IMT មួយណាដែលខ្លួនសំអាងទៅលើនោះឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ទំនងជាសំដៅទៅលើផ្នែកទាំងមូលនៃសាលក្រមដែលដោះស្រាយលើពិរុទ្ធភាពរបស់ជនជាប់ចោទទាំងពីរពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ឧ. ដូចជា* ទំព័រ ៣២០ ដល់ ៣២២ និង ៣៣៧ ដល់ ៣៣៨ នៅក្នុងសាលក្រមរបស់តុលាការ IMT។

៥២៧.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ទាំងនៅក្នុងសាលក្រម*រឿងក្តី Eichmann* ឬសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) មានបញ្ជាក់ពីអត្ថិភាពនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំ ហើយការដឹងរបស់ជនជាប់ចោទអំពីការសម្លាប់ដែលជាធាតុផ្សំនៃបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានកំណត់នៅក្នុង*រឿងក្តី Eichmann* ប៉ុន្តែមិនមាននៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ឡើយ។ ជាការពិត នៅក្នុងអត្ថបទដកស្រង់អំពីធាតុផ្សំនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំដែល នួន ជា បានយោងនោះ បានរួមបញ្ចូលយ៉ាងទូលំទូលាយនូវលក្ខខណ្ឌដែលថា ការសម្លាប់ត្រូវតែប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំ និងថា ចារីត្រូវដឹងអំពីការសម្លាប់នោះ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី Stakić* បានបដិសេធយ៉ាងច្បាស់លាស់នូវការដឹងរបស់ជនជាប់ចោទអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលជាលក្ខខណ្ឌតម្រូវនៃធាតុផ្សំ*អត្តនោម័ត* ដោយបានកត់សម្គាល់ថា ធាតុផ្សំនេះពុំមានការគាំទ្រនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់ថា បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងក្នុង*រឿងក្តី Vasiljević* នៃតុលាការ ICTY បានយល់ឃើញថា លក្ខខណ្ឌតម្រូវត្រូវតែ“ស៊ីសង្វាក់គ្នាទូលំទូលាយ”ជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការ ICTY ក៏ដោយ ក៏“ពុំមានការបង្ហាញថា លក្ខខណ្ឌនេះមានអត្ថិភាព” ហើយ“សាលក្រម*រឿងក្តី Vasiljević* ពុំបានដាក់បញ្ចូល*ការដឹងរបស់ជនជាប់ចោទអំពីការសម្លាប់ក្រុមមនុស្សក្នុងទ្រង់ទ្រាយធំ* នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយអំពីធាតុផ្សំនៃបទសម្លាប់រង្គាលឡើយ”[1349]។

៥២៨.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អត្ថិភាព និងការដឹងរបស់ជនជាប់ចោទអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំ គឺជាធាតុផ្សំនៃការសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ និងសម្រេចបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា ទាក់ទងបញ្ហានេះ។

## ៤.ឃ.២.ខ.ការសម្លាប់រង្គាលដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

៥២៩.ទាក់ទងទៅនឹងបញ្ហា ថាតើបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងដែរ ឬយ៉ាងណា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា “យ៉ាងហោចណាស់មានប្រជាជនរាប់ពាន់នាក់បានស្លាប់”ដោយសារ“ការសម្លាប់ ភាពអត់

[1349] សាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ២៥៨។

ឃ្លាន ការហេវហត់អស់កម្លាំង"នៅក្នុងអំឡុងពេលនៃការជម្លៀសនោះ[1350]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ពិតជាមានអត្ថិភាពនៃធាតុផ្សំសត្យានុម័តទ្រង់ទ្រាយធំសម្រាប់បទឧក្រិដ្ឋនៃការសម្លាប់រង្គាល[1351]។ ទាក់ទងទៅនឹងធាតុផ្សំ*អត្តនោម័ត*របស់ចារី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញពាក់ព័ន្ធទៅនឹងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងពេលនៃការផែកផេរទីក្រុងថា "មានប្រតិបត្តិការទ្រង់ទ្រាយធំ មានការរៀបចំ និងគិតទុកជាមុន ដើម្បីសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ" និងថា ផ្អែកតាមអត្ថន័យនេះ"ខ្មែរក្រហមមានចេតនាសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងទ្រង់ទ្រាយធំ" [1352]។ បន្ថែមលើនេះ ទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា កងទ័ពខ្មែរក្រហមបានប្រព្រឹត្តដោយ*ចេតនាប្រយោល* (dolus eventualis) និងមានចេតនាបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការស្លាប់ដោយមានហេតុផលត្រឹមត្រូវក្នុងការដឹងថា អំពើសកម្មឬអំពើអកម្មនោះ ទំនងជានឹងបង្កឱ្យមានការស្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ[1353]។ ផ្អែកលើមូលដ្ឋានទាំងនោះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានបានថា មានការប្រព្រឹត្តបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[1354]។

៥៣០.ជនជាប់ចោទទាំងពីរ បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ពីបទសម្លាប់រង្គាល*ក្នុងចំណោមនោះ* ដោយបានលើកឡើងផងដែរអំពីកំហុសអង្គហេតុនៅក្នុងការវាយតម្លៃលើភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង[1355]។

## ៤.ឃ.២.ខ.១.ការសម្លាប់រង្គាលលើជនស៊ីវិល

៥៣១.នួន ជា បានលើកឡើងទាក់ទងទៅនឹងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌនៃការជម្លៀសថា អង្គជំនុំជម្រះសាលាដំបូងពុំបានបែងចែក និងពិចារណាចំពោះអ្នកដែលបានស្លាប់*ដោយសារ*ការជម្លៀស ជាមួយនឹង

---

[1350] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២១។

[1351] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦០។

[1352] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦១។

[1353] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦២។

[1354] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦១ និង ៥៦២។

[1355] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤៦ ដល់ ៣៥១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦២ ដល់ ៣៦៤។

អ្នកដែលបានស្លាប់*នៅក្នុងអំឡុងពេល*នៃការជម្លៀស ប៉ុន្តែនៅពេលវាយតម្លៃលើធាតុផ្សំអំពីទ្រង់ទ្រាយធំនោះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាតែទៅលើអ្នកដែលស្លាប់*ដោយសារ*ការជម្លៀសប៉ុណ្ណោះ[1356]។ នួន ជា បានរំឭកថា យោងតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ការជម្លៀសបានចំណាយពេល"ច្រើនសប្តាហ៍"ទើបបានរួចរាល់[1357] និងបានអះអាងថា យោងតាមទិន្នន័យស្ថិតិ អត្រាមរណភាពជាធម្មតាសម្រាប់ប្រជាជនរស់នៅក្នុងទីក្រុងដែលមានទំហំប៉ុនទីក្រុងភ្នំពេញ គឺប្រហែលជា ៤០០០ នាក់[1358]។ នួន ជា បានអះអាងថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងគ្មានភស្តុតាងបញ្ជាក់ឡើយ ជាពិសេស ចម្លើយរបស់អ្នកដែលបានអះអាងថា មានការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស និងមិនមានភស្តុតាងបង្ហាញថា មានជនរងគ្រោះបានស្លាប់ដោយសារការជម្លៀសនោះឡើយ និងជាពិសេស នួន ជា បានកត់សម្គាល់លើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះក្រុមងាយទទួលរងគ្រោះជាងគេបំផុត ដែលងាយនឹងស្លាប់នៅពេលជម្លៀសនោះ[1359]។

៥៣២.តាមទស្សនរបស់ នួន ជា ថា ដោយផ្អែកលើចំនួនប្រជាជនរស់នៅទីក្រុងភ្នំពេញ តាមអត្រាមរណភាពជាធម្មតា ការស្លាប់ដោយលក្ខខណ្ឌផ្សេងៗ អាចមានចំនួនច្រើន ដូច្នេះ ពុំមានទំនាក់ទំនងហេតុ និងផលចំពោះអំពើរបស់ នួន ជា ជាមួយនឹងការស្លាប់របស់ជនរងគ្រោះដោយសារការជម្លៀសឡើយ[1360]។ នួន ជា បានរំឭកថា លក្ខខណ្ឌក្នុងទីក្រុងភ្នំពេញនៅពេលជម្លៀសនោះមានលក្ខណៈធ្ងន់ធ្ងររួចទៅហើយ និងបានលើកឡើងថា ដូច្នេះ អត្រាមរណភាពអាចខ្ពស់ជាងនេះទៀត[1361]។

៥៣៣.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងត្រឹមត្រូវថា ធាតុផ្សំទំហំធំនៃបទសម្លាប់រង្គាល ត្រូវបានបំពេញដោយផ្អែកលើភស្តុតាងពាក់ព័ន្ធទាំងមូល[1362]។ សហព្រះរាជអាជ្ញា

---

[1356] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤៧ ដល់ ៣៥១។ *សូមមើលផងដែរ* កថាខណ្ឌ ៤២៩។

[1357] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤៨ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៧។

[1358] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤៨។

[1359] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៥១។

[1360] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤៧ ដល់ ៣៥១។

[1361] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤៩។ *សូមមើលផងដែរ* កថាខណ្ឌ ៤២៩។

[1362] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០២ ដល់ ២០៦។

បានលើកឡើងថា ការសំអាងរបស់ នួន ជា ទៅលើប្រភពដែលនៅក្រៅកំណត់ត្រានៃការជំនុំជម្រះដែលបង្ហាញថា ការស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសពុំមានចំនួនលើសពីអត្រាមរណភាពធម្មតានោះ ជាការពុំត្រឹមត្រូវឡើយ[1363]។

៥៣៤.អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY នៅក្នុង*រឿងក្តី Čelebići* ដែលថា៖

> គោលការណ៍នីត្យានុកូលភាពដែលទទួលស្គាល់ជាទូទៅបានកំណត់ថា ប្រសិនបើចារីបង្កព្យសនកម្មដល់ជនរងគ្រោះ ចារីជាត្រូវទទួលខុសត្រូវចំពោះជនរងគ្រោះ។ ដូច្នេះ ប្រសិនបើចារីបានផ្តាច់ជីវិតជនរងគ្រោះតាមរយៈអំពើរបស់ខ្លួន តាមផ្លូវច្បាប់ពុំអាចនិយាយថា ជនរងគ្រោះអាចស្លាប់ភ្លាមៗ ដោយសារមូលហេតុអ្វីផ្សេងនោះក្រៅពីអំពើរបស់ចារីឡើយ។ ក្នុងការបង្ហាញពីអត្ថិភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក្នុងករណីដែលការដាក់លក្ខខណ្ឌលើរូបកាយបណ្តាលឱ្យជនរងគ្រោះស្លាប់នោះ ដូច្នេះជាចាំបាច់ត្រឹមតែបង្ហាញឃើញថា អំពើរបស់ជនជាប់ចោទបានរួមចំណែកក្នុងការធ្វើឱ្យជនរងគ្រោះស្លាប់ប៉ុណ្ណោះ[1364]។

៥៣៥.ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ប្រជាជនជាច្រើនបានស្លាប់ដោយសារលក្ខខណ្ឌនៅក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ។ អំណះអំណាងរបស់ នួន ជា ពុំសមស្របឡើយដែលលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល ទាក់ទងទៅនឹងទំនាក់ទំនងហេតុ និងផលរវាងលក្ខខណ្ឌនៃការជម្លៀស និងការស្លាប់របស់ជនរងគ្រោះនោះ។ អាស្រ័យហេតុនេះ ដោយស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុង*រឿងក្តី Čelebići* ដែលអង្គជំនុំជម្រះតុលាការកំពូលបានរំឭកខាងលើឃើញថា តាមផ្លូវច្បាប់ពុំអាចនិយាយបានថា ជនរងគ្រោះអាចស្លាប់ដោយសារមូលហេតុផ្សេង មិនមែនស្លាប់ដោយសារលក្ខខណ្ឌដែលពួកគេទទួលរងនៅក្នុងអំឡុងពេលនៃការជម្លៀសនោះទេ។

៥៣៦.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈសមហេតុផលដែលថា "យ៉ាងហោចណាស់មានប្រជាជនរាប់ពាន់នាក់បានស្លាប់"

---

[1363] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០៥។

[1364] សាលក្រម*រឿងក្តី Čelebići* (ICTY) កថាខណ្ឌ ៩០៩។ *សូមមើលផងដែរ រឿងក្តី Renoth* (តុលាការយោធាចក្រភពអង់គ្លេសប្រទេសអាល្លឺម៉ង់) ទំព័រ ៧៦។

នៅក្នុងអំឡុងពេលនៃការជម្លៀសដោយសារ"ការសម្លាប់ ភាពអត់ឃ្លាន និងការហេវហត់អស់កម្លាំង"[1365] (ដែលជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានស្តីពីធាតុផ្សំសត្យានុម័តពីទំហំ[1366])។ ដូចបានកត់សម្គាល់ខាងលើ នៅពេលពិភាក្សាអំពីបទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឃើញមានតែភស្តុតាងតិចតួចប៉ុណ្ណោះដែលអាចជឿទុកចិត្តបានទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិល និងការស្លាប់ដែលបានកើតឡើងដោយសារលក្ខខណ្ឌនោះ។ បើទោះបីទំនងជាមានការស្លាប់បានកើតឡើងច្រើនជាងការបង្ហាញតាមរយៈភស្តុតាងក៏ដោយ ក៏ចំនួននៃការស្លាប់ដែលបានបង្ហាញនេះពុំគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូង នៅពេលផ្តល់ការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងធាតុផ្សំសត្យានុម័តពីទំហំបានសំអាង[1367]ទៅលើការប៉ាន់ស្មានចំនួនមនុស្សស្លាប់ជាសរុបនៅក្នុងការជម្លៀសចេញពីទីក្រុងភ្នំពេញ ដូចជាលើកិច្ចសម្ភាសន៍ឆ្នាំ ១៩៧៧ របស់ អៀង សារី ជាមួយទស្សនាវដ្តីព័ត៌មានអាល្លឺម៉ង់(ដែលបានអះអាងថា "មានប្រជាជន ២.០០០ ទៅ ៣.០០០ នាក់បានស្លាប់នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ)[1368] ដែលជាការប៉ាន់ប្រមាណរបស់ Ben KIERMAN (ផ្អែកតាមការសម្ភាសន៍ជាមួយមនុស្ស ៣៦ នាក់ដែលត្រូវបានគេជម្លៀសបានប្រាប់គាត់ថា ហ្វូងមនុស្សដែលពួកគាត់ធ្វើដំណើរជាមួយនោះមានចំនួន ៣៧៦ នាក់ ក្នុងនោះមានមនុស្សពីរនាក់ដែលម្នាក់ជាទារកអាយុមួយខែ និងស្ត្រីចាស់ជរាម្នាក់បានស្លាប់តាមផ្លូវដែលគិតជាអត្រាស្លាប់ គឺស្មើនឹង ០.៥៣ ភាគរយដែលអាចស្មើនឹងចំនួនស្លាប់សរុប ១០.៦០០ នាក់ ក្នុងចំណោមប្រជាជនពីរលាននាក់)[1369] និងការប៉ាន់ស្មានរបស់ Philip SHORT (ផ្អែកតាមសៀវភៅរបស់គាត់អះអាងថា ស្លាប់ ២០.០០០ នាក់ ដែលគាត់ចាត់ទុកថា ជា"តួលេខមធ្យម"ក្នុងចំណោមការប៉ាន់ប្រមាណផ្សេងៗគ្នា ប៉ុន្តែបានអះអាងថា ចំនួនមនុស្សស្លាប់សរុបនោះ"គ្មានការបញ្ជាក់")[1370]។

---

[1365] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២១។

[1366] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦០។

[1367] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២១ ជើងទំព័រ ១៥៦២។

[1368] កិច្ចសម្ភាសន៍របស់ Der Spiegel ជាមួយ អៀង សារី ឯកសារលេខ E3/1589 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00796757 ទំព័រ ២។

[1369] សៀវភៅរបស់ Ben KIERMAN ចំណងជើងថា៖ *របប ប៉ុល ពត –ពូជសាសន៍ អំណាច និងប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម* ឯកសារលេខ E3/1593 ERN (ភាសាខ្មែរ) 00637430 ទំព័រ ៧៥។

[1370] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ៣១ ដល់ ៣២។

៥៣៧.ចំពោះភស្តុតាងនេះ មានតែការប៉ាន់ស្មានរបស់ Ben KIERMAN ប៉ុណ្ណោះដែលពន្យល់លម្អិតពីមូលដ្ឋានផ្នែកអង្គហេតុ ប៉ុន្តែបានផ្អែកលើភស្តុតាងមួយចំនួនតូចដែលមានមូលដ្ឋានខ្សោយពេកមិនអាចគាំទ្រការយល់ឃើញមួយឱ្យហួសពីវិមតិសង្ស័យបានឡើយ។ Philip SHORT បានទទួលស្គាល់ជាក់លាក់នូវលទ្ធភាពពុំអាចធ្វើទៅបានក្នុងការបង្ហាញអំពីចំនួនមនុស្សស្លាប់ជាសរុបបានឡើយ[1371]។ ហាក់បីដូចជាថា អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមដោះស្រាយលើភស្តុតាងដែលមានកម្រិតទាំងនេះ ដោយពុំបានផ្តល់ការយល់ឃើញជាក់លាក់ទាក់ទងទៅនឹងចំនួនមនុស្សស្លាប់ជាអប្បបរមា ប៉ុន្តែផ្ទុយទៅវិញបានបញ្ជាក់ថា "យ៉ាងហោចណាស់មានប្រជាជនរាប់ពាន់នាក់បានស្លាប់"[1372]។ ទោះជាយ៉ាងណាក្តី ដោយសារតែភស្តុតាងមានកម្រិតតិចតួចក្នុងការបង្ហាញការស្លាប់ជាក់ស្តែង ក្នុងអំឡុងពេលនៃការជម្លៀស និងមានមូលដ្ឋានខ្សោយក្នុងការសំអាងទៅលើដើម្បីបង្ហាញចំនួនមនុស្សស្លាប់ជាសរុប អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចផ្តល់ការយល់ឃើញបានបែបនេះឡើយ។ អាស្រ័យហេតុនេះ ធាតុផ្សំសត្យានុម័តពីទំហំនៃបទសម្លាប់រង្គាលពុំអាចនិយាយបានថា ត្រូវបានបង្ហាញទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយឡើយ។

៥៣៨.ខៀវ សំផន បានលើកឡើងថា ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាជនស៊ីវិលត្រូវបានសម្លាប់រង្គាលក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់បទដ្ឋានស្តីពីធាតុផ្សំ*អត្តនោម័ត*ពុំត្រឹមត្រូវ[1373]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបានទទួលយកទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះរួចហើយ[1374]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញជាក់លាក់ថា ទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌ ខ្មែរក្រហមបានប្រព្រឹត្ត*ដោយចេតនាប្រយោល (dolus eventualis)*[1375] ដែលអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ជាការពុំគ្រប់គ្រាន់ក្នុងការបង្ហាញនូវធាតុផ្សំ*អត្តនោម័ត*តម្រូវសម្រាប់បទសម្លាប់រង្គាលឡើយ។

---

[1371] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/189.1 ទំព័រ ៣២។

[1372] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២១។

[1373] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦២ ដល់ ៣៦៤។

[1374] *សូមមើលខាងលើ* កថាខណ្ឌ ៥២២។

[1375] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦២។

៥៣៩.សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា មានអត្ថិភាពនៃបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងជនស៊ីវិលដែលបានស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស។

## ៤.ឃ.២.ខ.២.ការសម្លាប់រង្គាលលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៥៤០.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មាន"ប្រតិបត្តិការត្រូវបានរៀបចំ និងគិតទុកជាមុនក្នុងទ្រង់ទ្រាយធំ ដើម្បីសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"[1376]។ សេចក្តីសន្និដ្ឋាននេះមានភស្តុតាងសំអាង និងជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញអំពីការសម្លាប់អ្នករដ្ឋការដែលត្រូវបានរកឃើញអត្តសញ្ញាណនៅពេលឆែកឆេរទីក្រុង និងតាមប៉ុស្តិ៍ត្រួតពិនិត្យ ឬតាមរយៈការប្រកាសតាមវិទ្យុ[1377]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា មានតែការសម្លាប់អ្នកទាំងនោះដែលជាអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះដែលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ ព្រមទាំងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានធ្វើតាមការអំពាវនាវឱ្យបង្ហាញខ្លួន[1378]។ ទោះជាយ៉ាងណាក្តី បើទោះបីជាការយល់ឃើញអំពីការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់ជាប់ពាក់ព័ន្ធទៅនឹងជនរងគ្រោះមួយចំនួនតូចក៏ដោយ ក៏ប៉ុន្តែផ្អែកតាមភស្តុតាងអំពីសម្លាប់ទាហានអាចសន្និដ្ឋានបានថា ពុំមានចំនួនបុគ្គលច្រើនគ្រប់គ្រាន់ត្រូវបានសម្លាប់[1379]។ ពុំមានការសម្លាប់ខុសច្បាប់លើទាហានត្រូវបានបង្ហាញស្របតាមលក្ខខណ្ឌនៃបទដ្ឋានឡើយ។ អាស្រ័យហេតុនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានមូលដ្ឋានសមស្របដែលថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំនោះ ដូច្នេះការយល់ឃើញនេះត្រូវបដិសេធចោល។

## ៤.ឃ.២.ខ.៣.សេចក្តីសន្និដ្ឋាន

---

[1376] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦១។

[1377] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦១។

[1378] *សូមមើលខាងលើ* កថាខណ្ឌ ៤៦៦ ដល់ ៤៨១។

[1379] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សក្ខីកម្មរបស់ ស៊ុំ ជា បានផ្តល់ការបញ្ជាក់ខ្លះៗថា ជនរងគ្រោះមានចំនួនច្រើននៅពេលគាត់សំដៅទៅលើឡានដប់គ្រឿងដែលដឹកអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ (ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ២៦ )។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូង ឬភាគីពុំបានសួរសំណួរលើបញ្ហានេះនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់គាត់ឡើយ។

៥៤១.សរុបសេចក្តីមក ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្លាប់រង្គាលបានកើតឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ត្រូវបដិសេធចោល ដោយសារពុំមានការបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យទាំង ធាតុផ្សំសត្យានុម័តពីទំហំ និងចេតនាតម្រូវនោះឡើយ។

## ៤.ឃ.២.គ.ការសម្លាប់រង្គាលដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៥៤២.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនពីប៉ែកទក្សិណ ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ប្រជាជនបានស្លាប់ដោយសារលក្ខខណ្ឌអមនុស្សធម៌ នៅក្នុងពេលផ្លាស់ទីលំនៅ" និងថា"កងទ័ពខ្មែរក្រហមបានបាញ់សម្លាប់ប្រជាជនដទៃទៀត"[1380]។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា "ចំនួនមនុស្សស្លាប់ពិតប្រាកដ [...] ពុំត្រូវបានដឹងច្បាស់" ប៉ុន្តែថា "ប្រជាជនរាប់សែននាក់ត្រូវបានផ្លាស់ទីលំនៅ ដោយទទួលបានជម្រក និងការជួយឧបត្ថម្ភគាំទ្រមិនគ្រប់គ្រាន់ និងស្ថិតនៅក្នុងលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗ" និងថា មានភស្តុតាងបង្ហាញថា "ប្រជាជនជាច្រើនបានស្លាប់ដោយសារការអត់អាហារ ការហេវហត់អស់កម្លាំង និងដោយសារតែអំពើរបស់កងទ័ពខ្មែរក្រហមនៅក្នុងអំឡុងពេល និងនៅក្នុងដំណាក់កាលផ្សេងៗនៃការផ្លាស់ទីលំនៅប្រជាជន"[1381]នេះ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះដែលបង្ហាញអំពីការស្លាប់នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ពីប៉ែកទក្សិណនៃប្រទេសកម្ពុជាទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ [...] គឺជាភ័ស្តុតាងតំណាងអំពីចំនួនសរុប" និងថា ប្រជាជន"បានស្លាប់ក្នុងទ្រង់ទ្រាយធំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅទាំងនោះ"[1382]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា "កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានបង្កើតលក្ខខណ្ឌជាប្រព័ន្ធ និងដោយចេតនាលើប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅពីប៉ែកទក្សិណនៃប្រទេសកម្ពុជា ទៅកាន់ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ [...]

[1380] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៦។

[1381] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៦ ដល់ ៦៤៧។

[1382] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៧។

ដែលទំនងជានាំឲ្យមានការស្លាប់មនុស្សក្នុងចំនួនច្រើន” និងថា ដូច្នេះ បទសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើង[1383]។

៩៤៣.ខៀវ សំផន បានជំទាស់ទៅនឹងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការសម្លាប់ជនស៊ីវិលជាទូទៅក្នុងអំឡុងពេលនៃការជម្លៀសដំណាក់កាលទីពីរ[1384] និងបានអះអាងថា មានកំហុសនៅក្នុងការអនុវត្តធាតុផ្សំ *អត្តនោម័ត*[1385]។

៩៤៤.នួន ជា បានធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ពីបទសម្លាប់រង្គាលទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដោយចោទប្រកាន់ថា មានកំហុសអង្គហេតុ *ក្នុងចំណោមនោះ* ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាង។ ការលើកឡើងជាចម្បងរបស់គាត់គឺថា ពុំមានភស្តុតាងគ្រប់គ្រាន់នៅមុខអង្គជំនុំជម្រះសាលាដំបូងក្នុងការបង្ហាញថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរបានបណ្ដាលឱ្យមានការស្លាប់ឡើយ កុំថាដល់ទៅស្លាប់ក្នុងទ្រង់ទ្រាយធំនោះ[1386]។

៩៤៥.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងត្រឹមត្រូវថា លក្ខខណ្ឌស្ដីពី“ទ្រង់ទ្រាយធំ”ក្នុងការសម្រេចដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាល ត្រូវបានបំពេញដោយផ្អែកលើភស្តុតាងពាក់ព័ន្ធទាំងមូល[1387]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាង“ដែលគួរឱ្យជឿជាក់ និងទុកចិត្តបាន”ក្នុងការវាយតម្លៃអំពីទំហំនៃការសម្លាប់ និងថា នួន ជា ត្រឹមតែពុំយល់ស្របទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ[1388]។

៩៤៦.អង្គជំនុំជម្រះតុលាការកំពូលយល់យ៉ាងច្បាស់ថា នៅក្នុងការធ្វើសេចក្ដីសន្និដ្ឋានដែលថា ការសម្លាប់រង្គាលបានកើតឡើង អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើហេតុការណ៍នៃការស្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែលបានយោងនៅក្នុងផ្នែកសាលក្រមពាក់ព័ន្ធទៅនឹងការយល់ឃើញផ្នែក

---

[1383] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៨។

[1384] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៧។

[1385] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៩៤។

[1386] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣២៧ ដល់ ៣២៨ និង ៣៥២ ដល់ ៣៥៤។

[1387] សារណាតបរបស់ហព្រះរាជអាជ្ញា កថាខណ្ឌ ២០២ ដល់ ២០៦។

[1388] សារណាតបរបស់ហព្រះរាជអាជ្ញា កថាខណ្ឌ ២០៧ ដល់ ២០៨។

អង្គច្បាប់[1389]។ ហេតុការណ៍ទាំងនេះ បានរួមបញ្ចូលបុគ្គលជាច្រើនដែលបានស្លាប់ដោយសារការអត់ឃ្លាន ការហេវហត់អស់កម្លាំង និងជំងឺ[1390] ប្រជាជនលង់ទឹកស្លាប់ដោយសារកប៉ាល់ពីរក្រឡាប់[1391] ប្រជាជនស្លាប់នៅ

---

[1389] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៦ ដល់ ៦៤៧ (ជើងទំព័រ ២០៣៧ និង ២០៣៩) យោងទៅលើកថាខណ្ឌ ៥៩២, ៥៩៤ ដល់ ៥៩៥, ៥៩៧ ដល់ ៥៩៨ ដែលយោងទៅលើប្រតិចារឹកថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ឯកសារលេខ E1/137.1 ទំព័រ ១៩, ២១ ដល់ ២២។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣៤។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៣៩។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ឯកសារលេខ E1/197.1 ទំព័រ ៣២។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៣៤ ដល់ ៣៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សាន មុំ ឯកសារលេខ E3/4992 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557955 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារលេខ E3/4695 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00365098 ទំព័រ ៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឌី វឿន ឯកសារលេខ E3/4656 ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00544561 ទំព័រ ៤។ កំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គង់ វាច ឯកសារលេខ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00420971-6 ទំព័រ ៣ ដល់ ៧។ ពាក្យបណ្ដឹងជនរងគ្រោះ ត្រិះ អាល់ ឯកសារលេខ E3/5324 គ្មានកាលបរិច្ឆេទ ទំព័រ ៧ ដល់ ៨។ **សក្ខីកម្មរបស់ជនភៀសខ្លួន**៖ ប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836285 ទំព័រ ២០៨។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836189 ទំព័រ ១១២។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (Francois PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤២។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១។ កត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា ភស្តុតាងរបស់ ទឹង សុខា ជាភស្តុតាងបង្ហាញពីការសម្លាប់។ *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៨៩ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៣៨ ដល់ ៣៩ និង ៤០ (ទឹង សុខា បានឮស្នូរកាំភ្លើង និងមានគេប្រាប់ថា ទាហានខ្មែរក្រហមបានបាញ់អ្នកដែលព្យាយាមរត់គេច)។

[1390] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារលេខ E3/4695 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00365098 ទំព័រ ៨ (កូនទីប្រាំរបស់គាត់ដាច់ខ្យល់ស្លាប់តាមផ្លូវយ៉ាងវេទនានៅតាមផ្លូវទៅកាន់ផ្សារសំរោងយ៉ោង និងថា កូនពៅរបស់គាត់ដែលទើបតែកើតបានប៉ុន្មានខែនោះ ក៏ដាច់ខ្យល់ស្លាប់ទៀតដោយសារតែគ្មានទឹកដោះបៅ នៅពេលឡានចេញពីសំរោងយ៉ោង)។ កំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គង់ វាច ឯកសារលេខ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ (ភាសាខ្មែរ) 00420971-5 ទំព័រ ៣ ដល់ ៧ (ពិពណ៌នាអំពីកូនប្រុសរបស់គាត់អាយុជាងមួយឆ្នាំបានស្លាប់នៅក្នុងសង្រែកពេលកំពុងដើរតាមផ្លូវដោយសារជម្ងឺរាក និងហើម)។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836285 ទំព័រ ២០៨ (ក្នុងពេលធ្វើដំណើរជិត ៥០០ គីឡូម៉ែត្រនេះ កុមារ និងមនុស្សចាស់ជាច្រើននាក់ស្លាប់ ព្រោះគ្មានអាហារ)។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៣៤

ក្នុងរថភ្លើងដែលដាក់មនុស្សណែនណាន់តាន់តាប់[1392] ប្រជាជនស្លាប់ជាទូទៅដោយសារលក្ខខណ្ឌ[1393] និង បុគ្គលម្នាក់ដែលកងទ័ពខ្មែរក្រហមបានបាញ់សម្លាប់[1394]។

៥៤៧.នៅក្នុងការផ្តល់ការយល់ឃើញទាក់ទងទៅនឹងការស្លាប់បណ្តាលមកពីការដាក់លក្ខខណ្ឌនោះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មក្នុងតុលាការរបស់សាក្សីចំនួន ៣ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី

---

ដល់ ៣៥ (ពិន យ៉ាថៃ បានឆ្លើយថា នៅក្នុងឡានដែលគាត់ជិះនោះមានមនុស្សពីរនាក់ស្លាប់ដោយសារខ្យល់គ)។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836189 ទំព័រ ១១២ (ពិពណ៌នាលម្អិតថា នៅក្នុងអំឡុងពេលធ្វើដំណើរនោះ កុមារបានស្លាប់ដោយសារការហេវហត់អស់កម្លាំង ឬជំងឺ)។

[1391] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាន មុំ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារលេខ E3/4992 ទំព័រ ៤ ERN (ភាសាខ្មែរ) 00557955 (រៀបរាប់ថា កប៉ាល់គូរទីពីរលិចទឹកស្លាប់ទាំងអស់ព្រោះគ្មានអ្នកធ្វើអន្តរាគមន៍ដើម្បីសង្គ្រោះជីវិតពីខ្មែរក្រហមទេ)។

[1392] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/148.1 (ពេជ ស្រីផល) ទំព័រ ៣៩ ដល់ ៤០ (ពិពណ៌នាថា គាត់បានជិះក្នុងទូរថភ្លើងមួយទៅកាន់ខេត្តកំពង់ឆ្នាំង និងថា បានឃើញទូរថភ្លើងបួនដាក់មនុស្សពេញណែន។ គាត់ក៏បានប្រាប់ផងដែរថា ខ្នោះឈើដាក់ឃាំងមាត់ទ្វារ និងមានគេនៅយាមនឹងមាត់ទ្វារហ្នឹង ហើយមានមនុស្សស្លាប់នៅក្នុងទូរដោយសារការហេវហត់អស់កម្លាំង ឬការដាក់មនុស្សណែនពេក)។ ពាក្យបណ្តឹងជនរងគ្រោះ ត្រិះ អាល់ ឯកសារលេខ E3/5324 គ្មានកាលបរិច្ឆេទ ទំព័រ ៧ ដល់ ៨ (ពិពណ៌នាអំពីម្តាយរបស់បានស្លាប់ដោយសារការអត់អាហារនៅក្នុងរថភ្លើង)។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E1/179.1 (Francois PONCHAUD) ទំព័រ ៤៣ (គាត់បានឮជនភៀសខ្លួនប្រាប់អំពីលក្ខខណ្ឌក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់ទីពីរ ដែលប្រជាជនត្រូវបានដាក់នៅក្នុងទូរថភ្លើងយ៉ាងណែន គ្មានការផ្តល់បាយទឹក ត្រូវបន្ទោរបង់ក្នុងទូរថភ្លើង មានមនុស្សស្លាប់ច្រើនក្នុងចំណោមនោះ)។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836285 ទំព័រ ២០៨ (បានឆ្លើយថា កងទ័ពខ្មែរក្រហមបានរុញមនុស្សចូលរថភ្លើងដូចហ្វូងគោ ទូមួយដាក់គ្នាជាង ១៥០ នាក់ និងថា នៅក្នុងការផ្លាស់ទីលំនៅដំណាក់កាលទីពីរធ្វើដំណើរចម្ងាយ ៥០០ គីឡូម៉ែត្រ កុមារ និងមនុស្សចាស់ជាច្រើននាក់បានស្លាប់ ព្រោះគ្មានអាហារ)។

[1393] ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/197.1 (អ៊ូន ផល្លី) ទំព័រ ៣២ (ពិពណ៌នាអំពីការធ្វើដំណើរដ៏លំបាក និងប្រជាជនដែលស្លាប់តាមផ្លូវត្រូវទុកចោលលើផ្លូវគ្របក្រណាត់ស)។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១ (ឆ្លើយថា គាត់បានដឹងអំពីការជម្លៀសពីអ្នកដទៃ និងថា មានមនុស្សស្លាប់ច្រើននៅក្នុងពេលជម្លៀសនោះ)។

[1394] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារលេខ E1/198.1 (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ទំព័រ ៣៤ (ពិពណ៌នាអំពីបុរសម្នាក់នៅពេលធ្វើដំណើរកាត់បរុមរាជវាំងបានស្រែកថា “ជ័យយោ! យើងមកដល់ភ្នំពេញហើយ!” និងក្រោយមកត្រូវបានខ្មែរក្រហមនាំយកចេញទៅ ហើយ ចាន់ សុភាព *ហៅ*ចាន់ សុជាតិ បានឮស្នូរកាំភ្លើងបាញ់ពីរគ្រាប់ បុរសនោះក៏ធ្លាក់ចូលក្នុងទឹកស្លាប់)។

ចំនួន ៣ នាក់ រួមទាំងចម្លើយក្រៅតុលាការ និងភស្តុតាងជាឯកសារផ្សេងៗទៀត។ សាក្សីពីរនាក់ គឺ François PONCHAUD និង នូ ម៉ៅ បានរំឭកនូវការស្លាប់ឮថា "ក្តីសង្ឃឹមថា នឹងរស់នោះមានតិចតួចណាស់"[1395] និងមាន"ការស្លាប់ជាច្រើន"[1396]បណ្តាលមកពីលក្ខខណ្ឌអមនុស្សធម៌នៅលើរថភ្លើង[1397]។ ទោះជាយ៉ាងណាក្តី ពុំមានសាក្សីណាមួយបានឃើញផ្ទាល់នូវការស្លាប់ឡើយ ដូចនេះសក្ខីកម្មរបស់គាត់ គឺជាភស្តុតាងចចាមអារ៉ាម។ សាក្សីទីបី សុខ ឈិន គឺជាកម្មករធ្វើផ្លូវរថភ្លើងក្នុងឆ្នាំ ១៩៧៥ បានផ្តល់សក្ខីកម្មថា គាត់បានឃើញសាកសពស្អុយរលួយតាមផ្លូវរថភ្លើងដែលគាត់ជឿជាក់ថា ជាសពរបស់អ្នកដែលត្រូវបានគេជម្លៀសនោះដែលត្រូវបានបានគេបោះចេញពីរថភ្លើង ប៉ុន្តែគាត់ពុំអាចប៉ាន់ស្មានថា បានឃើញសាកសពប៉ុន្មានឡើយ[1398]។ បន្ថែមលើនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ នាក់ បានផ្តល់សក្ខីកម្មក្នុងតុលាការថា បានឃើញប្រជាជនស្លាប់ដោយសារលក្ខខណ្ឌធ្ងន់ធ្ងរនោះ[1399]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានផ្តល់សក្ខីកម្មថា គាត់បានឃើញបុរសម្នាក់ត្រូវបានកងទ័ពខ្មែរក្រហមសម្លាប់ ព្រោះគាត់ស្រែកត្រេកអរថា មកដល់ភ្នំពេញហើយ[1400]។

៥៤៨.ក្នុងចំណោមសាក្សីបីនាក់ដែលផ្តល់ភស្តុតាងអំពីការស្លាប់ បានសំដៅលើទីកន្លែងដែលជម្លៀសទៅនៅក្នុងប៉ែកបស្ចិមនៃប្រទេសកម្ពុជាដែលចាប់តាំងពីខែ ឧសភា មិថុនា និង សីហា ឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦[1401]

---

[1395] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤២។

[1396] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៥៤។

[1397] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៤២ (François PONCHAUD) (E1/179.1)។

[1398] ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ឯកសារលេខ E1/137.1 ទំព័រ ១៩, ២១ ដល់ ២២។

[1399] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1ទំព័រ ៣៨ ដល់ ៤០ (អ្នកខ្លះស្លាប់ក្នុងទូរថភ្លើងដាក់មនុស្សណែនដោយសារហេវហត់អស់កម្លាំង)។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ឯកសារលេខ (E1/197.1) ទំព័រ ៣២ (ការធ្វើដំណើរមានការលំបាកខ្លាំង មនុស្សស្លាប់តាមផ្លូវ ដាក់ចោលនៅលើចិញ្ចើមផ្លូវគ្របក្រណាត់ស)។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៣៤ ដល់ ៣៥ (មនុស្សពីរនាក់បានស្លាប់ដោយសារខ្យល់គ)។

[1400] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣៤។

[1401] សុខ ឈិន ធ្វើការជាអ្នកជួសជុលផ្លូវរថភ្លើងក្នុងខែ សីហា ឆ្នាំ ១៩៧៥ ក្នុងខេត្តពោធិ៍សាត់ (ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ឯកសារលេខ E1/137.1 ទំព័រ ១៩, ២១ ដល់ ២២)។ François PONCHAUD បានឮតាមជនភៀសខ្លួននិយាយអំពីការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីពីក្នុងខែ ឧសភា ឬមិថុនា ឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦ ដែលប្រជាជនត្រូវបានបញ្ជូនមកពីខេត្តតាកែវកាត់តាមទីក្រុងភ្នំពេញទៅភ្នំអធិបតី(ជិតមង្គលបូរី) (ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣

។ ការរៀបរាប់ចំនួន ៣ របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឃើញផ្ទាល់ភ្នែកក្នុងចំណោម ៤ នាក់ គឺចាប់ពីខែ មេសា ឬ ខែ តុលា ឆ្នាំ ១៩៧៥ និងការរៀបរាប់ផ្សេងទៀតទំនងជាចាប់ពីខែនេះដូចគ្នាផងដែរ[1402]។ ការរៀបរាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីសំដៅលើទីកន្លែងពីរខុសគ្នា អាចនៅកំពង់ឆ្នាំង(ចេញពីភ្នំពេញទៅ) ឬនៅបាត់ដំបង[1403]។

៥៤៩.ប្រភពចំនួន ៦ អំពីភស្តុតាងនៃការស្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ គឺជាឯកសារ ដូចជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣ (មានមួយត្រួតគ្នានៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ) ពាក្យបណ្ដឹងរបស់ជនរងគ្រោះមួយ និងការរៀបរាប់ចំនួន ២ របស់ជនភៀសខ្លួន[1404]។ ពុំមានការរៀបរាប់ណាមួយក្នុងចំណោមនេះ សំដៅលើការផ្លាស់ទីទៅកន្លែងតែមួយ ឬក្នុងខែតែមួយឡើយ[1405]។

(François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤១ ដល់ ៤២ និង ៤៤)។ នូ ម៉ៅ បានឮថា ប្រជាជនត្រូវបានជម្លៀសទៅខេត្តបាត់ដំបង និងកំពង់ឆ្នាំ ប៉ុន្តែមិនច្បាស់ថា នៅពេលណា(ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១)។

[1402] អួន ផល្លី ពុំចងចាំកាលបរិច្ឆេទច្បាស់លាស់ ប៉ុន្តែបាននិយាយថា ត្រូវបានគេជម្លៀសតាមកាណូតទៅភ្នំពេញ និងក្រោយមកតាមរថភ្លើងទៅកាន់ខេត្តបាត់ដំបង"ប្រហែលជាក្នុងចុងឆ្នាំ ១៩៧៦ ឬចុងឆ្នាំ ១៩៧៧" (ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ២៨ ដល់ ២៩)។

[1403] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣៤ ដល់ ៣៥ (ការផ្លាស់ទីលំនៅទៅខេត្តកំពង់ឆ្នាំងកាត់តាមទីក្រុងភ្នំពេញ) ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៣៩ ដល់ ៤០ (រថភ្លើងចេញដំណើរពីភ្នំពេញទៅកាន់កំពង់ឆ្នាំង)។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (E1/197.1) (អួន ផល្លី) ទំព័រ ២៨ ដល់ ២៩, ៣២ (ព្រៃវែងទៅបាត់ដំបង)។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៣៤ ដល់ ៣៥ (ឡានចេញដំណើរឆ្ពោះទៅកាន់បាត់ដំបង)។

[1404] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ឌី រឿន ឯកសារលេខ E3/4656 ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00544561 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សាន មុំ ឯកសារលេខ E3/4992 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557955 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គង់ វ៉ាច ឯកសារលេខ E3/4695 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00365098 ទំព័រ ៨។ កំណត់ហេតុស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរបស់ គង់ វាច ឯកសារលេខ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ (ភាសាខ្មែរ) 00420971-6 ទំព័រ ៣ ដល់ ៧។ ពាក្យបណ្ដឹងជនរងគ្រោះរបស់ ត្រិះ អាល់ ឯកសារលេខ E3/5324 ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ទំព័រ ៧ ដល់ ៨។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ទំព័រ ២០៨ ERN (ភាសាខ្មែរ) 00836285។ សក្ខីកម្ម

៥៥០.អង្គជំនុំជម្រះសាលាដំបូង ពុំបានធ្វើការពិចារណាច្បាស់លាស់ណាមួយអំពីតម្លៃជាភស្តុតាងចំពោះភស្តុតាងដែលខ្លួនបានសំអាង ឬលើហេតុការណ៍ណាមួយអំពីការស្លាប់ដែលត្រូវមានភស្តុតាងគាំទ្រជាច្រើននោះ។ ដូចបានកត់សម្គាល់ខាងលើ[1406] ជាពិសេសនៅពេលដែលតម្លៃជាភស្តុតាងដែលការយល់ឃើញផ្អែកទៅលើមានមូលដ្ឋានខ្សោយ (ដូចជាករណីនៃចម្លើយក្រៅតុលាការរបស់សាក្សី និងរបស់ដើមបណ្តឹងរដ្ឋប្បវេណី) ការពន្យល់របស់អង្គជំនុំជម្រះសាលាដំបូងពីមូលហេតុក្នុងការជឿជាក់ថា ការយល់ឃើញហួសពីវិមតិសង្ស័យអាចផ្អែកលើភស្តុតាងនេះបាន មានសារៈសំខាន់ជាក់លាក់ នៅពេលកំណត់ ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងសមហេតុផល ដែរ ឬយ៉ាងណា។ ដោយសារពុំមានការពន្យល់ណាមួយនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញទាក់ទងទៅនឹងការស្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរដោយផ្អែកលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពាក្យបណ្តឹងរបស់ជនរងគ្រោះ និងការរៀបរាប់របស់ជនភៀសខ្លួន ពុំអាចនិយាយបានថា ធ្វើឡើងដោយសមហេតុផលឡើយ។ ប្រហាក់ប្រហែលគ្នានេះដែរ ដោយសារពុំមានការពន្យល់ណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងពីវិធីដែលខ្លួនវាយតម្លៃភស្តុតាងនេះយ៉ាងដូចម្តេចនោះ ភស្តុតាងចចាមអារ៉ាមជាទូទៅរបស់ François PONCHAUD និង នូ ម៉ៅ មានមូលដ្ឋានពុំគ្រប់គ្រាន់ សម្រាប់ការយល់ឃើញសមហេតុផលអំពីការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌ។ ផ្ទុយទៅវិញ ទាក់ទងទៅនឹងការយល់ឃើញពាក់ព័ន្ធទៅនឹងការស្លាប់ និងការសម្លាប់មួយករណីដែលបានផ្អែកលើសក្ខីកម្មក្នុងតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី សុខ ឈិន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នួន ជា ពុំបានបង្ហាញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចយល់ឃើញថា មានការស្លាប់ និងការសម្លាប់ទាំងនេះត្រូវបានបង្ហាញហួសពីវិមតិសង្ស័យឡើយ។

៥៥១.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណាក្នុងការយល់ឃើញថា មានការសម្លាប់ក្នុងទ្រង់ទ្រាយធំនោះ។ ទាក់ទងទៅនឹងបញ្ហានេះ គួររំឭកថា ពុំមាន

---

របស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ទំព័រ ១១២ ERN (ភាសាខ្មែរ) 00836189។

[1405] រយៈពេលដែលប្រជាជនត្រូវបានផ្លាស់ទីលំនៅចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ (គង់ វាច) ចាប់ពីខែ វិច្ឆិកា ឆ្នាំ ១៩៧៦ (សាន មុំ) ចុងឆ្នាំ ១៩៧៦ (ត្រឹះ អាល) ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៥ (អួន ចាន់ស៊ីយ៉ាវុទ្ធី) និងខែ ធ្នូ ឆ្នាំ ១៩៧៥ (ការរៀបរាប់របស់ជនភៀសខ្លួនអនាមិក)។

[1406] *សូមមើលខាងលើ* កថាខណ្ឌ ៩០។

ការកំណត់អំពីតួលេខអប្បបរមា។ ការសម្លាប់រង្គាលត្រូវបានយល់ឃើញថា បានប្រព្រឹត្តឡើងទាក់ទងទៅនឹងការសម្លាប់រាប់ពាន់ ឬប្រហាក់ប្រហែលតិចជា ៦០ នាក់[1407]។ នៅពេលកំណត់ ថាតើការសម្លាប់បានកើតឡើងក្នុងទ្រង់ទ្រាយធំ ដែរ ឬយ៉ាងណា កត្តាមួយចំនួនដែលត្រូវយកមកពិចារណានោះ មានដូចជាពេលវេលា ទីកន្លែងនៃការសម្លាប់ ប្រភេទនៃជនរងគ្រោះ ចរិតលក្ខណៈការកំណត់គោលដៅលើជនរងគ្រោះ និង ថាតើការសម្លាប់សំដៅលើក្រុមប្រមូលផ្តុំ ឬជនរងគ្រោះម្នាក់ៗ[1408]។ យោងតាមសាលក្រមរបស់តុលាការ ICTY *រឿងក្តី Perišić* លក្ខខណ្ឌតម្រូវកំណត់ថា ពុំចាំបាច់មានការសម្លាប់ក្នុងចំនួនច្រើនដែលកើតឡើងក្នុងអំឡុងពេលនៃឧប្បត្តិហេតុតែមួយ នៅក្នុងកន្លែងប្រមូលផ្តុំតែមួយ និងក្នុងពេលតែមួយដ៏ខ្លីឡើយ[1409]។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានយល់ឃើញថា ធាតុផ្សំពីទ្រង់ទ្រាយធំនៃបទសម្លាប់រង្គាលអាចបង្ហាញផងដែរដោយផ្អែកលើ"ការត្រួតគ្នានៃហេតុការណ៍ដាច់ដោយឡែកពីគ្នា និងពុំជាប់ពាក់ព័ន្ធគ្នា មានន័យថា ផ្អែកលើមូលដ្ឋានផ្តុំគ្នានៃហេតុការណ៍"[1410]។

៥៩២.នៅប៉ុន្មានខែបន្ទាប់ពីសាលក្រម*រឿងក្តី Perišić* (ICTY) អង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី Bagosora* (ICTR) បានសម្រេចដោយពុំបានដោះស្រាយលើការបញ្ជាក់នៅក្នុង*រឿងក្តី Perišić* ថា ជាការពុំសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា លក្ខខណ្ឌស្តីពី"ទ្រង់ទ្រាយធំ"សម្រាប់បទសម្លាប់រង្គាល ត្រូវបានបំពេញដោយ"ផ្អែកលើការពិចារណាជារួមនូវព្រឹត្តិការណ៍ដែលបានប្រព្រឹត្តឡើង*តាមតំបន់*ផ្សេងៗគ្នា កាលៈទេសៈខុសៗគ្នា ចារីខុសគ្នា និងអស់រយៈពេលជាងពីរខែ"[1411]។ ព្រឹត្តិការណ៍ដែលបង្កើតបានជាមូលដ្ឋានសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ត្រូវតែយល់ឃើញថា"ជាបទឧក្រិដ្ឋមួយដូចគ្នា និងមានធាតុផ្សំ*សត្យានុម័ត*ដូចគ្នា"[1412]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ក្នុង*រឿងក្តី Karemera និង Ngirumpatse* បានប្រើប្រាស់វិធីសាស្ត្រដូចគ្នា និងបានយល់ឃើញថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីនោះ ទំនងជាបានប្រមូលផ្តុំការសម្លាប់មួយចំនួនក្នុងការផ្តល់ការយល់ឃើញអំពីការសម្លាប់រង្គាល

---

[1407] សាលដីកា*រឿងក្តី Lukić និង Lukić* (ICTY) កថាខណ្ឌ ៥៣៦។ សាលដីកា*រឿងក្តី Ndahimana* (ICTR) កថាខណ្ឌ ២៣១។

[1408] សាលដីកា*រឿងក្តី Lukić និង Lukić* (ICTY) កថាខណ្ឌ ៥៣៨។

[1409] សាលក្រម*រឿងក្តី Perišić* (ICTY) កថាខណ្ឌ ១០៧។

[1410] សាលក្រម*រឿងក្តី Martić* (ICTY) កថាខណ្ឌ ៦៣ បានប្រើប្រាស់ភាសាចេញពី សាលក្រម*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៣៩១។ *សូមមើលផងដែរ* សាលក្រម*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៦៤០។

[1411] សាលដីកា*រឿងក្តី Bagosora* (ICTR) កថាខណ្ឌ ៣៩៦។

[1412] សាលដីកា*រឿងក្តី Bagosora* (ICTR) កថាខណ្ឌ ៣៩៦។

ក៏ដោយ ក៏ហេតុការណ៍នៃការសម្លាប់នីមួយៗ បានបំពេញតាមលក្ខខណ្ឌធាតុផ្សំនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំ[1413]។

៩៥៣.បន្ថែមលើនេះទៀត នៅក្នុង*រឿងក្តី Nizeyimana* បើទោះបីជាទទួលស្គាល់ថា ពុំមានបទដ្ឋានកំណត់អំពីតួលេខក្នុងការបង្ហាញនូវបទសម្លាប់រង្គាលក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានសម្រេចថា ការសម្លាប់ត្រូវតែកើតឡើងក្នុងទ្រង់ទ្រាយធំ[1414]។ អង្គជំនុំជម្រះនេះពុំជឿជាក់ថា៖

> […] ការសម្លាប់គ្រួសារ Ruhutinyanya ការសម្លាប់ Rosalie Gicanda និងអ្នកដទៃទៀត ត្រូវបានយកចេញពីផ្ទះរបស់គាត់ ការសម្លាប់ Remy Rwekaza និង Beata Uwambaye រួមទាំង ការវាយប្រហារលើសាក្សី ZAV នៅកន្លែងបិទផ្លូវត្រង់ផ្លូវបំបែកក្នុងទីក្រុង Gikongoro/Cyangugu និង Kigali ការសម្លាប់ Pierre Claver Karenzi នៅកន្លែងបិទផ្លូវនៅសណ្ឋាគារ Faucon ព្រមទាំងការសម្លាប់អ្នកដែលត្រូវបានយកមកពីលំនៅដ្ឋានរបស់ Matabaro និង Nyirinkwaya គឺជាការសម្លាប់រង្គាលនោះឡើយ។ ភស្តុតាងទាក់ទងទៅនឹងហេតុការណ៍នីមួយៗ មានមូលដ្ឋានស្រពេចស្រពិលពេក និង/ឬតម្លៃទាបពេកពុំអាចបង្ហាញការសម្លាប់ទាំងនេះក្នុងទ្រង់ទ្រាយធំបានឡើយ[1415]។

៩៥៤.ទាក់ទងទៅនឹងរឿងក្តីចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ភស្តុតាងនៃការសម្លាប់ និងការស្លាប់ដែលបណ្តាលមកពីការដាក់លក្ខខណ្ឌនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ជាពិសេសភស្តុតាងផ្ទាល់ មានលក្ខណៈពុំប្រាកដប្រជា ជួនកាលស្រពេចស្រពិល និងបានពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជនកម្ពុជាជាង ៣០០.០០០ នាក់ ទទួលរងផលប៉ះពាល់ដោយសារផ្លាស់ទីលំនៅនោះ[1416]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា មានតែការយល់ឃើញអំពីការស្លាប់ដោយសារលក្ខខណ្ឌនៃការផ្លាស់ទីលំនៅ និងការសម្លាប់ដោយសារកងទ័ពខ្មែរក្រហម ដែលបានផ្អែកលើភស្តុតាងក្នុងតុលាការប៉ុណ្ណោះ(លើកលែងតែភស្តុតាងចចាមអារ៉ាមក្នុងតុលាការដែលគ្មានការបញ្ជាក់បន្ថែម) ដែលបានធ្វើឡើងដោយសមហេតុផលនោះ។ ការស្លាប់ទាំងនេះបានកើតឡើងនៅតាមបណ្តាខេត្តផ្សេងៗគ្នា ក្រោម

---

[1413] សាលដីកា*រឿងក្តី Karemera* (ICTR) កថាខណ្ឌ ៦៦១ (ជនស៊ីវិលរាប់ពាន់នាក់ត្រូវបានសម្លាប់ត្រឹមខែ មេសា ឆ្នាំ ១៩៩៤ នៅតំបន់ Kigali ត្រង់កន្លែងបិទផ្លូវ និងរាប់ពាន់ត្រូវបានសម្លាប់បន្ទាប់ពីការវាយប្រហារនៅពាក់កណ្តាលខែឧសភា និងមិថុនា ឆ្នាំ ១៩៩៤ នៅក្នុង Bisesero Hills)។

[1414] សាលដីកា*រឿងក្តី Nizeyimana* (ICTR) កថាខណ្ឌ ១៥៤៦។

[1415] សាលដីកា*រឿងក្តី Nizeyimana* (ICTR) កថាខណ្ឌ ១៥៤៩។

[1416] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣០។

លក្ខខណ្ឌខុសគ្នា ចារីខុសៗគ្នា និងអស់រយៈពេលជាងពីរឆ្នាំ។ មានតែបុគ្គលម្នាក់គត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បានផ្តល់សក្ខីកម្មអំពីការសម្លាប់អ្នកដែលត្រូវបានជម្លៀសដោយកងទ័ពខ្មែរក្រហម[1417]។ ការយល់ឃើញទាំងនេះពុំអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃទ្រង់ទ្រាយធំជាលក្ខណៈបុគ្គល ឬក៏ការផ្តុំគ្នាឡើយ។

៥៥៥.យោងតាមមូលហេតុខាងលើនេះ អាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងនៅពេលយល់ឃើញថាធាតុផ្សំពីទ្រង់ទ្រាយធំមានអត្ថិភាពនោះ ពុំបានសំអាងលើការស្លាប់ និងការសម្លាប់នីមួយៗដែលខ្លួនបានរកឃើញនោះឡើយ ប៉ុន្តែបានផ្តល់ហេតុផលថា ការស្លាប់ និងការសម្លាប់ទាំងនោះ គឺជា"ភស្តុតាងតំណាងអំពីចំនួនសរុប"នៃការស្លាប់ និងការសម្លាប់[1418]។ ដូចបានកត់សម្គាល់ដោយ នួន ជា អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើភស្តុតាងណាមួយ ដើម្បីគាំទ្រការសន្និដ្ឋាននេះឡើយ។ ទោះជាយ៉ាងណាក្តី មានភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលបង្ហាញពីទំហំនៃការស្លាប់។ គួរកត់សំគាល់ ដោយផ្អែកលើការរៀបរាប់របស់ជនភៀសខ្លួន អ៊ូន សុខ ប្រហែលជា ១០% នៃប្រជាជនដែលធ្វើដំណើរជាមួយគាត់បានស្លាប់[1419]។ François PONCHAUD បានអះអាងថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ មានមនុស្សស្លាប់ច្រើន ដូចគ្នាទៅនឹងស្ថានភាពនៅពេលដែល"ជនជាតិជ្វីហ្វត្រូវបានណាហ្ស៊ីនាំយកទៅកាលពីអតីតនោះ"[1420]។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា មាន"មនុស្សស្លាប់ច្រើននៅក្នុងអំឡុងពេលនៃការជម្លៀស"[1421] បានឃើញសាកសពប្រជាជន"មួយចំនួន" ដែលបានស្លាប់នៅក្នុងពេលជម្លៀស[1422] និងបានឃើញ"ប្រជាជនខ្លះទៀត"ស្លាប់[1423]។ ភស្តុតាងក្រៅតុលាការក៏បាន

---

[1417] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣៤។

[1418] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៧។

[1419] សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836285 ទំព័រ ២០៨។

[1420] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (Francois PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤២ ដល់ ៤៣។ ទោះជាយ៉ាងណាក្តី គួរកត់សម្គាល់ផងដែរថា François PONCHAUD ពុំបានឃើញផ្ទាល់ភ្នែកនូវទិដ្ឋភាពណាមួយនៃការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទីពីរ។ សក្ខីកម្មរបស់គាត់ផ្អែកលើការរៀបរាប់ដែលគាត់បានប្រមូលពីជនភៀសខ្លួនប៉ុណ្ណោះ។

[1421] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១។

[1422] ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ឯកសារលេខ E1/137.1 ទំព័រ ១៩, ២១ ដល់ ២២។

[1423] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1ទំព័រ ៣៩ ដល់ ៤០។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អ៊ូន ផល្លី) ឯកសារលេខ E1/197.1 ទំព័រ ៣២។

បង្ហាញផងដែរថា មានការស្លាប់ជាច្រើនបានកើតឡើងដោយសារលក្ខខណ្ឌ និងកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជន[1424]។

៩៥៦.អង្គជំនុំជម្រះតុលាការកំពូលពិចារណា និងជាការសន្មតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងនេះ ដោយបានយោងនៅក្នុងផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលពិភាក្សាលើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ នៅពេលយល់ឃើញថា ហេតុការណ៍ជាក់ស្តែងនៃការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស ធ្វើជាឧទាហរណ៍នៃការស្លាប់ក្នុងទ្រង់ទ្រាយធំ។ ពិតប្រាកដណាស់ ភស្តុតាងនេះទំនងជឿជាក់បានថា មានការស្លាប់ច្រើនជាងការបង្ហាញតាមរយៈភស្តុតាងដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទីពីរ។ ទោះជាយ៉ាងណាក្តី ភស្តុតាងនេះពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងអាចសន្និដ្ឋានបានថា ការស្លាប់បានកើតឡើងក្នុង"ទ្រង់ទ្រាយធំ"។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានព្យាយាមប៉ាន់ស្មានន្ចូវចំនួនស្លាប់ជាក់ស្តែង មានន័យថា ពុំមានការបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណា ថាតើមានការស្លាប់រាប់រយ ឬរាប់ពាន់នាក់បានកើតឡើង ដែរ ឬយ៉ាងណានោះឡើយ។

៩៥៧.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ធាតុផ្សំទ្រង់ទ្រាយធំអំពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំត្រូវបានបង្ហាញដោយសមហេតុផលទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទីពីរឡើយ។

៩៥៨.ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង អំពីធាតុផ្សំអត្តនោម័តនៃបទសម្លាប់រង្គាល ពាក់ព័ន្ធទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀស ពុំមានការបង្ហាញឱ្យឃើញថា ចារីមានចេតនាសម្លាប់ប្រជាជនក្នុងទ្រង់ទ្រាយធំឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ថ្នាក់ដឹកនាំបក្សមិនបានគិតគូរអំពីមេរៀនផ្សេងៗដែលទទួលបានពីការផ្លាស់ទីលំនៅដំណាក់កាលទីមួយទេ ហើយមិនបានចាត់វិធានការដើម្បីធានាថា ប្រជាជនបានទទួលជំនួយឧបត្ថម្ភ ឬកន្លែងស្នាក់នៅគ្រប់គ្រាន់នៅក្នុងការផ្លាស់

---

[1424] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាន មុំ ឯកសារលេខ E3/4992 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557955 ទំព័រ ៤ (កប៉ាល់ពីរមនុស្សជិះ"ច្រើន"បានក្រឡាប់ ហើយក៏លង់ទឹកស្លាប់) សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836189 ទំព័រ ១១២ ("ក្នុងពេលធ្វើដំណើរ កុមារពីរនាក់ក្នុងចំណោមប្រាំនាក់ បានស្លាប់ដោយសារការហេវហត់អស់កម្លាំង ឬជំងឺ")។

ទីលំនៅដំណាក់កាលទីពីរ"ឡើយ[1425]។ នេះបញ្ជាក់ថា ចារីបានប្រព្រឹត្ត*ចេតនាប្រយោល* (dolus eventualis) ដែលអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញរួចរាល់ហើយថា ពុំមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការបង្ហាញពីធាតុផ្សំ*អត្តនោម័ត*នៃបទសម្លាប់រង្គាលឡើយ[1426]។

៥៥៩.បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ការយល់ឃើញថា មានបុគ្គលម្នាក់ត្រូវបានកងទ័ពខ្មែរក្រហមបាញ់សម្លាប់(តាមការសន្មតជាចេតនាផ្ទាល់)ក៏ដោយ ក៏ការយល់ឃើញពាក់ព័ន្ធទៅនឹងធាតុផ្សំ*អត្តនោម័ត*ពុំបានសំអាងទៅលើហេតុការណ៍នេះដែរ ដែលនៅគ្រប់កាលៈទេសៈទាំងអស់ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញអំពី "ការសម្លាប់ក្នុងទ្រង់ទ្រាយធំ"នោះ។

៥៦០.អាស្រ័យហេតុនេះ ធាតុផ្សំ*អត្តនោម័ត*នៃបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំត្រូវបានបង្ហាញ ហើយអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានការសម្លាប់រង្គាលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ ដូច្នេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំអាចយកជាបានការឡើយ។

៥៦១.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា យោងតាមវិធាន ១១០(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះមានសិទ្ធិអំណាច"ក្នុងការកែប្រែប្រភេទបទប្រកាន់ អង្គជំនុំជម្រះសាលាដំបូងបានកំណត់"[1427]។ សិទ្ធិអំណាចនេះ ត្រូវបានកម្រិតត្រឹមថា អង្គជំនុំជម្រះតុលាការកំពូលពុំអាច"បន្ថែមធាតុផ្សំថ្មីនៃបទល្មើសណាមួយដែលមិនដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ"។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការយល់ឃើញដែលបានផ្ដល់ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីដែលត្រូវបានទទួលនៅដំណាក់កាលបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងបញ្ហានេះ និងបើទោះបីជាពុំបានបំពេញតាមលក្ខខណ្ឌធាតុផ្សំនៃបទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏បានបំពេញតាមលក្ខខណ្ឌធាតុផ្សំនៃបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដោយសារអំពើដែលបានបង្កឱ្យមានការស្លាប់បុគ្គលណាម្នាក់នោះយ៉ាងហោចណាស់គឺជា*ចេតនាប្រយោល (dolus eventualis)*។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកជាការសមស្របក្នុងការកែប្រែប្រភេទគតិយុត្តនៃបទល្មើសដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញ និងផ្ដល់ការយល់

---

[1425] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៨។

[1426] *សូមមើលខាងលើ* កថាខណ្ឌ ៥២២។

[1427] វិធាន ១១០(២) នៃវិធានផ្ទៃក្នុង។

ឃើញមួយដែលថា បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។

៥៦២.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ទាក់ទងទៅនឹងបញ្ហានេះថា ដីកាដំណោះស្រាយ (D427) បានចោទប្រកាន់ជនជាប់ចោទពីបទសម្លាប់រង្គាលប៉ុណ្ណោះ ប៉ុន្តែពុំបានចោទប្រកាន់ជនជាប់ចោទពីបទមនុស្សឃាតទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរឡើយ[1428]។ ទោះជាយ៉ាងណាក្តី នេះពុំបានកម្រិតសិទ្ធិអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការកែប្រែប្រភេទបទចោទនៅក្នុងរឿងក្តីបច្ចុប្បន្នបានឡើយ។ វិធាន ៩៨(២) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានកម្រិតដោយការចោទប្រកាន់ផ្នែកអង្គហេតុដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ប៉ុន្តែពុំមែនប្រភេទបទចោទឡើយ។ ដូច្នេះ វិធាននេះបានបើកទូលាយសម្រប់អង្គជំនុំជម្រះសាលាដំបូង ហើយក្នុងពេលនេះបានបើកទូលាយសម្រាប់អង្គជំនុំជម្រះតុលាការកំពូលនៅដំណាក់កាលបណ្តឹងសាទុក្ខ ឱ្យធ្វើការកែប្រែប្រភេទបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ (D427) ដែលសហចៅក្រមស៊ើបអង្កេតបានចាត់ទុកថា ជាបទសម្លាប់រង្គាល ជាជាងបទមនុស្សឃាត។

### ៤.ឃ.២.ឃ.ការសម្លាប់រង្គាលដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ

៥៦៣.ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា “យ៉ាងតិចបំផុតមានអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចំនួន ២៥០ នាក់ ត្រូវបានសម្លាប់នៅពេលនោះ”[1429]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយផ្អែកទៅលើភស្តុតាងចំនួន ៧ ដែលមានសក្ខីកម្មរបស់សាក្សីផ្ទាល់ចំនួន ២ នាក់ កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរចំនួន ៣ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយ និងប្រភពមិនផ្ទាល់មួយ ដែលពិភាក្សាអំពីចំនួនឡានយ៉ាងច្រើនបានដឹកមនុស្សទៅកាន់ទួលពោធិ៍ជ្រៃដើម្បីសម្លាប់។ តាមការប៉ាន់ស្មាន គឺមានឡានចាប់ពី ៦ ទៅ ៨ ឬ ១០០ ឡាន ដែលឡាននីមួយៗដឹកមនុស្សបានចំនួនពី ២៥ ទៅ ៦០ នាក់។ ភស្តុតាងខ្លះបានបញ្ជាក់ផងដែរថា ឡានត្រឡប់ទៅមកចំនួនពីបីទៅបួនជើង[1430]

---

[1428] *សូមមើល* ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ១៣៧៣ (“ធាតុផ្សំផ្នែកអង្គច្បាប់នៃបទមនុស្សឃាត ត្រូវបានបង្ហាញផងដែរទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីបី […]” ) ១៣៨១ (“ធាតុផ្សំផ្នែកអង្គច្បាប់នៃបទសម្លាប់រង្គាលត្រូវបានបង្ហាញផងដែរទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ […]”)។

[1429] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨១។

[1430] ប្រតិចារិកចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ឯកសារលេខ E1/187.1 ទំព័រ ២០ និង ២៤ ដល់ ២៩។

។ អង្គជំនុំជម្រះសាលាដំបូង បានប៉ាន់ស្មានរបស់ខ្លួនទាក់ទងទៅនឹងចំនួនប្រជាជនដែលត្រូវបានសម្លាប់ដោយផ្អែកលើសក្ខីកម្មរបស់ លឹម សាត ដែលថា មានឡានចំនួនពី ១០ ទៅ ១៥ ដែលបានយកមកប្រើនោះ ហើយអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញស្របជាមួយនឹងភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង និងសក្ខីកម្មដែលថា ឡាននីមួយៗអាចដឹកបានជាមធ្យមចំនួនពី ២៥ ទៅ ៣០ នាក់ បើទោះបីជាមានភស្តុតាងខ្លះបានអះអាងថា ចំនួនមនុស្សក្នុងមួយឡានអាចច្រើនជាងនេះ[1431]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ចំនួនជនរងគ្រោះនេះ "គឺជាទំហំមួយដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃបទសម្លាប់រង្គាល"[1432]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា "កងទ័ពខ្មែរក្រហមដែលមកពីភូមិភាគពាយ័ព្យ មានបំណងសម្លាប់ក្នុងទ្រង់ទ្រាយធំនៅទួលពោធិ៍ជ្រៃ"[1433]។

៥៦៤.នួន ជា បានអះអាងថា ពុំមានមូលដ្ឋានគាំទ្រសម្រាប់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងចំនួនមនុស្សស្លាប់ ដែលបានផ្អែកលើភស្តុតាងពុំស៊ីសង្វាក់គ្នាឡើយ[1434] និងបានលើកឡើងថា បញ្ហានេះកាន់តែធ្ងន់ធ្ងរបន្ថែមទៀតដោយសារការដែលថា ពុំមែនរាល់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានធ្វើតាមការប្រកាសនោះត្រូវបានសម្លាប់ឡើយ និងថា មានអ្នកខ្លះត្រឹមតែបានបញ្ជូនទៅកាន់ទីកន្លែងធ្វើការដើម្បីអប់រំកែប្រែប៉ុណ្ណោះ[1435]។ នួន ជា បានអះអាងថា ពុំអាចធ្វើទៅបានឡើយដើម្បីកំណត់ឱ្យហួសពីវិមតិសង្ស័យថា មានប្រជាជនប៉ុន្មាននាក់ត្រូវបានសម្លាប់នោះ[1436]។ ចុងក្រោយ នួន ជា បានអះអាងថា ពុំមានភស្តុតាងរូបវ័អំពីការស្លាប់ ឬភស្តុតាងដែលបង្ហាញឈ្មោះជនរងគ្រោះ[1437]។

៥៦៥.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានទាក់ទងទៅនឹងចំនួនអប្បបរមាជនរងគ្រោះដោយផ្អែកលើអត្ថិភាពនៃភស្តុតាង។ អង្គជំនុំជម្រះគណនាចំនួនអប្បបរ

---

[1431] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧៦ ជើងទំព័រ ២១២៥។

[1432] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៤ ជើងទំព័រ ២១៤០ យោងទៅលើកថាខណ្ឌ ៦៨១។

[1433] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៤។

[1434] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦៦។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២៩។

[1435] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៩០។

[1436] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦៣ ដល់ ៤៦៦។

[1437] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦៥។

មាដោយផ្អែកលើអត្ថិភាពនៃព័ត៌មាន[1438] និងមានកំហុសដោយពុំបានគោរពតាមគោលការណ៍ស្ដីពី *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ*។ បើទោះបីជាភស្តុតាងប្រសើរជាងនេះដទៃទៀតពុំអាចរកបានក៏ដោយ ក៏ពុំអាចធ្វើឱ្យវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្លាយទៅជាពុំសមហេតុផលនោះឡើយ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខរបស់ នួន ជា ពាក់ព័ន្ធទៅនឹងបញ្ហានេះ ត្រូវបដិសេធចោល។

៥៦៦.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កំហុសអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងធាតុផ្សំ *អត្តនោម័ត*នៃបទសម្លាប់រង្គាល ពុំមានឥទ្ធិពលលើសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ ដោយសារសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើចេតនាផ្ទាល់ក្នុងការសម្លាប់មិនមែនផ្អែកលើ *ចេតនាប្រយោល (dolus eventualis)* នោះទេ។ អាស្រ័យហេតុនេះ ពុំមានមូលហេតុត្រូវបដិសេធសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហានេះឡើយ។

### ៤.ឃ.៣.អំពើអមនុស្សធម៌ផ្សេងៗទៀត

៥៦៧.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការប្រព្រឹត្ត"អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាបទឧក្រិដ្ឋមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ និងថា ជនជាប់ចោទ"អាចយល់ដឹងថា មានច្បាប់ចែង និងជាបទល្មើស"[1439]។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ឧក្រិដ្ឋកម្មនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺស្ថិតក្នុងប្រភេទបទឧក្រិដ្ឋមិនជាក់លាក់ដែលគ្របដណ្ដប់លើអំពើប្រព្រឹត្តដោយចេតនាដែលបណ្ដាលឱ្យមាន"ព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្ត ឬជាការប៉ះពាល់ធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូរ"[1440]។ អង្គជំនុំជម្រះបានយល់ឃើញថា ការប្រព្រឹត្តនេះត្រូវតែ"មានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលត្រូវធ្វើការវាយតម្លៃទៅតាមករណីជាក់ស្ដែងនីមួយៗ[1441]។

---

[1438] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៧៦។

[1439] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣៥។

[1440] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣៧។

[1441] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣៨។

៥៦៨.ដោយអនុវត្តតាមវិធីសាស្ត្រនៃដីកាដំណោះស្រាយ (D427) អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកបទចោទនានាមានការជាប់ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ។ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គិតចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានផ្លាស់ទីលំនៅប្រជាជន យ៉ាងតិចចំនួន ២ លាននាក់ក្រោមលក្ខខណ្ឌអមនុស្សធម៌ និងដោយបង្ខំចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ ដែលនេះជាការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការផ្លាស់ទីលំនៅដោយបង្ខំ[1442]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា លក្ខខណ្ឌ និងកាលៈទេសៈបែបហិង្សានៃការជម្លៀសចេញពីទីក្រុងភ្នំពេញ គឺជាបទនៃអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[1443]។

៥៦៩.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា នៅចន្លោះពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៧ ការផ្លាស់ទីលំនៅប្រជាជនយ៉ាងតិចចំនួនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ទៅកាន់កន្លែងផ្សេងៗ គឺជាអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការផ្លាស់ទីលំនៅដោយបង្ខំ[1444]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ខ្មែរក្រហម"បានដកហូតនូវសិទ្ធិសេរីភាពរបស់ប្រជាជន និងបានបដិសេធក្នុងការបង្ហាញព័ត៌មានទាក់ទងទៅនឹងវាសនា និងទីកន្លែងដែលប្រជាជនមួយចំនួន[ត្រូវបានផ្លាស់ទៅនៅ]" និងបានសន្និដ្ឋានថា នេះគឺជាអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[1445]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា លក្ខខណ្ឌនៃការជម្លៀសនេះបានបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្ត ដូច្នេះនេះគឺជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ដែលជាអំពើអមនុស្សធម៌ផ្សេងៗទៀត[1446]។

---

[1442] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤៧, ៥៥២។

[1443] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៥។

[1444] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៨ ដល់ ៦៣៩។

[1445] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤២ ដល់ ៦៤៣។

[1446] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៥។

៥៧០.សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទ"អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ)"[1447]។

៥៧១.នៅដំណាក់កាលនៃបណ្តឹងសាទុក្ខ នួន ជា និង ខៀវ សំផន បានជំទាស់ទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងការយល់ឃើញទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងទាំងនេះដូចខាងក្រោម។

### ៤.ឃ.៣.ក.វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំដែលជា"អំពើអមនុស្សធម៌ផ្សេងៗទៀត"

៥៧២.អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបដិសេធអំណះអំណាងរបស់ជនជាប់ចោទដែលថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងអំឡុងពេលដែលជាប់ពាក់ព័ន្ធទៅនឹងបទចោទនោះ ពុំមែនជាអំពើអមនុស្សធម៌ផ្សេងៗទៀត និងបានយល់ឃើញថា អាស្រ័យលើកាលៈទេសៈនៃរឿងក្តី អំពើទាំងពីរនេះព្រមទាំងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិផងនោះ អាចមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូច្នេះអំពើទាំងនេះស្ថិតក្នុងវិសាលភាពនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[1448]។

៥៧៣.យោងតាមយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ យុត្តិសាស្ត្រអន្តរជាតិដទៃទៀត និងលិខិតុបករណ៍ច្បាប់ក្រោយឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យនៃការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[1449]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការផ្លាស់ទីលំនៅដោយបង្ខំត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ ដោយហេតុថា ការផ្លាស់ទីលំនៅនេះបានបង្កឱ្យមាន"ព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ និងផ្លូវចិត្ត"ដល់ប្រជាជនដែលត្រូវបានផ្លាស់ទី

---

[1447] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២២។

[1448] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៤៣, ៤៤៨, ៤៥២, ៤៥៥, ៤៥៨។

[1449] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៤៨, ៤៥០។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៥១ ដល់ ៤៥៥។

លំនៅទាំងនោះ ដូច្នេះឈានដល់កម្រិតនៃបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1450]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា លក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ ដែលរួមបញ្ចូលការស្លាប់ដោយសារលក្ខខណ្ឌនេះ ត្រូវចាត់ជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ដូច្នេះ លក្ខខណ្ឌនេះបានឈានដល់កម្រិតធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1451]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ បានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ និងបានឈានដល់កម្រិតនៃបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើការរៀបរាប់អំពីការរងទុក្ខវេទនាដែលបានកើតឡើងដោយសារអំពើទាំងនេះ[1452]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា កម្មាភិបាល និងកងទ័ពខ្មែរក្រហមបានប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[1453]។

៥៧៤.នួន ជា បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំ[1454] ពីរយ៉ាងថា ទីមួយ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានរំលោភបំពានលើលក្ខខណ្ឌតម្រូវនៃភាពអាចយល់ដឹងជាមុនថា ជាបទល្មើស និងមានច្បាប់ចែងដែលកើតចេញពីគោលការណ៍នីត្យានុកូលភាព[1455] ដោយហេតុថា ក្នុងឆ្នាំ ១៩៧៥ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំ "ពុំមានអត្ថិភាពជាទម្រង់ណាមួយក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ" [1456]។ នួន ជា បានអះអាងពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅដោយបង្ខំថា មានតែការនិរទេសឆ្លងកាត់ព្រំដែនអន្តរ

---

[1450] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥២, ៦៣៩។

[1451] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៥, ៦៤៥។

[1452] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៣។

[1453] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥២, ៥៦៥, ៦៣៩, ៦៤៣, ៦៤៥។

[1454] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០០ ដល់ ៤២១។

[1455] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០១ ដល់ ៤០៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣៥ ដល់ ៤៣៦។

[1456] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៥។

ជាតិ ឬនៅក្នុងទឹកដីដែលត្រូវបានកាន់កាប់ប៉ុណ្ណោះ ទើបជាបទល្មើស និង[1457]ថា ទាក់ទងទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើ *រឿងក្តីទាក់ទងទៅនឹងវិស័យយុត្តិធម៌* ជាការពុំត្រឹមត្រូវឡើយ[1458]។ ទីពីរ អង្គជំនុំជម្រះសាលាដំបូង ពុំបានអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗលើបញ្ហា ថាតើការប្រព្រឹត្តដែលចោទជាបញ្ហានោះ មានសភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើឧក្រិដ្ឋជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណានោះឡើយ[1459]។ នួន ជា បានអះអាងទាក់ទងទៅនឹងបញ្ហានេះថា ជំនួសឱ្យការវាយតម្លៃជាក់ស្តែងតាមករណីនីមួយៗដែលតម្រូវនោះ អង្គជំនុំជម្រះបែរជា“បញ្ជាក់ធាតុផ្សំនៃបទឧក្រិដ្ឋជាក់លាក់ និងសម្រេចថា ការប្រព្រឹត្តដែលបំពេញតាមធាតុផ្សំទាំងអស់នេះ គឺជាបទឧក្រិដ្ឋតែម្តង”[1460]។

៩៧៥.សហព្រះរាជអាជ្ញាបានឆ្លើយតបថា នួន ជា បានបកស្រាយដោយពុំត្រឹមត្រូវលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងលើការវាយតម្លៃអំពីគោលការណ៍នីត្យានុកូលភាពដែលតាមការអះអាងរបស់សហព្រះរាជអាជ្ញាថា គោលការណ៍ទាំងនោះ“ត្រូវបានកំណត់នៅក្នុងប្រភេទនីមួយៗនៃអំពើអមនុស្សធម៌ផ្សេងៗទៀតរួចហើយ”សម្រាប់ការសម្រេចដាក់ពិរុទ្ធភាព[1461]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងត្រឹមត្រូវចំពោះអំពើប្រព្រឹត្តទៅតាមករណីជាក់ស្តែងនីមួយៗ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើអំពើប្រព្រឹត្តនៅក្នុងបរិបទ កាលៈទេសៈនៃអំពើ និងផលប៉ះពាល់ដល់ជនរងគ្រោះ និងបានកំណត់ថា ការប្រព្រឹត្តរបស់ ប.ក.ក. ក្នុងការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ មាន“លក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងច្បាប់ អ.វ.ត.ក.”[1462]។

៩៧៦.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ច្បាស់លាស់ណាស់ដែលថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ ១៩៧៥ “អំពើអមនុស្សធម៌ផ្សេងៗទៀត” ត្រូវបានទទួលស្គាល់ថា ជាប្រភេទនៃអំពើពុំជាក់លាក់នៅក្នុង

---

[1457] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៩ ដល់ ៤១៤។

[1458] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤១៥ ដល់ ៤២១។

[1459] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៧ ដល់ ៤០៨។

[1460] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៨។

[1461] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣១។

[1462] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣៣, ២៣៤, ២៣៦។

01358281



ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ករណីនេះត្រូវបានបង្ហាញតាមរយៈអត្ថិភាពនៃលិខិតុបករណ៍ច្បាប់អន្តរជាតិ[1463] ព្រមទាំងយុត្តិសាស្ត្រដែលបានមកពីរឿងក្តីនៅក្រោយសង្គ្រាមលោកលើកទីពីរ[1464]។ បន្ថែមលើនេះទៀត តុលាការអន្តរជាតិមួយចំនួន និងតុលាការឧក្រិដ្ឋកម្មនានាក្រោយមកបានអនុវត្តប្រភេទនៃបទឧក្រិដ្ឋនេះ[1465]។ យោងតាមហេតុការណ៍ទាំងអស់នេះ តុលាការពុំមែនទើបតែបានសំអាងទៅលើការអនុវត្តរបស់រដ្ឋក្រោយឆ្នាំ ១៩៧៥ ក្នុងការបង្ហាញពីអត្ថិភាពជាទំនៀមទម្លាប់នៃ“អំពើអមនុស្សធម៌ផ្សេងៗទៀត”នោះទេ ប៉ុន្តែតុលាការបានសំអាងទៅលើការអនុវត្តរបស់រដ្ឋដូចគ្នានេះតាំងពីក្រោយសង្គ្រាមលោកលើកទីពីរភ្លាមៗមកម្ល៉េះ។ យោងតាមហេតុផលទាំងនេះ មានការបង្ហាញថា អំពើអមនុស្សធម៌ផ្សេងៗទៀត គឺជាផ្នែកមួយដែលបានបង្កើតឡើងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងអំឡុងពេលជាប់ពាក់ព័ន្ធទៅនឹងរឿងក្តីនេះ។

៥៧៧.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់ផងដែរ ថាតើគោលគំនិតនៃ“អំពើអមនុស្សធម៌ផ្សេងៗទៀត”មានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ដើម្បីឱ្យស្របតាមគោលការណ៍*គ្មានបទល្មើសបើ*

---

[1463] *សូមមើល* មាត្រា ៦(គ) នៃធម្មនុញ្ញរបស់តុលាការ IMT មាត្រា ៥(គ) នៃធម្មនុញ្ញរបស់តុលាការ IMTFE មាត្រា ២(១-គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង គោលការណ៍ទី ៦(គ) នៃគោលការណ៍ Nuremberg។

[1464] *សូមមើលផងដែរ រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងផ្សេងៗ* ទំព័រ ៤៦៧ ដល់ ៤៦៨ (ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋជាច្រើន មានដូចជា “ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការសម្លាប់ចំណាប់ខ្មាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ សាសនា និងអមនុស្សធម៌ផ្សេងៗទៀត”)។ *រឿងក្តីពាក់ព័ន្ធទៅនឹងផ្នែកវេជ្ជសាស្ត្រ* ទំព័រ ១៨៩ ដល់ ១៩០, ១៩៣ ដល់ ១៩៨ (ជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធ ដោយសារបានចូលរួមដោយចេតនានៅក្នុងការប្រព្រឹត្ត“អំពើឃោរឃៅនៅក្នុងអំឡុងពេលនៃការសម្លាប់ អំពើឃោរឃៅសាហាវព្រៃផ្សៃ ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត”)។ *រឿងក្តី Gerbsch* (តុលាការពិសេស ប្រទេសហូឡង់) ទំព័រ ១៣៤ (“ការធ្វើបាបនានាត្រូវបានគ្របដណ្តប់ដោយពាក្យពេចន៍នៃអំពើ*អមនុស្សធម៌ផ្សេងៗទៀត*”)។ *រឿងក្តី Zuehlke* (តុលាការពិសេស ប្រទេសហូឡង់) ទំព័រ ១៤៥ (ការឃុំខ្លួនខុសច្បាប់“ស្ថិតក្រោមសញ្ញាណនៃ*អំពើអមនុស្សធម៌ដទៃទៀតដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល*”)។ រឿងក្តីក្នុងស្រុកមួយចំនួនរបស់អ៊ីស្រាអែលបានយកលំនាំតាមនេះ ដូចជា៖ *រឿងក្តី AG ទល់នឹង Tarnek* (តុលាការថ្នាក់ស្រុក អ៊ីស្រាអែល)។ *សូមមើលផងដែរ រឿងក្តី AG ទល់នឹង Enigster* (តុលាការថ្នាក់ស្រុក អ៊ីស្រាអែល)។

[1465] របាយការណ៍របស់ Bassiouni ថា មកដល់ខែ វិច្ឆិកា ឆ្នាំ ២០១០ តុលាការអន្តរជាតិ និងតុលាការឧក្រិដ្ឋកម្មនានាបានផ្តល់ការសម្រេចដាក់ពិរុទ្ធភាពចំនួន ៦៥ ពីបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបទឧក្រិដ្ឋនេះត្រូវបានចោទប្រកាន់នៅក្នុងរឿងក្តីយ៉ាងច្រើន។ *សូមមើល* អ្នកនិពន្ធ Bassiouni ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិការវិវត្តន៍នៃប្រវត្តិ និងអនុវត្តន៍ក្នុងពេលបច្ចុប្បន្ន ៤១១ (ព្រឹត្តិប័ត្រព័ត៌មានសាលកវិទ្យាល័យ Cambridge ឆ្នាំ ២០១៤)។

*គ្មានច្បាប់ថែង* (*nullum crime sine lege certa*) ដែរ ឬយ៉ាងណា ដែលជាធាតុផ្សំនៃគោលការណ៍នីត្យានុកូលភាព[1466]។

៥៧៨.ដោយកត់សម្គាល់ថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាប្រភេទនៃបទឧក្រិដ្ឋដែលបង្កើតឡើងក្នុងគោលបំណងប្រើប្រាស់ជា"ឃ្លាមិនជាក់លាក់" ដើម្បីជៀសវាងមិនឱ្យមានលទ្ធភាពគេចវេសពីច្បាប់មនុស្សធម៌[1467] ប៉ុន្តែអាចនឹងពុំស្របទៅតាមលក្ខខណ្ឌតម្រូវនៃ*សច្ចភាពផ្លូវច្បាប់*[1468]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ប្រសិនបើបកស្រាយ និងអនុវត្តក្នុងគោលបំណងដើម្បីរឹតត្បិតវិសាលភាពនៃប្រភេទមិនជាក់លាក់នេះ នោះសញ្ញាណនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត"ពិតជាមានភាពច្បាស់លាស់ និងជាក់លាក់គ្រប់គ្រាន់ស្របតាមគោលការណ៍ស្តីពីភាពអាចដឹងជាមុនថា ជាបទល្មើស និងមានច្បាប់ចែងដែលកើតចេញពីគោលការណ៍នីត្យានុកូលភាព។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបកស្រាយឃ្លាដែលថា*ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា* (*ejusdem generis*) បានផ្តល់នូវការធានាដ៏ចាំបាច់ដូចបានបញ្ជាក់តាមរយៈការពិចារណាយ៉ាងទូលំទូលាយរបស់អង្គបុរេជំនុំជម្រះលើបញ្ហានេះថា ត្រឹមឆ្នាំ ១៩៧៥ "គោលការណ៍ដែលចែងថា ជនណាម្នាក់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយសារការប្រព្រឹត្តបទឧក្រិដ្ឋ ដែល*មានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែល*ទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្កើតឡើង និងត្រូវបានយល់ដឹងជាទូទៅរួចហើយ"[1469]។ គួរកត់សម្គាល់ផងដែរថា មាត្រា ៧(១-ង) នៃលក្ខន្តិកៈរបស់តុលាការ ICC បានអនុម័តយកច្បាស់លាស់នូវគោល

---

[1466] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៣។

[1467] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ៣៨៣ យោងទៅលើសាលក្រមនៃសំណុំរឿង ០០១ កថាខណ្ឌ ៣៦៧។ សាលក្រម*រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៥៦៣។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានទទួលយកការយល់ឃើញនេះ នៅក្នុងសាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៣១៥ ដល់ ៣១៦។ *សូមមើលផងដែរ* សេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការនៃកាកបាតក្រហម (ICRC) ស្តីពីអនុសញ្ញាទីក្រុងហ្សឺណែវ IV ទំព័រ ៣៩។

[1468] *សូមមើល* សាលក្រម*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៧១៩។

[1469] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ៣៨៤ ដល់ ៣៩៦។ *សូមមើលផងដែរ* សព្វវចនាធិប្បាយដោយ Claus Kress in Max Planck អំពីនីតិសាធារណៈអន្តរជាតិ"*គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង*" រឹមដើមទំព័រ ៣០ គេហទំព័រ http://www.uni-koeln.de/jur-fak/kress/NullumCrimen24082010.pdf។

គំនិតនេះនៅពេលកំណត់និយមន័យនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀតដែល *មានចរិតលក្ខណៈប្រហាក់ប្រហែលគ្នា* [ទៅនឹងអំពើទាំងនោះដែលបានរៀបរាប់ពីមុន]"[1470]។

៥៧៩.ការកម្រិតដទៃទៀតបានលេចឡើងជាបណ្ដើរៗតាមរយៈការវិនិច្ឆ័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាំងនៅមុនពេល និងចាប់តាំងពីពេលមានការប្រព្រឹត្តនូវបទឧក្រិដ្ឋដែលជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីរឿងក្ដីបច្ចុប្បន្ន។ អង្គជំនុំជម្រះតុលាការកំពូលសំអាងទៅលើការអភិវឌ្ឍន៍ទាំងនេះ ដើម្បីបង្កើតការកម្រិតលើប្រភេទមិនជាក់លាក់នេះ និងបានពិចារណាឃើញថា គ្មានអ្វីអាចរារាំងតុលាការមិនឱ្យសំអាងទៅលើការអភិវឌ្ឍន៍ផ្នែកច្បាប់បន្តបន្ទាប់ដែលស្របទៅនឹងគោលការណ៍*ស្ដីពីការអនុវត្តន៍ច្បាប់ដែលស្រាលជាង* ក្នុងការកម្រិតវិសាលភាពនៃបទដ្ឋានច្បាប់ព្រហ្មទណ្ឌដែលត្រូវបានបង្កើតឡើង។ ដូច្នេះក្នុងការបញ្ជាក់លម្អិតអំពីអត្ថន័យនៃភាពធ្ងន់ធ្ងរ តុលាការជាច្រើនបានព្យាយាមកំណត់បញ្ហា ថាតើអំពើដែលបានចោទប្រកាន់នោះបានបង្កឱ្យមាន"ការឈឺចាប់លើរូបកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ"ដែរ ឬយ៉ាងណា បើទោះបីជា ខ្លួនជានិច្ចកាលពុំបានប្រើប្រាស់ពាក្យពេចន៍ស្របគ្នាក៏ដោយ។ លក្ខន្តិកៈរបស់តុលាការ ICC បានកំណត់និយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀតថា "ជាអំពើដែលមានចរិតលក្ខណៈប្រហាក់ប្រហែលគ្នាដែលមានចេតនាបង្កការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬសុខភាពផ្លូវចិត្ត ឬផ្លូវកាយ"[1471]។ ម្យ៉ាងវិញទៀត តុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍* បានប្រើប្រាស់ពាក្យពេចន៍ខុសប្លែកគ្នាបន្តិចបន្តួច ដូចជា"ការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត" ឬ"ព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយ ឬផ្លូវចិត្ត"[1472]។ ផ្អែកតាមការពិចារណាយ៉ាងហ្មត់ចត់ និងការទទួលស្គាល់នូវភាពខុសប្លែកគ្នាតិចតួចខាងពាក្យ

---

[1470] មាត្រា ៧(១-ង) នៃលក្ខន្តិកៈរបស់តុលាការ ICC (សេចក្ដីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សាលក្រម*រឿងក្ដី D.Milošević* (ICTY) កថាខណ្ឌ ៩៣៤ យោងទៅលើសាលក្រម*រឿងក្ដី Vasiljević* (ICTY) កថាខណ្ឌ ២៣៤ បានទទួលយកនៅក្នុងសាលដីកា*រឿងក្ដី Vasiljević* (ICTY) កថាខណ្ឌ ១៦៥។ សាលក្រម*រឿងក្ដី Galić* (ICTY) កថាខណ្ឌ ១៥២។ *សូមមើលផងដែរ* សាលដីកា*រឿងក្ដី Kordić និង Čerkez* (ICTY) កថាខណ្ឌ ១១៧។ សាលក្រម*រឿងក្ដី Martić* (ICTY) កថាខណ្ឌ ៨៣។ សាលក្រម*រឿងក្ដី Blagojević និង Jokić* (ICTY) កថាខណ្ឌ ៦២៦។ សាលក្រម*រឿងក្ដី Krnojelac* (ICTY) កថាខណ្ឌ ១៣០។ សាលក្រម*រឿងក្ដី* (ICTR) កថាខណ្ឌ ៩៣២ ដល់ ៩៣៣។ សាលក្រម*រឿងក្ដី Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១៥១។

[1471] មាត្រា ៧(១-ង) នៃលក្ខន្តិកៈរបស់តុលាការ ICC។

[1472] សាលដីកា*រឿងក្ដី Vasiljević* (ICTY) កថាខណ្ឌ ១៦៥។ សាលដីកា*រឿងក្ដី Kordić and Čerkez* (ICTY) កថាខណ្ឌ ១១៧។ សាលក្រម*រឿងក្ដី D. Milošević* (ICTY) កថាខណ្ឌ ៩៣៤។ សាលក្រម*រឿងក្ដី Galić* (ICTY) កថាខណ្ឌ ១៥២។ សាលដីកា*រឿងក្ដី Blagojević និង Jokić* (ICTY) កថាខណ្ឌ ៦២៦។ សាលក្រម*រឿងក្ដី Krnojelac* (ICTY) កថាខណ្ឌ ១៣០។ សាលក្រម*រឿងក្ដី Kajelijeli* (ICTR) កថាខណ្ឌ ៩៣២ ដល់ ៩៣៣ (ព្យសនកម្មធ្ងន់ធ្ងរលើសុខភាពផ្លូវកាយ និងផ្លូវចិត្ត)។ សាលក្រម*រឿងក្ដី*

ពេចន៍ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការកម្រិតខាងក្រោមនេះលើអំពើ“អមនុស្សធម៌ផ្សេងៗទៀត” មានការគាំទ្រយ៉ាងទូលំទូលាយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិសម័យទំនើប និងថា “អំពើអមនុស្សធម៌ផ្សេងៗទៀតនេះ”ត្រូវបានកម្រិតយ៉ាងគ្រប់គ្រាន់។

៥៨០.ធាតុផ្សំជាក់លាក់នៃបទអំពើអមនុស្សធម៌ផ្សេងៗទៀត គឺជា (i) អំពើសកម្ម ឬអកម្មដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ii) អំពើសកម្ម ឬអកម្មដែលបណ្តាលឱ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ (iii) អំពើសកម្ម ឬអកម្មដែលបានប្រព្រឹត្តឡើងដោយចេតនា។

៥៨១.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ស្ថាប័នតុលាការនានាបានអនុវត្តតាមការកំណត់និយមន័យនេះយ៉ាងតឹងរ៉ឹង។ តុលាការ ICC បានយល់ឃើញក្នុង *រឿងក្តី Kenyatta* ថា ការកាត់ស្បែកចុងអង្គជាតិដោយបង្ខំ[1473] ការគ្រៀវ[1474] ការសម្លាប់នៅចំពោះមុខកុមារ[1475] ការធ្វើឱ្យបាតុកររងរបួស អាចចាត់ជា“អំពើអមនុស្សធម៌ផ្សេងៗទៀត”[1476] ចំណែកការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិពុំអាចចាត់ជាអំពើបែបនេះឡើយ[1477]។ ប្រហាក់ប្រហែលគ្នានេះដែរ តុលាការអន្តរជាតិដទៃទៀត និងតុលាការឧក្រិដ្ឋកម្មបានផ្តល់ហេតុផលថា ការផ្លាស់ទីលំនៅដោយបង្ខំ[1478] លក្ខខណ្ឌនៃការឃុំខ្លួនដែលពុំអាចទទួលយកបាន[1479] ការបង្ខំឱ្យបុគ្គលមើលការសម្លាប់សមាជិកគ្រួសារ[1480] និងការប្រើប្រាស់អ្នកជាប់ឃុំធ្វើជារបាំងការពារ[1481] ទាំងអស់នេះសុទ្ធតែឈាន

---

*Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១៥១។*សូមមើលផងដែរ* សាលដីកា *រឿងក្តី Milutinović* កថាខណ្ឌ ៣៦៦ (អង្គជំនុំជម្រះតុលាការកំពូលនោះបានយល់ឃើញថា “អំពើអមនុស្សធម៌ផ្សេងៗទៀតតម្រូវឱ្យមានការបង្ហាញនូវអំពើសកម្ម ឬអកម្មដែលបណ្តាលឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ”(សេចក្តីបញ្ជាក់បន្ថែម))។

[1473] សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ *រឿងក្តី Kenyatta* (ICC) កថាខណ្ឌ ២៧០ ដល់ ២៧៣។

[1474] សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ *រឿងក្តី Kenyatta* (ICC) កថាខណ្ឌ ២៧០ ដល់ ២៧៣។

[1475] សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ *រឿងក្តី Kenyatta* (ICC) កថាខណ្ឌ ២៧៦ ដល់ ២៧៧។

[1476] សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ *រឿងក្តី Kenyatta* (ICC) កថាខណ្ឌ ២៨០។

[1477] សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ *រឿងក្តី Kenyatta* (ICC) កថាខណ្ឌ ២៧៩។

[1478] សាលក្រម *រឿងក្តី Đordjević* (ICTY) កថាខណ្ឌ ១៦២១។

[1479] សាលក្រម *រឿងក្តី Krnojelac* (ICTY) កថាខណ្ឌ ១៣៣។

[1480] សាលក្រម *រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៨១៩។

ដល់កម្រិតនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ប៉ុន្តែបើប្រៀបធៀប ជាមួយអំពើហិង្សាតូចតាច[1482] ឧទាហរណ៍ ដូចជា ការបង្ខំឱ្យជនជាតិ Tutsi មិនឱ្យចេញពីប្រទេសរវ៉ាន់ដាក្នុងអំឡុងពេលប្រល័យពូជសាសន៍[1483] និងការបង្ខំអ្នកជាប់ឃុំឱ្យប្រគល់ទ្រព្យសម្បត្តិឯកជនធ្វើជាទីបញ្ចាការយោធា ពុំត្រូវបានចាត់ទុកជា"អំពើអមនុស្សធម៌ផ្សេងៗទៀត"[1484]ឡើយ។ ផ្អែកតាមករណីជាក់ស្តែង អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការកម្រិតដែលបានរៀបរាប់ខាងលើត្រូវបានយកមកអនុវត្តដោយទៀងទាត់នៅក្នុងយុត្តាធិការផ្សេងៗដែលគ្របដណ្តប់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងថា ការកម្រិតទាំងនេះមានអត្ថន័យនៅក្នុងការអនុវត្ត។

៥៨២.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើយុត្តិសាស្ត្រក្នុង*រឿងក្តី Kupreškić* ដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានយល់ឃើញថា វិធានស្តីពី*ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា*"ពុំបានជួយអ្វីច្រើន" ដល់ការកំណត់អត្តសញ្ញាណនៃការប្រព្រឹត្ត ដែលមានលក្ខណៈជាអំពើអមនុស្សធម៌ផ្សេងៗទៀត[1485]នោះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានពិចារណាថា៖

> ការបកស្រាយលើ*អំពើអមនុស្សធម៌ផ្សេងៗទៀត* មានវិសាលភាពពុំសូវទូលំទូលាយឡើយនៅក្នុងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស [...]។ ដោយផ្អែកលើបទប្បញ្ញត្តិផ្សេងៗនៅក្នុងបទដ្ឋាននេះឃើញថា លទ្ធភាពអាចធ្វើទៅបានក្នុងការកំណត់អត្តសញ្ញាណនៃសិទ្ធិជាមូលដ្ឋានមួយចំនួនពាក់ព័ន្ធទៅនឹងមនុស្សជាតិ ដែលការរំលោភបំពានសិទ្ធិនេះ អាចស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែអាស្រ័យលើកាលៈទេសៈនាពេលនោះ[1486]។

---

[1481] សាលក្រម *រឿងក្តី Naletilić* (ICTY) កថាខណ្ឌ ២៤៥។ សាលក្រម *រឿងក្តី Blaškić* (ICTY)។ សាលក្រម *រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ៧៧៣។

[1482] សាលក្រម *រឿងក្តី Krnojelac* (ICTY) កថាខណ្ឌ ២០០ ដល់ ២០៤។

[1483] សាលក្រម *រឿងក្តី Nyiramasuhuko* (ICTR) កថាខណ្ឌ ៦១៩៤។

[1484] សាលក្រម *រឿងក្តី Naletilić* (ICTY) កថាខណ្ឌ ៣១១ ដល់ ៣១២។

[1485] សាលក្រម *រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៥៦៤។

[1486] សាលក្រម *រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៥៦៦។

៥៨៣.អង្គជំនុំជម្រះសាលាដំបូងនៃ*រឿងក្តី Kupreškić* បានយោងផងដែរទៅលើបទប្បញ្ញត្តិនៃច្បាប់មនុស្សធម៌ និងសេចក្តីសម្រេចរបស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ក្នុងការកំណត់អត្តសញ្ញាណនៃអំពើប្រព្រឹត្តដែលជាការប្រព្រឹត្តដោយអមនុស្សធម៌[1487]។

៥៨៤.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការភ្ជាប់ទំនាក់ទំនងរវាង"អំពើអមនុស្សធម៌ផ្សេងៗទៀត"ជាមួយនឹងអំពើប្រព្រឹត្តដែលរំលោភបំពានលើសិទ្ធិជាសារវ័ន្តរបស់មនុស្សជាតិ ដូចបានបញ្ជាក់នៅក្នុងលិខិតុបករណ៍ច្បាប់អន្តរជាតិនោះ គឺជាគោលគំនិតសមស្របមួយត្រង់ថា បន្ថែមទៅលើធាតុផ្សំសត្យានុម័តដែលត្រូវបានកំណត់អត្តសញ្ញាណតាមរយៈលក្ខណៈវិនិច្ឆ័យស្តីពី*ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា (ejusdem generis)* គោលគំនិតនេះបានបង្ហាញលក្ខខណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការជាអន្តរជាតិ និងតាមរបៀបនេះ គឺជាការកម្រិតមួយបន្ថែមទៀតទៅលើសិទ្ធិអំណាចទាំងមូល ក្នុងការបកស្រាយ"អំពើអមនុស្សធម៌ផ្សេងៗទៀត"។ បើទោះបីជា គោលគំនិតនេះហាក់បីដូចជាពុំត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនោះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់អំពីអត្ថប្រយោជន៍នៃគោលគំនិតនេះ សម្រាប់កំណត់លក្ខខណ្ឌតម្រូវនៃភាពអាចដឹងជាមុនបាន។ ទោះជាយ៉ាងណាក្តី ពុំមានលក្ខខណ្ឌតម្រូវថា អំពើប្រព្រឹត្តជាក់លាក់ត្រូវតែជាបទល្មើសច្បាស់លាស់តាមច្បាប់អន្តរជាតិ ដែលនេះត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ[1488] និងត្រូវបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូលផងដែរ ពីព្រោះការកំណត់លក្ខខណ្ឌបែបនោះ អាចធ្វើឱ្យគោលគំនិតនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែលជាប្រភេទពុំជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅជាឥតប្រយោជន៍ និងគ្មានប្រសិទ្ធភាព។ ផ្ទុយទៅវិញ ក្នុងការកំណត់"លក្ខខណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការ" ត្រូវតែធ្វើឡើងតាមរយៈការកំណត់អត្តសញ្ញាណនៃការបញ្ជាក់ច្បាស់លាស់នូវសិទ្ធិ និងការហាមឃាត់ដែលមានចែងនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស ដែលអនុវត្តបាននៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត"។ ក្នុងចំណោមលិខិតុបករណ៍នោះ និងសំខាន់សម្រាប់រឿងក្តីចំពោះមុខ មាត្រា ៣ ទូទៅនៃអនុសញ្ញាទីក្រុងហ្សឺណែវគន្លឹ I ដល់ IV កំណត់លក្ខខណ្ឌអំពីការប្រព្រឹត្តដោយអមនុស្សធម៌របស់បុគ្គលដែលពុំបានចូលរួមយ៉ាងសកម្មនៅក្នុងការប្រទូសរ៉ាយ និងហាមឃាត់*ក្នុងចំណោមនោះ*អំពើហិង្សាដល់អាយុជីវិតមនុស្សជាពិសេស ការធ្វើមនុស្សឃាតគ្រប់រូបភាព ការធ្វើកាយវិកលកម្ម អំពើឃោរឃៅ ការធ្វើទារុណកម្ម

[1487] សាលក្រម*រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៥៦៦។

[1488] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ៣៨៩។ *សូមមើលផងដែរ* សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣១ ដល់ ២៣២។

ការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់បុគ្គល និងជាពិសេសការធ្វើឱ្យអាម៉ាស់ និងអំពើបទ្ទាបបន្ថោក និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ[1489]។ បន្ថែមលើនេះទៀត សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្សដែលត្រូវបានអនុម័តស្ទើរតែភ្លាមៗនៅពេលនោះ បញ្ចូលទៅក្នុងគោលការណ៍ Nuremberg បានការពារសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់បុគ្គល[1490] និងសិទ្ធិសេរីភាពក្នុងការដើរហើរ និងការតាំងទីលំនៅក្នុងព្រំដែនរបស់រដ្ឋនីមួយៗ[1491] និងហាមឃាត់*ក្នុងចំណោមនោះ* មានដូចជា ការធ្វើទារុណកម្ម ឬអំពើឃោរឃៅអមនុស្សធម៌ ការបទ្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម[1492] ការរើសអើង[1493] និងការធ្វើទុក្ខបុកម្នេញ[1494] ការចាប់ខ្លួនតាមអំពើចិត្ត ការឃុំខ្លួន ឬការនិរទេស[1495] ការជ្រៀតជ្រែកតាមអំពើចិត្តចូលក្នុងជីវិតឯកជន គ្រួសារ ផ្ទះសម្បែង ឬការប្រាស្រ័យទាក់ទង និងការវាយប្រហារលើសេចក្ដីថ្លៃថ្នូរ និងកិត្តិយស[1496]។

៥៨៥.តាមលក្ខខណ្ឌជាក់ស្ដែង អំពើអមនុស្សធម៌ដែលឈានដល់កម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាធម្មតាអាចនឹងរំលោភបំពានលើគោលការណ៍ស្ដីពីសិទ្ធិមនុស្សដែលបានបញ្ជាក់ខាងដើមនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា សិទ្ធិសេរីភាព សេរីភាពក្នុងការដើរហើរ ការតាំងទីលំនៅក្នុងព្រំដែនរបស់រដ្ឋ និងការហាមឃាត់អំពើឃោរឃៅ អមនុស្សធម៌ ឬបទ្ទាបបន្ថោក ជាពិសេសមានការជាប់ពាក់ព័ន្ធសម្រាប់បទចោទបច្ចុប្បន្ន។ នៅក្នុងព្រឹត្តិការណ៍ដែលបទដ្ឋានបន្តបន្ទាប់ស្ដីពីសិទ្ធិមនុស្ស ពុំទំនងជាអាចលុបបំបាត់ ឬកម្រិតបទដ្ឋាននៃសិទ្ធិមនុស្ស ឬការហាមឃាត់នោះ ការអភិវឌ្ឍន៍បន្ថែមទៀតនៅក្នុងបទដ្ឋានស្ដីពីសិទ្ធិមនុស្ស និងការកែលំអបទដ្ឋាននេះ អាចត្រឹមតែពាក់ព័ន្ធទៅនឹង*គោលការណ៍ច្បាប់ដែលស្រាលជាង*ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ការលេចឡើងបន្តបន្ទាប់នូវបទដ្ឋានថ្មីស្ដីពីសិទ្ធិមនុស្សជាក់លាក់បន្ថែមទៀត រួមទាំងបទដ្ឋាននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចជា បទដ្ឋានប្រឆាំងនឹងការផ្លាស់ទីលំនៅដោយបង្ខំ ឬការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ អាចជាការអះអាងបន្ថែមលើអនីត្យានុកូលភាពអន្តរជាតិស្ដីពីអំពើប្រព្រឹត្តជាក់

---

1489 មាត្រា ៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវផ្នែក I-IV។

1490 មាត្រា ៣ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស។

1491 មាត្រា ១៣(១) នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស។

1492 មាត្រា ៥ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស។

1493 មាត្រា ៧ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស។

1494 មាត្រា ១៤(១) នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស។

1495 មាត្រា ៩ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស។

1496 មាត្រា ១២ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស។

លាក់ពីដំបូងដែលបានចោទប្រកាន់ថា "ជាអំពើអមនុស្សធម៌ផ្សេងៗទៀត" និងអាចត្រូវបានប្រើប្រាស់ជារង្វាស់សម្រាប់វាយតម្លៃលើបញ្ហា ថាតើអំពើប្រព្រឹត្តនោះឈានដល់កម្រិតធ្ងន់ធ្ងរដែលតម្រូវ ដែរ ឬយ៉ាងណា។ ទោះជាយ៉ាងណាក្តី អត្ថិភាពនៃបទដ្ឋានជាក់លាក់ជាងពុំអាចកំណត់ ថាតើបទចោទនោះស្របតាមគោលការណ៍នីត្យានុកូលភាព ដែរ ឬយ៉ាងណានោះឡើយ។

៥៨៦.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ នួន ជា ដែលថា ដោយសារតែ"បទល្មើសទាំងឡាយដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ពុំមានអត្ថិភាពតាមទម្រង់ណាមួយតាមច្បាប់ទំនៀមទម្លាប់នាពេលនោះឡើយ" ទើបជនជាប់ចោទពុំអាចយល់ដឹងជាមុនគ្រប់គ្រាន់ថា ការប្រព្រឹត្តនេះ គឺជាបទល្មើស[1497]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង*ត្រូវបានគោរព ប្រសិនបើអំពើប្រព្រឹត្តជាក់លាក់ដែលត្រូវបានរកឃើញថា ជាអំពើអមនុស្សធម៌ផ្សេងៗទៀតនោះ រំលោភបំពានលើសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ និងមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ផ្អែកតាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ចំណុចនេះតម្រូវឱ្យមានការពិចារណាដោយផ្អែកតាមករណីជាក់ស្តែងនីមួយៗអំពីផលប៉ះពាល់នៃអំពើប្រព្រឹត្តទៅលើជនរងគ្រោះ និងថាតើ អំពើនេះអាចប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា។ នៅក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ពុំចាំបាច់ពិចារណាលើអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនៅក្នុងរដ្ឋមួយដែលពុំមានការកាន់កាប់នោះ ពុំអាចបង្កើតឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬត្រូវបានហាមឃាត់ដោយច្បាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឬថា ពុំមានអត្ថិភាពនៃសញ្ញាណផ្លូវច្បាប់ស្តីពី"ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ"ឡើយ[1498]។

៥៨៧.នួន ជា បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ពីព្រោះអង្គជំនុំជម្រះពុំបានធ្វើការពិចារណាដោយផ្អែកលើករណីជាក់លាក់អំពីភាពធ្ងន់ធ្ងរនៃអំពើប្រព្រឹត្តដែលចោទជាបញ្ហានេះ តែផ្ទុយទៅ

---

[1497] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៥។

[1498] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៩ ដល់ ៤១៩។

វិញបាន"បញ្ជាក់ធាតុផ្សំនៃបទឧក្រិដ្ឋជាក់លាក់ និងបានសម្រេចថា អំពើប្រព្រឹត្តដែលស្របតាមលក្ខខណ្ឌនៃធាតុផ្សំទាំងអស់នោះ គឺជាបទឧក្រិដ្ឋតែម្តង"[1499]។

៥៨៨.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានបង្ហាញអំពីធាតុផ្សំនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[1500] និងការផ្លាស់ទីលំនៅដោយបង្ខំ[1501]។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើអង្គហេតុពាក់ព័ន្ធធៀបជាមួយនឹងធាតុផ្សំទាំងនេះ[1502]។ ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងក៏បានវាយតម្លៃរួចហើយលើបញ្ហា ថាតើ ក្នុងករណីនេះ អំពើប្រព្រឹត្តដែលខ្លួនរកឃើញនោះបានឈានដល់កម្រិតមួយស្មើនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ អ.វ.ត.ក. ដែរ ឬយ៉ាងណា ដើម្បីអាចចាត់ទុកបានថា ជា

---

[1499] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤០៨។

[1500] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៤៨ (អង្គជំនុំជម្រះបានសន្និដ្ឋានថា "ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំអាចមានទម្ងន់ប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [...] ដូច្នេះអាចស្ថិតក្នុងវិសាលភាពនៃ*អំពើអមនុស្សធម៌ផ្សេងៗទៀត*"។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់និយមន័យអំពីការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដោយបានកំណត់អត្តសញ្ញាណធាតុផ្សំសត្យានុម័តចំនួនបី: (i) បុគ្គលណាម្នាក់ត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ខ្លួន (ii) ការដកហូតសិទ្ធិសេរីភាពនេះត្រូវបានធ្វើឡើងតាមរយៈការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងទៅនឹងជោគវាសនា ឬទីកន្លែងដែលបុគ្គលជាប់ពាក់ព័ន្ធនោះស្ថិតនៅ ឬបដិសេធមិនទទួលស្គាល់ការដកហូតសេរីភាពនេះ ដោយបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់ និងការធានាផ្នែកនីតិវិធីចំពោះមុខបុគ្គលនោះ និង (iii) ធាតុផ្សំទីមួយ និងទីពីរត្រូវបានអនុវត្តដោយភ្នាក់ងាររដ្ឋ ឬដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ ឬអង្គការនយោបាយណាមួយ")។

[1501] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៥០ (អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការកំណត់និយមន័យនៃការផ្លាស់ទីលំនៅដោយបង្ខំ ដែលមានធាតុផ្សំបួន (ដូចជា "(i) ចេតនា (ii) នៃការផ្លាស់ទីលំនៅដោយបង្ខំ (iii) ឱ្យចាកចេញពីតំបន់មួយដែលពួកគេរស់នៅដោយស្របច្បាប់ (iv) ដោយគ្មានយុត្តិកម្មសមស្របអំពីក្តីបារម្ភផ្នែកសន្តិសុខរបស់ជនស៊ីវិល ឬភាពចាំបាច់ណាមួយខាងផ្នែកនយោបាយ")។

[1502] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤៧ ដល់ ៥៥២, ៦៣០ ដល់ ៦៣៩ (ការផ្លាស់ទីលំនៅដោយបង្ខំ) និង ៦៤០ ដល់ ៦៤៣ (ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទាក់ទងទៅនឹង"ការធ្វើឱ្យប៉ះពាល់លើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ" អង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់និយមន័យអំពីធាតុផ្សំ ប៉ុន្តែគ្រាន់តែយោងទៅលើយុត្តិសាស្ត្រដែលបានដាក់ចំណាត់ថ្នាក់"ការមិនផ្តល់ចំណីអាហារ ទឹក ជម្រកស្នាក់នៅ និងជំនួយថ្នាំសង្កូវឱ្យបានគ្រប់គ្រាន់ ព្រមទាំងស្ថានភាពអនាម័យកម្រិតទាប"ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (*សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ៤៥៧)។

"អំពើអមនុស្សធម៌"នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[1503]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ នួន ជា ពុំមានលក្ខណៈត្រឹមត្រូវ និងត្រូវបដិសេធចោល។

៥៨៩.ទោះជាយ៉ាងណាក្តី ការបង្ហាញរបស់អង្គជំនុំជម្រះសាលាដំបូងមានភាពច្របូកច្របល់ទាក់ទងទៅនឹងវិធីសាស្ត្រជាធរមាន ក្នុងការកំណត់អត្តសញ្ញាណនៃភាពជាបទល្មើសនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ដូចបានពិភាក្សាខាងលើ។ បើទោះបីជា មានការបង្ហាញច្បាស់លាស់ថា អំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ជាប្រភេទបទឧក្រិដ្ឋមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងឆ្នាំ ១៩៧៥ ក៏ដោយ[1504] ក៏ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំពុំមានចែងច្បាស់លាស់ថា ជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ពិតណាស់ ជាច្រើនឆ្នាំក្រោយមក ទើបមានការកំណត់ច្បាស់លាស់អំពីបទឧក្រិដ្ឋនេះ ដែលបង្ហាញឱ្យដឹងតាមរយៈការដាក់បញ្ចូលទៅជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា ៧(១-ឃ និង ឈ) នៃលក្ខន្តិកៈរបស់តុលាការ ICC[1505]។ អាស្រ័យហេតុនេះ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬការផ្លាស់ទីលំនៅដោយបង្ខំក្នុងឆ្នាំ ១៩៧៥ ពុំទាន់មានរូបរាងជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឡើយទេ ដូចគ្នានេះដែរ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំនេះ ពុំមានធាតុផ្សំ ឬអត្ថន័យជាក់លាក់*តាមច្បាប់* នៅឡើយដែរ។ ផ្អែកតាមមូលហេតុនេះ ការកំណត់ពីធាតុផ្សំនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬការផ្លាស់ទីលំនៅដោយបង្ខំថាជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំសមស្របតាមកាលកំណត់ និងពុំត្រឹមត្រូវតាមច្បាប់ឡើយ ដោយហេតុថា ការពិចារណាបន្តបន្ទាប់លើអំពើប្រព្រឹត្តនៅក្នុងផ្នែកដូចគ្នានេះស្តីពី "ការយល់ឃើញផ្នែកអង្គច្បាប់" ក្នុងចំណោមបទឧក្រិដ្ឋដាច់ដោយឡែកដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាអប្បបរមា ធ្វើឱ្យមានការភាន់ច្រឡំ។ ផ្ទុយទៅវិញ បញ្ហាដែលត្រូវបំភ្លឺ និងជាបញ្ហាតែមួយគត់ដែលមានការពាក់ព័ន្ធ គឺ ថាតើអំពើប្រព្រឹត្តដែលចោទជាបញ្ហានេះ ដោយផ្អែកលើកាលៈទេសៈជាក់លាក់ទាំងអស់នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ជាក់ស្តែងបានបំពេញតាមការកំណត់និយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែរ ឬយ៉ាងណា។

---

[1503] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៩ និង ៦៤៣។

[1504] *សូមមើលខាងលើ* កថាខណ្ឌ ៥៧៦។

[1505] មាត្រា ៧(១-ឃ និង ឈ) នៃលក្ខន្តិកៈរបស់តុលាការ ICC។

01358291



៥៩០.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តតាមរយៈការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ បានផ្អែកយ៉ាងសំខាន់ទៅលើព្រឹត្តិការណ៍ដូចគ្នា ដែលបានបង្ហាញទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ មានដូចជា ការផ្លាស់ទីលំនៅដោយបង្ខំចំពោះក្រុមប្រជាជនយ៉ាងច្រើន ក្រោមលក្ខខណ្ឌធ្ងន់ធ្ងរ[1506]។ ដោយសារភាពស៊ីសង្វាក់គ្នាក្រោមទម្រង់នៃការប្រព្រឹត្ត គោលបំណង *វិធីសាស្ត្រក្នុងការអនុវត្ត* ចារីផ្ទាល់ និងក្របខ័ណ្ឌពេលវេលាដែលបានកំណត់នោះ ព្រឹត្តិការណ៍នីមួយៗទាំងនេះត្រូវបានចាត់ជា“អំពើ” ឬ“ការប្រព្រឹត្ត” មួយ នៅក្នុងអត្ថន័យនៃច្បាប់ព្រហ្មទណ្ឌ[1507]។ អាស្រ័យហេតុនេះ ជាជាងពិចារណាល្អិតល្អន់លើធាតុផ្សំនៃអំពើនេះ និងញែកធាតុផ្សំនេះដាច់ដោយឡែកពីធាតុផ្សំនៃការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ ហើយបានចាត់ទុកដូចបទឧក្រិដ្ឋដាច់ដោយឡែកពីគ្នានោះ អង្គជំនុំជម្រះសាលាដំបូង គប្បីពិចារណាលើការប្រព្រឹត្តក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរជារួមសម្រាប់ដំណាក់កាលនីមួយៗ ដោយផ្អែកលើការកំណត់ ថាតើអំពើនេះមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការពិចារណាជារួមដែលជាលក្ខខណ្ឌតម្រូវ ទើបអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវធ្វើដូច្នោះដោយផ្អែកលើការយល់ឃើញផ្នែកអង្គហេតុពាក់ព័ន្ធ ដែលមាននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ដោយសារការយល់ឃើញផ្នែកអង្គហេតុមួយចំនួនត្រូវបានជំទាស់នៅដំណាក់កាលបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាទៅលើទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខណាដែលពាក់ព័ន្ធជាមុនសិន។

---

[1506] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤៨ និង ៥៦៣ ដល់ ៥៦៥ (ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ) និងកថាខណ្ឌ ៦៣០ ដល់ ៦៣៨, ៦៤០ ដល់ ៦៤២ និង ៦៤៤ ដល់ ៦៤៥ (ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ)។

[1507] *សូមមើល* ដីកាដំណោះស្រាយ (D427) កថាខណ្ឌ ២២១ ដល់ ២៦១ (ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ) កថាខណ្ឌ ២៦២ ដល់ ២៨២ (ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ)។

## ៤.ឃ.៣.ខ. លក្ខខណ្ឌនៃការជម្លៀស និងការប្រើអំពើហិង្សាក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

៥៩១.នៅពេលផ្តល់ការយល់ឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ការផ្លាស់ទីលំនៅដោយបង្ខំ និងធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ទៅលើការ"បង្ខិតបង្ខំ និងគំរាមកំហែង"[1508] និង"កាលៈទេសៈដែលមានអំពើហិង្សា"[1509] ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក៏ដូចជា"លក្ខខណ្ឌអមនុស្សធម៌"[1510] ដែលកើតមានចំពោះអ្នកត្រូវបានជម្លៀសនោះ រួមទាំង"ភាពធ្ងន់ធ្ងរ"[1511]ផងដែរ ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "យ៉ាងតិចណាស់ ក៏មានប្រជាជននៅទីក្រុងភ្នំពេញចំនួនពីរលាននាក់ដែរ ដែលត្រូវបានកងទ័ពខ្មែរក្រហមបណ្តេញចេញ [...] ដោយភ្ជង់កាំភ្លើង" និងថា "ប្រជាជនត្រូវបង្ខំឱ្យបោះបង់ចោលផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់ខ្លួន"[1512]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា "មនុស្សជាច្រើន[អ្នកដែលត្រូវបានគេជម្លៀស]បានមើលឃើញផ្ទាល់ភ្នែកនូវការវាយដំ ការបាញ់ប្រហារ និងការសម្លាប់"[1513]។

៥៩២.នួន ជា និង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុ នៅពេលផ្តល់ការយល់ឃើញពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃការជម្លៀស ដើម្បីឈានទៅដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការផ្លាស់ទីលំនៅដោយបង្ខំ[1514]។ នួន ជា បានទទួលស្គាល់ថា ប្រជាជននៅទីក្រុងភ្នំពេញត្រូវតែចាកចេញពីទីក្រុង និងថា "អ្នកដែលត្រូវបានជម្លៀសមួយចំនួន បានប្រឈមនឹងលក្ខខណ្ឌលំបាក ការគំរាមកំហែង និង/ឬអំពើហិង្សា"[1515]។ ទោះជាយ៉ាងណាក្តី នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"បានបំផ្លើសទាំងស្រុងអំពី

---

[1508] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥២។

[1509] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៥។

[1510] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥២។

[1511] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៥។

[1512] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៣។

[1513] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៣។

[1514] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២២ ដល់ ៤២៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៥១ ដល់ ៣៥២។

[1515] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៣។

លក្ខខណ្ឌធ្ងន់ធ្ងរ និងមានលក្ខខណ្ឌស្របគ្នាដែលអ្នកត្រូវបានជម្លៀសបានទទួលរង”[1516]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានអះអាងថា ជាពិសេស អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការថ្លឹងថ្លែងគ្រប់គ្រាន់ទៅលើភាពមិនស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មរបស់សាក្សីពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើប្រជាជន[1517]។

៥៩៣.ទាក់ទងទៅនឹងការអនុវត្តការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នួន ជា បានរំឭកថា ប្រជាជនមួយភាគធំនៅក្នុងទីក្រុង គឺជាជនភៀសខ្លួន ហើយបានលើកឡើងថា “ត្រឹមតែអង្គហេតុដែលថា ប្រជាជនត្រូវបានតម្រូវឱ្យចាកចេញពីទីក្រុង តាមការជូនដំណឹងក្នុងរយៈពេលខ្លី មិនអាចបញ្ជាក់ថា មានការគំរាមកំហែង ឬការបង្ខំលើរូបកាយ ដើម្បីធានាដល់ការចាកចេញរបស់ពួកគេនោះឡើយ”[1518]។ នួន ជា ក៏បានលើកឡើងផងដែរថា អង្គហេតុអំពីការបង្ខំឱ្យធ្វើដំណើរនៅពេលចេញផុតពីបរិវេណទីក្រុងភ្នំពេញពុំមានភស្តុតាងបញ្ជាក់ឡើយ ឬមានភស្តុតាងបង្ហាញក្នុងកម្រិតតិចតួចនៅប៉ុន្មានម៉ោងដំបូងក្រោយពេលដែលការជម្លៀសបានចាប់ផ្ដើម និងថា ដូច្នេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា “នៅគ្រប់កាលៈទេសៈទាំងអស់ អ្នកដែលត្រូវបានជម្លៀស ត្រូវបានបង្ខំឱ្យបន្តដំណើរទៅមុខ”[1519]។ នួន ជា បានលើកឡើងថា ការយល់ឃើញផ្នែកអង្គហេតុមួយចំនួនទាក់ទងទៅនឹងលក្ខខណ្ឌនៃការជម្លៀសត្រូវបានបំផ្លើស ដោយពុំបានផ្អែកលើភស្តុតាងគ្រប់គ្រាន់[1520] ឬពុំបានគាំទ្រដោយសក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែកឡើយ[1521]។

៥៩៤.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ជនជាប់ចោទបានប្រកាន់យកវិធីសាស្ត្រក្នុងការវិភាគលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទៅជាផ្នែកតូចៗដែលពុំចាំបាច់ និងមានលក្ខណៈចង្អៀតហួសហេតុ និងពុំបានផ្ដល់ទម្ងន់ត្រឹមត្រូវលើភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវទៅលើការប្រើប្រាស់ភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង[1522]។

---

1516 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៣។

1517 សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៤៧, ៣៥១ ដល់ ៣៥២។

1518 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៤។

1519 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩២។

1520 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦ ដល់ ៤២៩។ *សូមមើលផងដែរ* កថាខណ្ឌ ៣២២ ដល់ ៣២៦។

1521 សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦, ៤២៨។

1522 សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣៨។ *សូមមើលផងដែរ* កថាខណ្ឌ ២៣៩ ដល់ ២៤៧។

៥៩៥.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលលើកឡើងថា "ត្រឹមតែអង្គហេតុដែលថា ប្រជាជនត្រូវបានតម្រូវឱ្យចាកចេញពីទីក្រុង តាមការជូនដំណឹងក្នុងរយៈពេលខ្លី មិនអាចបញ្ជាក់ថា មានការគំរាមកំហែង ឬការបង្ខំលើរូបកាយ ដើម្បីធានាដល់ការចាកចេញរបស់ពួកគេនោះឡើយ" ដោយយោងទៅលើសក្ខីកម្មរបស់សាក្សីដែលបានអះអាងថា អ្នកដែលត្រូវបានជម្លៀស ចង់ត្រឡប់ទៅកន្លែងដើមដែលពួកគេបានចាកចេញ នៅពេលសង្គ្រាមបានបញ្ចប់[1523] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីជាអ្នកដែលត្រូវបានជម្លៀសនោះកំពុងស្នាក់នៅក្នុងទីក្រុងភ្នំពេញ ជាទូទៅអាចមានគំនិតត្រឡប់ទៅកាន់ផ្ទះសម្បែងរបស់ខ្លួននៅជនបទក៏ដោយ ក៏ពុំមានការបង្ហាញថា អ្នកទាំងនេះមានបំណងចាកចេញពីទីក្រុងភ្នំពេញនៅពេលនោះ និងក្រោមលក្ខខណ្ឌដែលបានដាក់ដោយខ្មែរក្រហមនោះ។ បន្ថែមលើនេះទៀត ដូចបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា[1524] អំណះអំណាងនេះបានសំអាងលើការយល់យ៉ាងចង្អៀតនូវអ្វីដែលហៅថា ការបង្ខំនោះ។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យនៃការបង្ខំ ដូចជា "ការបង្ខិតបង្ខំ ការបំភាន់ ការកេងយកប្រយោជន៍ពីភាពស្លន់ស្លោ និងការគាបសង្កត់ឱ្យមានការភ័យខ្លាច"[1525]។ ការកំណត់និយមន័យនេះស្របជាមួយនឹងវិធីសាស្ត្រដែលត្រូវបានអនុវត្តដោយតុលាការ ICTY ដែលបានយល់ឃើញថា ការបង្ខំមិនកម្រិតត្រឹមតែការបង្ខំលើរូបកាយប៉ុណ្ណោះទេ ថែមទាំងរួមបញ្ចូលការគំរាមកំហែងនៃការបង្ខំ ឬការបង្ខិតបង្ខំ ដូចជាការបង្កឡើងឱ្យភ័យខ្លាចដោយសារអំពើហិង្សា ការបង្ខិតបង្ខំ ការគាបសង្កត់ផ្លូវចិត្ត ឬការរំលោភអំណាច ឬការកេងយកប្រយោជន៍ពីបរិយាកាសដែលបង្ខិតបង្ខំ[1526]។ ដូច្នេះ ការសន្និដ្ឋានដែលថា ការបង្ខំជាក់ស្តែងត្រូវបានប្រើប្រាស់ក្នុងគោល

---

[1523] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៤ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ (Al ROCKOFF) ឯកសារលេខ E1/166.1 ទំព័រ ៨ ដល់ ១០។

[1524] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤១។

[1525] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៣២៩។

[1526] សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ៣១៩។ សាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ២៧៩ ដល់ ២៨១។ សាលដីកា*រឿងក្តី Đorđević* (ICTY) កថាខណ្ឌ ៧២៧ (ការផ្លាស់ទីលំនៅដោយបង្ខំតម្រូវឱ្យមាន*ក្នុងចំណោមនោះ*ជនរងគ្រោះពុំមានជម្រើសពិតប្រាកដ)។ ការភ័យខ្លាចអំពើហិង្សា ឬការប្រើកម្លាំងអាចបង្កើតនូវបរិយាកាសមួយដែលថា មានបុគ្គលម្នាក់ត្រូវបានបង្ខំឱ្យចាកចេញនោះ។ បញ្ហា ថាតើអ្នកដែលត្រូវបានជម្លៀសនេះមានជម្រើសផ្សេង ដែរ ឬយ៉ាងណានោះ ត្រូវពិចារណានៅក្នុងបរិបទនៃរឿងក្តីនីមួយៗ។ ជាឧទាហរណ៍ ជនជាប់ចោទត្រូវបានចោទប្រកាន់ និង/ឬដាក់ពិរុទ្ធភាពចំពោះអំពើខាងក្រោមដែលបានរួមចំណែកដល់លក្ខខណ្ឌដែលបង្កើតបានជាការផ្លាស់ទីលំនៅដោយបង្ខំ មានដូចជា៖ ការបញ្ជាឱ្យប្រជាជនចេញពីផ្ទះសម្បែងរបស់ពួកគេ និងក្នុងករណីខ្លះ ការរុករកពីផ្ទះមួយទៅផ្ទះដើម្បីធ្វើការផ្លាស់ទីលំនៅ (សាលក្រម*រឿងក្តី Milutinović* (ICTY) ភាគ ២ កថាខណ្ឌ ១, ៤៩ ដល់ ៥០, ២៨៨, ៦៩៤, ៧៣១, ៨០១ ដល់ ៨០២, ៨៩១ ដល់ ៨៩២, ៩៥០) និងការប្រើកម្លាំងប្រដាប់អាវុធ និងការ

បំណងធ្វើឱ្យអ្នកដែលត្រូវបានជម្លៀសចាកចេញពីទីក្រុងភ្នំពេញ នៅពេលដែលខ្មែរក្រហមបានគ្រប់គ្រងទីក្រុងនេះ ជាការសមហេតុផល។

៥៩៦.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលបានយល់ឃើញថា "បើទោះបីជានៅក្នុងកាលៈទេសៈបែបណាក៏ដោយ អ្នកដែលត្រូវបានជម្លៀសត្រូវបានបង្ខំឱ្យបន្តដំណើរទៅមុខ" ដោយសារតែភស្តុតាងភាគច្រើនដែលអង្គជំនុំជម្រះលើកយកមកសំអាងនោះគឺពាក់ព័ន្ធតែទៅនឹងរយៈពេលប៉ុន្មានម៉ោងដំបូងនៃការជម្លៀស និងថា ក្រោយមកទៀត អ្នកដែលត្រូវបានជម្លៀសភាគច្រើន ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរទៅតាមទីកន្លែងណាដែលពួកគេចង់ទៅ[1527]។ ចំណុចនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នួន ជា បានទទួលស្គាល់ថា អ្នកដែលត្រូវបានជម្លៀសត្រូវបានប្រាប់ បើទោះជាពីមូលហេតុអ្វីក៏ដោយ[1528]ថា ពួកគាត់ពុំអាចត្រឡប់មកទីក្រុងភ្នំពេញវិញបានឡើយ[1529]។ ដូច្នេះ នៅពេលដែលពួកគេបានចាកចេញពីទីក្រុងភ្នំពេញ ពួកគេពុំមានជម្រើសផ្សេងក្រៅតែពីការបន្តដំណើរទៅមុខចេញពីទីក្រុងភ្នំពេញប៉ុណ្ណោះ។ បន្ថែមលើនេះទៀត មានភស្តុតាងបង្ហាញថា ការបង្ខំត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃការជម្លៀស ដែលមិនត្រឹមតែប៉ុន្មានម៉ោងដំបូងនៃការជម្លៀសនោះឡើយ។ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅក្នុងទីក្រុងភ្នំពេញ អង្គជំនុំជម្រះសាលាដំបូងបានសំអាងយ៉ាងត្រឹមត្រូវ មិនត្រឹមតែលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន់ រួមទាំងភស្តុតាងក្រៅតុលាការមួយចំនួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង

---

បំភិតបំភ័យក្នុងការផ្លាស់ទីលំនៅ(សាលក្រម*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៥៤៨ និង ១០២៧។ សាលក្រម*រឿងក្តី Martić* (ICTY) កថាខណ្ឌ ៤២៧ និង ៤២៩។ សាលក្រម*រឿងក្តី Milutinović* (ICTY) ភាគ ២ កថាខណ្ឌ ៤៦៣ និង ៩៥០)។ ការរំលោភលើផ្លូវភេទដល់អ្នកដែលត្រូវបានជម្លៀស (សាលក្រម*រឿងក្តី Milutinović* (ICTY) ភាគ ២ កថាខណ្ឌ ៥០, ៦៩៤ និង ៨០២)។ ការវាយដំ និងការសម្លាប់អ្នកដែលត្រូវបានជម្លៀស (សាលក្រម*រឿងក្តី Martić* (ICTY) កថាខណ្ឌ ៤២៧។ សាលក្រម*រឿងក្តី Milutinović* (ICTY) ភាគ ២ កថាខណ្ឌ ២៨៨, ៤៦៣, ៥៥៧, ៧៣១, ៨០២ និង ១០០៥)។ ការលួចប្លន់ពីអ្នកដែលត្រូវបានជម្លៀស(សាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៣២១។ សាលក្រម*រឿងក្តី Martić* (ICTY) កថាខណ្ឌ ៤២៦, ៤២៩។ សាលក្រម*រឿងក្តី Milutinović* (ICTY) ភាគ ២ កថាខណ្ឌ ៥០ ២៨៨ ៥៥៧ ៦៩៤, ៧៣១, ៨០២, ១០០៥) និងការដាក់លក្ខខណ្ឌរស់ដោយមិនអាចទ្រាំទ្របាន (សាលក្រម*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ១០២៧)។

[1527] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩២។

[1528] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤២៥។

[1529] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៥។

បានយោងទៅលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នូវ ហ៊ាន់ ដែលបានអះអាងជាទូទៅថា គាត់ត្រូវបានបង្ខំឱ្យបន្តដំណើរទៅមុខ[1530]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងផ្នែកនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលដោះស្រាយស្ថានភាពក្នុងរយៈពេលបីថ្ងៃក្រោយការជួលរលំទីក្រុងភ្នំពេញ[1531] អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងបន្ថែម គឺការរៀបរាប់ចំនួន ១៣ ដាច់ដោយឡែកពីគ្នា ដែលបានបង្ហាញយ៉ាងជាក់ច្បាស់ថា នៅក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្មែរក្រហមបាន“បង្ខំ”[1532] “ប្រាប់”[1533] ឬ“បញ្ជា”[1534]ឱ្យប្រជាជនបន្តដំណើរទៅមុខ បើទោះបីក្នុងករណីមួយចំនួន ជនស៊ីវិលពុំបានដឹងពីទី

---

[1530] *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩២ ជើងទំព័រ ១៤៧៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ឯកសារលេខ E1/199.1 ទំព័រ ៦ ដល់ ៧។

[1531] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៦ ដល់ ៤៨៨។

[1532] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨១, ៤៨៦ ដល់ ៤៨៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៦៩ (យឹម សុវណ្ណ រៀបរាប់ថា គាត់ចំណាយពេលប្រហែលប្រាំទៅប្រាំមួយថ្ងៃបានទៅដល់ស្ទឹងកំពង់ទួល និងបន្តដំណើរទៅទៀត “បន្ទាប់ពីគេបានប្រាប់ឱ្យទៅមុខទៀត”។ ក្រោយមក គាត់ចំណាយពេលជាងមួយខែបានដល់វត្តពោធិ៍បាន)។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ឯកសារលេខ E1/198.1 ទំព័រ ៥ (ធុច ផាន់ដារា-ស ពិពណ៌នាអំពីកងទ័ពខ្មែរក្រហមចេះតែបង្ខំគ្រួសាររបស់គាត់ឱ្យទៅមុខជាមួយហ្វូងមនុស្សជាច្រើនបន្ទាប់ពីចាកចេញពីទីក្រុងភ្នំពេញ។ បន្ថែមលើនេះទៀត គាត់បានអះអាងថា “កងទ័ពខ្មែរក្រហមចេះតែបង្ខំឱ្យយើងថា ទៅមុខៗទៅ [...]”)។

[1533] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៦ ដល់ ៤៨៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (គឹម វ៉ាន់ឌី) ឯកសារលេខ E1/148.1 ទំព័រ ៨៦ ដល់ ៨៧ និង ៨៨ ដល់ ៨៩ (គឹម វ៉ាន់ឌី បានអះអាងថា កងទ័ពខ្មែរក្រហមបានប្រាប់ម្ដាយរបស់គាត់ បន្ទាប់ពីយប់ទីបីឱ្យបន្តដំណើរទៅភូមិរបស់ខ្លួន)។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៣៥ ដល់ ៣៦, ៣៨, ៦៧, ៨២ (ជុំ សុខា បានអះអាងថា នៅពេលចាកចេញពីទីក្រុងភ្នំពេញក្នុងថ្ងៃទី ១ ប្រជាជន “ពុំត្រូវបានអនុញ្ញាតឱ្យឈប់នៅមួយកន្លែង” ពួកគាត់“បន្តដើរទៅមុខទៀត” និងត្រូវបានប្រាប់ថា ពុំអាចត្រឡប់មកទីក្រុងភ្នំពេញវិញបាន)។ ប្រតិចារឹកចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ១៩, ២១, ២៤ (ពេជ ស្រីផល បានរំឭកថា គាត់បានឮការប្រកាសតាមមេក្រូថា ប្រជាជនត្រូវបន្តដំណើរទៅមុខរហូតទាល់តែរកផ្លូវឃើញទៅស្រុកកំណើតរបស់ខ្លួន)។ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៨០ ដល់ ៨១ (Denise AFFONCO បានអះអាងថា គាត់ចំណាយពេលអស់រយៈពេលបីថ្ងៃដើម្បីឱ្យទៅដល់កោះមួយ និងថា ខ្មែរក្រហមបានណែនាំអំពីទីកន្លែងដែលប្រជាជនត្រូវទៅ)។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៣២ ដល់ ៣៣, ៣៥ ដល់ ៣៦ (ទឹង សុខា ពិពណ៌នាថា បន្ទាប់ពីបានជម្លៀសចេញពីផ្ទះរបស់ខ្លួននៅទីក្រុងភ្នំពេញ គាត់ត្រូវបានប្រាប់ឱ្យធ្វើដំណើរទៅកាន់ទិសខាងត្បូងរហូតទាល់តែដល់ក្បាលថ្នល់នៅថ្ងៃបន្ទាប់ និងបានប្រាប់ឱ្យធ្វើដំណើរឆ្ពោះទៅទិសខាងលិច)។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (ស៊្វ សុទ្ធាវី) ឯកសារលេខ E1/197.1 ទំព័រ ៩ ដល់ ១០, ២០ (ស៊្វ សុទ្ធាវី បានអះអាងថា គាត់ត្រូវបានប្រាប់ឱ្យបន្តដំណើរទៅមុខ)។

កន្លែងដែលខ្លួនត្រូវទៅនោះឡើយ។ ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា អ្នកដែលត្រូវបានជម្លៀសអាចធ្វើដំណើរក្នុងល្បឿនយឺតៗបាននោះ[1535] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ល្បឿននៃការជម្លៀស ឬល្បឿននៃការធ្វើដំណើរ ពុំអាចធ្វើជាមូលដ្ឋានដើម្បីច្រានចោលការបង្ខិតបង្ខំ ឬកាលៈទេសៈបង្ខិតបង្ខំនោះបានឡើយ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងក៏ពុំបានផ្តល់ការយល់ឃើញថាប្រជាជនត្រូវបានតម្រូវឱ្យធ្វើដំណើរក្នុងល្បឿនលឿននោះដែរ ប៉ុន្តែថា ប្រជាជនគ្មានជម្រើស។ អាស្រ័យហេតុនេះ ជាការសមហេតុផលហើយដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ទោះបីជានៅក្រោមកាលៈទេសៈបែបណាក៏ដោយ អ្នកដែលត្រូវបានជម្លៀសត្រូវបានបង្ខំឱ្យបន្តដំណើរទៅមុខ"[1536]។

៥៩៧.បន្ថែមលើនេះទៀត នួន ជា បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលតាមការយល់ឃើញរបស់គាត់ថា ជាការបំផ្លើស ឬការធ្វើយុត្តិកម្មជាទូទៅ[1537]។ នួន ជា បានយោងជាពិសេសទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "លក្ខខណ្ឌនៃការធ្វើដំណើរតាំងពីដើមរហូតដល់ចប់មានភាពលំបាកវេទនា ហើយភាគច្រើនមានការខ្វះទាំងឧបករណ៍ជាមូលដ្ឋានសំខាន់សម្រាប់ជាស្តួ"[1538] "ការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀស ភាគច្រើនបានជួបប្រទះការភ័យខ្លាច និងការគម្រាមកំហែង ឬក៏ហេតុការណ៍អំពើហិង្សាផ្សេងៗ"[1539]ពីសំណាក់កងទ័ពខ្មែរក្រហម "អ្នកដែលត្រូវបានជម្លៀសទាំងនោះ ក៏បានជួបប្រទះនូវលក្ខខណ្ឌដ៏លំបាកនៅក្នុងអំឡុងពេលធ្វើដំណើររបស់ពួកគេ ដូចជា ស្ថិតនៅក្រោមកម្តៅថ្ងៃខ្លាំង ខ្វះ

---

[1534] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ឯកសារលេខ E1/141.1 ទំព័រ ១៤ ដល់ ១៥ (មុម សំអឿន បានពិពណ៌នាថា ក្រោយពីធ្វើដំណើរជិតមួយសប្តាហ៍មក ពួកគាត់បានទៅដល់កន្លែងទីមួយនៅក្នុងភូមិសំរោងបន្ទាប់ពីការចាកចេញពីទីក្រុងភ្នំពេញ ប្រមាណ ៤០ គីឡូម៉ែត្រពីទីក្រុង និងក្រោយមកត្រូវបានបញ្ជាឱ្យធ្វើដំណើរទៅព្រៃកគយ ប្រហែលជាង ១០ ទៅ ២០ គីឡូម៉ែត្រពីភូមិសំរោង)។

[1535] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤២៥។

[1536] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩២។

[1537] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦ ដល់ ៤២៩។

[1538] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៧។

[1539] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៩។

ស្បៀងអាហារ ទឹកស្អាត ថ្នាំពេទ្យ ឬ ជម្រកស្នាក់នៅជាដើម”[1540] “ប្រជាជនភាគច្រើន(ដែលត្រូវបានជម្លៀសចេញពីផ្ទះសំបែងរបស់ខ្លួន)បានមើលឃើញផ្ទាល់នឹងភ្នែកនូវការវាយដំ ការបាញ់ប្រហារ និងការសម្លាប់ ព្រមទាំង បានឃើញសាកសពរាប់មិនអស់នៅតាមផ្លូវ នៅពេលពួកគាត់ចាកចេញពីទីក្រុងភ្នំពេញ”[1541] និង“ការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀសទាំងនោះត្រូវបានកត់សម្គាល់ឃើញថា ស្ទើរតែគ្មានស្បៀងអាហារ ទឹក ថ្នាំពេទ្យ ជម្រក និងសម្ភារអនាម័យ ទាល់តែសោះ នៅក្នុងអំឡុងពេលជាច្រើនថ្ងៃ ទៅច្រើនសប្តាហ៍នោះ”[1542]។ ខៀវ សំផន បានជំទាស់បន្ថែមទៀតទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភស្តុតាងទាក់ទងទៅនឹងបញ្ហានេះ ដោយបានអះអាងថា ភស្តុតាងនេះ ពុំបាននាំទៅដល់ការយល់ឃើញអំពីភាពស៊ីសង្វាក់គ្នានៅក្នុងការប្រព្រឹត្តទៅលើប្រជាជននោះឡើយ[1543]។

៥៩៨.ក្នុងអំណះអំណាងរបស់ នួន ជា និង ខៀវ សំផន បានលើកបញ្ហាចំនួនពីរ។ បញ្ហាទីមួយ ថាតើអង្គជំនុំជម្រះសាលាដំបូង ត្រូវបានអនុញ្ញាតឱ្យផ្តល់ការយល់ឃើញជាទូទៅអំពីបទពិសោធន៍របស់អ្នកដែលត្រូវបានជម្លៀសទាំងអស់ ឬភាគច្រើន ដោយផ្អែកលើសក្ខីកម្មរបស់សាក្សីមួយចំនួនតូច ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅក្នុងរឿងក្តីពាក់ព័ន្ធទៅនឹងបទល្មើសធំធេង ការកោះហៅសាក្សីទាំងអស់មកផ្តល់សក្ខីកម្មអំពីព្រឹត្តិការណ៍ជាច្រើនដែលចោទជាបញ្ហានេះ គឺពុំអាចធ្វើទៅបានឡើយ។ ក្នុងស្ថានភាពបែបនេះ តុលាការអង្គហេតុអាចតម្រូវឱ្យទាញយកសេចក្តីសន្និដ្ឋានចេញពីភស្តុតាងទាក់ទងទៅនឹងបទពិសោធន៍យ៉ាងទូលំទូលាយនោះ។ វិធីសាស្ត្របែបនេះ *ជាធម្មតា* ពុំមានកំហុសឡើយ។ ដោយសារតែការដាក់ពិរុទ្ធភាពបានផ្អែកលើការយល់ឃើញជាទូទៅ ដូច្នេះតម្រូវឱ្យមានការបង្ហាញឱ្យហួសពីវិមតិសង្ស័យ។ ទោះជាយ៉ាងណាក្តី ម្ចាស់បណ្តឹងសាទុក្ខដែលចោទថា មានកំហុសអង្គហេតុ មានបន្ទុកត្រូវបង្ហាញថា ការគិតដោយស្មានៗរបស់តុលាការជាន់ដំបូងក្នុងការផ្តល់ការយល់ឃើញនោះ ជាការពុំសមហេតុផល។

[1540] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩១។

[1541] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៨ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៣។

[1542] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៩ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៤។

[1543] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៤៧។

៥៩៩.បញ្ហាទីពីរ គឺទាក់ទងទៅនឹងការវាយតម្លៃលើភស្តុតាងជាមូលដ្ឋានសម្រាប់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងយ៉ាងទូលំទូលាយនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានឆ្លុះបញ្ចាំងឱ្យឃើញនូវលក្ខខណ្ឌ និងបទពិសោធន៍ខុសៗគ្នាយ៉ាងច្រើនសន្ធឹកសន្ធាប់[1544]។ ដោយសារទំហំនៃការផ្លាស់ទីលំនៅប្រជាជនទាំងអស់ក្នុងរយៈពេលខ្លី[1545] និងកងពលធំជាច្រើននៃកងទ័ពខ្មែរក្រហម បានចូលរួមនៅក្នុងការជម្លៀសនោះ[1546] ទើបមានការរៀបរាប់ខុសៗគ្នា ដូចបានឆ្លុះបញ្ចាំងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[1547] ដែលផ្ទុយពីអ្វីដែល ខៀវ សំផន បានលើកឡើង[1548]។

៦០០.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា “ប្រជាជន*ភាគច្រើន*បានមើលឃើញផ្ទាល់នឹងភ្នែកនូវការវាយដំ ការបាញ់ប្រហារ និងការសម្លាប់ ព្រមទាំងបានឃើញសាកសពរាប់មិនអស់នៅតាមដងផ្លូវ នៅពេលពួកគាត់ចាកចេញពីទីក្រុងភ្នំពេញ”[1549]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង នៅក្នុងកថាខណ្ឌដដែលនៃសាលក្រមបានយល់ឃើញថា “យ៉ាងតិចក៏មានប្រជាជននៅទីក្រុងភ្នំពេញចំនួន ២.០០០.០០០ នាក់ដែរ ដែលត្រូវបានកងទ័ពខ្មែរក្រហមបណ្តេញចេញពីផ្ទះសម្បែងដោយបង្ខំ”[1550]។ ដូច្នេះ អ្នកដែលត្រូវបានជម្លៀស“ភាគច្រើន”គឺសំដៅលើយ៉ាងតិចក៏ ១.០០០.០០០ នាក់ដែរ។ ក្នុងការគាំទ្រការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើកថាខណ្ឌចំនួន ៨ នៅ

---

[1544] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៦០ ដល់ ៥៧៤។

[1545] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២០។

[1546] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧០ (កងកម្លាំងខ្លះទទួលបន្ទុកក្នុងការជម្លៀស ចំណែកកងកម្លាំងដទៃទៀតទទួលខុសត្រូវក្នុងការត្រួតពិនិត្យការជម្លៀសនោះ)។

[1547] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៤៧, ៣៥១ ដល់ ៣៥២។

[1548] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨ (កន្លែងខ្លះ “ប្រជាជនថ្មី”ត្រូវបានផ្លាស់ទីលំនៅ ខ្លះទៀត ទាំង“ប្រជាជនថ្មី” ទាំង“ប្រជាជនចាស់”ត្រូវបានផ្លាស់ទីលំនៅ និងលក្ខខណ្ឌនៅក្នុងការដឹកជញ្ជូនខុសៗគ្នា)។

[1549] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៣ (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៩ (“ការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀស ភាគច្រើនបានជួបប្រទះការភ័យខ្លាច និងការគម្រាមកំហែង ឬក៏ហេតុការណ៍អំពើហិង្សាផ្សេងៗពីសំណាក់កងទ័ពខ្មែរក្រហម”)។

[1550] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៣។

ក្នុងផ្នែកដំបូង[1551]ដែលបានរួមបញ្ចូលនូវការយល់ឃើញទាក់ទងទៅនឹងបទពិសោធន៍ និងលក្ខខណ្ឌនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយផ្អែកលើភស្តុតាងជាច្រើនរួមទាំងភស្តុតាងក្រៅតុលាការ និងសក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែកផងដែរ[1552]។ ដោយហេតុថា ការយល់ឃើញផ្នែកអង្គហេតុដែលទាក់ទងទៅនឹងបទពិសោធន៍របស់អ្នកដែលត្រូវបានជម្លៀសមួយចំនួន មានភាពច្បាស់លាស់ណាស់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលខ្លួនអាចសន្និដ្ឋានបានថា យ៉ាងតិចណាស់ក៏មានប្រជាជន ១.០០០.០០០ នាក់ បានឆ្លងកាត់បទពិសោធន៍ដូចគ្នាដោយបានឃើញការវាយដំ ការបាញ់ប្រហារ និងការសម្លាប់ និងអាចផ្តល់ការយល់ឃើញបែបនេះឱ្យហួសពីវិមតិសង្ស័យដែរ ហើយក៏ពុំបានផ្តល់ការពន្យល់ច្បាស់លាស់ដែរ។ ក្នុងករណីគ្មានការពន្យល់ណាមួយនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាការសន្និដ្ឋានដោយពុំសមហេតុផល។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើផលប៉ះពាល់នៃកំហុសអង្គហេតុនេះដូចខាងក្រោម។ ប្រហាក់ប្រហែលគ្នានេះដែរ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ប្រជាជន*ភាគច្រើន* ខ្វះសម្ភារមូលដ្ឋានសម្រាប់ដាំស្ល"[1553] "ការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀស *ភាគច្រើន*បានជួបប្រទះការភ័យខ្លាច និងការគម្រាមកំហែង ឬក៏ហេតុការណ៍អំពើហិង្សាផ្សេងៗពីសំណាក់កងទ័ពខ្មែរក្រហម"[1554] គឺការសន្និដ្ឋានដោយពុំសមហេតុផលដែលពុំមានភស្តុតាងជាមូលដ្ឋានឡើយ។

៦០១.ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញដែលថា"អ្នកដែលត្រូវបានជម្លៀសទាំងនោះ ក៏បានជួបប្រទះនូវលក្ខខណ្ឌដ៏លំបាកនៅក្នុងអំឡុងពេលធ្វើដំណើររបស់ពួកគេ ដូចជា ស្ថិតនៅក្រោមកម្តៅថ្ងៃខ្លាំង ខ្វះស្បៀងអាហារ ទឹកស្អាត ថ្នាំពេទ្យ ឬជម្រកស្នាក់នៅជាដើម"[1555] និងថា "ការធ្វើដំណើររបស់អ្នកដែលត្រូវបានជម្លៀសទាំងនោះ ត្រូវបានគេកត់សម្គាល់ឃើញថា ស្ទើរតែគ្មានស្បៀងអាហារ ទឹក ថ្នាំពេទ្យ ជម្រក និងសម្ភារអនាម័យទាល់តែសោះ នៅក្នុងអំឡុងពេលជាច្រើនថ្ងៃ ទៅច្រើនសប្តាហ៍

[1551] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៦៧៤ កថាខណ្ឌ ៤៧៣ ដល់ ៤៧៤, ៤៨៦, ៤៨៩ ដល់ ៤៩១, ៤៩៧ ដល់ ៤៩៨។

[1552] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧១, ៤៧៣ ដល់ ៤៧៤, ៤៨៦, ៤៨៩ ដល់ ៤៩១, ៤៩៧ ដល់ ៤៩៨។

[1553] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៧ (សេចក្តីបញ្ជាក់បន្ថែម)។

[1554] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៩ (សេចក្តីបញ្ជាក់បន្ថែម)។

[1555] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩១។

នោះ"[1556] មានភស្តុតាងគាំទ្រគ្រប់គ្រាន់ហើយ។ បន្ថែមលើនេះទៀត ការយល់ឃើញទាំងនេះ បើទោះបីជាបង្ហាញក្នុងលក្ខណៈទូទៅក៏ដោយ ក៏ពុំមែនជាការស្មានដែលធ្វើឱ្យប៉ះពាល់ដល់ចំនួនសមាមាត្រនៃអ្នកដែលត្រូវបានជម្លៀសនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងបញ្ជាក់បន្ថែមគ្នាទៅវិញទៅមកដែលមានដូចជា ការរៀបរាប់ចំនួនបីដែលជាសក្ខីកម្មផ្ទាល់របស់សាក្សី និងការរៀបរាប់ជាច្រើនដែលជាសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានពិពណ៌នាអំពីកង្វះស្បៀងអាហារ[1557] ទឹកស្អាត[1558]ទីជម្រក[1559]

---

[1556] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៩ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៤។

[1557] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៧, ៤៩១ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ (សតឹម ល្មុត) ឯកសារលេខ E1/79.1 ទំព័រ ៦ ដល់ ៧ (សតឹម ល្មុត បានអះអាងថា ពេលនោះគឺឃើញដូចជាមិនទាន់មានការរៀបរយអីទេ ទៅតាមនុំង គឺតាមមួយៗហ្នឹង ខំដោះស្រាយខ្លួនឯងអីចឹងទៅ ដូចរកត្រី រកអីនៅជិតទន្លេមេគង្គហ្នឹង ទៅរកអី ដូចជានៅតាមរៀងៗគ្រួសារ)។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (គីម វ៉ាន់ឌី) ឯកសារលេខ E1/148.1 ទំព័រ ៨៧ ដល់ ៩០ (គីម វ៉ាន់ឌី បានផ្តល់សក្ខីកម្មថា នៅតាមផ្លូវ នៅត្រើយខាងកើតទន្លេ ស្ថានភាពហូបចុកវេទនា។ គាត់ និងគ្រួសាររបស់គាត់អត់តាំងពីឆ្នាំងដាំបាយដាំអី ពេលដាំបាយម្តងៗរត់រកខ្ចីគេ។ ពួកគាត់រស់ពីមួយថ្ងៃទៅមួយថ្ងៃទឹកឃើញថា ពេលវេលាហ្នឹងវាអត់យូរ វាមិនយូរទេ)។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា) ឯកសារលេខ E1/199.1, ទំព័រ ៨៣ (ប៉ូ ឌីណា បានអះអាងថា ការធ្វើដំណើរតាមផ្លូវមានការលំបាក អត់ស្បៀងអាហារ ខ្វះខាតហូបចុក គ្មានចាន គ្មានឆ្នាំង ពេលនោះហើយដែលធ្វើឱ្យនាងខ្ញុំមានការឈឺចាប់)។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៦១ (យឹម សុវណ្ណ បានផ្តល់សក្ខីកម្មថា គ្មានម្ហូបអាហារ នៅតាមផ្លូវ)។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ឯកសារលេខ E1/145.1 ទំព័រ ៨២ (អោ រី បានពិពណ៌នាអំពីការយំស្រេកឃ្លានរបស់ប្អូនៗគាត់)។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ (នូវ ហ៊ន់) ឯកសារលេខ E1/199.1 ទំព័រ ៧ (នូវ ហ៊ន់ បានអះអាងថា សភាពការណ៍ពេលនោះគឺជួបប្រទះ ជាពិសេស គឺកង្វះស្បៀង ឱសថព្យាបាលថ្នាំផ្សេងៗ)។

[1558] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៣៧ និង ៣៨ ដល់ ៣៩ (ជុំ សុខា រំឭកថា នៅក្នុងខែដែលពួកគាត់ធ្វើដំណើរ ពួកគាត់លំបាក់ក្នុងការស្វែងរកទឹកស្អាតសម្រាប់ហូប និងសម្រាប់ដាំបាយ។ ប្រសិនបើរកទឹកសម្រាប់ហូប និងដាំបាយពុំបានទេនោះ ពួកគាត់ត្រូវប្តូរទីតាំងទៅជិតត្រពាំង ឬបឹងក្បែរៗ ដើម្បីអាចមានទឹកប្រើប្រាស់)។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1ទំព័រ ៦១ ដល់ ៦២ (យឹម សុវណ្ណ បានផ្តល់សក្ខីកម្មថា ពុំមានទឹកតាមផ្លូវ ហើយត្រូវហូបទឹកត្រពាំង)។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ហូ ចន្ថា) ឯកសារលេខ E1/198.1ទំព័រ ៥៦ (ហូ ចន្ថា បានអះអាងថា គាត់មានការលំបាកខ្លាំងក្នុងការរកទឹកនៅថ្ងៃទី ២ ក្រោយការជម្លៀស ហើយគាត់ហូបទឹកត្រពាំង បើទោះបីមានខ្ចិនស្អុយ និងមានមេរោគក៏ដោយ)។

ព្រមទាំងថ្នាំពេទ្យ[1560] និងផ្អែកលើហេតុការពិតដែលថា អ្នកដែលត្រូវបានជម្លៀសមួយចំនួនបានយករបស់ផ្ទាល់ខ្លួនដូរអង្ករ ឬដូរវត្ថុអ្វីមួយដើម្បីបានបាយហូប[1561]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានសំអាង

---

[1559] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៨ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៣៧, ៨១ ដល់ ៨២ (ជុំ សុខា បានអះអាងថា ពួកគាត់ឈប់សម្រាកតាមផ្លូវ ឬនៅមុខខ្លោងទ្វារវត្ត ឬជួនកាលក្រោមដើមឈើ និងថា គ្មាននរណាប្រាប់ថា ត្រូវទៅសម្រាកនៅកន្លែងណាឡើយ)។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ឯកសារលេខ E1/200.1 ទំព័រ ៨ (បេ សុផានី បានបញ្ជាក់ថា នៅតាមផ្លូវ ពួកគាត់ឈប់សម្រាកក្នុងផ្ទះទទេស្អាតដែលជារបស់គ្រួសារចិន)។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ១៧ ដល់ ១៨ (ពេជ ស្រីផល បានលើកឡើងថា នៅយប់ទីមួយ គាត់ដេកតាមចញ្ចើមផ្លូវ និងបានរៀបរាប់ថា មានអ្នកខ្លះដេកលើគ្រែក្នុងផ្សារ និងអ្នកខ្លះទៀតដេកលើផ្លូវតែម្តងដោយសារគ្មានចរាចរទៅមកឡើយ។ ពួកគាត់រកកន្លែងសម្រាករៀងៗខ្លួននៅក្នុងយប់នោះដោយយកស្លឹកឈើក្រាលដេក)។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (ប៉ូ ឌីណា ) ឯកសារលេខ E1/199.1 ទំព័រ ៨១ (ប៉ូ ឌីណា បានផ្តល់សក្ខីកម្មថា ពួកគាត់ដេកតាមផ្លូវ និងធ្វើដំណើរដោយពុំដឹងគោលដៅត្រូវទៅឡើយ)។ ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ (មុម សំអឿន) ឯកសារលេខ E1/141.1 ទំព័រ ៩ ដល់ ១០ (មុម សំអឿន បានរៀបរាប់អំពីការទទួលទានដំណេករបស់ក្រុមគ្រួសារគាត់នៅខឿនវិហារលើឥដ្ឋហ្នឹងតែម្តង)។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ឯកសារលេខ E1/145.1 ទំព័រ ៨២ (អោ រី បានរៀបរាប់ថា ក្នុងយប់នោះ ពួកគាត់ដេកលើដីនៅកណ្តាលព្រៃមានមូសខាំច្រើន)។ ប្រតិចារឹកចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៣ (បេ សុផានី) ឯកសារលេខ E1/200.1 ទំព័រ ៩ ដល់ ១០ (បេ សុផានី បានរៀបរាប់ថា គាត់ និងកូនៗត្រូវបានខ្មែរក្រហមបណ្តេញឱ្យទៅរហូតដល់ភូមិត្រើយស្លា។ ពួកគាត់បានធ្វើជម្រកប្រក់ស្លឹកត្នោត និងមែកឈើ)។

[1560] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩១ យោងទៅលើ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ២០១៣ (នូវ ហ៊ាន់) ឯកសារលេខ E1/199.1 ទំព័រ ៧ (នូវ ហ៊ាន់ បានរៀបរាប់ថា សភាពការណ៍ពេលនោះគឺជួបប្រទះ ជាពិសេស គឺកង្វះស្បៀង ឱសថព្យាបាលថ្នាំផ្សេងៗ)។ កំណត់ហេតុស្តាប់ចម្លើយ យឹម សុវណ្ណ ឯកសារលេខ E3/5787 ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373423 ទំព័រ ៥ (យឹម សុវណ្ណ បានផ្តល់សក្ខីកម្មថា ក្នុងអំឡុងពេលធ្វើដំណើរនោះ គ្មានការជួយអ្វីដល់ពួកគាត់ឡើយ គ្មានស្បៀង គ្មានទឹក និងថ្នាំពេទ្យជាដើម)។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (យស ផល) ឯកសារលេខ E1/197.1 ទំព័រ ៦០ ដល់ ៦១, ៦៤ ដល់ ៦៥ (យស ផល បានផ្តល់សក្ខីកម្មថា ក្នុងអំឡុងពេលធ្វើដំណើរ សុខភាពរបស់គាត់កាន់តែចុះដុនដាប គ្រុនក្តៅ និងគ្មានថ្នាំពេទ្យ ដូចនេះ គាត់ដើរបេះស្លឹកស្តៅតាមផ្លូវហ្នឹង យកមកបុកយកទឹកដាំផឹកធ្វើជាថ្នាំ។ ក្នុងអំឡុងពេលធ្វើដំណើរ គាត់ធ្លាក់ខ្លួនស្គមស្គេកស្គាំងឈឺគ្រុនក្តៅផង និងឃ្លានផង)។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/137.1 ទំព័រ ៨០ ដល់ ៨១ (ឡាយ បូនី បានអះអាងថា កូនស្រីតូចរបស់គាត់មានជំងឺរាកមួលឈាម ព្រោះគ្នាក្មេងផង ហើយធ្លាប់តែហូបបាយបញ្ចុក ដល់ទៅហូបអង្ករពោត អីចឹងធ្វើឱ្យពោះវៀនហ្នឹងមិនអាចទទួលបាន ទៅជាមានជំងឺប្រចាំកាយ ជំងឺរាកមួល ហើយគ្មានថ្នាំព្យាបាល)។

[1561] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៨៧ ជើងទំព័រ ១៤៥៤ យោងទៅលើ*ក្នុងចំណោមនោះ*ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០៣១ (រស់ ស៊ុយ) ឯកសារលេខ E1/184.1 ទំព័រ ៧៤ (រស់ ស៊ុយ បានពិពណ៌នាថា ប្រជាជនឈប់តាមផ្លូវយក

លើភស្តុតាងដែលបង្ហាញថា កម្តៅថ្ងៃខ្លាំងបានធ្វើឱ្យស្ថានភាពកាន់តែអាក្រក់[1562]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ នួន ជា ដែលថា ប្រសិនបើលក្ខខណ្ឌពិតជាធ្ងន់ធ្ងរដូចការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមែននោះ នោះ"នឹងមានប្រជាជនរាប់សែននាក់បានស្លាប់"[1563]។ ដូច្នេះ អំណះអំណាងនេះគ្រាន់តែជាការធ្វើប្រមាណវិធីប៉ុណ្ណោះ។

៦០២.ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងដែលពុំស៊ីសង្វាក់គ្នាពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើអ្នកដែលត្រូវបានជម្លៀស និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា "ជាទូទៅ"ខ្មែរក្រហមពុំបានផ្តល់ជំនួយគ្រប់គ្រាន់[1564]នោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដោយផ្អែកលើការលើកឡើងខាងលើនេះ អំណះអំណាងរបស់ ខៀវ សំផន ពុំបានបង្ហាញថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលឡើយ ដោយសារ ជាក់ស្តែង នៅពេលផ្តល់ការយល់ឃើញទាក់ទងទៅនឹងកង្វះ"ជាទូទៅ"ក្នុងការផ្តល់ជំនួយនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ភស្តុតាងពាក់ព័ន្ធទាំងនេះពុំមានលក្ខណៈស្របគ្នាទាំងស្រុងនោះឡើយ។

៦០៣.សរុបសេចក្តីមក ដោយផ្អែកលើការលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង អំពីលក្ខខណ្ឌក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

---

សម្លៀកបំពាក់ដូរអង្ករដើម្បីបានការហូបចុក)។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/137.1 ទំព័រ ៨០ (ឡាយ បូនី បានរំឭកថា គាត់យកសម្ភារខ្លះដូរអង្ករពោតជាមួយប្រជាជនមូលដ្ឋានយកមកដាំបាយហូប)។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៣៥ (ទឹង សុខា បានរៀបរាប់ថា គាត់បានយកមាសពេជ្រដូររបស់បន្តិចបន្តួចដើម្បីរស់ប៉ុណ្ណោះ)។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចៅ នី) ឯកសារលេខ E1/146.1 ទំព័រ ៤៥ (ចៅ នី បានអះអាងថា ក្នុងពីរបីខែដំបូង ពួកគាត់នៅមានអីវ៉ាន់នៅជាប់ខ្លួនដោះដូរហូបបន្ត)។

[1562] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩១ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (នូវ ហ៊ាន់) ឯកសារលេខ E1/199.1 ទំព័រ ៦ (នូវ ហ៊ាន់ បានរៀបរាប់ថា ការជម្លៀសចេញពីទីក្រុងភ្នំពេញបានកើតឡើងនៅពាក់កណ្តាលខែប្រាំងជារដូវក្តៅណាស់។ ប្រជាជនខ្លះអត់បានយកស្បែកជើងតាមខ្លួន ត្រូវយកស្រទបចេកទៅចងទៅនឹងបាតជើងសម្រាប់ដើរ។ គាត់បានរំឭកថា សត្វរុយដូចឃ្មុំ រុយសំបូរនៅតាមផ្លូវ គ្មានបន្ទប់អនាម័យ មានសំអាងតែព្រៃរៀងៗខ្លួន)។

[1563] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤២៩។

[1564] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៥១ ដល់ ៣៥២។

## ៤.ឃ.៣.គ.យុត្តិកម្មដែលបានអះអាងសម្រាប់ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

៦០៤.អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងរបស់ជនជាប់ចោទដែលបានលើកឡើងថា ការជម្លៀសចេញពីទីក្រុងភ្នំពេញ គឺជាការផ្លាស់ទីលំនៅប្រជាជនដោយត្រឹមត្រូវ និងស្របច្បាប់ ដោយមូលហេតុយោធា ឬសេដ្ឋកិច្ច រួមទាំងការភ័យខ្លាចយុទ្ធនាការទម្លាក់គ្រាប់បែករបស់អាម៉េរិកដែលនឹងកើតមាន[1565]។ ទាក់ទងទៅនឹងយុទ្ធនាការទម្លាក់គ្រាប់បែកនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បានបញ្ចប់ត្រឹមខែសីហា ឆ្នាំ ១៩៧៣[1566] ដោយមានតែហេតុការណ៍ដាច់ដោយឡែក(និងពុំជាប់ពាក់ព័ន្ធ)មួយគត់ដែលបានកើតឡើងក្នុងខែ ឧសភា ឆ្នាំ ១៩៧៥[1567]។ ដោយផ្អែកលើមូលដ្ឋាន*ក្នុងចំណោមនោះ* ចម្លើយរបស់សាក្សី និងឯកសារបោះពុម្ពផ្សាយមួយរបស់ ប.ក.ក. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "សេចក្តីសម្រេចដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ពុំមែនឈរលើមូលដ្ឋានដែលមានគោលបំណងការពារប្រជាជនពីការទម្លាក់គ្រាប់បែករបស់អាម៉េរិកនោះទេ" ប៉ុន្តែបានផ្អែកលើការអនុវត្តន៍ និងបទពិសោធន៍ពីមុននៅក្នុងតំបន់ដទៃទៀត និងសម្រាប់"ហេតុផលយោធា សេដ្ឋកិច្ច និងមនោគមវិជ្ជា"នោះ ដើម្បីអាចគ្រប់គ្រងប្រជាជនបានល្អ[1568]
។

៦០៥.ទាក់ទងទៅនឹងអំណះអំណាងដែលថា មានវិបត្តិស្បៀងអាហារនៅទីក្រុងភ្នំពេញ ដែលការជម្លៀសចេញពីទីក្រុង គឺក្នុងគោលបំណងសម្រាលវិបត្តិនោះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខ្មែរក្រហមបានគ្រប់គ្រងផ្លូវដឹកជញ្ជូនទាំងអស់ រួមទាំងព្រលានយន្តហោះពោធិ៍ចិនតុងផងដែរ នៅក្នុងខណៈដែលស្ថានភាពស្បៀងអាហារនៅក្នុងទីក្រុងភ្នំពេញមានភាពកាន់តែធ្ងន់ធ្ងរឡើង ប៉ុន្តែថ្នាក់ដឹកនាំខ្មែរក្រហមបានបដិសេធមិនទទួលយកជំនួយមនុស្សធម៌ពីបណ្តាប្រទេសទាំងឡាយ ដែលខ្លួនចាត់ទុកថា ជាសត្រូវនោះឡើយ ហើយបែរជាសម្រេចជម្លៀសប្រជាជនចេញពីទីក្រុង ដោយមានផែនការ និងការរៀបចំជាមុនតែបន្តិចបន្តួចប៉ុណ្ណោះ[1569]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា "ការនាំយកស្បៀងអាហារចូលមកក្នុងទីក្រុង មានភាពងាយ

---

[1565] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២៥ ដល់ ៥៤៥។

[1566] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២៧។

[1567] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២៨។

[1568] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៤។

[1569] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៧ ដល់ ៥៣៩។

ស្រួលជាងការសម្រេចឱ្យប្រជាជនរាប់លាន់នាក់ចេញពីទីក្រុងទៅគ្រប់ទិសទី"[1570]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ស្ថានភាពស្បៀងអាហារក្នុងទីក្រុងភ្នំពេញពុំមែន"ជាមូលហេតុចម្បង"ក្នុងការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញភ្លាមៗនោះទេ[1571]។

៦០៦.នៅក្នុងការយល់ឃើញផ្នែកអង្គច្បាប់ទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ការផ្លាស់ទីលំនៅដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញពុំមែនដោយសារ"មូលហេតុចាំបាច់ផ្នែកយោធា" និងដោយសារគោលបំណងមនុស្សធម៌នោះឡើយ[1572]។ អង្គជំនុំជម្រះបានកត់សម្គាល់លើការលើកឡើងដែលថា ការជម្លៀសនេះ គឺជាផ្នែកមួយនៃគោលនយោបាយតាំងទីលំនៅស្របច្បាប់មួយ ប៉ុន្តែបានសន្និដ្ឋានថា "គោលនយោបាយផ្នែកសេដ្ឋកិច្ច មិនមែនជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានទាំងឡាយដែលត្រូវបានទទួលស្គាល់តាមច្បាប់អន្តរជាតិ ដែលអាចយកមកធ្វើយុត្តិកម្មចំពោះការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនោះបានឡើយ"[1573]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នៅគ្រប់កាលៈទេសៈទាំងអស់ ការជម្លៀសពុំមានលក្ខណៈសមាមាត្រឡើយ[1574]។

៦០៧.នួន ជា បានជំទាស់ទៅនឹងការយល់ឃើញ និងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង[1575]។ នួន ជា បានលើកឡើងថា "បើពិនិត្យលើចំណុចនេះជារួម ដោយអនុលោមតាមស្ថានភាពច្បាប់នៅក្នុងឆ្នាំ ១៩៧៥ ការជម្លៀស គឺជាការស្របច្បាប់ មិនមែនជាបទឧក្រិដ្ឋនោះឡើយ"[1576]។ នួន ជា បានលើកសាជាថ្មីនូវអំណះអំណាងក្នុងពេលជំនុំជម្រះថា ការជម្លៀសនេះត្រូវបានជំរុញដោយកត្តាស្របច្បាប់នានា និងថា ការលំបាកនឹងកើតមាន ទោះបីជាខ្លួនជ្រើសរើសយកសកម្មភាពមួយណាក៏ដោយ[1577]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំ

[1570] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៩។

[1571] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤០។

[1572] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤៩។

[1573] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤៩។

[1574] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥១។

[1575] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៣ ដល់ ៤៤១។

[1576] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៤។

[1577] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៤។

ផន បានលើកឡើងថា ការជម្លៀសជាការស្របច្បាប់ និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ដោយបានកាត់បន្ថយបរិបទជាប្រវត្តិនៃការធ្វើសេចក្ដីសម្រេចជម្លៀសនេះ[1578]។

៦០៨.សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានគតិយុត្តត្រឹមត្រូវក្នុងការវាយតម្លៃរបស់ខ្លួនលើអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ការផ្លាស់ទីលំនៅដោយបង្ខំ និងបានសន្និដ្ឋានយ៉ាងសមហេតុផលដោយផ្អែកលើភស្តុតាងទាំងមូលថា ការជម្លៀសនេះ គឺជាអំពើអនីត្យានុកូល[1579]។

៦០៩.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ការយល់ឃើញទាក់ទងទៅនឹងយុត្តិកម្មជាសក្ដានុពលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដើម្បីកំណត់ថា ការជម្លៀសនេះ គឺជា"ការផ្លាស់ទីលំនៅដោយបង្ខំ" ដែលជាបទឧក្រិដ្ឋមួយក្នុងចំណោមប្រភេទបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា[1580]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា វិធីសាស្ត្របែបនេះពិតជាមានកំហុស ដោយហេតុថា ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងគប្បីផ្ដោតទៅលើការកំណត់ ថាតើក្នុងកាលៈទេសៈនៃរឿងក្ដីនេះ ការប្រព្រឹត្តដែលរកឃើញថា បានកើតឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ត្រូវចាត់ទុកជា"អំពើអមនុស្សធម៌" ដែរ ឬយ៉ាងណា[1581]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បញ្ហានៃការធ្វើយុត្តិកម្មជាសក្ដានុពលលើការជម្លៀសនៅតែកើតមាន បើទោះបីជាតាមវិធីសាស្ត្របែបណាក៏ដោយ ដូច្នេះអង្គជំនុំជម្រះនឹងត្រូវពិចារណាលើអំណះអំណាងរបស់ នួន ជា និង ខៀវ សំផន តាមលំដាប់លំដោយ។

៦១០.ដំបូង នួន ជា បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ពុំបានឈរលើមូលដ្ឋាននៃការភ័យខ្លាចការទម្លាក់គ្រាប់បែកអាម៉េរិកឡើយ[1582]។ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើសំអាងហេតុមិនត្រឹមត្រូវទៅលើសេចក្ដីថ្លែងការណ៍របស់ ប.ក.ក. ដែលថា សេចក្ដីសម្រេចជម្លៀសត្រូវបានធ្វើឡើងដើម្បី"កម្ទេច""ឧបាយកលដ៏ខ្មៅងងឹត និង [...] ផែនការឧក្រិដ្ឋ"របស់អាម៉េរិក ដោយសារការទម្លាក់គ្រាប់បែកនៅទីក្រុងភ្នំពេញ ជាការពិត គឺជាការវាយ

---

[1578] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២២៤ ដល់ ២២៨។

[1579] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៥២ ដល់ ២៦៣។

[1580] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤៩ ដល់ ៥៥២។

[1581] *សូមមើលខាងលើ* កថាខណ្ឌ ៥៩០។

[1582] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៥ ដល់ ៤៣៨។

ប្រហារមួយប្រភេទដែល ប.ក.ក. មានការភ័យខ្លាច អាស្រ័យហេតុនេះ សេចក្តីថ្លែងការណ៍របស់ ប.ក.ក. បានបញ្ជាក់បន្ថែមពីការទម្លាក់គ្រាប់បែកនេះ ដែលពុំមែនជាការភ័យខ្លាចការទំលាក់គ្រប់បែករបស់អាម៉េរិកនោះឡើយ គឺជាមូលហេតុសម្រាប់ការជ្រៀសប្រជាជន[1583]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង មានលក្ខណៈសមហេតុផល។ ប្រសិនបើពិចារណាទៅតាមបរិបទ ការយោងដែលបានសំអាងទៅលើនោះ អាចត្រូវបានយល់យ៉ាងសមហេតុផលថា ពុំមែនសំដៅទៅលើការវាយប្រហារទម្លាក់គ្រាប់បែកពីលើអាកាសនោះទេ ប៉ុន្តែសំដៅលើការប្រឆាំងនៅក្នុងទីក្រុង។ ប្រហាក់ប្រហែលគ្នានេះដែរ ពាក់ព័ន្ធទៅនឹងការជំទាស់របស់ នួន ជា ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរនយោបាយ និងស្ថានភាពយោធា និងជាពិសេសការសម្រេចរបស់ព្រឹទ្ធសភារបស់សហរដ្ឋអាម៉េរិកឱ្យបញ្ឈប់ផ្តល់មូលនិធិសម្រាប់ការទម្លាក់គ្រាប់បែកពីលើអាកាសនោះ[1584] នួន ជា គ្រាន់តែលើកបង្ហាញអំពីជម្រើសនៃការវាយតម្លៃលើភស្តុតាង ប៉ុន្តែពុំបានបង្ហាញថា ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងនោះ មានភាពមិនត្រឹមត្រូវនោះឡើយ។ ចំណុចនេះបានបញ្ជាក់ការពិតចំពោះអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងលើអង្គហេតុដែលថា ថ្នាក់ដឹកនាំ ប.ក.ក. បានសម្រេចផ្លាស់មកកាន់ទីក្រុងភ្នំពេញនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ដើម្បីឱ្យអង្គជំនុំជម្រះអាចធ្វើសេចក្តីសន្និដ្ឋានបានថា ពុំមានក្តីបារម្ភពិតប្រាកដណាមួយអំពីការទម្លាក់គ្រាប់បែកពីលើអាកាសនោះឡើយ[1585]។ ទាក់ទងទៅនឹងបញ្ហានេះ គប្បីធ្វើការកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែសំអាងទៅលើអង្គហេតុដែលថា ថ្នាក់ដឹកនាំ ប.ក.ក. បានផ្លាស់មកកាន់ទីក្រុងភ្នំពេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថា សមាជិកនៃថ្នាក់ដឹកនាំរបស់ ប.ក.ក. "ក៏បានបង្កើតមូលដ្ឋានរបស់ពួកគេនៅតាមទីកន្លែងសំខាន់ៗ ដោយជាក់ស្តែងពុំមានការត្រៀមរៀបចំការប្រុងប្រយ័ត្នជាមុន ដើម្បីទប់ទល់នឹងការទម្លាក់គ្រាប់បែកពីលើអាកាសនោះឡើយ"[1586]។ ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសក្ខីកម្មរបស់ទាហានថ្នាក់ក្រោមតែម្នាក់ក្នុងការយល់ឃើញថា ការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់អាម៉េរិក គឺគ្រាន់តែជាឧបាយកលប្រើប្រាស់ដើម្បីបោកបញ្ឆោតប្រជាជននៅទីក្រុងនោះ[1587] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើការយល់

---

[1583] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៥ ដកស្រង់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៥៣១។

[1584] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៦។

[1585] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៧។

[1586] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥២៨។

[1587] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៨។

ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សក្ខីកម្មនេះ"បានកាត់បន្ថយការជឿជាក់បន្ថែមទៀត"ទៅលើការអះអាងរបស់ នួន ជា ដែលថា ថ្នាក់ដឹកនាំរបស់ ប.ក.ក. បានជឿជាក់ថា ពិតជាមានភាពចាំបាច់ក្នុងការជម្លៀសភ្លាមៗនោះ។ ដូច្នេះ សក្ខីកម្មរបស់សាក្សីនេះ គ្រាន់តែជាធាតុផ្សំមួយក្នុងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ។

៦១១.ជាសរុប នួន ជា ពុំបានបង្ហាញឱ្យឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់អាម៉េរិក ដែលជាយុត្តិកម្មសម្រាប់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ គឺជាការយល់ឃើញដែលពុំមានតុលាការអង្គហេតុសមស្របណាមួយអាចធ្វើដូច្នោះបាននោះឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ នួន ជា ត្រូវបដិសេធចោល។

៦១២.ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយសារបានបដិសេធការលើកឡើងដែលថា ថ្នាក់ដឹកនាំរបស់ ប.ក.ក. មានការជឿជាក់ថា ការគំរាមកំហែងទម្លាក់គ្រាប់បែករបស់អាម៉េរិក ពិតជាមានអត្ថិភាព និងជាគ្រោះថ្នាក់ពិតប្រាកដនៅក្នុងអំឡុងពេលនៃការជម្លៀសនោះមែន[1588]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើព្រឹត្តិការណ៍ដោយផ្អែកលើទស្សនៈវិស័យក្នុងឆ្នាំ ២០១៤ ជាជាងទស្សនៈវិស័យក្នុងសង្គ្រាមត្រជាក់ ប៉ុន្តែ ខៀវ សំផន ពុំបានលើកមូលដ្ឋានគាំទ្រអំណះអំណាងរបស់ខ្លួន និងពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង មានភាពពុំសមហេតុផលយ៉ាងដូចម្ដេចឡើយ។ ខៀវ សំផន បានយោងទៅលើភស្តុតាងដែលតាមការលើកឡើងរបស់គាត់បង្ហាញពីការភ័យខ្លាចការអន្តរាគមន៍របស់អាម៉េរិក ឬចលនាប្រឆាំងរបស់កងកម្លាំងនៃរបបសាធារណរដ្ឋខ្មែរ ប៉ុន្តែពុំបានបង្ហាញថា ការវាយតម្លៃលើភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលគាត់ពុំបានពិភាក្សាលម្អិតនោះថា ពុំសមហេតុផលយ៉ាងដូចម្ដេចឡើយ។

៦១៣.នួន ជា បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង"បានបដិសេធទាំងស្រុងទៅលើការពន្យល់[របស់គាត់]ដែលថា ការផ្គត់ផ្គង់ស្បៀងអាហារនៅទីក្រុងភ្នំពេញ មានឥទ្ធិពលទៅលើសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង"[1589]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការអះអាងបែបនេះខុសការពិតទាំងស្រុង។ អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា កង្វះការផ្គត់ផ្គង់ស្បៀងអាហារនៅទីក្រុង

---

[1588] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២២៦។

[1589] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៩។

ភ្នំពេញ ពុំជាប់ពាក់ព័ន្ធទៅនឹងការសម្រេចជម្លៀសនោះទេ ប៉ុន្តែបានយល់ឃើញថា នេះពុំមែនជា"មូលហេតុចម្បង"សម្រាប់ការជម្លៀសនោះឡើយ[1590]។

៦១៤.ទាក់ទងទៅនឹងការជំទាស់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយពុំសមហេតុផលថា ការផ្តល់ជំនួយអាចមានពីប្រភពខាងក្រៅ ដោយពុំចាំបាច់បញ្ជាក់ពីប្រភពមួយណាដែលអាចផ្តល់បាន និងថា កង្វះស្បៀងអាហារក្នុងទីក្រុងភ្នំពេញ ពុំគប្បីត្រូវបានច្រានចោលសម្រាប់មូលហេតុក្នុងការជម្លៀសនោះ[1591] ដំបូងអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កងកម្លាំងខ្មែរក្រហមបានគ្រប់គ្រងផ្លូវដឹកជញ្ជូន ប៉ុន្តែជាទូទៅបានបដិសេធមិនទទួលជំនួយបរទេស លើកលែងតែជំនួយគ្មានលក្ខខណ្ឌ[1592]។ ជាសំខាន់ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ប្រសិនបើថ្នាក់ដឹកនាំរបស់ ប.ក.ក មានក្តីបារម្ភក្នុងការសម្រាលស្ថានភាពខ្វះស្បៀងអាហារដែលប្រជាជនក្នុងទីក្រុងភ្នំពេញកំពុងប្រឈមមុខនោះ ជាការងាយស្រួលដែលឱ្យប្រជាជនស្ថិតនៅក្នុងទីក្រុង ជាងឱ្យប្រជាជនចេញពីទីក្រុងដោយគ្មានការត្រៀមរៀបចំណាមួយនោះ[1593]។ ដូច្នេះ បញ្ហា ថាតើមានប្រទេសផ្តល់ជំនួយផ្នែកមនុស្សធម៌មានសក្តានុពលពិតប្រាកដ ដែរ ឬយ៉ាងណានោះ ពុំមែនជាចំណុចសំខាន់នៃសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ហេតុដូច្នេះ ជាការសមហេតុផលដែលអង្គជំនុំជម្រះពុំចាំបាច់ពិចារណាលើបញ្ហា ថាតើជំនួយពិតប្រាកដនោះអាចមានអត្ថិភាពដែរ ឬយ៉ាងណានោះឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ នួន ជា ត្រូវបដិសេធចោល។

៦១៥.ប្រហាក់ប្រហែលគ្នានេះដែរ អំណះអំណាងរបស់ ខៀវ សំផន ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង ពុំបានដោះស្រាយនូវភាពពុំច្បាស់លាស់ក្នុងការផ្តល់ជំនួយផ្នែកមនុស្សធម៌របស់អាម៉េរិក ត្រូវបដិសេធចោល ដោយសារអំណះអំណាងនេះពុំសមស្របក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល[1594]។

៦១៦.ខៀវ សំផន និង នួន ជា បានលើកឡើងថា ការហាមឃាត់របស់កងកម្លាំងខ្មែរក្រហមមិនឱ្យមានចរាចរណ៍តាមទន្លេមេគង្គមុនពេលកាន់កាប់ទីក្រុងភ្នំពេញ ពុំគប្បីត្រូវបានយល់ថា ជាកត្តាស្ថានទម្ងន់ទៅលើ

---

[1590] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៤០។

[1591] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៩។

[1592] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៨។

[1593] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៩ ដល់ ៥៤០។

[1594] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២២៧។

វិបត្តិផ្នែកមនុស្សធម៌ ប៉ុន្តែជាយុត្តិសាស្ត្រយោធាស្របច្បាប់[1595]។ ជនជាប់ចោទពុំបានបង្ហាញ ថាតើអង្គជំនុំជម្រះសាលាដំបូងបានសំអាងដោយពុំសមហេតុផលទៅលើប្រភព ដែលបញ្ជាក់បន្ថែមនោះយ៉ាងដូចម្តេចឡើយ ដូចជា ការលើកឡើងរបស់ ខៀវ សំផន ខ្លួនឯងផ្ទាល់ថា ការហាមឃាត់មិនឱ្យមានចរាចរណ៍តាមទន្លេមេគង្គបានកាត់ផ្តាច់ផ្លូវតែមួយគត់សម្រាប់ការដឹកជញ្ជូនស្រូវអង្ករ និងស្បៀងដទៃទៀតប៉ុណ្ណោះ[1596]។ តាមការសន្និដ្ឋានជាទូទៅ ការកាត់ផ្តាច់មិនឱ្យមានចរាចរណ៍នេះបានរួមចំណែកដល់វិបត្តិផ្នែកមនុស្សធម៌។ គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បញ្ហាមិនមែនស្ថិតត្រង់ ថាតើការកាត់ផ្តាច់ផ្លូវតាមទន្លេមេគង្គ គឺជាយុទ្ធសាស្ត្រយោធាស្រប ឬមិនស្របច្បាប់នោះឡើយ ប៉ុន្តែបញ្ហា គឺស្ថិតនៅត្រង់ ថាតើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជាចម្បងដើម្បីដោះស្រាយកង្វះស្បៀងអាហារក្នុងទីក្រុង ដែរ ឬយ៉ាងណា។ ហេតុផលសម្រាប់កង្វះស្បៀងអាហារ ប្រសិនបើមាន ជាប់ពាក់ព័ន្ធយ៉ាងតិចតួចទៅនឹងសំណួរនេះ។

៦១៧.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ នួន ជា និង ខៀវ សំផន ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង អំពីអនីត្យានុកូលភាពនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ពាក់ព័ន្ធទៅនឹងការអះអាងរបស់ នួន ជា ដែល ថាតើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជាអំពើអមនុស្សធម៌ ដែរ ឬយ៉ាងណានោះ ត្រូវតែមានការវាយតម្លៃដោយពិចារណាលើរាល់កាលៈទេសៈពាក់ព័ន្ធទាំងអស់“ដោយផ្អែកលើការអនុវត្តជាក់លាក់របស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់* ដែលទទួលស្គាល់នូវបុព្វសិទ្ធិអធិបតេយ្យដ៏ទូលំទូលាយក្នុងបញ្ហានេះ”[1597] អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងទាំងនេះដូចខាងក្រោម[1598]។

## ៤.ឃ.៣.ឃ.លក្ខខណ្ឌ និងកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៦១៨.ទាក់ទងទៅនឹងលក្ខខណ្ឌ និងកាលៈទេសៈនៃការជម្លៀសប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋាននៅក្នុងផ្នែកស្តីពី“ការផ្លាស់ទីលំនៅដោយបង្ខំ”ថា “ប្រជាជនភាគច្រើនលើសលុបដែលត្រូវបានផ្លាស់ទីលំនៅដំណាក់កាលទីពីរ គឺជាប្រជាជនកម្ពុជាដែលត្រូវបានខ្មែរក្រហមផ្លាស់ទីលំនៅរួចមកហើយ

---

[1595] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤០។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២២៥។

[1596] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៧ ជើងទំព័រ ១៦០៨។

[1597] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣៣។

[1598] *សូមមើលខាងក្រោម* កថាខណ្ឌ ៦៥៤ *ជាដើម*។

នៅមុនខែ កញ្ញា ឆ្នាំ ១៩៧៥"[1599] និងថា ប្រជាជនភាគច្រើន"ត្រូវបានបញ្ជាឱ្យចាកចេញ" និង"ត្រូវបានផ្លាស់ទីលំនៅក្រោមការឃាមកាមដោយកងកម្លាំងប្រដាប់អាវុធ"[1600] និងថា ប្រជាជនត្រូវបានបង្ខំ និងពុំមានជម្រើសអ្វីក្រៅតែពីបន្តដំណើរទៅមុខ[1601]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា "ប្រជាជនត្រូវបានបំបែកចេញពីគ្រួសាររបស់ពួកគេ និងពុំទទួលបាន ឬទទួលបានដោយមិនគ្រប់គ្រាន់នូវការផ្តល់ជំនួយ ផ្តល់កន្លែងស្នាក់នៅ និងភាពសុខដុមរម្យនា"[1602]។

៦១៩.នៅក្នុងផ្នែកស្តីពី"ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ" អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជាប្រព័ន្ធ ខ្មែរក្រហម"ពុំបានផ្តល់ស្បៀងអាហារ ទឹក ជម្រក ជំនួយផ្នែកវេជ្ជសាស្ត្រ និងសម្ភារអនាម័យគ្រប់គ្រាន់" ដោយសារស្ថានភាពទាំងនេះហើយទើបធ្វើឱ្យប្រជាជនខ្លះស្លាប់ដែលនេះ គឺជាការដកហូតឱកាសរបស់គ្រួសារពួកគេក្នុងការធ្វើបុណ្យកាន់ទុក្ខសម្រាប់អ្នកស្លាប់[1603]។

៦២០.នួន ជា បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងលក្ខខណ្ឌក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ បានផ្អែកលើ"ភស្តុតាងពុំគ្រប់គ្រាន់ទាល់តែសោះ"[1604]។ នួន ជា បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញជាទូទៅ បើទោះបីជាការយល់ឃើញនីមួយៗនោះបានសំអាងលើភស្តុតាងតែមួយ ដែលពាក់ព័ន្ធទៅនឹងហេតុការណ៍តែមួយក៏ដោយ និងបើទោះបីជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា លក្ខខណ្ឌនៃការផ្លាស់ទីលំនៅខុសៗគ្នាក៏ដោយ[1605]។ នួន ជា បានជំទាស់បន្ថែមទៀតទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបរិបទនៃការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិថា មានលក្ខខណ្ឌជាប្រព័ន្ធក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរទាំងមូល និងបានអះអាងថា ភស្តុតាងដែលអង្គជំនុំជម្រះសាលា

---

[1599] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣១។

[1600] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣២។

[1601] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៣។

[1602] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៩។

[1603] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៤ (ជើងទំព័រលុបចោល)។

[1604] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣០។

[1605] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣០ ដល់ ៤៣២។

ដំបូងបានសំអាងនោះ"ពាក់ព័ន្ធទៅនឹងការជ្រើសរើសយកតាមអំពើចិត្តនូវហេតុការណ៍ ដែលពុំមានលក្ខណៈជាប្រព័ន្ធ" និង"មិនមានលក្ខណៈស្របគ្នា"[1606]។

៦២១.ខៀវ សំផន បានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា នៅមុនថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ មានលំនាំនៃការផ្លាស់ទីលំនៅប្រជាជនពាក់ព័ន្ធទៅនឹង"ប្រជាជនថ្មី" មានកំហុសដោយសារអង្គជំនុំជម្រះសាលាដំបូងបានសំអាងពុំត្រឹមត្រូវតាមកាលវេលាលើការផ្លាស់ទីលំនៅប្រជាជន ដែលកើតឡើងមុនការជួលរលំទីក្រុងភ្នំពេញ និងទោះជាយ៉ាងណាក្តី យោងតាមអង្គជំនុំជម្រះសាលាដំបូង ពាក្យថា"ប្រជាជនថ្មី"ត្រូវបានប្រើប្រាស់តែនៅក្រោយខែ មេសា ឆ្នាំ ១៩៧៥ ប៉ុណ្ណោះ[1607]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានមើលឃើញពីភាពផ្ទុយគ្នានៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង[1608] ត្រង់ចំណុចដែលអង្គជំនុំជម្រះបានយល់ឃើញថា "ជាញឹកញាប់*ប្រជាជនថ្មី* ត្រូវបានកំណត់គោលដៅសម្រាប់ការផ្លាស់ទីលំនៅ"[1609] ទន្ទឹមនឹងនោះក៏បានយល់ឃើញថា នៅតាមតំបន់មួយចំនួនទាំង"ប្រជាជនចាស់" និង"ប្រជាជនថ្មី" ត្រូវបានផ្លាស់ទីលំនៅ[1610]។ ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ប្រជាជនត្រូវបានបង្ខំ គំរាម ឬបោកបញ្ឆោតឱ្យធ្វើការផ្លាស់ទីលំនៅជាបន្តបន្ទាប់"[1611] ពុំមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងការយល់ឃើញរបស់ខ្លួនដែលថា ប្រជាជនមួយចំនួនបានចាកចេញដោយស្ម័គ្រចិត្ត ឬគ្មានការប្រឈមនឹងផលវិបាកអវិជ្ជមាននោះទេ ប្រសិនបើពួកគេពុំព្រមចាកចេញ[1612]។ ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា "កម្មាភិបាលខ្មែរក្រហមមានហេតុផលក្នុងការជឿជាក់ថា អ្នកដែលត្រូវបានជម្លៀសទៅនោះនឹងទទួលបានលក្ខខណ្ឌរស់នៅល្អ

---

[1606] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៧ ដល់ ៤៤៨ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣០ ដល់ ៤៣២, ៦៤៤។

[1607] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩១, ៤៥២។

[1608] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៣។

[1609] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។

[1610] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣ និង ៥៨៨។

[1611] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៤ (សេចក្តីបញ្ជាក់លុបចោល) យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨។

[1612] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៤ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨។

ប្រសើរ” ជាជាងថា កម្មាភិបាលទាំងនេះបានបោកបញ្ឆោតប្រជាជនជាប្រព័ន្ធ[1613]។ យោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា *ក្នុងចំណោមនោះ*ការបោកបញ្ឆោតត្រូវបានប្រើប្រាស់ដើម្បីផ្លាស់ទីលំនៅប្រជាជន[1614] ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា មានការបោកបញ្ឆោតបែបនេះត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរឡើយ និងថា ហេតុដូច្នេះ ការយល់ឃើញនេះត្រូវទុកជាមោឃៈ[1615]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញដែលពាក់ព័ន្ធទៅនឹងធាតុផ្សំ*អត្តនោម័ត*ទាក់ទងទៅនឹងការផ្លាស់ទីលំនៅដោយបង្ខំ ដូចជាទាក់ទងទៅនឹង“ការដឹងរបស់កងទ័ពខ្មែរក្រហម និងកម្មាភិបាលអំពីឧបាយកលបោកបញ្ឆោតនៃការផ្លាស់ទីលំនៅ”[1616]។

៦២២.សហព្រះរាជអាជ្ញាបានឆ្លើយតបថា មានភស្តុតាងគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ ទីមួយ សហព្រះរាជអាជ្ញាបានអះអាងថា ការលើកឡើងអំពីហេតុការណ៍មួយៗដែល នួន ជា បានជំទាស់នោះ ពុំអាចចាត់ទុកជាការយល់ឃើញទូទៅបានឡើយ[1617]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើការរៀបរាប់នីមួយៗដែលផ្គួបផ្គាបង្កើតបានជាលំនាំនៃលក្ខខណ្ឌអមនុស្សធម៌[1618]។ តាមការលើកឡើងរបស់សហព្រះរាជអាជ្ញាបង្ហាញថា ភស្តុតាងទាំងនេះរួមមានសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវជារួម និងបានបង្ហាញច្បាស់លាស់អំពីលក្ខខណ្ឌយ៉ាងធ្ងន់ធ្ងរ និងលំនាំនៃការរងទុក្ខវេទនាទូទៅនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរទាំងមូល[1619]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថា លក្ខខណ្ឌនៅក្នុងការផ្លាស់ទីលំនៅដែលត្រូវចាត់ទុកជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ មានដូចជា ពុំមានស្បៀងអាហារ ទឹក ជម្រក ថ្នាំពេទ្យ និងអនាម័យគ្រប់

---

[1613] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៥។

[1614] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៣។

[1615] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥០៤។

[1616] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥០៨។

[1617] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤៨។

[1618] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤៨។

[1619] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤៩ ដល់ ២៥១។

គ្រាន់ក្នុងកម្រិតអប្បបរមា[1620]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញថា នៅពេលទាំង"ប្រជាជនចាស់" និង"ប្រជាជនថ្មី"ត្រូវបានផ្លាស់ទីលំនៅសម្រាប់បំពេញកូតានៃការផលិត ទន្ទឹមនឹងនោះ"ប្រជាជនថ្មី"ក៏ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំផងដែរនោះ ពុំមែនជាការយល់ឃើញផ្ទុយគ្នាទេ[1621]។

### ៤.ឃ.៣.ឃ.១.ការយល់ឃើញទូទៅទាក់ទងទៅនឹងលក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៦២៣.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញទូទៅទាក់ទងទៅនឹងលក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដោយផ្អែកលើភស្តុតាងពុំគ្រប់គ្រាន់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៅលើកប៉ាល់ រថភ្លើង និងឡាននោះ[1622] ធ្វើឱ្យមានការភាន់ច្រឡំប្រាកដមែន ដោយសារបានបង្កើតឱ្យមាន

---

[1620] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦៨ ដល់ ២៧០។

[1621] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២៥។

[1622] ជាការកត់សម្គាល់ ទាក់ទងទៅនឹងលក្ខខណ្ឌនៅលើកប៉ាល់ឃើញថា "ខ្មែរក្រហមពុំបានផ្តល់ស្បៀងអាហារ"ដល់ប្រជាជនដែលត្រូវបានដឹកជញ្ជូនតាមកប៉ាល់ ផ្អែកលើការរៀបរាប់មួយដែលមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី(សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៤ និង ជើងទំព័រ ១៨១០) និងថា "ប្រជាជនជាច្រើននៅលើកប៉ាល់មានជំងឺ ប៉ុន្តែកងទ័ពខ្មែរក្រហមពុំបានយកចិត្តទុកដាក់លើពួកគាត់ឡើយ" ផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់(សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៤ និងជើងទំព័រ ១៨១២) និងថា គ្មានការផ្តល់ជំនួយ"នៅពេលកប៉ាល់ក្រឡាប់ដោយសារទឹកហូរខ្លាំង ហើយប្រជាជនខ្លះលង់ទឹកស្លាប់" ផ្អែកលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយ(សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៤ ជើងទំព័រ ១៨១៣) និងថា "កុមារខ្លះនៅលើកប៉ាល់យំដោយសារស្រេកឃ្លាន កងទ័ពខ្មែរក្រហមបានគំរាមថា នឹងបោះចូលទៅក្នុងទឹក" ផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់(សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៤ ជើងទំព័រ ១៨១១) និងថា ទាក់ទងទៅនឹងលក្ខខណ្ឌនៅលើរថភ្លើង "កងទ័ពខ្មែរក្រហម ពុំបានផ្តល់ជំនួយដល់ប្រជាជនដែលងាយទទួលរងគ្រោះ" ផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់(សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៧ និងជើងទំព័រ ១៨៣៤) និងថា "ប្រជាជនបានសុំឱ្យកងទ័ពខ្មែរក្រហមឈប់រថភ្លើងដើម្បីបត់ជែងបត់ជើង" ផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរនាក់(សាលក្រមរបស់អង្គជំនុំជម្រះសាលដំបូង កថាខណ្ឌ ៥៩៧ និងជើងទំព័រ ១៨៣៥) និងថា ទាក់ទងទៅនឹងលក្ខខណ្ឌនៅលើឡាន"កងទ័ពខ្មែរក្រហមបានបាញ់អ្នកដែលព្យាយាមរត់គេច" ផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់(សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៨ ជើងទំព័រ ១៨៤៥)។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣០ ដល់ ៤៣១។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៦។

ការយល់ថា ជាលក្ខខណ្ឌទូទៅ បើទោះបីជាការយល់ឃើញនេះបានផ្អែកលើភស្តុតាងមួយៗដែលពាក់ព័ន្ធទៅនឹងហេតុការណ៍ជាក់លាក់នោះក៏ដោយ។

៦២៤.ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បន្ថែមលើការយល់ឃើញជាក់លាក់ដែល នួន ជា បានជំទាស់ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានការយល់ឃើញមួយចំនួនដទៃទៀតស្តីពីលក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជន ដែលត្រូវយកមកធ្វើការពិចារណាផងដែរ នៅពេលពិភាក្សាលើភាពសមហេតុផលនៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងលក្ខខណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ ទាក់ទងទៅនឹងកង្វះស្បៀងអាហារ និងទឹក ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការរៀបរាប់ចំនួន ១៣ ផ្សេងៗគ្នាដើម្បីគាំទ្រការយល់ឃើញរបស់ខ្លួន ដែលការរៀបរាប់ចំនួន ៧ គឺជាសក្ខីកម្មផ្ទាល់ និងដទៃទៀតជាការបញ្ជាក់បន្ថែមទាក់ទងទៅនឹងកង្វះស្បៀងអាហារ[1623]។ សក្ខីកម្មទាំងនេះបានបង្ហាញជាទូទៅថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ

---

[1623] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩១ ដល់ ៥៩២, ៥៩៤ ដល់ ៥៩៥, ៥៩៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១ និង ៤៣ (បានអះអាងថា ពុំមានស្បៀងអាហារគ្រប់គ្រាន់ក្នុងអំឡុងពេលជម្លៀសលើកទីពីរ)។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ឯកសារលេខ E1/197.1 ទំព័រ ៤៨ ដល់ ៤៩, ៥៣ ដល់ ៥៤ (បានពិពណ៌នាអំពីហេតុការណ៍ដែលប្រជាជនពុំបានយកស្បៀងតាមខ្លួន និងពុំត្រូវបានផ្តល់អាហារ ឬទឹកដោយខ្មែរក្រហមក្នុងពេលធ្វើដំណើរនោះ)។ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៦៧ ដល់ ៦៨ និង ៨៣ ដល់ ៨៤ (បានអះអាងថា ខ្មែរក្រហមពុំបានផ្តល់អាហារ និងទឹកក្នុងអំឡុងពេលធ្វើដំណើរ)។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៣៧ ដល់ ៣៩ (បានរៀបរាប់ថា ខ្មែរក្រហមពុំបានចែកអីដល់ប្រជាជន ហើយពួកគាត់មានតែបាយក្រៀមហ្នឹងចូលទៅក្នុងមាត់បៀមឱ្យរីក ដែលសាច់ញាតិឱ្យពីភូមិ)។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៧៤ (បានបង្ហាញថា ពួកគាត់ផឹកទឹកតាមត្រពាំងសុទ្ធតែលាមក និងពុំត្រូវបានផ្តល់អាហារ លើកលែងតែចែកនំប៉័ងម្នាក់មួយ)។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ១១ ដល់ ១២ (បានរំឭកថា ប្រជាជនធ្លាក់ខ្លួនឈឺធ្ងន់ ដោយសារខ្សត់អាហារ និងថា សូម្បីតែជ្រូកក៏មានបាយស៊ីច្រើនជាងមនុស្សដែរ)។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣៤ ដល់ ៣៥ និង ៤៣ (ពិពណ៌នាថា ក្រុមគ្រួសារគាត់ទទួលបានអង្ករបីកំប៉ុងក្នុងពេលធ្វើដំណើរ មួយកំប៉ុងហូបគ្នាបីនាក់)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាន មុំ ឯកសារលេខ E3/4992 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557955 ទំព័រ ៤ (បានអះអាងថា កងទ័ពខ្មែរក្រហមពុំបានចែកអាហារ ឬទឹកក្នុងពេលធ្វើដំណើរឡើយ និងនៅពេលយប់ត្រឹមតែចែករបបម្នាក់បាយមួយកញ្ចប់ប៉ុណ្ណោះ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារលេខ E3/4695 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00365048 ទំព័រ ៨ (បានអះអាងថា ពុំមានអាហារ

ប្រជាជនពុំមានស្បៀងអាហារ ឬមានតិចតួច។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មានការរៀបរាប់មួយចំនួនបង្ហាញថា ប្រជាជនខ្លះដែលត្រូវបានផ្លាស់ទីលំនៅទទួលបានស្បៀងអាហារ[1624]។ ទោះជាយ៉ាងណាក្តី ផ្អែកតាមទំហំ និងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ភស្តុតាងនេះពុំបានប៉ះពាល់ដល់ការយល់ឃើញដែលថា ជាទូទៅពុំមានស្បៀងអាហារគ្រប់គ្រាន់ឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខ្មែរក្រហមពុំបានផ្តល់ស្បៀងអាហារគ្រប់គ្រាន់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលនេះឡើយ។

៦២៥.ទាក់ទងទៅនឹងការយល់ឃើញដែលថា ខ្មែរក្រហមពុំបានផ្តល់ជម្រកគ្រប់គ្រាន់ ក្នុងចំណោមភស្តុតាងដទៃទៀត អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ នាក់[1625]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា បើទោះបីជាសក្ខីកម្មចំនួន ៣ បានបង្ហាញថា ប្រជាជនត្រូវរង់

---

គ្រប់គ្រាន់ និងកូនរបស់គាត់បានស្លាប់ដោយសារការអត់អាហារនេះ)។ ពាក្យសុំតាំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជា សុវត្ថា ឯកសារលេខ E3/5084 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00865604 ទំព័រ ៩ (បានអះអាងថា កងទ័ពខ្មែរក្រហមពុំបានចែកអាហារឱ្យប្រជាជនក្នុងអំឡុងពេលធ្វើដំណើរតាមកប៉ាល់ឡើយ)។ ពាក្យបណ្តឹង ត្រឹះ អ៊ាល ឯកសារលេខ E3/5324 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00451229-30 ទំព័រ ៧ ដល់ ៨ (បានអះអាងថា ពុំមានអាហារគ្រប់គ្រាន់ក្នុងអំឡុងពេលជម្លៀសប្រជាជន និងក្នុងករណីរបស់គាត់ ជីដូនរបស់គាត់បានស្លាប់ដោយសារការអត់អាហារ)។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836285 ទំព័រ ២០៨ (បានអះអាងថា កុមារ និងមនុស្សចាស់ជាច្រើនបានស្លាប់ដោយសារការឃ្លានក្នុងការជម្លៀសទីពីរចម្ងាយជាង ៥០០ គីឡូម៉ែត្រ ដោយសារការខ្វះអាហារ)។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦០៨ ជើងទំព័រ ១៨៩៨ យោងទៅលើសក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836240 ទំព័រ ១៦២ (បានអះអាងថា ប្រជាជនត្រូវធ្វើដំណើរឆ្ងាយនៅពេលនោះដែលប្រជាជនអាចទ្រាំទ្របាន ប្រសិនបើពុំមានការខ្វះខាតអាហារនោះ)។

[1624] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៧ ជើងទំព័រ ១៨៣៤ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៧៤ (សាក្សី និងគ្រួសាររបស់គាត់ទទួលបានអង្ករបីគីឡូ និងនំប៉័ងម្នាក់មួយ)។

[1625] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩១ ជើងទំព័រ ១៧៩២ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៣៧។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1ទំព័រ ៧៤។ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៦៧ ដល់ ៦៨។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ឯកសារលេខ E1/197.1 ទំព័រ ៤៨ ដល់ ៤៩ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាន មុំ ឯកសារលេខ E3/4992 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557455 ទំព័រ ៤។

01358317



ចាំការដឹកជញ្ជូនអស់រយៈពេលពីពីរទៅបីថ្ងៃ ប៉ុន្តែពុំបានតវ៉ាជាក់លាក់អំពីកង្វះជម្រកក៏ដោយ ក៏ពុំមានការបញ្ជាក់នៅក្នុងភស្តុតាងទាំងមូលបង្ហាញឱ្យឃើញថា ខ្មែរក្រហមជាក់ស្តែងបានផ្តល់ជម្រក ជាគោលការណ៍ដែលពុំមែនជាការជ្រកកោនដោះទាល់នោះទេ។ នួន ជា ពុំបានយោងទៅលើភស្តុតាងណាមួយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលអាចបង្ហាញជាទូទៅថា មានការផ្តល់ទីជម្រក។

៦២៦.ទាក់ទងទៅនឹងកង្វះសម្ភារអនាម័យ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងចំនួន ២ គឺសក្ខីកម្មផ្ទាល់របស់សាក្សី សុខ ឈិន[1626] និងពីប្រភពមិនផ្ទាល់នៃការដកស្រង់ចេញពីសៀវភៅរបស់ Elizabeth BECKER ដោយផ្អែកលើបទសម្ភាសន៍ជាមួយអ្នករួចជីវិតចំនួន ៤ នាក់[1627]។ បន្ថែមលើនេះទៀត ភស្តុតាងដទៃទៀត ដែលបានយោងនៅក្នុងផ្នែកនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងផ្តល់ជាមូលដ្ឋានគាំទ្រដល់ការយល់ឃើញអំពីកង្វះសម្ភារអនាម័យនេះ។ តាមការពិនិត្យលើភស្តុតាងបង្ហាញថា ភស្តុតាងចំនួន ២៥[1628]

---

[1626] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦០០ ជើងទំព័រ ១៨៥៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ឯកសារលេខ E1/137.1 ទំព័រ ៣៨ ដល់ ៣៩ (ប្រជាជនមុជ និងផឹកទឹកតាមវាលស្រែ ហើយពេលយប់ពុំបានផ្តល់មុងឡើយ)។

[1627] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦០០ ជើងទំព័រ ១៨៥៦ យោងទៅលើសៀវភៅរបស់ E. BECKER *នៅពេលសង្គ្រាមរលត់ទៅ: កម្ពុជា និងបដិវត្តន៍ខ្មែរក្រហម* ឯកសារលេខ E3/20 ERN (ភាសាខ្មែរ) 00232305-6 ទំព័រ ៣០៧ ដល់ ៣០៨ ("ប្រជាជនថ្មី"រាប់ពាន់នាក់បោះជំរំនៅខាងក្រៅអយស្ម័យយានខេត្តពោធិ៍សាត់ ដែលអាចម៍មនុស្សមាននៅរាយតែពីសតែពាស និងមានសត្វរុយច្រើនឥតគណនា។ ពុំមានអ្វីគ្រាន់បើសម្រាប់ហូបទេ ហើយក៏គ្មានកន្លែងសម្រាប់ទម្រេតខ្លួនដែរ ពុំមានទឹកផឹកឱ្យគ្រប់គ្រាន់ ដោយមិនទាន់គិតដល់ទឹកសម្រាប់មុជផងនោះ)។

[1628] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ឯកសារលេខ E1/137.1 ទំព័រ ៣៨ ដល់ ៣៩។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤៣ និង ៧៧។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៦។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៥៦។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៤០ និង ៦៣ ដល់ ៦៤។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សុវណ្ណី) ឯកសារលេខ E1/199.1 ទំព័រ ៤៦។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភាព *ហៅ*ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៤៤ ដល់ ៤៥។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ឯកសារលេខ E1/145.1 ទំព័រ ១៣។ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៦៧ ដល់ ៦៨ និង ៨៣ ដល់ ៨៤។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ឯកសារលេខ E1/198.1ទំព័រ ២៥។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង វ៉ាត់) ឯកសារលេខ E1/197.1 ទំព័រ ៤៩។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៧៤។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ១០ ដល់ ១១។ ប្រតិចារឹកចុះ

ដែលក្នុងចំណោមនោះ ខ្លះបង្ហាញពីហេតុការណ៍នៃការខ្វះការយកចិត្តទុកដាក់សមស្របទៅលើប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាក់ទងទៅនឹងការខ្វះអនាម័យ[1629]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា ជាការពុំសមហេតុផលចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីកង្វះសម្ភារអនាម័យនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរឡើយ។

---

ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ឯកសារលេខ E1/197.1 ទំព័រ ៣២។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១ និង ៤៣។ កំណត់ហេតុស្ដាប់ចម្លើយរបស់ គង់ វាច ឯកសារលេខ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00420972-5 ទំព័រ ៤ ដល់ ៧។ កំណត់ស្ដាប់ចម្លើយរបស់ សួង ស៊ីម ឯកសារលេខ E3/4657 ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00349498 ទំព័រ ៦។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារលេខ E3/4695 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00365097-8 ទំព័រ ៧ ដល់ ៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ម៉ម សុខលី ឯកសារលេខ E3/5022 ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00561594-5 ទំព័រ ៩ ដល់ ១០។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឌី រឿន ឯកសារលេខ E3/4656 ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00544561 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឆិត សារុន ឯកសារលេខ E3/5006 ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00559763 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សាន មុំ ឯកសារលេខ E3/4992 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557955 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជា សុវត្ថា ឯកសារលេខ E3/5084 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 0865603-4 ទំព័រ ៨ ដល់ ៩។ កំណត់ហេតុស្ដាប់ចម្លើយរបស់ អ៊ុំ ព្រឿង ឯកសារលេខ E3/3957 ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00414475-6 ទំព័រ ៤ ដល់ ៥ ។ ពាក្យបណ្ដឹងជនរងគ្រោះ ត្រិះ អ៊ាល ឯកសារលេខ E3/5324 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00451229-30 ទំព័រ ៧ ដល់ ៨។

[1629] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៨ ជើងទំព័រ ១៨៤៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៦ (ពិន យ៉ាថៃ បានអះអាងថា ប្រជាជនត្រូវបត់ជែបត់ជើងលើឡាន)។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៥៦ (ទឹង សុខា បានអះអាងថា ខ្មែរក្រហមបានឈប់ឡានដើម្បីបត់ជែបត់ជើងខ្លួនឯង ប៉ុន្តែពុំបានអនុញ្ញាតឱ្យប្រជាជនចុះពីលើឡានក្នុងពេលធ្វើដំណើរយ៉ាងយូររហូតទាល់តែទៅដល់ពោធិ៍សាត់)។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៤៣ និង ៥៣ ដល់ ៥៤ (François PONCHAUD បានផ្ដល់សក្ខីកម្មថា គាត់បានឮប្រជាជនពិពណ៌នាអំពីលក្ខខណ្ឌក្នុងអំឡុងពេលជម្លៀសលើកទីពីរថា ពួកគាត់គ្មានបានចែកទឹកឱ្យ ហើយត្រូវបត់ជែបត់ជើងនៅក្នុងទូរថភ្លើង)។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៤០ និង ៧៣ (ពេជ ស្រីផល បានអះអាងថា ប្រជាជនលើរថភ្លើងដែលឈឺបត់ជែបត់ជើងត្រូវប្រាប់ទាហានឈ្លបខ្មែរក្រហម និងមួយស្របក់ក្រោយមក រថភ្លើងបានឈប់ឱ្យចុះ ឈ្លបតាមយើងទៅខ្លាចយើងរត់។ មានបាញ់សម្លាប់កើតឡើងនៅក្នុងទូរថភ្លើងមួយដោយសារបត់ជើងក្នុងទូរភ្លើងនោះ)។

៦២៧.ចុងក្រោយ ទាក់ទងទៅនឹងកង្វះថ្នាំពេទ្យ និងការផ្តល់ជំនួយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ភស្តុតាងចំនួន ៩ បានគាំទ្រការយល់ឃើញនេះ ដែលក្នុងចំណោមនោះ មានភស្តុតាងចំនួន ៤ ជាសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ សាក្សី Denise AFFONÇO បានផ្តល់សក្ខីកម្មថា ក្នុងអំឡុងពេលធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ ឬសប្តាហ៍នោះ ប្រជាជនពុំបានទទួលជំនួយផ្នែកវេជ្ជសាស្ត្រ និងការផ្តល់ថ្នាំពេទ្យណាមួយឡើយ[1630]។ សាក្សី អោ រី និង យឹម សុវណ្ណ បានអះអាងថា ប្រជាជនជាច្រើនធ្លាក់ខ្លួនឈឺក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ហើយកងទ័ពខ្មែរក្រហមពុំបានយកចិត្តទុកដាក់មកលើពួកគាត់ឡើយ[1631]។ ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ បានបង្ហាញថា គាត់បានឃើញមនុស្សខ្យល់គហើយបានដួលស្លាប់ នេះជាការរៀបរាប់មួយដែលមានការបញ្ជាក់បន្ថែមពីការរៀបរាប់ប្រហាក់ប្រហែលគ្នា

---

[1630] ប្រតិចារឹកចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៦៧ (Denise AFFONÇO បានអះអាងថា នៅក្នុងការជម្លៀសលើកទីពីរ អ្នកត្រូវបានជម្លៀស បានស្នើសុំជំនួយថ្នាំពេទ្យ ប៉ុន្តែគ្មានការឆ្លើយតបឡើយ)។ *សូមមើលផងដែរ* កំណត់ ហេតុស្តាប់ចម្លើយរបស់ គង់ វាច ឯកសារលេខ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 004220973-4 ទំព័រ ៥ ដល់ ៦ (នៅពេលជម្លៀសទៅខេត្តបាត់ដំបង កងទ័ពខ្មែរក្រហមពុំបានផ្តល់ថ្នាំពេទ្យសោះឡើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ វ៉ាច ឯកសារលេខ E3/4695 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00365097-8 ទំព័រ ៧ ដល់ ៨ (គង់ វ៉ាច បានអះអាងថា នៅក្នុងឆ្នាំ ១៩៧៧ ពុំមានការចែកថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺគ្រុនចាញ់ដល់កូនស្រីច្បងរបស់គាត់ឡើយ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជា សុវត្ថា ឯកសារលេខ E3/5084 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00865605 ទំព័រ ១០ (ជា សុវត្ថា បានអះអាងថា នៅក្នុងរដូវច្រូតដើមឆ្នាំ ១៩៧៦ គាត់ និងក្រុមគ្រួសាររបស់គាត់ ប្តី និងជីតាដែលមានជំងឺគ្រុនចាញ់ ត្រូវបានខ្មែរក្រហមប្រាប់ឱ្យរៀបចំឥវ៉ាន់ដើម្បីចាក់ចេញ ពួកគាត់ត្រូវសែងជីតារបស់គាត់នៅក្នុងអង្រឹងពីព្រោះគាត់មិនអាចដើរបាន។ ប្តីរបស់ខ្ញុំអាចដើរបានយ៉ាងពិបាកដោយមានឈើច្រត់)។ ពាក្យបណ្តឹងជនរងគ្រោះ សោ ធឿន ឯកសារលេខ E3/5436 ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00483749 ទំព័រ ៧ (សោ ធឿន បានអះអាងថា ក្នុងឆ្នាំ ១៩៧៧ បងទីពីររបស់គាត់ឈ្មោះ គឹម សាយន (ស្រី) បានស្លាប់ដោយជម្ងឺគ្រុនចាញ់ គ្មានថ្នាំពេទ្យព្យាបាល)។

[1631] ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ឯកសារលេខ E1/146.1 ទំព័រ ១៣ (អោ រី បានអះអាងថា បន្ទាប់ពីត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ គ្រួសាររបស់គាត់ត្រូវជម្លៀសម្តងទៀតពីស្រុកកំណើត ដែលក្នុងពេលនោះបងស្រីរបស់គាត់មានជំងឺ និងត្រូវការថ្នាំពេទ្យ ប៉ុន្តែគ្មានអ្នកណាចាប់អារម្មណ៍ឡើយ)។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1ទំព័រ ៧៤ ដល់ ៧៥ (យឹម សុវណ្ណ បានអះអាងថា ក្នុងអំឡុងពេលជម្លៀសបន្តទៀតនៅក្នុងចុងឆ្នាំ ១៩៧៥ អ្នកត្រូវបានជម្លៀសពុំត្រូវបានផ្តល់ថ្នាំពេទ្យសោះឡើយ)។

01358320



មួយរបស់ជនភៀសខ្លួន[1632]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ផងដែរលើការរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានបញ្ជាក់លម្អិតថា ខ្មែរក្រហមបានផ្ដល់ប្រេងក្រឡា និងថ្នាំពេទ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ[1633]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បើទោះបីជាមានភស្តុតាងបញ្ជាក់ខុសៗគ្នាក៏ដោយ ក៏នៅតែមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ជាញឹកញាប់ពុំមានការផ្ដល់ថ្នាំពេទ្យ និងជំនួយផ្នែកវេជ្ជសាស្ត្រឡើយ។

៦២៨.សរុបសេចក្ដីមក ផ្អែកលើភស្តុតាងទាំងនេះ ពុំមែនជាការពុំសមហេតុផលក្នុងការដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជាទូទៅមានកង្វះស្បៀងអាហារ ទឹក និងសម្ភារអនាម័យ រួមទាំងថ្នាំពេទ្យ និងជំនួយផ្នែកវេជ្ជសាស្ត្រជាដើម។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ប្រជាជនមួយចំនួនទទួលរងការលំបាកដោយសារកង្វះជម្រកយ៉ាងណាក៏ដោយ ក៏ពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់ការយល់ឃើញទូទៅទាក់ទងទៅនឹងបញ្ហានេះឡើយ។

## ៤.ឃ.៣.ឃ.២.ការយល់ឃើញទូទៅថា មានមនុស្សស្លាប់ និងការទុកសាកសពចោល

៦២៩.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ដោយសារលក្ខខណ្ឌទាំងនេះ ទើបបណ្ដាលឱ្យមានមនុស្សស្លាប់។ សាកសពទាំងនេះត្រូវបានទុកចោលតាមផ្លូវ និងខ្លះទៀតត្រូវបានបោះចេញតាមបង្អួចរថភ្លើង ដែលនេះជាការដកហូតឱកាសរបស់គ្រួសារសពក្នុងការធ្វើបុណ្យកាន់ទុក្ខសម្រាប់អ្នកស្លាប់"[1634]។ នួន ជា បានជំទាស់ទៅនឹងការយល់ឃើញនេះថា ជាការបង្កើតជាលក្ខណៈទូទៅហួសហេតុ[1635]។

៦៣០.ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ដោយសារលក្ខខណ្ឌទាំងនេះទើបបណ្ដាលឱ្យមានមនុស្សស្លាប់" អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានសន្និដ្ឋានថា ការ

---

[1632] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៣៥ ដល់ ៣៦ (ពិន យ៉ាថៃ បានអះអាងថា គាត់បានឃើញមនុស្សពីរនាក់ស្លាប់ដោយសារខ្យល់គ)។ សក្ខីកម្មរបស់ជនភៀសខ្លួន ឯកសារលេខ E3/4590 ទំព័រ ១១២ ERN (ភាសាខ្មែរ) 00836189 (នៅតាមផ្លូវ ពីរភាគប្រាំនៃកុមារបានស្លាប់ដោយសារអស់កម្លាំង ឬឈឺ)។

[1633] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សាន មុំ ឯកសារលេខ E3/4992 ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00557955 ទំព័រ ៤។

[1634] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៤ (ជើងទំព័រលុបចោល)។

[1635] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៦។

យល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌ ពុំមែនជាការមិនសមហេតុផលដោយសារបានផ្អែកលើសក្ខីកម្មក្នុងតុលាការទេ[1636]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមែនជាការពុំសមហេតុផលក្នុងការយល់ឃើញទូទៅដែលថា ប្រជាជន*ខ្លះ*បានស្លាប់នោះឡើយ។ ទាក់ទងទៅនឹងការយល់ឃើញដែលថា សាកសពត្រូវបានទុកចោលតាមផ្លូវ ឬបោះចោលតាមបង្អួចរថភ្លើងដែលកំពុងបើកនោះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល[1637] ដែលការរៀបរាប់របស់គាត់ត្រូវបានបញ្ជាក់បន្ថែមពីសាក្សី សុខ ឈិន ដែលបានបង្ហាញថា សាកសពដែលគាត់បានឃើញតាមផ្លូវរថភ្លើងនោះ គឺជាសាកសពរបស់ប្រជាជននៅលើរថភ្លើង[1638]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមែនជាការពុំសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញបែបនេះ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា តាមការបង្ហាញនៃការយល់ឃើញនេះបានធ្វើឱ្យមានការភាន់ច្រឡំបន្តិចត្រង់ថា ការទុកសាកសពចោលតាមផ្លូវត្រូវបានធ្វើឡើងជាប្រព័ន្ធ ដែលនេះពុំមានភស្តុតាងគាំទ្រឡើយ។

៦៣១.ផ្ទុយទៅវិញ ការយល់ឃើញផ្នែកអង្គហេតុដែលថា កុមារវង្វេងឪពុកម្តាយដែលយំជាប់រហូតត្រូវបានកងទ័ពខ្មែរក្រហមគ្រវែងចេញតាមបង្អួចរថភ្លើងនោះ[1639] បានផ្អែកលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែមួយគត់ និងសក្ខីកម្មរបស់សាក្សីម្នាក់ដែលបានអះអាងថា គាត់បានឮរឿងប្រហាក់ប្រហែលគ្នានេះដែរ ដែល

---

[1636] *សូមមើលខាងលើ* កថាខណ្ឌ ៥៣៦ *ជាអាទិ៍* ៥៥០។

[1637] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៧ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៣៩។

[1638] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៧ ជើងទំព័រ ១៨៣៨ ដល់ ១៨៤០ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (សុខ ឈិន) ឯកសារលេខ E1/137.1 ទំព័រ ទំព័រ ១៩, ២១ ដល់ ២២។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឌី វឿន ឯកសារលេខ E3/4656 ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00544561-2ទំព័រ ៤ ដល់ ៥ (បានអះអាងថា កុមារដែលយំត្រូវបានគ្រវែងចេញពីរថភ្លើង)។ ការរៀបរាប់នេះត្រូវបានបញ្ជាក់នៅក្នុងប្រតិចារឹកចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/223.1 ទំព័រ ៦៣ ដល់ ៦៦។

[1639] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៧។

ទោះជាយ៉ាងណាក្តី ពុំបានផ្តល់ព័ត៌មានលម្អិតឡើយ[1640]។ យោងតាមភស្តុតាងដែលមានមូលដ្ឋានខ្សោយបែបនេះ ពុំមានតុលាការអង្គហេតុសមស្របណាមួយអាចផ្តល់ការយល់ឃើញបែបនេះបានឡើយ។

## ៤.ឃ.៣.ឃ.៣.ការសន្និដ្ឋានដែលថា ប្រជាជនភាគច្រើនដែលត្រូវបានផ្លាស់ទីលំនៅ គឺជា"ប្រជាជនថ្មី"

៦៣២.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានលំនាំនៃការប្រព្រឹត្តនៃការផ្លាស់ទីលំនៅប្រជាជន"ប្រជាជនថ្មី"[1641] និងភាពផ្ទុយគ្នាដែលបានចោទប្រកាន់នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហា ថាតើមានតែ"ប្រជាជនថ្មី" ប៉ុណ្ណោះដែលត្រូវបានផ្លាស់ទីលំនៅ ដែរ ឬយ៉ាងណានោះ[1642] អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការយល់ឃើញដែលថា "ប្រជាជនភាគច្រើនលើសលុបដែលត្រូវបានផ្លាស់ទីលំនៅដំណាក់កាលទីពីរត្រូវបានខ្មែរក្រហមផ្លាស់ទីលំនៅរួចមកហើយនៅមុនខែកញ្ញា ឆ្នាំ ១៩៧៥" បានផ្អែកទៅលើការយល់ឃើញនៅក្នុងកថាខណ្ឌចំនួន ៥ នៅក្នុងផ្នែកខាងដើមនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[1643]។ កថាខណ្ឌមួយក្នុងចំណោមនោះមានការយល់ឃើញមួយដែលថា "ប្រជាជនរាប់សែននាក់"ត្រូវបានផ្លាស់ទីលំនៅ ដោយបានយោងជាឧទាហរណ៍ទៅលើខេត្តចំនួន ៦ ទាក់ទងទៅនឹងខេត្តនីមួយៗ អង្គជំនុំជម្រះសាលាដំបូងបានសំអាងក្នុងការយល់ឃើញរបស់ខ្លួនទៅលើបទពិសោធន៍របស់បុគ្គលពីមួយទៅប្រាំមួយនាក់ ដោយយោងទៅលើសក្ខីកម្មក្នុងតុលាការ កំណត់ហេតុស្តាប់ចម្លើយ និង/ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គលដែលពាក់ព័ន្ធ[1644]។ ជាចំនួនសរុប អង្គជំនុំជម្រះសាលាដំបូងបានវិភាគលើបទពិសោធន៍របស់បុគ្គលចំនួន ១៩ នាក់នៅក្នុង

---

[1640] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៧ ជើងទំព័រ ១៨៣៨ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen Heder) ឯកសារលេខ E1/223.1 ទំព័រ ៦៣ ដល់ ៦៦។

[1641] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩១, ៤៥៣ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។

[1642] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៣ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨។

[1643] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣១ និង ជើងទំព័រ ២០០០។

[1644] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨ ជើងទំព័រ ១៧៦៤ ដល់ ១៧៧០ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ធុច ផាន់ដារា-ស) ទំព័រ ៣ ដល់ ៦។ ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ធុច ផាន់ដារា-ស ឯកសារលេខ E3/5732 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00916998 ទំព័រ ១។ ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុជាតិ) ឯកសារលេខ E1/198.1 ទំព័រ ៣៤ ដល់ ៣៥។ ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២

កថាខណ្ឌនោះ។ អង្គជំនុំជម្រះបានយល់ឃើញបន្ថែមទៀតថា "នៅតំបន់ខ្លះ មានតែ*ប្រជាជនថ្មី*ទេដែលត្រូវបានផ្លាស់ទីលំនៅ ចំណែកឯតំបន់ដទៃទៀត ទាំង*ប្រជាជនចាស់* និង*ប្រជាជនថ្មី*ត្រូវបានផ្លាស់ទីលំនៅ" ដោយយោងទៅលើភស្តុតាងចំនួន ១៣ និងប្រភពចំនួន ៣ ផ្សេងៗគ្នា[1645]។ នៅក្នុងកថាខណ្ឌបន្ទាប់បានពិភាក្សាលើមូល

---

(យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៦៨ ដល់ ៧០។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ឯកសារលេខ E1/199.1 ទំព័រ ៣៩ ដល់ ៤៣, ៤៥។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/137.1 ទំព័រ ៨២ ដល់ ៨៣។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1ទំព័រ ២ ដល់ ៣, ៤៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោ រី ឯកសារលេខ E3/3967 ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00565893-4 ទំព័រ ៣ ដល់ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សួង សុភា ឯកសារលេខ E3/4837 ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00526041-2 ទំព័រ ៣ ដល់ ៤។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ទំព័រ ៥ ដល់ ៦។ ប្រតិចារឹកចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ទំព័រ ២៩ ដល់ ៣៨។ កំណត់ហេតុស្តាប់ចម្លើយរបស់ គង់ វាច ឯកសារលេខ E3/5590 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00420971-5 ទំព័រ ៣ ដល់ ៧។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ទំព័រ ២៨ ដល់ ២៩។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សែម វីរៈ ឯកសារលេខ E3/4678 ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00323529-30 ទំព័រ ៥ ដល់ ៦ ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈិន សារុធ ឯកសារលេខ E3/5006 ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00559762-4 ទំព័រ ៣ ដល់ ៥។ កំណត់ហេតុស្តាប់ចម្លើយរបស់ សេង ម៉ារឌី ឯកសារលេខ E3/5613 ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ ERN (ភាសាខ្មែរ) 00491045 ទំព័រ ៣។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុធ ពុំ ឯកសារលេខ E3/4714 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00397780-1 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន សំអាត ឯកសារលេខ E3/4707 ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00387631 ទំព័រ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាយ កាណាល់ ឯកសារលេខ E3/4699 ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00368783-4 ទំព័រ ៤ ដល់ ៥។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ីម ឯកសារលេខ E3/3978 ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00565831-2 ទំព័រ ៤ ដល់ ៥។ ប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ (លឹម សាត) ទំព័រ ៤៩។

[1645] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨ ជើងទំព័រ ១៧៧១ ដល់ ១៧៧២ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៧៣ ដល់ ៧៤។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សូវណ្ណី) ឯកសារលេខ E1/199.1 ទំព័រ ៤៥។ ប្រតិចារឹកចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ (Denise AFFONÇO) ឯកសារលេខ E1/152.1 ទំព័រ ៦៥ ដល់ ៦៦។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៣៧ ដល់ ៣៨។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អួន ផល្លី) ឯកសារលេខ E1/197.1 ទំព័រ ៣៧ និង ៤២ ដល់ ៤៣។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/137.1 ទំព័រ ៨៤ ដល់ ៨៥។ ប្រតិចារឹកចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (អោ រី) ឯកសារលេខ E1/145.1 ទំព័រ ៨៦ ដល់ ៨៧, ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោ រី ឯកសារលេខ E3/3967 ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00565893-4 ទំព័រ ៣ ដល់ ៤។ កំណត់ហេតុស្តាប់

ហេតុដែលបានប្រាប់ទៅប្រជាជនឱ្យផ្លាស់ទីលំនៅ ដូចជា"ប្រជាជនត្រូវបានប្រាប់ថា ពួកគាត់នឹងត្រូវបញ្ជូនត្រឡប់ទៅផ្ទះវិញ" និងថា ពួកគាត់ធ្លាប់ត្រូវបានជម្លៀសចេញពីទីក្រុងម្តងរួចមកហើយ អាចចាត់ទុកជា*ប្រជាជនថ្មី* ដែរ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ពុំបានផ្តល់ការយល់ឃើញទាក់ទងទៅនឹងបញ្ហានេះឡើយ[1646]។ នៅក្នុងកថាខណ្ឌចំនួន ២ ផ្សេងទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានយោងនោះ មាននៅក្នុងផ្នែកដែលដោះស្រាយអំពីការផ្លាស់ទីលំនៅប្រជាជនសម្រាប់គោលបំណងនៃ*ការតស៊ូវណ្ណៈ* ដែលរៀបរាប់អំពីបទពិសោធន៍របស់បុគ្គលចំនួន ៨ នាក់ដទៃទៀត និងគ្រួសាររបស់ពួកគាត់[1647]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា មានហេតុការណ៍ជាច្រើនដែលទាំង"ប្រជាជនថ្មី" និង"ប្រជាជនចាស់"ត្រូវបានផ្លាស់ទីលំនៅ[1648]។

៦៣៣.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា *ភស្តុតាង*ភាគច្រើនដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកពិចារណា គឺជាប់ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅ"ប្រជាជនថ្មី"។ ទន្ទឹមនឹងនេះដែរ អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាទៅលើភស្តុតាងនៃការផ្លាស់ទីលំនៅ"ប្រជាជនចាស់" និងជាពិសេសបានទទួលស្គាល់ថា ការផ្លាស់ទីលំនៅទាំងនេះបានកើតឡើងប្រាកដមែន។ បន្ថែមលើនេះទៀត ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងពិចារណានោះ ជាប់ពាក់ព័ន្ធតែប្រជាជនមួយចំនួនតូចដែលបានទទួលរងផលប៉ះពាល់ការផ្លាស់ទីលំនៅប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ពុំមានមូលដ្ឋានណាមួយដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានថា អ្នកដែលត្រូវបានជម្លៀស"ភាគច្រើនលើសលុប" គឺពិតជា"ប្រជាជនថ្មី"នោះឡើយ។

## ៤.ឃ.៣.ឃ.៤.ការយល់ឃើញទាក់ទងទៅនឹងការសម្លាប់

---

ចម្លើយ ថេង ហ៊ុយ ឯកសារលេខ E3/5244 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00224795-6 ទំព័រ ៣ ដល់ ៤។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ឹម ឯកសារលេខ E3/3978 ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00565832 ទំព័រ ៥។ កំណត់ហេតុស្តាប់ចម្លើយ ម៉ាន់ សារឿន ឯកសារលេខ E3/5258 ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00249910-11 ទំព័រ ២ ដល់ ៣។ កំណត់ហេតុស្តាប់ចម្លើយ សួង ស៊ឹម ឯកសារលេខ E3/4657 ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00349497-8 ទំព័រ ៥ ដល់ ៦។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ទំព័រ ៤៧ និង ៥៣។ កំណត់ហេតុស្តាប់ចម្លើយ ព្រាប ព្រឿង ឯកសារលេខ E3/5132 ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00165244-5 ទំព័រ ២ ដល់ ៣។

[1646] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៩។

[1647] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២២ ដល់ ៦២៣។

[1648] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨។

៦៣៤.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ឬនៅពេលទៅដល់កន្លែងរៀងៗខ្លួន"ខ្មែរក្រហមបានបាញ់សម្លាប់ប្រជាជន[1649] ដោយផ្អែកលើមូលដ្ឋានចំនួន ២ គឺវិសាលភាពនៃការជំនុំជម្រះ និងភស្តុតាងតិចតួច[1650]។ ទាក់ទងទៅនឹងចំណុចទីមួយ ខៀវ សំផន បានអះអាងថា វិសាលភាពនៃការជំនុំជម្រះត្រូវបានកម្រិតត្រឹមព្រឹត្តិការណ៍ដែលបានកើតឡើង*ក្នុងអំឡុងពេល*នៃការផ្លាស់ទីលំនៅប្រជាជន មិនមែនក្រោយមកទៀតនោះទេ[1651]។

៦៣៥.នួន ជា បានអះអាងថា អង្គជំនុំជម្រះមានកំហុសដោយបានផ្តល់ការយល់ឃើញមានលក្ខណៈទូទៅដែលថា ខ្មែរក្រហមបានបាញ់សំដៅអ្នកដែលព្យាយាមរត់គេចខ្លួន និងបានផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់ប៉ុណ្ណោះ[1652]។

៦៣៦.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងវិសាលភាពនៃការជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន បានដកស្រង់ពុំត្រឹមត្រូវនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ប្រជាជនត្រូវបានបាញ់សម្លាប់ទាំងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ឬនៅពេលទៅដល់ទីកន្លែងនោះឡើយ[1653]។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

៦៣៧.ទាក់ទងទៅនឹងការយល់ឃើញដទៃទៀត ដែលត្រូវបានជំទាស់ពាក់ព័ន្ធទៅនឹងការសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះតុលាការកំពូលយោងទៅលើការសន្និដ្ឋានដំបូងរបស់ខ្លួន[1654] និងដូច្នេះយល់ឃើញថា ការយល់ឃើញទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលនោះទេ ដោយសារពុំមានភស្តុតាងគាំទ្រការសន្និដ្ឋានដែលថា ការសម្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទី

---

[1649] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។

[1650] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៧។

[1651] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៨។

[1652] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣១ យោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៨ "កងទ័ពខ្មែរក្រហមបានបាញ់អ្នកដែលព្យាយាមរត់គេចខ្លួន"។

[1653] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣ ("ក្នុងអំឡុងពេលជម្លៀស ឬនៅពេលទៅដល់ទីកន្លែង" និយាយពាក់ព័ន្ធទៅនឹងកង្វះស្បៀងអាហារ ទឹក និងជម្រក)។

[1654] *សូមមើលខាងលើ* កថាខណ្ឌ ៥៥៦ ដល់ ៥៥៧។

លំនៅ គឺជាផ្នែកមួយនៃ“លំនាំនៃកាប្រព្រឹត្តស៊ីសង្វាក់គ្នា”[1655]។ មានមូលដ្ឋានគាំទ្រនៅក្នុងអំណះអំណាងរបស់ នួន ជា ដែលថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា “ខ្មែរក្រហមបានបាញ់អ្នកដែលព្យាយាមរត់គេច”[1656]នោះ ពុំមែនជាលក្ខណៈទូទៅនោះទេ ដោយសារអង្គជំនុំជម្រះបានផ្អែកទៅលើសក្ខីកម្មចចាមអារ៉ាមមួយមុខគត់ទាក់ទងទៅនឹងហេតុការណ៍តែមួយប៉ុណ្ណោះ។

## ៤.ឃ.៣.ឃ.៥.ការយល់ឃើញដែលថា ប្រជាជនត្រូវបានបង្ខំ គំរាម ឬបោកបញ្ឆោត ឱ្យផ្លាស់ទីលំនៅ

៦៣៨.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជន“ត្រូវបានបង្ខិតបង្ខំ គំរាម ឬបោកបញ្ឆោតឱ្យធ្វើការផ្លាស់ទីលំនៅ”[1657]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា “ប្រជាជនណាដែលមិនព្រមផ្លាស់ទីលំនៅ ឬព្យាយាមរត់គេចខ្លួន ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬផ្លាស់ទីលំនៅជាថ្មីម្តងទៀត”[1658]។ ជនជាប់ចោទទាំងពីរបានជំទាស់ទៅនឹងការយល់ឃើញទាំងនោះ ដោយបានចោទប្រកាន់ថា ភស្តុតាងដែលបានយោងដោយអង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈគ្រប់គ្រាន់ និងផ្ទុយគ្នា[1659]។

៦៣៩.ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលរងការជំទាស់នោះ បានផ្អែកលើភស្តុតាងដែលបានយោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ កថាខណ្ឌពាក់ព័ន្ធទីមួយយោងទៅលើការរៀបរាប់ចំនួន ៦[1660] ទាក់ទងទៅនឹងផលវិបាកជាសក្តានុពលនៃការពុំព្រមស្តាប់តាមបញ្ជាឱ្យផ្លាស់ទីលំនៅ ប៉ុន្តែទំនងជាថា មានចម្លើយបួនក្នុងចំណោមនោះពាក់ព័ន្ធទៅនឹង*ការគំរាមកំហែង*ចំពោះផលវិបាកនៃការមិនគោរពតាមបទបញ្ជាឱ្យផ្លាស់ទីលំនៅ ដែលពុំមែនជាផលវិបាកជាក់ស្តែងឡើយ[1661]។ កថាខណ្ឌពាក់ព័ន្ធទីពីរមានការយល់ឃើញមួយដែលថា “កងទ័ពខ្មែរក្រហមបានបាញ់សម្លាប់អ្នកដែលព្យាយាមរត់” បានសំអាងលើសក្ខីកម្មរបស់

---

[1655] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។

[1656] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៨ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147/.1 ទំព័រ ៤០។

[1657] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣ យោងទៅលើកថាខណ្ឌ ៥៩១ ដល់ ៥៩៩។

[1658] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣២ យោងទៅលើកថាខណ្ឌ ៥៨៨, ៥៩៨ និង ៦០៩។

[1659] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៣២។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៤។

[1660] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៧៧៦ (សក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ នាក់ និងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីចំនួន ៣ នាក់ ត្រូវបានយកមកសំអាង)។

[1661] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨ ជើងទំព័រ ១៧៧៦។

ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា តែម្នាក់ប៉ុណ្ណោះ ដូចបានសង្ខេបខាងលើ[1662]។ កថាខណ្ឌមួយទៀតបានរៀបរាប់ថា ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងចំណោមនោះបានពន្យល់ថា "ប្រជាជនដែលព្យាយាមរត់គេចខ្លួនត្រូវបានកងទ័ពខ្មែរក្រហមដេញចាប់។ គាត់បានឮសម្រែករបស់ពួកគេស្រែក ក្រោយពីពួកគេត្រូវបានចាប់ខ្លួន ទោះបីជាគាត់ពុំបានបញ្ជាក់អំពីជោគវាសនារបស់ពួកគេឱ្យបានច្បាស់លាស់ក៏ដោយ"[1663]។

៦៤០.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការពុំសមហេតុផលក្នុងការផ្តល់ការយល់ឃើញយ៉ាងទូលំទូលាយមួយទាក់ទងទៅនឹងផលវិបាកនៃការមិនធ្វើតាមការបញ្ជាឱ្យផ្លាស់ទីលំនៅ ដោយសារបានផ្អែកលើភស្តុតាងនៃការគំរាមកំហែង ភស្តុតាងចចាមអារ៉ាម ឬភស្តុតាងពុំច្បាស់លាស់អំពីផលវិបាក និងដោយសារពុំមានការពន្យល់បន្ថែមណាមួយទាក់ទងទៅនឹងមូលហេតុ ដែលអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើភស្តុតាងយ៉ាងដូចម្តេចឡើយ។ ទោះជាយ៉ាងណាក្តី ពុំបានប៉ះពាល់ដល់ការយល់ឃើញដែលថា ការផ្លាស់ទីលំនៅត្រូវបានធ្វើឡើងដោយបង្ខំឡើយ។ មានភស្តុតាងបង្ហាញថា ខ្មែរក្រហមដែលបានគ្រប់គ្រងប្រទេសទាំងស្រុងនៅពេលនោះ និងបានផ្តួលរំលំរបបចាស់តាមរយៈកម្លាំងយោធា បានប្រាប់ បានគំរាមកំហែង ឬបានបញ្ជាប្រជាជនឱ្យផ្លាស់ទីលំនៅ ដូច្នេះប្រជាជនគ្មានជម្រើសអ្វីផ្សេងក្រៅតែពីផ្លាស់ទីលំនៅនោះទេ[1664]។ ទាក់ទងទៅនឹងបញ្ហានេះ

---

[1662] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៨ ជើងទំព័រ ១៨៤៥ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៤០។

[1663] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦០៩ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ឯកសារលេខ E1/197.1 ទំព័រ ៣២។

[1664] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៨ ជើងទំព័រ ១៧៧៤ ដល់ ១៧៧៦ យោងទៅលើ*ក្នុងចំណោមនោះ*ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (សាំង រ៉ាត់) ឯកសារលេខ E1/197.1 ទំព័រ ៤៧ និង ៥៣ (ក្នុងចុងឆ្នាំ ១៩៧៥ ប្រធានភូមិបានប្រាប់ សាំង រ៉ាត់ ប្តីរបស់គាត់ កូនប្រុសចំនួន ៤ នាក់ និងគ្រួសារចំនួន ៤ ឬ៥ ដទៃទៀត ឱ្យចាកចេញពីភូមិរបស់ខ្លួននៅក្នុងស្រុកសំរោងខេត្តកំពង់ស្ពឺ ទៅកាន់ស្រុកមោងឫស្សីខេត្តបាត់ដំបង។ ពួកគាត់បានសុំមិនចាកចេញ ប៉ុន្តែនេះគឺជា"បញ្ជាដាច់ខាត" ដូច្នេះពួកគាត់ត្រូវតែចេញ)។ ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/137.1 ទំព័រ ៨៤ ដល់ ៨៥ (ប្រធានភូមិបានប្រាប់ប្រជាជនថ្មីក្នុងខេត្តកណ្តាលឱ្យរៀបចំអីវ៉ាន់ចាកចេញ)។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ២៧ (មេភូមិបានប្រាប់ពួកគាត់ឱ្យចាកចេញពីខ្សាច់កណ្តាលទៅខេត្តបាត់ដំបង)។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ (សូផាន់ សុវណ្ណី) ឯកសារលេខ E1/199.1 ទំព័រ ៤៥ (សូផាន់ សុវណ្ណី បាននិយាយថា "អង្គការដាក់ទិសដៅ"ឱ្យគ្រួសារ និងប្រជាជនថ្មីនៅក្នុងភូមិរកាកោងខេត្តកណ្តាលត្រូវបានផ្លាស់ទីលំនៅទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបង)។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (អូន ផល្លី) ឯកសារលេខ E1/197.1 ទំព័រ ៣៦ ដល់ ៣៧ (គេប្រាប់ឱ្យពួកគាត់ចាកចេញពីខេត្តព្រៃវែង ហើយត្រូវធ្វើតាម បើមិនដូច្នេះទេជួបផលវិបាក។ បញ្ជាខ្មែរក្រហមបានបង្ខំមកលើពួកគាត់)។ ប្រតិចារឹកចុះ

អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដោយផ្ទុយទៅនឹងអ្វីដែលជនជាប់ចោទបានអះអាងនោះ ការបង្ខំរួមបញ្ចូលការគំរាមកំហែង ឬការបង្ខិតបង្ខំ ដូចជា ការធ្វើឱ្យភ័យខ្លាចដោយអំពើហិង្សា ការបង្ខិតបង្ខំ ការគាបសង្កត់ផ្លូវចិត្ត ឬការរំលោភអំណាច ឬតាមរយៈការកេងយកផលប្រយោជន៍ក្នុងបរិយាកាសបង្ខិតបង្ខំ[1665]។

៦៤១.ខៀវ សំផន បានជំទាស់ផងដែរទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប្រជាជនត្រូវបានបោកបញ្ឆោតដើម្បីឱ្យផ្លាស់ទីលំនៅ ពីព្រោះកម្មាភិបាលខ្មែរក្រហមមានមូលហេតុត្រឹមត្រូវដែលជឿបានថា អ្នកដែលត្រូវបានជម្លៀសនោះនឹងទទួលបានលក្ខខណ្ឌរស់នៅល្អប្រសើរនៅកន្លែងថ្មី យោងតាម ខៀវ សំផន ដែលនេះ គឺជាមូលហេតុសម្រាប់កម្មាភិបាលធ្វើការផ្លាស់ទីលំនៅនោះ[1666]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការយល់ឃើញដែលថា ការបោកបញ្ឆោតត្រូវបានប្រើប្រាស់ គឺពាក់ព័ន្ធទៅនឹង*ទីកន្លែង*ដែលត្រូវផ្លាស់ទីលំនៅទៅកាន់នោះ មិនមែនមូលហេតុនៃការផ្លាស់ទីលំនៅឡើយ[1667]។ ក្នុងចំណោមភស្តុតាងដទៃទៀត ការយល់ឃើញនេះបានផ្អែកលើសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី[1668] និង ពិន យ៉ាថៃ[1669]។ នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងក៏បានយោងទៅលើសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតផងដែរ និងចម្លើយក្រៅតុលាការចំនួន ២ ដែលបានអះអាងថា ខ្មែរក្រហមបានប្រាប់ទៅប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅថា ពួកគេត្រូវត្រឡប់ទៅកាន់ផ្ទះសំបែងរបស់ខ្លួន ប៉ុន្តែជាក់ស្តែង

---

ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (យឹម សុវណ្ណ) ឯកសារលេខ E1/135.1 ទំព័រ ៧៣ (យឹម សុវណ្ណ បានផ្តល់សក្ខីកម្មថា អស់រយៈពេលប្រាំមួយខែបន្ទាប់ពីការជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់ភូមិលេខ ៥ គ្រួសាររបស់គាត់ត្រូវបានប្រាប់ថា ប្រសិនបើមិនចាកចេញទេ ពួកគាត់នឹងត្រូវបានឃុំខ្លួន)។ ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៥២ ដល់ ៥៤ (ប្រហែលក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ ទឹង សុខា និងប្រជាជនដទៃទៀតដែលត្រូវបានគេជួយលាក់ពួនមិនឱ្យជម្លៀសលើកទីពីរនោះ ក្រោយមកពួកគាត់ត្រូវបានប្រមូលហៅ។ ខ្មែរក្រហមបានជម្លៀសពួកគាត់ទៅពាយ័ព្យ មួយខែក្រោយមក)។

[1665] *សូមមើលខាងលើ* កថាខណ្ឌ ៥៩៥។

[1666] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៤ ដល់ ៤៥៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣ ដែលកថាខណ្ឌនេះបានយោងតទៀតទៅលើកថាខណ្ឌ ៥៩១ ដល់ ៥៩៩។

[1667] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៩ (“ទីតាំងដែលឱ្យប្រជាជនចុះនោះពុំមែនជាកន្លែងដែលពួកគាត់ត្រូវបានប្រាប់ពីដំបូងថា ជាកន្លែងត្រូវផ្លាស់ទីលំនៅទៅកាន់នោះឡើយ”)។

[1668] ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ៩។

[1669] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៧។

ត្រូវបាននាំទៅកន្លែងផ្សេងទៅវិញ[1670]។ ផ្អែកលើភស្តុតាងនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំមែនជាការមិនសមហេតុផលក្នុងការយល់ឃើញថា *ក្នុងចំណោមនោះ* ការបោកបញ្ឆោតត្រូវបានប្រើប្រាស់ដើម្បីឱ្យមានការផ្លាស់ទីលំនៅ។ បញ្ហាដែលថា កម្មាភិបាលខ្មែរក្រហមមួយចំនួនមានមូលហេតុជឿជាក់ថា អ្នកដែលត្រូវបានជម្លៀសនឹងទទួលបានលក្ខខណ្ឌរស់នៅប្រសើរនៅទីកន្លែងដែលត្រូវផ្លាស់ទីលំនៅទៅកាន់នោះ ពុំជាប់ពាក់ព័ន្ធនៅក្នុងបញ្ហានេះឡើយ។

## ៤.ឃ.៣.ឃ.៦.អនីត្យានុកូលភាពនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៦៤២.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការផ្លាស់ទីលំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែលរួមបញ្ចូលការផ្លាស់ទីលំនៅប្រជាជនចេញពីព្រំដែនកម្ពុជាវៀតណាមពុំមែនជាមូលហេតុសមស្រប ដូច្នេះ "ពុំអាចធ្វើយុត្តិកម្មដោយផ្អែកលើសន្តិសុខជនស៊ីវិល ឬភាពចាំបាច់ផ្នែកយោធានោះទេ និងនៅគ្រប់កាលៈទេសៈទាំងអស់ ពុំមានភាពចាំបាច់ និងសមាមាត្រឡើយ"[1671]។ ជាពិសេសទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីព្រំដែនវៀតណាម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "កងទ័ពខ្មែរក្រហម និងកម្មាភិបាលបានផ្លាស់ទីលំនៅប្រជាជនទាំងនេះមួយចំនួនដើម្បីយកទៅអប់រំកែប្រែ ខ្លះទៀតត្រូវបានធ្វើឱ្យបាត់ខ្លួន ឬយកទៅកាន់ជួរមុខដើម្បីធ្វើការងារ" និងបានសន្និដ្ឋានថា "ការដាក់ប្រជាជនទាំងនេះឱ្យស្ថិតនៅ

[1670] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ៥៨៩ ជើងទំព័រ ១៧៨៣ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ (ចាន់ សុភា *ហៅ*ចាន់ សុជាតិ) ទំព័រ ៣៣ (ចាន់ សុជាតិ បានផ្ដល់សក្ខីកម្មថា អស់រយៈពេលប្រាំមួយខែបន្ទាប់ពីត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ "មេអង្គការ"បានប្រាប់គ្រួសាររបស់គាត់ថា ពួកគាត់ត្រូវបានអនុញ្ញាតឱ្យត្រឡប់ពីស្រុកកៀនស្វាយទៅភ្នំពេញ ប៉ុន្តែផ្ទុយទៅវិញពួកគាត់ត្រូវបានបញ្ជូនទៅកាន់ស្រុកមោងឫស្សី)។ កំណត់ហេតុស្ដាប់ចម្លើយរបស់ ជា ឡេង ឯកសារលេខ E3/5231 ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00267730 ទំព័រ ៣ (ជា ឡេង បាននិយាយថា ក្រោយមកក្នុងឆ្នាំ ១៩៧៦ គាត់ និងប្ដីរបស់គាត់គិតថា ពួកគាត់ត្រូវបានបញ្ជូនទៅកាន់ស្រុកកំណើតនៅក្នុងខេត្តកំពង់ចាម ប៉ុន្តែជាក់ស្ដែងត្រូវនាំទៅខេត្តពោធិ៍សាត់)។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836357-8 ទំព័រ ២០៧ ដល់ ២០៨ (ប្រជាជនត្រូវបានប្រាប់ថា ពួកគាត់ត្រូវនាំទៅទីក្រុងភ្នំពេញ ពុំចាំបាច់យកអ្វីមកជាមួយទេ ពីព្រោះគេបានរៀបចំផ្ទះរួចហើយ) ERN (ភាសាខ្មែរ) 00836292 ទំព័រ ២១៥ (នៅក្នុងចុងឆ្នាំ ១៩៧៥ ខ្មែរក្រហមបានប្រកាសថា អង្គការបានអនុញ្ញាតឱ្យប្រជាជនពីខេត្តបាត់ដំបង កំពង់ធំ និងកំពង់ឆ្នាំងត្រឡប់ទៅភូមិរបស់ខ្លួនវិញ។ ជាក់ស្ដែង ខ្មែរក្រហមធ្វើនេះ គឺដើម្បីបង្ខំប្រជាជនឱ្យទៅកាន់ខេត្តបាត់ដំបង)។

[1671] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៦។ *សូមមើលផងដែរ* កថាខណ្ឌ ៦៣៥។

ក្នុងស្ថានភាពប្រឈមនឹងគ្រោះថ្នាក់ខ្ពស់បែបនេះ មិនមែនជាយុត្តិកម្មដោយផ្អែកលើបញ្ហាសន្តិសុខសម្រាប់ប្រជាជននោះទេ”[1672]។

៦៤៣.ខៀវ សំផន បានអះអាងថា ប្រជាជនត្រូវបានផ្លាស់ទីលំនៅដើម្បីផ្តល់ឱ្យ“អ្នកដែលបានផ្លាស់ទៅនោះមានជីវភាពរស់នៅប្រសើរឡើង” ដែលអង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើអំណះអំណាងនេះ[1673] និងដើម្បីកសាងសេដ្ឋកិច្ចរបស់ប្រទេសតាមរយៈកសិកម្ម[1674] និងថា ការផ្លាស់ទីលំនៅនេះជាការត្រឹមត្រូវ ពុំមែនជាបទល្មើសនោះឡើយ។ ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីព្រំដែនវៀតណាម និងបានអះអាងថា ការផ្លាស់ទីលំនៅទាំងនោះធ្វើឡើងដើម្បីការពារប្រជាជនស៊ីវិល ឬភាពចាំបាច់ផ្នែកយោធា ជាមូលហេតុត្រឹមត្រូវ[1675]។ ទាក់ទងទៅនឹងភាពពុំមានលក្ខណៈសមាមាត្រនៃការផ្លាស់ទីលំនៅទាំងនោះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង ពុំបានផ្តល់ការយល់ឃើញណាមួយទាក់ទងទៅនឹងលក្ខខណ្ឌនៃការផ្លាស់ទីលំនៅតាមព្រំដែនវៀតណាម ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវទុកជាមោឃៈ[1676]។ ខៀវ សំផន ក៏បានអះអាងផងដែរថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ពីព្រោះការផ្លាស់ទីលំនៅប្រជាជនទៅកាន់ផ្ទះសម្បែងរបស់ពួកគេវិញជាកាតព្វកិច្ច នៅពេលការប្រទូសរ៉ាយបានបញ្ចប់ ដែលអង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា មានការកើតឡើងឡើយ[1677]។

៦៤៤.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហានៃការផ្តល់យុត្តិកម្មជាសក្តានុពល អំពីការផ្លាស់ទីលំនៅប្រជាជនទាក់ទងទៅនឹង“ការផ្លាស់ទីលំនៅដោយបង្ខំ” ប៉ុណ្ណោះ[1678]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាជារួមទៅលើបញ្ហានៃការធ្វើយុត្តិ

[1672] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៥។

[1673] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៥។

[1674] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥១៦។

[1675] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥០៥។

[1676] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥០៧។

[1677] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥០៦។

[1678] *សូមមើលខាងលើ* កថាខណ្ឌ ៦០៤ *ជាអាទិ៍*។

កម្មជាសក្តានុពល និងអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបទ"អំពើអមនុស្សធម៌ផ្សេងៗទៀត"នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៦៤៥.ទាក់ទងទៅនឹងគោលបំណងទូទៅនៃការផ្លាស់ទីលំនៅប្រជាជន អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហានេះ ប៉ុន្តែបានសម្រេចបដិសេធថា ជាយុត្តិកម្មដោយផ្អែកលើការពិចារណាថា ខ្មែរក្រហមទទួលខុសត្រូវមួយផ្នែកធំចំពោះស្ថានភាពធ្ងន់ធ្ងររបស់ប្រជាជន[1679] និងថាគ្រប់កាលៈទេសៈទាំងអស់ ការផ្លាស់ទីលំនៅប្រជាជនពុំមានភាពចាំបាច់ និងសមស្របឡើយ[1680]។ ខៀវ សំផន ពុំបានព្យាយាមពន្យល់ និងដោះស្រាយសមស្របលើសំអាងហេតុនេះ ឬបង្ហាញថា មានកំហុសនោះឡើយ។

៦៤៦.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីព្រំដែនវៀតណាម ដើម្បីការពារប្រជាជនទាំងនេះពីការវាយប្រហារណាមួយរបស់វៀតណាមនោះ[1681] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនស៊ីវិលមួយចំនួនដែលត្រូវបានផ្លាស់ទីលំនៅ ត្រូវបានបញ្ជូនទៅដើម្បីធ្វើការនៅជួរមុខ[1682] ដែលពុំមែនជាយុត្តិកម្មដោយផ្អែកលើសន្តិសុខរបស់ប្រជាជនដែលពាក់ព័ន្ធនោះឡើយ[1683]។ ខៀវ សំផន ពុំបានលើកបង្ហាញជាក់លាក់អំពីបញ្ហានេះ និងពុំបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហានេះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងផ្ទាល់ជាឯកសារក្នុងឆ្នាំ ១៩៧៧ ចំនួន ២ មានដូចជា ទូរលេខរបស់ ប.ក.ក. ដែលបង្ហាញថា កងចល័តត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន[1684] រួមទាំងភស្តុតាងដែលបញ្ជាក់បន្ថែមលើចម្លើយក្រៅតុលា

---

[1679] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៤ ដល់ ៦៣៥។ *សូមមើល* សាលដីកា*រឿងក្តី Stakić* (ICTY) កថាខណ្ឌ ២៨៧ ("បើទោះបីជាការផ្លាស់ទីលំនៅដោយសារមូលហេតុមនុស្សធម៌ ត្រូវបានធ្វើយុត្តិកម្មក្នុងស្ថានភាពមួយចំនួនក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនេះយល់ស្របជាមួយនឹងអយ្យការថា ជាការពុំអាចធ្វើយុត្តិកម្មបានឡើយប្រសិនបើវិបត្តិមនុស្សធម៌នេះដែលបានបណ្តាលឱ្យមានការផ្លាស់ទីលំនៅ បានបង្កឡើងដោយសារសកម្មភាពពុំស្របច្បាប់នោះ")(ជើងទំព័រលុបចោល)។ សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ៣០៨ ជើងទំព័រ ៧៣៩។

[1680] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៤ ដល់ ៦៣៦។

[1681] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៧២ ដល់ ៤៧៤។

[1682] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៥។

[1683] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៥។

[1684] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២៥ យោងទៅលើទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/906 ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00020922 ទំព័រ ១ (កងទ័ពវៀតណាមបានចាប់កងចល័តកំពុងច្រូតស្រូវ

ការដែលពន្យល់ថា ប្រជាជនមួយចំនួនត្រូវបានបញ្ជូនទៅកាន់ព្រំដែនដើម្បីធ្វើការ[1685]។ ផ្អែកលើភស្តុតាងនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការយល់ឃើញថា ការផ្លាស់ទីលំនៅប្រជាជនចេញពីព្រំដែនវៀតណាម ពុំត្រូវបានធ្វើឡើងដោយផ្អែកលើក្តីបារម្ភអំពីសុវត្ថិភាពរបស់ប្រជាជនដែលពាក់ព័ន្ធឡើយ។ អាស្រ័យហេតុនេះ ពុំចាំបាច់ពិនិត្យលើអំណះអំណាងបន្តបន្ទាប់របស់ ខៀវ សំផន ដែលលើកឡើងថា ការផ្លាស់ទីលំនៅនោះជាការត្រឹមត្រូវ។

## ៤.ឃ.៣.ង.ការយល់ឃើញទាក់ទងទៅនឹងការធ្វើឱ្យបាត់ខ្លួនអ្នកដែលត្រូវបានជម្លៀស

៦៤៧.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កងទ័ព និងកម្មាភិបាលខ្មែរក្រហម“មានចេតនាដកហូតនូវសេរីភាពរបស់ប្រជាជនទាំងនោះ មានចេតនាមិនផ្តល់ព័ត៌មានអំពីទីកន្លែងដែលពួកគេត្រូវផ្លាស់ទៅ និងមានចេតនាធ្វើឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់អ្នកទាំងឡាយដែលត្រូវបានធ្វើឱ្យបាត់ខ្លួន ព្រមទាំងអ្នកដែលរស់នៅក្នុងតំបន់ដែលត្រូវបានផ្លាស់ចេញ”[1686]។

៦៤៨.នួន ជា បានអះអាងបន្ថែមទៀតថា ហេតុការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនៅពេលយល់ឃើញថា ទីកន្លែងដែលប្រជាជនត្រូវបានផ្លាស់ទៅកាន់នោះពុំដូចអ្វីដែលពួកគេត្រូវបានប្រាប់ថា នឹងត្រូវបញ្ជូនទៅនោះ ជាក់ស្តែងពុំមែនជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ពីព្រោះផ្អែកតាមភស្តុតាងជាមូលដ្ឋានបង្ហាញច្បាស់លាស់ថា ហេតុការណ៍ទាំងនេះពាក់ព័ន្ធទៅនឹងករណីដែលគ្រួសារទាំងមូលត្រូវបានផ្លាស់ទីលំនៅជាមួយគ្នា[1687]។ នួន ជា បានអះអាងថា ការយល់ឃើញដទៃទៀតពុំមានភស្តុតាងណាមួយគាំទ្រឡើយ[1688] និងថា កម្មាភិបាលរបស់ ប.ក.ក. មិនប្រាប់ពីទីកន្លែងរបស់ប្រជាជននោះ។ បន្ថែមលើនេះ នួន ជា បានលើកឡើងថា ហេតុ

---

ប្រហែលជាង ១០០ នាក់។ ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/984 ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00020904 ទំព័រ ១ (ខ្មាំងយួនបានចូលដល់ការដ្ឋានកំពឹងពួយ បំផ្លាញទំនប់សត្រសេក និងបានចាប់សមាជិកកងចល័ត)។

[1685] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦២៥ ជើងទំព័រ ១៩៧៩ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់ ខឹម ឡេង ឯកសារលេខ E3/5539 ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00373239 ទំព័រ ៨ (ប្រជាជនត្រូវចាត់ឱ្យទៅរើផ្ទះតាមព្រំដែនវៀតណាម ហើយយកឈើមកសង់ផ្ទះនៅក្បែរក្រុងស្វាយរៀង)។

[1686] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤៣។

[1687] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៤។

[1688] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៤។

ការណ៍ ដែលគ្រួសារត្រូវបានបំបែកចេញពីគ្នានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ឃើញ"មានម្តងម្កាល និងតិចតួចបំផុត"[1689]។

៦៤៩.ខៀវ សំផន បានលើកអំណះអំណាងប្រហាក់ប្រហែលគ្នានេះដែរថា ការប៉ាន់ស្មានរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានមូលដ្ឋានគ្រប់គ្រាន់គាំទ្រការយល់ឃើញដែលថា មាន"ការបិទបាំងដោយចេតនា"ពីសំណាក់ខ្មែរក្រហមក្នុងការផ្តល់ព័ត៌មានអំពីបុគ្គលដែលត្រូវបានផ្លាស់ទីលំនៅ ដែលតាមការលើកឡើងរបស់គាត់ ពុំអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ទាំងធាតុផ្សំ*សត្យានុម័ត* និង*អត្តនោម័ត*នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំបានឡើយ[1690]។

៦៥០.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវថា មានការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំបានកើតឡើង។ សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយសារការផ្លាស់ទីលំនៅ នៅតែបន្ត ព្រមទាំងការកំណត់គោលដៅរបស់ ប.ក.ក. លើសមាសភាពមិនល្អ ឬខ្មាំងមិនចប់មិនហើយ ការយល់ឃើញទាំងនេះ"ពុំអាចបំបែក"ចេញពីការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរឡើយ[1691]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានអះអាងថា ការយល់ឃើញទាំងនេះមានភស្តុតាងគាំទ្រគ្រប់គ្រាន់ និងថា បើទោះបីជាគ្មានសំណើជាក់លាក់សុំបង្ហាញព័ត៌មានក៏ដោយ ក៏ការបិទបាំងដោយចេតនាមិនព្រមផ្តល់ព័ត៌មានអំពីទីកន្លែងរបស់ប្រជាជនត្រូវបានបង្ហាញផងដែរ[1692]។

៦៥១.ពាក់ព័ន្ធទៅនឹងការជំទាស់លើការយល់ឃើញអំពីការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកវិធីសាស្ត្រក្នុងការពិចារណាទៅលើអត្ថិភាពនៃធាតុផ្សំជាក់លាក់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ជាជាងការពិចារណាជាទូទៅលើបញ្ហា ថាតើនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ធាតុផ្សំនៃបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបំពេញ ដែរ ឬយ៉ាងណានោះ[1693]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់ ថាតើអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផល ដែរ ឬយ៉ាងណា ក្នុងការដែល

---

[1689] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៤៥។

[1690] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥០៩ ដល់ ៥១០។

[1691] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦៥។

[1692] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦៦ ដល់ ២៦៧។

[1693] *សូមមើលខាងលើ* កថាខណ្ឌ ៥៨៩។

ថា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ មានការបិទបាំងដោយចេតនាមិនផ្តល់ព័ត៌មានទាក់ទងទៅនឹងទីកន្លែងរបស់អ្នកដែលត្រូវបានជម្លៀស ឬថាតើអ្នកទាំងនោះត្រូវបាននាំយកទៅកន្លែងផ្សេងទៀតដែលខុសពីអ្វីដែលពួកគេបានប្រាប់នោះ ដែរ ឬយ៉ាងណា។

៦៥២.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២ នាក់ រួមទាំងឯកសារក្រៅតុលាការផងដែរនោះ[1694]បានបង្ហាញថា មានបុគ្គលមួយចំនួនត្រូវបានបញ្ជូនទៅកាន់កន្លែងមួយផ្សេងខុសពីអ្វីដែលបានប្រាប់[1695]។ ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល ក៏បានឮតាមពាក្យចចាមអារ៉ាមថា គ្រួសាររបស់គាត់ត្រូវបានសម្លាប់[1696]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើហេតុការណ៍របស់បុគ្គល ដែលពុំដែលបានឮអំពីវាសនារបស់អ្នកដែលត្រូវបានផ្លាស់ទីលំនៅ ជាពិសេសសមាជិកគ្រួសារ[1697]។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា នេះជាភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រដល់ការ

---

[1694] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៩ ជើងទំព័រ ១៨៥៣ យោងទៅលើសៀវភៅរបស់ E. BECKER៖ *នៅពេលដែលសង្គ្រាមរលត់ទៅៈ កម្ពុជា និងបដិវត្តន៍ខ្មែរក្រហម* ឯកសារលេខ E3/20 ERN (ភាសាខ្មែរ) 00232305-6 ទំព័រ ៣០៧ ដល់ ៣០៨។

[1695] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៩៩ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ (ពិន យ៉ាថៃ) ឯកសារលេខ E1/170.1 ទំព័រ ៧ ដល់ ៨។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ៥។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦១៨។

[1696] ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ (ពេជ ស្រីផល) ឯកសារលេខ E1/148.1 ទំព័រ ៥២ ដល់ ៥៣។

[1697] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៧៨៧ យោងទៅលើសាក្សីផ្ទាល់ម្នាក់ដែលផ្តល់សក្ខីកម្មចចាមអារ៉ាម ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៤១ ដល់ ៤២ (នូ ម៉ៅ បានផ្តល់សក្ខីកម្មថា នៅក្រោយខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនត្រូវបានជម្លៀសពាសពេញភូមិភាគ រួមទាំងសាច់ញាតិរបស់គាត់ ប៉ុន្តែថា ពុំដែលបានឮដំណឹងអំពីវាសនារបស់ពួកគេឡើយ) *សូមមើល* ជើងទំព័រ ១៧៨៧។ ពាក្យបណ្តឹងរបស់ជនរងគ្រោះ ថាច់ យ៉ុង ឯកសារលេខ E3/5427 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00483321-2 ទំព័រ ៧ ដល់ ៨(រៀបរាប់ថា គ្រួសាររបស់ត្រូវផ្លាស់ទីលំនៅ និងថា ពុំដែលឮដំណឹងពីពួកគេឡើយ)។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៦០១ ជើងទំព័រ ១៨៥៩ យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុធ ពុំ ឯកសារលេខ E3/4714 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00397781 ទំព័រ ៥។

យល់ឃើញដែលថា គ្រួសារមួយចំនួនត្រូវបានបំបែកចេញពីគ្នា និងពុំដែលបានឮអំពីវាសនាសមាជិកគ្រួសាររបស់ខ្លួនដែលនេះចាត់ទុកថា ត្រូវបានធ្វើឱ្យបាត់ខ្លួន[1698]។

៦៥៣.ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខ្មែរក្រហមមានចេតនាបិទបាំងព័ត៌មានអំពីទីកន្លែងរបស់អ្នកដែលត្រូវបានជម្លៀស និងអំណះអំណាងរបស់ នួន ជា និង ខៀវ សំផន អំពីបញ្ហានេះ[1699] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញទាំងនេះមានការជាប់ពាក់ព័ន្ធតែទៅនឹងធាតុផ្សំជាក់លាក់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំប៉ុណ្ណោះ ប៉ុន្តែមិនជាប់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀតត្រូវបានបំពេញ ដែរ ឬយ៉ាងណានោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចមិនពិចារណាលើបញ្ហានេះបន្តទៀតឡើយ។ ប្រហាក់ប្រហែលគ្នានេះដែរ បញ្ហា ថាតើការផ្លាស់ទីលំនៅប្រជាជនទៅកាន់ទីកន្លែងដែលខុសពីអ្វីដែលបានប្រាប់នោះ ចាត់ទុកជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដែរ ឬយ៉ាងណានោះ គឺជាបញ្ហាពុំជាប់ពាក់ព័ន្ធដែរ ពីព្រោះដូចបានពន្យល់ខាងលើ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំពុំមានអត្ថិភាពជាបទឧក្រិដ្ឋមួយប្រភេទដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលនៃអង្គហេតុនោះឡើយ។

## ៤.ឃ.៣.ច.ថាតើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ គឺជា"អំពើអមនុស្សធម៌" ដែរ ឬយ៉ាងណា ក្នុងកាលៈទេសៈនោះ

៦៥៤.ដូចបានកត់សម្គាល់ខាងលើ ដោយសារពុំមានការយល់ឃើញជារួមរបស់អង្គជំនុំជម្រះសាលាដំបូងដែលជាប់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ គឺជា"អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែរ ឬយ៉ាងណា ក្នុងកាលៈទេសៈនោះ និងថាតើ អំពើអមនុស្សធម៌នេះមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើដទៃទៀត ដែលជាបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណានោះ ដូចនេះអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើការវាយតម្លៃលើបញ្ហាទាំងនេះ[1700]។ អង្គជំនុំជម្រះ

---

[1698] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤២ ដល់ ៦៤៣ (អង្គជំនុំជម្រះបានរកឃើញថា ខ្មែរក្រហមបានលាក់បាំងព័ត៌មានអំពី"ការជម្លៀសប្រជាជន*មួយចំនួន*" និងកថាខណ្ឌ ៦៤៣ "បិទបាំងចំពោះ*អ្នក*ដែលត្រូវបានផ្លាស់ទីលំនៅ" ដែលបានបង្កការឈឺចាប់ដល់សាច់ញាតិ")។

[1699] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៤២។

[1700] *សូមមើលខាងលើ* កថាខណ្ឌ ៥៩០។

តុលាការកំពូលនឹងត្រូវធ្វើដូច្នេះ ដោយផ្អែកលើការយល់ឃើញផ្នែកអង្គហេតុនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង តែក្នុងករណីដែលការយល់ឃើញនេះមានលក្ខណៈសមស្របសម្រាប់ការវាយតម្លៃនេះតែប៉ុណ្ណោះ។

## ៤.ឃ.៣.ច.១.ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

៦៥៥.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា យ៉ាងតិចបំផុត ក៏មានប្រជាជនរស់នៅទីក្រុងភ្នំពេញចំនួន ២.០០០.០០០ នាក់ដែរ ដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញក្នុងសភាពគួរឱ្យភ័យរន្ធត់ និងប្រើហិង្សាដោយគ្មានការប្រាប់ជាមុននោះ ពុំចាំបាច់ឱ្យមានការពិនិត្យឡើងវិញ[1701] ព្រមទាំងការយល់ឃើញដែលថា ការជម្លៀសបានប្រព្រឹត្តទៅនៅក្នុងរដូវប្រាំងដែលក្តៅបំផុត គ្មានទឹក គ្មានស្បៀងអាហារ ជម្រក សម្ភារអនាម័យ និងការថែទាំផ្នែកវេជ្ជសាស្ត្រ[1702]។ ការយល់ឃើញដែលថា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជនស៊ីវិលត្រូវបានសម្លាប់ និងអ្នកដទៃទៀតបានស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀសនោះ ត្រូវបានទទួលយកផងដែរ បើទោះបីជាការយល់ឃើញមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទៅនឹងទំហំនៃព្រឹត្តិការណ៍ទាំងនេះ ពុំសមហេតុផលក៏ដោយ[1703]។ អង្គជំនុំជម្រះតុលាការកំពូលគាំទ្របន្ថែមទៀតនូវការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ពុំអាចធ្វើយុត្តិកម្មបានដោយសារភាពចាំបាច់ផ្នែកយោធា ឬមូលហេតុមនុស្សធម៌ ឬសេដ្ឋកិច្ចឡើយ[1704]។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ផងដែរថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងដោយចេតនា[1705]។

៦៥៦.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលជាការពុំត្រឹមត្រូវតាមច្បាប់នោះ បានរំលោភបំពានលើសិទ្ធិមានសេរីភាព សិទ្ធិមានសន្តិសុខរបស់បុគ្គល និងសេរីភាពក្នុងការដើរហើរ និងតាំងទីជម្រក។ នៅក្នុងកាលៈទេសៈពាក់ព័ន្ធទៅនឹងរូបកាយ ការជម្លៀសនេះបានរំលោភ

---

[1701] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៣។

[1702] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៤។

[1703] *សូមមើលខាងលើ* កថាខណ្ឌ ៤១៣ ដល់ ៤៦០។

[1704] *សូមមើលខាងលើ* កថាខណ្ឌ ៦១៧។

[1705] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣៣ ដល់ ៥៣៤។

បំពានលើសេរីភាពតាមរយៈអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក។ ដូច្នេះ ការជម្លៀសនេះ បានបង្កការរងទុក្ខផ្នែករូបកាយ និងផ្លូវចិត្ត និងព្យសនកម្មធ្ងន់ធ្ងរ និងជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូរបស់មនុស្សជាតិ។ ការជម្លៀសនេះមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ ដោយសារបានបង្ហាញឱ្យឃើញតាមរយៈហេតុការណ៍ពិតដែលប្រជាជនមួយចំនួនធំបានទទួលរងផលប៉ះពាល់នោះ ហើយប្រជាជនខ្លះ ត្រូវបានសម្លាប់ ឬបានស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀសនោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា អំពើប្រព្រឹត្តនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអំពើល្មើសនៃបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពោលគឺ ការនិរទេស។ ទាក់ទងទៅនឹងបញ្ហានេះ ដោយផ្ទុយទៅនឹងការលើកឡើងរបស់ នួន ជា អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា មានការជាប់ពាក់ព័ន្ធជាចម្បងនូវបញ្ហា ថាតើប្រជាជនត្រូវបានផ្លាស់ទីលំនៅឆ្លងកាត់ព្រំដែនអន្តរជាតិ ឬថាតើទឹកដីនោះ ស្ថិតក្រោមការកាន់កាប់ដោយបរទេស ដែរ ឬយ៉ាងណានោះឡើយ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ការនិរទេសឆ្លងកាត់ព្រំដែនបរទេសអាចនាំទៅរកការកម្រិតបន្ថែមទៀតលើសិទ្ធិ និងការប៉ះពាល់ដល់ជនរងគ្រោះក៏ដោយ។ ផ្អែកតាមកាលៈទេសៈរឿងក្ដីបច្ចុប្បន្ន ជនរងគ្រោះបានទទួលរងផលប៉ះពាល់នៃការផ្លាស់ទីលំនៅដែលធ្វើបានធ្វើឱ្យពួកគាត់បាត់បង់ទីលំនឹង (ដូចគ្នាទៅនឹងផលវិបាកនៃការផ្លាស់ទីលំនៅឆ្លងកាត់ព្រំដែនដែរ ប្រសិនបើពួកគាត់ត្រូវផ្លាស់ទីលំនៅដូច្នោះនោះមែន) និងទទួលរងលក្ខខណ្ឌអមនុស្សធម៌ដោយសារការផ្លាស់ទីលំនៅនេះ។

៦៥៧.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ដោយផ្អែកលើហេតុការណ៍ពិតដែលត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវចាត់ទុកជាបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ៤.ឃ.៣.ច.២.ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៦៥៨.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា យ៉ាងតិច មានប្រជាជនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅ នៅចន្លោះពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ដើមឆ្នាំ ១៩៧៧ ពីភូមិភាគមួយទៅភូមិភាគមួយទៀត រួមទាំងប្រជាជនជាង ៣០.០០០ នាក់ ដែលត្រូវបានផ្លាស់ទីលំនៅនៅចន្លោះពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ នៅក្នុងភូមិភាគ[1706]។ បើ

---

[1706] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣០។

ទោះបីជាការយល់ឃើញទាំងនេះពុំត្រូវបានជំទាស់នៅដំណាក់កាលបណ្តឹងសាទុក្ខនោះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនេះ ជាការពុំសមហេតុផលដែលថា ប្រជាជនភាគច្រើនលើសលុបដែលត្រូវបានផ្លាស់ទីលំនៅនោះ គឺជាប្រជាជនដែលត្រូវបានខ្មែរក្រហមផ្លាស់ទីលំនៅពីមុនរួចមកហើយ។ ការជំទាស់នៅដំណាក់កាលបណ្តឹងសាទុក្ខ ពុំទទួលបានជោគជ័យទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប្រជាជនត្រូវបានបង្ខំឱ្យចាកចេញនោះ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅ បានទទួលរងនូវលក្ខខណ្ឌធ្ងន់ធ្ងរ ដូចជា ការខ្វះស្បៀងអាហារ ទឹក ទីជម្រក ថ្នាំពេទ្យ និងសម្ភារអនាម័យ។ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រផងដែរនូវការយល់ឃើញដែលថា ប្រជាជនខ្លះបានស្លាប់នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដោយសារលក្ខខណ្ឌ និងថា មានហេតុការណ៍មួយករណីដែលបុគ្គលម្នាក់ត្រូវបានបាញ់សម្លាប់ដោយកងទ័ពខ្មែរក្រហម។ ចុងក្រោយ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ មានការបង្ហាញឱ្យឃើញពីហេតុការណ៍នៃការបំបែកក្រុមគ្រួសារចេញពីគ្នា។

៦៥៩.ប្រហាក់ប្រហែលគ្នាទៅនឹងការពិចារណា ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយដែលមាននៅក្នុងកថាខណ្ឌខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្នុងកាលៈទេសៈនោះ មានការបង្ហាញហួសពីវិមតិសង្ស័យថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរបានបង្កឱ្យមានការរងទុក្ខវេទនាលើរូបកាយ និងផ្លូវចិត្ត និង ព្យសនកម្មយ៉ាងធ្ងន់ធ្ងរ។ ការដែលថា ការជម្លៀសនោះមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញតាមរយៈហេតុការណ៍ពិតដែលថា មានបុគ្គលមួយចំនួនធំបានទទួលរងនូវផលប៉ះពាល់ដោយសារការជម្លៀសនេះ និងថាអ្នកខ្លះត្រូវបានសម្លាប់ ឬបានស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀសនេះ។

៦៦០.ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ដោយផ្អែកលើហេតុការណ៍ពិតដែលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ចាត់ទុកជាបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ៤.ឃ.៤.ការធ្វើទុក្ខបុកម្នេញ

៦៦១.អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ទីពីរ និងនៅទួលពោធិ៍ជ្រៃ[1707]។

៦៦២.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជនចំនួន ៣ ក្រុម គឺជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (i) នាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ (ii) អ្នកមានតួនាទីនៅក្នុងអតីតរបបសាធារណរដ្ឋខ្មែរ ទាំងទាហាន និងអ្នករដ្ឋការស៊ីវិល (iii) ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញក្នុងពេលដួលរលំ ដែលគេហៅថាជា "ប្រជាជន ១៧ មេសា" ឬ"ប្រជាជនថ្មី"[1708]។ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ប្រជាជនថ្មី" គឺជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[1709]។ ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនរងគ្រោះនៃអំពើមនុស្សឃាត និងអំពើសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ"ដែលជាក្រុមគេស្គាល់យ៉ាងច្បាស់"[1710]។

៦៦៣.នួន ជា និង ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើនដែលពាក់ព័ន្ធគ្នា នៅក្នុងការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការចោទប្រកាន់អំពីកំហុសអង្គច្បាប់ពាក់ព័ន្ធទៅនឹងការកំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែលធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ជាពិសេស ពាក់ព័ន្ធទៅនឹងការយល់ឃើញដែលថា បទឧក្រិដ្ឋនេះអាចត្រូវបានប្រព្រឹត្តឡើងមិនត្រឹមតែប្រឆាំងនឹងក្រុមនយោបាយ ឬបុគ្គលដែលប្រកាន់ទស្សនៈនយោបាយមួយចំនួនប៉ុណ្ណោះទេ ថែមទាំងប្រឆាំងនឹងក្រុមដែលគេស្គាល់យ៉ាងច្បាស់(ដែលពុំចាំបាច់ប្រកាន់ទស្សនៈនយោបាយរួមណាមួយ) ដែលត្រូវបានរើសអើង

---

[1707] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤០, ១០៥៣។

[1708] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៩។

[1709] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៣។

[1710] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៥។

តាមឆន្ទៈនយោបាយ ឬកម្មវិធីនយោបាយមួយរបស់អ្នកធ្វើទុក្ខបុកម្នេញនោះ[1711]។ នួន ជា និង ខៀវ សំផន បាន ចោទប្រកាន់ផងដែរអំពីកំហុសអង្គហេតុ និងអង្គច្បាប់ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការកំណត់និយមន័យអំពី"ប្រជាជនថ្មី"[1712] និងទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានដែលថា ធាតុផ្សំនៃ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញនៅក្នុង អំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ[1713]។

### ៤.ឃ.៤.ក.ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងពីបទធ្វើទុក្ខបុកម្នេញ

៦៦៤.អង្គជំនុំជម្រះសាលាដំបូងបានឱ្យនិយមន័យទៅលើជនរងគ្រោះជាសក្តានុពលនៃការធ្វើទុក្ខបុកម្នេញដោយ មូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចខាងក្រោមៈ

> អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បុគ្គលទាំងឡាយដែលប្រកាន់យកទស្សនៈនយោបាយ ឬជាសមាជិកនៃក្រុមនយោបាយ ឬបក្សណាមួយ គឺជាឧទាហរណ៍ជាក់ស្តែងបំផុតមួយនៃអ្នកដែលអាចជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ប៉ុន្តែ ទោះបីយុត្តិសាស្ត្រអន្តរជាតិមួយចំនួនបានបកស្រាយពាក្យថា "មូលហេតុនយោបាយ" ក្នុងន័យចង្អៀតក៏ដោយ តែយុត្តិសាស្ត្រអន្តរជាតិដទៃទៀតបានយល់ឃើញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ កើតមានឡើងនៅក្នុងករណីដែលមានការរើសអើងត្រូវបានកើតមានឡើង ស្របទៅតាមឆន្ទៈនយោបាយ ឬ កម្មវិធីនយោបាយមួយប្រឆាំងទៅនឹងក្រុមណាមួយ បើទោះបីជាក្រុមនោះមិនបានប្រកាន់យកទស្សនៈនយោបាយណាមួយក៏ដោយ[1714]។

៦៦៥.នួន ជា បានជំទាស់ទៅនឹងការកំណត់និយមន័យនេះ ដោយបានអះអាងថា ការធ្វើទុក្ខបុកម្នេញដោយមូល ហេតុនយោបាយ អាចត្រឹមតែប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកនៃក្រុមនយោបាយ ឬក្រុមមនុស្សដែលប្រកាន់ទស្សនៈនយោបាយរួមប៉ុណ្ណោះ។ ហេតុនេះ នៅក្នុងសារណារបស់គាត់បានលើកឡើងថា ជាការពុំគ្រប់គ្រាន់នោះ

---

[1711] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៥៥ ដល់ ៣៦៤។

[1712] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៦៥ ដល់ ៣៨៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧, ៤៧៨ ដល់ ៤៨២, ៥១២។

[1713] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៤ ដល់ ៣៩៤ និង ៣៩៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៥ ដល់ ៣៦៨, ៤៨៣, ៤៨៦ ដល់៤៨៩, ៤៩១, ៥១៣ ដល់ ៥១៤។

[1714] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣០ (ជើងទំព័រលុបចោល)។

ទេដែលថា ក្រុមមួយត្រូវបានធ្វើទុក្ខបុកម្នេញដោយសារឆន្ទៈនយោបាយ ឬកម្មវិធីនយោបាយមួយរបស់*ចារី*នោះឡើយ[1715]។

៦៦៦.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវតាមច្បាប់នៅពេលកំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដោយបានអះអាងថា ក្នុងស្ថានការណ៍ដែលក្រុមគោលដៅ ត្រូវបានកំណត់ជាសត្យានុម័តដោយចារីដែលផ្អែកលើមូលហេតុនយោបាយអវិជ្ជមាននោះ ស្របទាំងស្រុងទៅនឹងហេតុផល និងគោលបំណងនៃបទធ្វើទុក្ខបុកម្នេញ[1716]។

៦៦៧.នៅក្នុងសាលដីកា*រឿងក្តី ឌុច* (001-F28) អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការវិភាគយ៉ាងលម្អិត អំពីការធ្វើទុក្ខបុកម្នេញ ដែលជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[1717]។ ជាការកត់សម្គាល់ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការកំណត់ថា ជាការធ្វើទុក្ខបុកម្នេញ ការប្រព្រឹត្តរបស់ចារីត្រូវតែជាការរើសអើងជាក់ស្តែង ហើយអង្គជំនុំជម្រះបានយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងដែលកំណត់ថា “ជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះជាសមាជិកនៃក្រុមណាមួយ *ដែលចារីបានកំណត់*ដោយផ្អែកលើមូលហេតុជាក់លាក់ ដូចជា មូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា”[1718]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ផងដែរថា ជនរងគ្រោះ“*ជាក់ស្តែងត្រូវតែ* ស្ថិតក្នុងក្រុម នយោបាយ ពូជសាសន៍ ឬសាសនាណាមួយដែល*ស្តែងឱ្យឃើញ*គ្រប់គ្រាន់”[1719] និងថា “ចេតនារើសអើងពាក់ព័ន្ធត្រូវបានសន្មតថា មានអត្ថិភាព នៅពេលជនរងគ្រោះ ជាសមាជិកនៃក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយនោះ”[1720]។

---

1715 សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៥៨ ដល់ ៣៦៤។

1716 សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០៩ ដល់ ២១១។

1717 សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២១៥ ដល់ ២៧៨។

1718 សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៧២ យោងទៅលើសាលក្រម*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៣៧៧ (សេចក្តីបញ្ជាក់ដើម)។

1719 សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៧៤។

1720 សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៦៥ យោងទៅលើសាលក្រម*រឿងក្តី Krnojelac* (ICTY) កថាខណ្ឌ ៤៣២ ជើងទំព័រ ១២៩៤ និងសាលក្រម*រឿងក្តី Blaškić* (ICTY) កថាខណ្ឌ ២៣៥។

៦៦៨.ដូច នួន ជា បានកត់សម្គាល់នោះ ពុំមានការជំទាស់ទេដែលថា ជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាក់ស្ដែង ត្រូវតែស្ថិតក្នុងក្រុមដែល“*ស្ដែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់*”នោះ[1721]។ វិធីសាស្ត្រនេះស្របជាមួយនឹងលក្ខន្តិកៈរបស់តុលាការ ICC ដែលបានកំណត់និយមន័យនៃការធ្វើទុក្ខបុកម្នេញថា ជាអំពើដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងបុគ្គលណាមួយដែលស្ថិតក្នុង“ក្រុម ឬសមូហភាពដែលអាចកំណត់អត្តសញ្ញាណបាន”[1722] និងស្របជាមួយនឹងការយល់ជាទូទៅដែលថា គោលបំណងនៃបទធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដើម្បីការពារ“សមាជិកក្រុមនយោបាយ ពូជសាសន៍ និងសាសនាឱ្យរួចផុតពីការរើសអើង ដោយសារសមាជិកនេះស្ថិតនៅក្នុងក្រុមណាមួយនៃក្រុមទាំងនេះ”[1723]។ បញ្ហាដែលចោទឡើងដោយ នួន ជា នៅក្នុងទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខថាតើបុគ្គលក្រុម*ណាខ្លះ* ពិតជាអាចកំណត់បានជាជនរងគ្រោះសម្រាប់បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងពិសេសជាងនេះទៀត ថាតើមានលក្ខខណ្ឌតម្រូវថា សមាជិកនៃក្រុមនោះត្រូវតែប្រកាន់ទស្សនៈនយោបាយរួម ដែរ ឬយ៉ាងណា។

៦៦៩.មានភស្តុតាងគ្រប់គ្រាន់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិដែលថា វិធានការដែលមានលក្ខណៈរើសអើងប្រឆាំងនឹងសមាជិកនៃក្រុមនយោបាយ អាចជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[1724]។ លើសពីនេះទៀត ដូចបានកត់សម្គាល់ខាងលើ នៅក្នុងសាលដីកា*រឿងក្ដី ឌុច* (001-F28) អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា បើទោះបីជាក្រុមដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញ ត្រូវបានស្ដែងឱ្យឃើញយ៉ាងច្បាស់ក៏ដោយ ក៏អាស្រ័យលើចារីដែលជាអ្នកកំណត់[1725]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា “ក្រុមដែល

---

[1721] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៦៧។

[1722] មាត្រា ៧(១-ល) នៃលក្ខន្តិកៈរបស់តុលាការ ICC។ *សូមមើលផងដែរ* ធាតុផ្សំនៃឧក្រិដ្ឋកម្មរបស់តុលាការ ICC ធាតុផ្សំទីពីរនៃមាត្រា ៧(១-ល) ។

[1723] សាលដីកា*រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ២៦៥ យោងទៅលើសាលក្រម*រឿងក្ដី Krnojelac* (ICTY) កថាខណ្ឌ ៤៣២ ជើងទំព័រ ១២៩៣។ *សូមមើលផងដែរ* សាលក្រម*រឿងក្ដី Blaškić* (ICTY) កថាខណ្ឌ ២៣៥ (ការកត់សម្គាល់ទាក់ទងទៅនឹងគោលដៅនៃការធ្វើទុក្ខបុកម្នេញឃើញថា “ចារីនៃអំពើធ្វើទុក្ខបុកម្នេញ ជាដំបូងពុំបានកំណត់គោលដៅលើបុគ្គល ប៉ុន្តែលើភាពជាសមាជិកនៅក្នុងក្រុមនយោបាយ សាសនា ឬពូជសាសន៍ជាក់លាក់”)។

[1724] សាលក្រម*រឿងក្ដី Naletilić* (ICTY) កថាខណ្ឌ ៦៨១។ សាលដីកា*រឿងក្ដី Naletilić* (ICTY) កថាខណ្ឌ ៥១១។ សាលក្រម*រឿងក្ដី Bagosora* (ICTR) កថាខណ្ឌ ២១៧៨។

[1725] សាលដីកា*រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ២៧២ ដល់ ២៧៣។

ទទួលរងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អាចរួមបញ្ចូលក្រុមមនុស្សផ្សេងៗ ដូចជា អ្នករាជការ ឬសកម្មជននយោបាយ ក្រុមជនដែលមានទស្សនៈ និន្នាការ និងជំនឿណាមួយ ឬក្រុមជនដែលជាជនជាតិភាគតិចណាមួយ ឬក្រុមជនជាតិណាមួយ ឬក្រុមជនដែលតំណាងឱ្យវណ្ណៈណាមួយនៅក្នុងសង្គម (ឧទាហរណ៍ "បញ្ញវន្ត" បុព្វជិត ឬវណ្ណៈគហបតី)"[1726]។ ជាពិសេស ទាក់ទងទៅនឹងក្រុមចុងក្រោយ ក្រុមនេះអាចត្រូវបានកំណត់ជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនត្រឹមតែដោយសារសមាជិកទាំងអស់ ឬក៏ភាគច្រើននៃក្រុមនោះ ប្រកាន់ទស្សនៈនយោបាយ ដែលផ្ទុយពីទស្សនៈនយោបាយរបស់ចារីប៉ុណ្ណោះទេ ថែមទាំងដោយសារក្រុមនេះ*ត្រូវបានសន្មត*ដោយចារីថា ជាអ្នកប្រឆាំង(មានសក្តានុពល) ឬក៏ជាឧបសគ្គរាំងដល់ការអនុវត្តនៃកម្មវិធីនយោបាយរបស់ចារី[1727]។ ពាក់ព័ន្ធទៅនឹងអំណះអំណាងជាក់លាក់របស់ នួន ជា អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ចំពោះការបកស្រាយរបស់គាត់លើសាលដីកា*រឿងក្តី Kvočka* របស់តុលាការ ICTY ដែលថា មានតែក្រុមដែលប្រកាន់ទស្សនៈជាក់លាក់ប៉ុណ្ណោះ ទើបអាចជាគោលដៅនៃការធ្វើទុក្ខបុកម្នេញ[1728]។ ផ្ទុយទៅវិញ ក្នុងរឿងក្តីនោះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY គ្រាន់តែបានពិពណ៌នាអំពីព្រឹត្តិការណ៍ជាសម្ភតិកម្មដែលអាចនឹងជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬពូជសាសន៍[1729]។ ការដកស្រង់របស់ នួន ជា នៅក្នុងសាលដីកានោះ មិនមានចំណុចណាមួយបង្ហាញឱ្យឃើញពីលក្ខខណ្ឌតម្រូវដែលថា ដើម្បីចាត់ទុកថា មានអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សមាជិកនៃក្រុមគោលដៅត្រូវតែជាក់ស្តែងប្រកាន់ទស្សនៈនយោបាយនោះឡើយ។

៦៧០.ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងដែលបានលើកឡើងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងពុំស្របតាមកាលវេលា។ ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលទំនងជាថា នៅក្នុងបរិបទសង្គ្រាមត្រជាក់ ការប្រើប្រាស់ហិង្សានៅក្នុងការធ្វើបដិវត្តន៍ ដើម្បីលុបបំបាត់វ

[1726] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៧២។

[1727] *សូមមើល* សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ*រឿងក្តី Kenyatta* (ICC) កថាខណ្ឌ ១៤៤ ("ចារីបានជ្រើសរើសគោលដៅរៀងៗខ្លួនដោយផ្អែកលើភាពជាប់ពាក់ព័ន្ធទៅនឹងនយោបាយរបស់ក្រុមនៃជាតិពិន្ទុជាក់លាក់")។ សេចក្តីសម្រេចស្តីពីការបញ្ជាក់អំពីបទចោទ*រឿងក្តី Gbagbo* (ICC) កថាខណ្ឌ ២០៥ ("កងកម្លាំងគាំទ្រ Gbagbo បានកំណត់គោលដៅ […] លើប្រជាជននៅក្នុងតំបន់ដែលសន្មតថាបានគាំទ្រ Alassane Ouattara")។ សេចក្តីសម្រេចស្តីពីការបញ្ជាក់បទចោទ*រឿងក្តី Blé Goudé* (ICC) កថាខណ្ឌ ១២៣ ("សមាជិកនៃក្រុមទាំងនេះត្រូវបានសន្មតថា ជាអ្នកគាំទ្រ Alassane Ouattara")។

[1728] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៥៩ និង ៣៦៣។

[1729] សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៤៥៦។

01358344



ណ្ណៈប្រកួតប្រជែងក្នុងសង្គម និងដើម្បីទទួលបានសង្គមស្មើភាពគ្នា នឹងត្រូវធ្វើយុត្តិកម្មចំពោះអំពើប្រព្រឹត្តដែលចាត់ទុកជាការធ្វើទុក្ខបុកម្នេញក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[1730]នោះ អំណះអំណាងនេះ ពុំមានមូលដ្ឋានគាំទ្រឡើយ។ ចំពោះការចោទប្រកាន់របស់គាត់ដែលថា ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើយុត្តិសាស្ត្រក្រោយព្រឹត្តិការណ៍នោះ អំណះអំណាងនេះដែលនឹងត្រូវបង្ហាញនៅខាងក្រោម ពុំបានពិចារណាទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ដែលបានបង្ហាញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយអាចកើតមានឡើង ដោយសារជនរងគ្រោះត្រូវបានសន្មតថា ជាគូបដិបក្ខនយោបាយ ឬបានសហការជាមួយក្រុមនយោបាយប្រឆាំង។

៦៧១.ក្នុងឆ្នាំ ១៩៤៦ លោក Egon Schwelb បានសរសេរថា ហេតុផលមួយដែលប្រទេសសម្ព័ន្ធមិត្តគាំទ្រការដាក់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) គឺដើម្បីដោះស្រាយការធ្វើទុក្ខបុកម្នេញលើគូបដិបក្ខនយោបាយប្រឆាំងនឹងលទ្ធិសង្គមនិយមជាតិនិយម។ ដកស្រង់តាមសំដីរបស់គាត់ថា៖

> អ្នកនិពន្ធ អ្នកនយោបាយ រដ្ឋបុរស និងអង្គការនានា ដែលគាំទ្រការដាក់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT) នេះ បានពិចារណាឃើញថា អំពើឃោរឃៅដែលបានប្រព្រឹត្តឡើង ខ. ដោយជនជាតិអាល្លឺម៉ង់ក្នុងប្រទេសអ៊ីតាលី និងប្រឆាំងនឹងជនជាតិអ៊ីតាលីនៅមុន និងក្រោយការចុះចាញ់របស់អ៊ីតាលី គឺ*ជាការធ្វើទុក្ខបុកម្នេញរបស់រដ្ឋាភិបាលណាហ្ស៊ីទៅលើក្រុមប្រឆាំងនយោបាយក្នុងប្រទេសអាល្លឺម៉ង់* (*សហជីពពាណិជ្ជកម្ម អ្នកកាន់សង្គមលទ្ធិប្រជាធិបតេយ្យ អ្នកកាន់លទ្ធិកុម្មុយនីស្ត គ្រីស្តបរិស័ទ*) និងពិតណាស់ ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ បើទោះបីជាមានសញ្ជាតិអ្វីក៏ដោយនោះ។ ទាំងអស់នេះជាករណីដែលពុំត្រូវបានគ្របដណ្តប់ដោយសញ្ញាណទំនៀមទំលាប់នៃឧក្រិដ្ឋកម្មសង្គ្រាមឡើយ[1731]។

៦៧២.ពិតណាស់ ពុំមានការអះអាងថា ជនរងគ្រោះនៃអំពើធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសហជីពពាណិជ្ជកម្ម គ្រីស្តបរិស័ទ ឬចលនានយោបាយ*ទាំងអស់នេះ* បានបង្ហាញយ៉ាងសកម្មនូវជំហរនយោបាយរបស់ខ្លួនប្រឆាំងទៅនឹងលទ្ធិសង្គមនិយមជាតិនិយម ឬជាអ្នកប្រឆាំងពិតប្រាកដ (អាចសន្មតបានថា ជាឧទាហរណ៍ សមាជិកខ្លះនៃ

---

[1730] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ កថាខណ្ឌ ៣៦០។

[1731] អ្នកនិពន្ធ Egon Schwelb៖ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" *សៀវភៅប្រចាំឆ្នាំស្តីពីច្បាប់អន្តរជាតិរបស់ចក្រភពអង់គ្លេស* ភាគ ២៣ (១៩៤៦) ទំព័រ ១៧៨, ១៨៣ (សេចក្តីបញ្ជាក់បន្ថែម)។

សហជីពពាណិជ្ជកម្ម ឬគ្រឹស្តបរិស័ទ ជាក់ស្តែង គឺជាអ្នកគាំទ្រលទ្ធិសង្គមនិយមជាតិនិយម)។ ទោះជាយ៉ាងណាក្តី ពួកគេត្រូវបានសន្មតថា បានស្ថិតក្នុងក្រុម*សក្តានុពល*នៃអ្នកប្រឆាំងទៅនឹងរបបណាហ្ស៊ី និងត្រូវបានកំណត់ជាគោលដៅនៃអំពើធ្វើទុក្ខបុកម្នេញ។

៦៧៣.ការយល់ឃើញនេះស្របតាមយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ។ ឧទាហរណ៍ តុលាការយោធាអន្តរជាតិ (IMT) បានសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទ Hans Frank ដែលជាអគ្គទេសាភិបាលកាន់កាប់ប្រទេសប៉ូឡូញពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំងបទធ្វើទុក្ខបុកម្នេញដោយសារបានបង្កើតផែនការសកម្មភាព*ប្រតិបត្តិការវិសាមញ្ញនៃការធ្វើអោយស្ងប់ស្ងាត់* A-B *(Ausserordentliche Befriedungsaktion)*[1732]ដែល"ក្នុងគោលបំណងសម្លាប់រង្គាលវណ្ណៈបញ្ញវន្តដែលជាជនជាតិប៉ូឡូញពាក់ព័ន្ធទៅនឹងផែនការមហាអស្ចារ្យមួយ ក្នុងការកាត់បន្ថយ"សេដ្ឋកិច្ចទាំងមូលរបស់ប៉ូឡូញមកត្រឹមកម្រិតអប្បបរមាដាច់ខាត ដែលត្រឹមតែរស់ប៉ុណ្ណោះ។ ជនជាតិប៉ូឡូញត្រូវតែធ្វើជាទាសកររបស់អាណាចក្រពិភពអាល្លឺម៉ង់មហាអស្ចារ្យ"[1733]។

៦៧៤.នៅក្នុង*រឿងក្តីទាក់ទងទៅនឹងក្រសួងផ្សេងៗ* ជនជាប់ចោទ Richard Walther Darré, Otto Dietrich, Hans Heinrich Lammers, Wilhelm Stuckart និង Lutz Schwerin von Krosigk ត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញលើជនជាតិប៉ូឡូញ ជ្វីហ្វ និង"បច្ចាមិត្ត និងអ្នកប្រឆាំងទៅនឹងលទ្ធិសង្គមនិយមជាតិនិយម"ដោយមូលហេតុពូជសាសន៍ និងនយោបាយ[1734]។ ពុំមានការបង្ហាញថា ជនរងគ្រោះនីមួយៗបានបង្ហាញពីជំហរនយោបាយរបស់ខ្លួនដោយចំហ ឬថា ជនរងគ្រោះទាំងអស់នោះមានទស្សនៈនយោបាយរួមឡើយ។

៦៧៥.ប្រហាក់ប្រហែលគ្នានេះដែរ *ក្នុងរឿងក្តី Einsatzgruppen* បានបង្ហាញថា ស្លាកសម្គាល់នយោបាយ និងការរើសអើងផ្អែកសាសនា និងជាតិពន្ធុ គឺជាហេតុផលចម្បងសម្រាប់ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ។ តុលាការបានផ្តល់មូលហេតុថា៖

---

[1732] សាលក្រមរបស់តុលាការ IMT កថាខណ្ឌ ២៩៦ ដល់ ២៩៨។

[1733] សាលក្រមរបស់តុលាការ IMT កថាខណ្ឌ ២៣៧ ដល់ ២៣៨។

[1734] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២២២ យោងទៅលើ*រឿងក្តីពាក់ព័ន្ធក្រសួងផ្សេងៗ* ភាគ XIV ទំព័រ ៥៦៣ ដល់ ៥៦៥, ៦០០ ដល់ ៦០៥, ៦៤៥ ដល់ ៦៤៦, ៦៧៥ ដល់ ៦៨០។

មានករណីពីរ ឬបីដែលថា ការប៉ុនប៉ងត្រូវបានធ្វើឡើងដើម្បីបង្ហាញថា ជនជាតិជ្វីហ្វនៅក្នុងប្រទេសរុស្ស៊ីកាន់តួនាទីជាផ្លូវការក្នុងភាគរយខ្ពស់ ដែលពុំសមាមាត្រទៅនឹងចំនួនប្រជាជនជ្វីហ្វជាក់ស្តែង។ នេះគឺជាទ្រឹស្តីរួមទូទៅបំផុតដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសអាល្លឺម៉ង់សម្រាប់ការគាបសង្កត់ និង ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីហ្វ[1735]។

៦៧៦.ក្នុង *រឿងក្តី Buhler* តុលាការរបស់ប៉ូឡូញបានសម្រេចដាក់ពិរុទ្ធភាពអតីតអគ្គទេសាភិបាលរងពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិសម្រាប់អំពើឃោរឃៅទាំងនេះ និងអំពើដទៃទៀតដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការកាន់កាប់របស់អាល្លឺម៉ង់។ យោងតាមគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ (UNWCC) បានបង្ហាញថា "វិធានការទាំងអស់នេះ បានបណ្តាលឱ្យមានការធ្វើទុក្ខបុកម្នេញជាទូទៅផងដែរទៅលើពលរដ្ឋរបស់ប៉ូឡូញ"[1736]។ ដូចគ្នានេះដែរ បញ្ញវន្តជាជនជាតិប៉ូឡូញត្រូវបានធ្វើទុក្ខបុកម្នេញមិនត្រឹមតែដោយសារការប្រកាន់ទស្សនៈនយោបាយរួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារការសម្លាប់រង្គាលលើបញ្ញវន្តទាំងនេះ ដែលស្របតាមកម្មវិធីនយោបាយរបស់រដ្ឋអំណាចអាល្លឺម៉ង់។

៦៧៧.ដូច្នេះ ផ្ទុយទៅនឹងអំណះអំណាងរបស់ នួន ជា[1737] យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរបានបង្ហាញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានយល់ច្បាស់ថា មានការរួមបញ្ចូលស្ថានការណ៍នានាដែល ក្នុងនោះចារីបានកំណត់ក្រុមគោលដៅជាទូទៅដោយមិនចាំបាច់ពិនិត្យដោយហ្មត់ចត់ទៅលើទស្សនៈនយោបាយរបស់បុគ្គលនោះ និងជាញឹកញាប់គ្របដណ្តប់លើមូលហេតុដទៃទៀតនៃការរើសអើង។ ជាលទ្ធផល ជនរងគ្រោះពុំចាំបាច់ជាអ្នកប្រកាន់ទស្សនៈនយោបាយរួម ឬពុំស្ថិតក្នុងក្រុមនយោបាយណាមួយដែលមានលក្ខណៈស្ថាប័ននោះទេ។ ការយល់បែបនេះត្រូវបានទទួលស្គាល់ជាបន្តបន្ទាប់នៅក្នុងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌ *មិនអចិន្ត្រៃយ៍*នានា។ នៅក្នុងសាលក្រម *រឿងក្តី Stakić* តុលាការ ICTY ជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពីព្រោះជនជាប់ចោទមានចេតនារើសអើងប្រឆាំងនឹងអ្នកដែលពុំមែនជាជនជាតិស៊ែប "ឬ អ្នកដែលជាប់ពាក់ព័ន្ធ ឬអ្នកដែលមានការអាណិតអាសូរអ្នកដែលពុំមែនជាជនជាតិស៊ែបនោះ"[1738]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY

---

[1735] *រឿងក្តី Einsatzgruppen* ទំព័រ ៤៦៩។

[1736] *ការជំនុំជម្រះរឿងក្តី Buhler* (តុលាការកំពូល ប្រទេសប៉ូឡូញ) ទំព័រ ៣៧។

[1737] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៥៨។

[1738] សាលក្រម *រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៨២៦។

01358347



បានកត់សម្គាល់ឃើញថា ជនរងគ្រោះនៃអំពើធ្វើទារុណកម្មត្រូវបាន"រើសអើង [...] ដោយសារមូលហេតុនយោបាយ" ពីព្រោះជនរងគ្រោះ"ត្រូវបានសន្មតថា មានការសហការជាមួយនឹងជនជាតិស៊ែប"[1739]។

៦៧៨.បញ្ហា ថាតើក្រុមទាំងនេះត្រូវបានកំណត់ក្នុងន័យអវិជ្ជមានថា បានស្ថិតនៅក្នុង"ក្រុមអ្នកពុំមែនជនជាតិស៊ែប"[1740] ឬថា ជាក្រុម"បច្ចាមិត្ត និងប្រឆាំងទៅនឹងសង្គមនិយមជាតិនិយម"[1741] ឬក៏ថា ស្ថិតនៅក្នុងក្រុមរួមដែលមានដូចជា"ជនជាតិស៊ែប ជ្វីហ្វ ជីពស៊ី (Gypsies) ព្រមទាំងក្រុអាត ដែលមិនព្រមទទួលយកមនោគមន៍វិជ្ជានេះ"[1742] ហើយថា ក្រុមដែលទទួលរងការធ្វើទុក្ខបុកម្នេញទាំងនោះ ពុំមានទម្រង់ស្របគ្នាតែមួយ ដែរ ឬយ៉ាងណា។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់លទ្ធភាពដែលថា ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចកំណត់គោលដៅលើក្រុមប្រមូលផ្តុំ ដែលគ្មានអត្តសញ្ញាណ ឬកម្មវិធីរួមគ្នាណាមួយបាន។

៦៧៩.អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលស្របជាមួយនឹងវិធីសាស្ត្រនៅក្នុងសាលដីកា*រឿងក្តី ឌុច* (001-F28) "ពុំសមស្រប"នោះឡើយ ពីព្រោះអាចមានន័យយ៉ាងទូលំទូលាយថា បុគ្គលម្នាក់ដែលដោយសារមូលហេតុសាសនា បានរើសអើងអ្នកដែលមានសក់ក្រហម អាចនឹងត្រូវជាប់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា បើទោះបីជាអ្នកដែលមានសក់ក្រហមនោះពុំស្ថិតក្នុងក្រុមសាសនាក៏ដោយ[1743]។ ផ្ទុយទៅវិញ ឧទាហរណ៍ដែល នួន ជា បានលើកឡើងនេះបង្ហាញថា ជាការសមស្រប និងចាំបាច់ត្រូវពិចារណាលើទស្សនវិស័យរបស់ចារី នៅពេលធ្វើការកំណត់ក្រុមដែលជាគោល

---

[1739] សាលក្រម*រឿងក្តី Haradinaj* (ICTY) កថាខណ្ឌ ៣៩២ (ត្រូវកត់សម្គាល់ថា ជនជាប់ចោទក្នុងរឿងក្តីនេះ ទោះជាយ៉ាងណា ពុំត្រូវបានដាក់ពិរុទ្ធភាពពីបទទុក្ខបុកម្នេញឡើយ)។

[1740] សាលក្រម*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ៧១៤ ដល់ ៧១៨។ សាលដីកា*រឿងក្តី Krnojelac* (ICTY) ផ្នែកសម្រេចសេចក្តី។

[1741] *រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងផ្សេងៗ* ទំព័រ ៦០៥។

[1742] សាលក្រម*រឿងក្តី Kupreškić* (ICTY) កថាខណ្ឌ ៦០២ យោងទៅលើ*រឿងក្តី Artuković* (តុលាការថ្នាក់ស្រុក Zagreb Yugoslavia) ទំព័រ ២៣។

[1743] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៦៤។

ដៅនៃការធ្វើទុក្ខបុកម្នេញ ប្រសិនបើពុំធ្វើដូច្នេះទេ ក្រុមដែលស្តែងឱ្យឃើញច្បាស់លាស់ដែលត្រូវបានធ្វើទុក្ខបុកម្នេញដោយ មូលហេតុមិនអាចកំណត់បាន[1744] ពុំអាចត្រូវបានការពារឡើយ។

៦៨០.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយអាចត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុម ប៉ុន្តែមិនមែនប្រឆាំងនឹងសមាជិកនៃក្រុមនយោបាយ ឬអ្នកដែលប្រកាន់ទស្សនៈនយោបាយនោះ។

### ៤.ឃ.៤.ខ.ការយល់ឃើញដែលថា "ប្រជាជនថ្មី" គឺជាក្រុមដែលអាចកំណត់បានច្បាស់លាស់

៦៨១.នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា "ប្រជាជនថ្មី" គឺជាក្រុមនយោបាយ ដោយបានលើកឡើងថា ផ្អែកលើការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង ប្រជាជនថ្មីពុំមែនជាក្រុម"ដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់" និងថា "ប្រជាជនថ្មី"ពុំបានប្រកាន់ទស្សនៈនយោបាយរួមដូចគ្នា ឬពួកគាត់ពុំត្រូវបាន ប.ក.ក. មើលឃើញថា ជាអ្នកប្រឆាំងនយោបាយឡើយ[1745]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសន្និដ្ឋានថា "ប្រជាជនថ្មី" គឺជាក្រុម"ដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់" ដោយបានលើកឡើងថា ការកំណត់និយមន័យលើ"ប្រជាជនថ្មី"របស់អង្គជំនុំជម្រះសាលាដំបូង មានលក្ខណៈផ្ទុយគ្នា និងពុំស៊ីសង្វាក់គ្នា[1746]ឡើយ។

៦៨២.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យយ៉ាងត្រឹមត្រូវ និងស៊ីសង្វាក់គ្នាលើពាក្យថា "ប្រជាជនថ្មី" និងបានយល់ឃើញយ៉ាងត្រឹមត្រូវថា "ប្រជាជនថ្មី" គឺជាក្រុមដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់[1747]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលា

---

[1744] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា តាមស្មារតីនៃច្បាប់ អំពើណាមួយដែលចាត់ទុកជាការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រាដកជាស្រពេចស្រពិលពិបាកយល់។

[1745] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៦៥ ដល់ ៣៨៣។

[1746] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧, ៤៧៩ ដល់ ៤៨២, ៥១២។

[1747] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១៣ ដល់ ២១៤។

ដំបូងបានយល់ឃើញយ៉ាងត្រឹមត្រូវថា "ប្រជាជនថ្មី"ត្រូវបានចាត់ទុកថា ជាខ្មាំង ឬខបសគ្គដល់កម្មវិធីនយោបាយរបស់ខ្មែរក្រហម ដូច្នេះ "ប្រជាជនថ្មី"គឺជាក្រុមនយោបាយ[1748]។

៦៨៣.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ពាក្យពេចន៍ជាច្រើនមកជំនួសសម្រាប់"ប្រជាជនថ្មី" ដូចជា "ប្រជាជន ១៧ មេសា"[1749] និង"ប្រជាជនទីក្រុង"[1750]។ បើទោះបីជាមានភាពស្រពេចស្រពិលបែបនេះ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏នៅតែបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះបានសំដៅទាំងស្រុងទៅលើក្រុមប្រជាជនតែមួយគឺ អ្នកដែលបានរស់នៅក្នុងទីក្រុងភ្នំពេញមកដល់ត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ប្រជាជនថ្មី"បានរួមបញ្ចូលអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បញ្ញវន្ត ម្ចាស់ដី នាយទុន សក្តិភូមិ ព្រមទាំងអនុធនផងដែរ ដែលអ្នកទាំងអស់នេះត្រូវបានចាត់ទុកថា ជាសត្រូវនឹងបដិវត្តន៍សង្គមនិយម[1751]។ យោងតាមអង្គជំនុំជម្រះសាលាដំបូង ពាក្យពេចន៍នេះបានរួមបញ្ចូលអ្នកទីក្រុងទាំងអស់ដែលត្រូវបានចាត់ទុកថា មានសមាសភាព"ពុករលួយ"[1752] ដែលផ្ទុយពី"ប្រជាជនមូលដ្ឋាន"ដែលត្រូវបានសំដៅផងដែរថា ជា"ប្រជាជនចាស់" ឬ"ប្រជាជន ១៨ មេសា"[1753]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ផងដែរថា នៅមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅទៀតនោះ ខ្មែរក្រហមបាន"បង្កឱ្យមានការស្អប់ខ្ពើមចំពោះប្រជាជនទីក្រុង"[1754]។ បន្ថែមលើនេះទៀត នៅក្នុងការពិភាក្សាអំពីមូលហេតុសម្រាប់ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា"ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន មានគោលបំណងពីរ ពោលគឺ ដើម្បីរារាំងសត្រូវមិនឱ្យបង្កអស្ថេរភាពដល់កងកម្លាំង ប.ក.ក. និងរារាំងការធ្វើឱ្យខូចដល់កម្មាភិបាលដោយសារប្រជាជនទីក្រុងផងដែរ"[1755]។ ដូច្នេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញថា ប្រជាជនទីក្រុងទាំងមូលត្រូវបានចាត់ទុកថា ជាការ

---

[1748] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១៥ ដល់ ២២០។

[1749] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧, ៥៦៩, ៥៧១ និង ៦៥០។

[1750] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១២, ៥១៧, ៧៨៧ និង ៨៧៣។

[1751] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៦៩ និង ៦១៣។

[1752] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១២ និង ៨៧៣។

[1753] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧ និង ៨៧៣។

[1754] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧។

[1755] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១២។

គំរាមកំហែងដល់គោលបំណងនយោបាយរបស់ខ្មែរក្រហម និងជាក្រុមអាចកំណត់បានច្បាស់លាស់ដែលរួមបញ្ចូលទាំងប្រជាជនដែលបានរស់នៅក្នុងទីក្រុងជាយូរមកហើយ ទាំងអ្នកដែលមានដើមកំណើតនៅកន្លែងផ្សេងក្នុងប្រទេស ប៉ុន្តែបានស្វែងរកទីជម្រកពីសង្គ្រាមក្នុងអំឡុងពេលឆ្នាំ ១៩៧០ ដល់ ១៩៧៥ ផងដែរ[1756]។

៦៨៤.នួន ជា និង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញភស្តុតាងពុំត្រឹមត្រូវ ដោយហេតុថា ប.ក.ក. បានចាត់ទុកក្រុមមួយក្តាប់តូចប៉ុណ្ណោះដែលមានដូចជា"នាយទុន" "ពួកសក្តិភូមិ" និង"សមាសភាពអាក្រក់"ថា ជាអ្នកប្រឆាំងនឹងបដិវត្តន៍[1757] ដោយមិនបានចាត់ទុកថា "ប្រជាជនថ្មី" ឬអ្នកទីក្រុងទាំងអស់ជាសត្រូវរបស់ ប.ក.ក. ទេ។ ពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញដូចការកត់សម្គាល់របស់សហព្រះរាជអាជ្ញា[1758]ថា ពុំមានភាពចាំបាច់ទេដែលថា សមាជិកទាំងអស់នៃក្រុមដែលត្រូវបានធ្វើទុក្ខបុកម្នេញបានទទួលរងការរើសអើងក្នុងកម្រិតដូចគ្នានោះឡើយ។ ដូចនេះ ពុំមានភាពផ្ទុយគ្នាទេក្នុងការរកឃើញថា ក្រុមមួយក្តាប់តូចនៃ"ប្រជាជនថ្មី"បានទទួលរងការធ្វើទុក្ខបុកម្នេញធ្ងន់ធ្ងរជាងក្រុមដទៃទៀតនោះទេ។ ផ្អែកតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង "ប្រជាជនថ្មី"ជាទូទៅត្រូវបានធ្វើបាបដោយសង្ស័យថា ប្រជាជនទាំងនេះ"*អាច*ផ្តល់ទីកន្លែងជ្រកកោនដល់អ្នកដែលមិនយល់ស្របជាមួយនឹងមនោគមន៍វិជ្ជារបស់ ប.ក.ក."[1759]។

៦៨៥.ពាក់ព័ន្ធទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា ពាក្យពេចន៍"ប្រជាជនថ្មី" ឬ"ប្រជាជន ១៧ មេសា" ត្រូវបានប្រើប្រាស់សម្រាប់តែនៅក្រោយពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញប៉ុណ្ណោះ និងថាពាក្យទាំងនេះពុំត្រូវបានប្រើប្រាស់ដើម្បីកំណត់ថា "ជាក្រុមដែលអាចកំណត់បានច្បាស់លាស់"ដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញនោះឡើយ[1760] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អ្វីដែលសំខាន់នោះ គឺ

---

[1756] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៥៧ ("ចាប់ពីឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧៥ មានការហូរចូលជនភៀសខ្លួនពីជនបទទៅទីក្រុងភ្នំពេញ បានបង្កើនចំនួនប្រជាជននៅទីក្រុងប្រហែលពីកន្លះលាននាក់នៅក្នុងឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧១ រហូតដល់ប្រមាណជាពីរទៅពីរលានកន្លះក្នុងខែ មេសា ឆ្នាំ ១៩៧៥")(ជើងទំព័រលុបចោល)។

[1757] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៧៨ ដល់ ៣៧៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៧៨ ដល់ ៤៨២។

[1758] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១៨។

[1759] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧២ (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១២។

[1760] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៧។

មិនមែនលើបញ្ហាដែលថា ឈ្មោះជាក់លាក់មួយត្រូវបានប្រើប្រាស់នៅក្នុងអំឡុងពេលនៃអង្គហេតុនោះ ដែរ ឬយ៉ាងណានោះទេ ប៉ុន្តែបញ្ហាគឺ ថាតើអ្នកទីក្រុងត្រូវបានធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា។ បញ្ហានេះនឹងត្រូវវាយតម្លៃនៅខាងក្រោម។

៦៨៦.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលបានលើកឡើងដោយ នួន ជា និង ខៀវ សំផន ទាក់ទងទៅនឹងការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពី“ប្រជាជនថ្មី”។

## ៤.ឃ.៤.គ.ការធ្វើទុក្ខបុកម្នេញនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

៦៨៧.នៅពេលកំណត់និយមន័យធាតុផ្សំនៃបទធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា តាមការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថា ទោះបីជា“ចេតនា(រើសអើង)ជាក់លាក់ដែលជាលក្ខខណ្ឌតម្រូវនោះ មិនអាចសន្និដ្ឋានដោយផ្ទាល់ចេញពីលក្ខណៈនៃការរើសអើងជាទូទៅនៃការវាយប្រហារក៏ដោយ ក៏អាចសន្និដ្ឋានចេញពីបរិបទបានដែរ ប្រសិនបើពិចារណាទៅលើអង្គហេតុនៃរឿងក្តី កាលៈទេសៈជុំវិញការប្រព្រឹត្តិបទល្មើសដែលបានចោទប្រកាន់ បញ្ជាក់អំពីអត្ថិភាពនៃចេតនានោះ”[1761] និងថា “‘ការរើសអើងជាការពិត’កើតមានឡើង នៅពេលដែលជនរងគ្រោះដែលត្រូវបានកំណត់គោលដៅ គឺជាសមាជិកនៅក្នុងក្រុមមួយដែលចារីបានកំណត់”[1762]។ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា “ដោយពិចារណាឃើញថា កងទ័ពខ្មែរក្រហមបានស្វែងរកយ៉ាងសកម្មនូវសមាជិកនៃរបបសាធារណរដ្ឋខ្មែរនៅទូទាំងទីក្រុងភ្នំពេញ [...] មុនពេលធ្វើការចាប់ខ្លួន ឬសម្លាប់ពួកគេ និងថា ទាហានទាំងនោះត្រូវបានចាត់ទុកថា ជាខ្មាំង អង្គជំនុំជម្រះជឿជាក់ថា ការចាប់ខ្លួន និងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានប្រព្រឹត្តដោយមានចេតនារើសអើងដោយមូលហេតុនយោបាយ”[1763]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញបន្ថែមទៀតថា “ដោយបានពិចារណាផងដែរ ទៅលើអាកប្បកិរិយារបស់ខ្មែរក្រហមនិងកងទ័ពរបស់ខ្លួនចំពោះប្រជាជនទីក្រុង ភស្តុតាងដែលបញ្ជាក់ពីការរើសអើងដែលថា ប្រជាជនទាំងនោះជា

---

[1761] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤២៩។ យោងទៅលើសាលក្រម *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ៣៧៧។ សាលដីកា *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ២៧២។

[1762] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤២៨ យោងទៅលើសាលដីកា *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ២២៥។

[1763] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧១ (ជើងទំព័រលុបចោល)។

ពួកមូលធននិយម ហើយដោយសារតែអ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ត្រូវបានគេហៅឈ្មោះថា ជា“ប្រជាជន ១៧ មេសា” ឬ“ប្រជាជនថ្មី” និងត្រូវបានគេធ្វើបាប ដោយសារតែមានការសង្ស័យនៅតាមភូមិនានានោះ អង្គជំនុំជម្រះជឿជាក់ថា កងទ័ពខ្មែរក្រហមមានចេតនារើសអើងប្រឆាំងនឹងប្រជាជនទីក្រុង ដែលត្រូវបានជម្លៀសដោយមូលហេតុនយោបាយ។ ផ្អែកទៅលើចំណុចនេះ អង្គជំនុំជម្រះយល់ឃើញថា កងទ័ពខ្មែរក្រហមបានប្រព្រឹត្តដោយមានចេតនារើសអើង នៅពេលធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ”[1764]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា “លើសពីនេះទៀត ក្រុមដែលគេអាចស្គាល់អត្តសញ្ញាណទាំងនេះ ត្រូវបានខ្មែរក្រហមកំណត់ជាគោលដៅដោយសារតែការរើសអើង ដោយលើកឡើងថា ក្រុមទាំងនេះអាចផ្តល់ទីកន្លែងជ្រកកោនដល់អ្នកដែលមិនយល់ស្របជាមួយនឹងមនោគមន៍វិជ្ជារបស់ ប.ក.ក.”[1765]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា “អំពើដែលបានលើកឡើងខាងលើ ក៏មានលក្ខណៈរើសអើងផងដែរ ដោយសារតែជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណនៅតាមប៉ុស្តិ៍ត្រួតពិនិត្យនានា នៅក្នុងអំឡុងពេលនៃការជម្លៀស ទាំងចំពោះមន្ត្រីជាន់ខ្ពស់ និងមន្ត្រីថ្នាក់ក្រោមនៃរបបសាធារណរដ្ឋខ្មែរ(ស៊ីវិល និងយោធា) ក៏ដូចជាប្រជាជនទីក្រុង ផងដែរ”[1766]។

៦៨៨.នួន ជា និង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានយល់ឃើញថា ធាតុផ្សំ*អត្តនោម័ត*សម្រាប់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការរើសអើងជាក់ស្តែង ដែលកើតមានទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[1767]។ ទាក់ទងទៅនឹងធាតុផ្សំ*អត្តនោម័ត*ជាលក្ខខណ្ឌតម្រូវនេះ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងពុំគ្រប់គ្រាន់ក្នុងការយល់ឃើញថា ចេតនារើសអើងត្រូវបានបង្ហាញទាក់ទងទៅនឹង“ប្រជាជនថ្មី” និងថា អង្គជំនុំជម្រះពុំបានកំណត់ត្រឹមត្រូវពីចរិតនៃភស្តុតាងដែលខ្លួនបានសំអាងនៅក្នុងការយល់ឃើញថា ចេតនារើសអើងត្រូវបានបង្ហាញ[1768]។ នួន ជា បានលើកឡើងបន្ថែមទៀតថា លក្ខខណ្ឌតម្រូវអំពីធាតុផ្សំនៃការ

---

[1764] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧១ (ជើងទំព័រលុបចោល)។

[1765] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧២ (ជើងទំព័រលុបចោល)។

[1766] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧២។

[1767] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៤ ដល់ ៣៨៨។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៦៤ ៣៦៥ ដល់ ៣៦៦, ៣៦៨។

[1768] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៤ ដល់ ៣៨៧។

ធ្វើទុក្ខបុកម្នេញ ពុំត្រូវបានបំពេញទាក់ទងទៅនឹងអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ[1769]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញអំពីធាតុផ្សំ *អត្តនោម័ត*លាយឡំគ្នាទាក់ទងទៅនឹងសមាជិករបស់ក្រុមដំបូងចំនួន ២ ដែលខ្លួនបានយល់ឃើញថា ជាអ្នកទទួលរងការធ្វើទុក្ខបុកម្នេញនោះ*ដូចជា* (១) នាយទាហាន និងអ្នករដ្ឋការស៊ីវិលជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និង (២) នាយទាហាន និងអ្នករដ្ឋការស៊ីវិលដទៃទៀតនៃរបបសាធារណរដ្ឋខ្មែរ[1770]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងដែលបានកើតក្រោយអង្គហេតុនោះ នៅពេលយល់ឃើញថា ចេតនារើសអើងមានអត្ថិភាពពាក់ព័ន្ធទៅនឹង"ប្រជាជនថ្មី"[1771]។ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានយល់ឃើញថា ការស្អប់ប្រជាជនទីក្រុង គឺជាកត្តាជំរុញសម្រាប់ការជម្លៀសចេញពីទីក្រុង និងទីប្រជុំជនមួយចំនួន និងថា អង្គជំនុំជម្រះពុំអើពើលើភស្តុតាងដែលប្រជាជនមូលដ្ឋាន និងអ្នកដែលត្រូវបានជម្លៀសអាចរស់នៅ"ដោយចុះសម្រុង"ជាមួយគ្នា បានចែករំលែកស្បៀងអាហារគ្នា និងថា ប.ក.ក. បានចេញសេចក្តីណែនាំ"អំពាវនាវឱ្យមានសាមគ្គីរួបរួមគ្នារវាងក្រុមទាំងពីរនោះ"[1772]។

៦៨៩.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវថា ធាតុផ្សំ *សត្យានុម័ត* និង*អត្តនោម័ត*តម្រូវនៃបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ដោយផ្អែកលើការកំណត់និយមន័យយ៉ាងត្រឹមត្រូវលើធាតុផ្សំនៃបទឧក្រិដ្ឋនេះ[1773]។

៦៩០.ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅពេលដែលអង្គជំនុំជម្រះបានបង្ហាញអត្ថិភាពនៃធាតុផ្សំ*សត្យានុម័ត*នៃការរើសអើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា "ការរើសអើងជាក់ស្តែង"បានកើតឡើង នៅពេលដែលជនរងគ្រោះត្រូវបានកំណត់គោលដៅដោយសារជាសមាជិកក្នុងក្រុមមួយ ដែលចារីបានកំណត់ដោយផ្អែកលើ

---

[1769] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៨។

[1770] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៨។

[1771] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៨។

[1772] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៦៥។

[1773] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២១ ដល់ ២២២។

មូលហេតុជាក់លាក់ ដូចជា មូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ដែលផលវិបាកនៃការរើសអើងនឹងកើតឡើងសម្រាប់ក្រុមនេះ[1774]។

៦៩១.ចំពោះការលើកឡើងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា "ប្រជាជនថ្មី" ត្រូវដាក់ឱ្យទទួលរងការរើសអើងជាក់ស្តែងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយដោយបានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងពាក់ព័ន្ធនោះ[1775] អង្គជំនុំជម្រះតុលាការកំពូលយល់ច្បាស់អំពីអំណះអំណាងចម្បងរបស់ នួន ជា គឺថា "ប្រជាជនថ្មី"ពុំមែនជាសត្រូវរបស់ ប.ក.ក. (ដូច្នេះ ពុំមែនជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ)ឡើយ[1776]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការរើសអើងជាក់ស្តែងលើ"ប្រជាជនថ្មី"នៅក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ស្ថិតនៅត្រង់ការបណ្តេញពួកគេចេញពីទីក្រុងភ្នំពេញរួមជាមួយនឹងការរំលោភលើសិទ្ធិរបស់ពួកគេផងដែរ។ បើទោះបីជា ប្រជាជនក្នុងទីក្រុងភ្នំពេញទាំងមូលត្រូវបានដាក់ឱ្យស្ថិតក្រោមការជម្លៀសក៏ដោយ ក៏នេះពុំមែនមានន័យថា ជាអំពើប្រព្រឹត្តដោយមិនរើសមុខ និងពុំអាចចាត់ជាការធ្វើទុក្ខបុកម្នេញនោះទេ។ ដូចបានបង្ហាញខាងលើនៅក្នុងការយោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ប្រជាជនទីក្រុងទាំងអស់ត្រូវបានចាត់ទុកថា ជា"ប្រជាជនថ្មី"[1777] ជាក្រុមមួយដែលបានរួមបញ្ចូលអ្នកដែលជា"សត្រូវ"ជាក់ស្តែង និងអ្នកដែលប្រឆាំងជាសក្តានុពលទៅនឹងបដិវត្តន៍សង្គមនិយមដោយសារតែបានទៅរស់នៅក្នុងទីក្រុង ព្រមទាំងអ្នកដែលជ្រើសរើសយកជីវិតទីក្រុងដែល"ពុករលួយ"ផ្ទុយពីមនោគមន៍វិជ្ជាផ្នែកនយោបាយរបស់ខ្មែរក្រហម។

៦៩២.ពាក់ព័ន្ធទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា ការសម្លាប់នាយទាហាន និងអ្នករដ្ឋការស៊ីវិលជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរពុំបានកើតឡើងទេ ដូច្នេះពុំអាចចាត់ទុកជាអំពើប្រព្រឹត្តមូលដ្ឋានសម្រាប់ការធ្វើទុក្ខបុកម្នេញនោះ[1778] អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់បួនរូប និងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមួយចំនួនដែលបានធ្វើតាមការអំពាវនាវនោះត្រូវបានបង្ហាញ

---

[1774] សាលដីកា *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ២៧២។

[1775] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៧។

[1776] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៧។

[1777] *សូមមើលខាងលើ* កថាខណ្ឌ ៦៨៣។

[1778] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៨ យោងទៅលើសារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៥៨៨ ដល់ ៥៩៦។

សមហេតុផលដោយអង្គជំនុំជម្រះសាលាដំបូង[1779]។ ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទសម្លាប់រង្គាល និងការផ្លាស់ទីលំនៅដោយបង្ខំ ត្រូវបានប្រព្រឹត្តឡើង និងថា បទឧក្រិដ្ឋទាំងនេះពុំអាចចាត់ជាមូលដ្ឋានសម្រាប់ការយល់ឃើញដែលថា មានការធ្វើទុក្ខបុកម្នេញបានកើតឡើងនោះ[1780] អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងការសម្លាប់រង្គាលក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[1781]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ហេតុការណ៍នៃការសម្លាប់រង្គាល គឺជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនោះ ពុំអាចយកជាការបានឡើយ[1782]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1783]។ អាស្រ័យហេតុនេះ ផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញអាចត្រូវបានចាត់ទុកថាជាអំពើនៃការបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៦៩៣.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងលើការចាប់ខ្លួនទាហាននៃរបបសាធារណរដ្ឋខ្មែរ ធ្វើជាអំពើប្រព្រឹត្តមូលដ្ឋានសម្រាប់បទធ្វើទុក្ខបុកម្នេញ ព្រោះការចាប់ខ្លួននេះជាអំពើត្រឹមត្រូវតាមច្បាប់[1784] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់នូវការរំឭករបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ដីកាដំណោះស្រាយ (D424) ទាក់ទងទៅនឹងអំពើដែលចាត់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនោះបានកត់សម្គាល់ថា “ការចាប់ខ្លួន *និងការសម្លាប់*អ្នករដ្ឋការថ្នាក់ក្រោមនៃ

[1779] *សូមមើលខាងលើ* កថាខណ្ឌ ៤៦៦, ៤៨៦។

[1780] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៦។

[1781] *សូមមើលខាងលើ* កថាខណ្ឌ ៥៤១, ៥៦០។

[1782] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧៤។

[1783] *សូមមើលខាងលើ* កថាខណ្ឌ ៥៦៧ *ជាអាទិ៍*។

[1784] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៨ យោងទៅលើសារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៧៩ ដល់ ៤៨១។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២៤។

01358356



របបសាធារណរដ្ឋខ្មែរត្រូវបានប្រព្រឹត្តឡើងតាមរយៈការធ្វើមនុស្សឃាត និង/ឬការសម្លាប់រង្គាល"[1785]។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងការយល់ឃើញផ្នែកច្បាប់ទាក់ទងទៅនឹងបទធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "ការចាប់ខ្លួន និងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានប្រព្រឹត្តឡើងដោយមានចេតនារើសអើងដោយសារមូលហេតុនយោបាយ"[1786]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាថា ការចាប់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមបញ្ចូលការចាប់ខ្លួនស្របច្បាប់នៃទាហាន) ត្រូវបានចាត់ជាការធ្វើទុក្ខបុកម្នេញឡើយ ប៉ុន្តែបានត្រឹមតែពិចារណាអំពីការចាប់ខ្លួន *និងការសម្លាប់ក្រោយមក*ប៉ុណ្ណោះ។ ដូច្នេះ អំណះអំណាងរបស់ នួន ជា គ្មានមូលដ្ឋានគាំទ្រឡើយ។

៦៩៤.ទាក់ទងទៅនឹងការលើកឡើងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងអំពីការធ្វើបាបអ្នកដែលត្រូវបានជម្លៀសនៅក្នុងភូមិ ដើម្បីបង្ហាញពីចេតនារើសអើងលើ"ប្រជាជនថ្មី"ក្នុងអំឡុងពេលនៃការជម្លៀស អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដើម្បីគាំទ្រការយល់ឃើញទាក់ទងទៅនឹងចេតនារើសអើងនេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញមួយពាក់ព័ន្ធទៅនឹងការធ្វើបាបធ្ងន់ធ្ងរលើអ្នកដែលត្រូវបានជម្លៀសក្នុងអំឡុងពេលនៃការជម្លៀស ព្រមទាំងនៅពេលទៅដល់ភូមិពីសំណាក់អ្នកភូមិនិងកងទ័ពខ្មែរក្រហម[1787]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អ្នកដែលត្រូវបានជម្លៀស ត្រូវបាន "សង្ស័យថា ជាពួកនាយទុន ឬសក្តិភូមិ និងត្រូវបានគេគេចមុខពុំចង់ជួប និងត្រូវបានដេញឱ្យទៅមុខទៀត" និងថា "អ្នកដទៃទៀតក្រោយមកបានទទួលបញ្ជាឱ្យចាកចេញ ឬរើចេញទៅកន្លែងផ្សេង"[1788]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា នៅមុនពេលជម្លៀស ខ្មែរក្រហមបាន"បង្កើតឱ្យមានការស្អប់ខ្ពើមអ្នកទីក្រុង"[1789]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ផ្ទុយទៅនឹងអំណះអំណាងដែលបានលើកឡើងដោយ នួន ជា និង ខៀវ សំផន[1790]សម្រាប់គោលបំណងនៃការបង្ហាញពីចេតនារើសអើង អាកប្បកិរិយានៅមុន

---

[1785] សាលក្រមរបស់អង្គជំនុំជុំម្រះសាលាដំបូង កថាខណ្ឌ ៥៦៨ (សេចក្តីបញ្ជាក់បន្ថែម ដើងទំព័រលុបចោល) យោងទៅលើដីកាដំណោះស្រាយ (D427) ថាខណ្ឌ ២០៨, ២០៩, ២៣៥។

[1786]សាលក្រមរបស់អង្គជំនុំជុំម្រះសាលាដំបូង កថាខណ្ឌ ៥៧១ (សេចក្តីបញ្ជាក់បន្ថែម)។

[1787] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧។

[1788] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧។

[1789] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧។

[1790] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៥។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៨។

ពេល និងក្រោយពេលដែលអំពើនោះបានកើតឡើងភ្លាមៗ អាចត្រូវបានយកមកពិចារណាផងដែរ ដោយសារអាកប្បកិរិយានេះ អាចបង្ហាញឱ្យឃើញពីផ្នត់គំនិតរបស់ចារីនៅក្នុងអំឡុងពេលនៃអង្គហេតុ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងនៃការប្រើអំពើហិង្សាលើរូបកាយពីសំណាក់កងទ័ពខ្មែរក្រហមទៅលើអ្នកដែលត្រូវបានជម្លៀស[1791]បន្ថែមលើការគំរាមកំហែង និងការគាបសង្កត់ផ្លូវចិត្ត[1792]ទាំងក្នុងពេល និងក្រោយពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្លាមៗនោះ។

៦៩៥.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើការយល់ឃើញដែលថា "ប្រជាជនថ្មី"ត្រូវបាន"សង្ស័យនៅតាមមូលដ្ឋាន"[1793]ដោយអ្នកផ្សេង ជាជាងកងទ័ពខ្មែរក្រហមនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្នុងការបង្ហាញអំពីចេតនារើសអើងតម្រូវសម្រាប់ការធ្វើទុក្ខបុកម្នេញ គឺមានតែអាកប្បកិរិយារបស់ចារីប៉ុណ្ណោះដែលជាប់ពាក់ព័ន្ធ។ ទោះជាយ៉ាងណាក្តី ដោយសារបញ្ហានេះជាប់ពាក់ព័ន្ធទៅនឹងទិដ្ឋភាពនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលរួមបញ្ចូលការប្រព្រឹត្តអំពើរើសអើងលើ"ប្រជាជនថ្មី"ដោយកងទ័ព និងកម្មាភិបាលខ្មែរក្រហម[1794] ចំណុចនេះពុំចោទជាបញ្ហាចំពោះភាពសមហេតុផលនៃការសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងអត្ថិភាពនៃចេតនារើសអើងប្រឆាំងនឹង"ប្រជាជនថ្មី" និងការរើសអើងជាក់ស្តែងឡើយ។

៦៩៦.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញពីភាពខុសគ្នាឱ្យឃើញច្បាស់លាស់រវាងចេតនារើសអើង មួយផ្នែកទាក់ទងទៅនឹងនាយទាហាន និងអ្នករដ្ឋការស៊ីវិលជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងមួយផ្នែកទៀតទាក់ទងទៅនឹង"ប្រជាជនថ្មី"នោះឡើយ[1795]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំឃើញមានមូលហេតុអ្វីដែលកាលៈទេសៈជុំវិញការប្រព្រឹត្តអំពើជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញនោះ ពុំអាចយកមកប្រើដើម្បីបង្ហាញចេតនារើសអើងទៅលើក្រុមលើសពីមួយនោះទេ ពីព្រោះអំពើប្រព្រឹត្តធ្វើទុក្ខបុកម្នេញនេះពុំមានកម្រិត ឬប្រភេទដូចគ្នាទៅ

---

[1791] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧១ ដល់ ៤៧៤, ៤៨៩ ដល់ ៤៩០។

[1792] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៥, ៤៨១, ៤៨៩ និង ៥១៧។

[1793] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧១ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧។

[1794] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥១៧ ជើងទំព័រ ១៥៤៨ ដល់ ១៥៥០។

[1795] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៦៨។

នឹងការរើសអើងឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដោយសារពុំមានមូលដ្ឋានគាំទ្រចំពោះការអះអាងរបស់ខ្លួន។

៦៩៧.ជាសរុបសេចក្តី អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បទធ្វើទុក្ខបុកម្នេញត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។

### ៤.ឃ.៤.ឃ.ការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៦៩៨.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការផ្លាស់ទីលំនៅបានធ្វើឡើងដើម្បីសម្រេចគោលដៅនៃការផលិត[1796] និងថា ដោយគ្មានការបែងចែករវាង "ប្រជាជនថ្មី" និង"ប្រជាជនមូលដ្ឋាន" "ប្រជាជនថ្មី"ត្រូវបាន"ផ្តល់ហេតុផលផ្សេងៗសម្រាប់ការផ្លាស់ទីលំនៅ" ដូចជា ពុំមានស្បៀងអាហារគ្រប់គ្រាន់នៅក្នុងទីកន្លែងកំពុងស្នាក់នៅថា ពួកគេត្រូវបានបញ្ជូនត្រឡប់ទៅផ្ទះសម្បែងរបស់ខ្លួនវិញ ព្រមទាំងថា "ប្រជាជនផ្សេងទៀតយល់ថា ការនៅក្បែរព្រំប្រទល់ប្រទេសថៃអាចជួយសម្រួលក្នុងការរត់គេចខ្លួនពីខ្មែរក្រហម"[1797]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា "នៅតាមកន្លែងជាច្រើនមានតែ*ប្រជាជនថ្មី*ប៉ុណ្ណោះដែលត្រូវបានបង្ខំឲ្យផ្លាស់ទីលំនៅ រីឯនៅតាមកន្លែងខ្លះទៀត ទាំង*ប្រជាជនចាស់*និង*ប្រជាជនថ្មី*ត្រូវបានផ្លាស់ទីលំនៅ"[1798]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ការផ្លាស់ទីលំនៅទាំងប្រជាជនចាស់ និងប្រជាជនថ្មីនេះ បានកើតឡើងដោយសារមូលហេតុជាក់លាក់ថា ដោយសារការមិនទុកចិត្តចំពោះប្រជាជនទាំងអស់ដែលរស់នៅក្នុងភូមិភាគបូព៌ាតាមបណ្តោយព្រំដែនជាប់ប្រទេសវៀតណាម ឬដោយសារការជំរុញរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្រេចគោលដៅសម្រាប់ការបង្កបង្កើនផលរបស់ពួកគេ"[1799]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នៅមុនពេល ឬក្នុងពេលជម្លៀស ប្រជាជនត្រូវបានសួរសំណួរអំពីប្រវត្តិរបស់ខ្លួន លទ្ធផលនៃការសួរនេះ"ញឹកញាប់ គឺដើម្បីកំណត់ទីតាំងដែលត្រូវបញ្ជូនប្រជាជនទាំងនេះទៅ រួមទាំង ទៅកាន់តំបន់ព្រៃដែលប្រជាជនទាំងនោះត្រូវទៅកាប់ឆ្ការ និងសង់ទីជម្រករបស់ពួកគេដោយ

---

[1796] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧៦ ដល់ ៦០២។

[1797] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៨៩។

[1798] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៥។

[1799] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៥។

ផ្ទាល់ខ្លួន។ "ប្រជាជនថ្មី"ផ្សេងទៀតត្រូវបានយកទៅកសាង ឬអប់រំកែប្រែនៅតាមមន្ទីរសន្តិសុខនានា"[1800]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា កងទ័ព និងកម្មាភិបាលខ្មែរក្រហម មានចេតនារើសអើងដែលជាលក្ខខណ្ឌតម្រូវ[1801]។

៦៩៩.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញអំពីអត្ថិភាពនៃធាតុផ្សំ *អត្តនោម័ត*តម្រូវសម្រាប់ការធ្វើទុក្ខបុកម្នេញ និងការរើសអើងជាក់ស្តែង ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[1802]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន ក៏បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ប្រជាជនថ្មី"ប្រឈមនឹងការរើសអើងជាក់ស្តែង ដោយបានអះអាងថា ពុំមានភស្តុតាងបង្ហាញពីចេតនារើសអើងប្រឆាំងនឹង"ប្រជាជនថ្មី" នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរឡើយ[1803]។

៧០០.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយត្រឹមត្រូវអំពីអត្ថិភាពនៃធាតុផ្សំនៃអំពើធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដោយបានសំអាងទៅលើភស្តុតាងគ្រប់គ្រាន់ រួមទាំងភស្តុតាងប្រយោលផងដែរ ដើម្បីគាំទ្រតាមបរិបទសម្រាប់ការយល់ឃើញរបស់ខ្លួនដែលស្ថិតក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ[1804]។

៧០១.ផ្អែកតាមអង្គជំនុំជម្រះសាលាដំបូង "ប្រជាជនថ្មី"[1805] គឺជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ផ្អែកតាមវិសាលភាពនៃសំណុំរឿង ០០២/០១ អំពើប្រព្រឹត្តតែមួយដែលត្រូវបានយកមកពិចារណាក្នុងការផ្តល់ការយល់ឃើញអំពីធាតុផ្សំ*សត្យានុម័ត*នៃបទធ្វើទុក្ខបុកម្នេញ នៅក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរនោះ គឺការផ្លាស់ទីលំនៅជាក់ស្តែងរបស់ប្រជាជនប៉ុណ្ណោះ ពុំមែនអ្វីដែលបានកើតឡើង

---

[1800] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៥ (ជើងទំព័រលុបចោល)។

[1801] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៦។

[1802] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៨៩ ដល់ ៣៩៤ និង ៣៩៩។

[1803] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៨៣, ៤៨៦ ដល់ ៤៨៩ និង ៤៩១។

[1804] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២៣ ដល់ ២២៨។

[1805] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៦ និង ៦៥៧។

ចំពោះពួកគេនៅពេលទៅដល់កន្លែងដែលត្រូវផ្លាស់ទៅនោះទេ[1806]។ ដូច្នេះ ដើម្បីបង្ហាញអំពីការធ្វើទុក្ខបុកម្នេញលើ"ប្រជាជនថ្មី"ដូចមាននៅក្នុងសំណុំរឿងបច្ចុប្បន្ន ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ការផ្លាស់ទីលំនៅប្រជាជនបានធ្វើឱ្យប៉ះពាល់យ៉ាងហោចណាស់ជាចម្បង ឬតែ"ប្រជាជនថ្មី"ប៉ុណ្ណោះ ដូច្នេះ គឺជាការរើសអើង ឬថា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ"ប្រជាជនថ្មី"បានទទួលរងការប្រព្រឹត្តខុសប្លែកពី"ប្រជាជនចាស់"។

៧០២.ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួន[1807]ថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំសមហេតុផលថា "ប្រជាជនភាគច្រើនលើសលុប"ដែលត្រូវបានផ្លាស់ទីលំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ គឺជា"ប្រជាជនថ្មី"ដោយសារភស្តុតាងតិចតួចគាំទ្រការសន្និដ្ឋាននេះ[1808]។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងភស្តុតាងដែលបានយកមកសំអាងនោះឃើញថា ការផ្លាស់ទីលំនៅប្រជាជនដោយសារមូលហេតុសេដ្ឋកិច្ច និងចេញពីព្រំដែនវៀតណាមពាក់ព័ន្ធទាំងប្រជាជន*ចាស់* ទាំង*ថ្មី* ដែលជាការពិតមួយត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់របស់ខ្លួន[1809]។ ដោយសារការផ្លាស់ទីលំនៅនេះបានប៉ះពាល់មិនត្រឹមតែប្រជាជន*ថ្មី* ដូច្នេះពុំអាចនិយាយបានថា ជាការរើសអើងជាក់ស្តែង ឬបង្ហាញពីចេតនារើសអើងឡើយ។

៧០៣.បន្ថែមលើនេះ ទាក់ទងទៅនឹងការធ្វើឱ្យបាត់ខ្លួនក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដែលជាអំពើរើសអើងដែលប៉ះពាល់លើ"ប្រជាជនថ្មី"អង្គជំនុំជម្រះតុលាការកំពូលទទួលយកអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា "ក្រោយពេលត្រូវបានផ្លាស់ទីលំនៅ មាន"ប្រជាជនថ្មី"ជាច្រើនត្រូវបានធ្វើឱ្យបាត់ខ្លួន"[1810] ដោយបានសំអាងទៅលើសក្ខីកម្មទូទៅរបស់សាក្សីតែម្នាក់ប៉ុណ្ណោះ[1811]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ប្រជាជនថ្មី"ត្រូវបានធ្វើឱ្យបាត់ខ្លួនក្នុងអំឡុងពេលនៃ

---

[1806] *សូមមើលខាងលើ* កថាខណ្ឌ ២៣០ *ជាអាទិ៍*។

[1807] *សូមមើលខាងលើ* កថាខណ្ឌ ៦៣៣។

[1808] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣១។

[1809] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៤។

[1810] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦១៤ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៣៥ និង ៤១, ៤២។

[1811] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៤ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៣៥, ៤១ ដល់ ៤២។ នៅក្នុងទំព័រ ៣៥ នូ ម៉ៅ បានផ្តល់សក្ខីកម្មថា នៅពេលជម្លៀសខុដុង្គ"ប្រជាជនខ្លះត្រូវបានធ្វើឱ្យបាត់ខ្លួនដោយអាថ៌កំបាំង"។ នៅទំព័រ ៤១ ដល់ ៤២ នូ ម៉ៅ ពុំបានរៀបរាប់អំពីការធ្វើឱ្យបាត់ខ្លួន"ប្រជាជនថ្មី"ឡើយ។

ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរក៏ដោយ[1812] ក៏ការយល់ឃើញទាំងនេះបានផ្អែកលើភស្តុតាងមិនគ្រប់គ្រាន់ដែលជាមូលដ្ឋានក្នុងការបង្ហាញពីការធ្វើឱ្យបាត់ខ្លួន"ប្រជាជនថ្មី" *ជាច្រើន*ដែលត្រូវបានជម្លៀសនោះ។ ដូច្នេះ ការធ្វើឱ្យបាត់ខ្លួនប្រជាជនថ្មី ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ពុំអាចជាមូលដ្ឋានសម្រាប់ការយល់ឃើញអំពីការរើសអើងជាក់ស្តែង ឬចេតនារើសអើងឡើយ។

៧០៤.បន្ថែមលើនេះទៀត ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសួរសំណួរ"ប្រជាជនថ្មី""ជាញឹកញាប់ដើម្បីកំណត់ទីកន្លែងដែលត្រូវបញ្ជូនទៅនៅនោះ"[1813] អង្គជំនុំជម្រះតុលាការកំពូលទទួលយកការលើកឡើងរបស់ នួន ជា ដែលថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងពាក់ព័ន្ធទៅនឹងបញ្ហានេះ ពុំគ្រប់គ្រាន់សម្រាប់គាំទ្រសេចក្តីសន្និដ្ឋាននេះឡើយ[1814]។ បើទោះបីជាការសមហេតុផលដែលអាចសន្និដ្ឋានថា ប្រជាជនត្រូវបានសួរពីប្រវត្តិរបស់ខ្លួន"នៅមុន ឬក្នុងពេលនៃការផ្លាស់ទីលំនៅ"[1815] ដោយផ្អែកលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1816]ក៏ដោយ ក៏ភស្តុតាងជាច្រើនបង្ហាញឱ្យឃើញថា ការសួរសំណួរបានកើតឡើង*នៅក្រោយ*ការផ្លាស់ទីលំនៅប្រជាជន[1817]ដូចការអះអាងរបស់ នួន ជា[1818]ដែរ។ យោងតាមហេតុផលទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកលើភស្តុតាងតិចតួចថា ការសាកសួរពីប្រវត្តិរូបរបស់"ប្រជាជនថ្មី"ជាញឹកញាប់មានការប៉ះពាល់ទៅលើទីកន្លែងដែលត្រូវបញ្ជូនពួកគេទៅ ដែលអាចបង្ហាញនូវអត្ថិភាពនៃការរើសអើងជាក់ស្តែងនោះឡើយ។

---

[1812] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦១៨, ៦២៣ និង ៦២៥។

[1813] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦០០ ដល់ ៦០១, ៦១៧។

[1814] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩២ ដល់ ៣៩៣។

[1815] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៥។

[1816] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៥៥ ជើងទំព័រ ២០៥៧ យោងទៅលើកថាខណ្ឌ ៦០០ ដល់ ៦០១, ៦១៧។

[1817] ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ២៧ ដល់ ២៨ (ត្រូវបានសួរនូវអ្វីដែលគាត់បានធ្វើក្នុងទីក្រុងភ្នំពេញបន្ទាប់ពីបានមកដល់សហករណ៍កោះជុំ)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជា សុវត្ថា ឯកសារលេខ E3/5084 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00865605 ទំព័រ ១១ (ត្រូវបានសួរនូវព័ត៌មាន ក្រោយពេលការផ្លាស់ទីលំនៅពីខេត្តកណ្តាលទៅបាត់ដំបង)។

[1818] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៩៣។

01358362



៧០៥.យោងតាមខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំអាចនិយាយបានថា មានការបង្ហាញឱ្យឃើញថា ការផ្លាស់ទីលំនៅប្រជាជនត្រូវបានធ្វើឡើងក្នុងលក្ខណៈរើសអើង ឬដោយចេតនារើសអើង។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើភស្តុតាងសំខាន់ៗនៃការតស៊ូវណ្ណៈរបស់ ប.ក.ក. ប្រឆាំងនឹង"ប្រជាជនថ្មី" ក្នុងអំឡុងពេលជាប់ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[1819] និងដោយកត់សម្គាល់ថា អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាសត្រូវចម្បងរបស់បក្សក៏ដោយ[1820] ក៏ការយល់ឃើញទាំងនេះបង្ហាញជាចម្បងថា ចេតនាទូទៅក្នុងការរើសអើងប្រឆាំងនឹង"ប្រជាជនថ្មី"ដែលត្រូវបានបង្ហាញតាមរយៈការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះបានបន្តដែរ។ ទោះជាយ៉ាងនេះក្តី ដោយហេតុថា ការផ្លាស់ទីលំនៅប្រជាជនដែលជាចម្បងសម្រាប់គោលបំណងសេដ្ឋកិច្ច ទំនងជាការអនុវត្តន៍ទូទៅដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនគ្រប់ផ្នែកនោះ ទើបការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរពុំមែនជាការរើសអើង ឬកើតចេញពីចេតនាធ្វើទុក្ខបុកម្នេញ។ យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ប្រជាជនត្រូវបានផ្លាស់ទីលំនៅដើម្បីជំរុញការតស៊ូវណ្ណៈ"[1821] ពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ឡើយ។

៧០៦.សរុបសេចក្តីមក ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ គឺជាបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានចាត់ទុកជាបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ ដូចនេះអង្គជំនុំជម្រះសាលាដំបូងមានកំហុស។

## ៤.ឃ.៥.ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៧០៧.នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានតែអំពើជាមូលដ្ឋានមួយចំនួនដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ប៉ុណ្ណោះ ដែលអាចចាត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើបានបំពេញតាមលក្ខខណ្ឌតម្រូវ*តាមបរិបទ* ដែលមានដូចជា៖ "(i) ត្រូវតែមានការវាយប្រហារ (ii) ការវាយប្រហារត្រូវតែមានលក្ខណៈទូទៅ ឬជាប្រព័ន្ធ (iii) ការវាយប្រហារសំដៅលើប្រជាជនស៊ីវិល (iv) ការវាយ

---

[1819] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៩២៣, ១៩២៥ ដល់ ១៩២៩។

[1820] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦១៣។

[1821] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦១៣។

ប្រហារត្រូវតែធ្វើឡើងដោយសារមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ (v) ត្រូវតែមានទំនាក់ទំនងរវាងអំពើរបស់ចារីផ្ទាល់ជាមួយនឹងការវាយប្រហារ និង (vi) ជនជាប់ចោទ ឬចារី ត្រូវមានការដឹងជាចាំបាច់អំពីការវាយប្រហារ"[1822]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា និយមន័យនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ ១៩៧៥ លែងតម្រូវឱ្យមាន"ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធទៀតហើយ"[1823]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការវាយប្រហារបានរួមបញ្ចូលនូវអំពើ"ដែលជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តអំពើហិង្សាជាបន្តបន្ទាប់ [...] ហើយមិនកម្រិតត្រឹមតែការប្រើកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះទេ"[1824] និងថា សម្រាប់ការវាយប្រហារជាលក្ខណៈទូទៅ ឬជាប្រព័ន្ធ ជាទូទៅ គឺសំដៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ ឬមានការរៀបចំ និងមានអំពើល្មើសដោយចេតនាដែលមានលំនាំប្រហាក់ប្រហែលគ្នា[1825]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ផ្អែកតាមនិយមន័យនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំចាំបាច់តម្រូវឱ្យមានការប្រព្រឹត្តឡើងស្របទៅនឹង"គោលនយោបាយ ឬផែនការរបស់រដ្ឋ ឬអង្គការណាមួយ"ឡើយ[1826]។ ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវដែលថា ការវាយប្រហារត្រូវតែសំដៅទៅលើប្រជាជនស៊ីវិលណាមួយនោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ប្រជាជនដែលត្រូវបានកំណត់គោលដៅ ត្រូវតែជាគោលដៅចម្បងនៃការវាយប្រហារ និងជាជនស៊ីវិលពិតប្រាកដ[1827]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទាហាន*ដែលបាត់បង់សមត្ថភាពប្រយុទ្ធ* ពុំអាចចាត់ទុកជា ជនស៊ីវិលសម្រាប់គោលបំណងក្នុងការវាយតម្លៃ ថាតើមួយណាជាជនស៊ីវិលដែលជាកម្មវត្ថុនៃការវាយប្រហារនោះឡើយ[1828]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការវាយប្រហារ"ត្រូវតែបានធ្វើឡើងប្រឆាំងនឹងជនស៊ីវិលដោយ

---

[1822] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៧ យោងទៅលើសាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១០៦។

[1823] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៧ យោងទៅលើសាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៩១ ដល់ ២៩២។

[1824] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៨។

[1825] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៩។

[1826] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨១។

[1827] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨២ ដល់ ១៨៣។

[1828] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨៦។

ផ្អែកលើមូលដ្ឋានរើសអើង ដូចជា មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"[1829]។ ជាចុងក្រោយពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា អំពើរបស់ចារី"ត្រូវតែជាផ្នែកមួយនៃការវាយប្រហារ" ដែលមានន័យថា ទោះបីជាអំពើនោះជាអំពើប្រភេទណា ឬមានផលវិបាកយ៉ាងណាក៏ដោយ ក៏ជាសត្យានុម័តត្រូវតែជាផ្នែកនៃការវាយប្រហារ[1830] និងថា ជនជាប់ចោទ ឬចារីត្រូវតែបានដឹងឮអំពីការវាយប្រហារ និងថា អំពើរបស់ខ្លួនបង្កើតបានជាផ្នែកនៃការវាយប្រហារនោះ[1831]។

៧០៨.នៅក្នុងការយល់ឃើញផ្នែកអង្គច្បាប់របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួនជឿជាក់ចំពោះលក្ខខណ្ឌនៃធាតុផ្សំតាមបរិបទទាំងអស់ត្រូវបានបំពេញ[1832] ដោយបានសន្និដ្ឋានថា ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ យ៉ាងហោចណាស់រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ មានការវាយប្រហារជាប្រព័ន្ធ និងទូទៅ[1833]ទៅលើប្រជាជនស៊ីវិលកម្ពុជា[1834]ដែលធ្វើឡើងដោយមូលហេតុនយោបាយ[1835]និងថា ការវាយប្រហារមានទំនាក់ទំនងជាមួយនឹងអំពើរបស់ នួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរថា ជនជាប់ចោទបានដឹងអំពីការវាយប្រហារនេះ និងថា អំពើរបស់ជនជាប់ចោទ គឺជាផ្នែកមួយនៃការវាយប្រហារ[1836]។

៧០៩.នួន ជា និង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសមួយចំនួនទាក់ទងទៅនឹងធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទីមួយ នួន ជា និង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការយល់ឃើញថា នៅត្រឹមឆ្នាំ ១៩៧៥ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លែងតម្រូវឱ្យមានការបង្ហាញអំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធទៀតហើយ

---

[1829] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨៨។

[1830] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩០។

[1831] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩១។

[1832] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៨។

[1833] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៣។

[1834] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៤។

[1835] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៥។

[1836] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៧។

[1837]។ ទីពីរ បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការយល់ឃើញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំបានតម្រូវឱ្យបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋឡើយ[1838] ហើយចុងក្រោយ បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការយល់ឃើញថា អំពើរបស់ពួកគាត់មានទំនាក់ទំនងជាមួយនឹងការវាយប្រហារជាប្រព័ន្ធ និងទូទៅលើប្រជាជនស៊ីវិលដោយមូលហេតុនយោបាយនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[1839]។ ផ្អែកលើកំហុសដែលបានលើកឡើងទាំងនេះ នួន ជា និង ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមោឃៈការសម្រេចដាក់ពិរុទ្ធភាពលើពួកគាត់ពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងសុំឱ្យរួចផុតពីបទចោទទាំងនេះ[1840]។

៧១០.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ពុំបានតម្រូវឱ្យមាន“ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ”[1841]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះ និងបានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយយ៉ាងត្រឹមត្រូវលើធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) និងសេចក្ដីសម្រេចរបស់តុលាការយោធា Nuremberg ក្នុងការយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំបានតម្រូវឱ្យបង្ហាញពីអត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋនោះទេក្នុងឆ្នាំ ១៩៧៥[1842]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានឆ្លើយតបថា

---

[1837] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦៧ ដល់ ៤៧៣។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥២ ដល់ ៥៤ និង ៣៣៣។

[1838] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៤។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៥ ដល់ ៥៨ និង ៣៣៣។

[1839] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៥ ដល់ ៤៨៣។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣០ ដល់ ៣៤០ និង ៣៥៨។

[1840] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៣ និង ៧៣០។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៤, ៥៨, ៣៥៨ និង ៦៥៩។

[1841] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២៦ ដល់ ១២៨។

[1842] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣១។

អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងត្រឹមត្រូវថា មានការវាយប្រហារជាប្រព័ន្ធនិងជាទូទៅបានកើតឡើងដោយសារមូលហេតុនយោបាយ[1843]។

## ៤.ឃ.៥.ក.ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ

៧១១.ទាក់ទងទៅនឹងអំណះអំណាងទីមួយ ដែលបានលើកឡើងថា ក្នុងឆ្នាំ ១៩៧៥ ការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យបង្ហាញពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធពុំមែនជាផ្នែកមួយក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឡើយ"[1844]។ នៅក្នុងសេចក្តីសម្រេចដំបូងស្តីពីកម្មវត្ថុ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ហេតុផលថា៖

> ក្រោយពីបានពិនិត្យមើលឡើងវិញលើការអនុវត្តរបស់រដ្ឋ និងសច្ចធារណ៍ធម្មានុរូប ដែលមានការពាក់ព័ន្ធនៅចន្លោះពីឆ្នាំ ១៩៤៥ ដល់ឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ចាប់តាំងពីការកកើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងធម្មនុញ្ញ (IMT) និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ យើងឃើញមាននិន្នាការសំខាន់មួយរួចហើយ នៃការមិនដាក់លក្ខខណ្ឌតម្រូវទំនាក់ទំនងឧក្រិដ្ឋកម្មទាំងនេះជាមួយនឹងជម្លោះប្រដាប់អាវុធ។ និន្នាការនេះគឺថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដោយមិនជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ បានចាប់ផ្តើមវិវឌ្ឍន៍ខ្លាំងនៅក្រោយសម័យ Nuremberg ហើយរហូតបានបង្កើតជាច្បាប់ដោយមានការឯកភាពមួយនៅត្រឹមឆ្នាំ ១៩៧៥ [1845]។

៧១២.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) និងគោលការណ៍ Nuremberg ពុំបានយោងទៅលើលក្ខខណ្ឌតម្រូវ"ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ"ឡើយ។ ផ្ទុយទៅវិញ គោលការណ៍ Nuremberg បានបញ្ជាក់ថា អំពើដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែ

---

[1843] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣២ ដល់ ១៣៦។

[1844] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៧ រំឭកឡើងវិញ និងទទួលយកសេចក្តីសម្រេចលើសំណើសុំដកលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ (E95/8) កថាខណ្ឌ ៣៣។

[1845] សេចក្តីសម្រេចលើសំណើសុំដកលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (E95/8) កថាខណ្ឌ ៣៣។

"មានការប្រព្រឹត្តឡើង ឬទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមណាមួយ"[1846] ដោយបានដាក់បញ្ចូលនូវពាក្យពេចន៍ដែលមាននៅក្នុងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ (IMT)[1847]។ លក្ខខណ្ឌតម្រូវនេះមានភាពស្មុគស្មាញជាងលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ដោយសារតម្រូវឱ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ជាមួយនឹងឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀតដែលជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព[1848]។ អាស្រ័យហេតុនេះ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលគឺ ថាតើត្រឹមឆ្នាំ ១៩៧៥ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានទំនាក់ទំនងនេះ ដែរ ឬយ៉ាងណា។

៧១៣.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទាក់ទងទៅនឹងបញ្ហានេះ លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) អាចត្រូវបានយល់ឃើញពីរយ៉ាងផ្សេងគ្នា ទីមួយជាធាតុផ្សំសត្យានុម័តក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬម្យ៉ាងទៀត គ្រាន់តែជាធាតុផ្សំយុត្តាធិការដែលកម្រិតសមត្ថកិច្ចរបស់តុលាការយោធាអន្តរជាតិ (IMT) ត្រឹមបទឧក្រិដ្ឋទាំងនោះនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព។ បើទោះបីជាសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ពុំបានដោះស្រាយបញ្ហានេះច្បាស់លាស់ក៏ដោយ ក៏នៅក្នុងផ្នែកផ្សេងៗទៀតនៃសាលក្រមនេះបានបញ្ជាក់ថា តុលាការយោធាអន្តរជាតិ (IMT) បានបកស្រាយលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងថា ជាធាតុផ្សំសត្យានុម័តដើម្បីកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

---

[1846] គោលការណ៍ទី VI(គ) នៃគោលការណ៍ Nuremberg។

[1847] មាត្រា ៦(គ) នៃធម្មនុញ្ញភាពរបស់តុលាការឧក្រិដ្ឋកម្ម IMT។

[1848] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការប្រើពាក្យពេចន៍ជារួមនៃ"លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ" គឺទាញចេញពីមាត្រា ៥ នៃលក្ខន្តិកៈតុលាការ ICTY។ លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនេះត្រូវបានបកស្រាយក្នុងន័យត្រឹមតែតម្រូវឱ្យបង្ហាញថា ជម្លោះប្រដាប់អាវុធមានអត្ថិភាពនាពេលនោះ និងដាក់ឱ្យមានការទាក់ទងគ្នាសម្រាប់ការចោទប្រកាន់ប៉ុណ្ណោះ មិនមែនជាការបង្ហាញអំពីទំនាក់ទំនងជាសត្យានុម័តរវាងអំពើរបស់ជនជាប់ចោទ និងឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀតដែលអាច ឬពុំអាចត្រូវបានប្រព្រឹត្តឡើងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដែលកំពុងកើតមាននោះឡើយ។ ដូច្នេះ មិនដូចគ្នាទៅនឹងលក្ខខណ្ឌតម្រូវទំនាក់ទំនងដែលមាននៅក្នុងគោលការណ៍ Nuremberg ឡើយ។ *សូមមើល* សាលដីកា *រឿងក្តី Kunarac* (ICTY) កថាខណ្ឌ ៨៣។ សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២៤៩, ២៥១។ ដូច្នេះ លក្ខខណ្ឌតម្រូវទំនាក់ទំនងក្នុងលក្ខន្តិកៈរបស់តុលាការ ICTY ពុំដូចគ្នាទៅនឹងលក្ខខណ្ឌតម្រូវនៅក្នុងគោលការណ៍ Nuremberg ឡើយ។

ជាតិតាមច្បាប់អន្តរជាតិ[1849]។ ជាការកត់សម្គាល់ នៅពេលធ្វើការសម្រេចដាក់ពិរុទ្ធភាពទាក់ទងទៅនឹងជនជាប់ចោទមួយចំនួន តុលាការយោធាអន្តរជាតិ (IMT) បានយកលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងមកធ្វើជាផ្នែកមួយនៃការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយបានពិចារណាឃើញថា មានតែអំពើដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មផ្សេងទៀតនៅក្នុងយុត្តាធិការរបស់ខ្លួនប៉ុណ្ណោះ ដែលអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1850]
។

៧១៤.ទោះជាយ៉ាងណាក្តី នៅក្រោយពេលបញ្ចប់សង្គ្រាមលោកលើកទីពីរភ្លាម លក្ខណៈពិតប្រាកដនៃលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងមិនថា ជាយុត្តាធិការ ឬជាសត្យានុម័តនោះទេ ពុំមានភាពច្បាស់លាស់ឡើយ។ ជាពិសេស ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងដែលត្រូវបានអនុម័តត្រឹមតែបួនខែបន្ទាប់ពីការអនុម័តធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ពុំបានដាក់បញ្ចូលលក្ខខណ្ឌអំពីទំនាក់ទំនងក្នុងការកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1851]។ ទន្ទឹមនឹងនោះដែរ ផ្អែកតាមបុព្វកថានៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ច្បាប់នេះបានបង្កើតឡើងក្នុងគោលបំណងផ្តល់អានុភាពដល់ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) (បានរួមបញ្ចូលលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង)[1852]។

---

[1849] *សូមមើល* សាលក្រមរបស់តុលាការ IMT ទំព័រ ២៥៤ ("ដើម្បីចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើដែលបានសំអាងទៅលើនៅមុនពេលសង្គ្រាម ត្រូវជាការសម្លាប់ ឬពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មណាមួយនៅក្នុងយុត្តាធិការរបស់តុលាការ")។ *ប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ (UNWCC) និងការអភិវឌ្ឍន៍ច្បាប់សង្គ្រាមឆ្នាំ* ១៩៤៨ ទំព័រ ១៩២, ២០១ ដល់ ២០៣។ Henri Donnedieu DE VABRES "ការជំនុំជម្រះរបស់ Nuremberg និងគោលការណ៍ទំនើប" នៅក្នុងការបោះពុម្ពផ្សាយរបស់ Guénaël METTRAUX ទស្សនវិស័យស្តីពីការជំនុំជម្រះ Nuremberg ព្រឹត្តិប័ត្រព័ត៌មានសាលកវិទ្យាល័យ Oxford ឆ្នាំ ២០០៨ ទំព័រ ២១៣ *ជាអាទិ៍* ទំព័រ ២៤០ ដល់ ២៤១ កត់សម្គាល់ថា តុលាការ IMT បានពិចារណាលើគោលការណ៍នីត្យានុកូលភាព ដោយបានបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព"ផ្អែកតាមទស្សនៈនៃយុត្តាធិការ"។

[1850] *សូមមើលឧ.* សាលក្រមរបស់តុលាការ IMT ទំព័រ ៣០៤ (អំពើរបស់ Streicher "គឺជាការធ្វើទុកបុកម្នេញ [...] ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម [...] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") ៣១៨ ដល់ ៣១៩ (ការគ្រប់គ្រងរបស់ Austria "គឺជាឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់តុលាការ [...] ជាលទ្ធផល គឺជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀត និង ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ សាសនា ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមមាត្រានោះ")។

[1851] មាត្រា ២(១-គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។

[1852] បុព្វកថា នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។

៧១៩.យុត្តិសាស្ត្រស្តីពីលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងជាមួយនឹងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងពុំមានលក្ខណៈស៊ីសង្វាក់គ្នា។ ដោយសារមួយផ្នែក ក្នុងរឿងក្តីរបស់តុលាការឧក្រិដ្ឋកម្មយោធា Nuremberg (NMT) (ដែលបានផ្អែកលើច្បាប់នេះ) ទំនងជាបកស្រាយលក្ខខណ្ឌតម្រូវនេះថា ជាធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1853] និងមួយផ្នែកទៀត នៅក្នុង*រឿងក្តី Flick* (តុលាការឧក្រិដ្ឋកម្មយោធាសហរដ្ឋអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) អង្គជំនុំជម្រះមួយនៃតុលាការឧក្រិដ្ឋកម្មយោធា Nuremberg (NMT) បានយល់ឃើញថា លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងត្រូវតែបង្ហាញ ដោយសារធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) គឺជាផ្នែកមួយដ៏សំខាន់នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ប៉ុន្តែហាក់បីដូចជាបានពិភាក្សាតែក្នុងលក្ខខណ្ឌយុត្តាធិការ មិនមែនធាតុផ្សំសត្យានុម័តទេ និងបានយល់ឃើញថា លក្ខខណ្ឌនេះពុំត្រូវបានបង្ហាញដោយសារខ្លួនខ្វះយុត្តាធិការ[1854]។ ជាសំខាន់ ក្នុង*រឿងក្តី Einsatzgruppen* អង្គជំនុំជម្រះមួយនៃតុលាការយោធា Nuremberg (NMT) បានសម្រេចថា ដោយសារពុំបានចែងជាក់លាក់នូវលក្ខខណ្ឌអំពីទំនាក់ទំនងនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ខ្លួនមានយុត្តាធិការក្នុងការ"វិនិច្ឆ័យរាល់បទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលគេស្គាល់ និងយល់ច្បាស់ជាយូរមកហើយស្របតាមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ" ដោយពុំចាំបាច់មានការបង្ហាញពីទំនាក់ទំនងនោះឡើយ[1855]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ការសម្រេចក្នុង*រឿងក្តី Einsatzgruppen* គឺជា*អ្វីដែលពុំជាប់ពាក់ព័ន្ធ* ព្រោះបទចោទក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងរឿងក្តីនេះ បានប្រព្រឹត្តឡើងក្នុងអំឡុងពេលសង្គ្រាម[1856]។ ដោយពុំពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃរឿងក្តីនេះ នៅតែជាបន្ទុករបស់តុលាការឧក្រិដ្ឋកម្មនេះក្នុងការសម្រេច ថាតើទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព គឺជាធាតុផ្សំផ្នែកច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរ ឬយ៉ាងណា។ បន្ថែមលើនេះទៀត *រឿងក្តី Sch.* ដែលត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការអាល្លឺម៉ង់ ដោយផ្អែកលើច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង គឺពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើង

---

[1853] *សូមមើល រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងយុត្តិធម៌* ទំព័រ ៩៧១។ *រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងផ្សេងៗ* ទំព័រ ៦០៦។ *រឿងក្តី Pohl* ទំព័រ ៩៩១ ដល់ ៩៩២។

[1854] *រឿងក្តី Flick* (តុលាការឧក្រិដ្ឋកម្មយោធាអាម៉េរិក ប្រទេសអាល្លឺម៉ង់) ទំព័រ ១២១៣។

[1855] *រឿងក្តី Einsatzgruppen* ទំព័រ ៤៩៩។

[1856] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៦៨។ ខៀវ សំផន កថាខណ្ឌ ៥៣ (រួមបញ្ចូលការយោងទៅលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចដកលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ (E95/8/1/1) កថាខណ្ឌ ៣១)។

01358370



ក្នុងអំឡុងពេលនៃការសម្លាប់រយ៉ាងរង្គាល ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៣៨ *ជាអាទិ៍* នៅមុនពេលការផ្ទុះសង្គ្រាមលោកលើកទីពីរ និងពុំមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពឡើយ[1857]។

៧១៦.ភស្តុតាងបន្ថែមនៃការដកលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងលិខិតុបករណ៍អន្តរជាតិជាច្រើននៅក្រោយឆ្នាំ ១៩៤៥[1858]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដកលក្ខខណ្ឌតម្រូវនេះស្របតាមទស្សនៈវិវឌ្ឍន៍ថ្មីៗដែលលើកឡើងថា ការហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺក្នុងគោលបំណងដើម្បីការពារមនុស្សជាតិពីការប្រព្រឹត្តអំពើឃោរឃៅ ដូច្នេះតម្រូវឱ្យមានការកំណត់និយមន័យមួយដែលពុំតម្រូវឱ្យមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពឡើយ។

៧១៧.ជាការកត់សម្គាល់ នៅក្នុងឆ្នាំ ១៩៥៤ គណៈកម្មការនីតិអន្តរជាតិបានទម្លាក់ចោលនូវលក្ខខណ្ឌអំពីទំនាក់ទំនង ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងសេចក្តីព្រាងក្រមលើកទីពីរស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ[1859]។ បើទោះបីជា មហាសន្និបាតពុំបានអនុម័តសេចក្តីព្រាង

---

[1857] *សូមមើល រឿងក្តី* Sch. (តុលាការកំពូលសម្រាប់ចក្រភពអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់)។

[1858] សេចក្តីសម្រេចស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ១០ ដល់ ១១ ខែ កក្កដា ឆ្នាំ ១៩៧៤ មាត្រា ១ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (អំពើប្រល័យពូជសាសន៍គឺជាសញ្ញាណដែលទាញចេញពីសញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) មាត្រា ១ នៃអនុសញ្ញាស្តីពីអាជ្ញាយុកាលពុំអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការពង្រីកប្រភេទនៃអំពើនានាដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយរួមបញ្ចូលនិយមន័យនៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិដែលមានលក្ខខណ្ឌតម្រូវទំនាក់ទំនង និងរួមបញ្ចូលការបំបែកពូជសាសន៍ និងអំពើប្រល័យពូជសាសន៍ដែលពុំមានលក្ខខណ្ឌតម្រូវ ប៉ុន្តែនៅតែទទួលស្គាល់ផងដែរថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចប្រព្រឹត្តឡើង"នៅក្នុងពេលសង្គ្រាម ឬក្នុងពេលសន្តិភាព")។ មាត្រា I-II នៃអនុសញ្ញាអន្តរជាតិស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មលើបទឧក្រិដ្ឋនៃការបំបែកពូជសាសន៍។

[1859] មាត្រា ២(១១) នៃសេចក្តីព្រាងក្រមនៃបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ឆ្នាំ ១៩៥៤ គណៈកម្មការនីតិអន្តរជាតិ បានបោះឆ្នោតឱ្យលុបចោលលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងចេញពីនិយមន័យ)។ *សូមមើល* កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ២៦៧ របស់គណៈកម្មការច្បាប់អន្តរជាតិ កថាខណ្ឌ ៤០ ដល់ ៦២។

ក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិក៏ដោយ[1860] ក៏នៅពេលគណៈកម្មការនីតិអន្តរជាតិនេះបានដោះស្រាយម្តងទៀតនៅក្នុងឆ្នាំ ១៩៨៤ នោះ បានកត់សម្គាល់ថា "សេចក្តីព្រាងឆ្នាំ ១៩៥៤ បានឃ្លាតឆ្ងាយពីបរិបទ Nürnberg ដោយសារការកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំពិចារណាអំពីទំនាក់ទំនងណាមួយទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម"[1861] និងថា "បន្ទាប់ពីការជំនុំជម្រះក្តីនៅ Nürnberg ដែលបានកន្លងផុតទៅ ទើបគោលគំនិតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទទួលស្វ័យភាពផ្ទាល់ខ្លួន និងបានផ្តាច់ចេញពីលក្ខខណ្ឌសង្គ្រាម"[1862]។

៧១៨.តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) បង្ហាញទស្សនប្រហាក់ប្រហែលគ្នានេះដែរក្នុង *រឿងក្តី Korbely ទល់នឹង ប្រទេសហុងគ្រី (Hungary)* ដោយបានយោងទៅលើសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ និងបានធ្វើសេចក្តីសន្និដ្ឋានថា ក្នុងឆ្នាំ ១៩៥៦ លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងពុំអាចជាធាតុផ្សំនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលស្របតាមច្បាប់ទំនៀមទំលាប់អន្តរជាតិឡើយ[1863]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងលើ *រឿងក្តី Korbely ទល់នឹង ប្រទេសហុងគ្រី (Hungary)*[1864]។ បើទោះបីជាតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស(ECtHR) បានប្រើប្រាស់ពាក្យ "អាច"នៅក្នុងការសន្និដ្ឋានរបស់ខ្លួនស្តីពីលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនោះយ៉ាងណាក៏ដោយ ក៏នៅក្នុងសាលក្រមរបស់តុលាការនេះបានបង្ហាញថា ទើបតែភ្លាមៗបន្ទាប់ពីការកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានធ្វើក្រមនីយកម្មក្នុងគោលការណ៍ Nuremberg ប៉ុណ្ណោះ មានភស្តុតាងបង្ហាញថា ការកំណត់និយមន័យនេះមានការវិវឌ្ឍន៍ទៅរកការដកលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនេះចេញ។ បន្ថែមលើនេះទៀត បើទោះបីជាតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) ពុំបានព្យាយាមបង្កើតជាមូលដ្ឋានច្បាប់នូវការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៥៦ សម្រាប់គោលបំណងនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈ

---

[1860] ការអនុម័តសេចក្តីព្រាងក្រមត្រូវបានពន្យារពេល ដើម្បីសិក្សាបន្ថែមលើការខ្វែងយោបល់គ្នាជុំវិញនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងអំពើឈ្លានពាន។ *សូមមើល* ក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិ(ECOSOC)"បញ្ហានៃការដាក់ទោសឧក្រិដ្ឋជន និងជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" កថាខណ្ឌ ៤០ និង ៤៨។

[1861] សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការនីតិអន្តរជាតិ (ភាគ II ផ្នែកទី ១) ឆ្នាំ ១៩៨៤ ទំព័រ ៩០ កថាខណ្ឌ ១១។

[1862] សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការនីតិអន្តរជាតិ (ភាគ II ផ្នែកទី ១) ឆ្នាំ ១៩៨៤ ទំព័រ ៩៤ កថាខណ្ឌ ៤០។

[1863] សាលក្រម *រឿងក្តី Korbely ទល់នឹង ប្រទេសហុងគ្រី* (ECtHR) កថាខណ្ឌ ៨២។

[1864] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧០។

បុគ្គលក៏ដោយ ក៏ដើម្បីគោលបំណងនៃគោលការណ៍នីត្យានុកូលភាព តុលាការនេះនៅតែបង្ហាញថា មាន"មូលដ្ឋានច្បាស់លាស់ និងគ្រប់គ្រាន់ក្នុងការពិចារណាពាក់ព័ន្ធទៅនឹងច្បាប់អន្តរជាតិ [...] សម្រាប់ការដាក់ពិរុទ្ធភាពលើម្ចាស់បណ្តឹងសាទុក្ខ"ពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1865]ក្នុងប្រទេសហុងគ្រី (Hungary)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់សេចក្តីសម្រេចរបស់តុលាការ ECtHR ក្នុង*រឿងក្តី Kolk និង Kislyiy ទល់នឹង Estonia* តុលាការនេះបានបដិសេធសំណើដោយសារពុំមានមូលដ្ឋានគ្រប់គ្រាន់ ក្នុងការជំទាស់ការសម្រេចដាក់ពិរុទ្ធភាពរបស់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងក្នុងឆ្នាំ ១៩៤៩ ដោយពុំមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពឡើយ[1866]។

៧១៩.បន្ថែមលើនេះ នៅពេលតាក់តែងច្បាប់ជាតិ ការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥ បានលុបចោលនូវលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនេះ[1867]។ មានសេចក្តីសម្រេចរបស់តុលាការជាតិមួយចំនួនបានប្រកាសដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងអំពើដែលបានកើតឡើងមុនឆ្នាំ ១៩៧៥ ដែលនៅក្នុងពេលនោះ សេចក្តីសម្រេចទាំងនេះបានដកចេញយ៉ាងជាក់ច្បាស់នូវលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង ឬសម្រេចពុំដោះស្រាយលើបញ្ហានេះឡើយ[1868]។

៧២០.បន្ថែមលើនេះទៀត រាល់លក្ខន្តិកៈ និងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិចម្រុះ និងមានស្តង់ដារអន្តរជាតិទាំងអស់ដែលបានបង្កើតឡើងចាប់ពីឆ្នាំ ១៩៩៣ នោះ បានលុបចោលការយោងណាមួយទៅលើលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនេះ នៅក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (បើទោះបីជា

---

[1865] សាលក្រម*រឿងក្តី* Korbely *ទល់នឹង ប្រទេសហុងគ្រី* (ECtHR) កថាខណ្ឌ ៧៨។

[1866] សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបានក្នុង *រឿងក្តី Kolk និង Kislyiy ទល់នឹង Estonia*។

[1867] *សូមមើលឧ.* មាត្រា ១(ខ) នៃច្បាប់របស់ប្រទេសអ៊ីស្រាអែលស្តីពីការទោសអ្នកឃុបឃិតជាមួយនឹងណាហ្ស៊ី (Nazis) ក្នុងឆ្នាំ ១៩៥០។ ក្រិត្យច្បាប់លេខ ១ របស់ប្រទេសហុងគ្រីឆ្នាំ ១៩៧១ (ការផ្សព្វផ្សាយឱ្យប្រើប្រាស់និយមន័យយ៉ាងទូលំទូលាយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីដែនកំណត់នៃអាជ្ញាយុកាលពុំអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ)។

[1868] *សូមមើលឧ. ការជំនុំជម្រះរឿងក្តី Gauleiter Artur Greiser* ទំព័រ ១០៤ ដល់ ១១៤។ សាលក្រម*រឿងក្តី* Eichmann (តុលាការថ្នាក់ស្រុក អ៊ីស្រាអែល)។ *រឿងក្តី* Barbie។ *រឿងក្តី R. ទល់នឹង Finta* (តុលាការកំពូលរបស់ប្រទេសកាណាដា) ទំព័រ ៨១៣។ *រឿងក្តី Simón, Julio Héctor* (តុលាការកំពូល Argentina)។

លក្ខន្តិកៈរបស់តុលាការ ICTY បានតម្រូវឱ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធក៏ដោយ)[1869]។ ពិតប្រាកដណាស់ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានយល់ឃើញថា ពុំមាន"មូលដ្ឋានសមស្រប ឬស្របច្បាប់" ដែលតម្រូវឱ្យមានលក្ខខណ្ឌអំពីទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាមនោះទេ[1870]។ ដូចគ្នានេះដែរ ពុំមានសេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិដែលបានបង្កើតឡើងដោយគណៈកម្មការនីតិអន្តរជាតិ (ILC) ក្នុងឆ្នាំ ១៩៨៦[1871] ១៩៩១[1872] និង ១៩៩៦[1873] បានបញ្ចូលលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនេះទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ជាចុងក្រោយ បើទោះបីជា មានប្រតិភូមួយចំនួនតំណាងគណៈកម្មការរៀបចំសម្រាប់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាដំបូងបានស្នើសុំឱ្យដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវអំពី"ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ"នៅក្នុងលក្ខន្តិកៈរបស់តុលាការនេះក៏ដោយ ក៏មតិទូទៅបានជំទាស់ទៅនឹងការដាក់

---

[1869] *សូមមើល* មាត្រា ៥ នៃលក្ខន្តិកៈរបស់តុលាការ ICTY មាត្រា ៣ នៃលក្ខន្តិកៈរបស់តុលាការ ICTR មាត្រា ២ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) មាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ផ្នែក ៥ នៃបទបញ្ញារដ្ឋបាលអន្តរកាលអង្គការសហប្រជាជាតិក្នុងទីម័រខាងកើត (UNTAET) លេខ ២000/១៥ ស្តីពីការបង្កើតក្រុមប្រឹក្សាដែលមានយុត្តាធិការពិសេសលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ មាត្រា ១៧២ នៃក្រមព្រហ្មទណ្ឌរបស់ Bosnia និង Herzegovina មាត្រា ១១៧ (អង្គជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមក្នុងតុលាការនៃ Bosnia និង Herzegovina មានយុត្តាធិការ *សូមមើល*ច្បាប់ស្តីពីតុលាការរបស់ Bosnia និង Herzegovina មាត្រា ៧(១) អានជាមួយ មាត្រា ១៤)។ មាត្រា ៥ នៃច្បាប់ អ.វ.ត.ក, មាត្រា ៦ នៃលក្ខន្តិកៈរបស់អង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិកនៅក្នុងតុលាការនៃទីក្រុង Senegal។ *សូមមើលផងដែរ* មាត្រា ៧(២) នៃលក្ខន្តិកៈរបស់ ICC។ ដូចបានកត់សម្គាល់ខាងលើ បើទោះបីជាលក្ខន្តិកៈរបស់តុលាការ ICTY បានរួមបញ្ចូលធាតុតាមបរិបទនៃឃ្លាដែលថា "នៅពេលត្រូវបានប្រព្រឹត្តនៅក្នុងជម្លោះប្រដាប់អាវុធ"ទៅក្នុងនិយមន័យយ៉ាងណាក៏ដោយ ក៏ពុំមែនដូចគ្នាទៅនឹងទំនាក់ទំនងដែលមាននៅក្នុងគោលការណ៍ Nuremberg ឆ្នាំ ១៩៥0 ដែរ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចនៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Tadić* កថាខណ្ឌ ៧៨ ថា "ច្បាប់ទំនៀមទម្លាប់លែងតម្រូវឱ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមួយនឹងជម្លោះប្រដាប់អាវុធទៀតឡើយ"។ *សូមមើលផងដែរ* កថាខណ្ឌ ១៤០ ដល់ ១៤១។

[1870] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ១៤០។

[1871] របាយការណ៍ទីបួនស្តីពីសេចក្តីព្រាងក្រមនៃបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ (ឆ្នាំ ១៩៨៦) ទំព័រ ៨៥ ដល់ ៨៦ (មាត្រា ១២)។

[1872] របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្តីពីកិច្ចការនាសម័យប្រជុំទី ៤៨ ទំព័រ ៩៦ ដល់ ៩៧, ១០១ ដល់ ១០៤។

[1873] របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្តីពីកិច្ចការនាសម័យប្រជុំលើកទី ៤៨ ទំព័រ ១៥ ដល់ ៥៦ (មាត្រា ១៨)។

បញ្ចូលទំនាក់ទំនងនេះ ឱ្យស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ[1874] ដែលលក្ខណៈបែបនេះចុងក្រោយពុំត្រូវបានអនុម័តឡើយ។

៧២១.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា ពុំមានលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនេះសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥ នោះឡើយ។ លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពនៅក្នុងគោលការណ៍ Nuremberg ពុំមែនជាផ្នែកមួយក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥ ទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាក់ទងទៅនឹងបញ្ហានេះ។

## ៤.ឃ.៥.ខ.ផែនការ ឬគោលនយោបាយរបស់រដ្ឋ

៧២២.នួន ជា និង ខៀវ សំផន ក៏បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយបានអះអាងថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធសម្រាប់បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ ពុំបានរួមបញ្ចូលការបង្ហាញអំពីអត្ថិភាពនៃផែនការ ឬគោលនយោបាយរបស់រដ្ឋដែលជាធាតុផ្សំនៃលក្ខខណ្ឌតម្រូវតាមបរិបទ ("លក្ខខណ្ឌតម្រូវស្តីពីផែនការ ឬគោលនយោបាយរបស់រដ្ឋ")[1875]។ ដោយបានពិចារណាលើកំហុសដែលបានចោទប្រកាន់នេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសាលក្រមរបស់ខ្លួននៅក្នុង *រឿងក្តី ឌុច* (001-E188) ដូចតទៅ៖

> នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើករណី *កាំង ហ្កេកអ៊ាវ ហៅ ឌុច* អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទោះបីអត្ថិភាពនៃគោលនយោបាយ ឬផែនការមួយអាចជាភស្តុតាងមួយទាក់ទងទៅនឹងការបង្កើតឱ្យមាននូវការវាយប្រហារ ដែលមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធក៏ដោយ ក៏អត្ថិភាពនៃគោលនយោបាយ និងផែនការទាំងនោះ មិនមែនជាធាតុផ្សំចាំបាច់នៃឧក្រិដ្ឋកម្មនោះទេ។

---

[1874] កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៣ របស់គណៈកម្មាធិការពាក់ព័ន្ធទៅនឹងការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឆ្នាំ ២០០២ ទំព័រ ១៤៦ ដល់ ១៥៤ កថាខណ្ឌ ១៧៦។

[1875] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៤ (រួមបញ្ចូលការយោងទៅលើការលើកឡើងដែលបានធ្វើនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ នួន ជា (E295/6/3) កថាខណ្ឌ ២១០ ដល់ ២១៣)។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៥ ដល់ ៥៨ និង ៣៣៣។

ទោះបីការយល់ឃើញនេះ ស្របជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្រោយឆ្នាំ ១៩៧៥ ក៏ដោយ ក៏ការយល់ឃើញនេះផ្អែកលើការពិនិត្យទៅលើប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងពេលវេលានៃការអនុវត្តនៅពេលនោះដែរ។ ប្រភពទាំងអស់នេះ បង្ហាញនូវទស្សនៈផ្ទុយទៅលើបញ្ហានេះ។ ទោះបីជាក្រុមមេធាវីការពារក្តីបានបង្ហាញអត្តសញ្ញាណនៃប្រភពមួយចំនួន ដែលគាំទ្រដល់ទឡ្ហីករណ៍គតិយុត្តិរបស់ខ្លួនក៏ដោយ ក៏មានការគាំទ្រផងដែរដល់ទស្សនៈ ដែលបានលើកឡើងពីលើកមុនដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រម កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ដែលតម្រូវឱ្យមានការសម្រេចថាការអនុវត្តរបស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់* នៅពេលនោះ គឺមិនបានគាំទ្រឱ្យបានច្បាស់លាស់ចំពោះលក្ខខណ្ឌតម្រូវអំពីគោលនយោបាយ ឬផែនការរបស់រដ្ឋ ឬអង្គការមួយឡើយ[1876]។

៧២៣.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ឬគោលការណ៍ Nuremberg ពុំបានរួមបញ្ចូល“អត្ថិភាពនៃផែនការ ឬគោលនយោបាយរបស់រដ្ឋ” នៅក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ អាស្រ័យហេតុនេះ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះគឺ ថាតើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៤៦ បានបញ្ចូលដោយប្រយោលនូវលក្ខខណ្ឌតម្រូវអំពីផែនការ ឬគោលនយោបាយរបស់រដ្ឋត្រឹមឆ្នាំ ១៩៧៥ ឬបានវិវឌ្ឍន៍ និងបង្ហាញច្បាស់លាស់នូវការបញ្ចូលលក្ខខណ្ឌនេះត្រឹមឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា។

៧២៤.អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយនឹង ខៀវ សំផន ដែលបានលើកឡើងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាញឹកញាប់ជាប់ពាក់ព័ន្ធទៅនឹងផែនការ ឬគោលនយោបាយរបស់រដ្ឋ[1877]។ ទោះជាយ៉ាងណាក្តី ការកំណត់និយមន័យនៃឧក្រិដ្ឋកម្មទាំងនេះនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ដែលរួមបញ្ចូលពាក្យពេចន៍ថា “ធ្វើសកម្មភាពក្នុងផលប្រយោជន៍របស់ប្រទេសសម្ព័ន្ធមិត្តអាក់ស៊ីសអឺរ៉ុប (European Axis)”នៅក្នុង*ធាតុផ្សំតាមបរិបទ*នៃមាត្រា ៦ នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ពុំបានតម្រូវឱ្យមានការបង្ហាញនូវផែនការ ឬគោលនយោបាយរបស់រដ្ឋជាធាតុផ្សំផ្នែកច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។[1878]។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា

---

[1876] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨១។

[1877] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៧។

[1878] មាត្រា ៦ នៃធម្មនុញ្ញរបស់តុលាការឧក្រិដ្ឋកម្ម IMT (“តុលាការឧក្រិដ្ឋកម្មដែលត្រូវបានបង្កើតឡើង […] នៅទីនេះសម្រាប់ការជំនុំជម្រះក្តី និងដាក់ទោសរបស់លើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗរបស់ប្រទេសសម្ពន្ធមិត្ត Axis អឺរ៉ុប មានសិទ្ធិអំណាចចោទប្រកាន់ និងផ្ត

បុព្វកថានៃកិច្ចព្រមព្រៀងទីក្រុងឡុងដ៍ និងសេចក្តីប្រកាសទីក្រុងមូស្គូបានបង្ហាញថា ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) បានបង្កើតអត្ថិភាពនៃផែនការ ឬគោលនយោបាយរបស់រដ្ឋធ្វើជាផ្នែកនៃការកំណត់និយមន័យផ្នែកច្បាប់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1879]។ ពុំមានឯកសារណាយោងទៅលើលក្ខខណ្ឌតម្រូវបែបនោះឡើយ។ តាមការពិត ប្រវត្តិនៃសេចក្តីព្រាងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ពុំបានគាំទ្រដល់ការយល់ឃើញដែលថា ប្រទេសសម្ព័ន្ធមិត្តចង់ឱ្យមានលក្ខខណ្ឌអំពីផែនការ ឬគោលនយោបាយរបស់រដ្ឋនៅក្នុងផ្នែកណាមួយក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របតាមមាត្រា ៦(គ) នៃធម្មនុញ្ញនោះឡើយ[1880]។

៧២៥.ប្រហាក់ប្រហែលគ្នានេះដែរ សាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ពុំមានការយោងណាមួយអំពីធាតុផ្សំផែនការ ឬធាតុផ្សំគោលនយោបាយរបស់រដ្ឋនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ នៅក្នុងផ្នែកនៃសាលក្រមដែលពិពណ៌នាពីអំពើជាមូលដ្ឋាន ដែលបានប្រព្រឹត្តឡើងនៅមុនការចាប់ផ្តើមសង្គ្រាមក្នុងឆ្នាំ ១៩៣៩ តុលាការនេះពុំបានពិចារណា ឬបញ្ជាក់ថា ការចោទប្រកាន់ត្រូវតែបង្ហាញថា អំពើនេះមានទំនាក់ទំនងជាមួយនឹងផែនការ ឬគោលនយោបាយរបស់រដ្ឋ មកធ្វើជាលក្ខខណ្ឌតាមបរិបទឡើយ[1881]។ ពាក្យពេចន៍ដែលបានពិពណ៌នាពីអំពើប្រឆាំងនឹងប្រជាជនស៊ីវិលទាំងមុន និងក្រោយសង្គ្រាម ពុំបានគាំទ្រការបកស្រាយបែបនោះឡើយ។ តុលាការនេះបានចាត់ទុកអំពើទាំងនេះថា “ទូលំទូលាយ” ឬនាពេលនោះ “ដោយមានការរៀបចំ និងជាប្រព័ន្ធ” ឬដោយស្របតាមគោលនយោបាយ។ ទោះជាយ៉ាងណាក្តី ពុំមានការបញ្ជាក់ដោយផ្ទាល់ ឬដោយប្រយោលពីតុលាការនេះថា ដើម្បីអាចដាក់ពិរុទ្ធភាពបាន តុលាការត្រូវតែបង្ហាញថា អំពើរបស់ជនជាប់ចោទមានការជាប់ពាក់ព័ន្ធទៅនឹងផែនការ ឬគោលនយោបាយរបស់រដ្ឋឡើយ បើទោះបី នេះគឺជា

---

ន្មាទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៃសម្ពន្ធមិត្ត Axis អឺរ៉ុប *ដែលធ្វើសកម្មភាពក្នុងផលប្រយោជន៍របស់ប្រទេសសម្ពន្ធមិត្ត Axis អឺរ៉ុប* បើទោះបីជាលក្ខណៈបុគ្គល ឬជាសមាជិកនៃអង្គការណាមួយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មខាងក្រោមនេះ”)(សេចក្តីបញ្ជាក់បន្ថែម)។

[1879] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧។

[1880] *សូមមើល* Robert H. Jackson៖ កំណត់ហេតុនៃសំណើស្តីពីការកំណត់និយមន័យដែលបានស្នើឡើងអំពី“ឧក្រិដ្ឋកម្ម”(ឆ្នាំ ១៩៤៥) និង Robert H. Jackson៖ កំណត់ហេតុសម័យប្រជុំ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៤៥។ Robert H. Jackson៖ កំណត់ហេតុសម័យប្រជុំ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៤៥។ Robert H. Jackson៖ កំណត់ហេតុសម័យប្រជុំ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៤៥។

[1881] សាលក្រមរបស់តុលាការ IMT ទំព័រ ២៥៤ ដល់ ២៥៥។

ករណីជាក់ស្តែងក៏ដោយ[1882]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំអាចសន្និដ្ឋានថា ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) គោលការណ៍ Nuremberg បានដាក់បញ្ចូលដោយប្រយោលនូវលក្ខខណ្ឌតម្រូវអំពីផែនការ ឬគោលនយោបាយរបស់រដ្ឋនោះឡើយ។

៧២៦.ទីពីរ ផ្អែកលើសំណួរ ថាតើច្បាប់ទំនៀមទម្លាប់អន្តរជាតិបានវិវឌ្ឍជាបន្តបន្ទាប់ក្រោយគោលការណ៍ Nuremberg ដើម្បីដាក់បញ្ចូលលក្ខខណ្ឌអំពីផែនការ ឬគោលនយោបាយរបស់រដ្ឋត្រឹមឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការបកស្រាយរបស់គណៈកម្មាធិការផ្នែកច្បាប់នៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ (UNWCC) លើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំមានការយោងណាមួយទៅលើលក្ខខណ្ឌបែបនេះ[1883] និងនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ពុំបានយោងទៅលើលក្ខខណ្ឌនោះទេ[1884]។

៧២៧.បើទោះបីជា *រឿងក្តីពាក់ព័ន្ធនឹងក្រសួងយុត្តិធម៌* ទំនងជាបកស្រាយច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងថា តម្រូវដោយប្រយោលឱ្យមានផែនការ ឬគោលនយោបាយ ដើម្បីបែងចែកបទឧក្រិដ្ឋ និងបទល្មើសក្នុងស្រុកឱ្យដាច់ដោយឡែកចេញពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1885]ក៏ដោយ ក៏រឿងក្តីដទៃទៀតជាច្រើនដែលក្នុងនោះការដាក់ពិរុទ្ធភាពត្រូវបានធ្វើឡើងសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងពុំបានថ្លែងអំពីអត្ថិភាពនៃផែនការ ឬគោលនយោបាយរបស់រដ្ឋ ធ្វើជាផ្នែកមួយនៃធាតុផ្សំតាមបរិបទឡើយ[1886]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញផងដែរថា លិខិតុបករណ៍ច្បាប់អន្តរជាតិ

---

[1882] *សូមមើលឧ.* សាលក្រមរបស់តុលាការ IMT ទំព័រ ២៨១ ដល់ ២៨២, ២៨៧ ដល់ ៣០៧, ៣១៨ ដល់ ៣២២, ៣២៤ ដល់ ៣២៥, ៣២៧ ដល់ ៣៣៦, ៣៣៩ ដល់ ៣៤១។

[1883] UNWCC *ប្រវត្តិនៃគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ និងការអភិវឌ្ឍន៍នៃច្បាប់សង្គ្រាម* ឆ្នាំ ១៩៤៨ ទំព័រ ១៧៩ ("ផ្អែកតាមវិធាន អំពើដែលជាប្រព័ន្ធក្នុងទ្រង់ទ្រាយធំ ជាពិសេស ដូចជាប្រើអំណាចផ្តាច់ការ គឺជាអំពើចាំបាច់ក្នុងការប្រែក្លាយបទឧក្រិដ្ឋសាមញ្ញមួយដែលមានតែច្បាប់ក្នុងស្រុកអាចដាក់ទណ្ឌកម្មបានប៉ុណ្ណោះនោះ ឱ្យទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនេះជាក្តីកង្វល់ចំពោះច្បាប់អន្តរជាតិ")។ អំពើផ្តាច់ការពុំចាំបាច់ត្រូវតែស្របតាមគោលនយោបាយ ឬផែនការរបស់រដ្ឋនោះទេ។

[1884] មាត្រា ២(១-គ) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។

[1885] *រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងផ្សេងៗ* ទំព័រ ៩៧២ ដល់ ៩៧៣, ៩៨១ ដល់ ៩៨២, ៩៨៤។

[1886] *សូមមើល រឿងក្តី* Flick (តុលាការឧក្រិដ្ឋកម្មយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ១១៩១, ១២១២ ដល់ ១២១៦ (ដូចកត់សម្គាល់ខាងលើ ទោះជាយ៉ាងណាក្តី តុលាការឧក្រិដ្ឋកម្មនេះបានតម្រូវឱ្យមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្ម

ជាច្រើនពុំបានដាក់បញ្ចូលផែនការ ឬគោលនយោបាយរបស់រដ្ឋ ធ្វើជាធាតុផ្សំតាមបរិបទតម្រូវសម្រាប់កំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[1887]។

៧២៨.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មានការយោងទៅលើអត្ថិភាពនៃ"ផែនការ ឬគោលនយោបាយរបស់រដ្ឋ" នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៥៦ ក្នុង *រឿងក្តី* Korbely *ទល់នឹង ប្រទេសហុងគ្រី (Hungary)* អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR)[1888]។ ទោះជាយ៉ាងនេះក្តី យោងតាមតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR) បានឱ្យដឹងថា បញ្ហាចម្បង គឺត្រូវដកអំពើដែលមានលក្ខណៈ"ដាច់ដោយឡែក ឬម្តងម្កាល"ចេញ ដូច្នេះ តម្រូវថាអំពើទាំងនោះគ្រាន់តែ"ជាផ្នែកនៃ'សកម្មភាព ឬគោលនយោបាយរបស់រដ្ឋ *ឬ* ការវាយប្រហារជាប្រព័ន្ធ និងជាទូទៅលើប្រជាជនស៊ីវិល"[1889]។ ហេតុនេះ ដរាបណាការវាយប្រហារជាប្រព័ន្ធ និងទូទៅនៅតែមានអត្ថិភាពលើជនស៊ីវិល ពុំតម្រូវឱ្យមានសកម្មភាព ឬគោលនយោបាយរបស់រដ្ឋឡើយ។

៧២៩.លើសពីនេះទៀត បើទោះបីជាយុត្តិសាស្ត្រ និងបទប្បញ្ញត្តិជាតិមួយចំនួនដែលដោះស្រាយបញ្ហានេះតម្រូវឱ្យមានការបង្ហាញអំពីផែនការ ឬគោលនយោបាយរបស់រដ្ឋ ដែលជាធាតុផ្សំតាមបរិបទសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1890]ក៏ដោយ ក៏នៅក្នុងរឿងក្តីរបស់តុលាការក្នុងស្រុក បានបដិសេធយ៉ាងច្បាស់លាស់ ឬពុំ

---

ប្រឆាំងនឹងសន្តិភាព)។ *រឿងក្តីពាក់ព័ន្ធផ្នែកវេជ្ជសាស្ត្រ* ទំព័រ ១៧២ ដល់ ១៧៣។ *រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងផ្សេងៗ* ទំព័រ ៦៥៣ ដល់ ៦៥៤, ៧៩៧, ៨៧៧។ *រឿងក្តី* Farben ទំព័រ ១១២៩ ដល់ ១១៣០។ *រឿងក្តី* High Command ទំព័រ ៤៦៩ *ជាអាទិ៍*។

[1887] *សូមមើល* សេចក្តីសម្រេចស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ១០ ដល់ ១១ ខែ កក្កដា ឆ្នាំ ១៩៤៧។ មាត្រា ១ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍, មាត្រា I (៩) នៃសេចក្តីព្រាងក្រមនៃបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិឆ្នាំ ១៩៥១ ទំព័រ ៥៩, មាត្រា I នៃអនុសញ្ញាស្តីពីដែនកំណត់អាជ្ញាយុកាលដែលពុំអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, មាត្រា I-II នៃអនុសញ្ញាអន្តរជាតិស្តីពីការទប់ស្កាត់ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មបំបែកពូជសាសន៍, សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៣០៧៤ (ឆ្នាំ ១៩៧៣)។

[1888] សាលក្រម *រឿងក្តី* Korbely *ទល់នឹង ប្រទេសហុងគ្រី (Hungary)* (ECtHR) កថាខណ្ឌ ៨២។

[1889] សាលក្រម *រឿងក្តី* Korbely *ទល់នឹង ប្រទេសហុងគ្រី (Hungary)* (ECtHR) កថាខណ្ឌ ៨៣ (សេចក្តីបញ្ជាក់បន្ថែម)។

[1890] *រឿងក្តី* Barbie (តុលាការកំពូល ប្រទេសបារាំង) ទំព័រ ៧៦១។ *រឿងក្តី* Touvier (តុលាការកំពូលប្រទេសបារាំង) ទំព័រ ១៥។ *រឿងក្តី R. ទល់នឹង* Finta (តុលាការកំពូល ប្រទេសកាណាដា)។ នៅក្នុងសាលក្រម *រឿងក្តី* Eichmann (តុលាការថ្នាក់ស្រុក) កថាខណ្ឌ ៥៦ ដល់ ៨៨ តុលាការបានផ្តល់ការយល់ឃើញយ៉ាងទូលំទូលាយផ្នែកអង្គហេតុទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយរបស់រដ្ឋ។ *រឿងក្តី P. ទល់នឹង* Menten (តុលាការកំពូលប្រទេសហូឡង់) ទំព័រ ៣៦២ ដល់ ៣៦៣។

បានយោងទៅលើលក្ខខណ្ឌនេះម្តងណាឡើយ[1891]។ អាស្រ័យហេតុនេះ បញ្ហានេះទំនងជាពុំមានការអនុវត្តដូចគ្នានោះទេ។

៧៣០.នៅក្នុងអំឡុងពេលក្រោយយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ការអនុវត្តរបស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់* ទៅលើលក្ខខណ្ឌតាមបរិបទទាក់ទងទៅនឹងផែនការ ឬគោលនយោបាយរបស់រដ្ឋ បានបន្តបង្ហាញពីភាពផ្ទុយគ្នាទាក់ទងទៅនឹងលក្ខខណ្ឌនេះ នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិចម្រុះដែលបង្កើតថ្មីៗស្ទើរតែទាំងអស់ បានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយគ្មានលក្ខខណ្ឌតម្រូវតាមបរិបទអំពីផែនការ ឬគោលនយោបាយរបស់រដ្ឋឡើយ[1892]។ បន្ថែមលើនេះ ចាប់ពីឆ្នាំ ២០០២[1893]មក តុលាការឧក្រិដ្ឋកម្មអន្តរជាតិចម្រុះ បានបញ្ជាក់ដោយស៊ីសង្វាក់គ្នាថា ពុំមានលក្ខខណ្ឌតម្រូវបែបនេះឡើយ[1894]។

៧៣១.ចុងក្រោយ បើទោះបីជាសេចក្តីព្រាងក្រមឆ្នាំ ១៩៨៦ ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ ដែលបានបង្កើតឡើងដោយគណៈកម្មការនីតិអន្តរជាតិ ពុំបានយោងទៅលើលក្ខខណ្ឌតម្រូវ

---

[1891] *រឿងក្តី In re Ahlbrecht* (លេខ ២) (តុលាការកំពូលពិសេសប្រទេសហូឡង់)។

[1892] *សូមមើល* មាត្រា ៥ នៃលក្ខន្តិកៈរបស់តុលាការ ICC មាត្រា ៣ នៃលក្ខន្តិកៈរបស់តុលាការ ICTR មាត្រា ២ នៃលក្ខន្តិកៈរបស់តុលាការ SCSL បទបញ្ជារដ្ឋបាលអន្តរកាលរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតស្តីពីការបង្កើតក្រុមប្រឹក្សាដែលមានយុត្តាធិការពិសេសលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ លេខ 2000/15 (UNTAET) កថាខណ្ឌ ៥ មាត្រា ១៧២ នៃក្រមព្រហ្មទណ្ឌរបស់ Bosnia និង Herzegovina មាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌអន្តរកាលរបស់ Kosovo មាត្រា ៥ នៃច្បាប់ អ.វ.ត.ក. មាត្រា ៦ នៃលក្ខន្តិកៈរបស់អង្គជំនុំជម្រះវិសាមញ្ញទ្វីបអាហ្វ្រិកក្នុងតុលាការ Senegal។ ប៉ុន្តែ មាត្រា ៧(២)(ក) នៃលក្ខន្តិកៈរបស់តុលាការ ICC ដែលតម្រូវយ៉ាងពិសេសថា ការវាយប្រហារត្រូវបានប្រព្រឹត្តឡើង"ដោយស្របតាម ឬជំរុញគោលនយោបាយរបស់រដ្ឋ ឬអង្គការឱ្យធ្វើការវាយប្រហារនោះ"។ មានការលើកឡើងថា អ្នកធ្វើសេចក្តីព្រាងលក្ខន្តិកៈរបស់តុលាការ ICC ប្រហែលជាមានចេតនាងាកចេញពីវិធានតាមទម្លាប់ទាក់ទងទៅនឹងបញ្ហានេះ *សូមមើល* សេចក្តីសម្រេចស្តីពីមាត្រា ១៥ *រឿងក្តី Kenya* (ICC) មតិជំទាស់របស់ចៅក្រម Kaul កថាខណ្ឌ ៣២។

[1893] សាលដីកា*រឿងក្តី Kunarac* (ICTY) កថាខណ្ឌ ៩៨។

[1894] សាលដីកា*រឿងក្តី Blaškić* (ICTY) កថាខណ្ឌ ១២០។ សាលដីកា*រឿងក្តី Krstić* (ICTY) កថាខណ្ឌ ២២៥។ សាលដីកា*រឿងក្តី Kordić និង Čerkez* (ICTY) កថាខណ្ឌ ៩៨។ សាលដីកា*រឿងក្តី Semanza* (ICTR) កថាខណ្ឌ ២៦៩។ សាលដីកា*រឿងក្តី Nahimana* (ICTR) កថាខណ្ឌ ៩២២។ សាលដីកា*រឿងក្តី Gacumbitsi* (ICTR) កថាខណ្ឌ ៨៤។ សាលក្រម*រឿងក្តី Brima* (SCSL) កថាខណ្ឌ ២១៥។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង*រឿងក្តី Fofana និង Kondewa* (SCSL) កថាខណ្ឌ ១១៣។ សាលក្រម*រឿងក្តី Sesay* (SCSL) កថាខណ្ឌ ៧៩។

តាមបរិបទអំពីផែនការ ឬគោលនយោបាយរបស់រដ្ឋ ធ្វើជាផ្នែកនៃធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏សេចក្ដីព្រាងក្រមឆ្នាំ ១៩៩៦ ស្ដីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ អាចត្រូវបានបកស្រាយថា បានដាក់បញ្ចូលឡើងវិញនូវលក្ខខណ្ឌនេះផ្អែកលើសេចក្ដីព្រាងក្រមឆ្នាំ ១៩៥៤[1895]។ ប្រហាក់ប្រហែលគ្នាទៅនឹងនិយមន័យនៃធាតុផ្សំតាមបរិបទនៅក្នុងលក្ខន្តិកៈរបស់តុលាការ ICC ដែរ សេចក្ដីព្រាងក្រមឆ្នាំ ១៩៩៦ ស្ដីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិបានចែងថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយដូចខាងក្រោម នៅពេលអំពើនេះត្រូវបានប្រព្រឹត្តឡើងជាប្រព័ន្ធ ឬក្នុងទ្រង់ទ្រាយធំ *និង*មានការញុះញង់ ឬមានការណែនាំពីរដ្ឋាភិបាល ឬអង្គការ ឬក្រុមណាមួយ"[1896]។ ទោះជាយ៉ាងនេះក្ដី ដោយយោងទៅលើសេចក្ដីប្រកាសរបស់តុលាការយោធាឧក្រិដ្ឋកម្មអន្តរជាតិ (IMT) អំពីចរិតល្មើសរបស់អង្គការជាច្រើននោះ គណៈកម្មការនីតិអន្តរជាតិ (ILC) បានកត់សម្គាល់នៅក្នុងសេចក្ដីអធិប្បាយរបស់ខ្លួនទៅលើសេចក្ដីព្រាងក្រមឆ្នាំ ១៩៩៦ ថា ការញុះញង់ ឬការណែនាំ អាចធ្វើឡើងតាមរយៈរដ្ឋាភិបាល *ឬ*អង្គការ ឬក្រុមណាមួយ"ដែលអាចជាប់ ឬពុំជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាល"[1897]។ អាស្រ័យហេតុនេះ ពាក្យពេចន៍នេះពុំបានគាំទ្រលក្ខខណ្ឌនៃការបង្ហាញអំពីផែនការ ឬគោលនយោបាយរបស់*រដ្ឋ* ធ្វើជាធាតុផ្សំតាមបរិបទឡើយ ពីព្រោះការបង្ហាញអំពីផែនការ ឬគោលនយោបាយដែលកើតចេញពីអង្គការ ឬក្រុមដែលមិនមែនជារដ្ឋអាចជាការពង្រីកធាតុផ្សំនេះបន្ថែមទៀត។

៧៣២.យោងតាមហេតុផលខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសន្និដ្ឋានថា "ការអនុវត្តរបស់រដ្ឋ និង*ការប្រកាសពីឆន្ទៈទទួលយកជាច្បាប់* [ត្រឹមឆ្នាំ ១៩៧៥] ពុំគាំទ្រលក្ខខណ្ឌតម្រូវនៃផែនការ ឬគោលនយោបាយរបស់រដ្ឋ ឬអង្គការ"[1898] ដោយឯករាជ្យក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនាពេលនោះឡើយ។ បើទោះបីជាមានប្រភពមួយចំនួនគាំទ្រលក្ខខណ្ឌតម្រូវនោះក៏ដោយ ក៏ច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំមានការវិវឌ្ឍន៍បន្ទាប់ពីគោលការណ៍

---

[1895] របាយការណ៍ទីបួនស្ដីពីសេចក្ដីព្រាងក្រមនៃបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ ឯកសារអង្គការសហប្រជាជាតិ (ឆ្នាំ ១៩៨៦) ទំព័រ ៨៦ (មាត្រា ១២) (*សូមមើលផងដែរ* សំណើឆ្នាំ ១៩៩១ សម្រាប់មាត្រា ២១ នៃសេចក្ដីព្រាងក្រមដែលពុំមានចែងអំពីលក្ខខណ្ឌតម្រូវ-របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្ដីពីកិច្ចការសម័យប្រជុំលើកទី ៤៣ ទំព័រ ២២២)។ របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្ដីពីកិច្ចការសម័យប្រជុំលើកទី ៤៨ ទំព័រ ៤៧ ដល់ ៥០ (មាត្រា ១៨)។

[1896] របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្ដីពីកិច្ចការសម័យប្រជុំលើកទី ៤៨ ទំព័រ ៤៧ (មាត្រា ១៨)។

[1897] របាយការណ៍របស់គណៈកម្មការនីតិអន្តរជាតិស្ដីពីកិច្ចការសម័យប្រជុំលើកទី ៤៨ ទំព័រ ៤៧។

[1898] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨១។

Nuremberg ដល់កម្រិតមួយដែលអាចនិយាយបានថា ធាតុផ្សំតាមបរិបទបានបង្ហាញយ៉ាងជាក់ច្បាស់ក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហានេះ។

## ៤.ឃ.៥.គ.ទំនាក់ទំនងជាមួយនឹងការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធសំដៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

៧៣៣.នួន ជា និង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសមួយចំនួនទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវ ស្របតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ដែលចែងថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានទំនាក់ទំនងទៅនឹងការវាយប្រហារជាប្រព័ន្ធ ឬជាទូទៅ ដែលសំដៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា[1899]។

### ៤.ឃ.៥.គ.១.ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធសំដៅទៅលើប្រជាជនស៊ីវិល

៧៣៤.ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវដែលថា ការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ ត្រូវតែសំដៅលើជនស៊ីវិលណាមួយ អង្គជំនុំជម្រះសាលាដំបូងបានឃើញការវាយប្រហារបែបនេះមានអត្ថិភាពព្រោះ៖

> [...] ការវាយប្រហារនេះត្រូវបានធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិលនៃប្រទេសកម្ពុជា។ ជម្លោះប្រដាប់អាវុធរវាងរបបសាធារណរដ្ឋខ្មែរ និងខ្មែរក្រហម បានបញ្ចប់នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅពេលដែលខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ហើយទាហាននៃរបបសាធារណរដ្ឋខ្មែរបានចុះចាញ់។ ហេតុដូច្នេះ ទាហានទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ ដែលមិនបានចូលរួមដោយផ្ទាល់នៅក្នុងជម្លោះប្រដាប់អាវុធ ឬយ៉ាងហោចណាស់ជា *ទាហានដែលបាត់បង់សមត្ថភាពប្រយុទ្ធ* មានសិទ្ធិទទួលបានការការពារដូចគ្នានឹងប្រជាជនស៊ីវិលដែរ។ ទោះជាក្នុងករណីណាក៏ដោយ អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរគ្រាន់តែជាផ្នែកមួយនៃប្រជាជនស៊ីវិលរាប់លាននាក់ ដែលត្រូវបានវាយប្រហារតែប៉ុណ្ណោះ[1900]។

---

[1899] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៥ ដល់ ៤៨៣។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣០ ដល់ ៣៤១ និង ៣៥៨។

[1900] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៤ (ជើងទំព័រលុបចោល)។

៧៣៥.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើហិង្សាទាំងនេះដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើក្នុងការយល់ឃើញពីអត្ថិភាពនៃការវាយប្រហារនោះ បានសំដៅលើជនស៊ីវិល ដែលពុំមែនជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបាន *បាត់បង់សមត្ថភាពប្រយុទ្ធ* នោះទេ[1901]។ នួន ជា បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអំពើហិង្សានេះ គឺគ្រាន់តែជាការសម្រេចពាក់ព័ន្ធទៅនឹងទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលអាចមានឋានៈដូចជា *ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ*ប៉ុណ្ណោះ ប៉ុន្តែមិនមែនជាជនស៊ីវិលឡើយ[1902]។ នួន ជា បានលើកឡើងបន្ថែមទៀតថា *ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ* ពុំអាចក្លាយជាគោលដៅនៃការវាយប្រហារជាប្រព័ន្ធ ឬជាទូទៅប្រឆាំងទៅលើ *ជនស៊ីវិល*ណាមួយនោះទេ[1903]។ នួន ជា បានជំទាស់បន្ថែមទៀតទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ប.ក.ក. បានអនុម័តគោលនយោបាយ“កម្ទេចខ្មាំង”ដែលគាត់បានអះអាងថា ពុំស្របតាមបទដ្ឋាននៃ“អំពើហិង្សា” ដែលតម្រូវបង្ហាញឱ្យឃើញអំពីការវាយប្រហារនោះឡើយ[1904]។

៧៣៦.ខៀវ សំផន បានលើកឡើងថា នៅក្នុងការយល់ឃើញដែលថា មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើព្រឹត្តិការណ៍ និងហេតុការណ៍ដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលត្រូវបានបំបែក និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស[1905]។

៧៣៧.សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវថា មានអត្ថិភាពនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ ដោយបានសំអាងលើភស្តុតាងគ្រប់គ្រាន់អំពីការវាយប្រហារទៅលើជនស៊ីវិល រួមទាំងអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរដែល *បាត់បង់សមត្ថភាពប្រយុទ្ធ*[1906]។ សហព្រះរាជអាជ្ញាបានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសន្និដ្ឋានថា អតីតអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ គឺជាផ្នែកមួយក្នុងចំណោមជនស៊ីវិលរាប់លាននាក់ដែលរងការវាយ

---

[1901] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨០ ដល់ ៤៨២។

[1902] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨០។

[1903] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨១ ដល់ ៤៨២។

[1904] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៣។

[1905] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣០ ដល់ ៣៤១, *សូមមើលផងដែរ* កថាខណ្ឌ ៣៥៨។

[1906] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣២។

ប្រហារនោះ[1907]។ នៅចុងក្រោយទាក់ទងទៅនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការសំអាងលើភស្តុតាងក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីបញ្ជាក់បន្ថែមលើការយល់ឃើញរបស់ខ្លួន និងបានលើកឡើងថា អំណះអំណាងសំខាន់ជាងគេដែល ខៀវ សំផន បានលើកឡើងនោះពុំបានបំពេញតាមបទដ្ឋានតម្រូវសម្រាប់ការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខនោះទេ[1908]។

៧៣៨.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ផ្អែកលើយុត្តិសាស្ត្រដែលបានបង្កើតឡើងដោយតុលាការ ICTY និង ICTR[1909] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងត្រឹមត្រូវថា ដើម្បីឱ្យមានលក្ខណៈគ្រប់គ្រាន់អាចចាត់ទុកថា ជាប្រជាជនស៊ីវិលសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ “លុះត្រាតែប្រជាជនដែលជាគោលដៅនៃការវាយប្រហារនោះ ត្រូវតែជាជនស៊ីវិលច្រើនលើសលុប”[1910]។ នៅក្នុងសាលដីកា *រឿងក្ដី Blaškić* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសង្កេតឃើញថា “វត្តមានរបស់អតីតទាហានដែលបានដាក់អាវុធចុះក្នុងចំណោមប្រជាជន [...] ពុំអាចកែប្រែចរិតលក្ខណៈជនស៊ីវិល បានឡើយ” [1911]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការសង្កេតយ៉ាងត្រឹមត្រូវថា យុត្តិសាស្ត្រនេះស្របទៅនឹងមាត្រា

---

[1907] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣៣ ល់ ១៣៤។

[1908] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣៥ ដល់ ១៣៦។

[1909] សាលដីកា *រឿងក្ដី Blaškić* (ICTY) កថាខណ្ឌ ១០៧។ សាលដីកា *រឿងក្ដី Kunarac* (ICTY) កថាខណ្ឌ ៩១ ដល់ ៩២។ សាលដីកា *រឿងក្ដី Galić* (ICTY) កថាខណ្ឌ ១៤៤។ សាលដីកា *រឿងក្ដី Kordić និង Čerkez* (ICTY) កថាខណ្ឌ ៥០។ សាលដីកា *រឿងក្ដី D. Milošević* (ICTY) កថាខណ្ឌ ៥០ ដល់ ៥១។ សាលក្រម *រឿងក្ដី Semanza* (ICTR) កថាខណ្ឌ ៣៣០។ សាលក្រម *រឿងក្ដី Akayesu* (ICTR) កថាខណ្ឌ ៥៨២។ សាលក្រម *រឿងក្ដី Rutaganda* (ICTR) កថាខណ្ឌ ៧២។ សាលក្រម *រឿងក្ដី Musema* (ICTR) កថាខណ្ឌ ២០៧។ សាលក្រម *រឿងក្ដី Bagilishema* (ICTR) កថាខណ្ឌ ៧៩។ សាលក្រម *រឿងក្ដី Kayishema និង Ruzindana* (ICTR) កថាខណ្ឌ ១២៨។

[1910] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨៣។

[1911] សាលដីកា *រឿងក្ដី Blaškić* (ICTY) កថាខណ្ឌ ១១៣។

៥០(៣) នៃពិធីសារបន្ថែម I[1912]ដែលចែងថា "ទាហាន*ដែលបាត់បង់សមត្ថភាពប្រយុទ្ធ* មិនត្រូវបានចាត់ទុកថាជា"ជនស៊ីវិល"នោះឡើយ ផ្អែកតាមគោលបំណងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក."[1913]។

៧៣៩.អង្គជំនុំជម្រះតុលាការកំពូលបដិសេធការលើកឡើងរបស់ នួន ជា ដែលថា ការយល់ឃើញនៅក្នុងសាលក្រមទាក់ទងទៅនឹង"អំពើហិង្សា"ទៅលើអ្នកប្រឆាំងខាងនយោបាយរបស់ ប.ក.ក. ពាក់ព័ន្ធតែនឹងទាហាននៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះ[1914]។ ទីមួយ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងយ៉ាងទូលំទូលាយដែលបង្ហាញថា អ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ជាក្រុមមនុស្សដែលជាប្រជាជន មិនមែនជាទាហាននៃរបបសាធារណរដ្ឋខ្មែរនោះ ត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើហិង្សាលើរូបកាយ[1915] ការគំរាមកំហែង និងការគាបសង្កត់ផ្លូវចិត្ត[1916]ពីសំណាក់កងទ័ពខ្មែរក្រហម។ ទីពីរ អំណះអំណាងរបស់ នួន ជា បានផ្អែកទៅលើការកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើការយល់ឃើញរបស់អង្គជំនុំជម្រះដែលថា មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធទៅលើ"ប្រជាជនស៊ីវិលកម្ពុជា"[1917]ដែលមិនមែនត្រឹមតែលើវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន "ប្រជាជនថ្មី" និងអ្នកប្រឆាំងបដិវត្តន៍ពិតប្រាកដ ឬតាមការសន្មត និងសមូហភាវូបនីយកម្ម ដូចដែល នួន ជា បានអះអាងនោះឡើយ[1918]។

៧៤០.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់លើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា "អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរត្រឹមតែជាផ្នែកមួយក្នុងចំណោមជនស៊ីវិលរាប់លាននាក់ ដែលទទួលរង

---

[1912] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨៥ យោងទៅលើសាលដីកា*រឿងក្តី* *Blaškić* (ICTY) កថាខណ្ឌ ១១០ ដល់ ១១៣។ *សូមមើលផងដែរ* សាលដីកា*រឿងក្តី* *Galić* កថាខណ្ឌ ១៤៤។ សាលដីកា*រឿងក្តី* *Martić* (ICTY) កថាខណ្ឌ ២៩៧។

[1913] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨៦ យោងទៅលើសាលដីកា*រឿងក្តី* *Mrkšić និង Šljivančanin* (ICTY) កថាខណ្ឌ ៣៥។ សាលដីកា*រឿងក្តី* *Mrkšić និង Šljivančanin* យោងបន្តទៅលើសាលដីកា*រឿងក្តី* *Blaškić* (ICTY) កថាខណ្ឌ ១១០, ១១៣ ដល់ ១១៥។ សាលដីកា*រឿងក្តី* *Kordić និង Čerkez* (ICTY) កថាខណ្ឌ ៩៧។ សាលដីកា*រឿងក្តី* *Galić* (ICTY) កថាខណ្ឌ ១៤៤ ជើងទំព័រ ៤៣៧។

[1914] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨០។

[1915] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧១ ដល់ ៤៧៤ និង ៤៨៩ ដល់ ៤៩០។

[1916] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៧៥, ៤៨១, ៤៨៩ និង ៥១៧។

[1917] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៥។

[1918] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៦ ដល់ ៤៨០ និង ៤៨៣។

ការវាយប្រហារប៉ុណ្ណោះ”[1919]។ នេះអាចត្រូវបានយល់ថា ជាការចាត់ទុកទាហានដែល*បាត់បង់សមត្ថភាពប្រយុទ្ធ* ដូចគ្នាទៅនឹងប្រជាជនស៊ីវិលដែលនេះតាមការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងថា ការបកស្រាយពុំត្រឹមត្រូវលើមាត្រា ៥ នៃច្បាប់ អ.វ.ត.ក.[1920]។ ដូច្នេះ បើយល់ដោយត្រឹមត្រូវ គឺក្នុងន័យថា បើទោះបីជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរស្ថិតក្នុងចំណោមប្រជាជនស៊ីវិល ដែលទទួលរងការវាយប្រហារក៏ដោយ ក៏ពុំបានធ្វើឱ្យពួកគេក្លាយជាជនស៊ីវិលដែរ និងពុំបានប្រែក្លាយចរិតលក្ខណៈប្រជាជនស៊ីវិលឱ្យទទួលរងការវាយប្រហារឡើយ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសង្កេតរួចមកហើយថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងត្រឹមត្រូវថា ប្រជាជនដែលជាគោលដៅនៃការវាយប្រហារ ត្រូវតែជាជនស៊ីវិល*ច្រើនលើសលុប*ដើម្បីបំពេញតាមធាតុផ្សំ*តាមបរិបទ*នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងថា វត្តមានរបស់អតីតទាហានពុំអាចកែប្រែឋានៈនេះបានឡើយ[1921]។ ហេតុដូច្នេះ វត្តមានរបស់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅក្នុងចំណោមប្រជាជនស៊ីវិលកម្ពុជា ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការវាយប្រហារជាទូទៅ និងជាប្រព័ន្ធក្នុងអំឡុងពេលនោះ ពុំអាចមោឃៈសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការវាយប្រហារបែបនេះបានកើតឡើងនោះឡើយ។ យោងតាមហេតុផលដូចគ្នានេះ អំណះអំណាងរបស់ នួន ជា ដែលលើកឡើងថា “ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានចាប់ខ្លួនភ្លាមៗបន្ទាប់ពីការបញ្ចប់សង្គ្រាម [...] គឺជាទាហានដែល*បាត់បង់សមត្ថភាពប្រយុទ្ធ* ដូច្នេះ ពុំអាចជាគោលដៅនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធលើប្រជាជនស៊ីវិល”ត្រូវបដិសេធចោល[1922]។ ពិតណាស់ ការវាយប្រហារ គឺសំដៅលើប្រជាជនស៊ីវិល មិនមែនលើទាហានដែល*បាត់បង់សមត្ថភាពប្រយុទ្ធ*នោះទេ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ ដោយយល់ស្របជាមួយនឹងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃ តុលាការ ICTY ក្នុង*រឿងក្តី Martić* ដែលបានបញ្ជាក់ថា បញ្ហានៃឋានៈរបស់ជនស៊ីវិលកើតឡើងពាក់ព័ន្ធទៅនឹងគោលដៅនៃការវាយប្រហារ ប៉ុន្តែទាក់ទងទៅនឹងករណីនីមួយៗរបស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1923]។

---

[1919] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៤។

[1920] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨៦។

[1921] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៨៣។

[1922] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨២។

[1923] សាលដីកា*រឿងក្តី Martić* (ICTY) កថាខណ្ឌ ៣០៧ (“នៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈ ឬសំអាងផ្លូវច្បាប់ពីមុនរបស់អង្គជំនុំជម្រះតុលាការកំពូលពុំបានតម្រូវថា ជនរងគ្រោះនីមួយៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែជាជនស៊ីវិលនោះឡើយ”)។ *សូមមើលផង*

៧៤១.ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីអត្ថិភាពនៃការវាយប្រហារ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើអង្គហេតុដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[1924] អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា បញ្ហានេះបានផ្អែកលើការយល់ពុំត្រឹមត្រូវលើផ្នែកពាក់ព័ន្ធនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងផ្នែកស្តីពីសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងផ្នែកអង្គច្បាប់ ទាក់ទងទៅនឹងអត្ថិភាពនៃធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើការយល់ឃើញពីដំបូងរបស់ខ្លួន[1925]។ ច្បាស់ណាស់ ការយល់ឃើញទាំងនេះ គឺស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ពាក់ព័ន្ធទៅនឹងបញ្ហានៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបនជនបទមួយទៀត និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[1926]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការចោទប្រកាន់ដទៃទៀតដែលពុំមែនជាផ្នែកនៃសំណុំរឿង ០០២/០១ ក៏ដោយ ក៏អង្គជំនុំជម្រះបានបញ្ជាក់ថា ទាំងនេះគ្រាន់តែជាការចោទប្រកាន់ដែល"ស្របតាមដីកាដំណោះស្រាយ"[1927]ប៉ុណ្ណោះ ហេតុនេះមានការបង្ហាញច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើបទចោទទាំងនេះនោះទេ ក្នុងការសម្រេចបញ្ហា ថាតើធាតុផ្សំតាមបរិបទត្រូវបានបង្ហាញ ដែរ ឬយ៉ាងណានោះ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ៤.ឃ.៥.គ.២.ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

៧៤២.ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ដែលចែងថា ការវាយប្រហារត្រូវតែធ្វើឡើង"*ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា*" អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

---

*ដែរ* កថាខណ្ឌ ៣០២ ដល់ ៣០៦, ៣០៨ ដល់ ៣០៨ និង ៣១៤។ សាលដីកា*រឿងក្តី Mrkšić និង Šljivančanin* (ICTY) កថាខណ្ឌ ២៨។

[1924] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣០ ដល់ ៣៩១។

[1925] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៣ ជើងទំព័រ ៥៧៨, ៥៧៩ យោងទៅលើកថាខណ្ឌ ១៦៩ ដល់ ១៧៣។

[1926] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៦៩ ដល់ ១៧២។

[1927] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៣។

> [...] ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនេះ ត្រូវបានអនុវត្តឡើងដោយមូលហេតុនយោបាយស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ ដើម្បីសម្រេចបានទិសដៅនេះ បក្សយល់ថា វណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុនត្រូវតែកម្ទេចចោល។ "ប្រជាជនថ្មី"ទាំងនេះត្រូវបានគេចាត់ទុកថាជាខ្មាំងខាងនយោបាយ និងខ្មាំងខាងសង្គមរបស់បដិវត្ត និងប្រព័ន្ធសមូហភាព។ លើសពីនេះទៀត ប្រជាជនកម្ពុជាទាំងអស់ត្រូវតែជាផ្នែកមួយនៃបដិវត្ត និងប្រព័ន្ធសមូហភាពនេះ។ អ្នកដែលប្រឆាំង ឬត្រូវបានគេសន្មតថាបានប្រឆាំងនឹងបដិវត្ត និងប្រព័ន្ធសមូហភាពនេះ គឺជាគោលដៅនៃការធ្វើបាប និងអំពើហិង្សា។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះត្រូវបានអនុវត្តឡើងដោយមូលហេតុនយោបាយ[1928]។

៧៤៣.នួន ជា បានអះអាងថា ពុំមានភស្តុតាងបង្ហាញថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលត្រូវបានធ្វើឡើងដោយមូលហេតុរើសអើង ឬថា វណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុនត្រូវបានប្រព្រឹត្តក្រោមទម្រង់នៃការរើសអើង ដោយបានកត់សម្គាល់យ៉ាងពិសេសទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា មិនមានការវាយប្រហារខាងនយោបាយប្រឆាំងនឹងក្រុមណាមួយនោះឡើយ[1929]។ គាត់បានទទួលស្គាល់ថា "ការជម្លៀសប្រជាជនចេញពីទីក្រុងនានា និងបញ្ជូនទៅនៅតាមសហករណ៍កសិកម្ម គឺជាផ្នែកនៃបដិវត្តន៍សង្គមនិយម"[1930]។

៧៤៤.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការបង្ហាញឱ្យឃើញពី"មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា" មិនត្រឹមតែមាននៅក្នុងនិយមន័យនៃធាតុផ្សំតាមបរិបទទាក់ទងទៅនឹងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ប៉ុណ្ណោះទេ ថែមទាំងមាននៅក្នុងនិយមន័យនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។ ទោះជាយ៉ាងណាក្តី នេះគ្រាន់តែជាធាតុផ្សំដែលកម្រិតយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះ[1931]។ ទាក់ទងទៅនឹងបទធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញ

---

[1928] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៥ (ជើងទំព័រលុបចោល)។

[1929] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៥ ដល់ ៤៧៩។

[1930] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៣៤៥។

[1931] *សូមមើល* សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១០០ កត់សម្គាល់តួនាទីនៃយុត្តាធិការរបស់ អ.វ.ត.ក តាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក។

ថា អំពើជាមូលដ្ឋានដែលជាការធ្វើទុក្ខបុកម្នេញ ត្រូវតែមាន"លក្ខណៈរើសអើងជាក់ស្តែង"[1932]ហើយជនរងគ្រោះ ជាក់ស្តែងត្រូវតែបង្ហាញឱ្យឃើញច្បាស់លាស់ និងគ្រប់គ្រាន់ថា ស្ថិតនៅក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ[1933]។ ម្យ៉ាងទៀត ការរើសអើងលើក្រុមណាមួយ គឺជាធាតុផ្សំចាំបាច់នៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៤៥.ផ្ទុយទៅវិញ ពាក់ព័ន្ធទៅនឹងធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយនឹង នួន ជា ដែលបានអះអាងថា ការវាយប្រហារត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបៀបរើសអើងនោះឡើយ[1934]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា អត្ថន័យនៃធាតុផ្សំតាមបរិបទនេះតម្រូវថា ការវាយប្រហារត្រូវតែប្រព្រឹត្តឡើងដោយផ្អែកលើមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។

៧៤៦.ទាក់ទងទៅនឹងបញ្ហានេះ ហេតុផលនៅក្នុងសាលដីកា*រឿងក្តី Tadić* របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ដែលបានពិភាក្សា និងបានសម្រេចបដិសេធការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នូវលក្ខខណ្ឌតម្រូវដោយប្រយោលថា រាល់បទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែបានប្រព្រឹត្តឡើងដោយចេតនារើសអើងស្របតាមមាត្រា ៥ នៃលក្ខន្តិកៈរបស់តុលាការ ICTY នោះ គឺជាការណែនាំយ៉ាងពិសេសថា៖

> ការតាក់តែងសមហេតុផលនៃមាត្រា ៥ [...] អាចនាំទៅរកការធ្វើសេចក្តីសន្និដ្ឋានបានថា បើនិយាយជាទូទៅ លក្ខខណ្ឌតម្រូវនេះ [ឧ.ចេតនារើសអើង] ពុំត្រូវបានកំណត់សម្រាប់រាល់បទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ប្រសិនបើកំណត់ផ្ទុយពីនេះមែននោះ ហេតុអ្វីបានជាមាត្រា ៥ (ល)បញ្ជាក់ថា"ការធ្វើទុក្ខបុកម្នេញ"ត្រូវស្ថិតក្នុងយុត្តាធិការរបស់តុលាការ ប្រសិនបើអំពើនេះត្រូវបានប្រព្រឹត្តឡើង"ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"? នោះមានន័យថា ការបញ្ជាក់នេះអាចនឹងពុំសមហេតុផល និងលែងចាំបាច់តទៅទៀត។ វិធានមូលដ្ឋាននៃការបកស្រាយកំណត់ថា ពុំគប្បីបកស្រាយបទប្បញ្ញត្តិ ឬផ្នែកនៃបទប្បញ្ញត្តិ ឱ្យទៅជាការពុំសមហេតុផល និងជាការលែងចាំបាច់

---

[1932] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៦៣ ដល់ ២៧១។ សាលដីកា*រឿងក្តី Bagasora* កថាខណ្ឌ ៤១៤។ សាលដីកា*រឿងក្តី Blaškić* កថាខណ្ឌ ១៣១។ សាលដីកា*រឿងក្តី Naletilić* កថាខណ្ឌ ៥៩០។ សាលដីកា*រឿងក្តី Stanišić* កថាខណ្ឌ ១២៣៨។ សេចក្តីសម្រេចស្តីពីការបញ្ជាក់អំពីបទចោទ*រឿងក្តី Ruto* (ICC) កថាខណ្ឌ ២៨០។

[1933] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៧៤។

[1934] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៥ ដល់ ៤៧៩។

តទៅទៀតឡើយ ដោយសារសច្ចធារណ៍ត្រូវបានតម្រូវថា អ្នកធ្វើច្បាប់បានអនុម័ត ឬយល់ស្រប ជាមួយនឹងវិធាននានាដែលត្រូវបានត្រិះរិះពិចារណាយ៉ាងត្រឹមត្រូវ និងប្រកបដោយអត្ថន័យនៅក្នុងធាតុផ្សំទាំងអស់នោះ[1935]។

៧៤៧.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា លក្ខន្តិកៈរបស់តុលាការ ICTR ដូចគ្នាទៅនឹងច្បាប់ អ.វ.ត.ក. ផងដែរ បានតម្រូវឱ្យមានការវាយប្រហារដោយផ្អែកលើ"មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"[1936]។ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង*រឿងក្តី* *Bagilishema* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានបញ្ជាក់ដូចខាងក្រោមថា៖

> ការបង្ហាញអំពី"មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា" [...] ដែលជាបញ្ហានៃការតាក់តែង គប្បីត្រូវបានបកស្រាយថា ជាការកំណត់ចរិតលក្ខណៈទៅលើ*វាយប្រហារ* ជាជាងការកំណត់ចរិតលក្ខណៈទៅលើ*ធាតុផ្សំអត្តនោម័ត*របស់ចារី[1937]។

៧៤៨.អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យរួចហើយឃើញថា នៅក្នុងយុត្តិសាស្ត្រទាក់ទងទៅនឹងធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ជាទៀងទាត់បានយោងទៅលើមូលហេតុទាំងនេះមកធ្វើជា"ការរើសអើង"[1938]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយោងទៅលើ"មូលដ្ឋាន"ជាក់លាក់ក្នុងមាត្រា ៣ នៃលក្ខន្តិកៈរបស់តុលាការ ICTR សំដៅលើចរិតជាយុត្តាធិការសម្រាប់កំណត់និយមន័យអំពីដែនកំណត់យុត្តាធិការរបស់តុលាការ ICTR ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីកាត់ទោសជនណាដែលទទួលខុសត្រូវលើការប្រព្រឹត្តបទឧក្រិដ្ឋក្នុងអំឡុង

---

1935 សាលដីកា*រឿងក្តី* *Tadić* (ICTY) កថាខណ្ឌ ២៨៤។

1936 មាត្រា ៣ នៃលក្ខន្តិកៈរបស់តុលាការ ICTR ចែងដូចតទៅថា៖ "តុលាការ [ICTR] មានសិទ្ធិអំណាចកាត់ទោសជនណាដែលទទួលខុសត្រូវលើឧក្រិដ្ឋកម្មដូចខាងក្រោម នៅពេលបានប្រព្រឹត្តដោយសារជាផ្នែកនៃការវាយប្រហារជាប្រព័ន្ធ និងទូទៅប្រឆាំងនឹងប្រជាជនស៊ីវិលដោយមូលហេតុសាសនា ពូជសាសន៍ ជាតិពន្ធុ ឬ នយោបាយ [...]"។

1937 សាលក្រម*រឿងក្តី* *Bagilishema* (ICTR) កថាខណ្ឌ ៨១ (ជើងទំព័រលុបចោល)។

1938 *សូមមើល* សាលក្រម*រឿងក្តី* *Akayesu* (ICTR) កថាខណ្ឌ ៥៨៣។ សាលក្រម*រឿងក្តី* *Bagilishema* (ICTR) កថាខណ្ឌ ៨១។ សាលក្រម*រឿងក្តី* *Rutaganda* (ICTR) កថាខណ្ឌ ៧៤។ សាលក្រម*រឿងក្តី* *Semanza* (ICTR) កថាខណ្ឌ ៣៣១។ សាលក្រម*រឿងក្តី* *Musema* (ICTR) កថាខណ្ឌ ២០៩។

ពេលនៃការជម្លោះរវាងក្រុមជនជាតិភាគតិចនៅក្នុងប្រទេសរវ៉ាន់ដា និងរដ្ឋដែលមានព្រំប្រទល់ជាប់គ្នា[1939]។ ការវាយប្រហារដែលត្រូវបានប្រព្រឹត្តឡើងដោយមូលហេតុ ជាតិពន្ធុ ជាមូលដ្ឋាន គឺជាការរើសអើង ប៉ុន្តែសម្រាប់តុលាការ ICTR បញ្ហាគឺ ថាតើការវាយប្រហារ ជាក់ស្តែងត្រូវតែជាការរើសអើង ដែរ ឬយ៉ាងណានោះ ពុំត្រូវបានបង្ហាញច្បាស់លាស់ឡើយ។ បន្ថែមលើនេះទៀត តុលាការ ICTR បានបញ្ជាក់ស្របគ្នាថា អំពើដែលបានប្រព្រឹត្តឡើងប្រឆាំងទៅនឹងបុគ្គលដែលពុំស្ថិតក្នុង"ប្រភេទនៃក្រុមដែលមានការរើសអើង" ទោះជាយ៉ាងណាក្តី អាចជាផ្នែកនៃការវាយប្រហារ ក្នុងករណីដែលអំពើប្រឆាំងទៅនឹងក្រុមដែលពុំស្ថិតក្នុងប្រភេទនោះបានគាំទ្រ ឬជំរុញ ឬក្នុងគោលបំណងដើម្បីគាំទ្រ ឬដើម្បីជំរុញការវាយប្រហារទៅនឹងក្រុមនោះ[1940]។ នេះបញ្ជាក់ថា ទោះបីជាមានក៏ដោយ ក៏តុលាការ ICTR ពុំបានយកមកដាក់ជាបន្ទុកលើខ្លួនច្រើនអំពីបញ្ហាដែល ថាតើការវាយប្រហារនោះជាការរើសអើង ដែរ ឬយ៉ាងណានោះឡើយ។

៧៤៩.ដោយសារមូលហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះពុំតម្រូវឱ្យអនុវត្តតាមការបកស្រាយរបស់តុលាការ ICTR អំពីធាតុផ្សំនៃយុត្តាធិការ និងថា សេចក្តីសន្និដ្ឋានជាទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការវាយប្រហារបានកើតឡើងដោយមូលហេតុនយោបាយនោះ ពុំមែនជាកំហុសឡើយ[1941]។

### ៤.ឃ.៥.គ.៣.ទំនាក់ទំនងជាមួយនឹងការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ

៧៥០.ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវដែលថា ត្រូវតែមានទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទជាមួយនឹងការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធនោះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា៖

> អង្គជំនុំជម្រះជឿជាក់បន្ថែមទៀតថា មានទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទ និងការវាយប្រហារនេះ។ អំពើរបស់ចារី និងជនជាប់ចោទនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន នៅ

---

[1939] *សូមមើល* មាត្រា ១ នៃលក្ខន្តិកៈរបស់តុលាការ ICTR ("តុលាការ [ICTR] ត្រូវមានសិទ្ធិអំណាចកាត់ទោសជនដែលទទួលខុសត្រូវលើការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិដែលបានប្រព្រឹត្តឡើងនៅលើទឹកដីរបស់ប្រទេសរវ៉ាន់ដា និងជនជាតិរវ៉ាន់ដាដែលទទួលខុសត្រូវសម្រាប់ការរំលោភបំពាននេះដែលប្រព្រឹត្តឡើងនៅលើទឹកដីរដ្ឋជាប់ព្រំប្រទល់ពីចន្លោះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្របតាមបទប្បញ្ញត្តិនៃលក្ខន្តិកៈរដ្ឋបច្ចុប្បន្ន")។

[1940] សាលក្រម *រឿងក្តី* *Semanza* (ICTR) កថាខណ្ឌ ៣៣១។ សាលក្រម *រឿងក្តី Musema* (ICTR) កថាខណ្ឌ ២០៩។ សាលក្រម *រឿងក្តី Akayesu* (ICTR) កថាខណ្ឌ ៥៨៤។ សាលក្រម *រឿងក្តី Rutaganda* (ICTR) កថាខណ្ឌ ៧៤។

[1941] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៦។

01358391



ដំណាក់ទីមួយ និងដំណាក់ទីពីរ និងក្នុងអំឡុងពេលនៃការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ត្រូវបានប្រព្រឹត្តឡើងនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងខែ ធ្នូ ឆ្នាំ ១៩៧៧ និងត្រូវបានអនុវត្តឡើងដើម្បីជំរុញ និងស្របតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការការពារ និងកសាងសង្គមនិយម[1942]។

៧៥១.ទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវដែលថា ជនជាប់ចោទបានដឹងអំពីការវាយប្រហារ និងថា អំពើរបស់ខ្លួនគឺជាផ្នែកមួយនោះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាៈ

> [...] ដោយពិចារណាទៅលើទំហំ និងវិសាលភាពនៃការវាយប្រហារនេះ និងចំណុចដែលថា ការវាយប្រហារនេះត្រូវបានអនុវត្តឡើងដើម្បីជាការជំរុញ និងស្របតាមគោលនយោបាយ និងផែនការរបស់បក្សនោះ អង្គជំនុំជម្រះជឿជាក់ថា ទាំងចារី និងជនជាប់ចោទបានដឹងអំពីការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល និងបានដឹងថា អំពើទាំងឡាយរបស់ពួកគេបង្កើតបានជាផ្នែកមួយនៃការវាយប្រហារនេះ[1943]។

៧៥២.នួន ជា និង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថាទំនាក់ទំនងមានអត្ថិភាពរវាងការវាយប្រហារជាមួយនឹងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះ[1944]។ ខៀវ សំផន ក៏បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីការវាយប្រហារនេះ[1945]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់នៅក្នុងសាលដីកា*រឿងក្តី Kunarac* ថា ទំនាក់ទំនងនេះមានធាតុផ្សំពីរយ៉ាងដែលអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាតាមលំដាប់លំដោយដូចតទៅៈ

> (i) ផ្អែកតាមចរិតលក្ខណៈ និងផលវិបាក ការប្រព្រឹត្តអំពើដែលជាសត្យានុម័ត គឺជាផ្នែកនៃការវាយប្រហារ និងត្រូវបូករួមជាមួយនឹង

---

[1942] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៧ (ជើងទំព័រលុបចោល)។

[1943] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៧ (ជើងទំព័រលុបចោល)។

[1944] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៧៨។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣៨ និង ៣៤១។

[1945] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣៨ និង ៣៤១។

01358392



(ii) ការដឹងពីសំណាក់ជនជាប់ចោទថា មានការវាយប្រហារទៅលើប្រជាជនស៊ីវិល និងថា អំពើរបស់គាត់ គឺជាផ្នែកមួយនោះ[1946]។

៧៥៣.ទាក់ទងទៅនឹងធាតុផ្សំទីមួយ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកលើសាលដីកា *រឿងក្តី Kunarac* ថា "អំពើរបស់ចារីត្រូវតែជាផ្នែកមួយនៃការវាយប្រហារ មានន័យថា អំពើនោះផ្អែកតាមចរិតលក្ខណៈ និងផលវិបាកនៃអំពើជាសត្យានុម័ត ត្រូវតែជាផ្នែកនៃការវាយប្រហារ"[1947]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានប្រើប្រាស់ពាក្យពេចន៍"ជនជាប់ចោទ" និង"ចារី"ជំនួសគ្នាបាននៅក្នុងផ្នែកដែលពាក់ព័ន្ធនៅក្នុងសាលដីកា *រឿងក្តី Kunarac* (ICTY)[1948]។ ក្នុងសាលដីកា *រឿងក្តី Mrkšić និង Šljivančanin* (ICTY) នៅក្នុងបរិបទដូចគ្នានេះ បានប្រើប្រាស់ពាក្យថា"ជនជាប់ចោទ"[1949] ហើយក្នុងសាលដីកា *រឿងក្តី Šainović* (ICTY) បានប្រើប្រាស់ពាក្យ"ចារី"ទៅវិញ[1950]។

៧៥៤.ផ្អែកតាមមូលដ្ឋានខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំពើរបស់ជនជាប់ចោទ បើទោះបីជាពុំមែនជាចារីផ្ទាល់ក៏ដោយ ក៏ត្រូវតែជាផ្នែកមួយនៃការវាយប្រហារដែរ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្តទៀតអំពីទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទជាមួយនឹងការវាយប្រហារ និងបានយោងទៅលើ"អំពើរបស់ចារីផ្ទាល់ និងរបស់ជនជាប់ចោទ"នៅក្នុងការយល់ឃើញនេះ[1951]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសទាក់ទងទៅនឹងបញ្ហានេះឡើយ។

---

[1946] សាលដីកា *រឿងក្តី Kunarac* (ICTY) កថាខណ្ឌ ៩៩។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី Mrkšić និង Šljivančanin* (ICTY) កថាខណ្ឌ ៤១។ សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២៤៨។

[1947] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩០ យោងទៅលើសាលដីកា *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ៣១៨។ សាលដីកា *រឿងក្តី Kunarac* (ICTY) កថាខណ្ឌ ៨៥។ សាលដីកា *រឿងក្តី Šainović* (ICTY) កថាខណ្ឌ ២៦៤។

[1948] សាលដីកា *រឿងក្តី Kunarac* (ICTY) កថាខណ្ឌ ៨៥។

[1949] សាលដីកា *រឿងក្តី Mrkšić និង Šljivančanin* (ICTY) កថាខណ្ឌ ៤១។

[1950] សាលដីកា *រឿងក្តី Šainović* (ICTY) កថាខណ្ឌ ២៦៤។

[1951] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៧។

៧៥៥.បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងដែលថា អំពើរបស់ ខៀវ សំផន និង អំពើរបស់ចារីផ្ទាល់ ផ្អែកតាមចរិតលក្ខណៈ ឬផលវិបាកនៃអំពើនេះ គឺជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធលើប្រជាជនស៊ីវិលកម្ពុជា[1952]ដែលផ្ទុយពីការអះអាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះ[1953] ។ ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា[1954] ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការប្រើអំពើហិង្សាលើប្រជាជនស៊ីវិលមុនខែ មេសា ឆ្នាំ ១៩៧៥ នោះ អង្គជំនុំជម្រះតុលាការ កំពូលកត់សម្គាល់ឃើញថា ពាក់ព័ន្ធទៅនឹងការវាយប្រហារលើប្រជាជនស៊ីវិលដែលជាផ្នែកនៃធាតុផ្សំ*តាមបរិបទ*នោះ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ការយល់ឃើញទាក់ទងទៅនឹងអត្ថិភាពនៃការវាយប្រហារដែលជាប់ ពាក់ព័ន្ធទៅនឹងអំឡុងពេលត្រឹមតែចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ (យ៉ាងហោចណាស់)ខែ ធ្នូ ឆ្នាំ ១៩៧៧[1955]ប៉ុណ្ណោះ។

## ៤.ឃ.៥.គ.៤.ការដឹង

៧៥៦.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ទាំងចារីផ្ទាល់ និងជនជាប់ចោទ បានដឹងអំពីការវាយប្រហារលើប្រជាជនស៊ីវិល និងថា អំពើនេះ គឺជាផ្នែកមួយនៃការវាយ ប្រហារ"[1956] ដោយបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានចំណាយត្រឹមតែ"ពីរ ឬបីបន្ទាត់" ប៉ុណ្ណោះលើបញ្ហានេះ[1957]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា នៅក្នុងជើងទំព័រដែលបានភ្ជាប់ ទៅនឹងការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើការយល់ឃើញផ្សេងៗទៀតនៅក្នុង សាលក្រមរបស់ខ្លួនដែល ខៀវ សំផន ពុំបានពិភាក្សា។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

---

[1952] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៧ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៦៩, ៥៤៧ ដល់ ៥៧៤, ៦៣០ ដល់ ៦៥៧, ៦៨២ ដល់ ៦៨៧, ៦៩០ ដល់ ៧០២។

[1953] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣៨។

[1954] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៧៨។

[1955] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៣។

[1956] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៩៧។

[1957] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៣៨។

៧៥៧.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាអំពើដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះ មានទំនាក់ទំនងជាមួយនឹងការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធប្រឆាំងទៅលើប្រជាជនស៊ីវិលកម្ពុជាដោយមូលហេតុនយោបាយ នៅក្នុងអំឡុងពេលយុត្តាធិការពេលវេលានៃសំណុំរឿង ០០២/០១ ដោយមានការដឹងអំពីការវាយប្រហារ និងថា អំពើរបស់ជនជាប់ចោទ គឺជាផ្នែកមួយនៃការវាយប្រហារ។

## ៤.ឃ.៦.ភាពអាចដឹងជាមុន/គោលការណ៍នីត្យានុកូលភាព

៧៥៨.អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា "នៅក្នុងបរិបទជាក់លាក់របស់ អ.វ.ត.ក. គោលការណ៍នីត្យានុកូលភាពតម្រូវថា បទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ ត្រូវបានទទួលស្គាល់ស្របតាមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិដោយមានអត្ថិភាពនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយជនជាប់ចោទអាចដឹងជាមុនបានគ្រប់គ្រាន់ថា ជាបទល្មើស និងមានច្បាប់ចែង"[1958]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមទៀតថា "អនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. បទចោទស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានលក្ខណៈស្របទៅនឹងគោលការណ៍នីត្យានុកូលភាព លុះណាតែមានសេចក្តីសន្និដ្ឋានបន្ថែមថា ជនជាប់ចោទ*អាចយល់ដឹងជាមុនបានគ្រប់គ្រាន់អំពីបទល្មើសដែលបានចោទប្រកាន់ ឬទម្រង់នៃការទទួលខុសត្រូវនោះ និងមានច្បាប់ចែងអំពីការទទួលខុសត្រូវផងដែរនាពេលនោះ*"[1959]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ការវិភាគបែបនេះត្រូវធ្វើឡើងសម្រាប់បទឧក្រិដ្ឋជាមូលដ្ឋាន ឬទម្រង់នៃការទទួលខុសត្រូវ មិនមែនធ្វើឡើងសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងមូលនោះឡើយ"[1960]។ ផ្អែកតាមវិធីសាស្ត្រនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា

---

[1958] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៦ យោងទៅលើសាលក្រម*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៦ ដល់ ៣៤។ សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៨៩ ដល់ ៩៧។ មាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

[1959] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៦ យោងទៅលើសាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៩៦ និង ដកស្រង់សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Ojdanić* (ICTY) កថាខណ្ឌ ២១ និង ៣៧ (ជើងទំព័រលុបចោល) ។

[1960] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៦។

បទមនុស្សឃាត[1961] បទសម្លាប់រង្គាល[1962] បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[1963] និងបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានបំពេញតាមគោលការណ៍នីត្យានុកូលភាព[1964]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា ការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមទម្រង់មូលដ្ឋាន និងជាប្រព័ន្ធ (“JCE I” និង “JCE II”) ស្របតាមគោលការណ៍នេះ ដោយផ្អែកលើចរិតលក្ខណៈជាច្បាប់ទំនៀមទម្លាប់នៅចន្លោះរវាងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ និងតួនាទីជាន់ខ្ពស់របស់ជនជាប់ចោទ[1965]។

៧៥៩.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពិចារណាថា មុខងារជាន់ខ្ពស់របស់គាត់ក្នុងអំឡុងពេលនោះ បានធ្វើឱ្យគាត់ទទួលរងការចោទប្រកាន់ពីបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវដែលគាត់អាចដឹងជាមុនបានគ្រប់គ្រាន់ថា មានច្បាប់ចែង និងជាបទល្មើស[1966]។ ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា ភាពអាចដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែងចំពោះអំពើនោះ អាស្រ័យលើភាពច្បាស់លាស់ និងភាពអាចយល់ដឹងជាមុនពីសំណាក់“ប្រជាពលរដ្ឋគ្រប់រូប”ជាជាងលើមុខងាររបស់ជនជាប់ចោទ[1967]។ បន្ថែមលើនេះទៀត ខៀវ សំផន បានអះអាងថា “ការពិតថា បទឧក្រិដ្ឋមួយ ឬទម្រង់នៃការទទួលខុសត្រូវមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ នោះ ពុំគ្រប់គ្រាន់ដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពអាចយល់ដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែង” ជាពិសេសដោយផ្អែកលើហេតុការណ៍ពិតដែលថា កម្ពុជាមានប្រព័ន្ធគតិយុត្តទ្វិកនិយមដែលមានន័យថា ដោយសារពុំមានការអនុវត្តក្នុងស្រុក ទើបពុំមានបទដ្ឋានអន្តរជាតិណាមួយបានបង្កើតជាផ្នែកនៃច្បាប់កម្ពុជាឡើយ[1968]។ ខៀវ សំផន បានជំទាស់បន្ថែមទៀតថា និយមន័យនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវដែលបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង មិនអាចយល់ដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែងនៅក្នុងឆ្នាំ ១៩៧៥[1969] រួម

---

[1961] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១១។

[1962] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤១៥។

[1963] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤២៦។

[1964] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៣៥។

[1965] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩១។

[1966] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៩។

[1967] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០០។

[1968] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០១។

[1969] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០២។

ទាំងធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1970] *ធាតុផ្សំអត្តនោម័ត*នៃបទមនុស្សឃាត បទសម្លាប់រង្គាល[1971] ហើយអំពើប្រព្រឹត្ត និងចេតនាដែលជាលក្ខខណ្ឌតម្រូវក្នុងការបង្ហាញអំពីទម្រង់នៃការទទួលខុសត្រូវ ដែលស្របទៅនឹងការដាក់ពិរុទ្ធភាពលើរូបគាត់[1972]ឡើយ។

៧៦០.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការពិចារណាទៅលើមុខងារជាន់ខ្ពស់របស់ ខៀវ សំផន ដោយបានយល់ឃើញថា គាត់អាចយល់ដឹងបានជាមុនថា មានច្បាប់ចែង[1973]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងដែលបានលើកឡើងដោយ ខៀវ សំផន ជាទឡ្ហីករណ៍នៅក្នុងបណ្តឹងសាទុក្ខនេះ បានបកស្រាយពុំត្រឹមត្រូវលើលក្ខខណ្ឌតម្រូវនៃភាពអាចយល់ដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស ដែលមាននៅក្នុងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និងនៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28)[1974]។

៧៦១.ទាក់ទងទៅនឹងការលើកឡើងដែលថា បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ត្រូវតែច្បាស់លាស់ ហើយ“ប្រជាពលរដ្ឋគ្រប់រូប”អាចយល់ដឹងជាមុនបានថា មានច្បាប់ចែង ដើម្បីកុំឱ្យការដាក់ពិរុទ្ធភាពរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាពនោះ[1975] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ការសម្រេចរបស់ខ្លួននៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28)ថា ភាពត្រឹមត្រូវ និងក្តីបារម្ភឱ្យមានកិច្ចដំណើរការនីតិវិធីបានឆាប់រហ័សដែលជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិបានតម្រូវថា រាល់បទល្មើសដែលបានចោទប្រកាន់ ឬរាល់ទម្រង់នៃការទទួលខុសត្រូវ “ត្រូវមានលក្ខណៈអាចយល់ដឹងជាមុនបានគ្រប់គ្រាន់ថា ជាបទល្មើស ហើយថា ជនជាប់ចោទអាចដឹងបានថា មានច្បាប់ចែង [...] នាពេលនោះ”[1976]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា លក្ខខណ្ឌតម្រូវនៃភាពអាចយល់ដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើស

---

[1970] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៣។

[1971] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៤។

[1972] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៥ ដល់ ១០៧។

[1973] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦។

[1974] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦។

[1975] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០០។

[1976] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៩៦ ដកស្រង់សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Ojdanić* (ICTY) កថាខណ្ឌ ២១, ៣៧ និង យោងទៅលើសាលក្រម *រឿងក្តី Blagojević និង Jokić* (ICTY) កថាខណ្ឌ ៦៩៥ ជើងទំព័រ ២១៤៥ និង សាលក្រម *រឿងក្តី S.W. ទល់នឹងចក្រភពអង់គ្លេស* (ECtHR) កថាខណ្ឌ ៣៥ ដល់ ៣៦។

ត្រូវតែកំណត់តាមរយៈការវិភាគជាសត្យានុម័ត មានន័យថា បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអាចយល់ដឹងបានជាមុនថា ជាបទល្មើស និងមានច្បាប់ចែងជាទូទៅ ដូចដែល ខៀវ សំផន បានលើកឡើងដែរ[1977]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងសមហេតុផលទៅលើមុខងារជាន់ខ្ពស់របស់ ខៀវ សំផន ក្នុងការកំណត់ ថាតើគោលការណ៍នីត្យានុកូលភាពត្រូវតែគោរពតាមសម្រាប់បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ ដែរ ឬយ៉ាងណានោះ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានទទួលយកវិធីសាស្ត្រនេះនៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28) ដោយបានធ្វើការពិចារណាយ៉ាងច្បាស់លាស់ថា ឌុច ដែលជា"កម្មាភិបាលម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ" និងបានយល់ឃើញថា "ជនជាប់ចោទអាចយល់ដឹងជាមុនបានយ៉ាងគ្រប់គ្រាន់ថា មានច្បាប់កំណត់អំពីនិយមន័យនៃបទធ្វើទុក្ខបុកម្នេញនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តបទល្មើសដែលរងការចោទប្រកាន់នោះ"[1978]។ បន្ថែមលើនេះទៀត វិធីសាស្ត្រនេះស្របជាមួយនឹងគោលបំណងនៃគោលការណ៍នីត្យានុកូលភាព[1979]។ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះ។

៧៦២.ទាក់ទងទៅនឹងអំណះអំណាងដែលថា លក្ខណៈវិនិច្ឆ័យនៃភាពអាចយល់ដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើសពុំអាចត្រូវបានបំពេញដោយសារហេតុការណ៍ពិតដែលថា បទឧក្រិដ្ឋមួយ ឬទម្រង់នៃការទទួលខុសត្រូវ មានអត្ថិភាពស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ នោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅក្នុងសាលដីកា *រឿងក្តី ឌុច* (001-F28) បានពិចារណាឃើញថា "រាល់បទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. ត្រូវតែមានអត្ថិភាពក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលអំពើល្មើសដែលបានចោទប្រកាន់នោះបានកើតឡើងនៅក្នុងចន្លោះពីថ្ងៃទី ១៧ ខែ មេ

---

[1977] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៩ ដល់ ១០០។

[1978] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ២៨០។

[1979] *សូមមើល* សាលក្រម *រឿងក្តី Vasiljević* (ICTY) កថាខណ្ឌ ១៩៣ ("ការសម្រេចដាក់ពិរុទ្ធភាពផ្អែកព្រហ្មទណ្ឌ [...] ពុំគប្បីត្រូវបានផ្អែកទៅលើបទដ្ឋានដែលជនជាប់ចោទពុំបានដឹងដោយសមហេតុផលអំពីអំឡុងពេលនៃអំពីប្រព្រឹត្ត ហើយបទដ្ឋាននេះត្រូវតែមានលក្ខណៈច្បាស់ លាស់គ្រប់គ្រាន់ថា តើអំពើសកម្ម ឬអំពើអកម្មអ្វីខ្លះ ដែលជាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទនោះ") យោងទៅលើ សាលក្រម *រឿងក្តី S.W. ទល់នឹងចក្រភពអង់គ្លេស* (ECtHR) ទំព័រ ៤២។ សាលក្រម *រឿងក្តី Giniewski ទល់នឹងប្រទេសបារាំង* (ECtHR) ទំព័រ ៣៨។ សាលក្រម *រឿងក្តី Kokkinakis ទល់នឹងប្រទេសក្រិច* (ECtHR) ទំព័រ ២២ ។

សា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩”[1980] ដែលជាវិធីសាស្ត្រមួយស្របជាមួយនឹងគោលបំណងនៃគោលការណ៍នីត្យានុកូលភាព បទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងយុត្តិសាស្ត្ររបស់តុលាការ ICTY[1981]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកបន្ថែមទៀតថា ទាក់ទងទៅនឹងលក្ខខណ្ឌនៃភាពអាចយល់ដឹងជាមុនបានថា មានច្បាប់ចែងនោះ ក្រៅពីសន្ធិសញ្ញានានា នៅមាន“ច្បាប់នានាដែលបានផ្អែកលើទំនៀមទម្លាប់ [...] អាចយកមកធ្វើជាសំអាងក្នុងការបញ្ជាក់ថា ជនជាប់ចោទអាចយល់ដឹងគ្រប់គ្រាន់បានថា មានច្បាប់ចែង”[1982] និងថា ចំពោះភាពអាចយល់ដឹងជាមុនបាន ជនជាប់ចោទ“ត្រូវតែអាចយល់ដឹងថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាបទល្មើសក្នុងន័យដែលគេអាចយល់ដឹងជាទូទៅបាន ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះទេ”[1983]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា ដោយសារតែបទឧក្រិដ្ឋមួយចំនួនដែល ខៀវ សំផន ត្រូវបានដាក់ពិរុទ្ធភាពនោះ “គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុតដែលគេអាចយល់ដឹងបាន។ ខៀវ សំផន មិនអាចប្រកែកថា គាត់មិនអាចយល់ដឹងបានថា អំពើរបស់គាត់ គឺជាអំពើល្មើសក្នុងន័យដែលមនុស្សទូទៅអាចយល់ដឹងបាននោះឡើយ”[1984]។

---

[1980] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៩១ (ជើងទំព័រលុបចោល)។

[1981] *សូមមើល* សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៩១ យោងទៅលើមាត្រា ១៥(១-២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Ojdanić* (ICTY) កថាខណ្ឌ ១០, ៣៨ និង មាត្រា ១ នៃច្បាប់ អ.វ.ត.ក ។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/2/15) កថាខណ្ឌ ៩៨។

[1982] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៩៦ យោងទៅលើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Hadžihasanović និង Kubura* (ICTY) កថាខណ្ឌ ៣៤ និងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Ojdanić* (ICTY) កថាខណ្ឌ ៤០។

[1983] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៩៦ យោងទៅលើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Hadžihasanović និង Kubura* (ICTY) កថាខណ្ឌ ៣៤។

[1984] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៩៦ យោងទៅលើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីយុត្តាធិការ *រឿងក្តី Ojdanić* (ICTY) កថាខណ្ឌ ៤២ (“បើទោះបីជាអំពើអសីលធម៌ ឬមានចរិតគួរឱ្យរន្ធត់ ពុំមែនជាកត្តាគ្រប់គ្រាន់ក្នុងការធានាបាននូវការចាត់ទុកជាបទឧក្រិដ្ឋក៏ដោយ [...] ក៏អំពើទាំងនេះជាក់ស្តែងអាចដើរតួនាទី [...] ត្រង់ចំណុចថា អំពើនេះអាចបដិសេធការអះអាងណាមួយរបស់ជនជាប់ចោទដែលថា ខ្លួនពុំបានដឹងអំពីចរិតល្មើសនៃអំពើនោះ”)។

៧៦៣.ចំពោះអំណះអំណាងដែលបានលើកឡើងថា បទដ្ឋានអន្តរជាតិពុំអាចបង្កើតបានជាផ្នែកមួយនៃច្បាប់ជាតិនៅក្នុងអំឡុងពេលនៃអង្គហេតុដោយសារកម្ពុជាមានប្រព័ន្ធគតិយុត្តទ្វិកនិយម និងថា ពុំអាចរំពឹងទុកបានចំពោះការអនុវត្តបទដ្ឋានអន្តរជាតិនោះ ខៀវ សំផន បានបង្ហាញពុំត្រឹមត្រូវអំពីការយល់ឃើញរបស់អង្គបុរេជំនុំជម្រះដែលខ្លួនបានយោងនៅក្នុងសារណាបណ្តឹងសាទុក្ខ[1985]។ នៅក្នុងកថាខណ្ឌបន្ទាប់ដែល ខៀវ សំផន បានយោងទៅលើនោះ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "ច្បាប់ អ.វ.ត.ក. [...] តម្រូវឱ្យ អ.វ.ត.ក. អនុវត្តយុត្តាធិការរបស់ខ្លួនឱ្យស្របតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដែលបានអនុញ្ញាតសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសទាំងឡាយដែលមានចរិតលក្ខណៈជាតិ ឬអន្តរជាតិក្នុងអំឡុងពេលនៃការប្រព្រឹត្តបទល្មើសទាំងនេះ"[1986] ដែលជាការយល់ឃើញមួយស៊ីសង្វាក់គ្នាយ៉ាងច្បាស់ជាមួយនឹងសាលដីកា *រឿងក្តី ឌុច* (001-F28)។

៧៦៤.ទាក់ទងទៅនឹងភាពអាចយល់ដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែងអំពីធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1987] អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការវិភាគលើបញ្ហា ថាតើបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់នោះបានបំពេញតាមគោលការណ៍នីត្យានុកូលភាព ដែរ ឬយ៉ាងណានោះ គប្បី"ត្រូវធ្វើឡើងទៅតាមកម្រិតនៃបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវដែលជាមូលដ្ឋាន ជាជាងធ្វើឡើងសម្រាប់ប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងមូល"[1988]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញនៅក្នុងសាលដីកា*រឿងក្តី ឌុច* (001-F28) ដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើនោះ[1989] ថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មអន្តរជាតិស្ថិតក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក."[1990]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញដូចខាងលើថា ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានចែងនៅក្នុងលិខិតុបករណ៍ផ្នែកច្បាប់អន្តរជាតិ និងក្នុងស្រុក

---

[1985] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០១ យោងទៅលើ*ក្នុងចំណោមនោះ*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីការដំណោះស្រាយ ឯកសារលេខ D427/2/15 កថាខណ្ឌ ៩៧ ជើងទំព័រ ២១៥។

[1986] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីការដំណោះស្រាយ (D427/2/15) កថាខណ្ឌ ៩៨ (សេចក្តីបញ្ជាក់ដើម)។

[1987] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៣។

[1988] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៦។

[1989] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧៦។

[1990] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១០៤, ៩៩ ដល់ ១០៣។

ជាច្រើននៅក្រោយសង្គ្រាមលោកលើកទីពីរ និងជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥[1991]។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន អាចយល់ដឹងជាមុនគ្រប់គ្រាន់បានថា ជាបទល្មើស និងមានច្បាប់ចែងអំពីធាតុផ្សំនេះ ក្នុងឋានៈខ្លួនជាកម្មាភិបាលម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ ១៩៧៥។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

៧៦៥.ចំពោះភាពអាចយល់ដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែងអំពីធាតុផ្សំ*អត្តនោម័ត*នៃបទមនុស្សឃាត និងបទសម្លាប់រង្គាល[1992] អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យពិចារណាឡើងវិញយ៉ាងទូលំទូលាយអំពីធាតុផ្សំអត្តនោម័តនៃបទឧក្រិដ្ឋទាំងនេះ[1993]។ ទាក់ទងទៅនឹងបទមនុស្សឃាត ការពិចារណានេះឈានទៅធ្វើសេចក្តីសន្និដ្ឋានបានថា ធាតុផ្សំអត្តនោម័តដែលមានលក្ខណៈពុំសូវរឹតត្បិតដោយយកទាំងចេតនាផ្ទាល់ និងប្រយោល គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥[1994]។ ដូចបានកត់សម្គាល់ខាងលើពាក់ព័ន្ធទៅនឹងភាពអាចយល់ដឹងជាមុនបាន ជនជាប់ចោទ"អាចដឹងគ្រប់គ្រាន់បានថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើល្មើសក្នុងន័យដែលមនុស្សទូទៅអាចយល់ដឹងបាន ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយ"នោះឡើយ[1995]។ ដូច្នេះ អ្វីដែលតម្រូវនោះ គឺមិនមែនជាការពិចារណាអំពីពាក្យពេចន៍បច្ចេកទេសក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនោះឡើយ ប៉ុន្តែនៅត្រង់ ថាតើជាទូទៅអាចយល់ដឹងជាមុនបានថា អំពើនោះអាចតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ ពុំមានភាពចាំបាច់ត្រូវបង្ហាញថា អាចយល់ដឹងជាមុនបានថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអាចកើតឡើងនៅក្នុងកាលៈទេសៈនៃការប្រព្រឹត្តដោយ *ចេតនាប្រយោល* (dolus eventualis) ដែលផ្ទុយពី*ចេតនាផ្ទាល់* (dolus directus) នោះទេ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលបានលើកឡើងទាក់ទងទៅនឹងបញ្ហានេះ។

---

[1991] *សូមមើលខាងលើ* កថាខណ្ឌ ៧២១។

[1992] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៤។

[1993] *សូមមើលខាងលើ* កថាខណ្ឌ ៣៨៧ *ជាអាទិ៍*។ *សូមមើលខាងលើ* កថាខណ្ឌ ៥១០ *ជាអាទិ៍*។

[1994] *សូមមើលខាងលើ* កថាខណ្ឌ ៥១០។

[1995] *សូមមើលខាងលើ* កថាខណ្ឌ ៧៦២។

៧៦៦.អង្គជំនុំជម្រះតុលាការកំពូល នឹងត្រូវធ្វើការដោះស្រាយលើអំណះអំណាងទាក់ទងទៅនឹងភាពអាចយល់ដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែងអំពីទម្រង់នៃការទទួលខុសត្រូវដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពដូចខាងក្រោម[1996]។

## ៤.ង.ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ

## ៤.ង.១.ការរួមចំណែកក្នុងគោលបំណងរួម("សហឧក្រិដ្ឋកម្មរួម")

៧៦៧.អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានដូចជា បទមនុស្សឃាត បទសម្លាប់រង្គាល បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងបទអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើការរួមចំណែកសំខាន់នៅក្នុងការអនុវត្តគោលបំណងរួម[1997]។ នៅដំណាក់កាលបណ្តឹងសាទុក្ខ នួន ជា និង ខៀវ សំផន បានលើកអំណះអំណាងជាច្រើនទាក់ទងទៅនឹងវិធីសាស្រ្ត និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវនេះ ដែលអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយបញ្ហានេះតាមលំដាប់លំដោយ។

### ៤.ង.១.ក.អត្ថិភាព និងវិសាលភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើការរួមចំណែកយ៉ាងសំខាន់នៅក្នុងគោលបំណងរួម

៧៦៨.ទាក់ទងទៅនឹងការចោទប្រកាន់ដែលថា នួន ជា និង ខៀវ សំផន ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងនៅទួលពោធិ៍ជ្រៃដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវ ដែលនៅក្នុងយុត្តិសាស្រ្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍* បានសំដៅលើសហឧក្រិដ្ឋកម្មរួម"JCE"ទម្រង់មូលដ្ឋាន (ដែលហៅថា ទម្រង់ I "JCE I") អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការទទួលខុសត្រូវបែបនេះត្រូវតែមានការរួមចំណែករបស់បុគ្គលជាច្រើននៅក្នុងគោលបំណងរួមមួយដែលជាការប្រព្រឹត្តបទឧក្រិដ្ឋ ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តនេះ និងថា ជនជាប់ចោទត្រូវចូលរួមនៅក្នុងគោលបំណងរួមនេះតាមរយៈការរួមចំណែកយ៉ាងសំខាន់នៅក្នុងការអនុវត្ត ប៉ុន្តែពុំ

---

[1996] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៥ ដល់ ១០៧។

[1997] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧៧ (នួន ជា) និង ៩៦៦ (ខៀវ សំផន)។

ចាំបាច់ថា មិនអាចខ្វះបាននោះទេ[1998]។ នៅក្នុងសាលក្រម ទាក់ទងទៅនឹងគោលនយោបាយផ្លាស់ទីលំនៅប្រជាជន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយនេះ"*បានបណ្តាលឱ្យមាន* និង/ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ"[1999]។

៧៦៩.អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម"អាចនឹងទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ ដែលពុំមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដរាបណាមានការបង្ហាញឱ្យឃើញថា យ៉ាងហោចណាស់មានអ្នកចូលរួមនៃសហឧក្រិដ្ឋកម្មរួមម្នាក់ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះ ហើយអ្នកចូលរួមនេះបានប្រើប្រាស់ចារីផ្ទាល់ដើម្បីជំរុញនូវគោលបំណងរួម"[2000]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការទទួលខុសត្រូវក្រោមទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមតម្រូវថា ជនជាប់ចោទ"ត្រូវតែមានចេតនាចូលរួមក្នុងគោលបំណងរួម ហើយចេតនានេះត្រូវតែបានរួមចំណែកពីសំណាក់អ្នកចូលរួមដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម"[2001]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អ្នកចូលរួមនៃសហឧក្រិដ្ឋកម្មរួម"ត្រូវតែបានបង្ហាញឱ្យឃើញថា បានរួមចំណែកនៅក្នុងចេតនាតម្រូវរបស់ចារីផ្ទាល់ រួមទាំងចេតនាជាក់លាក់ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មនោះផងដែរ"[2002]។

៧៧០.នួន ជា បានអះអាងថា នៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទ សញ្ញាណនៃសហឧក្រិដ្ឋកម្មរួមពុំមានអត្ថិភាពជាទម្រង់ដូចការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ត្រឹមតែតម្រូវឱ្យមានការរួមចំណែកយ៉ាងសំខាន់របស់ជនជាប់ចោទទៅលើការអនុវត្តគោលបំណងរួម[2003]។ នៅក្នុងសារណា នួន ជា បានលើកឡើងថា "នៅចន្លោះរវាងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ការប្រព្រឹត្តបទល្មើសរួម គឺជាទម្រង់មួយយ៉ាងចង្អៀត

---

[1998] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩២។

[1999] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៤ (សេចក្តីបញ្ជាក់បន្ថែម)។

[2000] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៣។

[2001] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៤។

[2002] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៤។

[2003] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩២។

ចំពោះការទទួលខុសត្រូវជាលក្ខណៈបុគ្គលដែលត្រូវបានកម្រិតត្រឹមការរួមចំណែករួមគ្នានៅក្នុងអំពើល្មើស *ជាក់លាក់* ដោយមានចេតនាល្មើសរួមប៉ុណ្ណោះ”[2004]។ នួន ជា បានលើកឡើងថា សញ្ញាណនៃសហឧក្រិដ្ឋកម្មរួមតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង “ត្រូវបានបង្កើតឡើងក្នុងរយៈពេល ២០ ឆ្នាំក្រោយមកដោយអ្នក(ជ្រុលនិយម)នៅអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY” ក្នុង*រឿងក្តី Tadić*[2005]។ នួន ជា បានរំឭកថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក្នុង*រឿងក្តី Tadić* បានសំអាងជាចម្បងទៅលើរឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរចំនួន ៨ និងបានលើកឡើងថា ក្នុងចំណោមរឿងក្តីទាំងនេះ មាន*រឿងក្តី Ponzano* (តុលាការយោធាចក្រភពអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) តែមួយគត់ដែលពិភាក្សាអំពីការរួមចំណែកមិនផ្ទាល់ក្នុងការប្រព្រឹត្តបទល្មើស ប៉ុន្តែពុំបានពិភាក្សាលើកម្រិតនៃការរួមចំណែកដែលតម្រូវឡើយ[2006]។ នួន ជា បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ទៅលើប្រភពដទៃទៀត ដែលខ្លួនចាត់ទុកថា ពុំជាប់ពាក់ព័ន្ធ ឬពុំគ្រប់គ្រាន់ក្នុងការបង្ហាញពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលជាប់ពាក់ព័ន្ធ[2007]។

៧៧១.បន្ថែមលើនេះទៀត នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ជាការគ្រប់គ្រាន់ដែលបទឧក្រិដ្ឋនេះ “បានបណ្តាលមកពី”ការកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជាទាក់ទងទៅនឹងគោលនយោបាយផ្លាស់ទីលំនៅប្រជាជន ដែលនេះពុំស្របទៅនឹងបទដ្ឋានជាធរមាន ដូចដែលអង្គជំនុំជម្រះបានទទួលស្គាល់ថា គោលបំណងរួមត្រូវតែ“ជា ឬពាក់ព័ន្ធទៅនឹង”ការប្រព្រឹត្តបទឧក្រិដ្ឋ[2008]។ នួន ជា បានលើកឡើងថា ការទទួលខុសត្រូវតាមទម្រង់ I នៃសហឧក្រិដ្ឋកម្មរួមពុំអាចកើតមានបានឡើយប្រសិនបើ ការអនុវត្តនៃគោលបំណងរួមត្រឹមតែ“បានបណ្តាលឱ្យមាន”ការប្រព្រឹត្តបទល្មើសនោះ ដោយបានអះអាងថា“សញ្ញាណនៃគោលបំណងរួមដែល*បណ្តាលឱ្យមាន*បទឧក្រិដ្ឋ(ចេតនាប្រយោល) មានទំនាក់ទំនងជាមួយនឹង និងកម្រិតត្រឹមសហឧក្រិដ្ឋកម្មរួមទម្រង់ III ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជាទម្រង់មិនអាចអនុវត្តបាននៅ

---

[2004] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៥។

[2005] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៦។

[2006] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៨ ដល់ ៤៩០។

[2007] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩១ ដល់ ៤៩២។

[2008] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៩ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩២។

តុលាការឧក្រិដ្ឋកម្មនេះឡើយ”[2009]។ ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីធាតុផ្សំនៃការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួម និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានយល់ឃើញថា គោលបំណងរួមត្រូវតែ“បានបណ្តាលឱ្យ និង/ឬពាក់ព័ន្ធទៅនឹង”ការប្រព្រឹត្តបទឧក្រិដ្ឋ ដែលតាមទស្សនៈរបស់គាត់ ជាការបង្ហាញធាតុផ្សំនៃការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមទម្រង់ III[2010]។

៧៧២.សហព្រះរាជអាជ្ញាបានឆ្លើយតបថា សញ្ញាណនៃសហឧក្រិដ្ឋកម្មរួមត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវសម្រាប់ទម្រង់នៃការទទួលខុសត្រូវក្រោយសង្គ្រាមលោកលើកទីពីរ និងបានបង្ហាញដល់អង្គជំនុំជម្រះតុលាការកំពូលតាមរយៈរឿងក្តី ដែលមានកាលបរិច្ឆេទចាប់តាំងពីអំឡុងពេលក្រោយសង្គ្រាមលោកលើកទីពីរ ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង គោលការណ៍ Nuremberg របស់អង្គការសហប្រជាជាតិ និងសេចក្តីថ្លែងការណ៍របស់គណៈកម្មការនីតិអន្តរជាតិ[2011]។ ទាក់ទងទៅនឹងបទដ្ឋានដែលថា ឧក្រិដ្ឋកម្មកើតចេញពីសហឧក្រិដ្ឋកម្មរួមនោះ សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណបទដ្ឋានត្រឹមត្រូវ ពោលគឺថា គោលបំណងរួមត្រូវតែចាត់ទុកជា ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ និងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទដ្ឋាននេះត្រូវបានបំពេញ[2012]។

៧៧៣.អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះនៃ អ.វ.ត.ក. ព្រមទាំងតុលាការឧក្រិដ្ឋកម្ម *មិនអចិន្ត្រៃយ៍* ដូចជាតុលាការ SCSL និង STL[2013] បានដោះស្រាយយ៉ាងទូលំទូលាយលើបញ្ហា ថាតើ ដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចែងសម្រាប់ការដាក់ឱ្យទទួលខុសត្រូវជាលក្ខណៈបុគ្គលសម្រាប់បទឧក្រិដ្ឋអន្តរ

---

[2009] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០០។

[2010] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៩។

[2011] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១២។

[2012] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៧ ដល់ ៣២១។

[2013] *សូមមើលឧ.* សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៥៣ *ជាអាទិ៍*។ សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ១៩៥ *ជាអាទិ៍*។ សាលដីកា *រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៣៩៣ *ជាអាទិ៍*។ សេចក្តីសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម *រឿងក្តី Rwamakuba* (ICTR) កថាខណ្ឌ ៩ *ជាដើម*។ សាលដីកា *រឿងក្តី Brima* (SCSL) កថាខណ្ឌ ៧៥ *ជាអាទិ៍*។ *សូមមើលផងដែរ* សេចក្តីសម្រេចបន្ទាន់បង្ខំស្តីពីច្បាប់ជាធរមាន (STL) កថាខណ្ឌ ២៣៧ *ជាអាទិ៍*។

ជាតិទាក់ទងទៅនឹងបុគ្គល ដែលបានរួមចំណែកដោយមានចេតនាតម្រូវ យ៉ាងសំខាន់នៅក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួម ដែរ ឬយ៉ាងណា និងស្ថិតក្រោមលក្ខខណ្ឌអ្វីខ្លះ។ សាលដីកា *រឿងក្តី Tadić* (ICTY) គឺជារឿងក្តីដំបូងគេបង្អស់ដែលតុលាការអន្តរជាតិ បានកំណត់ច្បាស់លាស់នូវធាតុផ្សំនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់អ្វីដែលហៅថា "សហឧក្រិដ្ឋកម្មរួម" ដោយបានសំអាងទៅលើការពិនិត្យឡើងវិញនូវយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ[2014] យុត្តិសាស្ត្រជាតិ[2015] ច្បាប់ជាតិ[2016] និងសន្ធិសញ្ញាអន្តរជាតិនានា[2017]។ តាមការពិនិត្យឃើញថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកំណត់អត្តសញ្ញាណនៃការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមជាបីប្រភេទ គឺប្រភេទទីមួយ ជាសហឧក្រិដ្ឋកម្មរួមប្រភេទមូលដ្ឋាន ("JCE I") ដែលគ្របដណ្តប់លើរឿងក្តី ក្នុងនោះ"សហជនជាប់ចោទមានចេតនាល្មើសដូចគ្នាតែមួយប្រព្រឹត្តស្របតាមផែនការរួម។ ជាឧទាហរណ៍ ការបង្កើតផែនការក្នុងចំណោមសហចារីដើម្បីធ្វើមនុស្សឃាត ដើម្បីសម្រេចផែនការរួមនេះ(និងបើទោះបីជា សហចារីនីមួយៗបានអនុវត្តតួនាទីខុសៗគ្នាក៏ដោយ) ក៏ទោះជាយ៉ាងនេះក្តី ចារីទាំងអស់នេះពិតជាមានចេតនាធ្វើមនុស្សឃាត"[2018]។ ប្រភេទទីពីរ ហៅថា"ករណីនៅជំរំប្រមូលផ្តុំ" ("JCE II") គ្របដណ្តប់លើករណី"ដែលបទល្មើសត្រូវបានចោទប្រកាន់ថា បានកើតមានដោយការប្រព្រឹត្តឡើងរបស់សមាជិកនៃកងយោធា ឬរដ្ឋបាល ដូចជាកងដែលគ្រប់គ្រងជំរំប្រមូលផ្តុំនោះ"[2019] ដែលតម្រូវឱ្យមាន"ការចូលរួមយ៉ាងសកម្មរបស់(ជនជាប់ចោទ)នៅក្នុងការអនុវត្តប្រព័ន្ធនៃការគាបសង្កត់ ដែលនេះអាចសន្និដ្ឋានចេញពីតួនាទីក្នុងរដ្ឋអំណាច និងមុខងារជាក់លាក់របស់ជនជាប់ចោទនីមួយៗ"[2020] និងទាក់ទងទៅនឹងធាតុផ្សំអត្តនោម័ត "ការដឹងអំពីលក្ខណៈនៃប្រព័ន្ធការធ្វើបាបនិងចេតនាជំរុញផែនការរួមនៃការធ្វើបាប" (JCE II)[2021]។ ប្រភេទទីបី (JCE III) គ្របដណ្តប់ករណី "ដែលជាប់ពាក់ព័ន្ធទៅនឹងផែនការរួមក្នុងការបន្តលំនាំនៃការប្រព្រឹត្តដែលក្នុងនោះ ចារីម្នាក់ក្នុងចំណោមចារីទាំងនោះប្រព្រឹត្តអំពើមួយបើទោះបីជាពុំស្ថិតក្នុងផែនការរួមក៏ដោយ ក៏ទោះជា

---

2014 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ១៩៥ *ជាអាទិ៍*។

2015 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២១៤ *ជាអាទិ៍*។

2016 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២២៤ ដល់ ២២៥។

2017 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២២១ ដល់ ២២៣។

2018 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ១៩៦។

2019 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២០២។

2020 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២០៣។

2021 សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២២០។

យ៉ាងណាក្តី ផលវិបាកដែលកើតឡើងដោយធម្មជាតិ និងដែលអាចដឹងជាមុនអំពីការសម្រេចគោលបំណងរួម នោះ"[2022]។

៧៧៤.ធាតុផ្សំនៃសញ្ញាណសហឧក្រិដ្ឋកម្មរួមត្រូវបានបញ្ជាក់បន្ថែមទៀត នៅក្នុងយុត្តិសាស្ត្របន្តបន្ទាប់ជាពិសេសសេចក្តីសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម*រឿងក្តី Rwamakuba* (ICTR)[2023] និងសាលដីកា*រឿងក្តី Brđanin* (ICTY)[2024]។ គួរកត់សម្គាល់ ដោយផ្អែកលើការវិភាគលើរឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានយល់ឃើញនៅក្នុង*រឿងក្តី Rwamakuba* ថា ការទទួលខុសត្រូវដែលផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម ពុំត្រូវបានកម្រិតចំពោះ"បទឧក្រិដ្ឋដែលមានភាពជាក់លាក់បំផុត"នោះទេ ប៉ុន្តែថា ជាពិសេសក្នុង*រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងយុត្តិធម៌* បានបង្ហាញថា "ការទទួលខុសត្រូវចំពោះការចូលរួមក្នុងផែនការឧក្រិដ្ឋ មានលក្ខណៈទូលាយដូចផែនការនេះតែម្តង បើទោះបីជាផែនការនេះ គឺជាប្រព័ន្ធនៃអំពើឃោរឃៅ និងអយុត្តិធម៌ដែលបានបង្កើតដោយរដ្ឋាភិបាល និងមានលក្ខណៈទូលំទូលាយទូទាំងប្រទេសក៏ដោយ"[2025]។ ក្នុង*រឿងក្តី Brđanin* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានយល់ឃើញថា យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរបានបង្ហាញថា ការទទួលខុសត្រូវអាចកើតឡើងសម្រាប់ការចូលរួមនៅក្នុងគោលបំណងរួម ក្នុងករណី"ដែលប្រព្រឹត្តដែលមានអំពើ*សត្យានុម័ត*ល្មើស ត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលដែលពុំបានរួមចំណែកក្នុងគោលបំណងរួម" និងថា ពុំមានលក្ខខណ្ឌតម្រូវនៃការព្រមព្រៀងរវាងជនជាប់ចោទ និងចារីផ្ទាល់ថា ចារីផ្ទាល់ត្រូវតែប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់នោះឡើយ[2026]។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) បានដោះស្រាយលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម។ បន្ទាប់ពីបានពិនិត្យលើយុត្តិសាស្ត្រ និងមូលដ្ឋានសំអាងផ្លូវច្បាប់ដទៃទៀតដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "ដោយផ្អែកលើធម្មនុញ្ញទីក្រុងឡុងដ៍ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង រឿងក្តីអន្តរជាតិ និងសេចក្តីប្រកាសដែលមានអានុភាពជាច្បាប់ ដោយគ្មានមន្ទិលសង្ស័យថា សហឧក្រិដ្ឋកម្មរួមទម្រង់ I និង II ត្រូវបានទទួលស្គាល់ថា ជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ទំនៀម

---

[2022] សាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២០៤។

[2023] សេក្តីសម្រេច*រឿងក្តី Rwamakuba* (ICTR) កថាខណ្ឌ ១៤ *ជាអាទិ៍*។

[2024] សាលដីកា*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៣៩៣ *ជាអាទិ៍*។

[2025] សេក្តីសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម*រឿងក្តី Rwamakuba* (ICTR) កថាខណ្ឌ ២៥។

[2026] សាលដីកា*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៤០៤។

ទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធសម្រាប់សំណុំរឿង ០០២”[2027]។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះបានយល់ឃើញទាក់ទងទៅនឹងទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមទម្រង់ III ថា មូលដ្ឋានសំអាងផ្លូវច្បាប់ដែលបានយកមកសំអាងនៅក្នុង*រឿងក្តី Tadić* ពុំមែន“ជាមូលដ្ឋានរឹងមាំគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមទម្រង់ III គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២”[2028]។ អង្គបុរេជំនុំជម្រះក៏បានយល់ឃើញផងដែរថា សហឧក្រិដ្ឋកម្មរួមទម្រង់ III ពុំអាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក. ធ្វើជាគោលការណ៍ទូទៅនៃច្បាប់បានឡើយ[2029]។

៧៧៥.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ប្រភេទដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកំណត់អត្តសញ្ញាណក្នុង*រឿងក្តី Tadić* ទំនងជាបានផ្អែកជាចម្បងលើការវាយតម្លៃអង្គហេតុនៃរឿងក្តីជាមូលដ្ឋាន។ ប្រភេទនេះពុំត្រូវបានប្រើប្រាស់ច្បាស់លាស់នៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ និងពុំមែនជាការកំណត់និយមន័យច្បាស់លាស់ផ្នែកច្បាប់ដាច់ដោយឡែកពុំត្រួតគ្នានោះឡើយ[2030]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការផ្តោតលើពាក្យពេចន៍ដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និងប្រភេទនៃសហឧក្រិដ្ឋកម្មរួមដែលអង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណ ពុំអាចរកឃើញបញ្ហាពិតប្រាកដដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយ ដូចជា ប្រសិនបើមាន ថាតើច្បាប់ជាធរមានដែលមានអត្ថិភាពនៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទ បានចែងក្នុងកម្រិតណាសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល នៅក្នុងករណីដែលជនជាប់ចោទពុំបានប្រព្រឹត្តអំពើ*សត្យានុម័ត*នៃឧក្រិដ្ឋកម្មអន្តរជាតិដែលបានចោទប្រកាន់នោះ ប៉ុន្តែបានប្រព្រឹត្តរួមជាមួយអ្នកដទៃទៀតតាមរយៈគោលបំណងរួម និងបានរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួមនោះ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គជំនុំជម្រះ

---

[2027] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៦៩ (ជើងទំព័រលុបចោល)។

[2028] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៨៣។

[2029] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៨៧។

[2030] ជាឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានទទួលស្គាល់ថា សហឧក្រិដ្ឋកម្មរួមទម្រង់ II គឺជាទម្រង់ “ក្លាយមកពី”សហឧក្រិដ្ឋកម្មរួមទម្រង់ I (សាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២០៣)។ *សូមមើលផងដែរ* កថាខណ្ឌ ២០២ ៖ “ប្រភេទដាច់ដោយឡែកទីពីរនៃរឿងក្តី មានលក្ខណៈប្រហាក់ប្រហែលយ៉ាងខ្លាំងទៅនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ I”)។ សារណារបស់ Kai Ambos អ្នកដែលពុំមែនជាភាគីនៃរឿងក្តី (D99/3/27) កថាខណ្ឌ ២ ដែលលើកឡើងថា “សហឧក្រិដ្ឋកម្មរួមទម្រង់ II អាចត្រូវបានចាត់ទុកជាផ្នែកបន្ទាប់ពីសហឧក្រិដ្ឋកម្មរួមទម្រង់ I ប្រសិនបើបកស្រាយក្នុងន័យចង្អៀត។ តាមន័យទូលាយនៃការទទួលខុសត្រូវ សហឧក្រិដ្ឋកម្មរួមទម្រង់ II ដូចគ្នាទៅនឹងទម្រង់ III ដែរ”។

តុលាការកំពូលរំឭកថា នួន ជា ពុំបានជំទាស់ទៅនឹងការលើកឡើងដែលថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាពនៅចន្លោះរវាងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ "មានលទ្ធភាពក្នុងការចោទប្រកាន់ការប្រព្រឹត្តអំពើល្មើសរួមដែលជាទម្រង់នៃការទទួលខុសត្រូវ"[2031]។ ទោះជាយ៉ាងណាក្តី នួន ជា បានជំទាស់ថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអាចកើតមានតែក្នុងករណីដែលបុគ្គលនោះ បានត្រឹមរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួម ដោយគ្មានការប្រព្រឹត្តជាក់ស្តែងយ៉ាងហោចណាស់ផ្នែកមួយនៃអំពើសត្យានុម័តនៃបទឧក្រិដ្ឋនោះ និងបានលើកឡើងថា នៅក្នុងអំឡុងពេលនៃបទចោទ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ត្រូវបាន"កម្រិតត្រឹមការរួមចំណែករួមគ្នានៅក្នុងអំពើល្មើស*ជាក់លាក់*ដោយមានចេតនាល្មើសរួមតែប៉ុណ្ណោះ"[2032]។

៧៧៦.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ជាញឹកញាប់ពុំបានកំណត់អំពីទម្រង់នៃការទទួលខុសត្រូវដែលបានយកមកសំអាង[2033]នោះ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា យុត្តិសាស្ត្រជានិច្ចកាលពុំមែនសុទ្ធតែបង្ហាញច្បាស់លាស់ទាក់ទងទៅនឹងបញ្ហានេះឡើយ ដែលនេះចាំបាច់ត្រូវពិចារណាដោយប្រុងប្រយ័ត្ន។ ទោះជាយ៉ាងណាក្តី អំណះអំណាងរបស់ នួន ជា ពុំបានពិចារណាផងដែរថា ច្បាប់ទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះបទឧក្រិដ្ឋអន្តរជាតិ ពុំបានលេចចេញជារូបរាងតាមរយៈសកម្មភាពនៃការតាក់តែងឱ្យស៊ីសង្វាក់គ្នានោះឡើយ។ ផ្ទុយទៅវិញ ក្រោយសង្គ្រាមលោកលើកទីពីរ តុលាការផ្សេងៗបានជំនុំជម្រះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលសង្គ្រាម ដោយបានផ្អែកយ៉ាងពិសេសទៅលើលក្ខន្តិកៈរបស់តុលាការយោធាអន្តរជាតិ(IMT) លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មយោធាអន្តរជាតិចុងបូព៌ា (IMTFE) និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងរួមទាំងច្បាប់ក្នុងស្រុកផងដែរ។ អាស្រ័យហេតុនេះនៅពេលកំណត់ ថាតើក្នុងកាលៈទេសៈណាខ្លះដែលការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់បទឧក្រិដ្ឋអន្តរជាតិមានអត្ថិភាពនោះ ត្រូវតែធ្វើការពិចារណាទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ និងត្រូវទាញយកលំនាំនៃគំនិត និងធាតុផ្សំរួម។ នេះ គឺជាអ្វីដែលសាលដីកា*រឿងក្តី Tadić* របស់តុលាការ ICTY និងសេចក្តីសម្រេចជាបន្តបន្ទាប់របស់តុលាការ ICTY ICTR SCSL STL និង អ.វ.ត.ក. បានធ្វើឡើង។

---

[2031] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៧។

[2032] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៥។

[2033] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៨។

៧៧៧.សារៈសំខាន់នៃការពិចារណានេះពុំមែនផ្តោតលើបញ្ហា ថាតើពាក្យពេចន៍ជាក់លាក់មួយត្រូវបានប្រើប្រាស់នៅក្នុងសេចក្តីសម្រេចណាមួយ និងពុំមែន ថាតើមានប្រព័ន្ធខុសប្លែកគ្នានៃទម្រង់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណានោះទេ ប៉ុន្តែ ថាតើប្រភេទនៃអំពើប្រព្រឹត្តដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះអាចស្តែងឱ្យឃើញថា ជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែរ ឬយ៉ាងណានោះ[2034]។ ក្នុងការរំពឹងទុកថា នឹងមានពាក្យពេចន៍ស្របគ្នា ច្បាស់លាស់ និងស៊ីសង្វាក់គ្នានៅក្នុងការបែងចែករវាងការទទួលខុសត្រូវរបស់ចារីចម្បង និងចារីសមគំនិតនៅក្នុងយុត្តិសាស្ត្រនោះចេញពីប្រភពនានាជាច្រើន ពិតជាពុំអាចទៅរួចឡើយ។

៧៧៨.នួន ជា បានចង្អុលបង្ហាញ[2035]ត្រឹមត្រូវថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY កត់សម្គាល់ក្នុង *រឿងក្តី Tadić* ដើម្បីគាំទ្រសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមថា ការដាក់បុគ្គលដែល"ផ្តល់លទ្ធភាពដល់ចារីតាមរបៀបណាមួយដើម្បីប្រព្រឹត្តអំពើល្មើសផ្ទាល់"ឱ្យទទួលខុសត្រូវ"ត្រឹមតែជាអ្នកជួយជំរុញនោះ អាចកាត់បន្ថយកម្រិតនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលទាំងនេះ"[2036]។ ទោះជាយ៉ាងណាក្តី ការកត់សម្គាល់របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY នេះ ត្រូវតែផ្អែកតាមបរិបទនៃលក្ខន្តិកៈរបស់តុលាការ ICTY ដែលក្នុងមាត្រា ៧ បានបែងចែកភាពខុសគ្នារវាងអ្នកដែល"ប្រព្រឹត្ត"បទឧក្រិដ្ឋ និងដែល"រៀបចំផែនការ ញុះញង់ បញ្ជា [...] ឬជួយ និងជំរុញ"ឱ្យប្រព្រឹត្ត[2037] ដែលតុលាការនេះបកស្រាយស្របទៅនឹងប្រព័ន្ធទ្វិកនិយមអំពីការប្រព្រឹត្តបទល្មើស[2038]។ ក៏ប៉ុន្តែ នៅក្នុងសាលដីកា *រឿងក្តី Brđanin* (ICTY) ដែលបានដោះស្រាយ

---

[2034] ពាក់ព័ន្ធទៅនឹងបញ្ហានេះ គួរកត់សម្គាល់លើសាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២២៤ ដែលមិនត្រឹមតែយោងទៅលើទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដែលអាចត្រូវចាត់ទុកជាការទទួលខុសត្រូវចម្បងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការទទួលខុសត្រូវជាអ្នកសមគំនិត ព្រមទាំងយោងទៅលើយុត្តាធិការ(ដូចជា អ៊ីតាលី) ដែលពុំបានបែងចែកច្បាស់លាស់រវាងការទទួលខុសត្រូវចម្បង និងការទទួលខុសត្រូវជាអ្នកសមគំនិតឡើយ។

[2035] សារណាតបរបស់ នួន ជា ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ឯកសារលេខ F11/2 កថាខណ្ឌ ១៥។

[2036] សាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ១៩២។

[2037] មាត្រា ៧ នៃលក្ខន្តិកៈរបស់តុលាការ ICTY។

[2038] *សូមមើលឧ.* សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៩២ ("ការជួយនិងជំរុញជាទូទៅពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្នុងកម្រិតតិចជាងការប្រព្រឹត្តផ្ទាល់រួមគ្នានៅក្នុងសហឧក្រិដ្ឋកម្មរួម")(ជើងទំព័រលុបចោល)។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា មាត្រា ២៩(១) នៃច្បាប់ អ.វ.ត.ក. មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទោះជាយ៉ាងណាក្តី

លើសហឧក្រិដ្ឋកម្មរួមយ៉ាងទូលំទូលាយដែលក្នុងនោះ ពុំមានសមាជិកណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម មានធាតុផ្សំ*សត្យានុម័ត*ប្រព្រឹត្តបទល្មើសផ្ទាល់នោះទេ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកត់សម្គាល់ឃើញថា៖

> យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម ជាធម្មតា បានចាត់ទុកការដាក់ពិរុទ្ធភាពសម្រាប់សហឧក្រិដ្ឋកម្មរួមស្មើគ្នាទៅនឹងទម្រង់នៃការទទួលខុសត្រូវចំពោះ*ការប្រព្រឹត្ត* ដែលស្របតាមមាត្រា ៧(១) នៃលក្ខន្តិកៈរបស់តុលាការ ICTY។ អង្គជំនុំជម្រះតុលាការកំពូល ក្នុងពេលនេះបានសម្រេចមិនដោះស្រាយលើបញ្ហា ថាតើការចាត់ទុកស្មើគ្នានេះនៅតែសមស្រប ដែរ ឬយ៉ាងណា នៅពេលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពតាមរយៈសហឧក្រិដ្ឋកម្មរួមពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ដែលពុំមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ប៉ុន្តែត្រូវបានប្រើប្រាស់ដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួម[2039]។

ដូច្នេះ សូម្បីតែនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY ការបែងចែកអំពីភាពខុសគ្នាចំពោះការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួម រវាងការទទួលខុសត្រូវចម្បងជាមួយនឹងការទទួលខុសត្រូវសមគំនិត មានការជាប់ពាក់ព័ន្ធតិចតួចប៉ុណ្ណោះ។

៧៧៩.អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាបញ្ហាពុំជាប់ពាក់ព័ន្ធចំពោះការលើកឡើងដែលថា ពុំមានយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរណាមួយ ជាក់ស្តែងបានប្រើប្រាស់ឃ្លាថា "ការរួមចំណែកយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលបំណងរួម"។ ឃ្លានេះដែលត្រូវបានបង្កើតឡើងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY គឺក្នុងគោលបំណងដើម្បីបញ្ជាក់ពីភាពចាំបាច់នៃយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ដូចជា ការ

---

នេះពុំចាំបាច់បង្ហាញថា ត្រូវតែអនុវត្តតាមលក្ខណៈពិសេសដែលមាននៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍*ឡើយ។ សម្រាប់ អ.វ.ត.ក. អ្វីដែលសំខាន់ គឺអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទ។

[2039] សាលដីកា*រឿងក្តី Brđanin* (ICTY) ជើងទំព័រ ៨៩១។ *សូមមើលផងដែរ* មតិដាច់ដោយឡែករបស់ចៅក្រម Meron ចំពោះសាលដីកា*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៨ ដែលពិចារណាថា "ក្នុងករណីដែលសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួមប្រើប្រាស់ចារីដែលពុំមែនសមាជិកឱ្យប្រព្រឹត្តបទឧក្រិដ្ឋមួយនៅក្នុងគោលបំណងឧក្រិដ្ឋរួម សមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមក៏ត្រូវទទួលខុសត្រូវផងដែរចំពោះបទឧក្រិដ្ឋនេះដែលមានមូលដ្ឋានចេញពីទំនាក់ទំនងរបស់ពួកគេជាមួយនឹងសមាជិកម្នាក់នោះ។ ដូចនេះ ខ្ញុំអាចប្រៀបធៀបគ្នាបានរវាងការសម្រេចដាក់ពិរុទ្ធភាពរបស់សមាជិកពីបទសហឧក្រិដ្ឋកម្មរួមទាក់ទងទៅនឹងបទឧក្រិដ្ឋនេះ ជាមួយទៅនឹងទម្រង់នៃការទទួលខុសត្រូវបែបណាមួយដែលដូចគ្នាទៅនឹងការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមរបស់សមាជិកនៃសហឧក្រិដ្ឋកម្មរួមដែលបានប្រើប្រាស់អ្នកដែលពុំមែនសមាជិក"។

ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល អាចមានអត្ថិភាពផងដែរក្នុងកាលៈទេសៈដែលបុគ្គលណាមួយបានរួមចំណែកនៅក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួម បើទោះបីជា ការរួមចំណែកនោះពុំមែនជាធាតុផ្សំ *សត្យានុម័ត*នៃបទឧក្រិដ្ឋ ឬក៏ត្រូវបានដកចេញពីការប្រព្រឹត្តបទឧក្រិដ្ឋនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហានេះបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីគោលជំហរនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ។

៧៨០.ឧទាហរណ៍ នៅក្នុងរឿងក្តីទាក់ទងទៅនឹងការសម្លាប់ឈ្លើយសឹក ឬជនស៊ីវិល ជនជាប់ចោទជាច្រើនត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីការចូលរួមក្នុងគោលបំណងឧក្រិដ្ឋមួយ បើទោះបីជាខ្លួនពុំមែនជាអ្នកសម្លាប់ជនរងគ្រោះដោយផ្ទាល់ក៏ដោយ និងពុំមានតួនាទីសំខាន់នៅក្នុងការអនុវត្តផែនការក៏ដោយ។ គួរកត់សម្គាល់ ក្នុង *រឿងក្តី Almelo* ទាក់ទងទៅនឹងការសម្លាប់ឈ្លើយសឹកម្នាក់ និងជនស៊ីវិលម្នាក់ដោយទាហានអាល្លឺម៉ង់[2040] ក្នុងចំណោមជនជាប់ចោទទាំងនោះ មានជនជាប់ចោទពីរនាក់ត្រូវបានរកឃើញថា មានពិរុទ្ធភាព បើទោះបីជាជនជាប់ចោទនេះពុំបានសម្លាប់ជនរងគ្រោះ ប៉ុន្តែត្រឹមតែបាននៅក្នុងឡាន និង"បានរារាំងអ្នកដទៃកុំឱ្យរំខានដល់ទាហានពីរនាក់ទៀតដែលកំពុងប្រព្រឹត្តបទល្មើសនោះ"[2041]។ គួរកត់សម្គាល់ផងដែរថា "ប្រសិនបើមានវត្តមានទាំងអស់គ្នាក្នុងពេលតែមួយ ហើយបានចូលរួមក្នុងផែនការរួមដែលពុំស្របច្បាប់ និងបានជួយជំរុញគោលបំណងរួមទាំងអស់គ្នាទៅតាមវិធីរៀងៗខ្លួន អ្នកទាំងអស់គ្នានោះនឹងត្រូវដាក់ឱ្យជាប់ពិរុទ្ធស្មើៗគ្នាតាមច្បាប់"[2042]។

៧៨១.ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុង*រឿងក្តី Schonfeld* ជនជាប់ចោទដែលជាអ្នកបើកឡានទៅកាន់ទីកន្លែងប្រព្រឹត្តបទល្មើស និងទៅស្វែងរកផ្ទះក្រុមទាហានដែលក្រោយមកត្រូវបានគេបាញ់សម្លាប់ និងអ្នកដែលបានយាមកាមនៅក្រោយផ្ទះ ជាទីកន្លែងដែលការសម្លាប់បានកើតឡើង និងបានចាប់ខ្លួនសាក្សីម្នាក់បន្ទាប់ពីការសម្លាប់នោះ និងក្រោយមកបានជូនដំណឹងដល់ប៉ូលិសថា ទាហានទាំងនោះត្រូវបានបាញ់សម្លាប់ នៅខណៈ

---

[2040] *រឿងក្តី Almelo* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសហូឡង់) ទំព័រ ៣៥ ដល់ ៣៦។

[2041] *រឿងក្តី Almelo* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសហូឡង់) ទំព័រ ៤៣។

[2042] *រឿងក្តី Almelo* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសហូឡង់) ទំព័រ ៤៣។

ពេលព្យាយាមរត់គេច និងបង្គាប់ឱ្យប៉ូលិសចាត់ចែងដឹកសាកសពយកទៅកប់នោះ[2043] ត្រូវបានរកឃើញថាបានចូលរួមនៅក្នុងការធ្វើមនុស្សឃាតនេះ បើទោះបីជាពុំបានប្រព្រឹត្តដោយផ្ទាល់ក៏ដោយ[2044]។

៧៨២.*រឿងក្តី Einsatzgruppen* ដែលតុលាការឧក្រិដ្ឋកម្មយោធាអាម៉េរិកជំនុំជម្រះក្នុងទីក្រុង Nuremberg កាត់ទោសនាយទាហាន ២២ នាក់ដែលមកពីកងសន្តិសុខរបស់អាល្លឺម៉ង់ពីការ"ចូលរួមយ៉ាងសកម្ម"នៅក្នុងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាឧទាហរណ៍មួយផ្សេងទៀតសម្រាប់ការទទួលខុសត្រូវនៃគោលបំណងរួម[2045]។ នៅក្នុងសេចក្តីថ្លែងបញ្ចប់កិច្ចពិភាក្សាដេញដោល តំណាងអយ្យការបានអះអាងថា៖

> មិនត្រឹមតែចារីផ្ទាល់ប៉ុណ្ណោះទេដែលជាប់ពិរុទ្ធនោះ ប៉ុន្តែថែមទាំងអ្នកសមគំនិតផងដែរ ដែលបានចូលរួមដោយចេតនានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬមានការជាប់ពាក់ព័ន្ធទៅនឹងផែនការ ឬអង្គការដែលជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តនោះ និងអ្នកដែលបញ្ជា ឬជួយនិងជំរុញការប្រព្រឹត្តបទឧក្រិដ្ឋ និងអ្នកដែលជាសមាជិកនៃអង្គការ ឬក្រុមមួយដែលជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ។ [...] សមាជិកណាមួយដែលបានជួយជំរុញឱ្យកងទាំងនេះអាចបំពេញមុខងារបាន ដោយដឹងថា មានអ្វីកំពុងកើតឡើងនោះ ត្រូវជាប់ពិរុទ្ធពីបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយកងនោះ[2046]។

៧៨៣.ផ្អែកលើមូលដ្ឋាននេះ តុលាការឧក្រិដ្ឋកម្មបានសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទ បើទោះបីជាជនជាប់ចោទពុំបានប្រព្រឹត្តជាក់ស្តែងក៏ដោយ។ ជាឧទាហរណ៍ តុលាការឧក្រិដ្ឋកម្មបានរកឃើញថា ជនជាប់ចោទ Sandberger ដែលជាសមាជិកនៃកងការពារ (SS និង កងពិឃាដ SD) បានបង្ហាញ"ឆន្ទៈ និងភាពសាទរស្របតាមការបញ្ជារបស់ Fuehrer និងជនផ្តាច់ការដទៃទៀតរបស់ណាហ្ស៊ី"[2047] និងបានរកឃើញផងដែរថា ជនជាប់ចោទ Seibert បានដឹងច្បាស់លាស់អំពីសកម្មភាពរបស់កងពិឃាដ (Einsatzgruppe D) នេះ និងបានចូលរួមដូចចារី និងក៏ដូចអ្នកសមគំនិតផងដែរ នៅក្នុងប្រតិបត្តិការរបស់ខ្លួនដែលរំលោភបំពានលើច្បាប់អន្តរជាតិ

---

[2043] *រឿងក្តី Schonfeld* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ៦៦។

[2044] *រឿងក្តី Schonfeld* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ៦៧។

[2045] *រឿងក្តី Einsatzgruppen* ទំព័រ ៤១១ ដល់ ៤១២។

[2046] *រឿងក្តី Einsatzgruppen* ទំព័រ ៣៧២ ដល់ ៣៧៣។

[2047] *រឿងក្តី Einsatzgruppen* ទំព័រ ៥៣៦។

និងត្រូវជាប់ពិរុទ្ធគ្រប់បទចោទទាំងអស់[2048]។ ទាក់ទងទៅនឹងជនជាប់ចោទ Haensch តុលាការឧក្រិដ្ឋកម្មបានរកឃើញថា៖

> ជាមន្ត្រីជាន់ខ្ពស់ដែលបានរៀបចំប្រតិបត្តិការ ឬបានចូលរួមក្នុងផែនការ និងជាអ្នកគ្រប់គ្រងលើមន្ត្រីនានាដែលបានចូលរួមនៅក្នុងសកម្មភាពនោះច្បាស់ណាស់ មិនអាចគេចផុតពីការទទួលខុសត្រូវចំពោះសកម្មភាពនោះ ដោយសារអវត្តមាននៅថ្ងៃប្រតិបត្តិការផែនការនោះទេ។ ជនជាប់ចោទ Haensch មិនត្រឹមតែទទួលខុសត្រូវចំពោះកងពិឃាដ (Sonerkommando) [កងតូចពិឃាតរបស់កង *Einsatzgruppen*] ក្នុងអំឡុងពេលប្រតិបត្តិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានទទួលស្គាល់ថា គាត់បានទទួលដំណឹងពីលទ្ធផលនៃប្រតិបត្តិការនេះផងដែរ[2049]។

ដូច្នេះ គាត់ត្រូវបានដាក់ឱ្យជាប់ពិរុទ្ធផងដែរ។

៧៨៤.ទាក់ទងទៅនឹងជនជាប់ចោទ Von Radetzky ដែលបានបម្រើការក្នុងកងពិឃាដ (*Sonderkommando 4a)* មានមុខងារជាអ្នកបកប្រែភាសា/មន្ត្រីទំនាក់ទំនង[2050] និងបានទទួលដំណឹងជាផ្លូវការនៅក្នុងអង្គការនាពេលនោះថា មានការសម្លាប់បានកើតឡើង។ តុលាការឧក្រិដ្ឋកម្មបានរកឃើញថា ជនជាប់ចោទនេះបានចូលរួមដោយចេតនានៅក្នុងការសម្លាប់នោះ ដូច្នេះមានពិរុទ្ធភាព[2051]។

៧៨៥.ក្នុង*រឿងក្តី RuSHA* ពាក់ព័ន្ធទៅនឹងជនជាប់ចោទចំនួន ១៤ នាក់ តាមតួនាទីរៀងៗខ្លួន បានពាក់ព័ន្ធទៅនឹងអង្គការចំនួន ៤ ដែលស្ថិតក្រោមការគ្រប់គ្រង និងការណែនាំរបស់មេដឹកនាំអាណាចក្រ Reich ឈ្មោះ SS Himmler[2052]។ ជនជាប់ចោទមួយចំនួនត្រូវបានរកឃើញថា អាដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះទិដ្ឋភាពផ្សេងៗនៃកម្មវិធីពូជសាសន៍របស់ណាហ្ស៊ី រួមទាំងការចាប់ជំរិតកុមារដែល“មានតម្លៃខាងពូជសាសន៍” ដើម្បីយកមកពង្រីកពូជសាសន៍អេរៀន (Aryanization) ការជម្លៀសជនជាតិបរទេសចេញពីផ្ទះសម្បែងដោយបង្ខំ ដើម្បីផ្តល់ផលប្រយោជន៍ដល់ជនជាតិអាល្លឺម៉ង់ ឬជនជាតិភាគតិចអាល្លឺម៉ង់ និងការធ្វើទុក្ខបុកម្នេញ និង

---

[2048] *រឿងក្តី Einsatzgruppen* ទំព័រ ៥៣៩។

[2049] *រឿងក្តី Einsatzgruppen* ទំព័រ ៥៤៩។

[2050] *រឿងក្តី Einsatzgruppen* ទំព័រ ៥៧៣។

[2051] *រឿងក្តី Einsatzgruppen* ទំព័រ ៥៧៧ ដល់ ៥៧៨។

[2052] សាលក្រម*រឿងក្តី RuSHA* ទំព័រ ៨៩ ដល់ ៩០។

ការសម្លាប់រង្គាលលើជនជាតិជ្វីហ្វទូទាំងប្រទេសអាល្លឺម៉ង់[2053] និងប៉ែកអឺរ៉ុបដែលបានកាន់កាប់ដោយអាល្លឺម៉ង់[2054]។ ក្នុង *រឿងក្តី Einsatzgruppen* ដើម្បីឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជនជាប់ចោទ Greifelt ត្រូវបានរកឃើញថា បានចេញ *បទបញ្ជាលេខ 67/I* ដែលត្រូវបានបញ្ជូនទៅកាន់ការិយាល័យជាច្រើន និងបានគូសបញ្ជាក់អំពីគោលនយោបាយចាប់ជំរិត។ តុលាការឧក្រិដ្ឋកម្មបានសន្និដ្ឋានថា បទបញ្ជានេះបានបណ្តាលឱ្យមានការចាប់ជំរិតជាច្រើន[2055]។ ជនជាប់ចោទ Creutz "ដែលជាអនុ Greifelt ត្រូវបានរកឃើញថា ជាប់ពាក់ព័ន្ធទៅនឹងការចាប់ជំរិតកុមារបរទេស"[2056]។ Creutz បានសរសេរទៅកាន់អភិបាលនៃអាណាចក្រ Reich អំពីតម្លៃនៃការចាប់ជំរិតកុមារបរទេស និងបានបង្ហាញពីវិធីដែលអាចធ្វើទៅបាន[2057]។ តុលាការឧក្រិដ្ឋកម្មបានរកឃើញផងដែរថា Creutz បានចេញសេចក្តីណែនាំឱ្យអនុវត្ត"ប្រតិបត្តិការកុមារ" ដែលក្នុងគោលបំណងនាំកុមារទាំងនេះចូលមកអាល្លឺម៉ង់ ដើម្បីពង្រីកពូជសាសន៍អាល្លឺម៉ង់។ ផ្អែកលើមូលដ្ឋាននេះ ជនជាប់ចោទ Creutz ត្រូវទទួលខុសត្រូវពេញលេញចំពោះកម្មវិធីនេះ[2058]។

៧៨៦.ចុងក្រោយ ក្នុង*រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងយុត្តិធម៌* បុគ្គលិករដ្ឋបាលចំនួន ១៦ នាក់របស់ក្រសួងយុត្តិធម៌នៃអាណាចក្រ Reich ឬចៅក្រមនៃតុលាការពិសេស និងតុលាការប្រជាជនរបស់ណាហ្ស៊ីអាល្លឺម៉ង់ ត្រូវបានកាត់ទោសដោយសារបានចូលរួមក្នុងផែនការរួម ចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ដោយសារបានអនុវត្តច្បាប់កាត់ទោសប្រហារជីវិតលើជនជាតិប៉ូឡូញ និងជនជាតិជ្វីហ្វ ពីអំពើក្បត់ជាតិកម្រិតខ្ពស់[2059]។ តុលាការឧក្រិដ្ឋកម្មបានបញ្ជាក់ថា៖

> ជាសង្ខេប បទចោទ គឺស្តីពីការចូលរួមដោយចេតនាក្នុងអំពើឃោរឃៅ និងអយុត្តិធម៌នៅក្នុងប្រព័ន្ធគ្រប់គ្រងទូទាំងប្រទេសដោយរដ្ឋាភិបាល ដោយបានរំលោភបំពានលើច្បាប់សង្គ្រាម និងច្បាប់មនុស្សធម៌

---

[2053] សាលក្រម *រឿងក្តី RuSHA* ទំព័រ ៩៤។

[2054] សាលក្រម *រឿងក្តី RuSHA* ទំព័រ ៨៩។

[2055] សាលក្រម *រឿងក្តី RuSHA* ទំព័រ ១០៣។

[2056] សាលក្រម *រឿងក្តី RuSHA* ទំព័រ ១០៦។

[2057] សាលក្រម *រឿងក្តី RuSHA* ទំព័រ ១០៦។

[2058] សាលក្រម *រឿងក្តី RuSHA* ទំព័រ ១០៦។

[2059] *រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងយុត្តិធម៌* ទំព័រ ៣, ១១២៣។

និងបានប្រព្រឹត្តឡើងក្នុងនាមច្បាប់តាមរយៈសិទ្ធិអំណាចរបស់ក្រសួងយុត្តិធម៌ និងបានប្រើប្រាស់តុលាការជាមធ្យោបាយ។ កាំបិតស្នៀតរបស់ឃាតករបានលាក់នៅក្នុងអាវផាយរបស់គណៈវិនិច្ឆ័យ[2060]។

៧៨៧.តាមការកត់សម្គាល់របស់តុលាការ ICTR *រឿងក្តី ពាក់ព័ន្ធទៅនឹងក្រសួងយុត្តិធម៌* បានបង្ហាញថា "ការទទួលខុសត្រូវចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍បានរួមបញ្ចូលមិនត្រឹមតែអ្នក ដែលបានប្រព្រឹត្តដោយផ្ទាល់ ឬជួយជំរុញឱ្យមានការសម្លាប់ ឬអំពើប្រល័យពូជសាសន៍ដទៃទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអ្នកផ្សេងទៀតដែលបានចូលរួមដោយចេតនានៅក្នុងផែនការរួមដែលធ្វើឱ្យមានអំពើបែបនេះកើតឡើង"[2061]។

៧៨៨.បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា មាត្រា II(2) នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ដែលកំណត់និយមន័យអំពីទម្រង់ផ្សេងៗគ្នាចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ បានចែងថា បុគ្គលណាម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋ នៅពេលបុគ្គលនោះ ជា"(ក) ចារីផ្ទាល់ ឬ (ខ)ជាអ្នកសមគំនិតចំពោះការប្រព្រឹត្តបទឧក្រិដ្ឋណាមួយនោះ ឬបានបញ្ជា ឬជំរុញឱ្យប្រព្រឹត្ត ឬ (គ) ចូលរួមដោយចេតនានៅក្នុងការប្រព្រឹត្ត ឬ (ឃ) ជាប់ពាក់ព័ន្ធទៅនឹងផែនការ ឬការរៀបចំដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តនោះ"។ ដូច្នេះ វិសាលភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមានលក្ខណៈទូលំទូលាយ និងបានរួមបញ្ចូលបញ្ហាជាច្រើនលើសពីការទទួលខុសត្រូវចំពោះការប្រព្រឹត្តអំពើ*សត្យានុម័ត*នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់នោះ។ ជាការកត់សម្គាល់ ជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ បើទោះបីជាអ្នកដទៃទៀតបានប្រព្រឹត្តអំពើ*សត្យានុម័ត*នៃបទឧក្រិដ្ឋនេះក៏ដោយ ដោយផ្អែកលើការរួមចំណែកនៅក្នុងគោលបំណងរួម ឧទាហរណ៍ទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថា ជាសហឧក្រិដ្ឋកម្មរួម។

៧៨៩.ទាក់ទងទៅនឹងធាតុផ្សំនៃការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួម ការវិភាគខាងលើបង្ហាញថា គោលបំណងរួម គឺជាចំណុចស្នូលនៃទម្រង់ទទួលខុសត្រូវ ដោយសារធាតុផ្សំនេះចងភ្ជាប់សមាជិកទាំងអស់រួមគ្នា និងផ្តល់យុត្តិកម្មសម្រាប់ការដាក់ឱ្យទទួលខុសត្រូវរួមចំពោះអំពើរបស់សមាជិកនេះ ដែលត្រូវចាត់ទុកជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[2062]។ ទោះជាយ៉ាងណាក្តី ការធ្វើយុត្តិកម្មចំពោះការដាក់ឱ្យទទួលខុសត្រូវរួមបែបនេះមិនត្រឹមតែគ្រប់គ្រាន់សម្រាប់អ្នកដែលបានយល់ស្របប្រព្រឹត្តជារួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានយល់ស្រប

---

[2060] *រឿងក្តីពាក់ព័ន្ធទៅនឹងក្រសួងយុត្តិធម៌* ទំព័រ ៩៨៥។

[2061] សេចក្តីសម្រេច *រឿងក្តី Rwamakuba* (ICTR) កថាខណ្ឌ ១៩។

[2062] *សូមមើលផងដែរ* ទាក់ទងទៅនឹងសញ្ញាណពាក់ព័ន្ធនៃការប្រព្រឹត្តសហឧក្រិដ្ឋកម្ម សាលដីកា*រឿងក្តី Lubanga* (ICC) កថាខណ្ឌ ៩៤៥។

បន្តគោលបំណងរួមនោះ។ អ្វីដែលតម្រូវគឺថា ពួកគេយល់ស្របទៅនឹងគោលបំណឧក្រិដ្ឋរួមដែលមានចរិតល្មើស។ ការយល់បែបនេះបានបញ្ជាក់តាមរយៈយុត្តិសាស្ត្ររបស់តុលាការ ICTY ICTR ព្រមទាំង SCSL និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរដូចបានពិចារណាខាងលើ[2063] ទាក់ទងទៅនឹងសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម។ នៅក្នុង*រឿងក្តី Tadić* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានតម្រូវឱ្យមាន "អត្ថិភាពនៃគោលបំណង ឬផែនការរួមដែល*ជាបទឧក្រិដ្ឋ ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ* ដែលមានចែងនៅក្នុងលក្ខន្តិកៈ"[2064]។ បន្ទាប់ពីបានពិភាក្សាទៅលើការចូលរួមរបស់បុគ្គលនៅក្នុងសហឧក្រិដ្ឋកម្មរួម បានបង្ហាញឱ្យឃើញថា "ការចូលរួមពុំចាំបាច់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ ដូចដែលមានចែងនៅក្នុងបទប្បញ្ញត្តិណាមួយនៃបទប្បញ្ញត្តិទាំងនោះ [...] ប៉ុន្តែអាចពាក់ព័ន្ធទៅនឹងទម្រង់នៃការជួយនិងជំរុញ ឬរួមចំណែកនៅក្នុងការអនុវត្តផែនការ ឬគោលបំណងរួម"[2065]។ នៅក្នុង*រឿងក្តី Martić* នៅពេលពិចារណាលើគោលដៅកាត់យកទឹកដីមួយផ្នែករបស់ Bosnia និង Croatia ទៅជា"រដ្ឋថ្មីមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ Serb" អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបញ្ជាក់ថា គោលដៅនេះខ្លួនឯងផ្ទាល់ពុំមែន"ជាគោលបំណងរួមតាមអត្ថន័យច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួមឡើយ [...]។ ប៉ុន្តែ ប្រសិនបើការបង្កើតដែនដីថ្មីនេះត្រូវបានអនុវត្តឡើងដោយចេតនាតាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងលក្ខន្តិកៈ *ករណីនេះអាច*

---

[2063] *សូមមើលខាងលើ* កថាខណ្ឌ ៧៧៤ *ជាអាទិ៍*។

[2064] សាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២២៧ (សេចក្តីបញ្ជាក់បន្ថែមផ្នែកខ្លះត្រូវបានដកចេញ)។

[2065] សាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២២៧។ *សូមមើលផងដែរ* សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ២១៨ ("ការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម ពុំចាំបាច់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ ប៉ុន្តែអ្វីដែលសំខាន់ គឺថា ការចូលរួមនេះបានជំរុញការអនុវត្តគោលដៅ ឬគោលបំណងរួមដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះដែរ ឬទេ")។ សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៩៩ ("អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមពុំចាំបាច់ចូលរួមដោយផ្ទាល់នៅក្នុងធាតុផ្សំមួយៗនៃឧក្រិដ្ឋកម្មឡើយ ដរាបណាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម")។ សាលដីកាស្តីពីការប្រកាសទោស*រឿងក្តី Babić* (ICTY) កថាខណ្ឌ ៣៨ ("ការទទួលខុសត្រូវជាសហចារីនៅក្នុងសហឧក្រិដ្ឋកម្មរួមដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធនោះ តម្រូវថា ជនជាប់ចោទត្រូវរួមចំណែកធាតុផ្សំ*អត្តនោម័ត* ឬចេតនាបន្តគោលបំណងរួម និងប្រព្រឹត្តអំពើមួយចំនួន *តាមវិធីសាស្ត្រផ្សេងៗដែលសំដៅជំរុញផែនការរួម*")។ សាលដីកា*រឿងក្តី Ntakirutimana* (ICTR) កថាខណ្ឌ ៤៦៦។ សាលដីកា*រឿងក្តី Vasiljević* (ICTY) កថាខណ្ឌ ១០០។ សាលដីកា*រឿងក្តី Krnojelac* (ICTY) កថាខណ្ឌ ៣១ និង ៨១ ("នៅពេលអ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមបានរួមចំណែកចេតនានៃសហឧក្រិដ្ឋកម្មនេះ ការចូលរួមរបស់គាត់អាចធ្វើឡើងក្រោមទម្រង់នៃការជួយ ឬការរួមចំណែកដើម្បីអនុវត្តផែនការ ឬគោលបំណងរួម។ ភាគីដែលពាក់ព័ន្ធក្នុងសហឧក្រិដ្ឋកម្មនេះពុំចាំបាច់ប្រព្រឹត្តផ្ទាល់លើបទឧក្រិដ្ឋមួយ ឬច្រើនដែលមាននៅក្នុងសហឧក្រិដ្ឋកម្មរួមឡើយ")។

*មានលក្ខណៈគ្រប់គ្រាន់ជាគោលបំណងឧក្រិដ្ឋរួម*”[2066]។ ផ្អែកតាមយុត្តិសាស្ត្រនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL ក្នុង*រឿងក្តី Brima* នៅពេលពិភាក្សាអំពីចរិតលក្ខណៈនៃផែនការ ការរៀបចំ ឬគោលបំណងរួម បានបញ្ជាក់ថា “តាមការពិនិត្យលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិអាចយល់បានថា គោលបំណងឧក្រិដ្ឋដែលជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម មិនត្រឹមតែអាចសន្និដ្ឋានចេញពីគោលដៅចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចេញពីមធ្យោបាយនានាដែលប្រើប្រាស់ដើម្បីសម្រេចគោលដៅនោះផងដែរ។ គោលដៅ និង មធ្យោបាយដើម្បីសម្រេចបានគោលដៅនេះ អាចចាត់ទុកជាការរៀបចំ ឬផែនការរួម”[2067]។ ថ្មីៗនេះ នៅក្នុង*រឿងក្តី Karadžić* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានរំឭកថា ជាការចាំបាច់ត្រូវ“មានការបញ្ជាក់ឱ្យបានច្បាស់ពីគោលបំណងឧក្រិដ្ឋរួមទាក់ទងទៅនឹងចំណុចទាំងពីរ គឺគោលដៅល្មើសដោយចេតនា និងវិសាលភាពនៃគោលដៅនេះ(ឧ. ដែនកំណត់នៃភូមិសាស្ត្រ និងពេលវេលានៃគោលដៅនេះ និងអត្តសញ្ញាណទូទៅរបស់ជនរងគ្រោះដោយសារគោលដៅល្មើសនោះ)”[2068]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ ផងដែរថា អង្គជំនុំជម្រះមួយចំនួននៃតុលាការ ICTY បានរកឃើញថា ការទទួលខុសត្រូវតាមទម្រង់នៃសហឧក្រិដ្ឋកម្មរួម មានអត្ថិភាពដោយផ្អែកលើគោលបំណងរួមដែលទាក់ទងទៅនឹងគោលដៅចុងក្រោយពុំមែនជាបទល្មើសដែលការអនុវត្តគោលដៅនេះមានការជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ[2069]។

៧៩០.ដូចបានកត់សម្គាល់ដោយជនជាប់ចោទ[2070] ខុសពីរឿងក្តីខាងលើ នៅពេលយកច្បាប់មកអនុវត្តចំពោះអង្គហេតុនៃរឿងក្តី អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយផ្លាស់ទីលំនៅប្រជាជន“បានបណ្តាលឱ្យមាន និង/ឬពាក់ព័ន្ធទៅនឹង”ការប្រព្រឹត្តបទឧក្រិដ្ឋ ដោយពុំបានប្រកាសថា បទឧក្រិដ្ឋនេះមានបំណង

---

[2066] សាលក្រម *រឿងក្តី Martić* (ICTY) កថាខណ្ឌ ៤៤២។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី Martić* (ICTY) កថាខណ្ឌ ១១២។

[2067] សាលដីកា *រឿងក្តី Brima* (SCSL) កថាខណ្ឌ ៧៦។ *សូមមើលផងដែរ* កថាខណ្ឌ ៧៨។

[2068] សាលក្រម *រឿងក្តី Karadžić* (ICTY) កថាខណ្ឌ ៥៦៣ ដកស្រង់សាលដីកា *រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៤៣០។

[2069] *សូមមើលឧ.* សាលដីកា *រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ១០៧៨, ១០៩០ ដល់ ១១៤២។ ក្នុង *រឿងក្តី Krajišnik* អង្គជំនុំជម្រះសាលាដំបូង(ICTY) បានយល់ឃើញថា មានសហឧក្រិដ្ឋកម្មមួយដែលមានគោលបំណងដើម្បីបង្កើតទឹកដីឡើងវិញក្រោមការគ្រប់គ្រងរបស់សាធារណៈរដ្ឋសម្រាប់ក្រុមជាតិសាសន៍ Bosnian-Serb ដោយកាត់បន្ថយយ៉ាងគំហុកនូវមួយភាគធំនៃក្រុមមូស្លីម Bosnian និង Bosnian Croats តាមរយៈការប្រព្រឹត្តបទល្មើសផ្សេងៗ។ សាលក្រម *រឿងក្តី Prlić* (ICTY) កថាខណ្ឌ ១៦ និង ៩០០ (គោលបំណងចុងក្រោយនៃសហឧក្រិដ្ឋកម្មរួម គឺត្រូវបង្កើតអត្ថិភាព Croatian មួយតាមរយៈការបង្កើតជាតិសាសន៍ និងការបោសសម្អាត)។

[2070] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៩ និង ៥០២។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៩។

ប្រព្រឹត្តគិតទុកជាមុន ឬមាននៅក្នុងគោលបំណងរួម[2071]។ នេះបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបណ្ដាលមកពីការអនុវត្តគោលបំណង ជាជាងបទឧក្រិដ្ឋដែលមានបំណងប្រព្រឹត្ត ឬគិតទុកក្នុងគោលបំណងរួម។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ការទទួលខុសត្រូវបែបនេះ គឺជាអ្វីដែលចាត់ទុកថា ជាការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ ឬទម្រង់ III ក្នុង*រឿងក្ដី* *Tadić*[2072]។ អាស្រ័យហេតុនេះ សំណួរបន្ទាប់ដែលត្រូវដោះស្រាយគឺ ថាតើជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋដែលជនជាប់ចោទពុំបានប្រព្រឹត្តអំពើ*សត្យានុម័ត* ដែលពុំមាននៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណា។

៧៩១.ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ដោយស្របជាមួយនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះស្ដីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) ដែលក្នុងនោះអង្គបុរេបានពិចារណាលម្អិតលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *មិនអចិន្ត្រៃយ៍*ជ ទាក់ទងទៅនឹងសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ III និងបានសន្និដ្ឋានថា សេចក្ដីសម្រេចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសំអាងក្នុង*រឿងក្ដី* *Tadić* ដោយយល់ឃើញថា សហឧក្រិដ្ឋកម្មរួមទម្រង់ III គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ ពុំមែនជា"*មូលដ្ឋានរឹងមាំគ្រប់គ្រាន់*"សម្រាប់ការយល់ឃើញណាមួយឡើយ[2073]។ ជាពិសេស អង្គបុរេជំនុំជម្រះបានយល់ឃើញថា ដោយសារមានការយល់ដឹងតិចតួចបំផុតក្នុង*រឿងក្ដី* *Essen Lynching* (តុលាការយោធាចក្រភពអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) *និង* *Borkum Island* (តុលាការយោធារដ្ឋាភិបាលទូទៅ ក្នុងប្រទេសអាល្លឺម៉ង់) ទើបពុំអាចសន្និដ្ឋានបានថា សញ្ញាណដែលចាត់ជាសហឧក្រិដ្ឋកម្មរួមទម្រង់ III

---

[2071] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៤។ *សូមមើលផងដែរ* កថាខណ្ឌ ៨៣៥។

[2072] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ភាគីបានដោះស្រាយយ៉ាងលម្អិតនូវបញ្ហាស្ដីពីការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមទម្រង់ III ពាក់ព័ន្ធទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣ *ជាអាទិ៍*។ សារណាតបរបស់ នួន ជា កថាខណ្ឌ ១៦ *ជាអាទិ៍*។ សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤៧ ជាអាទិ៍។ បើទោះបីជា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំអាចទទួលយកបានចំពោះបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា(*សូមមើល* កថាខណ្ឌ ១១២២ *ជាអាទិ៍*)ក៏ដោយ ក៏អង្គជំនុំជម្រះចាត់ទុកជាការសមស្របក្នុងការពិចារណាអំណះអំណាងរបស់ភាគីនៅពេលសម្រេចលើបញ្ហាចំពោះមុខ។

[2073] សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះស្ដីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៨៣។

ត្រូវបានយកមកអនុវត្តនោះឡើយ[2074]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាមួយនឹងការវាយតម្លៃនេះ[2075]។ ការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលបានធ្វើឡើងនៅក្នុងបរិបទនៃបណ្តឹងសាទុក្ខដែលជាក់ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញថា អង្គបុរេជំនុំជម្រះពិចារណាពុំត្រឹមត្រូវលើ *រឿងក្តី Essen Lynching និង Borkum*[2076] ដោយសារត្រឹមតែបង្ហាញអំពីការបកស្រាយជាសក្តានុពលនៃរឿងក្តីនេះ ប៉ុន្តែពុំបានដោះស្រាយបញ្ហាចម្បងដែលអង្គបុរេជំនុំជម្រះបានបញ្ជាក់ គឺថា កង្វះព័ត៌មានទាក់ទងទៅនឹងគោលគំនិតផ្លូវច្បាប់ដែលតុលាការឧក្រិដ្ឋកម្មបានយកមកអនុវត្តជាក់ស្តែងក្នុងរឿងក្តីទាំងពីរនោះឡើយ។

៧៩២.បញ្ហាប្រហាក់ប្រហែលគ្នាកើតមានទាក់ទងទៅនឹងរឿងក្តីដទៃទៀត ដែលសហព្រះរាជអាជ្ញាបានយោងទៅលើដែលពុំត្រូវបានដោះស្រាយនៅក្នុង *រឿងក្តី Tadić* ក៏ដូចជាក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9)[2077]។ ទាក់ទងទៅនឹង *រឿងក្តី Renoth* (តុលាការយោធាចក្រភពអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) នៅក្នុងសេចក្តីសង្ខេបនៃការជំនុំជម្រះដែលបុគ្គលចំនួន ៣ រូប ត្រូវបានរកឃើញថា មានពិរុទ្ធភាពពីបទសម្លាប់ឈ្លើយសឹករបស់ប្រទេសសម្ព័ន្ធមិត្ត បើទោះបីជាការសម្លាប់ជាក់ស្តែងត្រូវបានប្រព្រឹត្តដោយជនជាប់ចោទដទៃទៀតក៏ដោយ[2078] ក៏បានកត់សម្គាល់ជាក់លាក់ថា "ពុំអាចនិយាយដោយសង្ខេបបាន ថាតើតុលាការបានយល់ឃើញថា ជនជាប់ចោទទាំងបីនាក់នេះបានចូលរួមយ៉ាងសកម្មនៅក្នុងការវាយដំ ដែរ ឬយ៉ាងណា ឬថាតើជនជាប់ចោទត្រូវទទួលខុសត្រូវតាមគោលការណ៍ដែលបានកំណត់ដោយរដ្ឋអាជ្ញា ដែរ ឬយ៉ាងណា"ដែលបានអះអាងថា បើសូម្បីតែគ្មានការចូលរួមយ៉ាងសកម្មនៅក្នុងការវាយដំក៏ដោយ ក៏ជនជាប់ចោទទាំងនេះអាចជាប់ពិរុទ្ធបានដែរនោះ[2079]។ សហព្រះរាជអាជ្ញាបានអះអាងថា លក្ខខណ្ឌតម្រូវនៃសហ

---

[2074] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9) កថាខណ្ឌ ៧៩ ដល់ ៨១។

[2075] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសហឧក្រិដ្ឋកម្មរួម (E100/6) កថាខណ្ឌ កថាខណ្ឌ ៣០ ដល់ ៣១។

[2076] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១ ដល់ ៣៣។

[2077] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៤ ដល់ ៤០។

[2078] *រឿងក្តី Renoth* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ៧៦។

[2079] *រឿងក្តី Renoth* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ៧៦ ដល់ ៧៧។

ឧក្រិដ្ឋកម្មរួមទម្រង់ III "ទំនង"ជាត្រូវបានបំពេញនៅក្នុងរឿងក្តីនេះ[2080] ដែលពុំអាចធ្វើជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការកំណត់អត្ថសញ្ញាណនៃវិធានស្តីពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

៧៩៣.ពុំមានរឿងក្តីដទៃទៀត[2081]ដែលសហព្រះរាជអាជ្ញាបានយោងទៅលើនោះ គាំទ្រអត្ថិភាពនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះបទឧក្រិដ្ឋ ដែលជនជាប់ចោទពុំត្រូវបានប្រព្រឹត្តអំពើ *សត្យានុម័ត* នៃបទនេះ និងពុំស្ថិតក្រោមវិសាលភាពនៃគោលបំណងរួម។ ជាការកត់សម្គាល់ ការដកស្រង់សាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ទាក់ទងទៅនឹង*រឿងក្តី Sauckel និង Speer*[2082] *រឿងក្តី RuSHA* ទាក់ទងទៅនឹងជនជាប់ចោទ Hildebrandt[2083] *រឿងក្តី Einsatzgruppen* ទាក់ទងទៅនឹងជនជាប់

---

[2080] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥។

[2081] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨ ដល់ ៤០។

[2082] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨ ដល់ ៣០ យោងទៅលើសាលក្រមរបស់តុលាការយោធាអន្តរជាតិ (IMT) ទំព័រ ៣៣១ ដល់ ៣៣៣, ២៤៥, ៣២១, ៣៣១ ដល់ ៣៣៣។ ទាក់ទងទៅនឹងជនជាប់ចោទ Sauckel អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការយោងរបស់សហព្រះរាជអាជ្ញាទៅលើកង្វះចេតនានោះ បានផ្អែកលើការពិនិត្យពុំបានត្រឹមត្រូវទៅលើសាលក្រមរបស់តុលាការឧក្រិដ្ឋកម្មយោធាអន្តរជាតិ ដោយសារទាក់ទងទៅនឹងចំណុចដែលសហព្រះរាជអាជ្ញាបានយោងទៅលើនោះ(ទំព័រ ៤៥) មានការយោងទៅលើចេតនារបស់ជនជាប់ចោទ Sauckel ដែលពុំត្រូវបានបង្ហាញត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ ប៉ុន្តែបានបង្ហាញច្បាស់លាស់តាមរយៈអត្ថបទថា ជនជាប់ចោទពិតជាបានដឹងពីការធ្វើបាបដោយអមនុស្សធម៌ទៅលើជនរងគ្រោះ ហើយនៅក្នុងផ្នែកនៃសាលក្រមដែលពិភាក្សាអំពីពិរុទ្ធភាពរបស់គាត់ តុលាការនេះបានបញ្ជាក់ច្បាស់លាស់ថា ជនជាប់ចោទ "បានដឹងពីវិធីសាស្រ្តព្រៃផ្សៃដែលបានប្រើប្រាស់សម្រាប់ទទួលបានពលករ ហើយគាត់បានគាំទ្រយ៉ាងពេញទំហឹងដោយមូលហេតុថាជាការចាំបាច់ដើម្បីសម្រេចតាមកូតាកំណត់"(ទំព័រ ៣២១)។ អំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា នេះត្រូវបានចាត់ទុកជាការទទួលខុសត្រូវតាមទម្រង់សហឧក្រិដ្ឋកម្មរួម III មានភាពពុំច្បាស់លាស់។ ប្រហាក់ប្រហែលគ្នានេះដែរ ផ្ទុយទៅនឹងសារណារបស់សហព្រះរាជអាជ្ញានោះ ពុំមានការបង្ហាញថា ជនជាប់ចោទ Speer មានឆន្ទៈចូលរួមនៅក្នុងកម្មវិធីពលកម្មទាសករដោយផ្អែកលើសញ្ញាណនៃការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមទម្រង់ III។ តុលាការនេះបានយល់ឃើញថា Speer បានដឹងការកេណ្ឌជនរងគ្រោះដោយហិង្សា ដែលបានកើតចេញពីតម្រូវការខ្ពស់របស់ Speer (ទំព័រ ៣៣១ ដល់ ៣៣៣)។

[2083] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧ យោងទៅលើសាលក្រម*រឿងក្តី RuSHA* ទំព័រ ១ ដល់ ១៩២។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា តុលាការឧក្រិដ្ឋកម្មបានយល់ឃើញទាក់ទងទៅនឹងជនជាប់ចោទ Hildebrandt ថា ដំបូង គាត់បានបដិសេធថា ពុំបានដឹងអំពីហេតុការណ៍ថា "ការធ្វើបាបយ៉ាងពិសេស"ទៅលើជាតិសាសន៍បរទេស ដែលរួមសង្វាសជាមួយស្ត្រីជនជាតិអាល្លឺម៉ង់នោះ ត្រូវប្រហារជីវិតដោយការព្យួរក។ តុលាការឧក្រិដ្ឋកម្មបានពិភាក្សាភស្តុតាងដែលបង្ហាញថា Hildebrandt បានដឹងអំពីអត្ថន័យនៃពាក្យពេចន៍នោះ និងបានដោះស្រាយជាក់ស្តែងលើករណីនៃ"ការធ្វើបាបយ៉ាងពិសេសនេះ"ផងដែរ(ទំព័រ)។ ក្នុងផ្នែកដែលពិភាក្សាលើពិរុទ្ធភាពរបស់គាត់ ពុំបានយោងទៅលើបញ្ហានៃចេតនាឡើយ ប៉ុន្តែគ្រាន់តែបានយល់ឃើញថា "តាមរយៈភស្តុតាងជា

ចោទប្រាំមួយនាក់[2084] ដែលបានយោងដោយសហព្រះរាជអាជ្ញានោះពុំបានបង្ហាញថា មានភាពខ្វែងគ្នាចំពោះបទឧក្រិដ្ឋដែលបានកើតឡើងតាមរយៈគោលបំណងរួមនោះឡើយ។ ផ្ទុយទៅវិញ បញ្ហាគឺ ថាតើជនជាប់ចោទ *បានដឹង*អំពីបទឧក្រិដ្ឋទាំងនេះ ដែរ ឬយ៉ាងណា ហើយប្រសិនបើពុំបានដឹងទេនោះ ពុំមានទម្រង់នៃចេតនាត្រូវបានបង្ហាញឡើយ។ *រឿងក្តី* Pohl (ដែលសហព្រះរាជអាជ្ញាបានសំអាងទៅលើទាក់ទងទៅនឹងជនជាប់ចោទ *Hohberg និង Baier*[2085]) និង*រឿងក្តី ជំរំប្រមូលផ្តុំ Dachau*[2086] ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងជំរំប្រមូលផ្តុំ។ ក្នុង*រឿងក្តី Pohl* តុលាការឧក្រិដ្ឋកម្មដែលជំនុំជម្រះរឿងក្តីនេះបានកត់សម្គាល់ទាក់ទងទៅនឹងជនជាប់ចោទ Hohberg ថា ជនជាប់ចោទរូបនេះ"បានចោទប្រកាន់ *Pohl* ពីបទឧក្រិដ្ឋ និងបានបង្ហាញការឈឺចាប់ចំពោះការប្រើអំពើហិង្សាហួសហេតុនៅជំរំប្រមូលផ្តុំ"[2087]។ ទោះជាយ៉ាងណាក្តី ផ្ទុយទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា ពុំមានការបញ្ជាក់នៅក្នុងការយល់ឃើញរបស់តុលាការនេះថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងជំរំនោះពុំមែនជាផ្នែកនៃគោលបំណងរួម ប៉ុន្តែបានយល់ឃើញថា ជនជាប់ចោទ Hohberg ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ ព្រោះជនជាប់ចោទអាចដឹងជាមុនថា ជាបទល្មើស[2088]។ ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹង ជនជាប់ចោទ Baier ពុំមានការបញ្ជាក់ថា តុលាការឧក្រិដ្ឋកម្មបានដាក់ឱ្យគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួមឡើយ ដោយសារតុលាការបានយល់ឃើញថា មាន "ការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធ ការធ្វើឱ្យក្រលំបាក ការឃុំខ្លួន និងការសម្លាប់អ្នកដែលទទួលរងការធ្វើទុក្ខបុកម្នេញនេះ" និងថា ជនជាប់ចោទ Baier "បានយល់ព្រម និងចូលរួមយ៉ាងសកម្ម

---

ច្រើន មានការបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ជនជាប់ចោទ Hildebrandt បានចូលរួមយ៉ាងសកម្ម និងត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើល្មើសដូចតទៅ៖ [...] ការដាក់ទណ្ឌកម្មជាតិសាសន៍បរទេសដោយខុសច្បាប់ និងអយុត្តិធម៌ចំពោះការរួមសង្វាសជាមួយជនជាតិអាល្លឺម៉ង់"(ទំព័រ ១៦១)។ ជាថ្មីម្តងទៀត បញ្ហា ថាតើរឿងក្តីនេះបានគាំទ្រអត្ថិភាពនៃសញ្ញាណសហឧក្រិដ្ឋកម្មរួមទម្រង់ III បែបណានោះ ពុំមានភាពច្បាស់លាស់ឡើយ។

[2084] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨ យោងទៅលើសាលក្រម*រឿងក្តី* *Einsatzgruppen* ទំព័រ ៤២៧ ដល់ ៤៣៣ និង ៥២៦។

[2085] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥ ដល់ ៣៦ យោងទៅលើសាលក្រម*រឿងក្តី Pohl* ទំព័រ ១០៤១ ដល់ ១០៤២, ១០៤៧។

[2086] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០ យោងទៅលើ *រឿងក្តីជំរំប្រមូលផ្តុំ Dachau* ទំព័រ ១៤១។

[2087] *រឿងក្តី Pohl* ទំព័រ ១០៤២។

[2088] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥។

នៅក្នុងការកេងចំណេញពីការងារទាសករនោះ”[2089]។ ទាក់ទងទៅនឹង*រឿងក្ដី ជំរំប្រមូលផ្ដុំ Dachau* ពុំមានការបញ្ជាក់ថា តុលាការឧក្រិដ្ឋកម្មបានដាក់ជនជាប់ចោទណាមួយឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋដែលពុំស្ថិតក្នុងផែនការឧក្រិដ្ឋរួមនៅក្នុងជំរំប្រមូលផ្ដុំ Dachau។ របាយការណ៍របស់គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមអង្គការសហប្រជាជាតិ (UNWCC) ស្ដីពីរឿងក្ដី កត់សម្គាល់ពាក់ព័ន្ធនឹងបញ្ហានេះថា “នៅក្នុងជំរំមានប្រព័ន្ធទូទៅនៃអំពើឃោរឃៅ និងការសម្លាប់អ្នកជាប់ឃុំ [...] និងថា ជនជាប់ចោទដែលសមាជិកនៃបុគ្គលិកក្នុងជំរំនោះ បានដឹងអំពីការអនុវត្តប្រព័ន្ធនេះ និងបានចូលរួមយ៉ាងសកម្ម”[2090]។ ចំណុចដែលសហព្រះរាជអាជ្ញាបានសំអាងទៅលើនោះ មាននៅក្នុងរបាយការណ៍របស់តំណាងអយ្យការនៅក្នុងបរិបទនៃការពិនិត្យឡើងវិញលើរឿងក្ដីដែលនេះពុំបានបង្ហាញថា តុលាការឧក្រិដ្ឋកម្មដែលចេញសាលក្រមក្នុង*រឿងក្ដី Martin Gottfried Weiss* ជាក់ស្ដែងបានរួមចំណែកទស្សនៈនេះឡើយ[2091]។ ទាក់ទងទៅនឹង*រឿងក្ដី Sch.*[2092] មានការបង្ហាញការផ្ទុយគ្នា ជាជាងការបង្ហាញគាំទ្រចំពោះសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយនេះ ដោយសារក្នុងការបង្វិលរឿងក្ដីទៅឱ្យតុលាការជាន់ទាប តុលាការកំពូលសម្រាប់ចក្រភពអង់គ្លេសបានណែនាំថា តុលាការត្រូវពិចារណាបន្ថែមទៀតលើបញ្ហា ថាតើជនជាប់ចោទ នៅពេលនាំជនរងគ្រោះទៅកាន់វិហារជនជាតិជ្វីហ្វនោះ បានដឹងថា ជនរងគ្រោះត្រូវបានធ្វើបាបនៅទីនោះ ដែរ ឬយ៉ាងណា និងបានកត់សម្គាល់ថា យ៉ាងហោចណាស់ជនជាប់ចោទអាចទទួលខុសត្រូវចំពោះការធ្វើបាបនេះ ព្រោះជនជាប់ចោទពុំបានការពារជនរងគ្រោះ ដែលកំពុងស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។ ជាសំខាន់ ទោះបីជាយ៉ាងណាក្ដី ពុំមានការបញ្ជាក់ថា តុលាការកំពូលសម្រាប់ចក្រភពអង់គ្លេសបានពិចារណាថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះការបាញ់ប្រហារជនរង

[2089] *រឿងក្ដី Pohl* ទំព័រ ១០៤៧។

[2090] *រឿងក្ដី ជំរំប្រមូលផ្ដុំ Dachau* ទំព័រ ១៤។

[2091] *រឿងក្ដី ជំរំប្រមូលផ្ដុំ Dachau* ទំព័រ ៥៖ “បទចោទចំនួន ២ បានចោទប្រកាន់ថា ជនជាប់ចោទបានអនុវត្តដោយស្របជាមួយនឹងផែនការរួមក្នុងការប្រព្រឹត្តអំពើដែលបានចោទប្រកាន់នោះ និងក្នុងនាមជាបុគ្គលនៃជំរំប្រមូលផ្ដុំ Dachau និងជំរំក្រោមការគ្រប់គ្រងផ្សេងទៀត [...]ជួយ និងជំរុញ និងចូលរួមដោយឆន្ទៈ ដោយចេតនា និងដោយពុំត្រឹមត្រូវនៅក្នុងការដាក់ជនស៊ីវិលជាតិសាសន៍នានាក្រោមអំណាចរបស់ខ្លួន [...] ទំព័រ ៨ ដែលការយល់ឃើញត្រូវបានសង្ខេបដូចតទៅ៖ “ជនជាប់ចោទចំនួន ៤០ នាក់ ត្រូវបានរកឃើញថា មានពិរុទ្ធ ហើយការយល់ឃើញត្រូវបានតម្កល់ក្នុងរឿងក្ដីនីមួយ [...]។ ការប្រកាសទោសរបស់ជនជាប់ចោទត្រូវបានកាត់បន្ថយដោយស្ថាប័នដែលសើរើរឿងក្ដី [...]។ ស្ថាប័ននេះបានបន្ធូរបន្ថយទោសជនជាប់ចោទ ៥ នាក់ក្នុងចំណោម ៣៣ នាក់ដែលនៅរស់ជាប់ទោសប្រហារជីវិតនោះ មកត្រឹម ២ នាក់ជាប់ទោស ២០ ឆ្នាំដោយធ្វើការជាទម្ងន់ និង ៣ នាក់ទៀតជាប់ទោស ១០ ឆ្នាំដោយធ្វើការជាទម្ងន់”។

[2092] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាកថាខណ្ឌ ៣៩។

គ្រោះ ដែលបានកើតឡើងនៅពេលដែលជនរងគ្រោះត្រូវបាននាំត្រឡប់ទៅប៉ុស្តិ៍ប៉ូលីសវិញ ហើយទាក់ទងទៅនឹងបញ្ហានេះ ពុំមានការបង្ហាញអំពីការរួមចំណែករបស់ជនចាប់ចោទឡើយ[2093]។ ចុងក្រោយ នៅក្នុង *រឿងក្តី Ikeda* តុលាការបានបង្ហាញអំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងការបង្កើតផែនការ និងការគូសបញ្ជាក់លម្អិតលើផែនការបង្កើតកន្លែងពេស្យា និងប្រើប្រាស់ក្មេងស្រី និងស្ត្រីពីជំរំប្រមូលផ្តុំធ្វើជាស្រីពេស្យានៅក្នុងផ្ទះពេស្យាទាំងនេះ[2094]។ តុលាការបានយល់ឃើញបន្ថែមទៀតថា ជនជាប់ចោទបានដឹងថា ផែនការនេះត្រូវបានអនុវត្ត[2095]។ ដោយផ្អែកលើតួនាទីរបស់ជនជាប់ចោទក្នុងរដ្ឋអំណាច តុលាការបានយល់ឃើញថា ជនជាប់ចោទគប្បីដឹងអំពីការធ្វើបែបនេះដោយគ្មានការយល់ព្រមពីជនរងគ្រោះទាំងនោះ និងថា គាត់គប្បីរារាំងការជំរុញណាមួយនៃឧក្រិដ្ឋកម្មនេះព្រមទាំងគប្បីស៊ើបអង្កេតបញ្ហានេះផងដែរ។ តុលាការបានសន្និដ្ឋានថា៖

> ជនជាប់ចោទដែលកំពុងបំពេញតួនាទីនាយទាហាន និងតាមរយៈការឯកភាពលើផែនការប្រភេទនេះ ការចូលរួមនៅក្នុងការគូសបញ្ជាក់លម្អិតអំពីផែនការ និងពុំបានពិនិត្យឡើងវិញ ថាតើផែនការនោះជាក់ស្តែងត្រូវបានអនុវត្តយ៉ាងដូចម្តេចបន្ទាប់ពីបានដឹងហេតុកើតឡើង និងថាតើផ្ទះពេស្យាដែលបានបង្កើតឡើង ដោយផ្អែកតាមផែនការបានប្រព្រឹត្តទៅយ៉ាងដូចម្តេចនោះ ត្រូវដាក់ឱ្យទទួលខុសត្រូវពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅក្នុងដំណើរការនោះ[2096]។

៧៩៤.សាលក្រមក្នុងនៅក្នុង *រឿងក្តី Ikeda* (តុលាការអាជ្ញាសឹកបណ្តោះអាសន្ន Batavia) ពុំបានដោះស្រាយជាក់លាក់លើទម្រង់នៃការទទួលខុសត្រូវនោះឡើយ។ ផ្អែកតាមអង្គហេតុនៃរឿងក្តី លទ្ធភាពអាចកើតមានគឺថា ការទទួលខុសត្រូវនេះត្រូវបានរកឃើញដោយផ្អែកលើការទទួលខុសត្រូវ តាមគោលបំណងរួមសម្រាប់ឧក្រិដ្ឋកម្មដែលជាក់ស្តែងពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួមនោះ។ ទោះបីជាយ៉ាងណាក្តី លទ្ធភាពអាចកើតមានដែលថា ក្នុង *រឿងក្តី Ikeda* តុលាការបានយល់ឃើញថា ឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តឡើងដោយប្រយោលនៅក្នុងគោលបំណងរួម ឬថា ជនជាប់ចោទទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ជាពិសេសនៅពេលដែលតុលាការបានកត់សម្គាល់លើតួនាទី និងឋានន្តរសក្តិរបស់ជនជាប់ចោទ និងការពុំបានចាត់វិធានការស៊ើបអង្កេត។ ដោយផ្អែក

---

[2093] *រឿងក្តី Sch.* (តុលាការកំពូលសម្រាប់ចក្រភពអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ១៣ *ជាអាទិ៍* (ភាសាអាល្លឺម៉ង់) (ការដែលថា ជនជាប់ចោទពុំត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការសម្លាប់ជនរងគ្រោះ បានផ្តុះបញ្ចាំងនៅក្នុងបទចោទប្រឆាំងនឹងជនជាប់ចោទតាមច្បាប់អាល្លឺម៉ង់ដែលពុំបានដាក់បញ្ចូលបទមនុស្សឃាត ឬឃាតកម្មឡើយ)។

[2094] *រឿងក្តី Ikeda* (តុលាការអាជ្ញាសឹកបណ្តោះអាសន្ន Batavia) ទំព័រ ៥។

[2095] *រឿងក្តី Ikeda* (តុលាការអាជ្ញាសឹកបណ្តោះអាសន្ន Batavia) ទំព័រ ៥។

[2096] *រឿងក្តី Ikeda* (តុលាការអាជ្ញាសឹកបណ្តោះអាសន្ន Batavia) ទំព័រ ៥។

លើភាពពុំច្បាស់លាស់ទាំងនេះ និងដោយគ្មានការអនុវត្តរបស់រដ្ឋដែលពាក់ព័ន្ធដទៃទៀត *រឿងក្តី Ikeda* (តុលាការអាជ្ញាសឹកបណ្តោះអាសន្ន Batavia) ពិតជាពុំមានភាពគ្រប់គ្រាន់ក្នុងការបង្ហាញថា ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួម មានអត្ថិភាពតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទឡើយ។

៧៩៥.ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា រឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរដូចជារឿងក្តីរបស់ប្រទេសអ៊ីតាលីដែលបានដកស្រង់នៅក្នុង *រឿងក្តី Tadić* ពុំបានផ្តល់ការគាំទ្ររឹងមាំចំពោះសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ III ឡើយ។ សាលដីកា *រឿងក្តី Tadić* បានសំអាងទៅលើរឿងក្តីរបស់អ៊ីតាលីក្នុងការសន្និដ្ឋានថា “បុគ្គលម្នាក់អាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយសមាជិកដទៃទៀតនៃក្រុមមួយ និងពុំត្រូវបានគិតទុកនៅក្នុងផែនការល្មើសនោះឡើយ” ដរាបណាគេអាចដឹងជាមុនបានថា ជាបទឧក្រិដ្ឋ[2097]។ នៅក្នុង *រឿងក្តី D'Ottavio* ទោះជាយ៉ាងណាក្តី សមាជិកនៃក្រុមពុំត្រូវបានដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋណាមួយឡើយ ព្រោះពុំស្ថិតក្នុងផែនការរួម។ តុលាការកំពូលរបស់អ៊ីតាលីបានបញ្ជាក់ថា ជនជាប់ចោទ D'Ottavio ដែលបានបាញ់ចំដៃរបស់អ្នករត់គេចខ្លួន ពុំមានចេតនាសម្លាប់ឡើយ ប៉ុន្តែត្រឹមតែរារាំងការរត់គេចខ្លួនប៉ុណ្ណោះ និងចាប់ខ្លួនជនរងគ្រោះ ដែលជាគោលដៅត្រូវបានបន្តដោយក្រុមនោះ[2098]។ ការស្លាប់របស់ជនរងគ្រោះបានកើតឡើងដោយសារតែកាលៈទេសៈស្មានមិនដល់ ដែលនេះជាការរងរបួសមួយពុំត្រូវបានព្យាបាលភ្លាមៗ[2099]។ ពិតណាស់ សមាជិកប្អូននាក់នៃក្រុមនោះត្រូវបានដាក់ពិរុទ្ធភាពពីបទមនុស្សឃាតគ្មានមរណចេតនា *(omicidio preterintenzionale)* ជាបទល្មើសមួយដែលត្រឹមតែមានចេតនាបង្កឱ្យមានព្យសនកម្មលើរូបកាយ ដោយជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការស្លាប់នេះតាមរយៈទម្រង់នៃការទទួលខុសត្រូវតឹងរ៉ឹង ស្របតាមយុត្តិសាស្ត្រដែលមានអត្ថិភាពក្នុងឆ្នាំ ១៩៤០។

៧៩៦.*រឿងក្តី Artano* ក៏ត្រូវបានយោងទៅលើដោយពុំត្រឹមត្រូវដូចគ្នាផងដែរ។ តុលាការកំពូលរបស់អ៊ីតាលី*បានបដិសេធ*ការសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាត ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃប្រតិបត្តិការក្នុងគោលបំណងចាប់ខ្លួនអ្នកគាំទ្របក្សប្រឆាំងមួយចំនួន ដោយសារគោលបំណងរួមនៃប្រតិបត្តិការនោះ ពុំ

---

[2097] សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២១៨។

[2098] *រឿងក្តី D'Ottavio* (តុលាការជាន់ខ្ពស់ អ៊ីតាលី) ទំព័រ ៦ ដល់ ៧។

[2099] *រឿងក្តី D'Ottavio* (តុលាការជាន់ខ្ពស់ អ៊ីតាលី) ទំព័រ ២។

បានរួមបញ្ចូលការសម្លាប់ឡើយ[2100]។ អាស្រ័យហេតុនេះ "ព្រឹត្តិការណ៍"នៃការសម្លាប់ដោយគ្មានចេតនាដែលស្ថិតក្រៅផែនការរបស់ក្រុម ពុំអាចដាក់ឱ្យសមាជិកទាំងអស់នៃក្រុមទទួលខុសត្រូវបានឡើយ និងបើទោះបីជាការពិតថា ការសម្លាប់នេះអាចដឹងជាមុនបានថា ជាបទល្មើសក៏ដោយ និងដោយហេតុថា កងជីវពលប្រដាប់ដោយអាវុធ និងអ្នកគាំទ្របក្សប្រឆាំងនោះទំនងជាពុំព្រមចូលសារភាព។ ដោយបានរំឭក*រឿងក្តី* Beraschi តុលាការកំពូលបានបញ្ជាក់ច្បាស់លាស់ថា ការទទួលខុសត្រូវសម្រាប់ការសម្លាប់ដែលបានកើតឡើងក្នុងអំឡុងពេលនៃប្រតិបត្តិការបោសសម្អាតដែលបានធ្វើឡើងដោយមនុស្សមួយចំនួននោះ តម្រូវឱ្យមានការបង្ហាញពី "អំពើដោយចេតនា [*attività volontaria*] ពាក់ព័ន្ធទៅនឹងការសម្លាប់នោះ"[2101]។

៧៩៧.ចំពោះរឿងក្តីទាក់ទងទៅនឹងភាពអាចអនុវត្តបាននៃច្បាប់របស់អ៊ីតាលី ស្តីពីការលើកលែងទោសចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៤៦[2102] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ច្បាប់នេះផ្អែកយ៉ាងខ្លាំងទៅតាមបរិបទ ដូចបានបង្ហាញតាមរយៈយុត្តិសាស្ត្រដែលពុំសូវស៊ីសង្វាក់គ្នា[2103]។ អាស្រ័យហេតុនេះ រឿងក្តីប្រភេទនេះពុំអាចផ្តល់ជាការណែនាំច្បាស់លាស់បានឡើយ។

៧៩៨.ប្រភេទរឿងក្តីចុងក្រោយរបស់អ៊ីតាលីពុំជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ប៉ុន្តែត្រឹមតែជាបទឧក្រិដ្ឋធម្មតាតាមច្បាប់របស់អ៊ីតាលី ដែលបានប្រព្រឹត្តឡើងដោយ និងទៅលើជនជាតិអ៊ីតាលី ហើយត្រូវបានជំនុំជម្រះ

---

[2100] *រឿងក្តី Artano* (តុលាការជាន់ខ្ពស់ អ៊ីតាលី) ទំព័រ ១៣។

[2101] *រឿងក្តី Artano* (តុលាការជាន់ខ្ពស់ អ៊ីតាលី) ទំព័រ ១៤។

[2102] សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២១៧។

[2103] ជាឧទាហរណ៍ *រឿងក្តី compare Tossani* (តុលាការជាន់ខ្ពស់ អ៊ីតាលី) ទំព័រ ៨៨ ដល់ ៨៩ (ការលើកលែងទោសអាចអនុវត្តបាន នៅពេលជនជាប់ចោទពុំបានប្រព្រឹត្តអំពើណាមួយក្នុងការជំរុញប្រតិបត្តិការ ឬប្រើប្រាស់អាវុធ និងដោយសារការសម្លាប់នោះ គឺជាហេតុការណ៍ដែលមានលក្ខណៈពិសេស និងពុំអាចប្រមើលដឹងជាមុនបាន) និង *រឿងក្តី Ferrida* (តុលាការជាន់ខ្ពស់ អ៊ីតាលី) ទំព័រ ៨៨ (ការលើកលែងទោសអាចអនុវត្តបាន ដោយហេតថា ជនជាប់ចោទបានចូលរួមក្នុងការជំរុញប្រតិបត្តិការត្រឹមតែជាអ្នកព្យាលបាល និងដោយសារបទឃាតកម្មនេះខុសប្លែកពីបទដែលជនជាប់ចោទមានបំណងប្រព្រឹត្ត ដូចជា ការសហការជាមួយសត្រូវ) *រឿងក្តី Palmia* (តុលាការជាន់ខ្ពស់ អ៊ីតាលី) ទំព័រ ៨៩ (បានសម្រេចថា ការលើកលែងទោស ក្នុងករណីឃាតកម្មដែលបានប្រព្រឹត្តឡើងក្នុងពេលជំរុញប្រតិបត្តិការដែលអនុវត្តដោយបុគ្គលមួយចំនួន ពុំអាចអនុវត្តបាន នៅពេលដែលប្រតិបត្តិការនេះ តាមធម្មតា ឬដោយចៃដន្យក្តី (*rapporto di causalità o anche solo di occasionalità*) បានភ្ជាប់ទំនាក់ទំនងទៅនឹងការធ្វើមនុស្សឃាត)។ បន្ថែមលើនេះទៀត កំណត់សង្ខេបរឿងក្តី ពុំបានផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ដែលអាចយល់បានច្បាស់លាស់អំពីតួនាទីនៃភាពអាចដឹងជាមុនបាន នៅក្នុងការដាក់សមាជិកទាំងអស់ដែលជំរុញប្រតិបត្តិការឱ្យទទួលខុសត្រូវចំពោះបទមនុស្សឃាតឡើយ។

ក្តីនៅចំពោះមុខអាជ្ញាធររបស់អ៊ីតាលីប៉ុណ្ណោះ[2104]។ អាស្រ័យហេតុនេះ រឿងក្តីនេះអាចត្រូវបានចាត់ទុកថា មានការជាប់ពាក់ព័ន្ធតិចតួចនៅក្នុងបរិបទនេះ។ អង្គជំនុំជម្រះតុលាការកំពូលក្នុង *រឿងក្តី Tadić* បានសំអាងទៅលើរឿងក្តីនេះដើម្បីជឿជាក់បានថា ធាតុផ្សំ *អត្តនោម័ត* តម្រូវសម្រាប់ដាក់ការទទួលខុសត្រូវចំពោះអំពើដែលបានប្រព្រឹត្តឡើងដោយសមាជិកដទៃទៀតនៅក្នុងប្រតិបត្តិការល្មើស ប៉ុន្តែពុំបានរួមបញ្ចូលនៅក្នុងផែនការរួមនោះ ពិតជាមានអត្ថិភាពនៅជុំវិញភាពអាចដឹងជាមុនបានថា ជាបទល្មើស[2105]។ ទោះជាយ៉ាងណាក្តី សាលដីកា *រឿងក្តី Mannelli* ដែលអង្គជំនុំជម្រះតុលាការកំពូលនៃរឿងក្តីនេះបានដកស្រង់យ៉ាងទូលំទូលាយ នៅក្នុងការវិភាគរបស់ខ្លួនអំពីបញ្ហាអត្តនោម័ត ពុំទំនងជាផ្ទុយគ្នាទាំងស្រុងនោះទេ។ ក្នុង *រឿងក្តី Mannelli* តុលាការកំពូលបានពង្រីកលើប្រធានបទស្តីពីហេតុ និងផលជាសត្យានុម័ត (*rapporto di causalità materiale*) ក្នុងការបញ្ជាក់អំពីគោលការណ៍ដែលថា ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយបុគ្គលដទៃទៀត និងខុសពីបទឧក្រិដ្ឋដែលបានព្រមព្រៀងគ្នាដោយសមាជិកនោះ អាចមានអត្ថិភាព តែក្នុងករណីដែលបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយបុគ្គលដទៃនោះ គឺជាការវិវឌ្ឍន៍សមស្រប និងអាចស្មានដឹងជាមុនបានចេញពីបទឧក្រិដ្ឋដែលបានព្រមព្រៀងគ្នានោះ (*logico e prevedibile sviluppo*)[2106]។ គួរកត់សម្គាល់ លក្ខខណ្ឌតម្រូវនៃការវិវឌ្ឍន៍សមស្របនេះ យោងតាមតុលាការកំពូលនោះ ពាក់ព័ន្ធទៅនឹងធាតុផ្សំនៃហេតុ និងផលជាសត្យានុម័ត ពុំមែនធាតុផ្សំ *អត្តនោម័ត* នោះទេ។ ដូចនេះ ជាឧទាហរណ៍ ផ្នត់គំនិតរបស់ចារីពុំមានការជាប់ពាក់ព័ន្ធទៅនឹងការវាយតម្លៃអំពីហេតុ និងផល *ជាសត្យានុម័ត* ឡើយ។

៧៩៩.អង្គជំនុំជម្រះតុលាការកំពូល ក៏បានពិនិត្យផងដែរលើយុត្តិសាស្ត្រជាច្រើនដទៃទៀតចាប់តាំងពីក្រោយសង្គ្រាមលោកលើកទីពីរ។ ភាគច្រើននៃរឿងក្តីទាំងនេះពុំបានគាំទ្រដល់ការលើកឡើងដែលថា ជនជាប់ចោទអាចត្រូវបានសម្រេចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋ ដែលជនជាប់ចោទពុំបានប្រព្រឹត្តអំពើ *សត្យានុម័ត* នៃបទនេះ[2107] និងពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួមឡើយ។ ទោះជាយ៉ាងណាក្តី រឿងក្តីចំនួន ៥ ស័ក្តិសមនឹងទទួលបានការពិភាក្សាបន្ថែមទៀត។

---

[2104] សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២១៨ ដល់ ២១៩។

[2105] សាលដីកា *រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២១៨ ដល់ ២១៩។

[2106] *រឿងក្តី Mannelli* (តុលាការជាន់ខ្ពស់ អ៊ីតាលី) កថាខណ្ឌ ៦៩៦ ដល់ ៦៩៧។

[2107] អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យបន្ថែមលើរឿងក្តីដែលបានបង្ហាញខាងលើ ដូចជា *រឿងក្តី Belsen* (តុលាការយោធាអង់គ្លេស ក្នុងប្រទេសអាល្លឺម៉ង់) មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹង *រឿងក្តី ជំរំប្រមូលផ្តុំ Dachau* ដោយសារពាក់ព័ន្ធទៅនឹង

៨០០.រឿងក្តីពីរក្នុងចំណោមនេះ គឺ *រឿងក្តី* *Rüsselsheim* (គណៈកម្មការយោធាសហរដ្ឋអាម៉េរិកក្នុងប្រទេសអាល្លឺម៉ង់) និង*រឿងក្តី* *Tashiro* (គណៈកម្មការយោធាសហរដ្ឋអាម៉េរិកក្នុងប្រទេសជប៉ុន) ដែលត្រូវបានសម្រេចនៅចំពោះមុខគណៈកម្មការយោធាអាម៉េរិក។ ក្នុង*រឿងក្តី* *Rüsselsheim* ជនស៊ីវិលអាល្លឺម៉ង់ដប់មួយនាក់ត្រូវបានចោទប្រកាន់ពីបទប្រើប្រាស់អំពើហិង្សា និងការធ្វើមនុស្សឃាតមកលើអាកាសយានិកអាម៉េរិកចំនួនប្រាំមួយនាក់បានធ្លាក់យន្តហោះ ដែលត្រូវបានហ្វូងមនុស្សវាយដំ និងចុងក្រោយត្រូវបានបាញ់សម្លាប់ដោយ

---

ការចូលរួមក្នុងការជំរុញការធ្វើបាបជាប្រព័ន្ធ (ទំព័រ ១)។ *រឿងក្តី* *Farben* (តុលាការយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) ដែលជនជាប់ចោទមួយចំនួនត្រូវបានចោទប្រកាន់ដោយសារបានចូលរួមនៅក្នុងការបង្កើត និងអនុវត្តផែនការរួម ឬសមគំនិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងសន្តិភាព (ទំព័រ ១) តុលាការនេះបានបញ្ជាក់ថា "ត្រូវតែមានការបង្ហាញថា *ជនជាប់ចោទ ពិតជាភាគី*នៃផែនការ ឬការសមគំនិត ឬបានដឹងអំពីផែនការ និងបានជំរុញគោលបំណង និងគោលដៅតាមរយៈការចូលរួមនៅក្នុងការរៀបចំសម្រាប់ធ្វើសង្គ្រាមឈ្លានពាន"(ទំព័រ ១៦ សេចក្តីបញ្ជាក់បន្ថែម)។ *រឿងក្តី* *Hadamar* (គណៈកម្មការយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) ជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយសារការចូលរួមនៅក្នុងផែនការរួមសម្លាប់ជនស៊ីវិលរាប់រយនាក់នៅកន្លែងសម្រាប់ព្យាបាលរោគ (ទំព័រ ៤៧, ៥១)។ *រឿងក្តី* *Hostage* ជនជាប់ចោទត្រូវបានចោទប្រកាន់*ក្នុងចំណោមនោះ*ដោយសារការចូលរួមនៅក្នុងផែនការគិតទុកជាមុននៃភេរវកម្ម និងការបំភិតបំភ័យ ទោះជាយ៉ាងណាក្តី ជនជាប់ចោទពុំត្រូវបានរកឃើញថា មានពិរុទ្ធដោយសារពុំមានភស្តុតាងបង្ហាញអំពីការចូលរួមនៅក្នុងផែនការគិតទុកជាមុននោះ (ទំព័រ ១២៣០ និង ១២៦០)។ *រឿងក្តី* *Mauthausen* (តុលាការយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) តុលាការនេះបានសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទចំនួន ៦១ នាក់ ដោយសារ "ការអនុវត្តតាមផែនការរួមក្នុងការដាក់បុគ្គលនានា"ឱ្យទទួលរងគ្រោះដោយសារឧក្រិដ្ឋកម្មផ្សេងៗ (ទំព័រ ២ ដល់ ៤ *សូមមើលផងដែរ* ទំព័រ ១៤ ដល់១៥) ដូច្នេះ តុលាការបានទទួលស្គាល់ការចូលរួមនៅក្នុងផែនការរួមដែលជាទម្រង់នៃការទទួលខុសត្រូវ បើទោះបីជាពុំបានបញ្ជាក់ថា នេះអាចរួមបញ្ចូលការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលពុំមាននៅក្នុងផែនការរួមនោះក៏ដោយ (ទំព័រ ១៤)។ សាលក្រមរបស់តុលាការ IMFTE បានសម្រេចថា ជនជាប់ចោទមួយចំនួនបានចូលរួមនៅក្នុងការបង្កើត និងការអនុវត្តផែនការរួម ឬសមគំនិតរក្សាអំណាចត្រួតត្រារបស់ជប៉ុននៅក្នុងតំបន់តាមរយៈការធ្វើសង្គ្រាមឈ្លានពាន (ទំព័រ ៤៩៧៦៨ ដល់ ៤៩៧៦៩) ដែលតុលាការបានសម្រេចថា ជាអំពើល្មើស ដោយសារ"អ្នកទាំងអស់នោះដែលនៅគ្រប់ពេល គឺជាភាគីនៅក្នុងការសមគំនិតល្មើស ឬនៅក្នុងពេលណាមួយបានដឹងថា ជាបទល្មើស បានចូលរួមក្នុងការអនុវត្តផែនការនោះ និងមានពិរុទ្ធពីបទចោទដែលមានចែងនៅក្នុងបទចោទទីមួយ" (ទំព័រ ៤៩៧៧០)។ *រឿងក្តី* *Ulrich and Merkle* (តុលាការយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) ជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធដោយសារបានអនុវត្តតាមផែនការរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងកិច្ចប្រតិបត្តិការនៅជំរំប្រមូលផ្តុំ Dachau (ទំព័រ ១)។ *រឿងក្តី* *Wuelfert* (តុលាការយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) ជនជាប់ចោទត្រូវបានចោទប្រកាន់ពីការធ្វើមនុស្សឃាត ការវាយដំ និងការធ្វើទារុណកម្មលើសមាជិកកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ ដោយបានអនុវត្តតាមផែនការរួមតាមរយៈការលើកទឹកចិត្តដោយឆន្ទៈ និងដោយចេតនា ជួយនិងជំរុញ និងចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនោះ (ទំព័រ១)។

ជនជាប់ចោទម្នាក់ក្នុងចំណោមនោះ[2108]។ តំណាងអយ្យការបានអះអាងថា ជនជាប់ចោទបានចូលរួមក្នុងគោលបំណងរួម ដូច្នេះត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះការសម្លាប់ណាដែលជាផលវិបាកទំនងជាកើតមានតាមធម្មជាតិ "បើទោះបីជាភាគីពុំមានបំណងជាក់លាក់ ឬហាមឃាត់ដោយជនជាប់ចោទក៏ដោយ"[2109]។ ដូច្នេះអយ្យការទំនងជាយល់ឃើញថា ការទទួលខុសត្រូវចំពោះគោលបំណងរួមបានពន្លាតដល់ឧក្រិដ្ឋកម្មដែលពុំបានមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដរាបណាគេអាចដឹងជាមុនបានថា ជាបទល្មើស។ ប៉ុន្តែ ក្នុង*រឿងក្តី Essen Lynching* (តុលាការយោធាចក្រភពអង់គ្លេសក្នុងប្រទេសអាល្លឺម៉ង់) ពុំមានភាពច្បាស់លាស់ ថាតើតុលាការជាក់ស្តែងមានទស្សនៈដូចគ្នានេះ និងបានអនុវត្តទស្សនៈនេះនៅក្នុងរឿងក្តី ដែរ ឬយ៉ាងណា។ ជាការកត់សម្គាល់ ជនជាប់ចោទម្នាក់ ត្រូវបានដោះលែងឱ្យរួចខ្លួន ដោយសារត្រឹមតែបានឈរមើល។ ជនជាប់ចោទដទៃទៀតត្រូវបានរកឃើញថា មានពិរុទ្ធដោយ"បានធ្វើសកម្មភាពរួមគ្នា ... ដោយឆន្ទៈ ដោយចេតនា និងបានលើកទឹកចិត្តជួយជំរុញដោយពុំត្រឹមត្រូវ និងបានចូលរួមក្នុងការសម្លាប់ [...] សមាជិកនៃអាកាសយានិកអាម៉េរិក"[2110]។ ការសម្រេចដាក់ពិរុទ្ធភាពនេះបានបង្ហាញថា ការធ្វើមនុស្សឃាតចុងក្រោយ គឺជាផ្នែកនៃគោលបំណងរួម។

៨០១.នៅក្នុង*រឿងក្តី Tashiro* បុគ្គលិកប្រាំនាក់នៃពន្ធនាគារយោធាតូក្យូ (Tokyo) ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះការស្លាប់អ្នកទោសសង្គ្រាមជនជាតិអាម៉េរិកដែលត្រូវបានឆេះស្លាប់ ក្នុងអំឡុងពេលនៃការវាយប្រហារទម្លាក់គ្រាប់បែក ដោយសារពួកគេពុំត្រូវបានដោះលែងចេញពីបន្ទប់ឃុំខ្លួន[2111]។ ក្នុងរឿងក្តីនេះ អយ្យការបានអះអាងថា "អ្នកទោសជនជាតិអាម៉េរិកត្រូវបានធ្វើឱ្យឆេះស្លាប់ដោយចេតនា និងស្របតាមផែនការដែលបានគិតទុកជាមុន ឬយ៉ាងហោចណាស់ ដោយសារការមិនយកចិត្តទុកដាក់ទាំងស្រុងរបស់ជនជាប់ចោទ TASHIRO និង KOSHIKAWA ក្នុងការមិនបានដោះលែងពួកគេឱ្យបានមុន"[2112]។ បើទោះបីជាការយោងទៅលើការមិនយកចិត្តទុកដាក់ទាំងស្រុងអាចត្រូវបានបកស្រាយថា ជាការយោងទៅលើការទទួលខុសត្រូវក្នុងគោលបំណងរួមចំពោះឧក្រិដ្ឋកម្មដែលជាក់ស្តែងពុំបានមានរួមបញ្ចូលនៅក្នុងគោលបំណងរួមនេះក៏ដោយ ក៏

---

[2108] *រឿងក្តី Rüsselsheim* (គណៈកម្មការយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ២ ដល់ ៣ និង ៦។

[2109] ប្រតិចារឹកជំនុំជម្រះ *រឿងក្តី Rüsselsheim* ដកស្រង់ដោយ Robert Clarke៖ "ការវិលត្រឡប់ទៅកាន់កោះ Borkum ការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទូលាយនៅក្នុងព្រឹត្តិការណ៍សង្គ្រាមលើកទីពីរ" *ព្រឹត្តិប័ត្រនៃយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ* ភាគ ៩ (ឆ្នាំ ២០០៩) ទំព័រ ៨៣៩ និង ៨៥៤។

[2110] *រឿងក្តី Rüsselsheim* (គណៈកម្មការយោធាអាម៉េរិក ក្នុងប្រទេសអាល្លឺម៉ង់) ទំព័រ ១។

[2111] *រឿងក្តី Tashiro* (គណៈកម្មការយោធាអាម៉េរិក ក្នុងប្រទេសជប៉ុន) ទំព័រ ៧ ដល់ ៨ និង ១១។

[2112] *រឿងក្តី Tashiro* (គណៈកម្មការយោធាអាម៉េរិក ក្នុងប្រទេសជប៉ុន) ទំព័រ ១១។

ទំនងជាថា ការយោងនេះសំដៅទៅលើការទទួលខុសត្រូវចំពោះការធ្វើមនុស្សឃាតគ្មានមរណចេតនា។ អាស្រ័យហេតុនេះ ពុំអាចសន្និដ្ឋានថា រឿងក្ដីនេះបានបង្ហាញអំពីការដាក់ឱ្យទទួលខុសត្រូវដោយផ្អែកលើទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមបានឡើយ។

៨០២.មានរឿងក្ដីដែលពាក់ព័ន្ធក្រោយសង្គ្រាមលោកលើកទីពីរចំនួន ៣ ដទៃទៀតនៅចំពោះមុខតុលាការយោធាអូស្ត្រាលី។ ក្នុង *រឿងក្ដី Hatakeyama* អ្នកចូលរួមជនជាតិជប៉ុនចំនួន ៧ នាក់ ត្រូវបានចោទប្រកាន់ពីបទសម្លាប់ជនស៊ីវិលជនជាតិចិនម្នាក់[2113]ដែលបានស្លាប់ដោយសារការវាយដំ និងការធ្វើទារុណកម្ម[2114]។ នៅក្នុងរបាយការណ៍របស់ខ្លួនចំពោះមុខតុលាការ តំណាងអយ្យការបានយោងទៅលើសៀវភៅមួយក្បាលស្ដីពីច្បាប់ព្រហ្មទណ្ឌក្នុងស្រុកដែលពិភាក្សា“អំពីផែនការរួម” ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ[2115]។ ទោះបីជាយ៉ាងណាក្ដីពុំមានការបញ្ជាក់ថា តុលាការបានសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវដែលដូចគ្នាទៅនឹងទម្រង់ទូលាយនៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមឡើយ[2116]។

៨០៣. ក្នុង *រឿងក្ដី Matsumoto* ជនជាប់ចោទចំនួន ៣ នាក់ ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាតលើជនស៊ីវិលជនជាតិចិនម្នាក់ដែលពួកគេសង្ស័យអំពីសកម្មភាពចារកម្ម ដែលក្រោយមកបានស្លាប់ដោយសារការធ្វើទារុណកម្ម និងការធ្វើបាប[2117]។ តំណាងអយ្យការបានលើកឡើងថា ទាក់ទងទៅនឹងជនជាប់ចោទ Matsumoto តុលាការគប្បីពិចារណា ថាតើជនជាប់ចោទ ជា“បុគ្គលម្នាក់ក្នុងចំណោមនោះដែលបានរួមគ្នាសម្រាប់គោលបំណងពុំស្របច្បាប់ ឬសម្រាប់គោលបំណងពុំស្របច្បាប់ដែលត្រូវបានធ្វើឱ្យប្រសិទ្ធភាពតាមរយៈមធ្យោបាយមិនស្របច្បាប់ ដែរ ឬយ៉ាងណា”[2118]។ គាត់បានបន្ថែមទៀតថា ជនជាប់ចោទ Matsumoto ពុំគប្បីត្រូវបានដាក់ឱ្យទទួលខុសត្រូវឡើយ ប្រសិនបើគាត់ពុំបានដឹង ឬប្រសិនបើគាត់ពុំបានយល់ព្រមថា ការសួរយកចម្លើយជនរងគ្រោះត្រូវបានធ្វើឡើងតាមរយៈអំពើហិង្សាដល់ស្លាប់នោះ[2119]។ ដូច្នេះ របាយការណ៍របស់

---

[2113] *រឿងក្ដី* Hatakeyama (តុលាការយោធា អូស្ត្រាលី) ទំព័រ ៨៤។

[2114] *រឿងក្ដី* Hatakeyama (តុលាការយោធា អូស្ត្រាលី) ទំព័រ ៥១។

[2115] *សូមមើល រឿងក្ដី* Hatakeyama (តុលាការយោធា អូស្ត្រាលី) ទំព័រ ៥២។

[2116] *រឿងក្ដី* Matsumoto (តុលាការយោធា អូស្ត្រាលី) ទំព័រ ៤៦។

[2117] *រឿងក្ដី* Matsumoto (តុលាការយោធា អូស្ត្រាលី) ទំព័រ ១៧។

[2118] *រឿងក្ដី* Matsumoto (តុលាការយោធា អូស្ត្រាលី) ទំព័រ ១៧។

[2119] ការជំនុំជម្រះ *រឿងក្ដី* Matsumoto (តុលាការយោធា អូស្ត្រាលី) ទំព័រ ៤៦។

តំណាងអយ្យការ បង្ហាញថា យោងតាមទស្សនៈរបស់គាត់ ពុំមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលពុំត្រូវបានគិតទុកតាមរយៈគោលបំណងរួមឡើយ។ តុលាការរកពុំឃើញថា ជនជាប់ចោទ Matsumoto មានពិរុទ្ធឡើយ[2120]។

៨០៤.ចុងក្រោយ ក្នុង*រឿងក្តី Ishiyama និង Yasusaka* ជនជាប់ចោទពីរនាក់ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាតលើឈ្លើយសឹកសង្គ្រាមជនជាតិឥណ្ឌាពីរនាក់[2121]។ ជនជាប់ចោទទាំងពីរបានបំភិតបំភ័យឈ្លើយសឹកដោយចងពួកគេភ្ជាប់នឹងដើមឈើ។ នៅពេលជនជាប់ចោទ Yasusaka ប្រាប់ជនជាប់ចោទ Ishiyama ថា គួរ "ដោះលែងពួកគេទៅ" ជនជាប់ចោទ Ishiyama បានឆ្លើយថា "យើងបានធ្វើមកដល់ត្រឹមនេះហើយ យើងអាចបញ្ចប់វាតែម្តងទៅ" និងបានបាញ់សម្លាប់ឈ្លើយសឹកនោះ[2122]។ នៅក្នុងការបង្ហាញដល់តុលាការ តំណាងអយ្យការបានញ្ញាក់ដូចខាងក្រោម៖

> ផែនការរួម រួមបញ្ចូលផែនការរួបរួមព្រមព្រៀងគ្នាប្រព្រឹត្តអំពើមនុស្សឃាត ឬបទល្មើសណាមួយ។ ប្រសិនបើអំពើមួយដែលបានប្រព្រឹត្តឡើងដោយនរណាម្នាក់នៃសមាជិកក្រុម ក្នុងគោលបំណងជំរុញគោលដៅរួមរបស់សមាជិកក្រុមនោះ បានបណ្តាលឱ្យមានការស្លាប់មនុស្ស សមាជិកទាំងអស់នោះត្រូវទទួលខុសត្រូវចំពោះបទមនុស្សឃាតក្នុងកម្រិតទីពីរស្មើគ្នានឹងចារីនោះដែរ។
>
> ប្រសិនបើអ្នកជឿជាក់ថា ការព្រមព្រៀងគ្នារវាងជនជាប់ចោទទាំងពីរ គឺដើម្បីបំភិតបំភ័យឈ្លើយសឹកជនជាតិឥណ្ឌាពីរនាក់នោះ និងថា ជនជាប់ចោទម្នាក់បានសម្រេចបាញ់សម្លាប់ឈ្លើយសឹកនោះ ហើយថា ការបាញ់ប្រហារនោះពុំបានធ្វើឡើងក្នុងគោលបំណងជំរុញគោលដៅរួមនោះទេ ដូច្នេះជនជាប់ចោទដទៃទៀតពុំអាចដាក់ឱ្យទទួលខុសត្រូវដូចចារីក្នុងកម្រិតទីពីរតាមគោលការណ៍នៃផែនការរួមឡើយ[2123]
> ។

អាស្រ័យហេតុនេះ ផ្ទុយទៅនឹង*រឿងក្តី Matsumoto* តំណាងអយ្យការក្នុង*រឿងក្តី Ishiyama និង Yasusaka* ទំនងជាយល់ថា បើទោះបីជាគោលបំណងរួម គឺដើម្បីប្រព្រឹត្តបទឧក្រិដ្ឋមួយ ការទទួលខុសត្រូវក៏មានអត្ថិភាពផងដែរទាក់ទងទៅនឹងបទឧក្រិដ្ឋនានាដែលពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួមនោះ។ ទោះជាយ៉ាងណាក្តី

---

[2120] *រឿងក្តី Ishiyama និង Yasusaka* ទំព័រ ៥។

[2121] *រឿងក្តី Ishiyama និង Yasusaka* ទំព័រ ៤ ដល់ ៥។

[2122] *រឿងក្តី Ishiyama និង Yasusaka* ទំព័រ ២៤ ដល់ ២៥។

[2123] *រឿងក្តី Ishiyama និង Yasusaka* ទំព័រ ២៧។

ពុំមានការបញ្ជាក់ថា តុលាការបានយល់ឃើញថា បទមនុស្សឃាត ឬបទឧក្រិដ្ឋដទៃទៀតមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដូចករណីដែលជនជាប់ចោទ *Ishiyama* ត្រូវបានដាក់ពិរុទ្ធភាពឡើយ[2124]។ អាស្រ័យហេតុនេះ ពុំមានការបង្ហាញថា តុលាការបានអនុវត្តគោលគំនិតនេះឡើយ។

៨០៥.ទាក់ទងទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថា អត្ថិភាពតាមច្បាប់ទំនៀមទម្លាប់នៃការទទួលខុសត្រូវក្នុងគោលបំណងរួមចំពោះបទឧក្រិដ្ឋ ដែលពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួម អាចត្រូវបានបង្ហាញដោយផ្អែកលើការពិនិត្យលើច្បាប់ព្រហ្មទណ្ឌក្នុងស្រុកនោះ អំណះអំណាងនេះបានផ្អែកលើការយល់ច្រឡំជាមូលដ្ឋានថា រឿងក្តីមួយចំនួនធំ និងការតាក់តែងច្បាប់ដែលសហព្រះរាជអាជ្ញាបានយោងទៅលើនោះ ពាក់ព័ន្ធទៅនឹងច្បាប់ព្រហ្មទណ្ឌសាមញ្ញក្នុងស្រុក ដោយគ្មានរួមបញ្ចូលសមាសភាពនៃច្បាប់អន្តរជាតិណាមួយឡើយ[2125]។ ការអនុវត្តយុត្តាធិការព្រហ្មទណ្ឌក្នុងស្រុកមកលើឧក្រិដ្ឋកម្មអន្តរជាតិដែលបានប្រព្រឹត្តឡើងដោយជនបរទេសនោះ អាចចាត់ជាការអនុវត្តរបស់រដ្ឋពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណនៃវិធានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានយកមកអនុវត្ត។ ផ្ទុយទៅវិញ ការអនុវត្តយុត្តាធិការព្រហ្មទណ្ឌក្នុងស្រុកទូទៅ ពុំអាចធ្វើជាមូលដ្ឋានសម្រាប់បង្ហាញអំពីវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបាននោះទេ ដោយហេតុថា ខ្វះសមាសភាពអន្តរជាតិ។ ការអនុវត្តក្នុងស្រុកបែបនេះត្រឹមតែអាចប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណគោលការណ៍ទូទៅនៃច្បាប់ (ក្នុងស្រុក) ឬធ្វើជាការយោងសម្រាប់បកស្រាយឧក្រិដ្ឋកម្មអន្តរជាតិ គោលគំនិត និងគោលការណ៍នោះប៉ុណ្ណោះ ដោយហេតុថា គោលគំនិតច្បាប់ព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើង ដោយផ្អែកលើគោលគំនិតច្បាប់ព្រហ្មទណ្ឌក្នុងស្រុក[2126]។ ផ្អែកតាមវិធីសាស្ត្រដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាគឺថា វិធានសំខាន់ៗជាច្រើននៃច្បាប់ព្រហ្មទណ្ឌក្នុងស្រុកមានលក្ខណៈដូចជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ បើទោះបីជាគ្មានសមាសភាពច្បាប់អន្តរជាតិណាមួយចូលរួមក៏ដោ

---

[2124] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥០ ដល់ ៧៥។

[2125] ក្នុងចំណោមយុត្តិសាស្ត្រដែលបានដកស្រង់នោះ បន្ថែមលើរឿងក្តីដកស្រង់ទាក់ទងទៅនឹងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ ទំនងជាថា មានតែរឿងក្តីប៉ូឡូញ *ការជំនុំជម្រះក្តី Goeth* (តុលាការកំពូលនៃតុលាការឧក្រិដ្ឋកម្មរបស់ប៉ូឡូញ)ប៉ុណ្ណោះដែលដាក់បញ្ចូលធាតុផ្សំចេតនា។

[2126] *សូមមើលខាងលើ* កថាខណ្ឌ ៣៨៧ *ជាអាទិ៍*។ *សូមមើលផងដែរ* Boris Burghardt៖ “Die Rechtsvergleichung in der völkerstrafrechtlichen Rechtsprechung *ច្បាប់ប្រហាក់ប្រហែលនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*” នៅក្នុង៖ Susanne Beck, Christoph Burchard, Bijan Fateh-Moghadam (eds), *Strafrechtsvergleichung als Problem und Lösung ច្បាប់ព្រហ្មទណ្ឌជាដំណោះស្រាយ និងបញ្ហា* Nomos: ឆ្នាំ ២០០១ ទំព័រ ២៣៥ ជាអាទិ៍។

យ។ ការលើកឡើងបែបនេះធ្វើឱ្យប៉ះពាល់ដល់ការបែងចែងដាច់ពីគ្នារវាងច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុក ព្រមទាំងរវាងច្បាប់ទំនៀមទម្លាប់*អន្តរជាតិ* និងគោលការណ៍ទូទៅនៃច្បាប់*ក្នុងស្រុក*[2127]។

---

[2127] *សូមមើល* មាត្រា ៣៨ នៃសលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ Joseph L. Kunz៖ "ចរិតលក្ខណៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ" *ព្រឹត្តិប័ត្រអាម៉េរិកស្តីពីច្បាប់អន្តរជាតិ* ភាគ ៤៧ (ឆ្នាំ ១៩៥៣) ទំព័រ ៦៦៦ បានលើកឡើងទាក់ទងទៅនឹងការបង្ហាញអំពីច្បាប់ទំនៀមទម្លាប់ថា "ត្រូវតែជា*ការអនុវត្ត*ដែលបើទោះបីជាអំពើសកម្ម ឬអកម្ម និងបើទោះបីជានៅក្នុងអំឡុងពេលនៃសង្គ្រាម ឬសន្តិភាពក៏ដោយ។ ការអនុវត្តនេះត្រូវតែសំដៅទៅលើស្ថានភាពមួយប្រភេទដែលស្ថិតក្នុងវិសាលភាពនៃទំនាក់ទំនងអន្តរជាតិ"។ Eric David៖ *គោលការណ៍នីតិនៃជម្លោះប្រដាប់អាវុធ* ទំព័រ ៦៣ បានពន្យល់ថា "គោលការណ៍ទូទៅនៃច្បាប់មនុស្សធម៌" ដែលបានពិភាក្សានៅក្នុង*រឿងក្តី Nicaragua* (ICJ) ពុំគប្បីយល់ច្រឡំជាមួយនឹងគោលការណ៍នីតិទូទៅរបស់ជាតិសាសន៍ដែលមានអារ្យធម៌ ពីព្រោះគោលការណ៍នីតិទូទៅនេះ គឺជាមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ Ian Brownlie៖ *គោលការណ៍នៃនីតិសាធារណៈអន្តរជាតិ* បោះពុម្ពផ្សាយលើកទីប្រាំពីរ ដោយព្រឹត្តិប័ត្រសារព័ត៌មានសាកលវិទ្យាល័យ Oxford ឆ្នាំ ២០០៨ ទំព័រ ១៧ បានកត់សម្គាល់ទាក់ទងទៅនឹងគោលការណ៍នីតិទូទៅថា "គោលការណ៍នីតិទូទៅ គឺជាគោលការណ៍ពាក់ព័ន្ធទៅនឹងវិធានដែលបានទទួលស្គាល់នៅក្នុងច្បាប់ក្នុងស្រុករបស់រដ្ឋដែលមានអារ្យធម៌" [...]។ គោលបំណង គឺដើម្បីផ្តល់សិទ្ធិអំណាចឱ្យតុលាការអនុវត្តគោលការណ៍ទូទៅរបស់យុត្តិសាស្ត្រក្នុងស្រុក [...] ត្រង់ថាគោលការណ៍នេះអាចអនុវត្តបានចំពោះទំនាក់ទំនងរបស់រដ្ឋ"។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា យុត្តិសាស្ត្ររបស់តុលាការ ICTY ទាក់ទងទៅនឹងបញ្ហានេះ នៅតែមានភាពពុំច្បាស់លាស់៖ ដូចអង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី Kunarac* បញ្ជាក់ថា "ដើម្បីឱ្យស្របតាមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសន្និដ្ឋានថា "អំពើរំលោភផ្លូវភេទ [...] ចាត់ជាឧក្រិដ្ឋកម្មសង្គ្រាមដែលត្រូវបានទទួលស្គាល់តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអំពើនេះទទួលទោសតាមមាត្រា ៣ នៃលក្ខន្តិកៈ។ *ការចាត់ទុកជាសាកលនូវអំពើរំលោភផ្លូវភេទជាបទល្មើសតាមយុត្តិសាស្ត្រក្នុងស្រុក* ការហាមឃាត់ជាក់ច្បាស់ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវលើកទីបួន និងនៅក្នុងពិធីសារបន្ថែមទីមួយ និងទីពីរ និងការទទួលស្គាល់ភាពធ្ងន់ធ្ងរនៃបទល្មើសនេះនៅក្នុងយុត្តិសាស្ត្រនៃស្ថាប័នអន្តរជាតិ រួមមានគណៈកម្មការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងគណៈកម្មការអន្តរទ្វីបអាម៉េរិកស្តីពីសិទ្ធិមនុស្ស ទាំងអស់នេះសុទ្ធតែនាំទៅរកការសន្និដ្ឋានបែបនេះ"(ជើងទំព័រលុបចោល សេចក្តីបញ្ជាក់បន្ថែម)។ (សាលដីកា*រឿងក្តី Kunarac* (ICTY) កថាខណ្ឌ ១៩៥) ដូចនេះបង្ហាញថា ការអនុវត្តក្នុងស្រុក អាចជាប់ពាក់ព័ន្ធទៅនឹងការបញ្ជាក់អំពីវិធានស្តីពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ខណៈពេលដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY *រឿងក្តី Čelebići* បានបញ្ជាក់ថា "ជាការពុំអាចបដិសេធបានថា អំពើដូចជាការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម រំលោភផ្លូវភេទ និងអំពើអមនុស្សធម៌ ត្រូវតែជាបទល្មើសស្របតាម*គោលការណ៍នីតិទូទៅ*ដែលត្រូវបានទទួលស្គាល់ដោយប្រព័ន្ធគតិយុត្តទាំងអស់" (សេចក្តីបញ្ជាក់បន្ថែម)(សាលដីកា*រឿងក្តី Čelebići* (ICTY) កថាខណ្ឌ ១៧៩ ដល់ ១៨០)។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការយោងនៅក្នុង*រឿងក្តី Kunarac* ទៅលើច្បាប់ក្នុងស្រុក ត្រូវបានយល់ច្បាស់លាស់ថា ជាការយោងទៅលើបទល្មើសក្នុងស្រុកនៃការរំលោភផ្លូវភេទធ្វើជាឧក្រិដ្ឋកម្មសង្គ្រាម ដោយសារបទប្បញ្ញត្តិប្រឆាំងនឹងការរំលោភផ្លូវភេទនៅកម្រិតអន្តរជាតិ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញពីអត្ថិភាពនៃការរំលោភផ្លូវភេទនេះជាឧក្រិដ្ឋកម្មអន្តរជាតិនោះឡើយ (*សូមមើល* សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១៨២)។

៨០៦.ឧទាហរណ៍របស់សហព្រះរាជអាជ្ញាអំពីការតាក់តែងច្បាប់ក្នុងស្រុក និងយុត្តិសាស្ត្រនោះ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញពីអត្ថិភាពនៃគោលការណ៍ទូទៅនៃច្បាប់ដែលចែងថា បទឧក្រិដ្ឋដែលអ្នកដទៃប្រព្រឹត្តអាចដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវដែលខ្លួនពុំបានប្រព្រឹត្តដោយផ្ទាល់នូវអំពើ*សត្យានុម័ត* បើទោះបីជាបទឧក្រិដ្ឋនេះពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួមក៏ដោយ។ បើទោះបីនេះជាការពិតដែលយុត្តាធិការមួយចំនួនដែលបានបង្ហាញដោយសហព្រះរាជអាជ្ញានោះ ភាគច្រើនជាយុត្តាធិការដែលយកលំនាំតាមទំនៀមទម្លាប់ច្បាប់អង់គ្លេសាក់សុង (common law) ចែងអំពីការដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបណ្ដាលមកពីការអនុវត្តគោលបំណងរួម និងសូម្បីតែបទនេះពុំចាំបាច់ជាផ្នែកនៃគោលបំណងរួមក៏ដោយ[2128]។ ទោះជាយ៉ាងណាក្ដី យោងតាមយុត្តាធិការមួយចំនួននោះទំនងជាបង្ហាញអំពីការកម្រិតដែនកំណត់ចំពោះប្រភេទបទឧក្រិដ្ឋមួយចំនួន (ដូចជាបទមនុស្សឃាតនៅក្នុងសហរដ្ឋអាមេរិក[2129])។ ជាមួយគ្នានេះដែរ មានយុត្តាធិការដទៃទៀតបានកម្រិតការដាក់ឱ្យទទួលខុសត្រូវយ៉ាងខ្លាំង ដូចជា ទាក់ទងទៅនឹងបទឧក្រិដ្ឋជាក់លាក់[2130] ឬពាក់ព័ន្ធទៅនឹងបណ្ដុំប្រតិបត្តិការជាក់លាក់នៃការញុះញង់ ឬការជួយនិងជំរុញបទឧក្រិដ្ឋ[2131]។ នេះទំនងជាបង្ហាញថា យោងតាមយុត្តាធិការទាំងអស់នេះ គោលការណ៍ទូទៅកំណត់ថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជាធម្មតាត្រូវបានកម្រិតត្រឹមតែអំពើ

---

[2128] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥២ ដល់ ៥៣ (ឧទាហរណ៍ដែលបានដកស្រង់ដោយសហព្រះរាជអាជ្ញាចេញពី Australia, Bermuda, Botwsana, Canada, Fiji, Israel, Kenya, Malawi, New Zealand, Nigeria, Papua New Guinea, Seychelles, South Africa, Tanzania, Uganda, United States, Western Samoa និង Zambia ព្រមទាំងឧទាហរណ៍ដកចេញពី Egypt, Iraq and Uruguay ទំនងជាដូចគ្នាទៅនឹងទម្រង់នៃការទទួលខុសត្រូវនៃ)។

[2129] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជើងទំព័រ ១៤១ ឧទាហរណ៍ដកស្រង់ចេញពីរដ្ឋ Texas។

[2130] *សូមមើលឧ.* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជើងទំព័រ ១៧៦ យោងទៅលើមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌបារាំងឆ្នាំ ១៨១០ (ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងអធិរាជ្យ និងឧក្រិដ្ឋកម្មនៃការបះបោរ) និងមាត្រា ៣១៣ (ទាក់ទងទៅនឹងបទមនុស្សឃាត ជាដើម) មាត្រា ២៦៥ ដល់ ២៦៦ (ដែលត្រូវបានដកស្រង់ដោយសហព្រះរាជអាជ្ញានោះ ជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃ“association de malfaiteurs” *ការសមគំនិត* ដូច្នេះ ពុំជាប់ពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវនេះឡើយ)។ ឧទាហរណ៍ដទៃទៀត បានរួមបញ្ចូលទាំងឧទាហរណ៍ដែលសហព្រះរាជអាជ្ញាដកស្រង់ចេញពីប្រទេស បង់ក្លាដេស កម្ពុជា ក្រិច ឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង ថៃឡង់ យូរហ្គាយ និងសហភាពសូវៀត ដែលដោះស្រាយលើបទឧក្រិដ្ឋជាក់លាក់ដែលបានប្រព្រឹត្តឡើងដោយហ្វូងមនុស្សច្រើន ឬបទឧក្រិដ្ឋដែលជាពិសេសសម្រាប់ការផ្ដល់ស្ពានទម្ងន់ទោស (សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៣)។

[2131] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥២ ដល់ ៥៣ ឧទាហរណ៍ដែលបានដកស្រង់ចេញពីប្រទេស បង់ក្លាដេស អ៊ីស្សូភា ហ្គាណា ប៉ាគីស្ថាន និងថៃឡង់។

ផ្ទាល់ខ្លួនរបស់ចារីប៉ុណ្ណោះ។ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវលើអំពើរបស់អ្នកដទៃ លក្ខខណ្ឌជាក់លាក់សម្រាប់ការដាក់ឱ្យទទួលខុសត្រូវ ត្រូវតែកំណត់ដោយច្បាប់ ដូចជា បទឧក្រិដ្ឋនេះបានកើតចេញពីការព្រមព្រៀង ឬគោលបំណងឧក្រិដ្ឋរួម។ គោលការណ៍នេះនឹងផ្ទុយខ្លួនឯង ប្រសិនបើការទទួលខុសត្រូវយ៉ាងទូលំទូលាយដែលសហព្រះរាជអាជ្ញាបានគាំទ្រ ត្រូវយកមកអនុវត្តតាមនោះ។

៨០៧.ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើការរួមចំណែកនៅក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួម នៅក្នុងអំឡុងពេលជាប់ពាក់ព័ន្ធទៅនឹងបទចោទនៅក្នុងរឿងក្តីចំពោះមុខ ត្រូវបានកម្រិតត្រឹមបទឧក្រិដ្ឋដែលជាក់ស្តែងមានរួមបញ្ចូលនៅក្នុងគោលបំណងរួមប៉ុណ្ណោះ។ ដោយផ្អែកតាមសេចក្តីសន្និដ្ឋាននេះ លក្ខណៈវិនិច្ឆ័យសម្រាប់ការសម្រេច ថាតើបទឧក្រិដ្ឋមួយណាដែលមានរួមបញ្ចូលនៅក្នុងគោលបំណងរួមនោះ មានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំងនោះ។ ដូចបានកត់សម្គាល់ខាងលើ យុត្តិសាស្ត្រចាប់តាំងពី *រឿងក្តី Tadić* មក តម្រូវថា គោលបំណងរួម "គឺជា" ឬ"ជាប់ពាក់ព័ន្ធ"ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលបំណងរួម "គឺជា"ការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើការប្រព្រឹត្តបទឧក្រិដ្ឋនោះ គឺជា ឬស្ថិតក្នុងចំណោមគោលដៅចម្បងនៃគោលបំណងរួម។ ជាឧទាហរណ៍ បញ្ហានេះកើតមានក្នុងករណីដែលគោលបំណងរួម គឺចង់សម្លាប់សត្រូវនយោបាយមួយក្រុម។ ក្នុងកាលៈទេសៈនោះ បង្ហាញច្បាស់ណាស់ថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការសម្លាប់នោះ។

៨០៨.ផ្ទុយទៅវិញ គោលបំណងរួមមានការ"ជាប់ពាក់ព័ន្ធ"ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើបទឧក្រិដ្ឋនោះ គឺជា*មធ្យោបាយ*ដើម្បីសម្រេចគោលដៅចុងក្រោយមួយ[2132] (ដែលគោលដៅនេះអាចពុំមែនជាបទល្មើស)។ នៅក្នុងកាលៈទេសៈបែបនេះ ពុំចាំបាច់ថា អ្នកដែលយល់ស្របជាមួយគោលបំណងរួមជាក់ស្តែងត្រូវតែ*មានចេតនា*ចង់ឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលបំណងចុងក្រោយ។ នេះអាចរួមបញ្ចូលបទឧក្រិដ្ឋដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយក្នុងការសម្រេចគោលបំណងរួមណាមួយនោះ បើទោះបីជាការប្រព្រឹត្តពុំមានលក្ខណៈច្បាស់

---

[2132] សាលដីកា*រឿងក្តី Brima* (SCSL) កថាខណ្ឌ ៨០ ("អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការនេះបានសន្និដ្ឋានថា លក្ខខណ្ឌតម្រូវដែលថា ផែនការរួម ការរៀបចំ ឬគោលបំណងនៃសហឧក្រិដ្ឋកម្មរួម គឺជាបទល្មើសនោះ គឺត្រូវតែមានគោលដៅជាបទឧក្រិដ្ឋមួយដូចមានចែងក្នុងលក្ខន្តិកៈ ឬប៉ុនប៉ងប្រព្រឹត្តអំពីបទឧក្រិដ្ឋដែលមានចែងនៅក្នុងលក្ខន្តិកៈយកមកធ្វើជាមធ្យោបាយសម្រេចគោលដៅនោះ")។

លាស់ក៏ដោយ។ ឧទាហរណ៍ ប្រសិនបើក្រុមមួយបានព្រមព្រៀងគ្នាចូលលួចក្នុងផ្ទះមួយ ហើយក្នុងករណីចាំបាច់ត្រូវសម្លាប់មនុស្សប្រសិនបើថៃដន្យមានការតដៃ។ នេះជាការពុំសមស្របទាំងស្រុងក្នុងការសន្និដ្ឋានថា ការធ្វើមនុស្សឃាតជាយថាហេតុនោះពុំមែនរួមបញ្ចូលនៅក្នុងគោលបំណងរួម ដោយសារពុំមានភាពច្បាស់លាស់ថា មានការសម្លាប់មនុស្សនឹងកើតជាក់ស្តែងនៅក្នុងអំឡុងពេលនៃការចូលលួចនោះ។ ផ្ទុយទៅវិញ ក្នុងកាលៈទេសៈនេះ បទមនុស្សឃាត គឺជាធាតុផ្សំនៃផែនការដែលបានគ្រោងទុក បើទោះបីជាសមាជិកនៃក្រុមនោះពុំបានដឹង ថាតើមានការសម្លាប់មនុស្សជាក់ស្តែង ដែរ ឬយ៉ាងណានោះក៏ដោយ។ ដូច្នេះ ប្រសិនបើគោលដៅនៃគោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ និងមានការព្រមព្រៀងគ្នាបន្តសម្រេចគោលដៅនេះដោយពុំគិតពីបញ្ហាពាក់ព័ន្ធនោះ ទើបកំណត់ថា បទឧក្រិដ្ឋទាំងនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ព្រោះបើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏បទឧក្រិដ្ឋនេះត្រូវបានគ្រោងទុកដោយគោលបំណងរួម។ បញ្ហា ថាតើបទឧក្រិដ្ឋមួយមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណានោះ ជាចម្បង គឺជាបញ្ហាអង្គហេតុ ដោយសារពុំមានការព្រមព្រៀងច្បាស់លាស់ ទើបតម្រូវឱ្យធ្វើការវាយតម្លៃដោយពិចារណាលើរាល់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងគោលដៅទូទៅនៃគោលបំណងរួម និងភាវនីយភាពដែលថា គោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ។ អ្វីដែលត្រូវកត់សម្គាល់គឺថា គោលបំណងរួមអាចរួមបញ្ចូលបទឧក្រិដ្ឋដែលចារីពុំមានចេតនាប្រព្រឹត្ត ឬពុំដឹងច្បាស់លាស់ ដោយសារនេះជាការគ្រប់គ្រាន់សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួនដែលចារីបានប្រព្រឹត្តដោយ*ចេតនាប្រយោល* បើទោះបីជាចារីពុំចង់ឱ្យមានការប្រព្រឹត្ត និងពុំដឹងច្បាស់លាស់ថា ការប្រព្រឹត្តនឹងអាចកើតមានក៏ដោយ។

៨០៩.អ្វីដែលស័ក្តិសមនឹងបញ្ជាក់នោះគឺថា នៅគ្រប់កាលៈទេសៈទាំងអស់ដែលបានពិពណ៌នាខាងលើ មានការយល់ស្របគ្នាជាផ្លូវមួយបើទោះបីជាក់ច្បាស់ក្តី ឬប្រយោលក្តី ទាក់ទងទៅនឹងបទឧក្រិដ្ឋរបស់អ្នកដែលបានយល់ស្របជាមួយគោលបំណងរួម។ ដូច្នេះ សមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងជាគោលដៅ ទាំងជាផលវិបាកដែលជៀសមិនរួចនៃគោលបំណងបឋម ឬទាំងគ្មានការអើពើពីយថាហេតុដែលអាចកើតឡើង។ ទាក់ទងទៅនឹងអ្នកដែលយល់ស្របជាមួយនឹងគោលបំណងរួម និងពុំត្រូវបានរំពឹងថា ការប្រព្រឹត្តអំពើ*សត្យានុម័ត*នៃបទឧក្រិដ្ឋផ្ទាល់ ប៉ុន្តែបានផ្អែកលើអ្នកដទៃក្នុងការធ្វើដូច្នោះ នេះអាចត្រូវបានបកស្រាយថា ជាទម្រង់នៃការប្រគល់អំណាចឱ្យចារីផ្ទាល់ក្នុងការសម្រេចទាក់ទងទៅនឹងការអនុវត្តចុងក្រោយនៃអំពើ*សត្យានុម័ត* ដែលនេះដូចគ្នាទៅនឹងគោលគំនិតស្តីពី*ចេតនាប្រយោល*។ ផ្ទុយទៅវិញ ក្នុងករណីដែលបទឧក្រិដ្ឋពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួមដូចការបញ្ជាក់ខាងលើនេះ ការប្រព្រឹត្តបទឧក្រិដ្ឋនេះ គឺជាការ

សម្រេចដោយស្វ័យភាពរបស់ចារីផ្ទាល់ ហើយពុំមានមូលដ្ឋានសម្រាប់ការដាក់ឱ្យអ្នកដទៃទទួលខុសត្រូវឡើយ។

៨១០.សរុបសេចក្តីមក បើទោះបីជាយុត្តិសាស្ត្រដែលបានសង្ខេបខាងលើជានិច្ចកាលពុំបានប្រើប្រាស់ពាក្យពេចន៍ស្របគ្នាក៏ដោយ ក៏នៅតែច្បាស់លាស់គ្រប់គ្រាន់ក្នុងការបង្ហាញថា ជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅក្នុងពេលអនុវត្តគោលបំណងរួម ដែលខ្លួនបានរួមចំណែកក្នុងកម្រិតមួយលើសពីការត្រឹមតែឈរមើល។ អំណះអំណាងរបស់ នួន ជា ដែលថា នេះពុំមែនជាមូលដ្ឋានគ្រប់គ្រាន់ដែលបង្កើតបានជាការទទួលខុសផ្នែកព្រហ្មទណ្ឌនោះ ត្រូវបដិសេធចោល។ ដូច្នេះ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់ការរួមចំណែក ក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួមមានអត្ថិភាពតែក្នុងករណីពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលជាក់ស្តែងមានរួមបញ្ចូលនៅក្នុងគោលបំណងរួមដូចបានពិភាក្សាខាងលើ។ យោងតាមហេតុផលនេះ ដោយយោងទៅលើបទឧក្រិដ្ឋដែលគ្រាន់តែ"បណ្តាល"មកពីការអនុវត្តគោលបំណងរួម អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការប្រើប្រាស់សញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មណ្ឌ ដែលពុំមានអត្ថិភាពទាំងក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តបទល្មើស ទាំងពុំមែនជាគោលការណ៍ទូទៅនៃច្បាប់។ ទោះជាយ៉ាងណាក្តី ដូចបានកំណត់ខាងលើ[2133] ពុំមែនរាល់កំហុសអង្គច្បាប់សុទ្ធតែនាំឱ្យបដិសេធសាលក្រមនៅដំណាក់កាលបណ្តឹងសាទុក្ខនោះឡើយ លើកលែងតែមានកំហុសដែលអាចមោឃៈសាលក្រមបានប៉ុណ្ណោះ ប៉ុន្តែក្នុងករណីកំហុសដែលពុំអាចមោឃៈបាន អង្គជំនុំជម្រះសាលាដំបូងអាចផ្តល់ការយល់ឃើញមួយផ្សេងទាំងស្រុង ឬក្នុងផ្នែកខ្លះ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ការលើកឡើងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះតុលាការកំពូលពុំមាន"យុត្តាធិការបដិសេធការយល់ឃើញពាក់ព័ន្ធនៃអង្គហេតុដែលថា ភស្តុតាងពុំបានបង្ហាញឱ្យហួសពីវិមតិសង្ស័យថា គោលនយោបាយ ប.ក.ក. *ជាប់ពាក់ព័ន្ធទៅនឹង*ការប្រព្រឹត្តបទឧក្រិដ្ឋ" ដូច្នេះ រាល់ការសម្រេចដាក់ពិរុទ្ធភាពទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយផ្អែកលើការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមទម្រង់ I ត្រូវបដិសេធចោល[2134]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងនេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់វិធីសាស្ត្រពុំត្រឹមត្រូវតាមច្បាប់ទាក់ទងទៅនឹងការទទួលខុសត្រូវ។ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញផ្នែកអង្គហេតុដែលគ្មានការបង្ហាញអំពីគោលនយោបាយផ្លាស់ទីលំនៅប្រជាជននោះទេ។ ផ្ទុយទៅ

---

[2133] *សូមមើល*កថាខណ្ឌ ៨៥។

[2134] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០១។

01358437



វិញ អង្គជំនុំជម្រះបានបដិសេធយុត្តិកម្មរបស់ជនជាប់ចោទសម្រាប់ការផ្លាស់ទីលំនៅប្រជាជន។ ដូចគ្នាដែរ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ត្រូវផ្តល់ការយល់ឃើញ*សាឡើងវិញ* ទាក់ទងទៅនឹងបញ្ហា ថាតើគោលបំណងរួមនេះជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ដែរ ឬយ៉ាងណានោះឡើយ[2135]។ បញ្ហាចាំបាច់ គឺបញ្ហាផ្នែកអង្គច្បាប់ដែលអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវសម្រេចដោយផ្អែកលើការយល់ឃើញផ្នែកអង្គហេតុដែលបានបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ នៅក្នុងផ្នែកបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការវាយតម្លៃលើបញ្ហា ថាតើកំហុសអង្គច្បាប់អាចមោឃៈសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែរ ឬយ៉ាងណា ដោយផ្អែកជាចម្បងលើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដោយពិចារណាទៅលើអំណះអំណាងពាក់ព័ន្ធរបស់ជនជាប់ចោទនៅក្នុងបញ្ហានេះ។

### ៤.ង.១.ខ.គោលបំណងរួមជាបទល្មើស

៨១១.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "យ៉ាងយូរបំផុតត្រឹមខែមិថុនា ឆ្នាំ ១៩៧៤ រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ មនុស្សជាច្រើនមានគោលបំណងរួមដើម្បីកសាងបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាម*សន្ទុះមហាលោតផ្លោះមហាអស្ចារ្យ* និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ តាមរយៈមធ្យោបាយចាំបាច់ទាំងអស់"[2136]។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា "មានត្រឹមតែគោលបំណងរួមនេះពុំមានលក្ខណៈឧក្រិដ្ឋគ្រប់គ្រាន់ ឬទាំងស្រុងនោះទេ" ប៉ុន្តែអង្គជំនុំជម្រះបានរំឭកថា ដីកាដំណោះស្រាយ(D427) បានចោទប្រកាន់ថា គោលបំណងរួមនេះត្រូវបានអនុវត្ត"តាមរយៈគោលនយោបាយផ្លាស់ទីលំនៅប្រជាជន [...] និងគោលនយោបាយកំណត់គោលដៅ [...] ដែលធ្វើឱ្យមាន និង/ឬពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម"[2137]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបន្តការពិចារណារបស់ខ្លួនលើបញ្ហា ថាតើគោលនយោបាយទាំងពីរនេះមានអត្ថិភាព ដែរ ឬយ៉ាងណា[2138]។

---

[2135] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០២។

[2136] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧៧។

[2137] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧៨។

[2138] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧៩ ដល់ ៨៣៤។

៨១២.នួន ជា បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលបំណងរួមនេះត្រូវបានអនុវត្តឡើង"តាមរយៈមធ្យោបាយចាំបាច់ទាំងអស់"[2139]។ ដោយយោងទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY នួន ជា បានលើកឡើងថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម តម្រូវឱ្យមានអត្ថិភាពនៃការព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសមួយ និងថា ក្នុងករណីដែលគោលបំណងរួមមិនមានលក្ខណៈជាបទល្មើស ការទទួលខុសត្រូវនេះត្រូវតែបង្ហាញឱ្យឃើញថា ជនជាប់ចោទមានចេតនាអនុវត្តគោលបំណងរួមតាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋមួយ[2140]។ ដោយរំឭកនូវការយល់ឃើញនៅក្នុងសាលដីកា*រឿងក្តី* *Brđanin* (ICTY) នួន ជា បានលើកឡើងថា ខ្លឹមសារ និងវិសាលភាពនៃគោលបំណងឧក្រិដ្ឋត្រូវតែជាក់លាក់ និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបានបញ្ជាក់ថា គោលបំណងរួមត្រូវបានអនុវត្តឡើង"តាមរយៈមធ្យោបាយចាំបាច់ទាំងអស់"តែប៉ុណ្ណោះ ដោយពុំបានគោរពតាមលក្ខខណ្ឌតម្រូវដែលថា ធាតុផ្សំ*សត្យានុម័ត*នៃបទល្មើសត្រូវតែកំណត់ឱ្យបានជាក់លាក់ ដែលតាមការលើកឡើងរបស់គាត់ថានេះជាការដាក់"ការទទួលខុសត្រូវដោយស្វ័យប្រវត្តិមកលើរូបគាត់ចំពោះអំពើល្មើសនានាដែលកើតឡើងក្រោយការចូលរួមរបស់គាត់នៅក្នុងគោលបំណងរួមនោះ ដែលជាសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ III មុនពេលបទដ្ឋានពាក់ព័ន្ធសម្រាប់ធាតុផ្សំ*អត្តនោម័ត*ត្រូវបានកំណត់ទៅទៀត"[2141]។ បន្ថែមលើនេះទៀត នួន ជា បានរំឭកអំពីការកម្រិតទៅលើវិសាលភាពនៃសំណុំរឿង ០០២/០១ និងបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានអត្ថន័យត្រឹមត្រូវតាមអង្គហេតុ ប៉ុន្តែជាការស្តែងឱ្យឃើញពីភាពលម្អៀងរបស់ខ្លួនចំពោះជនជាប់ចោទ[2142] បើទោះបីជាយ៉ាងនេះក្តី នួន ជា បានទទួលស្គាល់ថា "ពិបាកយល់ឱ្យបានច្បាស់លាស់" អំពីឥទ្ធិពលនៃកំហុសនេះទៅលើលទ្ធផលនៃសាលក្រម[2143]។

៨១៣.ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ នួន ជា ពុំបានបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ និងពុំបានលើកឡើងក្នុងដំណាក់កាលមុនការជំនុំជម្រះ ឬក្នុង

---

[2139] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៤។

[2140] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៥។

[2141] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៥ ដល់ ៤៩៦។

[2142] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៧។

[2143] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៨។

កិច្ចដំណើរការនីតិវិធីជំនុំជម្រះឡើយ។ អាស្រ័យហេតុនេះ គប្បីត្រូវបដិសេធចោល[2144]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា នួន ជា និង ខៀវ សំផន ពុំបានលើកអំពី"គោលនយោបាយ *ដាក់លាក់* ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវបានប្រើប្រាស់ដើម្បីសម្រេចគោលបំណងរួម និងបទឧក្រិដ្ឋ*ដាក់លាក់*ដែលជាគោលនយោបាយ ឬជាប់ពាក់ព័ន្ធ" និងបានបញ្ជាក់ថា ជនជាប់ចោទពុំត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយសារតែ"ជាអ្នកបដិវត្តធម្មតា"នោះឡើយ[2145]។

៨១៤.អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនថា ដើម្បីបង្ហាញថា មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គោលបំណងរួមត្រូវតែជាបទល្មើស ក្នុងន័យថា មានលក្ខណៈជា ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ[2146]។ ទាក់ទងទៅនឹងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូង នៅពេលរៀបរាប់អំពីច្បាប់ជាធរមានបានកត់សម្គាល់យ៉ាងត្រឹមត្រូវថា "ប្រាកដជាមានគោលបំណងរួមមួយដែលជាបទឧក្រិដ្ឋ ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ"[2147]។ ស្របនឹងដីកាដំណោះស្រាយ (D427) អង្គជំនុំជម្រះសាលាដំបូងបានកំណត់ការកសាង"បដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាម*សន្ទុះមហាលោតផ្លោះមហាអស្ចារ្យ*" និងការការពារ ប.ក.ក. "ប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ តាមរយៈមធ្យោបាយចាំបាច់ទាំងអស់"[2148]ថា ជាគោលបំណងរួម។ យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា ត្រឹមតែគោលបំណងរួមនេះពុំមានលក្ខណៈឧក្រិដ្ឋ"គ្រប់គ្រាន់ ឬទាំងស្រុងនោះទេ"[2149]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមថា ត្រឹមតែគោលបំណងរួមដែល"ជាការកសាងបដិវត្តន៍សង្គមនិយមក្នុងប្រទេសកម្ពុជា" ពុំមានលក្ខណៈឧក្រិដ្ឋ"គ្រប់គ្រាន់ ឬទាំងស្រុងនោះទេ"[2150]។ ដូច្នេះ ជាការពុំសមស្របដែលចាត់ទុកថា គោលបំណងរួម គឺជាការទទួលខុសត្រូវផ្នែក*ព្រហ្មទណ្ឌ*នោះ។ ដូចគ្នានេះដែរ តាមគំនិតរបស់ខ្លួនផ្ទាល់ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា

---

[2144] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៥។

[2145] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៦។

[2146] *សូមមើលខាងលើ* កថាខណ្ឌ ៧៨៩ *ជាអាទិ៍*។

[2147] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩២ យោងទៅលើសាលក្រម*រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ៥០៨។ សាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ២២៧។

[2148] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧៧។

[2149] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧៨។

[2150] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៤៖ *សូមមើលផងដែរ* កថាខណ្ឌ ៨៣៥៖ "គោលបំណងរួមនេះពុំមានចរិតជាបទល្មើសឡើយ"។

បដិវត្តន៍សង្គមនិយមដែលត្រូវបានអនុវត្តឡើង“តាមរយៈមធ្យោបាយចាំបាច់ទាំងអស់” ពុំអាចជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់កំណត់គោលបំណង*ឧក្រិដ្ឋ*រួមបានឡើយ ដោយសារតែទម្រង់ប្រភេទនេះពុំមានភាពច្បាស់លាស់ត្រង់ ថាតើត្រូវរួមបញ្ចូលការប្រព្រឹត្តបទឧក្រិដ្ឋ ដែរ ឬយ៉ាងណា ហើយប្រសិនបើមាន ការរួមបញ្ចូល ថាតើជាបទឧក្រិដ្ឋណាមួយ។

៨១៥.ទោះជាយ៉ាងណាក្តី ដូចបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា[2151] គោលបំណងរួមនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ (ដូចបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង) ក្នុងការកសាងបដិវត្តន៍សង្គមនិយម ត្រូវតែបានយល់ច្បាស់ក្នុងបរិបទនៃគោលនយោបាយរបស់ ប.ក.ក. ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ ដូចជា គោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជន និងគោលនយោបាយកំណត់គោលដៅទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ផ្អែកតាមអង្គជំនុំជម្រះសាលាដំបូង គោលនយោបាយទាំងនេះត្រូវបានប្រើប្រាស់ក្នុងការជំរុញបដិវត្តន៍សង្គមនិយមឱ្យទទួលបានផ្លែផ្កា និងជាប់ពាក់ព័ន្ធទៅនឹង ឬបណ្តាលឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ[2152]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ច្បាស់លាស់ថា គោលនយោបាយទាំងនេះជាក់ស្តែងគឺជា*ផ្នែកមួយ*នៃគោលបំណងរួមក្នុងន័យច្បាប់ព្រហ្មទណ្ឌក្តី ប៉ុន្តែហាក់បីដូចជាបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងគោលបំណងរួម(ពុំមែនជាបទល្មើស) និងគោលនយោបាយក៏ដោយ ក៏ផ្អែកតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញច្បាស់លាស់ថា គោលនយោបាយដែលមានការជំទាស់នៅពេលជំនុំជម្រះនេះមានទំនាក់ទំនងជាមូលដ្ឋានជាមួយនឹងការកសាងបដិវត្តន៍សង្គមនិយមក្នុងប្រទេសកម្ពុជា។

៨១៦.នៅក្នុងបរិបទនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលបំណងរួមត្រូវបានអនុវត្តតាមរយៈ“មធ្យោបាយចាំបាច់ទាំងអស់”ត្រូវតែយល់ច្បាស់ថា ការផ្លាស់ទីលំនៅប្រជាជន និងគោលនយោបាយកំណត់គោលដៅ គឺជា“មធ្យោបាយនានា”នៅក្នុងរឿងក្តីនេះ។ ដូច្នេះ បើទោះបីជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអាចមានកង្វះភាពជាក់លាក់យ៉ាងណាក៏ដោយ ក៏មានភាពច្បាស់លាស់ដែលថា នៅក្នុងគោលនយោបាយទាំងពីរនេះ ពិតជាមានទិដ្ឋភាពឧក្រិដ្ឋដែលជាស្នូលនៃសំណុំរឿង ០០២/០១ និងមិនត្រឹមតែ“មធ្យោបាយចាំបាច់ទាំងអស់”សម្រាប់កសាងបដិវត្តន៍សង្គមនិយមប៉ុណ្ណោះឡើយ។ ដូច្នេះ ត្រូវបានយល់ថាគោលបំណងរួមក្នុងការកសាងបដិវត្តន៍សង្គមនិយមតាមរយៈគោលនយោបាយទាំងនេះ គឺជាបទឧក្រិដ្ឋពិត

---

[2151] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៦។

[2152] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៤។ *សូមមើលផងដែរ* កថាខណ្ឌ ៨៣៥៖ “គោលនយោបាយដែលខ្មែរក្រហមបានបង្កើតឡើង ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋដែលជាមធ្យោបាយក្នុងការជំរុញឱ្យគោលបំណងរួមទទួលបានផ្លែផ្កា”។

ប្រាកដណាស់។ និយាយម្យ៉ាងទៀត ដោយសារគោលបំណងនេះត្រូវបានសម្រេចតាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋដែលកើតចេញពីគោលនយោបាយ គោលដៅនៃការកសាងបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសកម្ពុជា គឺជាបទឧក្រិដ្ឋពិតប្រាកដមែន។

៨១៧.យោងតាមហេតុផលនេះ បើទោះបីជាការពុំសមស្របដែលការបែងចែករបស់អង្គជំនុំជម្រះសាលាដំបូងនូវភាពខុសគ្នារវាងគោលបំណងរួមដែលខ្លួនបានពិចារណានោះ ពុំអាចជាបទល្មើស និងគោលនយោបាយឧក្រិដ្ឋនោះ បានធ្វើឱ្យមានការភាន់ច្រឡំក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយសារកាលៈទេសៈនៃរឿងក្ដី ដូច្នេះពុំអាចចាត់ទុកជាកំហុសដែលអាចប្ដឹងសាទុក្ខបាន និងអាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខរបស់ នួន ជា ទាក់ទងទៅនឹងបញ្ហានេះ។

### ៤.ង.១.គ.អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន

៨១៨.អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា គោលនយោបាយផ្លាស់ទីលំនៅប្រជាជននេះត្រូវបានអនុម័តជាផ្នែកមួយនៃគោលនយោបាយសេដ្ឋកិច្ចទូទៅ ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាសេដ្ឋកិច្ចបែបកសិកម្ម ដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម[2153]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា ដោយសារលទ្ធផលនៃការផ្លាស់ទីលំនៅប្រជាជន "បណ្ដាញខ្មាំងនឹងត្រូវបំបែក ពិសេស ខ្មាំងដែលបង្កប់ក្នុងចំណោម*ប្រជាជនថ្មី*ដែលត្រូវបានសង្ស័យជាដរាបមក" និង"ការបះបោរ និង/ឬការជ្រៀតជ្រែកពីបរទេសនឹងអាចទប់ស្កាត់បាន"[2154]។ អង្គជំនុំជម្រះសាលាដំបូងបន្តដោះស្រាយយ៉ាងលម្អិតអំពីគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា និងផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត[2155]។

៨១៩.នួន ជា និង ខៀវ សំផន បានលើកអំណះអំណាងមួយចំនួនចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជននោះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយតាមលំដាប់លំដោយ។

---

[2153] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨២ ដល់ ៧៨៣។

[2154] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៤។

[2155] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧៩ ដល់ ៨៣៤។

## ៤.ង.១.គ.១.អត្ថិភាពនៃគោលនយោបាយផ្លាស់ទីលំនៅអ្នកទីក្រុងដោយបង្ខំ និងគោលបំណងនេះ

៨២០.ទាក់ទងទៅនឹងគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាអំពីអាកប្បកិរិយាអមិត្តរបស់ខ្មែរក្រហមចំពោះអ្នកទីក្រុង និងសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំ ប.ក.ក. ដែលបានធ្វើឡើងក្នុងឆ្នាំ ១៩៧៤ និងម្តងទៀតនៅក្នុងខែ កុម្ភៈ និងមេសា ឆ្នាំ ១៩៧៥ ដើម្បីផ្លាស់ទីលំនៅអ្នកទីក្រុងដោយបង្ខំទៅកាន់ទីជនបទក្រោយពេលរំដោះប្រទេសបាន ដោយមិនបានផ្តល់ការផ្គត់ផ្គង់សម្រាប់សុខុមាលភាព និងសុខភាពដល់អ្នកដែលត្រូវបានជម្លៀសនោះឡើយ[2156]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញផងដែរថា មូលហេតុនៃការជម្លៀសត្រូវបានពិភាក្សានៅក្នុងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. និងនៅក្នុងកិច្ចប្រជុំនានា ក្នុងគោលបំណងកំណត់អត្តសញ្ញាណ“ខ្មាំង”ក្នុងចំណោម“ប្រជាជនថ្មី” អប់រំកែប្រែ និងបែងចែកកម្លាំងការងារដោយផ្អែកតាមអាទិភាពសេដ្ឋកិច្ច[2157]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកផងដែរថា អង្គជំនុំជម្រះបានដោះស្រាយ និងបដិសេធរួចហើយចំពោះយុត្តិកម្មដែលបានធ្វើឡើងដោយថ្នាក់ដឹកនាំ ប.ក.ក. ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្ត ជាពិសេសចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនេះ គឺដើម្បីដោះស្រាយកង្វះស្បៀងអាហារ និងដោយសារមានការភ័យខ្លាចការវាយប្រហាររបស់សត្រូវ[2158]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា មានលំនាំនៃការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានាដែលបានចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ ១៩៧២ នៅតាមតំបន់ក្រោមការកាន់កាប់របស់ ប.ក.ក. និងបន្តរហូតដល់ខែ មិថុនា ឆ្នាំ ១៩៧៥[2159]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការជម្លៀសភាគច្រើនបានធ្វើតាមលំនាំដូចគ្នា ដោយការបោកបញ្ឆោត គំរាមកំហែង ប្រើអំពើហិង្សា រួមទាំងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងបានធ្វើឡើង“ដោយស្របតាមផែនការ និងគោលនយោបាយបក្ស”[2160]។

៨២១.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានលំនាំស៊ីសង្វាក់គ្នាចំពោះការផ្លាស់ទីលំនៅប្រជាជនចេញពីក្រុង និងទីរួមខេត្តនានាទៅជនបទ មុនការជម្លៀសនៅទីក្រុង

[2156] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៧៨៧ ដល់ ៧៨៨។

[2157] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៨។

[2158] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៧៨៩ ដល់ ៧៩០។

[2159] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩១ ដល់ ៧៩៣។

[2160] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៤។

ភ្នំពេញ[2161]។ ខៀវ សំផន បានរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជននៅខេត្តក្រចេះ កំពង់ចាម បាណន់ និងឧដុង្គ[2162]ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំ និងបានអះអាងថា ការផ្លាស់ទីលំនៅប្រជាជនទាំងនេះពុំបានបង្ហាញអំពីលំនាំនៃការប្រព្រឹត្តដែលថា ប្រជាជនត្រូវបាន"ជម្លៀសដោយបង្ខំចេញពីទីរួមខេត្ត និងទីប្រជុំជននានាក្រោមការបោកបញ្ឆោត ដោយគ្មានការបារម្ភអំពីសុខុមាលភាព ឬសុខភាពរបស់ប្រជាជន" និងក្នុងគោលបំណងអប់រំកែប្រែពួកគេ[2163]។ ទាក់ទងទៅនឹងការជម្លៀសនៅខេត្តក្រចេះ ខៀវ សំផន បានលើកឡើងថា ការជម្លៀសនេះបានកើតឡើងនៅក្នុងឆ្នាំ ១៩៧៣ បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់អស់រយៈពេលបីឆ្នាំ ដូចនេះពុំអាចប្រៀបធៀបបានជាមួយនឹងការជម្លៀសនៅទីក្រុងភ្នំពេញ ដែលបានកើតឡើងភ្លាមៗបន្ទាប់ពីការដួលរលំទីក្រុងនេះទេ[2164]។ ខៀវ សំផន បានអះអាងផងដែរថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញជាពិសេសថា ការជម្លៀសក្នុងខេត្តក្រចេះបានកើតឡើង"ដោយបង្ខំ" និង"ក្រោមការបោកបញ្ឆោត" និងដោយគ្មានការបារម្ភអំពីសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាជនឡើយ[2165]។ ទាក់ទងទៅនឹងការជម្លៀសនៅក្នុងខេត្តកំពង់ចាម ខៀវ សំផន បានលើកអំណះអំណាងប្រហាក់ប្រហែលគ្នានេះដែរថា សាក្សី និងភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះបានសំអាងទៅលើនោះពុំបានបង្ហាញនូវអ្វីដែលបានកើតឡើងនោះឡើយ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបែរជាបដិសេធដោយពុំត្រឹមត្រូវទៅលើភស្តុតាងរបស់សាក្សី ភី ភួន ដែលបានអះអាងថា ទីក្រុងនេះពុំដែលត្រូវបានជម្លៀសនោះទេ[2166]។ ទាក់ទងទៅនឹងបាណន់ ខៀវ សំផន បានកត់សម្គាល់ឃើញថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើនោះពុំបានបញ្ជាក់ច្បាស់លាស់អំពីលក្ខខណ្ឌនៃការជម្លៀស ហេតុដូច្នេះ ភស្តុតាងនេះពុំសមស្របក្នុងការគាំទ្រដល់ការយល់

---

[2161] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៧ ដល់ ១៨០ អំណះអំណាងនេះបានលើកឡើងច្រំដែលនៅក្នុងកថាខណ្ឌ ២៣២, ២៣៤, ៣៥៣។

[2162] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩១។

[2163] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៧ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៥។

[2164] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៨។

[2165] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៨ ដល់ ១៨១។

[2166] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៨២ ដល់ ១៨៤។

ឃើញរបស់ខ្លួនឡើយ[2167]។ ទាក់ទងទៅនឹងឧដុង្គ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបាន ផ្តល់ទម្ងន់ធ្ងន់ទៅលើការជម្លៀសចេញពីក្រុងនេះ បើទោះបីជាមានភស្តុតាងរូបីយតិចតួចទាក់ទងទៅនឹងអ្វីដែល បានកើតឡើងក៏ដោយ[2168]។ ខៀវ សំផន បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការ ជម្លៀសនៅឧដុង្គបានធ្វើឡើងជាពីរដំណាក់កាល។ នៅដំណាក់កាលទីមួយ មានការចាប់ខ្លួន និងការសួរចម្លើយ ដែលបានធ្វើឡើងមុនពេលផ្លាស់ទីលំនៅប្រជាជន ដែលពុំបង្កើតឱ្យមានលំនាំនៃការប្រព្រឹត្តស៊ីសង្វាក់គ្នាឡើយ [2169]។ លើសពីនេះទៀត ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបាន សំអាងទៅលើសក្ខីកម្មរបស់សាក្សីដែលបានអះអាងថា ប្រជាជននៅឧត្តុង្គបានរត់ចេញពីទីក្រុងនេះដោយសារ តែមានការប្រយុទ្ធគ្នានោះ[2170]។

៨២២.ខៀវ សំផន ក៏បានជំទាស់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើបញ្ហាដែលថា ការផ្លាស់ទី លំនៅប្រជាជននៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ក្នុងគោលបំណងដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងនៃសង្គ្រាម និងថា លក្ខខណ្ឌលំបាករបស់ប្រជាជន គឺបណ្ដា លមកពីជម្លោះប្រដាប់អាវុធនោះ[2171]។ ខៀវ សំផន បានលើកឡើងថា ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសន្និដ្ឋានថា ការផ្លាស់ទីលំនៅប្រជាជនពីដំបូងត្រូវបានធ្វើឡើងដោយសារមូលហេតុដូចគ្នា ទៅនឹងមូលហេតុនៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2172]។ ខៀវ សំផន បានលើកឡើងបន្ថែមថា អង្គ ជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការជម្លៀសទាំងនេះ គឺជាផ្នែកនៃគោលនយោបាយ ឧក្រិដ្ឋ បើទោះបីជាវិធីសាស្ត្រដែលបានប្រើប្រាស់នោះពុំមែនជាបទឧក្រិដ្ឋក៏ដោយ[2173]។

---

[2167] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៨៥ ដល់ ១៨៧ យោងទៅលើទស្សវដ្តី ប.ក.ក.៖ ទង់បដិវត្តន៍ បញ្ហា ពិសេស ឯកសារលេខ E3/25 ខែ ធ្នូ ឆ្នាំ ១៩៧៦ ដល់ ខែ មករា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00063040 ទំព័រ ៤១។

[2168] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៨៨។

[2169] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៨៨។

[2170] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៨៩។

[2171] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៤ ដល់ ១៧៥។ *សូមមើលផងដែរ* កថាខណ្ឌ ២៣៣។

[2172] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៦។

[2173] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣៣ ដល់ ២៣៤។

៨២៣.ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងគោលដៅ និងគោលបំណងនៃការផ្លាស់ទីលំនៅប្រជាជន និងការបង្កើតសហករណ៍មុនឆ្នាំ ១៩៧៥[2174]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការបង្កើតសហករណ៍ គឺដើម្បីហេតុផលមនោគមន៍វិជ្ជាដែលផ្ទុយទៅនឹងគោលបំណងដើម្បីធានា ជាពិសេស ក្នុងការផ្គត់ផ្គង់ស្បៀងអាហារឱ្យបានគ្រប់គ្រាន់ដល់ប្រជាជន[2175]។ ខៀវ សំផន បានអះអាងថា ដោយសារនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ទើបពុំអាចធ្វើសេចក្ដីសន្និដ្ឋានបានថា ថ្នាក់ដឹកនាំបានសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ"ដោយផ្អែកលើបទពិសោធន៍មុនឆ្នាំ ១៩៧៥ និងគោលនយោបាយបង្កើតសហករណ៍ទូទាំងប្រទេស" និងបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងបានទទួលស្គាល់ថា មានហេតុផលផ្សេងៗសម្រាប់ការជម្លៀសនេះ[2176]។

៨២៤.សហព្រះរាជអាជ្ញាបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងជាការសមហេតុផល និងបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងមិនត្រឹមតែទៅលើការជម្លៀសក្នុងខេត្តក្រចេះ កំពង់ចាម បាណន់ និងឧដុង្គប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើការជម្លៀសក្នុងខេត្តបាត់ដំបង ស្វាយរៀង និងព្រៃវែងផងដែរ[2177]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ការសំអាង និងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងទាំងនោះមានលក្ខណៈសមហេតុផល និងជាឆន្ទានុសិទ្ធិ[2178]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកាលៈទេសៈនៃការជម្លៀសប្រជាជននៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រួមមានអត្ថិភាពនៃជម្លោះប្រដាប់អាវុធ កង្វះស្បៀងអាហារ និងការទម្លាក់គ្រាប់បែករបស់អាម៉េរិក ដោយបានយោងទៅលើកថាខណ្ឌមួយចំនួននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[2179]។ ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងសហករណ៍ សហ

---

[2174] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩៦ *ជាអាទិ៍* យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ១០៦, ១១០, ១១៣ ដល់ ១១៦។

[2175] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩៨ ដល់ ២០០។

[2176] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២០១។

[2177] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៧ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩១។

[2178] សារណារតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៨ ដល់ ៣៣៩។

[2179] សារណារតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៥។

ព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងនេះគប្បីត្រូវបានបដិសេធចោលដោយពុំចាំបាច់ពិចារណាបន្តទៀតឡើយ ពីព្រោះពុំមានសក្តានុពលអាចមោឃៈសាលក្រម ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះឡើយ[2180]។

៨២៥.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខុសពីអ្វីដែល ខៀវ សំផន បានអះអាង អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានលំនាំនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដែលបានចាប់ផ្តើមមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2181] ប៉ុន្តែ មិនមែនថា ការផ្លាស់ទីលំនៅប្រជាជនពីមុននោះបានកើតឡើងក្រោមកាលៈទេសៈដូចៗគ្នាទាំងអស់ និងដូចគ្នាទៅនឹង*វិធីសាស្ត្រអនុវត្ត*ក្នុងការជម្លៀសនៅទីក្រុងភ្នំពេញឡើយ។ ហេតុនេះ បញ្ហាពុំមែនត្រង់ ថាតើភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើពាក់ព័ន្ធនៅខេត្តក្រចេះ កំពង់ចាម បាណន់ និងឧត្តុង្គ បានបង្ហាញថា ប្រជាជនត្រូវបានផ្លាស់ទីលំនៅក្រោម“ការបោកបញ្ឆោត” និង “ដោយគ្មានការបារម្ភពីសុខភាព និងសុខុមាលភាព”របស់ប្រជាជនដែលត្រូវបានជម្លៀសនោះ ដែរ ឬយ៉ាងណាឡើយ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ គួរកត់សម្គាល់ថា ការយល់ឃើញដែលរងការជំទាស់នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា “ភាគច្រើននៃការជម្លៀសចេញពីទីរួមខេត្តទាំងនេះ” គឺជាឧទាហរណ៍នៃការផ្លាស់ទីលំនៅដោយបង្ខំក្រោមលក្ខខណ្ឌទាំងនេះ[2182]។ តាមការកត់សម្គាល់របស់សហព្រះរាជអាជ្ញាថា អង្គជំនុំជម្រះសាលាដំបូង បានដោះស្រាយមិនត្រឹមតែទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងចំនួន ៤ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទីកន្លែងដទៃទៀតដែល ខៀវ សំផន ពុំបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខផងដែរ[2183]។ ជាមួយគ្នានេះដែរ ខៀវ សំផន ពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំបានកើតឡើងក្នុងខេត្តក្រចេះ កំពង់ចាម បាណន់ និងឧត្តុង្គ មានកំហុស បើទោះបីជា កាលៈទេសៈដូចគ្នានៃការជម្លៀសទាំងនេះពុំអាចត្រូវបានគេដឹងនោះ។

៨២៦.ទាក់ទងទៅនឹងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មរបស់ ភី ភួន ដែលបានអះអាងថា ខ្មែរក្រហមបានកាន់កាប់ខេត្តកំពង់ចាមតែមួយរយៈខ្លី ដែលពុំអាចធ្វើការជម្លៀសបាននោះ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា ខ្លួនពុំចាត់ទុកសក្ខីកម្មនេះអាចជឿទុកចិត្តបានឡើយបើប្រៀបធៀបជាមួយនឹង

---

[2180] សារណារតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៥។

[2181] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩១។

[2182] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៥។

[2183] សារណារតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៧។

"ការរៀបរាប់យ៉ាងលម្អិតដទៃទៀត អំពីការផ្លាស់ទីលំនៅប្រជាជនក្នុងទីរួមខេត្តនេះ"[2184]។ *ក្នុងចំណោមនោះ* ភស្តុតាងបានបង្ហាញថា ការជម្លៀសបានកើតឡើងនៅពេលដែល"មួយផ្នែកធំ"នៃទីរួមខេត្តត្រូវបានកាន់កាប់ និងថា ការវាយទីរួមខេត្តនេះត្រូវបានធ្វើឡើងជាពីរមុខព្រួញ[2185]។ នេះអាចបញ្ជាក់បានថា ភី ភួន ពុំអាចដឹងអំពីការជម្លៀសនៅក្នុង (ផ្នែកដទៃទៀត)នៃទីរួមខេត្តឡើយ។ ខៀវ សំផន ពុំបានបង្ហាញថា គ្មានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើសេចក្តីសន្និដ្ឋានយ៉ាងដូច្នេះបានឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងនេះត្រូវបដិសេធចោល។

៨២៧.បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយនឹងការជំទាស់របស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញអំពីវិធីសាស្ត្រល្មើសដែលបានប្រើប្រាស់ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានាក្នុងអំឡុងពេលមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2186] ។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងដែលបានពិពណ៌នាអំពីការបំផ្លិចបំផ្លាញផ្ទះសម្បែងដើម្បីរារាំងប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅនោះ មិនឱ្យមានការវិលត្រឡប់មកវិញ និងចរិតលក្ខណៈនៃការផ្លាស់ទីលំនៅដោយបង្ខំ[2187] ដែលជាបទល្មើស និង បានផ្តល់ការយល់ឃើញអំពីបញ្ហានេះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះ។

៨២៨.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា ការផ្លាស់ទីលំនៅប្រជាជនមុនឆ្នាំ ១៩៧៥ ត្រូវបានធ្វើឡើងដោយសារគោលដៅខុសប្លែកគ្នាទាំងស្រុងពីការជម្លៀសប្រជាជននៅទីក្រុងភ្នំពេញ និងជាកំហុសក្នុងការពិចារណាថា ការជម្លៀសនេះ គឺជាផ្នែកមួយនៃលំនាំដូចគ្នានោះឡើយ[2188]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការជម្លៀសប្រជាជនមុនឆ្នាំ ១៩៧៥ ត្រូវបានធ្វើឡើងដោយសារគោលដៅផ្សេងៗ ដូចជា មូលហេតុសេដ្ឋកិច្ច យោធា និងមនោគមន៍វិជ្ជា[2189]។ ពុំមានការបញ្ជាក់ថា ការជម្លៀសប្រជាជននៅទីក្រុងភ្នំពេញត្រូវបានធ្វើឡើងដោយសារមូលហេតុខុសប្លែកពីគេនោះឡើយ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលយល់

[2184] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧។

[2185] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៩៧។

[2186] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣៥។

[2187] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៥, ១០៧។

[2188] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៤ ដល់ ១៧៦, ១៩៦ ដល់ ២០១។

[2189] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៤ ដល់ ១១២, ១១៥។

ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការចាត់ទុកការបង្កើតសហករណ៍ ជាហេតុផលមួយសម្រាប់ការជម្លៀសប្រជាជនឡើយ[2190]។ បើទោះបីជាការត្រឹមត្រូវដែលថា បទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅសហករណ៍ និងការដ្ឋានពុំត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នេះក៏ដោយ ក៏ពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងពុំអាចចាត់ទុកសហករណ៍ជាគោលដៅមួយក្នុងចំណោមគោលដៅមូលដ្ឋានដទៃទៀតនៃការផ្លាស់ទីលំនៅប្រជាជន។ ជាការពិត ទំនងជាបង្ហាញថា ការដាក់ប្រជាជនឱ្យក្លាយជាទាសករ គឺជាគោលដៅមួយក្នុងចំណោមគោលដៅចម្បងនានានៃរបបខ្មែរក្រហមដែលការផ្លាស់ទីលំនៅប្រជាជន គឺជាជំហានដំបូងបង្អស់។

៨២៩.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលចោទប្រកាន់ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយផ្លាស់ទីលំនៅអ្នកទីក្រុង។

## ៤.ង.១.គ.២.អត្ថិភាពនៃគោលនយោបាយចំពោះការផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត

៨៣០.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជនបានរួមបញ្ចូលគោលនយោបាយដែលខ្មែរក្រហម"បានផ្លាស់ទីលំនៅប្រជាជនក្នុងតំបន់ ឬពីតំបន់មួយទៅតំបន់មួយទៀត ដើម្បីបែងចែកកម្លាំងទៅតាមការប៉ាន់ស្មានរបស់ពួកគេ ផ្អែកលើតម្រូវការពលកម្ម និងទិសដៅផលិតកម្ម ព្រមទាំងដើម្បីជំរុញការតស៊ូវណ្ណៈ"[2191]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើសេចក្តីសម្រេចផ្សេងៗរបស់ថ្នាក់ដឹកនាំរបស់បក្សដើម្បីផ្លាស់ទីលំនៅប្រជាជន រួមទាំងសេចក្តីសម្រេចដាក់ចំណាត់ថ្នាក់ប្រជាជនទៅជាប្រភេទផ្សេងៗ ដូចជា"ប្រជាជនពេញសិទ្ធិ" "ប្រជាជនត្រៀម" និង"ប្រជាជនបញ្ញើ"[2192]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ផងដែរថា នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល "កម្មាភិបាល និងលេខាភូមិភាគបានរាយការណ៍ទៅ ប៉ុល ពត នួន ជា វន វ៉េត សុន សេន ឌឿន និង/ឬ មន្ទីរ ៨៧០ អំពីការផ្លាស់ទីលំនៅប្រជាជន ហើយពេលខ្លះបានស្នើសុំការណែនាំបន្ថែមទៀតផង"[2193]។ អង្គជំនុំជម្រះសាលាដំបូងបាន

[2190] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩៧។

[2191] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៥។

[2192] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៧។

[2193] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៨។

វំឭកថា អង្គជំនុំជម្រះបានបដិសេធយុត្តិកម្មសម្រាប់ការផ្លាស់ទីលំនៅប្រជាជន ហើយនៅគ្រប់កាលៈទេសៈទាំងអស់ ការផ្លាស់ទីលំនៅនេះពុំមានលក្ខណៈសមាមាត្រឡើយ[2194] និងបានយល់ឃើញថា យ៉ាងហោចណាស់ចាប់តាំងពីឆ្នាំ ១៩៧២ មក មានលំនាំនៃការផ្លាស់ទីលំនៅប្រជាជនដែលក្នុងពេលនោះ"ប្រជាជនថ្មី"ជាញឹកញាប់ត្រូវបានកំណត់គោលដៅសម្រាប់ការផ្លាស់ទីលំនៅ[2195]។

៨៣១.នួន ជា បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស[2196]។ នួន ជា បានជំទាស់ទៅលើការយល់ឃើញដែលថា មានគោលនយោបាយនៃការជម្លៀសដោយបង្ខំពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត ដោយបានលើកឡើងថា ពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា (i) គោលនយោបាយផ្លាស់ទីលំនៅប្រជាជនត្រូវបានពិពណ៌នាយ៉ាងញឹកញាប់នៅក្នុងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. (ii) គណៈអចិន្ត្រៃយ៍បានសម្រេចផ្លាស់ទីលំនៅប្រជាជននៅក្នុងខែសីហា ឆ្នាំ ១៩៧៥ ដែលក្រោយមកត្រូវបានអះអាងដោយគណៈមជ្ឈិមក្នុងខែកញ្ញា ឆ្នាំ ១៩៧៥ (iii) នួន ជា បានចូលរួមក្នុងការសម្រេចនេះ[2197]។

៨៣២.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស និងបានបំភ្លៃភស្តុតាងក្នុងការយល់ឃើញថា មានលំនាំនៃការផ្លាស់ទីលំនៅប្រជាជននៅមុនពេលឆ្នាំ ១៩៧៥[2198]។ ខៀវ សំផន ក៏បានជំទាស់ផងដែរ[2199]ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើឯកសារដែលចុះកាលបរិច្ឆេទខែ កញ្ញា ឆ្នាំ ១៩៧៥ ដែល*ក្នុងចំណោមនោះ* បានយោងទៅលើផែនការផ្លាស់ទីលំនៅប្រជាជនចំនួន ៥០០.០០០ នាក់ទៅកាន់ភូមិភាគពាយ័ព្យ រួមទាំងតម្រូវការប្រជាជនបន្ថែមនៅក្នុងភូមិភាគឧត្តរ និងបូព៌ា[2200]។ បន្ថែមលើនេះទៀត ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញដែលថា ផែនការសេដ្ឋកិច្ចឆ្នាំ ១៩៧៧ ដែលត្រូវបានអនុម័តក្នុងខែ វិច្ឆិកា ឆ្នាំ

---

[2194] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៩។

[2195] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៨០០ ដល់ ៨០៣។

[2196] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១៤ *ជាអាទិ៍*។

[2197] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១៥។

[2198] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩១ ដល់ ១៩៥។

[2199] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៩ *ជាអាទិ៍*។

[2200] ការក្ដាប់ និងអនុវត្តមាគ៌ានយោបាយ ស្ដារសេដ្ឋកិច្ច និងរៀបចំប្រទេសគ្រប់ផ្នែក ឯកសារលេខ E3/781 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00072397-8 ទំព័រ ៣១ ដល់ ៣២។

១៩៧៦ គឺសម្រាប់"ការបែងចែកប្រជាជនទៅតាមវណ្ណៈរបស់ពួកគេ" និងបានលើកអំណះអំណាងមួយចំនួនពាក់ព័ន្ធទៅនឹងបញ្ហានេះ[2201]។

៨៣៣.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ត្រឹមត្រូវថា មជ្ឈិមបក្ស រួមមាន នួន ជា ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការពិភាក្សា ការបង្កើត និងការអនុវត្តគោលនយោបាយឧក្រិដ្ឋក្នុងការផ្លាស់ទីលំនៅប្រជាជន[2202]តាមរយៈលេខាភូមិភាគ[2203]នៅដើមឆ្នាំ ១៩៧២[2204] ដែលបានអនុវត្តការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពី"ទីក្រុង និងទីរួមខេត្ត និង រវាងតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត" តាមរយៈលក្ខខណ្ឌនៃការរងទុក្ខវេទនា អំពើហិង្សា និងសកម្មភាពគួរឱ្យភ័យខ្លាច[2205] ជាពិសេសទៅលើ"ប្រជាជនថ្មី"[2206] ក្នុងគោលបំណងដើម្បីជំរុញការកសាងបដិវត្តន៍សង្គមនិយម[2207]។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា អំណះអំណាងរបស់ ខៀវ សំផន អំពីការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងពុំគ្រប់គ្រាន់ក្នុងការបង្ហាញពីកំហុសនៅក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ និងពុំបានធ្វើឱ្យសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទៅជាមោឃៈឡើយ ដូច្នេះ គប្បីត្រូវបដិសេធចោល[2208]។ តាមការលើកឡើងរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាដោយត្រឹមត្រូវទៅលើហេតុការណ៍ពិតនៅមុនឆ្នាំ ១៩៧៥ ដែល"បង្កើតជាលំនាំ"នៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន[2209]។

៨៣៤.ទាក់ទងទៅនឹងការជំទាស់របស់ នួន ជា ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. បានពិពណ៌នាអំពីការផ្លាស់ទីលំនៅប្រជាជន ជាការពិតដែលថា សេចក្តីដកស្រង់នៃឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. ដែលបានយោងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង

---

[2201] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦៦ ដល់ ៤៦៩។

[2202] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៨។

[2203] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២៣។

[2204] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៩។

[2205] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៩ ដល់ ៣២០។

[2206] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២០។

[2207] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១៧។

[2208] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៤ ដល់ ៣៤១។

[2209] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៥។

[2210] ពុំបានសំដៅជាក់លាក់ទៅលើការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគដាច់ស្រយាលមួយទៅភូមិភាគដាច់ស្រយាលមួយទៀតនោះទេ ប៉ុន្តែសំដៅលើការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា។ ទោះជាយ៉ាងណាក្តី ការដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត និងពីទីក្រុង និងទីរួមខេត្តទៅកាន់តំបន់ជនបទ គឺជាផ្នែកមួយនៃគោលនយោបាយទូទៅនៃការផ្លាស់ទីលំនៅប្រជាជន ដោយបានសំអាងលើឯកសារបោះពុម្ពផ្សាយទាំងនេះនោះ ការពិតមានភាពសមហេតុផលហើយ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្រោយពីបានរកឃើញថា ឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. មានការនិយាយអំពីការផ្លាស់ទីលំនៅប្រជាជននោះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ជាទូទៅ ឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. នេះ ត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនងគោលនយោបាយបក្ស[2211]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ទៅលើអំណះអំណាងបន្ថែមរបស់ នួន ជា ដែលថា ឯកសារបោះពុម្ពផ្សាយទាំងនេះ ពុំបានលើកឡើងអំពីគោលនយោបាយផ្លាស់ទីលំនៅប្រជាជន ពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត ព្រោះបក្សពុំមានគោលនយោបាយចំពោះបញ្ហានេះឡើយ[2212]។ បញ្ហាត្រឹមតែថា នៅក្នុងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក. ពុំមានសេចក្តីយោងអំពីគោលនយោបាយនោះ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីអត្ថិភាពនៃគោលនយោបាយនេះ ជាការពុំសមហេតុផលនោះឡើយ។

៨៣៥.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា អំពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងខែសីហា ឆ្នាំ ១៩៧៥ ដែលបានបង្ហាញតាមរយៈរបាយការណ៍នៃដំណើរទស្សនកិច្ចសិក្សាមួយ និងតាមរយៈការចូលរួមរបស់ នួន ជា នៅក្នុងការធ្វើសេចក្តីសម្រេចនេះ និងបើទោះបីជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា នួន ជា បានចូលរួមនៅក្នុងដំណើរទស្សនកិច្ចសិក្សារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក៏ដោយ[2213] ក៏អង្គជំនុំជម្រះតុលាការកំពូល

---

[2210] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧៧។

[2211] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧៧។

[2212] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១៦ ដល់ ៥១៧។

[2213] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២០។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤៥ ដល់ ៧៤៦។

យល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា អំណះអំណាងនេះគ្មានមូលដ្ឋានគាំទ្រឡើយ[2214]។ អង្គជំនុំជម្រះសាលាដំបូងពុំបានសន្និដ្ឋានថា នួន ជា បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចដោយផ្អែកលើដំណើរទស្សនកិច្ចសិក្សានេះឡើយ ប៉ុន្តែបានសំអាងទៅលើតួនាទីជាទូទៅរបស់គាត់នៅក្នុង ប.ក.ក.[2215]។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ការសម្រេចនេះត្រូវបានធ្វើឡើងជាក់លាក់នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចសិក្សានោះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើរបាយការណ៍នៃដំណើរទស្សនកិច្ចសិក្សានេះ ធ្វើជាភស្តុតាងមួយក្នុងចំណោមភស្តុតាងទាំងនោះដែលអង្គជំនុំជម្រះបានសំអាងទៅលើក្នុងការធ្វើសេចក្តីសន្និដ្ឋានថា សេចក្តីសម្រេចបានធ្វើឡើងនោះ[2216]។

៨៣៦.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា នៅក្នុងកិច្ចប្រជុំខែកញ្ញា ឆ្នាំ ១៩៧៥ គណៈមជ្ឈិមបានអះអាងអំពីសេចក្តីសម្រេចផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត[2217]នោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ដូចការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញាថា[2218] អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញបែបនេះឡើយ ប៉ុន្តែគ្រាន់តែបានយល់ឃើញថា "គោលនយោបាយសេដ្ឋកិច្ច"ត្រូវបានពិភាក្សានៅពេលប្រជុំនោះ[2219]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ នួន ជា ត្រូវបដិសេធចោល។

៨៣៧.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងអត្ថិភាពនៃលំនាំនៃការផ្លាស់ទីលំនៅប្រជាជនចាប់តាំងពីឆ្នាំ ១៩៧២ រហូតមក[2220] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការប្រើប្រាស់ពាក្យពេចន៍ "ប្រជាជនថ្មី"របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជននៅមុនឆ្នាំ ១៩៧៥ បានធ្វើឱ្យភាន់ច្រឡំខ្លះៗ ដោយសារពាក្យនេះត្រូវបានប្រើប្រាស់ក្រោយការជួលរលំទីក្រុងភ្នំពេញតែប៉ុណ្ណោះ[2221]

---

[2214] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣១។

[2215] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤៦។

[2216] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤៥ និងកថាខណ្ឌ ៧៩៥ *ជាអាទិ៍* និងជើងទំព័រភ្ជាប់ជាមួយ។

[2217] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១៨។

[2218] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣០។

[2219] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤៩ ដល់ ៧៥១។

[2220] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩១ ដល់ ១៩៤។

[2221] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩១។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០០ ដល់ ៨០៣។

01358453



។ ទោះជាយ៉ាងនេះក្តី ការយោងទៅលើពាក្យ"ប្រជាជនថ្មី" មាននៅក្នុងកថាខណ្ឌមួយក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានសង្ខេបការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងអំឡុងពេលទាំងនៅមុន និងក្រោយការជួលរលំទីក្រុងភ្នំពេញ ដោយបានរួមបញ្ចូលអំឡុងពេលដែលពាក្យ"ប្រជាជនថ្មី"ត្រូវបានប្រើប្រាស់[2222]។ អាស្រ័យហេតុនេះ ក្រៅតែពីពាក្យពេចន៍ពុំច្បាស់លាស់ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ទាក់ទងទៅនឹងអំណះអំណាងដទៃទៀតរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីលំនាំមុនឆ្នាំ ១៩៧៥ ចំពោះការផ្លាស់ទីលំនៅប្រជាជន[2223] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងទាំងនោះបានផ្អែកយ៉ាងច្រើនទៅលើការបកស្រាយពុំត្រឹមត្រូវលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ជាសំខាន់ អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា លំនាំច្បាស់លាស់មានអត្ថិភាពនៅក្នុងអំឡុងពេលមុនខែមេសា ឆ្នាំ ១៩៧៥ នោះទេ អង្គជំនុំជម្រះបានយល់ឃើញថា លំនាំនេះបានលេចចេញជារូបរាង"នៅក្នុងអំឡុងពេលនៃការជម្លៀសទាំងនេះ"ដែលរួមបញ្ចូលអំឡុងពេលក្រោយឆ្នាំ ១៩៧៥[2224]។ យោងតាមហេតុផលដូចគ្នា ផ្ទុយពីការលើកឡើងរបស់ ខៀវ សំផន[2225] អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសផងដែរ ក្នុងការសំអាងទៅលើភស្តុតាងពាក់ព័ន្ធទៅនឹងអំឡុងពេលមុនឆ្នាំ ១៩៧៥ ដែលពុំបានបង្ហាញអំពីលំនាំច្បាស់លាស់នៃការផ្លាស់ទីលំនៅពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសន្និដ្ឋានថា មានការបន្តនៃលំនាំ ដោយពុំបានពិចារណាលើបរិបទនៃជម្លោះប្រដាប់អាវុធក្នុងអំឡុងពេលមុនឆ្នាំ ១៩៧៥[2226]។ ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា មានការបន្តលំនាំនោះឡើយ ប៉ុន្តែបានយល់ឃើញថា លំនាំនេះបាន"លេចជារូបរាងឡើង"ពេលក្រោយមកទៀត។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រឡើយ។

---

[2222] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។

[2223] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩២ ដល់ ១៩៤។

[2224] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៣។

[2225] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩២ ដល់ ១៩៤។

[2226] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩៤។

៨៣៨.ចំពោះអំណះអំណាងទាក់ទងទៅនឹងឯកសារចុះកាលបរិច្ឆេទខែកញ្ញា ឆ្នាំ ១៩៧៥[2227] អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើឯកសារនេះ និងភស្តុតាងមួយចំនួនដទៃទៀត និងបានសន្និដ្ឋានថា "មានកិច្ចប្រជុំមួយរបស់ថ្នាក់ដឹកនាំបក្សនៅដើមខែកញ្ញា ឆ្នាំ ១៩៧៥ ពាក់ព័ន្ធទៅនឹងគោលនយោបាយសេដ្ឋកិច្ចដែលក្រោយមកត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឯកសារគោលនយោបាយខែកញ្ញា ឆ្នាំ ១៩៧៥"[2228]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះមិនអាចធ្វើសេចក្តីសន្និដ្ឋានបែបនេះ ដែលជាការ"មិនបានរំលោភលើគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*"នោះឡើយ[2229] និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងដោយសមហេតុផលទៅលើភស្តុតាងដែលខ្លួនបានយោងទៅលើនោះឡើយ[2230] និងបានលើកឡើងថា ដោយសារតែ "ប្រភព និងអ្នកនិពន្ធនៃឯកសារគោលនយោបាយឆ្នាំ ១៩៧៥"ពុំអាចត្រូវបានគេស្គាល់ ទើបឯកសារនេះគប្បីត្រូវបានដកចេញពីសំណុំរឿង[2231]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា រាល់ការយល់ឃើញផ្នែកអង្គហេតុដែលពាក់ព័ន្ធគប្បីត្រូវបដិសេធចោល រួមទាំងការយល់ឃើញអំពីការជាប់ពាក់ព័ន្ធរបស់ ខៀវ សំផន ទៅនឹងគោលនយោបាយនេះផងដែរ[2232]។

៨៣៩.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងរបស់ ខៀវ សំផន បានលើកបញ្ហាចំនួន ២ បញ្ហាទីមួយ ថាតើឯកសារដែលចុះកាលបរិច្ឆេទខែកញ្ញា ឆ្នាំ ១៩៧៥ គប្បីត្រូវបានទទួលយកជាភស្តុតាងដែរ ឬយ៉ាងណា។ បញ្ហាទីពីរ ថាតើការយល់ឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅដើមខែកញ្ញា ឆ្នាំ ១៩៧៥ មានលក្ខណៈពុំសមហេតុផល ដែរ ឬយ៉ាងណា។ ទាក់ទងទៅនឹងបញ្ហាទីមួយ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា យោងតាមវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងដែលជាវិធានទូទៅបានចែងថា "ភស្តុតាងអាចជូនបានដោយសេរី"។ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងបានបញ្ជាក់ពីមូលដ្ឋានសំអាងណាមួយដែលអង្គជំនុំជម្រះអាចបដិសេធសំណើសុំពិនិត្យភស្តុតាង។ ខៀវ សំផន ពុំបានលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហានេះឡើយ។ គាត់គ្រាន់តែលើកឡើងថា ឯកសារ"ពុំមានតម្លៃជាភស្តុតាង"ដោយសារ

---

[2227] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៩ *ជាដើម*។

[2228] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៥៩។

[2229] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥៩។

[2230] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦០។

[2231] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦៥។

[2232] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦៥។

តែអ្នកនិពន្ធ និងប្រភពនៃឯកសារនេះពុំត្រូវបានគេស្គាល់[2233]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងនេះឡើយ។ បើទោះបីជាតម្លៃនៃភស្តុតាងជាឯកសារនេះ ទំនងជាមានតិចតួចដោយសារតែអ្នកនិពន្ធ និងប្រភពដើមពុំត្រូវបានគេស្គាល់យ៉ាងណាក៏ដោយ ក៏ពុំមែនមានន័យថា ឯកសារនេះពុំអាចទទួលយកធ្វើជាភស្តុតាងបាននោះឡើយ។

៨៤០.ទាក់ទងទៅនឹងបញ្ហាទីពីរដែល ខៀវ សំផន បានលើកឡើងនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ក្នុងការយល់ឃើញទាក់ទងទៅនឹងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំបក្សនៅដើមខែកញ្ញា ឆ្នាំ ១៩៧៥ ស្តីអំពីគោលនយោបាយសេដ្ឋកិច្ច អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងមួយចំនួន ប៉ុន្តែក្នុងចំណោមនោះ មានភស្តុតាងមួយជាឯកសារបានចុះកាលបរិច្ឆេទខែកញ្ញា ឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះក៏បានសំអាងលើចម្លើយរបស់ ខៀវ សំផន ផងដែរពាក់ព័ន្ធទៅនឹងគោលបំណងទូទៅរបស់គណៈមជ្ឈិម ចម្លើយរបស់ អៀង សារី ទាក់ទងទៅនឹងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំបក្សក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ ភស្តុតាងរបស់ Philip SHORT ទាក់ទងទៅនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិមក្នុង "ពាក់កណ្តាលខែ កញ្ញា" សេចក្តីយោងនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ស្តីពីសេចក្តីសម្រេចរបស់"សមាជមជ្ឈិមបក្ស"ដែលបានធ្វើឡើងមុនខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ទាក់ទងទៅនឹងគោលដៅកំណត់ទិន្នផលស្រូវ រួមទាំងសក្ខីកម្មរបស់ David CHANDLER ទាក់ទងទៅនឹងផែនការសេដ្ឋកិច្ចទូទៅដែល"លេចចេញជារូបរាងនៅចុងឆ្នាំ ១៩៧៥"[2234]។ ខៀវ សំផន បានចង្អុលបង្ហាញអំពីភាពកម្សោយ និងភាពមិនស៊ីសង្វាក់គ្នាទាក់ទងទៅនឹងភស្តុតាងនីមួយៗនោះ[2235]។

៨៤១.បើទោះបីជាការត្រឹមត្រូវដែលថា មានភាពពុំស៊ីសង្វាក់គ្នាក្នុងចំណោមភស្តុតាងដែលអង្គជំនុំជម្រះបានសំអាងទៅលើនោះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាពុំឃើញថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈពុំសមហេតុផល ឬរំលោភបំពានលើគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*នោះឡើយ។ គោលការណ៍នេះពុំអនុវត្តដោយផ្អែកទៅលើកម្រិតនៃភស្តុតាងនីមួយៗឡើយ ដែលមានន័យថា ភស្តុតាងនីមួយៗគប្បីត្រូវបកស្រាយថា មានកម្រិតដាក់បន្ទុកតិចតួចបំផុត។ ផ្ទុយទៅវិញ តុលាការអង្គហេតុគប្បីពិចារណា ថាតើនៅពេលវាយតម្លៃនៃភស្តុតាងនោះ ជារួមមានលក្ខណៈគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការយល់ឃើញឱ្យហួសពីវិមតិសង្ស័យ ដែរ ឬយ៉ាងណា។ ភស្តុតាងនីមួយៗអាចបំពេញគ្នា

---

[2233] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦៥ ជើងទំព័រ ១០០៨។

[2234] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤៩ និងជើងទំព័រនៅទីនោះ។

[2235] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦១ ដល់ ៤៦៤។

ទៅវិញទៅមក និងនាំឱ្យតុលាការអង្គហេតុអាចធ្វើសេចក្តីសន្និដ្ឋានបានថា លក្ខខណ្ឌតម្រូវមួយត្រូវបានបំពេញ។ លើកលែងតែក្នុងករណីដែលផ្អែកលើការវាយតម្លៃភស្តុតាងជារួមរួចហើយ នៅតែមានវិមតិសង្ស័យទៀត នោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវថា តុលាការអង្គហេតុពុំអាចផ្តល់ការយល់ឃើញមួយដែលធ្វើឱ្យប៉ះពាល់ដល់ជនជាប់ចោទឡើយ។

៨៤២.អង្គជំនុំជម្រះតុលាការកំពូលពិចារណាពុំឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើភស្តុតាងជារួម មានលក្ខណៈពុំសមហេតុផលនោះឡើយ។ ជាពិសេស ទោះបីមានភាពមិនស៊ីសង្វាក់គ្នាខ្លះក៏ដោយ ក៏តុលាការអង្គហេតុសមហេតុផលអាចផ្តល់ការយល់ឃើញទាំងនេះបានដែរ។ ជាឧទាហរណ៍ ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អៀង សារី បានបដិសេធជាក់លាក់ថា ការផ្លាស់ទីលំនៅប្រជាជនត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំកាលពីខែ កញ្ញា ឆ្នាំ ១៩៧៥[2236] ដែលទំនងជា អៀង សារី បានសំដៅទៅលើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[2237]។ ដូចគ្នានេះដែរ ហេតុការណ៍ពិតដែល Philip SHORT សំដៅទៅលើការប្រជុំនៅពាក់កណ្តាលខែ កញ្ញា មិនមែននៅដើមខែ កញ្ញា[2238] ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់យ៉ាងច្បាស់លាស់នោះ ពុំបានធ្វើឱ្យការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនេះមានលក្ខណៈពុំសមហេតុផលឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន។

៨៤៣.ខៀវ សំផន ក៏បានជំទាស់ផងដែរទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ផែនការសេដ្ឋកិច្ចសម្រាប់ឆ្នាំ ១៩៧៧ បានកំណត់*ក្នុងចំណោមនោះ*សម្រាប់“ការបែងចែកប្រជាជនទៅតាមវណ្ណៈរបស់ពួកគេ” និងបានអះអាងថា ភស្តុតាងដែលបានដកស្រង់នោះពុំមានមូលដ្ឋានគាំទ្រដល់ការយល់ឃើញបែប

---

[2236] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦១។

[2237] *សូមមើល* កិច្ចសម្ភាសន៍របស់ Stephen HEDER ជាមួយនឹង អៀង សារី ឯកសារលេខ E3/89 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ERN(ភាសាខ្មែរ) 00062457 ទំព័រ ៦ (ចម្លើយពេញលេញទៅនឹងសំណួររបស់ Stephen HEDER លើបញ្ហា ថាតើផែនការផ្លាស់ទីលំនៅប្រជាជនទៅកាន់ភូមិភាគផ្សេងៗ ត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា មានដូចតទៅៈ “បើទោះបីជាពុំមានការពិភាក្សានៅក្នុងការប្រជុំនោះក៏ដោយ *ក៏បញ្ហានៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានសម្រេចតាំងដំបូងមកម្ល៉េះ*។ នោះបើផ្អែកតាមអ្វីដែលគេប្រាប់ខ្ញុំ”)(សេចក្តីបញ្ជាក់បន្ថែម)។ កិច្ចសម្ភាសន៍នេះពុំបានបន្តលើបញ្ហានេះបន្ថែមទៀតឡើយ។

[2238] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦២។

នេះឡើយ[2239]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងនេះ ពុំបានផ្ដល់មូលដ្ឋានគាំទ្រគ្រប់គ្រាន់ ពីព្រោះការយល់ឃើញពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងនេះ បានយោងទៅលើផ្នែកដទៃទៀតនៃសាលក្រមរបស់ខ្លួន រួមមានកថាខណ្ឌទីមួយនៃផ្នែកស្ដីពី“*ការបែងចែកសមាសភាពឲ្យបានច្បាស់លាស់* (ឆ្នាំ ១៩៧៧)”[2240]ដោយបានផ្អែកលើភស្ដុតាងមួយចំនួន។ ខៀវ សំផន ពុំបានពន្យល់ពីមូលហេតុដែលថា ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្ដុតាងនេះមានលក្ខណៈពុំសមហេតុផលនោះឡើយ។ ផ្ទុយទៅវិញ ខៀវ សំផន បានផ្ដោតទៅលើការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើទស្សនាវដ្ដី*ទង់បដិវត្តន៍* ឆ្នាំ ១៩៧៦ ដែលរៀបរាប់អំពីផែនការសេដ្ឋកិច្ចឆ្នាំ ១៩៧៧ ដោយពុំបានយោងជាក់លាក់ទៅលើការបែងចែកប្រជាជនតាមវណ្ណៈរបស់ពួកគេ[2241]។ ទោះជាយ៉ាងណាក្ដី *ទស្សនាវដ្ដីទង់បដិវត្តន៍* មានការយោងមួយចំនួនទៅលើការតស៊ូវណ្ណៈ និងអ្នកប្រឆាំងនឹងបដិវត្តន៍ និងអំពីបញ្ហារបបអាហារដែលប្រជាជនត្រូវទទួលបានតាមការបែងចែកនោះ[2242]។ សរុបសេចក្ដីមក ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា ជាការមិនសមហេតុផលនោះឡើយ។ បន្ថែមលើនេះទៀត តាមការកត់សម្គាល់របស់សហព្រះរាជអាជ្ញាឃើញថា[2243] ខៀវ សំផន ពុំបានផ្ដល់មូលដ្ឋានគាំទ្រច្បាស់លាស់ចំពោះផលប៉ះពាល់ទៅលើការសម្រេចដាក់ពិរុទ្ធភាពដែលកើតឡើងដោយសារកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ។ អំណះអំណាងបន្ថែមរបស់ ខៀវ សំផន ទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើចម្លើយជាលាយលក្ខណ៍អក្សរត្រូវបានដោះស្រាយរួចហើយនៅក្នុងសាលដីកានេះ[2244]។

---

[2239] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦៦ ដល់ ៤៦៧ យោងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងកថាខណ្ឌ ១០២៦។

[2240] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៦២១ ដល់ ៦២៣។

[2241] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៦៧ យោងទៅលើទស្សនាវដ្ដី ប.ក.ក.៖ *ទង់បដិវត្តន៍* ឯកសារបញ្ហាទី ១១ ឯកសារលេខ E3/139 ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00064960 ទំព័រ ៣។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើឯកសារនេះក្នុងសាលក្រម កថាខណ្ឌ ៧៧០ ជើងទំព័រ ២៤៣០។

[2242] ទស្សនាវដ្ដី ប.ក.ក.៖ *ទង់បដិវត្តន៍* បញ្ហាទី ១១ ឯកសារលេខ E3/139 ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00064966 ទំព័រ ៩, ERN (ភាសាខ្មែរ) 00064967 ទំព័រ ១០, ERN (ភាសាខ្មែរ) 00064973-4 ទំព័រ ១៦ ដល់ ១៧, ERN (ភាសាខ្មែរ) 00064982-3 ទំព័រ ២៥ ដល់ ២៦។

[2243] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៤។

[2244] *សូមមើល* កថាខណ្ឌ ២៤០ *ជាអាទិ៍*។

៨៤៤.ជាការសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ជនជាប់ចោទទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង អំពីគោលនយោបាយផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត។

## ៤.ង.១.គ.៣.ឧក្រិដ្ឋកម្មដែលមានរួមបញ្ចូលនៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ

៨៤៥.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា បទឧក្រិដ្ឋនានានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានដូចជា បទមនុស្សឃាត បទសម្លាប់រង្គាល បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ រួមទាំងបទអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានប្រព្រឹត្តឡើង[2245]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា គោលនយោបាយផ្លាស់ទីលំនៅប្រជាជន"បានបណ្តាលឱ្យមាន និង/ឬជាប់ពាក់ព័ន្ធទៅនឹង"ការប្រព្រឹត្តបទឧក្រិដ្ឋ មានដូចជា"ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ"[2246]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានយល់ឃើញថា ដីកាដំណោះស្រាយ (D427) ពុំបានដាក់បញ្ចូលនូវការទទួលខុសត្រូវចំពោះបទសម្លាប់រង្គាលក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមឡើយ ហេតុដូចនេះទើបពុំបានពិចារណាលើការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវនេះ[2247]។ នៅគ្រប់កាលៈទេសៈទាំងអស់ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា ពុំមានការសម្រេចដាក់ពិរុទ្ធភាពដាច់ដោយឡែកណាមួយត្រូវបានធ្វើឡើងទាក់ទងទៅនឹងការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តី

---

[2245] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥២, ៥៥៩, ៥៦២, ៥៦៥ និង ៥៧៤។

[2246] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៤។

[2247] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨០។

ថ្លៃថ្នូររបស់មនុស្សជាតិ ដោយហេតុថា អំពើទាំងនេះពុំមែនជាបទឧក្រិដ្ឋដាច់ដោយឡែកពីគ្នានោះទេ ប៉ុន្តែបានស្ថិតក្រោម"អំពើអមនុស្សធម៌ផ្សេងៗទៀត"នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2248]។

៨៤៦.ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ នួន ជា បានទទួលស្គាល់ថា គាត់បានឯកភាពចំពោះការជម្លៀសចេញពីទីក្រុងភ្នំពេញ ប៉ុន្តែបានបដិសេធថា ការឯកភាពនេះមិនមែនមានន័យថា មានអំពើ"ដែលជា ជាប់ពាក់ព័ន្ធ ឬរួមបញ្ចូលការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញ ឬអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ"[2249]នោះឡើយ។ នួន ជា បានលើកឡើងថា ពុំមានភស្តុតាងបង្ហាញថា ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងខែ មេសា ឆ្នាំ ១៩៧៥ ស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្រោយពេលដួលរលំនោះ មានជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មណាមួយឡើយ ដែលផ្អែកតាមទស្សនៈរបស់គាត់បានពន្យល់ ថាតើមានមូលហេតុអ្វីបានជាអង្គជំនុំជម្រះបានយល់ឃើញថា ការសម្រេចបែបនេះ"បណ្តាលឱ្យមាន និង/ឬជាប់ពាក់ព័ន្ធទៅនឹង"ការប្រព្រឹត្តបទឧក្រិដ្ឋនោះ[2250]។ នួន ជា បានរំឭកថា គាត់បានតវ៉ានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានប្រព្រឹត្តឡើងក្រោមសិទ្ធិអំណាចរបស់មេដឹកនាំភូមិភាគ ប៉ុន្តែពុំស្ថិតក្រោមមជ្ឈិមបក្សឡើយ និងបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានបដិសេធអំណះអំណាងនេះ ដោយបានយល់ឃើញថា មេដឹកនាំភូមិភាគបានត្រឹមតែ"អនុវត្ត"សេចក្តីណែនាំរបស់មជ្ឈិមបក្សប៉ុណ្ណោះ[2251]។ តាមទស្សនៈរបស់គាត់ ការយល់ឃើញនេះផ្ទុយគ្នាទាំងស្រុងទៅនឹងការយល់ឃើញដទៃទៀតរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា យ៉ាងហោចណាស់ មានមេដឹកនាំភូមិភាគមួយចំនួនបានចូលរួមក្នុងការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍[2252]។ នួន ជា បានលើកឡើងថា មជ្ឈិមបក្ស និងមេដឹកនាំភូមិភាគបានឯកភាពគ្នាត្រឹមតែការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញប៉ុណ្ណោះ និងថា ការណែនាំដទៃៗទៀតទាក់ទងទៅនឹងបញ្ហា ថាតើត្រូវអនុវត្តការព្រមព្រៀងនេះបែបណានោះ គឺចេញពីថ្នាក់ភូមិភាគដែលមជ្ឈិមបក្សមានអំណាចគ្រប់គ្រងក្នុងកម្រិតតិចតួចប៉ុណ្ណោះ ហើយ

---

[2248] *សូមមើលខាងលើ* កថាខណ្ឌ ៥៨៩ *ជាអាទិ៍*។

[2249] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៣។

[2250] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៤។

[2251] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៥។

[2252] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៥។

ដែលនៅក្នុងខែមេសា ឆ្នាំ ១៩៧៥ បានធ្វើការតស៊ូដណ្តើមអំណាចជាមួយមជ្ឈិមបក្ស[2253]។ ទាក់ទងទៅនឹងបញ្ហានេះ នួន ជា បានរំឭកថា ហេង សំរិន ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនកោះហៅនោះ បានបញ្ជាក់ក្នុងកិច្ចសម្ភាសន៍ជាមួយ Ben KIERNAN ថា កើតមានជម្លោះរវាងភូមិភាគ និងភូមិភាគចាប់តាំងពីឆ្នាំ ១៩៧៣ មកម្ល៉េះ។ នួន ជា បានអះអាងថា "ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចសន្និដ្ឋានបានថា កងទ័ពទាំងអស់ដែលបានប្រឈមមុខដាក់គ្នាយ៉ាងសកម្ម និងបានរាយការណ៍ទៅសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដែលតំណាងឱ្យក្រុមដែលប្រជែងជាមួយគ្នានៅក្នុងបក្ស អាចធ្វើសកម្មភាពតាមការណែនាំលម្អិត (ដែលមិនមានភស្តុតាងសោះ) ពីប៉ុល ពត ឬ នួន ជា នោះទេ"[2254]។

៨៤៧.ទាក់ទងទៅនឹងបទមនុស្សឃាត នួន ជា បានអះអាងថា កាលៈទេសៈប្រហាក់ប្រហែលគ្នាទៅនឹងសម្មតិកម្មដែលបានពិពណ៌នានៅក្នុងសាលដីការ*រឿងក្តី Tadić* ដែលថា ត្រឹមតែអាចយល់ដឹងជាមុនថា អំពើមនុស្សឃាតនឹងកើតមានប៉ុណ្ណោះ ប៉ុន្តែពុំមែនជាផ្នែកមួយនៃការព្រមព្រៀងក្នុងចំណោមសមាជិកនៃសហឧក្រិដ្ឋកម្មរួមឡើយ។ អាស្រ័យហេតុនេះ បទឧក្រិដ្ឋនេះអាចត្រឹមតែជាការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ III ប៉ុណ្ណោះ[2255]។ នួន ជា ក៏បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះដែលថា ការផ្លាស់ទីលំនៅប្រជាជនបានធ្វើតាមលំនាំនៃការប្រព្រឹត្ត និងត្រូវបានអនុវត្តឡើង"តាមរយៈគ្រប់មធ្យោបាយ" ហើយបានចោទប្រកាន់ថា មានកំហុសអង្គហេតុទាក់ទងទៅនឹងបញ្ហានេះ[2256]។ ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញ នួន ជា បានអះអាងថា ពុំមានភស្តុតាងបង្ហាញឱ្យឃើញពីគោលបំណងរួមដែលបានជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនេះឡើយ ដោយបានរំឭកនូវអំណះអំណាងនានាពីខាងដើម[2257]។ នៅក្នុងសារណា នួន ជា បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរងទុក្ខវេទនាដែលកើតមានក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងគោលបំណងដើម្បីអប់រំ"ប្រជាជនថ្មី"នោះ គឺជាការ"មិនសមហេតុផល" និង

---

[2253] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៦។

[2254] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៧។

[2255] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៨។

[2256] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥០៩ ដល់ ៥១១។

[2257] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១២។

ថា ប្រព្រឹត្តកម្មទៅលើ“ប្រជាជនថ្មី” ក៏ដូចគ្នាទៅលើ“ប្រជាជនមូលដ្ឋាន”នៅក្នុងសហករណ៍នោះពុំចាត់ទុកជាការរើសអើងឡើយ[2258]។

៨៤៨.សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងដែលដោះបន្ទុក នួន ជា ហើយដាក់បន្ទុកទៅលើលេខាភូមិភាគថា ជាអ្នកអនុវត្តផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការពុំត្រឹមត្រូវឡើយ ដោយសារលេខាភូមិភាគ គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម[2259]។ សហព្រះរាជអាជ្ញាបានបង្ហាញពីភាពខុសប្លែកគ្នារវាង*រឿងក្តី* *Tadić* ជាមួយនឹងរឿងក្តីនៅចំពោះមុខ ដោយបានកត់សម្គាល់ថា សម្មតិកម្មដែលបានពិភាក្សានៅក្នុង*រឿងក្តី* *Tadić* ពាក់ព័ន្ធទៅនឹងស្ថានភាពដែលការធ្វើមនុស្សឃាត ពុំមែនជាផ្នែកនៃផែនការរួមនោះទេ ចំណែកឯក្នុងរឿងក្តីបច្ចុប្បន្ន ការធ្វើមនុស្សឃាតត្រូវបានបង្ហាញថា “បានពិចារណាយ៉ាងល្អិតល្អន់ជាមុនដែលជាផ្នែកនៃមធ្យោបាយក្នុងការអនុវត្តគោលបំណងរួម”[2260]។ សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរថា អត្ថិភាពនៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម ពុំតម្រូវឱ្យមានការព្រមព្រៀងគ្នាច្បាស់លាស់ឡើយ ប៉ុន្តែគេអាចសន្និដ្ឋានអំពីអត្ថិភាពនៃការព្រមព្រៀងគ្នានេះចេញពីអង្គហេតុដទៃទៀតបាន[2261]។ សហព្រះរាជអាជ្ញាក៏បានច្រានចោលអំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញ ដោយបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើ“ភស្តុតាងគ្រប់គ្រាន់”ហើយ[2262]។

៨៤៩.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការពិភាក្សារបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហា ថាតើបទឧក្រិដ្ឋណាមួយដែលមានរួមបញ្ចូលនៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ឬគោលនយោបាយការផ្លាស់ទីនោះ ពុំមានភាពលម្អិតដោយគ្រាន់តែធ្វើការរៀបរាប់អំពីបទឧក្រិដ្ឋប៉ុណ្ណោះ[2263]។ ដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅត្រង់ចំណុចស្តីពីបទដ្ឋានច្បាប់ជាធរមាន ដែលបានដាក់បញ្ចូលនូវបទឧក្រិដ្ឋនានាដែលត្រឹមតែជា*លទ្ធផល*

---

[2258] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១៣។

[2259] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២៣។

[2260] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២៥។

[2261] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២៦។

[2262] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣២៧។

[2263] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៤។

01358462



*កើតចេញពី*ការអនុវត្តគោលបំណងរួមប៉ុណ្ណោះ[2264]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណា ថាតើបទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ រួមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត បានមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ក្នុងន័យថា គោលនយោបាយពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ត្រូវចាត់ជា ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ ដែរ ឬយ៉ាងណា និងអនុវត្តតាមគោលការណ៍ដែលបានកំណត់ខាងលើ[2265]។

## ៤.ង.១.គ.៣.ក.អំពើអមនុស្សធម៌ផ្សេងៗទៀត

៨៥០.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ផ្អែកតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចដែលត្រូវបានទទួលយកនៅដំណាក់កាលបណ្តឹងសាទុក្ខនេះបង្ហាញឱ្យឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាជនយ៉ាងតិចពីរលាននាក់ បានកើតឡើងនៅក្នុងកាលៈទេសៈដោយប្រើអំពើហិង្សា និងគួរឱ្យភ័យខ្លាចដោយគ្មានការជូនដំណឹងជាមុន និងថា ជនស៊ីវិលត្រូវបានសម្លាប់ និងស្លាប់នៅក្នុងអំឡុងពេលនោះដោយសារលក្ខខណ្ឌនៃការជម្លៀស និងថា នៅក្នុងកាលៈទេសៈនោះ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជា"អំពើអមនុស្សធម៌ផ្សេងៗទៀត"នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2266]។ ដូចបានកត់សម្គាល់ខាងលើ យោងតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង គោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជន គឺជាប់ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅអ្នកទីក្រុងទៅកាន់ទីជនបទ[2267]។ ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលពុំត្រូវបានបដិសេធចោលនៅដំណាក់កាលបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា ផែនការ"ពុំបានលើកឡើងអំពីការផ្គត់ផ្គង់ដល់សុខុមាលភាពរបស់អ្នកដែលត្រូវបានផ្លាស់ទីលំនៅនោះទេ ជាពិសេស អ្នកដែលងាយរងគ្រោះ" និងថា ជនជាប់ចោទទាំងពីរបានទទួលស្គាល់ថា ប្រជាជនបានទទួលរងយ៉ាងដូច្នេះដោយសារលទ្ធផលនៃការជម្លៀសមែន[2268]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការធ្វើយុត្តិ

---

[2264] *សូមមើលខាងលើ* កថាខណ្ឌ ៨១០។

[2265] *សូមមើលខាងលើ* កថាខណ្ឌ ៨០៧ *ជាអាទិ៍*។

[2266] *សូមមើលខាងលើ* កថាខណ្ឌ ៤៥៥ ដល់ ៤៥៧។

[2267] អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយអំណះអំណាងរបស់ ខៀវ សំផន ដែលថា គាត់ពុំបានចូលរួមនៅក្នុងសេចក្តីសម្រេចជម្លៀសទីក្រុងភ្នំពេញដូចខាងក្រោម(*សូមមើលខាងក្រោម* កថាខណ្ឌ ១០០៤ *ជាអាទិ៍*)។

[2268] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៤, ៧៨៥។

កម្មក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[2269]។ អាស្រ័យហេតុនេះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ បានកើតចេញពីគោលបំណងរួម។

### ៤.ង.១.គ.៣.ខ.ការធ្វើមនុស្សឃាត

៨៥១.ទាក់ទងទៅនឹងបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានទទួលយកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះបញ្ហានេះ ទាក់ទងទៅនឹងប្រភេទមួយចំនួននៃជនរងគ្រោះ។ បញ្ហា ថាតើបទឧក្រិដ្ឋទាំងនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណា ត្រូវតែបង្ហាញទាក់ទងទៅនឹងប្រភេទនីមួយៗ។

### ៤.ង.១.គ.៣.ខ.១.ការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌនៃការជម្លៀស

៨៥២.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជនបានស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសដោយសារលក្ខខណ្ឌទាំងនោះ។ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកការយល់ឃើញនេះនៅដំណាក់កាលបណ្តឹងសាទុក្ខ[2270]។ ទាក់ទងទៅនឹងបញ្ហា ថាតើការស្លាប់ទាំងនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ដោយផ្អែកយ៉ាងពិសេសលើការទទួលស្គាល់របស់ នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បក្សបានដឹងថា អ្នកដែលត្រូវបានជម្លៀសនឹងទទួលរងទុក្ខវេទនា និងប្រឈមការលំបាក និងស្លាប់[2271]។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា ពុំមានការផ្គត់ផ្គង់ណាមួយត្រូវបានធ្វើឡើងសម្រាប់សុខុមាលភាព និងសុខភាពរបស់អ្នកដែលត្រូវបានជម្លៀស រួមទាំងអ្នកដែលងាយទទួលរងគ្រោះបំផុតផងដែរ[2272]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់លើសក្ខីកម្មរបស់ នួន ជា ដែលថា ថ្នាក់ដឹកនាំបក្សពុំមានពេលគ្រប់គ្រាន់ក្នុងការចាត់វិធានការដាក់លាក់ទាក់ទង

---

[2269] *សូមមើល ខាងលើ* កថាខណ្ឌ ៦០៤ *ជាអាទិ៍*។

[2270] *សូមមើលខាងលើ* កថាខណ្ឌ ៤៥៩ ដល់ ៤៦០។

[2271] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៥។

[2272] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៨។

ទៅនឹងអ្នកជំងឺនៅមន្ទីរពេទ្យ ប៉ុន្តែបានអះអាងថា បក្សអាចគ្រប់គ្រងលើការជម្លៀសនេះបាន[2273]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា មានការជម្លៀសតាមទីក្រុង និងទីរួមខេត្តដទៃទៀតដែលប្រជាជនត្រូវបានបង្ខំឱ្យចាកចេញ"ដោយពុំបានគិតគូរអំពីសុខុមាលភាព ឬសុខភាពរបស់ពួកគេឡើយ"[2274]។

៨៩៣.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅក្នុងកាលៈទេសៈទាំងនេះ បានបង្ហាញឱ្យឃើញថា គោលបំណងរួមនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ ដូចមានលើកឡើងនៅក្នុងគោលនយោបាយផ្លាស់ទីលំនៅប្រជាជន គឺជាប់ពាក់ព័ន្ធទៅនឹងការស្លាប់របស់ជនស៊ីវិលដែលបណ្តាលមកពីលក្ខខណ្ឌនៃការជម្លៀសនោះ។ នេះ គឺដោយសារមានការបង្ហាញថា សមាជិកនៃសហឧក្រិដ្ឋកម្មរួម មានដូចជាថ្នាក់ដឹកនាំបក្សបានដឹងអំពីលក្ខខណ្ឌចំពោះអ្នកដែលត្រូវជម្លៀស រួមទាំងអ្នកដែលងាយទទួលរងគ្រោះបំផុតនោះនឹងត្រូវទទួលរងទុក្ខវេទនា និងជាពិសេស អ្នកដែលងាយទទួលរងគ្រោះបំផុតនឹងត្រូវស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសនោះ។ ទាក់ទងទៅនឹងបញ្ហានេះ គួររំឭកថា ការជម្លៀសនេះ គឺជាប់ពាក់ព័ន្ធទៅនឹងប្រជាជនក្នុងទីក្រុងភ្នំពេញទាំងមូលក្នុងរដូវក្តៅបំផុត និងក្នុងរយៈពេលដ៏ខ្លី។

## ៤.ង.១.គ.៣.ខ.២.ការសម្លាប់ជនស៊ីវិល

៨៩៤.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជនស៊ីវិលត្រូវបានសម្លាប់ ប្រសិនបើពួកគាត់ពុំបានគោរពតាមបទបញ្ជាឱ្យចាកចេញពីទីក្រុង និងដោយគ្មានមូលហេតុជាក់លាក់។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភស្តុតាងជាមូលដ្ឋានមួយចំនួនក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកការយល់ឃើញជាទូទៅនេះនៅដំណាក់កាលបណ្តឹងសាទុក្ខ[2275]។

៨៩៥.បញ្ហានៅចំពោះមុខគឺ ថាតើការសម្លាប់ទាំងនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះសាលាដំបូងពុំបានយោងទៅលើភស្តុតាងណាមួយដែលអាចបង្ហាញថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានព្រមព្រៀងគ្នាយ៉ាងជាក់ច្បាស់ថា អ្នកទីក្រុងដែលពុំព្រមចាកចេញពីផ្ទះរបស់ខ្លួន នឹងត្រូវសម្លាប់ចោល ហើយភាគីពុំបានចង្អុលបង្ហាញដល់អង្គជំនុំជម្រះតុលាការកំពូលនូវភស្តុតាងណាមួយនោះឡើយ។

---

[2273] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៨។

[2274] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៤។

[2275] *សូមមើលខាងលើ* កថាខណ្ឌ ៤៤៧។

៨៥៦.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានលំនាំនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុង និងទីរួមខេត្តទៅកាន់ទីជនបទមុនឆ្នាំ ១៩៧៥ ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញថា ការផ្លាស់ទីលំនៅប្រជាជនទាំងនេះមានការសម្លាប់ជនស៊ីវិល ប្រសិនបើពួកគាត់ពុំព្រមធ្វើតាមបទបញ្ជានោះ[2276]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មរបស់ François PONCHAUD ដែលថា មេឃុំត្រូវបានសម្លាប់[2277] និងបានកត់សម្គាល់លើសក្ខីកម្មរបស់ Stephen HEDER ទាក់ទងទៅនឹងការសម្លាប់ដូនជីនៅក្នុងអំឡុងពេលនៃការជម្លៀសនៅឧដុង្គក្នុងខែ មីនា ឆ្នាំ ១៩៧៤ ដែលគាត់បានឃើញសាកសពនោះ[2278]។ ដូច្នេះ មានភស្តុតាងបង្ហាញថា មានការប្រើអំពើហិង្សា និងបណ្តាលឱ្យស្លាប់នៅក្នុងបរិបទនៃការជម្លៀសដែលបានកើតឡើងនៅមុនពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

៨៥៧.ជាសំខាន់ អង្គជំនុំជម្រះតុលាការកំពូលរំឮកថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងក្នុងរយៈពេលដ៏ខ្លី និងតាមរយៈកងទ័ពប្រដាប់ដោយអាវុធធុនធ្ងន់ និងគ្មានការបណ្តុះបណ្តាលត្រឹមត្រូវដែលរួមមានកុមារ និងក្មេងជំទង់ផងដែរ[2279]។ កាលៈទេសៈទាំងនេះដែលរួមបញ្ចូលនូវកង្វះការផ្គត់ផ្គង់សុខុមាលភាពដល់អ្នកដែលត្រូវបានជម្លៀស បានបង្ហាញឱ្យឃើញដោយប្រយោលថា គោលបំណងរួមបានរួមបញ្ចូលការរំពឹងទុកនូវការប្រើប្រាស់អំពើហិង្សា ដែលបណ្តាលឱ្យស្លាប់ដោយកងទ័ពដែលត្រូវទទួលភារកិច្ចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង ប្រសិនបើមានការចចេសរឹងរូសណាមួយនោះ។ នេះដោយសារមានភស្តុតាងបង្ហាញថា កងកម្លាំងដែលបានទទួលភារកិច្ចអនុវត្តការជម្លៀសប្រជាជនចេញពីទីក្រុង ទំនងជាប្រើអំពើហិង្សាដែលបណ្តាលឱ្យស្លាប់ ប្រសិនបើមានការចចេសរឹងរូស។ នេះពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើមានបទបញ្ជាជាក់លាក់ឱ្យសម្លាប់ អ្នកណាជាអ្នកដាក់បទបញ្ជា ហើយបទបញ្ជានេះបានដាក់ត្រឹមតែទៅលើកងទ័ពដោយមេបញ្ជាការមួយចំនួន ដែរ ឬយ៉ាងណា នោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងនេះ។

---

[2276] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៤ ដល់ ១១២។

[2277] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧ និងជើងទំព័រ ២៩៥។

[2278] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៤ និងជើងទំព័រ ៣៦២ និង ៣៦៣។

[2279] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៦០។

៨៥៨.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានរួមបញ្ចូលនៅក្នុងគោលបំណងរួម។

## ៤.ង.១.គ.៣.ខ.៣.ការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៨៥៩.ដូចបានកត់សម្គាល់ខាងលើ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ដូចជា ឡុង បូរ៉េត លន់ ណុន សិរិមតៈ អ៊ុង ប៊ុនហ៊ី និង ថាច់ សារី ពុំត្រូវបានបដិសេធចោលនៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ[2280]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខ្មែរក្រហមបានប្រកាសជាសាធារណៈរួចជាស្រេចថា“ពួកជនមហាក្បត់”ទាំងនេះ ត្រូវតែប្រហារជីវិត[2281] និងបានកត់សម្គាល់លើការអះអាងរបស់ នួន ជា ដែលថា ការកម្ចាត់“ពួកជនមហាក្បត់”ក្រោយពេលបរាជ័យ គឺផ្អែកលើបទបញ្ជានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[2282]។ ដូច្នេះ ការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ គឺជាផ្នែកនៃគោលបំណងរួមទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

៨៦០.ទាក់ទងទៅនឹងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលបានធ្វើតាមការអំពាវនាវឱ្យបង្ហាញអត្តសញ្ញាណរបស់ខ្លួន និងក្រោយមកត្រូវបានសម្លាប់នោះ អង្គជំនុំជម្រះតុលាកាកំពូលកត់សម្គាល់ឃើញថា តាមការពិភាក្សាលម្អិតបន្ថែមខាងក្រោម ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[2283]។ ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅក្នុងបរិបទនៃការជម្លៀសចេញពីទីក្រុងភ្នំពេញនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការសម្លាប់ទាំងនោះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម។ នេះគឺដោយសារ មានការទាក់ទងទៅនឹងជនស៊ីវិលដែលត្រូវបានសម្លាប់ដោយសារពុំស្តាប់តាមបទបញ្ជាឱ្យចាកចេញ និងបើទោះបីជាគ្មានបទបញ្ជាឱ្យសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងកាលៈទេសៈដែលការជម្លៀសចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងក៏ដោយ ក៏ទំនងជាថា ការសម្លាប់នោះបានកើតឡើងដែរ។ ដូច្នេះ ការ

---

[2280] *សូមមើលខាងលើ* កថាខណ្ឌ ៤៦៦។

[2281] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៦៩។

[2282] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៥១០។

[2283] *សូមមើលខាងលើ* កថាខណ្ឌ ៨៦៩ *ជាអាទិ៍*។

សម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរបង្ហាញដោយប្រយោលថា គឺជាផ្នែកមួយនៃគោលបំណងរួម ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

### ៤.ង.១.គ.៣.គ.ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៨៦១.ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើ"ប្រជាជនថ្មី"[2284]។ ក្នុងការផ្តល់សេចក្តីសន្និដ្ឋាន អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបដិសេធអំណះអំណាងរបស់ នួន ជា ទាក់ទងទៅនឹងបញ្ហា ថាតើ"ប្រជាជនថ្មី" គឺជាក្រុមជាក់លាក់គ្រប់គ្រាន់ និងត្រូវបានដាក់ឱ្យស្ថិតក្រោមការរើសអើងជាក់ស្តែង ដែរ ឬយ៉ាងណា[2285]។ នួន ជា បានលើកអំណះអំណាងទាំងនេះម្តងទៀតដោយបានជំទាស់ថា ការធ្វើទុក្ខបុកម្នេញមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ប៉ុន្តែពុំបានលើកអំណះអំណាងថ្មីបន្ថែមទាក់ទងទៅនឹងបញ្ហានេះឡើយ[2286]។

៨៦២.ដោយសារការធ្វើទុក្ខបុកម្នេញលើ"ប្រជាជនថ្មី" គឺជាផ្នែកសំខាន់នៃការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលតាមនិយមន័យ ការជម្លៀសនេះប៉ះពាល់ត្រឹមតែអ្នកទីក្រុងប៉ុណ្ណោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការធ្វើទុក្ខបុកម្នេញនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម។

### ៤.ង.១.គ.៤.បទឧក្រិដ្ឋដែលមានរួមបញ្ចូលនៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៨៦៣.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទសម្លាប់រង្គាល បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងនាពេលនោះ[2287]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងបទធ្វើទុក្ខបុកម្នេញថា បទឧក្រិដ្ឋនេះពុំត្រូវបានបង្ហាញដោយសមហេតុផល

[2284] *សូមមើលខាងលើ*កថាខណ្ឌ ៦៩៧។

[2285] *សូមមើលខាងលើ* កថាខណ្ឌ ៦៨១។

[2286] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥១២ ដល់ ៥១៣។

[2287] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៩, ៦៤៣, ៦៤៨ និង ៦៥៧។

01358468



ឡើយ[2288]។ អាស្រ័យហេតុនេះ បញ្ហា ថាតើការធ្វើទុក្ខបុកម្នេញមានរួមបញ្ចូលនៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរនេះ ដែរ ឬយ៉ាងណានោះ ត្រូវចាត់ទុកជាអសារបង់។

៨៦៤.ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2289]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាក់ទងទៅនឹងការសម្លាប់រង្គាល ប៉ុន្តែបានដាក់ជំនួសមកវិញនូវការយល់ឃើញដែលថា បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[2290]។

## ៤.ង.១.គ.៤.ក.អំពើអមនុស្សធម៌ផ្សេងៗទៀត

៨៦៥.ទាក់ទងទៅនឹងបញ្ហា ថាតើអំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណា ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរនោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា បើទោះបីជាអង្គជំនុំជម្រះបានរកឃើញថា ការយល់ឃើញទូទៅមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងលក្ខខណ្ឌ ដែលប្រជាជនបានទទួលរងដោយសារការផ្លាស់ទីលំនៅដំណាក់កាលទីពីរនេះ ជាការពុំសមហេតុផលក៏ដោយ[2291] ក៏អង្គជំនុំជម្រះពិចារណាឃើញថា មានការបង្ហាញហួសពីវិមតិសង្ស័យថា ប្រជាជនមួយចំនួនធំបានទទួលរងផលប៉ះពាល់ដោយសារការជម្លៀសនេះ និងថា ប្រជាជនបានស្លាប់ដោយសារលក្ខខណ្ឌនៃការផ្លាស់ទីលំនៅ[2292]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានទទួលយកផងដែរថា ថ្នាក់ដឹកនាំរបស់ ប.ក.ក. បានអនុម័តគោលនយោបាយផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត[2293]។

---

[2288] *សូមមើលខាងលើ* កថាខណ្ឌ ៧០៦។

[2289] *សូមមើលខាងលើ* កថាខណ្ឌ ៦៦០។

[2290] *សូមមើលខាងលើ* កថាខណ្ឌ ៥៦០ ដល់ ៥៦២។

[2291] *សូមមើលខាងលើ* កថាខណ្ឌ ៦១៨ *ជាអាទិ៍*។

[2292] *សូមមើលខាងលើ* កថាខណ្ឌ ៥៥០។

[2293] *សូមមើលខាងលើ* ៨៣០ *ជាអាទិ៍*។

៨៦៦.នួន ជា បានអះអាងជាទូទៅថា ពុំមានភស្តុតាងបង្ហាញថា ថ្នាក់ដឹកនាំរបស់ ប.ក.ក. "បានព្រមព្រៀងគ្នាដាក់អ្នកដែលត្រូវបានជម្លៀសក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ឱ្យស្ថិតក្រោមលក្ខខណ្ឌដែលជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ"[2294]ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការអះអាងនេះពុំគួរឱ្យជឿជាក់បានឡើយ ដោយសារដូចបានរៀបរាប់ខាងលើ នេះគឺជាការផ្លាស់ទីលំនៅប្រជាជនដែលក្នុងកាលៈទេសៈនោះ គឺជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាក់ស្តែងជាស្នូលនៃគោលនយោបាយរបស់ ប.ក.ក. ហើយពុំមានលក្ខខណ្ឌតម្រូវឱ្យមានការព្រមព្រៀងគ្នាច្បាស់លាស់ក្នុងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឡើយ។

៨៦៧.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ មានរួមបញ្ចូលនៅក្នុងគោលបំណងរួម។

### ៤.ង.១.គ.៤.ខ.ការធ្វើមនុស្សឃាត

៨៦៨.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានសម្រេចកែប្រែបទចោទ និងបានផ្តល់ការយល់ឃើញថា បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែលនេះពុំមែនជាបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ បញ្ហានេះបានផ្អែកលើការយល់ឃើញដែលអង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថា មានការពិចារណាយ៉ាងសមហេតុផលថា ប្រជាជនបានស្លាប់ដោយសារលក្ខខណ្ឌ ដែលបានកើតឡើងនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ និងការសម្លាប់អ្នកដែលត្រូវបានជម្លៀសមួយករណី។ ផ្អែកតាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ហេតុការណ៍នៃការធ្វើមនុស្សឃាតទាំងនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួមពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដោយហេតុថា ក្នុងកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជនដែលត្រូវបានធ្វើឡើងនោះ ពុំមានការបង្ហាញថា គោលនយោបាយផ្លាស់ទីលំនៅប្រជាជនបានផ្តល់ការយកចិត្តទុកដាក់គ្រប់គ្រាន់ដល់អ្នកដែលត្រូវបានជម្លៀស ឬការពារពួកគេពីអំពើហិង្សាដោយកងទ័ពដែលមានភារកិច្ចអនុវត្តការជម្លៀសនោះ។ ដូច្នេះ ការស្លាប់ក្នុងចំណោមអ្នកដែលត្រូវបានជម្លៀស ទំនងជាកើតមានមែន។ ទោះជាយ៉ាងនេះក្តី សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានចូលរួមក្នុងការអនុវត្តគោលបំណងរួមនេះ។

---

[2294] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២១។

អាស្រ័យហេតុនេះ គោលនយោបាយផ្លាស់ទីលំនៅប្រជាជន បានរួមបញ្ចូលដោយប្រយោលនូវបទមនុស្សឃាត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

## ៤.ង.១.ឃ.អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយកំណត់គោលដៅ

៨៦៩.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "មានគោលនយោបាយកំណត់គោលដៅដែលពាក់ព័ន្ធទៅនឹងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ"[2295] ។ ក្នុងការផ្តល់ការយល់ឃើញនេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងប្រយោល។ ជាការកត់សម្គាល់ នៅក្នុងផ្នែកមួយនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី"គោលនយោបាយ" អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស និងបទបញ្ជារបស់សមាជិកនៃ ប.ក.ក . ឬរបស់បុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់ ប.ក.ក. ប្រឆាំងនឹងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលទាំងអស់នេះពុំបានបង្ហាញពីអត្ថិភាពនៃគោលនយោបាយជាប់ពាក់ព័ន្ធទៅនឹងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ឬគោលនយោបាយកំណត់គោលដៅទូទៅឡើយ[2296]។ អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សា (និងបានសម្រេចបដិសេធតាមសេចក្តីបញ្ជាក់ដំបូង)លើ"ការធ្វើយុត្តិកម្ម និងការបដិសេធ" អំពីគោលនយោបាយកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ និងសេចក្តីប្រកាសដទៃទៀតនាពេលនោះ[2297]។ អង្គជំនុំជម្រះសាលាដំបូងក៏បានសំអាងផងដែរលើភស្តុតាងទាក់ទងទៅនឹង"លំនាំស៊ីសង្វាក់គ្នា"នៃការសម្លាប់ ការចាប់ខ្លួន[2298] និងការធ្វើឱ្យបាត់ខ្លួនអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ[2299]។ ជាពិសេសេ ទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយមុនឆ្នាំ ១៩៧៥ អង្គជំនុំជម្រះសាលាដំបូង ពុំបានបែងចែករវាងមួយផ្នែកនៃការយល់ឃើញដែលកើតចេញពីសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស និងបទបញ្ជារបស់ ប.ក.ក. និងមួយផ្នែកទៀតនៃអង្គហេតុគាំទ្រការយល់ឃើញស្តីពីលំនាំនៃការប្រព្រឹត្តឡើយ[2300]។

---

[2295] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៥។

[2296] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៤ ដល់ ៨៣៧។

[2297] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៩ ដល់ ៨២៩។

[2298] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៥។

[2299] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣០ ដល់ ៨៣៤។

[2300] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២០ ដល់ ១២៧ *ជាអាទិ៍*។

៨៧០.បើទោះបីជា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងផ្នែកស្តីពី"ការយល់ឃើញផ្នែកអង្គច្បាប់"ទាក់ទងទៅនឹងគោលនយោបាយកំណត់គោលដៅថា អត្ថិភាពនៃលំនាំនេះ"បានបង្ហាញ"ផងដែរអំពីអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅ[2301] ដោយបានលើកឡើងថា មានមូលដ្ឋានពីរដាច់ដោយឡែកពីគ្នាសម្រាប់ការយល់ឃើញរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិចារណាលើការយល់ឃើញដែលថា សេចក្តីសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាព និងខ្លឹមសារនៃគោលនយោបាយកំណត់គោលដៅ បានផ្អែកជាមូលដ្ឋានទៅលើភស្តុតាងត្រួតគ្នាទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស និងបទបញ្ជា ប.ក.ក. និងទៅលើលំនាំស៊ីសង្វាក់គ្នា។

៨៧១.អាស្រ័យហេតុនេះ បន្ទាប់ពីដោះស្រាយលើអំណះអំណាងពាក់ព័ន្ធទៅនឹងការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលនយោបាយ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើអំណះអំណាងរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងភស្តុតាងជាក់លាក់ ដើម្បីវាយតម្លៃលើភាពខ្លាំង ឬភាពកម្សោយនៃភស្តុតាងនីមួយៗ។ បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងពិចារណាលើបញ្ហា ថាតើផ្អែកលើភស្តុតាងទាំងមូល សេចក្តីសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាព និងខ្លឹមសារនៃគោលនយោបាយ បានធ្វើឡើងដោយសមហេតុផល ដែរ ឬយ៉ាងណា។

## ៤.ង.១.ឃ.១.ការបង្ហាញពុំច្បាស់លាស់អំពីគោលនយោបាយ

៨៧២.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញនៅក្នុងសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់របស់ខ្លួនថា"មានគោលនយោបាយកំណត់គោលដៅដែលពាក់ព័ន្ធទៅនឹងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ"[2302]។ នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើ"គោលនយោបាយកំណត់គោលដៅសម្រាប់ការចាប់ខ្លួន ការសម្លាប់ និង/ឬការធ្វើឱ្យបាត់ខ្លួនសមាសភាពទាំងអស់នៃអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"[2303]។

---

[2301] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៥។

[2302] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៥។

[2303] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨២៩។ *សូមមើលផងដែរ* កថាខណ្ឌ ១៧២ ("អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់គោលដៅសម្លាប់ ចាប់ខ្លួន និងការឃុំខ្លួន [...]។ គោលនយោបាយកំណត់គោលដៅសម្លាប់ ចាប់ខ្លួន និង ធ្វើឱ្យបាត់ខ្លួនអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរបានបន្តរហូតមក") កថាខណ្ឌ ៨៣២ ("ការកំណត់គោលដៅលើអតីតអ្នករដ្ឋ

៨៧៣.នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានចេតនាពុំបញ្ជាក់ឱ្យច្បាស់លាស់អំពីគោលនយោបាយរបស់ ប.ក.ក. ក្នុងការកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងគោលបំណងដើម្បីប្រើប្រាស់"ភស្តុតាងនៃ*ការចាប់ខ្លួន* មកធ្វើជាភស្តុតាងនៃ*ការសម្លាប់*សម្រាប់ការដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"[2304]។

៨៧៤.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា បទមនុស្សឃាត បទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ សុទ្ធតែបានផ្អែកលើការសម្លាប់ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខ្មែរក្រហមបានប្រព្រឹត្តនៅទីនោះ[2305]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញផងដែរថា យោងតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ខ្មែរក្រហមបានសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ដោយគ្មានគិតអំពីតួនាទី ឬឋានន្តរស័ក្តិយោធារបស់ជនរងគ្រោះឡើយ[2306]។ ដូចនេះ ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃបានកើតចេញពីគោលបំណងឧក្រិដ្ឋរួមនោះ ចាំបាច់ត្រូវបង្ហាញថា គោលនយោបាយកំណត់គោលដៅបានរួមបញ្ចូលនូវការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ធ្វើការវាយតម្លៃ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែរ ឬយ៉ាងណា ក្នុងការធ្វើសេចក្តីសន្និដ្ឋានថា "គោលនយោបាយ"ទូលំទូលាយមួយ មានអត្ថិភាពជាទូទៅ ប៉ុន្តែចាំបាច់ត្រូវកម្រិតការពិនិត្យឡើងវិញរបស់ខ្លួនត្រឹមបញ្ហា ថាតើមានតុលាការអង្គហេតុសមហេតុផលណាមួយអាចយល់ឃើញថា មានអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅដែលមានការពិចារណាល្អិតល្អន់ជាមុនអំពី*ការសម្លាប់* ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលពុំស្ថិតក្នុងស្ថានភាពប្រយុទ្ធ ដែរ

---

ការនៃរបបសាធារណរដ្ឋខ្មែរតាមរយៈការចាប់ខ្លួន ការសម្លាប់ និងការធ្វើឱ្យបាត់ខ្លួន បានបន្តដល់ចុងខែ មេសា និងឧសភា ឆ្នាំ ១៩៧៥") កថាខណ្ឌ ៨៣៣ ("ខ្មែរក្រហមតាមរយៈការចាប់ខ្លួន ការសម្លាប់ និងការធ្វើឱ្យបាត់ខ្លួន បានបន្តកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងគ្រួសាររបស់ពួកគេ") កថាខណ្ឌ ៨៣៤ ("អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងទាហាន ក្រោយមកត្រូវបានចាប់ខ្លួន សម្លាប់ ឬត្រូវបានធ្វើឱ្យបាត់ខ្លួន")។

[2304] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២៦ ដល់ ៥២៧។

[2305] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៣ ដល់ ៦៨៧។

[2306] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៨៣ ("ជនរងគ្រោះនៃការសម្លាប់នៅទួលពោធិ៍ជ្រៃ រួមមានជនស៊ីវិល និងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានចុះចាញ់ និងលែងជាការចូលរួមយ៉ាងសកម្មនៅក្នុងការប្រយុទ្ធនោះតទៀត")។

ឬយ៉ាងណា។ ទោះជាយ៉ាងណាក្តី ដោយផ្អែកលើកាលៈទេសៈបែបនេះ ភស្តុតាងទាក់ទងទៅនឹងការចាប់ខ្លួន និងការធ្វើឱ្យបាត់ខ្លួនទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អាចបញ្ជាក់ពីការសម្លាប់នោះបាន នៅពេលពិចារណាផ្គួបជាមួយនឹងភស្តុតាងដទៃទៀត។

### ៤.ង.១.ឃ.២.អត្ថិភាពនៃលំនាំ

៨៧៥.ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកជាមូលដ្ឋានលើសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា គោលនយោបាយមានអត្ថិភាព *ក្នុងចំណោមនោះ* ដោយផ្អែកលើភស្តុតាងបង្ហាញពីអត្ថិភាពនៃលំនាំក្នុងការកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

### ៤.ង.១.ឃ.២.ក.ការចោទប្រកាន់អំពីការសម្លាប់នៅឧដុង្គក្នុងឆ្នាំ ១៩៧៤

៨៧៦.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នៅក្នុងឆ្នាំ ១៩៧៤ "ទាហាននៃរបបសាធារណរដ្ឋខ្មែរប្រហែលរាប់ពាន់នាក់ ត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំភ្លាមៗក្រោយពេលដណ្តើមបានឧដុង្គ"[2307]។

៨៧៧.នួន ជា និង ខៀវ សំផន បានជំទាស់ថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើក្នុងការទាញយកសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីព្រឹត្តិការណ៍នៅឧដុង្គ ពុំគ្រប់គ្រាន់ឡើយ[2308]។ ជាពិសេស ពួកគាត់បានជំទាស់ទៅនឹងតម្លៃជាភស្តុតាងនៃ (i) សក្ខីកម្មរបស់អ្នកជំនាញ Philip SHORT (ii) សៀវភៅរបស់ Philip SHORT និងប្រភពដែលបានយោងនៅក្នុងនោះ (iii) សក្ខីកម្មរបស់ ឌុច និងសាក្សី អ៊ុំ ស៊ន (iv) សក្ខីកម្មរបស់ Stephen HEDER (v) សក្ខីកម្មរបស់សាក្សី នូ ម៉ៅ (vi) សុន្ទរកថាចំនួន ២ របស់ ខៀវ សំផន និង (vii) ឯកសារបោះពុម្ពផ្សាយជាផ្លូវការរបស់រណសិរ្សរួបរួមជាតិកម្ពុជា។

៨៧៨.សហព្រះរាជអាជ្ញាបានឆ្លើយតបថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង គឺផ្អែកលើភស្តុតាងដែលអាចជឿទុកចិត្តបាន ដូចជា ពាក្យចចាមអារ៉ាមដែលអង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវធ្វើការពិចារណា និងភស្តុតាងដែលបានលើកឡើងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងថា នៅគ្រប់កាលៈទេសៈ

---

[2307] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៧។

[2308] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២៩ ដល់ ៥៣៥។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២១៨ ដល់ ២២៣។

ទាំងអស់ កំហុសពាក់ព័ន្ធទៅនឹងការយល់ឃើញស្តីពីព្រឹត្តិការណ៍នៅឧដុង្គ ពុំអាចមានឥទ្ធិពលលើសាលក្រម ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះឡើយ[2309]។

៨៧៩.សៀវភៅរបស់ Philip SHORT និងសក្ខីកម្មរបស់គាត់ជាអ្នកជំនាញ និងចម្លើយរបស់សាក្សី គឺជាប្រភពសំខាន់ដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកសំអាងក្នុងការផ្តល់ការយល់ឃើញដែលថា ក្រោយពីការជម្លៀសនៅឧដុង្គ ទាហាននៃរបបសាធារណរដ្ឋខ្មែររាប់ពាន់នាក់ត្រូវបាន"បំបែកចេញពីគ្នា រួចនាំយកទៅសម្លាប់"[2310]។ ទាំង នួន ជា និង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានវាយតម្លៃលើតម្លៃជាភស្តុតាងនៃពាក្យចចាមអារ៉ាមអនាមិក[2311]។ យោងតាមអង្គជំនុំជម្រះសាលាដំបូង Philip SHORT បានសន្និដ្ឋាន ដោយផ្អែកលើ"កិច្ចសម្ភាសន៍ជាមួយនឹងអ្នកភូមិមួយចំនួន និងប្រភពដទៃទៀត"[2312] នៅក្នុងសៀវភៅរបស់គាត់។ នៅក្នុងសក្ខីកម្មរបស់ Philip SHORT នៅក្នុងតុលាការបានបញ្ជាក់ថា ប្រភពផ្តល់ព័ត៌មានចម្បងរបស់គាត់គឺ ភី ភួន[2313] និងអ្នកភូមិ"ម្នាក់ ឬពីរ"នាក់ប៉ុណ្ណោះ[2314]។ គាត់ក៏បានលើកឡើងផងដែរអំពីសៀវភៅរបស់ Wilfred P. DEAC និងឯកសារបោះពុម្ពផ្សាយចំណងជើង*ការពិតរបស់កម្ពុជា (Réalité Cambodgiennes)* បើទោះបីជាគាត់ពុំអាចចាំថា "តើប្រភពផ្តល់ព័ត៌មានមួយណាក្នុងចំណោមនោះ សំដៅលើការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ"[2315]ក៏ដោយ។ គាត់បានពន្យល់ថា សេចក្តីសន្និដ្ឋានរបស់គាត់ដែលថា ការសម្លាប់បានកើតឡើងនៅឧដុង្គបានផ្អែកលើមូលដ្ឋានថា ប្រភពទាំងនោះស៊ីសង្វាក់គ្នា ហើយព្រឹត្តិការណ៍ប្រហាក់ប្រហែលគ្នា"បានកើតឡើងគ្រប់ទីកន្លែង"[2316]។

៨៨០.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា Philip SHORT ពុំបានសង្កេតឃើញព្រឹត្តិការណ៍នៅឧដុង្គដោយផ្ទាល់នោះទេ សក្ខីកម្ម និងចម្លើយរបស់គាត់នៅក្នុងសៀវភៅនោះ គឺជាភស្តុតាងចចាមអារ៉ាមដែលតុលាការអង្គ

---

[2309] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥៤។

[2310] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៤ និង ១២៧។

[2311] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៣១។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២១៩។

[2312] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៤។

[2313] ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1 ទំព័រ ៦៩។

[2314] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1 ទំព័រ ៥២។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1 ទំព័រ ៦៩ ដល់ ៧០។

[2315] ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1 ទំព័រ ៦៩។

[2316] ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1 ទំព័រ ៧០។

ហេតុត្រូវតែពិចារណាដោយប្រុងប្រយ័ត្ន។ តម្លៃជាភស្តុតាងនៃចម្លើយរបស់អ្នកជំនាញ Philip SHORT បានផ្អែកយ៉ាងសំខាន់ទៅលើគុណភាពនៃប្រភពព័ត៌មានរបស់គាត់ ដែលអង្គជំនុំជម្រះសាលាដំបូងពុំបានពិនិត្យពិចារណាឱ្យបានល្អិតល្អន់។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម ៦ ថ្ងៃ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សាក្សី ភី ភួន ដែលជាប្រភពព័ត៌មានចម្បងរបស់ Philip SHORT[2317]ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅឧដុង្គ ពុំបានអះអាងថា បានឃើញការសម្លាប់ណាមួយលើទាហានដែលពុំជាប់ពាក់ព័ន្ធការប្រយុទ្ធគ្នានោះឡើយ បើទោះបីជាគាត់"ចុះឡើងៗតាមហ្វ្រឹង" និងជុំវិញតំបន់ឧដុង្គ និងបានធ្វើដំណើរទៅទីប្រជុំជនក្រោយពេលរំដោះមួយអាទិត្យ[2318]។ គាត់ក៏ពុំបានអះអាងថាបានឮព័ត៌មានអំពីការសម្លាប់បែបនេះចេញពី ប៉ុល ពត ឬ មេដឹកនាំផ្សេងទៀតរបស់បក្សដែលនៅឈរជើងនៅប៉ុស្តិ៍បញ្ជាការ ប-៥ កន្លែងដែល ភី ភួន បានទៅដល់ភ្លាមៗបន្ទាប់ពីការដួលរលំឧដុង្គ[2319]។ ផ្ទុយទៅវិញ ភី ភួន បានភ្ជាប់វិធានការប្រឆាំងនឹងទាហាននៃរបបសាធារណរដ្ឋខ្មែរទៅនឹង"សមរភូមិ" និង"ពេលសង្គ្រាម"[2320]។ គាត់បានរំឮកអំពីការណែនាំដាច់ខាតថា បើទាហាននៃរបបសាធារណរដ្ឋខ្មែរចាញ់ហើយ គឺដាច់ខាតអត់មានឱ្យប៉ះពាល់ទេ[2321]។

៨៨១.ទាក់ទងទៅនឹងប្រភពព័ត៌មានដទៃទៀតដែល Philip SHORT បានអះអាងនោះ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា (i) អ្នកភូមិអនាមិក"ម្នាក់ ឬពីរនាក់"ពុំអាចធ្វើជាប្រភពអាចជឿទុកចិត្តបាន ដូច្នេះពុំគប្បីផ្តល់តម្លៃជាភស្តុតាង ឬផ្តល់តិចតួចទៅលើព័ត៌មានដែលបានមកយ៉ាងដូច្នោះ (ii) ការរៀបរាប់លម្អិតនៅក្នុងសៀវភៅរបស់ Wilfred P. DEAC បើទោះបីជា ពុំបានលើកឡើងជាក់លាក់នូវការសម្លាប់ណាមួយលើទាហាននៃរបបសាធារណរដ្ឋខ្មែរដែលកើតឡើងក្រៅសមរភូមិក៏ដោយ ក៏បានលើកឡើងថា មានទាហាន ៦០០ នាក់"បានបាត់ខ្លួន"ដែរ[2322] និងបានពិពណ៌នាអំពីដំណើររឿងដែលក្នុងនោះជនស៊ីវិលបានទទួលរងផលប៉ះពាល់

---

[2317] ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1 ទំព័រ ៦៩ ដល់ ៧០។

[2318] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/98.1 ទំព័រ ៥៥។ ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ២២ ដល់ ២៣។

[2319] ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ២១ ដល់ ២២, ២៣។

[2320] ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ៧។

[2321] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/98.1 ទំព័រ ៧០។

[2322] សៀវភៅរបស់ Wilfred P. Deac៖ *ដំណើរឆ្ពោះទៅកាន់វាលពិឃាត* ឯកសារលេខ E3/3328 ឆ្នាំ ១៩៩៧ ERN (ភាសាអង់គ្លេស) 00430777 ទំព័រ ១៩៧ ("ជនស៊ីវិលជាង ២០.០០០ ត្រូវបានប្រមូលផ្តុំទៅកាន់ទីជនបទដើម្បីសម្លាប់ ឬបង្ខំឱ្យរស់នៅ និងធ្វើ

ដោយសារការបំផ្លិចបំផ្លាញទាំងស្រុង និងថា (iii) ទស្សនៈរបស់ Philip SHORT ដែលថា មានការសម្លាប់ប្រហាក់ប្រហែលគ្នា"បានកើតឡើងគ្រប់ទីកន្លែង" ពុំឃើញមានភស្តុតាងជាក់លាក់គ្រប់គ្រាន់គាំទ្រនៅក្នុងសក្ខីកម្មទាំងមូលរបស់គាត់ឡើយ។ ទាក់ទងទៅនឹងការយោងទៅលើឯកសារបោះពុម្ពផ្សាយចំណងជើង*ការពិតរបស់ប្រជាជនកម្ពុជា (Réalité Cambodgiennes)* នោះ Philip SHORT ពុំបានបង្ហាញបញ្ហាជាក់លាក់ដែលគាត់បានសំអាង។ ទោះជាយ៉ាងណាក្តី នៅពេលពិចារណាលើបរិបទដែល Philip SHORT បានយោងទៅលើទស្សនាវដ្តីនោះ ទំនងជាថា គាត់ជាក់ស្តែងពុំបានយោងទៅលើបញ្ហានៃ*ការពិតរបស់ប្រជាជនកម្ពុជា (Réalité Cambodgiennes)* នោះទេ ប៉ុន្តែទៅលើបញ្ហានៃ*កម្ពុជាថ្មី (Nouvelles du Cambodge)* ដែលតម្លៃជាភស្តុតាងនៃឯកសារនេះនឹងត្រូវធ្វើការវាយតម្លៃខាងក្រោម។

៨៨២.ទាក់ទងទៅនឹងភស្តុតាងផ្សេងៗដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនោះ ឌុច និង អ៊ុច ស៊ន ពុំបានបញ្ជាក់ថា តើអ្នកដែលបញ្ជូនពីឧដុង្គទៅមន្ទីរសន្តិសុខ ម-១៣ ត្រូវបានសម្លាប់ ដែរ ឬយ៉ាងណាឡើយ ផ្ទុយទៅវិញបានបង្ហាញថា មួយភាគធំចុងក្រោយត្រូវបានដោះលែងពីមន្ទីរឃុំឃាំង និងត្រូវបានផ្លាស់ទីលំនៅ[2323]។ Stephen HEDER ដែលគាត់ផ្ទាល់បានស្ថិតនៅមួយរយៈពេលខ្លីបន្ទាប់ពីការដួលរលំ បានអះអាងថា គាត់ពុំបានចាំ ថាតើមានគេប្រាប់គាត់អំពីការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែរ ឬយ៉ាងណាឡើយ ប៉ុន្តែបាន

ការនៅតាមឃុំនានា") ERN (ភាសាអង់គ្លេស) 00430778 ទំព័រ ១៩៨ (នៅថ្ងៃទី ២៧ ដល់ ២៨ ខែ មីនា "សត្រូវបានបំបែកខ្សែការពារ […]។ ANK G.I.s ដែលរងរបួសត្រូវបានសម្លាប់។ អ្នកខ្លះទៀតបានប្រគល់ M-15 និង M-16s ទៅឱ្យគ្រួសាររបស់ខ្លួន មុនពេលធ្វើអត្តឃាតខ្លួនឯងដើម្បីជៀសវាងការចាប់ខ្លួន និងការធ្វើទារុណកម្ម។ ខ្មែរក្រហមបាញ់រះគ្មានរើសមុខ […]"។ នៅថ្ងៃទី ២១ ខែ មេសា […] កងទ័ពរដ្ឋាភិបាល លន់ នល់ ដែលចាញ់សង្គ្រាម បានដកថយ […]។ ប្រហែលជាប្រាំមួយរយនាក់*បានបាត់ខ្លួន*ផងដែរ") ERN (ភាសាអង់គ្លេស) 00430783-00430784 ទំព័រ ២០៣ ដល់ ២០៤ (នៅថ្ងៃទី ២៩ ខែ មិថុនា ឧដុង្គត្រូវបានដណ្តើមមកវិញដោយកងកម្លាំងរដ្ឋាភិបាលដែលបានចូលទៅក្នុង"ទីក្រុងដែលរងការវាយប្រហារបែកបាក់ខ្ទេចខ្ទីនោះ")។

[2323] ប្រតិចារឹកក្នុងចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ *ហៅ ឌុច*) ឯកសារលេខ E3/5791 ទំព័រ ២៤ ("បញ្ហាឈ្នះនៅឧដុង្គ […] មេខ្ញុំបញ្ជូន[មនុស្ស]ទៅ ម-១៣ ច្រើនដែរ បណ្តោះអាសន្នម៉ាយប់ ឬពីរយប់ គាត់ចាត់ចែងឱ្យគេដឹកទៅខាងបាត់ដំបងពាយ័ព្យ ហើយទុកមួយចំនួនប្រហែលជា ៥ ទៅ ៦ នាក់ ឱ្យខ្ញុំសួរចម្លើយ")។ ប្រតិចារឹកចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ ឌុច*) ឯកសារលេខ E1/51.1 ទំព័រ ៥២។ ប្រតិចារឹកថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ ឌុច*) ឯកសារលេខ E1/58.1 ទំព័រ ៣៤ ("គេយកទៅកម្ទេចប៉ុន្មាន អីប៉ុន្មាន ខ្ញុំមិនដឹងទេ")។ ប្រតិចារឹកថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩ (អ៊ុច ស៊ន) ឯកសារលេខ E3/1559 ទំព័រ ៦១ (រាយការណ៍ការឈ្នះឧដុង្គមួយលើកក្នុងចំណោមបីលើក"ពេលឈ្នះមួយលើកហ្នឹង"ជាពេលដែល"គេដាក់បណ្តោះអាសន្នសម្រាប់បញ្ជូនទៅខាងពាយ័ព្យ") ទំព័រ ៨០ ដល់ ៨១ (ប្រកាសថា គាត់ត្រូវបានដោះលែងពី ម-១៣ និងពុំបានលើកឡើងអំពីការសម្លាប់អ្នកដែលត្រូវបានគេជម្លៀសណាមួយឡើយ)។

ទទួលស្គាល់ថា ប្រជាជនបានអះអាងអំពី"ការសម្លាប់ប្រជាជនមួយចំនួននៅនឹងកន្លែង"[2324]។ Stephen HEDER ពិតជាបានផ្តល់សក្ខីកម្មថា គាត់បានឃើញសាកសពដូនជីមួយចំនួន[2325]។ ទោះជាយ៉ាងណាក្តី នេះពុំអាចចាត់ទុកថា ជាការបង្ហាញឱ្យឃើញគ្រប់គ្រាន់ថា ប្រជាជនដទៃទៀតត្រូវបានសម្លាប់ផងដែរនោះឡើយ។ ទាក់ទងទៅនឹងសក្ខីកម្មរបស់ នូ ម៉ៅ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា"ពុំមានព័ត៌មានថា ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់"[2326]។ ផ្ទុយទៅវិញ សាក្សីបាននិយាយថា ឈ្លើយសឹកត្រូវបានជម្លៀសរួមជាមួយនឹងប្រជាជនទូទៅផងដែរ ហើយការស្លាប់បានកើតឡើងដោយសារកង្វះស្បៀងអាហារ និងថ្នាំពេទ្យ[2327]។ ចំពោះការប្រព្រឹត្តទៅលើអ្នកដែលត្រូវបានជម្លៀស មានដូចជាឈ្លើយសឹកនោះ ខ្មែរក្រហមពុំបានយកចិត្តទុកដាក់ចំពោះជោគវាសនារបស់ពួកគេឡើយ។

៨៨៣.បញ្ហានៃ*កម្ពុជាថ្មី (Nouvelles du Cambodge)* ដែលជាឯកសារបោះពុម្ពផ្សាយជាផ្លូវការរបស់រណសិរ្សរួបរួមជាតិកម្ពុជាដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសុន្ទរកថាដែល ខៀវ សំផន បានធ្វើឡើងក្នុងប្រទេសកូរ៉េខាងជើងមួយខែក្រោយការដួលរលំខុដុង្គ។ ផ្ទុយទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង សុន្ទរកថានេះ ពុំបានផ្តល់"ការបង្ហាញច្បាស់លាស់នូវអ្វីដែលបានកើតឡើង"[2328]។ ទីមួយ ដោយសារខ្លឹម

---

[2324] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) E1/221.1 ទំព័រ ៥៨ ដល់ ៥៩ ("ខ្ញុំក៏បានសម្ភាសន៍ជាមួយមនុស្សមួយចំនួនដែលនិយាយថា មានការសម្លាប់ប្រភេទមនុស្សខ្លះនៅនឹងកន្លែង [...] ពួកគាត់ប្រហែលជាបានប្រាប់ខ្ញុំថា មានការ សម្លាប់។ ខ្ញុំចាំមិនច្បាស់ដែរ") ទំព័រ ៦៤ ដល់ ៦៥ ("ខ្ញុំចាំមិនសូវច្បាស់ថា មានការនិយាយអំពីការសម្លាប់មន្ត្រីយោធា ឬស៊ីវិល ដែរ ឬយ៉ាងណាឡើយ")។

[2325] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/221.1 ទំព័រ ៥៨ ដល់ ៥៩ ("ខ្ញុំបានឃើញសាកសពនោះ នៅចាំប្រហែលជា ប្រាំមួយប្រាំពីរ [*សំដីដើម*] គឺជាសាកសពស្ត្រីដែលស្លៀកពាក់ជាដូនជីពុទ្ធសាសនា ដែលស្លាប់នៅទីនោះ")។

[2326] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៥។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៥ ("គេរៃនៅស្រុកខុដុង្គ ជម្លៀសប្រជាជន ទាំងឈ្លើយសឹក ទាំងប្រជាជន [...]។ ខ្ញុំមិនដឹងថាយ៉ាងម៉េចយ៉ាម៉ាទេ")។

[2327] ប្រតិចារឹកចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (នូ ម៉ៅ) ឯកសារលេខ E1/209.1 ទំព័រ ៥ និង ៣៣ (សាក្សីបានដឹងតាមរយៈកិច្ចប្រជុំរបស់គណៈឃុំ"[កងកម្លាំង តាម៉ុក] ចាប់តាំងពីឈ្លើយសឹក និងប្រមូលជម្លៀសប្រជាជនថា ប្រជាជនទៅលើ បញ្ជូនទៅតាមផ្លូវអមលាំងហ្នឹង [...]។ ប្រជាជនកាលនុ៎ងដែលជម្លៀសទៅអត់មានបាយមានទឹកអីទេ។ អីចឹងងាប់ពីព្រោះអត់បាយក៏ងាប់ ស្លាប់ព្រោះអត់បាយហូរហែ") ទំព័រ ៣៣ ("អ្នកដែលត្រូវបានជម្លៀស រួមមានឈ្លើយសឹក")។

[2328] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៥។

សារពុំជាក់លាក់ត្រង់ថា អាចបកស្រាយយ៉ាងសមហេតុផលផងដែរថា ជាការសំដៅលើការសម្លាប់នៅក្នុងពេលប្រយុទ្ធ[2329]។ ច្បាស់លាស់ណាស់ ទីពីរ មានគោលបំណងឃោសនាដែលកាត់បន្ថយភាពគួរឱ្យជឿជាក់បាននៃឯកសារនេះ។ Stephen HEDER បានអះអាងពាក់ព័ន្ធទៅនឹងបញ្ហានេះថា សេចក្តីប្រកាសរបស់រណសិរ្សរួបរួមជាតិកម្ពុជាមួយចំនួនបានបំផ្លើសព្រឹត្តិការណ៍ទាំងស្រុងត្រង់ថា ព្រឹត្តិការណ៍ទាំងនេះ“ពុំដែលកើតមានឡើង ឬមានការបំប៉ោងចំនួនតួលេខយ៉ាងច្រើន” នៅពេលប្រៀបធៀបជាមួយនឹងអ្វីដែលគាត់បានសង្កេតដោយផ្ទាល់ជាក់ស្តែង ឬបានឮពីប្រភពដែលគួរឱ្យជឿទុកចិត្តបាន[2330]។ បើទោះបីជា ខៀវ សំផន បានលើកសរសើរនៅក្នុងសុន្ទរកថារបស់គាត់អំពី“ការកម្ទេច” និង“ការលុបបំបាត់” “ទាហានអាយ៉ង”ទាំងអស់ ដោយប្រើប្រាស់ពាក្យពេចន៍អុចអាល ញុះញង់ ផ្តល់យុត្តិកម្មសម្រាប់ការសម្លាប់“ទាហានអាយ៉ង” បើទោះបីជាបានប្រព្រឹត្តនៅក្នុងពេលប្រយុទ្ធ ឬពុំមែនក្នុងពេលប្រយុទ្ធក៏ដោយ។ គោលបំណង និងចរិតលក្ខណៈនៃសុន្ទរកថានេះគឺពុំអាចសន្និដ្ឋានបានថា មានការសម្លាប់ពុំស្របច្បាប់លើទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានកើតឡើងនៅឧដុង្គនោះឡើយ។

៨៨៤.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងក្នុងការសន្និដ្ឋានថា ទាហាននៃរបបសាធារណរដ្ឋខ្មែររាប់ពាន់នាក់ ត្រូវបានសម្លាប់ក្រោយពីការដណ្តើមបានក្រុងឧដុង្គក្នុងឆ្នាំ ១៩៧៤ ពុំមានលក្ខណៈច្បាស់លាស់ ពុំអាចជឿទុកចិត្តបាន និងជាទូទៅមានកម្រិតខ្សោយ។ បន្ថែមលើនេះទៀត ទាក់ទងទៅនឹងការលើកឡើងមួយចំនួនដែលពុំច្បាស់លាស់ចំពោះការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់មូលហេតុគ្រប់គ្រាន់ដែលខ្លួនពុំអាចយោងសមស្របទៅលើការសម្លាប់ ដែលបានកើតឡើងនៅក្នុងពេលប្រយុទ្ធនោះឡើយ។ អាស្រ័យហេតុនេះទើប អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញ ដោយបានសំអាងទៅលើភស្តុតាងមានកម្រិតតិចតួចនៅ

---

[2329] ឯកសារបោះពុម្ពផ្សាយរណសិរ្សរួបរួមជាតិកម្ពុជាៈ ទីភ្នាក់ងារព័ត៌មានកម្ពុជានៃរណសិរ្សរួបរួមជាតិកម្ពុជា ឯកសារលេខ E3/167 ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៤ ERN (ភាសាខ្មែរ) 00596141 ទំព័រ ២៤(រាយការណ៍អំពីសុន្ទរកថាដែល ខៀវ សំផន បានថ្លែងនៅក្នុងកូរ៉េខាងជើងកាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៧៤ ថា “ថ្ងៃទី ១៨ ខែ មីនា កន្លងទៅនេះ កងទ័ពប្រជាជនរំដោះជាតិកម្ពុជារបស់យើងបានរំដោះទីក្រុងមួយទៀត គឺទីក្រុងឧត្តុង្គ ដោយកម្ទេចចោលឱ្យអស់នូវកងទ័ពអាយ៉ងទាំងអស់ដែលនៅទីនោះ ហើយនឹងកម្លាំងជំនួយពួកវា ដែលក្នុងនោះ ខ្មាំងចំនួនជាង ៥.០០០ នាក់ត្រូវបានកម្ទេចហើយ ១.៥០០ នាក់ត្រូវចាប់បាន”។ អត្ថបទនេះ គឺជាផ្នែកមួយសុន្ទរកថាពាក់ព័ន្ធទៅនឹង“ដំណឹងស្តីពីការជោគជ័យដែលមានលក្ខណៈយុទ្ធសាស្ត្រ”“ដែលកងទ័ពប្រជាជនរំដោះជាតិ និងប្រជាជនកម្ពុជាទទួលបានលើពួកចក្រពត្តិអាម៉េរិក និងបរិវាររបស់ពួកវានៅគ្រប់ទីកន្លែង”។

[2330] ប្រតិចារឹកចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEsDER) ឯកសារលេខ E1/223.1 ទំព័រ ២៤។

ចំពោះមុខខ្លួនថា ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ក្នុង*ទ្រង់ទ្រាយធំ*នៅឧដុង្គ។ សេចក្តីសន្និដ្ឋាននេះបានមោឃៈការដាក់ជាប់ពាក់ព័ន្ធដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងថា មេដឹកនាំ ប.ក.ក. បានពិភាក្សាការសម្លាប់ក្នុងទ្រង់ទ្រាយធំដែលបានកើតឡើងនៅឧដុង្គក្នុងអំឡុងពេលប្រជុំមួយក្នុងខែមិថុនា ឆ្នាំ ១៩៧៤[2331]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ភស្តុតាងមូលដ្ឋានពុំបានបង្ហាញថា ខ្មែរក្រហមមិនត្រឹមតែមិនអើពើចំពោះប្រជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកោតសរសើរការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ដោយប្រើប្រាស់ពាក្យពេចន៍អុចអាលមិនរើសមុខឡើយ។

## ៤.ង.១.ឃ.២.ខ.ភស្តុតាងដទៃទៀតនៃការសម្លាប់មុនឆ្នាំ ១៩៧៥

៨៨៥.អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា៖ (i) ក្នុងឆ្នាំ ១៩៧២ ទាហាននៃរបបសាធារណរដ្ឋខ្មែរចំនួន ៥០០ នាក់ ដែលបានចាប់ខ្លួន ត្រូវខ្មែរក្រហមសម្លាប់ចោលទាំងអស់នៅក្នុងភូមិភ្លើងឆេះ (ii) នៅក្នុងខែកញ្ញា ឆ្នាំ ១៩៧៣ ខ្មែរក្រហមបានកំណត់គោលដៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរក្នុងខេត្តកំពង់ចាម (iii) ក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ ទាហានដែលចុះចាញ់ និងក្រុមគ្រួសាររបស់ពួកគេត្រូវបានសម្លាប់ក្នុងខេត្តបាត់ដំបង (iv) មានសេចក្តីរាយការណ៍ពីជនភៀសខ្លួនអំពីការសម្លាប់ខ្នាំងនៅក្នុងខែ មីនា ឆ្នាំ ១៩៧៤[2332]។ ភស្តុតាងដែលជាមូលដ្ឋាននៃការយល់ឃើញទាំងនេះ និងបានបែងចែកជាពីរផ្នែកដាច់ដោយឡែកពីគ្នានៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[2333] មានដូចជា៖ (i) បទសម្ភាសន៍របស់ជនភៀសខ្លួនជាមួយ Stephen HEDER និង Masato MATSUSHITA (ii) សក្ខីកម្មរបស់ Stephen HEDER និងអ្នកជំនាញ Philip SHORT (iii) អនុស្សរណៈចំនួន ២ របស់រដ្ឋាភិបាលនៃសហរដ្ឋអាម៉េរិក និង (iv) សេចក្តីថ្លែងការណ៍រួមជាសាធារណៈរបស់ ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម។

---

[2331] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩១៨ និង ១០៣៩។

[2332] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣០។ *សូមមើលផងដែរ* កថាខណ្ឌ ១២១ (បានពិពណ៌នាអំពីគោលនយោបាយពាក់ព័ន្ធទៅនឹងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានចាប់ខ្លួនចាប់ពីឆ្នាំ ១៩៧០ ដល់ ១៩៧៥)។

[2333] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២០ ដល់ ១២៣ និង ៨៣០។

៨៨៦.នួន ជា និង ខៀវ សំផន បានលើកឡើងថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមស្រប និងគ្មានមូលដ្ឋានគាំទ្រ ដោយសារភស្ដុតាងនោះស្រពេចស្រពិល ពុំច្បាស់លាស់ និងជាពាក្យចចាមអារ៉ាម អនាមិកតៗគ្នាពីរ ឬបីដង និងបានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់អំពីមូលហេតុ ដែលថា ការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ពុំបានកើតឡើងនៅក្នុងពេលប្រយុទ្ធ ឬជាអំពើហិង្សាដាច់ដោយឡែក ជាជាងលទ្ធផលនៃគោលនយោបាយប្រព្រឹត្តបទឧក្រិដ្ឋនោះ[2334]។

៨៨៧.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ភស្ដុតាងនោះគ្រប់គ្រាន់ និងស៊ីសង្វាក់គ្នា ដូច្នេះ នាំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្ដល់ការយល់ឃើញដោយសមហេតុផល[2335]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញភស្ដុតាងបន្ថែមទៀតដែលអង្គជំនុំជម្រះសាលាដំបូងពុំបានយោង ប៉ុន្តែគប្បីត្រូវបានសន្មតថា បានពិចារណាក្នុងការផ្ដល់សេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុនោះ[2336]។

៨៨៨.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ក្នុងការផ្ដល់ការយល់ឃើញទាក់ទងទៅនឹងហេតុការណ៍សម្លាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានសំអាងតែលើពាក្យចចាមអារ៉ាម ចម្លើយក្រៅតុលាការ និងឯកសារប៉ុណ្ណោះ។ មានតែបទសម្ភាសន៍មួយប៉ុណ្ណោះក្នុងចំណោមបទសម្ភាសន៍ជាច្រើនរបស់ជនភៀសខ្លួន ដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនោះ សំដៅទៅលើការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលជនភៀសខ្លួនអនាមិកម្នាក់បានរៀបរាប់ថា ទាហាន"ចំនួន ៥០០ នាក់"ត្រូវបានចាប់ខ្លួន និងសម្លាប់នៅក្នុងឆ្នាំ ១៩៧២ នៅភូមិភ្លើងឆេះ[2337]។ ការរៀបរាប់នេះមានតម្លៃភស្ដុតាងទាប និងត្រូវបានវាយតម្លៃដោយផ្អែកលើភស្ដុតាងបញ្ជាក់បន្ថែមដទៃទៀត។ Stephen HEDER បានផ្ដល់សក្ខីកម្មថា គាត់មានការ"ចងចាំជាទូទៅ"នូវអ្វីដែលអ្នកភូមិបានប្រាប់គាត់អំពីមនុស្សដែលត្រូវបានជម្លៀស និង"បានសម្លាប់នៅនឹងកន្លែង" នៅពេលដែលខ្មែរក្រហមបានកាន់កាប់ផ្នែកខ្លះនៃខេត្តកំពង់ចាមក្នុងខែកញ្ញា ឆ្នាំ ១៩៧៣[2338]។ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់

[2334] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៤១ ដល់ ៥៤៨។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២០២ ដល់ ២១៧។

[2335] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥៦ ដល់ ៣៦០។

[2336] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦០ ដល់ ៣៦១។

[2337] របាយការណ៍របស់ S. HEDER និង M. MATSUSHITA៖ កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជាថៃ ឯកសារលេខ E3/1714 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 00324777 ទំព័រ ១០៦។

[2338] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/221.1 ទំព័រ ៦៥ និង ៦៩។

01358481



ទម្ងន់សមស្របចំពោះការរៀបរាប់នេះ ដូចការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញា[2339]ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញថា ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់នៅកំពង់ចាមនោះទេ ប៉ុន្តែគ្រាន់តែ"ត្រូវបានកំណត់គោលដៅ"[2340]ប៉ុណ្ណោះ។ អ្នកជំនាញ Philip SHORT បានអះអាងថា គាត់ជឿជាក់ថា ការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"បានកើតឡើងគ្រប់ទីកន្លែង"[2341]។ ដោយហេតុថា គាត់ពុំបានផ្តល់ការគាំទ្រជាក់លាក់ដល់ការអះអាងរបស់គាត់[2342] ទើបតុលាការអង្គហេតុត្រឹមតែអាចផ្តល់ទម្ងន់ក្នុងកម្រិតតិចតួចចំពោះសក្ខីកម្មនេះប៉ុណ្ណោះ។ បន្ថែមលើនេះទៀត Philip SHORT បានបញ្ជាក់ពីរលើកថា ហេតុការណ៍ដែលគាត់បានដឹងនោះជាប់ពាក់ព័ន្ធទៅនឹង"ទាហានដែលមានឋានន្តរស័ក្តិខ្ពស់" និង "អ្នករដ្ឋការជាន់ខ្ពស់" ហើយពុំមែនជាទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់នោះទេ[2343] ដែលការអះអាងនេះមានផ្នែកខ្លះផ្ទុយនឹងចម្លើយពីមុនរបស់គាត់[2344]។

៨៨៩.អង្គជំនុំជម្រះសាលាដំបូងបានសំអាងផងដែរលើអនុស្សរណៈចំនួន ២ ចេញពីរដ្ឋាភិបាលសហរដ្ឋអាម៉េរិកធ្វើជាភស្តុតាងនៃការសម្លាប់សត្រូវ មានដូចជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុង"ទឹកដីខ្មែរក្រហម" និងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានចុះចាញ់ រួមទាំងគ្រួសាររបស់ពួកគេនៅក្នុងខេត្តបាត់ដំបង[2345]។ អនុស្សរណៈទាំងពីរមានប្រភពជា"របាយការណ៍របស់មន្ត្រីស្ថានទូតសហរដ្ឋអាម៉េរិក" ដែលបានអះអាងអំពីការសម្លាប់ជនស៊ីវិល និងទាហានដែលចុះចាញ់នៅក្នុងខេត្តបាត់ដំបងក្នុងឆ្នាំ ១៩៧៤[2346]។ អាស្រ័យហេតុនេះ

---

[2339] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦០។

[2340] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣០។

[2341] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1 ទំព័រ ៧១ ដល់ ៧២។

[2342] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1 ទំព័រ ៨៩ ដល់ ៩០។

[2343] ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/191.1 ទំព័រ ៦៦ ដល់ ៦៧។

[2344] ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1 ទំព័រ ៥៥ ដល់ ៥៦ ("មានលំនាំទូទាំងប្រទេសនៃការសម្លាប់អតីតនាយទាហាននៃរបបសាធារណរដ្ឋខ្មែរមិនថាក្នុងឋានៈណាក៏ដោយ និងការសម្លាប់អ្នករដ្ឋការដែលជាអតីតនៃរដ្ឋាភិបាល លន់ នល់ ចាប់ពីកម្រិតមួយចំនួនឡើងទៅ។ ខ្ញុំគិតថា នៅក្នុងករណីនាយទាហាន ជួរយោធា គឺមានលក្ខណៈជាប្រព័ន្ធជាងអ្នករដ្ឋការស៊ីវិល។ សម្រាប់អ្នករដ្ឋការស៊ីវិល [...] ពុំមានលក្ខណៈជាប្រព័ន្ធ - បើទោះបីជាប្រព័ន្ធក៏ដោយ ក៏មាននៅចន្លោះប្រហោងនោះដែរ")។

[2345] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣០។

[2346] អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិរបស់សហរដ្ឋអាម៉េរិក កម្មវត្ថុ៖ ព័ត៌មានសំខាន់ៗអំពីប្រទេសកម្ពុជា ឯកសារលេខ E3/4197 ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00939695 ទំព័រ ៥។ អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិរបស់

អនុស្សរណៈចំនួន ២ ត្រូវបានសន្មតថា ជាខ្លឹមសារតែមួយ។ ដូចបានកត់សម្គាល់ដោយ នួន ជា និង ខៀវ សំផន[2347] អនុស្សរណៈនេះ គឺជាពាក្យចចាមអារ៉ាមអនាមិកតៗគ្នា។ ទោះជាយ៉ាងណាក្តី ចំណុចនេះតែឯងពុំអាចកាត់បន្ថយតម្លៃនៃការជឿទុកចិត្តបានជាទូទៅនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ប្រភពព័ត៌មាននៅក្នុងអនុស្សរណៈមួយក្នុងចំណោមអនុស្សរណៈនោះ ដែលរៀបរាប់អំពីការសម្លាប់ដែលបានកើតឡើងនៅលើទឹកដីរបស់ខ្មែរក្រហម គឺជាអត្ថបទកាសែតមួយចំនួនដែលបានចុះផ្សាយនៅក្នុងឯកសារបោះពុម្ពផ្សាយនានា ដែលបាននិពន្ធដោយអ្នកការសែតផ្សេងៗ។ អត្ថបទនោះបានពិពណ៌នាសង្ខេបអំពីព្រឹត្តិការណ៍នៃសោកនាដកម្មដែលបានកើតឡើងលើជនស៊ីវិល និងទាហាននៃរបបសាធារណរដ្ឋខ្មែរ។ ការពិពណ៌នាទាំងនោះមានលក្ខណៈស៊ីសង្វាក់គ្នា ហើយភាពអាចជឿជាក់បានបញ្ជាក់បន្ថែមគ្នាទៅវិញទៅមក ប៉ុន្តែភាគច្រើនជាប់ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលកើតមានចំពោះជនស៊ីវិល ពុំមែនលើទាហាននៃរបបសាធារណរដ្ឋខ្មែរឡើយ ដូច្នេះការពិពណ៌នានេះបានផ្តល់ព័ត៌មានលម្អិតក្នុងកម្រិតតិចតួចដែលរារាំងតុលាការអង្គហេតុសមហេតុផល ពុំអាចផ្តល់ទម្ងន់ធ្ងន់ចំពោះភស្តុតាងនេះបាន[2348]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញលើភស្តុតាងបន្ថែមទៀតដែលតាមការលើកឡើងរបស់សហព្រះរាជអាជ្ញា ត្រូវបានសន្មតថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណា។ ភស្តុតាងទីមួយជាប់ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងភូមិមួយ និងគ្មានកាលបរិច្ឆេទជាក់លាក់ បើទោះបីទំនងជានៅក្រោយការជួលរលំទីក្រុងភ្នំពេញនោះ[2349] ភស្តុតាងដទៃទៀតជាប់ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយពីការដណ្តើមបានបាត់ដំបងក្នុងខែ មេសា ឆ្នាំ ១៩៧៥ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងត្រូវពិចារណានៅក្នុងផ្នែកពាក់ព័ន្ធដូចខាងក្រោម[2350]។

៨៩០.ចុងក្រោយ សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម ដែល*ក្នុងចំណោមនោះ*សំដៅលើ“ការកម្ទេច”“កម្លាំងរបស់ខ្មាំងចំនួន ១.៥៥០ ក្បាល ក្នុងនោះមានអាសក្តិប្រាំ សក្តិបី សក្តិពីរ និង

---

សហរដ្ឋអាម៉េរិក កម្មវត្ថុ៖ ការវាយតម្លៃនៃការអភិវឌ្ឍន៍នៅក្នុងឥណ្ឌូចិនចាប់តាំងពីការបញ្ចប់សង្គ្រាម ឯកសារលេខ E3/3472 ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00742973 ទំព័រ ៦។

[2347] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៤៨។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២០៣។

[2348] អនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិរបស់សហរដ្ឋអាម៉េរិក កម្មវត្ថុ៖ ព័ត៌មានសំខាន់ៗអំពីប្រទេសកម្ពុជា ឯកសារលេខ E3/4197 ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00939692-4 ទំព័រ ១ ដល់ ៤។

[2349] របាយការណ៍របស់រដ្ឋាភិបាលចក្រភពអង់គ្លេស៖ *ការរំលោភសិទ្ធិមនុស្សនៅក្នុងកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/3319 ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00699249 ទំព័រ ៤០។

[2350] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ២០ ដល់ ២១។

សត្តិមួយរាប់សិបក្បាល ត្រូវបានយើងកំទេច"នៅទីតាំងចំនួនដប់កន្លែង"តាមបណ្ដោយផ្លូវជាតិលេខ ៣" និងសំដៅលើ"ការកម្ទេច""ខ្មាំងសរុបចំនួន ១០.២៤៥ ក្បាល [...] មកទល់នឹងពាក់កណ្ដាលខែ មករា ឆ្នាំ ១៩៧៣"[2351] ប្រហាក់ប្រហែលគ្នាទៅនឹងសេចក្ដីថ្លែងការណ៍ខាងលើនេះ កោតសរសើរការសម្លាប់នៅឧដុង្គ។ បើទោះបីជាតួលេខដែលបានយោងទៅលើនោះទំនងជាមានការបំប៉ោង ដោយសារចរិតលក្ខណៈនៃការឃោសនាក៏ដោយ ក៏សេចក្ដីថ្លែងការណ៍នេះបានដាស់សតិអារម្មណ៍ហិង្សាប្រឆាំងនឹងទាហាននៃរបបសាធារណរដ្ឋខ្មែរ។ ទោះជាយ៉ាងណាក្ដី ផ្អែកតាមចរិតលក្ខណៈ និងគោលបំណងនៃសេចក្ដីថ្លែងការណ៍នេះ ពុំអាចជាការបង្ហាញឱ្យឃើញការសម្លាប់ក្រៅសមរភូមិប្រយុទ្ធជាក់ស្ដែងបានកើតឡើងនោះទេ។

៨៩១.សរុបសេចក្ដីមក ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនោះ មានមូលដ្ឋានខ្សោយ និងពុំអាចបង្ហាញសមហេតុផលថា មានការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុង"ទ្រង់ទ្រាយធំ"[2352]បានកើតឡើងនៅមុនឆ្នាំ ១៩៧៥ ឡើយ។ ភស្តុតាងនេះជាក់ស្ដែងពុំបានបង្ហាញសមស្របទៅនឹងបទដ្ឋានតម្រូវដែលនៅក្នុងអំឡុងពេលជាប់ពាក់ព័ន្ធនោះ គោលនយោបាយកំណត់គោលដៅមានអត្ថិភាពរួចហើយនោះឡើយ។ ទោះជាយ៉ាងណាក្ដី ភស្តុតាងនោះបង្ហាញសញ្ញាណខ្លះៗអំពីវិធានការហិង្សា ដែលបានធ្វើឡើងក្រៅសមរភូមិប្រយុទ្ធប្រឆាំងនឹងអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ។ ទោះជាយ៉ាងនេះក៏ដោយ សញ្ញាណទាំងនោះមាននៅក្នុងភស្តុតាងដែលមានតម្លៃទាប ដែលពុំអាចធ្វើការពិភាក្សាណាមួយលើភាពជាប់ពាក់ព័ន្ធ ភាពអាចជឿទុកចិត្តបាន និងការបញ្ជាក់បន្ថែមដែលអាចមាននោះឡើយ។

## ៤.ង.១.ឃ.២.គ.ការចោទប្រកាន់អំពីការសម្លាប់នៅចុងខែ មេសា និង ខែឧសភា ឆ្នាំ ១៩៧៥

៨៩២.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការចាប់ខ្លួន ការសម្លាប់ និងការធ្វើឱ្យបាត់ខ្លួនអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាក់ទងទៅនឹងការជម្លៀស បានបន្តរហូតដល់ចុងខែមេសា និងខែឧសភា ឆ្នាំ ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ បាត់ដំបង កំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង កណ្ដាល តាកែវ សៀមរាប និងទួលពោធិ៍ជ្រៃ[2353]។

---

[2351] សេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ហ៊ូ នឹម ហ៊ូ យន់ ឯកសារលេខ E3/637 ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00442328 ទំព័រ ៣ និង 00442332 ទំព័រ ៧។

[2352] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២៧។

[2353] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣១ ដល់ ៨៣២។

៨៩៣.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ និងអង្គច្បាប់ក្នុងការយោងទៅលើទីក្រុង និងទីរួមខេត្តនានាតាម"ការជ្រើសរើសដោយអំពើចិត្ត"ដែលខ្លួនបានរកឃើញថា ត្រូវបានជម្លៀស និងបានសំអាងទៅលើភស្តុតាងពុំគ្រប់គ្រាន់ និងពុំអាចជឿទុកចិត្តបានក្នុងការបង្ហាញអំពីការសម្លាប់[2354]។ ខៀវ សំផន បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពុំបានពិចារណាលើស្វ័យភាពរបស់ភូមិភាគនៅក្នុងកិច្ចការយោធា មុនពេលការបង្កើតកងទ័ពបដិវត្តន៍កម្ពុជាក្នុងខែកក្កដា ឆ្នាំ ១៩៧៥[2355]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា ភស្តុតាងអំពីការធ្វើបាបលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពុំអាចជឿជាក់បានទាំងស្រុងនោះឡើយ[2356]។

៨៩៤.សហព្រះរាជអាជ្ញាបានអះអាងថា ទីតាំងដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង គ្រាន់តែជាការរៀបរាប់ត្រួសៗប៉ុណ្ណោះ និងបានលើកឡើងថា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានយោងនោះ អាចជឿទុកចិត្តបាន[2357]។

៨៩៥.ទាក់ទងទៅនឹងការចោទប្រកាន់អំពីការសម្លាប់ នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរបានកើតឡើងក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នោះ។ ទោះបីជាយ៉ាងនេះក្តី ដោយសារភស្តុតាងមានកម្រិតតិចតួចនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអង្គជំនុំជម្រះតុលាការកំពូលបានទទួលយកត្រឹមតែការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់ចំនួន ៤ នាក់ដែលពុំមានការជំទាស់ និងការសម្លាប់ដែលបានរៀបរាប់ដោយសាក្សីម្នាក់[2358]។

៨៩៦.ទាក់ទងទៅនឹងការសម្លាប់នៅក្នុងខេត្តបាត់ដំបង អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មផ្ទាល់មួយ កំណត់ហេតុស្តាប់ចម្លើយចំនួន ២ និងការរៀបរាប់ក្រៅតុលាការចំនួន ៣ ដទៃទៀត ក្នុងការផ្តល់ការយល់ឃើញ[2359]។ សាក្សី ហ៊ុន ឈុនលី បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា គាត់បាន

---

[2354] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨១ ដល់ ៥៨៥។

[2355] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២២។

[2356] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២៧។

[2357] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨១ ដល់ ៣៨៣។

[2358] *សូមមើល* កថាខណ្ឌ ៤៦១ *ជាអាទិ៍*។

[2359] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៦៣៥។

ឃើញអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងកូនទាហាន បានប្រមូលផ្ដុំក្នុងទីកន្លែងពីរខុសគ្នានៅក្នុងខេត្តបាត់ដំបង[2360]។ គាត់បានឮការប្រកាសថា អ្នករដ្ឋការត្រូវទៅទទួលសម្ដេច នរោត្តម សីហនុ។ ក្រោយមកគាត់បានដឹងដោយសារអ្នកបើកឡានម្នាក់ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការនោះថា អ្នករដ្ឋការទាំងនោះត្រូវបាននាំយកទៅសម្លាប់នៅភ្នំអធិបតី ចំណែកទាហានស័ក្តិមួយត្រូវបានយកទៅប៉ៃលិន និងឱ្យធ្វើស្រែចម្ការ។

៨៩៧.យោងតាមកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ព្រំ សារុន ដែលជាកូនទាហាននៃរបបសាធារណរដ្ឋខ្មែរ បានរៀបរាប់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា ខ្មែរក្រហមបានសួររកទាហានដែលមានបណ្ដាស័ក្តិធំៗ ដើម្បីយកទៅសម្លាប់ចោល[2361]។ បន្ថែមលើនេះ គាត់បានឃើញការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ និងឃើញសាកសពនៃអតីតមេបញ្ជាការរបស់គាត់ ដែលតាមគាត់ឮ ខ្មែរក្រហមបានវាយរហូតដល់ស្លាប់[2362]។ យោងតាមកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ជុច ពន្លក បានរៀបរាប់ថា អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលខ្មែរក្រហមដឹកជញ្ជូនចេញតាមឡានទៅរៀនសូត្រនោះ ក្រោយមកគាត់បានឮថា អ្នកទាំងនោះត្រូវបានសម្លាប់[2363]។ គាត់ក៏បានអះអាងផងដែរថា មានទាហានពី ៣០០ ទៅ ៤០០ នាក់ត្រូវបាននាំយកទៅធ្វើការនៅកន្លែងផ្សេង[2364]។

៨៩៨.ការរៀបរាប់ក្រៅតុលាការចំនួន ៣ បានបញ្ជាក់អំពីការសម្លាប់នាយទាហាននៃរបបសាធារណរដ្ឋខ្មែរនៅក្នុងស្រុកមោងឫស្សី(ភ្នំអធិបតី) និងស្រុកថ្មគោលក្នុងខេត្តបាត់ដំបង[2365]។ ការរៀបរាប់នេះបានបញ្ជាក់បន្ថែម

---

[2360] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ (ហ៊ុន ឈុនលី) ឯកសារលេខ E1/149.1 ទំព័រ ៣៣។

[2361] កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារុន ឯកសារលេខ E3/5187 ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00197917-8 ទំព័រ ៣ និង ៤។

[2362] កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារុន ឯកសារលេខ E3/5187 ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00197917-8 ទំព័រ ៣ និង ៤។

[2363] កំណត់ហេតុស្ដាប់ចម្លើយ ជុច ពន្លក ឯកសារលេខ E3/5211 ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00221544 ទំព័រ ៣។

[2364] កំណត់ហេតុស្ដាប់ចម្លើយ ជុច ពន្លក ឯកសារលេខ E3/5211 ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00221544 ទំព័រ ៣។

[2365] កំណត់ហេតុរបស់ H. LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្ដីពីបណ្ដាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 002333845 ទំព័រ ៣ ដល់ ៤, ERN (ភាសាខ្មែរ) 002333402 ទំព័រ ២១។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ថាច់ សាលី ឯកសារលេខ E3/4966 ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧

លើភស្តុតាងដទៃទៀតដែលពាក់ព័ន្ធទៅនឹងការសម្លាប់នៅខេត្តបាត់ដំបងត្រង់ថា មានការអះអាងនូវទីកន្លែងនៃការសម្លាប់ដូចគ្នា ចំនួន និងអត្តសញ្ញាណរបស់ជនរងគ្រោះប្រហាក់ប្រហែលគ្នា និងកាលៈទេសៈស្រដៀងគ្នាដូចជាបែបផែនក្នុងការបោកបញ្ឆោតជនរងគ្រោះ មធ្យោបាយក្នុងការដឹកជញ្ជូន និងវិធីសាស្ត្រនៃការសម្លាប់។ បន្ថែមលើនេះ ការរៀបរាប់នេះបានផ្តល់ចំណុចពិសេសៗដែលបញ្ជាក់ពីភាពអាចជឿទុកចិត្តបាន។ យោងតាមការរៀបរាប់មួយក្នុងចំណោមនោះឃើញថា នាយទាហានថ្នាក់ក្រោម និងកូនទាហានសាមញ្ញជាច្រើននាក់ពុំត្រូវបានសម្លាប់ ប៉ុន្តែត្រូវបាននាំយកទៅឱ្យធ្វើការធ្ងន់នៅម្តុំជិតប៉ៃលិន[2366]។

៨៩៩.សក្ខីកម្មរបស់សាក្សី ទាត់ ធឿន នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខ បានផ្តល់ការបញ្ជាក់បន្ថែមផងដែរថា ទាហាននៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់នៅក្នុងខេត្តបាត់ដំបងនៅប៉ុន្មានថ្ងៃក្រោយពីបានរំដោះ។ នៅពេលស្នាក់នៅជាមួយ រស់ ញឹម(ញឹម រស់) ជាលេខាភូមិភាគពាយ័ព្យនៅកំពង់ព្រះ[2367] ទាត់ ធឿន បានឃើញទាហានត្រូវបានដឹកតាមឡានទិសដៅទៅកាន់ស្រុកមោង[2368] គាត់បានស្តាប់ឮពួកគេស្រែកជ័យឃោសអបអរសម្តេច នរោត្តម សីហនុ[2369]។ ទាត់ ធឿន បានសន្និដ្ឋានថា ពួកគេស្តាប់តាមការប្រកាសតាមវិទ្យុអញ្ជើញពួកគេឱ្យទៅចូលរួមពិធីស្វាគមន៍សម្តេច។ ក្រោយមក អង្គរក្សរបស់ រស់ ញឹម(ញឹម

---

ERN (ភាសាខ្មែរ) 00565114-6 ទំព័រ ១ ដល់ ៣។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ២០ ដល់ ២១ (យោងទៅលើសាក្សីបួននាក់ដែលបានប្រាប់គាត់អំពីការសម្លាប់អ្នករដ្ឋការនៃរបបសាធារដ្ឋខ្មែរប្រមាណ ៣០០ នៅភ្នំអធិបតី ដែលម្នាក់ក្នុងចំណោមនោះបានឃើញដោយផ្ទាល់ការសម្លាប់ និងពីរនាក់បានត្រឹមឃើញលលាក្បាល ឬសាកសព)។ ទូរលេខរបស់ក្រសួងការងាររបស់សហរដ្ឋអាម៉េរិក កម្មវត្ថុ៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ឯកសារលេខ E3/3559 ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00709582 ទំព័រ ៦ (ពិភាក្សាលើស្ថានការណ៍ក្នុងស្រុកភ្នំស្រុកខេត្តបាត់ដំបង ជាពិសេសលើការសម្លាប់នាយទាហានទាំងអស់ដោយមេដឹកនាំយោធាខ្មែរកុម្មុយនីស្ត)។

[2366] កំណត់ហេតុរបស់ H. LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្តីពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៧ ERN (ភាសាខ្មែរ) 00233385 ទំព័រ ៥។

[2367] ការយោងម្តងម្កាលទៅលើ"Kampong Treas"នៅក្នុងប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ១០៥ ដល់ ១០៦ (ភាសាអង់គ្លេស), ទំព័រ ៨១ ដល់ ៨២ (ភាសាខ្មែរ) បកប្រែខុស(*សូមមើល* ទំព័រ ៤៨, ៥៨ ដល់ ៥៩ និង ៩១ (ភាសាខ្មែរ)សំដៅលើកំពង់ព្រះ)។

[2368] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៩១។

[2369] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៨២។

រស់) បានប្រាប់គាត់ថា ពួកគេទាំងអស់នោះត្រូវបានសម្លាប់[2370]។ មានឡានជាច្រើនជាងដប់គ្រឿង ដែលឡាននីមួយៗដឹកអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរប្រហែលពី ៣០ ទៅ ៤០ នាក់ និងបានបើកកាត់មុខផ្ទះរបស់ រស់ ញ៉ឹម(ញ៉ឹម រស់) ម្តងនៅពេលថ្ងៃ និងម្តងទៀតនៅពេលល្ងាច[2371]។ បើទោះបីជាសាក្សីរូបនេះពុំបានស្គាល់ទីកន្លែងដែលទាហានទាំងនោះត្រូវបាននាំយកទៅក៏ដោយ ក៏ផ្អែកលើភស្តុតាងទាំងមូល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការសមហេតុផលក្នុងការសន្និដ្ឋានថា ទាហានទាំងនេះត្រូវនាំយកទៅភ្នំអធិបតី[2372]។ ផ្អែកលើសក្ខីកម្មរបស់សាក្សីទាំងមូល និងភស្តុតាងដទៃទៀតពាក់ព័ន្ធទៅនឹង រស់ ញ៉ឹម(ញ៉ឹម រស់)[2373] អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានក្នុងកម្រិតអប្បបរមាថា រស់ ញ៉ឹម(ញ៉ឹម រស់) បានគាំទ្រការសម្លាប់នោះ។

៩០០.អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ជាការសមស្របចំពោះអង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជននៅក្នុងខេត្តបាត់ដំបងភ្លាមៗក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

៩០១.ទាក់ទងទៅនឹងការសម្លាប់នៅក្នុងខេត្តកំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង កណ្តាល និងតាកែវ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មផ្ទាល់របស់ François PONCHAUD ដែលអង្គជំនុំជម្រះតុលាការ

---

[2370] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៤៤ ដល់ ៤៥, ៤៧, ៨០ ដល់ ៨១ និង ៩២។

[2371] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៩៤។

[2372] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) F1/3.1 ៨២ និង ៩២ (ការសំដៅទៅលើពាក្យ“Tuol Sdach”ពុំមែនជាទីកន្លែងនោះទេ ដោយសារកំហុសនៃការបកប្រែភាសា និងប្រតិចារឹក)។ ដោយសារ ទាត់ ធឿន បានឃើញឡានឆ្ពោះទៅមោង(ដែលចេញពីកំពង់ព្រះសំដៅទៅកាន់ភ្នំអធិបតី) និងបានពិចារណាឃើញថា កាលៈទេសៈនៃហេតុការណ៍នេះ(មានកាលបរិច្ឆេទនៃព្រឹត្តិការណ៍ វិធីនៃការបោកបញ្ឆោតជនរងគ្រោះ មធ្យោបាយដឹកជញ្ជូន ចំនួនជនរងគ្រោះ)ស៊ីសង្វាក់ជាមួយនឹងសាក្សីទាំងនោះដែលបានបង្ហាញការសម្លាប់នេះកើតឡើងនៅភ្នំអធិបតី ដូច្នោះ អង្គជំនុំជម្រះពិចារណាឃើញថា សក្ខីកម្មរបស់គាត់ទំនងសំដៅទៅលើហេតុការណ៍សម្លាប់ជាច្រើនដែលបានកើតឡើងនៅភ្នំអធិបតី។

[2373] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៤៥៤ (ត្រឹមឆ្នាំ ១៩៦៣ ញ៉ឹម រស់ គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍ និងបានចូលរួមសមាជបក្សទាំងអស់។ គាត់ក៏ជាលេខាភូមិភាគពាយ័ព្យ ជាអនុប្រធានរដ្ឋ និងបានចូលរួមកិច្ចប្រជុំទៀងទាត់របស់មជ្ឈិមនៅភ្នំពេញ ឬភូមិភាគរបស់គាត់) និងកថាខណ្ឌ ៦៦៣, ៦៦៦, ៦៨៦, និង ៨៣៦ (ក្នុងនាមជាលេខាភូមិភាគពាយ័ព្យ ញ៉ឹម រស់ បានធ្វើជាអធិបតីក្នុងកិច្ចប្រជុំនៅពេលនោះ ការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងទ្រង់ទ្រាយធំ នៅទួលពោធិ៍ជ្រៃដែលនៅក្នុងភូមិភាគពាយ័ព្យ ត្រូវបានបញ្ជា ហើយគាត់បានចូលរួមនៅក្នុងការរៀបចំនោះ)។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ២៤០, ២៤៥។

កំពូលបានដោះស្រាយរួចហើយនោះ[2374] និង សាក្សី ទឹង សុខា ដែលបានផ្ដល់ភស្ដុតាងចចាមអារ៉ាមថា អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានផ្លាស់ទីលំនៅ និងទៅបាត់រហូត និងបានបញ្ជាក់ថា គាត់ពុំបានដឹងថា ពួកគេត្រូវបានសម្លាប់ ឬយ៉ាងណានោះឡើយ[2375]។ ទាក់ទងទៅនឹងចម្លើយក្រៅតុលាការដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនោះ ចម្លើយទាំងនេះពុំបានផ្ដល់ការគាំទ្រគ្រប់គ្រាន់ក្នុងការបញ្ជាក់បន្ថែមហេតុការណ៍ ដែលបានលើកឡើងនៅក្នុងសក្ខីកម្មទាំងពីរនោះទេ។ តាមការកត់សម្គាល់របស់ នួន ជា[2376]ឃើញថា ចម្លើយមួយចំនួនបង្ហាញជាក់ស្ដែងថា ទាហាននៃរបបសាធារណរដ្ឋខ្មែរពុំត្រូវបានសម្លាប់[2377] ចំណែកទាហានដទៃទៀតទំនងជាត្រូវបានសម្លាប់នៅមុនការបញ្ចប់ការប្រយុទ្ធគ្នា[2378]។ ជាការកត់សម្គាល់ ការរៀបរាប់ជាច្រើនបានអះអាងថា មានភាពខុសគ្នារវាងអ្នករដ្ឋការជាន់ខ្ពស់ និងទាហានថ្នាក់ក្រោមតាមរយៈការព្យាយាមយ៉ាងខ្លាំងក្នុងគោលបំណងស្វែងរកអ្នករដ្ឋការជាន់ខ្ពស់[2379]។

៩០២.ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង សមហេតុផលដែលថា យ៉ាងហោចណាស់មានអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចំនួន ២៥០ នាក់ ត្រូវបានសម្លាប់នៅទីនោះ ប្រហែលមួយសប្ដាហ៍ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2380]។

---

[2374] *សូមមើលខាងលើ* កថាខណ្ឌ ៤៨៤។

[2375] ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (ទឹង សុខា) ឯកសារលេខ E1/147.1 ទំព័រ ៦៩។

[2376] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨៥។

[2377] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី គង់ សំអាត ឯកសារលេខ E3/5232 ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00269055 ទំព័រ ៣។ កំណត់ហេតុស្ដាប់ចម្លើយរបស់ យស ផល ឯកសារលេខ E3/4611 ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00418484-5 ទំព័រ ៣ ដល់ ៤។

[2378] កំណត់ហេតុស្ដាប់ចម្លើយរបស់ ពៅ ស៊ីនួន ឯកសារលេខ E3/5545 ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00385096 ទំព័រ ៣។

[2379] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី យស ផល ឯកសារលេខ E3/4611 ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00418484-5 ទំព័រ ៣ ដល់ ៤។ លិខិតរបស់ស្ថានទូតបារាំង កម្មវត្ថុ៖ សក្ខីកម្មរបស់ឧត្ដមសេនីយ៍ត្រី សរ ប៊ុន ឯកសារលេខ E3/2666 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00499666 ទំព័រ ៦។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៩។

[2380] សូមមើលខាងលើ កថាខណ្ឌ ៤៨៧ *ជាអាទិ៍*។

01358489



៩០៣.ទាក់ទងទៅនឹងបញ្ហានៅខេត្តសៀមរាប សាក្សី ប៉េជុយ ជីបសែ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអំពីការសម្លាប់អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេទាំងអស់នៅកំពង់ក្តី ដែលជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសនៅក្នុងខេត្តសៀមរាប[2381]។ ផ្ទុយទៅនឹងការអះអាងរបស់ នួន ជា[2382] ការរៀបរាប់របស់ ជីបសែ បើទោះបីជាពាក្យចចាមអារ៉ាមទាក់ទងទៅនឹងអំពើជាក់ស្តែងនៃការសម្លាប់ក៏ដោយ ក៏មានព័ត៌មានលម្អិត និងខ្លឹមសារស៊ីសង្វាក់គ្នា និងជាក់លាក់គ្រប់គ្រាន់ក្នុងការបញ្ជាក់ពីប្រភពព័ត៌មាន ដែលត្រូវបានពិនិត្យល្អិតល្អន់នៅក្នុងអំឡុងពេលសួរដេញដោល[2383]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ទាក់ទងទៅនឹងការជម្លៀសនៅក្នុងខេត្តសៀមរាប។

៩០៤.សរុបសេចក្តីមក ភស្តុតាងនៃការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅចន្លោះពីចុងខែ មេសា ដល់ខែ ឧសភា ឆ្នាំ ១៩៧៥ មានមូលដ្ឋានខ្សោយ លើកលែងតែពាក់ព័ន្ធទៅនឹងការសម្លាប់នៅក្នុងខេត្តបាត់ដំបង ទួលពោធិ៍ជ្រៃ និងសៀមរាប ព្រមទាំងការសម្លាប់មួយចំនួនទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បញ្ហា ថាតើហេតុការណ៍ទាំងនេះ គឺជាលំនាំស៊ីសង្វាក់គ្នានៃការសម្លាប់ទាហាន និងអ្នករដ្ឋការទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ ដែរ ឬយ៉ាងណានោះ នឹងត្រូវដោះស្រាយដោយផ្អែកលើភស្តុតាងទាំងមូល ដូចខាងក្រោម។

### ៤.ង.១.ឃ.២.ឃ.ការចោទប្រកាន់អំពីការសម្លាប់នៅចុងឆ្នាំ ១៩៧៥ ១៩៧៦ និងក្រោយមកទៀត

---

[2381] ប្រតិចារឹកចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ប៉េជុយ ជីបសែ) ឯកសារលេខ E1/143.1 ទំព័រ ៥៤, ៥៧ ដល់ ៥៨ និង ៧០ ដល់ ៧១។

[2382] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជើងទំព័រ ១៥៣៨។

[2383] ប្រតិចារឹកចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ប៉េជុយ ជីបសែ) ឯកសារលេខ E1/143.1 ទំព័រ ៥៥ (គាត់បានឃើញទាហានកុមារដែលត្រូវបានឃុំឃាំង មុនពេលយកទៅសម្លាប់) ទំព័រ ៥៧ ដល់ ៥៨ (គាត់បានដឹងពីការប្រព្រឹត្តិចំពោះទាហានដែលបានចាប់ខ្លួន និងបានឃើញថា ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានយាមកាមយ៉ាងតឹងតែង) ទំព័រ ៥៩ ដល់ ៦០ និង ៧២ (គាត់បានដឹងអំពីការសម្លាប់ពីខ្មែរក្រហមដទៃទៀត ដែលបានចូលរួមក្នុងការប្រត្តិបត្តិការនោះ និងតាមរយៈមនុស្សបីនាក់ទៀតដែលគាត់ជឿថា ពុំមានហេតុផលដែលត្រូវកុហកគាត់ឡើយ)។ នួន ជា មានឱកាសសួរដេញដោលអំពីភាពអាចជឿទុកចិត្តបានពីប្រភពរបស់សាក្សី និងសាក្សីបានផ្តល់ព័ត៌មានពិស្តារ៖ ប្រតិចារឹកចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ប៉េជុយ ជីបសែ) ឯកសារលេខ E1/144.1 ទំព័រ ១២ និង ១៧ ដល់ ២២។

៩០៥.ក្នុងការផ្តល់ការយល់ឃើញពាក់ព័ន្ធទៅនឹងអត្ថិភាពនៃលំនាំ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងអំពីការសម្លាប់ក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> "នៅចុងឆ្នាំ ១៩៧៥ ១៩៧៦ និងក្រោយមកទៀត តាមរយៈការចាប់ខ្លួន ការសម្លាប់ និង/ឬការធ្វើឱ្យបាត់ខ្លួន ខ្មែរក្រហមបានបន្តកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ រួមទាំងនៅខេត្តបាត់ដំបង ខេត្តកណ្តាល ខេត្តតាកែវ ខេត្តសៀមរាប/ឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តព្រៃវែង ផងដែរ"[2384]។

៩០៦.នួន ជា បានអះអាងថា ភស្តុតាងជាមូលដ្ឋានភាគច្រើនពាក់ព័ន្ធទៅនឹងអំឡុងពេលក្រោយពីការដួលរលំទីក្រុងភ្នំពេញ"មានកាលបរិច្ឆេទនៅក្នុងឆ្នាំ ១៩៧៦ ឬក្រោយៗមកទៀត" ដូច្នេះ ជាការពុំសមហេតុផលដែលប្រើប្រាស់ភស្តុតាងនេះ ដើម្បីបង្ហាញពីអត្ថិភាពនៃគោលនយោបាយក្នុងពេលរំដោះនោះឡើយ[2385]។ នួន ជា បានកត់សម្គាល់បន្ថែមទៀតថា បើទោះបីជាក្របខ័ណ្ឌពេលវេលា និងភូមិសាស្ត្រទូលំទូលាយក៏ដោយ ក៏អង្គជំនុំជម្រះបានបង្ហាញសាក្សីផ្ទាល់តែម្នាក់ប៉ុណ្ណោះដែលបានពិពណ៌នាអំពីការសម្លាប់ ហើយក្រៅពីនេះបានសំអាងទៅលើប្រភពដែលមានតម្លៃភស្តុតាងទាប[2386]។ ខៀវ សំផន បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គហេតុ ដែលបានកើតក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដោយបានលើកឡើងថា ការសំអាងបែបនេះបានរំលោភបំពានលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ (E284) និងសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ[2387]។

៩០៧.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងដោយសមហេតុផល ហើយការអះអាងរបស់ជនជាប់ចោទពុំបានបង្ហាញថា ការយល់ឃើញដូចនេះចោទជាបញ្ហាឡើយ[2388]។

៩០៨.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការសំអាងទៅលើអង្គហេតុដែលបានកើតឡើងក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការបំបែកកិច្ចដំណើរ

---

[2384] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៣ (ជើងទំព័រលុបចោល)។

[2385] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨៦។

[2386] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨៧។

[2387] KHIEU សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៤៤ ដល់ ៦៤៥។

[2388] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨៤ និង ៣៨៩។

01358491



ការនីតិវិធីនៃសំណុំរឿង ០០២ បានកំណត់*បទចោទ* ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ *ដូចជា* បទឧក្រិដ្ឋដែលជនជាប់ចោទទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ទោះជាយ៉ាងណាក្តី ការបំបែកកិច្ចដំណើរការនីតិវិធីនេះពុំបានកម្រិតសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការពិចារណាលើព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្រោយបទចោទដែលអាចជាប់ពាក់ព័ន្ធទៅនឹងការបង្ហាញពីការចោទប្រកាន់ផ្នែកអង្គហេតុ ដែលជាមូលដ្ឋាននៃបទចោទនោះ[2389]។

៩០៩.អំណះអំណាងរបស់ នួន ជា ដែលថា ភស្តុតាងក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃពុំជាប់ពាក់ព័ន្ធនោះត្រូវបដិសេធចោលផងដែរ ដោយសារតុលាការអង្គហេតុសមហេតុផលមួយអាចសំអាងយ៉ាងសមស្របបានទៅលើភស្តុតាងក្រោយព្រឹត្តិការណ៍ណាមួយ ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីគោលនយោបាយមួយដែលមានអត្ថិភាពនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះ។ បញ្ហាសំខាន់គឺ ថាតើអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃសមស្របលើភស្តុតាង ដែរ ឬយ៉ាងណា នៅពេលផ្តល់ការយល់ឃើញដោយផ្អែកលើភស្តុតាងក្រោយព្រឹត្តិការណ៍ជាប់ពាក់ព័ន្ធនោះ បញ្ហានេះអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយដូចខាងក្រោម។

៩១០.ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានថា ការចាប់ខ្លួន ការធ្វើឱ្យបាត់ខ្លួន និង/ឬការសម្លាប់ដែលបានកើតឡើងយ៉ាងហោចណាស់ចំនួន ៩ ទីតាំងពាសពេញផ្ទៃប្រទេស ក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសក្ខីកម្មផ្ទាល់ចំនួន ៣ កំណត់ហេតុស្តាប់ចម្លើយចំនួន ៥ ការរៀបរាប់ក្រៅតុលាការចំនួន ១១ (ដែលប្រាំពីរបានបង្ហាញតាមរយៈកំណត់ហេតុរបស់ Henri LOCARD ឬឯកសារចងក្រងរបស់ François) ឯកសារចំនួន ៣ ប្រភពមកពីរដ្ឋាភិបាលបរទេស និងឯកសារមួយរបស់អង្គការក្រៅរដ្ឋាភិបាល[2390]
។

៩១១.ឌុច និង François PONCHAUD បានផ្តល់សក្ខីកម្មដែលអាចជាប់ពាក់ព័ន្ធយ៉ាងសមហេតុផលទៅនឹងលំនាំទូទាំងប្រទេស។ ឌុច បានពន្យល់ថា ជនរងគ្រោះជាច្រើនដែលមានឈ្មោះនៅក្នុងឯកសារមួយចំនួនដែលបានមកពីមន្ទីរសន្តិសុខ ស-២១ គឺជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ[2391]។ គាត់ក៏បានបញ្ជាក់ផងដែរថា

---

[2389] *សូមមើលខាងលើ* កថាខណ្ឌ ២២៧។

[2390] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៦៤៣ ដល់ ២៦៥២។

[2391] ប្រតិចារឹកចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/51.1 ទំព័រ ៥៤ ដល់ ៥៥។ ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/54.1 ទំព័រ ១២។

ឯកសារមួយដែលយោងនៅក្នុងសក្ខីកម្មរបស់គាត់ ត្រូវបានកែកាលបរិច្ឆេទពីខែមីនា ឆ្នាំ ១៩៧៥ មកជាឆ្នាំ ១៩៧៦ ពីព្រោះនៅក្នុងខែមីនា ឆ្នាំ ១៩៧៥ មន្ទីរ ស-២១ "អត់ទាន់កកើតមន្ទីរនគរបាល ឬក៏យើងមិនទាន់ឈ្នះ លន់ នល់ នៅឡើយទេ ទៅចាប់ទាហានគេយកមកកម្ទេចម៉េច(សំដីដើម)"[2392]។ ចម្លើយរបស់ ឌុច ពុំអាចធ្វើការសន្និដ្ឋានបានថា ដោយសារលំនាំនៃការសម្លាប់មានអត្ថិភាពនៅឆ្នាំ ១៩៧៦ ដូច្នេះគោលនយោបាយនៃការសម្លាប់បានកើតឡើងប្រហែល ឬនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នោះទេ[2393]។ បន្ថែមលើនេះទៀត François PONCHAUD បានពន្យល់ថា បដិវត្តន៍នៅប្រទេសកម្ពុជាបានកើតឡើងជាបីដំណាក់កាល ទីមួយ គឺជា"បដិវត្តន៍ជាតិ"ដែលក្នុងនោះខ្មែរក្រហម"សំដៅបំផ្លាញអ្នកណាដែលធ្វើការបម្រើអាម៉េរិកាំង ឬរបប លន់ នល់ ដែលត្រូវបានចាត់ទុកថា ជាជនក្បត់"[2394]។ ទោះជាយ៉ាងណាក្តី គាត់បានធ្វើការអះអាងបែបនេះពាក់ព័ន្ធទៅនឹងហេតុការណ៍នៅក្នុងខេត្តបាត់ដំបងដែលបានពិភាក្សាខាងលើ ប៉ុន្តែពុំបានផ្តល់ព័ត៌មានអំពីព្រឹត្តិការណ៍ដទៃទៀតឡើយ។ ដូច្នេះ ចម្លើយទូទៅរបស់គាត់ ពុំមានលក្ខណៈសមស្របក្នុងការបង្ហាញអំពីលំនាំទូលំទូលាយមួយនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីទីបី ឡាយ បូនី បានផ្តល់សក្ខីកម្មថា ប្តីរបស់គាត់ដែលជាអតីតអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ក្រោយពេលខ្មែរក្រហមរកឃើញមុខងារពីមុនរបស់គាត់ ដែលគាត់បានលាក់បាំងជាយូរមក[2395]។ ឡាយ បូនី ក៏បានផ្តល់ភស្តុតាងអំពីការបាត់ខ្លួនដោយបង្ខំផងដែរ[2396]។ សក្ខីកម្មនេះពាក់ព័ន្ធទៅនឹងហេតុការណ៍មួយ អាស្រ័យហេតុនេះ មានតម្លៃភស្តុតាងតិចតួចក្នុងការគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលរងការជំទាស់ទាក់ទងទៅនឹងអត្ថិភាពនៃលំនាំទូទៅ និងទូលំទូលាយ។

---

[2392] ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/54.1 ទំព័រ ១២។

[2393] *សូមមើលផងដែរ* សាលក្រម *រឿងក្តី ឌុច* (001-E188) កថាខណ្ឌ ១១៩ ដកស្រង់ដីកាដំណោះស្រាយដែលបានធ្វើវិសោធនកម្មក្នុងសំណុំរឿង ០០១ កថាខណ្ឌ ២១ ("មន្ទីរ ស-២១ បានដំណើរការពេញលេញនៅក្នុងខែ តុលា ឆ្នាំ ១៩៧៥")។

[2394] ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ១៩ ដល់ ២០ និង*សូមមើលផងដែរ* ទំព័រ ២៣ ("ជារបៀបប្រព្រឹត្តរបស់អង្គការគ្រប់ទីកន្លែងដដែល")។

[2395] ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ១២, ១៤ ដល់ ១៥។

[2396] ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ១៤ ដល់ ១៧។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយរបស់ សួង ស៊ីម ឯកសារលេខ E3/4657 ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00349501-2 ទំព័រ ៨ ដល់ ៩ (យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៦៥០ តាមរយៈការយោងទៅលើកថាខណ្ឌ ៦១៨)។

៩១២.កំណត់ហេតុស្តាប់ចម្លើយចំនួន ៤ ដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើនោះ តាមការកត់សម្គាល់របស់ នួន ជា[2397] ពុំមានភស្តុតាងអំពីការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប៉ុន្តែសំដៅទៅលើការចាប់ខ្លួន និងការឃុំខ្លួនដែលភាគច្រើនបានកើតឡើងនៅចុងឆ្នាំ ១៩៧៧ និង ១៩៧៨[2398]។ កំណត់ហេតុស្តាប់ចម្លើយចំនួន ៥ ដែលត្រូវបានធ្វើនៅចំពោះមុខសហព្រះរាជអាជ្ញា មិនមែនសហចៅក្រមស៊ើបអង្កេត បញ្ជាក់បន្ថែមលើការសម្លាប់អ្នកទាំងនោះដែលមាន"ជាប់ពាក់ព័ន្ធទៅនឹងសង្គមចាស់" ដែលបានប្រព្រឹត្តឡើងនៅចុងឆ្នាំ ១៩៧៧ រហូតដល់ ១៩៧៨ ដោយខ្មែរក្រហមដែលមកពីភូមិភាគនិរតី[2399]។

៩១៣.ក្នុងចំណោមចម្លើយក្រៅតុលាការដទៃទៀត គឺជាបទសម្ភាសន៍របស់ អៀង សារី ជាមួយនឹង Elizabeth BECKER ដែលផ្អែកតាមបទសម្ភាសន៍នេះ ថ្នាក់ដឹកនាំបក្សបានព្រមព្រៀងគ្នាស្វែងរក"អ្នកដែលគាំទ្ររបបលន់ នល់" ត្រឹមតែក្នុងឆ្នាំ ១៩៧៦ ប៉ុណ្ណោះ[2400]។ អៀង សារី បានអះអាងថា មុនពេលសម្រេចនេះ ពុំមានបទបញ្ជាបែងចែកប្រជាជនទៅតាមប្រភេទឡើយ ប៉ុន្តែ សោ ភឹម និង រស់ ញឹម(ញឹម រស់) ជាអ្នកធ្វើដំបូងគេបង្អស់ដោយគ្មានការយល់ព្រមពីថ្នាក់ដឹកនាំ[2401]។ ចម្លើយដទៃទៀត ខ្លះដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពាក្យបណ្តឹងរបស់ជនរងគ្រោះ និងកំណត់ហេតុរបស់អ្នកស្រាវជ្រាវពុំមានលក្ខណៈច្បាស់លាស់

---

[2397] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨៧។

[2398] កំណត់ហេតុស្តាប់ចម្លើយរបស់ ចក់ ធឿង ឯកសារលេខ E3/5541 ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00369903 ទំព័រ ៥ (ត្រូវបានចាប់ខ្លួនជាមួយនឹងប្រជាជន ៤៧ នាក់ដទៃទៀតនៅក្នុងឆ្នាំ ១៩៧៨)។ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ហេង ជុយ ឯកសារលេខ E3/5215 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00224048 ទំព័រ ៣ (ឃើញការចាប់ខ្លួន និងមនុស្សត្រូវបានឃុំឃាំងនៅក្នុងឆ្នាំ ១៩៧៨ និងមនុស្សដែលត្រូវបានចាប់ខ្លួន និងបាននាំយកទៅ)។ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ហេង ស្រ៊ុន ឯកសារលេខ E3/1692 ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ERN (ភាសាខ្មែរ) 00218551-2 ២ ដល់ ៣ (ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ ១៩៧៦)។ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ចាន់ សុគាត ឯកសារលេខ E3/5169 ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ៥ ដល់ ៦ ERN (ភាសាខ្មែរ) 00186330-1 (បានឃើញការចាប់ខ្លួនក្នុងឆ្នាំ ១៩៧៧ ដល់ ១៩៧៨)។

[2399] កិច្ចសម្ភាសន៍របស់ Stephen HEDER និង Robert PETIT ជាមួយនឹង សឹង លីម ឯកសារលេខ E3/4649 ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ERN (ភាសាខ្មែរ) 00744607 ទំព័រ ២។

[2400] កិច្ចសម្ភាសន៍របស់ Elizabeth BECKER ជាមួយ អៀង សារី ឯកសារលេខ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00578899-00578900 ទំព័រ ៨ ដល់ ៩។

[2401] កិច្ចសម្ភាសន៍របស់ Elizabeth BECKER ជាមួយ អៀង សារី ឯកសារលេខ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00578899-00578900 ទំព័រ ៨ ដល់ ៩។

ទាក់ទងទៅនឹងប្រភពព័ត៌មាន និងទំនងជាភស្តុតាងចចាមអារ៉ាម[2402] ចំណែកចម្លើយដទៃទៀតពាក់ព័ន្ធទៅនឹងការធ្វើឱ្យបាត់ខ្លួន ប៉ុន្តែមិនមែនជាការសម្លាប់ឡើយ[2403]។ ការរៀបរាប់មួយចំនួនទំនងជាបញ្ជាក់ថា ខ្មែរក្រហមបានបែងចែករវាងអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ជាមួយនឹងទាហានថ្នាក់ក្រោម ឬថា ទាហានដែលត្រូវបានចាប់ខ្លួនទាំងអស់នោះចុងក្រោយពុំត្រូវបានសម្លាប់[2404]ឡើយ។ ចុងក្រោយ ដូច នួន ជា បានកត់សម្គាល់[2405] ចម្លើយភាគច្រើនសំដៅលើព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងឆ្នាំ ១៩៧៦ ឬក្រោយៗមកទៀត[2406]

---

[2402] កំណត់ហេតុរបស់ Henri LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្តីពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00233387 ទំព័រ ៦ ERN (ភាសាខ្មែរ) 00233406-7 ទំព័រ ២៥ ដល់ ២៦។ ពាក្យបណ្តឹងជនរងគ្រោះ អ៊ុន វឿន ឯកសារលេខ E3/5395 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00479581 ទំព័រ ៧។

[2403] កំណត់ហេតុរបស់ Henri LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្តីពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00233415-6 ទំព័រ ៣៤ ដល់ ៣៥។

[2404] កំណត់ហេតុរបស់ Henri LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្តីពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00233387 ទំព័រ ៦ និង ERN (ភាសាខ្មែរ) 00233406 ទំព័រ ២៥។ សក្ខីកម្មរបស់ជនភៀសខ្លួនដែលប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836225-6 ទំព័រ ១៤៨ ដល់ ១៤៩ និង ERN (ភាសាខ្មែរ) 00836267-8 ទំព័រ ១៨៩ ដល់ ១៩០។

[2405] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៨៦។

[2406] កិច្ចសម្ភាសន៍របស់ Elizabeth BECKER ជាមួយ អៀង សារី ឯកសារលេខ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ) 00578899-00578900 ទំព័រ ៨ ដល់ ៩។ កំណត់ហេតុរបស់ Henri LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្តីពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00233403 ទំព័រ ២២ និង ERN (ភាសាខ្មែរ) 00233406 ទំព័រ ២៥។ សក្ខីកម្មរបស់ជនភៀសខ្លួនដែលបានធ្វើឡើងនៅក្នុងទីក្រុងប៉ារីស និងប្រទេសថៃ និងត្រូវបានប្រមូលដោយ François PONCHAUD ឯកសារលេខ E3/5776 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00840922-3 ទំព័រ ២៧៥ ដល់ ២៧៦។ សក្ខីកម្មរបស់ជនភៀសខ្លួនដែលបានប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836267-8 ទំព័រ ១៨៩ ដល់ ១៩០ ។ ពាក្យបណ្តឹងជនរងគ្រោះ ស៊ឹម ហ៊ីប ឯកសារលេខ E3/5355 ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00462347-8 ទំព័រ ៧ ដល់ ៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាំង រី ឯកសារលេខ E3/4919 ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00545275-6 ទំព័រ ១ ដល់ ២។

ដែលមានតែការរៀបរាប់បីប៉ុណ្ណោះដែលសន្មតថា សំដៅទៅលើព្រឹត្តិការណ៍ក្នុងឆ្នាំ ១៩៧៥[2407] និងការរៀបរាប់មួយ ពុំមានកាលបរិច្ឆេទជាក់លាក់អំពីព្រឹត្តិការណ៍ឡើយ[2408]។

៩១៤.សរុបសេចក្ដីមក ភស្តុតាងពាក់ព័ន្ធទៅនឹងការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅចុងឆ្នាំ ១៩៧៥ និងក្រោយៗមកទៀត មានមូលដ្ឋានខ្សោយ។ ដំបូង ការរៀបរាប់ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើជាញឹកញាប់ខ្វះព័ត៌មានលម្អិត និងភាគច្រើនជាឯកសារក្រៅតុលាការ ដែលភាពជឿជាក់ និងទុកចិត្តបាននៃឯកសារនេះពុំត្រូវបានដោះស្រាយជាក់លាក់ឡើយ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់អំពីមូលហេតុដែលនាំឱ្យមានការសន្និដ្ឋានបានថា ភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើងយ៉ាងយូរក្រោយខែ មេសា ឆ្នាំ ១៩៧៥ បានបង្ហាញថា គោលនយោបាយចាស់បានបន្តនិរន្តរភាពរហូត ជាជាងការបង្កើតគោលនយោបាយថ្មី។

## ៤.ង.១.ឃ.៣.លំនាំទាក់ទងទៅនឹងបែបបទសម្រាប់ការកំណត់អត្តសញ្ញាណទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងវាសនាចុងក្រោយរបស់ពួកគេ

៩១៥.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "មានលំនាំច្បាស់លាស់"នៅទូទាំងប្រទេសអំពីការកំណត់អត្តសញ្ញាណទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[2409]។ យោងតាមអង្គជំនុំជម្រះសាលាដំបូង អ្នកទាំងនេះ ដំបូង ត្រូវបានគេបញ្ចុះបញ្ចូលតាមរយៈការបោកបញ្ឆោត និងភូតកុហកអោយបង្ហាញអត្តសញ្ញាណរបស់ខ្លួន បន្ទាប់មក"ត្រូវចាប់ខ្លួន សម្លាប់ ឬធ្វើឱ្យបាត់ខ្លួន"[2410]។

---

[2407] កំណត់ហេតុរបស់ Henri LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្ដីពីបណ្ដាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៧ ERN (ភាសាខ្មែរ) 00233387 ទំព័រ ៦ និង ERN (ភាសាខ្មែរ) 00233415-6 ទំព័រ ៣៤ ដល់ ៣៥។ សក្ខីកម្មរបស់ជនភៀសខ្លួនដែលប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836225-6 ទំព័រ ១៤៨ ដល់ ១៤៩។

[2408] ពាក្យបណ្ដឹងរបស់ អ៊ុន វឿន ឯកសារលេខ E3/5395 ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ៧ ERN (ភាសាខ្មែរ) 00479581។

[2409] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៤។

[2410] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៤។

៩១៦.នួន ជា បានអះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថា មានលំនាំស៊ីសង្វាក់គ្នានៅទូទាំងប្រទេសឡើយ[2411]។

៩១៧.សហព្រះរាជអាជ្ញាបានលើកឡើងថា នួន ជា ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស និងក៏ពុំបានលើកបង្ហាញភស្តុតាងណាមួយ ដែលមានយោងនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ[2412]។

៩១៨.ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាញឹកញាប់ត្រូវបានគេបញ្ចុះបញ្ចូលឱ្យបង្ហាញខ្លួន ពិតជាមានមូលដ្ឋានគាំទ្រតាមរយៈ*ក្នុងចំណោមនោះ* ការរៀបរាប់មួយចំនួនដែលអង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យខាងលើ[2413] រួមទាំងសក្ខីកម្មផ្ទាល់របស់ Philip SHORT Stephen HEDER និង François PONCHAUD[2414]ផងដែរ។ អាស្រ័យហេតុនេះ ការយល់ឃើញនេះត្រូវបានគាំទ្រដោយភស្តុតាងគ្រប់គ្រាន់ដែលអាចជឿទុកចិត្តបាន។

៩១៩.អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានកំណត់អត្តសញ្ញាណបែបនោះ ត្រូវបាននាំយកទៅសម្លាប់ ឬត្រូវបានធ្វើឱ្យបាត់ខ្លួន និងថា មានការប្រើប្រាស់វិធីសាស្ត្រដូចគ្នានៃការកំណត់អត្តសញ្ញាណនៅទូទាំងប្រទេស។ ដើម្បីគាំទ្រដល់ការយល់ឃើញរបស់ខ្លួន

---

[2411] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ៥៩៨ ដល់ ៥៩៩។

[2412] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨៩។

[2413] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៤៤ ដល់ ៤៥, ៨០ ដល់ ៨១។ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ស៊ុំ ជា) ឯកសារលេខ E1/140.1 ទំព័រ ១៣ ដល់ ១៤ (យោងទៅលើកំណត់ហេតុស្ដាប់ចម្លើយរបស់ ស៊ុំ ជា ឯកសារលេខ E3/3961 ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00205057-8 ទំព័រ ២ ដល់ ៣) ១៨, ២៥ ដល់ ២៦, ៣២, ៤៦, ៨៦។ ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ (ឡាយ បូនី) ឯកសារលេខ E1/138.1 ទំព័រ ២៤ ដល់ ២៥ ERN (ភាសាខ្មែរ) 00856250-1។ កំណត់ហេតុស្ដាប់ចម្លើយរបស់ សំ សិទ្ធី ឯកសារលេខ E3/5201 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00212121 ទំព័រ ៣។ កំណត់ហេតុរបស់ Henri LOCARD៖ *កំណត់ហេតុស្រាវជ្រាវស្ដីពីបណ្ណាញពន្ធនាគារកម្ពុជាប្រជាធិបតេយ្យ* ឯកសារលេខ E3/2071 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00233384-5 ទំព័រ ៣ ដល់ ៤។ សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសារលេខ E3/4590 ERN (ភាសាខ្មែរ) 00836225-1 ទំព័រ ១៤៨ ដល់ ១៤៩។

[2414] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៤ (យោងទៅលើ Philip SHORT and François PONCHAUD)។ *សូមមើលផងដែរ* កថាខណ្ឌ ៨៣០ ជើងទំព័រ ២៦១៩ (យោងទៅលើ Philip SHORT and François PONCHAUD)។

អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា និងអ្នកជំនាញ Philip SHORT និង David CHANDLER និងឯកសារក្រៅតុលាការចំនួន ២[2415]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា បានផ្តល់សក្ខីកម្មថា អ្នកដែលមានការពាក់ព័ន្ធជាមួយនឹងរបបសាធារណរដ្ឋខ្មែរត្រូវបានឃុំខ្លួន ប៉ុន្តែពុំបានលើកឡើងថា ពួកគាត់ត្រូវបានសម្លាប់ឡើយ[2416]។ ដោយហេតុថា ជុំ សុខា ខ្លួនឯង គឺជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ទើបគាត់ត្រូវបានចាត់ឱ្យទៅធ្វើស្រែចម្ការ[2417]។ គាត់បានផ្តល់សក្ខីកម្មថា ឪពុកបង្កើត និងឪពុកមារបស់គាត់ដែលជាទាហាននៃរបបសាធារណរដ្ឋខ្មែរដែរនោះក៏ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងបង្ខំឱ្យធ្វើការជាទម្ងន់នៅក្នុងមន្ទីរសន្តិសុខ ដែលពួកគាត់ពុំដែលឃើញត្រឡប់មកវិញឡើយ[2418]។ ដូច្នេះ ការរៀបរាប់នេះបង្ហាញពីការចាប់ខ្លួន ការឃុំខ្លួន និងការធ្វើឱ្យបាត់ខ្លួន ប៉ុន្តែពុំបានបង្ហាញអំពីកាលៈទេសៈដែលនាំទៅដល់ការស្លាប់សាច់ញាតិរបស់គាត់ឡើយ។

៩២០.ចំពោះអ្នកជំនាញ Philip SHORT អង្គជំនុំជម្រះតុលាការកំពូលរំឭកថា គាត់ពុំបានផ្តល់ការគាំទ្រជាក់លាក់គ្រប់គ្រាន់ដល់ការអះអាងរបស់គាត់ដែលថា ការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរបានកើតឡើងនៅទូទាំងប្រទេស[2419] ដូច្នេះ សក្ខីកម្មរបស់គាត់ត្រង់ចំណុចនេះត្រឹមតែទទួលបានទម្ងន់ក្នុងកម្រិតតិចតួចប៉ុណ្ណោះ។ ពាក់ព័ន្ធទៅនឹងអ្នកជំនាញ David CHANDLER ដែលបានអះអាងថា នៅក្នុងដំណាក់កាលដំបូងនៃរបបខ្មែរក្រហម អ្នកដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងរបបសាធារណរដ្ឋខ្មែរនឹងក្លាយជាគោលដៅនៃ"ការសងសឹកមួយប្រភេទ" ដែលពាក់ព័ន្ធទៅនឹងករណីសម្លាប់ជាច្រើន[2420]។ គាត់បានបន្ថែមទៀតថា នេះបាន"បង្ហាញយ៉ាងពេញលេញ"តាមរយៈកិច្ចសម្ភាសន៍ដែលគាត់បានធ្វើឡើង តាមរយៈរបាយការណ៍របស់ជន

---

[2415] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៤ រួមបញ្ចូលជើងទំព័រភ្ជាប់ជាមួយ។

[2416] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៦៥៥ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៥៧។

[2417] ប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៦៣ ដល់ ៦៤ និង ៧៥។

[2418] ប្រតិចារឹកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ (ជុំ សុខា) ឯកសារលេខ E1/136.1 ទំព័រ ៥៥ ដល់ ៥៧។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយរបស់ ជុំ សុខា ឯកសារលេខ E3/5788 ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00373217-8 ទំព័រ ៤ ដល់ ៥។

[2419] *សូមមើលខាងលើ* កថាខណ្ឌ ៨៨១ ដល់ ៨៨៨។

[2420] ប្រតិចារឹកចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ឯកសារលេខ E1/93.1 ទំព័រ ៧ ដល់ ៨។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ឯកសារលេខ E1/91.1ទំព័រ ១៩។

ភៀសខ្លួន និងឯកសារដទៃទៀត[2421]។ ទាក់ទងទៅនឹងមតិយោបល់របស់ David CHANDLER ដោយផ្អែកលើប្រភពព័ត៌មានដែលជាផ្នែកនៃកំណត់ត្រាជាភស្តុតាងនោះឃើញថា ជាចម្បង ពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាដែលថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរពិតជាត្រូវបានសម្លាប់នោះឡើយ ដោយហេតុថា នេះជាតួនាទីរបស់តុលាការ មិនមែនជាតួនាទីរបស់អ្នកជំនាញនោះទេ ក្នុងការធ្វើសេចក្ដីសន្និដ្ឋានអង្គច្បាប់ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានផ្ដល់នោះ។ ក្នុងករណីដែលសេចក្ដីសន្និដ្ឋានរបស់ David CHANDLER បានផ្អែកលើប្រភពព័ត៌មានដែលពុំមែនជាផ្នែកនៃកំណត់ត្រាជាភស្តុតាង អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្ដីសន្និដ្ឋាននេះចាត់ជាពាក្យចចាមអារ៉ាមទូទៅ ដោយសារគាត់ទំនងជាបានដឹងតាមរយៈការសន្ទនាជាមួយបុគ្គលផ្សេងៗ ដែលពុំមែនជាបទពិសោធន៍ផ្ទាល់ខ្លួន និងដោយសារគាត់ពុំបានផ្ដល់ព័ត៌មានលម្អិតគ្រប់គ្រាន់ទាក់ទងទៅនឹងហេតុការណ៍នៃការសម្លាប់ ដែលគាត់បានលើកឡើងនោះឡើយ។

៩២១.ក្នុងការគាំទ្រដល់ការយល់ឃើញរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើសេចក្ដីសង្ខេបនៃការរៀបរាប់របស់ជនភៀសខ្លួន និងកំណត់ត្រាបទសម្ភាសន៍របស់ François PONCHAUD។ អត្ថបទពាក់ព័ន្ធនៃសេចក្ដីសង្ខេបនោះបង្ហាញថា “ជនភៀសខ្លួនទាំងអស់ផ្ដល់ចម្លើយដូចគ្នាថា ទាហាន និងអ្នករដ្ឋការស៊ីវិលទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេ*ធ្វើឱ្យបាត់ខ្លួន*”[2422]។ តម្លៃជាភស្តុតាងនៃភស្តុតាងចចាមអារ៉ាមអនាមិក មានកម្រិតទាប។ François PONCHAUD ដែលជាអ្នកចងក្រងសេចក្ដីសង្ខេបនេះ បានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា មានមនុស្សជាច្រើនបានរៀបរាប់ហេតុការណ៍នៃការសម្លាប់អ្នករដ្ឋការស៊ីវិល និងយោធានៃរបបសាធារណរដ្ឋខ្មែរដែលគួរឱ្យជឿបាន[2423]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសំអាងលើភស្តុតាងនេះ និងពិចារណាឃើញថា ភាគីត្រូវបានផ្ដល់ឱកាសគ្រប់គ្រាន់ក្នុងការសួរដេញដោល François PONCHAUD យ៉ាងទូលំទូលាយ រួមទាំងលើបញ្ហាពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការធ្វើបទសម្ភាសន៍របស់គាត់[2424]។ ទោះជាយ៉ាងណាក្ដី ចម្លើយនេះត្រឹមតែ

---

[2421] ប្រតិចារឹកចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ (David CHANDLER) ឯកសារលេខ E1/93.1 ទំព័រ ៧។

[2422] សក្ខីកម្មរបស់ជនភៀសខ្លួនប្រមូលដោយ François PONCHAUD ឯកសាលេខ E3/4590 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00836085 ទំព័រ ៨។

[2423] កំណត់ហេតុស្ដាប់ចម្លើយរបស់ François PONCHAUD ឯកសារលេខ E3/370 ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ទំព័រ ១៤ ដល់ ១៥ ERN (ភាសាខ្មែរ) 00286614-5។

[2424] *សូមមើលឧ.* ប្រតិចារឹកចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/178.1 ទំព័រ ៥៨ ដល់ ៥៩, ៧១ ដល់ ៧២។ ប្រតិចារឹកចុះថ្ងៃទី ១០ ខែ មេសា (François PONCHAUD) ឯកសារលេខ E1/179.1 ទំព័រ ៥២, ៧៨

ទទួលបានតម្លៃជាភស្តុតាងក្នុងកម្រិតតិចតួចប៉ុណ្ណោះ ដោយសារអត្តសញ្ញាណរបស់បុគ្គលភាគច្រើនដែល François PONCHAUD បានសម្ភាសន៍នោះ ពុំត្រូវបានគេស្គាល់ និងពុំបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៩២២.សរុបសេចក្ដីមក បើទោះបីជាមានភស្តុតាងបញ្ជាក់ថា ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណយ៉ាងណាក៏ដោយ ក៏មានតែភស្តុតាងដែលមានមូលដ្ឋានខ្សោយប៉ុណ្ណោះដែលបង្ហាញថា អ្នកទាំងនេះក្រោយមកត្រូវបានសម្លាប់។ ជាពិសេស មានតែដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សុខា ម្នាក់ជាសាក្សីអង្គហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង បានរួចជីវិត បើទោះបីគាត់ជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរម្នាក់ក៏ដោយ។ ជុំ សុខា បានផ្ដល់សក្ខីកម្មអំពីការស្លាប់សាច់ញាតិពីរនាក់របស់គាត់ដែលបានបាត់បង់ជីវិតក្រោមលក្ខខណ្ឌដែលពុំអាចដឹងបាន។ បន្ថែមលើនេះ ឯកសារក្រៅតុលាការភាគច្រើនជាភស្តុតាងចចាមអារ៉ាមទូទៅ ហើយសក្ខីកម្មរបស់អ្នកជំនាញគ្មានការបញ្ជាក់ច្បាស់លាស់គាំទ្រទាក់ទងទៅនឹងប្រភពជាក់លាក់ និងអាចផ្ទៀងផ្ទាត់បាននៃចំណេះដឹងដែលជាមូលដ្ឋានគាំទ្រមតិយោបល់របស់អ្នកជំនាញឡើយ។

## ៤.ង.១.ឃ.៤.សេចក្ដីថ្លែងការណ៍ សេចក្ដីប្រកាស និងបទបញ្ជារបស់ ប.ក.ក.

៩២៣.ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលនយោបាយ“កំណត់គោលដៅសម្រាប់ការចាប់ខ្លួន ការសម្លាប់ និង/ឬការធ្វើឱ្យបាត់ខ្លួនសមាសភាពទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ”[2425]បានបន្តពេញមួយរយៈកាលនៃសំណុំរឿង ០០២/០១ បានផ្អែកជាមូលដ្ឋានទៅលើភស្តុតាងដែលពាក់ព័ន្ធទៅនឹងគោលជំហរ និងការណែនាំរបស់ ប.ក.ក. ជាពិសេស ពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តចំពោះ “ខ្មាំង”[2426]។ ជនជាប់ចោទបានលើកទឡ្ហីករណ៍មួយចំនួននៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងបញ្ហានេះ និងពាក់ព័ន្ធ

---

ដល់ ៨០។ ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ (François PONCHAUD) ឯកសារលេខ E1/180.1 ទំព័រ ៥០ ដល់ ៥១។

[2425] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨២៩។

[2426] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៥ ដល់ ៨១៧។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៩ ដល់ ៨២៩។

01358500



ទៅនឹងការយល់ឃើញដែលថា នៅមុនឆ្នាំ ១៩៧៥ មានគោលនយោបាយបែបនេះ (ការយល់ឃើញនេះ ពុំបានផ្អែកជាមូលដ្ឋានលើលំនាំនៃការសម្លាប់ដែលបានពិភាក្សានៅក្នុងផ្នែកខាងលើ)។

### ៤.ង.១.ឃ.៤.ក.មនោគមវិជ្ជារបស់ ប.ក.ក. និងការពិភាក្សាអំពី"បទពិសោធន៍នៅឧដុង្គ"

៩២៤.អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សេចក្ដីសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅ *ក្នុងចំណោមនោះ* ដោយផ្អែកទៅលើការយល់ឃើញដែលថា "នៅមុនឆ្នាំ ១៩៧៥ ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់អត្តសញ្ញាណថា ជាខ្មាំងដ៏សំខាន់"[2427]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា យ៉ាងហោចណាស់រហូតដល់ឆ្នាំ ១៩៧៦ ថ្នាក់ដឹកនាំបក្សបានចាត់ទុកនាយទាហាននៃរបបសាធារណរដ្ឋខ្មែរជា"ខ្មាំងចម្បង" និងបានព្យាយាម"លុបបំបាត់*កាកសំណល់ទាំងអស់*នៃអតីតពួកសក្តិភូមិ ចក្រពត្តិ និងមូលធននិយម ចេញពីរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល"[2428]។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា មេដឹកនាំបក្សបានពិភាក្សាអំពី"បទពិសោធន៍នៅឧដុង្គ"ក្នុងកិច្ចប្រជុំមួយក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងបានលើកឡើងថា ការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាផ្នែកនៃ"បទពិសោធន៍"ដែលត្រូវបានពិភាក្សានៅក្នុងពេលនោះ[2429]។

៩២៥.នួន ជា បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹង"ទស្សនវិជ្ជាបក្ស" និងសេចក្ដីណែនាំអំពីអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺ"មានកំហុស និងពុំជាប់ពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ចំពោះមុខឡើយ"[2430]។ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃភស្តុតាង និងប្រើប្រាស់ភស្តុតាងតាមចំណង់ចិត្ត និងថា "ការយល់ឃើញទូទៅ"អំពីទ្រឹស្ដីអរូបិយស្ដីពីវណ្ណៈ មិនចាត់ជាគោលនយោបាយសម្លាប់បានឡើយ ប៉ុន្តែជាគោលនយោបាយដែលមានគោលដៅចម្បងសម្រាប់ការអប់រំកែប្រែផ្នែក

---

[2427] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១៨។

[2428] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៥ (ដើងទំព័រលុបចោល)។

[2429] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៦។

[2430] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥១។

01358501



នយោបាយ[2431]។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន ក៏បានជំទាស់ទៅនឹងភាពជាប់ពាក់ព័ន្ធ និងតម្លៃជាភស្តុតាងនៃភស្តុតាងមូលដ្ឋានផងដែរ[2432]។

៩២៦.ទាក់ទងទៅនឹងការយោងទៅលើការប្រើប្រាស់ពាក្យថា "ខ្មាំង"នៅមុនពេលដួលរលំទីក្រុងភ្នំពេញ នួន ជា និង ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលមិនអាចប្រើប្រាស់ការកំណត់បែបនេះក្នុងបរិបទយ៉ាងសមហេតុផលសម្រាប់យុទ្ធសាស្ត្រស្របច្បាប់របស់យោធា[2433]។

៩២៧.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងត្រឹមត្រូវពីចរិតនៃភស្តុតាង និងថា នួន ជា ពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល ឬនាំឱ្យមោឃៈសាលក្រមបាន ឬនាំឱ្យមានភាពមិនយុត្តិធម៌នោះឡើយ[2434]។

៩២៨.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់គ្រប់គ្រាន់អំពីរបៀបដែលខ្លួនបានវាយតម្លៃភស្តុតាងទាក់ទងទៅនឹងមនោគមវិជ្ជាបក្ស និងជាពិសេសអំពីមូលហេតុអ្វីខ្លះដែលអង្គជំនុំជម្រះពុំបានពិចារណាអំពីទិដ្ឋភាពដោះបន្ទុកដែលមានសក្តានុពលនោះ។ ជាការកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញ ថាតើខ្លួនអាចសន្និដ្ឋានបានយ៉ាងដូចម្តេចអំពីគោលការណ៍អរូបិយនៃទ្រឹស្តីស្តីពីវណ្ណៈ លទ្ធិកុម្មុយនីស្ត និងការតស៊ូប្រឆាំងពួកចក្រពត្តិដែលថា មានគោលនយោបាយច្បាស់លាស់ក្នុងការកំណត់គោលដៅសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

៩២៩.តាមការពិនិត្យភស្តុតាងបានបង្ហាញឱ្យឃើញបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់ធ្ងន់ហួស។ ឧទាហរណ៍ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានចាត់ទុកថា ជា"ខ្មាំងចម្បង"[2435] ប៉ុន្តែ ដូចការកត់សម្គាល់របស់ នួន ជា ដែរ[2436] ភស្តុតាងជាមូលដ្ឋានផ្តោតទៅលើការចោទប្រកាន់ជាទូទៅប្រឆាំងនឹង"បរិវារ"របស់ពួកសក្តិភូមិ មូលធន និង/ឬពួកចក្រពត្តិ និងភាព

---

[2431] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥៤ ដល់ ៥៥៨។

[2432] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២០៧ ដល់ ២១៧, ៤២៤ ដល់ ៤២៦, ៤២៨។ *សូមមើលផងដែរ* កថាខណ្ឌ ១៥៩។

[2433] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៤៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៦៦។

[2434] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦៣ ដល់ ៣៦៥។

[2435] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៥។

[2436] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥៧។

ចាំបាច់ក្នុងការទប់ស្កាត់សត្រូវផ្ទៃក្នុង[2437]។ សាក្សីម្នាក់ដែលជាអ្នកស្វែងរក“អ្នកដែលនៅសេសសល់ពីរបបមុន” បានបញ្ជាក់ថា ទិសដៅសំខាន់នៃការអប់រំផ្នែកមនោគមវិជ្ជា គឺការកម្ចាត់“ខ្សែខ្មាំង”មិនមែនជាបុគ្គល និង“កេរដំណែលរបស់វណ្ណៈសក្តិភូមិ”[2438]។ អាស្រ័យហេតុនេះ អាចជឿជាក់បានថា គោលដៅរបស់ខ្មែរក្រហម គឺត្រូវបំបាត់ប្រព័ន្ធអំណាចចាស់ និងបណ្តុះមនោគមវិជ្ជាក្នុងសង្គម ដោយពុំចាំបាច់ប្រើប្រាស់គោលនយោបាយសម្លាប់មិនរើសមុខរាល់បុគ្គលទាំងឡាយដែលពាក់ព័ន្ធទៅនឹងរបបមុននោះឡើយ។ នៅក្នុងសក្ខីកម្មរបស់គាត់ ឌុច បានអះអាងថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជា“ខ្មាំងចម្បង”[2439] ប៉ុន្តែបានបញ្ជាក់ផងដែរថា អ្នកទាំងនោះត្រូវបានបែងចែកជាបីប្រភេទ និងមានតែអ្នកនៅក្នុងប្រភេទទីមួយប៉ុណ្ណោះទេដែល“ត្រូវបានកម្ទេចដោយសម្ងាត់”[2440]។ បន្ថែមលើនេះទៀត ផ្អែកតាម ឌុច បញ្ហានេះកើតមាននៅក្រោយឆ្នាំ ១៩៧៥។

៩៣០.ភស្តុតាងដទៃទៀត មានអត្ថិភាពនៅមុនការជួលរលំទីក្រុងភ្នំពេញនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៥[2441]។ ទាក់ទងទៅនឹងការប្រើប្រាស់ពាក្យ“ខ្មាំង”នៅក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ពីមូលហេតុ ដែលពាក្យ“ខ្មាំង”នៅក្នុងបរិបទនេះពុំបានយោងតែមួយមុខគត់ទៅលើការកំណត់គោលដៅលើទាហាន ដូចបានអះអាងដោយ នួន ជា និង ខៀវ សំផន ឡើយ[2442]។ ទោះជាយ៉ាងណាក្តី ចម្លើយបានបញ្ជាក់ថា ក្នុងគំនិតរបស់ថ្នាក់ដឹកនាំបក្ស “មហាជន [...] ស្អប់ លន់ នល់ យ៉ាងខ្លាំង” និង“ប្រជាជន និងកងទ័ពបដិវត្តន៍ មានការប្រុងប្រយ័ត្នចំពោះចរិតពិតនៃពួកក្បត់ ចក្រពត្តិអាម៉េរិក

---

[2437] សៀវភៅកំណត់ហេតុរបស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/925 ឆ្នាំ ១៩៧៦ ដល់ ១៩៧៩ គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00003769 ទំព័រ ១០, ERN (ភាសាខ្មែរ) 00003872 ទំព័រ ១១៣ (យោងទៅលើកំណត់ហេតុនៃកិច្ចប្រជុំផ្ទៃក្នុងធ្វើឡើងនៅក្នុងក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យក្នុងខែ ឧសភា និង កក្កដា ឆ្នាំ ១៩៧៦)។ បទសម្ភាសន៍របស់ អៀ ម៉េងទ្រី និង សូត្រ័ក្ត លឿង ជាមួយនឹង ខៀវ សំផន និង នួន ជា ឯកសារលេខ E3/108 ថ្ងៃទី ០៩ ដល់ ១១ ខែ មិថុនា ឆ្នាំ ២០០៦ ERN (ភាសាខ្មែរ) 00347039 ទំព័រ ៩ (យោងទៅលើ“ការសម្លាប់ខ្មាំងផ្ទៃក្នុង” គឺថា “នៅក្នុងចំណោមកម្មាភិបាលខ្មែរក្រហម”)។

[2438] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១២ (សួង ស៊ីគឿន) ឯកសារលេខ E1/102.1 ទំព័រ ៣៨។

[2439] ប្រតិចារឹកចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) ឯកសារលេខ E1/52.1 ទំព័រ ២០។

[2440] ប្រតិចារឹកជំនុំជម្រះក្នុងសំណុំរឿង ០០១ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច) (សំណុំរឿង ០០១) ឯកសារលេខ E3/345 ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00328656 ទំព័រ ៩ (យោងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៧៥)។

[2441] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៦៨ យោងទៅលើកថាខណ្ឌ ១២១ ដល់ ១២៣។

[2442] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៤៩។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៦៦។

ឈ្លានពានទេសានុពន្ធនិយម និងសាហាវឃោរឃៅ និងបរិវាររបស់ពួកវាដែលជាសត្រូវរបស់ប្រជាជនយើងគ្រប់គ្នា"ដែលជាសត្រូវរបស់ប្រជាជន[2443]។

៩៣១.នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ខុសពីការលើកឡើងរបស់គាត់ដែលបានធ្វើឡើងនៅក្នុងតុលាការដែលអង្គជំនុំជម្រះបានសំអាងទៅលើនោះ[2444]។ ការលើកឡើងរបស់ នួន ជា មានភាពត្រឹមត្រូវថា សក្ខីកម្មរបស់គាត់បានសំដៅលើ"ការកម្ទេច"ដែលប្រើប្រាស់តែក្នុងករណីពិសេសប៉ុណ្ណោះ បន្ទាប់ពីពុំអាចរកជម្រើសអ្វីផ្សេងបាននោះ[2445]។ ទោះជាយ៉ាងណាក្ដី បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងប្រហែលជាបានកែប្រែសក្ខីកម្មរបស់ នួន ជា ក៏ដោយ ក៏ពុំមែនលើកខុសពីខ្លឹមសារមូលដ្ឋានដែលថា គោលការណ៍កុម្មុយនីស្ដដែល ប.ក.ក. ប្រកាន់ខ្ជាប់នោះ កំណត់"ឱ្យលុបបំបាត់អ្នកទាំងឡាយណាដែល [...] ពុំអាចអប់រំកែប្រែបាន"[2446]។

៩៣២.ទាក់ទងទៅនឹងកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងកម្មវិធីនៃកិច្ចប្រជុំ អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការយល់ឃើញរបស់ខ្លួនដែលថា ជាការពុំសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការសម្លាប់នៅឧដុង្គត្រូវបានពិភាក្សានៅក្នុងពេលប្រជុំនោះ ដោយហេតុថា អត្ថិភាពនៃការសម្លាប់ពុំត្រូវបានបង្ហាញដោយសមហេតុផលឡើយ[2447]។

៩៣៣.សរុបសេចក្ដីមក ភស្តុតាងអំពីមនោគមវិជ្ជារបស់ ប.ក.ក. អាចអនុញ្ញាតឱ្យតុលាការអង្គហេតុសមហេតុផលមួយផ្ដល់ការសន្និដ្ឋានបានថា មាគ៌ាបក្សដូចបានពិពណ៌នា និងប្រសិនបើផ្សព្វផ្សាយតាមរយៈសេចក្ដីថ្លែងការណ៍ជាសាធារណៈ និងវគ្គបណ្ដុះបណ្ដាលនានានោះ អាចធ្វើជាមូលដ្ឋាននៃមនោគមវិជ្ជាសម្រាប់វិធាន

---

[2443] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៦៩ យោងទៅលើ*ក្នុងចំណោមនោះ*ប្រតិចារិកនៃកិច្ចសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/3198 គ្មានកាលបរិច្ឆេទ ERN (ភាសាខ្មែរ) 00807466-7 ទំព័រ ១២ ដល់ ១៣។ សុន្ទរកថារបស់ អៀង សារី នៅមហាសន្និបាតអង្គការសហប្រជាជាតិសម័យប្រជុំលើកទី ៣២ ឯកសារលេខ E3/1586 ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ កថាខណ្ឌ ៤៧ ERN (ភាសាខ្មែរ) 00291026។

[2444] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥៤(យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៥ (ដកស្រង់ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ឯកសារលេខ E1/21.1 ទំព័រ ២៧ និង ៣០)។

[2445] ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ឯកសារលេខ E1/21.1 ទំព័រ ២៧ ដល់ ៣០។

[2446] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៨១៥។

[2447] *សូមមើល* កថាខណ្ឌ ៨៨៤។

ការផ្សេងៗប្រឆាំងនឹងខ្មាំងដែលត្រូវបានកំណត់ទុកជាមុន រួមទាំងការលុបបំបាត់ផ្នែករូបកាយផងដែរ។ បញ្ហាថាតើជំហរផ្នែកមនោគមនវិជ្ជាប្រឆាំងនឹង"ខ្មាំង" នាំទៅរកការបង្កើតនូវគោលនយោបាយមួយដែលមានបំណងសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះ ដែរ ឬយ៉ាងណានោះ នឹងត្រូវដោះស្រាយដូចខាងក្រោមដោយផ្អែកលើភស្តុតាងទាំងមូល។

## ៤.ង.១.ឃ.៤.ខ.សេចក្តីណែនាំរបស់ ប.ក.ក.

៩៣៤.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "មានភស្តុតាងយ៉ាងច្រើនលើសលុបបង្ហាញថា គោលនយោបាយក្នុងការកំណត់គោលដៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានបញ្ជា និងបញ្ជាក់ច្បាស់លាស់ដោយថ្នាក់ដឹកនាំបក្ស"[2448]។

៩៣៥.នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញរបស់ខ្លួនដោយផ្អែកទៅលើភស្តុតាងចំនួន ៥ ប៉ុណ្ណោះ ដែលភាគច្រើនជាភស្តុតាងពុំមានការជាប់ពាក់ព័ន្ធ ហើយអង្គជំនុំជម្រះពុំបានអើពើទៅលើភស្តុតាងដោះបន្ទុកឡើយ[2449]។ ខៀវ សំផន ក៏បានអះអាងផងដែរថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រដល់ការយល់ឃើញដែលរងការជំទាស់នេះឡើយ ដោយបានកត់សម្គាល់ជាពិសេសថា ភស្តុតាងនេះពុំជាប់ពាក់ព័ន្ធដោយសារតែកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដែលបានពិពណ៌នានៅក្នុងនោះ[2450]។

៩៣៦.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានមូលដ្ឋានសំអាងសមស្រប និងបានផ្អែកលើ"ភស្តុតាងគ្រប់គ្រាន់"ដែលបានយោងនៅក្នុងកថាខណ្ឌដដែលនៃសាលក្រម[2451]។

៩៣៧.ទាក់ទងទៅនឹងអំឡុងពេល នៅមុន ឬភ្លាមៗក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើ (i) កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ខឹម សំហួន និង អៀង ផាន (ii) កិច្ចសម្ភាសន៍របស់ អៀង សារី ជាមួយ Stephen HEDER (iii) ឯកសារចំនួន ១ របស់ ប.ក.ក. និង (iv) ឯកសារចំនួន ២

---

[2448] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៧។

[2449] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥៩ ដល់ ៥៧៣។

[2450] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២១៧, ៤២៤ ដល់ ៤២៥។

[2451] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦៧។ *សូមមើលផងដែរ* កថាខណ្ឌ ៣៦៨ ដល់ ៣៧៦។

ដែលមួយបានមកពីរដ្ឋាភិបាលសហរដ្ឋអាម៉េរិក និងមួយទៀតបានមកពីគណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិ [2452]។

៩៣៨.ផ្ទុយពីការលើកឡើងរបស់ នួន ជា[2453] សាក្សី ខឹម សំហួន បានអះអាងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា ក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ គាត់បានដឹងអំពីបទបញ្ជាឱ្យចាប់ខ្លួនមិនត្រឹមតែអ្នករដ្ឋការមានឋានន្តរស័ក្តិធំៗ ដែលពុំព្រមចាកចេញពីទីក្រុងភ្នំពេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលាផងដែរ[2454] និងគាត់បានផ្តល់សក្ខីកម្មថា ក្រោយមកគាត់បានដឹងថា "មន្ត្រីនៃរបប លន់ នល់ យ៉ាងច្រើន និងអ្នកបម្រើរបស់ពួកគេត្រូវបានចាប់ខ្លួនពីភ្នំពេញ"យកទៅសម្លាប់[2455]។ ទាក់ទងទៅនឹងប្រភពនៃបទបញ្ជា យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា សុន សេន ជាអ្នកចេញបញ្ជា[2456] ដែលនេះបានបញ្ជាក់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ខឹម សំហួន។ ទោះជាយ៉ាងណាក្តី ដូច នួន ជា បានកត់សម្គាល់ ខ្សែអាត់ថតសម្លេងនៃការស្តាប់ចម្លើយបានបង្ហាញថា ខឹម សំហួន ជាក់ស្តែងបានអះអាងថា បទបញ្ជាត្រូវបានដាក់ចេញដោយកងពល ហើយគាត់គ្រាន់តែប៉ាន់ស្មានថា បទបញ្ជានេះប្រាកដជាចេញមកពី"ថ្នាក់លើ" ដូចជា សុន សេន[2457]។ ទោះជាយ៉ាងណាក្តី ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា នេះ"ទំនងជា" សុន សេន ជាអ្នកចេញបញ្ជា[2458]។ ដូច្នេះ ការកំណត់ចរិតនៃភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង ជាការសមហេតុផលនៅក្នុងកាលៈទេសៈនេះ។ ទោះបីជាយ៉ាង

---

[2452] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៧៤ ដល់ ២៥៧៧។ ដោយសារសក្ខីកម្មរបស់ Stephen HEDER សំដៅលើឆ្នាំ ១៩៧៦ ទើបទុកសួរក្នុងផ្នែកបន្ទាប់។

[2453] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦០។

[2454] កំណត់ហេតុស្តាប់ចម្លើយរបស់ ខឹម សំហួន ឯកសារលេខ E3/3962 ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00287536 ទំព័រ ៤។

[2455] កំណត់ហេតុស្តាប់ចម្លើយរបស់ ខឹម សំហួន ឯកសារលេខ E3/3962 ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00287536 ទំព័រ ៤។

[2456] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៧៤ ("ក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ សុន សេន ចេញបញ្ជាឱ្យចាប់ខ្លួនអ្នករដ្ឋការស៊ីវិល និងទាហានជាន់ខ្ពស់នៃរបប លន់ នល់") យោងទៅលើកំណត់ហេតុស្តាប់ចម្លើរបស់ ខឹម សំហួន ឯកសារលេខ E3/3962 ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00287536 ទំព័រ ៤។

[2457] កំណត់ហេតុស្តាប់ចម្លើយជាសម្លេងរបស់ ខឹម សំហួន D166/117R ម៉ោង ៤៨:០០ ដល់ ៥០:០០។

[2458] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១៥៣០ ("ទំនងជាថា សុន សាន គឺជាថ្នាក់លើដែលជាអ្នកគ្រប់គ្រងកងពលទាំងអស់")។

01358506



នេះក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សាក្សីរូបនេះបានផ្តល់ភស្តុតាងចចាមអារ៉ាមទាក់ទងទៅនឹងការសម្លាប់ទាំងនោះ និងថា ការរៀបរាប់របស់គាត់ពុំត្រូវបានសួរដេញដោលនៅក្នុងតុលាការឡើយ។ ដូច្នេះ តុលាការអង្គហេតុសមហេតុផលមួយអាចសំអាងលើការរៀបរាប់នេះតែក្នុងកម្រិតតិចតួចប៉ុណ្ណោះ។ បន្ថែមលើនេះទៀត តាមការកត់សម្គាល់ឃើញថា បទបញ្ជាបានកំណត់គោលដៅតែលើក្រុមជាក់លាក់នៃទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប៉ុន្តែពុំមែនសំដៅលើទាហាន និងអ្នករដ្ឋការជាទូទៅនោះឡើយ។

៩៣៩.អង្គជំនុំជម្រះសាលាដំបូងក៏បានសំអាងផងដែរទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី អៀង ផាន ដោយបានសង្ខេបដូចតទៅ៖ “គាត់ទទួលបញ្ជាឱ្យស្វែងរកទាហាន លន់ នល់”[2459]។ តាមការរៀបរាប់នេះពុំបានគាំទ្រដល់ការយល់ឃើញពាក់ព័ន្ធទៅនឹងការសម្លាប់ឡើយ។ បន្ថែមលើនេះ ដូច នួន ជា បានកត់សម្គាល់ថា[2460] សំណួរដែលសួរដោយអ្នកស៊ើបអង្កេត គឺជាសំណួរនាំមុខ ហើយចម្លើយពុំមានភាពជាក់លាក់។ ការកត់សម្គាល់ពិសេសគឺថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ពីមូលហេតុអ្វីដែលខ្លួនបានជ្រើសយកកំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃកិច្ចស៊ើបសួរនេះមកសំអាងឡើយ បើទោះបីជា អៀង ផាន បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះក្នុងនាមជាសាក្សីក៏ដោយ។ ជាក់ស្តែង ដូច នួន ជា បានអះអាង[2461] សក្ខីកម្មផ្ទាល់របស់ អៀង ផាន គឺជាភស្តុតាងដោះបន្ទុកត្រង់ចំណុចថា គាត់បានអះអាងដដែលៗអំពីបទបញ្ជាមានយូរហើយដែលចេញដោយថ្នាក់លើថា ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលចាប់បាននៅសមរភូមិមុខ ពុំត្រូវប៉ះពាល់ឡើយ ប៉ុន្តែត្រូវបញ្ជូនទៅ“សមរភូមិក្រោយ”[2462]។ អៀង ផាន បានផ្តល់សក្ខីកម្មថា គាត់ពុំដែលទទួលបទបញ្ជាណាមួយឱ្យសម្លាប់ ឬធ្វើបាបទាហាន និងបានអះអាងជាច្រើនដងថា ពួកគាត់ត្រូវបានបញ្ជាដោយ“ថ្នាក់លើ”ឱ្យគោរពតាម“វិធានជាសាកល”ថា ឈ្លើយសឹកសង្គ្រាមពុំត្រូវធ្វើបាបឡើយ[2463]។ អាស្រ័យហេតុនេះ ភស្តុតាងដែលបានផ្តល់ដោយ អៀង ផាន ពុំមែនជាភស្តុតាងបង្ហាញពីគោលនយោបាយពាក់ព័ន្ធទៅ

[2459] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ១៥៧៤ (យោងទៅលើកំណត់ហេតុសម្លាប់ចម្លើយរបស់ អៀង ផាន ឯកសារលេខ E3/419.1 ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ERN (ភាសាខ្មែរ) 00909627 ទំព័រ ២)។

[2460] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦១។

[2461] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦១។

[2462] ប្រតិចារឹកថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ឯកសារលេខ E1/193.1 ទំព័រ ៧, ១៣ ដល់ ១៤, ៣០។

[2463] ប្រតិចារឹកថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ (អៀង ផាន) ឯកសារលេខ E1/193.1 ទំព័រ ៣០, ៥២ ដល់ ៥៨។

នឹងការសម្លាប់នោះឡើយ។ ផ្ទុយទៅវិញ បានបង្ហាញថា មានបទបញ្ជាច្បាស់លាស់មិនឱ្យប៉ះពាល់ទាហានដែលចាប់បានក្នុងពេលប្រយុទ្ធ។

៩៤០.នួន ជា និង ខៀវ សំផន ជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងកិច្ចសម្ភាសន៍របស់ អៀង សារី ជាមួយនឹង Stephen HEDER ដែលតាមការអះអាងរបស់ពួកគាត់ គឺជាការប៉ាន់ស្មាន មានលក្ខណៈផ្ទុយ និងខ្វះភាពអាចជឿជាក់បាន[2464]។ ក្នុងបទសម្ភាសន៍នោះ អៀង សារី បានអះអាងថា ប្រហែលជានៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៥ ដោយសាររកឃើញអាវុធដែលបានលាក់ទុកនៅក្នុងផ្ទះរបស់នាយទាហាន ទើបសេចក្តីសម្រេចមួយដើម្បីសម្លាប់ទាហាន លន់ នល់[2465]ត្រូវបានធ្វើឡើង។ ដោយហេតុថា អៀង សារី ពុំមានវត្តមានក្នុងពេលធ្វើសេចក្តីសម្រេចនោះ[2466] ទើបគាត់បានពន្យល់ថា គាត់បានដឹងរឿងនេះក្រោយមក និងបានបញ្ជាក់ថា សេចក្តីសម្រេចនោះពាក់ព័ន្ធទៅនឹងការធ្វើ"អ្វីៗទាំងអស់ដែលចាំបាច់"ក្នុងការទប់ស្កាត់អតីតសមាសភាពនៃរបបសាធារណរដ្ឋខ្មែរ មិនឱ្យធ្វើបដិវត្តន៍ប្រឆាំង[2467]។ ទោះជាយ៉ាងណាក្តី ពុំបានបង្ហាញច្បាស់លាស់ ថាតើសេចក្តីសម្រេចនោះជាទូទៅពាក់ព័ន្ធទៅនឹងការសម្លាប់អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរណាមួយ ឬត្រឹមអ្នកដែលត្រូវបានរកឃើញថា មានជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពប្រឆាំងតែប៉ុណ្ណោះ ដែរ ឬយ៉ាងណា នោះទេ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងពុំបានពិភាក្សាអំពីការលើកឡើងរបស់ អៀង សារី ក្នុងកិច្ចសម្ភាសន៍ជាមួយនឹង Stephen HEDER ដូចដែលបានលើកឡើងខាងលើ និងបទសម្ភាសន៍ពីដំបូងជាមួយនឹង Elizabeth BECKER បើទោះបីជាមានភាពផ្ទុយគ្នាជាសក្តានុពលក៏ដោយ[2468]។

---

[2464] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦២។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២៤ ដល់ ៤២៥។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦០៧។

[2465] កិច្ចសម្ភាសន៍របស់ Stephen HEDER ជាមួយនឹង អៀង សារី ឯកសារលេខ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ERN (ភាសាខ្មែរ) 00062459-00062462 ទំព័រ ៨ ដល់ ១១។

[2466] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ៩១៧ យោងទៅលើកិច្ចសម្ភាសន៍របស់ Stephen HEDER ជាមួយនឹង អៀង សារី ឯកសារលេខ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ERN (ភាសាខ្មែរ) 00062459 ទំព័រ ៨។

[2467] កិច្ចសម្ភាសន៍របស់ អៀង សារី ជាមួយនឹង Stephen HEDER ឯកសារលេខ E3/89 ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ១១ ERN (ភាសាខ្មែរ) 00062462។

[2468] *សូមមើលខាងលើ* កថាខណ្ឌ ៩១៣។

៩៤១.អង្គជំនុំជម្រះសាលាដំបូងក៏បានសំអាងផងដែរទៅលើឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ដូចជា“សេចក្តីសម្រេច”ចុះកាលបរិច្ឆេទថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៥ បានចុះហត្ថលេខាដោយ“សមមិត្ត ពីន”ដែលបក្សបានសម្រេចកម្ទេចទាហាននៃរបបសាធារណរដ្ឋខ្មែរចំនួន ១៧ នាក់ ដែលមានឈ្មោះក្នុងបញ្ជី បន្ទាប់ពី“ការពិនិត្យរបស់បក្ស”[2469]។ “សេចក្តីសម្រេច”នេះក៏បានបង្ហាប់ថា“ស្នើសមមិត្ត [...] អនុវត្តតាមគោលការណ៍របស់បក្ស”[2470]។ “សេចក្តីសម្រេចនេះ”ត្រូវបានបកប្រែជាភាសាអង់គ្លេសចំនួន ២ ច្បាប់ ដែលឯកសារមួយក្នុងចំណោមនោះមាន“កំណត់សម្គាល់របស់អ្នកបកប្រែ”បញ្ជាក់អំពីតួនាទី និងប្រវត្តិរូបរបស់សមមិត្ត ពីន នៅផ្នែកខាងក្រោមនៃទំព័រមានសេចក្តី“ស្នើទុកពិនិត្យថែម”ឈ្មោះ បីនាក់ដូចខាងក្រោម[2471]។

៩៤២.នួន ជា បានស្នើសុំឱ្យបញ្ជាក់ពីភាពត្រឹមត្រូវ និងភាពអាចជឿទុកចិត្តបានចំពោះឯកសារនេះ និងស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលស្វែងរកច្បាប់ដើម និងផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃឯកសារនេះ[2472]។ នួន ជា បានលើកឡើងបន្ថែមទៀតថា ឯកសារនេះពុំបានបង្ហាញពីប្រភពនៃការចេញបញ្ជាឱ្យកម្ទេច និងបានកត់សម្គាល់ថានៅគ្រប់កាលៈទេសៈទាំងអស់ បទបញ្ជាឱ្យកម្ទេចពាក់ព័ន្ធទៅនឹងអ្នករដ្ឋការដែលមានឋានន្តរស័ក្តិខ្ពស់ ត្រូវធ្វើឡើងបន្ទាប់ពីបានពិនិត្យជាមុន។

៩៤៣.សហព្រះរាជអាជ្ញាបានអះអាងថា អំណះអំណាងរបស់ នួន ជា មានភាពច្រំដែល និងជម្រើសនៃការបកស្រាយរបស់គាត់អំពីឯកសារនេះ គឺពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ[2473]។

៩៤៤.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នួន ជា ពុំបានលើកពីបញ្ហាមន្ទិលសង្ស័យពិតប្រាកដទាក់ទងទៅនឹងភាពត្រឹមត្រូវនៃឯកសារនេះដែលប្រភពដើមជាភាសាខ្មែរ ហើយដូចគ្នាបេះបិទទៅនឹងច្បាប់ចម្លងទាំងអស់ដែលមាននៅក្នុងសំណុំរឿង។ ឯកសារបកប្រែជាភាសាអង់គ្លេសចំនួន ២ ច្បាប់ក៏បានបង្ហាញឱ្យឃើញថា មានភាពត្រឹមត្រូវជាទូទៅដែរ និងបើទោះបីជាត្រួតគ្នាយ៉ាងណាក៏ដោយ ក៏នៅតែស្របគ្នាជាមួយច្បាប់ដើ

---

[2469] សេចក្តីសម្រេចចិត្ត ឯកសារលេខ E3/832 ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00068914 ទំព័រ ១។

[2470] សេចក្តីសម្រេចចិត្ត ឯកសារលេខ E3/832 ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00068914 ទំព័រ ១។

[2471] សេចក្តីសម្រេចចិត្ត ឯកសារលេខ E3/832 ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៥ ERN (ភាសាអង់គ្លេស) 00068919 ទំព័រ ៦។

[2472] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៤។

[2473] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧៣។

ម។ អាស្រ័យហេតុនេះ សំណើរបស់ នួន ជា សុំឱ្យស្វែងរកច្បាប់ដើមនៃឯកសារនេះ និងសុំឱ្យបញ្ជាក់ពីភាពត្រឹមត្រូវនោះ ត្រូវបដិសេធចោល។

៩៤៥.ទាក់ទងទៅនឹងខ្លឹមសារនៃឯកសារនេះ ដូច នួន ជា បានកត់សម្គាល់ គឺសំដៅលើ"ភ្នាក់ងារសម្ងាត់ម្នាក់" និងមន្ត្រីចំនួន ១៦ នាក់ ចាប់ពីស័ក្តិមួយឡើងទៅ។ ការកម្ទេចអ្នកទាំង ១៧ នាក់នេះ ទំនងជាត្រូវបានចេញបញ្ជាតាមរយៈដំណើរការពិនិត្យលើបុគ្គលម្នាក់ៗដោយបក្ស។ បន្ថែមលើនេះ ទាក់ទងទៅនឹង"គោលការណ៍របស់បក្ស"ដែលជា"សេចក្តីសម្រេច"ស្នើឱ្យអនុវត្តនោះ បើទោះបីជាពាក្យពេចន៍មិនមានភាពច្បាស់លាស់ក៏ដោយ ក៏ទំនងជាសំដៅលើបទបញ្ជាជាក់លាក់ឱ្យសម្លាប់តែបុគ្គលដែលមានឈ្មោះនៅក្នុងបញ្ជីនោះប៉ុណ្ណោះ ប៉ុន្តែពុំមែនសំដៅលើគោលនយោបាយទូទៅ ឬមិនរើសមុខនោះទេ។

៩៤៦.ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើឯកសារចំនួន ២ ដែលមួយច្បាប់ចេញពីរដ្ឋាភិបាលសហរដ្ឋអាម៉េរិក និងមួយច្បាប់ទៀតពីគណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិ[2474]។ អនុស្សរណៈរបស់អង្គការសហប្រជាជាតិ ត្រូវបានលើកយកមកពិចារណារួចហើយ នៅក្នុងផ្នែកស្តីពីលំនាំនៃការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[2475]។ បន្ថែមលើការពិចារណាខាងលើ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើភស្តុតាងនៃ"របាយការណ៍ដែលថា ខ្មែរក្រហមបានដាក់បញ្ជាឱ្យសម្លាប់នាយទាហាន និងអ្នករដ្ឋការស៊ីវិលទាំងអស់នៃរដ្ឋាភិបាល លន់ នល់"[2476]។ បទបញ្ជាសម្លាប់ត្រូវបានរាយការណ៍នៅក្នុងអត្ថបទនៃទស្សនាវដ្តីថែម (Time) ប៉ុន្តែ ដូចបានលើកឡើងដោយជនជាប់ចោទ[2477] ការរៀបរាប់នោះ គឺជាពាក្យចចាមអារ៉ាមអនាមិកនៅក្នុងឯកសារក្រៅតុលាការ។ ដូច្នេះ បើទោះបីជាអំណះអំណា

---

[2474] អនុស្សរណៈក្រុមប្រឹក្សាសន្តិសុខជាតិសហរដ្ឋអាម៉េរិក កម្មវត្ថុ៖ ការវាយតម្លៃអំពីការអភិវឌ្ឍន៍នៅក្នុងឥណ្ឌូចិនក្រោយពេលបញ្ចប់សង្គ្រាម ឯកសារលេខ E3/3472 ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦។ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ៖ របាយការណ៍បន្ថែមរបស់គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិតាមសេចក្តីសម្រេចលេខ ៩ របស់គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្ស (XXXIV) ឯកសារលេខ E3/3327 ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩។

[2475] *សូមមើលខាងលើ* កថាខណ្ឌ ៨៨៩។

[2476] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៧៤ យោងទៅលើអនុស្សរណៈក្រុមប្រឹក្សាសន្តិសុខជាតិសហរដ្ឋអាម៉េរិក កម្មវត្ថុ៖ ការវាយតម្លៃអំពីការអភិវឌ្ឍន៍នៅក្នុងឥណ្ឌូចិនក្រោយពេលបញ្ចប់សង្គ្រាម ឯកសារលេខ E3/3472 ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00742970 ទំព័រ ៣។

[2477] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧៥។ សារណាបណ្តឹងសទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២៤។

ងរបស់សហព្រះរាជអាជ្ញាដែលថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការសំអាងលើភស្តុតាង[2478]ក៏ដោយ ក៏ជាការសមហេតុផលដែលថាភស្តុតាងនេះត្រឹមតែទទួលបានតម្លៃទាបតែប៉ុណ្ណោះ។

៩៨៧.ឯកសាររបស់គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិ មានការរៀបរាប់របស់អតីតកម្មាភិបាលខ្មែរក្រហមម្នាក់ដែលបានអះអាងថា គណៈមជ្ឈិមបានកែប្រែគោលនយោបាយប្រឆាំងនឹងទាហាននៃរបបសាធារណរដ្ឋខ្មែរ "ក្នុងឆ្នាំ ១៩៧៥" ក្រោយពីទទួល"ជ័យជំនះនៃបដិវត្តន៍"[2479]។ យោងតាមឯកសារនេះ អតីតកម្មាភិបាលខ្មែរក្រហមបានរៀបរាប់ថា ជាលទ្ធផល មាន"ភាពចាំបាច់ក្នុងការលុបបំបាត់មិនត្រឹមតែអ្នករដ្ឋការប៉ុណ្ណោះទេ ថែមទាំងទាហានសាមញ្ញ រួមទាំងប្រពន្ធ និងកូនរបស់ពួកគេផងដែរ"[2480]។ ផ្ទុយពីអំណះអំណាងរបស់ នួន ជា និង ខៀវ សំផន[2481] មានការបង្ហាញយ៉ាងច្បាស់ថា ការកែប្រែគោលនយោបាយបានកើតចេញពីមជ្ឈិមបក្ស ដូច្នេះពុំមានហេតុផលអ្វីត្រូវសង្ស័យលើប្រភពដែលអាចជឿទុកចិត្តនេះបានឡើយ។ ទោះជាយ៉ាងណាក្តី ដោយសារការរៀបរាប់នេះ គឺជាឯកសារក្រៅតុលាការ និងជាពាក្យចចាមអារ៉ាម ទើបត្រូវផ្តល់តម្លៃជាភស្តុតាងក្នុងកម្រិតទាប។ លើសពីនេះទៀត ការរៀបរាប់នេះពុំបានបញ្ជាក់ ថាការកែប្រែគោលនយោបាយបានធ្វើឡើងនៅមុនព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ឬនៅពេលណាមួយក្រោយមកទៀត។

៩៨៨.នួន ជា បានចង្អុលបង្ហាញទៅលើភស្តុតាងដោះបន្ទុក ដែលតាមគំនិតរបស់គាត់ថា អង្គជំនុំជម្រះមានកំហុសក្នុងការពុំបានពិចារណាទាក់ទងទៅនឹងបញ្ហានេះ។ សាក្សី ភី ភួន បានផ្តល់សក្ខីកម្មអំពីសេចក្តីណែនាំជាក់លាក់មិនឱ្យប៉ះពាល់ដល់ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលបានចុះចាញ់[2482]។ បើទោះបីជាសហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង"បានទទួលយក"ភស្តុតាងនេះ និងត្រូវបានសន្មតថា បាន

[2478] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧៨។

[2479] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ៖ របាយការណ៍បន្ថែមរបស់គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិតាមសេចក្តីសម្រេចលេខ ៩ របស់គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្ស (XXXIV) ឯកសារលេខ E3/3327 ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00723754។

[2480] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ៖ របាយការណ៍បន្ថែមរបស់គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិតាមសេចក្តីសម្រេចលេខ ៩ របស់គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្ស (XXXIV) ឯកសារលេខ E3/3327 ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩ ទំព័រ ២ ERN (ភាសាខ្មែរ) 00723754។

[2481] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៥។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤២៤។

[2482] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/98.1 ទំព័រ ៧០។

ពិចារណាក៏ដោយ[2483] ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើផ្នែកនេះនៃសក្ខីកម្មដែរ។ បញ្ហានេះពុំអាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើភស្តុតាងនេះដោយសារតែភាពពុំអាចជឿទុកចិត្តបាននោះទេ ពីព្រោះអង្គជំនុំជម្រះបានសំអាងយ៉ាងទូលំទូលាយទៅលើសក្ខីកម្មរបស់ ភី ភួន នៅក្នុងសាលក្រមទាំងមូល រួមទាំងនៅក្នុងការផ្តល់សំអាងហេតុសំខាន់ៗ[2484]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា ផ្នែកខ្លះនៃសក្ខីកម្មរបស់គាត់ពុំអាចជឿទុកចិត្តបាននោះទេ ប៉ុន្តែអង្គជំនុំជម្រះពុំបានយោងទៅលើចំណុចជាក់លាក់នោះឡើយ[2485]។ ដោយពិចារណាលើភាពពាក់ព័ន្ធផ្ទាល់នៃចម្លើយរបស់ ភី ភួន និងទម្ងន់សំខាន់ៗដែលបានផ្តល់ជាទូទៅដល់សក្ខីកម្មរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយពុំបានពិចារណាលើភស្តុតាងនេះ ដែលជាប់ពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់គោលដៅ។ ជាដំណោះស្រាយចំពោះកំហុសនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើចម្លើយនេះ នៅពេលផ្តល់ការវាយតម្លៃចុងក្រោយរបស់ខ្លួនលើបញ្ហា ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះបានធ្វើឡើងដោយសមហេតុផល ដែរ ឬយ៉ាងណា។

៩៤៩.នួន ជា បានយោងបន្ថែមទៀតទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី សៅ វ៉ន[2486] ដែលអង្គជំនុំជម្រះសាលាដំបូងពុំបានលើកយកមកពិចារណានៅក្នុងសាលក្រមរបស់ខ្លួនផងដែរ។ ផ្អែកតាម នួន ជា ឯកសារនេះបង្ហាញពីការណែនាំមិនឱ្យប៉ះពាល់ដល់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលមានបណ្តាស័ក្តិមួយចំនួន ដែលនេះជាមូលហេតុគាត់ស្នើសុំឱ្យកោះហៅសាក្សីរូបនេះនៅដំណាក់កាលបណ្តឹងសាទុក្ខ[2487]។ អង្គជំនុំជម្រះតុលាការកំពូលបានស្តាប់សាក្សី សៅ វ៉ន កាលពីថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥[2488]។ ក្នុងសក្ខីកម្មរបស់ខ្លួន សៅ វ៉ន បានអះអាងថា នៅពេលប្រជុំដែលគាត់បានចូលរួមនោះ មានបទបញ្ជាមិនឱ្យប៉ះពាល់ទាហានរហូត

---

[2483] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧៥។

[2484] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៣ ដល់ ១៣៥, ១៣៩, ១៤៤, ១៤៦ និងជើងទំព័រ ២៥៨០។

[2485] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧។

[2486] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៧។

[2487] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៧។

[2488] សេចក្តីសម្រេចស្តីពីការកោះហៅសាក្សីនៅដំណាក់កាលបណ្តឹងសាទុក្ខ (F2/5) កថាខណ្ឌ ២៦ (យោងទៅលើ សៅ វ៉ន *ហៅ* សៅ ពត មានរហស្សនាមថា SCW-4)។

ដល់ស័ក្តិប្រាំ[2489] ប៉ុន្តែគាត់ពុំអាចចងចាំបាននូវកាលបរិច្ឆេទពិតប្រាកដនៃកិច្ចប្រជុំនោះទេ[2490]។ ផ្អែកលើមូលដ្ឋាននៃភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង[2491] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សេចក្តីណែនាំនោះទំនងជាដាក់ចេញយ៉ាងយូរបំផុតប្រហែលមួយខែក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ សាក្សីបានអះអាងថា ពុំមានគោលនយោបាយសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរក្នុងពេលរំដោះនោះឡើយ[2492] ប៉ុន្តែ

---

[2489] *សូមមើល ឧ.* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ (សៅ វ៉ន) ឯកសារលេខ F1/1.1 ទំព័រ ២៧ ដល់ ២៨, ៣៥ ដល់ ៣៦។

[2490] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ (សៅ វ៉ន) ឯកសារលេខ F1/1.1 ទំព័រ ២០ ដល់ ២១, ៤២ (បានអះអាងថា គាត់ត្រូវបានផ្លាស់ទីលំនៅទៅតំបន់ ២៥ ក្នុង ឆ្នាំ ១៩៧៦) ទំព័រ ២៦ (បទបញ្ជាហាមប៉ះពាល់ត្រូវបានផ្សព្វផ្សាយបីខែក្រោយពេលរំដោះ) ទំព័រ ៣៤ ដល់ ៣៥ (នៅពេលគាត់ចូលប្រជុំនៅសាលាខេត្តតាកែវ គាត់ត្រូវបានបញ្ជូនទៅដល់តំបន់ ២៥ នៅមុនពេលប្រជុំនោះ) ទំព័រ ៤០ ដល់ ៤១ (កាលបរិច្ឆេទនៃសេចក្តីណែនាំហាមប៉ះពាល់ទាហាននៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពភ្លាមៗក្រោយពេលរំដោះ ប៉ុន្តែ គាត់បានបញ្ជាក់ថា គាត់បានសំដៅលើការប្រកាសតាមវិទ្យុរបស់ ខៀវ សំផន (*ប៉ុន្តែ សូមមើល* ទំព័រ ៨៨ កាលបរិច្ឆេទនៃការប្រកាសតាមវិទ្យុនៅពេលនោះ គឺមុនពេលរំដោះ)) ទំព័រ ៩៣ (កិច្ចប្រជុំនៅក្នុងខេត្តតាកែវ ក្រោយឆ្នាំ ១៩៧៥) ទំព័រ ៩៥ (កិច្ចប្រជុំក្នុងខេត្តតាកែវបានធ្វើឡើងពីរ ឬបីថ្ងៃក្រោយការរំដោះ) ទំព័រ ៩៥ (តាមការពិតកិច្ចប្រជុំបានធ្វើឡើងនៅភ្នំត្រែងក្រោយរំដោះ) ទំព័រ ៩៧ ដល់ ៩៨ (ការប្រជុំនៅភ្នំត្រែងបានធ្វើឡើងពីរខែក្រោយថ្ងៃរំដោះ ការប្រជុំនៅខេត្តកែវបានធ្វើឡើងក្នុងឆ្នាំ ១៩៧៦)។

[2491] ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជីម) (សំណុំរឿង ០០២/០២) ឯកសារលេខ F2/6.1.2 ទំព័រ ១២ ដល់ ១៣ (កិច្ចប្រជុំនៅតាកែវ ដែល តា ម៉ុក និង តា សោម បានចូលរួមនោះ ប្រព្រឹត្តទៅក្រោយកិច្ចប្រជុំថ្ងៃទី ២០ ដល់ ២៤ ខែ ឧសភា ឆ្នាំ ១៩៧៥ នៅភ្នំពេញ)។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ជាមួយ សៅ វ៉ន ឯកសារលេខ F2/9.1 ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១ ERN (ភាសារខ្មែរ) 00957793 ទំព័រ ២៣ (កិច្ចប្រជុំដែល តា ម៉ុក បានប្រកាសពាក់ព័ន្ធទៅនឹងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ បានប្រព្រឹត្តទៅប្រហែលមួយខែក្រោយការរំដោះ)។

[2492] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ (សៅ វ៉ន) ឯកសារលេខ F1/1.1 ទំព័រ ២៧ ដល់ ២៨ (មាគ៌ានយោបាយនៅពេលរំដោះបញ្ជាក់ថា ទាហានដល់ស័ក្តិហាមប៉ះពាល់) ទំព័រ ៣៣ (អះអាងបញ្ជាក់ខ្លឹមសារនៃការបញ្ជានោះ) ទំព័រ ៩៧ ដល់ ៩៨ (បទបញ្ជាហាមប៉ះពាល់ ពុំមែនបង្ហាញពីការកែប្រែគោលនយោបាយដែលក្រោយមកបានកែប្រែក្នុងចុងឆ្នាំ ១៩៧៧)។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ (សៅ វ៉ន) ឯកសារលេខ F1/1.1 ទំព័រ ៨២ ដល់ ៨៣ (ការប្រុងប្រយ័ត្ន និងការអប់រំកសាងមិនចាំបាច់តែទាហានទេ តែទូទៅទាំងអស់) ទំព័រ ៨៦ (គាត់មិនដែលទទួលបានបទបញ្ជា ឬឮថា ទាហាននៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានបញ្ចុះបញ្ចូលតាមមធ្យោបាយបោកបញ្ឆោត និងក្រោយមកចាប់ខ្លួនឡើយ) ទំព័រ ៩១ ដល់ ៩២ (អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ពុំត្រូវបានចាត់ទុកថា ជាខ្មាំងដោយសារតែមូលដ្ឋានមួយនៃការជាប់ពាក់ព័ន្ធទៅនឹងរបបមុននោះឡើយ)។ *សូមមើលផងដែរ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ជាមួយ សៅ វ៉ន ឯកសារលេខ F2/9.1 ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ១៨ ដល់ ១៩, ២៣, ៥០ (បញ្ជាក់ថា នៅមុន និងក្រោយការបញ្ចប់សង្គ្រាមប្រឆាំងនឹងរបប លន់ នល់ តា ម៉ុក បានណែនាំកម្មាភិបាលហាមប៉ះពាល់ទាហាននៃរបបសាធារណរដ្ឋខ្មែរ)។

បានឆ្លើយដោយប្រុងប្រយ័ត្នថា ការយល់ដឹងរបស់គាត់នៅមានកម្រិតចំពោះហេតុការណ៍ដែលបានកើតឡើងនៅក្នុងឃុំរបស់គាត់[2493]។ សក្ខីកម្មចំនួន ២ របស់សាក្សី ពេជ្រ ជឹម នៅក្នុងសំណុំរឿង ០០២/០២ ដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួលយកជាភស្តុតាង[2494] បានបញ្ជាក់ថា កិច្ចប្រជុំដែល សៅ វ៉ន បានលើកឡើងនៅក្នុងសក្ខី កម្មរបស់គាត់ និងថា ពេជ្រ ជឹម ក៏បានចូលរួមដែរនោះ ពិតជាមានចេញសេចក្តីណែនាំមិនឱ្យប៉ះពាល់ទាហាននៃរបបសាធារណរដ្ឋខ្មែររហូតដល់ស័ក្តិប្រាំប្រាកដមែន[2495]។

៩៥០.នួន ជា បានលើកឡើងថា ភស្តុតាងពីស្រុកត្រាំកក់ និងគុកក្រាំងតាចាន់ដែលស្ថិតនៅក្នុងតំបន់តែមួយដែល សៅ វ៉ន បានបម្រើការនៅក្នុងអំឡុងពេលនោះ បានបញ្ជាក់បន្ថែមលើចម្លើយរបស់គាត់ដែលថា ពុំមានគោលនយោបាយសម្លាប់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរឡើយ[2496]។ ជាការកត់សម្គាល់ នួន ជា បានអះអាងថា កំណត់ត្រាក្នុងសំណុំរឿងបង្ហាញថា កម្មាភិបាលខ្មែរក្រហមបានដឹងពីទីកន្លែងរបស់អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរនៅក្នុងតំបន់នោះ និងបានព្យាយាមអប់រំកែប្រែទាហានទាំងនោះ និងបានចាប់ខ្លួន តែក្នុងករណីមានការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តខុសឆ្គងជាក់លាក់ប៉ុណ្ណោះ ដោយពុំបានផ្អែកលើមូលដ្ឋាននៃការ

---

[2493] ប្រតិចារឹកចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ (សៅ វ៉ន) ឯកសារលេខ F1/1.1 ទំព័រ ៥៧ ដល់ ៥៨, ៨៤ ដល់ ៨៥, ៨៧, ៩៦។

[2494] ផ្នែកសម្រេចសេចក្តីលើសំណើសុំដាក់ភស្តុតាងបន្ថែម (F2/9) ទំព័រ ១០។

[2495] ប្រតិចារឹកថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម) (សំណុំរឿង ០០២/០២) ឯកសារលេខ F2/6.1.2 ទំព័រ ១៣, ១៥ ដល់ ១៦, និង ១៧។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានស្នើសុំផ្តល់ទម្ងន់ដល់ភាពអាចជឿជាក់បាននៃការអះអាងរបស់ ពេជ្រ ជឹម ផ្អែកលើការយោងទៅលើចំណុចដទៃទៀតនៃសក្ខីកម្មរបស់គាត់(សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីបួនដាក់ភស្តុតាងបន្ថែម (F2/6/2) កថាខណ្ឌ ៧)។ ទោះជាយ៉ាងណាក្តី កិច្ចប្រជុំដែល ខុម ជាប្រធានភូមិ បានពាំនាំផែនការពីថ្នាក់លើពាក់ព័ន្ធទៅនឹងការបោសសម្អាតអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះបានប្រព្រឹត្តទៅយ៉ាងយូរបំផុត“ប្រហែលបី ឬបួនខែក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥” (ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម)(សំណុំរឿង ០០២/០២) ឯកសារលេខ F2/6.1.1 ទំព័រ ២៥)។ បន្ថែមលើនេះទៀត នៅពេល ពេជ្រ ជឹម ត្រូវបានសួរដេញដោលដោយសហព្រះរាជអាជ្ញាអំពីភាពមិនស៊ីសង្វាក់គ្នារវាងការណែនាំហាមមិនឱ្យប៉ះពាល់ទាហាននៃរបបសាធារណរដ្ឋខ្មែរថ្នាក់ក្រោមដែលបានប្រាប់ក្នុងពេលប្រជុំជាមួយ ខុម នោះ គាត់ពុំបានចងចាំអំពីការអះអាងដំបូងរបស់គាត់ស្តីពីការណែនាំនេះទេ ប៉ុន្តែបានលើកឡើងថា បើទោះបីជាមិនច្បាស់លាស់យ៉ាងណាក៏ដោយ ក៏មានដំណាក់កាលពីរខុសគ្នានៃការប្រព្រឹត្តទៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែរ(ប្រតិចារឹកចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (ពេជ្រ ជឹម)(សំណុំរឿងលេខ ០០២/០២) ឯកសារលេខ F2/6.1.2 ទំព័រ ៦៥ ដល់ ៦៧។

[2496] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៨។

01358514



ជាប់ពាក់ព័ន្ធទៅនឹងអតីតភាពរបស់ពួកគេជាមួយនឹងរបបសាធារណរដ្ឋខ្មែរ តែមួយមុខគត់នោះឡើយ[2497]។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ភស្តុតាងនេះពុំអាចបង្កើតឱ្យមានការសង្ស័យចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនោះឡើយ[2498]។

៩៥១.អង្គជំនុំជម្រះតុលាកាកំពូលសង្កេតឃើញថា ភស្តុតាងដែលបានលើកឡើងខាងលើបានបង្ហាញថា អ្នកជាប់ឃុំភាគច្រើននៅគុកទាំងពីរនេះ គឺជាអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានចោទប្រកាន់ ដូចជា ពីការលួច ការរំលោភផ្លូវភេទ ការរត់គេចខ្លួន ការប្រើល្បិច ការញុះញង់ប្រជាជនឱ្យប្រឆាំងនឹងរបប ឬជាញៀកញាប់ ការធ្វើការងារពុំបានល្អ។ ទោះជាយ៉ាងណាក្តី ក៏នៅតែមានភាពមិនច្បាស់លាស់ ថាតើការចោទប្រកាន់ទាំងនោះពិតជាកើតមាន ឬមិនមាននោះឡើយ និងថាតើអ្នកជាប់ឃុំទាំងនោះចុងក្រោយបានរួចផុតជីវិតដែរ ឬយ៉ាងណានោះឡើយ។ សំខាន់បំផុតនោះគឺថា កំណត់ត្រាបានបង្ហាញថា ព្រឹត្តិការណ៍បានកើតឡើងក្រោយការណែនាំដែល សៅ វ៉ន និង ពេជ្រ ជឹម បានលើកឡើងនៅក្នុងសក្ខីកម្មរបស់ពួកគាត់ អាស្រ័យហេតុនេះ ពុំសមស្របក្នុងការផ្តល់ការបញ្ជាក់បន្ថែមនោះឡើយ។

៩៥២.ផ្អែកលើសំណើរបស់ នួន ជា អង្គជំនុំជម្រះតុលាការកំពូលក៏បានកោះហៅសាក្សី ទាត់ ធឿន មកផ្តល់សក្ខីកម្មនៅចំពោះមុខផងដែរ[2499]។ សាក្សីបានបញ្ជាក់ថា មានគោលនយោបាយ"កម្ទេច"អតីតពួកចក្រពត្តិ និងសក្តិភូមិទាំងអស់ ដែលគោលនយោបាយនេះបានផ្សព្វផ្សាយនៅពេលប្រជុំមួយក្រោមការដឹកនាំរបស់ រស់ ញឹម (ញឹម រស់)ដែលកម្មាភិបាលដទៃទៀតថ្នាក់ភូមិភាគបានចូលរួម ហើយគាត់បានស្តាប់ឮពីបន្ទប់មួយទៀត[2500]។

---

[2497] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៨។

[2498] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧៥ ជើងទំព័រ ១៥៥០។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការកត់សម្គាល់នៅក្នុងការលើកឡើងជាក់លាក់នៅក្នុងសារណាតបរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងភាពជាប់ពាក់ព័ន្ធ និងទម្ងន់នៃភស្តុតាងដែល នួន ជា បានលើកឡើង ទៅនឹងសំណើទីបួនសុំដាក់ភស្តុតាងបន្ថែម (F2/6/2) កថាខណ្ឌ ៨, ១០, ១២ ដល់ ១៦។ ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងការលើកឡើងដែលបានផ្អែកលើភស្តុតាងក្នុងសំណុំរឿងលេខ ០០២/០២ ដែលពុំមាននៅក្នុងសំណុំរឿង ០០២/០១ នោះ ការលើកឡើងទាំងនេះពុំអាចយកមកពិចារណាបានឡើយ។ បន្ថែមលើនេះទៀត សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកភស្តុតាងជំទាស់បន្ថែមនោះ ពុំមានមូលដ្ឋាននៅក្នុងក្របខ័ណ្ឌគតិយុត្តជាធរមាននោះទេ ដូច្នេះត្រូវបដិសេធចោលដោយពុំចាំបាច់ពិនិត្យបន្តទៀតឡើយ ដោយពិចារណាឃើញថា សហព្រះរាជអាជ្ញាពុំបានបង្ហាញ ថាតើភស្តុតាងដែលផ្តល់នេះបំពេញតាមលក្ខខណ្ឌតម្រូវតាមវិធាន ១០៤(១) និង១០៨(៧) នៃវិធានផ្ទៃក្នុងយ៉ាងដូចម្តេចឡើយ។

[2499] សេចក្តីសម្រេចស្តីពីការកោះហៅសាក្សី (F2/5) កថាខណ្ឌ ២៦ (យោងទៅលើ ទាត់ ធឿន មានរហស្សនាម SCW-5)។

[2500] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៩៥ ដល់ ៩៦។

គោលនយោបាយនេះ ត្រូវបានលើកឡើងតាមរយៈការបញ្ជាពី“ថ្នាក់លើ” និងថា ពី“អ្នកដែលនៅមជ្ឈិម”[2501]។ កិច្ចប្រជុំបានកើតឡើងប្រហែលមួយខែក្រោយការរំដោះ ក្រោយការសម្លាប់នៅបាត់ដំបងដែលបានយោងដូចខាងលើ[2502]។ យោងតាម ទាត់ ធឿន ដោយសារកិច្ចប្រជុំនោះបានធ្វើឡើងនៅថ្នាក់ភូមិភាគ ដែលជាកម្រិតខ្ពស់បំផុតតាមតំបន់ ហើយ រស់ ញឹម(ញឹម រស់) បានកំណត់ចរិតគោលនយោបាយនេះថា កើតចេញពីមជ្ឈិមបក្សនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការគួរឱ្យជឿជាក់ថា កិច្ចប្រជុំនេះមិនមែនក្នុងគោលបំណងពាំនាំការណែនាំរបស់បក្សដែលទើបបានទទួលថ្មីៗនោះទេ ប៉ុន្តែជាការបញ្ជាក់អះអាងគោលនយោបាយរបស់បក្សពីមុន។

៩៥៣.ចុងក្រោយ នួន ជា បានរំឭកថា ហេង សំរិន ពុំត្រូវបានកោះហៅមកធ្វើជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងបានលើកឡើងថា សាក្សីរូបនេះនឹងអាចផ្តល់ភស្តុតាងដោះបន្ទុក[2503]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយអំណះអំណាងនេះរួចហើយ និងបានសន្និដ្ឋានថា ពុំទំនងជាថា សក្ខីកម្មរបស់ ហេង សំរិន អាចនឹងមានព័ត៌មានសំខាន់បន្ថែមដែលដោះបន្ទុកទាក់ទងទៅនឹងកិច្ចប្រជុំនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ប៉ុន្តែថា អង្គជំនុំជម្រះតុលាការកំពូលក្នុងករណីសមស្របនឹងត្រូវធ្វើសេចក្តីសន្និដ្ឋានដែលកើតចេញពីបទសម្ភាសន៍របស់ ហេង សំរិន ត្រូវទុកជាប្រយោជន៍ដល់ជនជាប់ចោទ[2504]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា តាមបទសម្ភាសន៍នេះបានបង្ហាញថា នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ថ្នាក់ដឹកនាំបក្សរួមមាន នួន ជា បានប្រកាសថា មេដឹកនាំនៃរបបសាធារណៈរដ្ឋខ្មែរត្រូវតែដកចេញពីក្របខ័ណ្ឌ ដោយពុំបាននិយាយថា ត្រូវសម្លាប់ពួកគេចោលនោះឡើយ[2505]។

---

[2501] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៩៥ ដល់ ៩៦។

[2502] ប្រតិចារឹកចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន) ឯកសារលេខ F1/3.1 ទំព័រ ៩៥។ *សូមមើលខាងលើ* កថាខណ្ឌ ៩០០។

[2503] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៦៩ ដល់ ៥៧០។

[2504] *សូមមើលខាងលើ* កថាខណ្ឌ ១៥៥។

[2505] កំណត់ហេតុនៃកិច្ចសម្ភាសន៍វាយសាឡើងវិញរបស់ KIERNAN ឯកសារលេខ E3/1568 ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩១ ERN (ភាសាខ្មែរ) 00713954-5 ទំព័រ ៣៦ ដល់ ៣៧។

៩៥៤.ទាក់ទងទៅនឹងភស្តុតាងនៃកិច្ចសម្ភាសន៍របស់ ថេត សម្បត្តិ និង Robert LEMKIN ដែល នួន ជា បាន យោងនោះ[2506] អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចរួចហើយថា ខ្លឹមសារនៃកិច្ចសម្ភាសន៍នេះពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហា ថាតើមានគោលនយោបាយប្រឆាំងនឹងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដែរ ឬយ៉ាងណានោះឡើយ[2507]។

៩៥៥.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើបញ្ហាមួយចំនួននៃទស្សនាវដ្ដី*ទង់បដិវត្តន៍* និងសក្ខីកម្មរបស់ ពេជ្រ ជឹម[2508]។ អង្គជំនុំជម្រះបានសំអាងលើបញ្ហាទាំងនេះ មិនមែនក្នុងគោលបំណងបង្ហាញពីអត្ថិភាពនៃគោលនយោបាយ ឬខ្លឹមសារនោះទេ ប៉ុន្តែដើម្បីបង្ហាញឱ្យឃើញពីរបៀបដែលគោលនយោបាយទាក់ទងទៅនឹង“ខ្មាំង”របស់ ប.ក.ក. ត្រូវបានផ្សព្វផ្សាយ ដូចជា តាមរយៈឯកសារបោះពុម្ពផ្សាយ និងវគ្គបណ្តុះបណ្តាលនានា។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានបញ្ហាតែមួយនៅក្នុងទស្សនាវដ្ដី*ទង់បដិវត្តន៍* គិតមកដល់ត្រឹមឆ្នាំ ១៩៧៥ នោះ គឺទាំងភាសា និងបរិបទរបស់ទស្សនាវដ្ដីនេះបានសំដៅច្បាស់លាស់លើការសម្លាប់ក្នុងពេលប្រយុទ្ធ[2509]។

៩៥៦.អង្គជំនុំជម្រះសាលាដំបូងក៏បានសំអាងផងដែរទៅលើរបាយការណ៍ ទូរលេខ និងឯកសារដទៃទៀតរបស់ ប.ក.ក. ដែលមានកាលបរិច្ឆេទដល់ឆ្នាំ ១៩៧៦ (ចំនួន ២) ឆ្នាំ ១៩៧៧ (ចំនួន ៥) និងឆ្នាំ ១៩៧៨ (ចំនួន ២)[2510]។ នួន ជា បានអះអាងថា ភស្តុតាងនៃសេចក្តីណែនាំរបស់ ប.ក.ក. ដែលកើតក្រោយឆ្នាំ ១៩៧៥ គឺពុំជាប់ពាក់ព័ន្ធទៅនឹងការបង្ហាញនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ ចំពោះព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃឡើយ ដោយសារអ្វីដែលចាំបាច់នោះ គឺត្រូវមានភស្តុតាងបញ្ជាក់ថា មានសេចក្ដីសម្រេចជាក់លាក់ក្នុងការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបានធ្វើឡើងនៅក្នុងអំឡុងពេលរំដោះ[2511]។ អង្គជំនុំ

---

[2506] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧២។

[2507] *សូមមើលខាងលើ* កថាខណ្ឌ ៣៩ *ជាអាទិ៍*។

[2508] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៨។

[2509] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៨២ ដល់ ២៥៨៣ (យោងទៅលើទស្សនាវដ្ដី ប.ក.ក.៖ *ទង់បដិវត្តន៍* បញ្ហាទី ៨ ឯកសារលេខ E3/5 ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00063336 ទំព័រ ២៦ និង*សូមមើលផងដែរ* ERN (ភាសាខ្មែរ) 00063318 ទំព័រ ៨។

[2510] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៧៨ ដល់ ២៥៧៩។

[2511] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៥២។

ជម្រះតុលាការកំពូលពិចារណាឃើញថា ដូចបានកត់សម្គាល់ខាងលើ ចាំបាច់ត្រូវកំណត់ថាតើ គោលនយោបាយក្នុងគោលបំណងសម្លាប់នោះ មានអត្ថិភាពនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដែរឬយ៉ាងណា។ ទោះជាយ៉ាងណាក្តី នេះពុំមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងលើភស្តុតាងក្រោយព្រឹត្តិការណ៍ ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីគោលនយោបាយនៅមុនព្រឹត្តិការណ៍បាននោះទេ ដរាបណាអង្គជំនុំជម្រះបានផ្តល់ហេតុផលគ្រប់គ្រាន់ទាក់ទងទៅនឹងមូលហេតុ ដែលភស្តុតាងនេះបានបង្ហាញអំពីការបន្តគោលនយោបាយនេះ ពុំមែនបង្ហាញគោលនយោបាយដែលត្រូវបានកែប្រែ ឬបង្កើតថ្មីឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងទូទៅរបស់ នួន ជា ទាក់ទងទៅនឹងភាពពុំជាប់ពាក់ព័ន្ធនៃភស្តុតាងក្រោយខែ មេសា ឆ្នាំ ១៩៧៥ ត្រូវបដិសេធចោល។

៩៥៧.ទាក់ទងទៅនឹងខ្លឹមសារនៃភស្តុតាង ដូច នួន ជា បានកត់សម្គាល់[2512] ឯកសារជាច្រើនជាក់ស្តែងពុំបានបង្ហាញថា មានការសម្លាប់បានកើតឡើងនោះទេ ប៉ុន្តែគ្រាន់តែបង្ហាញអំពីការចាប់ខ្លួន។ សំខាន់បំផុតនោះ នៅតែពុំមានភាពច្បាស់លាស់ថាតើ ឯកសារនេះអាចគាំទ្រដល់អត្ថិភាពនៃគោលនយោបាយក្នុងខែ មេសា ឆ្នាំ ១៩៧៥ យ៉ាងដូចម្តេចឡើយ។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើកំណត់ហេតុប្រជុំក្នុងខែ កញ្ញា ឆ្នាំ ១៩៧៦ របស់សមមិត្ត ១៦៤ ដើម្បីផ្តល់ការយល់ឃើញថា មានបទបញ្ជាឱ្យ“បន្ត”ប្រមូលប្រវត្តិរូប និងចាប់ខ្លួនអតីតទាហាន[2513]។ ទោះជាយ៉ាងណាក្តី តាមការពិនិត្យដោយល្អិតល្អន់លើភស្តុតាងឃើញថា កម្មាភិបាលខ្មែរក្រហមបានរកឃើញ“ផែនការរត់គេចខ្លួន”ដែលពាក់ព័ន្ធទៅនឹងមនុស្សចំនួន ៤០ នាក់ ដែលពុំមែនជាទាហាននៃរបបសាធារណរដ្ឋខ្មែរទាំងអស់នោះទេ[2514]។ ក្រោយមកមានការសម្រេចថា អ្នកដែលរត់ទាំងនេះត្រូវបានប្រមូលឱ្យមក“បង្កបង្កើនផលមួយដុំ” ប៉ុន្តែពុំបានយកទៅសម្លាប់ឡើយ[2515]។ មានការបង្ហាញពិតណាស់ថា

---

[2512] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥៧៧ ដល់ ៥៨០។

[2513] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៧។

[2514] កំណត់ហេតុកិច្ចប្រជុំសមមិត្ត ១៦៤ ឯកសារលេខ E3/813 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00162489 ទំព័រ ២។

[2515] កំណត់ហេតុកិច្ចប្រជុំសមមិត្ត ១៦៤ ឯកសារលេខ E3/813 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00162490 ទំព័រ ៣។

អតីតទាហានត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងយ៉ាងម៉ត់ចត់[2516] ទោះជាយ៉ាងណាក្តី យោងតាមកំណត់ហេតុនៃកិច្ចប្រជុំនោះ អ្នកទាំងនេះពុំត្រូវបានកំណត់គោលដៅដោយសារតែមានការជាប់ពាក់ព័ន្ធទៅនឹងរបបសាធារណរដ្ឋខ្មែរនោះឡើយ ប៉ុន្តែដោយសារការប្រឆាំងនឹងបទបញ្ជាទៅវិញ។ ឯកសារនេះសំដៅបន្ថែមទៀតលើការប្រព្រឹត្តចំពោះអ្នកដទៃទៀតដែលបានរត់ពីមុនៗ និងបានបង្ហាញថា អ្នកទាំងនេះត្រូវបាន"បែងចែកទៅតាមកងនានា" និងថា "អ្នកទាំងនេះភាគច្រើនបានកែប្រែល្អប្រសើរ" បើទោះបីជាមានអ្នកខ្លះ"មិនដែលបានឃើញត្រឡប់មកវិញ"ក៏ដោយ[2517]។ ជាសេចក្តីសន្និដ្ឋាន ឯកសារនេះពុំបានបង្ហាញថា មានគោលនយោបាយសម្លាប់ ឬថា គោលនយោបាយនេះពាក់ព័ន្ធជាក់លាក់ទៅនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរឡើយ ប៉ុន្តែ ទំនងជាវិធានការដែលត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការប្រឆាំងនឹងបទបញ្ជា រួមទាំង"ប្រជាជនមូលដ្ឋាន"ផងដែរ[2518] និងថា វិធានការទាំងនេះ យ៉ាងហោចណាស់សម្រាប់អ្នកប្រព្រឹត្តមិនល្អភាគច្រើន បាននាំទៅរកការចាប់ខ្លួន និងការផ្លាស់ទីលំនៅ។ ប្រហាក់ប្រហែលគ្នានេះដែរ បើទោះបីជាទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ បានរាយការណ៍អំពីវិធានការដែលត្រូវធ្វើឡើងប្រឆាំងនឹងអតីតទាហាន និង"ភ្នាក់ងារ"ដែលទទួលខុសត្រូវចំពោះសកម្មភាពបះបោរក៏ដោយ ក៏ពុំបានបង្ហាញឱ្យឃើញពីការភ្ជាប់ទំនាក់ទំនងទៅនឹងគោលនយោបាយដែលមានអត្ថិភាពក្នុងខែ មេសា ឆ្នាំ ១៩៧៥ និងពុំអាចចាត់ទុកជាភស្តុតាងអំពីគោលនយោបាយមិនរើសមុខបាននោះឡើយ[2519]។

៩៥៨.ទាក់ទងទៅនឹងទូរលេខ និងឯកសារដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានយោងនោះ[2520] ពិតជាបានបង្ហាញឱ្យឃើញពីការដាក់ចេញ និងអនុវត្តនូវសេចក្តីណែនាំឱ្យកំណត់អត្តសញ្ញាណ និង"បោសសម្អាត

---

[2516] កំណត់ហេតុកិច្ចប្រជុំសមមិត្ត ១៦៤ ឯកសារលេខ E3/813 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00162489 ទំព័រ ២ ("នៅក្នុងប្រជាជនេះ ភាគច្រើន[ក្នុងចំណោមប្រជាជនមូលដ្ឋាននេះពាក់ព័ន្ធទៅនឹងសកម្មភាពប្លែកផ្សេងៗ]ល្អ តែទាហានមានចលនាមិនល្អ") និង ERN (ភាសាខ្មែរ) 00143487 ទំព័រ ៣ ("សមាសភាពទាហានត្រូវប្រមូល")។

[2517] កំណត់ហេតុកិច្ចប្រជុំសមមិត្ត ១៦៤ ឯកសារលេខ E3/813 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00162489 ទំព័រ ២។

[2518] កំណត់ហេតុកិច្ចប្រជុំសមមិត្ត ១៦៤ ឯកសារលេខ E3/813 ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00162489 ទំព័រ ២។

[2519] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/511 ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00000766 ទំព័រ ១ ។

[2520] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៧៩។

ឱ្យស្អាត"ខ្លាំង រួមទាំង"អ្នកនៅសេសសល់"នៃរបបចាស់[2521]។ ទោះជាយ៉ាងណាក្តី ឯកសារទាំងអស់នេះចុះកាលបរិច្ឆេទដល់ឆ្នាំ ១៩៧៧ និង ១៩៧៨ ប៉ុន្តែពុំមានចំណុចណាមួយបានបញ្ជាក់ថា គោលនយោបាយពាក់ព័ន្ធទៅនឹងការសម្លាប់ដែលកើតមាននៅក្នុងអំឡុងពេលនៃការសម្លាប់នៅទួលពោធិ៍ជ្រៃឡើយ។

៩៥៩.ទាក់ទងទៅនឹងសក្ខីកម្មរបស់ Stephen HEDER ដែលថា ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៧៦ ផ្នែកសន្តិសុខបានទទួលសញ្ញាពីថ្នាក់ដឹកនាំបក្សថា ពួកគេត្រូវតែ"*បង្កើនការ*ប្រឹងប្រែងកំណត់អត្តសញ្ញាណអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបានរត់គេចខ្លួន"[2522]នោះ និងនៅតែពុំមានភាពច្បាស់លាស់ថា ការអះអាងនេះបានផ្អែកលើប្រភពអ្វីខ្លះនោះឡើយ។ បន្ថែមលើនេះទៀត ចម្លើយរបស់គាត់ពុំបានបញ្ជាក់ ថាតើសេចក្តីណែនាំនោះបានដាក់ចេញនៅពេលណា និងថាតើមានអ្វីកើតឡើងចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានកំណត់អត្តសញ្ញាណរួចហើយនោះ។

៩៦០.សរុបសេចក្តីមក ភស្តុតាងទាក់ទងទៅនឹងសេចក្តីណែនាំរបស់ ប.ក.ក. ឱ្យសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមកដល់ត្រឹមអំឡុងពេល ឬក្រោយពេលភ្លាមៗនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ មានកម្រិតខ្សោយ។ ភស្តុតាងទាក់ទងទៅនឹងអំឡុងពេលនៅក្រោយនោះ ទំនងជាមានកម្រិតខ្លាំងជាងនេះ ប៉ុន្តែខ្វះការភ្ជាប់ទំនាក់ទំនងច្បាស់លាស់ទៅនឹងខែ មេសា ឆ្នាំ ១៩៧៥។

## ៤.ង.១.ឃ.៥.ភាពសមហេតុផលនៃការសន្និដ្ឋានជាទូទៅ

៩៦១.អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើអំណះអំណាងទាក់ទងទៅនឹងភស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ ព្រមទាំងភស្តុតាងពាក់ព័ន្ធទៅនឹងការយល់ឃើញជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង។ ផ្អែកលើភស្តុតាង និងការយល់ឃើញទាំងនេះជារួម អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់

---

[2521] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៧៩ ដកស្រង់*ក្នុងចំណោមនោះ* ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/511 ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00000766 ទំព័រ ១ ។ សេចក្តីរាយការណ៍របស់អនុប្រធាន មឿន ទៅកាន់ស្រុកត្រាំកក់) ឯកសារលេខ E3/4141 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00079089 ទំព័រ ១។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/995 ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00019201 ទំព័រ ១។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/996 ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ ERN (ភាសាខ្មែរ) 00001084-5 ទំព័រ ១ ដល់ ២)។

[2522] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ២៥៧៤ (យោងទៅលើប្រតិចារឹកចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (Stephen HEDER) ឯកសារលេខ E1/222.1 ទំព័រ ៤៥ (សេចក្តីបញ្ជាក់បន្ថែម))។

01358520



ថាតើជាការសមហេតុផលសម្រាប់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសន្និដ្ឋានថា អត្ថិភាពនៃគោលនយោបាយដែលគ្រោងទុកជាមុននូវការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យនោះ មានភាពសមហេតុផល ដែរ ឬយ៉ាងណា។ គួររំឭកថា ក្នុងការផ្តល់ការយល់ឃើញរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើភស្តុតាងអំពីលំនាំនៃការសម្លាប់ផង និងលើសេចក្តីថ្លែងការណ៍ សេចក្តីសម្រេច និងបទបញ្ជារបស់ ប.ក.ក.។

៩៦២.ទាក់ទងទៅនឹងភស្តុតាងស្តីពីលំនាំ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទាក់ទងទៅនឹងអំឡុងពេលមុនឆ្នាំ ១៩៧៥ ដែលជាអំឡុងពេលសំខាន់ក្នុងការបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃនោះ មានភស្តុតាងបង្ហាញឱ្យឃើញនូវចំណុចមួយចំនួនថា មានការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរយ៉ាងច្រើនបានកើតឡើង ប៉ុន្តែភស្តុតាងនេះ មិនច្បាស់លាស់ មិនស៊ីសង្វាក់ ពុំមានការបញ្ជាក់បន្ថែម និងជាភស្តុតាងចចាមអារ៉ាម។ ពុំមានសាក្សីអង្គហេតុបានមកផ្តល់សក្ខីកម្មផ្ទាល់អំពីហេតុការណ៍នៅក្នុងអំឡុងពេលនោះទេ។ ភស្តុតាងជាច្រើនមានប្រភពមកពីឯកសារដែលបានបង្កើតឡើងសម្រាប់គោលបំណងផ្សេង ដែលពុំមែនសម្រាប់ប្រើប្រាស់នៅក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌឡើយ មានដូចជា របាយការណ៍ សក្ខីកម្មរបស់ជនភៀសខ្លួនដែលពុំបានធ្វើសម្បថ និងអត្ថបទកាសែតដែលមានតម្លៃភស្តុតាងទាប។ លើសពីនេះទៀត មានករណីជាច្រើនដែលកាលៈទេសៈជុំវិញការសម្លាប់ មានភាពមិនប្រាកដប្រជាទាក់ទងទៅនឹងបញ្ហា ថាតើការសម្លាប់នោះបានកើតឡើងនៅក្នុងស្ថានភាពពុំមែនជាការប្រយុទ្ធគ្នា ឬជាលទ្ធផលនៃការប្រព្រឹត្តអំពើហិង្សាមួយដាច់ដោយឡែក ដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលខ្លួនបានចាត់ទុកអំពើទាំងនេះថា ជាការបង្ហាញអំពីគោលនយោបាយដែលបង្កើតឡើងដោយមជ្ឈិមប្រឆាំងនឹងទាហាន ដែលពុំពាក់ព័ន្ធទៅនឹងការប្រយុទ្ធគ្នា។ ដូចគ្នានេះដែរ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មាន“ភស្តុតាងស៊ីសង្វាក់បង្ហាញអំពីការកែប្រែ”នូវគោលនយោបាយនោះ ក៏ពុំបានផ្តល់មូលដ្ឋានគាំទ្រច្បាស់លាស់ផងដែរ[2523]។ ជាសំខាន់ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការសម្លាប់នៅឧដុង្គ ដែលជាចំណុចសំខាន់នៃសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីអត្ថិភាពនៃគោលនយោបាយមុនឆ្នាំ ១៩៧៥ ពុំត្រូវបានធ្វើឡើងដោយសមហេតុផលឡើយ។

---

[2523] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២១។

៩៦៣.ទាក់ទងទៅនឹងអំឡុងពេលមុន និងក្រោយភ្លាមៗនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ មានហេតុការណ៍សម្លាប់តែពីរ ឬបីប៉ុណ្ណោះ ដែលអាចចាត់ទុកថា បានបង្ហាញឱ្យឃើញដោយសមហេតុផល ដូចជា ការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់ចំនួន ៤ នាក់ (ដែលពីរនាក់ត្រូវបាន"កំណត់គោលដៅ"ជាមុន ដើម្បីប្រហារជីវិត) និងទាហានដទៃទៀតក្នុងទីក្រុងភ្នំពេញ ការសម្លាប់ទាហានដែលមានឋានន្តរស័ក្តិធំៗនៅក្នុងខេត្តបាត់ដំបង ការសម្លាប់នៅពោធិ៍សាត់ (នៅទួលពោធិ៍ជ្រៃ) និងការសម្លាប់ទាហាន និងអ្នករដ្ឋការក្នុងខេត្តសៀមរាប។ ហេតុការណ៍ទាំងអស់នេះបានកើតឡើងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និង/ឬនៅថ្ងៃបន្ទាប់ ដែលជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តចំនួន ៤។ ការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់ចំនួន ៤ នាក់នៅទីក្រុងភ្នំពេញ បើទោះបីជាតាមរយៈទម្រង់នៃការប្រកាស និងការសម្លាប់ក៏ដោយ ក៏នៅតែជាលក្ខណៈខុសប្លែកពីព្រឹត្តិការណ៍ដទៃទៀតក្នុងចំណោមព្រឹត្តិការណ៍ទាំងឡាយដែលស្ថិតក្រោមការពិចារណានេះ។ ព្រឹត្តិការណ៍ទាក់ទងទៅនឹងការសម្លាប់ក្នុងខេត្តបាត់ដំបង រួមមានក្របខ័ណ្ឌនៃពេលវេលា និងទម្រង់នៃការសម្លាប់ មានភាពប្រហាក់ប្រហែលទៅនឹងព្រឹត្តិការណ៍ទាំងនោះដែលនាំទៅដល់ការសម្លាប់នៅទួលពោធិ៍ជ្រៃ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ហេតុការណ៍ក្នុងខេត្តបាត់ដំបងប្រាកដជា យ៉ាងហោចណាស់ត្រូវបានទទួលការយល់ព្រមពី រស់ ញឹម(ញឹម រស់) ជាលេខាភូមិភាគ ដែលត្រូវបានរកឃើញផងដែរថា បានចេញបញ្ជាឱ្យសម្លាប់នៅទួលពោធិ៍ជ្រៃ។ បើទោះបីជាព្រឹត្តិការណ៍ទាំងពីរនេះមានភាពប្រហាក់ប្រហែលគ្នាយ៉ាងខ្លាំងក៏ដោយ ក៏ពុំមានភាពច្បាស់លាស់ ថាតើ រស់ ញឹម(ញឹម រស់) បានប្រព្រឹត្តតាមឆន្ទៈរបស់ខ្លួនដោយឯករាជ្យ ឬស្របតាមគោលនយោបាយចេញពីមជ្ឈិមបក្ស ដែរ ឬយ៉ាងណានោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ក្នុងការសន្និដ្ឋានសមហេតុផលពីការសម្លាប់ដែលមានអត្ថិភាពនៃគោលនយោបាយដែលបានបង្កើតឡើងដោយមជ្ឈិមនោះ ចាំបាច់ត្រូវតែបង្ហាញឱ្យឃើញពីហេតុការណ៍មួយចំនួនទៀតនៃការសម្លាប់ដែលបានកើតឡើងក្នុងភូមិភាគផ្សេងៗទៀត។ ទោះជាយ៉ាងណាក្តី ក្នុងរឿងក្តីបច្ចុប្បន្ននេះ ហេតុការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញឱ្យឃើញដោយសមហេតុផលនោះ មានតែពីរ ឬបីប៉ុណ្ណោះ និងស្ថិតក្នុងកម្រិតត្រឹមតែផ្នែកតូចមួយនៃតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម។ ជាការពិតក្រៅតែពីហេតុការណ៍ចំនួន ២ ដែលបានសន្មតថា ជាអំពើរបស់ រស់ ញឹម(ញឹម រស់) និងហេតុការណ៍សម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៅក្នុងទីក្រុងភ្នំពេញដែលមានលក្ខណៈខុសប្លែកពីគេនោះ គឺនៅមានការសម្លាប់មួយទៀតដែលបានកើតឡើងក្នុងខេត្តសៀមរាប និងការសម្លាប់ទាហាននៅក្នុងទីក្រុងភ្នំពេញ។ អាស្រ័យហេតុនេះ ហេតុការណ៍ទាំងនេះបើសូម្បី

ពិចារណាជារួមក៏ដោយ ក៏ពុំអាចចាត់ជាមូលដ្ឋានរឹងមាំបញ្ជាក់ពីអត្ថិភាពនៃគោលនយោបាយដែលបង្កើតឡើងដោយមជ្ឈិម ដែលមានគោលបំណងក្នុងការសម្លាប់នោះឡើយ។

៩៦៤. ទាក់ទងទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងនៃការចាប់ខ្លួន ដែលបានកើតឡើងនៅមុន ឬក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ផ្អែកតាមហេតុការណ៍ជាច្រើននៃការចាប់ខ្លួន និងដូចអង្គជំនុំជម្រះបានទទួលស្គាល់ផងដែរនោះ[2524] ការចាប់ខ្លួនទាំងនេះ ជាលទ្ធផល បានបណ្ដាលឱ្យមានការផ្លាស់ទីលំនៅ ការឃុំខ្លួន ការធ្វើការជាទម្ងន់ និង/ឬចុងក្រោយត្រូវបានដោះលែង[2525]។ អាស្រ័យហេតុនេះ ភស្តុតាងនេះពុំអាចចាត់ជាមូលដ្ឋានរឹងមាំបញ្ជាក់ពីអត្ថិភាពលំនាំនៃ*ការសម្លាប់*ឡើយ។ បន្ថែមលើនេះ ភស្តុតាងនេះក៏បានបង្ហាញផងដែរថា មានការប្រឹងប្រែងក្នុងការកំណត់អត្តសញ្ញាណ និងការស្វែងរកបុគ្គលដែលមានតួនាទីក្នុងកម្រិតមួយ ជាពិសេស ក្នុងជួរទាហាន[2526]។

៩៦៥.ទាក់ទងទៅនឹងភស្តុតាងនៃការសម្លាប់ក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងជាចម្បងទៅលើឯកសារក្រៅតុលាការ ដែលភាពជឿជាក់ និងភាពជឿទុកចិត្តបាននៃឯកសារនេះ ពុំត្រូវបានដោះស្រាយច្បាស់លាស់ ដូច្នេះភស្តុតាងទាំងនេះមានមូលដ្ឋានខ្សោយ។ មានតែការរៀបរាប់មួយគត់ដែលបានផ្ដល់ដោយសាក្សីនៅចំពោះមុខតុលាការ ដែលជាប់ពាក់ព័ន្ធទៅនឹងហេតុការណ៍មួយដាច់ដោយឡែក ដែលពុំមែនជាការបង្ហាញឱ្យឃើញពីគោលនយោបាយទូលំទូលាយ និងទូទៅនោះទេ។ អ្វីដែលសំខាន់បំផុតនោះគឺថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលខ្លួនធ្វើសេចក្ដីសន្និដ្ឋានថា ភស្តុតាងពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើងយ៉ាងយូរមកហើយ ក្រោយខែ មេសា ឆ្នាំ ១៩៧៥ នោះ បានបង្ហាញថា ហេតុការណ៍នេះ គឺជាលទ្ធផលនៃគោលនយោបាយដែលមានអត្ថិភាពនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ មិនមែនជាគោលនយោបាយបង្កើតថ្មី ឬត្រូវបានកែប្រែនោះឡើយ។

---

[2524] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៥៥ ជើងទំព័រ ១៦៥៧ ដល់ ១៦៥៨ (យោងទៅលើកថាខណ្ឌ ៥១៣ ដល់ ៥១៤)។

[2525] *សូមមើលខាងលើ.* ជើងទំព័រ ២៣២៧, ២៣៦៤ និង ២៣៧០, ២៣៦៨, ២៣៨១, ២៤០២, ២៤០៨។ *សូមមើលផងដែរ* របាយការណ៍របស់ Stephen HEDER និង Masato MATSUSHITA៖ កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅតាមព្រំដែនខ្មែរថៃ ឯកសារលេខ E3/1714 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨០ ERN (ភាសាខ្មែរ) 00324712 ទំព័រ ៤១, ERN (ភាសាខ្មែរ) 00324738-9 ទំព័រ ៦៧ ដល់ ៦៨, ERN (ភាសាខ្មែរ) 00324752-3 ទំព័រ ៨១ ដល់ ៨២។

[2526] *សូមមើលខាងលើ.* កថាខណ្ឌ ៤៦៦, ៨៩៦ ដល់ ៨៩៨, ៩៤៥, ៩៤៩ និងជើងទំព័រ ២៣៤៧, ២៣៨៣, ២៣៩៩, ២៤០៨។

ហេតុការណ៍ដែលអង្គជំនុំជម្រះបានយោងទៅលើ ដែលភាគច្រើនមានកាលបរិច្ឆេទដល់ឆ្នាំ ១៩៧៦ និងនៅពេលក្រោយមកទៀតនោះ ពុំមានការជាប់ពាក់ព័ន្ធជាក់លាក់ទៅនឹងអំឡុងពេលមុនព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃឡើយ[2527]។ ផ្ទុយទៅវិញ មានភស្តុតាងបញ្ជាក់ថា គោលនយោបាយយ៉ាងទូលំទូលាយមួយប្រឆាំងនឹងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទើបតែត្រូវបានយកមកអនុវត្តនៅក្រោយខែ មេសា ឆ្នាំ ១៩៧៥ ប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើបញ្ហានេះឡើយ។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើផ្នែកមួយនៃសក្ខីកម្មរបស់ ឌុច ដែលគាត់បាននិយាយថា ឯកសារដែលគេបង្ហាញគាត់ គឺសំដៅដល់ការឃុំខ្លួន និងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងឆ្នាំ ១៩៧៦ ដែលពុំមែនធ្វើនៅក្នុងឆ្នាំ ១៩៧៥ នោះទេ។ ប្រហាក់ប្រហែលគ្នាដែរ តាមការបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍របស់ អៀង សារី ឃើញថា គោលនយោបាយចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទើបតែត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៧៦ ប៉ុណ្ណោះ[2528]។

៩៦៦.សរុបសេចក្តីមក ភស្តុតាងមានកម្រិតខ្សោយដែលបានបង្ហាញឱ្យឃើញពីលំនាំនៃការសម្លាប់នៅក្នុងអំឡុងពេលនៅមុន ឬនៅថ្ងៃមានព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ។

៩៦៧.ចំពោះភស្តុតាងពាក់ព័ន្ធទៅនឹងគោលជំហរជាទូទៅរបស់ ប.ក.ក. ស្តីពីមនោគមវិជ្ជារបស់កុម្មុយនីស្តចំពោះសត្រូវ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ជាការគួរឱ្យជឿជាក់ថា សេចក្តីថ្លែងការណ៍របស់បក្សដែលបានដកស្រង់នោះអាចត្រូវចាត់ទុកបានថា ជាការត្រួសត្រាយផ្លូវសម្រាប់គោលនយោបាយដែលកំណត់គោលដៅសម្លាប់ខ្មាំង។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលសេចក្តីថ្លែងការណ៍អរូបីយទូទៅអំពីទ្រឹស្តីកុម្មុយនីស្ត និងការតស៊ូវណ្ណៈបានអនុញ្ញាតឱ្យខ្លួនអាចសន្និដ្ឋានបានយ៉ាងសមហេតុផលថា មានគោលនយោបាយសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរឡើយ។

៩៦៨. ទាក់ទងទៅនឹងសេចក្តីណែនាំរបស់ ប.ក.ក. ឱ្យសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ភស្តុតាងមានដូចជា៖ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ខឹម សំហួន

---

[2527] *សូមមើលខាងលើ* កថាខណ្ឌ ៩១៤, ៩៥៥ ដល់ ៩៥៦, ៩៥៨។

[2528] *សូមមើលឧ. សូមមើល* កិច្ចសម្ភាសន៍របស់ Elizabeth BECKER ជាមួយនឹង អៀង សារី ឯកសារលេខ E3/94 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ERN (ភាសាខ្មែរ)00578899 ទំព័រ ៨ (បានអះអាងថា រស់ ញឹម និង សោ ភឹម គឺជាមនុស្សទីមួយដែលបែកចែកប្រជាជនទៅតាមប្រភេទ និងថា ក្រោយមក "ការបែងចែកនេះត្រូវបានទទួលយកដោយថ្នាក់ដឹកនាំ"តែក្នុងឆ្នាំ ១៩៧៦ ប៉ុណ្ណោះដែលថ្នាក់ដឹកនាំសម្រេចបែងចែកតាមប្រភេទ រួមទាំងក្រុម"អ្នកដែលគាំទ្រ លន់ នល់ ផងដែរ")។

បទសម្ភាសន៍របស់ អៀង សារី ជាមួយ Stephen HEDER “សេចក្ដីសម្រេច”របស់កម្ពុជាប្រជាធិបតេយ្យ ឯកសារមួយចំនួនរបស់កម្ពុជាប្រជាធិបតេយ្យនៅសម័យនោះ និងរបាយការណ៍របស់គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិ។ ទោះជាយ៉ាងណាក្ដី ភស្តុតាងនីមួយៗមានកម្រិតខ្សោយដែលបានកាត់បន្ថយយ៉ាងច្រើននូវតម្លៃជាភស្តុតាង ដោយហេតុថា ទីមួយ ពុំមានការរៀបរាប់ត្រូវបានធ្វើឡើងដោយសាក្សីផ្ទាល់ណាម្នាក់។ ទីពីរ ចម្លើយរបស់ អៀង សារី របាយការណ៍របស់គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិ និងចម្លើយរបស់ ខឹម សំហួន ទាក់ទងទៅនឹងការសម្លាប់នោះ គឺជាភស្តុតាងចចាមអារ៉ាម។ ទីបី ពុំមានការរៀបរាប់ណាមួយដែលអាចបញ្ជាក់បានពីគោលនយោបាយទូទៅឡើយ។ ផ្ទុយទៅវិញ ភស្តុតាងទាំងអស់នេះសំដៅលើហេតុការណ៍ជាក់លាក់ ជាពិសេស“សេចក្ដីសម្រេច”របស់កម្ពុជាប្រជាធិបតេយ្យ ដែលផ្ទុយទៅនឹងអត្ថិភាពនៃគោលនយោបាយទូទៅចាប់ពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៥។ ទីបួន ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ មានអត្ថិភាពក្រោយព្រឹត្តិការណ៍ទួលពោធិ៍ជ្រៃ។ ឯកសារពីរដែលមានអត្ថិភាពភ្លាមៗបន្ទាប់ពីព្រឹត្តិការណ៍ទួលពោធិ៍ជ្រៃ រហូតដល់ឆ្នាំ ១៩៧៦ ជាក់ស្ដែង ជាប់ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលខ្មែរក្រហមទំនងជាឆ្លើយតបទៅនឹងការប្រឆាំងនឹងបទបញ្ជា និងសកម្មភាពបង្កការរំខាននានា ដោយពុំគិតថា ជនល្មើសនោះស្ថិតក្នុងប្រភេទណាឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ភស្តុតាងក្រោយឆ្នាំ ១៩៧៥ នៃការណែនាំរបស់បក្សទំនងជាមានលក្ខណៈរឹងមាំ ប៉ុន្តែអង្គជំនុំជម្រះរកពុំឃើញមានទំនាក់ទំនងច្បាស់លាស់ជាមួយនឹងអំឡុងពេលពាក់ព័ន្ធបទចោទនោះឡើយ។ បន្ថែមលើនេះទៀត ឯកសារនេះពុំបានបង្ហាញឱ្យឃើញថា ការសម្លាប់ត្រូវបានគិតទុកជាមុននៅក្នុងគោលនយោបាយរបស់បក្សឡើយ។ អាស្រ័យហេតុនេះ ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងក្នុងការបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពុំមានមូលដ្ឋានរឹងមាំ និងស៊ីសង្វាក់គ្នាឡើយ។ បន្ថែមលើនេះទៀត មានចំណុចខ្លះ ភស្តុតាងនេះបានចង្អុលទៅលើគោលនយោបាយដែលពុំមានលក្ខណៈទូទៅ ប៉ុន្តែសំដៅលើហេតុការណ៍ជាក់លាក់នៃការរំខាន ដោយពុំមានការជាប់ពាក់ព័ន្ធ ឬមានជាប់ពាក់ព័ន្ធតិចតួចទៅនឹងអតីតភាពនៅក្នុងសង្គមរបស់ជនល្មើសនោះឡើយ។

៩៦៩.ចំពោះភស្តុតាងដែល នួន ជា បានលើកឡើងថា ជាភស្តុតាងដោះបន្ទុកនោះ សាក្សី ភី ភួន ដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថា អាចជឿជាក់បាននោះ បានបញ្ជាក់ពីបទបញ្ជាហាមប៉ះពាល់ទាហាននៃរបបសាធារណរដ្ឋខ្មែរដែលចាប់បាននៅក្នុងសមរភូមិ។ សាក្សី អៀង ផាន ក៏បានបញ្ជាក់ពីអត្ថិភាពនៃបទបញ្ជានោះផងដែរ។ អង្គជំនុំជម្រះសាលាដំបូងពុំបានវាយតម្លៃសក្ខីកម្មនេះទេ នៅពេលដោះស្រាយអំពីការប្រព្រឹត្តលើទាហានដែលចាប់បាននៅពេលប្រយុទ្ធ ដែលសក្ខីកម្មនេះបានបញ្ជាក់ផងដែរថា ជាទូទៅ ពុំមានគោលនយោ

បាយប្រឆាំងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរឡើយ។ អត្ថិភាពនៃគោលនយោបាយសម្លាប់នេះនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ មានភាពមិនច្បាស់លាស់ថែមទៀត ដោយសារសក្ខីកម្មរបស់សាក្សី ជុំ សុខា សៅ វ៉ន និង ពេជ្រ ជឹម និងកិច្ចសម្ភាសន៍របស់ ហេង សំរិន។ បើទោះជាសាក្សី សៅ វ៉ន ហាក់បីដូចជាបានកំណត់កាលបរិច្ឆេទនៃការចេញបទបញ្ជា មិនឱ្យប៉ះពាល់ទាហាននៃរបបសាធារណរដ្ឋខ្មែរដល់ខែ ឧសភា ឬមិថុនា ឆ្នាំ ១៩៧៥ ក៏ដោយ ក៏សក្ខីកម្មរបស់គាត់ពុំបានបញ្ជាក់ឱ្យឃើញថា បទបញ្ជានេះបានជំនួសឱ្យបទបញ្ជាឱ្យសម្លាប់ពីមុនណាមួយឡើយ។ ប្រហាក់ប្រហែលគ្នានេះដែរ ការរៀបរាប់របស់ ហេង សំរិន បានបង្ហាញថា នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ពុំមានបទបញ្ជាឱ្យសម្លាប់ចេញពីថ្នាក់ដឹកនាំបក្សឡើយ។

៩៧០.សរុបសេចក្តីមក ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ មានកម្រិតខ្សោយ ពុំមានភាពច្បាស់លាស់ និងមានតម្លៃទាប និងចោទជាបញ្ហាដោយសារភស្តុតាងដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា មានការរៀបរាប់មួយចំនួននៅក្នុងសំណុំរឿងដែលពិពណ៌នាអំពីការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ទោះជាយ៉ាងណាក្តី ការរៀបរាប់ទាំងនេះភាគច្រើនលើសលុបបានមកពីចម្លើយក្រៅតុលាការ ដែលពុំមែនផ្អែកលើសក្ខីកម្មផ្ទាល់ ដូច្នេះហើយមានតម្លៃជាភស្តុតាងទាបបន្ថែមទៅលើកង្វះព័ត៌មានលម្អិត និងភាពស្រពិចស្រពិលទាក់ទងទៅនឹងចំណុចសំខាន់ៗនៃហេតុការណ៍ដែលបានពិពណ៌នានោះ។ ការពិចារណារបស់អង្គជំនុំជម្រះតុលាការកំពូលឃើញថា ការពុំបានវាយតម្លៃឱ្យបានគ្រប់គ្រាន់លើភស្តុតាង គឺជាកត្តាមួយទៀតដែលសំខាន់នៅក្នុងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយបញ្ហាជាមូលដ្ឋានដែលមានឥទ្ធិពលលើទម្ងន់នៃភស្តុតាង ដូចជា ខ្វះភាពសមហេតុផលក្នុងការបកស្រាយផ្សេងៗពាក់ព័ន្ធទៅនឹងការប្រើប្រាស់ពាក្យពេចន៍ថា "ខ្មាំង"នៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរនៅពេលប្រយុទ្ធ និងជាទូទៅ ភស្តុតាងអាចបកស្រាយក្នុងន័យច្រើនយ៉ាងដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជាភស្តុតាងដាក់បន្ទុកដោយពុំបានផ្តល់ការពន្យល់គ្រប់គ្រាន់ឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការពិចារណាសមស្របបន្ថែមទៀតលើលទ្ធភាពដែលថា ការសម្លាប់មួយចំនួនដូចជានៅទួលពោធិ៍ជ្រៃ អាចត្រូវបានបញ្ជាដោយឯករាជ្យនៅកម្រិតថ្នាក់ភូមិភាគ ដែលអាចមានន័យថាពុំត្រូវបានយកមកពិចារណាក្នុងការបង្ហាញនូវលំនាំទូទាំងប្រទេស ជាពិសេស ដោយសារពុំមានភស្តុតាងរឹងមាំបង្ហាញឱ្យឃើញពីហេតុការណ៍ដទៃទៀតដែលបានកើតឡើងនៅកន្លែងផ្សេងទៀតនៃទឹកដីក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា

ភស្តុតាងដែលមានអត្ថិភាពក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ជាទូទៅទំនងជារឹងមាំជាងភស្តុតាងដែលមានអត្ថិភាពមុនព្រឹត្តិការណ៍នោះ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងពុំបានលើកមូលដ្ឋានគាំទ្រមូលហេតុដែលភស្តុតាងនេះអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានអំពីអត្ថិភាពនៃគោលនយោបាយ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃនោះទេ។

៩៧១.អង្គជំនុំជម្រះតុលាការកំពូលរំឮកទាក់ទងទៅនឹងបរិបទនេះថា ដោយសារការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ទើបវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលពាក់ព័ន្ធទៅនឹងគោលនយោបាយប្រឆាំងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានកម្រិតត្រឹមព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃដែលបានកើតឡើងនៅចុងខែមេសា ឆ្នាំ ១៩៧៥ ប៉ុណ្ណោះ។ លទ្ធផលចុងក្រោយនៃការពិចារណានេះ ទទួលរងនូវផលប៉ះពាល់ដោយសារការកម្រិតពេលវេលា ដែលធ្វើឱ្យភស្តុតាងមួយផ្នែកធំទៅជាលែងជាប់ពាក់ព័ន្ធតាមពេលវេលានេះ ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញពីមូលហេតុអ្វីបានជាសេចក្តីណែនាំចេញក្នុងឆ្នាំ ១៩៧៦ និងក្រោយមក បង្ហាញដោយប្រយោលថា គោលនយោបាយមានអត្ថិភាពក្នុងខែ មេសា ឆ្នាំ ១៩៧៥ ទៅវិញនោះ។

៩៧២.យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការពុំសមហេតុផលក្នុងការរកឃើញឱ្យហួសពីវិមតិសង្ស័យថា គោលនយោបាយកំណត់គោលដៅសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ។ អាស្រ័យហេតុនេះ គោលបំណងរួមប្រព្រឹត្តបទល្មើសទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ពុំត្រូវបានបង្ហាញឱ្យឃើញ ហើយជនជាប់ចោទពុំអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា បានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃបានឡើយ ។

## ៤.ង.១.ង.បរិបទនយោបាយទូទៅ និងការយល់ឃើញដែលថា ប.ក.ក. បានអនុវត្តគោលនយោបាយស្តីពីការតស៊ូប្រដាប់អាវុធ

៩៧៣.ខៀវ សំផន បានអះអាងថា ជាញឹកញាប់ អង្គជំនុំជម្រះសាលាដំបូងមិនបានអើពើទៅលើបរិបទនយោបាយទូទៅក្នុងអំឡុងពេលអង្គហេតុ ជាពិសេសសង្គ្រាមត្រជាក់ និងជាលទ្ធផល បានបកស្រាយពុំត្រឹមត្រូវលើពាក្យពេចន៍ដែលបានប្រើប្រាស់នៅពេលនោះ។ ខៀវ សំផន បានលើកឡើងថា ការមិនអើពើក្នុងការពិចារណាបរិបទនេះបានបណ្តាលឱ្យអង្គជំនុំជម្រះសាលាដំបូង បកស្រាយគោលបំណងដែលក្នុងបរិបទនោះ“ត្រូវបានចាត់

ទុកជាថ្លៃថ្នូរត្រឹមត្រូវស្របច្បាប់" ទៅជា"ភស្តុតាងបង្ហាញអំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋ" ដែលនេះនាំទៅរកការបំភ្លៃភស្តុតាង[2529]។ ខៀវ សំផន ក៏បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ប.ក.ក. បានអនុវត្តគោលនយោបាយដោយប្រើប្រាស់ការតស៊ូប្រដាប់អាវុធនៅដើមឆ្នាំ ១៩៦០ ដែលនេះនាំឲ្យអង្គជំនុំជម្រះសន្និដ្ឋានពុំត្រឹមត្រូវថា គោលបំណងរួមនេះមានចរិតជាបទល្មើស[2530]។ ស្រដៀងគ្នានេះដែរ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់អំពីមូលហេតុដែលខ្លួនពុំបានពិចារណាទៅលើជម្លោះប្រដាប់អាវុធទូទៅ រួមទាំងការទម្លាក់គ្រាប់បែករបស់អាម៉េរិកលើប្រទេសកម្ពុជា និង*ការធ្វើរដ្ឋប្រហារ*របស់ លន់ នល់ ដែលនេះនាំឲ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ចលនាខ្មែរក្រហម គឺជាចលនា "ហិង្សាពិតប្រាកដ" ដែលនេះ គឺជាមូលដ្ឋានសម្រាប់ការយល់ឃើញថា គោលបំណងរួមជាបទល្មើស[2531]។

៩៧៤.សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងគោលនយោបាយរបស់ ប.ក.ក. ដែលប្រើប្រាស់ការតស៊ូប្រដាប់អាវុធនោះ ពុំមានសក្តានុពលអាចមោឃៈការសម្រេចដាក់ពិរុទ្ធភាព ឬនាំឲ្យមានភាពមិនយុត្តិធម៌នោះឡើយ[2532]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានពិចារណាថា ខ្មែរក្រហមមានជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ[2533]។

៩៧៥.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ពុំបានចង្អុលបង្ហាញអំពីកំហុសណាមួយនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ និងពុំបានពន្យល់អំពីផលប៉ះពាល់នៃកំហុសនោះដែលមានឥទ្ធិពលទៅលើការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ទាក់ទងទៅនឹងបញ្ហានេះឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា គោលបំណងរួមនេះជាបទល្មើស នោះឡើយ ដោយសារគោលបំណងរួមនេះ ជាការកសាងបដិវត្តន៍សង្គមនិយម ឬជាការព្យាយាមផ្តួលរំលំ លន់ នល់ ប៉ុណ្ណោះ។ ផ្ទុយទៅវិញ ដូចបានលើកឡើងខាងលើ[2534] ការអនុវត្តគោលបំណងរួមនេះ គឺជាបទល្មើស ដោយសារជាប់ពាក់

---

[2529] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៥០ ដល់ ១៥១។

[2530] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៥៣ ដល់ ១៥៥។

[2531] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៥៦ ដល់ ១៥៨។

[2532] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣៤។

[2533] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០០។

[2534] *សូមមើលខាងលើ* កថាខណ្ឌ ៨១៤ ដល់ ៨១៧។

ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការនេះ។ លើសពីនេះទៀត ដូចដែលសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញ អង្គជំនុំជម្រះសាលាដំបូងបានលើកបង្ហាញឱ្យឃើញអំពីបរិបទជាប្រវត្តិឧក្រិដ្ឋកម្មនៅក្នុងផ្នែកផ្សេងៗនៃសាលក្រម[2535]។ ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលអាចត្រូវបានយល់ថា ជម្លោះប្រដាប់អាវុធទូទៅបានធ្វើយុត្តិកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋ ដែលការលើកឡើងបែបនេះពុំមានមូលដ្ឋានច្បាប់ណាមួយគាំទ្រឡើយ។

## ៤.ង.១.ច.បទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការរួមចំណែកក្នុងគោលបំណងរួម

៩៧៦.តាមការបង្ហាញលម្អិតបន្ថែមនៅខាងក្រោម ក្នុងការយល់ឃើញថា នួន ជា និង ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងរួមនេះ ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ*ក្នុងចំណោមនោះ* សកម្មភាពដែលពុំជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋតាមរយៈការផ្លាស់ទីលំនៅប្រជាជន ឬគោលនយោបាយកំណត់គោលដៅ ប៉ុន្តែជាទូទៅជាប់ពាក់ព័ន្ធទៅនឹងការកសាងបដិវត្តន៍សង្គមនិយមមួយនៅប្រទេសកម្ពុជា។

---

[2535] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៧ (យោងទៅលើយុទ្ធនាការទម្លាក់គ្រាប់បែករបស់អាម៉េរិកមកលើប្រទេសកម្ពុជាពីចន្លោះឆ្នាំ ១៩៦៩ ដល់ ១៩៧៣ និងលក្ខខណ្ឌនៃការរស់នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ក្នុងប្រទេសកម្ពុជា) ៩៤ (ពិពណ៌នាអំពីបរិបទភូមិសាស្ត្រពាក់ព័ន្ធទៅនឹងជម្លោះរវាងវៀតណាម និងសហរដ្ឋអាម៉េរិក និងឥទ្ធិពលមកលើកម្ពុជា) ៩៦ (យោងទៅលើវិបត្តិសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និងសម្ពាធបន្ថែមទៀតពាក់ព័ន្ធទៅនឹងជម្លោះវៀតណាម) ១២១ (ឥទ្ធិពលមួយនៃការទម្លាក់គ្រាប់បែករបស់អាម៉េរិក គឺថា "បានធ្វើឱ្យប្រជាជនខឹងសម្បាខ្លាំង និងសង្ស័យលើអ្នកខាងក្រៅ" ១៥៣ ដល់ ១៥៦ (រៀបរាប់លម្អិតអំពីយុទ្ធនាការយោធាទម្លាក់គ្រាប់បែកអាម៉េរិកមកលើប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៦៩ ដល់ ១៩៧៣ ដែលជាប់ពាក់ព័ន្ធទៅនឹង "គ្រាប់បែករាប់រយពាន់តោន"ដែលបានទម្លាក់ បន្ថែមលើកងទ័ពថ្មើរជើងដែលបានចល័តចាប់ពីខែ មេសា រហូតដល់ ខែ មិថុនា ឆ្នាំ ១៩៧០។ ការទម្លាក់គ្រាប់បែកបានបង្កឱ្យមានការស្លាប់ប្រជាជនកម្ពុជា"រាប់ម៉ឺននាក់" និងធ្វើឱ្យអ្នកដែលរស់នៅតាមតំបន់ជនបទស្វែងរកការជ្រកកោនក្នុងទីក្រុងភ្នំពេញ) ១៥៧ ដល់ ១៦០ (ជនភៀសខ្លួនបានកើនឡើងក្នុងទីក្រុងភ្នំពេញពីមួយលានកន្លះទៅពីរលានក្នុងរយៈពេលប្រាំឆ្នាំ។ កិច្ចសម្ភាសន៍របស់ជនភៀសខ្លួនបានយោងការទម្លាក់គ្រាប់បែកនេះ និងការកើនឡើងរបស់ខ្មែរក្រហម ធ្វើជាមូលហេតុសម្រាប់ការស្វែងរកន្លែងជ្រកកោន។ ស្ថានភាពនៅក្នុងជំរំជនភៀសខ្លួន និងទូទាំងទីក្រុងភ្នំពេញ មានលក្ខណៈធ្ងន់ធ្ងរ កង្វះស្បៀងអាហារ។ នៅពេលខ្មែរក្រហមចាប់ផ្តើមវាយប្រហារផ្លូវដែលសហរដ្ឋអាម៉េរិកប្រើប្រាស់សម្រាប់ផ្តល់ជំនួយស្បៀងអាហារទៅតំបន់ដែលកាន់កាប់ដោយរដ្ឋាភិបាល លន់ នល់ ស្ថានភាពស្បៀងអាហារកាន់តែអាក្រក់ឡើងៗ។ នៅពេលខ្លះ ស្បៀងអាហារផ្គត់ផ្គង់បានតែរយៈពេលបីថ្ងៃប៉ុណ្ណោះ មានទុរភិក្សរាលដាលគ្រប់ទីកន្លែង។

៩៧៧.បើទោះបីជាពុំបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីកំហុសអង្គច្បាប់ពាក់ព័ន្ធទៅនឹងបញ្ហានេះក៏ដោយ[2536] ក៏ នួន ជា បានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការរួមចំណែករបស់គាត់ "គឺជាការយល់ឃើញដែលថា [គាត់] បានចូលរួមចំណែកយ៉ាងសំខាន់ដល់បដិវត្តន៍សង្គមនិយមមួយ មិនមែនមានន័យថា គាត់បានរួមចំណែកក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋនោះឡើយ"[2537]។

៩៧៨.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ ថាតើគាត់ជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពឧក្រិដ្ឋ ឬទៅនឹងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម យ៉ាងដូចម្តេច ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នោះ និងថា មិនមែនជាបទល្មើស(ទាំងស្រុង) នោះឡើយ[2538]។ ខៀវ សំផន បានអះអាងថា ការយល់ស្របតាមមាគ៌ាបក្សដែលមិនមែនជាបទឧក្រិដ្ឋនោះ ពុំអាចបង្កើតឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញពីចេតនាឧក្រិដ្ឋតម្រូវរបស់គាត់ ព្រមទាំងថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយសារការរួមចំណែករបស់គាត់ក្នុងគោលបំណងរួមដែលគ្រាន់តែជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនោះ គឺជាការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ III[2539]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ការចូលរួមចំណែករបស់គាត់បានបំពេញលក្ខខណ្ឌតម្រូវ ក្នុងការដាក់ឲ្យគាត់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌស្ថិតក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម[2540]។ ជាពិសេស ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារអង្គជំនុំជម្រះបានផ្អែកទៅលើវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលនានា[2541] ការថ្លែងសុន្ទរកថា[2542] តួនាទី

---

[2536] កត់សម្គាល់ជាពិសេសថា នួន ជា ពុំបានលើកឡើងថា តាមផ្លូវច្បាប់ ការរួមចំណែកដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញពីការទទួលខុសត្រូវក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមឡើយ និងសញ្ញាណនេះពុំមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ (*សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦១៧)។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ(និងបដិសេធចោល)ទឡ្ហីករណ៍នេះខាងលើ(*សូមមើលខាងលើ* កថាខណ្ឌ ៧៧០ *ជាអាទិ៍* ៨០៧, ៨១០, ៨៤៥)។

[2537] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦១៦។

[2538] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣១។

[2539] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣១។

[2540] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩២ ដល់ ២៩៥, ៣១៦, ៥៩៩ ដល់ ៦០១, ៦២៤។

[2541] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩៨ ដល់ ៣០១, ៦០៤ ដល់ ៦០៧។

[2542] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣០៦ ដល់ ៣០៧, ៦១២ ដល់ ៦១៣។

របស់គាត់ក្នុងការទំនាក់ទំនងជាមួយនឹងសម្តេច នរោត្តម សីហនុ និងសកម្មភាពការទូតរបស់គាត់[2543] មុខតំណែងផ្សេងៗទៀតរបស់គាត់ក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ[2544] និងកេរ្តិ៍ឈ្មោះរបស់គាត់[2545] ដោយបានសន្និដ្ឋានថា គាត់បានរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួមនេះ។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងទៅលើព្រឹត្តិការណ៍ដែលកើតឡើងក្នុងសម័យនោះ ឬក្រោយអង្គហេតុនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយដែលរងការចោទប្រកាន់ ដោយបានយល់ឃើញថា ការរួមចំណែករបស់គាត់ក្នុងគោលបំណងរួមនោះ មានលក្ខណៈសំខាន់[2546]។ ខៀវ សំផន ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ការរួមចំណែករបស់គាត់នៅមុន និងក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ គឺគ្រប់គ្រាន់ក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ឱ្យទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម[2547]។ ហេតុដូច្នេះ នួន ជា និង ខៀវ សំផន បានលើកឡើងថា ការរួមចំណែករបស់ពួកគាត់ដែលសំដៅលើការកសាងបដិវត្តន៍សង្គមនិយម ពុំមែនជាបទឧក្រិដ្ឋជាក់លាក់ដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃនោះ ពុំអាចធ្វើជាមូលដ្ឋានក្នុងការយល់ឃើញដែលថា ពួកគាត់បានរួមចំណែកយ៉ាងសំខាន់នៅក្នុងសហឧក្រិដ្ឋកម្មរួមនោះឡើយ[2548]។

៩៧៩.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន មានការភាន់ច្រឡំលើបទដ្ឋានគតិយុត្តត្រឹមត្រូវទាក់ទងទៅនឹងការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម ដោយសារគាត់បានគិតថា ពាក្យ"សំខាន់" និង"ច្រើន" ជាពាក្យ

---

[2543] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣០៨ ដល់ ៣១១, ៦១៨ ដល់ ៦២១។

[2544] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦០៨ ដល់ ៦០៩ (ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរប៉ុណ្ណោះ)។

[2545] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១២ ដល់ ៣១៣ និង ៦១៦ ដល់ ៦១៧។

[2546] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤០២ ដល់ ៤១២។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៤៤។

[2547] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៤១ ដល់ ៤៤៤។

[2548] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩២ ដល់ ៣១៦។ សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦១៦។

តែមួយ និងថា ខៀវ សំផន ពុំទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការរួមចំណែកទាំងមូលរបស់គាត់ថា ជាការ*សំខាន់*នៅក្នុងសហឧក្រិដ្ឋកម្មរួម ជាជាងលើផ្នែកនីមួយៗនៃការរួមចំណែករបស់គាត់[2549]។

៩៨០.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើយុត្តិសាស្ត្រជាពិសេសតុលាការឧក្រិដ្ឋកម្មមិនអចិន្ត្រៃយ៍ ជាទូទៅបានបញ្ជាក់បទដ្ឋានគតិយុត្តត្រឹមត្រូវដែលអាចអនុវត្តបានចំពោះការចូលរួមរបស់ជនជាប់ចោទ ក្នុងការអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ពោលគឺ ការរួមចំណែករបស់គាត់ត្រូវតែ"សំខាន់ ប៉ុន្តែពុំមែនរហូតដល់មិនអាចខ្វះបាននោះទេ"[2550]។ ក្នុងការវាយតម្លៃនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសកម្មភាព*ទាំងមូល*របស់ នួន ជា និង ខៀវ សំផន[2551]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះជាវិធីសាស្ត្រត្រឹមត្រូវ ដូចបានបង្ហាញនៅក្នុងយុត្តិសាស្ត្រពាក់ព័ន្ធដែលបានបញ្ជាក់ថា ការរួមចំណែកណាមួយពុំគប្បីវាយតម្លៃដាច់ដោយឡែកពីគ្នានោះទេ[2552] ដូចគ្នាទៅនឹងអ្វីដែល ខៀវ សំផន ទំនងជាបានគាំទ្រនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ទាំងមូល[2553]។ អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាយ៉ាងត្រឹមត្រូវផងដែរថា "ភាពសំខាន់នៃការរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួម នឹងត្រូវកំណត់ទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាលើកត្តាជាច្រើន រួមទាំង តួនាទីរបស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ហើយនិងរាល់កិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់បទឧក្រិដ្ឋ"[2554]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានសម្រេចថា ការរួមចំណែកបែបនោះពុំចាំបាច់ត្រូវតែ"ចាំបាច់ ឬច្រើន"នោះទេ ប៉ុន្តែថា "យ៉ាងហោចណាស់ត្រូវតែជាការរួមចំណែកសំខាន់នៅក្នុងបទឧក្រិដ្ឋដែលជនជាប់

---

[2549] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៨៥។

[2550] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩២ យោងទៅលើសាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៥០៨។ សាលដីកា*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៤៣០។

[2551] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦១ ដល់ ៨៨២ (នួន ជា) ៩៦១ ដល់ ៩៦៣ (ខៀវ សំផន)។

[2552] *សូមមើលឧ.* សាលដីកា*រឿងក្តី* Kvočka (ICTY) កថាខណ្ឌ ៩៥។ សាលដីកា*រឿងក្តី* Šainović (ICTY) កថាខណ្ឌ ៩២០, ៩៣០ ដល់ ៩៣២។ សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ២១៧។

[2553] *សូមមើលឧ.* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៩៨ ដល់ ២៩៩, ៣០០ ដល់ ៣០១, ៣០៦ ដល់ ៣០៧, ៣០៨ ដល់ ៣០៩, ៣១០ ដល់ ៣១១, ៣១២ ដល់ ៣១៣, ៤០៥ ដល់ ៤០៦, ៤០៧ ដល់ ៤០៨, ៤០៩ ដល់ ៤១០, ៦០៤ ដល់ ៦០៥, ៦០៦ ដល់ ៦០៧, ៦០៨ ដល់ ៦០៩, ៦១២ ដល់ ៦១៣, ៦១៦ ដល់ ៦១៧, ៦១៨ ដល់ ៦១៩, ៦២០ ដល់ ៦២១។

[2554] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៣ យោងទៅលើសាលក្រម*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៣១១។

ចោទត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវ"[2555]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានយល់ឃើញថា "ច្បាប់[ដែលអាចអនុវត្តបានចំពោះសហឧក្រិដ្ឋកម្មរួម] ពុំអាចកំណត់ទុកជាមុននូវប្រភេទជាក់លាក់នៃអំពើប្រព្រឹត្ត ដែល*ជាចម្បង*ពុំអាចត្រូវបានចាត់ទុកថា ជាការរួមចំណែកដល់គោលបំណងរួម"នោះឡើយ[2556]។

៩៨១.នៅក្នុង*រឿងក្តី* *Blagojević និង Jokić* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានយល់ឃើញ ថា

> បុគ្គលម្នាក់អាចចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមតាមវិធីផ្សេងៗច្រើនយ៉ាង ដូចជា៖ (i) បើតាមរយៈការប្រព្រឹត្តដោយផ្ទាល់នូវបទល្មើសដែលបានព្រមព្រៀងគ្នានោះ គឺជាចារីផ្ទាល់ (ii) បើតាមរយៈការជួយដល់ចារីផ្ទាល់ ក្នុងការប្រព្រឹត្តិបទល្មើសដែលបានព្រមព្រៀងគ្នានោះ គឺជាសហចារី ពោលគឺ ជួយសម្រួលដល់ការប្រព្រឹត្តិបទល្មើសក្នុងគោលបំណងដើម្បីអនុវត្តផែនការរួម ឬ (iii) បើតាមរយៈសកម្មភាពក្នុងការជំរុញប្រព័ន្ធពិសេសមួយ ដែលក្នុងនោះបទល្មើសត្រូវបានប្រព្រឹត្តឡើងដោយហេតុផលនៃមុខតំណែងជារដ្ឋអំណាច ឬមុខងាររបស់ជនជាប់ចោទ និងដោយបានដឹងពីលក្ខណៈនៃប្រព័ន្ធនោះ ព្រមទាំងចេតនាបន្តអនុវត្តប្រព័ន្ធនោះ[2557]។

៩៨២.ផ្អែកតាមទិដ្ឋភាពអង្គហេតុ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់ថា ការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមអាចមានច្រើនយ៉ាង។ នៅក្នុងសាលដីកា*រឿងក្តី Krajišnik* អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់[2558]ថា អំពើប្រព្រឹត្តដែលត្រូវបានចាត់ទុកថា ជាការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមមានដូចខាងក្រោមនេះ៖

> (ក) បង្កើត ផ្តួចផ្តើម លើកកម្ពស់ ចូលរួមក្នុង និង/ឬ លើកទឹកចិត្តឲ្យមានការបង្កើត និងអនុវត្ត [ ... ] គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីជំរុញគោលដៅនៃសហឧក្រិដ្ឋកម្មរួម
>
> (ខ) ចូលរួមនៅក្នុងការបង្កើត ការគាំទ្រ ឬបន្ត [ ... ] ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ [ជាតិ] តំបន់ ក្រុង និងមូលដ្ឋាន [...] ដែលតាមរយៈស្ថាប័នទាំងនេះ [គាត់] អាចអនុវត្តគោលដៅនៃសហឧក្រិដ្ឋកម្មរួម

---

[2555] សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ២១៥។ *សូមមើលផងដែរ* សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៩៧ ដល់ ៩៨។ សាលដីកា*រឿងក្តី Tadić* (ICTY) កថាខណ្ឌ ១៩៩។

[2556] សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ៦៩៦។

[2557] សាលក្រម*រឿងក្តី Blagojević និង Jokić* (ICTY) កថាខណ្ឌ ៧០២។

[2558] សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ២១៧។

(គ) គាំទ្រ លើកទឹកចិត្ត ជួយសម្រួល ឬចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន ដើម្បី [...] ទទួលបានការគាំទ្រ និងការចូលរួមដើម្បីសម្រេចនូវគោលដៅនៃសហឧក្រិដ្ឋកម្មរួម

(ឃ) ដឹកនាំ ញុះញង់ លើកទឹកចិត្ត និងផ្តល់អំណាច [...] ដល់កងកម្លាំងឲ្យប្រព្រឹត្តអំពើនានា ដើម្បីជំរុញគោលដៅនៃសហឧក្រិដ្ឋកម្មរួម [...]

(ង) ចូលរួម គាំទ្រ ឬសម្រួលដល់កិច្ចខិតខំប្រឹងប្រែងបដិសេធ ឬផ្តល់នូវព័ត៌មានដែលនាំឲ្យមានការយល់ច្រឡំចំពោះឧក្រិដ្ឋកម្ម ដល់តំណាងរបស់សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសាធារណៈជន[2559]។

៩៨៣.ដូច្នេះ ការរួមចំណែកនេះអាចមានច្រើនយ៉ាង។ ដំណាលគ្នានេះដែរ យុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ការរួមចំណែកត្រូវតែធ្វើឡើងដើម្បីប្រព្រឹត្ត*បទឧក្រិដ្ឋ*។ ឧទាហរណ៍ នៅក្នុងសាលដីកា*រឿងក្តី Krajišnik* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានយល់ឃើញថា “អ្វីដែលសំខាន់នៅក្នុងលក្ខខណ្ឌច្បាប់ គឺថា ជនជាប់ចោទបានរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្ត*បទឧក្រិដ្ឋ* ដែលពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម”[2560]។

៩៨៤.អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ក្នុងរឿងក្តីចំពោះមុខ “គោលបំណងរួម”នៅក្នុងសហឧក្រិដ្ឋកម្មរួម គឺជាការកសាងបដិវត្តន៍សង្គមនិយមដ៏ឆាប់រហ័ស នៅក្នុងប្រទេសកម្ពុជាដែលទោះជាយ៉ាងណាបានផ្សាភ្ជាប់ជាមួយនឹងគោលនយោបាយឧក្រិដ្ឋពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជន និងការកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[2561]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា តាមគោលបំណងរួមនេះ សូម្បីតែសកម្មភាពដែលមើលពីខាងក្រៅពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក៏ដោយ ក៏អាចលើកយកមកពិចារណាបានដែរ នៅពេលកំណត់ ថាតើជនជាប់ចោទបានរួមចំណែកយ៉ាងសំខាន់ ដែរ ឬយ៉ាងណា ពីព្រោះសកម្មភាពនេះអាចជំរុញ និងគាំទ្រការប្រព្រឹត្តបទឧក្រិដ្ឋបាន បើទោះបីជាសកម្មភាពនោះត្រឹមតែប្រយោលក៏ដោយ។ ជាធម្មតា បើសកម្មភាពមួយឃ្លាតកាន់តែឆ្ងាយពីការប្រព្រឹត្តជាក់ស្តែងនូវបទឧក្រិដ្ឋនោះ ទម្ងន់ដែលត្រូវផ្តល់កាន់តែស្រាលនៅក្នុងការពិចារណាពាក់ព័ន្ធទៅនឹងបញ្ហា ថាតើការរួមចំណែកយ៉ាងសំខាន់

---

[2559] សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ២១៦ យោងទៅលើសាលក្រម*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ១១២១។

[2560] សាលដីកា*រឿងក្តី Krajišnik* (ICTY) កថាខណ្ឌ ៦៩៦ (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សាលដីកា*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ៤៣០។

[2561] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០៤, ៨៣៥។ *សូមមើលផងដែរ* ខាងលើកថាខណ្ឌ ៨១៥។

នេះ ពិតជាបានធ្វើឡើង ដែរ ឬយ៉ាងណា។ ការកត់សម្គាល់ខាងលើនេះមានន័យថា ការកំណត់បែបនេះជានិច្ចកាលគួរតែផ្អែកលើការវាយតម្លៃសកម្មភាពនានារបស់ជនជាប់ចោទ។

៩៨៥.យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការពិចារណាទៅលើសកម្មភាពរបស់ជនជាប់ចោទ តាមទិដ្ឋភាពខាងក្រៅដែល ពុំមែនសំដៅលើការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ នៅពេលកំណត់ថា ជនជាប់ចោទបានរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តគោលបំណងឧក្រិដ្ឋរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនោះ។

### ៤.ង.១.ឆ.ការយល់ឃើញដែលថា ការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមអាចធ្វើឡើងតាមរយៈអំពើអកម្ម

៩៨៦.ដោយយោងជាពិសេសទៅលើសាលដីកា*រឿងក្តី Kvočka* (ICTY) អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមអាចធ្វើឡើងតាមរយៈអំពើសកម្ម ឬអំពើអកម្ម[2562]។ នៅក្នុងបណ្តឹងសាទុក្ខ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ព្រោះយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ មិនបានចែងអំពីការទទួលខុសត្រូវតាមរយៈអំពើអកម្មឡើយ[2563]។ អំណះអំណាងរបស់ ខៀវ សំផន ក៏បានលើកឡើងអំពីទម្រង់ដទៃទៀតនៃការទទួលខុសត្រូវទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើអកម្មអាចនាំឱ្យមានការទទួលខុសត្រូវដូចជា ការជួយ និងការជំរុញ[2564]។ គាត់បានលើកឡើងថា ដោយសារអង្គជំនុំជម្រះសាលាដំបូងមានកំហុសនោះ គាត់គួរតែត្រូវបានដោះលែងទាក់ទងទៅនឹងរាល់ការយល់ឃើញទាំងអស់ដែលបានផ្អែកលើអំពើអកម្មរបស់គាត់នោះ[2565]។ នៅក្នុងជើងទំព័រមួយ ខៀវ សំផន បានបង្ហាញកថាខណ្ឌមួយចំនួននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា *ជាលក្ខណៈទ្រឹស្តី* ហើយគាត់បានកត់សម្គាល់បន្ថែមទៀតថា កង្វះសំអាងហេតុដែល

---

[2562] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៣ យោងទៅលើសាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ១៨៧, ៤២១, ៥៥៦។ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងផងដែរទៅលើរឿងក្តីដទៃទៀត នៅចំពោះមុខតុលាការ ICTY និង ICTR (សាលដីកា*រឿងក្តី Blaški* (ICTY) កថាខណ្ឌ ៦៦៣។ សាលដីកា*រឿងក្តី Galić* (ICTY) កថាខណ្ឌ ១៦៨, ១៧៥។ សាលដីកា*រឿងក្តី Ntagerura* (ICTY) កថាខណ្ឌ ៣៣៤)។

[2563] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៣ ដល់ ៩៨។

[2564] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧០០ និង ៧០៦។

[2565] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៩៨។

បានអះអាងនោះ ពុំអាចធ្វើឱ្យគេដឹង ថាតើអំពើអកម្មណាខ្លះ ត្រូវបានសម្រេចដាក់ពិរុទ្ធភាពមកលើរូបគាត់[2566]។ ទោះជាយ៉ាងណាក្តី កថាខណ្ឌភាគច្រើនដែលបានយោងនោះមិនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តរបស់ ខៀវ សំផន ទេ ប៉ុន្តែពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជន។ មានតែនៅក្នុងកថាខណ្ឌ ១០៤៥ ប៉ុណ្ណោះដែលបាននិយាយពី“អំពើសកម្ម និងអំពើអកម្មរបស់ ខៀវ សំផន” ដែលបានរួមចំណែកយ៉ាងច្រើនដល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ។ ទោះបីជាយ៉ាងណាក៏ដោយ ឃ្លាដែលថា “អំពើសកម្ម និងអំពើអកម្ម”ទំនងជាត្រូវបានប្រើក្នុងន័យទូទៅនៅក្នុងកថាខណ្ឌនេះប៉ុណ្ណោះ ពីព្រោះពុំមានការចង្អុលបង្ហាញណាដែលថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានសំអាងលើអំពើអកម្មណាមួយនោះឡើយ។

៩៨៧.អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញមិនត្រឹមតែថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបង្ហាញ ថាតើកំហុសនោះអាចមោឃៈសាលក្រមបានយ៉ាងដូចម្តេចផងដែរ[2567]។ ដោយសារ ខៀវ សំផន ពុំបានលើកមូលដ្ឋានគាំទ្រ ថាតើ កំហុសដែលខ្លួនបានអះអាងនោះ អាចមោឃៈសាលក្រមបានយ៉ាងដូចម្តេចនោះ ទើបអង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ពិចារណាលើអំណះអំណាងនេះបន្តទៀត និងត្រូវបដិសេធទឡ្ហីករណ៍នេះចោល *តែម្តង*។

### ៤.ង.១.ជ.ការរួមចំណែករបស់ នួន ជា ក្នុងការអនុវត្តគោលបំណងរួម

៩៨៨.ទាក់ទងទៅនឹងការរួមចំណែករបស់ នួន ជា ក្នុងការអនុវត្តគោលបំណងរួម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នួន ជា “មិនត្រឹមតែបានចូលរួមនៅក្នុងការរៀបចំគោលនយោបាយដំបូងរបស់របបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែក៏បានចូលរួមយ៉ាងសកម្មនៅក្នុងអំឡុងពេលពាក់ព័ន្ធសំណុំរឿង ០០២/០១ ក្នុងការអនុវត្តបន្តគោលនយោបាយទាំងនោះ”[2568]។ អង្គជំនុំជម្រះសាលាដំបូងបានបែងចែកការរួមចំណែករបស់ នួន ជា ជាពីរប្រភេទ (i) ការជាប់ពាក់ព័ន្ធទៅនឹងការរៀបចំគោលបំណងរួម[2569]និង (ii) តួនាទីរបស់គាត់នៅ

---

[2566] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជើងទំព័រ ២១២ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៥២, ៧៨៨, ៧៩៤, ៨០៥, ៩៩៩, ១០២៥ ដល់ ១០២៦, ១០១៤, ១០៣១, ១០៤៥, ១០៣៤ និង ១០៤៨។

[2567] *សូមមើលខាងលើ* កថាខណ្ឌ ៨៤។

[2568] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦១។

[2569] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៣ ដល់ ៨៦៩។

ក្នុងការផ្សព្វផ្សាយ និងអនុវត្តគោលបំណងរួមនេះតាមរយៈការឃោសនា ការអប់រំ និងការបណ្តុះបណ្តាលជាសាធារណៈ[2570]។

៩៨៩.ទាក់ទងទៅនឹងការឃោសនា អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៦០ នួន ជា មានការជាប់ពាក់ព័ន្ធទៅនឹងការបង្កើតគោលនយោបាយ ប.ក.ក. ទាក់ទងទៅនឹងអំពើហិង្សាបដិវត្តន៍ និងការតស៊ូប្រដាប់អាវុធ រួមទាំងការសម្រេចធ្វើបដិវត្តន៍ប្រដាប់អាវុធ[2571]។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំចំនួន ២ ដែលក្នុងនោះសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើង និងថា គាត់បានធ្វើដំណើរទៅកាន់ប្រទេសវៀតណាម ដើម្បីជូនដំណឹងដល់ថ្នាក់ដឹកនាំវៀតណាមអំពីសេចក្តីសម្រេចវាយប្រហារទីក្រុងភ្នំពេញ និងស្នើសុំជំនួយអាវុធយុទ្ធភណ្ឌ[2572]។ អង្គជំនុំជម្រះសាលាដំបូងក៏បានរំឭកផងដែរថា នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំមួយក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ដែលក្នុងនោះ ផែនការអនុវត្តសមូហភាវូបនីយកម្មត្រូវបានពិភាក្សា ហើយការអនុវត្តផែនការនេះ“លុបចោលយ៉ាងមានប្រសិទ្ធភាពនូវលទ្ធភាពដែលថា មានករណីតិចតួចណាស់ ដែលអ្នកត្រូវបានផ្លាស់ទីលំនៅចេញពីទីក្រុងភ្នំពេញអាចត្រឡប់មកកាន់ផ្ទះសម្បែងរបស់ខ្លួនវិញបាននោះ។ នួន ជា មិនបានបដិសេធចំពោះផែនការនេះទេ”[2573]។

៩៩០.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា ក្នុងខែ សីហា ឆ្នាំ ១៩៧៥ បន្ទាប់ពីទស្សនកិច្ចនៅភូមិភាគពាយ័ព្យ គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចផ្លាស់ទីលំនៅប្រជាជនប្រហែលពី ៤០០.០០០ ទៅ ៥០០.០០០ នាក់ ទៅកាន់ភូមិភាគនោះ[2574]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើរបាយការណ៍មួយស្តីពីដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ទៅកាន់ភូមិភាគពាយ័ព្យ ដែលផ្អែកតាមការយល់ឃើញនេះបានឆ្លុះបញ្ចាំងអំពីគំនិតរបស់គណៈកម្មាធិការអចិន្ត្រៃយ៍លើបញ្ហានេះ។ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា នួន ជា បានរួមចំណែកនៅក្នុងគំនិតនេះដែរ បើទោះបីជាគាត់ប្រហែលជាពុំបានចូលរួមនៅក្នុងដំណើរ

---

[2570] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧០ ដល់ ៨៧៤។

[2571] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៣ ដល់ ៨៦៤។

[2572] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៥។

[2573] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៦។

[2574] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៧។

ទស្សនកិច្ចនោះក៏ដោយ[2575]។ អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់លើឯកសារគោលនយោបាយខែកញ្ញា ឆ្នាំ ១៩៧៥ ដែលគូសបញ្ជាក់អំពីផែនការផ្លាស់ទីលំនៅប្រជាជនក្នុងទ្រង់ទ្រាយធំទៅកាន់ភូមិភាគដទៃទៀត និងលើគោលនយោបាយនានាដែលស្ថិតក្រោមមុខតំណែងរបស់ នួន ជា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍[2576]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ផែនការផ្លាស់ទីលំនៅប្រជាជនក្រោយមកត្រូវបានអនុម័តនៅក្នុងសមាជជាតិលើកទីមួយស្ដីពីសេដ្ឋកិច្ច ហើយត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុង*ទស្សនាវដ្ដីទង់បដិវត្តន៍* ខែ តុលា/វិច្ឆិកា ឆ្នាំ ១៩៧៥ និងបានយល់ឃើញថា "នួន ជា បានដឹង និងបានគាំទ្រដល់ផែនការផ្លាស់ទីលំនៅប្រជាជនដែលធ្វើឲ្យប៉ះពាល់ដល់ប្រជាជនជាងកន្លះលាននាក់"[2577]។

៩៩១.ផ្អែកតាមការលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងបានជឿជាក់ថា "តាមរយៈការរួមចំណែករបស់ នួន ជា នៅក្នុងមហាសន្និបាតបក្ស និងនៅក្នុងកិច្ចប្រជុំនានាជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត [...] គាត់មិនត្រឹមតែបានរួមចំណែកគាំទ្រដល់ផែនការរួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការតាក់តែងខ្លឹមសារនេះផងដែរ"[2578]។

៩៩២.ទាក់ទងទៅនឹងតួនាទីរបស់ នួន ជា ក្នុងការផ្សព្វផ្សាយ និងអនុវត្តគោលបំណងរួមតាមរយៈការឃោសនាការអប់រំ និងវគ្គបណ្ដុះបណ្ដាលសាធារណៈ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា "នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងក្នុងអំឡុងពេលក្រោយៗមកទៀតក្នុងរបបកម្ពុជាប្រជាធិតេយ្យ នួន ជា បានផ្ដោតយ៉ាងសកម្មទៅលើការឃោសនា និងការបណ្ដុះបណ្ដាលកម្មាភិបាលខ្មែរក្រហមនៅតាមជនបទ ដោយគាំទ្រដល់គោលនយោបាយបដិវត្ត និងសេដ្ឋកិច្ចរបស់បក្ស ការបង្កើតសហករណ៍ និងការប្រុងប្រយ័ត្នចំពោះខ្មាំង" និងថា នួន ជា បានផ្សព្វផ្សាយមាគ៌ាបក្សនៅតាមកិច្ចប្រជុំ និងវគ្គបណ្ដុះបណ្ដាលរៀនសូត្រផ្សេងៗ[2579]។ ក្រោយពីបានរំឭកអំពីការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងវគ្គបណ្ដុះបណ្ដាលអស់រយៈពេលប្រាំថ្ងៃក្នុងខែ ឧសភា ឆ្នាំ ១៩៧៥[2580] នៅក្នុងការផ្សព្វផ្សាយ*ទង់បដិវត្តន៍* (ដែលផ្អែកតាមអង្គជំនុំជម្រះសាលា

---

[2575] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៧។

[2576] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៨។

[2577] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៨។

[2578] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៩។

[2579] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧០។

[2580] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧១។

ដំបូង គាត់គឺជាអ្នកនិពន្ធម្នាក់ក្នុងចំណោមអ្នកនិពន្ធចម្បងនានា)[2581]និងនៅក្នុងការបង្កើតគោលនយោបាយពាក់ព័ន្ធទៅនឹង*ការតស៊ូវណ្ណៈ* ក្នុង ប.ក.ក.[2582] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "តាមរយៈតួនាទីរបស់គាត់នៅក្នុងយុទ្ធនាការឃោសនា (រួមទាំងតួនាទីស្នូលរបស់គាត់នៅក្នុងការចេញផ្សាយទស្សនាវដ្ដីទង់បដិវត្តន៍) និងការបណ្ដុះបណ្ដាលកម្មាភិបាលនៅអំឡុងពេលមុន និងក្រោយខែ មេសា ឆ្នាំ ១៩៧៥ នួន ជា បានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ និងការអនុវត្តគោលបំណងរួមនេះ"[2583]។

៩៩៣.នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គាត់មានតួនាទីនៅក្នុង ប.ក.ក. ដែលហួសពីការទទួលខុសត្រូវចំពោះមុខនាទីសាមញ្ញរបស់គាត់[2584]។ ជាពិសេស នួន ជា បានអះអាងថា ទាក់ទងទៅនឹងការសន្និដ្ឋានថា គាត់មានតួនាទីក្នុងគោលនយោបាយយោធា និងការអនុវត្តគោលនយោបាយនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានកំណត់ចរិតលក្ខណៈត្រឹមត្រូវលើសក្ខីកម្មរបស់គាត់ និងកំហុសក្នុងការផ្ដល់ការយល់ឃើញ ដែលពុំស៊ីសង្វាក់គ្នាជាមួយនឹងការយល់ឃើញដទៃទៀតនៅក្នុងសាលក្រមនោះ[2585]។ នួន ជា ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការយល់ឃើញថា គាត់ជាអ្នកទទួលខុសត្រូវលើ"វិន័យរបស់កម្មាភិបាល និងបញ្ហាសន្តិសុខផ្ទៃក្នុងដទៃទៀត"[2586] និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើភស្តុតាងរបស់សាក្សីពីររូបដែលអង្គជំនុំជម្រះបានសំអាងទៅលើនោះ[2587] និងទៅលើសក្ខីកម្មរបស់ ឌុច ដើម្បីធ្វើសេចក្ដីសន្និដ្ឋាននេះ[2588]។ បន្ថែមលើនេះទៀត នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានគ្រប់គ្រងលើសកម្មភាពទាំងអស់របស់ ប.ក.ក. និងថា គាត់"មានអំណាចក្នុងការធ្វើសេចក្ដីសម្រេចចុងក្រោយរបស់បក្ស"ដែលអង្គជំនុំជម្រះបានសំអាងក្នុងការសន្និដ្ឋានរបស់ខ្លួនថា "គាត់មានតួនាទី និងបានអនុវត្ត

---

[2581] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២៦៥។

[2582] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧១ ដល់ ៨៧៣។

[2583] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧៤។

[2584] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥០។

[2585] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥១ ដល់ ២៥៣។

[2586] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៤ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣២៩។

[2587] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៥ ដល់ ២៥៨។

[2588] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៩។

សិទ្ធិអំណាចរបស់គាត់ដើម្បីបង្កើត និង អនុវត្តគោលនយោបាយ និងសេចក្តីសម្រេចរបស់ ប.ក.ក.”[2589]។ ទាក់ទងទៅនឹងបញ្ហានេះ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើសក្ខីកម្មរបស់អ្នកជំនាញ ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងដើម្បីគាំទ្រដល់ការយល់ឃើញនេះ[2590]។ នួន ជា បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់ត្រូវបានគេស្គាល់ថា ជា *បងធំទីពីរ* និងថា គាត់ជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជាប្រជាធិបតេយ្យ[2591]។ បន្ថែមលើនេះ នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើអង្គហេតុដែលពុំស្ថិតក្នុងវិសាលភាពនៃដីកាដំណោះស្រាយ (D427) ដូចជា លើកិច្ចប្រជុំចំនួន ២ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងដើមខែ មេសា ឆ្នាំ ១៩៧៥ ក្នុងការបង្ហាញអំពីការទទួលខុសត្រូវចំពោះការសម្លាប់នៅទួលពោធិ៍ជ្រៃ[2592]។ នួន ជា បានអះអាងថា ដោយសារកិច្ចប្រជុំនេះ ពុំបានលើកឡើងនៅក្នុងដីកាដំណោះស្រាយនៅក្នុងបរិបទនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ទើបសិទ្ធិរបស់គាត់ក្នុងការទទួលបានការជូនព័ត៌មានលម្អិតអំពីបទចោទប្រឆាំងនឹងរូបគាត់ត្រូវបានរំលោភបំពាន ដែលនេះធ្វើឱ្យការយល់ឃើញណាមួយដែលបានផ្អែកលើកិច្ចប្រជុំទាំងពីរនេះទៅជាមោឃៈ[2593]។

៩៩៤.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់នៅក្នុងគោលនយោបាយយោធា និងការអនុវត្តគោលនយោបាយនេះ ពុំបានបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខដោយសារកំហុសអង្គហេតុនោះទេ[2594]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហានេះ ត្រូវបានគាំទ្រដោយភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់បន្ថែមឱ្យគ្នាទៅវិញទៅមក ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈយ៉ាងត្រឹមត្រូវនៅក្នុងសាលក្រមរបស់ខ្លួន[2595]។ ទាក់ទងទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់មានមុខតំណែងពាក់ព័ន្ធទៅនឹងវិន័យ និងបញ្ហាសន្តិសុខផ្ទៃក្នុងដទៃទៀតដែល នួន ជា បានជំទាស់នោះ សហព្រះរាជ

---

[2589] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦០ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦១។

[2590] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦២ ដល់ ២៦៥។

[2591] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦៦ ដល់ ២៦៧។

[2592] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦៣០។

[2593] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦៣៦ ដល់ ៦៣៨។

[2594] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០២។

[2595] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០៣ ដល់ ៤១០។

អាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងយ៉ាងសមហេតុផលលើសក្ខីកម្មរបស់សាក្សី និងភស្តុតាងជាឯកសារយ៉ាងទូលំទូលាយ[2596]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈយ៉ាងត្រឹមត្រូវលើ នួន ជា ថា ជាអ្នកធ្វើសេចក្តីសម្រេចចុងក្រោយជាមួយ ប៉ុល ពត និងបានអះអាងថា នួន ជា កំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើភស្តុតាងដែលបានដកស្រង់ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួននោះ[2597]។ ចុងក្រោយ ពាក់ព័ន្ធទៅនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានលើកឡើងថា នួន ជា ពុំបានផ្តល់ហេតុផលណាមួយដែលគួរឱ្យជឿជាក់បានដែលអង្គជំនុំជម្រះតុលាការកំពូលគប្បីពិនិត្យលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សាក្សីជាច្រើនបានអះអាងថា នួន ជា ត្រូវបានគេស្គាល់តាមរយៈរហស្សនាមថា "ជាបងធំទីពីរ" និងថា គាត់ជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជាប្រជាធិបតេយ្យនៅពេលដែល ប៉ុល ពត អវត្តមាន[2598]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា មានភស្តុតាងយ៉ាងច្រើនសម្រាប់គាំទ្រដល់ការយល់ឃើញទាំងនេះ[2599]។ ទាក់ទងទៅនឹងអំណះអំណាងអំពីការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើការចូលរួមរបស់ នួន ជា នៅក្នុងកិច្ចប្រជុំចំនួន ២ ដែលពុំបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ (D427) នៅក្នុងបរិបទនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ សហព្រះរាជអាជ្ញាបានអះអាងថា អំណះអំណាងរបស់ នួន ជា គប្បីបដិសេធចោលដោយពុំចាំបាច់ពិចារណាបន្តទៀតឡើយ ដោយសារខ្វះការលើកមូលដ្ឋានគាំទ្រ និងបន្ថែមលើនេះទៀត អង្គហេតុសត្យានុម័តនៃបទចោទចាំបាច់ត្រូវបង្ហាញ ប៉ុន្តែភស្តុតាងបញ្ជាក់ពុំចាំបាច់ឡើយ[2600]។

៩៩៥.អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការយល់ឃើញថា នួន ជា ត្រូវបានគេស្គាល់ទូទៅថា "ជាបងធំទីពីរ"និងជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជាប្រជាធិបតេយ្យនៅពេល ប៉ុល ពត អវត្តមាន[2601]។ នួន ជា បានទទួលស្គាល់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនថា កំហុសពាក់ព័ន្ធទៅនឹងចំណុចទីមួយពុំបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និងពុំ

---

[2596] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤១១ ដល់ ៤១៧។

[2597] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤១៨ ដល់ ៤២១។

[2598] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤២២។

[2599] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤២២។

[2600] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១៦។

[2601] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦៦ ដល់ ២៦៧។

មានឥទ្ធិពលលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលឡើយ[2602]។ អាស្រ័យហេតុនេះ បើទោះបីជាមានការបង្ហាញអំពីកំហុសនេះក៏ដោយ ក៏ពុំអាចធ្វើយុត្តិកម្មចំពោះការអន្តរាគមន៍នៅដំណាក់កាលបណ្តឹងសាទុក្ខបានឡើយ ដូចនេះពុំចាំបាច់ពិភាក្សាបន្ថែមទៀតទេ[2603]។

៩៩៦.បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ នួន ជា ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញរបស់ខ្លួនដែលថា គាត់"មានឥទ្ធិពលយ៉ាងខ្លាំងទៅលើគោលនយោបាយយោធារបស់កម្ពុជាប្រជាធិបតេយ្យ និងការអនុវត្តគោលនយោបាយនេះ"[2604]។ ផ្ទុយទៅនឹងអ្វីដែល នួន ជា បានអះអាង[2605] អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិចារណាច្បាស់លាស់ទៅលើការយល់ឃើញពីមុនរបស់ខ្លួន[2606]ដែលថា ពុំមានភស្តុតាងបង្ហាញឱ្យហួសពីវិមតិសង្ស័យថា នួន ជា គឺជាសមាជិកនៃគណៈកម្មាធិការយោធាឡើយ[2607]។ ដូច នួន ជា បានទទួលស្គាល់[2608] អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងដែលថា គាត់បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំនានាជាបន្តបន្ទាប់របស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងឆ្នាំ ១៩៧៦ ដែលបានពិភាក្សាទៅលើបញ្ហាយោធានោះ[2609]។ អំណះអំណាងផ្សេងទៀតដែល នួន ជា បានលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហានេះ គឺគ្រាន់តែជាការបកស្រាយមួយផ្សេងទៀតលើភស្តុតាង ដែលអង្គជំនុំជម្រះបានសំអាងនោះតែប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នួន ជា ពុំបានបង្ហាញថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចយល់ឃើញថា គាត់"មានឥទ្ធិពលខ្លាំងលើគោលនយោបាយយោធារបស់កម្ពុជាប្រជាធិបតេយ្យ និងការអនុវត្តគោលនយោបាយនេះ" ដោយផ្អែកលើភស្តុតាងដែលមាននោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ។

---

[2602] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦៦ ដល់ ២៦៧។

[2603] *សូមមើលខាងលើ* កថាខណ្ឌ ៨៤។

[2604] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥១ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤១។

[2605] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៣។

[2606] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៣៣។

[2607] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤១ ("សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការយោធាមានសារៈសំខាន់តិចតួច ដោយសារតួនាទីជាន់ខ្ពស់របស់ នួន ជា នៅក្នុងបក្ស")។

[2608] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥២។

[2609] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ១០២០ ដល់ ១០២១ និង ១០២៤ ដល់ ១០២៥។

៩៩៧.ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការយល់ឃើញថា តួនាទីផ្លូវការរបស់ នួន ជា បានរួមបញ្ចូលការដាក់វិន័យ និងបញ្ហាសន្តិសុខផ្ទៃក្នុងដទៃទៀតនោះ[2610] អង្គជំនុំជម្រះតុលាការកំពូលទទួលយកអំណះអំណាងរបស់ នួន ជា ដែលថា សក្ខីកម្មរបស់ សាក្សី សាឡុត បាន ពុំបានគាំទ្រដល់ការយល់ឃើញទាំងមូលរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហានេះឡើយ[2611]។ ទោះជាយ៉ាងនេះក្តី ដូច ការជំទាស់របស់ នួន ជា សាឡុត បាន បានអះអាងថា នួន ជា ទទួលខុសត្រូវលើ"ការចាត់តាំង"មួយចំនួន ប៉ុន្តែពុំបានបញ្ជាក់ ថាតើ នួន ជា បានគ្រប់គ្រងលើការចាត់តាំងណាមួយឡើយ ហើយសាក្សីរូបនេះក៏ពុំបានផ្តល់សក្ខីកម្មថា នួន ជា ទទួលខុសត្រូវលើវិន័យរបស់កម្មាភិបាលផងដែរ[2612]។ ទាក់ទងទៅនឹងសក្ខីកម្មរបស់សាក្សី នង សុផង់ ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនោះ ជាការត្រឹមត្រូវដែល នង សុផង់ បានផ្តល់សក្ខីកម្មថា នៅពេលនោះ គាត់ពុំយល់ពីមូលហេតុអ្វីបានជាទូរលេខពាក់ព័ន្ធទៅនឹងការធ្វើខុសសីលធម៌ និងសភាពការណ៍សន្តិសុខផ្ទៃក្នុង ត្រូវបញ្ជូនទៅឱ្យ នួន ជា ប៉ុន្តែ នង សុផង់ បានបកស្រាយថា នេះជារឿងធម្មតា ពីព្រោះ នួន ជា "ទទួលបន្ទុកខាងកិច្ចការសង្គម និងវប្បធម៌"[2613]។ ការអះអាងនេះស្របជាមួយនឹងសក្ខីកម្មពីមុនរបស់ នង សុផង់ ដែលថា នួន ជា គឺជាអ្នកទទួលខុសត្រូវខាងកិច្ចការវប្បធម៌ រួមមាន"បញ្ហាអ្វីៗដែលប៉ះពាល់ខាងសីលធម៌"[2614]។ ចុងក្រោយពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានយល់ឃើញដូចខាងលើថា សក្ខីកម្មរបស់ ឌុច គប្បីពិចារណាដោយប្រុងប្រយ័ត្ន[2615]។ អាស្រ័យហេតុនេះ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទំនងជាមានលក្ខណៈគ្រប់គ្រាន់ក្នុងការគាំទ្រដល់ការយល់

---

[2610] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣២៨ ("សាឡុត បាន [...] ផ្តល់សក្ខីកម្មថា នួន ជា ទទួលបន្ទុកខាងចាត់តាំង និងដាក់វិន័យសមាជិកបក្ស")។

[2611] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣២៨ ("សាឡុត បាន [...] ផ្តល់សក្ខីកម្មថា នួន ជា ទទួលបន្ទុកខាងចាត់តាំង និងដាក់វិន័យសមាជិកបក្ស")។

[2612] ប្រតិចារឹកចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ឯកសារលេខ E1/66.1 ទំព័រ ៥៩ ដល់ ៦០ ("លោក នួន ជា ទទួលខុសត្រូវខាងចាត់តាំង ឯចាត់តាំអីៗ ខ្ញុំអត់ដឹងទេ")។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ (សាឡុត បាន) ឯកសារលេខ E1/70.1 ទំព័រ ៦០ ("ខ្ញុំមិនយល់ដែរកិច្ចការផ្ទៃក្នុងរបស់លោកទាំងពីរ មួយនយោបាយ មួយចាត់តាំងនេះ។ គ្រាន់តែដឹងពាក្យថា ប៉ង់ ប្រាប់ថា ប៉ុល ពត នយោបាយ នួន ជា ចាត់តាំង")។

[2613] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (នង សុផង់) ឯកសារលេខ E1/120.1 ទំព័រ ២៣។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥៧ ដល់ ២៥៨។

[2614] ប្រតិចារឹកចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ (នង សុផង់) ឯកសារលេខ E1/117.1 ទំព័រ ៣៩។

[2615] សូមមើលខាងលើ កថាខណ្ឌ ៣៤៩។

ឃើញដែលថា នួន ជា មានតួនាទីផ្លូវការសម្រាប់ការដាក់វិន័យសមាជិកបក្ស។ ទោះជាយ៉ាងណាក្តី ភស្តុតាងនេះបង្ហាញច្បាស់លាស់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា នួន ជា ពិតជាមានតួនាទីទាក់ទងទៅនឹងបញ្ហានេះមែន បើទោះបីជាផ្នែកជាក់លាក់នៃការជាប់ពាក់ព័ន្ធរបស់គាត់ពុំត្រូវបានដឹងច្បាស់ក៏ដោយ។

៩៩៨.ទាក់ទងទៅនឹងអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា នួន ជា ជាអ្នកគ្រប់គ្រងរាល់សកម្មភាពរបស់បក្ស និងមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស រួមទាំងកិច្ចការរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ និងកិច្ចការយោធាផងនោះ[2616] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ជាដំបូងឃើញថា កថាខណ្ឌទាក់ទងទៅនឹងការយល់ឃើញនេះ គឺជាផ្នែកនៃសេចក្តីសន្និដ្ឋានអំពីតួនាទីរបស់ នួន ជា។ ហេតុនេះ ការយល់ឃើញនេះមិនត្រឹមតែផ្អែកលើភស្តុតាងដែលបានយោងជាក់លាក់នៅក្នុងកថាខណ្ឌនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើភស្តុតាងទាំងអស់ដែលបានសំអាងនៅក្នុងផ្នែកនេះផងដែរ។ អាស្រ័យហេតុនេះ ដូចដែល នួន ជា បានអះអាងដែរថា ជាការពុំត្រឹមត្រូវដែល"ភស្តុតាងសំខាន់ មានតែសេចក្តីដកស្រង់ចេញពីសក្ខីកម្មរបស់អ្នកជំនាញ David Chandler និង Philip Short ចំនួន ៤ ប៉ុណ្ណោះ"[2617]។ ដោយសារអំណះអំណាងដទៃទៀតដែល នួន ជា បានលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហានេះ គ្រាន់តែជាការបកស្រាយមួយផ្សេងទៀតលើភស្តុតាងនោះប៉ុណ្ណោះ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងទាំងនេះ។

៩៩៩.ទាក់ទងទៅនឹងអំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងដើមខែ មេសា ឆ្នាំ ១៩៧៥ ក្នុងការបង្ហាញអំពីការទទួលខុសត្រូវរបស់គាត់ចំពោះព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[2618] អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនថា អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ពុំត្រូវបានបង្ហាញដោយសមហេតុផលឡើយ។ អាស្រ័យហេតុនេះ បទឧក្រិដ្ឋនេះពុំអាចដាក់ឱ្យ នួន ជា ទទួលខុសត្រូវឡើយចំពោះបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងលើកិច្ចប្រជុំទាំងពីរនេះ ដែរ ឬយ៉ាងណា ត្រូវចាត់ទុកជាអសារបង់។

---

[2616] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦០ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៤៨។

[2617] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦២។

[2618] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦៣០, ៦៣៦ ដល់ ៦៣៨។

01358544



១០០០.សរុបសេចក្តីមក បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ភស្តុតាងនេះមានលក្ខណៈពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា នួន ជា មានតួនាទីជាផ្លូវការទាក់ទងទៅនឹងវិន័យរបស់បក្សក៏ដោយ ក៏នៅតែគាំទ្រដល់សេចក្តីសន្និដ្ឋានថា នួន ជា ពិតជាមានតួនាទីពាក់ព័ន្ធទៅនឹងបញ្ហានេះដែរ។ អាស្រ័យហេតុនេះ ពុំមានឥទ្ធិពលលើសេចក្តីសន្និដ្ឋានចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា នួន ជា "បានចូលរួមនៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម និងបានរួមចំណែកយ៉ាងសំខាន់"[2619]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណនៃការរួមចំណែកយ៉ាងច្រើនរបស់ នួន ជា នៅក្នុងគោលបំណងរួម[2620] ដែលចំនួនសរុបនៃការរួមចំណែកនោះអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ជា"ការសំខាន់"។ នួន ជា ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធទៅនឹងបញ្ហានេះឡើយ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា ត្រូវបដិសេធចោល។

### ៤.ង.១.ឈ.ការរួមចំណែករបស់ ខៀវ សំផន ក្នុងការអនុវត្តគោលបំណងរួម

១០០១.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងរួមតាមរយៈ (i) ការចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងមជ្ឈិម និងសមាជបក្ស "ដែលនៅពេលនោះគោលបំណងរួម និងគោលនយោបាយត្រូវបានរៀបចំ និងបង្កើតឡើង" (ii) ការចូលរួមកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលដែលនៅពេលនោះកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមត្រូវបានជូនដំណឹងអំពីគោលបំណងរួម និងគោលនយោបាយនានា (iii) ការចូលរួមនៅក្នុងបញ្ហាសេដ្ឋកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសក្នុងវិស័យពាណិជ្ជកម្ម ការនាំចេញ/នាំចូល និងសេដ្ឋកិច្ច (iv) ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈគាំទ្រគោលបំណងរួម និងគោលនយោបាយនានា លើកទឹកចិត្តកម្មាភិបាលខ្មែរក្រហម និងប្រជាជនមួយចំនួនធំឱ្យប្រកាន់ខ្ជាប់តាមមាគ៌ាបក្ស និង (v) មានទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ និងមានតួនាទីជាអ្នកការទូត ដោយមានទស្សនៈចង់ទាក់ទាញការគាំទ្រពីខាងក្រៅដល់កម្ពុជាប្រជាធិបតេយ្យ[2621]។

---

[2619] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦២។

[2620] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៦៣ ដល់ ៨៧៤។

[2621] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦០ ដល់ ៩៩២។

១០០២.ខៀវ សំផន បានលើកឡើងអំពីកំហុសអង្គហេតុជាច្រើនក្នុងការយល់ឃើញដែលជាមូលដ្ឋាននៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលគាត់បានជំទាស់នោះ[2622]។ ជាពិសេស គាត់បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងទំនាក់ទំនងរបស់គាត់ជាមួយនឹងមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. មុនពេលគាត់បានចូលរួមជាមួយបក្ស[2623] ការមិនបានពិចារណារបស់អង្គជំនុំជម្រះអំពីបំណងរបស់គាត់ដែលចង់ធ្វើកំណែទម្រង់ជាបណ្តើរៗ[2624] និងការមិនចុះសម្រុងរបស់គាត់ជាមួយសម្តេច នរោត្តម សីហនុ[2625] ការកំណត់ចរិតលក្ខណៈរបស់អង្គជំនុំជម្រះទៅលើតួនាទីរបស់គាត់ជាអ្នកទំនាក់ទំនង និងជាអ្នកការទូតពីចន្លោះឆ្នាំ ១៩៧០ ទៅឆ្នាំ ១៩៧៥[2626] ការសំអាងរបស់អង្គជំនុំជម្រះទៅលើសុន្ទរកថា និងវគ្គឃោសនាដែលបានធ្វើនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2627] និងការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា គាត់ត្រូវបាន ប.ក.ក. ជឿទុកចិត្ត និងសហការជាមួយមេដឹកនាំក្នុង ប.ក.ក.[2628]។ លើសពីនេះទៀត ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការចូលរួម និងការពាក់ព័ន្ធរបស់គាត់ក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមដែលបានធ្វើឡើងនៅខែ មិថុនា ឆ្នាំ ១៩៧៤[2629] និងក្នុងកិច្ចប្រជុំមួយនៅទីបញ្ជាការ ប-៥ នៅដើមខែ មេសា ឆ្នាំ ១៩៧៥[2630]។ ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងមុខងារ និងសកម្មភាពរបស់គាត់ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ជាពិសេសសកម្មភាពការទូត[2631] ការថ្លែងក្នុងវគ្គបណ្តុះបណ្តាលនយោបាយ[2632] និងសុន្ទរកថា ព្រមទាំងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់គាត់[2633]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង

---

[2622] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣៧ ដល់ ២៨៥, ៥២២ ដល់ ៥៨៧។

[2623] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣៧ ដល់ ២៤៥។

[2624] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤៦ ដល់ ២៤៨។

[2625] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤៩ ដល់ ២៥២។

[2626] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥៣ ដល់ ២៥៦។

[2627] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥៧ ដល់ ២៦៣។

[2628] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៦៤ ដល់ ២៦៩។

[2629] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧០ ដល់ ២៧៨។

[2630] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧៩ ដល់ ២៨៥។

[2631] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥២២ ដល់ ៥២៨។

[2632] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៣២ ដល់ ៥៣៥។

[2633] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៣៦ ដល់ ៥៣៩។

មានកំហុសទាក់ទងទៅនឹងការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងការចូលរួមរបស់គាត់ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់ ប.ក.ក. សេចក្តីជឿទុកចិត្ត និងឥទ្ធិពលដែលគាត់មាន និងព័ត៌មានដែលគាត់បានដឹង[2634] តួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០ និងការទទួលខុសត្រូវលើកិច្ចការសេដ្ឋកិច្ច[2635] ការចូលរួមរបស់គាត់ក្នុងការបង្កើតផែនការរបស់ ប.ក.ក. សម្រាប់ឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៧[2636] ការកំណត់ពេលវេលានៃការតែងតាំងគាត់ជាសមាជិកពេញសិទ្ធិក្នុងគណៈមជ្ឈិម[2637] និងមុខងាររបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ[2638]។

១០០៣.សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញ ថាតើកំហុសដែលរងការចោទប្រកាន់នោះបានបំពេញតាមបទដ្ឋានតម្រូវសម្រាប់ការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ ដែរ ឬយ៉ាងណា ផ្ទុយទៅវិញ ខៀវ សំផន បែរជាផ្តល់ការបកស្រាយមួយបែបផ្សេងអំពីភស្តុតាងដាច់ដោយឡែកដោយគ្រាន់តែជំទាស់ទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ឬគ្រាន់តែលើកឡើងដដែលៗនូវទឡ្ហីករណ៍ដែលបានដាក់ជូនរួចហើយនៅដំណាក់កាលជំនុំជម្រះ[2639]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃរបស់ខ្លួនអំពីមុខងាររបស់គាត់ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ [2640] ការចូលរួមរបស់គាត់ក្នុងការធ្វើសេចក្តីសម្រេចរបស់គណៈមជ្ឈិម[2641] និងតួនាទីរបស់គាត់នៅក្នុងអំឡុងពេលនៃអង្គហេតុជម្លៀសប្រជាជនដំណាក់កាលទីមួយ ទីពីរ និងនៅទួលពោធិ៍ជ្រៃ[2642]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញយ៉ាងត្រឹមត្រូវថា ការចូលរួមរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំនានា[2643] វគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា សុន្ទរកថា និងការឃោសនា គឺជា

---

[2634] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៤០ ដល់ ៥៥០។

[2635] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៥១ ដល់ ៥៥៩។

[2636] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៦០ ដល់ ៥៧០។

[2637] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៧១ ដល់ ៥៧២។

[2638] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៧៣ ដល់ ៥៨៧។

[2639] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤២៣។

[2640] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤២៤ ដល់ ៤៤១។

[2641] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៤២ ដល់ ៤៥៨។

[2642] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៥៩ ដល់ ៤៨១។

[2643] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៩០ ដល់ ៥៩២។

ការរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងរួម[2644]។ ចុងបញ្ចប់ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងកេរ្តិ៍ឈ្មោះ និងមុខតំណែងជាផ្លូវការ តួនាទីជាអ្នកទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ មុខងារការទូត និងតួនាទីជាផ្លូវការរបស់គាត់[2645]។

### ៤.ង.១.ឈ.១.ការចូលរួមរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំស្តីពីគោលនយោបាយបង្កើតគោលបំណងរួម

១០០៤.អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទាំងមូល ខៀវ សំផន បានចូលរួម និងក្នុងករណីខ្លះ បានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំជាច្រើនរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ព្រមទាំងសមាជបក្សនៅទូទាំងសម័យបដិវត្តន៍ ដែលគោលបំណងរួមដើម្បីកសាងបដិវត្តន៍សង្គមនិយមឲ្យបានឆាប់រហ័ស និងគោលនយោបាយដែលត្រូវបានចាត់ទុកថា ជាការចាំបាច់នោះ ត្រូវបានរៀបចំ សម្រេច និងធ្វើឲ្យបានជោគជ័យ[2646]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "នៅឆ្នាំ ១៩៦៩ នៅពេលដែលគាត់បានចូលរួមជាមួយ ប.ក.ក. ខៀវ សំផន បានដឹងច្បាស់ណាស់ពីគោលបំណងរួម [...] ព្រមទាំងការបង្កើតគោលបំណងនេះ [...] ហើយថា គាត់បានយល់ស្របជាមួយនឹងគោលបំណងនេះ"[2647]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា នៅខែ មិថុនា ឆ្នាំ ១៩៧៤ ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំមេដឹកនាំ ប.ក.ក. ដែលនាពេលនោះមានការសម្រេចឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងថា គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយនៅដើមខែ មេសា ឆ្នាំ ១៩៧៥ ដែលនាពេលនោះមានការបញ្ជាក់អំពីការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[2648]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ឯកសារនៅក្នុងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦ បានបង្ហាញថា ខៀវ សំផន បានចូលរួមនៅក្នុងការបង្កើតផែនការសេដ្ឋកិច្ចសម្រាប់ឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៧ ដើម្បីបង្កើនផលិតកម្មកសិកម្ម បែងចែកធនធានពលកម្មជាយុទ្ធសាស្ត្រ និងបែង

---

[2644] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦០២ ដល់ ៦០៤។

[2645] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦១០ ដល់ ៦១២។

[2646] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦៤ ដល់ ៩៧១។

[2647] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦៥ (ជើងទំព័រលុបចោល)។

[2648] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦៦ យោងលើកថាខណ្ឌ ១៣៣ ដល់ ១៣៨ នៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងកិច្ចប្រជុំនៅខែ មិថុនា ឆ្នាំ ១៩៧៤ និងកថាខណ្ឌ ១៤៤ ដល់ ១៤៩ ទាក់ទងទៅនឹងកិច្ចប្រជុំនៅខែ មេសា ឆ្នាំ ១៩៧៥។

ចែកប្រជាជនតាមប្រភេទ ជាដើម[2649]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខៀវ សំផន "មិនត្រឹមតែបានចែករំលែកគោលបំណងរួមដែលនាំឲ្យមាន និង/ឬជាប់ពាក់ព័ន្ធទៅនឹងគោលនយោបាយជម្លៀសប្រជាជនចេញពីទីប្រជុំជន ផ្លាស់ទីលំនៅប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត និងកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតខ្លឹមសារនៃគោលបំណងរួម និងគោលនយោបាយនានាផងដែរ"[2650]។

១០០៥.ជាដំបូង ទាក់ទងទៅនឹងការជំទាស់របស់ ខៀវ សំផន[2651]ទៅលើការយល់ឃើញផ្នែកអង្គហេតុដែលគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានដឹងអំពីគោលបំណងរួមត្រឹមឆ្នាំ ១៩៦៩[2652]នោះ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ដោយសារគោលបំណងនេះត្រូវបានផ្សាភ្ជាប់ទៅនឹងគោលនយោបាយនៃការជម្លៀសប្រជាជន ដូចនេះគោលបំណងរួមនៃការកសាងបដិវត្តន៍សង្គមនិយមឲ្យបានឆាប់រហ័ស (ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១) គឺជាបទឧក្រិដ្ឋ[2653]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការជម្លៀសប្រជាជនបានធ្វើឡើងចាប់ពីឆ្នាំ ១៩៧០ រហូតមក[2654]។ ហេតុដូច្នេះ រាល់សកម្មភាពរបស់ ខៀវ សំផន ដែលទាក់ទងទៅនឹងអំឡុងពេល *មុន*ឆ្នាំ ១៩៧០ គឺច្បាស់ណាស់មិនជាប់ពាក់ព័ន្ធទៅនឹងការកំណត់ ថាតើគាត់បាន"រួមចំណែកយ៉ាងសំខាន់"នៅក្នុងការអនុវត្តគោលបំណងរួម ដែលឈានទៅដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម ដែរ ឬយ៉ាងណា។ ជាការពិតណាស់ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើអំឡុងពេលមុនឆ្នាំ ១៩៧០ នៅក្នុងផ្នែកនៃសាលក្រមរបស់ខ្លួនដែលពិភាក្សាអំពីការរួមចំណែករបស់គាត់នោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្តីយោងទាំងនេះត្រូវបានធ្វើឡើងក្នុងបំណងបង្ហាញអំពីបរិបទនៃការចូលរួមរបស់គាត់ ជាជាងផ្តល់មូលដ្ឋាន

---

[2649] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦៨, ៩៧១។

[2650] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧២។

[2651] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៣៧ ដល់ ២៤៨។

[2652] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦៥។

[2653] *សូមមើលខាងលើ* កថាខណ្ឌ ៨១៥។ អង្គជំនុំជម្រះតុលាការកំពូលរំឭកទាក់ទងទៅនឹងបញ្ហានេះថា អង្គជំនុំជម្រះបានយល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុដែលថា គោលនយោបាយកំណត់គោលដៅមានអត្ថិភាពនោះ។ អាស្រ័យហេតុនេះ គោលនយោបាយកំណត់គោលដៅពុំចាំបាច់ត្រូវធ្វើការពិចារណាបន្តទៀតនៅក្នុងបរិបទនៃទឡ្ហីករណ៍បណ្តឹងសាទុក្ខបច្ចុប្បន្នឡើយ។

[2654] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៥។

សម្រាប់ការយល់ឃើញថា គាត់បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលបំណងរួមដែលជា ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ នោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំគប្បីពិចារណាអំពីអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហានេះតទៅទៀតឡើយ។

១០០៦.ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសមួយចំនួនក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងការបង្កើតផែនការសេដ្ឋកិច្ចឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៧ ដោយសារអង្គជំនុំជម្រះបានផ្អែកលើឯកសារគោលនយោបាយខែ កញ្ញា ឆ្នាំ ១៩៧៥ និងលើការសន្និដ្ឋានដែលថា គាត់បានដឹង និងបានចូលរួមកិច្ចប្រជុំក្នុងឆ្នាំ ១៩៧៤ និងឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនោះមានការរៀបចំ និងពិភាក្សាអំពីផែនការទាំងនោះ[2655]។ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ខៀវ សំផន បានលើកអំណះអំណាងទាំងនេះយ៉ាងលម្អិតនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ដែលក្នុងនោះគាត់បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយជម្លៀសប្រជាជនពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀត[2656]។ យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងទាំងនេះរួចហើយ[2657]។

១០០៧.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ចាប់ពីឆ្នាំ ១៩៧៣ គណៈមជ្ឈិមរបស់ ប.ក.ក. ជារួមបានសម្រេចជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ[2658]ក្នុងកិច្ចប្រជុំជាច្រើន ដែលក្នុងនោះគាត់បានអះអាងថា គាត់មិនបានចូលរួមយ៉ាងសកម្មនោះទេ[2659]។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការលើកឡើងជាច្រើនរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហានេះបានចង្អុលបង្ហាញអំពីកង្វះសំអាងហេតុរបស់អង្គ

---

[2655] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៦០ ដល់ ៥៧០។

[2656] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៥១ ដល់ ៤៦៩។

[2657] *សូមមើល* កថាខណ្ឌ ៨៣០ *ជាដើម*។

[2658] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧០ ដល់ ២៨៥។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៦៥ ។

[2659] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣២។

01358550



ជំនុំជម្រះសាលាដំបូង[2660]។ អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចផ្តល់សំអាងហេតុពេញលេញនៅក្នុងសាលក្រមរបស់ខ្លួនទាំងមូល ជាជាងផ្តល់សំអាងហេតុចំពោះតែការលើកឡើងនីមួយៗនៅពេលជំនុំជម្រះនោះ[2661]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកជាការសមហេតុផលក្នុងការសន្និតថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាអំពីការលើកឡើងនីមួយៗ នៅពេលធ្វើការវាយតំលៃលើភស្តុតាង និងអំណះអំណាងទាំងមូលនៅចំពោះមុខខ្លួន[2662]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងការពុំបានផ្តល់សំអាងហេតុ ត្រូវបដិសេធចោល។ អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងខ្លឹមសារនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំចំនួន ២ នឹងត្រូវដោះស្រាយដូចខាងក្រោម។

### ៤.ង.១.ឈ.១.ក.កិច្ចប្រជុំរបស់ ប.ក.ក. ក្នុងខែ មិថុនា ឆ្នាំ ១៩៧៤

១០០៨.ក្នុងការជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ នោះ ខៀវ សំផន បានយោងទៅលើឯកសារជាភស្តុតាងរបស់ David CHANDLER និង ប៉ុល ពត ដែលបានបញ្ជាក់ថា សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានធ្វើឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារអង្គជំនុំជម្រះពុំបានពន្យល់ពីមូលហេតុដែលសេចក្តីសម្រេចនេះពុំអាចត្រូវបានធ្វើឡើងនៅពេលនោះ និងបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូង“បានជ្រើសរើសទ្រឹស្តីមួយដែលធ្វើឱ្យម្ចាស់បណ្តឹងសាទុក្ខមានការជាប់ពាក់ព័ន្ធ”[2663]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងរបស់ ខៀវ សំផន បានបំភ្លៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើភស្តុតាងពាក់ព័ន្ធទៅនឹងកិច្ចប្រជុំក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ និងបានលើកឡើងថា “មានភស្តុ

[2660] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧១, ២៧៤, ២៧៩, ២៨៤ ដល់ ២៨៥។

[2661] *សូមមើល* សាលដីកា*រឿងក្តី Renzaho* (ICTR) កថាខណ្ឌ ៤០៥។ សាលដីកា*រឿងក្តី Ntabakuze* (ICTR) កថាខណ្ឌ ១៦១។ សាលដីកា*រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ២៣។ សាលដីកា*រឿងក្តី Limaj* (ICTY) កថាខណ្ឌ ៨១។ សាលដីកា*រឿងក្តី Gatete* (ICTR) កថាខណ្ឌ ៦៥។

[2662] សាលដីកា*រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ១១។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការផ្ទេរសំណុំរឿង*រឿងក្តី Uwinkindi* (ICTR) កថាខណ្ឌ ៣២។

[2663] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧១។

តាងបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានលើកយកមកពិភាក្សាសាជាថ្មីនៅក្នុង ប.ក.ក. នៅខែ កុម្ភៈ ឆ្នាំ ១៩៧៥" និងបានកត់សម្គាល់នៅក្នុងបរិបទនៃសក្ខីកម្មរបស់ នួន ជា ថា "សេចក្តីសម្រេចជម្លៀសនេះត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំជាច្រើន"[2664]។ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ការយល់ឃើញជាក់លាក់អំពីកាលបរិច្ឆេទច្បាស់លាស់នៃសេចក្តីសម្រេចជម្លៀសនោះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានយល់ឃើញថា គណៈមជ្ឈិមបានសម្រេចជារួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ"ក្នុងពេលប្រជុំជាច្រើនបន្តបន្ទាប់ ចាប់ពីឆ្នាំ ១៩៧៣" ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា "អង្គជំនុំជម្រះត្រូវបានបង្ហាញភស្តុតាងលម្អិតនៃកិច្ចប្រជុំនានាដែលបានចាប់ផ្តើមធ្វើនៅក្នុងខែមិថុនា ឆ្នាំ ១៩៧៤ តែប៉ុណ្ណោះ"[2665]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងនៃកិច្ចពិភាក្សាក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៥ អំពីសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញស៊ីសង្វាក់គ្នាជាមួយនឹងការយល់ឃើញជារួមរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង "ក្នុងពេលប្រជុំជាច្រើនបន្តបន្ទាប់ចាប់ពីឆ្នាំ ១៩៧៣"[2666]។

១០០៩.ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងកិច្ចប្រជុំគណៈមជ្ឈិមក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដែលអង្គជំនុំជម្រះបានបញ្ជាក់ថា អ្នកចូលរួមបានគាំទ្រដល់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ[2667] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ច្បាស់លាស់ថា ការរៀបរាប់របស់ នួន ជា និង សាក្សី ភី ភួន ដែលជាអ្នកយាមកិច្ចប្រជុំនោះ មានការខ្វែងគ្នាទាក់ទងទៅនឹងវត្តមានរបស់ ខៀវ សំផន[2668]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើប្រភពនៃឯកសារ និងសក្ខីកម្មផ្ទាល់របស់សាក្សី ស្វួង

---

[2664] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៣។

[2665] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣២ ជើងទំព័រ ៣៧៦។

[2666] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣២។

[2667] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧ ដល់ ២៧៨។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៦៥។

[2668] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៥ ("មានការរៀបរាប់នូវភាពខុសគ្នាអំពីបញ្ហា ថាតើ ខៀវ សំផន មានវត្តមានក្នុងកិច្ចប្រជុំ ដែរ ឬយ៉ាងណា នៅពេលដែលការសម្រេចជម្លៀសប្រជាជនចេញពីភ្នំពេញត្រូវបានធ្វើឡើងនោះ។ ខៀវ សំផន បានអះអាងថា គាត់មិនបានចូលរួមប្រជុំនោះទេ ហើយគាត់ក៏មិននៅក្នុងប្រទេសកម្ពុជាដែរនៅពេលប្រជុំនោះ។ នួន ជា គាំទ្រការរៀបរាប់ហេតុការណ៍ទាំងនេះ ដោយបានលើកឡើងថា ខៀវ សំផន មិនមានវត្តមាននៅក្នុងពេលប្រជុំនោះទេ ហេតុដូច្នេះ ខៀវ សំផន

ស៊ីគឿន ដើម្បីប្រមូលព័ត៌មានអំពីកម្មវិធីស្តីពីការធ្វើដំណើររបស់ ខៀវ សំផន ពីប្រទេសឡាវមកកម្ពុជាបន្ទាប់ពីសប្តាហ៍ទីមួយខែ មិថុនា ឆ្នាំ ១៩៧៤[2669]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួន"បានចាត់ទុកថា កិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ទំនងជាត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឲ្យ ខៀវ សំផន និង អៀង សារី អាចចូលរួមបាន និងរាយការណ៍ជូនសមាជិកគណៈមជ្ឈិមនៃ ប.ក.ក. អំពីកិច្ចប្រជុំផ្សេងៗដែលបានទទួលជោគជ័យដ៏ធំធេងជាមួយនឹងមេដឹកនាំជាន់ខ្ពស់នៃប្រទេសចិន វៀតណាម និង ឡាវ"[2670]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលខ្លួនសម្រេចបដិសេធសក្ខីកម្មផ្ទាល់ និងលម្អិតរបស់ នួន ជា ដែលបានលើកឡើងថា ខៀវ សំផន និង អៀង សារី (យោងតាមអង្គជំនុំជម្រះសាលាដំបូងបានធ្វើដំណើរជាមួយ ខៀវ សំផន) នោះ[2671] ពុំបានចូលរួមក្នុងកិច្ចប្រជុំនេះទេ[2672] ចំណែក ភី ភួន ត្រឹមតែបានលើកឡើងត្រួសៗថា ប៉ុល ពត នួន ជា និង ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤[2673]។ ក្នុងបរិបទនេះ ត្រូវកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានយល់ពុំត្រឹមត្រូវលើផ្នែកខ្លះនៃសក្ខីកម្មរបស់ ភី ភួន ក្នុងការលើកឡើងថា "យោងតាមសក្ខីកម្មរបស់ ភី ភួន ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ ក្នុងស្រុកមាយ និងបានយល់ស្របលើផែនការជម្លៀសប្រជាជនចេញពីទីក្រុង"[2674]។ បើទោះបីជា ខៀវ សំផន បានយល់ស្របលើសេចក្តីសម្រេចជម្លៀសប្រជាជនក៏ដោយ ក៏តាមការពិត ភី ភួន បានសំដៅលើការយល់ស្របរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំក្នុង ខែ មេសា ឆ្នាំ ១៩៧៥ ឯណោះទេ[2675]។ សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការពុំសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ នោះ ព្រោះភស្តុតាងដែលគាំទ្រការយល់ឃើញនោះ ដូចជា សក្ខីកម្មរបស់ ភី ភួន ផ្នែកខ្លះពុំត្រូវបានយល់ត្រឹមត្រូវ និងមានលក្ខណៈពុំសូវលម្អិត

---

មិនបានដឹងអំពីសេចក្តីសម្រេចនោះឡើយ។ ផ្ទុយទៅវិញ សាក្សី រ៉ចាម តុន *ហៅ* ភី ភួន បានឆ្លើយថា ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ នៅភូមិមាយ និងបានយល់ស្របលើផែនការជម្លៀសប្រជាជនចេញពីទីក្រុង"(ជើងទំព័រលុបចោល)។

2669 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៦ ដល់ ១៣៧។

2670 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៨។

2671 សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៦ ដល់ ១៣៧។

2672 ប្រតិចារឹកចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ (នួន ជា) ឯកសារលេខ E1/22.1 ទំព័រ ២ ដល់ ៦។

2673 ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ៣៦។

2674 សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៥។

2675 ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ១៤។

ដូចសក្ខីកម្មរបស់ នួន ជា ដែលបានចូលរួមផ្ទាល់នៅក្នុងកិច្ចប្រជុំនោះ និងបានអះអាងច្បាស់លាស់ថា ខៀវ សំផន ពិតជាពុំបានចូលរួមមែន ទន្ទឹមនឹងនេះ ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ទំនងជាកិច្ចប្រជុំនោះធ្វើឡើងក្នុងការគោលបំណងអាចឱ្យ ខៀវ សំផន និង អៀង សារី ចូលរួមបាននោះ ពុំមានភស្តុតាងផ្តល់ជាមូលដ្ឋានគាំទ្រឡើយ។

## ៤.ង.១.ឈ.១.ខ.កិច្ចប្រជុំរបស់ ប.ក.ក. ក្នុងខែ មេសា ឆ្នាំ ១៩៧៥

១០១០.អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅដើមខែ មេសា ឆ្នាំ ១៩៧៥ "មេដឹកនាំជាន់ខ្ពស់ ប.ក.ក. បានជួបប្រជុំគ្នានៅមន្ទីរ ប-៥ ដែលជាទីបញ្ជាការវាយប្រហារទីក្រុងភ្នំពេញ [...] ដើម្បីពិភាក្សាការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ"[2676]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញ*ក្នុងចំណោមនោះ*ថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំនេះដែរ ដោយអង្គជំនុំជម្រះបានកត់សម្គាល់ថា "យោងតាមចម្លើយរបស់សាក្សី ភី ភួន ថា ទាំង នួន ជា និង ខៀវ សំផន បានគាំទ្រផែនការនេះ"[2677]។ ខៀវ សំផន បានអះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ពីព្រោះ ភី ភួន គឺជាបុគ្គលតែម្នាក់គត់ដែលបានរៀបរាប់អំពីកិច្ចប្រជុំនេះ និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងភាពផ្ទុយគ្នា និងភាពមិនអាចជឿទុកចិត្តបាននៃសក្ខីកម្មរបស់ ភី ភួន[2678]។

១០១១.ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនៅដើមខែ មេសា ឆ្នាំ ១៩៧៥ អំពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ បានផ្អែកស្ទើរតែទាំងស្រុងទៅលើសក្ខីកម្មរបស់ ភី ភួន[2679] និងកិច្ចសម្ភាសន៍របស់ អៀង សារី ជាមួយ Stephen HEDER ដែលបានលើកឡើងអំពីកិច្ចប្រជុំមួយ"នៅចុងខែ មីនា ឬដើមខែ មេសា ឆ្នាំ ១៩៧៥" ដែលនិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បើទោះបីជា អៀង សារី ពុំបានចូលរួមក្នុងកិច្ចប្រជុំនេះក៏ដោយ[2680]។ ខៀវ សំផន បានលើកអំណះអំណាងដែលបានលើកឡើង នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ជាថ្មីនៅដំណាក់កាលប

[2676] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៤។

[2677] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៥ ដល់ ១៤៦។

[2678] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧៩។

[2679] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៦ ជើងទំព័រ ៤២១ ដល់ ៤២៥។

[2680] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៥ ជើងទំព័រ ៤២០ យោងទៅលើកិច្ចសម្ភាសន៍របស់ Stephen HEDER ជាមួយ អៀង សារី ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ឯកសារលេខ E3/89 ERN (ភាសាខ្មែរ) 00062457។

ណ្ដឹងសាទុក្ខ ទាក់ទងទៅនឹងសក្ខីកម្មរបស់ ភី ភួន[2681]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ផ្ទុយទៅនឹងអ្វីដែល ខៀវ សំផន បានចោទប្រកាន់នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយយ៉ាងជាក់លាក់ទៅលើអំណះអំណាងមួយចំនួនរួចហើយ និងបានពន្យល់មូលហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សាក្សីរូបនោះមានភាពគួរឱ្យជឿជាក់បាន[2682]។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយឲ្យបានជាក់លាក់លើអំណះអំណាងរបស់ ខៀវ សំផន ដែលលើកឡើងអំពីសក្ខីកម្មរបស់ ភី ភួន ដែលមានដូចជា គាត់អាចស្ដាប់ឮនូវអ្វីដែលបាននិយាយក្នុងកិច្ចប្រជុំនៅដើមខែ មេសា នោះ ផ្ទុយគ្នាទៅនឹងសក្ខីកម្មរបស់សាក្សីពីររូបទៀតដែលបានផ្ដល់សក្ខីកម្មថា អង្គរក្សត្រូវបានណែនាំឲ្យនៅឆ្ងាយពីទីកន្លែងដែលកិច្ចប្រជុំបានប្រព្រឹត្តទៅ[2683]។ យោងទៅលើសក្ខីកម្មលម្អិតរបស់ ភី ភួន អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងមានភាពសមហេតុផលហើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ៤.ង.១.ឈ.២.ការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំណែនាំដើម្បីផ្សព្វផ្សាយគោលបំណងរួម

១០១២.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានវត្តមាន និងបានចូលរួមក្នុងកិច្ចប្រជុំណែនាំ និងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាដែលគោលបំណងរួម និងគោលនយោបាយនានា ត្រូវបានផ្សព្វផ្សាយ[2684]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ក្នុងអំឡុងពេលធ្វើបដិវត្តន៍ ខៀវ សំផន បានជួយរៀបចំឯកសារឃោសនារបស់រណសិរ្សរួបរួមជាតិកម្ពុជា និងបានបង្រៀនវគ្គបណ្ដុះបណ្ដាលនយោបាយនៅក្នុងតំបន់រំដោះ[2685]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា វត្តមាន និងការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំ

---

[2681] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៧៩។

[2682] សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E295/6/4) កថាខណ្ឌ ២៩ ដល់ ៣១។ សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៥ ជើងទំព័រ ៤២៥។

[2683] សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (E295/6/4) កថាខណ្ឌ ៣០ និង ៣១ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ (សាឡុត បាន) ឯកសារលេខ E1/71.1 ទំព័រ ១០ និងប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ (អៀន តាន) ឯកសារលេខ E1/86.1 ទំព័រ ១៥។

[2684] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៣ ដល់ ៩៧៦។

[2685] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៣ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៦៧។

និងវគ្គបណ្ដុះបណ្ដាលទាំងនេះបានបន្តក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2686] និងថា កិច្ចប្រជុំ និងវគ្គបណ្ដុះបណ្ដាលទាំងនេះបានលើកឡើង*ក្នុងចំណោមនោះ* នូវការកំណត់អត្តសញ្ញាណ និងការលុបបំបាត់ខ្មាំង និងការផ្តល់យុត្តិកម្មអំពីការជម្លៀសប្រជាជនចេញពីទីប្រជុំជននានា[2687]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា វត្តមាន និងការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំ និងវគ្គបណ្ដុះបណ្ដាលទាំងនេះបានបង្ហាញថា "គាត់បានដើរតួនាទីសំខាន់មួយនៅក្នុងការផ្សព្វផ្សាយខ្លឹមសារនៃគោលបំណងរួម និងគោលនយោបាយនានា" និងថា "វត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំទាំងនេះបានជួយសម្រួលឲ្យការណែនាំទាំងនេះមានប្រសិទ្ធភាព ដោយបង្ហាញដល់អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនោះថា គាត់បានយល់ស្របលើគោលបំណងរួម និងគោលនយោបាយនោះ" និងថា "នេះកាន់តែគូសបញ្ជាក់ឲ្យឃើញកាន់តែច្បាស់ថែមទៀត គឺនៅពេលដែលគាត់បានចេញសេចក្តីណែនាំដោយផ្ទាល់"[2688]។

១០១៣.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានបង្រៀនវគ្គបណ្ដុះបណ្ដាលនយោបាយនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយបានអះអាងថា គាត់ត្រឹមតែបានចូលរួមវគ្គនោះម្តងប៉ុណ្ណោះនៅមុនកាលបរិច្ឆេទនេះ[2689]។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា ភី ភួន ដែលជាសាក្សីម្នាក់ក្នុងចំណោមសាក្សីពីរនាក់ដែលសក្ខីកម្មរបស់ខ្លួនត្រូវបានអង្គជំនុំជម្រះសាលាដំបូងយកមកសំអាងនោះ បាននិយាយអំពីវគ្គបណ្ដុះបណ្ដាលមួយចំនួនដោយបានអះអាងថា "អ៊ំ ខៀវ សំផន ក៏ត្រូវបានឃើញបង្រៀននៅក្នុងវគ្គនោះដែរ"[2690]។ ដូច្នេះ អំណះអំណាងរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគ្រប់គ្រាន់ និងត្រូវបដិសេធចោល។

---

[2686] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៣។

[2687] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៤ ដល់ ៩៧៥។

[2688] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៦។

[2689] សារណារបស់បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៦៣។

[2690] ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ាចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/96.1 ទំព័រ ៥៣ ដល់ ៥៤។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៦៧ ជើងទំព័រ ១១០៦ អង្គជំនុំជម្រះពុំបានយោងទៅលើផ្នែកជាក់លាក់នៃសក្ខីកម្មរបស់ រ៉ាចាម តុន *ហៅ* ភី ភួន ប៉ុន្តែទៅលើចំណុចដទៃទៀតដែលបានបង្ហាញថា ខៀវ សំផន បានចូលរួមមិនត្រឹមតែក្នុងវគ្គបណ្ដុះបណ្ដាលមួយប៉ុណ្ណោះទេនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នោះ។

១០១៤.ខៀវ សំផន ក៏បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានផ្សព្វផ្សាយគោលនយោបាយបក្សទាក់ទងទៅនឹង"ខ្មាំង"[2691] និងបានអះអាងថា សក្ខីកម្មរបស់សាក្សីដែលបានយកមកសំអាងនោះ ពុំបានបង្ហាញឱ្យឃើញថា មានគោលនយោបាយកម្ទេចខ្មាំងឡើយ ហើយថា ប្រសិនបើគោលនយោបាយនេះមានអត្ថិភាពមែននោះ ក៏គាត់ពុំមានជាប់ពាក់ព័ន្ធជាមួយនឹងគោលនយោបាយបែបនេះដែរ[2692]។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញរួចហើយថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅនោះពុំត្រូវបានបង្ហាញឱ្យឃើញដោយសមហេតុផលឡើយ[2693]។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះ ពុំចាំបាច់ត្រូវពិចារណាបន្តទៀតឡើយ។

១០១៥.ចុងក្រោយ ខៀវ សំផន បានអះអាងថា "ការលើកឡើងដាច់ដោយឡែកមួយ"របស់អង្គជំនុំជម្រះសាលាដំបូងដែលថា រូបគាត់បានផ្តល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង ក្នុងអំឡុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជានោះ គឺបានផ្អែកតែទៅលើភស្តុតាងចចាមអារ៉ាមប៉ុណ្ណោះ[2694]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងចំណោមភស្តុតាងចំនួន ៤ ដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកសំអាងដើម្បីគាំទ្រដល់ការយល់ឃើញរបស់ខ្លួននោះ មានភស្តុតាងមួយជាសៀវភៅដែលនិពន្ធដោយ Ben KIERNAN ដែលបានយោងជាក់លាក់ទៅលើការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា ធ្វើជាប្រធានបទនៃវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ចំណែកប្រភពផ្សេងទៀតពិពណ៌នាជាទូទៅអំពីការចូលរួមរបស់ ខៀវ សំផន ក្នុងវគ្គទាំងនោះ[2695]។ Ben KIERNAN បានដកស្រង់កិច្ចសម្ភាសន៍មួយធ្វើជាប្រភពដែលគាត់បានធ្វើឡើងនៅក្នុងឆ្នាំ ១៩៨០ ជាមួយអ្នកជំនាញរូបវិទ្យាកម្ពុជាម្នាក់ដែលបានត្រឡប់ពីប្រទេសបារាំងមកប្រទេសកម្ពុជានៅចុងឆ្នាំ

---

[2691] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៣២ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨១៨ ជើងទំព័រ ១១៥៥។

[2692] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៣២ ដល់ ៥៣៤។

[2693] *សូមមើលខាងលើ* កថាខណ្ឌ ៩៧២។

[2694] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៣៥ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៥៧។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៧៩ ការយល់ឃើញតែមួយត្រូវបានធ្វើឡើយ។

[2695] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៥៧ ជើងទំព័រ ២៣៨៥។

01358557



១៩៧៥[2696]។ ទោះជាយ៉ាងណាក្តី ដូចបានកត់សម្គាល់ខាងលើ ដោយហេតុថា Ben KIERNAN ពុំបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដូច្នេះ អង្គជំនុំជម្រះពុំគប្បីផ្តល់ទម្ងន់ធ្ងន់ដល់សៀវភៅរបស់គាត់ឡើយ ជាពិសេស នៅពេលផ្តល់ការយល់ឃើញដែលពាក់ព័ន្ធទៅនឹងអំពើប្រព្រឹត្តរបស់ ខៀវ សំផន និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់គាត់[2697]។ ទោះជាយ៉ាងណាក្តី គួរតក់សម្គាល់ថា នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំដែលមានរយៈពេល ១០ ថ្ងៃក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ នៅវិហារព្រះកែវមរកត(ក្នុងវាំង) ដែលក្នុងអំឡុងពេលនោះ មេដឹកនាំបក្សបានផ្តល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា[2698]។ ដូច្នេះ មានភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលបង្ហាញថា វគ្គបំពាក់បំប៉នមនោគមន៍វិជ្ជានេះបានរួមបញ្ចូលការធ្វើយុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា និងថា ខៀវ សំផន បានដឹកនាំវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាមួយចំនួន។ អាស្រ័យហេតុនេះ ដោយពិចារណាលើភស្តុតាងជារួមពាក់ព័ន្ធទៅនឹងចំណុចនេះ រួមទាំងទម្ងន់ដែលអាចផ្តល់តិចតួចទៅលើការរៀបរាប់របស់ Ben KIERNAN ការយល់ឃើញរបស់អង្គ

---

[2696] *សូមមើល* សៀវភៅដោយ B. KIERNAN៖ *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជាក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ឆ្នាំ ១៩៧៥-១៩៧៩* ឯកសារលេខ E3/1593 ឆ្នាំ ១៩៩៦ ERN (ភាសាខ្មែរ) 00637575 ទំព័រ ២១៩ ចុងទំព័រខាងស្តាំ។ ប្រភពដទៃទៀតដែលបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូង គឺប្រតិចារឹកចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ (អុង ថុងហឿង) ឯកសារលេខ E1/103.1 ទំព័រ ៨៤ (អុង ថុងហឿង បានឆ្លើយថា ភរិយារបស់គាត់បានរំឮកថា ខៀវ សំផន ហ្នឹងគាត់ថា "ប្រទេសកម្ពុជាកំពុងតែកសាងរីកចម្រើន ឱ្យទុកចិត្តប្រជារាស្ត្រ ប្រជាជនកម្ពុជា ហើយឱ្យខំកសាងខ្លួនផ្សេងទៀតខ្ញុំអត់ចាំទេបាទ"។ កំណត់ហេតុស្តាប់ចម្លើយរបស់ អុង ថុងហឿង ឯកសារលេខ E3/97 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ERN (ភាសាខ្មែរ) 00270696 ទំព័រ ១៧ (អុង ថុងហឿង បានឆ្លើយថា ភរិយារបស់គាត់បានចូលរួមប្រជុំមួយជាមួយ ខៀវ សំផន ដែលបានមក "និយាយពី […] ថាតើត្រូវធ្វើយ៉ាងណាដើម្បីអប់រំខ្លួនយើងឡើងវិញ និងដើម្បីទម្លាប់ខ្លួនឱ្យដូចពួកកសិករ"។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1 ទំព័រ ១៣ ដល់ ១៤ (Philip SHORT បានពិភាក្សាអំពីទស្សនទាននៃ"ទ្រព្យសម្បត្តិឯកជនខាងស្មារតី" និងគោលការណ៍រក្សាការសម្ងាត់ក្នុងបរិបទនៃវគ្គបណ្តុះបណ្តាលផ្នែកមនោគមន៍វិជ្ជា)។

[2697] *សូមមើលខាងលើ* កថាខណ្ឌ ៣២៥ *ជាអាទិ៍*។

[2698] សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤៣, ៩៧៤។

ជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានធ្វើយុត្តិកម្មជម្លៀសប្រជាជនយ៉ាងហោចណាស់នៅម្តងនៅក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាទាំងនោះ[2699] មានភាពសមហេតុផល។

## ៤.ង.១.ឈ.៣.តួនាទីរបស់ ខៀវ សំផន ជាអ្នកសេដ្ឋកិច្ចក្នុងការអនុវត្តគោលបំណងរួម

១០១៦.ទាក់ទងទៅនឹងតួនាទីរបស់ ខៀវ សំផន ក្នុងគោលនយោបាយសេដ្ឋកិច្ច អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គាត់មានតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ និងជាពិសេស ក្នុងតំណែងរបស់គាត់ជាសមាជិកមន្ទីរ ៨៧០ *ក្នុងចំណោមនោះ* មានការបែងចែកទំនិញទៅកាន់ភូមិភាគ ការចុះពិនិត្យផលិតផលតាមឃ្លាំងដែលត្រូវនាំចេញ (ដូចជា ស្រូវ) ការទទួលព័ត៌មានទំនាក់ទំនងអំពីពាណិជ្ជកម្មអន្តរជាតិ និងការទទួលខុសត្រូវលើការប្រើប្រាស់ឥណទាន[2700]។ ដោយរំលឹកថា "គោលបំណងរួមនេះមានគោលដៅបង្កើតរដ្ឋមួយដោយខ្លួនទីពឹងខ្លួន រដ្ឋមួយពឹងផ្អែកលើកសិកម្មសម័យទំនើបក្នុងរយៈពេលពី ១០ ទៅ ១៥ ឆ្នាំ និងបន្ទាប់មក ជារដ្ឋមួយពឹងផ្អែកលើសេដ្ឋកិច្ចឧស្សាហកម្ម"នោះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខៀវ សំផន "មិនត្រឹមតែរួមចំណែកក្នុងគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង [...] មានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តទិដ្ឋភាពមួយចំនួននៃគោលបំណងរួមនេះផងដែរ"[2701]។

១០១៧.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំអាចទាញសេចក្តីសន្និដ្ឋានដោយសមហេតុផលចេញពីភស្តុតាងដែលថា គាត់បានចូលរួមក្នុងមន្ទីរ ៨៧០ នៅខែ តុលា ឬប្រហែលក្នុងខែតុលា ឆ្នាំ ១៩៧៥ បានឡើយ[2702]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដើម្បីគាំទ្រដល់ការយល់ឃើញ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥។ យោងតាមកំណត់ហេតុនោះ សមមិត្ត ហែម (រហស្សនាមរបស់ ខៀវ សំផន) ត្រូវបានចាត់ឲ្យទទួល

---

[2699] *ប្រៀបធៀប* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៥៧ ដែលនិយាយអំពីយុត្តិកម្មនៃការជម្លៀសប្រជាជននៅក្នុងវគ្គបណ្តុះបណ្តាលមនោគមន៍វិជ្ជា ជាមួយនឹងកថាខណ្ឌ ៣៧៩ ដែលនិយាយអំពី"យ៉ាងហោចណាស់មួយ"ក្នុងចំណោមវគ្គបណ្តុះបណ្តាលនានា។

[2700] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៧ ដល់ ៩៧៨ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៩០ និង ៤០៦ ដល់ ៤០៧។

[2701] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៩។

[2702] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៥១ ដល់ ៥៥៣ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៩០។

01358559



ខុសត្រូវចំពោះ"វណសិប្ប និងរាជរដ្ឋាភិបាល និងពាណិជ្ជកម្មសម្រាប់គណនេយ្យ និងការកំណត់តម្លៃ" នៅខណៈដែល"សមមិត្ត ឌឿន" ត្រូវបានតែងតាំងជា"ប្រធានមន្ទីរនយោបាយ ៨៧០"[2703] ក៏ដូចជាតាមកំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ផងដែរ គាត់បានសារភាពថា គាត់ធ្លាប់ជាសមាជិកមួយរូបក្នុងចំណោមសមាជិកពីររូបនៃមន្ទីរ ៨៧០ (សមាជិកម្នាក់ទៀត គឺ"ឌឿន") និងមានការទទួលខុសត្រូវ ដែលរួមមាន"ការរៀបចំបញ្ជីតម្លៃ និងបែងចែកទំនិញទៅកាន់ភូមិភាគ ក្រោមការណែនាំពីគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយក៏ជាអ្នកដែលត្រូវរក្សាទំនាក់ទំនងល្អជាមួយសម្តេច នរោត្តម សីហនុ ផងដែរ"[2704]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងទៅលើសៀវភៅមួយក្បាលដែលនិពន្ធដោយ ខៀវ សំផន ផងដែរ ដែលក្នុងនោះយោងលើការអះអាងរបស់គាត់ដែលថា គាត់បានចូលរួមក្នុងមន្ទីរ ៨៧០ "ប្រហែលក្នុងខែ តុលា ឆ្នាំ ១៩៧៥" និងបានពិពណ៌នាអំពីការទទួលខុសត្រូវរបស់គាត់ស្រដៀងគ្នានេះដែរ[2705]។ តាមរយៈការបង្ហាញជាភស្តុតាងដោយកំណត់ហេតុនៃកិច្ចប្រជុំដទៃទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ទោះបីជាពេលនេះ ខៀវ សំផន បានអះអាងថា សេចក្តីថ្លែងរបស់គាត់មានកំហុសក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានចូលរួមក្នុងមន្ទីរ ៨៧០ នៅក្នុងអំឡុងខែ តុលា ឆ្នាំ ១៩៧៥ នោះ ជាការសមហេតុផលហើយ ដោយយោងទៅលើភស្តុតាងដែលបានលើកឡើងខាងលើដែលបានបញ្ជាក់បន្ថែមឱ្យគ្នាទៅវិញទៅមក។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

១០១៨.ខៀវ សំផន ក៏បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានគ្រប់គ្រងលើគណៈកម្មាធិការពាណិជ្ជកម្ម ដោយបានលើកឡើងថា តួនាទីរបស់គាត់នៅក្នុងសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ មានកម្រិត ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម[2706]។ ជាពិសេស គាត់

[2703] កំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារលេ E3/182 ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00019108 ទំព័រ ១។

[2704] កំណត់ហេតុស្តាប់ចម្លើយរបស់ ខៀវ សំផន លេខ E3/37 ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00156676 ទំព័រ ៣។

[2705] សៀវភៅរបស់ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារលេខ E3/18 ទំព័រ ៧៣ ដល់ ៧៤ ERN (ភាសាខ្មែរ) 00103844-5។

[2706] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៥៤ ដល់ ៥៥៩ *យោងទៅលើ*សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤០៩។

បានអះអាងថា ឯកសារដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងក្នុងការយល់ឃើញថា គាត់បានគ្រប់គ្រងលើគណៈកម្មាធិការពាណិជ្ជកម្មនោះ ជាក់ស្តែងត្រឹមតែបង្ហាញអំពីមុខងាររបស់គាត់ដែល មានកម្រិតប៉ុណ្ណោះ[2707]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានគ្រប់គ្រងលើគណៈកម្មាធិការពាណិជ្ជកម្មនោះ ពុំបានផ្អែកលើភស្តុតាងដែលបានសួរដេញដោលតែមួយមុខនោះទេ ប៉ុន្តែបានផ្អែកលើការយល់ឃើញទាំងអស់ទាក់ទងទៅនឹងតួនាទីរបស់គាត់ពាក់ព័ន្ធទៅនឹងគណៈកម្មាធិការពាណិជ្ជកម្មផងដែរ[2708]។ ខៀវ សំផន បានត្រឹមតែលើកឡើងនូវជម្រើសនៃការបកស្រាយអំពីភស្តុតាងប៉ុណ្ណោះ ប៉ុន្តែពុំបានបង្ហាញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងមានភាពមិនសមហេតុផលនោះឡើយ។ ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានសំអាងលើសក្ខីកម្មរបស់សាក្សី សគីម ល្មុត ដើម្បីគាំទ្រដល់ការយល់ឃើញដែលថា ជារឿយៗ គណៈកម្មាធិការពាណិជ្ជកម្មបានស្នើសុំសេចក្តីណែនាំពី ខៀវ សំផន នោះ ដោយផ្អែកលើវិធីសាស្ត្រនៃការស្តាប់ចម្លើយសាក្សីរូបនេះក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[2709] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់សក្ខីកម្មរបស់សាក្សីរូបនេះធ្វើជាប្រភពព័ត៌មានបន្ថែម ("*សូមមើលផងដែរ*")ប៉ុណ្ណោះ និងក៏បានផ្អែកជាចម្បងទៅលើរបាយការណ៍ និងលិខិតចំនួន ៦ របស់គណៈកម្មាធិការពាណិជ្ជកម្ម ដែល ខៀវ សំផន ពុំបានជំទាស់ឡើយ។ ដូច្នេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

### ៤.ង.១.ឈ.៤.សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន ដែលគាំទ្រគោលបំណងរួម

១០១៩.អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ក្នុងនាមជាកម្មាភិបាលជាន់ខ្ពស់បំផុតម្នាក់នៅក្នុងពេលតស៊ូនៅក្នុងប្រទេស និងក្រោយមក ក្នុងនាមគាត់ជាថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ជាពិសេសជា ប្រធាននៃគណៈប្រធានរដ្ឋ"[2710] ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍គាំទ្រគោលនយោបាយខ្មែរក្រហម[2711] រួមទាំងបានផ្តល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលទទួលបានការគាំទ្រនៅក្នុង និងនៅក្រៅ

---

[2707] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៥៥។

[2708] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤០៩។

[2709] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៥៦ ដល់ ៥៥៧។

[2710] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨០។

[2711] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨១ ដល់ ៩៨៦។

ប្រទេសដល់បដិវត្តន៍[2712]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា “សេចក្តីថ្លែងការណ៍ទាំងនេះ ដែលបានគាំទ្រអស់ពីចិត្តពីថ្លើមលើបដិវត្តន៍ដោយគ្មានការរិះគន់ណាមួយនោះ បានបង្ហាញឲ្យឃើញថា ខៀវ សំផន រួមចំណែកក្នុងគោលបំណងរួម និងគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា ផ្លាស់ទីលំនៅប្រជាជនពីជនបទមួយទៅជនបទមួយទៀត និងបានកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរសម្រាប់ការចាប់ខ្លួន ការសម្លាប់ និងការធ្វើឱ្យបាត់ខ្លួន” និងគាត់បានប្រើប្រាស់មុខតំណែង និងតួនាទីរបស់គាត់ដើម្បីបង្ហាញខ្លួនគាត់“ជាមេដឹកនាំសំខាន់មួយរូប និង[បានជំរុញទឹកចិត្ត] ឲ្យប្រជាជនកម្ពុជា និងកម្មាភិបាលខ្មែរក្រហមបន្តកសាងបដិវត្តន៍សង្គមនិយម”[2713]។

១០២០.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសុន្ទរកថាដែលបានធ្វើឡើងនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលសន្ទរកថានេះបានផ្តល់ការធានាតាមរយៈការបោកបញ្ឆោតចំពោះទាហាននៃរបបសាធារណរដ្ឋខ្មែរថា ពួកគេនឹងត្រូវទុកជីវិត ប្រសិនបើចូលរួមជាមួយកម្លាំងតស៊ូ និងបានអះអាងថា ពុំមានហេតុផលដែលត្រូវជឿថា ការធានានោះមិនពិតប្រាកដនោះឡើយ[2714]។ គាត់បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានបំភ្លៃភស្តុតាងក្នុងការធ្វើសេចក្តីសន្និដ្ឋានថា ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ពេលដែលគាត់ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ សុន្ទរកថារបស់គាត់ បានបង្ហាញថា គាត់បានចូលរួមក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះ[2715]។ គាត់បានជំទាស់ថា សុន្ទរកថាតែមួយគត់ទាក់ទងទៅនឹងករណីនេះ គឺសុន្ទរកថាដែលគាត់បានធ្វើឡើងកាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ក្នុងការអបអរសាទរចំពោះកងទ័ពខ្មែរក្រហម និងប្រជាជនកម្ពុជាដែលបានរំដោះប្រទេស ហើយគាត់បានជំទាស់ថា សុន្ទករថារបស់គាត់ពុំមានអ្វីជាប់ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរឡើយ[2716]។ ចុងក្រោយ ទាក់ទងទៅនឹងបញ្ហានេះ ខៀវ សំផន បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសុន្ទរកថាដែលគាត់បានថ្លែងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៦ ថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ១៩៧៦ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧

---

[2712] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨០។

[2713] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨៧។

[2714] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥៧ ដល់ ២៦២។

[2715] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៣៨។

[2716] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៣៦ ដល់ ៥៣៨។

និង ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៧ ក្នុងការសន្និដ្ឋានថា គាត់បានរួមចំណែកក្នុងការអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមតាមរយៈការគាំទ្រដល់ការប្រព្រឹត្តបទឧក្រិដ្ឋ[2717]។

១០២១.ពាក់ព័ន្ធទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសទាក់ទងទៅនឹងសុន្ទរកថាមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា គាត់ពុំបានជំទាស់ថា គាត់ពុំបានថ្លែងសុន្ទរកថាទាំងនោះ ឬខ្លឹមសារក្នុងសុន្ទរកថាទាំងនោះទេ ប៉ុន្តែ គាត់បានប្រៀបធៀបជាមួយនឹងសុន្ទរកថារបស់សម្តេចនរោត្តម សីហនុ ដោយបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តខុសគ្នាចំពោះសុន្ទរកថាទាំងនោះ ឬថា សុន្ទរកថាទាំងនោះពុំអាចមានផលប៉ះពាល់ទៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះទេ[2718]។ អំណះអំណាងទាំងនេះពុំមានភាពសមស្របក្នុងការបង្ហាញពីកំហុស ក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ដូច្នេះ អំណះអំណាងនេះត្រូវបដិសេធចោល។

១០២២.ទាក់ទងទៅនឹងសុន្ទរកថាថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ និងផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន[2719] អង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា ខ្លឹមសារនៃសុន្ទរកថានោះអំពាវនាវឲ្យធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬផ្លាស់ទីលំនៅរបស់ប្រជាជនដំណាក់កាលទីពីរឡើយ ប៉ុន្តែ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នៅក្នុងសុន្ទរកថានោះ ខៀវ សំផន "បានលើកសរសើរកងទ័ពដែលបាន "រំដោះ"ប្រទេស បានប្រកាសថា សត្រូវទាំងអស់បានស្លាប់យ៉ាងវេទនា និងបានកត់សម្គាល់ចំពោះការលះបង់របស់ប្រជាជននៅក្នុងតំបន់រំដោះ និងការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការលើកភ្លឺស្រែ ជីកប្រឡាយ និងធ្វើអាងស្តុកទឹក"[2720] ដែលមានភាពស្របគ្នាយ៉ាងច្រើនទៅនឹងការពិពណ៌នាផ្ទាល់ខ្លួនរបស់គាត់អំពីខ្លឹមសារក្នុងសុន្ទរកថានោះ។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសុន្ទរកថាថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៥ ដែលស្ថិតក្នុងចំណោមសុន្ទរកថាដទៃទៀតជាច្រើន មុនផ្តល់ការយល់ឃើញអំពីការរួមចំណែកក្នុងគោលបំណងរួម តាមរយៈសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន[2721]។ ខៀវ សំផន ពុំបានលើក

---

[2717] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៨២ ដល់ ៥៨៧។

[2718] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥៨ ដល់ ២៦២។

[2719] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៨៨ ដល់ ៣៩១។

[2720] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨២។

[2721] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨១ ដល់ ៩៨៧ (រំឭកសុន្ទរកថាដែលគាត់បានថ្លែងនៅចន្លោះខែ មិថុនា ឆ្នាំ ១៩៧៣ ដល់ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៧)។

មូលដ្ឋានគាំទ្រគ្រប់គ្រាន់ដល់ការអះអាងរបស់គាត់ដែលថា សុន្ទរកថាដទៃទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនោះ ពុំមានភាពជាប់ពាក់ព័ន្ធឡើយ។ យោងតាមមូលហេតុដូចគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងសុន្ទរកថាដែលគាត់បានថ្លែងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៦, ថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ១៩៧៦ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ និង ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៧[2722]។ ខៀវ សំផន ពុំបានជំទាស់ថា គាត់ពុំបានថ្លែងសុន្ទរកថាទាំងនេះឡើយ ប៉ុន្តែព្យាយាមធ្វើការបកស្រាយ ដែលមានលក្ខណៈខុសពីការបកស្រាយដោយអង្គជំនុំជម្រះសាលាដំបូងដែលការបកស្រាយរបស់គាត់ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញអំពីកំហុសផ្នែកអង្គហេតុ។

១០២៣.ផ្ទុយទៅវិញ ទាក់ទងទៅនឹងសុន្ទរកថាបើកសម័យប្រជុំនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ជាការត្រឹមត្រូវដែលខៀវ សំផន បានអះអាងថា[2723] អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ជាសុន្ទរកថារបស់គាត់[2724]។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានសំអាងលើឯកសារបកប្រែជាភាសាអង់គ្លេសនៃកំណត់ហេតុកិច្ចប្រជុំសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យ ដែលបានបញ្ជាក់ថា អ្នកថ្លែងសុន្ទរកថានោះជា"ប្រធានគណៈប្រធានរដ្ឋ"[2725]ក៏ដោយ ក៏សំណៅដើមជាភាសាខ្មែរ និងភាសាបារាំងបានសំដៅលើ"ប្រធានគណៈអធិបតី"ថា ជាអ្នកថ្លែងសុន្ទរកថាទៅវិញទេ។ ឈ្មោះ ខៀវ សំផន ត្រូវបានលើកឡើងតែម្តងទាក់ទងទៅនឹងការជ្រើសតាំងគាត់ជាប្រធានគណៈប្រធានរដ្ឋ[2726]។ ពុំមានការបញ្ជាក់នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះថា ខៀវ សំផន បានបំពេញតួនាទីជា"ប្រធានគណៈអធិបតី" និងថ្លែងសុន្ទរកថាបើកសម័យប្រជុំនោះឡើយ។

១០២៤.ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសំអាងលើសុន្ទរកថារបស់គាត់នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៧ ដើម្បីសន្និដ្ឋានថា "គាត់បានទទួល

---

[2722] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៨២ ដល់ ៥៨៣ និង ៥៨៥ ដល់ ៥៨៧។

[2723] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៨០។

[2724] សាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨៥។

[2725] កំណត់ហេតុនៃកិច្ចប្រជុំសភាតំណាងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/165 ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00053610-18 ទំព័រ ៨ ដល់ ១៦ ERN (ភាសាអង់គ្លេស) 00184052-6 ទំព័រ ៥ ដល់ ៩។

[2726] កំណត់ហេតុនៃកិច្ចប្រជុំសភាតំណាងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ ឯកសារលេខ E3/165 ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦ ERN (ភាសាខ្មែរ) 00053610-18 ទំព័រ ៨ ដល់ ១៦, ERN (ភាសាបារាំង) 00301338-42។

ស្គាល់ថា មនុស្សរាប់ម៉ឺននាក់ត្រូវបានប្រមូលផ្តុំនៅតាមការដ្ឋានផ្សេងៗគ្នាជាច្រើន"នោះ [2727] អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា សុន្ទរកថានេះពុំបានលើកឡើងជាក់លាក់នូវបញ្ហានៃការផ្លាស់ទីលំនៅប្រជាជនឡើយ[2728] ប៉ុន្តែ បានលើកឡើងអំពីចំនួនពលករជាច្រើនធ្វើការនៅការដ្ឋានសាងសង់អាងស្តុកទឹក ប្រឡាយទឹក និងទំនប់ទឹក និងជាការសមហេតុផលក្នុងការសន្និដ្ឋានថា ពលករធ្វើការនៅការដ្ឋានសាងសង់ទាំងនេះ ត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋាននោះពីមុនរួចហើយ។ ដូច្នេះ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើសុន្ទរកថា និងការប្រើប្រាស់សុន្ទរកថានេះ គឺស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ទាំងស្រុង[2729]។ អំណះអំណាងដែលនៅសេសសល់របស់ ខៀវ សំផន ទាក់ទងទៅនឹងចំណុចនេះ[2730] គ្រាន់តែជាការផ្តល់នូវការបកស្រាយមួយផ្សេងទៀតប៉ុណ្ណោះទៅលើភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាង ដូច្នេះ អំណះអំណាងនេះពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលនោះឡើយ។

## ៤.ង.១.ឈ.៥.តួនាទីការទូតរបស់ ខៀវ សំផន ក្នុងការការពារគោលបំណងរួម

១០២៥.អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ក្នុង ប.ក.ក. អាស្រ័យលើ ខៀវ សំផន ក្នុងការប្រើប្រាស់កេរ្តិ៍ឈ្មោះល្អរបស់គាត់ដើម្បីបង្កើតទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ និងអ្នកគាំទ្ររបស់ទ្រង់ ដែលជាតួនាទីមួយ ខៀវ សំផន បានចាត់ទុកថា ជាតួនាទី"ដែលមានសារៈសំខាន់ ប៉ុន្តែពុំមែនរហូតដល់ខ្វះមិនបាននោះទេ"[2731]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានអមដំណើរសម្តេច នរោត្តម សីហនុ ក្នុងដំណើរទស្សនកិច្ចទៅកាន់តំបន់រំដោះក្នុងឆ្នាំ ១៩៧៣ និងទៅកាន់ទីជនបទក្នុងដើមឆ្នាំ ១៩៧៦ រួមទាំងទៅកាន់ការដ្ឋាននានាដែលគាត់បានលើកសរសើរអំពីការកសាងទំនប់ទឹក និងប្រឡាយទឹក និងផលិតកម្មកសិកម្ម

---

[2727] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៨៤ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៥៦។

[2728] *សូមមើល* សុន្ទរកថារបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំគំរប់ខួប ឯកសារលេខ E3/201 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៧ ERN (ភាសាខ្មែរ) 00292807 ("ដូច្នេះ យើងអាចមើលឃើញថា ទីជនបទយើងមានការប្រែប្រួលយ៉ាងខ្លាំង។ ការដ្ឋានសាងសង់អាងស្តុកទឹក ប្រឡាយទឹក ឬទំនប់ទឹកនីមួយៗមានកម្មករធ្វើការប្រហែល ១០.០០០, ១២.០០០, ៣០.០០០ នាក់")។

[2729] *សូមមើលខាងលើ* កថាខណ្ឌ ២២១, ២៣៦។

[2730] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៨៤ ដល់ ៥៨៥ និង ៥៨៧។

[2731] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨៨។

[2732]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូងបានរំលឹកអំពីតួនាទីរបស់ ខៀវ សំផន ក្នុងទំនាក់ទំនងការទូត ដែលក្នុងតួនាទីនេះ *ក្នុងចំណោមតួនាទីផ្សេងៗទៀត* គាត់បានធ្វើដំណើរទៅប្រទេសចិន និងកូរ៉េខាងជើងក្នុងខែ សីហា ឆ្នាំ ១៩៧៥ ដើម្បីចរចាអំពីការយាងត្រឡប់របស់សម្តេច នរោត្តម សីហនុ[2733] និងបានផ្តល់យុត្តិកម្ម ចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា[2734]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខៀវ សំផន បានគាំទ្រ និងបានបន្តរួមចំណែកក្នុងគោលបំណងរួម និងគោលនយោបាយជាមូលដ្ឋាន ដែលបាន ធ្វើឲ្យខ្មែរក្រហមទទួលបានការគាំទ្រលើឆាកអន្តរជាតិ"ក្នុងការខិតខំប្រឹងប្រែងរបស់គាត់ដើម្បីផ្តល់យុត្តិកម្ម និង លើកសរសើរដល់សកម្មភាព និងគោលនយោបាយរបស់បក្ស និងដើម្បីបង្វែរការចាប់អារម្មណ៍ និងក្តីបារម្ភពី ការជ្រៀតជ្រែក"[2735]។

១០២៦.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបំប៉ោងតួនាទីរបស់គាត់ ក្នុងនាមជាអ្នកទំ នាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ និងសារៈសំខាន់នៃសកម្មភាពការទូតរបស់គាត់ ដោយពុំបានអើពើ លើភស្តុតាងដែលថា គាត់ពុំបានចុះសម្រុងជាមួយនឹងសម្តេច នរោត្តម សីហនុ និងថា អៀង សារី គឺជាអ្នកការ ទូតលេចធ្លោជាងរូបគាត់នៅក្នុងឆាកអន្តរជាតិ និងបានធ្វើទំនាក់ទំនងច្រើនជាមួយសម្តេច នរោត្តម សីហនុ ជាង អ្វីដែលគាត់បានធ្វើ[2736]។ គាត់បានអះអាងថា ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគួរសន្និដ្ឋានថា ការរួម ចំណែករបស់គាត់ដើម្បីកៀងគរការគាំទ្រសម្រាប់ខ្មែរក្រហម មានកម្រិតតិចតួចណាស់[2737]។

១០២៧.ទាក់ទងទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយ សារពុំបានពិចារណាអំពីការមិនចុះសម្រុងរបស់គាត់ជាមួយនឹងសម្តេច នរោត្តម សីហនុ[2738]នោះ អង្គជំនុំជម្រះ តុលាការកំពូលបដិសេធអំណះអំណាងនេះដោយពុំធ្វើការពិចារណាបន្តទៀតឡើយ ដោយសារ ខៀវ សំផន ពុំ

---

[2732] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨៩ ដល់ ៩៩០។

[2733] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨៩ ជើងទំព័រ ២៩៨០ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលា ដំបូង កថាខណ្ឌ ៣៧៤, ៧៥៧ ដល់ ៧៥៨។

[2734] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩១។

[2735] សាលក្រមរបស់ជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩២។

[2736] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤៩ ដល់ ២៥៦។

[2737] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥២ និង ២៥៦។

[2738] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤៩ ដល់ ២៥២។

បានបង្ហាញ ថាតើបញ្ហានេះអាចមានផលប៉ះពាល់ដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់យ៉ាងដូចម្ដេចនោះឡើយ។ ទាក់ទងទៅនឹងអំណះអំណាងដែលនៅសេសសល់ ខៀវ សំផន បានត្រឹមតែផ្ដល់ការបកស្រាយមួយផ្សេងទៀតអំពីភស្តុតាង ដោយពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលនោះឡើយ។ បន្ថែមលើនេះទៀត ផ្ទុយពីអ្វីដែល ខៀវ សំផន បានអះអាងនោះ[2739] អង្គជំនុំជម្រះសាលាដំបូងពុំបានផ្ដល់ការយល់ឃើញពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ ដោយផ្អែកលើព័ត៌មានដែលប្រមូលបានពីសកម្មភាពការទូតរបស់គាត់នោះទេ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋាន*ក្នុងចំណោមនោះ*ថា តួនាទីការទូតរបស់គាត់ទទួលបានការគាំទ្រទាំងក្នុងទាំងក្រៅស្រុកសម្រាប់ខ្មែរក្រហម ដែលតាមរយៈនេះបានបង្វែរការចាប់អារម្មណ៍ និងការជ្រៀតជ្រែកពីខាងក្រៅដែលអាចមាន[2740]។ ការដែលថា អៀង សារី ប្រហែលជាបានចូលរួមក្នុងកិច្ចខិតខំផ្នែកការទូតស្រដៀងគ្នានេះ ពុំបានសម្រាល ឬពុំបានធ្វើឱ្យកិច្ចខិតខំផ្ទាល់ខ្លួនរបស់ ខៀវ សំផន ចុះថយដល់កម្រិតអប្បបរមាឡើយ។ ស្រដៀងគ្នានេះដែរ ការលើកឡើងរបស់ ខៀវ សំផន ដែលថា សម្ដេច នរោត្តម សីហនុ មានចេតនានយោបាយផ្ទាល់ខ្លួនចំពោះការគាំទ្រខ្មែរក្រហម និងថា ទ្រង់ពុំបានដឹងអំពីភារកិច្ចរបស់ ខៀវ សំផន ក្នុងការបំពេញតួនាទីជាអ្នកទំនាក់ទំនងជាមួយ ប.ក.ក. មិនផ្ទុយទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន ពិតជាបានបំពេញតួនាទីជាអ្នកទំនាក់ទំនង និងបានរួមចំណែកក្នុងការអនុវត្តគោលបំណងរួមតាមរយៈការធានាឱ្យមានការគាំទ្រពីសម្ដេច នរោត្តម សីហនុ[2741]។

១០២៨.ចំពោះការធ្វើដំណើរទៅក្រៅប្រទេស ខៀវ សំផន បានទទួលស្គាល់ថា គាត់ (និងអ្នកដទៃទៀត) បានធ្វើដំណើរទៅប្រទេសចិន និងកូរ៉េខាងជើងក្នុងខែ សីហា ឆ្នាំ ១៩៧៥ ប៉ុន្តែបានលើកឡើងថា ពុំមានភស្តុតាងបង្ហាញថា គោលបំណងនៃការធ្វើដំណើរនេះ គឺដើម្បីចរចាអំពីការយាងត្រឡប់របស់សម្ដេចនរោត្តម សីហនុ ឡើយ[2742]។ តាមការពិនិត្យភស្តុតាងដែលសំអាងដោយអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា ការចោទ

---

[2739] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥៦។

[2740] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦២ និង ៩៩២។

[2741] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៥៤។

[2742] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥២៣ យោងទៅលើ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៧៤, ៧៥៨។ ខៀវ សំផន បានលើកឡើងផងដែរថា គ្មានភស្តុតាងបង្ហាញថា មានការផ្លាស់ប្ដូរព័ត៌មានទាក់ទងទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ។ *សូមមើល* សារណាបណ្ដឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៥២៣។ ការពិនិត្យឡើងវិញលើផ្នែកពាក់ព័ន្ធនានានៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពុំបានបង្ហាញឱ្យឃើញពីការយល់ឃើញណាមួយទាក់ទងទៅនឹងទំនាក់ទំនងរបស់គាត់

ប្រកាន់អំពីកង្វះភស្តុតាងស្តីពីបញ្ហានេះ គឺពុំត្រឹមត្រូវឡើយ[2743]។ ទាក់ទងទៅនឹងភស្តុតាងដែលបង្ហាញថា ខៀវ សំផន បានអមដំណើរសម្តេច នរោត្តម សីហនុ ក្នុងដំណើរទស្សនកិច្ចទៅកាន់ការដ្ឋាននានាបន្ទាប់ពីសម្តេច នរោត្តម សីហនុ បានយាងត្រឡប់មកកម្ពុជាវិញនោះ គាត់បានលើកឡើងថា ភស្តុតាងបែបនេះពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និងគ្រប់ករណីទាំងអស់ ពុំមែនជាភស្តុតាងដាក់បន្ទុកឡើយ ហើយការពិតដែលថា គាត់បានលើកសរសើរពីការកសាង និងការងារកសិកម្មដែលកំពុងធ្វើនៅទីនោះ ក៏ពុំមែនជាភស្តុតាងដាក់បន្ទុកផងដែរ[2744]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ភស្តុតាងនេះ ជាប់ពាក់ព័ន្ធត្រង់ចំណុចថា ប្រជាជនមួយចំនួនដែលត្រូវបានផ្លាស់ទីលំនៅដំណាក់កាលទីពីរ ត្រូវបានបញ្ជូនទៅកាន់ការដ្ឋាននានា[2745]។ សរុបសេចក្តីមក អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ៤.ង.១.ឈ.៦.ការរួមចំណែកជាទូទៅរបស់ ខៀវ សំផន តាមរយៈសិទ្ធិអំណាច និងឥទ្ធិពល

១០២៩.អង្គជំនុំជម្រះតុលាការកំពូលបដិសេធការលើកឡើងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការជឿទុកចិត្តដែលគាត់បានទទួលពីថ្នាក់ដឹកនាំ ប.ក.ក. ព្រមទាំងការចូល

---

ជាមួយសម្តេច នរោត្តម សីហនុ ការធ្វើដំណើររបស់គាត់ទៅបរទេសពាក់ព័ន្ធទៅនឹងបញ្ហានេះ ឬការរួមចំណែករបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមនោះឡើយ។ ហេតុនេះ អំណះអំណាងនេះត្រូវបដិសេធ។

[2743] *សូមមើល ឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៧៤ យោងទៅលើទូរលេខរបស់ក្រសួងការបរទេសរបស់សហរដ្ឋអាម៉េរិក កម្មវត្ថុៈ ខៀវ សំផន ចាកចេញទៅកាន់ប្រទេសកូរ៉េខាងជើ ឯកសារលេខ E3/3350 ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00740887 ទំព័រ ២ ("ក្នុងក្រុងព្យុងយ៉ាង លោក ខៀវ សំផន ត្រូវបានគេរំពឹងថានឹងរកមធ្យោបាយយាងសម្តេច សីហនុ ឲ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ(សម្ងាត់)") និងកថាខណ្ឌ ៧៥៨ យោងទៅលើទូរលេខក្រសួងការបរទេសបារាំង កម្មវត្ថុៈ ទស្សនកិច្ចទៅកាន់ប្រទេសចិនរបស់ ខៀវ សំផន និង អៀង សារី ឯកសារលេខ E3/2721 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00662229 ទំព័រ ៣ ("នាពេលនេះ គេអាចយល់បានថាក្រោយទស្សនកិច្ចនៅប៉េកាំង គណៈប្រតិភូនឹងធ្វើដំណើរទៅទទួលសម្តេច សីហនុ នៅក្រុងព្យុងយ៉ាងជាបន្តទៀត")។ ទូរលេខក្រសួងការបរទេសរបស់សហរដ្ឋអាម៉េរិក កម្មវត្ថុៈ ទស្សនកិច្ចរបស់ ខៀវ សំផន ទៅកាន់សាធារណៈរដ្ឋប្រជាមានិតចិន ឯកសារលេខ ឯកសារ E3/619 ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៧៥ ERN (ភាសាខ្មែរ) 00635940 ទំព័រ ៣ ("តាមពាក្យចចាមអារ៉ាមដែលលេចលឺក្នុងទីក្រុងប៉េកាំងបានឲ្យដឹងថា វាប្រហែលជាការពិតដែលថា លោក ប៉ែន នុត គឺនៅទីនេះដើម្បីចរចាទំនាក់ទំនងរបស់សម្តេច សីហនុ ជាមួយលោក ខៀវ សំផន និងល័ក្ខខ័ណ្ឌផ្សេងៗសម្រាប់ការត្រឡប់ចូលប្រទេសកម្ពុជាវិញ មុនពេលដែលសម្តេច សីហនុ នឹងបង្ហាញមុខដោយខ្លួនព្រះអង្គផ្ទាល់")។

[2744] សារណាបណ្តឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៥២៤ ដល់ ៥២៥។

[2745] *សូមមើលឧ.* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦០១។

រួមរបស់គាត់ក្នុងដំណើរការធ្វើសេចក្ដីសម្រេចរបស់ ប.ក.ក. ឬសិទ្ធិអំណាច និងឥទ្ធិពលដែលគាត់មាន[2746]។ បើត្រឹមតែការលើកឡើងដែលថា អាចមានការសន្និដ្ឋាន ឬការបកស្រាយមួយផ្សេងទៀតអំពីភស្តុតាងដដែល ដែលបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងនោះ[2747] អំណះអំណាងរបស់ ខៀវ សំផន ពុំគ្រប់គ្រាន់ក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផលនោះឡើយ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អ្វីដែលត្រូវបង្ហាញគឺថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចផ្ដល់ការយល់ឃើញផ្នែកអង្គហេតុ ដែលរងការជំទាស់ដូចនេះឡើយ ហេតុដូច្នេះ ជាការពុំគ្រប់គ្រាន់ដោយត្រឹមតែលើកការសន្និដ្ឋានមួយផ្សេងទៀតដែលអង្គជំនុំជម្រះសាលាដំបូងអាចធ្វើបាននោះ[2748]។ លើសពីនេះទៀត អំណះអំណាងរបស់ ខៀវ សំផន ដែលថា តួនាទីរបស់គាត់ គឺគ្រាន់តែជានិម្មិតរូប ឬមានតែសំបកក្រៅ ដូច្នេះពុំមានសិទ្ធិអំណាចអ្វីនោះ[2749] ពុំអាចជឿជាក់បានឡើយ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ជនជាប់ចោទពុំចាំបាច់ស្ថិតក្នុងតួនាទីដែលមានសិទ្ធិអំណាច ដើម្បីរួមចំណែកសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួមឡើយ[2750] និងបានយល់ឃើញថា “ឋានៈ និងតួនាទីរបស់គាត់ជាផ្នែកមួយនៃការបិទបាំង” ប៉ុន្តែថានេះបានបម្រើដល់គោលបំណងយ៉ាងសំខាន់ និងជាក់ស្ដែងក្នុងការគាំទ្រដល់គោលនយោបាយ ប.ក.ក. និងការបោកបញ្ឆោតប្រជាជន[2751] ជាបញ្ហាមួយដែល ខៀវ សំផន ពុំបានលើកឡើងឡើយ។

## ៤.ង.១.ឈ.៧.សេចក្ដីសន្និដ្ឋាន

១០៣០.បើទោះបីអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៤ និងបានគាំទ្រផែនការជម្លៀសនៅក្នុងកិច្ចប្រជុំនេះ និងថា គាត់បានថ្លែងសុន្ទរកថាបើកកិច្ចប្រជុំសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យនោះ ពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់ក៏ដោយ ក៏ការសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានរួមចំណែក“យ៉ាងសំខាន់”ក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ពុំមានកំហុសឡើយ។ ទាក់ទងទៅនឹង

[2746] សារណាបណ្ដឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ២៦៤ ដល់ ២៦៩, ៥៤០ ដល់ ៥៥០,៥៧៣ ដល់ ៥៧៥។

[2747] សារណាបណ្ដឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ២៦៤, ២៦៩, ៥៤១ ដល់ ៥៤៥, ៥៤៩ ដល់ ៥៥០។

[2748] *សូមមើលខាងលើ* កថាខណ្ឌ ៨៨។

[2749] សារណាបណ្ដឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៥៤៨, ៥៧៣ ដល់ ៥៧០។

[2750] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦៥។

[2751] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨៧។

បញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើប្រព្រឹត្តសរុបរបស់ ខៀវ សំផន ត្រូវបានបែងចែកជាប្រាំប្រភេទ ("កិច្ចប្រជុំគោលនយោបាយ"[2752] "កិច្ចប្រជុំណែនាំ"[2753] "សេដ្ឋកិច្ចវិទូ"[2754] "សេចក្តីថ្លែងការណ៍ជាសាធារណៈ"[2755] "កម្មាភិបាលតំណាងទូត"[2756]) គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងរួម។ ដោយពិចារណាអំពីបទដ្ឋានគតិយុត្តដូចបានលើកឡើងខាងលើ[2757] អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការយល់ឃើញថា ការរួមចំណែករបស់គាត់បានឈានដល់លក្ខខណ្ឌចាំបាច់ក្នុងការដាក់ឱ្យគាត់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមសហឧក្រិដ្ឋកម្មរួមឡើយ[2758]។

១០៣១.ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដូច បាន បញ្ជាក់ខាងលើ[2759] និងដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ បានភ្ជាប់ទំនាក់ទំនងយ៉ាងមាំទៅនឹងគោលនយោបាយឧក្រិដ្ឋ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ដែលថា ទង្វើរបស់គាត់ពុំបានរួមចំណែកដល់ទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម ពុំអាចជឿជាក់បានឡើយ[2760]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលថា ការចូលរួមរបស់គាត់បានជំរុញដល់ការអនុវត្តគោលដៅ ឬគោលបំណងរួម ពោលគឺ ការកសាងបដិវត្តសង្គមនិយមដែលជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ស្របតាមគោលនយោបាយផ្លាស់ទីលំនៅប្រជាជន[2761]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ។

[2752] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៦៤ ដល់ ៩៧២។

[2753] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៣ ដល់ ៩៧៦។

[2754] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៧៧ ដល់ ៩៧៩។

[2755] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨០ ដល់ ៩៨៧។

[2756] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៨៨ ដល់ ៩៩២។

[2757] *សូមមើលខាងលើ* កថាខណ្ឌ ៩៨០ *ជាអាទិ៍*។

[2758] សារណាបណ្តឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ២៩២។

[2759] *សូមមើលខាងលើ* កថាខណ្ឌ ៨១១ ដល់ ៨១៧។

[2760] សារណាបណ្តឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ២៩៩, ៣០៧, ៣១១, ៤០៦, ៤១០, ៦០៥ និង ៦១៩។

[2761] *សូមមើលខាងលើ* កថាខណ្ឌ ៧៦៨ *ជាអាទិ៍*។

01358570



១០៣២.ដោយហេតុថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា អំពើរបស់គាត់ គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងបញ្ហានេះ។

## ៤.ង.១.ញ.ការយល់ឃើញថា ប.ក.ក. ជាបក្សដែលមានការឯកភាព និងឋានានុក្រម និងថា កងកម្លាំងប្រដាប់អាវុធដែលពាក់ព័ន្ធក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានការឯកភាពគ្នា

១០៣៣.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ក្នុងការចាត់ទុក ប.ក.ក. ជា"បក្សដែលមានរចនាសម្ព័ន្ធច្បាស់លាស់ប្រទាក់ក្រឡាគ្នា ដែលក្នុងនោះកម្មាភិបាលថ្នាក់ក្រោមអនុវត្តដោយភក្តីភាព និងស៊ីសង្វាក់គ្នាទៅតាមការណែនាំរបស់ថ្នាក់ដឹកនាំបក្ស"[2762]។ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង "ពុំបានលើកមូលដ្ឋានគាំទ្រគ្រប់គ្រាន់ដល់ការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងរចនាសម្ព័ន្ធ ប.ក.ក." ដែល"មិនលើសពីតារាងលម្អិតនៃអង្គការមួយឡើយ"[2763]។ គាត់បានអះអាងថា មជ្ឈិមបក្សកម្រចេញសេចក្តីណែនាំ និងថា ការបញ្ជាឲ្យសម្លាប់បានចេញពីថ្នាក់ក្រោម និងថា ស្ថានភាពពុំដូចគ្នានៅទូទាំងប្រទេសឡើយ។ គាត់បានលើកឡើងថា "មានភស្តុតាងជាច្រើនបង្ហាញថា បក្សត្រូវបានបែកជាក្រុមតូចៗ មានអំណាចស្មើៗគ្នា ប្រយុទ្ធគ្នានៅក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុងដែលបានរីកធំឡើងៗ ក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យទាំងមូល និងរហូតដល់មានការឈ្លានពានពីវៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ"[2764]។

១០៣៤.ជាក់លាក់ជាងនេះទៅទៀត នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវអំពីតួនាទីរបស់មេដឹកនាំភូមិភាគដែលជាសមាជិកនៃគណៈមជ្ឈិម ឬជាគណៈអចិន្ត្រៃយ៍ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង"បានចាត់ទុកអ្នកទាំងនេះថា ជាមនុស្សស្ថិតក្រោម"ថ្នាក់ដឹកនាំបក្ស"ដែលគ្មានការកំណត់ច្បាស់លាស់[2765]។ យោងតាម នួន ជា ទាំងអស់នេះបានផ្តល់ជាមូលដ្ឋានដល់អង្គជំនុំជម្រះក្នុងការយល់ឃើញថា ពួកគេត្រឹមតែជាអ្នកអនុវត្ត ឬពាំនាំបទបញ្ជា ផ្ទុយទៅវិញតាមការជាក់ស្តែងពួកគេបានជួយបង្កើតនូវ "គោលបំណងរួមរបស់ ប.ក.ក. ស្របតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំដែលពុំមែនជាបទឧក្រិដ្ឋ

---

[2762] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២៥។

[2763] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២៧។

[2764] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២៨។

[2765] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៣០។

នោះទេ”[2766]។ ទាក់ទងទៅនឹងបញ្ហានេះ នួន ជា បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងរវាងមជ្ឈិមបក្ស ជាមួយនឹងផ្នែកដទៃទៀតនៃអង្គការ[2767]។ គាត់ក៏បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងពុំ បានយកចិត្តទុកដាក់ទៅលើភស្តុតាងអំពី“ស្វ័យភាពកម្រិតខ្ពស់”របស់មេដឹកនាំភូមិភាគ ដែល“បានបង្កើតសម្ព័ន្ធមិត្តប្រឆាំង ប៉ុល ពត និង នួន ជា ហើយឆ្លៀតប្រើប្រាស់តួនាទីនៃសិទ្ធិអំណាចរបស់ខ្លួនប្រព្រឹត្តផ្ទុយ និងធ្វើវិទ្ធង្សនាផ្ទុយនឹងឆន្ទៈរបស់គណៈកម្មាធិការអចិន្ត្រៃយ៍”[2768]។ ទាក់ទងទៅនឹងបញ្ហានេះ នួន ជា បានយោងទៅលើចម្លើយរបស់ អៀង សារី ក្នុងកិច្ចសម្ភាសន៍ជាមួយ Stephen HEDER ដែលយោងតាមចម្លើយនេះ ភូមិភាគនីមួយៗមានលក្ខណៈឯករាជ្យ ដែលអង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយលើបញ្ហានេះ[2769] ដែលគាំទ្រភស្តុតាងដទៃទៀតនៃជម្លោះក្នុងចំណោមភូមិភាគនានានោះទេ[2770]។ គាត់បានលើកឡើងថា មានផែនការក្បត់ប្រឆាំងនឹង ប៉ុល ពត “ប្រហែលចាប់ពីដើមខែឧសភា ឆ្នាំ ១៩៧៥” និងមានការចាប់ខ្លួនពីបទក្បត់ជាតិពីឆ្នាំ ១៩៧៦ ដែលផ្ទុយទៅនឹងការលើកឡើងរបស់ ហេង សំរិន ដែលថា ការរៀបចំផែនការក្នុងភូមិភាគបូព៌ាដើម្បីផ្តួលរំលំ ប៉ុល ពត បានចាប់ផ្តើមក្នុងខែ ឧសភា ឆ្នាំ ១៩៧៨ តែប៉ុណ្ណោះ[2771]។ នួន ជា បានអះអាងបន្ថែមទៀតថា ការប្រឆាំងមិនត្រឹមតែចេញមកពីសមាជិក ប.ក.ក. ដែលគាំទ្រវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចេញមកពីអ្នកស្មោះត្រង់ជាមួយសម្តេច នរោត្តម សីហនុ ដែលបង្ហាញតាមរយៈរបាយការណ៍ជាភាសាចិនមួយចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៩ ដែលកិច្ចស៊ើបសួរពុំបានលាតត្រដាងអំពីបញ្ហានេះទេ បើទោះបីជារបាយការណ៍នេះត្រូវបានចេញជាសាធារណៈក៏ដោយ[2772]។

១០៣៩.នួន ជា បានរំលឹកថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនកោះហៅសាក្សី ហេង សំរិន ដែលយោងតាម នួន ជា គឺជាសាក្សីសំខាន់ដើម្បីបំភ្លឺលើអន្តរកម្មរវាង“ថ្នាក់ដឹកនាំបក្ស”ជាមួយនឹងកម្មាភិបាលខ្មែរក្រហមដែលមានអំណាចដទៃទៀត និងថា តំណែងរបស់គាត់“ស្ថិតនៅចន្លោះរវាង“មជ្ឈិមបក្ស” និងចារីផ្ទាល់

---

[2766] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៣១។

[2767] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៣២ ដល់ ២៣៦។

[2768] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៣៧។

[2769] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៣៨។

[2770] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៣៩។

[2771] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤០។

[2772] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤១។

នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១”[2773]។ នួន ជា ក៏បានរំលឹកអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនកោះហៅសាក្សីដទៃទៀត ដែលអាចផ្តល់សក្ខីកម្មអំពីការបែកបាក់ក្នុង ប.ក.ក.[2774] ដែលគាត់បានលើកឡើងក្នុងបរិបទនៃ“កិច្ចខិតខំប្រឹងប្រែងយូរលង់មកហើយរបស់វៀតណាមក្នុងការព្យាយាមយកទឹកដីខ្មែរ” និងចេតនាដើម្បី“គ្រប់គ្រងពេញលេញទៅលើលទ្ធិកុម្មុយនីស្តនៅឥណ្ឌូចិន”[2775]។ នួន ជា បានអះអាងថា ក្រៅតែពីលក្ខន្តិកៈរបស់ ប.ក.ក. ពុំមានភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលគាំទ្រការយល់ឃើញរបស់ខ្លួនដែលថា មេដឹកនាំភូមិភាគពុំមានតួនាទីផ្សេងក្រៅពីអនុវត្ត សេចក្តីសម្រេចរបស់មជ្ឈិមបក្សដោយស្មោះត្រង់[2776]។ តាមទស្សនៈរបស់គាត់ លក្ខន្តិកៈរបស់ ប.ក.ក. ជាការពុំសមស្របក្នុងការបង្ហាញអំពីទំនាក់ទំនងអំណាចជាក់ស្តែងក្នុង ប.ក.ក.[2777]ឡើយ។ គាត់បានលើកឡើងជាទូទៅថា អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលស្គាល់ភស្តុតាងដែលបានបង្ហាញថា កម្មាភិបាល ប.ក.ក. មានស្វ័យភាពក្នុងកម្រិតខ្ពស់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០២/០១ និងថា លក្ខខណ្ឌក្នុងចំណោមភូមិភាគមានការប្រែប្រួលខុសគ្នាគួរឲ្យកត់សម្គាល់[2778]។

១០៣៦.នួន ជា បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធទៅនឹងការយល់ឃើញអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាច្រើនយ៉ាងរបស់គាត់ និងបានយោងទៅលើផ្នែកនានានៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានពិភាក្សាអំពីការទទួលខុសត្រូវរបស់គាត់ចំពោះការរៀបចំផែនការ និងការបញ្ជា ព្រមទាំងការទទួលខុសត្រូវរបស់ថ្នាក់លើ[2779]។ លើសពីនេះទៀត ក្នុងសំណើទីប្រាំមួយសុំដាក់ភស្តុតាង

---

[2773] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤២។

[2774] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤២។

[2775] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤៣។

[2776] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤៤។

[2777] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤៤ ដល់ ២៤៥។

[2778] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៤៦ ដល់ ២៤៩។

[2779] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២៦។ នួន ជា បានអះអាងផងដែរថា ការយល់ឃើញនេះជាប់ពាក់ព័ន្ធទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះការញុះញង់ និងការជួយនិងជំរុញឧក្រិដ្ឋកម្ម។ ទោះជាយ៉ាងណាក្តី នួន ជា ពុំបានចង្អុលបង្ហាញទៅលើផ្នែកណាមួយនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការយល់ឃើញនេះត្រូវបានយកមកសំអាងទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវទាំងនោះ ហើយការយល់ឃើញទាំងនេះពុំមានអត្ថិភាពផងដែរ។

01358573



បន្ថែម (F2/8) នួន ជា បានលើកឡើងថា "ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចសន្និដ្ឋានបានថា ប៉ុល ពត និង នួន ជា បានរួមចំណែកក្នុងគោលបំណងរួម និងទំនងជាឃុបឃិតនៅក្នុងសហឧក្រិដ្ឋកម្មរួម *ជាមួយបណ្តាមេដឹកនាំទាំងអស់ដែលមានបំណងបង្កការបះបោរ និង/ឬ អំពើក្បត់ប្រឆាំងនឹងពួកគាត់* ឬថា នួន ជា បានធ្វើការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើកងកម្លាំងរបស់មេដឹកនាំស៊ីវិល និងយោធា"[2780]។ នួន ជា ក៏បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីរចនាសម្ព័ន្ធរបស់ ប.ក.ក. បាននាំដល់ការសម្រេចបដិសេធការរៀបរាប់របស់គាត់ទាក់ទងទៅនឹងតួនាទីរបស់មេដឹកនាំភូមិភាគ[2781]។

១០៣៧.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គហេតុមួយចំនួនទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលកំហុសនេះបណ្តាលឱ្យមានភាពមិនយុត្តិធម៌[2782]។ ជាបឋម គាត់បានលើកថា អង្គជំនុំជម្រះបានប្រើប្រាស់ខ្លឹមសារ និងពាក្យពេចន៍មិនច្បាស់លាស់ នៅពេលពិពណ៌នារបៀបនៃការចេញបទបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុង បើទោះជាអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា កងកម្លាំងប្រដាប់អាវុធពុំស្ថិតក្រោមបញ្ជារបស់មជ្ឈិមបក្សក៏ដោយ ប៉ុន្តែក្រោមបញ្ជារបស់ភូមិភាគ និងបានតវ៉ាផងដែរថា ការផ្តល់សំអាងហេតុលើចំណុចនេះ មានភាពពុំគ្រប់គ្រាន់[2783]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា កងកម្លាំងដែលបានចូលរួមក្នុងការកាន់កាប់ទីក្រុងភ្នំពេញ គឺជាកងទ័ពបដិវត្តន៍កម្ពុជា ដែលតាមពិតទើបតែបានបង្កើតឡើងប៉ុន្មានខែក្រោយពេលរំដោះប៉ុណ្ណោះ និងបានអះអាងថា នេះគឺជា"ការបង្ហាញឱ្យឃើញល្អតែសំបកក្រៅ"[2784]។ ជាចុងក្រោយ គាត់បានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការរៀបចំ ការបញ្ជា និងការអនុវត្តការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បានផ្អែកជាចម្បងលើភស្តុតាងរបស់សាក្សីមួយចំនួនមកពីកងកម្លាំងប្រដាប់អាវុធនៃភូមិភាគនិរតី និងភូមិភាគឧត្តរ ខណៈដែលភស្តុតាងចេញមកពីភូមិភាគបូព៌ា និងភូមិភាគពិសេសមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលទោះបីជាយ៉ាងណាក្តី កង

[2780] សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ១៣។

[2781] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២៦។

[2782] សារណាបណ្តឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៣៤៣។

[2783] សារណាបណ្តឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៣៤៥។

[2784] សារណាបណ្តឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៣៤៦។

កម្លាំងទាំងនោះមានការជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងផងដែរ[2785]។ គាត់បានអះអាងថា ចំណុចនេះបានបណ្ដាលឲ្យអង្គជំនុំជម្រះចាត់ទុកកងកម្លាំងប្រដាប់អាវុធទាំងនេះថា ជាកងកម្លាំងតែមួយ និងធ្វើឱ្យអង្គជំនុំជម្រះភ្ជាប់ទំនាក់ទំនងរវាងចារីនៃឧក្រិដ្ឋកម្មក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ជាមួយនឹងសមាជិកនៃសហឧក្រិដ្ឋកម្មរួម[2786]។

១០៣៨.សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងអំណះអំណាងរបស់ នួន ជា និងបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ហើយ[2787]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងតួនាទីរបស់មេដឹកនាំភូមិភាគ មានហេតុផលសមស្រប និងជាពិសេសថា ប្រធានភូមិភាគពុំអាចធ្វើសកម្មភាពដោយស្វ័យតបាននោះទេ[2788]។ សហព្រះរាជអាជ្ញាក៏បានអះអាងផងដែរថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសេចក្ដីណែនាំរបស់មជ្ឈិមបក្ស មានលក្ខណៈសមហេតុផល និងថា នួន ជា បានបំភ្លៃភស្តុតាង[2789]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងអំណះអំណាងរបស់ នួន ជា ដែលថា មាន"ជម្លោះជាចំហ"រវាងក្រុមតូចៗនៅក្នុង ប.ក.ក. និងបានកត់សម្គាល់ថា ពុំមានភស្តុតាងគាំទ្រការលើកឡើងនេះឡើយ និងបានអះអាងថា គ្មានអ្វីផ្ទុយទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ថ្នាក់ក្រោមមានអំណាចតិចតួចក្នុងការធ្វើសេចក្ដីសម្រេចនោះ[2790]។ សហព្រះរាជអាជ្ញាក៏បានជំទាស់ផងដែរទៅនឹងអំណះអំណាងរបស់ ខៀវ សំ ផន។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញថា ការប្រើប្រាស់ពាក្យពេចន៍ និងខ្លឹមសារមិនច្បាស់លាស់នោះ គឺជាកំហុស និងបានគូសបញ្ជាក់ថា តាមការអានលម្អិតនូវសាលក្រមរបស់អង្គជំនុំជម្រះបានបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងយល់ច្បាស់លាស់អំពីរចនាសម្ព័ន្ធយោធានៃកងកម្លាំងប្រដាប់អាវុធ បើទោះជា អង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើកងទ័ពបដិវត្តន៍កម្ពុជាក៏ដោយ[2791]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងភាពស៊ីសង្វាក់នៃការ

[2785] សារណាបណ្ដឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៣៤៧ ដល់ ៣៤៨។

[2786] សារណាបណ្ដឹងសាទុក្ខ ខៀវ សំផន កថាខណ្ឌ ៣៥០។

[2787] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩២ ដល់ ៣០០។

[2788] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩៣ ដល់ ២៩៥។

[2789] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩៦ ដល់ ២៩៩។

[2790] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០០ ដល់ ៣០១។

[2791] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១១។

ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មិនត្រឹមបានផ្អែកតែលើភស្តុតាងរបស់កងទ័ពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្អែកលើភស្តុតាងជាច្រើនដែលភាគច្រើនបានមកពីជនរងគ្រោះ[2792]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ខៀវ សំផន ពុំបានបង្ហាញព្យសនកម្មណាមួយដែលកើតចេញពី កំហុសនោះឡើយ[2793]។

១០៣៩.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែល បានជំទាស់ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធឋានានុក្រមនៃ ប.ក.ក. គឺពាក់ព័ន្ធជាចម្បងទៅនឹងការសម្រេចផ្តន្ទាទោស នួន ជា ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវចំពោះការរៀបចំផែនការ ការបញ្ជា និងការទទួលខុសត្រូវរបស់ថ្នាក់លើ[2794]។ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើមូលដ្ឋាននេះឡើយ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា "ទទួលខុសត្រូវដោយផ្ទាល់"ចំពោះឧក្រិដ្ឋកម្មនោះក៏ដោយ[2795]។ ហេតុដូច្នេះ ការភ័ន្តច្រឡំណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងជាសក្តានុពល ពុំអាចបណ្តាលឲ្យមានភាពមិនយុត្តិធម៌ពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវនេះឡើយ។ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវចំពោះការបញ្ជា និងការរៀបចំផែនការឧក្រិដ្ឋកម្មដូចដែលបានលើកឡើងក្នុងសាលដីកានេះ និងដោយសារមានការយល់ឃើញពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើងទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ បានផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម ដូច្នេះការសម្រេចដាក់ពិរុទ្ធភាពនេះយកជាបានការ បើទោះបីជាមានការកែតម្រូវលើការយល់ឃើញផ្នែកអង្គហេតុ និងអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវចំពោះការបញ្ជា ការរៀបចំផែនការក៏ដោយ[2796]។ យោងតាមសំអាងហេតុនេះ ពុំមានភាពចាំបាច់ក្នុងការពិចារណាលើអំណះអំណាងរបស់ នួន ជា ចោទប្រកាន់អំពីកំហុសទាក់ទងទៅនឹងបញ្ហានេះឡើយ។

---

[2792] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១១។

[2793] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១១។

[2794] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២៦ ជើងទំព័រ ៦១៥, ៦១៦, ៦១៧ និង ៦១៩ ដែលយោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៨៥, ៩២៤ (ទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះការបញ្ជា) ៩០៤, ២៩៤ (ទាក់ទងទៅនឹងការរៀបចំផែនការ), ៨៩២ និង ៨៩៣ (ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ)។

[2795] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤១។

[2796] *សូមមើលខាងក្រោម* កថាខណ្ឌ ១០៩៩។

១០៤០.ទាក់ទងទៅនឹងការលើកឡើងរបស់ នួន ជា ដែលថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង បាននាំឱ្យអង្គជំនុំជម្រះនេះបដិសេធការរៀបរាប់របស់គាត់អំពីសិទ្ធិអំណាចរបស់មេដឹកនាំភូមិភាគនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងនេះជាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់គាត់ស្ថិតក្រោមសហឧក្រិដ្ឋកម្មរួម។ ទាក់ទងទៅនឹងបញ្ហានេះ ជាបឋម អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ក្នុងករណីដែលឧក្រិដ្ឋកម្មនោះពុំត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃសហឧក្រិដ្ឋកម្មរួមណាម្នាក់ ប៉ុន្តែដោយបុគ្គលដទៃទៀត សមាជិកទាំងអស់នៃសហឧក្រិដ្ឋកម្មរួមក៏ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងនេះផងដែរ បើសិនជាសមាជិកណាម្នាក់ក្នុងចំណោមសមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវបានដាក់ឱ្យទទួលខុសត្រូវនោះ ដោយសារសមាជិកនេះបានធ្វើសកម្មភាពស្របតាមគោលបំណងរួម ហើយឧក្រិដ្ឋកម្មនេះគឺជាផ្នែកនៃគោលបំណងរួម[2797]។ នួន ជា ពុំបានពន្យល់ថាតើកំហុសដែលជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិអំណាចរបស់ថ្នាក់ដឹកនាំភូមិភាគ បានប៉ះពាល់ការទទួលខុសត្រូវរបស់គាត់ក្រោមសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការជម្លៀសដំណាក់កាលទីមួយ និងទីពីរនោះឡើយ និងថាតើផលប៉ះពាល់នោះបានកើតមានពិតប្រាកដដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលរំលឹកទាក់ទងទៅនឹងបញ្ហានេះថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា មានបុគ្គលជាច្រើនដែលបានព្រមព្រៀងលើគោលបំណងរួម ពោលគឺការកសាងបដិវត្តសង្គមនិយមដ៏ឆាប់រហ័សដែលជា ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ[2798]។ យោងតាមអង្គជំនុំជម្រះសាលាដំបូង សមាជិកនៃសហឧក្រិដ្ឋកម្មរួមនេះបានរួមបញ្ចូល នួន ជា និង ខៀវ សំផន ព្រមទាំងបុគ្គលដទៃទៀតផងដែរ ជាពិសេសមេដឹកនាំភូមិភាគ មានដូចជា រស់ ញឹម (ញឹម រស់) និង សោ ភឹម[2799]។ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មជាក់ស្តែងដែលបានប្រព្រឹត្តក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា កងទ័ពក្រោមបញ្ជារបស់ភូមិភាគនានា បានចូលរួមក្នុងការចាប់ខ្លួន និងក្រោយមកក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[2800]។ ដូចបានលើកឡើងខាងលើ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនស្ថិតក្នុងគោលបំណងរួមទាំងស្រុង[2801]។ ដូចគ្នានេះដែរ អង្គ

---

[2797] *សូមមើលខាងលើ* កថាខណ្ឌ ៧៦៨ *ជាអាទិ៍*។

[2798] ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ នួន ជា ទាក់ទងទៅនឹងបញ្ហាដែលត្រូវបានដោះស្រាយ។ *សូមមើលខាងលើ* កថាខណ្ឌ ៨១១ *ជាអាទិ៍*។

[2799] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧៧។

[2800] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២៤០, ៤៦០។

[2801] *សូមមើលខាងលើ* កថាខណ្ឌ ៨៤៥ *ជាអាទិ៍*។

ជំនុំជម្រះសាលាដំបូងក៏បានរកឃើញអំពីអត្ថិភាពនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលជម្លៀសប្រជាជនដំណាក់កាលទីពីរផងដែរ[2802]។ ចំពោះឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅពុំត្រូវបានបង្ហាញឱ្យឃើញដោយសមហេតុផលនោះឡើយ។ ហេតុដូច្នេះ បញ្ហាដែលថាតើឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃត្រូវបានប្រព្រឹត្តឡើងតាមគោលបំណងរួម ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំចាំបាច់ពិចារណាទៀតទេ។

១០៤១.ទោះបីជាមានការសន្មតថា មេដឹកនាំភូមិភាគមួយចំនួនដែលជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម បានប្រឆាំង ប៉ុល ពត និង នួន ជា ឬក៏បានចូលរួមជាសម្ងាត់ក្នុងផែនការក្បត់ដើម្បីផ្តួលរំលំពួកគាត់ក៏ដោយ ក៏ពុំមែនមានន័យថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទីពីរដែលមេដឹកនាំភូមិភាគត្រូវដាក់ឱ្យទទួលខុសត្រូវនោះ ពុំអាចដាក់បន្ទុកទៅលើសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមនោះឡើយ។ ការយល់ឃើញ*ក្នុងចំណោមនោះ* ដែលថា មេដឹកនាំភូមិភាគបានរួមចំណែកក្នុងគោលបំណងរួមជាមួយ នួន ជា ទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងនោះ ពុំបានផ្អែកលើការសន្មតដែលថា មេដឹកនាំភូមិភាគបានព្រមព្រៀងទាំងស្រុង និងបានគាំទ្រថ្នាក់ដឹកនាំ ប.ក.ក. ដែលរួមមាន នួន ជា នោះឡើយ។ ផ្ទុយទៅវិញ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហា ថាតើនរណាខ្លះបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនោះ គឺបានផ្អែកទៅលើការវាយតម្លៃរបស់ខ្លួនដែលថា តើនរណាខ្លះដែលបានជាប់ពាក់ព័ន្ធទៅនឹងការបង្កើត និងការធ្វើសេចក្តីសម្រេចនៅក្នុង ប.ក.ក. នៅគ្រប់ដំណាក់កាលនៃបដិវត្តន៍[2803]។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា រស់ ញឹម(ញឹម រស់) និង សោ ភឹម (ជាមេដឹកនាំភូមិភាគពីររូប ដែលតាមការលើកឡើងរបស់ នួន ជា ថា បានប្រឆាំងនឹង ប៉ុល ពត និង នួន ជា[2804]) បានចូលរួមក្នុងកិច្ចប្រជុំមួយនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដែលក្នុងពេលនោះសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើង[2805]។ ស្រដៀងគ្នានេះដែរ ភស្តុតាងដែលសំអាងដោយអង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងកិច្ចប្រជុំមួយក្នុងដើមខែ មេសា ឆ្នាំ ១៩៧៥ ដែលក្នុងនោះសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបាន

---

[2802] *សូមមើលខាងលើ* កថាខណ្ឌ ៨៦៣ *ជាអាទិ៍*។

[2803] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧២៤ ដល់ ៧៧៦។

[2804] *សូមមើល* ជាឧទាហរណ៍ សំណើទីប្រាំមួយរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម (F2/8) កថាខណ្ឌ ១១។

[2805] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៣៣។

01358578



ចាត់ទុកជាបានការនោះ បានបង្ហាញថា សោ ភឹម ក៏បានចូលរួមកិច្ចប្រជុំនោះដែរ(ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងពុំបានលើកឡើងជាក់លាក់អំពីចំណុចនេះឡើយ)[2806]។ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ កម្មាភិបាល និងលេខាភូមិភាគបានរាយការណ៍ទៅ ប៉ុល ពត នួន ជា វន វ៉េត សុន សេន ខៀន និង/ឬ មន្ទីរ ៨៧០ អំពីការផ្លាស់ទីលំនៅប្រជាជន ហើយពេលខ្លះក៏បានស្នើសុំការណែនាំបន្ថែមទៀតផង"នេះបើយោងលើ*ក្នុងចំណោមនោះ*របាយការណ៍ដែលបានផ្ញើដោយ សោ ភឹម[2807]។

១០៤២.គួរកត់សម្គាល់ផងដែរថា ការកើតមានជម្លោះក្នុងចំណោមមេដឹកនាំក្នុងអង្គការចាត់តាំងធំមួយគឺជារឿងធម្មតា។ ហេតុនេះ ជម្លោះទាំងនេះពុំប៉ះពាល់ទៅលើបញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌស្ថិតក្រោមសហឧក្រិដ្ឋកម្មរួមនោះឡើយ ដរាបណាធាតុផ្សំទាំងអស់សម្រាប់ទម្រង់នៃការទទួលខុសត្រូវនេះត្រូវបានបង្ហាញឱ្យឃើញ។ ស្រដៀងគ្នានេះដែរ នួន ជា ពុំបានពន្យល់ ថាតើស្វ័យភាពដ៏ធំធេងរបស់មេដឹកនាំភូមិភាគ បានប៉ះពាល់ដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ស្ថិតក្រោមសហឧក្រិដ្ឋកម្មរួមនោះ យ៉ាងដូចម្ដេចឡើយ។ ដូចបានកត់សម្គាល់ខាងលើ យោងតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង មេដឹកនាំភូមិភាគ គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ ផ្អែកតាមគោលការណ៍នៃសញ្ញាណសហឧក្រិដ្ឋកម្មរួម ក្នុងចំណោមសមាជិកនានាដែលបានចូលរួមចំណែកក្នុងការអនុវត្តគោលបំណងរួម បើទោះបីជា មានសមាជិកខ្លះមានស្វ័យភាពក្នុងកម្រិតមួយទាក់ទងទៅនឹងការអនុវត្តនូវទិដ្ឋភាពនានានៃគោលបំណងរួមនោះក៏ដោយ ក៏ពុំធ្វើឱ្យសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះបានដែរ។

១០៤៣.អង្គជំនុំជម្រះតុលាការកំពូលពុំមានភាពចាំបាច់ក្នុងការដោះស្រាយលើខ្លឹមសារនៃអំណះអំណាងរបស់ នួន ជា ឡើយ ដោយហេតុថា ពុំមានការផ្ដល់មូលដ្ឋានគាំទ្រគ្រប់គ្រាន់ទាក់ទងទៅនឹងបញ្ហា ថាតើកំហុសផ្នែក

---

[2806] *សូមមើល* ឧទាហរណ៍ ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ែចាម តុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 (ភាសាខ្មែរ) ទំព័រ ១២ ("ដូចតាមការខ្ញុំចាំ គឺថា ដើមខែ ០៤ នៅឆ្នាំ ៧៥ អ៊ំៗគាត់បានប្រជុំពិគ្រោះពិភាក្សាពីរឿងជម្លៀសប្រជាជនដែរ។ មានៗ អ៊ំ ប៉ុល ពត គាត់លើកឡើង ហើយអង្គប្រជុំនោះ កាលហ្នឹង អ៊ំ នួន ជា ក៏នៅហ្នឹង អ៊ំ ខៀវ សំផន ក៏នៅហ្នឹង សុន សេន កុយ ធួន វន វ៉េត ចេង អន អីហ្នឹង ហើយនិង តាភឹម អីហ្នឹង សោ ភឹម អីហ្នឹង នៅហ្នឹងទាំងអស់")។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងយ៉ាងខ្លាំងទៅលើសក្ខីកម្មរបស់សាក្សីនេះ *សូមមើល*សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ជើងទំព័រ ៤១៦ ដល់ ៤២៥។

[2807] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៩៨ និង ជើងទំព័រ ២៥៤២។

អង្គហេតុដែលបានអះអាង បានបណ្តាលឲ្យមានភាពមិនយុត្តិធម៌យ៉ាងដូចម្តេចនោះ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះត្រូវបដិសេធចោល។

១០៨៤.ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងរបស់ ខៀវ សំផន ពុំមានលក្ខណៈសមស្របក្នុងការបង្ហាញនូវកំហុសដែលអាចប្តឹងសាទុក្ខបាននោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ពីខាងលើរួចមកហើយថា ការដែលថា កងទ័ពដែលបានចូលរួមការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺស្ថិតក្រោមបញ្ជារបស់ភូមិភាគ និងពុំមែនស្ថិតក្រោមមជ្ឈិមបក្សនោះ គឺពុំប៉ះពាល់ដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទស្ថិតក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួមឡើយ ជាការស្របគ្នាទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មេដឹកនាំភូមិភាគ គឺជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម និងថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងស្របតាមគោលបំណងរួម។ ផ្អែកតាមហេតុផលនេះ ជាការពុំជាប់ពាក់ព័ន្ធឡើយទៅនឹងបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងបានស្តាប់ជាចម្បង តែភស្តុតាងដែលទាក់ទងទៅនឹងកងកម្លាំងនៃភូមិភាគមួយចំនួន ដែរ ឬយ៉ាងណានោះទេ។ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ពាក្យពេចន៍ និងខ្លឹមសារ បើទោះបីជា ជាការពិត អង្គជំនុំជម្រះសាលាដំបូងពេលខ្លះ បានសំដៅលើកងទ័ពបដិវត្តន៍កម្ពុជាក្នុងបរិបទនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា កងទ័ពបដិវត្តន៍កម្ពុជា ទើបតែត្រូវបានបង្កើតឡើង ក្រោយពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងខែកក្កដា ឆ្នាំ ១៩៧៥[2808]ក៏ដោយ ក៏កំហុសនេះពុំមានផលប៉ះពាល់ណាមួយទៅលើសុពលភាពនៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ដូចការលើកឡើងរបស់ ខៀវ សំផន[2809] អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលស្គាល់ជាក់លាក់ផងដែរថា កងកម្លាំងដែលបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺស្ថិតក្រោមបញ្ជាផ្ទាល់របស់ភូមិភាគ មិនមែនមជ្ឈិមបក្សឡើយ[2810]។ ចំណុចនេះក៏បង្ហាញផងដែរថា អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកកងកម្លាំងទាំងនេះថា ជាកងកម្លាំងឯកភាពតែមួយ និងគោរពតាមរចនាសម្ព័ន្ធបញ្ជារាងជាសាជីនោះ[2811] គឺជាការបកស្រាយខុសអំពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតាមពិតការយល់ឃើញទាក់ទងទៅនឹងបញ្ហានេះមានខ្លឹមសារច្រើន

[2808] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៨ ដល់ ១៤៩ និង ២៤០។

[2809] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៤៥។

[2810] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២៤០។

[2811] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៤៥។

លើសពីអ្វីដែល ខៀវ សំផន បានលើកឡើង។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

### ៤.ង.១.ដ.តួនាទីរបស់គណៈកម្មាធិការមជ្ឈិម

១០៤៥.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គណៈកម្មាធិការមជ្ឈិម មានអំណាចធ្វើសេចក្តីសម្រេច និងមានមុខងារ“ដូចជា [...] វិភាគទៅលើការអនុវត្តគោលនយោបាយរបស់បក្ស កែតម្រូវការរំលោភបំពាន និងចេញសេចក្តីណែនាំនានា”[2812]។ ខៀវ សំផន បានអះអាងថា ការយល់ឃើញនេះមានភាពផ្ទុយគ្នាទៅនឹងការយល់ឃើញផ្សេងទៀតរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គណៈកម្មាធិការអចិន្ត្រៃយ៍គឺជាអ្នកមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយ[2813]។ គាត់បានអះអាងបន្ថែមទៀតថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម បានផ្អែកលើការបកស្រាយពុំត្រឹមត្រូវនៃភស្តុតាងនេះ ជាពិសេស ការលើកឡើងរបស់គាត់ដែលបានធ្វើឡើងនៅក្នុងសៀវភៅមួយ[2814] និងថា ការយល់ឃើញនេះបានផ្អែកជាមូលដ្ឋានលើការយល់ពុំត្រឹមត្រូវអំពីភស្តុតាងដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា សេចក្តីសម្រេចផ្សេងៗ ជាពិសេសសេចក្តីសម្រេចទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានធ្វើដោយគណៈកម្មាធិការមជ្ឈិម[2815]។ ខៀវ សំផន បានអះអាងថា ការយល់ឃើញនេះគឺជាការបំភ្លៃអំពីតួនាទីរបស់គណៈកម្មាធិការមជ្ឈិម ដែលជាហេតុធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌមកលើរូបគាត់ បើទោះបីជាគាត់ពុំដែលជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ក៏ដោយ[2816]។ ខៀវ សំផន បានលើកឡើងផង

---

[2812] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១២០ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៤៧ (កត់សម្គាល់ថា កថាខណ្ឌ ១២០ ជើងទំព័រ ២៤៨ បានយោងទៅលើកថាខណ្ឌ ៣៤ នៃសាលក្រមនេះ។ មានតែកថាខណ្ឌ ៨៤៧ ប៉ុណ្ណោះ ដែលមានការដកស្រង់ចំណុចនេះ)។

[2813] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១២១ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២០១៣ និង ២២៣។

[2814] *សូមមើល* សៀវភៅរបស់ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារលេខ E3/18 ឯកសារលេខ E3/18 ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៤ ERN (ភាសាខ្មែរ) 00103840-1 ទំព័រ ៦៥ ដល់ ៦៦។

[2815] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១២៣ ដល់ ១២៥។

[2816] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១២៥។

ដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការរកឃើញថា ឯកសារមួយចុះកាលបរិច្ឆេទថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ចេញពីគណៈកម្មាធិការមជ្ឈិម ដែលឯកសារនោះបានរៀបរាប់អំពីសេចក្ដីសម្រេចមួយចំនួនដែលត្រូវបានធ្វើឡើង និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយអំណះអំណាងរបស់មេធាវីការពារក្ដីទាក់ទងទៅនឹងតម្លៃជាភស្តុតាងដែលមានកម្រិតតិចតួច និងបញ្ហាទាក់ទងទៅនឹងដំណើរនៃការរក្សាទុកឯកសារនោះ[2817]។

១០៤៦.សហព្រះរាជអាជ្ញាពុំបានយល់ស្របជាមួយនឹងអំណះអំណាងរបស់ ខៀវ សំផន ឡើយ និងបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានភាពផ្ទុយគ្នាទេ ព្រមទាំងថា ភស្តុតាងបានបង្ហាញថា គណៈកម្មាធិការមជ្ឈិមបានចេញសេចក្ដីសម្រេច និងសេចក្ដីណែនាំលើបញ្ហាមួយចំនួន[2818] ។ សហព្រះរាជអាជ្ញាបានអះអាងថា ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើចម្លើយផ្ទាល់របស់ ខៀវ សំផន គឺជាការត្រឹមត្រូវ និងថា ភស្តុតាងដទៃទៀតដែល ខៀវ សំផន បានយកមកសំអាងនោះក៏បង្ហាញឱ្យឃើញថា គណៈកម្មាធិការមជ្ឈិមពិតជាមានសិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចប្រាកដមែន[2819]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ខៀវ សំផន "ពុំបានផ្អែកទាំងស្រុងទៅលើតែទំនាក់ទំនងរបស់គាត់ជាមួយនឹងគណៈកម្មាធិការមជ្ឈិមនោះឡើយ" ដែលចំណុចនេះបានធ្វើឱ្យអំណះអំណាងរបស់គាត់ទាក់ទងទៅនឹងឯកសារ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ លែងមានប្រសិទ្ធភាពផងដែរ[2820]។ តាមការលើកឡើងរបស់សហព្រះរាជអាជ្ញាថា អំណះអំណាងរបស់ ខៀវ សំផន មានភាពយឺតយ៉ាវ និងបានលើកឡើងលាយឡំគ្នារវាងភាពអាចទទួលយកបាននៃភស្តុតាង ជាមួយនឹងបទដ្ឋានស្ដីអំពី"ការបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យ"[2821]។

១០៤៧.អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ ខៀវ សំផន ឡើយ។ ជាដំបូង ប្រហែលជា ខៀវ សំផន បានបកស្រាយពុំត្រឹមត្រូវអំពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងតួនាទី និងសិទ្ធិអំណាចរបស់គណៈមជ្ឈិម។ ផ្ទុយទៅនឹងការលើកឡើងរបស់ ខៀវ សំផន ការយល់

---

[2817] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៩៧ ដល់ ៥០១។

[2818] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០២។

[2819] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០៣ ដល់ ៣០៤។

[2820] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០៥។

[2821] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០៥។

ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំមានលក្ខណៈផ្ទុយគ្នាឡើយ ប៉ុន្តែគ្រាន់តែបានបង្ហាញក្នុងរូបភាពខុសគ្នាតិចតួចអំពីមុខងាររបស់គណៈមជ្ឈិម ដោយបានទទួលស្គាល់ច្បាស់លាស់ថា សិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចចុងក្រោយ គឺស្ថិតនៅកន្លែងផ្សេង។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏មានសេចក្ដីសម្រេចមួយចំនួនពិតជាត្រូវបានធ្វើឡើងនៅថ្នាក់គណៈមជ្ឈិមដែរ ហើយ ខៀវ សំផន ពុំបានបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហានេះ ពុំសមហេតុផលនោះឡើយ។ ជាការកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើអត្ថបទដកស្រង់នៅក្នុងសៀវភៅរបស់ ខៀវ សំផន ដែលយោងតាមសៀវភៅនេះ គណៈមជ្ឈិមបានចេញ"សេចក្ដីបង្គាប់"មួយចំនួនស្ដីពីបញ្ហាផ្សេងៗ[2822]។ បើទោះបីជាជើងទំព័រទាក់ទងទៅនឹងសេចក្ដីដកស្រង់ខាងលើបានបង្ហាញថា គណៈមជ្ឈិមពុំមែនជា"អង្គការនីតិប្រតិបត្តិ" ប៉ុន្តែត្រឹមតែ"បានពិភាក្សាអំពីការអនុវត្តគោលនយោបាយដែលបង្កើតឡើងដោយការិយាល័យអចិន្ត្រៃយ៍" (ប្រហែលសំដៅលើគណៈអចិន្ត្រៃយ៍)ក៏ដោយ ក៏ចំណុចនេះស៊ីសង្វាក់គ្នាជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលតាមការកត់សម្គាល់ខាងលើ បានទទួលស្គាល់ជាក់លាក់ថា គណៈអចិន្ត្រៃយ៍ គឺជាអ្នកធ្វើសេចក្ដីសម្រេចចុងក្រោយ។ ទាក់ទងទៅនឹងឯកសារចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ខៀវ សំផន ពុំបានផ្ដល់មូលដ្ឋានគាំទ្រគ្រប់គ្រាន់ថាកំហុសផ្នែកអង្គហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានយោងលើឯកសារនេះ អាចបណ្ដាលឲ្យមានភាពមិនយុត្តិធម៌នោះឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

## ៤.ង.១.ឋ.គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ

១០៤៨.ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងប្រជាធិបតេយ្យប្រមូលផ្ដុំ ដែលជាគោលការណ៍គ្រឹះនៃដំណើរការធ្វើសេចក្ដីសម្រេចរបស់ ប.ក.ក.។ គាត់បានលើកឡើងថា តាមទ្រឹស្ដី គោលការណ៍"ប្រជាធិបតេយ្យប្រមូលផ្ដុំ"មានពីរផ្នែកគឺ ទីមួយកិច្ចពិភាក្សាតាមលទ្ធិប្រជាធិបតេយ្យអំពីបញ្ហានានាចេញពីឋានានុក្រមថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់កំពូល និងទីពីរ សេចក្ដីសម្រេចនៅថ្នាក់កំពូលអំពីបញ្ហានេះ ដែលត្រូវបញ្ជូនទៅថ្នាក់ក្រោមរបស់អង្គការវិញ[2823]។ តាមការលើកឡើងរបស់ ខៀវ សំផន ថា ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញឱ្យឃើញតែផ្នែកទីពីរនៃ

---

[2822] សៀវភៅរបស់ ខៀវ សំផនៈ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារលេខ E3/18 ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៤ ERN (ភាសាខ្មែរ) 00103840 ទំព័រ ៦៥។

[2823] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១២៨។

ដំណើរការធ្វើសេចក្តីសម្រេចនេះប៉ុណ្ណោះ[2824]។ ខៀវ សំផន បានជំទាស់ទៅនឹងភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងលើកមកសំអាង ក្នុងការបង្ហាញឱ្យឃើញផ្នែកទីមួយនៃដំណើរការធ្វើសេចក្តីសម្រេច ដែលមានដូចជា ចម្លើយរបស់ នួន ជា ពាក់ព័ន្ធទៅនឹងការប្រើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ និងចំណុចដែលថា ប៉ុល ពត ពុំមែនជាអ្នកមានសិទ្ធិអំណាចដាច់ខាត ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សក្ខីកម្មរបស់ David CHANDLER នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង កំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានបដិសេធដោយពុំត្រឹមត្រូវ ឬពុំបានពិចារណាលើភស្តុតាងដែលបង្ហាញថា ទិដ្ឋភាពនៃ“លទ្ធិប្រជាធិបតេយ្យ” ពុំមានអត្ថិភាពឡើយនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ ប.ក.ក.[2825]។ ខៀវ សំផន បានអះអាងថា មានការសន្និដ្ឋានដ៏ សមហេតុផលមួយផ្សេងទៀត ដែលអង្គជំនុំជម្រះសាលាដំបូងគួរធ្វើឡើង ដូចជាថា អង្គការចាត់តាំងរបស់ ប.ក.ក. មានលក្ខណៈតឹងរឹង និងមានឋានានុក្រមរឹតត្បិត ដូច្នេះជាការពុំត្រឹមត្រូវទេដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការធ្វើសេចក្តីសម្រេចត្រូវបានធ្វើឡើងជាសមូហភាព និងបានផ្អែកលើការឯកភាពទូលំទូលាយនោះ[2826]។ ខៀវ សំផន បានអះអាងថា ការយល់ឃើញដែលមានកំហុសរបស់អង្គជំនុំជម្រះសាលាដំបូង បានផ្អែកលើការសន្និដ្ឋានថា រូបគាត់បានចូលរួម និងបានគាំទ្រសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលបានធ្វើឡើងក្នុងកិច្ចប្រជុំក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ និងខែ មេសា ឆ្នាំ ១៩៧៥ និងថា គាត់អាចធ្វើបទអន្តរាគមន៍ជំទាស់លើសេចក្តីសម្រេចនេះក្នុងកិច្ចប្រជុំនៅខែ មិថុនា ឆ្នាំ ១៩៧៤ ព្រមទាំងថាគាត់មានតំណែងពិតប្រាកដក្នុងរដ្ឋអំណាចនៅពេលចូលរួមក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នោះ[2827] ។

១០៤៩.សហព្រះរាជអាជ្ញាបានអះអាងថា អំណះអំណាងរបស់ ខៀវ សំផន បានផ្អែកលើការយល់ពុំ ត្រឹមត្រូវអំពីគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ដោយហេតុថា ក្រៅពីលក្ខខណ្ឌតម្រូវឱ្យមានការបោះឆ្នោតជ្រើសរើសសមាជិករបស់គណៈកម្មាធិការណាមួយដោយថ្នាក់ក្រោមបន្ទាប់នោះ គឺគោលការណ៍ប្រជាធិបតេយ្យ

---

[2824] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១២៩។

[2825] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៣០ ដល់ ១៣៦។

[2826] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៣៧។

[2827] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៣៨ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤២, ៧៣៥, ៩៩៧ និង ១០០៦។

ប្រមូលផ្តុំ បើយោងតាមអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា សេចក្តីសម្រេចត្រូវធ្វើឡើងជាសមូហភាព មិនមែនជាលក្ខណៈបុគ្គលឡើយ[2828]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា កំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ បានបញ្ជាក់បន្ថែមលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយពុំមែនបន្ថយតម្លៃនៃការយល់ឃើញនេះឡើយ ពីព្រោះកំណត់ហេតុនេះបានបង្ហាញថា គណៈអចិន្ត្រៃយ៍បានព្រមព្រៀងតាមសេចក្តីសម្រេចនានាដែល ប៉ុល ពត បានណែនាំ។

១០៥០.បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូល ពុំយល់ស្របជាមួយនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថា ខៀវ សំផន បានយល់ពុំត្រឹមត្រូវនូវអត្ថន័យនៃគោលការណ៍“ប្រជាធិបតេយ្យប្រមូលផ្តុំ” ដោយសារមានការបង្ហាញច្បាស់លាស់ថា គាត់បានជំទាស់ជាចម្បងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលការណ៍នេះជាប់ពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេចជាសមូហភាពក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង បានផ្អែកជាចម្បងលើចម្លើយចំនួន ២ របស់ នួន ជា ទាក់ទងទៅនឹងដំណើរការធ្វើសេចក្តីសម្រេចសមូហភាព ព្រមទាំងចម្លើយរបស់ ខៀវ សំផន និង អៀង សារី ដែលសុទ្ធតែជាបុគ្គលបានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍[2829]។ នៅក្នុងកាលៈទេសៈបែបនេះ ជាការសមហេតុផលដែលត្រឹមតែផ្តល់ទម្ងន់តិចតួចលើសក្ខីកម្មរបស់ Philip SHORT ដែលបានអះអាងថា ប៉ុល ពត គឺជាអ្នកធ្វើសេចក្តីសម្រេចជាក់ស្តែង ដោយសារសក្ខីកម្មរបស់គាត់ពុំមែនជាការរៀបរាប់អំពីហេតុការណ៍ផ្ទាល់នោះឡើយ។ យោងតាមកំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦[2830] អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា ការដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើឯកសារនេះពាក់ព័ន្ធទៅនឹងគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ជាកំហុសនោះឡើយ ដោយសារ តាមការគូសបញ្ជាក់របស់សហព្រះរាជអាជ្ញា ឯកសារនេះពិតជាបានបង្ហាញថា គណៈកម្មាធិការអចិន្ត្រៃយ៍ជាប់ពាក់ព័ន្ធទៅនឹងការធ្វើសេចក្តីសម្រេច និងពុំចោទជាបញ្ហាដល់ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដទៃទៀតឡើយ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះត្រូវដិសេធចោល។

---

[2828] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០៦ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២២៣។

[2829] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២២៨។

[2830] កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្ស ឯកសារលេខ E3/197 ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦។

## ៤.ង.១.ឌ.ច្បាប់ពាក់ព័ន្ធទៅនឹងចេតនាតម្រូវ

១០៥១.ដោយយោងទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសហឧក្រិដ្ឋកម្មរួម (100/6) និងសាលដីកា*រឿងក្ដី Kvočka* (ICTY) ទាក់ទងទៅនឹងធាតុផ្សំ*អត្តនោម័ត*ក្នុងការទទួលខុសត្រូវតាមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ជនជាប់ចោទប្រាកដជាមានចេតនាចូលរួមក្នុងគោលបំណងរួម និងថា ចេតនានេះប្រាកដជាបានរួមចំណែកជាមួយនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម"[2831]។ អង្គជំនុំជម្រះនេះក៏បានយល់ឃើញផងដែរថា "ត្រូវតែបង្ហាញឱ្យឃើញថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានរួមចំណែកក្នុងចេតនាតម្រូវរបស់ចារីផ្ទាល់ រួមមានចេតនាជាក់លាក់ដែលតម្រូវសម្រាប់បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ"[2832]។ នៅក្នុងផ្នែកនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលដោះស្រាយលើ*ធាតុផ្សំអត្តនោម័ត*របស់ ខៀវ សំផន អង្គជំនុំជម្រះនេះបានយល់ឃើញថា គាត់មានចេតនាតម្រូវសម្រាប់ការទទួលខុសត្រូវតាមទម្រង់នៃសហឧក្រិដ្ឋកម្មរួម *ក្នុងចំណោមនោះ* ដោយសារគាត់ទំនងជាបានដឹងពីភាវនីយភាពច្បាស់លាស់ថា ការអនុវត្តគោលនយោបាយនេះនឹងបណ្ដាលឱ្យមានឧក្រិដ្ឋកម្ម និងថា ជាក់ស្ដែងគោលនយោបាយនេះបានបណ្ដាលឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន និងនៅទួលពោធិ៍ជ្រៃ[2833]។

១០៥២.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាក់ទងទៅនឹង*ធាតុផ្សំអត្តនោម័ត*ដែលតម្រូវ ដោយបានយល់ឃើញថា ជនជាប់ចោទមានចេតនាចូលរួមក្នុងគោលបំណងរួម ដែលបានរួមចំណែកជាមួយនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម។ តាមការយោងទៅលើសាលដីកា*រឿងក្ដី Kvočka*[2834] គាត់បានអះអាងថា បញ្ហានេះត្រូវតែបង្ហាញថា ជនជាប់ចោទ និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមត្រូវមានចេតនាធ្វើឱ្យសម្រេចគោលបំណងរួម[2835]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបាន

---

[2831] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៥។

[2832] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៥។

[2833] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៥។

[2834] *សូមមើល* សាលដីកា*រឿងក្ដី Kvočka* (ICTY) កថាខណ្ឌ ៨២។

[2835] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧០។

បន្ទាបបទដ្ឋានដោយពុំត្រឹមត្រូវសម្រាប់*ធាតុផ្សំអត្តនោម័ត* ដែលតម្រូវ តាមរយៈការវាយតម្លៃលើបញ្ហា ថាតើគាត់បានដឹងពីភវនីយភាពច្បាស់លាស់នៃការប្រព្រឹត្តបទឧក្រិដ្ឋ ដែរ ឬយ៉ាងណា[2836]។

១០៥៣.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដើម្បីសម្រេចឱ្យជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មួយដែលផ្អែកលើការទទួលខុសត្រូវតាមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម *ធាតុផ្សំអត្តនោម័ត*របស់ជនជាប់ចោទត្រូវតែគ្របដណ្ដប់ទាំងធាតុផ្សំនានានៃបទឧក្រិដ្ឋនោះ និងធាតុផ្សំនានានៅក្នុងទម្រង់នៃការទទួលខុសត្រូវ។ អាស្រ័យហេតុនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ចេតនាត្រូវតែគ្របដណ្ដប់ទាំងគោលបំណងរួម និងបទឧក្រិដ្ឋដែលមានរួមបញ្ចូលនៅក្នុងគោលបំណងនេះ ជាការត្រឹមត្រូវ។ ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានលើកឡើងថា ជនជាប់ចោទប្រាកដជាមានចេតនាចូលរួមក្នុងគោលបំណងរួម ដែលខុសគ្នាពីការធ្វើឱ្យសម្រេចគោលបំណងរួម និងការប្រព្រឹត្តបទឧក្រិដ្ឋនោះ[2837] អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការលើកឡើងនេះមានកំហុសអង្គច្បាប់។ បើទោះបីជាការបង្ហាញរបស់អង្គជំនុំជម្រះសាលាដំបូង ខុសពីការបង្ហាញដែលបានប្រើប្រាស់ក្នុងសាលដីកា*រឿងក្ដី Kvočka* (ICTY) (ដែលទោះជាយ៉ាងណាក្ដី បានដកស្រង់ក្នុងជើងទំព័រ)ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នៅក្នុងកថាខណ្ឌដូចគ្នាថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមប្រាកដជាបានរួមចំណែកក្នុងចេតនារបស់ចារីផ្ទាល់ គឺជាចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់[2838]។ ជាការពិត នៅពេលពិចារណាលើ*ធាតុផ្សំអត្តនោម័ត* របស់ នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយជាក់លាក់លើបញ្ហា ថាតើជនជាប់ចោទមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល អំពើអនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញ[2839] ដែរ ឬយ៉ាងណា។

១០៥៤. ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានបន្ទាបបទដ្ឋានតម្រូវចំពោះ*ធាតុផ្សំអត្តនោម័ត* ដោយបានយោងទៅលើភវនីយភាព ច្បាស់លាស់មួយអំពីការ

---

[2836] សារណាបណ្ដឹងសាទុក្ខរបស់ខៀវ សំផន កថាខណ្ឌ ៧១ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៥៤។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨៧។

[2837] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៧០។

[2838] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩៤។

[2839] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧៦ (នួន ជា) និង ៩៩៥ (ខៀវ សំផន)។

កើតឡើងនៃបទឧក្រិដ្ឋ[2840]នោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភវនីយភាពដែលថា បទឧក្រិដ្ឋនឹងត្រូវបានប្រព្រឹត្តឡើងនោះ ពុំមែនជាបទដ្ឋានត្រឹមត្រូវចំពោះ*ធាតុផ្សំអត្តនោម័ត*ឡើយ។ ដូចបានកត់សម្គាល់ខាងលើ អ្វីដែលតម្រូវ គឺថា ជនជាប់ចោទ និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ត្រូវតែរួមចំណែកក្នុង "ចេតនាធ្វើឱ្យសម្រេចគោលបំណងរួម"[2841]។ ទោះជាយ៉ាងណាក្តី នេះគឺជាការលើកឡើងទូទៅដែលតម្រូវឱ្យមានការបកស្រាយលម្អិតបន្ថែមទៀត ទាក់ទងទៅនឹងបទឧក្រិដ្ឋដែលរងការចោទប្រកាន់ និងកាលៈទេសៈនៃរឿងក្តី។ ជាឧទាហរណ៍ ដូចបានពន្យល់ខាងលើ[2842] សម្រាប់បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធាតុផ្សំអត្តនោម័តតម្រូវ គឺចេតនាផ្ទាល់ ឬ*ចេតនាប្រយោល (dolus eventualis)*។ ដូច្នេះ ប្រសិនបើបទមនុស្សឃាតត្រូវបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ជនជាប់ចោទមានគោលដៅអនុវត្តគោលបំណងរួមនាំឱ្យជនរងគ្រោះស្លាប់ ឬបានដឹងថា ការស្លាប់មនុស្សប្រាកដជាកើតមានជាក់ច្បាស់ ដោយសារការអនុវត្តគោលបំណងរួមនោះ(ចេតនាផ្ទាល់) ឬថា ជនជាប់ចោទបានដឹងថា ការស្លាប់ជនរងគ្រោះ គឺជាផលវិបាកដែលអាចកើតមាន ដោយសារការអនុវត្តគោលបំណងរួមនោះ ប៉ុន្តែនៅតែបន្តអនុវត្តបើទោះបីជាយ៉ាងនេះក្តី ដោយទទួលយកលទ្ធភាពនៃការស្លាប់ដែលអាចកើតឡើង(ចេតនាប្រយោល)។ ផ្ទុយទៅវិញ ទាក់ទងទៅនឹងបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ជនជាប់ចោទមានចេតនាអនុវត្តគោលបំណងរួមដែលនាំឱ្យមានការប្រព្រឹត្តអំពើរើសអើងប្រឆាំងនឹងជនរងគ្រោះជាក្រុមដែលអាចកំណត់ច្បាស់លាស់ និងថា ជនជាប់ចោទបានប្រព្រឹត្តដោយមានចេតនារើសអើងជាក់លាក់។ ទាក់ទងទៅនឹងទិដ្ឋភាពនៃអង្គហេតុ ជាឧទាហរណ៍ នៅពេលរឿងក្តីពាក់ព័ន្ធទៅនឹងជនជាប់ចោទនៅក្នុងកម្រិតជាមេដឹកនាំ ការសម្រេចអំពីគោលបំណងរួមអាចមានអត្ថិភាពយូរមុននឹងមានការអនុវត្តគោលបំណងនេះ ហើយពុំអាចកំណត់បានច្បាស់លាស់ទាំងស្រុងថា បទឧក្រិដ្ឋអាចនឹងត្រូវប្រព្រឹត្តឡើងនៅក្នុងអនាគតនោះឡើយ[2843]។

១០៥៥.ហេតុដូច្នេះ អាស្រ័យទៅលើបទឧក្រិដ្ឋ និងអង្គហេតុនៃរឿង និងអាចជាការសមហេតុផលផងដែរក្នុងការពិចារណាលើបញ្ហា ថាតើជនជាប់ចោទបានដឹងអំពីភវនីយភាពច្បាស់លាស់ដែលថា បទឧក្រិដ្ឋនឹងត្រូវ

---

[2840] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៥។

[2841] សាលដីកា *រឿងក្តី Kvočka* (ICTY) កថាខណ្ឌ ៨២។

[2842] *សូមមើលខាងលើ* កថាខណ្ឌ ៥០៩ ដល់ ៥១០។

[2843] *សូមមើល* សាលដីកា *រឿងក្តី Lubanga* (ICC) កថាខណ្ឌ ៤៤៧។

ប្រព្រឹត្តឡើង ដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើបញ្ហានេះ *តាមធម្មតា* ពុំមែនជាកំហុសនោះឡើយ។ ប៉ុន្តែ ជាក់ស្តែងពុំមានភាពគ្រប់គ្រាន់ក្នុងការបង្ហាញអំពីធាតុផ្សំអត្តនោម័តក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដោយផ្អែកលើការទទួលខុសត្រូវតាមទម្រង់នៃសហឧក្រិដ្ឋកម្មរួម។ ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវធ្វើការពិចារណាបន្តទៀតលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងចេតនារបស់ជនជាប់ចោទ និងទឡ្ហីករណ៍ពាក់ព័ន្ធនៅក្នុងសារណាបណ្តឹងសាទុក្ខ ដោយផ្អែកលើការបកស្រាយខាងលើអំពីបទដ្ឋានជាធរមាន។

## ៤.ង.១.ឍ.ចេតនារបស់ នួន ជា

១០៥៦.ទាក់ទងទៅនឹងចេតនារបស់ នួន ជា ដែលជាប់ពាក់ព័ន្ធទៅនឹងការដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមនោះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកពីតួនាទីរបស់គាត់ក្នុងការតាក់តែងគោលនយោបាយរបស់ ប.ក.ក. សមាជិកភាពរបស់គាត់ក្នុងគណៈកម្មាធិការដែលបានធ្វើសេចក្តីសម្រេចលើការផ្លាស់ទីលំនៅប្រជាជន និងគាត់"ក៏ជាអ្នកគាំទ្រខ្លាំងក្លាឱ្យមាន"ការតស៊ូវណ្ណៈ" និងតួនាទីរបស់គាត់ក្នុងការបណ្តុះបណ្តាល និងសកម្មភាពឃោសនា ហើយផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "គាត់មានចេតនាជំរុញឱ្យអនុវត្តគោលបំណងរួម"[2844]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា នួន ជា បានរួមចំណែកក្នុងចេតនាតម្រូវជាមួយអ្នកចូលរួមដទៃទៀត នៅក្នុងសហឧក្រិដ្ឋកម្មរួមដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ[2845]។

១០៥៧.នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញពុំបានល្អិតល្អន់ពាក់ព័ន្ធទៅនឹងចេតនារបស់គាត់ចំពោះការទទួលខុសត្រូវតាមទម្រង់សហឧក្រិដ្ឋកម្មរួម[2846]។ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងប្រហែលជាពុំបានពិចារណាសមស្របលើបញ្ហានេះ ដែលតាមការលើកឡើងរបស់គាត់បានផ្ទុះបញ្ច្រាំងឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា នួន ជា មានចេតនាជាក់លាក់ចំពោះ"ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ បើទោះបីជាគាត់ពុំត្រូវបានចោទប្រកាន់ ឬពុំត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតពាក់ព័ន្ធទៅនឹងការ

---

[2844] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧៥។

[2845] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៧៦។

[2846] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦១៨។

ផ្លាស់ទីលំនៅទីពីរនេះក៏ដោយ[2847]។ នួន ជា បានលើកឡើងបន្ថែមទៀតថា ដោយសារពុំមានការយល់ឃើញដែលមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងចេតនារបស់គាត់ "មេធាវីការពារក្តីត្រឹមតែអាចបង្ហាញ*សាជាថ្មី* ថា នួន ជា ពុំមានចេតនាតម្រូវទាក់ទងទៅនឹងឧក្រិដ្ឋកម្មណាមួយដែលបានចោទប្រកាន់នោះឡើយ" [2848]។

១០៥៨.ទាក់ទងទៅនឹងចេតនាក្នុងការប្រព្រឹត្តបទមនុស្សឃាតពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ នួន ជា បានអះអាងថា មានភស្តុតាងអន្លើៗប៉ុណ្ណោះដែលបង្ហាញពីការសម្លាប់ជនស៊ីវិលក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងថា អង្គជំនុំជម្រះសាលាដំបូងពុំបានកោះហៅសាក្សី ហេង សំរិន ដែលតាមការអះអាងរបស់ នួន ជា អាចផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងការចេញបទបញ្ជាទាំងនោះ[2849]។ នួន ជា បានអះអាងបន្ថែមទៀតថា ពុំមានភស្តុតាងបង្ហាញថា គាត់មានចេតនាបង្កឱ្យមានការស្លាប់ ឬបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយលើជនស៊ីវិល និងថា បើទោះបីជាគាត់អាច ឬបានយល់ដឹងជាមុនថា លក្ខខណ្ឌនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញអាចនឹងបង្កឱ្យមានការស្លាប់(ដែលគាត់បានជំទាស់)ក៏ដោយ នេះជាការពុំគ្រប់គ្រាន់ក្នុងការបង្ហាញពីចេតនាតម្រូវនោះឡើយ[2850]។ នួន ជា ក៏បានលើកឡើងផងដែរថា ដូចអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ពីគោលបំណងរបស់គាត់ គឺដើម្បីបង្កើនចំនួនប្រជាជន ដែលផ្ទុយទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់មានចេតនាបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយលើជនស៊ីវិល[2851]។ នួន ជា បានរំលឹកថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនោះ និងបានជំទាស់ថា ដោយសារតែពុំមានភាពច្បាស់លាស់ ថាតើអង្គជំនុំជម្រះសាលាដំបូងបានសំអាងលើការយល់ឃើញទាំងនេះ ក្នុងការបង្ហាញពីចេតនារបស់គាត់ ដែរ ឬយ៉ាងណា ទើបការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុស ព្រោះអង្គជំនុំជម្រះបានផ្អែកលើការលើកឡើងដែលថា គាត់បានឃើញសាកសពក្នុងផ្ទះនៅទីក្រុងភ្នំពេញ ដែលតាមការ

---

[2847] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦១៩។

[2848] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២០។

[2849] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២១។

[2850] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២២។

[2851] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២២។

លើកឡើងរបស់គាត់ នេះជាការ"ពុំជាប់ពាក់ព័ន្ធច្បាស់ក្រឡែត" និងបានផ្អែកដោយពុំត្រឹមត្រូវលើភស្តុតាងមួយផ្សេងទៀតដែលជាប្រតិចារិកនៃកិច្ចសម្ភាសន៍ជាមួយអ្នកកាសែតជនជាតិជប៉ុននោះ[2852]។

១០៥៩.សហព្រះរាជអាជ្ញាបានឆ្លើយតបថា "ក្នុងសាលក្រមទាំងមូល" អង្គជំនុំជម្រះសាលាដំបូងបានផ្តល់"ការយល់ឃើញយ៉ាងច្រើន [...] ពាក់ព័ន្ធទៅនឹងចេតនារបស់ នួន ជា"[2853] និងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងចេតនារបស់គាត់ក្នុងការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញនោះ មានលក្ខណៈសមហេតុផល[2854]។

១០៦០.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធទៅនឹងកង្វះចេតនាក្នុងការធ្វើមនុស្សឃាត ហាក់ដូចជាបានផ្អែកលើការសន្មតថា ធាតុផ្សំ*អត្តនោម័ត*នៃការធ្វើមនុស្សឃាតចាំបាច់តម្រូវឱ្យមានការបង្ហាញពីគោលបំណងរបស់ចារីក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ នួន ជា បានអះអាងពាក់ព័ន្ធទៅនឹងបញ្ហានេះថា "ទោះបីជាអាចនិយាយបានថា នួន ជា បាន [...] ដឹងជាមុនអំពីការស្លាប់ទាំងនោះក៏ដោយ [...] ក៏មិនមែនជាបទដ្ឋាននោះទេ"[2855]។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទីមួយ នួន ជា បានទទួលស្គាល់ជាក់លាក់ថា គាត់មានចេតនាសម្លាប់"ជនមហាក្បត់"ទាំង ៧ រូបនោះ ដូច្នេះ អំណះអំណាងរបស់គាត់ពុំអាចជឿជាក់បាន ដោយសារមានការជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់នោះ[2856]។ មានការបង្ហាញឱ្យឃើញថា នួន ជា មានចេតនាប្រព្រឹត្តដោយផ្ទាល់ក្នុងការសម្លាប់ទាក់ទងទៅនឹងបញ្ហានេះ។

១០៦១.ទាក់ទងទៅនឹងការសម្លាប់ដទៃទៀត ដែលបានកើតឡើងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដូចបានពន្យល់ខាងលើ "ចេតនា"ប្រព្រឹត្តបទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏មានអត្ថិភាពផងដែរក្នុងករណីដែលចារីបានប្រព្រឹត្ត*ដោយប្រយោល*[2857]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ឃើញយ៉ាងទូលំទូលាយពាក់ព័ន្ធទៅនឹងការដឹងរបស់ នួន ជា អំពីឧក្រិដ្ឋកម្មនានា រួមទាំងភវនីយភាព

---

[2852] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២៣។

[2853] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៨៤។

[2854] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៨៨ ដល ៤៩៤។

[2855] សារណាបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២២។

[2856] *សូមមើលខាងលើ* កថាខណ្ឌ ៣៥៨, ៨៥៩។

[2857] *សូមមើលខាងលើ* កថាខណ្ឌ ៤១០។

ច្បាស់លាស់ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនោះផងដែរ[2858]។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងដោយគ្មាន"ការគិតគូរអំពីសុខុមាលភាព ឬសុខភាពរបស់ប្រជាជនដែលត្រូវផ្លាស់ទីលំនៅនោះឡើយ ជាពិសេសអ្នកដែលងាយទទួលរងគ្រោះបំផុត"[2859] ដែលនៅក្នុងកាលៈទេសៈនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ(រយៈពេលខ្លីហួសហេតុ និងនៅក្នុងរដូវប្រាំងដែលក្តៅបំផុត)នោះ បានបង្ហាញច្បាស់លាស់ថា នួន ជា បានដឹងអំពីភវនីយភាពច្បាស់លាស់ចំពោះការស្លាប់ដោយសារលក្ខខណ្ឌនៃការជម្លៀសនេះ។ បើទោះបីជាបានដឹងដូច្នេះក៏ដោយ ក៏ នួន ជា នៅតែរួមចំណែកក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួមនេះដែរ ដូចនេះបង្ហាញឱ្យឃើញថា គាត់បានទទួលយកការស្លាប់ប្រជាជនដោយសារលទ្ធផលនៃការជម្លៀស។ អាស្រ័យហេតុនេះ ទាក់ទងទៅនឹងបទមនុស្សឃាតដែលបណ្តាលមកពី លក្ខខណ្ឌនៃការជម្លៀសប្រជាជនដំណាក់កាលទីមួយ ដោយផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញឱ្យឃើញថា នួន ជា បានប្រព្រឹត្ត*ដោយចេតនាប្រយោល*។

១០៦២.ពាក់ព័ន្ធទៅនឹងការសម្លាប់ជនស៊ីវិល និង អ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ អង្គជំនុំជម្រះតុលាការកំពូលរំលឹកការយល់ឃើញខាងលើទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលមានរួមបញ្ចូលនៅក្នុងគោលបំណងឧក្រិដ្ឋរួម[2860] ដែល បានយល់ឃើញថា នៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ គោលបំណងរួមបានរួមបញ្ចូលដោយប្រយោលនូវការរំពឹកទុកជាមុនថា នឹងមានការប្រើប្រាស់អំពើហិង្សាបណ្តាលឱ្យស្លាប់ ពីសំណាក់កងទ័ពដែលទទួលភារកិច្ចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ដោយហេតុថា នួន ជា បានចូលរួមដោយផ្ទាល់នៅក្នុងការធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ ដូច្នេះគាត់បានដឹងអំពីកាលៈទេសៈទាំងនេះ។ យោងតាមការសម្រេចរបស់គាត់ក្នុងការរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួមដោយពុំគិតគូរពីអ្វីកើតមាននោះ នួន ជា បានទទួលយកការកើតឡើងចំពោះការសម្លាប់ទាំងនោះ និងបានប្រព្រឹត្ត*ដោយចេតប្រយោល*។ ដោយផ្អែកលើការយល់ឃើញនេះ ពុំមានភាពចាំបាច់ត្រូវ ពិចារណាលើអំណះអំណាងដែលបានលើកឡើងថា អង្គជំនុំជម្រះ

---

[2858] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៣៩ ដល់ ៨៦០។ *សូមមើលផងដែរ* កថាខណ្ឌ ៩០៤ ដល់ ៩០៩។

[2859] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨៨។

[2860] *សូមមើលខាងលើ* កថាខណ្ឌ ៨៥៤ *ជាអាទិ៍*។

សាលាដំបូងមានកំហុស ដោយសារអង្គជំនុំជម្រះនេះ នៅពេលពិភាក្សាអំពីចេតនារបស់ នួន ជា បានយោងទៅលើការដែលគាត់បានឃើញសាកសពនៅក្នុងទីក្រុងភ្នំពេញនោះ។

១០៦៣.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានទទួលយកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនៃការផ្លាស់ទីលំនៅ និងការសម្លាប់មួយករណី[2861]។ ប៉ុន្តែ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ករណីទាំងនេះជាការសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចកែប្រែបទឧក្រិដ្ឋនេះ ទៅជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2862]។ អាស្រ័យហេតុនេះ ពាក់ព័ន្ធទៅនឹងចេតនារបស់ នួន ជា ចាំបាច់ត្រូវកំណត់ ថាតើផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង មានការបង្ហាញឱ្យឃើញថា នួន ជា មានចេតនាផ្ទាល់ ឬ*ចេតនាប្រយោល* ក្នុងការសម្លាប់តាមរយៈការអនុវត្តគោលបំណងរួម ដែរ ឬយ៉ាងណា។

១០៦៤.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញឱ្យឃើញថា នួន ជា មានគោលបំណងធ្វើឱ្យអ្នកដែលត្រូវជម្លៀសស្លាប់តាមរយៈការអនុវត្តការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ឬបានដឹងថា ប្រាកដជានឹងមានការស្លាប់កើតឡើងនោះឡើយ។ អាស្រ័យហេតុនេះ ពុំអាចនិយាយបានថា នួន ជា បានប្រព្រឹត្តអំពើមនុស្សឃាតដោយចេតនាផ្ទាល់ឡើយ។ ទោះជាយ៉ាងណាក្តី ដោយផ្អែកលើការពិតដែលថា គាត់បានដឹងអំពីផលវិបាកដែលធ្វើឱ្យបាត់បង់ជីវិតក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[2863] ហើយនៅតែបន្តចូលរួមដោយផ្ទាល់នៅក្នុងការធ្វើសេចក្តីសម្រេច និងការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជនក្នុងទ្រង់ទ្រាយធំដែលជាផ្នែកនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរនោះ នួន ជា បានដឹងថា ការស្លាប់ទំនងជាអាចកើតមានដោយសារការអនុវត្តការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ជាហេតុការណ៍ពិតមួយដែលគាត់បានទទួលស្គាល់។ ដូច្នេះ នួន ជា បានប្រព្រឹត្តអំពើមនុស្សឃាត*ដោយចេតនាប្រយោល*ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរនេះ។

---

[2861] *សូមមើលខាងលើ* កថាខណ្ឌ ៥៥០ *ជាអាទិ៍*។

[2862] *សូមមើលខាងលើ* កថាខណ្ឌ ៥៦០ ដល់ ៥៦២។

[2863] *សូមមើលខាងលើ* កថាខណ្ឌ ១០៦១។

១០៦៥.ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ នួន ជា បានលើកឡើងថា អំណះអំណាងរបស់គាត់ទាក់ទងទៅនឹងនត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវយកមកអនុវត្តដូចគ្នាចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហានេះដែរ[2864]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយចំពោះអំណះអំណាងនេះរួចរាល់ហើយនៅផ្នែកខាងលើ និងបានសន្និដ្ឋានថា គោលនយោបាយកំណត់គោលដៅពុំត្រូវបានបង្ហាញឱ្យឃើញដោយសមហេតុផលនោះឡើយ[2865]។ អាស្រ័យហេតុនេះ អំណះអំណាងអំពីចេតនាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ ពុំចាំបាច់ត្រូវធ្វើការពិចារណាបន្ថែមទៀតឡើយ។

១០៦៦.ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីចេតនារបស់ នួន ជា ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនោះ នួន ជា ពុំបានលើកអំណះអំណាងថ្មីណាមួយឡើយ ប៉ុន្តែគ្រាន់តែបានសំដៅទៅលើអំណះអំណាងដែលបានលើកឡើង នៅក្នុងផ្នែកផ្សេងនៃសារណាបណ្ដឹងសាទុក្ខរបស់គាត់ប៉ុណ្ណោះ ដែលអំណះអំណាងនេះអង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយ និងបដិសេធចោលរួចរាល់ហើយ[2866]។

### ៤.ង.១.ណ.ចេតនារបស់ ខៀវ សំផន

១០៦៧.ទាក់ទងទៅនឹងចេតនារបស់ ខៀវ សំផន ដែលត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមទម្រង់នៃសហឧក្រិដ្ឋរួម អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ការបន្តចូលរួមដោយចេតនានៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយបានដឹងថា បទឧក្រិដ្ឋនានាកំពុងត្រូវបានប្រព្រឹត្តឡើងនោះ បានបង្ហាញឱ្យឃើញពីចេតនាឧក្រិដ្ឋរបស់ ខៀវ សំផន"[2867]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំនានា ដែលក្នុងពេលនោះគោលបំណងរួមត្រូវបានបង្កើតឡើង និងបានអនុវត្តតាមរយៈគោលនយោបាយដែលបានព្រមព្រៀងផងដែរ និងថា គាត់បានដឹងអំពីភាវនីយភាពច្បាស់លាស់ថា បទឧក្រិដ្ឋនានានឹងកើតមាន

---

[2864] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២៦។

[2865] *សូមមើលខាងលើ* កថាខណ្ឌ ៩៧២។

[2866] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦២៤ ដល់ ៦២៥។

[2867] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៣។

ដោយសារលទ្ធផលនៃការអនុវត្តគោលនយោបាយទាំងនេះ[2868]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានដឹងថា គោលនយោបាយទាំងនេះបានបណ្តាលឲ្យមាន និង/ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និង នៅទួលពោធិ៍ជ្រៃ និងថា គាត់ក៏បានទទួលព័ត៌មានសម្ងាត់អំពីការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះផងដែរ[2869]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញបន្ថែមទៀតថា បើទោះបីជាគាត់បានដឹងដូច្នេះក៏ដោយ "ក៏គាត់នៅតែបានបន្តចូលរួមចំណែក និងឯកភាពលើដំណើរការវិវត្តនៃបដិវត្តន៍ប្រជាធិបតេយ្យ និងសង្គមនិយម"តាមរយៈការរៀបចំផែនការ ការផ្សព្វផ្សាយ ការអនុវត្ត ការគាំទ្រ និងការការពារគោលបំណងរួម ដែលបណ្តាលឲ្យមាន និងជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជន និងការការពារគោលនយោបាយកំណត់គោលដៅដែលបទឧក្រិដ្ឋនានាត្រូវបានប្រព្រឹត្តឡើងតាមរយៈគោលនយោបាយទាំងនេះ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និង នៅទួលពោធិ៍ជ្រៃ[2870]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានចេតនារួមចំណែកក្នុងចេតនារបស់សមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ក្នុងការអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយខាងលើដែលបណ្តាលឲ្យមាន និង/ឬជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និង នៅទួលពោធិ៍ជ្រៃ ដែលរួមមានបទមនុស្សឃាត បទសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត[2871]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានចេតនារួមចំណែកក្នុងចេតនារើសអើងរបស់សមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[2872]។

១០៦៨.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារពុំបានពិចារណាឲ្យបានគ្រប់គ្រាន់អំពីគោលការណ៍រក្សាការសម្ងាត់នៅក្នុង ប.ក.ក. និងបានលើកឡើងថា គោលការណ៍នេះអាចនាំឲ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានបានថា មានមន្ទិលសង្ស័យពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

[2868] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៤។

[2869] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៤។

[2870] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៤។

[2871] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៥។

[2872] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៥។

របស់គាត់[2873]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយបានយល់ឃើញថា ពាក្យ"មជ្ឈិមបក្ស" និង"អង្គការ"អាចកំណត់អត្តសញ្ញាណរបស់បុគ្គល និងស្ថាប័នច្បាស់លាស់បាន[2874]។ ខៀវ សំផន បានលើកឡើងថា ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ពាក្យ"មជ្ឈិមបក្ស"មានលក្ខណៈស្រពេចស្រពិល[2875] ទើបអង្គជំនុំជម្រះនេះបានយល់ឃើញផ្ទុយគ្នា ដោយបានកំណត់និយមន័យនៃពាក្យនេះសំដៅ"ជារួមទៅលើស្ថាប័នប្រតិបត្តិជាន់ខ្ពស់របស់ ប.ក.ក. ដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ"[2876]។ ខៀវ សំផន បានលើកឡើងថា ចំណុចនេះ គឺជាកំហុសធ្ងន់ធ្ងរ ដោយផ្អែកលើមូលដ្ឋាននេះពុំអាចឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាពេញលេញលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ និងពុំបានភ្ជាប់ទំនាក់ទំនងដោយពិតប្រាកដរវាងរូបគាត់ជាមួយនឹងសេចក្តីសម្រេចទាំងអស់ ដែលបានធ្វើឡើងដោយស្ថាប័ននានានៃកម្ពុជាប្រជាធិបតេយ្យឡើយ[2877]។ ទាក់ទងទៅនឹងពាក្យ"អង្គការ" ខៀវ សំផន បានអះអាងប្រហាក់ប្រហែលគ្នានេះដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានប្រើប្រាស់ពាក្យនេះពុំច្បាស់លាស់ជាហេតុធ្វើឱ្យមានការបញ្ចូលរូបគាត់ដោយប្រយោល[2878]។ ដូច្នេះ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានភ្ជាប់ទំនាក់ទំនងរវាងព្រឹត្តិការណ៍ដែល"មជ្ឈិមបក្ស" ឬ"អង្គការ"ជាអ្នកទទួលខុសត្រូវ ជាមួយនឹងការបានដឹងរបស់គាត់អំពីព្រឹត្តិការណ៍ទាំងនេះ ធ្វើជាលក្ខខណ្ឌតម្រូវសម្រាប់ដាក់គាត់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[2879]។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានដឹងជាមុនអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងថាគាត់បានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចដែលបណ្តាលឱ្យមានការសម្រេចបែបនេះ[2880]។ លើសពីនេះទៀត ខៀវ សំផន បានលើកឡើងថា អង្គជំនុំជ្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានដឹងអំពីបទឧក្រិដ្ឋនានា ឬគោលនយោបាយឧក្រិដ្ឋ ដែលបានប្រព្រឹត្ត ឬអនុវត្តនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ

---

[2873] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៤៩។

[2874] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៣៩។

[2875] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២០៥។

[2876] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២០៦។

[2877] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៤១។

[2878] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៤៣។

[2879] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៤៤។

[2880] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨០ ដល់ ២៨៥។

១៩៧៥ និងថា គាត់បានដឹងអំពីភវនីយភាពច្បាស់លាស់ថា មានការប្រព្រឹត្តបទឧក្រិដ្ឋនានាតាមរយៈការអនុវត្តគោលនយោបាយទាំងនេះ[2881]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញទាក់ទងទៅនឹងឯកសារបោះពុម្ពផ្សាយទស្សនាវដ្ដី *ទង់បដិវត្តន៍* និងទស្សនាវដ្ដី *យុវជនយុវនារីបដិវត្តន៍* នៅក្នុងអំឡុងពេលមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[2882]។ បន្ថែមលើនេះទៀត ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានធ្វើការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋរបស់គាត់ចេញពីការចូលរួមរបស់គាត់ក្នុងការអនុវត្តគោលបំណងរួមនេះតែមួយមុខគត់ ដែលនេះពុំមែនជាបទឧក្រិដ្ឋទាំងស្រុង និងដោយពុំបានយល់ឃើញថា អំពើរបស់គាត់បានរួមចំណែកក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម[2883]។ ខៀវ សំផន បានជំទាស់បន្ថែមទៀតទៅនឹងការយល់ឃើញដែលថា គាត់បានដឹងព័ត៌មានអំពីការប្រព្រឹត្តបទឧក្រិដ្ឋនានាក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ពីព្រោះគាត់បានជួបជាមួយមេដឹកនាំជាន់ខ្ពស់នានារបស់ ប.ក.ក. នៅមន្ទីរ ប-៥ និងនៅស្ថានីយរថភ្លើងក្នុងទីក្រុងភ្នំពេញ[2884]។ ជាមួយគ្នានេះដែរ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងអំពីការប្រព្រឹត្តបទឧក្រិដ្ឋនានាក្នុងពេលនោះតាមរយៈសារព័ត៌មានបរទេស របាយការណ៍ និងទំនាក់ទំនងការទូតរបស់គាត់[2885]។ បន្ថែមលើនេះទៀត ខៀវ សំផន បានចោទប្រកាន់អំពីកំហុសទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីកិច្ចប្រជុំ ដែលគាត់បានចូលរួមក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ និងការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំនោះ ព្រមទាំងខ្លឹមសារនៃកិច្ចប្រជុំ[2886]។ ខៀវ សំផន ក៏បានជំទាស់ជាទូទៅផងដែរទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការដឹងរបស់គាត់អំពីគោលនយោបាយរបស់ ប.ក.ក. និងការទទួលបានព័ត៌មានអំពីបទឧក្រិដ្ឋនានានោះ[2887]។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការយល់ឃើញថា

---

[2881] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨៦ និង ២៨៨ ដល់ ២៩១។

[2882] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧១ ដល់ ១៧៦។

[2883] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១៨ ដល់ ៣១៩, ៤១៤ ដល់ ៤១៥, ៤៤៦ ដល់ ៤៤៧, ៦២៦ ដល់ ៦២៧។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៥។

[2884] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧៤ ដល់ ៣៨២។

[2885] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣ ដល់ ៣៨៧។

[2886] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៣ ដល់ ៣៩៤។

[2887] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៥។

គាត់បានដឹងអំពីបទឧក្រិដ្ឋនានាក្នុងពេល និងក្រោយពេលប្រព្រឹត្ត ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទីមួយ[2888]។ បន្ថែមលើនេះទៀត ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹងអំពីភវនីយភាពច្បាស់លាស់ នៅមុនការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរថា មានការប្រព្រឹត្តបទឧក្រិដ្ឋនានា និងបានយល់ឃើញថា គាត់បានដឹងអំពីបទឧក្រិដ្ឋទាំងនេះក្នុងពេល និងក្រោយពេលប្រព្រឹត្ត[2889]។ បន្ថែមលើនេះ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានដឹងអំពីការប្រព្រឹត្តបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ[2890]។ ចុងក្រោយ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងពុំត្រឹមត្រូវទៅលើអង្គហេតុក្រោយការប្រព្រឹត្តឧក្រិដ្ឋកម្មទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដូច្នេះមានកំហុសក្នុងការបង្ហាញអំពីការដឹងបទល្មើសក្រោយការប្រព្រឹត្ត*(dolus subsequens)*។

១០៦៩.សហព្រះរាជអាជ្ញាបានឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូង“បានលើកមូលដ្ឋានបង្ហាញយ៉ាងច្បាស់ថា បើទោះជាមានគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. ក៏ដោយ ក៏ ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានរកឃើញថា គាត់មានពិរុទ្ធដោយសារការប្រព្រឹត្តនេះ” និងថា គាត់បានចូលរួមក្នុងការរក្សាការសម្ងាត់[2891]។ ទាក់ទងទៅនឹងការប្រើប្រាស់ពាក្យ“មជ្ឈិមបក្ស” និង“អង្គការ”របស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាបានលើកឡើងថា ការប្រើប្រាស់ពាក្យនេះត្រូវបានគាំទ្រដោយភស្តុតាង និងថា អង្គជំនុំជម្រះសាលាដំបូងបានដឹងអំពីភាពស្រពេចស្រពិលនៃពាក្យទាំងនេះ[2892]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ខៀវ សំផន “ពុំបានបង្ហាញអំពីកំហុស ឬព្យសនកម្មណាមួយដែលកើតចេញពីការប្រើប្រាស់ពាក្យពេចន៍ទាំងនេះពីសំណាក់អង្គជំនុំជម្រះ”នោះឡើយ និងបានកត់សម្គាល់ថា អំណះអំណាងរបស់ ខៀវ សំផន ពុំបានយោងទៅលើឯកសារណាមួយ និងទំនងជាមានលក្ខណៈផ្ទុយគ្នា[2893]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញត្រឹមត្រូវផ្អែកលើភស្តុតាងគ្រប់គ្រាន់ដែលអង្គជំនុំ

---

[2888] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៧ ដល់ ៤០១។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៥។

[2889] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៨៨ ដល់ ៥៩៨។

[2890] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣៧ ដល់ ៤៤០, ៦៣៦ ដល់ ៦៤១។

[2891] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០៩ (ជើងទំព័រលុបចោល)។

[2892] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០៧។

[2893] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០៨។

ជម្រះបានយកមកសំអាងនោះ និងថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំនៅខែ មេសា ឆ្នាំ ១៩៧៥ នៅមន្ទីរ ប-៥ ដែលក្នុងពេលនោះ ខៀវ សំផន បានគាំទ្រសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[2894] ដែលសេចក្តីសម្រេចនេះគាត់អាចជំទាស់បាន បើយោងតាមសហព្រះរាជអាជ្ញា[2895]។ ទាក់ទងទៅនឹងកំហុស ដែលខៀវ សំផន បានចោទប្រកាន់ពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុង អំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងនៅទួលពោធិ៍ជ្រៃនោះ សហព្រះរាជអាជ្ញាបាន ឆ្លើយតបថា ខៀវ សំផន ពុំបានបង្ហាញឱ្យឃើញ ថាតើកំហុសដែលបានចោទប្រកាន់នោះ បានបណ្តាលឲ្យមាន ភាពមិនយុត្តិធម៌យ៉ាងដូចម្តេចឡើយ[2896]។ ទាក់ទងទៅនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានឆ្លើយតបបន្ថែម ទៀតថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញយ៉ាងត្រឹមត្រូវថា ខៀវ សំផន បានដឹងព័ត៌មានអំពីឧក្រិដ្ឋកម្ម នៅពេលគាត់ជួបជាមួយមេដឹកនាំជាន់ខ្ពស់នានារបស់ ប.ក.ក. នៅមន្ទីរ ប-៥ ព្រមទាំងដឹងតាមរយៈរបាយ ការណ៍ការទូត និងទីភ្នាក់ងារសារព័ត៌មាននានា[2897]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមថា ខៀវ សំផន បានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានដឹងនៅ មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អំពី"ភវនីយភាពច្បាស់លាស់"ថា នឹងមានឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង និងថា គាត់ពិតជាបានដឹងអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងពេលនោះ[2898]។ សហព្រះរាជអាជ្ញាបានលើក ឡើងបន្ថែមទៀតថា ខៀវ សំផន ពុំបានបង្ហាញអំពីកំហុសផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មនោះ ហេតុដូច្នេះ ពុំបានកំណត់អត្តសញ្ញាណនៃកំហុសដែលអាចប្តឹង សាទុក្ខបាននោះ[2899]។ ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមាន កំហុសក្នុងការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋ ចេញតែពីការចូលរួមរបស់គាត់ក្នុងការអនុវត្តគោលបំណងរួម ដែល អង្គជំនុំជម្រះបានចាត់ទុកថា ពុំមែនជា"បទឧក្រិដ្ឋទាំងស្រុង"នោះ សហព្រះរាជអាជ្ញាបានលើកឡើងថា ការ យល់ឃើញរបស់អង្គជំនុំជម្រះបានផ្អែកលើមូលដ្ឋាននៃការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម និងការចូលរួមចំណែក របស់គាត់រហូតដល់ប្រាំដងនៅក្នុងគោលបំណងរួមដែលបានបណ្តាលឲ្យមាន និងជាប់ពាក់ព័ន្ធទៅនឹងការ

---

[2894] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៥៦ ដល់ ៤៥៧។

[2895] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៥៨។

[2896] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៥៩។

[2897] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៥៩ ដល់ ៤៦៥។

[2898] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦១៦ និង ៦១៨។

[2899] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦១៧ និង ៦១៩។

ជម្លៀសប្រជាជន និង គោលនយោបាយកំណត់គោលដៅ[2900]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា អំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់ អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃនោះ ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ ឬបានផ្អែកលើការយល់ពុំត្រឹមត្រូវអំពីច្បាប់ជាធរមាន និងថា នៅគ្រប់ករណីទាំងអស់ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងមានភាពត្រឹមត្រូវ ដោយបានផ្អែកលើការបង្ហាញពីលំនាំនៃឧក្រិដ្ឋកម្មដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងនោះ[2901]។

១០៧០.អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយលើអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីបញ្ហា ថាតើគាត់មានចេតនាតម្រូវ ក្នុងការដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែរឬយ៉ាងណា។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលនឹងពុំដោះស្រាយលើអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ[2902]នោះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញដូចខាងលើថា អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពុំត្រូវបានបង្ហាញសមហេតុផលដោយផ្អែកលើភស្តុតាងក្នុងសំណុំរឿង ០០២/០១[2903]។ អាស្រ័យហេតុនេះ ខៀវ សំផន ពុំអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងនេះឡើយ ហើយបញ្ហាស្តីពីចេតនារបស់គាត់ទាក់ទងទៅនឹងបញ្ហានេះ ត្រូវចាត់ជាអសារបង់។

១០៧១.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងគោលការណ៍រក្សាការសម្ងាត់នៅក្នុង ប.ក.ក .[2904] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចដែលថា គាត់បានដឹងអំពីឧក្រិដ្ឋកម្ម ដែលរូបគាត់ត្រូវបានប្រកាស ដាក់ពិរុទ្ធភាពនោះ។ ការយល់ឃើញទាំងនេះមានច្រើននៅក្នុងផ្នែកមួយដោយឡែកនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានពិពណ៌នាយ៉ាងលម្អិតពីរបៀបដែលខ្លួន បានធ្វើការ

---

[2900] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦២២ ដល់ ៦២៣។

[2901] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦២៥ ដល់ ៦២៧។

[2902] សារណាលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៤៣៧ ដល់ ៤៤០។

[2903] *សូមមើលខាងលើ* កថាខណ្ឌ ៩៧២។

[2904] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៤៥ ដល់ ១៤៩។

សន្និដ្ឋានពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មទាំងនោះ[2905]។ ខៀវ សំផន បានអះអាងត្រឹមតែថា បើផ្អែកលើគោលការណ៍រក្សាការសម្ងាត់ អង្គជំនុំជម្រះសាលាដំបូងអាចនឹងផ្តល់ការសន្និដ្ឋានផ្សេងពីនេះ។ ច្បាស់លាស់ណាស់ ចំណុចនេះពុំមានភាពសមស្របក្នុងការបង្ហាញឱ្យឃើញពីកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ អាស្រ័យហេតុនេះ អំណះអំណាងរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

១០៧២.ចំពោះអំណះអំណាងទាក់ទងទៅនឹងការផ្សព្វផ្សាយទស្សនាវដ្ដី *ទង់បដិវត្តន៍* និងទស្សនាវដ្ដី*យុវជនយុវនារីបដិវត្តន៍* ខៀវ សំផន បានលើកឡើងថា ទីមួយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មជ្ឈិមបក្សអាចទាក់ទងដោយងាយស្រួលជាមួយភូមិភាគ[2906]។ ដូចការកត់សម្គាល់របស់សហព្រះរាជអាជ្ញា[2907] នៅក្នុងកថាខណ្ឌមួយចំនួននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែល ខៀវ សំផន បានយោងនោះ អង្គជំនុំជម្រះពុំបានផ្តល់ការយល់ឃើញបែបនេះឡើយ ដូច្នេះអំណះអំណាងនេះត្រូវបដិសេធចោល[2908]។ ទីពីរ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើឯកសារបោះពុម្ពផ្សាយទាំងនេះ ក្នុងការបង្ហាញពីការដឹងរបស់ ខៀវ សំផន អំពីភវនីយភាពច្បាស់លាស់ថា មានការប្រព្រឹត្តឧក្រិដ្ឋកម្មដោយសារគោលនយោបាយផ្លាស់ទីលំនៅប្រជាជន ពីព្រោះពុំមានការបង្ហាញឱ្យឃើញថា គាត់បានទទួល ឬបានអានទស្សនាវដ្ដីទាំងនោះឡើយ[2909]។ អំណះអំណាងទាំងនេះត្រូវបដិសេធចោល ដោយសារនៅក្នុងកថាខណ្ឌសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលគាត់បានយោងនោះ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្អែកការដឹងរបស់គាត់ជាចម្បងតែទៅលើទស្សនាវដ្ដី*ទង់បដិវត្តន៍* និងទស្សនាវដ្ដី*យុវជនយុវនារីបដិវត្តន៍* ប៉ុណ្ណោះទេ ផ្ទុយទៅវិញ *ក្នុងចំណោមនោះ* អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើការចូលរួមរបស់គាត់នៅក្នុងការរៀបចំផែនការផ្លាស់ទីលំនៅប្រជាជន ការទាក់ទងរបស់គាត់ជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត ព្រមទាំងអ្នកការទូតបរទេស[2910]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងការប្រើប្រាស់ពាក្យ“មជ្ឈិមបក្ស” និង“អង្គការ”របស់អង្គជំនុំជម្រះសាលាដំបូង[2911] ដោយ

---

[2905] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤៤ ដល់ ៩៥៩។

[2906] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧២។

[2907] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១០។

[2908] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ២៧៤ ដល់ ២៧៥។

[2909] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៧៣។

[2910] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤៧ ដល់ ៩៥២។

[2911] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៣៩ ដល់ ១៤៤។

សារគាត់ពុំបានផ្ដល់មូលដ្ឋានគាំទ្រគ្រប់គ្រាន់ដល់ការអះអាងអំពីកំហុសនោះ និងផលប៉ះពាល់ជាសក្ដានុពលទៅលើសាលក្រម[2912]។ ទាក់ទងទៅនឹងអំណះអំណាងរបស់គាត់ដែលថា កំហុសនោះមានឥទ្ធិពលលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន ពុំបានពន្យល់បន្ថែមលើអំណះអំណាងរបស់ខ្លួនលើសពីនេះឡើយ ប៉ុន្តែគ្រាន់តែបានយោងទៅលើផ្នែកមួយទៀតនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួនប៉ុណ្ណោះ ដែលទោះជាយ៉ាងណាក្ដី ពុំបានពិភាក្សាអំពីបញ្ហានេះម្ដងទៀតឡើយ[2913]។

១០៧៣.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានបដិសេធរួចហើយនូវអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ[2914] ដូច្នេះអំណះអំណាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាក់ទងទៅនឹងបញ្ហានេះ និងទាក់ទងទៅនឹងការយល់ឃើញអំពីចេតនារបស់គាត់ ពុំអាចជឿជាក់បានឡើយ[2915]។ ដូចបានកត់សម្គាល់ខាងលើ[2916]ដោយហេតុថា ដោយផ្អែកលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មិនមានហេតុផលសមស្របក្នុងការសន្និដ្ឋានថា ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់មេដឹកនាំ ប.ក.ក. ក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ នោះ ដូច្នេះការដឹង ឬចេតនារបស់ ខៀវ សំផន ទាក់ទងទៅនឹងឧក្រិដ្ឋកម្ម ពុំអាចសន្និដ្ឋានដោយផ្អែកលើការចូលរួមនេះបានឡើយ។ នៅក្នុងកាលៈទេសៈនេះ ពុំមានមូលហេតុចាំបាច់ត្រូវដោះស្រាយអំណះអំណាងបន្ថែមរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះទេ[2917]។

១០៧៤.ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គាត់បានដឹងអំពីភាពនីយភាពខ្ពស់ថា បទឧក្រិដ្ឋនានាអាចនឹងត្រូវបានប្រព្រឹត្តឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងនៅ

---

[2912] *សូមមើលខាងលើ* កថាខណ្ឌ ១០១ ដល់ ១០២។

[2913] *សូមមើល* សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៤៤ ជើងទំព័រ ២៩៥ យោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨៦ ដល់ ៣២៩។

[2914] *សូមមើលខាងលើ* កថាខណ្ឌ ១០៧២។

[2915] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨២ ដល់ ២៨៣។

[2916] *សូមមើលខាងលើ* កថាខណ្ឌ ១០២៨។

[2917] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨៥។

01358602



ទួលពោធិ៍ជ្រៃ[2918] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងការគាំទ្រដល់អំណះអំណាងនេះ ខៀវ សំផន បានយោងទៅលើការលើកឡើងដទៃទៀត ដែលជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការចូលរួមរបស់គាត់ក្នុងការអនុវត្តគោលបំណងរួម[2919]។ ខៀវ សំផន បានប្រើប្រាស់វិធីសាស្ត្រស្រដៀងគ្នាទាក់ទងទៅនឹងអំណះអំណាងរបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានដឹងអំពីភវនីយភាពខ្ពស់នៃការប្រព្រឹត្តបទឧក្រិដ្ឋ នៅមុន ក្នុងអំឡុងពេល និងនៅក្រោយការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ក្នុងផ្នែកបន្ទាប់នៃសារណាបណ្តឹងសាទុក្ខរបស់គាត់[2920]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយកំហុសអង្គហេតុទាំងនេះរួចហើយដូចខាងលើ និងបានសន្និដ្ឋានថា ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើអំឡុងពេលមុនឆ្នាំ ១៩៧០ ធ្វើជាបរិបទនៃការយល់ឃើញរបស់ខ្លួន[2921] និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ ដែលនៅពេលនោះថា គាត់បានយល់ស្របជាមួយផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[2922] ព្រមទាំងថា គាត់បានថ្លែងសុន្ទរកថាប្រកាសបើកសម័យប្រជុំសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦[2923]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការយល់ឃើញផ្សេងទៀតរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហានេះមានភាពសមហេតុផល។ ការយល់ឃើញនេះបានផ្តល់មូលដ្ឋានគ្រប់គ្រាន់គាំទ្រសេចក្តីសន្និដ្ឋានដែលថា ខៀវ សំផន បានដឹងអំពីភវនីយភាពខ្ពស់ថា ឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងនៅទួលពោធិ៍ជ្រៃ ទោះបីជានៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឬនៅមុន ក្នុងអំឡុងពេល និងក្រោយការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរក៏ដោយ។

១០៧៥.ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋដោយបានសំអាងតែទៅលើការរួមចំណែករបស់គាត់ នៅក្នុងការអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម

[2918] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨៦ និង ២៨៩ ដល់ ២៩១។

[2919] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨៩។

[2920] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៥៨៨ ដល់ ៥៩៨។

[2921] *សូមមើលខាងលើ* កថាខណ្ឌ ១០០៥។

[2922] *សូមមើលខាងលើ* កថាខណ្ឌ ១០០៩។

[2923] *សូមមើលខាងលើ* កថាខណ្ឌ ១០២៣។

ដែលអង្គជំនុំជម្រះបានចាត់ទុកថា ពុំមែនជាបទឧក្រិដ្ឋទាំងស្រុងនោះ[2924]។ ដូចបានបញ្ជាក់ខាងលើ[2925] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា គោលបំណងរួម ត្រូវចាត់ជាបទឧក្រិដ្ឋ ដោយសារគោលបំណងរួមនេះមានទំនាក់ទំនងទៅនឹងគោលនយោបាយ ដែលការអនុវត្តគោលនយោបាយនេះត្រូវបានចាត់ជាការប្រព្រឹត្តបទឧក្រិដ្ឋ។ ហេតុនេះ ផ្ទុយពីការលើកឡើងរបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងពុំបានសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋចេញតែពីការគាំទ្ររបស់គាត់លើគោលបំណងរួមមួយផ្នែក ដែលពុំមែនជាបទឧក្រិដ្ឋទាំងស្រុងនោះប៉ុណ្ណោះទេ។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានចេតនាដូចគ្នាផងដែរក្នុងការសម្រេចគោលបំណងរួម ពោលគឺ ការកសាងបដិវត្តន៍សង្គមនិយមដែលពាក់ព័ន្ធជាចាំបាច់ទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា តាមរយៈការផ្លាស់ទីលំនៅប្រជាជន និងគោលនយោបាយកំណត់គោលដៅ ដូចគ្នានឹងអ្នកចូលរួមដទៃទៀតក្នុងសហឧក្រិដ្ឋកម្មរួម តាមរយៈការរួមចំណែករហូតដល់ប្រាំដង បើទោះបីជាគាត់បានដឹងមុនអំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងអំឡុងពេល និង*ក្រោយពេល*ប្រព្រឹត្តក៏ដោយ[2926]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន។

១០៧៦.ទាក់ទងទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់ទទួលបានព័ត៌មានពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយសារគាត់បានជួបជាមួយកម្មាភិបាល ប.ក.ក. នៅមន្ទីរ ប-៥ និងនៅស្ថានីយ៍រថភ្លើងក្នុងទីក្រុងភ្នំពេញ[2927] អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការយល់ឃើញរបស់ខ្លួនថា ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានចូលរួមកិច្ចប្រជុំនៅមន្ទីរ ប-៥ ក្នុងខែ មេសា ឆ្នាំ ១៩៧៥ នោះ មានភាពសមហេតុផល[2928]។ សាក្សី ភី ភួន បានផ្តល់សក្ខីកម្មយ៉ាងលម្អិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា ខៀវ សំផន មិនត្រឹមតែបានចូលរួមក្នុង

---

[2924] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១៨ ដល់ ៣១៩, ៤១៤ ដល់ ៤១៥, ៤៤៦ ដល់ ៤៤៧, ៦២៦ ដល់ ៦២៧។ *សូមមើលផងដែរ* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៥។

[2925] *សូមមើលខាងលើ* កថាខណ្ឌ ៨១៦ ដល់ ៨១៧។

[2926] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៤ ("ទោះបីជាគាត់បានដឹងដូច្នេះក៏ដោយ ក៏គាត់ [...] បានរៀបចំផែនការផ្សព្វផ្សាយ អនុវត្ត គាំទ្រ និងការពារគោលបំណងរួមដែលធ្វើឱ្យមានគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន ផ្លាស់ទីលំនៅប្រជាជនពីជនបទមួយទៅជនបទមួយទៀត និងកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ សម្រាប់ការចាប់ខ្លួន ការសម្លាប់ និងការធ្វើឱ្យបាត់ខ្លួន")។

[2927] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧៤ ដល់ ៣៨៣ និង*សូមមើលផងដែរ* កថាខណ្ឌ ២៨០ ដល់ ២៨៤។

[2928] *សូមមើលខាងលើ* កថាខណ្ឌ ១០១០ ដល់ ១០១១។

កិច្ចប្រជុំនៅមន្ទីរ ប-៥ ក្នុងដើមខែ មេសា ឆ្នាំ ១៩៧៥ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានយល់ស្របជាមួយនឹងសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំនោះផងដែរ[2929]។ ដោយផ្អែកលើមូលដ្ឋាននេះ តុលាការអង្គហេតុសមហេតុផលអាចសន្និដ្ឋានបានថា ខៀវ សំផន បានដឹងជាមុនអំពីព័ត៌មានលម្អិតនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់លើសេចក្តីសម្រេចរបស់ខ្លួន ដោយសារពុំបានឆ្លើយតបទៅនឹងអំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹងភាពកង្វះសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេច[2930]។ ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យផ្តល់សំអាងហេតុពេញលេញនៅក្នុងសាលក្រមរបស់ខ្លួនទាំងមូល ជាជាងការផ្តល់សំអាងហេតុតែទៅលើការលើកឡើងនីមួយៗដែលបានធ្វើឡើងនៅពេលជំនុំជម្រះនោះ[2931]។ ពុំមានការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើការលើកឡើងរបស់ ខៀវ សំផន នោះឡើយ[2932]។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញ ថាតើទំនាក់ទំនងជាក់ស្តែងរវាងភាពមាន ឬគ្មានសិទ្ធិអំណាចរបស់ ខៀវ សំផន ក្នុងការធ្វើសេចក្តីសម្រេចនោះ ជាប់ពាក់ព័ន្ធជាមួយនឹងបញ្ហា ចេតនាឧក្រិដ្ឋយ៉ាងដូចម្តេចឡើយ ហើយអង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភស្តុតាងដទៃទៀតដែលអង្គជំនុំជម្រះនេះបានដកស្រង់ដើម្បីគាំទ្រដល់ការយល់ឃើញរបស់ខ្លួននោះឡើយ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានសំអាងយ៉ាងសមហេតុផលទៅលើសៀវភៅរបស់ ខៀវ សំផន ក្នុងការបញ្ជាក់បន្ថែមអំពីវត្តមានរបស់គាត់នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនៅមន្ទីរ ប-៥[2933]។ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានដកស្រង់សក្ខីកម្ម

---

[2929] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៦ យោងទៅលើប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម គុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ១២ ដល់ ១៣, ១៤, ២០ ដល់ ២១។ ប្រតិចារឹកចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (វ៉ាចាម គុន *ហៅ* ភី ភួន) ឯកសារលេខ E1/99.1 ទំព័រ ៣៥ ដល់ ៣៦។

[2930] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៨៤។

[2931] *សូមមើលខាងលើ* កថាខណ្ឌ ១០០៧។

[2932] *សូមមើលខាងលើ* កថាខណ្ឌ ១០០៧។

[2933] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៣៥ ជើងទំព័រ ២៣០២ យោងទៅលើសៀវភៅរបស់ ខៀវ សំផន៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឯកសារលេខ E3/18 ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៤ ERN (ភាសាខ្មែរ) 00103838 ទំព័រ ៦០។

របស់គាត់ក្នុងពេលជំនុំជម្រះពុំត្រឹមត្រូវនោះ[2934] ជាការពុំសមស្របឡើយ ដោយហេតុថា ខៀវ សំផន ខ្លួនគាត់ផ្ទាល់បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានកោះហៅឱ្យទៅ"ចូលរួម" និង"ស្តាប់"[2935]។

១០៧៧.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានទទួលព័ត៌មានពី"មេដឹកនាំភូមិភាគដែលបញ្ជាកងទ័ពនៅមូលដ្ឋាន"ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយនោះ[2936] ខៀវ សំផន ពុំបានចង្អុលបង្ហាញឱ្យបានត្រឹមត្រូវអំពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ដូចបានកត់សម្គាល់ខាងលើ ខៀវ សំផន បានផ្តល់សក្ខីកម្មថា ប៉ុល ពត បានកោះហៅគាត់"ឱ្យចូលរួម និងស្តាប់"របាយការណ៍ពីកម្មាភិបាលយោធា[2937]។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើសក្ខីកម្មនេះក្នុងការផ្តល់ការយល់ឃើញរបស់ខ្លួន[2938]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានហេតុផលសមស្របក្នុងការលើកយកសក្ខីកម្មនេះដើម្បីធ្វើការសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីការប្រព្រឹត្តបទឧក្រិដ្ឋនានានៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងការផ្តល់ការសន្និដ្ឋានជារួម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើភស្តុតាងទាំងមូលដែលក្នុងនោះសក្ខីកម្មរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំជាមួយ ប៉ុល ពត គឺជាធាតុមួយនៃភស្តុតាងនេះផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលក៏ពិចារណាផងដែរថា ការយល់ឃើញនេះស្របជាមួយនឹងការសន្និដ្ឋានជាបន្តបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន "ពុំធ្លាប់បានទទួលខុសត្រូវដោយផ្ទាល់លើវិស័យយោធា"នោះឡើយ[2939]។

[2934] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧៦។

[2935] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ឯកសារលេខ E1/21.1 ទំព័រ ៦៤ ("ប៉ុល ពត ទេ [...]ដែលហៅខ្ញុំឱ្យទៅ[ទីបញ្ជាការបក្ស] ដើម្បីចូលរួមស្តាប់ពេលគាត់ធ្វើការជាមួយកម្មាភិបាលយោធាដែលមកពីសមរភូមិផ្សេងៗ [...] ហើយយល់សភាពការណ៍នៃការតស៊ូវិវត្តន៍ដល់ណាៗហើយ...")។

[2936] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៧៨ ដល់ ៣៨១។

[2937] ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ខៀវ សំផន) ឯកសារលេខ E1/21.1 ៦៤។

[2938] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៣៩។

[2939] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៨១ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៧៨។

01358606



១០៧៨.ពាក់ព័ន្ធទៅនឹងការលើកឡើងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានដឹងអំពីឧក្រិដ្ឋកម្ម ដោយសារគាត់បានជួបជាមួយមេដឹកនាំ ប.ក.ក. នៅស្ថានីយរថភ្លើងក្នុងទីក្រុងភ្នំពេញ និងការលើកឡើងថា សក្ខីកម្ម និងកំណត់ហេតុស្តាប់ចម្លើយរបស់ ភី ភួន ដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាង ពុំបានបង្ហាញឱ្យឃើញថា ខៀវ សំផន បាន"ចូលរួមដោយផ្ទាល់នៅក្នុងការបង្កើតផែនការ និងគោលនយោបាយរបស់ប្រទេស"ទេនោះ[2940] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង នៅពេលពិភាក្សាអំពីការដឹងរបស់ ខៀវ សំផន ពិតជាបានបញ្ជាក់ថា ខៀវ សំផន បានជួបជាមួយមេដឹកនាំជាន់ខ្ពស់នៅស្ថានីយរថភ្លើងប្រាកដមែន[2941]។ នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់មួយចំនួន រួមមាន ខៀវ សំផន ផងដែរ បានជួបគ្នាដើម្បី "ពិភាក្សាអំពីគោលនយោបាយ"[2942]។ ដូចការកត់សម្គាល់យ៉ាងត្រឹមត្រូវរបស់ ខៀវ សំផន ផ្អែកតាមកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ភី ភួន គាត់ពិតជាពុំបានដឹងអំពីអ្វីដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំមួយក្នុងចំណោមកិច្ចប្រជុំនានា ដែលបានធ្វើឡើងនៅស្ថានីយរថភ្លើងនោះឡើយ ដោយសារគាត់ពុំបានទៅ"យាមនៅទីនោះទេ"[2943]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងកិច្ចប្រជុំមួយនៅស្ថានីយរថភ្លើងនោះ ពុំមានឥទ្ធិពលដល់ការសម្រេចដាក់ពិរុទ្ធភាពលើរូបគាត់ឡើយ ដោយហេតុថា ការយល់ឃើញនោះមាននៅក្នុងផ្នែកមួយដែលពិភាក្សាអំពីការដឹងរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ ដោយពុំបានទទួលយកអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅ[2944]នោះ បញ្ហា ថាតើ ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មទាំងនេះដែរ ឬយ៉ាងណា ត្រូវចាត់ទុកជាអសារបង់ ពីព្រោះនៅគ្រប់ករណីទាំងអស់ ឧក្រិដ្ឋកម្មនេះពុំអាចដាក់ឱ្យ ខៀវ សំផន ទទួលខុសត្រូវឡើយ។

១០៧៩. ទាក់ទងទៅនឹងការជំទាស់របស់ ខៀវ សំផន ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការទទួលព័ត៌មានរបស់គាត់តាមរយៈសេចក្តីរាយការណ៍របស់សារព័ត៌មានបរទេស ក៏ដូចជា

---

[2940] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៨២ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៣៩, ៧៤០, ៩៤៦, ៩៥៣ និង ៩៥៤។

[2941] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៥៤។

[2942] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤០។

[2943] កំណត់ហេតុស្តាប់ចម្លើយរបស់ រ៉ាចាម គុន *ហៅ* ភី ភួន ឯកសារលេខ E3/24 ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00204069-00204070 ទំព័រ ៤ ដល់ ៥។

[2944] *សូមមើលខាងលើ* កថាខណ្ឌ ១០០៧។

01358607



របាយការណ៍និងទំនាក់ទំនងការទូត[2945] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មក្នុងពេលដំណាលគ្នាជាមួយនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ពីព្រោះថា គាត់មានទំនាក់ទំនងទៀងទាត់ជាមួយសម្តេច នរោត្តម សីហនុ សម្តេច ប៉ែន នុត ព្រមទាំងមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅក្រៅប្រទេស រួមទាំងមន្ត្រីនៃចលនាតស៊ូក្នុងប្រទេសដែលបានធ្វើដំណើរទៅក្រៅប្រទេសនៅក្នុងអំឡុងពេលនៃអង្គហេតុ ឬអ្នកដែលមានមូលដ្ឋាននៅបរទេស"ដូចជា អៀង សារី និង អៀង ធីរិទ្ធ"[2946]។ បើទោះបីជា ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងក្នុងការយល់ឃើញនោះ ពុំបានបង្ហាញឱ្យឃើញអំពីការដឹងដោយផ្ទាល់របស់គាត់ក៏ដោយ ក៏បានបង្ហាញឱ្យឃើញថា គាត់មានទំនាក់ទំនងជាមួយនឹងអ្នកដែលគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនោះដែរ។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន ជាក់ស្តែងបានដឹងតាមរយៈទំនាក់ទំនងទៀងទាត់ទាំងនោះ ជាការសមហេតុផល។ ចំពោះការលើកឡើងរបស់គាត់ទាក់ទងទៅនឹងការចោទប្រកាន់ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់សំអាងហេតុគ្រប់គ្រាន់នោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យផ្តល់សំអាងហេតុពេញលេញនៅក្នុងសាលក្រមរបស់ខ្លួនទាំងមូល ប៉ុន្តែពុំមែនផ្តល់សំអាងហេតុទៅលើតែចំណុចនីមួយៗដែលបានលើកឡើងក្នុងពេលសវនាការនោះឡើយ[2947]។

១០៨០.ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ខៀវ សំផន ធ្វើជាប្រធានសមាជជាតិពិសេស និងថា ពុំគប្បីសំអាងទៅលើការយល់ឃើញនេះក្នុងការសន្និដ្ឋានថា គាត់បានគាំទ្រដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[2948]នោះ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របថា ការយល់ឃើញនេះពុំមានហេតុផលសមស្របឡើយ។ តាមការសង្កេតឃើញថា ពុំមានភាពគួរឱ្យជឿជាក់ថា សមាជនោះពិតជាបានធ្វើឡើងប្រាកដ

---

[2945] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៨៣ ដល់ ៣៨៧។

[2946] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៥៣ និង*សូមមើលផងដែរ* កថាខណ្ឌ ៧៤០។

[2947] *សូមមើលខាងលើ* កថាខណ្ឌ ១០០៧។

[2948] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩២។

ដែរ ឬយ៉ាងណានោះទេ[2949] ដូច្នេះ អង្គជំនុំជម្រះពុំអាចសន្និដ្ឋានដោយសមហេតុផលអំពីការដឹង ផ្អែកលើមូលដ្ឋាននៃសេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងសមាជនោះបានឡើយ។

១០៨១.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ខៀវ សំផន ប្រហែលជាបានទទួលព័ត៌មានពីកិច្ចប្រជុំជាច្រើនបន្តបន្ទាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានធ្វើឡើងនៅវិហារព្រះកែវមរកតក្នុងខែ ឧសភា ឆ្នាំ ១៩៧៥[2950] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សាក្សី ភី ភួន និងអ្នកជំនាញ Philip SHORT ដែលសក្ខីកម្មរបស់ពួកគាត់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងយកមកសំអាងនោះ បានផ្តល់សក្ខីកម្មថា ការប្រជុំនៅវិហារព្រះកែវមរកត មានការពិភាក្សាអំពីការកែប្រែគោលនយោបាយ ប.ក.ក.[2951]។ ខៀវ សំផន ពុំបានបង្ហាញ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសបែបណានោះទេ ក្នុងការសន្និដ្ឋានថា គាត់បានទទួលព័ត៌មាននេះតាមរយៈការចូលរួមក្នុងកិច្ចប្រជុំទាំងនេះភ្លាមៗបន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលក្នុងពេលនោះឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ។

១០៨២.ចំពោះអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើអង្គហេតុកើតក្រោយការប្រព្រឹត្តបទឧក្រិដ្ឋ បើទោះបីជាការដឹងបទល្មើសក្រោយការប្រព្រឹត្ត (*dolus subsequens*) ពុំគ្រប់គ្រាន់ និងពុំជាប់ពាក់ព័ន្ធទៅនឹងការយល់ឃើញអំពីចេតនាក៏ដោយ[2952] ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសំអាង*ក្នុងចំណោមនោះ*ទៅលើការដឹងបទល្មើសក្រោយការប្រព្រឹត្តក្នុងការសន្និដ្ឋានថា ខៀវ សំផន មានចេតនាតម្រូវសម្រាប់ការទទួលខុសត្រូវ

---

[2949] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៧៧។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤២ ជើងទំព័រ ២៣៣៨។

[2950] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៣ ដល់ ៣៩៥។

[2951] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៤០ ជើងទំព័រ ២៣៣៥ *យោងទៅលើ* កំណត់ហេតុស្តាប់ចម្លើយរបស់ រ៉ចាម គុន *ហៅ* ភី ភួន ឯកសារលេខ E3/24 ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ERN (ភាសាខ្មែរ) 00204069-00204070 ទំព័រ ៤ ដល់ ៥។ ប្រតិចារឹកចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ (Philip SHORT) ឯកសារលេខ E1/190.1 ទំព័រ ៣ ដល់ ៥។ ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ (រ៉ចាម គុន *ហៅ* ភី ភួន) ឯកសារលេខ E1/97.1 ទំព័រ ៥៤ ដល់ ៥៥ និង ៥៨ ដល់ ៥៩។

[2952] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៣៦ ដល់ ៦៤០។

ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម[2953]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចេតនាដែលកើតឡើងក្រោយអង្គហេតុ ពិតជាពុំគ្រប់គ្រាន់ក្នុងការបង្ហាញអំពីចេតនាតម្រូវ ប៉ុន្តែពុំមានការបញ្ជាក់ថា នេះគឺជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងនោះដែរ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងពុំបានចាត់ទុកការដឹងក្រោយអង្គហេតុ ជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំដទៃទៀតក្នុងការកំណត់អំពីបញ្ហា ថាតើ ខៀវ សំផន មានចេតនាតម្រូវនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តនោះ ដែរ ឬយ៉ាងណា។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខៀវ សំផន "បានដឹងអំពីភវនីយភាពខ្ពស់ថា ឧក្រិដ្ឋកម្មនឹងកើតចេញពីការអនុវត្ត[ការផ្លាស់ទីលំនៅប្រជាជន និងគោលនយោបាយកំណត់គោលដៅ]" និងថា "គោលនយោបាយនេះជាក់ស្តែងពុំបានបណ្តាលឱ្យមាន និង/ឬជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងនៅទួលពោធិ៍ជ្រៃ"ឡើយ និងបានផ្អែកការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងចេតនានេះលើអង្គហេតុទាំងអស់នេះ[2954] អាស្រ័យហេតុនេះ អំណះអំណាងនេះរបស់ ខៀវ សំផន ត្រូវបដិសេធចោល។

១០៨៣.អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសត្រង់ចំណុចដែលថា អង្គជំនុំជម្រះបានសន្និដ្ឋានអំពីការដឹង ឬចេតនារបស់ ខៀវ សំផន ចេញពីការយល់ឃើញ ដែលមិនសមហេតុផលថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ ប.ក.ក. ក្នុងខែ មិថុនា ឆ្នាំ១៩៧៤[2955]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរ ដោយបានសន្និដ្ឋានអំពីចេតនា ឬការដឹងរបស់ ខៀវ សំផន ចេញពីវត្តមានរបស់គាត់នៅក្នុងសមាជជាតិពិសេសដែលបានធ្វើឡើងនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ នោះ[2956]។ ទោះជាយ៉ាងណាក្តី ដោយផ្អែកតាមការយល់ឃើញដ៏សមហេតុផលដទៃទៀតរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កំហុសដែលបានបង្ហាញខាងលើ ពុំមានឥទ្ធិពលលើការសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានដឹងជាមុន ក្នុងពេល និង

---

[2953] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៤។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការយោងរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងជើងទំព័រ ២៩៨៩ ទៅលើកថាខណ្ឌ ៧៥៨ ដល់ ៧៥៩ ប្រហែលជាចង់ចង្អុលបង្ហាញទៅលើកថាខណ្ឌ ៩៥៨ ដល់ ៩៥៩ ទាក់ទងទៅនឹង"ការដឹងក្រោយការប្រព្រឹត្តបទឧក្រិដ្ឋ"។

[2954] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៤ ដល់ ៩៩៥។

[2955] *សូមមើលខាងលើ* កថាខណ្ឌ ១០០៨ ដល់ ១០០៩។

[2956] *សូមមើលខាងលើ* កថាខណ្ឌ ១០៨០។

ក្រោយការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរនោះឡើយ។

១០៨៤.ទាក់ទងទៅនឹងបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពិចារណាពាក់ព័ន្ធទៅនឹងចេតនារបស់ ខៀវ សំផន ថា គាត់បានដឹងអំពីភវនីយភាពខ្ពស់អំពីឧក្រិដ្ឋកម្មនោះ[2957] អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានដោះស្រាយរួចរាល់ហើយលើអំណះអំណាងនេះនៅខាងលើ និងបានសន្និដ្ឋានថា អាស្រ័យលើកាលៈទេសៈ និងឧក្រិដ្ឋកម្មចំពោះមុខ ភវនីយភាពខ្ពស់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មអាចជាការពិចារណាមួយដែលជាប់ពាក់ព័ន្ធទៅនឹងការកំណត់ ថាតើជនជាប់ចោទមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្អែកលើការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ដែរ ឬយ៉ាងណា បើទោះបីជា ភវនីយភាពនេះ ពុំច្បាស់លាស់គ្រប់គ្រាន់ក្នុងការបង្ហាញពីចេតនាក៏ដោយ[2958]។ អាស្រ័យហេតុនេះ ដោយផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រូវកំណត់ ថាតើ ខៀវ សំផន មានចេតនាតម្រូវសម្រាប់ឧក្រិដ្ឋកម្មដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាព ដោយផ្អែកលើការទទួលខុសត្រូវក្នុង សហឧក្រិដ្ឋកម្មរួម ដែរ ឬយ៉ាងណា។

១០៨៥.ចំពោះការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បានបង្ហាញច្បាស់ថា ខៀវ សំផន ពិតជាបានប្រព្រឹត្តដោយចេតនាក្នុងការសម្លាប់អ្នកទាំងនោះតាមរយៈការអនុវត្តគោលបំណងរួម ដោយយោងទៅលើការប្រកាសជាសាធារណៈនូវការប្រហារជីវិតអ្នកដែលគេហៅថា"ជនមហាក្បត់ទាំងប្រាំពីររូប"[2959]។

១០៨៦.ទាក់ទងទៅនឹងការសម្លាប់ដទៃទៀត ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មនោះ រួមទាំងភវនីយភាពខ្ពស់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ត្រូវបានទទួលយកភាគច្រើននៅដំណាក់កាលបណ្តឹងសាទុក្ខ។ ជាការកត់សម្គាល់ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកការយល់ឃើញដែលថា ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំមួយនៅមន្ទីរ ប-៥ ក្នុងខែ មេសា ឆ្នាំ ១៩៧៥ ដែលក្នុងពេលនោះ

---

[2957] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៦។

[2958] *សូមមើលខាងលើ* កថាខណ្ឌ ១០៥៤ ដល់ ១០៥៥។

[2959] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១២០។

ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានពិភាក្សា ហើយ ខៀវ សំផន បានគាំទ្រផែនការនេះ[2960]។ ដោយសារកាលៈទេសៈនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ បានកើតឡើង(ក្នុងរយៈពេលដ៏ខ្លីនៅក្នុងរដូវប្រាំងដែលក្តៅបំផុតនោះ) ដូច្នេះបង្ហាញឱ្យឃើញច្បាស់ថា ខៀវ សំផន ពិតជាបានដឹងអំពីភវនីយភាពខ្ពស់នៃការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌនានានៃការជម្លៀសនោះ។ ជាការពិត អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខៀវ សំផន បានទទួលស្គាល់ថា គាត់ក៏បានរំពឹងទុកថា នឹងមានមនុស្សស្លាប់នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ[2961]។ បើទោះបីជាបានដឹងបែបនេះក៏ដោយ ក៏ ខៀវ សំផន នៅតែចូលរួមចំណែកក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួមនេះ ដោយពុំបានជំទាស់ឡើយ ដូច្នេះ បង្ហាញឱ្យឃើញថា គាត់បានយល់ព្រមទទួលយកការស្លាប់របស់ប្រជាជនដែលជាលទ្ធផលនៃការជម្លៀសនោះ។ បន្ថែមលើនេះទៀត ដោយសារកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ គោលបំណងរួមបានរួមបញ្ចូលដោយប្រយោលនូវការរំពឹងទុកថា នឹងមានការប្រើប្រាស់អំពើហិង្សាដល់អាយុជីវិតដោយកងទ័ពដែលទទួលភារកិច្ចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង ហើយពុំមានសញ្ញាណាមួយបង្ហាញថា ខៀវ សំផន ពុំបានដឹងអំពីបញ្ហានេះទេ ដោយសារគាត់បានចូលរួមនៅក្នុងការរៀបចំផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ពីព្រោះ ខៀវ សំផន បានរួមចំណែកក្នុងការអនុវត្តគោលបំណងរួមដោយពុំគិតពីលទ្ធផលនោះ ទើបមានការបង្ហាញឱ្យឃើញច្បាស់លាស់ថា ខៀវ សំផន បានយល់ព្រមទទួលយកលទ្ធភាពនៃការធ្វើមនុស្សឃាតដែលអាចកើតមាន។ សរុបសេចក្តីមក នេះបង្ហាញថា ខៀវ សំផន មានចេតនាតម្រូវដែលជាទម្រង់នៃ*ចេតនាប្រយោល* ទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនានា ព្រមទាំងការសម្លាប់ជនស៊ីវិល និង ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅក្នុងបរិបទនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

១០៨៧.មានការបង្ហាញផងដែរថា ខៀវ សំផន មានចេតនាផ្ទាល់ក្នុងការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងបញ្ហានេះ ដោយសារនៅក្នុងកាលៈទេសៈនោះ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បានបំពេញតាមធាតុផ្សំទាំងអស់ចំពោះបទឧក្រិដ្ឋនេះ។ បន្ថែមលើនេះទៀត ការជំទាស់របស់ ខៀវ សំផន ត្រូវបានបដិសេធចោលនៅដំណាក់កាលបណ្តឹងសាទុក្ខទាក់ទងទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានប្រព្រឹត្តដោយចេតនារើសអើងទាក់ទងទៅនឹងការ

[2960] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤៥។

[2961] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤៦ និង ៧៨៥ យោងទៅលើប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ ខៀវ សំផន ឯកសារលេខ E3/4040 គ្មានកាលបរិច្ឆេទ។

ជម្លៀសប្រជាជនដំណាក់កាលទីមួយ ដូច្នេះ ពិតជាបង្ហាញឱ្យឃើញពីចេតនាតម្រូវសម្រាប់បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រាកដមែន[2962]។

១០៨៨.ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះតុលាការកំពូលរំឮកថា អង្គជំនុំជម្រះបានទទួលយកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការស្លាប់ដោយសារលក្ខខណ្ឌនានានៃការផ្លាស់ទីលំនៅប្រជាជន និងការសម្លាប់មួយករណី[2963]។ ទោះជាយ៉ាងណាក្តី បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើនេះ គឺជាបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចកែប្រែប្រភេទបទល្មើសទៅជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2964]។ អាស្រ័យហេតុនេះ ជាការចាំបាច់ត្រូវកំណត់ ថាតើ ផ្អែកតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនោះ មានការបង្ហាញឱ្យឃើញថា ខៀវ សំផន មានចេតនាផ្ទាល់ឬចេតនាប្រយោលក្នុងការសម្លាប់តាមរយៈការអនុវត្តគោលបំណងរួមដែរ ឬយ៉ាងណា។

១០៨៩.ដូចគ្នាទៅនឹងករណីរបស់ នួន ជា[2965]ដែរ ពុំមានការយល់ឃើញណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា ខៀវ សំផន មានគោលបំណងធ្វើឱ្យជនរងគ្រោះស្លាប់តាមរយៈការអនុវត្តការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ឬបានដឹងថា ការស្លាប់នឹងកើតមានជាក់លាក់ឡើយ។ អាស្រ័យហេតុនេះ ពុំអាចនិយាយបានថា ខៀវ សំផន បានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការសម្លាប់នោះទេ។ ទោះជាយ៉ាងណាក្តី ដោយបានដឹងអំពីលទ្ធផលនៃការជម្លៀសប្រជាជនដំណាក់កាលទីមួយ និងបានចូលរួមនៅក្នុងការសម្រេច និងការរៀបចំផែនការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំដែលជាផ្នែកនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខៀវ សំផន បានដឹងថា អាចនឹងមានការស្លាប់ដោយសារលទ្ធផលនៃការអនុវត្តការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ហើយគាត់ព្រមទទួលយកនូវលទ្ធផលនេះ។ ដូច្នេះ ខៀវ សំផន បានប្រព្រឹត្ត*ដោយចេតនាប្រយោល*ទាក់ទងទៅនឹងអំពើមនុស្សឃាតនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។

---

[2962] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៩៥។

[2963] *សូមមើលខាងលើ* កថាខណ្ឌ ៥៥០។

[2964] *សូមមើលខាងលើ* កថាខណ្ឌ ៥៦០ ដល់ ៥៦២។

[2965] *សូមមើលខាងលើ* កថាខណ្ឌ ១០៦៤ *ជាអាទិ៍*។

01358613



១០៩០.អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា ដោយផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញឱ្យឃើញថា ខៀវ សំផន បានប្រព្រឹត្តដោយចេតនាផ្ទាល់នូវអំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការអនុវត្តគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដោយហេតុថា ការផ្លាស់ទីលំនៅប្រជាជនដែលជាចំណុចសំខាន់នៃគោលបំណងរួមនេះ ត្រូវបានចាត់ជាឧក្រិដ្ឋកម្មនៅក្នុងកាលៈទេសៈនោះ[2966]។

១០៩១.ទាក់ទងទៅនឹងបទធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីការយល់ឃើញរបស់ខ្លួនថា ធាតុផ្សំនៃបទឧក្រិដ្ឋនេះ ពុំត្រូវបានបង្ហាញទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរទេ។ អាស្រ័យហេតុនេះ ចេតនារបស់ ខៀវ សំផន ពុំចោទជាបញ្ហាឡើយ ហើយការបង្ហាញនេះ ក៏ដូចគ្នាទៅនឹងការសម្លាប់នៅទួលពោធិ៍ជ្រៃផងដែរ ដោយហេតុថា អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ផ្អែកលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គោលនយោបាយកំណត់គោលដៅពុំត្រូវបានចាត់ទុកថា បានបង្ហាញដោយសមហេតុផលឡើយ។

១០៩២.សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា ចេតនាតម្រូវពុំត្រូវបានបង្ហាញ។

## ៤.ង.២.គោលការណ៍នីត្យានុកូលភាពពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវ

១០៩៣.ទាក់ទងទៅនឹងអំណះអំណាងអំពីភាពអាចដឹងជាមុនថា ជាបទល្មើស និងមានច្បាប់ចែងអំពីទម្រង់នៃការទទួលខុសត្រូវដែល ខៀវ សំផន ត្រូវបានប្រកាសដាក់ពិរុទ្ធភាពនោះ[2967] អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញខាងលើរួចហើយថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា នៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទ បុគ្គលម្នាក់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារការរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងល្មើសរួម។ ការយល់ឃើញនេះបានផ្អែកជាពិសេសលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ[2968]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជនជាប់ចោទអាចយល់ដឹងជាមុនបានថា ទម្រង់នៃការទទួលខុសត្រូវនេះ មានច្បាប់

[2966] *សូមមើលខាងលើ* កថាខណ្ឌ ៨៦៣ *ជាអាទិ៍*។

[2967] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៥ ដល់ ១០៧។

[2968] *សូមមើលខាងលើ* កថាខណ្ឌ ៧៦៨។

ចែង និងជាបទល្មើស ដែលត្រូវដាក់អ្នកបានចូលរួមក្នុងគោលបំណងឧក្រិដ្ឋរួម និងរួមចំណែកក្នុងការអនុវត្ត ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលជា ឬពាក់ព័ន្ធទៅនឹងគោលបំណងរួមនេះ ពោលគឺដោយសារភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនេះ។ ខៀវ សំផន ពុំអាចអះអាងបានថា ខ្លួនពុំអាចដឹងជាមុនថា នឹងត្រូវដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការចូលរួមក្នុងសកម្មភាពដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនោះឡើយ។

១០៩៤.ចំពោះអំណះអំណាងដែលពាក់ព័ន្ធទៅនឹងភាពអាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើសចំពោះអំពើអកម្មដែលជាមូលដ្ឋានក្នុងការដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួមនោះ[2969] អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឃ្លាថា "អំពើសកម្ម និងអកម្ម"តែក្នុងន័យទូទៅប៉ុណ្ណោះ និងពុំមានចំណុចណាមួយនៅក្នុងសាលក្រមរបស់ខ្លួនដែលបានសំអាងទៅលើអំពើអកម្មរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានេះឡើយ[2970]។ ហេតុដូច្នេះ អំណះអំណាងនេះត្រូវបដិសេធចោល។

១០៩៥.ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានដឹងជាមុនគ្រប់គ្រាន់ថា គាត់អាចនឹងត្រូវដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម ដូចបានបញ្ជាក់ខាងលើ។

## ៤.ង.៣.ទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ

១០៩៦.អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា និង ខៀវ សំផន ទទួលខុសត្រូវពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានដូចជា បទសម្លាប់រង្គាល បទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ដោយផ្អែកលើការទទួលខុសត្រូវចំពោះការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ និងការបញ្ជា (នួន ជា តែម្នាក់) នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ និងការទទួលខុសត្រូវរបស់ថ្នាក់លើ(នួន ជា តែម្នាក់)[2971]។ ប៉ុន្តែ ដោយផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានសម្រេចដាក់ពិរុទ្ធភាពពីបទសម្លាប់រង្គាលតែប៉ុណ្ណោះ អង្គជំនុំ

---

[2969] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១០៦។

[2970] *សូមមើលខាងលើ* កថាខណ្ឌ ៩៨៦។

[2971] *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨៨៣, ៨៨៦, ៨៨៨, ៨៩១, ៨៩៨ (នួន ជា) និង ១០០៣, ១០០៥, ១០០៧, ១០១៣, ១០១៥, ១០២២ (ខៀវ សំផន)។

01358615



ជម្រះបានរកឃើញថា ការទទួលខុសត្រូវទាក់ទងទៅនឹងបទឧក្រិដ្ឋដទៃទៀតស្ថិតក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម[2972]។ ទាក់ទងទៅនឹងបទមនុស្សឃាត អង្គជំនុំជម្រះបានយល់ឃើញថា បទឧក្រិដ្ឋនេះបានស្រូបបញ្ចូលទៅក្នុងបទសម្លាប់រង្គាល[2973]។

១០៩៧.ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទទទួលខុសត្រូវពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា បទសម្លាប់រង្គាល បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយផ្អែកលើការទទួលខុសត្រូវចំពោះការរៀបចំផែនការ ការបញ្ជា (នួន ជា តែម្នាក់) ការញុះញង់ ការជួយនិងជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ (នួន ជា តែម្នាក់) ប៉ុន្តែបានសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើមូលដ្ឋាននេះពីបទសម្លាប់រង្គាលតែប៉ុណ្ណោះ ដោយសារ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថា ទទួលខុសត្រូវទាក់ទងទៅនឹងបទឧក្រិដ្ឋដទៃទៀតដោយផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម[2974]។

១០៩៨. នួន ជា និង ខៀវ សំផន បានលើកទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខជាច្រើនទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវដទៃទៀត ។

---

[2972] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤០, ៩៤២ (នួន ជា) និង ១០៥៣ ដល់ ១០៥៤ (ខៀវ សំផន)។

[2973] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៥៧។

[2974] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩០៤, ៩០៧, ៩០៩, ៩១២, ៩១៧, ៩៤០, ៩៤២ (នួន ជា) និង ១០២៩ ដល់ ១០៣០, ១០៣២, ១០៣៦, ១០៣៨, ១០៥៣ ដល់ ១០៥៤ (ខៀវ សំផន)។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញឱ្យឃើញពីភាពខុសគ្នាពាក់ព័ន្ធទៅនឹងបញ្ហានេះរវាងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃ"ការផ្លាស់ទីលំនៅដោយបង្ខំ" និង"ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ"ដែលអង្គជំនុំជម្រះបានរកឃើញថា ស្ថិតក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ I ជាមួយនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃ"ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ"ដែលអង្គជំនុំជម្រះបានរកឃើញថា ពុំស្ថិតក្នុងសហឧក្រិដ្ឋកម្មនេះ។ អង្គជំនុំជម្រះបានរកឃើញថា នួន ជា និង ខៀវ សំផន ទទួលខុសត្រូវទាក់ទងទៅនឹងចំណុចទីពីរនេះដោយសារបានរៀបចំផែនការជាដើម។ ដោយសារអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត (*សូមមើលខាងលើ* កថាខណ្ឌ ៥៧២ *ជាអាទិ៍*) អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបង្ហាញឱ្យឃើញពីភាពខុសគ្នានេះពុំមានភាពចាំបាច់ឡើយ។ ផ្ទុយទៅវិញ ការទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងៗទៀតគប្បីបានផ្អែកលើតែការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ I ប៉ុណ្ណោះ។

១០៩៩.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានតម្កល់ការទទួលខុសត្រូវរបស់ជនជាប់ចោទដោយផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទាក់ទងទៅនឹងអំពើមនុស្សឃាត[2975] អំពើអមនុស្សធម៌ផ្សេងៗទៀត និងអំពើធ្វើទុក្ខបុកម្នេញពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ រួមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត និងអំពើមនុស្សឃាតទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការពុំសមស្របក្នុងការពិចារណាលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវដទៃទៀត ដោយសារ តាមការពិនិត្យឡើងវិញ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះពុំអាចមោឃៈសាលក្រម ឬបណ្តាលឱ្យមានភាពមិនយុត្តិធម៌ឡើយ[2976]។ នេះដោយសារពុំជាប់ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃការយល់ឃើញផ្នែកអង្គច្បាប់ និងអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវទាំងនោះ ដូច្នេះ ការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទឧក្រិដ្ឋទាំងនោះដោយផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម ទុកជាបានការ។

១១០០.ផ្ទុយទៅវិញ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ការទទួលខុសត្រូវនេះពុំស្ថិតក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមនោះទេ ពីព្រោះអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅ(ដែលជាគោលបំណងឧក្រិដ្ឋរួម) ពុំត្រូវបានបង្ហាញដោយសមហេតុផលឡើយ។ ហេតុដូច្នេះ ជាទ្រឹស្តី ការទទួលខុសត្រូវអាចកើតចេញពីទម្រង់ដទៃទៀតបាន។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ដើម្បីផ្តល់ការយល់ឃើញអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន និង នួន ជា ក្នុងការរៀបចំផែនការ ការញុះញង់ ការបញ្ជា (នួន ជា តែម្នាក់) និង ការជួយនិងជំរុញ ព្រមទាំងការទទួលខុសត្រូវរបស់ថ្នាក់លើ (នួន ជា តែម្នាក់) អង្គជំនុំជម្រះសាលាដំបូងបានផ្អែកយ៉ាងជាក់លាក់ទៅលើការយល់ឃើញផ្នែកអង្គហេតុដែលជាមូលដ្ឋានសម្រាប់សន្និដ្ឋានទាក់ទងទៅនឹងគោលនយោបាយកំណត់គោលដៅ ដែលត្រូវបាន

---

[2975] ដោយសារអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា បទសម្លាប់រង្គាលពុំត្រូវបានបង្ហាញឱ្យឃើញទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ (*សូមមើលខាងលើ* កថាខណ្ឌ ៥៤១) បទមនុស្សឃាតក៏ពុំត្រូវបានស្របបញ្ចូលទៅក្នុងបទនេះបន្តទៅទៀតដែរ ហើយការទទួលខុសត្រូវមានអត្ថិភាពដោយផ្អែលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ I។

[2976] *សូមមើល* វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

បដិសេធចោលនៅដំណាក់កាលបណ្តឹងសាទុក្ខ។ ជាការកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកក្នុងកម្រិតច្បាស់លាស់ទៅលើគោលនយោបាយកំណត់គោលដៅដែលមេដឹកនាំ ប.ក.ក. បានបង្កើតឡើង[2977]។

១១០១.អាស្រ័យហេតុនេះ ដោយពិចារណាលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលលើកឡើងដោយ នួន ជា និង ខៀវ សំផន ពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហានេះ ការទទួលខុសត្រូវទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃពុំអាងផ្អែកលើការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ ឬការទទួលខុសត្រូវរបស់ថ្នាក់លើបានឡើយ។ ដូច្នេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបញ្ហានេះត្រូវបដិសេធចោល។

## ៤.ច.ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការប្រកាសទោសជនជាប់ចោទ និងផលប៉ះពាល់នៃកំហុសលើការប្រកាសទោសនេះ

១១០២.ដូចបានកត់សម្គាល់ខាងដើម អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា បទសម្លាប់រង្គាល(រួមបញ្ចូលបទធ្វើមនុស្សឃាត) បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងបទអំពើអមនុស្សធម៌ផ្សេងៗទៀត(រួមមានការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ) ហើយអង្គជំនុំជម្រះបានសម្រេចផ្តន្ទាទោសជនជាប់ចោទម្នាក់ៗដាក់ពន្ធនាគារអស់មួយជីវិត[2978]។ នៅក្នុងការប្រកាសទោស អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកត្តាផ្សេងៗមានដូចជា៖ ភាពធ្ងន់ធ្ងរនៃបទល្មើស ដោយផ្អែកលើចំនួនជនរងគ្រោះយ៉ាងច្រើន រួមទាំង"វិសាលភាពទូលំទូលាយផ្នែកទីតាំងភូមិសាស្ត្រ និងពេលវេលានៃការរងគ្រោះ"[2979] និងស្ថានទម្ងន់ទោស រួមបញ្ចូលតួនាទីរបស់ នួន ជា និង ខៀវ សំផន នៅក្នុងរដ្ឋអំណាចដែលពួកគាត់បានរំលោភបំពាននៅក្នុងការរួមចំណែកដល់ការប្រព្រឹត្តបទឧក្រិដ្ឋ និងការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម[2980] និងក្នុងនាមជាបុគ្គល"ដែលមានចំណេះដឹងខ្ពង់ខ្ពស់"[2981]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពុំ

---

[2977] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩១៨ ដល់ ៩៣១, ៩៣៦ ដល់ ៩៣៨ (នួន ជា) និង ១០៣៩ ដល់ ១០៥១ (ខៀវ សំផន)។

[2978] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧៤, ១១០៥, ១១០៧។

[2979] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧៥។

[2980] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៨៤ និង ១០៨៧។

[2981] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៨៦ និង ១០៨៩។

ពិចារណាពីស្ថានសម្រាលទោស ដូចជាការសោកស្តាយរបស់ នួន ជា[2982] បញ្ហាសុខភាព និងវ័យចាស់ជរា[2983] និងសក្ខីកម្មលើអត្តចរិតល្អរបស់ ខៀវ សំផន នោះឡើយ[2984]។

១១០៣.ខៀវ សំផន បានលើកអំណះអំណាងមួយចំនួនប្រឆាំងនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនេះថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ដែលស្តែងចេញឱ្យឃើញពីការប្រើប្រាស់ឆន្ទានុសិទ្ធិ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញពីកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការប្រកាសទោស និងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យពិចារណាលើកត្តាទាំងនេះ[2985]។

១១០៤.បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនថា ជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពពុំត្រឹមត្រូវ ពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ និង បទមនុស្សឃាត បទសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញកំហុសមួយចំនួននៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបទឧក្រិដ្ឋជាក់លាក់ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ។

១១០៥.ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវវាយតម្លៃលើការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសទាក់ទងទៅនឹងការប្រកាសទោសដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់មកនឹងត្រូវកំណត់ ថាតើផ្អែកតាមខ្លឹមសារនៃការយល់ឃើញដែលមានកំហុសនេះ ចាំបាច់ត្រូវកែប្រែការប្រកាសទោស

[2982] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៩២ និង ១០៩៣, ១០៩៦។

[2983] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៩៥ និង ១០៩៨។

[2984] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៩៩ ដល់ ១១០៣។

[2985] សារណាតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦២៨ ដល់ ៦៣០។

ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនោះ ដែរ ឬយ៉ាងណា[2986]។ ទោះជាយ៉ាងនេះក្តី ជាដំបូង អង្គជំនុំជម្រះនឹងត្រូវពិភាក្សាលើបទដ្ឋានជាធរមានស្តីពីការពិនិត្យឡើងវិញ។

## ៤.ច.១.បទដ្ឋាននៃការពិនិត្យឡើងវិញ

១១០៦.វិធាន ៩៨ នៃវិធានផ្ទៃក្នុង មាត្រា ៣៩ ថ្មី នៃច្បាប់ អ.វ.ត.ក និងមាត្រា ១០ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានកំណត់បទប្បញ្ញត្តិជាធរមានចំពោះការប្រកាសទោស[2987]។ បន្ថែមលើនេះទៀត វិធាន ១០៤ នៃវិធានផ្ទៃក្នុង បានអនុញ្ញាតឱ្យធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការប្រកាសទោសនេះ[2988]។

១១០៧.ទាក់ទងទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងការប្រកាសទោស អង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី ឌុច* (001-F28) បានយោងទៅលើបទដ្ឋាននេះដោយយល់ស្របជាមួយ[2989] នឹងការអនុវត្តបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY ក្នុង*រឿងក្តី D. Milošević* នៅក្នុងសេចក្តីដកស្រង់នៃសាលដីកាពាក់ព័ន្ធដូចខាងក្រោមថា៖

> ដោយសារកាតព្វកិច្ចរបស់ខ្លួនកំណត់ការផ្តន្ទាទោសនីមួយៗ ឱ្យស្របតាមកាលៈទេសៈរបស់ជនជាប់ចោទ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ អង្គជំនុំជម្រះសាលាដំបូងត្រូវបានផ្តល់នូវឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយក្នុងការសម្រេចប្រកាសទោសសមស្រប ដូចជាការសម្រេចអំពីទម្ងន់ ទៅលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស។ តាមវិធានទូទៅ អង្គជំនុំជម្រះតុលាការកំពូលនេះ ពុំត្រូវកែប្រែការប្រកាសទោសណាមួយឡើយ ដរាបណាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសដែលស្តែងចេញឱ្យឃើញពីការប្រើប្រាស់ឆន្ទានុសិទ្ធិ ឬពុំបានគោរពតាមច្បាប់ជាធរមាន។ ម្ចាស់បណ្តឹងសាទុក្ខមានកាតព្វកិច្ចក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់ទៅលើការពិចារណានានាដែលពុំជាប់ពាក់ព័ន្ធ ឬពុំចាំបាច់ ពុំបានផ្តល់ទម្ងន់ណាមួយ ឬគ្រប់គ្រាន់ទៅលើការពិចារណាដែលជាប់ពាក់ព័ន្ធ បានប្រព្រឹត្ត

---

[2986] *សូមមើលទូទៅ* សាលដីកា*រឿងក្តី Seromba* (ICTR) កថាខណ្ឌ ២២៦ (ជាឧទាហរណ៍ដែលកំហុសទាក់ទងទៅនឹងការប្រកាសទោសត្រូវបានរកឃើញនៅដំណាក់កាលបណ្តឹងសាទុក្ខ បានបណ្តាលឱ្យមានការកែប្រែការប្រកាសទោសនេះ)។

[2987] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៣៤៨ (សម្រាប់ការអនុវត្តច្បាប់របស់ អ.វ.ត.ក. ចំពោះករណីពិសេស ដែលខុសពីក្រមព្រហ្មទណ្ឌកម្ពុជាទាក់ទងទៅនឹងវិធានស្តីពីការប្រកាសទោសជាធរមាន)។

[2988] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៣៥៣។

[2989] សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៣៥៤។

កំហុសច្បាស់លាស់នៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងអង្គហេតុ ឬថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល ឬមិនយុត្តិធម៌យ៉ាងច្បាស់ដែលធ្វើឱ្យ អង្គជំនុំជម្រះតុលាការកំពូលអាចសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងពិតជាពុំបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនបានសមស្របឡើយ[2990]។

១១០៨.អង្គជំនុំជម្រះតុលាការកំពូលនឹង ត្រូវអនុវត្តបទដ្ឋាននេះនៅក្នុងរឿងក្តីចំពោះមុខ ក្នុងការពិចារណាលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ទាក់ទងទៅនឹងការប្រកាសទោសដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច។

១១០៩.បន្ថែមលើនេះ ស្របតាមយុត្តិសាស្ត្ររបស់ខ្លួនផ្ទាល់ ក៏ដូចជារបស់តុលាការឧក្រិដ្ឋកម្មមិនអចិន្ត្រៃយ៍នានា នៅពេលអង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធការដាក់ពិរុទ្ធភាពមួយ ឬច្រើនដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើសម្រាប់ធ្វើការប្រកាសទោសណាមួយនោះ អង្គជំនុំជម្រះតុលាការកំពូលមានសមត្ថកិច្ចក្នុងការសម្រេចប្រកាសទោសមួយផ្សេង ឬប្រកាសទោសដដែលសម្រាប់ការដាក់ពិរុទ្ធភាពដែលនៅសេសសល់ផ្សេងទៀត។ ការធ្វើដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលអាចកែប្រែការប្រកាសទោសដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច[2991]។

## ៤.ច.២.ការកំណត់អំពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន

១១១០.នៅក្នុងផ្នែកស្តីពី"គោលការណ៍ និងកត្តាពាក់ព័ន្ធនៃការប្រកាសទោស" អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះបានព្យាយាម"បង្ហាញដល់ជនរងគ្រោះដែលនៅរស់រានមានជីវិត ក្រុមគ្រួសាររបស់ពួកគេ សាក្សី និងសាធារណជនទូទៅថា ច្បាប់ត្រូវបានយកមកអនុវត្តយ៉ាងពិតប្រាកដ ហើយអនុវត្តចំពោះជនគ្រប់រូប ដោយមិនគិតអំពីបុណ្យស័ក្តិ ឬឋានៈអ្វីឡើយ"[2992]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងទៅលើការដាក់ទណ្ឌកម្ម(ដែលខុសពីការសងសឹក) និងការធ្វើឱ្យញញើត ដែលជាគោលបំណងនៃការប្រកាសទោស[2993]។ ខៀវ

---

[2990] សាលដីកា *រឿងក្តី D.Milošević* (ICTY) កថាខណ្ឌ ២៩៧(ជើងទំព័រលុបចោល)។ *សូមមើលផងដែរ* សាលដីកា *រឿងក្តី Mrkšić និង Šljivančanin* កថាខណ្ឌ ៣៥៣។ សាលដីកា *រឿងក្តី Martić* កថាខណ្ឌ ៣២៦។ សាលដីកា *រឿងក្តី Strugar* កថាខណ្ឌ ៣៣៦ ដល់ ៣៣៧។

[2991] សាលដីកា *រឿងក្តី Blaškić* (ICTY) កថាខណ្ឌ ៦៨០ (ជើងទំព័រលុបចោល)។

[2992] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៦៧។

[2993] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៦៧។

សំផន បានអះអាងថា នៅក្នុងការកំណត់គោលការណ៍ទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងពុំត្រឹមត្រូវនូវសារៈសំខាន់នៃការផ្តន្ទាទោស និងការធ្វើឱ្យញញើត[2994]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការអះអាងនេះពុំមានលក្ខណៈច្បាស់លាស់ និងត្រូវបដិសេធចោលតែម្តង។ ពុំមានការបង្ហាញណាមួយផងដែរថា ការលើកឡើងរបស់អង្គជំនុំជម្រះនោះ គឺជាការបង្ហាញឱ្យឃើញពីភាពលម្អៀងប្រឆាំងនឹងរូបគាត់ឡើយ[2995]។

១១១១.ខៀវ សំផន បានអះអាងថា ទាក់ទងទៅនឹងអំពីតួនាទីរបស់គាត់នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ[2996] អង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាលើការយល់ឃើញពីដំបូងរបស់ខ្លួនទាក់ទងទៅនឹងតួនាទីរបស់គាត់ដែលមានកម្រិតតិចតួច និងខ្វះសិទ្ធិអំណាចក្នុងការចេញបទបញ្ជា"ដែលគួរតែទទួលទោសស្រាលបំផុត"[2997]។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា តាមការពិនិត្យលើការដាក់ទោសរបស់តុលាការ ICTY និងតុលាការយោធាអន្តរជាតិ (IMT) បានបង្ហាញឱ្យឃើញថា ការផ្តន្ទាទោសធ្ងន់ធ្ងរបំផុត គប្បីត្រូវដាក់ទៅលើអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនោះ[2998]។

១១១២.អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ពុំបានបង្ហាញពីកំហុសណាមួយ ឬភាពផ្ទុយគ្នានៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ កថាខណ្ឌនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែល ខៀវ សំផន បានយោងទៅលើនោះ(គ្មានការពន្យល់បន្ថែម)[2999] ពុំបានបង្ហាញពីការមិនពិចារណាលើតួនាទីរបស់គាត់ ពាក់ព័ន្ធទៅនឹងការសម្រេចប្រកាសទោសឡើយ។ ទាក់ទងទៅនឹងគោលការណ៍ដែលថា ការផ្តន្ទាទោសធ្ងន់ធ្ងរ ត្រូវតែដាក់ទៅលើអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោសសមស្របជានិច្ចកាលនឹងត្រូវកំណត់ដោយផ្អែកលើអង្គហេតុនៃរឿងក្តីជាក់លាក់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទនីមួយៗ។ ការប្រៀបធៀបទោសដែលបាន

---

[2994] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៤៧។

[2995] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៤៨។

[2996] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៨០។

[2997] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥០។

[2998] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥១។

[2999] *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ជើងទំព័រ ១៣៤៨ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៨០ ធៀបជាមួយនឹងកថាខណ្ឌ ២០៣, ២៣០, ៥៧៨ និង ៥៨១។

សម្រេចដោយតុលាការឧក្រិដ្ឋកម្មដទៃទៀតចំពោះរឿងក្តីខុសៗគ្នានោះ ជាការពុំសមស្របក្នុងការបង្ហាញថា ជាកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូងក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីដាក់ទោសសមស្របណាមួយឡើយ។

១១១៣.ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរំលោភតួនាទីក្នុងរដ្ឋអំណាចរបស់គាត់ បង្កើតបានជាស្ថានទម្ងន់ទោស និងបានអះអាងថា តួនាទីក្នុងរដ្ឋអំណាចរបស់គាត់ពុំចាត់ជាស្ថានទម្ងន់ទោសដោយស្វ័យប្រវត្តិនោះឡើយ និងថា តួនាទីរបស់គាត់ត្រឹមតែជានិមិត្តរូបប៉ុណ្ណោះ[3000]។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងនោះឡើយ។ យោងតាមយុត្តិសាស្ត្ររបស់តុលាការ ICTY ឋានៈខ្ពស់នៅក្នុងផ្នែកយោធា ឬនយោបាយ ឬតួនាទីក្នុងរដ្ឋអំណាច ឬក្នុងជួរថ្នាក់ដឹកនាំ *ជាធម្មតា* ពុំអាចចាត់ជាស្ថានទម្ងន់ទោសបានឡើយ[3001]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងមាន"ឆន្ទានុសិទ្ធិក្នុងការលើកយកឋានៈខ្ពស់ តួនាទីក្នុងរដ្ឋអំណាច ឬតួនាទីជាថ្នាក់ដឹកនាំរបស់ជននោះ មកធ្វើជាស្ថានទម្ងន់ទោសបាន"[3002]។ ជាពិសេស នៅពេលបុគ្គលនោះបាន*ប្រើប្រាស់*តួនាទីទាំងនេះក្នុងការបង្កើតគោលបំណងល្មើស ឬរំលោភតួនាទីទាំងនេះ នោះទើបចាត់ជាស្ថានទម្ងន់ទោស។ ដូច្នេះ អ្វីដែលសំខាន់ គឺថាតើសិទ្ធិអំណាចនេះត្រូវបានប្រើប្រាស់ក្នុងលក្ខណៈបែបណាខ្លះ។ នៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការយល់ឃើញរបស់ខ្លួនទៅលើការរំលោភអំណាចរបស់ ខៀវ សំផន ដោយសារ"គាត់បានរួមចំណែកនៅក្នុង បទឧក្រិដ្ឋ ដែលរួមមាន ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម [ដែល] ត្រូវបានធ្វើឡើងតាមរយៈតួនាទីផ្លូវការរបស់គាត់ជាច្រើនមានដូចជា ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សមាជិកនៃមន្ទីរ ៨៧០ ប្រធានគណៈប្រធានរដ្ឋ និងជាកម្មាភិបាលថ្នាក់ខ្ពស់បំផុតនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា"[3003]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលដែលថា ការរួមចំណែកនេះ គឺជាការរំលោភតួនាទីរបស់គាត់ក្នុងរដ្ឋអំណាច និងឥទ្ធិពលប្រាកដមែន។

---

[3000] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥៣ យោងទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៨៧។

[3001] *សូមមើលឧ.* សាលដីកា*រឿងក្តី Deronjć* កថាខណ្ឌ ៦៧។ សាលដីកា*រឿងក្តី Babić* លើបណ្តឹងសាទុក្ខប្រឆាំងនឹងការប្រកាសទោស (ICTY) កថាខណ្ឌ ៨០។

[3002] សាលដីកា*រឿងក្តី Babić* លើបណ្តឹងសាទុក្ខប្រឆាំងនឹងការប្រកាសទោស (ICTY) កថាខណ្ឌ ៨០។

[3003] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៨៧។

១១១៤.ខៀវ សំផន ក៏បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូង"បានរំលោភលើគោលការណ៍នីត្យានុកូលភាពនៅក្នុងការចាត់ទុកកម្រិតនៃការអប់រំខ្ពស់របស់គាត់ថាជាស្ថានទម្ងន់ទោស" ដោយសារបញ្ហានេះ"ពុំមានចែងនៅក្នុងច្បាប់អន្តរជាតិ ឬច្បាប់កម្ពុជាឡើយ"[3004]។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ ដោយសារពុំបានបង្ហាញពីកំហុសនៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិ និងជាការសមហេតុផលក្នុងការសន្និដ្ឋានថា កម្រិតនៃការអប់រំខ្ពស់របស់ ខៀវ សំផន អាចធ្វើឱ្យគាត់យល់ដឹង និងគិតឃើញពីផលវិបាកអាក្រក់នៃការរួមចំណែករបស់គាត់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋបាន។ អំណះអំណាងរបស់ ខៀវ សំផន ពុំត្រឹមត្រូវ ដោយហេតុថា តុលាការនានា រួមទាំងតុលាការឧក្រិដ្ឋកម្មផងនោះ បានចាត់ទុកកម្រិតនៃការអប់រំរបស់ជនជាប់ចោទ ជាកត្តាស្ថានទម្ងន់ទោស[3005]។ អង្គជំនុំជម្រះតុលាកាកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការចាត់ទុកប្រវត្តិនៃការអប់រំរបស់ ខៀវ សំផន ថាជាកត្តាស្ថានទម្ងន់ទោសឡើយ។

១១១៥.ខៀវ សំផន ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានពិចារណាលើអត្តចរិតល្អរបស់គាត់ ដែលនេះជាការផ្ទុយទៅនឹងការបញ្ជាក់របស់អង្គជំនុំជម្រះដែលថា ខ្លួននឹងពិចារណាលើគ្រប់ស្ថានសម្រាលទោសទាំងអស់[3006]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកអំណះអំណាងនេះថា គ្មានមូលដ្ឋាន ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាសក្ខីកម្មរបស់សាក្សីទាក់ទងទៅនឹងអត្តចរិតរបស់ ខៀវ សំផន រួចហើយ[3007] និងបានសន្និដ្ឋានថា ខៀវ សំផន "អាចធ្វើអំពើល្អជាមួយភរិយារបស់គាត់ និងសន្តានចិត្តល្អចំពោះប្រជាជនក្នុងករណីមួយចំនួន"។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "កត្តាទាំងនេះ មិនមែនជាផ្នែកសំខាន់អាចសម្រាលទោសឧក្រិដ្ឋចំពោះភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនានាដែល ខៀវ សំផន ត្រូវបានរកឃើញថា មានពិរុទ្ធភាពនោះឡើយ ហើយនឹងពុំត្រូវផ្តល់តម្លៃឱ្យផងដែរ"[3008]។ បើទោះបីចំណុចនេះពុំមាននៅក្នុងផ្នែកនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី"ស្ថានសម្រាលទោស"ក៏ពិតមែន ប៉ុន្តែ នៅក្នុងផ្នែកបន្ទាប់ស្តីពី"សាក្សីអត្តចរិត"បានបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអត្តចរិតរបស់

---

[3004] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥៤។

[3005] សាលដីកា *រឿងក្តី Hadžihasanović និង Kubura* (ICTY) កថាខណ្ឌ ៣២៨ (ជើងទំព័រលុបចោល)។ *សូមមើលផងដែរ* សាលក្រម *រឿងក្តី Stakić* (ICTY) កថាខណ្ឌ ៩១៥។ សាលក្រម *រឿងក្តី Brđanin* (ICTY) កថាខណ្ឌ ១១១៤។ សេចក្តីសម្រេចស្តីពីការប្រកាសទោស *រឿងក្តី Lubanga* (ICC) កថាខណ្ឌ ៥៦។

[3006] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥៥ ដល់ ៦៥៧។

[3007] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៩៩ ដល់ ១១០២។

[3008] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១១០៣។

គាត់ដែលជាស្ថានម្រាលទោសមានសក្តានុពលនោះផងដែរ។ ទាក់ទងទៅនឹងអំណះអំណាងរបស់ ខៀវ សំផន ដែលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផ្ទុយគ្នា[3009] ពីព្រោះថា អង្គជំនុំជម្រះបាននិយាយថា គាត់មាន"អត្តចរិតល្អ" និងនៅកន្លែងផ្សេងទៀតយល់ឃើញថា អត្តចរិតរបស់គាត់"គួរឱ្យទុកចិត្ត និងគួរឱ្យគោរព"[3010]នោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភាពផ្ទុយគ្នានោះឡើយ ហើយជាក់ស្តែងបុគ្គលម្នាក់គួរឱ្យទុកចិត្ត និងគួរឱ្យគោរព ប៉ុន្តែ មិនធានាថា មានអត្តចរិតល្អនោះទេ។

១១១៦.ជាលទ្ធផល ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ទាក់ទងទៅនឹងការប្រកាសទោសត្រូវបដិសេធចោល។

## ៤.ច.៣.ផលប៉ះពាល់នៃការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីការប្រកាសទោស

១១១៧.អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្តន្ទាទោសជនជាប់ចោទម្នាក់ៗ ឱ្យជាប់ពន្ធនាគារអស់មួយជីវិតទាក់ទងទៅនឹងការសម្រេចដាក់ពិរុទ្ធភាពទាំងអស់ ពីបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំបានកំណត់ទោសសម្រាប់បទឧក្រិដ្ឋនីមួយៗឡើយ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះបានយល់ឃើញថា បទសម្លាប់រង្គាលពុំអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ[3011]។ ទាក់ទងទៅនឹងដំណាក់កាលទីពីរ អំពើប្រព្រឹត្តមូលដ្ឋាន ទោះជាយ៉ាងណាក្តី គឺជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3012]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ ដោយសារ អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅពុំត្រូវបានបង្ហាញដោយ

---

[3009] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៦៥៧។

[3010] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៨០ និង ១១០៣។

[3011] *សូមមើលខាងលើ* កថាខណ្ឌ ៥៤១ ដល់ ៥៦០។

[3012] *សូមមើលខាងលើ* កថាខណ្ឌ ៥៦០ ដល់ ៥៦២, ៨៦៨។

សមហេតុផលឡើយ[3013]។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញកំហុសនៅក្នុងការយល់ឃើញជាក់លាក់អំពីបទឧក្រិដ្ឋនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទីមួយ និងទីពីរ។ បញ្ហាគឺ ថាតើកំហុសនោះមានឥទ្ធិពលលើភាពសមស្របនៃការប្រកាសទោសដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនោះ ដែរ ឬយ៉ាងណា។

១១១៨.អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការប្រកាសទោសគប្បីឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃអំពើឧក្រិដ្ឋ[3014]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ គឺ"ជាលក្ខណៈវិនិច្ឆ័យសម្រាប់បញ្ជាក់អំពីភាពសមស្របនៃការប្រកាសទោស"[3015]។ ដូចបានលើកឡើងខាងលើ មានកត្តាជាច្រើនពាក់ព័ន្ធទៅនឹងការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដូចជាចំនួនជនរងគ្រោះ និងភាពងាយទទួលរងគ្រោះរបស់ជនរងគ្រោះ ផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ ចេតនារើសអើងរបស់ជនជាប់ចោទនៅពេលដែលពុំទាន់ក្លាយជាធាតុផ្សំនៃបទឧក្រិដ្ឋនៅឡើយនោះ។ ទំហំ និងភាពឃោរឃៅនៃបទល្មើស និងតួនាទីរបស់ជនជាប់ចោទ[3016]។

១១១៩.នៅក្នុងរឿងក្តីបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូលរំឭកថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ប្រជាជនចំនួនពី ២.៣៣០.០០០ ទៅ ២.៤៣០.០០០ នាក់ គឺជាជនរងគ្រោះនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ[3017]។ អង្គជំនុំជម្រះតុលាការកំពូលរំឭកបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា៖

> ចំនួនជនរងគ្រោះនៅក្នុងរឿងក្តីនេះ ស្ថិតនៅក្នុងចំណោមចំនួនជនរងគ្រោះដែលច្រើនបំផុតនៃរឿងក្តីដែលត្រូវបានជំនុំជម្រះពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិ។ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជាក្នុងអំឡុងពេលជិតពីរឆ្នាំ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ភាពធ្ងន់ធ្ងរនៃបទ

---

[3013] *សូមមើលខាងលើ* កថាខណ្ឌ ៩៧២។

[3014] សាលដីកា *រឿងក្តី Jelisić* (ICTY) កថាខណ្ឌ ៩៤។

[3015] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៦៨។ សាលក្រម *រឿងក្តី Čelebići* (ICTY) កថាខណ្ឌ ១២២៥ ត្រូវបានគាំទ្រនៅក្នុងសាលដីកា *រឿងក្តី Aleksovksi* (ICTY) កថាខណ្ឌ ១៨២។

[3016] សាលដីកា *រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ៣៧៥។ *សូមមើលផងដែរ* ជើងទំព័រ ៧៩៨។

[3017] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧៥។

ឧក្រិដ្ឋត្រូវបានឆ្លុះបញ្ចាំងតាមរយៈចំនួនជនរងគ្រោះដ៏ច្រើនលើសលប់ និងវិសាលភាពទូលាយផ្នែកទីតាំងភូមិសាស្ត្រ និងពេលវេលានៃការរងគ្រោះ[3018]។

១១២០.អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការយល់ឃើញទាំងនេះពុំទទួលរងផលប៉ះពាល់ដោយសារកំហុសដែលអង្គជំនុំជម្រះបានរកឃើញ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងបទឧក្រិដ្ឋជាក់លាក់។ ជាពិសេស ការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ជនជាប់ចោទពុំអាចដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃនោះ មានឥទ្ធិពលតិចតួចប៉ុណ្ណោះលើជនរងគ្រោះទូទៅដែលជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវនោះ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងផលប៉ះពាល់យូរអង្វែងនៃបទឧក្រិដ្ឋទៅលើជនរងគ្រោះ[3019]។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខ្លួនបានយល់ស្របចំពោះការសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្ម អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការខ្វះការយកចិត្តទុកដាក់ទាំងស្រុងទៅលើវាសនាចុងក្រោយរបស់ប្រជាជនកម្ពុជា ជាពិសេសក្រុមដែលងាយទទួលរងគ្រោះបំផុត និងជាការពិត បទឧក្រិដ្ឋនេះពុំមែនជាហេតុការណ៍ដាច់ដោយឡែកឡើយ ប៉ុន្តែបានកើតឡើងក្នុងរយៈពេលយ៉ាងយូរ និងដោយសារតួនាទីយ៉ាងសំខាន់របស់ជនជាប់ចោទ ទើបនាំឱ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការផ្ដន្ទាទោសជនជាប់ចោទម្នាក់ៗឱ្យជាប់ពន្ធនាគារអស់មួយជីវិត គឺជាការសមស្រប។

១១២១.យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដាក់ទោសជនជាប់ចោទម្នាក់ជាប់ពន្ធនាគារអស់មួយជីវិតជាការសមស្រប អាស្រ័យហេតុនេះ តម្កល់ការប្រកាសទោសដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង។

---

[3018] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧៥។

[3019] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១០៧៣។

## ៥.បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

១១២២.នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានរំឭកអំពីសេចក្តីសម្រេចរបស់ខ្លួន និងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[3020] ដោយយោងតាមសេចក្តីសម្រេចទាំងនេះ ទម្រង់នៃការទទួលខុសត្រូវដែលហៅថាទម្រង់“III” ឬទម្រង់“ទូលាយ”នៃសហឧក្រិដ្ឋកម្មរួម(“ទម្រង់ III”) ពុំអាចយកមកអនុវត្តបានទេនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. ដោយហេតុថា សហឧក្រិដ្ឋកម្មរួមទម្រង់ III ពុំមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលឧក្រិដ្ឋកម្មស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងនោះ។ ដោយផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពុំពិចារណាបន្ថែមទៀតលើការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ III ឡើយ[3021]។

១១២៣.នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ III អាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក.[3022]។ សហព្រះរាជអាជ្ញាពុំបានស្នើសុំឱ្យកែប្រែផ្នែកសម្រេចសេចក្តីនៅក្នុងសាលក្រមនេះទេ[3023] ព្រោះសហព្រះរាជអាជ្ញាពុំបានចោទប្រកាន់អំពីកំហុសណាមួយដែលអាចនាំឱ្យមោឃៈសាលក្រមនោះឡើយ ដោយហេតុថា នួន ជា និង ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត។ ក្នុងកាលៈទេសៈនេះ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ។

### ៥.ក.សារណាស្តីពីភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

១១២៤.សហព្រះរាជអាជ្ញាបានលើកឡើងថា ដូចបានទទួលស្គាល់នៅក្នុងសាលដីកា*រឿងក្តី ឌុច* (001-F28) អង្គជំនុំជម្រះតុលាការកំពូលមានសិទ្ធិអំណាចទទួលយកកំហុសអង្គច្បាប់ ដែលមាន“សារៈសំខាន់ជាទូទៅ

---

[3020] *សូមមើល* សាលដីការបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋកម្មរួម (D97/15/9)។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសហឧក្រិដ្ឋកម្មរួម (E100/6)។

[3021] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩១។

[3022] *សូមមើល* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E313/3/1)។ សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៩។

[3023] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E313/3/1) កថាខណ្ឌ ២។

សម្រាប់ជាយុត្តិសាស្ត្រ” បើទោះបីជាកំហុសទាំងនេះពុំមានឥទ្ធិពលណាមួយទៅលើសេចក្ដីសម្រេចក៏ដោយ[3024] ។ សហព្រះរាជអាជ្ញាបានអះអាងថា “នេះ គឺជាមូលដ្ឋានបង្អែកដោយខ្លួនឯងសម្រាប់ភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខ ដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងវិធានស្ដីពីនីតិវិធីអន្តរជាតិ ហើយត្រូវបានប្រតិបត្តិដោយឯករាជ្យពីការពិនិត្យឡើងវិញជាធម្មតាទៅលើកំហុសអង្គច្បាប់ក្រោមវិធាន ១០៤ នៃវិធានផ្ទៃក្នុង”[3025]។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា វិធាន ១០៥ (៣) នៃវិធានផ្ទៃក្នុង បានយោងទៅលើការចោទប្រកាន់អំពីកំហុសអង្គច្បាប់ដែលនាំឲ្យមោឃៈ*សេចក្ដីសម្រេច* ពុំមែនមោឃៈ*សាលក្រម*នោះទេ[3026]។ សហព្រះរាជអាជ្ញាបានយោងទៅសាលដីការបស់តុលាការ ICTR *រឿងក្ដី Akayesu* ដែលបានបង្ហាញថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការនេះមានឆន្ទានុសិទ្ធិក្នុងការប្រកាសដោយផ្អែកលើទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ ដែលពុំមានសក្ដានុពលនាំឱ្យមោឃៈសាលក្រម បើទោះបីជាក្នុងកាលៈទេសៈដែលម្ចាស់បណ្ដឹងសាទុក្ខបានត្រឹមតែលើកទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខនេះប៉ុណ្ណោះក៏ដោយ[3027]។ សហព្រះរាជអាជ្ញាបានយោងទៅលើហេតុការណ៍ដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានដោះស្រាយបញ្ហានៃការចោទប្រកាន់អំពីកំហុសអង្គច្បាប់ពាក់ព័ន្ធទៅនឹងសារៈសំខាន់ជាទូទៅសម្រាប់ជាយុត្តិសាស្ត្រ។ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះតុលាការកំពូល គឺជា“ស្ថាប័នតុលាការកំពូលរបស់ អ.វ.ត.ក.” គួរមានឱកាសដោះស្រាយ“បញ្ហាចាំបាច់នានានៃអង្គច្បាប់ បើទោះបីជាបញ្ហានេះពុំមានឥទ្ធិពលលើសាលក្រមចុងក្រោយក៏ដោយ និងបានកត់សម្គាល់ថា កិច្ចព្រមព្រៀង អ.វ.ត.ក. និងច្បាប់ អ.វ.ត.ក. ពុំមានចែងអំពីបណ្ដឹងសាទុក្ខបន្ទាន់បង្ខំ ដូចមានចែងក្នុងច្បាប់កម្ពុជាឡើយ[3028]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីប្រើប្រាស់ឆន្ទានុសិទ្ធិ

---

[3024] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦ យោងទៅលើ សាលដីកា*រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨ (“អង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្ដី Brđanin* បានយល់ស្របតាមសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺអំពីច្បាប់ […] បើទោះបីជាមានការយល់ព្រមពីភាគីទាំងអស់ថា អង្គជំនុំជម្រះតុលាការកំពូលនេះ ពុំអាចសម្រេចដាក់ពិរុទ្ធភាពថ្មីឡើយ”)(ជើងទំព័រលុបចោល)។

[3025] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦ (ជើងទំព័រលុបចោល)។

[3026] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦ (ជើងទំព័រលុបចោល)។

[3027] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧ យោងទៅលើសាលដីកា*រឿងក្ដី Akayesu* (ICTR) កថាខណ្ឌ ២១ *ជាអាទិ៍*។

[3028] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

របស់ខ្លួនក្នុងការអនុវត្តនីតិវិធីកម្ពុជា[3029]។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថាអង្គជំនុំជម្រះតុលាការកំពូលនឹង“គ្មានអំណាច”ដោះស្រាយបញ្ហា ដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ប្រសិនបើបណ្តឹងនេះត្រូវបានប្រកាសថា មិនអាចទទួលយកបាន និងថា អង្គជំនុំជម្រះសាលាដំបូងទំនងជាបន្តប្រព្រឹត្តកំហុសអង្គច្បាប់ដដែលដែលបានចោទប្រកាន់នោះក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. នៅថ្ងៃខាងមុខទៀត[3030]។ ចុងបញ្ចប់ សហព្រះរាជអាជ្ញាបានយោងទៅលើ“ការពិចារណាដែលចាំបាច់អំពីគោលនយោបាយសាធារណៈជាអន្តរជាតិ” ដើម្បីគាំទ្រដល់ការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូល[3031]។ សហព្រះរាជអាជ្ញាបានអះអាងថា សហឧក្រិដ្ឋកម្មរួមទម្រង់ III គឺជាយន្តការដ៏សំខាន់ដែលតាមរយៈនេះមេដឹកនាំដែលទទួលខុសត្រូវ អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូល គប្បីមានឱកាស“ធ្វើឲ្យជំហរផ្នែកច្បាប់របស់ អ.វ.ត.ក. ស្របគ្នាជាមួយនឹងសេចក្តីសម្រេចនានា ព្រមទាំងសាលក្រមស្ថាពររបស់តុលាការ ICTY ICTR SCSL និង STL ដែលសុទ្ធតែទទួលយកសហឧក្រិដ្ឋកម្មរួមទម្រង់ III ដែលជាទម្រង់ជាធរមាននៃការទទួលខុសត្រូវ[3032]។

១១២៥.ក្នុងសារណាតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ខៀវ សំផន និង នួន ជា បានជំទាស់ទៅនឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ ដោយផ្អែកទៅលើវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង ខៀវ សំផន បានលើកឡើងថា ការធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដោយពុំបានជំទាស់ទៅនឹងអានុភាពនៃការសម្រេច គឺពុំអាចទៅរួចឡើយ[3033]។ ខៀវ សំផន បានអះអាងថា បញ្ហាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ពុំត្រូវបានដោះស្រាយនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងពុំមានការប៉ះពាល់ណាមួយដល់សាលក្រមនេះឡើយ[3034]។ ខៀវ សំផន បានរំលឹកពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[3035] ដែលបានសម្រេចថា បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលបានសម្រេចក្នុងអំឡុងពេលនៃការជំនុំជម្រះ ដែលត្រូវបានអនុញ្ញាតឱ្យប្តឹងក្នុងពេលដំណាលគ្នាជាមួយនឹង

[3029] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

[3030] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

[3031] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១។

[3032] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១។

[3033] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ១៣។

[3034] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ១៤។

[3035] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ១៥។

សាលក្រមលើអង្គសេចក្ដី"ត្រូវតែបង្ហាញពី*ការប៉ះពាល់*ជានិរន្តលើម្ចាស់បណ្ដឹងសាទុក្ខ។ ដូច្នេះ បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចនេះ ត្រូវតែជាប់ទាក់ទងទៅនឹងទឡ្ហីករណ៍មួយ ឬច្រើននៃបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម"[3036]។ ខៀវ សំផន បានលើកឡើងថា សហព្រះរាជអាជ្ញាពុំទទួលរងការប៉ះពាល់ដោយសារសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដូច្នេះពុំមានអត្ថប្រយោជន៍ស្របច្បាប់។ ហេតុនេះ បណ្ដឹងសាទុក្ខនេះពុំអាចទទួលយកបានឡើយ[3037]។

១១២៦.បន្ថែមពីលើនេះទៀត ខៀវ សំផន បានលើកឡើងថា សហព្រះរាជអាជ្ញាបានបោះបង់សិទ្ធិរបស់ខ្លួនក្នុងការធ្វើបណ្ដឹងសាទុក្ខលើបញ្ហានេះ ព្រោះថា សហព្រះរាជអាជ្ញាពុំបានធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ (D427) និងពុំបានលើកបញ្ហានេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលបង្ហាញពីបញ្ហាអញ្ញត្រកម្មឡើយ[3038]។ លើសពីនេះទៀត ខៀវ សំផន បាន អះអាងថា បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ពុំស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ជាក់ស្ដែង គឺពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២[3039] ប៉ុន្តែពុំមែនសំណុំរឿង ០០២/០១ ឡើយ។ គាត់ក៏បានអះអាងផងដែរថា ដោយសារសហឧក្រិដ្ឋកម្មរួមទម្រង់ III ពុំត្រូវបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយ (D427) ទាក់ទងទៅនឹងសំណុំរឿង ០០២/០២ ដូចនេះ ទម្រង់នេះត្រូវបានដកចេញយ៉ាងច្បាស់ពីសំណុំរឿងនោះ ហេតុដូច្នេះ សហឧក្រិដ្ឋកម្មទម្រង់ III ពុំមានសារៈសំខាន់សម្រាប់សំណុំរឿងនោះផងដែរ[3040] ហើយការដែលថា សហព្រះរាជអាជ្ញាបានបង្ហាញថា ខ្លួនមានបំណងលើកសំអាងដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ III នៅក្នុងសំណុំរឿង ០០២/០២ នោះ ពុំបានកែប្រែការពិតនេះឡើយ[3041]។

---

[3036] សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប (F9) កថាខណ្ឌ ១៦។

[3037] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ១៦។

[3038] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ១៧ ដល់ ១៩។

[3039] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ២២ ដល់ ២៨។

[3040] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ២៦។

[3041] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤០។

១១២៧.ខៀវ សំផន បានលើកឡើងថា លក្ខខណ្ឌសម្រាប់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការប្រកាសទាក់ទងទៅនឹងភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ III ពុំត្រូវបានបំពេញឡើយ[3042] ។ ដោយយោងទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល និងតុលាការ ICTY និង ICTR ខៀវ សំផន បានលើកឡើងថា មានលក្ខខណ្ឌចំនួន ៣ សម្រាប់សេចក្ដីសម្រេចក្នុងការប្រកាសនោះ ប៉ុន្តែលក្ខខណ្ឌទាំងនេះពុំត្រូវបានបំពេញឡើយនៅក្នុងរឿងក្ដីបច្ចុប្បន្ន[3043]។

១១២៨.ខៀវ សំផន បានអះអាងបន្ថែមទៀតថា ពុំមែនរាល់បញ្ហាផ្នែកអង្គច្បាប់ត្រូវតែដោះស្រាយដោយអង្គជំនុំជម្រះតុលាការកំពូលនោះឡើយ[3044] និងថា ពុំមានភាពចាំបាច់ដែលតម្រូវឱ្យមានភាពស្របគ្នារវាងយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ជាមួយនឹងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ឬតុលាការដទៃទៀតដែលមានលក្ខណៈអន្តរជាតិ និងតុលាការឧក្រិដ្ឋកម្មនានា (ដែលទទួលស្គាល់សហឧក្រិដ្ឋកម្មរួមទម្រង់ III)[3045]ថា ពុំមានភាពចាំបាច់ឱ្យអង្គជំនុំជម្រះតុលាការកំពូលត្រូវផ្ដល់ការតម្រង់ទិសផ្នែកគតិយុត្ត[3046] និងថា ការសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺជា*អាជ្ញាអស់ជំនុំ* ហើយការជំនុំជម្រះត្រូវផ្អែកលើមូលដ្ឋាននេះដែរ[3047]។

១១២៩.នួន ជា បានលើកឡើងថា បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពុំស្របជាមួយនឹងលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុងដែលចែងថា កំហុសដែលរងការចោទប្រកាន់ត្រូវតែមានសក្ដានុពលអាចមោឃៈសាលក្រមបាន[3048]។ នួន ជា បានទទួលស្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញពីដំបូងថា ខ្លួនមានយុត្តាធិការលើកំហុសអង្គច្បាប់ដែលពុំធ្វើឱ្យសាលក្រមមោឃៈ ប៉ុន្តែមានសារៈសំខាន់ចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក.។ ទោះជាយ៉ាងណាក្ដី គាត់បានអះអាងថា នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ (E313/3/1) សហព្រះរាជអាជ្ញាគ្រាន់តែបានលើកឡើងថា ខ្លួនកំពុងធ្វើបណ្ដឹងសាទុក្ខដើម្បីអត្ថប្រយោជន៍នៃច្បាប់ ដោយពុំបាន

---

3042 សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៣០។

3043 សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៣៤ ដល់ ៣៧។

3044 សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៣៩។

3045 សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤១។

3046 សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤២។

3047 សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤៤។

3048 សារណាតបរបស់ នួន ជា កថាខណ្ឌ ៣ យោងទៅលើវិធាន ១០៤(១)(ក), ១០៥(២)(ក), ១០៥(៣) នៃវិធានផ្ទៃក្នុង។

បញ្ជាក់ថា បណ្ដឹងសាទុក្ខនេះ គឺធ្វើឡើងដើម្បីសារៈសំខាន់ចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក ឡើយ[3049]។ នួន ជា លើកឡើងថា នៅគ្រប់កាលៈទេសៈទាំងអស់ បញ្ហា ថាតើសហឧក្រិដ្ឋកម្មរួមទម្រង់ III អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. បានដែរ ឬយ៉ាងណានោះ ពុំមានសារៈសំខាន់ទូទៅឡើយ ដោយហេតុថា បញ្ហានេះត្រូវបានជំទាស់តវ៉ាយ៉ាងទូលំទូលាយនៅក្នុងបរិបទនៃសំណុំរឿង ០០២/០១ និងបានអះអាងថា "បើទោះបីជា ក្នុងពេលមួយ មាន*សារៈសំខាន់ចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក.* ដែលតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាក៏ដោយ ក៏សារៈសំខាន់នៅក្នុងសំណុំរឿង ០០២ នេះ បានសាបរលាបទៅជាយូរមកហើយ"[3050]។ នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធចោលនូវបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយប្រកាសថា ពុំអាចទទួលយកបាន[3051]។

## ៥.ខ.ការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូល

១១៣០.យោងតាមវិធាន ១១១(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលអាចប្រកាសថា បណ្ដឹងសាទុក្ខនេះពុំអាចទទួលយកបាន ប្រសិនបើអង្គជំនុំជម្រះរកឃើញថា បណ្ដឹងសាទុក្ខនេះ"បានដាក់យឺតពេល ឬម្យ៉ាងទៀត មានវិការៈផ្នែកនីតិវិធី"។ បណ្ដឹងសាទុក្ខមានវិការៈផ្នែកនីតិវិធី ក្នុងករណីដែលបណ្ដឹងសាទុក្ខនោះពុំបានគោរពតាមលក្ខខណ្ឌតម្រូវចាំបាច់ផ្នែកនីតិវិធី ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងច្បាប់ជាធរមាន។

១១៣១.វិធាន ១០៥ នៃវិធានផ្ទៃក្នុងចែងពីលក្ខខណ្ឌនីតិវិធីមួយចំនួនសម្រាប់"ភាពអាចទទួលយកបាន"នៃបណ្ដឹងសាទុក្ខ។ ជាការកត់សម្គាល់ វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុងចែងនៅក្នុងផ្នែកពាក់ព័ន្ធដូចតទៅថា៖

> ភាគីដែលមានបំណងប្ដឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្ដឹងសាទុក្ខនោះ។ សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខដែលបញ្ជាក់ពីមូលដ្ឋាននីមួយៗ ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្ដីសម្រេចនោះមោឃៈ និងកំហុសអង្គហេតុ ដែលនាំឱ្យសេចក្ដីសម្រេចនោះមានភាពមិនយុត្តិធម៌។

---

[3049] សារណាតបរបស់ នួន ជា កថាខណ្ឌ ៤ យោងទៅលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E131/3/1) កថាខណ្ឌ ២។

[3050] សារណាតបរបស់ នួន ជា (F11/2) កថាខណ្ឌ ៤។

[3051] សារណាតបរបស់ នួន ជា (F11/2) កថាខណ្ឌ ៥៨។

១១៣២.សហព្រះរាជអាជ្ញាពុំបានអះអាងថា កំហុសអង្គច្បាប់ដែលខ្លួនចោទប្រកាន់នោះ នាំឱ្យសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមោឃៈនោះទេ។ ដូច្នេះ សហព្រះរាជអាជ្ញាពុំបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់បណ្តឹងសាទុក្ខរបស់ខ្លួន ដូចជាការបញ្ជាក់ពីកំហុស*ដែលនាំឱ្យសេចក្តីសម្រេចមោឃៈ*។ សហព្រះរាជអាជ្ញាបានអះអាងថា វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង គឺសំដៅលើតែ"សេចក្តីសម្រេច"ប៉ុណ្ណោះ ពុំមែនសំដៅលើ"សាលក្រម"ដែលហាក់បីដូចជាចង់មានន័យថា នេះពុំមានភាពចាំបាច់បង្ហាញថា សាលក្រមនេះត្រូវមោឃៈទាំងមូលឡើយ។ ទាក់ទងទៅនឹងចំណុចនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការបកស្រាយបែបនេះលើវិធានខាងលើពុំអាចជឿបាន។ បទប្បញ្ញត្តិនេះ ចាំបាច់ត្រូវតែធ្វើការស្វែងយល់ទៅតាមបរិបទ ជាពិសេសដោយរួមបញ្ចូលវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងផងដែរ ដែលចែងថា៖

> អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖ ក) កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ [...]។

១១៣៣.ចំណុចនេះបញ្ជាក់ថា ពាក្យ"សេចក្តីសម្រេច"នៅក្នុងវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង ត្រូវតែបានស្វែងយល់ថា ជាការសំដៅទៅលើការវិនិច្ឆ័យរបស់អង្គជំនុំជម្រះសាលាដំបូងនៅចុងបញ្ចប់នៃរឿងក្តី ដូចជាសាលក្រមជាដើម។ នេះដោយសារគោលបំណងចម្បងនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខបន្ទាប់ពីការជំនុំជម្រះនេះ គឺជាការកំណត់ ថាតើសាលក្រមដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងត្រឹមត្រូវតាមអង្គច្បាប់ និងតាមអង្គហេតុ ដែរ ឬយ៉ាងណា។ ចំណុចនេះស្របទៅសំណៅជាភាសាបារាំងដែលមានតម្លៃគតិយុត្តស្មើគ្នាក្នុងវិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង និងបានប្រើប្រាស់ឃ្លាជាក់លាក់ថា *"le verdict prononcé"* ដែលត្រូវគ្នានឹងពាក្យពេចន៍ជាភាសាអង់គ្លេសថា "decision"[3052]។

១១៣៤.សេចក្តីសម្រេចថ្មីៗរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងទៅនឹងការកំណត់ចំនួនទំព័រ និងពេលវេលានៃសារណារបស់ភាគី[3053] បានបញ្ជាក់អំពីការស្វែងយល់បែបនេះ និងបានបង្ហាញថា ពុំមានអ្វីខុសគ្នាចំពោះការចោទប្រកាន់អំពីកំហុសដែលពុំមាននៅក្នុងសាលក្រម ប៉ុន្តែនៅក្នុងសេចក្តីសម្រេចដែលត្រូវបានធ្វើឡើងពីដំបូងក្នុងកិច្ចដំណើរការនីតិវិធី៖ ដូចការកត់សម្គាល់របស់ ខៀវ សំផន អង្គជំនុំជម្រះតុលាការកំពូលបាន

---

[3052] វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង(ភាសាបារាំង)។

[3053] សេចក្តីសម្រេចស្តីពីការកំណត់ពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាតប និងសារណាបណ្តឹងសាទុក្ខ (F9)។

បញ្ជាក់នៅក្នុងសេចក្ដីសម្រេចនោះថា ប្រសិនបើសេចក្ដីសម្រេចបន្ទាន់បង្ខំត្រូវបានជំទាស់នៅក្នុងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម "*ការប៉ះពាល់*ជានិរន្តរបស់ម្ចាស់បណ្ដឹងសាទុក្ខ[ត្រូវតែបានបង្ហាញ]។ អាស្រ័យហេតុនេះ បណ្ដឹងសាទុក្ខនោះត្រូវតែជាប់ពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍ដែលអនុញ្ញាតមួយ ឬច្រើននៃបណ្ដឹងសាទុក្ខលើសាលក្រម"[3054]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញច្បាស់លាស់នូវទំនាក់ទំនងរវាងសេចក្ដីសម្រេចបន្ទាន់បង្ខំដែលកំពុងត្រូវបានជំទាស់ និងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនៅតែជាកម្មវត្ថុចុងក្រោយនៃបណ្ដឹងសាទុក្ខ។

១១៣៥.នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួននឹងដាក់បណ្ដឹងសាទុក្ខនេះដើម្បី*អត្ថប្រយោជន៍ច្បាប់* 'dans l'intérêt de la loi' ដោយស្នើសុំដំណោះស្រាយឱ្យធ្វើការប្រកាសតែប៉ុណ្ណោះ[3055]។ សហព្រះរាជអាជ្ញាបានលើកឡើងថា៖

> វិធានស្ដីពីនីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិបានបញ្ជាក់ថា ដំណោះស្រាយសុំការប្រកាស គឺអាចធ្វើទៅបានតាមរយៈតុលាការឧទ្ធរណ៍ ដោយផ្អែកលើបញ្ហាអង្គច្បាប់សម្រាប់"សារៈសំខាន់ទូទៅ" ឬ"សារៈសំខាន់យ៉ាងច្រើន"ចំពោះយុត្តិសាស្ត្រ។ អង្គជំនុំជម្រះនេះបានអនុម័តតាមយ៉ាងច្បាស់លាស់នូវបទដ្ឋានគតិយុត្ត ដូចគ្នានៅក្នុងសាលដីកានៃសំណុំរឿង ០០១។ ជំហរនេះ ក៏ត្រូវបានទទួលស្គាល់ផងដែរនៅក្នុងច្បាប់បារាំងក្នុងករណីដ៏កម្រតាមរយៈ*ការដាក់បណ្ដឹងសាទុក្ខទៅតុលាការជាន់ខ្ពស់ដើម្បីផលប្រយោជន៍ច្បាប់* (pourvoi en cassation dans l'intérêt de la loi)[3056]។

១១៣៦.សហព្រះរាជអាជ្ញាពុំបានអះអាងថា ដំណោះស្រាយនៃ*ការដាក់បណ្ដឹងសាទុក្ខទៅតុលាការជាន់ខ្ពស់ដើម្បីផលប្រយោជន៍ច្បាប់* (pourvoi en cassation dans l'intérêt de la loi) មានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពុំបានចែងច្បាស់លាស់នូវបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងបញ្ហានេះដែរ។ ចំពោះច្បាប់បារាំង បើទោះបីជាក្រមនីតិវិធីបារាំងបានចែងអំពីប្បញ្ញត្តិទាក់ទងទៅនឹងបញ្ហានេះក៏ដោយ ក៏ទំនងជាមានលក្ខណៈផ្ទុយទៅនឹងបញ្ហាចំពោះមុខដែរ។ បទប្បញ្ញត្តិដែលពាក់ព័ន្ធនោះចែងថា៖

---

[3054] សេចក្ដីសម្រេចស្ដីពីការកំណត់ពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាតប និងសារណាបណ្ដឹងសាទុក្ខ (F9) កថាខណ្ឌ ១៦។

[3055] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E313/3/1) កថាខណ្ឌ ២ និង ៥។

[3056] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (E313/3/1) កថាខណ្ឌ ៥ (ជើងទំព័រលុបចោល)។

នៅពេលដែលតុលាការឧក្រិដ្ឋ ឬសាលាឧទ្ធរណ៍ ឬតុលាការជំនុំជម្រះបទមជ្ឈិម ឬតុលាការលហុ បាន ចេញសាលក្រមចុងក្រោយដែលបើកផ្លូវឱ្យធ្វើបណ្ដឹងសាទុក្ខ និងបើទោះបីជាយ៉ាងនេះក៏ដោយ ក៏គ្មាន ភាគីណាមួយបានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះតាមកាលបរិច្ឆេទ ដែលបានកំណត់នោះ ដែរ ដូច្នេះអគ្គរដ្ឋអាជ្ញាអមសាលាវិនិច្ឆ័យ(តុលាការកំពូល)អាចធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម នេះតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ក្នុងហេតុផលតែមួយគត់ គឺដើម្បីផលប្រយោជន៍ច្បាប់ បើទោះបីជា ផុតកំណត់នៃកាលបរិច្ឆេទដាក់ពាក្យបណ្ដឹងក៏ដោយ។ តុលាការត្រូវសម្រេចអំពីភាពអាចទទួលយក បាន និងអង្គសេចក្ដីនៃពាក្យបណ្ដឹងនេះ។ នៅពេលដែលបណ្ដឹងនេះត្រូវបានទទួលយក តុលាការត្រូវ ប្រកាសមោឃភាពចំពោះសាលក្រមនោះ ប៉ុន្តែភាគីពុំអាចពិនិត្យទៅលើមោឃភាពនេះ ឬជំទាស់ទៅ នឹងការអនុវត្តន៍នៃសេចក្ដីសម្រេចដែលត្រូវបានបដិសេធនោះឡើយ[3057]។

១១៣៧.ដូច្នេះ បណ្ដឹងសុំមោឃភាពដើម្បីផលប្រយោជន៍ច្បាប់ អាចធ្វើបានប្រឆាំងនឹងសាលក្រមដែលអាចធ្វើ បណ្ដឹងសាទុក្ខបានតាមកិច្ចដំណើរការនីតិវិធីធម្មតាមប៉ុណ្ណោះ ប៉ុន្តែពាក់ព័ន្ធទៅនឹងការដែល គ្មានភាគីណាមួយ ធ្វើបណ្ដឹងសាទុក្ខនេះ។ ក្នុងន័យម្យ៉ាងទៀត *បណ្ដឹងសាទុក្ខទៅតុលាការជាន់ខ្ពស់ដើម្បីផលប្រយោជន៍ច្បាប់* ពុំ មែនជាមធ្យោបាយធ្វើឱ្យសេចក្ដីសម្រេចមួយត្រូវតែបានពិនិត្យឡើងវិញ ក្នុងករណីដែលតុលាការជាន់ខ្ពស់ បំផុតខ្លួនឯងពុំអាចធ្វើការពិនិត្យបាននោះឡើយ ប៉ុន្តែគ្រាន់តែជាយន្តការមួយសម្រាប់ផ្ដល់សិទ្ធិអំណាចដល់អយ្យ ការជាន់ខ្ពស់បំផុត ក្នុងការធ្វើបណ្ដឹងទៅតុលាការជាន់ខ្ពស់ នៅពេលដែលពុំមានភាគីណាធ្វើដូច្នោះ។ អាស្រ័យ ហេតុនេះ សទិសភាពដែលសហព្រះរាជអាជ្ញាបានលើកឡើង ជាការភាន់ច្រឡំ និងត្រូវបដិសេធចោល។

១១៣៨.សហព្រះរាជអាជ្ញាបានលើកឡើងថា នៅក្នុងសាលដីកា *រឿងក្ដី ឌុច* (001-F28) អង្គជំនុំជម្រះតុលាការ កំពូលបានទទួលស្គាល់ថា អង្គជំនុំជម្រះអាចដោះស្រាយ“បញ្ហាស្ដីពីសារៈសំខាន់ទូទៅសម្រាប់យុត្តិសាស្ត្រ” បើ ទោះបីជាបញ្ហានេះពុំបានធ្វើឱ្យសាលក្រមដែលស្ថិតក្រោមការពិនិត្យនេះទៅជាមោឃៈក៏ដោយ ដែលតាមការ លើកឡើងរបស់សហព្រះរាជអាជ្ញា នេះបានផ្ដល់មូលដ្ឋានបង្អែកដោយខ្លួនឯងសម្រាប់ភាពអាចទទួលយកបាន នៃបណ្ដឹងសាទុក្ខ[3058]។ នៅក្នុងសាលដីកា *រឿងក្ដី ឌុច* (001-F28) អង្គជំនុំជម្រះតុលាការកំពូល បានលើកឡើង ដូចខាងក្រោមថា៖

[3057] មាត្រា ៦២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[3058] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦ យោងទៅលើសាលដីកា *រឿងក្ដី ឌុច* (001-F28) កថាខណ្ឌ ១៥។

ក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចលើកបញ្ហា*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ឬស្តាប់បណ្តឹងសាទុក្ខនៅពេលដែលភាគីលើកបញ្ហាផ្លូវច្បាប់ដែលពុំធ្វើឱ្យសាលក្រមមោឃៈ ប៉ុន្តែមានសារៈសំខាន់ទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក.[3059]។

១១៣៩.អង្គជំនុំជម្រះតុលាការកំពូល បានសំអាងលើសាលដីកាចំនួន ២ របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY។ ពិតណាស់ ដោយសារតែ សាលដីកា*រឿងក្តី Tadić* (ICTY) អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និង ICTR បានលើកឡើងថា អង្គជំនុំជម្រះទាំងនេះមានសិទ្ធិអំណាចក្នុងការប្រកាសដោយខ្លួនឯងស្តីពីបញ្ហាផ្លូវច្បាប់ បើទោះបីពុំមានសក្តានុពលធ្វើឱ្យសេចក្តីសម្រេចដែលស្ថិតក្រោមការពិនិត្យទៅជាមោឃៈនោះក៏ដោយ។ នៅក្នុងសាលដីកា*រឿងក្តី Tadić* (ICTY) បានកត់សម្គាល់ទាក់ទងទៅនឹងទឡ្ហីករណ៍ពីរនៃបណ្តឹងសាទុក្ខថា បើទោះបីជាទំនងជាពុំស្ថិតក្រោមមាត្រា ២៥(១) នៃលក្ខន្តិកៈរបស់តុលាការ ICTY (ដែលមានអានុភាពលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម)ក៏ដោយ ក៏ទឡ្ហីករណ៍ទាំងនេះបានលើកឡើងនូវបញ្ហានានាស្តីពីសារៈសំខាន់ ទូទៅសម្រាប់យុត្តិសាស្ត្ររបស់តុលាការ ICTY និងថា ហេតុនេះ ជាការសមស្របសម្រាប់អង្គជំនុំជម្រះក្នុងការទទួលយកទឡ្ហីករណ៍នេះ[3060]។ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY ពុំបានផ្តល់ការពន្យល់បន្ថែម ឬយុត្តិកម្មណាមួយសម្រាប់វិធីសាស្ត្ររបស់ខ្លួនលើបញ្ហានេះឡើយ។ នៅក្នុងសាលដីកា*រឿងក្តី Akayesu* (ICTR) (ដែលសហព្រះរាជអាជ្ញាបានផ្អែកទៅលើ) បានអនុវត្តតាមវិធីសាស្ត្រដូចគ្នានៅក្នុងករណីដែលអយ្យការបាន*ត្រឹមតែ*លើកទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខបែបនេះប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី គួរកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការឧក្រិដ្ឋកម្មមិនអចិន្ត្រៃយ៍បានចាត់ទុកបញ្ហានេះថា ជាសិទ្ធិរបស់*អង្គជំនុំជម្រះ* ពុំមែនជាសិទ្ធិរបស់*ម្ចាស់បណ្តឹងសាទុក្ខ*នោះឡើយ។ អង្គជំនុំជម្រះនេះបានគូសបញ្ជាក់នូវចរិតលក្ខណៈឆន្ទានុសិទ្ធិនៃសេចក្តីសម្រេច ក្នុងការដោះស្រាយទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ ដែលពុំមានសក្តានុពលធ្វើឱ្យសាលក្រមដែលត្រូវបានប្តឹងសាទុក្ខនោះមោឃៈ[3061]។ អាស្រ័យហេតុនេះ យុត្តិសាស្ត្រនេះពុំបានផ្តល់

---

[3059]សាលដីកា*រឿងក្តី ឌុច* (001-F28) កថាខណ្ឌ ១៥ (ជើងទំព័រលុបចោល)។

[3060] សាលដីកា*រឿងក្តី Tadić* កថាខណ្ឌ ២៤១, ២៤៧ និង ២៨១។

[3061] សាលដីកា*រឿងក្តី Akayesu* (ICTR) កថាខណ្ឌ ២៣ (អះអាងថា អង្គជំនុំជម្រះមានជម្រើសប្រើប្រាស់ឆន្ទានុសិទ្ធិនេះក្នុងករណី "ដំណោះស្រាយលើបញ្ហានេះទំនងជារួមចំណែកយ៉ាងខ្លាំងដល់ការអភិវឌ្ឍន៍យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម")។ *សូមមើលផងដែរ* ការយោងដទៃទៀតទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY ដែលសហព្រះរាជអាជ្ញាបានធ្វើឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ជើងទំព័រ ១៦ ដូចជា សាលដីកា*រឿងក្តី Galic* (ICTY) កថាខណ្ឌ ៦ ("ក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះឧទ្ធរណ៍នឹងត្រូវស្តាប់ផងដែរនូវបណ្តឹងសាទុក្ខរបស់ភាគីដែលបានលើកឡើងអំពីបញ្ហាអង្គច្បាប់ ដែលពុំបានធ្វើឱ្យសាលក្រមមោឃៈ ប៉ុន្តែទោះជា

ជាមូលដ្ឋាននៃ*សិទ្ធិ*ធ្វើបណ្តឹងសាទុក្ខ*ដល់សហព្រះរាជអាជ្ញា*ទេ។ ប៉ុន្តែ មានសារៈសំខាន់សម្រាប់ការពិភាក្សាលើបញ្ហា ថាតើអង្គជំនុំជម្រះតុលាការកំពូលអាចពិចារណាទៅលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខនេះ ដែរ ឬយ៉ាងណា បើទោះបីជាអង្គជំនុំជម្រះរកឃើញថា បណ្តឹងសាទុក្ខនេះពុំអាចទទួលយកបានក៏ដោយនោះ។

១១៨០.នៅក្នុងបរិបទនេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា វិធានផ្ទៃក្នុងចែងថា ប្រសិនបើបណ្តឹងសាទុក្ខមួយត្រូវបានរកឃើញថា មានវិការៈផ្នែកនីតិវិធីហើយនោះ អង្គជំនុំជម្រះតុលាការកំពូល*អាច*ប្រកាសបណ្តឹងសាទុក្ខនេះថា ពុំអាចទទួលយកបាន[3062]។ ការប្រើប្រាស់ពាក្យពេចន៍“អាច”អាចត្រូវបានយល់ថា ការបដិសេធបណ្តឹងសាទុក្ខថា ពុំអាចទទួលយកបានដោយសារវិការៈផ្នែកនីតិវិធី ពុំមែនជាការចាប់បង្ខំនោះទេ និងថា អង្គជំនុំជម្រះតុលាការកំពូលក៏អាចសម្រេចធ្វើការពិចារណាផងដែរទៅលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខនេះ ដោយពុំចាំបាច់គិតពីវិការៈផ្នែកនីតិវិធីនោះឡើយ ដែលនេះស្របជាមួយនឹងវិធីសាស្ត្ររបស់តុលាការ ICTR *រឿងក្តី Akayesu*[3063]។

១១៨១.ហេតុដូច្នេះ បញ្ហាដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយ គឺថាតើក្នុងកាលៈទេសៈនៃរឿងក្តីបច្ចុប្បន្ននេះ ជាការសមស្របក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន និងពិចារណាលើបញ្ហាដែលបានលើកឡើង

---

យ៉ាងណាក្តីបញ្ហានេះ មានសារៈសំខាន់ទូទៅចំពោះយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋអន្តរជាតិ”)។ បន្ថែមលើនេះទៀត ការលើកឡើងដូចគ្នានេះមាននៅក្នុងសាលដីកា*រឿងក្តី Stakic* (ICTY) កថាខណ្ឌ ៧។ សាលដីកា*រឿងក្តី Kupreskic* (ICTY) កថាខណ្ឌ ២២៖ (“នៅដំណាក់កាលបណ្តឹងសាទុក្ខ ភាគីត្រូវកម្រិតអំណះអំណាងរបស់ខ្លួនត្រឹមបញ្ហាដែលស្ថិតក្នុងវិសាលភាពមាត្រា ២៥ នៃលក្ខន្តិកៈ។ វិធានទូទៅចែងថា អង្គជំនុំជម្រះឧទ្ធរណ៍ពុំត្រូវពិចារណាលើអំណះអំណាងដែលពុំបានលើកឡើងអំពីកំហុសអង្គច្បាប់ ដែលនាំឱ្យសាលក្រមមោឃៈ ឬកំហុសអង្គហេតុដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ឡើយ លើកលែងតែក្នុងកាលៈទេសៈពិសេសដែលក្នុងនោះភាគីបានលើកបញ្ហាអង្គច្បាប់ដែលមានសារៈសំខាន់ទូទៅចំពោះយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ មានតែក្នុងករណីកម្របែបនេះប៉ុណ្ណោះ ដែលអង្គជំនុំជម្រះឧទ្ធរណ៍អាចចាត់ទុកថា ជាការសមស្រប និងជាករណីពិសេសចំពោះវិធានទូទៅ”)។

[3062] វិធាន ១១១(២) នៃវិធានផ្ទៃក្នុង (សេចក្តីបញ្ជាក់បន្ថែម)។

[3063] ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា យោងតាមមាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧ ចែងថា “កាលណាសាលាឧទ្ធរណ៍យល់ឃើញថា បណ្តឹងឧទ្ធរណ៍ធ្វើហួសពេលកំណត់ ឬ ធ្វើនៅក្នុងលក្ខខណ្ឌមិនត្រឹមត្រូវនោះ សាលាឧទ្ធរណ៍ប្រកាស់ថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន”(សេចក្តីបញ្ជាក់បន្ថែម)។ ដូច្នេះ វិធាន ១១១ (២) នៃវិធានផ្ទៃក្នុង ខុសពីនីតិវិធីព្រហ្មទណ្ឌធម្មតារបស់កម្ពុជា។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ករណីនេះអាចធ្វើយុត្តិកម្មបានដោយសារកាលៈទេសៈជាក់លាក់របស់ អ.វ.ត.ក. ដូចជា៖ ចំនួនរឿងក្តីដែលបានស្តាប់នៅចំពោះមុខយុត្តាធិការនេះមានកម្រិត។ អាស្រ័យហេតុនេះ ឱកាសក្នុងការបំភ្លឺច្បាប់តាមរយៈយុត្តិសាស្ត្រនានាក៏មានកម្រិតដូច្នោះដែរ។

ដោយសហព្រះរាជអាជ្ញា ដែរ ឬយ៉ាងណា។ ផ្ទុយទៅទៅនឹងអំណះអំណាងរបស់ ខៀវ សំផន[3064] ការសម្រេចនេះពុំត្រូវបានកម្រិតដោយលក្ខណៈវិនិច្ឆ័យរឹតត្បិតជាក់លាក់ណាឡើយ។

១១៤២.អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បញ្ហា ថាតើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ III អាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. ដែរ ឬយ៉ាងណានោះ ពិតជាមានការពាក់ព័ន្ធមួយចំនួនផងដែរទៅនឹងកិច្ចដំណើរការនីតិវិធីនាពេលអនាគត និងនៅចំពោះមុខតុលាការនេះ។ សញ្ញាណនៃសហឧក្រិដ្ឋកម្មរួមទម្រង់ III នេះ ជាញឹកញាប់ត្រូវបានប្រើប្រាស់នៅក្នុងរឿងក្ដីនានានៅចំពោះមុខតុលាការ *មិនអចិន្ត្រៃយ៍* ហើយអាចយល់បានថា សញ្ញាណនេះអាចមានតួនាទីនៅក្នុងកិច្ចដំណើរការនីតិវិធីដទៃទៀតនៅចំពោះមុខ អ.វ.ត.ក. ផងដែរ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បណ្ដឹងសាទុក្ខដែលដាក់ដោយ នួន ជា និង ខៀវ សំផន បានផ្ដល់ឱកាសឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមនេះ រួមទាំងទិដ្ឋភាពដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ហាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។ ករណីនេះនឹងផ្ដល់ជាគោលការណ៍ណែនាំគ្រប់គ្រាន់សម្រាប់កិច្ចដំណើរការនីតិវិធីនាពេលអនាគត អាស្រ័យហេតុនេះពុំមានភាពចាំបាច់ក្នុងការពិចារណាលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដោយឈរលើមូលដ្ឋានពិសេសនោះឡើយ។

១១៤៣.ផ្អែកតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលបដិសេធបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយសារកំហុសនីតិវិធី។

---

[3064] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ៣១, ៣៤, ៤២។

01358639



# ៦.ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

**ដោយអនុលោមតាម**វិធាន ៤ (១)(ខ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៤ ថ្មី(១)(ខ) និងមាត្រា ៣៦ ថ្មីនៃច្បាប់ អ.វ.ត.ក. និង វិធាន ១១១ នៃវិធានផ្ទៃក្នុង

**បានកត់សម្គាល់**សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរនីមួយៗរបស់ភាគី និងអំណះអំណាងដែលបានលើកឡើងនៅក្នុងសវនាការនៅថ្ងៃទី ១៦ ដល់ ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ទទួលយក**ផ្នែកខ្លះ និង **បដិសេធ**ផ្នែកខ្លះទៀតនៃបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ដែលៈ

**<u>ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ</u>**

**បដិសេធ**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

**តម្កល់**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

**<u>ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ</u>**

**បដិសេធ**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**តម្កល់**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង**កែប្រែ**ប្រភេទគតិយុត្តនៃបទល្មើសដោយសម្រេច **ដាក់ពិរុទ្ធភាព**លើ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ។

**<u>ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ</u>**

**បដិសធ**ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល បទមនុស្សឃាត និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

**ប្រកាសតម្កល់**ការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើ នួន ជា និង ខៀវ សំផន របស់អង្គជំនុំជម្រះសាលាដំបូង

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក./អ.ជ.ត.ក.

ឯកសារលេខ F36

**ប្រកាសបដិសេធ**បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាថា ពុំអាចទទួលយកបាន

**បង្គាប់**ថា នួន ជា និង ខៀវ សំផន ត្រូវស្ថិតក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រង់ចាំការរៀបចំរួចរាល់ ស្របតាមច្បាប់ នឹងត្រូវផ្ទេរទៅពន្ធនាគារដែលត្រូវអនុវត្តទោសនៅទីនោះ។

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក./អ.ជ.ត.ក.

ឯកសារលេខ F36

ធ្វើជាភាសាខ្មែរ និង ភាសាអង់គ្លេស ។
រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ក្រឡាបញ្ជី**

Volker NERLICH **ស៊ា ម៉ៅ** Paolo LOBBA **ផន ធឿន**

ចៅក្រម **គង់ ស្រីម** ប្រធាន

ចៅក្រម **Chandra Nihal JAYASINGHE**

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **Agnieszka KLONOWIECKA-MILART**

ចៅក្រម **ម៉ុង មុន្នីចរិយា**

ចៅក្រម **Judge Florence Ndepele MWACHANDE-MUMBA**

ចៅក្រម **យ៉ា ណារិន**